ការធ្វើអធិការកិច្ចពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ត្រូវបានពង្រឹងជាលំដាប់ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព គុណភាព និងសមិទ្ធកម្មនៃប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យានៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការធ្វើអធិការកិច្ច ត្រូវបានអនុវត្តចំនួន១៥២លើក និងបានដោះស្រាយ វិវាទមុខងារសាធារណៈចំនួន៣៩ករណី ព្រមទាំងបានចុះតាមដានការអនុវត្តសេចក្តីជូនដំណឹងលទ្ធផលអធិការកិច្ចចំនួន៤៥លើក។

### ១.៧.២- ការពង្រឹងសមត្ថភាពក្រសួងមុខងារសាធារណៈតាមរយៈសវនកម្មផ្ទៃក្នុង

បានផ្តល់អនុសាសន៍កែលម្អការអនុវត្តការងារលើកិច្ចការគ្រប់គ្រងហិរញ្ញវត្ថុ សមិទ្ធកម្ម និងបច្ចេកវិទ្យាព័ត៌មាននៅអង្គភាពថ្នាក់កណ្តាលនៃក្រសួងមុខងារសាធារណៈនិងមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត តាមរយៈ (១) ការចុះប្រមូលព័ត៌មាននិងសិក្សាហានិភ័យ ចំនួន៥៨លើក (២) ការចុះធ្វើសវនកម្ម ចំនួន៧១លើក និង

(៣) ការចុះតាមដានការអនុវត្តអនុសាសន៍សវនកម្ម ចំនួន៨២លើក និងបានរៀបចំរបាយការណ៍លទ្ធផលសង្ខេប របាយការណ៍បញ្ចប់សវនកម្មផ្ទៃក្នុងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជាលទ្ធផលនៃការពង្រឹងអភិបាលកិច្ចមុខងារសាធារណៈ ក្រសួងមុខងារសាធារណៈបានរកឃើញករណីបើកបៀវត្សផ្ទុយនឹងបែបបទនិងនីតិវិធីជាធរមាន (មរណភាព ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ស្ថិតនៅក្រៅក្របខ័ណ្ឌដើម មានមុខតំណែងលើសពីមួយ ការបោះបង់ការងារ ការលុបឈ្មោះចេញពីក្របខ័ណ្ឌ ការផ្ទេរនិងការផ្លាស់ប្តូរទីកន្លែងធ្វើការ ការបាត់បង់សម្បទាវិជ្ជាជីវៈ ។ល។) ដែលមានទឹកប្រាក់ប្រមាណ៤៧ ពាន់លានរៀល និងបានចាត់ចែងឱ្យបង្វែរចូលថវិកាជាតិវិញ (សំណៃសចំណាយ) បានចំនួន៨៧,៣៧%។

**១.៨- ការងារទំនាក់ទំនងអន្តរជាតិ**

ក្រសួងមុខងារសាធារណៈ បានពង្រឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យមុខងារសាធារណៈ ក្នុងកម្រិតអន្តរជាតិ តំបន់ និងទ្វេភាគី ដែលទទួលបានលទ្ធផល ដូចជា(១) បានចុះអនុស្សរណៈនៃការយោគយល់ជាមួយភាគីចិន ថៃ និងកូរ៉េ ព្រមទាំងបន្តកិច្ចសហការជាមួយប្រទេសបារាំង អាល្លឺម៉ង់ អូស្ត្រាលី ជប៉ុន សិង្ហបុរី តួគី និងឥណ្ឌា ព្រមទាំងដៃគូអភិវឌ្ឍផ្សេងទៀត ដូចជាធនាគារពិភពលោក កម្មវិធីអភិវឌ្ឍសហប្រជាជាតិ សហភាពអឺរ៉ុប (២) បានទទួលម៉ាស៊ីនផ្នែករឹង (Hardware) សម្រាប់អភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រង មន្ត្រីរាជការស៊ីវិលសរុបជាថវិកាប្រមាណ១,២លានដុល្លារអាមេរិក ដែលជាជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន (៣) បានរៀបចំសម្របសម្រួល និងចូលរួមក្នុងកិច្ចប្រជុំកិច្ចសហប្រតិបត្តិការអាស៊ាន អាស៊ាន+៣ ស្តីពីកិច្ចការមុខងារសាធារណៈ ចំនួន៨៩លើក ដែលមានប្រតិភូចូលរួមសរុបចំនួន២៤៤នាក់(ស្ត្រី ៤៦នាក់) និង(៤) បានចាត់មន្ត្រីនៃក្រសួងមុខងារសាធារណៈ (ក) ចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេស ចំនួន២០៨នាក់(ស្ត្រី ៥៦នាក់) និង(ខ) ចូលរួមដាក់ពាក្យអាហារូបករណ៍ និងវគ្គបណ្តុះបណ្តាលសរុបចំនួន១៣៣នាក់(ស្ត្រី ២៣នាក់)។

**២- ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យមុខងារសាធារណៈ**

**ការអភិវឌ្ឍធនធានមនុស្ស គឺជាការងារអាទិភាព ដែលត្រូវបានអនុវត្តជាប្រចាំ តាមរយៈការបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល និងតាមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាផ្សេងទៀត។** សាលាភូមិន្ទរដ្ឋបាល បានផ្តល់ការបណ្តុះបណ្តាលដល់សិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការ កម្មសិក្សាការីនៃវគ្គវិក្រឹតការ មន្ត្រីរាជការក្របខ័ណ្ឌថ្មី និងសិក្ខាកាមនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សរុបចំនួន**១០ ៣៥៩នាក់**(ស្ត្រី ២ ៩៣១នាក់) ដែលជាការរួមចំណែកដល់ការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនិងក្រសួង ស្ថាប័ន ឱ្យទទួលបានលទ្ធផលកាន់តែល្អប្រសើរ។ ទន្ទឹមនេះ មន្ត្រីរាជការនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សរុបចំនួន ៧ ៧៧៦នាក់ ក៏ទទួលបានការពង្រឹងសមត្ថភាពបន្ថែម តាមរយៈកម្មវិធីផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត កម្មវិធីចែករំលែកចំណេះដឹង និងការចូលរួមវគ្គបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេសផងដែរ។

**៣- ការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ**

ផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា ការកែទម្រង់រដ្ឋបាលសាធារណៈត្រូវបានបន្តជំរុញអនុវត្តយ៉ាងសកម្ម ដើម្បីរួមចំណែកដល់ការលើកកម្ពស់អភិបាលកិច្ចល្អក្នុងរដ្ឋបាលសាធារណៈ។ លទ្ធផលសម្រេចបានក្នុងផ្នែកសំខាន់ៗ រួមមានការកសាងឯកសារមូលដ្ឋាននៃកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ការពិនិត្យនិងកែលម្អរចនាសម្ព័ន្ធក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ការលើកកម្ពស់គុណភាព

សេវាសាធារណៈ ការកែទម្រង់បៀវត្សនិងការបើកបៀវត្សតាមប្រព័ន្ធធនាគារ ការបង្កើនរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន ការលើកកម្ពស់ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**៣.១- ការរៀបចំឯកសារមូលដ្ឋាននៃកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ**

ឯកសារទស្សនាទានស្តីពីការរៀបចំកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០ ត្រូវបានរៀបចំ និងទទួលបានការអនុម័តរួចហើយពីរាជរដ្ឋាភិបាល។ ផ្អែកលើឯកសារទស្សនាទាននេះ សេចក្តីព្រាងកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០២២-២០៣៥ ក៏ត្រូវបានរៀបចំនិងបានដាក់ឆ្លងការពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយនឹងការកំណត់ចក្ខុវិស័យ ដើម្បីធានាឱ្យបាននូវ**ការកសាងរដ្ឋបាលសាធារណៈមួយមានភាពខ្លាំង ស្អាតស្អំ ឆ្លាតនិងផ្តោតលើប្រជាជនជាស្នូល**។ កម្មវិធីកែទម្រង់ផ្តោតលើការសម្រេចគោលដៅសំខាន់ៗរួមមាន (១) ការកែទម្រង់និងការពង្រឹងប្រសិទ្ធភាពស្ថាប័ន (២) ការលើកកម្ពស់ប្រសិទ្ធភាពនៃសមិទ្ធកម្មស្ថាប័នសាធារណៈ និង (៣) គណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ។

**៣.២- ការកែលម្អរចនាសម្ព័ន្ធក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ**

រចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នចំនួន៣១ ស្មើនឹង១១៨ករណី ត្រូវបានពិនិត្យនិងកែសម្រួលឱ្យស្របតាមតម្រូវការនៃមុខងារបច្ចុប្បន្ន និងភាពចាំបាច់នៃដំណើរការរដ្ឋបាលសាធារណៈ។ ទន្ទឹមនេះ ការអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ ក៏បានរួមចំណែកដល់ការរៀបចំនិងដាក់ឱ្យដំណើរការអនុវត្តនូវរចនាសម្ព័ន្ធថ្មីរបស់ក្រុង ស្រុក ខណ្ឌ ព្រមទាំងបានផ្ទេរបុគ្គលិកចំនួន១៩ ៥៩៣នាក់ ទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងនោះគ្រូបង្រៀនចំនួន៦ ៥១៩នាក់ ត្រូវបានផ្ទេរទៅឱ្យក្រុង ស្រុកទាំង១៤ នៃខេត្តបាត់ដំបង។ បន្ថែមលើនេះ ក្នុងពេលដែលមុខងារគ្រប់គ្រងនិងការផ្តល់សេវាសុខាភិបាល ត្រូវបានប្រគល់ឱ្យទៅរដ្ឋបាលរាជធានី ខេត្ត បុគ្គលិកសុខាភិបាលចំនួន២០ ១២៤នាក់ ក៏ត្រូវបានធ្វើសមាហរណកម្មទៅក្នុងរដ្ឋបាលរាជធានី ខេត្ត ដើម្បីគាំទ្រឱ្យកាន់តែមានប្រសិទ្ធភាពនូវការផ្តល់សេវាសុខាភិបាលនៅមូលដ្ឋាន។

**៣.៣- ការលើកកម្ពស់គុណភាពសេវាសាធារណៈ**

ក្នុងក្របខ័ណ្ឌនៃការលើកកម្ពស់គុណភាពសេវាសាធារណៈ យន្តការនៃការគាំទ្រចលនាប្រឡងប្រណាំងការផ្តល់សេវាសាធារណៈ ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាពគួរជាទីកត់សម្គាល់ ដើម្បីជំរុញកែលម្អការផ្តល់សេវាសាធារណៈជូនប្រជាជនឱ្យកាន់តែប្រសើរ។ ជាលទ្ធផល ការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំក្នុងកម្រិតវិទ្យាល័យ និងវិស័យសុខាភិបាលក្នុងកម្រិតមន្ទីរពេទ្យបង្អែក (សំណុំសកម្មភាពបង្គ្រប់១ ២ និង៣) ត្រូវបានដំណើរការប្រកបដោយជោគជ័យ និងកំពុងបន្តដំណើរការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំក្នុងកម្រិតអនុវិទ្យាល័យ និងបឋមសិក្សា និងវិស័យសុខាភិបាលក្នុងកម្រិតមណ្ឌលសុខភាព។ លើសពីនេះ ក្រសួងមុខងារសាធារណៈ តាមរយៈគណៈ-កម្មាធិការជាតិវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូ ក៏បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ព្រមទាំងការចែករំលែកអំពីនវានុវត្តន៍ និងឧត្តមានុវត្តន៍ ដើម្បីជំរុញនិងរៀបចំការប្រឡងប្រណាំងអង្គភាពផ្តល់សេវាសាធារណៈគំរូរបស់ក្រសួង ស្ថាប័នផងដែរ។

លិខិតបទដ្ឋានគតិយុត្តជាមូលដ្ឋានបន្ថែមគាំទ្រដល់ការលើកកម្ពស់គុណភាពសេវាសាធារណៈមួយចំនួនត្រូវបានរៀបចំរួចរាល់ រួមមានសេចក្តីណែនាំអាស៊ាន ស្តីពីការផ្តល់សេវាសាធារណៈ និងមួយចំនួនទៀតកំពុងដំណើរការរៀបចំជាបណ្តើរៗ ក្នុងនោះរួមមានសេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ ឯកសារណែនាំស្តីពីការ

ចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការផ្តល់សេវាសាធារណៈ និងអនុក្រឹត្យស្តីពីការវាយតម្លៃនិងទទួលស្គាល់គម្រោងនវានុវត្តន៍ក្នុងរដ្ឋបាលសាធារណៈ។ ទន្ទឹមនេះ ច្រកទ្វារអេឡិចត្រូនិកផ្តល់ព័ត៌មានសេវាសាធារណៈនិងកម្មវិធីផ្តល់ព័ត៌មានសេវាសាធារណៈត្រូវបានដាក់ឱ្យដំណើរការ ព្រមទាំងបានធ្វើបច្ចុប្បន្នភាពកម្រងព័ត៌មានសេវាសាធារណៈជាប្រចាំ ដើម្បីពង្រឹងតម្លាភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាជន។

### ៣.៤- ការកែទម្រង់បៀវត្សនិងការបើកបៀវត្សតាមប្រព័ន្ធធនាគារ

ជានិច្ចកាល រាជរដ្ឋាភិបាលតែងតែផ្តល់ការយកចិត្តទុកដាក់ខ្ពស់ចំពោះជីវភាពរស់នៅសមរម្យរបស់មន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ។ ទោះបីប្រឈមនឹងការលំបាកបង្កដោយការរាលដាលនៃជំងឺកូវីដ-១៩ និងវិបត្តិផ្សេងៗយ៉ាងណាក៏ដោយ មន្ត្រីរាជការគ្រប់ប្រភេទ រួមទាំងមន្ត្រីកិច្ចសន្យា និងមន្ត្រីផ្សេងទៀត តែងទទួលបានការបើកផ្តល់បៀវត្សជាធម្មតា ទាន់ពេលវេលា និងទៀងទាត់រៀងរាល់២សប្តាហ៍ម្តង ព្រមទាំងទទួលបានប្រាក់ឧបត្ថម្ភបន្ថែម៥ម៉ឺនរៀល នៅរៀងរាល់ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិនិងបុណ្យភ្ជុំបិណ្ឌផងដែរ។

លើសពីនេះ រាជរដ្ឋាភិបាលបានខិតខំដំឡើងបៀវត្សនិងប្រាក់ដំណាច់មុខងារ ជូនមន្ត្រីរាជការស៊ីវិលកងកម្លាំងប្រដាប់អាវុធ និងមន្ត្រីផ្សេងទៀត ក្នុងក្របខ័ណ្ឌនៃលទ្ធភាពទ្រទ្រង់បាននៃថវិកាជាតិ ការលើកកម្ពស់ជីវភាពរបស់មន្ត្រី និងការបង្កើនប្រសិទ្ធភាពការងារមន្ត្រីជាបន្តបន្ទាប់ផងដែរ។ ដល់ឆ្នាំ២០២៣ បៀវត្សអប្បបរមាប្រចាំខែសម្រាប់មន្ត្រីរាជការស៊ីវិលនៅក្នុងវិស័យ (១) រដ្ឋបាលទូទៅ បច្ចេកទេស និងការទូត នឹងត្រូវដំឡើងដល់ចំនួន**១ ៣០០ ០០០រៀល** (២) អប់រំ និងសុខាភិបាល ដែលជាវិស័យអាទិភាព នឹងឡើងដល់ចំនួន**១ ៤០០ ០០០រៀល** (៣) មន្ត្រីនគរបាលជាតិ ដល់ចំនួន**១ ៣៨៤ ៤៧៧រៀល** និង(៤) យោធិនដល់ចំនួន**១ ៣០៩ ៤៧៧ រៀល**។ ទន្ទឹមនេះ ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យា នឹងត្រូវដំឡើងដល់ចំនួន**៧១០ ០០០រៀល** ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ដល់ចំនួន**១ ៥៧០ ០០០រៀល** សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ដល់ចំនួន**១ ១៩៥ ០០០រៀល** ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌដល់ចំនួន**១ ២៨៥ ០០០រៀល** សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ដល់ចំនួន**៩៧០ ០០០រៀល** ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ដល់ចំនួន**១ ២៤០ ០០០រៀល** ជំទប់ទី១ ទី២ ចៅសង្កាត់រងទី១ ទី២ ដល់ចំនួន**៩៣០ ០០០រៀល** សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដល់ចំនួន**៨២០ ០០០រៀល** មេភូមិ ដល់ចំនួន**៥១០ ០០០រៀល** អនុប្រធានភូមិ ដល់ចំនួន**៣៩០ ០០០រៀល** និងមន្ត្រីភូមិ ដល់ចំនួន**៣៦០ ០០០រៀល**។

### ៣.៥- ការបង្កើនរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន

ចាប់ពីឆ្នាំ២០១៥ មកដល់ឆ្នាំ២០២២ ប្រាក់សោធនប្រចាំខែរបស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ត្រូវបានដំឡើងជាបន្តបន្ទាប់ ដោយផ្តោតការយកចិត្តទុកដាក់លើប្រាក់សោធនកម្រិតអប្បបរមា និងការកាត់បន្ថយគម្លាតរវាងប្រាក់សោធនអប្បបរមានិងអតិបរមា ការដោះស្រាយបញ្ហាគម្លាតប្រាក់សោធនចាស់ និងប្រាក់សោធនថ្មីសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន (យោធិននិងមន្ត្រីនគរបាលជាតិ) ការធានាសង្គតិភាពរវាងប្រាក់សោធនរបស់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន ព្រមទាំងការគិតគូរផ្សារភ្ជាប់ជាមួយនិងគម្រោងដំឡើងបៀវត្សមន្ត្រីជាទូទៅ។ អតីតយុទ្ធជនដែលមានពិការភាពនិងបាត់បង់សមត្ថភាពការងារក៏ទទួលបានប្រយោជន៍ពីការដំឡើងរបបសន្តិសុខសង្គមជាទូទៅ ព្រមទាំងរបបឧបត្ថម្ភបន្ថែមដោយឡែកផងដែរ។

ផ្អែកលើវិធានការដំឡើងប្រាក់សោធន គួបផ្សំជាមួយវិធានការធ្វើសមាហរណកម្មប្រព័ន្ធប្រាក់សោធនបច្ចុប្បន្ន ទៅក្នុងប្រព័ន្ធប្រាក់សោធនថ្មី ប្រាក់សោធនអប្បបរមាប្រចាំខែរបស់អតីតមន្ត្រីរាជការស៊ីវិលនិងអតីត

យុទ្ធជន (អតីតយោធិននិងអតីតមន្ត្រីនគរបាលជាតិ) ដែលស្ថិតនៅក្រោម**៣២០ ០០០រៀល** មុនឆ្នាំ២០១៥ មានការកើនឡើងជាបន្តបន្ទាប់ដល់**៦៤០ ០០០រៀល** ក្នុងឆ្នាំ២០២១ ទៅ**៦៩០ ០០០រៀល** ក្នុងឆ្នាំ២០២២ ទៅ **៧៧០ ០០០រៀល** ក្នុងឆ្នាំ២០២៣ និងឡើងដល់រង្វង់**៨២៥ ០០០រៀល** ក្នុងឆ្នាំ២០២៤។

### ៣.៦- ការលើកកម្ពស់ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស ត្រូវបានគិតគូរនិងបន្តកែលម្អជាលំដាប់សម្រាប់ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយបានដាក់ឱ្យអនុវត្ត (១) លក្ខណវិនិច្ឆ័យការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សសម្រាប់ការផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំកម្រិតអនុវិទ្យាល័យនិងបឋមសិក្សា (២) លក្ខណ-វិនិច្ឆ័យការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សសម្រាប់ការផ្តល់សេវាសាធារណៈគំរូវិស័យសុខាភិបាលកម្រិតមណ្ឌលសុខភាព និង(៣) ការអនុវត្តសាកល្បងប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម នៅការិយាល័យច្រកចេញចូលតែមួយនៅស្រុកមោងឫស្សី និងក្រុងបាត់ដំបង ជាដើម។

ទន្ទឹមនេះ ឯកសារជាមូលដ្ឋានមួយចំនួនទៀត ក៏កំពុងត្រូវបានរៀបចំ ដោយមានការពិគ្រោះយោបល់ទូលំទូលាយនិងអនុវត្តសាកល្បងជាមួយបណ្តាក្រសួង ស្ថាប័ន ក្នុងនោះ រួមមាន(១) សេចក្តីព្រាងសេចក្តីណែនាំស្តីពីការពិពណ៌នាមុខតំណែង និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តការពិពណ៌នាមុខតំណែង (២) សេចក្តីព្រាងសេចក្តីណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម (៣) សេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍សមត្ថភាពមន្ត្រីរាជការថ្នាក់គ្រប់គ្រងកម្រិតនាយកដ្ឋាន និង(៤) គម្រោងអភិវឌ្ឍសមត្ថភាពស្តីពីភាពជាអ្នកដឹកនាំសម្រាប់មន្ត្រីរាជការគ្រប់គ្រងជាន់ខ្ពស់និងមធ្យមក្នុងវិស័យមុខងារសាធារណៈនៃប្រទេសក្នុងតំបន់អាស៊ាន ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអាស៊ានបូកបីស្តីពីវិស័យមុខងារសាធារណៈ។

**ការប្រើប្រាស់ក្របខ័ណ្ឌប្រចាំឆ្នាំ** (គិតជានាក់)

| ឆ្នាំ / បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| មន្ត្រីក្របខ័ណ្ឌថ្មី | ៥ ០២៩ | ៥ ៩៩៦ | ៦ ២១៤ | ៦ ១០៦ | ៣ ៤៥៣ | ៣ ៨៦៣ |
| មន្ត្រីជាប់កិច្ចសន្យា | ១៨ ១៤៦ | ១៨ ២៩២ | ១៩ ១៣៧ | ១៩ ១៣៧ | ១៨ ៩៩៦ | ១៩ ០៨៨ |
| គ្រូបង្រៀនជាប់កិច្ចសន្យាចំណេះទូទៅ | ៦ ៥៨៥ | ៧ ៩៩៦ | ៩ ៨៩៦ | ៩ ៨៩៦ | ៩ ៨៩៦ | ៩ ៨៩៦ |
| គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ | ២ ៤៧២ | ២ ៤៧២ | ២ ៤៧២ | ២ ៤៧២ | ២ ៤៧២ | ២ ៤៧២ |
| គ្រូបង្រៀនថ្នាក់ពីរវេន | ១៣ ៣៣១ | ១២ ៨៩៧ | ១១ ៦៧១ | ១១ ៦៧១ | ១១ ៦៧១ | ១១ ៦៧១ |
| គ្រូបង្រៀនថ្នាក់គួបគ្រប់កម្រិត | ២ ៩៣៥ | ២ ៧១៨ | ២ ៧១៨ | ២ ៧១៨ | ២ ៧១៨ | ២ ៧១៨ |
| គ្រូបង្រៀនជាប់កិច្ចសន្យាខ្មែរអ៊ិស្លាម | ០ | ១៧៨ | ១៧៨ | ១៧៨ | ១៧៨ | ១៧៨ |
| **សរុប** | **៤៨ ៤៩៨** | **៥០ ៥៤៩** | **៥២ ២៨៦** | **៥២ ១៧៨** | **៤៩ ៣៨៤** | **៤៩ ៨៨៦** |

## ចំនួនមន្ត្រីរាជការស៊ីវិលចូលនិវត្តន៍លុបឈ្មោះ
## និងបាត់បង់សម្បទាវិជ្ជាជីវៈ(គិតជានាក់)

| ឆ្នាំ / បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|
| ចូលនិវត្តន៍ | ៣ ១៤៧ | ២ ៥២២ | ១ ៩៨៦ | ១ ០៥៨ | ១ ៥៥២ | ១០ ២៦៥ |
| លុបឈ្មោះ | ៩៩៣ | ៧៨៩ | ៩៤៧ | ៨៤៣ | ៨៤១ | ៤ ៤១៣ |
| បាត់បង់សម្បទាវិជ្ជាជីវៈ | ១១ | ១០ | ២២ | ១០ | ៨ | ៦១ |

## ចំនួនមន្ត្រីរាជការស៊ីវិលតាមប្រភេទក្របខ័ណ្ឌក្នុងតារាងបៀវត្ស (គិតជានាក់)

| ឆ្នាំ / បរិយាយ | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| **១- ថ្នាក់កណ្ដាល** | | | | | | |
| ក | សរុប | ២៦ ០១៩ | ២៧ ១៧២ | ២៨ ៣០២ | ២៨ ៦២៩ | ២៩ ៦០៣ |
| | ស្ត្រី | ៦ ៨៩៩ | ៧ ៣២៥ | ៧ ៧៥៥ | ៧ ៨៩២ | ៨ ៣៤៦ |
| ខ | សរុប | ៧ ១៥២ | ៧ ១៤១ | ៧ ១២៩ | ៧ ៥៦១ | ៧ ៧៩៣ |
| | ស្ត្រី | ២ ៩៤៩ | ២ ៩៤៧ | ២ ៩១៩ | ៣ ១៥១ | ៣ ៣១២ |
| គ | សរុប | ៤ ១៣៦ | ៣ ៩៣៧ | ៣ ៧៧០ | ៣ ៩៧២ | ៣ ៩២០ |
| | ស្ត្រី | ១ ៦០៤ | ១ ៥១៧ | ១ ៤២០ | ១ ៥៧១ | ១ ៥១៨ |
| សរុប(១) | សរុប | ៣៧ ៣០៧ | ៣៨ ២៥០ | ៣៩ ២០១ | ៤០ ១៦២ | ៤១ ៣១៦ |
| | ស្ត្រី | ១១ ៤៥២ | ១១ ៧៨៩ | ១២ ០៩៤ | ១២ ៦១៤ | ១៣ ១៧៦ |
| **២- ថ្នាក់រាជធានី ខេត្ត** | | | | | | |
| ក | សរុប | ៣១ ៦៩៩ | ៣៤ ៣១០ | ៣៦ ៣៣៧ | ៣៧ ០៣៥ | ៣៧ ៨៤២ |
| | ស្ត្រី | ៩ ១០៨ | ១០ ១៨២ | ១០ ៩៩៧ | ១១ ៣៩០ | ១១ ៨៩៦ |
| ខ | សរុប | ៦២ ៨០០ | ៦៤ ១៦០ | ៦៤ ៨៩៦ | ៦៤ ២២៤ | ៦៦ ៥៧២ |
| | ស្ត្រី | ២៥ ៩៨៩ | ២៦ ៩៦៥ | ២៧ ៦៨៤ | ២៧ ៣៣៥ | ២៨ ៨៨៥ |
| គ | សរុប | ៧៦ ៨៦៤ | ៧៤ ៣៧៤ | ៧១ ៤៦២ | ៧១ ៨៥៥ | ៧២ ៦៧៧ |
| | ស្ត្រី | ៣៩ ២៦១ | ៣៨ ៥៨៦ | ៣៧ ១៨៣ | ៣៧ ៦៥៥ | ៣៨ ៤១៧ |
| សរុប(២) | សរុប | ១៧១ ៣៦៣ | ១៧២ ៨៤៤ | ១៧២ ៦៩៥ | ១៧៣ ១១៤ | ១៧៧ ០៩១ |
| | ស្ត្រី | ៧៤ ៣៥៨ | ៧៥ ៧៣៣ | ៧៥ ៨៦៤ | ៧៦ ៣៨០ | ៧៩ ១៩៨ |
| សរុបរួម (១)+(២) | **សរុប** | **២០៨ ៦៧០** | **២១១ ០៩៤** | **២១១ ៨៩៦** | **២១៣ ២៧៦** | **២១៨ ៤០៧** |
| | **ស្ត្រី** | **៨៥ ៨១០** | **៨៧ ៥២២** | **៨៧ ៩៥៨** | **៨៨ ៩៩៤** | **៩២ ៣៧៤** |

## ចំនួនមន្ត្រីរាជការតាមប្រភេទក្របខ័ណ្ឌ និងឋានន្តរសក្តិក្នុងតារាងបៀវត្ស (គិតជានាក់)

| ឆ្នាំ / បរិយាយ | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | |
|---|---|---|---|---|---|---|---|---|---|---|
| | **សរុប** | **ស្រី** | **សរុប** | **ស្រី** | **សរុប** | **ស្រី** | **សរុប** | **ស្រី** | **សរុប** | **ស្រី** |
| **ក១** | ២ ៩០៨ | ៣៦៧ | ៥ ៤៩៧ | ៩០៩ | ៩ ៧៧៦ | ១ ៧១៨ | ១០ ៤៧៨ | ១ ៨៤១ | ១១ ៦៣០ | ១ ៩៩៥ |
| **ក២** | ១៨ ៧៨៣ | ៣ ៦៧១ | ១៨ ៥៩២ | ៣ ៦៩៩ | ១៧ ១០៥ | ៣ ៦៧៤ | ១៦ ៧០៣ | ៣ ៦២៧ | ១៧ ១១៧ | ៣ ៩២៩ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| **ក៣** | ៣៦ ០២៧ | ១១ ៩៦៩ | ៣៧ ៣៩៣ | ១២ ៨៩៧ | ៣៧ ៧៥៨ | ១៣ ៣៥៨ | ៣៨ ៥៣៥ | ១៣ ៧៩៦ | ៣៨ ៦៩៨ | ១៤ ៣១៧ |
| **ខ១** | ២ ០៤១ | ៥០៤ | ២ ១៣៩ | ៥៣៥ | ៣ ៨៦៧ | ១ ០១៨ | ៣ ៨៧៩ | ៩៩៨ | ៤ ៣៥៦ | ១ ១១២ |
| **ខ២** | ១៤ ៨៥៩ | ៤ ៦៩៥ | ១៥ ៣២០ | ៤ ៨៩៤ | ២០ ០២១ | ៦ ៩៦៩ | ២០ ០៩៩ | ៦ ៩៥៩ | ២៤ ២៤៦ | ៨ ៩៥២ |
| **ខ៣** | ៥៣ ០៥២ | ២៣ ៧៣៩ | ៥៣ ៨៤២ | ២៤ ៤៨៣ | ៤៨ ១៣៧ | ២២ ៦១៧ | ៤៧ ៩៣០ | ២២ ៥៨៦ | ៤៥ ៧៦៣ | ២២ ១៣៣ |
| **គ** | ៨១ ០០០ | ៤០ ៨៦៥ | ៧៨ ៣១១ | ៤០ ១០២ | ៧៥ ២៣២ | ៣៨ ៦០២ | ៧៦ ០៧០ | ៣៩ ៣៥១ | ៧៦ ៥៩៧ | ៣៩ ៩៣៥ |

## ចំនួនមន្ត្រីរាជការស៊ីវិល និងមន្ត្រីប្រភេទផ្សេងទៀតក្នុងតារាងបៀវត្ស គិតត្រឹមខែកញ្ញា ឆ្នាំ២០២២ (គិតជានាក់)

| ឆ្នាំ / បរិយាយ | មន្ត្រីរាជការស៊ីវិល | | មន្ត្រីប្រភេទផ្សេងទៀត | | សរុប | |
|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ថ្នាក់កណ្ដាល | ៤១ ៣១៦ | ១៣ ១៧២ | ៨ ៥២៩ | ១ ៤២៨ | ៤៩ ៨៤៥ | ១៤ ៦០០ |
| ថ្នាក់រាជធានី ខេត្ត | ១៧៧ ០៩១ | ៧៩ ១៩៨ | ១៣ | ៥ | ១៧៧ ១០៤ | ៧៩ ២០៣ |
| **សរុប** | **២១៨ ៤០៧** | **៩២ ៣៧០** | **៨ ៥៤២** | **១ ៤៣៣** | **២២៦ ៩៤៩** | **៩៣ ៨០៣** |

## ភាគរយមន្ត្រីរាជការស៊ីវិលនិងមន្ត្រីប្រភេទផ្សេងទៀត នៅថ្នាក់កណ្ដាលនិងថ្នាក់រាជធានី ខេត្ត ក្នុងឆ្នាំ២០២២




## ភាគរយមន្ត្រីរាជការស៊ីវិលនិងមន្ត្រីប្រភេទផ្សេងទៀតតាមភេទ នៅក្នុងឆ្នាំ២០២២



## របាយសម្ព័ន្ធអាយុមន្ត្រីរាជការស៊ីវិលនិងមន្ត្រីប្រភេទផ្សេងទៀត នៅក្នុងឆ្នាំ២០២២




## ចំនួនការប្រែប្រួលស្ថានភាពរដ្ឋបាល និងគ្រួសារនៅក្នុងតារាងបៀវត្ស( គិតជានាក់ )

| ឆ្នាំ / បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| ស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស | ៥៩៦ | ៧២៧ | ៥៩៧ | ៣៦៧ | ៤២៤ |
| ចូលបម្រើការងារវិញក្រោយទំនេរគ្មានបៀវត្ស | ៤១២ | ៤៤៥ | ៤៩៩ | ៤៦៥ | ២៩១ |
| ក្របខ័ណ្ឌថ្មីបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យា | ៧ ០២២ | ២ ៨៣៣ | ៦ ១៥៤ | ៦ ៤០៧ | ៦ ៣៩១ |
| ក្របខ័ណ្ឌថ្មីបញ្ចូលប្រាក់បៀវត្ស | ៩ ៥៥០ | ៦ ៣៨៥ | ៤ ៥១១ | ៣ ៥៩០ | ៦ ៣៩១ |
| តាំងស៊ប់ | ១០ ១៧៨ | ១១ ៦១៥ | ៧ ២៦៤ | ៤ ៦១៩ | ២ ០១៦ |
| ប្ដូរក្របខ័ណ្ឌ | ២ ១៥២ | ៣ ៩៨៦ | ៣ ៦៣០ | ៣៨៧ | ៣៦៨ |
| តែងតាំង | ៩ ២០១ | ១១ ៨១០ | ១០ ២៤២ | ១៣ ០០៦ | ៩ ៧៦៨ |
| ទីប្រឹក្សា និងជំនួយការ | ៣៩៤ | ១ ៦៨៧ | ៧៤០ | ២១៦ | ១៥៧ |
| ដល់អាយុចូលនិវត្តន៍ | ៣ ១៤៧ | ២ ៥២២ | ១ ៩៨៦ | ១ ០៥៨ | ១ ៥៥២ |
| លាឈប់ពីការងារ | ៩០២ | ៨០៧ | ៧២៩ | ៥២៤ | ៤០២ |
| មរណភាព | ២០០ | ២២៩ | ២៧៨ | ៣១៦ | ២៣២ |
| ដំឡើងថ្នាក់ប្រចាំឆ្នាំ និងសញ្ញាបត្រ | ៨៩ ៨០២ | ៩៨ ១៤២ | ១៤២ ០៦២ | ២០ ០១៨ | ៦២ ៩៤១ |
| ឡើងឋានន្តរសក្តិ | ៤០៩ | ១ ៩៥៧ | ២ ៥១៩ | ៩៣០ | ១ ៨៥៧ |
| ផ្ទេរចេញ | ៣ ០៨២ | ២ ៥៩១ | ២ ២៩៤ | ២ ៦៨៥ | ១ ២៦២ |
| ផ្ទេរចូល | ៣ ២៩៩ | ២ ៤៩៤ | ២ ៣៧១ | ២ ៦៣២ | ១ ២៧៣ |
| សុំប្រាក់មុខងារ | ១ ៧៣៣ | ១ ៧៥៨ | ២ ១០៣ | ២១៥ | ១៤៣ |
| លម្ហែមាតុភាព | ០ | ០ | ១ ៤៧៤ | ២ ៤៩៥ | ១ ៥៨៩ |

| | | | | | |
|---|---|---|---|---|---|
| បញ្ចូលកូន | ១០ ១៤២ | ១១ ៤២៣ | ១២ ១២៥ | ៩ ៨៥៦ | ៧ ៧១៥ |
| បញ្ចូលប្រពន្ធ | ២ ២៤២ | ១ ៩៨៩ | ១ ៤២២ | ១ ៨២៣ | ២ ៧៩២ |
| ប្រាក់តំបន់ | ២០ ១៤៥ | ៤២ ០៩៧ | ៤១ ៩៤៧ | ៥ ៤២៧ | ១ ៦៩២ |
| ថ្នាក់ពីរពេល ថ្នាក់គួប | ១២ ៥៦៦ | ១៣ ៣៨៧ | ២១ ៩៦៧ | ២៥ ២៦៦ | ៦ ៦៥១ |
| **សរុប** | **១៨០ ១៧៤** | **២១៨ ៨៨៤** | **២៦៦ ៩១៥** | **១០២ ៣០២** | **១១៥ ៩០៧** |

## ការរៀបចំមុខតំណែងនៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័ន (គិតជានាក់)

| បរិយាយ / ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| **ក- ថ្នាក់កណ្តាល** | | | | | |
| អគ្គលេខាធិការនៃក្រសួង ស្ថាប័ន | ៥ | ៥ | ៧ | ៦ | ៩ |
| អគ្គនាយក/អគ្គាធិការ/អគ្គនាយកវិទ្យាស្ថាន/ផ្សេងៗ | ១៦០ | ១៤២ | ១២៩ | ១៣២ | ១៦២ |
| អគ្គលេខាធិការរងនៃក្រសួង-ស្ថាប័ន | ៥១ | ៥៦ | ៤៩ | ៤៧ | ៣២ |
| អគ្គនាយករង/អគ្គាធិការរង/អគ្គនាយករងវិទ្យាស្ថាន/ផ្សេងៗ | ៦១០ | ៦៥៩ | ៦៨៣ | ៧៣៧ | ៧៥៧ |
| ប្រធាននាយកដ្ឋាន/ប្រធានមជ្ឈមណ្ឌល/អធិការ/ផ្សេងៗ | ៨៤១ | ៨៦៤ | ៨៧៩ | ៩២២ | ១ ២៧៧ |
| អនុប្រធាននាយកដ្ឋាន/អនុប្រធានមជ្ឈមណ្ឌល/ផ្សេងៗ | ២ ៧៨៦ | ៣ ០៧១ | ៣ ១៨៨ | ៣ ៤៨៧ | ៤ ៣៥១ |
| ប្រធានការិយាល័យ | ៣ ១៦៣ | ៣ ៣៧៥ | ៣ ៥១១ | ៣ ៦៥២ | ៤ ២៤៤ |
| អនុប្រធានការិយាល័យ | ៥ ៤២៦ | ៥ ៨៩៤ | ៦ ៤៤៧ | ៧ ៣១៧ | ៧ ៧០៩ |
| **ខ- ថ្នាក់រាជធានី ខេត្ត** | | | | | |
| ប្រធានមន្ទីរជំនាញរាជធានី ខេត្ត | ៥៤៧ | ៥៤៥ | ៥៥៥ | ៥៦៧ | ៨០៤ |
| អនុប្រធានមន្ទីរជំនាញរាជធានី ខេត្ត | ១ ៣៩៦ | ១ ៤៣០ | ១ ៤៦៣ | ១ ៥២២ | ២ ១២០ |
| ប្រធានការិយាល័យមន្ទីរជំនាញរាជធានី ខេត្ត | ២ ១៥៨ | ២ ២៨៤ | ២ ៤៥៤ | ២ ៦៧៤ | ៤ ០៨៧ |
| អនុប្រធានការិយាល័យមន្ទីរជំនាញរាជធានី ខេត្ត | ២ ៩៦៥ | ៣ ២៧១ | ៣ ៦១៨ | ៤ ១៣៦ | ៧ ២៧៨ |
| ប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ | ១ ៤៤៣ | ១ ៤៤០ | ១ ៤៤៩ | ១ ៣៦៣ | ១ ៣១២ |
| អនុប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ | ៩៩៦ | ៩៦៣ | ៩៥០ | ៨៩៣ | ២ ១៥៣ |

*សម្គាល់៖ មុខតំណែងខាងលើ មិនទាន់រាប់បញ្ចូលមន្ត្រីក្នុងវិស័យអប់រំ វិស័យពន្ធនាគារ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់នោះទេ។*

## ចំនួនមន្ត្រីរាជការដល់អាយុចូលនិវត្តន៍ (គិតជានាក់)

| បរិយាយ / ឆ្នាំ | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|---|
| ថ្នាក់កណ្តាល | ដល់អាយុ | សរុប | ៦២៥ | ៥២០ | ៤២៨ | ២៩៤ | ៤៨៤ |
| | | ស្រី | ២០៨ | ១៧៨ | ១៩៨ | ១៧៨ | ១៧២ |
| | មុនអាយុ | សរុប | ៥០ | ៨០ | ៦២ | ៥០ | ២៤ |
| | | ស្រី | ១៩ | ៣២ | ៣២ | ២០ | ១២ |
| | សរុប (១) | សរុប | ៦៧៥ | ៦០០ | ៤៩០ | ៣៤៤ | ៥០៨ |
| | | ស្រី | ២២៧ | ២១០ | ២៣០ | ១៩៨ | ១៨៤ |
| ថ្នាក់រាជធានី ខេត្ត | ដល់អាយុ | សរុប | ២ ៥២២ | ២ ០០២ | ១ ៥៥៨ | ៧៦៤ | ១ ០៦៨ |
| | | ស្រី | ១ ០៣៩ | ៨៥៥ | ៨៨៨ | ៤៤៤ | ៥០២ |
| | មុនអាយុ | សរុប | ១៨៨ | ១៩១ | ២៩៧ | ១៩៣ | ១៦៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ស្រី | ៦៧ | ៧៩ | ១១៧ | ៧៨ | ៦៩ |
| | សរុប (២) | សរុប | ២ ៧១០ | ២ ១៩៣ | ១ ៨៥៥ | ៩៥៧ | ៩៣៤ |
| | | ស្រី | ១ ១០៦ | ៩៣៤ | ១ ០០៥ | ៥២២ | ៤១១ |
| **សរុប (១)+(២)** | | **សរុប** | **៣ ៣៨៥** | **២ ៧៩៣** | **២ ៣៤៥** | **១ ៣០១** | **១ ២៣៥** |
| | | **ស្រី** | **១ ៣៣៣** | **១ ១៤៤** | **១ ២៣៥** | **៧២០** | **៧៥៥** |

## ការគ្រប់គ្រងឯកសារមន្ត្រីរាជការស៊ីវិល (គិតជានាក់)

| ឆ្នាំ / **បរិយាយ** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** |
|---|---|---|---|---|---|
| បញ្ចូលទិន្នន័យមន្ត្រីរាជការស៊ីវិលក្នុងប្រព័ន្ធព័ត៌មានវិទ្យា | ២៣ ៩៣៦ | ២៨ ៧១១ | ២១ ៧១៧ | ១៥ ៨២៣ | ១៣ ០៩៧ |
| ធ្វើកំណែទិន្នន័យក្នុងប្រព័ន្ធ | ៣៤ ២៣៨ | ២៤ ៩៩២ | ៤១ ០០៤ | ២២ ៧៦៨ | ១៣ ០៩៧ |
| សលាកបត្រព័ត៌មានមន្ត្រីរាជការស៊ីវិលបានឡើងធ្មើរ | ៣៦ ២៤៤ | ៤ ៤៥០ | ០ | ០ | ០ |
| បោះពុម្ពសលាកបត្រចូលនិវត្តន៍ | ៣ ៤៣២ | ២ ៦៣៨ | ២ ៥៦៥ | ១ ១៧៩ | ១ ៥៥២ |
| លាឈប់ពីការងារ | ៩០២ | ៨០៧ | ៧២៩ | ៥២៤ | ៤០២ |
| មរណភាព | ២០០ | ២២៩ | ២៧៨ | ៣១៦ | ២៣២ |

## ចំនួនសំណើសុំបង្កើត និងកែលម្អរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន

| **ល.រ** | ឆ្នាំ / **ក្រសួង ស្ថាប័ន** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** | **សរុប** |
|---|---|---|---|---|---|---|---|
| ១ | ទីស្តីការគណៈរដ្ឋមន្ត្រី | ២ | ២ | | | | ៤ |
| ២ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៤ | ២ | | ១ | ៣ | ១០ |
| ៣ | ពាណិជ្ជកម្ម | | ១ | ១ | ១ | | ៣ |
| ៤ | សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១ | | | ១ | ១ | ៣ |
| ៥ | អប់រំ យុវជន និងកីឡា | ៥ | ៤ | ២ | ១ | ៨ | ២០ |
| ៦ | បរិស្ថាន | ១ | | ២ | | | ៣ |
| ៧ | ការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ២ | ១ | ២ | | ១ | ៦ |
| ៨ | សុខាភិបាល | ៤ | ៤ | ៣ | | ២ | ១៣ |
| ៩ | ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | | ១ | | | | ១ |
| ១០ | ព័ត៌មាន | ១ | | | | ១ | ២ |
| ១១ | មហាផ្ទៃ | | ១ | | | | ១ |
| ១២ | យុត្តិធម៌ | ១ | | | | | ១ |
| ១៣ | ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤ | ៣ | ១ | | ១ | ៩ |
| ១៤ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | | | | ២ | | ២ |
| ១៥ | រ៉ែនិងថាមពល | ២ | ១ | | | | ៣ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៦ | ផែនការ | ២ | | | ១ | | ៣ |
| ១៧ | ប្រៃសណីយ៍និងទូរគមនាគមន៍ | | ១ | | ១ | | ២ |
| ១៨ | សាធារណការនិងដឹកជញ្ជូន | ១ | ២ | ២ | ២ | ១ | ៨ |
| ១៩ | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ១ | ៤ | | ១ | ៣ | ៩ |
| ២០ | អភិវឌ្ឍន៍ជនបទ | ១ | | | | | ១ |
| ២១ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | | | ១ | | | ១ |
| ២២ | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | | | ១ | ១ | | ២ |
| ២៣ | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | | ១ | | | | ១ |
| ២៤ | អង្គភាពប្រឆាំងអំពើពុករលួយ | ២ | | | | | ២ |
| ២៥ | គណៈកម្មាធិការប្រឆាំងទារុណកម្ម | ១ | | | ១ | | ២ |
| ២៦ | គណៈកម្មាធិការជាតិនៃសមាគមច្បាប់អាស៊ាន | | | ១ | | | ១ |
| ២៧ | សាលាខេត្តកំពង់ឆ្នាំង | ១ | | | | | ១ |
| ២៨ | អង្គការជនពិការ | ១ | | | | | ១ |
| ២៩ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | | | ១ | | | ១ |
| ៣០ | សាលាខេត្តប៉ៃលិន | | | | ១ | | ១ |
| ៣១ | អាជ្ញាធរសេវនកម្មជាតិ | | | | | ១ | ១ |
| | សរុប | ៣៧ | ២៨ | ១៧ | ១៤ | ២២ | ១១៨ |

**ការដំឡើងតម្លៃសន្ទស្សន៍បៀវត្សមូលដ្ឋាន** (គិតជារៀល)



## ការដំឡើងបៀវត្សអប្បបរមា
## សម្រាប់មន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ (គិតជារៀល)

| ឆ្នាំ / បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| រដ្ឋបាលទូទៅ បច្ចេកទេស និងការទូត | ១ ០១៤ ៤៥០ | ១ ១០០ ១០០ | ១ ១៧២ ៥០០ | ១ ១៧២ ៥០០ | ១ ១៧២ ៥០០ | ១ ៣០០ ០០០ |
| អប់រំ | ១ ១១៤ ៤៥០ | ១ ២០០ ១០០ | ១ ២៧២ ៥០០ | ១ ២៧២ ៥០០ | ១ ២៧២ ៥០០ | ១ ៤០០ ០០០ |
| សុខាភិបាល | ១ ១១៤ ៤៥០ | ១ ២០០ ១០០ | ១ ២៧២ ៥០០ | ១ ២៧២ ៥០០ | ១ ២៧២ ៥០០ | ១ ៤០០ ០០០ |
| នគរបាលជាតិ | ១ ០៩៨ ៩២៧ | ១ ១៨៤ ៥៧៧ | ១ ២៥៦ ៩៧៧ | ១ ២៥៦ ៩៧៧ | ១ ២៥៦ ៩៧៧ | ១ ៣៨៤ ៤៧៧ |
| យោធិន | ១ ០៣៥ ០២៧ | ១ ១១៤ ៣៧៧ | ១ ១៨១ ៩៧៧ | ១ ១៨១ ៩៧៧ | ១ ១៨១ ៩៧៧ | ១ ៣០៩ ៤៧៧ |

## ការដំឡើងប្រាក់កម្រៃនិងប្រាក់ឧបត្ថម្ភប្រចាំខែ
## សម្រាប់មន្ត្រីជាប់កិច្ចសន្យា ក្រុមប្រឹក្សាគ្រប់ប្រភេទ និងមន្ត្រីភូមិ (គិតជារៀល)

| ឆ្នាំ / បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|---|
| មន្ត្រីជាប់កិច្ចសន្យា | ៦០០ ០០០ | ៦៥០ ០០០ | ៦៧០ ០០០ | ៦៧០ ០០០ | ៦៧០ ០០០ | ៧១០ ០០០ |
| ប្រធានក្រុមប្រឹក្សា រាជធានី ខេត្ត | ១ ៣៦០ ០០០ | ១ ៤៤០ ០០០ | ១ ៤៤០ ០០០ | ១ ៤៤០ ០០០ | ១ ៤៤០ ០០០ | ១ ៥៧០ ០០០ |
| ក្រុមប្រឹក្សា រាជធានី ខេត្ត | ១ ០៨៥ ០០០ | ១ ១៣៥ ០០០ | ១ ១៣៥ ០០០ | ១ ១៣៥ ០០០ | ១ ១៣៥ ០០០ | ១ ១៩៥ ០០០ |
| ប្រធានក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ | ១ ០៧៥ ០០០ | ១ ១៥៥ ០០០ | ១ ១៥៥ ០០០ | ១ ១៥៥ ០០០ | ១ ១៥៥ ០០០ | ១ ២៨៥ ០០០ |
| ក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ | ៨៦ ០០០០ | ៩១០ ០០០ | ៩១០ ០០០ | ៩១០ ០០០ | ៩១០ ០០០ | ៩៧០ ០០០ |
| ប្រធានក្រុមប្រឹក្សា ឃុំ សង្កាត់ | ១ ០៣០ ០០០ | ១ ១១០ ០០០ | ១ ១១០ ០០០ | ១ ១១០ ០០០ | ១ ១១០ ០០០ | ១ ២៤០ ០០០ |
| ជំទប់ទី១-ទី២ ចៅសង្កាត់រងទី១ ទី២ | ៨០០ ០០០ | ៨៥០ ០០០ | ៨៧០ ០០០ | ៨៧០ ០០០ | ៨៧០ ០០០ | ៩៣០ ០០០ |
| ក្រុមប្រឹក្សាឃុំ សង្កាត់ | ៧០០ ០០០ | ៧៤០ ០០០ | ៧៦០ ០០០ | ៧៦០ ០០០ | ៧៦០ ០០០ | ៨២០ ០០០ |
| មេភូមិ | ២៥០ ០០០ | ៤០០ ០០០ | ៤៣០ ០០០ | ៤៣០ ០០០ | ៤៣០ ០០០ | ៥១០ ០០០ |
| អនុប្រធានភូមិ | ២០០ ០០០ | ២៨០ ០០០ | ៣១០ ០០០ | ៣១០ ០០០ | ៣១០ ០០០ | ៣៩០ ០០០ |
| មន្ត្រីភូមិ | ១៨០ ០០០ | ២៥០ ០០០ | ២៨០ ០០០ | ២៨០ ០០០ | ២៨០ ០០០ | ៣៦០ ០០០ |

**ការដំឡើងរបបសន្តិសុខសង្គមអប្បបរមាប្រចាំខែ**
**សម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន** (គិតជារៀល)




## ទី២- ការពង្រឹងភាពស្អាតស្អំនៅក្នុងរដ្ឋបាលសាធារណៈ

### ១- ការប្រយុទ្ធប្រឆាំងអំពើពុករលួយ (គេហទំព័រ www.acu.gov.kh)

ក្នុងរយៈពេល៥ឆ្នាំនេះ ផ្អែកលើផែនការយុទ្ធសាស្ត្រជាតិ និងនយោបាយប្រយុទ្ធប្រឆាំងអំពើពុករលួយ ដែលបានដាក់ចេញដោយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ទាំងដំណាក់កាលទី២(ឆ្នាំ២០១៥-២០២០) និងដំណាក់ទី៣(ឆ្នាំ២០២០-២០២៥) ស្របជាមួយនឹងការគាំទ្រ ការផ្តល់នូវកម្លាំងចិត្ត ធនធានៈនយោបាយ និងការដាក់ចេញយុទ្ធសាស្ត្រ គោលនយោបាយ ក៏ដូចជាអភិក្រមដឹកនាំដ៏មុតស្រួច«**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**» រួមទាំងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងការដឹកនាំរបស់ក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ** អង្គភាពប្រឆាំងអំពើពុករលួយ បានបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយការច្នៃប្រឌិត និងបាននាំមកនូវសមិទ្ធផលជាបន្តបន្ទាប់ជូនសង្គមជាតិ។

សមិទ្ធផលនៃការប្រយុទ្ធប្រឆាំងអំពើពុករលួយ ត្រូវបានធ្វើឡើងតាមរយៈការងារស្នូលចំនួន៤ រួមមាន (១) ការអប់រំ (២) ការបង្ការទប់ស្កាត់ (៣) ការអនុវត្តច្បាប់បង្ក្រាបបទល្មើសពុករលួយ និង(៤) ការបំពេញកាតព្វកិច្ចជាតិនិងអន្តរជាតិ។

#### ១.១- ការអប់រំ

ការអប់រំអំពីការប្រយុទ្ធប្រឆាំងអំពើពុករលួយ ត្រូវបានធ្វើឡើងក្នុងមជ្ឈដ្ឋានសាលា ដោយបានបញ្ចូលនូវសៀវភៅសិក្សាស្តីពីការប្រឆាំងអំពើពុករលួយទៅក្នុង៣កម្រិតសិក្សា កម្រិតបឋមសិក្សា(ថ្នាក់ទី៤ ទី៥ និងទី៦) មធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧ ទី៨ និង៩) និងមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០ ទី១១ និងទី១២) និងបានបោះពុម្ពសៀវភៅអប់រំគាំទ្រការសិក្សា និងការបង្រៀនដល់សិស្សានុសិស្ស និងគ្រូសរុបចំនួន ៨២៥ ០០០ក្បាល ព្រមទាំងបានបណ្តុះបណ្តាលគ្រូបង្គោល និងបំពាក់បំប៉នការបង្រៀនដល់លោកគ្រូអ្នកគ្រូសរុប១២០នាក់។ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ សិស្សានុសិស្សចំនួនជាង២ ០០០ ០០០នាក់ ជារៀងរាល់ឆ្នាំ បានឆ្លងកាត់ការសិក្សាសៀវភៅទាំងនេះ។ បន្ថែមពីនេះ អង្គភាពប្រឆាំងអំពើពុករលួយក៏បាននិងកំពុងរៀបចំសៀវភៅអប់រំស្តីពីការប្រឆាំងអំពើពុករលួយ សម្រាប់ថ្នាក់ឧត្តមសិក្សានិងសាលាវិជ្ជាជីវៈនានាផងដែរ។

ការអប់រំអំពីការប្រយុទ្ធប្រឆាំងអំពើពុករលួយ ក៏ត្រូវបានធ្វើឡើងក្រោមដ្ឋជ្ជានសាលាផងដែរ ដែលមានច្រើនបែប ច្រើនរូបភាព ដូចជាការប្រារព្ធទិវាជាតិ អន្តរជាតិប្រឆាំងអំពើពុករលួយ ៩ធ្នូ ការចុះអប់រំផ្សព្វផ្សាយដោយផ្ទាល់នៅតាមបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ សាលាវិជ្ជាជីវៈ វិស័យឯកជន អង្គការសង្គមស៊ីវិល វិស័យសារព័ត៌មាន ការផលិត និងផ្សព្វផ្សាយឧបករណ៍អប់រំស្តីពីការប្រយុទ្ធប្រឆាំងអំពើពុករលួយតាមមធ្យោបាយផ្សេងៗ ការរៀបចំកម្មវិធីបណ្តុះគំនិតស្អាតស្អំផ្សេងៗ ដូចជាយុទ្ធនាការ "ព័ត៌មានស្អាត" ដោយសហការជាមួយសហភាពសហព័ន្ធអ្នកសារព័ត៌មានកម្ពុជា បានអនុវត្តស្របគ្នា ដើម្បីលើកកម្ពស់ការយល់ដឹង និងជំរុញការចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយ ឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

លើសពីនេះ ក្នុងស្មារតីទទួលខុសត្រូវដោយប្រកាន់ខ្ជាប់ថា ការងារអប់រំអំពីការប្រឆាំងអំពើពុករលួយ ជាភារកិច្ចរបស់អ្នកទាំងអស់គ្នា។ ក្នុងនោះ ក្រសួង ស្ថាប័ន ផ្នែកសិល្បករ ផ្នែកសារព័ត៌មាន ផ្នែកសិក្សាធិការ និងអង្គការសង្គមស៊ីវិល បានសហការយ៉ាងផុលផុសចូលរួមលើកិច្ចការនេះ តាមការស្នើសុំពីសំណាក់អង្គភាពប្រឆាំងអំពើពុករលួយ និងដោយស្ម័គ្រចិត្ត ដែលធ្វើឱ្យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ ការប្រគំតន្ត្រី ការផ្សាយស្ប៊ូតចម្រៀង សារអប់រំពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើពុករលួយតាមប្រព័ន្ធឃោសនា បណ្តាញទំនាក់ទំនងសង្គមនានា និងសកម្មភាពផ្សេងៗទៀត ត្រូវបានពង្រីកយ៉ាងទូលំទូលាយដល់មន្ត្រីរាជការ ធុរជន និងសាធារណជន។

ការអប់រំផ្សព្វផ្សាយទាំងនេះ បានធ្វើឱ្យមហាជននិងមន្ត្រីរាជការ មានការយល់ដឹងច្បាស់លាស់ និងគោរពអនុវត្តនូវអភិក្រមទាំង៥ "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល វះកាត់" របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការអនុវត្តការងារប្រចាំថ្ងៃ និងលើកកម្ពស់តម្លាភាពក្នុងកិច្ចការងារ និងការរស់នៅប្រចាំថ្ងៃរបស់ខ្លួន។

**ការងារអប់រំផ្សព្វផ្សាយការប្រយុទ្ធប្រឆាំងអំពើពុករលួយ**

| ល.រ | សកម្មភាពការងារ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ១ | ចំនួនអ្នកចូលរួមផ្ទាល់ការផ្សព្វផ្សាយច្បាប់ (នាក់) | ៣១ ២៨២ | ៤ ៩៨៦ | ១ ៣២៦ | ១ ៥១៨ | ១ ៨៨៦ | ៤០ ៩៩៨ |
| ២ | ចំនួនអ្នកទទួលបានការផ្សព្វផ្សាយតាមហ្វេសប៊ុក អ.ប.ព (នាក់) | ១៧៩ ០០០ | ១៨៤ ០០០ | ១៨៩ ៤៦៣ | ១៩៥ ៦០៣ | ១៩៦ ៨៥៥ | ១៩៦ ៨៥៥ |
| ៣ | ចំនួនសៀវភៅច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយដែលត្រូវបានបោះពុម្ព (ក្បាល) | ២០ ០០០ | - | ៣០ ០០០ | - | ៦ ០០០ | ៥៦ ០០០ |
| ៤ | ចំនួនសម្ភារៈ និង បណ្ណផ្សព្វផ្សាយ poster, sticker ដែលត្រូវបានបោះពុម្ព (សន្លឹក) | - | - | ១ ១០០០ | - | - | ១១ ០០០ |
| ៥ | ចំនួនចម្រៀង ស្ប៊ូតអប់រំ និងវីដេអូខ្លី ដែលបានផលិត | ៥ | ៣ | ៩ | ៧ | ២២ | ៤៦ |
| ៦ | - ការផ្សព្វផ្សាយតាមវិទ្យុចំនួន៣ ក្នុងនោះ ១- វិទ្យុជាតិកម្ពុជា ២- វិទ្យុវាយោ និង៣- វិទ្យុទន្លេ | | | ១-២លាននាក់ | ១-២លាននាក់ | ១-២លាននាក់ | ៤-៦លាននាក់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | - ការផ្សព្វផ្សាយតាមទូរទស្សន៍ចំនួន១០ ក្នុងនោះ ១- ទទក ២- បាយ័នអាស៊ីអាគ្នេយ៍ ៣- CTN ៤- ហង្សមាស ៥- អប្សរា ៦- CNC ៨- PNN ៩- PPCTV និង១០- CCTV<br>- ការផ្សព្វផ្សាយតាម LED របស់ក្រុមហ៊ុន ម៉ីង រ៉ួយ គ្រុប ចំនួន ១១កន្លែង ក្នុងនោះ ១- ហាងនំប៉័ងABC នៅស្តុបសន្ធរម៉ុក ២- ស្ពានជ្រោយចង្វារ ៣- បណ្ណាគារIBC នៅស្តុបដេអ៊ិន ៤- បណ្ណាគារIBC នៅស្តុបត្រសក់ផ្អែម ៥- ស្ថានីយប្រេងឥន្ធនៈ SOKIMEX ក្បាលថ្នល់ ៦- ស្តុបនាងគង្ហីង ៧- ស្តុបអាងទឹកអូឡាំពិក ៨- ស្តុបផ្សារដើមគរ ៩- ផ្សារអូរឫស្សី ១០- ស្តុបផ្សារថ្មី និង១១- រោងកុនអង្គរ។ | | | | | | |
| ៧ | ការរៀបចំនិងបណ្តុះបណ្តាលដល់គ្រូ អំពីការអប់រំស្តីពីការប្រឆាំងអំពើពុករលួយ (ចំនួនសិក្ខាកាម និងខេត្ត) | ១២០នាក់/១ខេត្ត | - | - | - | - | ១២០នាក់/១ខេត្ត |
| ៨ | ទិវាជាតិប្រឆាំងអំពើពុករលួយ ៩ធ្នូ (លើក) | ចុះផ្សព្វផ្សាយ ៣៧កន្លែង (២៤ ១៤៥ នាក់) | យុទ្ធនាការពិនិត្យសេវាសាធារណៈ សង្កាត់ ៤ ក្នុងខណ្ឌមានជ័យ | ចូលរួមកិច្ចប្រជុំASEAN-PAC និងផ្សព្វ-ផ្សាយតាមបណ្តាញសង្គមដែលអ្នកទស្សនាចំនួនជិត១លាននាក់ | ប្រារព្ធកម្មវិធីបំពាក់មេដាយ និងគ្រឿងឥស្សរិយ-យសជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ ព្រមទាំងសិល្បករចំនួន៣រូប | -រៀបចំសន្និបាតបូកសរុបប្រចាំឆ្នាំ ២០២២ និងប្រកាសឱ្យប្រើប្រាស់អាំងស៊ិញថ្មីជូនមន្ត្រីនគរបាលយុត្តិធម៌ អ.ប.ព<br>-ផ្សព្វផ្សាយខ្លឹមសារប្រឆាំងអំពើពុករលួយ | ៥លើក |

## ១.២- ការបង្ការទប់ស្កាត់

ការងារបង្ការទប់ស្កាត់អំពើពុករលួយ ក៏ត្រូវបានអនុវត្តស្របគ្នានឹងការអប់រំផ្សព្វផ្សាយដែរ សំដៅរួមចំណែកជាមួយគ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលុបបំបាត់ជាបណ្តើរៗនូវឱកាសប្រព្រឹត្តអំពើពុករលួយ។ អង្គភាពប្រឆាំងអំពើពុករលួយ បានចូលរួមសង្កេតការណ៍នៅក្នុងដំណើរការងារមួយចំនួន ដូចខាងក្រោម ៖

- ការងារលទ្ធកម្មរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចំនួន៣១៩ ស្មើនឹង៥ ៧៧៥គម្រោង

- ការប្រឡងជ្រើសរើសមន្ត្រីរាជការស៊ីវិលចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌក្រសួង ស្ថាប័ន ចំនួន៨ ស្មើនឹង ២៥លើក

- ការប្រឡងជ្រើសរើសសិស្ស និស្សិត ចូលសិក្សានៅតាមសាលាវិជ្ជាជីវៈ និងគ្រឹះស្ថានឧត្តមសិក្សាចំនួន៥ ស្មើនឹង១៩លើក

- ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំនួន៥លើក

- ការដាក់ចេញ និងកែសម្រួលប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័នចំនួន១៤ស្មើនឹង ៤៥ប្រកាស

- ការស្ទង់មតិ ពិនិត្យ និងផ្តល់យោបល់លើការអនុវត្តការផ្តល់សេវាសាធារណៈចំនួន១ក្រសួង ៩មន្ទីរ និង ៤សង្កាត់

- ការងារទារបំណុលអាជីវកម្មខ្សាច់និងរ៉ែផ្សេងៗ ចំនួន១១លើកនៅក្នុងខេត្តចំនួន៥។

ការពង្រឹងការបង្ការទប់ស្កាត់អំពើពុករលួយនៅក្នុងវិស័យឯកជន ក៏ជាការងារមួយមានសារៈសំខាន់ អង្គភាពប្រឆាំងអំពើពុករលួយ បានចុះអនុស្សរណៈនៃការយោគយល់គ្នា(MoU) ស្តីពីកិច្ចសហការប្រឆាំងអំពើពុករលួយ រវាងអង្គភាពប្រឆាំងអំពើពុករលួយជាមួយនឹងវិស័យឯកជន បានកើនដល់១០៥MoU ក្នុងគោលបំណងរួមគ្នាទប់ស្កាត់អំពើពុករលួយក្នុងវិស័យនេះ ដែលមានវិសាលភាពគ្របដណ្តប់លើក្រុមហ៊ុនជាង១ ០០០ និងគ្រឹះស្ថានឧត្តមសិក្សាឯកជនជាង៣០។ ទន្ទឹមនោះ អង្គភាពប្រឆាំងអំពើពុករលួយបានរៀបចំជាវេទិកាពិគ្រោះយោបល់ និងការដោះស្រាយបញ្ហាប្រឈមនានាដែលវិស័យឯកជនបានជួបប្រទះក្នុងធុរកិច្ចរបស់ខ្លួន បានជាបន្តបន្ទាប់។

រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ បានបង្កើតក្របខ័ណ្ឌគតិយុត្តជាច្រើន ដោយបាននិងកំពុងអនុវត្ត ព្រមទាំងបានបង្កើតឱ្យមានយន្តការការគ្រប់គ្រងតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលបានកាត់បន្ថយនូវឱកាសប្រព្រឹត្តអំពើពុករលួយ រវាងមន្ត្រីរាជការដែលជាភ្នាក់ងាររបស់រដ្ឋនិងប្រជាពលរដ្ឋ ឱ្យបានជាអតិបរមាក្នុងការប្រគល់ ទទួលសេវាកម្មបានទាន់ពេលវេលា មានភាពងាយស្រួល និងសាមញ្ញជាងមុន។ ជាមួយគ្នានេះ អង្គភាពប្រឆាំងអំពើពុករលួយបានចេញលិខិតព្រមានអ្នករាជការសាធារណៈ ដែលខកខានមិនបានបំពេញភារកិច្ចឱ្យបានត្រឹមត្រូវកន្លងមក ចំនួន៤៩នាក់។

ការប្រកាសទ្រព្យសម្បត្តិនិងបំណុល រយៈពេល៥ឆ្នាំ (ឆ្នាំ២០១៨-២០២២) ក៏នៅតែជាកិច្ចការថ្មី ពីព្រោះកន្លងមកក្នុងប្រវត្តិសាស្ត្រកម្ពុជាយើងមិនធ្លាប់មានការប្រកាសទ្រព្យសម្បត្តិនិងបំណុលនៅឡើយទេ។ ការប្រកាសទ្រព្យសម្បត្តិនិងបំណុល បានរួមចំណែកយ៉ាងសំខាន់ក្នុងការទប់ស្កាត់អំពើពុករលួយ និងបានចូលរួមចំណែកធ្វើឱ្យប្រែប្រួលឥរិយាបថសង្គម លើទ្រព្យសម្បត្តិរបស់ខ្លួន ហើយយើងនៅបន្តការងារប្រកាសទ្រព្យសម្បត្តិនិងបំណុលជាទៀងទាត់តាមរបប២ឆ្នាំ តាមពេលវេលាដែលទទួលតំណែងថ្មី ការលាឈប់ពីការងារ ចប់អាណត្តិពីការងារ ចូលនិវត្តន៍ ឬបញ្ឈប់ពីការងារ ដែលទោះបីជាការងារទាំងអស់នេះជាការងារដែលមានភាពស្មុគស្មាញជាច្រើនក៏ដោយក៏យើងនៅតែបន្តអនុវត្តនិងសម្រេចបានលទ្ធផលស្ទើរតែ១០០%។

**ការងារប្រកាសទ្រព្យសម្បត្តិនិងបំណុល**

| កាលបរិច្ឆេទ | តាមរបប២ឆ្នាំ | តែងតាំងថ្មី | លាឈប់ឬ ចប់អាណត្តិ | បញ្ឈប់ពី មុខតំណែង | ចូលនិវត្តន៍ | តម្រូវការ ស៊ើបអង្កេត | ចំនួន ឯកសារសរុប |
|---|---|---|---|---|---|---|---|
| ឆ្នាំ២០១៨ | ៥ ៧៤៤ | ៨ ១៧៧ | ៥០០ | ៣ ៨៨៨ | ៨៦ | ១៥ | **១៨ ៤០៥** |
| ឆ្នាំ២០១៩ | ២១ ៨៣៥ | ៥ ១៤៥ | ១ ៤៩៧ | ៥៤ | ៧៩០ | ២០ | **២៩ ៣៤១** |
| ឆ្នាំ២០២០ | ១២ ៥០៥ | ២ ៩៨៩ | ៣៦៣ | ៣០ | ៧០៦ | ៨ | **១៦ ៥៩៦** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ឆ្នាំ២០២១ | ២៤៤០៤ | ១ ៨២៨ | ២៧៥ | ៣៥ | ១ ០១៥ | ១០ | **២៧ ៥៥៨** |
| ឆ្នាំ២០២២ | ១៤ ៥១២ | ៦ ៩៨២ | ៤ ៦៤៦ | ២៥ | ៦៣០ | ២៣ | **២៦ ៧៩៥** |
| **សរុប** | **៧៩ ០០០** | **២៥ ១២១** | **៧ ២៨១** | **៤ ០៣២** | **៣ ២៣៧** | **៧៦** | **១១៨ ៦៩៥** |

## ១.៣- ការអនុវត្តច្បាប់បង្ក្រាប

ការងារអនុវត្តច្បាប់បង្ក្រាប ក៏បានដើរទន្ទឹមគ្នាជាមួយនឹងការអប់រំ បង្ការ និងទប់ស្កាត់ដែរ។ យន្តការទទួល និងដោះស្រាយពាក្យបណ្ដឹង ជាទូទៅត្រូវបានទទួលការវាយតម្លៃជាវិជ្ជមានពីសំណាក់អ្នកប្ដឹងដោយអ.ប.ព. ដោះស្រាយបានឆាប់រហ័សនិងគ្រប់ជ្រុងជ្រោយ និងបានចុះស្រាវជ្រាវដល់ក្រសួង ស្ថាប័ន និងទីកន្លែងមូលដ្ឋាន ហើយមានមូលដ្ឋានគតិយុត្តច្បាស់លាស់។ រាល់ការមកប្ដឹងផ្ទាល់ ប្ដឹងតាមប្រអប់សំបុត្រស តាមប្រៃសណីយ៍ ទូរសព្ទ អ៊ីមែល និងតាមបណ្ដាញទំនាក់ទំនងសង្គម (Facebook Telegram Line WeChat WhatsApp ព័ត៌មានជាចំហរលើសារព័ត៌មាន តាមការប្រមូលព័ត៌មានជាសម្ងាត់របស់អ.ប.ព.) ត្រូវបានយកមកពិនិត្យនិងដោះស្រាយក្នុងកិច្ចប្រជុំអាហារពេលព្រឹក(ចាប់ផ្ដើមម៉ោង៧:៣០នាទី) ជារៀងរាល់ព្រឹកនៃថ្ងៃធ្វើការ ដើម្បីពិនិត្យពាក្យប្ដឹងដែលបានដាក់មកអង្គភាពប្រឆាំងអំពើពុករលួយ ពាក្យបណ្ដឹងពិសេសមួយចំនួនត្រូវបានបញ្ជូនទៅក្រុមប្រឹក្សាវិន័យ និងត្រួតពិនិត្យផ្ទៃក្នុងដើម្បីប្រជុំវិភាគនិងដោះស្រាយ ដោយមានការបើកទ្វារជូនដល់ម្ចាស់បណ្ដឹងចូលស្ដាប់ការជជែកវែកញែកក៏ដូចជាការផ្ដល់នូវជាតុចូលបន្ថែមទៀត លើករណីបណ្ដឹងរបស់ខ្លួន។

**ការងារទទួលពាក្យប្ដឹង**

| យន្តការនៃការទទួលពាក្យបណ្ដឹង | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | |
| ប្ដឹងផ្ទាល់នៅអ.ប.ព | ១៧៤ | ៣៥,៧៣ | ២២៥ | ៣៦,២៣ | ៣២៥ | ៤៩,២៤ | ២០៦ | ៤៧,១៤ | ១៨៥ | ៥០,៥៥ | **១ ១១៥** |
| ប្រអប់សំបុត្រស | ២៤៧ | ៥០,៧២ | ២៤២ | ៣៨,៩៧ | ២៤៧ | ៣៧,៤២ | ១៨២ | ៤១,៦៥ | ១៥៣ | ៤១,៨០ | **១ ០៧១** |
| អ្នកបញ្ជូនសារ | ៣ | ០,៦២ | ១០៤ | ១៦,៧៥ | ២ | ០,៣០ | - | - | - | - | **១០៩** |
| ទូរសព្ទ | ៣ | ០,៦២ | ១ | ០,១៦ | ១ | ០,១៥ | - | - | - | - | **៥** |
| អ៊ីមែល | ២៨ | ៥,៧៥ | ១៩ | ៣,០៦ | ២៩ | ៤,៣៩ | ១៥ | ៣,៤៣ | ១០ | ២,៧៣ | **១០១** |
| ប្រៃសណីយ៍ | ៦ | ១,២៣ | ៨ | ១,២៩ | ៧ | ១,០៦ | ៦ | ១,៣៧ | ៥ | ១,៣៧ | **៣២** |
| ហ្វេសប៊ុក | ២៤ | ៤,៩៣ | ១៨ | ២,៩០ | ៤៥ | ៦,៨២ | ១៥ | ៣,៤៣ | ១១ | ៣,០១ | **១១៣** |
| You Tube | - | - | - | - | - | - | ១ | ០,២៣ | - | - | **១** |
| តេឡេក្រាម | ១ | ០,២១ | ៣ | ០,៤៨ | ៣ | ០,៤៥ | - | - | ២ | ០,៥៥ | **៩** |
| សារព័ត៌មាន | ១ | ០,២១ | ១ | ០,១៦ | ១ | ០,១៥ | ១២ | ២,៧៥ | - | - | **១៥** |
| **សរុប** | **៤៨៧** | **១០០** | **៦២១** | **១០០** | **៦៦០** | **១០០** | **៤៣៧** | **១០០** | ៣៦៦ | **១០០** | **២ ៥៧១** |

ឱកាសក្នុងការចូលរួម និងការមើលឃើញផ្ទាល់នូវសក្តិភាពនៃកិច្ចប្រឹងប្រែងប្រកបដោយសមត្ថភាព ដោយស្មារតីទទួលខុសត្រូវវិជ្ជាជីវៈច្បាស់លាស់របស់អង្គភាពប្រឆាំងអំពើពុករលួយ ក្នុងការដោះស្រាយពាក្យបណ្តឹងតែងតែទទួលបាននូវការសាទរពីសំណាក់អ្នកប្តឹង។ យន្តការដោះស្រាយបណ្តឹង និងស៊ើបអង្កេតក៏ត្រូវបានប្រើប្រាស់សម្រាប់ព័ត៌មានដែលទទួលបានទាំងប្រភពចំហរនិងចារកម្ម ក្រោមគោលការណ៍តឹងរឹង និងមិនអាចដោះដូរបាននៃការរក្សាការសម្ងាត់នៃប្រភពក៏ដូចជាសាក្សីទាំងនៅក្នុង និងនៅក្រៅអង្គភាពប្រឆាំងអំពើពុករលួយ។

**ការងារចំណាត់ការដោះស្រាយពាក្យបណ្តឹង**

| ចំណាត់ការ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|
| ១- រក្សាទុកជាព័ត៌មាន | ១៥៤ | ២៦០ | ២៤៧ | ១៧៣ | ២៣៦ | **១ ០៧០** |
| ២- ដោះស្រាយបញ្ចប់ពាក្យបណ្តឹង (មិនពាក់ព័ន្ធអំពើពុករលួយ) | ៣៣១ | ៣៥៦ | ៣៧៩ | ២៣៥ | ១០៩ | **១ ៤១០** |
| - អន្តរាគមន៍ | ៧ | ១២ | ៨ | ៧ | ១៤ | ៤៨ |
| - ឆ្លើយតប (+ចម្លងជូន) | ៨៥ | ៨៤ | ១៥២ | ១៤៤ | ៧៧ | ៥៥៧ |
| - ស្រាវជ្រាវ<br>- សុំការបំភ្លឺ | ២៣៩ | ២៦០ | ២១៩ | ៨៤ | ១៨ | ៨២០ |
| ៣- បញ្ជូនសំណុំរឿងទៅតុលាការ(ករណី) | ២ | ៥ | ៧ | ៧ | ៤ | **២៥** |
| ៤- ពាក្យបណ្តឹងកំពុងបន្តនីតិវិធី | **០** | **០** | **២៧** | **២២** | **១៧** | **៦៦** |

បទពិសោធបានចង្អុលបង្ហាញពីកិច្ចសហការជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ តាមក្រសួងស្ថាប័នប្រកបដោយភាពវិជ្ជមាន ក្នុងការដោះស្រាយពាក្យបណ្តឹងដែលមិនទាន់មាន ឬមិនអាចមាន ឬក៏មានភស្តុតាងដែរ ប៉ុន្តែភស្តុតាងត្រូវបានរលត់ និងមិនអាចយកមកប្រើប្រាស់ដើម្បីបញ្ជូនសំណុំរឿងទៅតុលាការបាន។ ទន្ទឹមនឹងនោះ ប្រសិទ្ធភាពនៃការដោះស្រាយបណ្តឹងតាមបែបរដ្ឋបាលនិងវិន័យ ក៏អាចនាំមកនូវឥទ្ធិពលដុំព្រិល(Snowball Effect) ពោលគឺបាននាំមកនូវលទ្ធផលដែលចង់បាននោះគឺកំហុសដដែលៗ មិនអាចកើតឡើងជាថ្មី ហើយការកែលម្អ និងធ្វើឱ្យប្រសើរឡើងនូវរដ្ឋបាលស្អាតស្អំនៅតាមស្ថាប័នសាធារណៈក៏មានសន្ទុះវិជ្ជមានគួរឱ្យកត់សម្គាល់។

កំណើននៃចំណាត់ការរដ្ឋបាលនិងវិន័យ ដែលជាលទ្ធផលនៃកិច្ចសហការជាមួយក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ព្រមទាំងជាមួយនឹងតម្រូវការ និងភាពចាំបាច់ក្នុងការរកឱ្យបាននូវភស្តុតាងឱ្យបានរឹងមាំ និងច្បាស់លាស់ ដែលជាទូទៅត្រូវការពេលវេលា បទពិសោធ និងជំនាញវិជ្ជាជីវៈគួបផ្សំគ្នាផងនោះ បានធ្វើឱ្យសំណុំរឿងបញ្ជូនទៅតុលាការ ត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ និងទទួលបានជោគជ័យ១០០%។

## ១.៤- ការបំពេញភារកិច្ចជាតិ និងអន្តរជាតិ

អង្គភាពប្រឆាំងអំពើពុករលួយ បានបំពេញភារកិច្ចក្នុងនាមជាស្ថាប័នតំណាងឱ្យរដ្ឋភាគីនៃអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ(UNCAC) ដោយអង្គភាពប្រឆាំងអំពើពុករលួយ គឺជាស្ថាប័នបង្គោលក្នុងការសម្របសម្រួលលើដំណើរការទទួលការត្រួតពិនិត្យ ការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ UNCAC ជុំទី២ នៅកម្ពុជា ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ រួមមានស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ

ស្ថាប័នតុលាការ វិស័យឯកជន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងផ្នែកសិក្សាធិការ។ ការអនុវត្តអនុសញ្ញា UNCAC នៅជុំទី២ នេះ អង្គភាពប្រឆាំងអំពើពុករលួយទទួលការត្រួតពិនិត្យរបស់UN ពីសំណាក់ប្រទេសថៃ និងប្រទេសអេស្វាទីនី ហើយតំណាងអង្គភាពប្រឆាំងអំពើពុករលួយរបស់កម្ពុជានិងUN នឹងត្រូវទៅត្រួតពិនិត្យការអនុវត្តអនុសញ្ញាUNCAC នៅប្រទេសគិរីបាទីនិងលីបង់វិញដែរ។

ការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម អង្គភាពប្រឆាំងអំពើពុករលួយបានចូលរួមយ៉ាងសស្រាក់សស្រាំក្នុងយន្តការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលកំណត់ដោយអង្គការFATF។ ការងារគាំទ្រ និងការបំពេញភារកិច្ចពីសំណាក់អង្គភាពប្រឆាំងអំពើពុករលួយ ក្រសួង ស្ថាប័ន និងអង្គភាព ពាក់ព័ន្ធនានា សំដៅរុញច្រានកម្ពុជាចេញពីបញ្ជីប្រផេះគឺជាអាទិភាពមួយចាំបាច់បំផុត។ អង្គភាពប្រឆាំងអំពើពុករលួយបានខិតខំប្រឹងប្រែងអនុវត្តកាតព្វកិច្ចអន្តរជាតិទាំងអស់ដែលពាក់ព័ន្ធជាមួយការងារប្រឆាំងអំពើពុករលួយ និងការសម្អាតប្រាក់ ហើយជឿថា កាតព្វកិច្ចទាំងនេះបាននាំមកដល់កម្ពុជា នូវឱកាសនៃការអភិវឌ្ឍផ្ទៃក្នុង ទាំងក្នុងក្របខ័ណ្ឌច្បាប់ និងការអនុវត្តតួនាទីរបស់តួអង្គពាក់ព័ន្ធទាំងអស់។

កម្ពុជាបានចាត់ទុកការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម គឺជាការងារសំខាន់ ចាំបាច់ និងបន្ទាន់។ រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញឆន្ទៈនិងការប្តេជ្ញាចិត្តខ្ពស់ចំពោះការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ យុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣ ការកែសម្រួលក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌស្ថាប័ន ដើម្បីធ្វើឱ្យការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មកាន់ តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

ក្នុងខណៈពេលដែលកម្ពុជាកំពុងស្ថិតក្នុងបញ្ជីប្រផេះ ធនាគារជាតិនៃកម្ពុជា(NBC) ដែលជាស្ថាប័នបង្គោលតំណាងឱ្យព្រះរាជាណាចក្រកម្ពុជា ដោយមានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ(FIU) ជាសេនាធិការ បានដើរតួនាទីដ៏សំខាន់ជាមួយគ្រប់ភាគីពាក់ព័ន្ធ បានអនុវត្តភារកិច្ចរបស់ខ្លួនស្របតាមផែនការយុទ្ធសាស្ត្រជាតិប្រឆាំងការសម្អាតប្រាក់ និងផែនការសកម្មភាពដែលកំណត់ដោយក្រុមអាស៊ីប៉ាស៊ីហ្វិកប្រឆាំងការសម្អាតប្រាក់(APG)។ អង្គភាពប្រឆាំងអំពើពុករលួយដែលជាសមាជិកសកម្មក្នុងកិច្ចការនេះ បានចូលរួមគ្រប់បែបយ៉ាងតាមការដឹកនាំរបស់ធនាគារជាតិនៃកម្ពុជា ដោយបានរៀបចំការបណ្តុះបណ្តាល សម្របសម្រួលការអនុវត្តច្បាប់សម្រាប់ស៊ើបអង្កេតបទល្មើសសម្អាតប្រាក់ ធ្វើរបាយការណ៍វឌ្ឍនភាព និងចូលរួមប្រជុំវាយតម្លៃដាក់ពិន្ទុលើវឌ្ឍនភាពការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម។ កម្ពុជាបានអនុវត្តផែនការសកម្មភាពចំនួន១៤ លើ១៤ ចំណុច រួចហើយ និងកំពុងរៀបចំទទួលការចុះមកត្រួតពិនិត្យដល់ប្រទេសកម្ពុជា ដោយក្រុមរួមរបស់APG ដែលនឹងធ្វើនៅខែមករា ឆ្នាំ២០២៣ ខាងមុខនេះ ដើម្បីដកកម្ពុជាចេញពីបញ្ជីប្រផេះ។

អង្គភាពប្រឆាំងអំពើពុករលួយ នឹងធ្វើជាម្ចាស់ផ្ទះ និងជាប្រធានកិច្ចប្រជុំថ្នាក់ដឹកនាំនៃស្ថាប័នប្រឆាំងអំពើពុករលួយអាស៊ាន(ASEAN-PAC)លើកទី១៨ នៅថ្ងៃទី២២-២៣ ខែវិច្ឆិកា ឆ្នាំ២០២២ នៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ដែលនឹងពិភាក្សាលើមូលបទ "រួមគ្នាប្រយុទ្ធប្រឆាំងអំពើពុករលួយ" ៖ ការពង្រឹងសមត្ថភាពស្ថាប័នប្រឆាំងអំពើពុករលួយ និងកិច្ចសហប្រតិបត្តិការនៅក្នុងចំណោមប្រទេសអាស៊ានផេក(ASEAN-PAC) នីមួយៗ និងនៅក្នុងរង្វង់អាស៊ានផេក(ASEAN-PAC)។ ស្ថាប័នប្រឆាំងអំពើពុករលួយអាស៊ាន(ASEAN-PAC) ត្រូវបានប្តូរមកពីឈ្មោះថាភាគីអាស៊ីអាគ្នេយ៍ប្រឆាំងអំពើពុករលួយ-ស៊ីផេក (SEA-PAC) កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ហើយនៅក្នុងរយៈពេល៥ឆ្នាំ(ឆ្នាំ២០១៨-២០២២)នេះ អង្គភាពប្រឆាំងអំពើពុករលួយកម្ពុជា បានចូលរួមក្នុងកិច្ចប្រជុំអាស៊ានផេក(ASEAN-PAC) ជាទៀងទាត់ចំនួន២លើក នៅរៀងរាល់ឆ្នាំ។

**ការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ**

| ប្រភេទកិច្ចសហប្រតិបត្តិការ (លើក) | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|
| កិច្ចប្រជុំអាស៊ានផេកASEAN-PAC | ២ | ២ | ២ | ២ | ២ | **១០** |
| កិច្ចប្រជុំUNCAC | ៣ | ៣ | - | ១ | ១ | **៨** |
| កិច្ចប្រជុំADB/OECD | ១ | ១ | ១ | ១ | ១ | **៥** |
| សន្និសីទ/កិច្ចប្រជុំIAACA | - | ១ | - | - | ១ | **១** |
| កិច្ចប្រជុំIACA | ១ | ១ | ១ | ១ | ១ | **៥** |
| កិច្ចប្រជុំ សន្និសីទ ទស្សនកិច្ចសិក្សា សិក្ខាសាលា | ២១ | ២៦ | ៦ | ១៥ | ១០ | **៧៧** |
| **សរុប** | **២៨** | **៣៤** | **១០** | **២០** | **១៦** | **១០៧** |

## ២- ការអប់រំ ផ្សព្វផ្សាយ និងអធិការកិច្ច

**ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច** (គេហទំព័រ www.monasri.gov.kh)

### ២.១- ការងារផែនការនិងស្ថិតិ

- បានរៀបចំគម្រោងផែនការវិនិយោគសាធារណៈ៣ឆ្នាំរំកិល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រថវិកា គម្រោងថវិការដ្ឋសម្រាប់គ្រប់គ្រង ផែនការសកម្មភាពស្តីពីការងារអប់រំផ្សព្វផ្សាយច្បាប់ចងក្រងទិន្នន័យស្ថិតិទូទៅក្របខ័ណ្ឌមន្ត្រីរាជការ និងថ្នាក់ដឹកនាំប្រចាំឆ្នាំ ចងក្រងទិន្នន័យស្ថិតិផ្លូវការដែលមានការចាត់តាំងតាមវិស័យ របាយការណ៍ពាក់កណ្តាលអាណត្តិអំពីសមិទ្ធផលរបស់ក្រសួង របាយការណ៍ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ របាយការណ៍ផែនការសកម្មភាពស្តីពីការងារអប់រំផ្សព្វផ្សាយច្បាប់ របាយការណ៍ត្រួតពិនិត្យដោយស្ម័គ្រចិត្តឆ្នាំ២០១៩ ស្តីពីសកម្មភាពការងារអប់រំផ្សព្វផ្សាយច្បាប់ និងបានរៀបចំបូកសរុបរបាយការណ៍សមិទ្ធកម្មតាមដានលទ្ធផលនៃការអនុវត្តថវិកាកម្មវិធី

- បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងបានចូលរួមកិច្ចប្រជុំនានាពាក់ព័ន្ធនឹងការងារជំនាញនិងការងារផ្សេងៗចំនួន**៦៧លើក**។

### ២.២- ការងារសហប្រតិបត្តិការអន្តរជាតិ

- ថ្នាក់ដឹកនាំក្រសួងបានទទួលជួបសវនាការការងារជាមួយឯកឧត្តម លោកជំទាវ ឯកអគ្គរដ្ឋទូត ឯកអគ្គរាជទូត និងភ្ញៀវអន្តរជាតិចំនួន**២៧លើក** នៅទីស្តីការក្រសួង

- គណៈប្រតិភូក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាមានិតចិន និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីផ្លាស់ប្តូរបទពិសោធអំពីការងារអធិការកិច្ច ការដោះស្រាយបណ្តឹងតវ៉ា បណ្តឹងបរិហារ និងការទប់ស្កាត់អំពើពុករលួយរវាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងក្រសួងត្រួតពិនិត្យនៃសាធារណរដ្ឋប្រជាមានិតចិន និងអគ្គាធិការកិច្ចរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

- បានទំនាក់ទំនងជាមួយវិទ្យាស្ថានសន្ទនាមេគង្គ និងវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា ដើម្បីវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសនិងភាសាចិន

- បានចូលរួមពិធីគោរពវិញ្ញាណក្ខន្ធសពឥស្សរជនជាន់ខ្ពស់នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅស្ថានទូតសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជាចំនួន២លើក

- បានចូលរួមពិធីបុណ្យជាតិនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ចំនួន១លើក សហព័ន្ធរុស្ស៊ីចំនួន១លើក សាធារណរដ្ឋកូរ៉េ ចំនួន១លើក ព្រះរាជាណាចក្រជប៉ុន ចំនួន១លើក និងព្រះរាជាណាចក្រថៃ ចំនួន១លើក នៅស្ថានទូតប្រចាំព្រះរាជាណាចក្រកម្ពុជា

- បានអញ្ជើញឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា និងវិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជា ដើម្បីចូលរួមពិធីប្រគល់វិញ្ញាបនបត្រដល់សិក្ខាកាមជាមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ដែលបានរៀនភាសាចិនកម្រិតបឋម

- បានចូលរួមទស្សនកិច្ចសិក្សាស្វែងយល់ពីបទពិសោធក្នុងការផ្តល់សេវាសាធារណៈ នៅវិទ្យាស្ថានបណ្តុះបណ្តាលមន្ត្រីរាជការរបស់ប្រទេសសិង្ហបុរី និងចូលរួមក្នុងកម្មវិធីទស្សនកិច្ចសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន រយៈពេល៨ថ្ងៃ

- បានចាត់មន្ត្រីរាជការចំនួន៤រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីនៃការដាក់ពាក្យស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការអេឡិចត្រូនិកថ្មី(E passport) និងជំនាញការទូតនិងទំនាក់ទំនងអន្តរជាតិ នៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងតាមប្រព័ន្ធអនឡាញ(ZOOM)

- បានចូលរួមសិក្ខាសាលាស្តីពីការចែករំលែកព័ត៌មាន បទពិសោធ និងនីតិវិធីគន្លឹះៗក្នុងការទទួលបានអាហារូបករណ៍ទៅប្រទេសអូស្ត្រាលី តាមប្រព័ន្ធអនឡាញ(ZOOM)

- បានចូលរួមពីធីបុណ្យខួបគម្រប់៧០ឆ្នាំនៃទំនាក់ទំនងការទូតរវាងអូស្ត្រាលី និងកម្ពុជា នៅគេហដ្ឋានឯកឧត្តមឯកអគ្គរដ្ឋទូតអូស្ត្រាលី

- បានចូលរួមពិធីទទួល និងជូនដំណើរគណៈប្រតិភូជាន់ខ្ពស់ដឹកនាំដោយឯកឧត្តម NGUYEN PHU TRONG អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាម និងជាប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម គណៈប្រតិភូជាន់ខ្ពស់ដឹកនាំដោយឯកឧត្តម **មូន ចេអ៊ីន** ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ ឯកឧត្តម **ប៊ុនញាំង វ៉រ៉ាជីត** អគ្គលេខាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ឡាវ និងជាប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិប-តេយ្យប្រជាមានិតឡាវ គណៈប្រតិភូជាន់ខ្ពស់សាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត ដឹកនាំដោយឯកឧត្តម **DR JOSE RAMOS HORIA** ប្រធានាធិបតី និងគណៈប្រតិភូជាន់ខ្ពស់ប្រទេសព្រុយណេ ដឹកនាំដោយព្រះចៅស៊ុលតង់ **HAJI HASSANAL BOLKIAH** ជាព្រះមហាក្សត្រនិងជាព្រះប្រមុខរដ្ឋ នៅមុខព្រះបរមរាជវាំង

-បានចូលរួមប្រជុំគណៈកម្មការចម្រុះកម្ពុជា វៀតណាម(JC) លើកទី១៦ និងលើកទី១៨ នៅទីក្រុងហាណូយនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងកិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិកឆ្នាំ២០១៩ កម្ពុជាកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនិងសង្គមស៊ីវិល នៅទីស្តីការគណៈរដ្ឋមន្ត្រី។

## ២.៣- សកម្មភាពការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា

### ២.៣.១- ការងារនីតិកម្ម

- បានរៀបចំកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច ចំនួន**៧៣លើក** និងប្រជុំឆ្លងសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច ចំនួន៤លើក នៅទីស្តីការក្រសួង

- បានចូលរួមការពារសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចក្នុងកិច្ចប្រជុំជំនាញបច្ចេកទេស ចំនួន៦លើក និងចូលរួមការពារសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ចក្នុងកិច្ចប្រជុំអន្តរក្រសួងចង្អៀត ចំនួន២លើក នៅទីស្តីការគណៈរដ្ឋមន្ត្រី

- បានចូលរួមកិច្ចប្រជុំអន្តរក្រសួង និងសិក្ខាសាលានៅតាមបណ្តាក្រសួង ស្ថាប័នផ្សេងៗ ចំនួន **២៥លើក**

- បានបញ្ចូលឯកសារច្បាប់ចំនួន**៨៦៧ច្បាប់** ទៅក្នុងបណ្ណាល័យអេឡិចត្រូនិក

- បានចុះស្ទង់មតិស្តីពីការយល់ដឹងរបស់ប្រជាពលរដ្ឋលើច្បាប់ចំនួន**៦០លើក** (អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភាចំនួន**២៨**លើក និងមន្ទីររាជធានី ខេត្ត ចំនួន**៣២លើក** ក្នុងនោះឆ្នាំ២០១៨ ចំនួន**១៤លើក** ឆ្នាំ២០១៩ ចំនួន**២១លើក** ឆ្នាំ២០២០ ចំនួន**៨លើក** ឆ្នាំ២០២១ ចំនួន៨ ឆ្នាំ២០២២ ចំនួន**៩លើក**) គឺច្បាប់ភូមិបាល ចំនួន**២៩លើក** ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ចំនួន**២០លើក** ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចំនួន៧លើក និងច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ផ្សេងទៀត ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ចំនួន៤លើក នៅខេត្ត ចំនួន១១ ដោយមានអ្នកចូលរួម ចំនួន៦ **២១០នាក់** (ស្ត្រីចំនួន២ ៩៦៣នាក់)។

**២.៣.២- ការងារអប់រំផ្សព្វផ្សាយច្បាប់**

បានចុះផ្សព្វផ្សាយច្បាប់ចំនួន**៥៥០លើក** (អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភាចំនួន៦០លើក និងមន្ទីររាជធានី ខេត្តចំនួន៤៩០លើក ក្នុងនោះឆ្នាំ២០១៨ ចំនួន១២៤លើក ឆ្នាំ២០១៩ ចំនួន១៤៤លើក ឆ្នាំ២០២០ ចំនួន១០២លើក ឆ្នាំ២០២១ ចំនួន៧៣លើក និងឆ្នាំ២០២២ចំនួន១០៧លើក) គឺច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន២៣០លើក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន១៧១លើក ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិចំនួន១លើក ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ចំនួន១លើក ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ចំនួន៩លើក ច្បាប់ស្តីពីការបង្ការនិងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ចំនួន៨លើក ច្បាប់ស្តីពីជលផល ចំនួន៣លើក ច្បាប់ភូមិបាល ចំនួន៩លើក ច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងអនុក្រឹត្យលេខ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ចំនួន១២លើក ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចំនួន២៩លើក ច្បាប់ស្តីពីផ្លូវគោក និងវិធីការពារជំងឺកូវីដ-១៩ ចំនួន៣៤លើក ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងវិធីការពារជំងឺកូវីដ-១៩ ចំនួន២៤លើក ច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ និងវិធីការពារជំងឺកូវីដ-១៩ ចំនួន២លើក ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន អំពើល្មើសច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា និងវិធីការពារជំងឺកូវីដ-១៩ ចំនួន១២លើក អនុក្រឹត្យស្តីពីការ

គ្រប់គ្រងដីរដ្ឋ ចំនួន៤លើក និងច្បាប់ភូមិបាល ច្បាប់ស្តីពីផលលផល និងអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ ចំនួន១លើក នៅរាជធានី ខេត្ត ចំនួន២២ ដោយមានអ្នកចូលរួម ចំនួន១២៩ ៣៤៣នាក់ (ស្ត្រីចំនួន៥៣ ១៤១នាក់) និងបានទទួលសំណួរ ចំនួន១២ ៦៧៧សំណួរ។

**២.៣.៣- ការងារទំនាក់ទំនងជាមួយរាជរដ្ឋាភិបាល**

បានចូលរួមប្រជុំអន្តរក្រសួងនៅទីស្តីការគណៈរដ្ឋមន្ត្រីអំពីសេចក្តីព្រាងព្រះរាជក្រឹត្យ ចំនួន៧លើក សេចក្តីព្រាងច្បាប់ ចំនួន៨៦លើក សេចក្តីព្រាងអនុក្រឹត្យ ចំនួន១០១លើក និងសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត ចំនួន៤៥លើក។

**២.៣.៤- ការងារទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា**

- បានចូលរួមស្តាប់សម័យប្រជុំពេញអង្គនិងសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា អំពីសេចក្តីស្នើច្បាប់ ចំនួន៣លើក សេចក្តីព្រាងច្បាប់ ចំនួន៩៨លើក ការបោះឆ្នោតជ្រើសតាំង ចំនួន១៦លើក របាយការណ៍របស់រដ្ឋសភា ចំនួន៥លើក ព្រះរាជសារ ចំនួន៦លើក ការអនុម័តបទបញ្ជាផ្ទៃក្នុងរដ្ឋសភានីតិកាលទី៦ ចំនួន១លើក ការបោះឆ្នោតផ្តល់សេចក្តីទុកចិត្តចំនួន៣លើក ការសម្រេចអំពីសុពលភាពចំនួន៥លើក និងបានចូលរួមអមដំណើរជាមួយគណៈកម្មការនានានៃរដ្ឋសភា ចំនួន៤លើក

- បានចូលរួមស្តាប់សម័យប្រជុំពេញអង្គនិងសម័យប្រជុំវិសាមញ្ញរបស់ព្រឹទ្ធសភា អំពីសេចក្តីស្នើច្បាប់ ចំនួន២លើក សេចក្តីព្រាងច្បាប់ ចំនួន១០៤លើក ការប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី ចំនួន៦លើក ការបោះឆ្នោតជ្រើសតាំង ចំនួន២លើក ការបោះឆ្នោតជ្រើសរើស ចំនួន៣លើក របាយការណ៍របស់ព្រឹទ្ធសភាចំនួន៣លើក បានចូលរួមអមដំណើរជាមួយគណៈកម្មការទី៦ ចំនួន១លើក និងបានចូលរួមអមដំណើរជាមួយគណៈកម្មការទី៨ ចំនួន១លើក។

**២.៣.៥- ការងារទំនាក់ទំនងជាមួយប្រជាពលរដ្ឋ**

បានចុះរៀបចំវេទិកាសាធារណៈដើម្បីទទួលសំណូមពរពីប្រជាពលរដ្ឋ ចំនួន២៨លើក(អគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា ចំនួន២៨លើក ក្នុងនោះឆ្នាំ២០១៨ ចំនួន១០លើក ឆ្នាំ២០១៩ ចំនួន១០លើក ឆ្នាំ២០២១ ចំនួន៤លើក ឆ្នាំ២០២២ចំនួន៤លើក) គឺនៅខេត្ត ចំនួន១០ ដោយមានអ្នកចូលរួម ចំនួន៥ ៨២៩នាក់(ស្ត្រី២ ៣០០នាក់) និងបានទទួលសំណូមពរពីប្រជាពលរដ្ឋ ចំនួន៨៦៦សំណូមពរ។

## ២.៤- សកម្មភាពការងារអធិការកិច្ច

**ការងារអធិការកិច្ច(លើវិស័យសេដ្ឋកិច្ច រដ្ឋបាលទូទៅ និងសង្គមកិច្ច)**

- បានចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០១៧-២០១៩ និងបណ្តាឆ្នាំពាក់ព័ន្ធនៅក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិចំនួន៣០ និង២៥មន្ទីររាជធានី ខេត្ត ស្មើនឹងចំនួន១ ៩៧៦មន្ទីរ អង្គភាព

- បានចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងការអនុវត្តតួនាទីភារកិច្ច ការផ្តល់សេវាសាធារណៈ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងការិយបរិច្ឆេទ២០២០-២០២១ និងបណ្តាឆ្នាំពាក់ព័ន្ធនៅក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិចំនួន១៣ និង២៥មន្ទីររាជធានី ខេត្ត ស្មើនឹងចំនួន២៩៨មន្ទីរ អង្គភាព

- បានធ្វើលិខិតជូនដំណឹងស្តីពីការជំរុញការកែលម្អចំណុចខ្វះខាតទៅក្រសួង ស្ថាប័នរងអធិការកិច្ច ចំនួន២៩៨ច្បាប់

- បានទទួលរបាយការណ៍ជូនជ្រាបពីតាមបណ្តាក្រសួង ស្ថាប័នចំនួន៣០ និងពីមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការរាជធានី ខេត្ត សរុបរួមស្មើនឹងចំនួនសរុប៧១៥លើក។

**២.៥- សកម្មភាពការងារវិទ្យាស្ថានជាតិអធិការកិច្ច**

- បានរៀបចំពង្រឹងការគ្រប់គ្រងរដ្ឋបាល និងចរន្តការងារទូទៅរបស់វិទ្យាស្ថាន
- បានរៀបចំលើកផ្លាកសញ្ញាវិទ្យាស្ថាន និងបំពាក់ឧបករណ៍មូលដ្ឋាននៅសាលសិក្សា
- បានរៀបចំស៊ីញ(និមិត្តសញ្ញាវិទ្យាស្ថាន) និងស្លាកឈ្មោះសម្រាប់មន្ត្រីរាជការវិទ្យាស្ថាន
- បានស្រាវជ្រាវ និងរៀបចំចងក្រងជាសៀវភៅស្តីពីរបៀបប្រើប្រាស់កម្មវិធីZoom និងGoogle Meet
- បានរៀបចំបង្កើតក្រុមគ្រូបង្គោលជំនាញវិជ្ជាជីវៈអធិការកិច្ចចំនួន៩រូប សម្រាប់វិទ្យាស្ថាន
- បានរៀបចំបង្កើតក្រុមស្រាវជ្រាវ ចងក្រងអនុសាសន៍របស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី**
- រៀបចំផែនការថវិកា និងផែនការសកម្មភាពឆ្នាំ២០២០ ឆ្នាំ២០២១ និងឆ្នាំ២០២២ របស់វិទ្យាស្ថាន
- រៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ និងឆ្នាំ២០២២-២០២៤ របស់វិទ្យាស្ថាន
- បានរៀបចំកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈអធិការកិច្ចឆ្នាំ២០២១ និងឆ្នាំ២០២២ របស់វិទ្យាស្ថាន
- បានរៀបចំសេចក្តីព្រាងទម្រង់ចុះឈ្មោះចូលរៀនតាមប្រព័ន្ធអនឡាញ(Online)
- បានរៀបចំបញ្ជីឈ្មោះអង្គការ និងស្ថានទូតប្រចាំនៅក្នុងប្រទេសកម្ពុជា ដើម្បីទំនាក់ទំនងស្នើសុំកិច្ចសហប្រតិបត្តិការ
- បានរៀបចំលិខិតទំនាក់ទំនងស្ថានទូតកូរ៉េ អូស្ត្រាលី ឥណ្ឌា សិង្ហបុរី អាល្លឺម៉ង់ ប្រចាំនៅកម្ពុជា និងអង្គការUNDP, Konrad Adenauer Stiftung, The Asia Foundation, Asian Development Bank
- បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ចបឋម ជូនមន្ត្រីរាជការ ចំនួន១៤វគ្គ ដោយមានសិក្ខាកាមចំនួន៤៨២រូប(ស្ត្រីចំនួន១៣៧រូប)
- បានចុះសិក្សាស្រាវជ្រាវអំពីតម្រូវការនៃការបណ្តុះបណ្តាលក្នុងវិស័យអធិការកិច្ច នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ចំនួន២០ខេត្ត
- បានចុះសិក្សាស្រាវជ្រាវអំពីការគ្រប់គ្រង និងការអភិវឌ្ឍការងារអធិការកិច្ច នៅមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ចំនួន២៤ខេត្ត
- បានរៀបចំធ្វើសម្រង់ស្ទង់មតិយោបល់សិក្ខាកាមចំនួន២លើក អំពីការវាយតម្លៃវគ្គបណ្តុះបណ្តាល និងគ្រូឧទ្ទេស
- បានចុះស្រាវជ្រាវស្ទង់មតិស្តីពីវឌ្ឍនភាពការងារមន្ត្រីរាជការដែលបានទទួលការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈអធិការកិច្ច នៅតាមមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច នៅតាមបណ្តាខេត្ត ចំនួន៦ខេត្ត
- បានសហការជាមួយអង្គការមូលនិធិអាស៊ី និងក្រុមហ៊ុនប្រឹក្សាយោបល់ CPS ផ្តល់ការបណ្តុះបណ្តាលស្តីពីការកសាងសមត្ថភាពស្រាវជ្រាវជូនមន្ត្រីរាជការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច ចំនួន២០រូប (ស្ត្រីចំនួន៤រូប)

- បានជួបពិភាក្សាការងារជាមួយលោក MANOJ KUMAR PUJARI លេខាទី២ នៃស្ថានទូតឥណ្ឌាប្រចាំនៅកម្ពុជា ដើម្បីស្នើសុំសហប្រតិបត្តិការ និងការគាំទ្រដល់វិទ្យាស្ថានជាតិអធិការកិច្ច

- បានទំនាក់ទំនង និងទទួលបានសៀវភៅ ចំនួន៨៩៦ក្បាលពីភាគីពាក់ព័ន្ធ និងបោះពុម្ពសៀវភៅចំនួន ៣២ក្បាល ដាក់ក្នុងបណ្ណាល័យវិទ្យាស្ថាន

- បានស្រាវជ្រាវ ចងក្រងអនុសាសន៍របស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី**សរុប ចំនួន១០៤ច្បាប់ និងស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តនានាសរុប ចំនួន២ ១២១ច្បាប់ រួមទាំងធ្វើសៀវភៅ ចំនួន១០៥ក្បាល។

**ទី៣- ការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ**

**១- ការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ**( គេហទំព័រ www.interior.gov.kh )

ក្នុងរយៈពេល៥ឆ្នាំនេះ ការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការបានយកចិត្តទុកដាក់ជាសំខាន់ទៅលើអភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយផ្តោតលើសកម្មភាពអាទិភាព រួមមាន ១- ការពង្រឹងការគ្រប់គ្រងការងារកំណែទម្រង់ ២- ការពង្រឹងនិងការកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ៣- ការលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ៤- ការជំរុញការផ្ទេរមុខងារក្នុងវិស័យអាទិភាពនានាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយភ្ជាប់ជាមួយនឹងធនធានហិរញ្ញវត្ថុនិងធនធានមនុស្សដើម្បីលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន និង ៥- ការធ្វើវិមជ្ឈការហិរញ្ញវត្ថុ។

**១.១- ការដឹកនាំនិងការសម្របសម្រួលការងារកំណែទម្រង់**

វឌ្ឍនភាពសំខាន់ៗពាក់ព័ន្ធនឹងការដឹកនាំនិងការសម្របសម្រួលការងារកំណែទម្រង់មានជាអាទិ៍៖ ការរៀបចំបង្កើតនិងការប្រព្រឹត្តទៅនៃគណៈកម្មការដឹកនាំការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ នៅតាមក្រសួងពាក់ព័ន្ធនិងនៅតាមរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ការដឹកនាំសម្របសម្រួលនិងការគាំទ្រដល់ការរៀបចំនិងការអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់គ.ជ.អ.ប. ការសម្របសម្រួលកិច្ចសហការជាមួយដៃគូអភិវឌ្ឍនិងអង្គការសង្គមស៊ីវិលក្នុងការកៀរគរការគាំទ្រ និងការចូលរួមចំណែកលើការរៀបចំនិងអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិតាមរយៈការចូលរួមដោយផ្ទាល់ និងការរៀបចំគម្រោង កម្មវិធីដាច់ដោយឡែកៗនានា ចំនួនប្រមាណ១០គម្រោង/កម្មវិធី និងថវិកាសរុបប្រមាណពី ៤០លានដុល្លារអាម៉េរិក ទៅ៥០លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំៗការរៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ រយៈពេល១០ឆ្នាំ( ២០២១-២០៣០ ) និងការរៀបចំនិងការដាក់ឱ្យអនុវត្តផែនការអនុវត្តរយៈពេល៥ឆ្នាំ ដំណាក់កាលទី១( ឆ្នាំ២០២១-២០២៥ ) នៃកម្មវិធីជាតិដំណាក់កាលទី២នេះ ។

**១.២- រចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ**

ផ្អែកតាមច្បាប់រៀបចំអង្គការក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិជ្ឈការនិងវិសហមជ្ឈការ បានតម្រូវឱ្យមានការពិនិត្យនិងកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនិងគោលការណ៍នៃរដ្ឋបាលឯកភាពនៅគ្រប់កម្រិត និងប្រភេទនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ពាក់ព័ន្ធនឹងកិច្ចការនេះនាពេលកន្លងមក រចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅគ្រប់កម្រិតត្រូវបានពិនិត្យនិងកែសម្រួលឱ្យស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្នុងនោះរួមមានការបង្កើតក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗតាមរយៈការបោះឆ្នោតការ

រៀបចំនិងដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធគ្រប់គ្រង ប្រព័ន្ធកសាងផែនការ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ នីតិវិធីអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗដែលជានាដល់ការលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌សង្គម។ វឌ្ឍនភាពសំខាន់ៗពាក់ព័ន្ធនឹងការរៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអាណត្តិទី៦ របស់រាជរដ្ឋាភិបាលនេះ រួមមាន៖

- បានកែសម្រួលរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ដោយធ្វើសមាហរណកម្មមន្ទីរសុខាភិបាល មន្ទីរពេទ្យ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ មណ្ឌលសុខភាព និងមណ្ឌលថែទាំកុមារដែលជាអង្គភាពខ្សែបណ្តោយរបស់ក្រសួងសុខាភិបាល ចូលទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រង របស់រដ្ឋបាលរាជធានី ខេត្តនៅទូទាំងប្រទេស

- បានកែសម្រួលរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយធ្វើសមាហរណកម្មការិយាល័យជំនាញនានារបស់ក្រសួង ស្ថាប័ននៅថ្នាក់ក្រុង ស្រុក ខណ្ឌចូលទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីធានាឱ្យរដ្ឋបាលទាំងនេះមានប្រព័ន្ធគ្រប់គ្រងស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដែលធានាដល់ការដឹកនាំសម្របសម្រួលលើការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។

## ១.៣- ការផ្ទេរមុខងារ និងការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

- ការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកិច្ចការដ៏មានសារៈសំខាន់និងជាអាទិភាពនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការដែលត្រូវរៀបចំនិងអនុវត្តជាជំហានៗតាមដំណាក់កាលនីមួយៗជាបន្តបន្ទាប់ក្នុងគោលបំណងបង្វិតការធ្វើសេចក្តីសម្រេចចិត្តលើការផ្តល់សេវាសាធារណៈឱ្យទៅកៀកជិតប្រជាពលរដ្ឋ ដើម្បីធានាដល់ការឆ្លើយតបនឹងតម្រូវការជាក់ស្តែងនិងមានលក្ខណៈដោយឡែកៗពីគ្នានៅតាមមូលដ្ឋាននីមួយៗ បានទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាបន្ន និងសមធម៌។ វឌ្ឍនភាពសំខាន់ៗពាក់ព័ន្ធនឹងការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងអាណត្តិទី៦ របស់រាជរដ្ឋាភិបាលនេះ រួមមាន៖

- មុខងារចំនួន៥៥ ក្នុងវិស័យចំនួន២០ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅទូទាំងប្រទេស ដែលមុខងារទាំងនេះពាក់ព័ន្ធទៅនឹងជីវភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋជាអាទិ៍ មុខងារក្នុងវិស័យ អប់រំ កសិកម្ម អនាម័យ បរិស្ថាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តខ្នាតតូចដូចជាផ្លូវជនបទ ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត អគ្គិសនី ប្រព័ន្ធធារាសាស្ត្រ សាលារៀនជាដើម

- មុខងារក្នុងវិស័យសុខាភិបាលដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការផ្តល់សេវាព្យាបាលនិងថែទាំសុខភាពសាធារណៈ និងមុខងារក្នុងការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋក្នុងវិស័យសង្គមកិច្ចត្រូវបានផ្ទេរទៅស្ថិតក្រោមការគ្រប់គ្រងនិងការទទួលខុសត្រូវដោយផ្ទាល់របស់រដ្ឋបាលរាជធានី ខេត្តនៅទូទាំងប្រទេស

- យន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានបន្តពង្រឹងនិងពង្រីកឱ្យដំណើរការយ៉ាងសកម្មនៅទូទាំងប្រទេស ដោយបានបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋមកទទួលសេវារដ្ឋបាលចាំបាច់នានាដែលរួមមានសេវារដ្ឋបាលប្រមាណជាង៨០០ប្រភេទ

- ការិយាល័យប្រជាពលរដ្ឋក៏ត្រូវបានពង្រឹងនិងពង្រីកឱ្យមានដំណើរការនៅតាមរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស។ ការិយាល័យប្រជាពលរដ្ឋនេះ ដើរតួនាទីជាយន្តការអព្យាក្រឹតមួយក្នុងការ

ប្រមូលទទួលនិងសម្រុះសម្រួលបណ្ដឹងតវ៉ានានារបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការបំពេញការងារ និងការផ្ដល់សេវានានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់គុណភាពនៃការផ្ដល់សេវាសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានប្រសិទ្ធភាពនិងគណនេយ្យភាព

- ការងារគណនេយ្យភាពសង្គមក៏ត្រូវបានបន្តនិងអនុវត្តនៅតាមរដ្ឋបាលឃុំ សង្កាត់ចំនួន១ ៤០០ នៅក្នុង១៧០ក្រុង ស្រុក។ ការអនុវត្តការងារគណនេយ្យភាពសង្គមនេះ គឺក្នុងគោលបំណងបង្កលក្ខណៈងាយស្រួលជូនប្រជាពលរដ្ឋឱ្យទទួលបាននូវព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងការប្រើប្រាស់ថវិការបស់រដ្ឋបាលឃុំ សង្កាត់បែបបទនិងនីតិវិធីនៃការផ្ដល់សេវានៅតាមសាលារៀននិងមណ្ឌលសុខភាព ព្រមទាំងជំរុញឱ្យប្រជាពលរដ្ឋចូលរួមតាមដាន ត្រួតពិនិត្យនិងផ្ដល់យោបល់កែលម្អលើការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់និងលើការផ្ដល់សេវានៅតាមសាលារៀននិងមណ្ឌលសុខភាពទាំងនោះផងដែរ

- ក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាអណត្តិទូទៅនិងមុខងារជាជម្រើសរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិបានសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចនិងអនុវត្តគម្រោងសេវាសង្គមប្រមាណជាង ២០០០គម្រោង ក្នុងមួយៗឆ្នាំដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងនៅតាមមូលដ្ឋានដែលជាការរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនិងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ

- មុខងារដែលបានផ្ទេរទាំងនេះ បានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានលទ្ធភាពនិងសមត្ថភាពក្នុងការផ្ដល់សេវាសាធារណៈចាំបាច់នានាជូនប្រជាពលរដ្ឋ ព្រមទាំងអាចដោះស្រាយបញ្ហាប្រឈមនានានៅតាមមូលដ្ឋានបានឆាប់រហ័សនិងទាន់ពេលវេលាជាពិសេសការគ្រប់គ្រងនិងការចាត់វិធានការទប់ស្កាត់ ថែទាំនិងព្យាបាលអ្នកជំងឺក្នុងស្ថានភាពនៃការរីករាលជំងឺកូវីដ-១៩ ក្នុងរយៈពេលជិតបីឆ្នាំកន្លងមកនេះនិងការជួយសង្គ្រោះប្រជាពលរដ្ឋដែលទទួលរងគ្រោះដោយគ្រោះធម្មជាតិ ដូចជាគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួតជាដើម ។

## ១.៤- ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- ក្នុងក្របខ័ណ្ឌនៃកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ រាជរដ្ឋាភិបាលបានរៀបចំនិងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់នូវប្រព័ន្ធគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលធានាដល់ការផ្ដល់សិទ្ធិអំណាចនិងការទទួលខុសត្រូវកាន់តែច្រើនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែងនិងប្រើប្រាស់បុគ្គលិករបស់ខ្លួនតាំងពីដំណាក់កាលនៃការប្រឡងជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ ការផ្លាស់ប្ដូរ ការដាក់ពិន័យ ការបណ្ដេញចេញនិងការដាក់ឱ្យចូលនិវត្តន៍។ វឌ្ឍនភាពសំខាន់ៗពាក់ព័ន្ធនឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងអាណត្តិទី៦របស់រាជរដ្ឋាភិបាលនេះ រួមមាន ៖

- ផ្អែកតាមការវិវឌ្ឍនៃការផ្ទេរមុខងារពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានសម្រេចផ្ទេរបុគ្គលិកចំនួនប្រមាណជាង៤០ ០០០នាក់ ឱ្យស្ថិតក្រោមការគ្រប់គ្រងនិងចាត់ចែងដោយផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះបុគ្គលិកក្របខ័ណ្ឌក្រសួងមហាផ្ទៃចំនួនជាង៧ ០០០នាក់ បុគ្គលិកក្របខ័ណ្ឌសុខាភិបាលចំនួនជាង២០ ០០០នាក់ បុគ្គលិកក្របខ័ណ្ឌអប់រំចំនួនប្រមាណជាង៦ ០០០នាក់ និងបុគ្គលក្របខ័ណ្ឌជំនាញបច្ចេកទេសពីក្រសួង ស្ថាប័នតាមវិស័យនានាចំនួនប្រមាណជិត១០ ០០០នាក់។

- ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវបានពង្រឹងជាប្រចាំអំពីក្របខ័ណ្ឌច្បាប់លិខិតបទដ្ឋានគតិយុត្ត និងអំពីក្របខ័ណ្ឌនៃការអនុវត្តការងារ តាមរយៈការរៀបចំវគ្គបណ្ដុះបណ្ដាលរយៈពេលខ្លីៗ

ជាបន្តបន្ទាប់ដល់សមាជិកក្រុមប្រឹក្សា និងបុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនេះ សាលាជាតិរដ្ឋបាលមូលដ្ឋាន ក៏ត្រូវបានបង្កើតនិងដាក់ឱ្យដំណើរការដើម្បីផ្តល់សេវាអភិវឌ្ឍសមត្ថភាពជាលក្ខណៈអចិន្ត្រៃយ៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ។

## ១.៥- ការធ្វើវិមជ្ឈការហិរញ្ញវត្ថុ និងផែនការរដ្ឋបាលថ្នាក់ក្រោមជាតិ

១- ការធ្វើវិមជ្ឈការហិរញ្ញវត្ថុក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ នាពេលកន្លងមក រាជរដ្ឋាភិបាលបានបង្កើតនិងដាក់ឱ្យប្រតិបត្តិការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានដូចជាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋបាលក្រុង ស្រុក និងការបង្កើតប្រភពចំណូលនានារបស់រដ្ឋបាលរាជធានី ខេត្ត ព្រមទាំងប្រព័ន្ធរៀបចំនិងអនុវត្តថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង ចាត់ចែងនិងប្រើប្រាស់ធនធានហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាពនិងគណនេយ្យភាព។ ធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេល៥ឆ្នាំនេះ មានដូចខាងក្រោម៖

| រដ្ឋបាលថ្នាក់ក្រោមជាតិ | ធនធានហិរញ្ញវត្ថុ (គិតជាលានដុល្លារ) | | | | | |
|---|---|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
| រាជធានី ខេត្ត | ២៦៩ | ៣៦៥ | ៥៦៣ | ៥៤៤ | ៧០៦ | ២ ៤៤៧ |
| ក្រុង ស្រុក | ៤០ | ៤៩ | ៦១ | ១២១ | ១៤០ | ៤១១ |
| ឃុំ សង្កាត់ | ១០៧ | ១២៩ | ១៩៨ | ១៧៥ | ២០៩ | ៨១៨ |
| សរុប | ៤១៦ | ៥៤៣ | ៨២២ | ៨៤០ | ១.០៥៥ | ៣ ៦៧៦ |

២- ដំណើរការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំដាក់ឱ្យអនុវត្តនិងកែលម្អជាបណ្តើរៗ ដើម្បីធានាឱ្យមានលក្ខណៈសមស្របទៅនឹងចរិតលក្ខណៈផ្សេងៗគ្នានៃប្រភេទរដ្ឋបាលថ្នាក់ក្រោមជាតិផង ធ្វើឱ្យមានប្រសិទ្ធភាពក្នុងការបែងចែកនិងការប្រើប្រាស់ធនធានសាធារណៈផង ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការអាទិភាពផង សំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅមូលដ្ឋានស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ វឌ្ឍនភាពសំខាន់ៗពាក់ព័ន្ធនឹងប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកែលម្អនៅក្នុងអាណត្តិទី៦របស់រាជរដ្ឋាភិបាលនេះ រួមមាន ៖

- ការកែសម្រួលប្រក្រតិទិននៃការរៀបចំផែនការអភិវឌ្ឍរយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានសង្គតិភាពជាមួយប្រតិទិននៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងន័យធានាឱ្យការវិភាជន៍និងការប្រើប្រាស់ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

- ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យជាមូលដ្ឋានបម្រើឱ្យការវិភាគ ការកំណត់បញ្ហានិងការកំណត់តម្រូវការអភិវឌ្ឍតាមប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដើម្បីធានាដល់ការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានសុក្រឹតភាពក្នុងការឆ្លើយតបនឹងការដោះស្រាយបញ្ហារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ

- ការរៀបចំនិងដាក់ឱ្យអនុវត្តនូវឧបករណ៍នានាសម្រាប់វិភាគ និងការបញ្ជ្រាបតម្រូវការសមភាពយេនឌ័រ តម្រូវការរបស់ក្រុមជនងាយរងគ្រោះ តម្រូវការនៃភាពធន់ទៅនឹងបម្រែបម្រួលអាកាសធាតុនិងបញ្ហាសង្គមនានា

ទៅក្នុងប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ កាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយឆ្លើយតបទៅនឹងតម្រូវការ និងដោះស្រាយបញ្ហាប្រឈមនានាប្រកបដោយ បរិយាបន្ន សមធម៌សង្គម និងប្រកបដោយនិរន្តរភាព។

**១.៦- ការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

- **អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត៖** អង្គភាពនេះ ត្រូវបានដាក់ឱ្យដំណើរការនៅពាក់កណ្តាល ឆ្នាំ២០១៨ ។ គិតចាប់ពីពេលដាក់ឱ្យដំណើរការរហូតដល់ខែកញ្ញា ឆ្នាំ២០២២ អង្គភាពច្រកចេញចូលតែមួយ រាជធានី ខេត្តទាំង២៥ផ្តល់សេវាបាន**២ ២៧៨ ២៧១សេវា** លើ១៤វិស័យទទួលបានចំណូលសរុប**៣២២ ៧៩២ ៨៣៣ ៥២៥រៀល**

- **ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ៖** បច្ចុប្បន្នមានចំនួន២០៤ការិយាល័យ ក្នុងនោះ គិតពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២ ការិយាល័យទាំងនេះ ផ្តល់សេវាបាន**៨ ១១៦ ៣៣៩សេវា** លើ១៧ វិស័យទទួលបានចំណូលសរុប**៨២ ៦៨១ ៣៣២ ៤៩៨រៀល**

- ក្រសួងមហាផ្ទៃបានផ្តល់ការគាំទ្រដល់ការងាររបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅក្នុងការសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ានានារបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល សាធារណៈនិងការគ្រប់គ្រងរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ចាប់ពីឆ្នាំ២០១៨ ដល់ខែកក្កដា ឆ្នាំ២០២២ ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តទាំង២៥គោលដៅទទួលបានពាក្យបណ្តឹងនិងព័ត៌មានផ្សេងៗចំនួន៣ ៨៦១ករណី ក្នុងនោះ បណ្តឹងក្នុងសមត្ថកិច្ច២ ០២៥ករណី (ដោះស្រាយបាន១ ៩៣៨ករណី)បណ្តឹងក្រៅ សមត្ថកិច្ច៨៤២ករណីនិងព័ត៌មានផ្សេងៗ៩៩៤កេណី។ ដោយឡែក ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ១២០គោលដៅទទួលបានពាក្យបណ្តឹងនិងព័ត៌មានផ្សេងៗចំនួន៤៤ ៣០០ករណី ក្នុងនោះបណ្តឹងក្នុងសមត្ថ កិច្ច៩៣៩ករណី(ដោះស្រាយបាន៩៣៣ករណី) បណ្តឹងក្រៅសមត្ថកិច្ច៩៤២ករណីនិងព័ត៌មានផ្សេងៗ ៤២ ៤២២ករណី។

**១.៧- ការងារទីក្រុងឆ្លាតវៃ**

នៅឆ្នាំ២០១៨ រាជធានីភ្នំពេញ ខេត្តសៀមរាបនិងខេត្តបាត់ដំបង បានចូលរួមក្នុងបណ្តាញទីក្រុងឆ្លាត អាស៊ាន។ នៅឆ្នាំ២០២២ កម្ពុជាបានធ្វើជាប្រធានប្តូរវេនអាស៊ានហើយ ក្រសួងមហាផ្ទៃក៏បានធ្វើជាប្រធាន ដឹកនាំកិច្ចប្រជុំបណ្តាញទីក្រុងឆ្លាតអាស៊ានប្រកបដោយជោគជ័យ។ ទន្ទឹមនេះ ក៏បានបន្តសហការជាមួយ ប្រទេសសមាជិកអាស៊ានបណ្តាប្រទេសជាមិត្តមួយចំនួននិងអង្គការនានា ក្នុងការអនុវត្តការងារទីក្រុងឆ្លាតវៃនិង កំពុងតែរៀបចំផែនទីបង្ហាញផ្លូវស្តីពីទីក្រុងឆ្លាតវៃ ដើម្បីជួយតម្រង់ទិសក្នុងការអនុវត្តសកម្មភាពការងារទីក្រុង ឆ្លាតវៃនៅកម្ពុជាផងដែរ។

**១.៨- ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន១ ខេត្ត២៤ ក្រុង៣១ ស្រុក១៦៣ ខណ្ឌ១៤ ឃុំ ១ ៣៨៥ សង្កាត់២៦៧ និងភូមិចំនួន១៤ ៥៤៥ ។ កត់សម្គាល់៖ ដោយផ្អែកលើស្ថានភាពភូមិសាស្ត្រនិងប្រជា សាស្ត្រក៏ដូចជាដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងឆ្លើយតបទៅនឹង តម្រូវការនៃការផ្តល់សេវាសាធារណៈនិងការអភិវឌ្ឍមូលដ្ឋាននៅក្នុងរយៈពេល៥ឆ្នាំនេះ រាជរដ្ឋាភិបាលបាន

សម្រេចបង្កើតក្រុងថ្មីចំនួន២ ស្រុកចំនួន៣ ខណ្ឌចំនួន២ បង្កើតសង្កាត់ថ្មីចំនួន២ បង្កើតឃុំថ្មី ចំនួន៤ ព្រមទាំងកែសម្រួលព្រំប្រទល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និងឃុំ ចំនួន៥លើក។ ទន្ទឹមនេះ ក្រសួងមហាផ្ទៃ ក៏បានសម្រេចបង្កើតភូមិថ្មីចំនួន៧៥ និងលុបចោលភូមិចំនួន៨ផងដែរ។ ចំពោះក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិដែលទើបបង្កើតថ្មីខាងលើត្រូវបានរៀបចំរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រង ផ្អែកតាមគោលការណ៍នៃច្បាប់រៀបចំអង្គការដើម្បីដំណើរការការងារ សំដៅធានានូវនិរន្តរភាពនិងប្រក្រតីភាពនៃការងាររដ្ឋបាល ការផ្ដល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាននិងការរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ។

រដ្ឋបាលគ្រប់ថ្នាក់នៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានពង្រឹងស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនិងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្ដល់សេវាសាធារណៈ ការអភិវឌ្ឍមូលដ្ឋាន ការរក្សាសន្តិសុខ សណ្ដាប់ធ្នាប់សង្គម ការសម្របសម្រួលដោះស្រាយបញ្ហាប្រឈមនិងវិវាទនានានៅមូលដ្ឋាន។ ដើម្បីចូលរួមគាំទ្រដល់ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ឆ្នាំ២០២២ កន្លងទៅ ក្រសួងមហាផ្ទៃបានសហការជាមួយគ.ជ.ប ដាក់ចេញនូវបែបបទនិងនីតិវិធីមួយចំនួនស្របតាមច្បាប់បោះឆ្នោត និងបទបញ្ជា នីតិវិធីនៃការបោះឆ្នោត ព្រមទាំងបានរៀបចំនូវលិខិតបទដ្ឋាននានា ដើម្បីគាំទ្រដល់ដំណើរការនៃការចូលកាន់តំណែងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីអាណត្តិទី៥នៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេសប្រព្រឹត្តទៅដោយរលូន។

## ២- ការពង្រឹងវិស័យយុត្តិធម៌និងនីតិរដ្ឋ

### ២.១- ការពង្រឹងវិស័យយុត្តិធម៌

ក្រសួងយុត្តិធម៌ សម្រេចការងារដូចខាងក្រោម៖ ( ផេក : Ministry of Justice គេហទំព័រ www.moj.gov.kh )

#### ក- ការផ្ដល់សេវាសាធារណៈលើលិខិតថ្កោលទោស

**ក.១- លទ្ធផលទទួលបានក្នុងការចាត់ការ សាលក្រម សាលដីកា**

- សាលក្រម សាលដីកាទទួលបាន**៣៦ ៩៨០ច្បាប់**
- សាលក្រម សាលដីកាចាត់ការរួច**២៩ ៩៦០ច្បាប់**។

**ក.២- អំពីការទទួលពាក្យសុំ និងចេញព្រឹត្តិបត្រថ្កោលទោស**

| ឆ្នាំ | ទទួលបានពាក្យសុំ ព្រឹត្តិបត្រថ្កោលទោស | ព្រឹត្តិបត្រថ្កោលទោស ចាត់ការរួច | ទឹកប្រាក់ទទួលបាន |
|---|---|---|---|
| ២០១៨ | ៤៥ ៣១៩ ច្បាប់ | ៤២ ៧៩៦ ច្បាប់ | ២ ២៧៣ ៤៥០ ០០០ រៀល |
| ២០១៩ | ៤៨ ៦៧៦ ច្បាប់ | ៤៥ ៩០០ ច្បាប់ | ២ ៤៨២ ០៩០ ០០០ រៀល |
| ២០២០ | ៤២ ៣៥៩ ច្បាប់ | ៣៩ ៨៣៩ ច្បាប់ | ២ ២៤០ ០០០ ០០០ រៀល |
| ២០២១ | ៣៥ ០១៥ ច្បាប់ | ១៤ ៤៧៧ ច្បាប់ | ២ ១៥៦ ០០០ ០០០ រៀល |
| ២០២២ ( គិតត្រឹមខែសីហា ) | ៣៥ ៣២៥ ច្បាប់ | ៣៤ ២៦៧ ច្បាប់ | ២ ១៥៦ ០០០ ០០០ រៀល |
| **សរុប** | **២០៦ ៦៩៤ ច្បាប់** | **១៧៧ ២៧៩ ច្បាប់** | **១១ ៤៦២ ៣២០ ០០០ រៀល** |

## ខ- ការងាររដ្ឋបាលសាលាជម្រះក្តី និងអភិវឌ្ឍន៍វិស័យយុត្តិធម៌

ក្នុងការងារគ្រប់គ្រងសំណុំរឿង ក្រសួងបានបង្កើតឱ្យមានប្រព័ន្ធចុះបញ្ជី ប្រព័ន្ធតម្កល់ និងការគ្រប់គ្រងសំណុំរឿង ដល់សាលាដំបូងរាជធានី ខេត្ត តាមប្រព័ន្ធព័ត៌មានវិទ្យា ក្នុងគោលបំណងធ្វើឱ្យការគ្រប់គ្រងរដ្ឋបាលនៅតាមសាលាដំបូងកាន់តែមានប្រសិទ្ធភាព សុវត្ថិភាព និងរហ័សទាន់ចិត្ត។

ក្នុងគោលបំណងបង្កិតសិទ្ធិទទួលបានយុត្តិធម៌ឱ្យកាន់តែខិតទៅជិតប្រជាពលរដ្ឋមូលដ្ឋានតំបន់ឆ្ងាយៗ សំដៅឱ្យចំណេញពេលវេលា ថវិកា មធ្យោបាយធ្វើដំណើរ និងការហូបចុក ស្នាក់នៅរបស់ប្រជាពលរដ្ឋក្នុងការដោះស្រាយរឿងក្តី ក្រសួងយុត្តិធម៌បានបង្កើតសាលាឧទ្ធរណ៍តំបន់ចំនួន៣ គឺសាលាឧទ្ធរណ៍ត្បូងឃ្មុំ សាលាឧទ្ធរណ៍បាត់ដំបង និងសាលាឧទ្ធរណ៍ព្រះសីហនុ។ បន្ថែមពីនេះ ក្រសួងយុត្តិធម៌ក៏បានបង្កើតលេខាធិការដ្ឋាននៅតាមសាលាជម្រះក្តីជាន់ទាបទូទាំងប្រទេស និងអគ្គលេខាធិការដ្ឋាននៅតាមសាលាជម្រះក្តីជាន់ខ្ពស់ សម្រាប់គ្រប់គ្រងការងាររដ្ឋបាល។

## គ- ការងារអធិការកិច្ច

ចាប់តាំងពីឆ្នាំ២០១៨ ដល់ឆមាសទី២ឆ្នាំ២០២២ ក្រសួងយុត្តិធម៌បានទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋសរុប **៦៧៨ករណី** បានចាត់ការរួចរាល់លើពាក្យបណ្តឹងសរុបចំនួន១៤២ និងកំពុងចាត់ការចំនួន៥៣៦ករណី។ សម្រាប់ការងារដោះស្រាយរឿងក្តីរបស់សាលាជម្រះក្តីទូទាំងប្រទេស ការចុះធ្វើអធិការកិច្ចតាមបណ្តឹងតវ៉ាពីរូបវន្តបុគ្គលឬនីតិបុគ្គល មានចំនួនសរុប៤៧លើក ដែលគិតជាករណីមានចំនួនសរុប៤៨ករណី។

ការចុះធ្វើអធិការកិច្ចជាប្រចាំលើការប្រព្រឹត្តទៅរបស់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់មានចំនួន២៧លើក និងការចុះស្រាវជ្រាវប្រមូលព័ត៌មានអំពីស្ថានភាពនៃការអនុវត្តច្បាប់ នៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់១៩លើក។ ការអញ្ជើញមន្ត្រីតុលាការ មេធាវី និងម្ចាស់បណ្តឹងមកបំភ្លឺ មានចំនួនសរុប៤៧លើក គិតជាករណីចំនួន៤៨ករណី ដែលធ្វើការសាកសួរសរុបចំនួន៥២នាក់ និងបានស្នើឱ្យមន្ត្រីតុលាការចំនួន៩២រូប ធ្វើរបាយការណ៍បំភ្លឺលើសំណុំរឿងសរុបចំនួន៨០ករណី។

## ២.២- រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានតួនាទីនិងបេសកកម្មចម្បងរួមមាន រៀបចំការប្រឡងប្រជែងជ្រើសរើសសិស្ស ធ្វើការបណ្តុះបណ្តាលបឋម និងបណ្តុះបណ្តាលបន្ត វិក្រឹតការ និងសុក្រឹតការ ដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា និងសារការី។

គិតចាប់ពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២នេះ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ បានបំពេញតួនាទីភារកិច្ច ស្របតាមផែនការសកម្មភាពរបស់ខ្លួន ដែលក្នុងនោះ សម្រេចបាននូវសមិទ្ធផលដូចខាងក្រោម៖

ស្ថិតិសិស្សវិជ្ជាជីវៈតុលាការ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ចាប់ពីឆ្នាំ២០១៨ រហូតមកដល់បច្ចុប្បន្ន

### ក- សាលាភូមិន្ទចៅក្រម

| ល.រ | ការបណ្តុះបណ្តាល | | ចំនួនសិស្សសរុប | ចៅក្រមអាសនៈ | ចៅក្រមអយ្យការ |
|---|---|---|---|---|---|
| | បរិយាយ | កាលបរិច្ឆេទបណ្តុះបណ្តាល | | | |
| ១ | សិស្សចៅក្រម ជំនាន់ទី៧ | ២៦ មេសា ២០១៦ ដល់១ មេសា ២០១៩ | ៥៤នាក់ (ស្រី ១១នាក់) | ៣៩នាក់ (ស្រី ៩នាក់) | ១៥នាក់ (ស្រី ២នាក់) |
| ២ | សិស្សចៅក្រម ជំនាន់ទី៨ | ៤ ធ្នូ ២០១៧ ដល់៨ កញ្ញា ២០២០ | ៥៥ នាក់ (ស្រី ១២នាក់) | ៣០នាក់ (ស្រី ៩នាក់) | ២៥នាក់ (ស្រី ៣នាក់) |

| | | | | | |
|---|---|---|---|---|---|
| ៣ | សិស្សចៅក្រម ជំនាន់ទី៩ | ១១ មករា ២០១៩ ដល់២៤ ឧសភា ២០២២ | ៥៦នាក់ (ស្រី ១៣ នាក់) | ៤០នាក់ (ស្រី១១នាក់) | ១៦នាក់ (ស្រី ២នាក់) |
| ៤ | សិស្សចៅក្រមផ្ទៃក្នុង | ១៩ មេសា ២០១៩ ដល់២៤ ឧសភា ២០២២ | ៣២នាក់ (ស្រី ៥នាក់) | ០នាក់ (ស្រី ០នាក់) | ៣២នាក់ (ស្រី ៥នាក់) |
| ៥ | សិស្សចៅក្រម ជំនាន់ទី១០ | ១៥ មករា ២០២០ ដល់ បច្ចុប្បន្ន | ៥៥នាក់ (ស្រី ១០នាក់) | ៣៥នាក់ (ស្រី ៤នាក់) | ២០នាក់ (ស្រី ៦នាក់) |
| ៦ | សិស្សចៅក្រម ជំនាន់ទី១១ | ១ កុម្ភៈ ២០២២ ដល់ បច្ចុប្បន្ន | ៥៦នាក់ (ស្រី ១២នាក់) | មិនទាន់បែងចែក | មិនទាន់បែងចែក |
| ៧ | សិស្សចៅក្រមផ្ទៃក្នុង ជំនាន់ទី២ | ១១ ឧសភា ២០២២ ដល់ បច្ចុប្បន្ន | ១៥នាក់ (ស្រី ៥នាក់) | មិនទាន់បែងចែក | មិនទាន់បែងចែក |
| **សរុប** | | | **៣២៣** នាក់ (ស្រី**៦៨** នាក់) | **១៤៤**នាក់ (ស្រី**៣៣**នាក់) | **១០៨**នាក់ (ស្រី**១៨**នាក់) |

## ខ- សាលាភូមិន្ទក្រឡាបញ្ជី

| ល.រ | ការបណ្តុះបណ្តាល | | ចំនួនសិស្ស |
|---|---|---|---|
| | បរិយាយ | កាលបរិច្ឆេទបណ្តុះបណ្តាល | |
| ១ | សិស្សក្រឡាបញ្ជី ជំនាន់ទី៥ | ២៦ កក្កដា ២០១៧ ដល់៧ មីនា ២០១៩ | ១១១នាក់(ស្រី២៦នាក់) |
| ២ | សិស្សក្រឡាបញ្ជី ជំនាន់ទី៦ | ១២ កុម្ភៈ ២០១៩ ដល់១៥ មិថុនា ២០២០ | ៩៩នាក់(ស្រី៣៧នាក់) |
| ៣ | សិស្សក្រឡាបញ្ជី ជំនាន់ទី៧ | ២០ កុម្ភៈ ២០២០ ដល់បច្ចុប្បន្ន | ១១៧នាក់(ស្រី៤៧នាក់) |
| ៤ | សិស្សក្រឡាបញ្ជី ជំនាន់ទី៨ | ២១ កុម្ភៈ ២០២២ ដល់បច្ចុប្បន្ន | ៩៨នាក់(ស្រី៤៥នាក់) |
| **សរុប** | | | **៤២៥នាក់(ស្រី១៥៥នាក់)** |

## គ- សាលាភូមិន្ទអាជ្ញាសាលា

| ល.រ | ការបណ្តុះបណ្តាល | | ចំនួនសិស្ស |
|---|---|---|---|
| | បរិយាយ | កាលបរិច្ឆេទបណ្តុះបណ្តាល | |
| ១ | សិស្សអាជ្ញាសាលា ជំនាន់ទី ២ | ១៨ មីនា ២០២២ ដល់បច្ចុប្បន្ន | ២៨នាក់(ស្រី៦នាក់) |

## ឃ- សាលាភូមិន្ទសារការី

| ល.រ | ការបណ្តុះបណ្តាល | | ចំនួនសិស្ស |
|---|---|---|---|
| | បរិយាយ | កាលបរិច្ឆេទបណ្តុះបណ្តាល | |
| ១ | សិស្សសារការី ជំនាន់ទី២ | ២៧ ធ្នូ ២០១៧ ដល់បច្ចុប្បន្ន | ២០នាក់(ស្រី៩នាក់) |
| ២ | សិស្សសារការី ជំនាន់ទី៣ | ១៨ មីនា ២០២២ ដល់បច្ចុប្បន្ន | ១៩នាក់(ស្រី៩នាក់) |

## ២.៣- គណៈមេធាវី

### ២.៣.១- មេធាវី

គិតមកដល់ខែកញ្ញា ឆ្នាំ២០២២ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានចុះឈ្មោះមេធាវីក្នុងបញ្ជីគណៈមេធាវី និងក្នុងបញ្ជីមេធាវីកម្មសិក្សាដូចខាងក្រោម៖

- មេធាវីពេញសិទ្ធិកំពុងប្រកបវិជ្ជាជីវៈមានចំនួន២ ១២៦រូប ក្នុងនោះ មេធាវីជាស្ត្រីមានចំនួន៥៣៣រូប
- មេធាវីពេញសិទ្ធិសុំមិនប្រកបវិជ្ជាជីវៈមេធាវីមានចំនួន១៥២រូប ក្នុងនោះ មេធាវីជាស្ត្រីមានចំនួន២៤រូប
- មេធាវីពេញសិទ្ធិសុំនៅក្រៅបញ្ជីមានចំនួន២២រូប ក្នុងនោះ មេធាវីជាស្ត្រីមានចំនួន៥រូប
- មេធាវីកំពុងធ្វើកម្មសិក្សាមានចំនួន២៩៨រូប ក្នុងនោះ មេធាវីកម្មសិក្សាជាស្ត្រីមានចំនួន៨២រូប។

### ២.៣.២- អំពីការបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី

ក្នុងរយៈពេល ៥ឆ្នាំនេះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានប្រឡងជ្រើសរើសសិស្សមេធាវីនិងធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីបានចំនួន៤ជំនាន់(ជំនាន់ទី១៥ដល់ជំនាន់ទី១៨) មានសិស្សមេធាវីសរុបចំនួន២៣៥រូប ក្នុងនោះ សិស្សមេធាវីជាស្ត្រីមានចំនួន៧៦រូប។

បន្ថែមពីនេះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការបណ្តុះបណ្តាលសុក្រឹតការដល់សិក្ខាកាមដែលសុំចូលប្រកបវិជ្ជាជីវៈមេធាវី តាមមាត្រា៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីបាន ចំនួន១២វគ្គ មានសិក្ខាកាមសរុបចំនួន១ ១០២រូប ក្នុងនោះមានសិក្ខាកាមជាស្ត្រីចំនួន២៩០រូប។

លើសពីនេះ ដើម្បីពង្រឹងសមត្ថភាពនិងជំនាញដល់មេធាវី គណៈមេធាវីតែងតែសហការជាមួយស្ថាប័នរដ្ឋនិងស្ថាប័ននៃវិជ្ជាជីវៈផ្សេងៗ រៀបចំសិក្ខាសាលាសម្រាប់ពង្រឹងសមត្ថភាពនិងជំនាញដល់មេធាវីបានជាច្រើនលើកក្នុងមួយឆ្នាំៗ។

### ២.៣.៣- អំពីការចូលរួមលើកកម្ពស់យុត្តិធម៌សង្គម

ដើម្បីចូលរួមលើកកម្ពស់យុត្តិធម៌សង្គម គណៈមេធាវីមានសកម្មភាពការងារ៣ជាចម្បង គឺការផ្សព្វផ្សាយច្បាប់ ការពិគ្រោះយោបល់ផ្លូវច្បាប់ដោយមិនយកកម្រៃ និងការចាត់តាំងមេធាវីជួយការពារក្តីជូនជនក្រីក្រដែលពុំមានលទ្ធភាពរកមេធាវីដោយមិនគិតកម្រៃ។ ដើម្បីជួយសម្រួលដល់ការចំណាយរបស់មេធាវីដែលបានស្ម័គ្រចិត្តចូលរួមពិគ្រោះយោបល់ផ្លូវច្បាប់ និងការពារក្តីជូនជនក្រីក្រ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានជួយឧបត្ថម្ភថវិកាជារៀងរាល់ឆ្នាំ តាមរយៈថវិកាប្រចាំឆ្នាំរបស់ក្រសួងយុត្តិធម៌ និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី។ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយលេខ០៩៨/សសគម/២១ ចុះថ្ងៃទី៥ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការពិគ្រោះយោបល់និងការពារក្តីជូនជនក្រីក្រដោយឥតគិតកម្រៃ ដើម្បីពង្រីកនិងពង្រឹងការផ្តល់ជំនួយផ្នែកច្បាប់ឱ្យកាន់តែមានប្រសិទ្ធភាព និងស្របតាមតម្រូវការជាក់ស្តែង។

### ២.៣.៤- ការផ្សព្វផ្សាយច្បាប់

ក្នុងរយៈពេល៥ឆ្នាំនេះ គណៈមេធាវីបានផ្សព្វផ្សាយច្បាប់តាមរយៈ៖

- វិទ្យុបានចំនួន៣៧លើក

- ទូរទស្សន៍បានចំនួន៤៩លើក
- បោះពុម្ពព្រឹត្តបត្រមេធាវីបានចំនួន៩ច្បាប់
- សិក្ខាសាលានានាបានចំនួន៤០លើក។

លើសពីនេះ ចាប់ពីខែតុលា ឆ្នាំ២០២០ ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើនការផ្សព្វផ្សាយច្បាប់ តាមរយៈការបង្កើតនូវកម្មវិធីថ្មីៗថែមទៀតរួមមាន៖

- កម្មវិធី៣សំណួរ(ថតនិងផ្សព្វផ្សាយបានចំនួន១៧ប្រធានបទ) ក្នុងគោលបំណងផ្សព្វផ្សាយច្បាប់ជូនសាធារណជន ដោយបានរៀបចំជាសំណួរពាក់ព័ន្ធនឹងច្បាប់ចំនួន៣សំណួរ ដែលជាសំណួរសាមញ្ញៗពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ ដោយឱ្យវាគ្មិនដែលជាមេធាវីមានចំណេះដឹងនិងបទពិសោធ ផ្តល់ចម្លើយខ្លីៗ សាមញ្ញៗ ហើយមានន័យគ្រប់គ្រាន់ ធ្វើយ៉ាងណាឱ្យសាធារណជនងាយយល់
- កម្មវិធីមេធាវីចុះដល់មូលដ្ឋាន ក្នុងគោលបំណងផ្សព្វផ្សាយអំពីវិជ្ជាជីវៈមេធាវី និងច្បាប់ដល់ថ្នាក់ដឹកនាំភូមិនិងក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលគម្រោងនេះបានរៀបចំគ្រូបណ្តុះបណ្តាលនិងសម្ភារៈសម្រាប់បណ្តុះបណ្តាលរួចរាល់ ហើយត្រូវចាប់ផ្តើមចុះអនុវត្តចាប់ពីខែមករា ឆ្នាំ២០២៣ ខាងមុខនេះ។

**២.៣.៥- ការពិគ្រោះយោបល់ផ្លូវច្បាប់ដោយមិនយកកម្រៃ**

ក្នុងរយៈពេល៥ឆ្នាំនេះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការពិគ្រោះយោបល់ផ្លូវច្បាប់ដោយមិនយកកម្រៃជូនដល់ជនក្រីក្រ កម្មករ កម្មការិនី និងសាធារណជនទូទៅ សរុបបានចំនួន ២ ៣៧៦ករណី។

**២.៣.៦- ការចាត់តាំងមេធាវីការពារក្តីជូនជនក្រីក្រ**

ក្នុងរយៈពេល៥ឆ្នាំនេះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានចាត់តាំងមេធាវីការពារក្តីដោយមិនយកកម្រៃ ជូនជនក្រីក្រ រួមទាំងអនីតិជននិងស្ត្រីនិងក្មេងស្រីក្រីក្រដែលជាជនរងគ្រោះក្នុងអំពើហិង្សាបានចំនួន ២៣ ៦៥៦ករណី មានកូនក្តីសរុប៣៦ ៦១០នាក់ ក្នុងនោះមានស្ត្រីចំនួន២ ៩២៩នាក់ និងអនីតិជនចំនួន ៩ ៤២៣នាក់។

ក្នុងរយៈពេល៥ឆ្នាំនេះ គណៈមេធាវីបានបង្កើតឱ្យមានការិយាល័យប្រតិភូគណៈមេធាវីប្រចាំគ្រប់រាជធានី ខេត្ត សាលាឧទ្ធរណ៍តំបន់ សាលាឧទ្ធរណ៍ភ្នំពេញនិងតុលាការកំពូល ដើម្បីបង្កិតសេវាពិគ្រោះយោបល់ផ្លូវច្បាប់និងចាត់តាំងមេធាវីជួយការពារក្តីជូនជនក្រីក្រដោយមិនយកកម្រៃនេះ ឱ្យកាន់តែខិតជិតប្រជាពលរដ្ឋនៅតាមមូលដ្ឋាន និងជួយសម្រួលដល់ការចាត់តាំងមេធាវីឱ្យបានឆាប់រហ័សនិងមានប្រសិទ្ធភាព។ លើសពីនេះ គណៈមេធាវីបានសហការជាមួយក្រសួងមហាផ្ទៃ សាងសង់បន្ទប់នៅគ្រប់ពន្ធនាគាររាជធានី ខេត្តសម្រាប់ទុកឱ្យមេធាវីចូលជួបពិគ្រោះយោបល់ជាមួយកូនក្តីដែលជាប់ឃុំដោយរក្សាបាននូវការសម្ងាត់វិជ្ជាជីវៈ។

## ២.៤- ការពង្រឹងនីតិរដ្ឋ

**ទីស្តីការគណៈរដ្ឋមន្ត្រី**(គេហទំព័រ https//www.ocm.gov.kh/)

### ១- ការងារចូលរួមកសាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត

ទីស្តីការគណៈរដ្ឋមន្ត្រី មានក្រុមប្រឹក្សាអ្នកច្បាប់ដែលមានភារកិច្ចពិនិត្យនិងកែសម្រួលរាល់សេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលក្រសួង ស្ថាប័ន បានស្នើសុំការពិនិត្យនិងសម្រេចពីរាជរដ្ឋាភិបាល និងមានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលមានភារកិច្ចវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ សិក្សាស្រាវជ្រាវបញ្ហាប្រឈមពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងប្រតិបត្តិការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA) របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

ក-  សេចក្តីព្រាងច្បាប់ត្រូវបានក្រុមប្រឹក្សាអ្នកច្បាប់បញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិអនុម័ត  និងព្រះរាជក្រម ដែលប្រកាសឱ្យប្រើច្បាប់

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| សេចក្តីព្រាងច្បាប់ត្រូវបានបញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិអនុម័ត(ច្បាប់) | ២០ | ៣០ | ៣៦ | ២១ | ១១ |
| ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ | ២១ | ២៤ | ៤១ | ២១ | ១០ |

✡ ច្បាប់ដែលរាជរដ្ឋាភិបាលបានក្រាបបង្គំទូលថ្វាយស្នើសូមព្រះករុណា ព្រះមហាក្សត្រទ្រង់ ព្រះរាជទាន ព្រះរាជក្រមប្រកាសឱ្យប្រើ បន្ទាប់ពីស្ថាប័ននីតិប្បញ្ញត្តិបានអនុម័តរួចចាប់ពីឆ្នាំ១៩៩៣ ដល់ខែវិច្ឆិកា ឆ្នាំ២០២២ សរុបមាន**៦១០ច្បាប់**។

✡ ទទួលសំណួរនិងសំណើពីសមាជិករដ្ឋសភា និងស្ថាប័នពាក់ព័ន្ធ៖

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| សំណួរ ចម្លើយ(ករណី) | ១៤ | ១៨ | ៥ | ១០ | ៥ |

### ខ- ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានធ្វើការវិភាគនិងរៀបចំដូចខាងក្រោម៖

តារាងទី១ : សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់

| ល.រ | សូចនាករ | មេគុណ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|---|
| | | | Æ | Æ | Æ | Æ | ៩ខែ |
| ០ | **គ្រប់មុខទំនិញ (២៥៩ មុខ)** | **១០០** | ១៧៤ | ១៧៧,៤ | ១៨២,៦ | ១៨៨ | ១៩៨,១ |
| | អត្រាអតិផរណាធៀបនឹងគ្រាមុន (%) | _ | **២,៥%** | **១,៩%** | **២,៩%** | **២,៩%** | **៥,៤%** |
| ១ | **ម្ហូបអាហារ និងភេសជ្ជៈមិនមែនជាតិស្រវឹង** | **៤៥** | ២១១,៨ | ២១៦,២ | ២២៦,២ | ២៣២,៤ | ២៤៣,៤ |
| | **០១.១. ម្ហូបអាហារ** | ៤៣ | ២១៤,២ | ២១៨,៧ | ២២៩,១ | ២៣៥,៥ | ២៤៦,៧ |
| | ០១.១.១.១ អង្ករ | ៦,២ | ២១៩,១ | ២២៦,៣ | ២៣៣,៥ | ២៣៥,៨ | ២៤០,៩ |
| | ០១.១.២.១ សាច់ជ្រូក | ៥,៦ | ២១២,៨ | ២០៩,៧ | ២២៦,៧ | ២៣៨,៦ | ២៤៧,៧ |
| | ០១.១.២.២ សាច់គោស្រស់ | ២,២ | ២៤៥,៧ | ២៥០,៤ | ២៥៩,២ | ២៦៤,៣ | ២៧៧,១ |
| | ០១.១.២.៤ សាច់មាន់ស្រស់ | ១,៣ | ២១២,២ | ២១៩ | ២២៣,៥ | ២២៦ | ២៣៤,៩ |
| | ០១.១.៣.១ ត្រីស្រស់ | ៧,៤ | ២១៥,៤ | ២២២,៦ | ២៤១,៣ | ២៥១,៦ | ២៦៣,១ |
| | ០១.១.៦ ផ្លែឈើ | ៤,៧ | ២១៧,៥ | ២២២,៦ | ២៣១,៨ | ២៣៦,៤ | ២៥៤ |
| | ០១.១.៧ បន្លែ | ៤,៨ | ២២៦,១ | ២៣១,២ | ២៣៨,៦ | ២៤៧,៥ | ២៦៦,៣ |
| ២ | **ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់** | **១,៦** | ១៦២,៧ | ១៧១,៤ | ១៧៥,៣ | ១៧៧,១ | ១៧៩ |
| ៣ | **សម្លៀកបំពាក់ និងស្បែកជើង** | **៣** | ១៤៧,៧ | ១៥១,៤ | ១៥៥,៨ | ១៦៣,៤ | ១៧៤,៩ |
| ៤ | **ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន និងឥន្ធនៈផ្សេងទៀត** | **១៧** | ១២៦,១ | ១២៧,៧ | ១២៩,១ | ១៣២,៩ | ១៤១ |
| | ០៤.៥.២ ឧស្ម័ន | ២,៧ | ១១៦,៥ | ១២៣,៣ | ១២២,៨ | ១៣៥,២ | ១៦២,៣ |
| ៥ | **គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់** | **២,៧** | ១៥០,៧ | ១៥២,៧ | ១៥៣,៦ | ១៥៥,១ | ១៦០,៥ |
| ៦ | **សុខាភិបាល** | **៥,១** | ១៣៥,៤ | ១៣៧,១ | ១៣៧,៣ | ១៣៨,៩ | ១៤២,៥ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៧ | **ការដឹកជញ្ជូន** | **១២** | ១១៦,៥ | ១១៣,៨ | ១០៨,៧ | ១១៨,២ | ១៣១ |
| | ០៧.២.២.១ ប្រេងសាំង | ៥ | ៩៧ | ៨៨,៦ | ៧៥,៤ | ៩៥,៥ | ១២១,៥ |
| | ០៧.២.២.២ ប្រេងម៉ាស៊ូត | ០,១ | ១១៣ | ១០៨,៥ | ៨៧ | ១០៨,៦ | ១៥៦,៧ |
| ៨ | **ទូរគមនាគមន៍** | **១,១** | ៦៧,៦ | ៦៧,១ | ៦៦,៧ | ៦៦,៥ | ៦៦,៦ |
| ៩ | **ការកម្សាន្ត និងវប្បធម៌** | **២,៩** | ១១៨,៤ | ១១៩,៣ | ១២០,៣ | ១២១,១ | ១២៧,៩ |
| ១០ | **ការសិក្សា** | **១,២** | ១៥៩,៦ | ១៦០,៤ | ១៦៥ | ១៦៥,៤ | ១៦៨,៦ |
| ១១ | **ភោជនីយដ្ឋាន** | **៥,៩** | ២៦៩,៨ | ២៨៦,៦ | ២៩៧,៨ | ៣០០,២ | ៣២១,២ |
| ១២ | **ទំនិញ និងសេវាកម្មផ្សេងៗ** | **២,៣** | ១៤៤,៨ | ១៤៧,៣ | ១៥៣,៥ | ១៦១,៥ | ១៦៧ |

[1] សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញ (គ្រាគោល: តុលា-ធ្នូ ២០០៦=១០០)

ប្រភពទិន្នន័យ : ០-១២ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ១៣, ១៤, ១៥ ធនាគារជាតិនៃកម្ពុជា

តារាងទី២ : ស្ថានភាពថវិកាជាតិ

គិតជាប៊ីលានរៀល

| ល.រ | សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(៩ខែ) |
|---|---|---|---|---|---|---|
| | **ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) *** | ៩៩ ៥៤៤ | ១១០ ០១៤ | ១០៩ ០៦២ | ១១៦ ៧១១ | ១១៨ ៣៨៨ |
| ១ | *I. ចំណូលថវិកាជាតិ* | *១៩ ៩៥៥,៦* | *២៥ ៦៥២,៥* | *២២ ៨៧០,០* | *២១២០២,៧* | *២០ ២៨៥,០* |
| | *% ធៀបនឹង ផ.ស.ស* | *២០,០%* | *២៥,៨%* | *២១,០%* | *១៨,២%* | *១៧,១%* |
| ២ | *I.១. ចំណូលមូលធន* | *៤០៦,៥* | *៦៣០,០* | *១ ៨៤២,០* | *១ ០៩៥,៥* | *១ ៦៦៤,៤* |
| | *I.២. ចំណូលចរន្ត* | *១៩ ៥៤៩,១* | *២៥ ០២២,៥* | *២១ ០២៧,៩* | *២០ ០១១,៩* | *១៨ ៦២០,៦* |
| | *% ធៀបនឹង ផ.ស.ស* | *១៩,៦%* | *២៥,១%* | *១៩,៣%* | *១៧,១%* | *១៥,៧%* |
| ៣ | *I.២.១. ចំណូលសារពើពន្ធ ** | *១៧ ០១៥,៩* | *២១ ៨២៩,៩* | *១៩ ២១៥,៨* | *១៨ ៣១៦,៤* | *១៧ ១៤៩,៧* |
| | | **១៨ ៧១១,៤** | **២៣ ៨៩១,៣** | **២១ ៤៥៩,១** | **២០ ៤៧៩,៧** | **១៩ ០៩៥,៦** |
| | *១. ពន្ធ និងអាករគយ* | *១០ ០៩៦,២* | *១២ ៨៩៧,៤* | *៩ ៦៧២,២* | *៩ ១៣៨,៨* | *៧ ៩៤២,៧* |
| | | ១០ ២៣១,៩ | ១៣ ៣៤៥,៨ | ១០ ១៣៤,១ | ៩ ៥៥៩,២ | ៨ ៥៣៧,៨ |
| | ១.១. ពន្ធគយ (របបនាំចូល) | ១ ៩២៥,៧ | ២ ៥២៦,១ | ១ ៨៥៩,៥ | ១ ៧៦៨,៩ | ១ ៦៦១,៣ |
| | ១.២. អាករពិសេសលើរបបនាំចូល | ៤ ០៧៦,៩ | ៥ ៤៦០,៥ | ៣ ៧៣១,៤ | ៣ ៥៩៧,២ | ៣ ២៣២,៨ |
| | ១.៣. អាករលើតម្លៃបន្ថែម (របបនាំចូល) | ៣ ៦៨២,៥ | ៤ ៧៤២,៦ | ៣ ៨៤៤,៧ | ៣ ៥៨៤,០ | ៣ ១៧១,៤ |
| | ១.៤. អាករនាំចេញ | ៥២,២ | ៤៩,៥ | ២៤,២ | ៤៤,២ | ៤៤,៩ |
| | ១.៥. អាករបន្ថែមលើផលិតផលតេលសិលា ** | ៣១៨,៥ | ៣៩០,៨ | ៤១៣,៦ | ៤០៩,៨ | ២៨៥,៥ |
| | ១.៦. ផ្សេងៗ | ១៧៤,២ | ១៧៥,១ | ១៤០,៦ | ១៨៧,៥ | ១៤១,៣ |
| ៤ | *២. ចំណូលពន្ធដារ* | *៦ ៩១៩,៧* | *៨ ៩៣២,៥* | *៩ ៥៤៣,៦* | *៩ ១៧៩,០* | *៩ ២០៧,០* |
| | | ៨ ៤៧៩,៦ | ១០ ៥៤៥,៤ | ១១ ៣២៥,១ | ១០ ៩២០,៥ | ១០ ៥៥៧,៨ |
| | ២.១. ពន្ធលើប្រាក់បៀវត្ស | ៦៨២,២ | ៨០១,៤ | ៩០៦,៧ | ៩៩០,៤ | ៩២៦,៨ |
| | ២.២. ពន្ធលើប្រាក់ចំណូល | ៣ ២០៤,៩ | ៣ ៩៦៤,៧ | ៦ ១៣០,១ | ៤ ៨៩២,៤ | ៥ ២១៩,៨ |
| | ២.៣. ពន្ធលើឈ្នួលផ្ទះ-ដី | 0.0 | 0.0 | 0.0 | 0.0 | ៩ ២០៧,០ |
| | ២.៤. អាករលើផលរបរ | ០,២ | 0.0 | ៤ ៩៧៣,៣ | 0.0 | ១០ ៥៥៧,៨ |

| | | | | | | |
|---|---|---|---|---|---|---|
| | ២.៥. អាករលើតម្លៃបន្ថែម | ២ ០២៦,២ | ២ ៥០៥,៦ | ២ ៥៨៨,៦ | ២ ៣៣៨,២ | ២ ២៨៣,៤ |
| | ២.៦. អាករពិសេស | ៨៥៣,៨ | ១ ០៥៨,៦ | ១ ០៤៨,៨ | ៧៨៦,៣ | ៧៨៩,១ |
| | ២.៧. ចំណូលផ្សេងៗ | ១៥០,៩ | ១៥៧,៦ | ២៣៩,៨ | ១៤៤,៤ | ១១១,៩ |
| | ២.៨. ថវិកាខេត្ត-រាជធានី | ១ ៥៥០,៣ | ២ ០៤៨,១ | ២ ៣៥២,០ | ១ ៦២៩,៩ | ១ ៣១១,២ |
| ៥ | *I.២.២. ចំណូលមិនមែនសារពើពន្ធ* | *២ ៥២៩,៣* | *៣ ១៩២,៦* | *២ ៥២២,២* | *១ ៦៩៤,៣* | *១ ៤៧០,៩* |
| | % ធៀបនឹង ផ.ស.ស | *២,៥%* | *៣,២%* | *២,៣%* | *១,៥%* | *១,២%* |
| | *១. កាស៊ីណូ* | *១៦៧,៦* | *៣៤៤,៧* | *១៦៣,៨* | *៧,៩* | *២៦,៧* |
| | *២. ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក* | *៤៣,១* | *៦៤,២* | *៤៥,៩* | *១០១,៧* | *២៥,០* |
| | *៣. កម្រៃការគ្រប់គ្រង និងទិដ្ឋាការនាំចេញ* | *៤៤,៨* | *៤៦,០* | *១៣,៧* | *១៧,៣* | *១២,៦* |
| | *៤. នេសាទ* | *១,៤* | *១,៦* | *០,៩* | *០,០០៥* | *0.0* |
| ៦ | **ផលិតផលក្នុងស្រុកសរុប (ផសស) *** | ៩៩ ៥៤៤ | ១១០ ០១៤ | ១០៩ ០៦២ | ១១៦ ៧១១ | ១១៨ ៣៨៨ |
| | ២. រុក្ខាប្រមាញ់ | ៩,៣ | ១៧,៣ | ១០,១ | ១៦,២ | ៣,៩ |
| | ៣. សម្បទានរ៉ែ | ៥៣,០ | ៦៤,០ | ៧៦,៩ | ៦៨,៥ | ៤៩,៨ |
| | ៤. អាកាសចរណ៍ស៊ីវិល | ១៤១,១ | ២១២,១ | ១៣២,៨ | ២១,២ | ១២,១ |
| | ៥. ផលទុននៃសកម្មភាពទេសចរណ៍ | ៤២២,៦ | ៣៧៥,៨ | ៨០,២ | ២,៩ | ៨,៧ |
| | ៦. ប្រៃសណីយ៍ និងទូរគមនាគមន៍ | ១១៦,៣ | ១៧០,០ | ១៨៦,៥ | ៤១៣,០ | ១៧៣,៨ |
| | ៧.អាករស្ថានទូត( លិខិតឆ្លងដែន និងទិដ្ឋាការ ) | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | ៨.ការត្រួតពិនិត្យគុណភាព ផលិតផល | ៨២,៨ | ៤៩,៦ | ៣៨,៤ | ៣៤,២ | ១៦,៥ |
| | ៩.ជួលសហគ្រាសសម្ភារៈម.ធ.ដ.ជ.ន | ២៤,៦ | ២៩,៥ | ២៤,៥ | ២៥,៥ | ១៤,៩ |
| ៧ | **II. ចំណាយថវិកាជាតិ** | ១៦ ៨២៧,៩ | ១៨ ៧៤០,៣ | ២២ ៣២៦,០ | ២២ ៩២០,១ | ១០ ៨៩២,៤ |
| | **% ធៀបនឹង ផ.ស.ស** | ១៦,៩% | ១៧,០% | ២០,៥% | ១៩,៦% | ៩,២% |
| ៨ | **II.១. ចំណាយចរន្ត** | ១៤ ០៧៦,៣ | ១៤ ៥៥២,១ | ១៦ ៤៩៧,០ | ១៦ ៩៨១,៦ | ៧ ៩៧៤,៩ |
| | % ធៀបនឹង ផ.ស.ស | ១៤,១% | ១៣,២% | ១៥,១% | ១៤,៦% | ៦,៧% |
| ៩ | មធ្យោបាយ និងសេវា | ១០ ៤១០,៩ | ៩ ៥៤៩,២ | ១០ ៦១៤,៩ | ៩ ៦៩៤,១ | ៤ ៥៦៦,២ |
| | បន្ទុកហិរញ្ញវត្ថុ | ៣៩១,៧ | ៤៤១,៦ | ៤៨៤,៤ | ៥០៣,៤ | ២២៩,៩ |
| | អន្តរាគមន៍សាធារណៈ | ២ ៨០៣,៣ | ៤ ០៩២,០ | ៤ ៨៦៩,៥ | ៦ ៥៣៤,៣ | ៣ ០៩៤,០ |
| | ចំណាយផ្សេងៗ | ៤៧១,៣ | ៤៦៩,៣ | ១ ០១២,៧ | ២៤៩,៧ | ៨៤,៩ |
| | ចំណាយតាមដីកា | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | ចំណាយមិនបានគ្រោងទុក | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ១០ | **II.២. ចំណាយមូលធន** | ២ ៧៥១,៥ | ៣ ៨១២,៩ | ៥ ៨២៩,០ | ៥ ៩៣៨,៥ | ២ ៩១៧,៥ |
| | % ធៀបនឹង ផ.ស.ស | ២,៨% | ៣,៥% | ៥,៣% | ៥,១% | ២,៥% |
| | ការទូទាត់ប្រាក់ខ្ចី | ៧៣៦,៦ | ៨៨៣,៩ | ១ ០៨២,៣ | ១ ១៨៩,៥ | ៦៣៤,៦ |
| | អចលនកម្ម | ២ ០១៥,០ | ២ ៩២៩,០ | ៤ ៧៤៦,៧ | ៤ ៧៤៩,០ | ២ ២៨២,៩ |
| | ចំណាយតាមដីកា | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | **តុល្យភាពថវិកាជាតិ** | ៣ ១២៧,៨ | ៦ ៩១២,២ | ៥៤៤,០ | -១ ៧១៧,៤ | ៣ ៥០៧,០ |

ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC)

| សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(៩ខែ) |
|---|---|---|---|---|---|
| អតិផរណាសរុប | ២,៥% | ១,៩% | ២,៩% | ២,៩% | ៦,១% |
| ក្រុមម្ហូបអាហារ | ២,៥% | ២,១% | ៤,៧% | ២,៨% | ៥,៣% |
| ក្រុមដឹកជញ្ជូន | ២,៩% | -២,៣% | -៤,៥% | ៨,៨% | ១២,៣% |




- **ការងារសំណង់**

| **ឆ្នាំ** | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ ៩ខែ |
|---|---|---|---|---|---|
| ក្រឡាផ្ទៃសរុប | ១២ ៣៧៨ | ២៣ ២៦៥ | ១៦ ៩៦៦ | ១២ ៩៩៨ | ៤ ៨២២ |
| លំនៅឋាន | ៥ ១៨៣ | ១០ ៦២៧ | ៧ ៥៦៧ | ៧ ៣៩៣ | ២ ៨១៧ |
| ក្រៅពីលំនៅឋាន | ៧ ១៩៥ | ១២ ៦៣៨ | ៩ ៣៩៨ | ៥ ៦០៥ | ២ ០០៦ |




- **ការងារវិនិយោគ(ឯកតាៈ ពាន់ដុល្លារអាម៉េរិក)**

| សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ ៩ខែ |
|---|---|---|---|---|---|
| ទុនវិនិយោគ អនុញ្ញាតសរុប | ៦ ៤៥២ | ៩ ៣៩៨ | ៨ ២៥១ | ៤ ៣៩៥ | ៣ ៤៦០ |
| កសិកម្មនិងកសិឧស្សាហកម្ម | ៤៥៨ | ១៧២ | ១៤៧ | ១៣៥ | ១០៥ |
| ឧស្សាហកម្ម | ១ ៥៤៩ | ១ ៩៣៤ | ១ ៤៧១ | ២ ១៧២ | ១ ៣៩៩ |
| ទេសចរណ៍ | ១ ៦១៣ | ៦ ៣១១ | ៣ ៨៦០ | ១២៨ | ១៦៤ |
| ហេដ្ឋារចនាសម្ព័ន្ធ និងផ្សេងៗ | ២ ៨៣៣ | ៩៨០ | ២ ៧៧៣ | ១ ៩២១ | ១ ៧៩១ |




- **ការងាររោងចក្រ**

| សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(៩ខែ) |
|---|---|---|---|---|---|
| រោងចក្រសរុប មានក្នុងបញ្ជី | ១ ៥២៨ | ១ ៧៣០ | ១ ៨៦៤ | ១ ៩៥៤ | ១ ៩៦២ |
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ១៧៨ | ២៦៩ | ២៣៥ | ១៦៣ | ១៤២ |
| រោងចក្រដែលបានលុបចេញពីបញ្ជី | ៤២២ | ៤៥៨ | ៤៦៨ | ១៤៨ | ៥៩ |




| សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(៩ខែ) |
|---|---|---|---|---|---|
| ការនាំចូល | ១៦ ៩៥៤ | ១៩ ៩៥១ | ១៩ ១៨៦ | ២៨ ៤១០ | ២២ ៥៦៤ |
| ការនាំចេញ | ១២ ៨៨៣ | ១៥ ១២១ | ១៧ ៦៣៣ | ១៨ ០០៩ | ១៦ ០៨២ |
| ជញ្ជីងពាណិជ្ជកម្ម | -៤ ០៧១ | -៤ ៨៣០ | -១ ៥៥៣ | -១០ ៤០១ | -៦ ៤៨២ |

- ការងារពាណិជ្ជកម្មអន្តរជាតិកម្ពុជា(ឯកតា: ពាន់ដុល្លារអាម៉េរិក)



## ២- ការងាររៀបចំកិច្ចប្រជុំ

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(៩ខែ) |
|---|---|---|---|---|---|
| កិច្ចប្រជុំជំនាញបច្ចេកទេស(លើក) | ២៤ | ៨៥ | ២៧ | ៣៣ | ២៣ |
| កិច្ចប្រជុំអន្តរក្រសួង(លើក) | ១៦ | ២៨ | ២០ | ២១ | ១៦ |
| កិច្ចប្រជុំអន្តរក្រសួងចង្អៀត(លើក) | ០ | ១៨ | ៣៣ | ៩ | ៣ |
| កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ(លើក) | ០ | ៧ | ២៧ | ៥ | ៣ |
| កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី(លើក) | ៦ | ៨ | ៧ | ៤ | ៤ |
| កិច្ចប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី(លើក) | ០ | ០ | ១ | ១ | ០ |

## ៣- ការងាររបាយការណ៍

ទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំរបាយការណ៍ស្តីពីសកម្មភាពការងាររបស់រាជរដ្ឋាភិបាលប្រចាំខែ ប្រចាំត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ ដើម្បីទូលថ្វាយព្រះមហាក្សត្រ និងជម្រាបជូនស្ថាប័ននីតិប្បញ្ញត្តិ ព្រមទាំងចម្លងជូនគ្រប់ក្រសួងស្ថាប័ន។

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| ប្រចាំខែ (ក្បាល) | ១ ៤៤០ | ១ ៤៤០ | ១ ៤៤០ | ១ ៤៤០ | ១ ៤៤០ |
| ត្រីមាស (ក្បាល) | ១៨០ | ១៨០ | ១៨០ | ១៨០ | ១៨០ |
| ឆមាស (ក្បាល) | ១៨០ | ១៨០ | ១៨០ | ១៨០ | ១៨០ |
| ៩ខែ (ក្បាល) | ១៨០ | ១៨០ | ១៨០ | ១៨០ | ១៨០ |
| ប្រចាំឆ្នាំ (ក្បាល) | ១៨០ | ១៨០ | ១៨០ | ១៨០ | ១៨០ |

ទីស្តីការគណៈរដ្ឋមន្ត្រី បានរៀបចំរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ទីស្តីការគណៈរដ្ឋមន្ត្រី ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ។

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| ត្រីមាស (ក្បាល) | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ឆមាស (ក្បាល) | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ៩ខែ (ក្បាល) | ១០០ | ១០០ | ១០០ | ១០០ | ១០០ |
| ប្រចាំឆ្នាំ (ក្បាល) | ១០០ | ១០០ | ១០០ | ១០០ | ១០០ |

## ៤- ការងាររដ្ឋបាល

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| សេចក្តីសម្រេច | ១០១ | ១៨៩ | ១១០ | ១២២ | ៩៤ |
| ប្រកាស | ១០៩ | ១២៨ | ៨៥ | ៣២ | ១៩ |
| អនុក្រឹត្យតែងតាំង | ១ ២៧៩ | ១ ៥២៦ | ១ ០៨៩ | ៦០៥ | ១ ២០២ |
| អនុក្រឹត្យបង្កើត | ១៩៦ | ២៥៣ | ២៤២ | ២៨១ | ២៩៧ |
| សារាចរ | ៧ | ៨ | ៧ | ៨ | ៩ |
| សារាចរណែនាំ | ៨ | ១២ | ៦ | ៧ | ៤ |
| សេចក្តីណែនាំ | ៣ | ២ | ០ | ៦ | ៣ |

**៥- ការងាររាជកិច្ច**( https://www.ocm.gov.kh/?reglation ) ( ministry=3637post_type=ocm ឬdocument_list&s= )

**ក- ការងារប្រមូលនិងចងក្រងឯកសារគតិយុត្ត**

ផ្នែកប្រមូលនិងចងក្រងឯកសារគតិយុត្តដែលបានបោះពុម្ពរួច គិតចាប់ពីឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២២ រយៈពេល៥ឆ្នាំ ដោយនៅក្នុងឆ្នាំ២០២២ លិខិតបទដ្ឋានគតិយុត្តបានបោះពុម្ពគិតត្រឹមខែកញ្ញា។

| ល.រ | លិខិតបទដ្ឋាន | ឯកសារគតិយុត្តបោះពុម្ពតាមឆ្នាំនីមួយៗ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | |
| ១ | ព្រះរាជក្រម | ២៣ | ២០ | ៤២ | ៣៦ | ៦ | ១២៧ |
| ២ | ព្រះរាជក្រឹត្យ | ១ ៦០៣ | ១ ៧៥៥ | ១ ៦៧០ | ៨៧០ | ៣១១ | ៦ ២០៩ |
| ៣ | ក្រុមប្រឹក្សាធម្មនុញ្ញ | ៥ | ០ | ១ | ១១ | ៤ | ២១ |
| ៤ | ព្រឹទ្ធសភា | ២ | ០ | ០ | ០ | ០ | ២ |
| ៥ | រដ្ឋសភា | ៣ | ២ | ១ | ២ | ១ | ៩ |
| ៦ | អនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ | ២២២ | ១៦០ | ២៧៧ | ៣០៦ | ៩១ | ១ ០៥៦ |
| ៧ | អនុក្រឹត្យមានលក្ខណៈជាឯកត្តភូត | ១ ៣៥៣ | ១ ៤៣០ | ១ ១៧០ | ៦១៨ | ២៨០ | ៤ ៨៥១ |
| ៨ | សេចក្តីសម្រេច | ១០០ | ១៧០ | ១២២ | ១១២ | ៤០ | ៥៤៤ |
| ៩ | សារាចរ | ៦ | ៧ | ៧ | ៦ | ៤ | ៣០ |
| ១០ | សារាចរណែនាំ | ៨ | ១០ | ៦ | ៧ | ៤ | ៣៥ |
| ១១ | សារាចរណែនាំបន្ថែម | ០ | ១ | ០ | ០ | ០ | ១ |
| ១២ | បទបញ្ជា | ០ | ០ | ០ | ១ | ០ | ១ |
| ១៣ | សេចក្តីណែនាំ | ៣ | ១ | ០ | ៤ | ២ | ១០ |
| ១៤ | សេចក្តីថ្លែងការណ៍ | ០ | ១ | ០ | ០ | ០ | ១ |
| ១៥ | សេចក្តីប្រកាស | ០ | ០ | ០ | ១ | ០ | ១ |
| ១៦ | យុទ្ធសាស្ត្រ | ២ | ០ | ០ | ០ | ០ | ២ |
| ១៧ | ទីស្តីការគណៈរដ្ឋមន្ត្រី | ០ | ១ | ០ | ១ | ០ | ២ |
| ១៨ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២៤២ | ២៦៥ | ១៤៥ | ១៦៦ | ៦២ | ៨៨០ |
| ១៩ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ២០៤ | ១៩០ | ១០៣ | ៤៧៧ | ១១៥ | ១ ០៨៩ |
| ២០ | ក្រសួងរ៉ែនិងថាមពល | ០ | ៥៦ | ៦៥ | ៦៩៨ | ១៦៦ | ៩៨៥ |
| ២១ | ក្រសួងមហាផ្ទៃ | ០ | ០ | ៥៣ | ៤២ | ០ | ៩៥ |
| ២២ | ក្រសួងការពារជាតិ | ៤ | ២ | ១១ | ១៣ | ០ | ៣០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២៣ | ក្រសួងយុត្តិធម៌ | ១ | ១០ | ១៥ | ៥៨ | ១៦ | ១០០ |
| ២៤ | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ១ | ០ | ០ | ០ | ០ | ១ |
| ២៥ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ០ | ១ | ២ | ៣ | ២ | ៨ |
| ២៦ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១ | ០ | ១ | ១ | ០ | ៣ |
| ២៧ | ក្រសួងពាណិជ្ជកម្ម | ១ | ០ | ០ | ១ | ០ | ២ |
| ២៨ | ក្រសួងបរិស្ថាន | ០ | ០ | ០ | ១ | ០ | ១ |
| ២៩ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ០ | ១ | ១ | ០ | ០ | ២ |
| ៣០ | ក្រសួងទេសចរណ៍ | ០ | ៤ | ៣ | ៦ | ១ | ១៤ |
| ៣១ | ក្រសួងអភិវឌ្ឍន៍ជនបទ | ០ | ០ | ១ | ០ | ០ | ១ |
| ៣២ | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | ០ | ៣ | ០ | ០ | ១ | ៤ |
| ៣៣ | ក្រសួងធម្មការនិងសាសនា | ០ | ០ | ០ | ៧ | ០ | ៧ |
| ៣៤ | ក្រសួងកិច្ចការនារី | ០ | ៣២ | ១៦ | ០ | ០ | ៤៨ |
| ៣៥ | ធនាគារជាតិនៃកម្ពុជា | ១៣ | ១ | ៤ | ០ | ០ | ១៨ |
| ៣៦ | អង្គភាពប្រឆាំងអំពើពុករលួយ | ០ | ០ | ០ | ១ | ០ | ១ |
| **សរុប** | | **៣ ៧៩៧** | **៤ ១២៣** | **៣ ៧១៦** | **៣ ៤៤៩** | **១ ១០៦** | **១៦ ១៩១** |

**ខ- ការងារផ្នែកបោះពុម្ព**

| ឆ្នាំបោះពុម្ព | ចំនួនសៀវភៅក្នុង១លេខ | ចំនួនសៀវភៅក្នុង១ខែ (៨លេខ) | ចំនួនសៀវភៅក្នុង១ឆ្នាំ (៩៦លេខ) |
|---|---|---|---|
| ២០១៨ | ១ ៧០០ ក្បាល | ១៣ ៦០០ ក្បាល | ១៦៣ ២០០ ក្បាល |
| ២០១៩ | ១ ៧០០ ក្បាល | ១៣ ៦០០ ក្បាល | ១៦៣ ២០០ ក្បាល |
| ២០២០ | ១ ៣២៦ ក្បាល | ១០ ៦០៨ ក្បាល | ១២៧ ២៩៦ ក្បាល |
| ២០២១ | ១ ៣២៦ ក្បាល | ១០ ៦០៨ ក្បាល | ១២៧ ២៩៦ ក្បាល |
| ២០២២ | ១ ៣២៦ ក្បាល | ១០ ៦០៨ ក្បាល | ១២៧ ២៩៦ ក្បាល |

ការផ្សព្វផ្សាយលើគេហទំព័រទីស្តីការគណៈរដ្ឋមន្ត្រី នាយកដ្ឋានរាជកិច្ចបានបញ្ចូលសៀវភៅរាជកិច្ចទៅក្នុងគេហទំព័រដែលអាចស្រាវជាវ និងទាញយកបាន គឺសៀវភៅរាជកិច្ចចាប់ពីឆ្នាំ១៩៩៩ រហូតដល់ឆ្នាំ២០២២ ដែលគិតត្រឹមខែកញ្ញាបានបញ្ចូលដល់ត្រឹមលេខ២៨។

## ៦- លទ្ធផលការងារសម្រេចបានរបស់នាយកដ្ឋានតម្កល់ឯកសារជាតិ

ហ្វេសប៊ុកផេកបណ្ណសារដ្ឋានជាតិនៃកម្ពុជា( National Archive of Cambodia )

### ក- ការងារចូលរួមបណ្តុះបណ្តាល សិក្ខាសាលា សន្និសីទ និងកម្មវិធីផ្សេងៗក្នុងនិងក្រៅប្រទេស

| ល.រ | បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ១ | ការងារបណ្តុះបណ្តាលក្នុងប្រទេស | ០ | ២ | ១ | ០ | ០ | ៣លើក |
| ២ | ការងារបណ្តុះបណ្តាលក្រៅប្រទេស | ១ | ១ | ០ | ០ | ០ | ២លើក |
| ៣ | ការងារសិក្ខាសាលាក្នុងប្រទេស | ២ | ០ | ០ | ២ | ៣ | ៧លើក |
| ៤ | ការងារសិក្ខាសាលាក្រៅប្រទេស | ១ | ៣ | ០ | ០ | ០ | ៤លើក |
| ៥ | ការងារសន្និសីទក្រៅប្រទេស | ២ | ០ | ០ | ០ | ០ | ២លើក |
| ៦ | ការងារបណ្តុះបណ្តាអនឡាញក្នុងប្រទេស | ០ | ០ | ០ | ២ | ១ | ៣លើក |
| ៧ | ការងារបណ្តុះបណ្តាអនឡាញក្រៅប្រទេស | ០ | ០ | ០ | ០ | ២ | ២លើក |
| ៨ | ការងារសន្និសីទ និងសិក្ខាសាលា អនឡាញក្រៅប្រទេស | ០ | ០ | ០ | ៧ | ០ | ៧លើក |
| ៩ | ការងារប្រជុំអនឡាញក្រៅប្រទេស | ០ | ០ | ០ | ០ | ៣ | ៣លើក |

### ខ- ការងារបច្ចេកទេស

| ល.រ | បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ១ | បកប្រែចំណងជើងសៀវភៅក្នុងកុំព្យូទ័រ | ០ | ២ ២៤៤ | ២ ៦២៩ | ២ ៣៤៣ | ០ | ៧ ២១៦ ចំណងជើង |
| ២ | កែហ្វុងអក្សរចំណងជើងសៀវភៅក្នុងកុំព្យូទ័រ | ៧០ | ៤ ៩៣៩ | ៥០ | ១៥០ | ០ | ៥ ២០៩ ចំណងជើង |
| ៣ | បញ្ចូលទិន្នន័យសៀវភៅ ទស្សនាវដ្តី និងខិត្តបណ្ណ | ៣៩៥ | ៣៥២ | ៤៩១ | ៣៣៦ | ៥៨៤ | ២ ១៥៨ក្បាល |
| ៤ | បញ្ចូលទិន្នន័យផែនទីប្លង់ | ០ | ០ | ០ | ០ | ១២៩ | ១២៩ផ្ទាំង |
| ៥ | បោះពុម្ពបញ្ជីស្ថិតិសម្រាប់បម្រើការស្រាវជ្រាវ | ០ | ០ | ០ | ២ ១១០ | ០ | ២ ១១០ទំព័រ |
| ៦ | ចំនួនឯកសារសម្អាតនិងចុះលេខមុនស្កេន | ០ | ៨ ២៧៥ | ៣ ៤៨៦ | ១ ៤២០ | ១ ៦៥៣ | ១៤ ៨៣៤ទំព័រ |
| ៧ | ចំនួនឯកសារស្កេន | ៣ ៤៥១ | ៣៣ ៥៤៧ | ១៦ ៩៨៣ | ២ ៣៦៦ | ១៧ ៧៣៦ | ៧៤ ០៨៣ទំព័រ |

ការងារគ្រប់គ្រង ហ្វេសប៊ុកផេកបណ្ណសារដ្ឋានជាតិនៃកម្ពុជា( National Archive of Cambodia ) ឆ្នាំ ២០២១-២០២២ ក្រុមការងារបានសរសេរអត្ថបទចំនួន១៣៤។ បច្ចុប្បន្ន ហ្វេសប៊ុកផេកមានសារបង្ហោះទៅដល់ (Page reach)ចំនួន១៣៦ ៥៣៧ អ្នកមើលទំព័រ(Page Veiw) ចំនួន៧ ៨៣៧ដង ការចូលរួម(Page engagement)ចំនួន១២ ៣៨៧ ការចែករំលែក(Shares) ចំនួន១ ៨៤០ដង និងអ្នកតាមដានទំព័រ(Follower) ២ ៧២៧នាក់។ បច្ចុប្បន្ន ហ្វេសប៊ុកផេកមានអ្នកចូលចិត្តទំព័រសរុប(Like) ចំនួន២ ១៤៩នាក់។

## គ- ការងារគ្រប់គ្រងឃ្លាំងបណ្ណសារ

| ល.រ | បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ១ | ផែនទី ប្លង់ដែលបានជួសជុល | ៧៥ | ៥៨ | ២១ | ១០ | ៣៧ | ២០១ផ្ទាំង |
| ២ | សៀវភៅដែលបានជួសជុល | ៣ | ១ | ១ | ២ | ៦ | ១៣ក្បាល |
| ៣ | កាសែតដែលជួសជុល | ៥០ | ០ | ០ | ០ | ៤ | ៥៤ទំព័រ |
| ៤ | ឯកសារក្រុមប្រឹក្សារដ្ឋ ដែលបានកែសម្រួល | ២៨ | ៣៦ | ២៩ | ៥ | ០ | ៩៨ប្រអប់ |
| ៥ | ឯកសារដែលបានត្រួតពិនិត្យ | ២៥ | ៤៩ | ២៨ | ៥ | ០ | ១០៧ប្រអប់ |
| ៦ | ឯកសារហ្វីលដែល បានត្រួតពិនិត្យ | ០ | ៤៥ | ០ | ០ | ០ | ៤៥ដុំ |
| ៧ | ភ្ញៀវជាតិដែលបានមកស្រាវជ្រាវ | ៥០ | ១ ១០៨ | ២៦២ | ២៣ | ១០៩ | ១ ៥៥២នាក់ |
| ៨ | ភ្ញៀវអន្តរជាតិដែលបាន មកស្រាវជ្រាវ | ៣៩ | ៣៣៨ | ៥៥ | ៤ | ២៨ | ៤៦៤នាក់ |
| ៩ | ភ្ញៀវជាតិនិងអន្តរជាតិដែលបាន មកទស្សនកិច្ច | ១៤២ | ២៣១ | ៦០ | ៩ | ៦២ | ៥០៤នាក់ |
| ១០ | សៀវភៅដែលទទួលបាន | ១ ៦៦០ | ១ ៤៩៩ | ៩១៦ | ២៦០ | ៤៣៣ | ៤ ៧៦៨ក្បាល |
| ១១ | ទស្សនវដ្តី ព្រឹត្តិប័ត្រ កាសែត ដែលទទួលបាន | ១៩១ | ១៥៨ | ២៦០ | ០ | ១៩១ | ៨០០ក្បាល |
| ១២ | ឯកសារថតចម្លង | ៨ ៨២៩ | ១០ ៣២១ | ១៣ ៤១៣ | ១ ៧០១ | ៦៥០ | ៣៤ ៩១៤ទំព័រ |
| ១៣ | ការងារធ្វើស្ថិតិកាសែត | ០ | ០ | ០ | ០ | ៩ | ៩ស្ថាប័ន |

## ៧- មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

(គេហទំព័រ www.ldc-eccc.gov.kh)

**សមិទ្ធផលសំខាន់ៗសម្រេចបានរយៈពេល៥ឆ្នាំ(ឆ្នាំ២០១៨ ដល់ឆ្នាំ២០២២) របស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានដូចខាងក្រោម៖**

-បានទទួលស្គាល់ជាសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២/០២ ដោយអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨

- ទទួលបានជំនួយនិងការគាំទ្រពីរដ្ឋាភិបាលនិងប្រជាជនជប៉ុន តាមរយៈស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នូវការប្រើប្រាស់ថវិកាចំនួន**២៥១ ៩៧០ដុល្លារអាម៉េរិក**(ពីររយហាសិបមួយពាន់ប្រាំបួនរយចិតសិបដុល្លារអាម៉េរិកគត់) ពីមូលនិធិបដិភាគជប៉ុន(Japan V) សម្រាប់ការអនុវត្តគម្រោង "អនុវត្តអាណត្តិកេរដំណែលរបស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់(ម.ត.ឯ.ច.) ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" រយៈពេលបីឆ្នាំ គឺឆ្នាំ២០១៩ដល់២០២១ និងទទួលបានការឯកភាពពន្យាររយៈពេលអនុវត្តរហូតដល់ចុងឆ្នាំ២០២៣ ពីស្ថានទូតជប៉ុន

- បានទទួលការណែនាំដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឱ្យមានការរៀបចំទីតាំងថ្មីសម្រាប់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអ.វ.ត.ក.

- សម្ពោធទីតាំងថ្មីស្ថិតនៅអគារលេខ៤០ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** និងឯកឧត្តម **មិកាមិ ម៉ាសាហ៊ីរ៉ូ** (Mikami Masahiro) ឯកអគ្គរាជទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

- ទទួលបានឯកសារសាធារណៈនៃសំណុំរឿង០០២/១ ពីអ.វ.ត.ក. ទី១- ប្រភេទជាឯកសារទន់មាន៨ឌីវីឌី សរុបចំនួន១៧ ២៦៧សំណុំ ស្មើនឹង១៧៥ ២៤៦ទំព័រ និងទី២- ប្រភេទជាសោតទស្សន៍សរុបមាន ៥៥៨សវនការស្មើនឹង៣ ៩៤៤វីដេអូ រួមមាន១- ឯកសារពីផ្នែកអង្គបុរេជំនុំជម្រះមាន២២សវនការចំនួន៦៧ វីដេអូ ២- ឯកសារពីអង្គជំនុំជម្រះសាលាដំបូងមាន៥២៧សវនការចំនួន ៣ ៨០៣វីដេអូ និង៣- ឯកសារពីអង្គជំនុំជម្រះតុលាការកំពូលមាន៩សវនការ ចំនួន៧៤វីដេអូ។

- បច្ចុប្បន្ន មានគេហទំព័រ (www.ldc-eccc.gov.kh) និងបណ្តាញទំនាក់ទំនងសង្គមផេកហ្វេសប៊ុករបស់មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអ.វ.ត.ក. LDC មានសារបង្ហោះទៅដល់(Page Reach) ៨២០០នាក់ អ្នកចូលចិត្តទំព័រសរុប(Like) ៥២០០នាក់ ការចូលរួម(Engagement) ២០២៧នាក់ និងអ្នកតាមដាន(Follower)៥ ៤០៦នាក់ ។

**ក- សមិទ្ធផលការងារផ្នែកបណ្ណសារ និងបណ្ណាល័យ**

| ឆ្នាំ | បរិយាយ |
|---|---|
| ២០១៨ | - កែសម្រួល Video Alignment និងTranscript ឡើងវិញ ក្នុងសំណុំរឿង០០១ ដើម្បីឱ្យមានភាពស៊ីគ្នារវាងវីដេអូ សំឡេង និងប្រតិចារឹកនៅក្នុងប្រព័ន្ធកម្មវិធីសាលាក្តីទូរនិម្មិត(VT) មាន៦៣០ វីដេអូ<br>- ថតចម្លងឯកសារសំឡេងពីកាស្សែតសាក្សីក្នុងរឿងខ្មែរក្រហម ទៅជាទម្រង់ឌីជីថលមាន២១កាស្សែត។ |
| ២០១៩ | - បោះត្រាឌីជីថលសំណុំរឿងអេឡិចត្រូនិកករណី០០១ មាន៧ ០២៦ សំណុំ ស្មើនឹង ៧៤៣២៤ទំព័រ<br>- បោះត្រាឌីជីថលសំណុំរឿងអេឡិចត្រូនិកករណី០០២ វគ្គ១មាន៥ ៤០២សំណុំ ស្មើនឹង៧៣ ៣១៨ទំព័រ។ |
| ២០២០ | - បោះត្រាឌីជីថលសំណុំរឿងអេឡិចត្រូនិកករណី០០២ វគ្គ១មាន ១១ ៨៦៥សំណុំ ស្មើនឹង ១០ ១៩២៨ទំព័រ<br>- បោះពុម្ពឯកសារសាលាក្តីខ្មែរក្រហម ករណី០០២ វគ្គ១ មាន២ ២៣៤ សំណុំ ស្មើនឹង១៦ ៦៩២ទំព័រ<br>- បញ្ចូលព័ត៌មានសៀវភៅឡើងវិញតាមកម្មវិធីញ៉ូដេលីបជាភាសាខ្មែរ និងភាសាអង់គ្លេស ១២៩ក្បាល។ |
| ២០២១ | - ធ្វើបញ្ជី ចុះលេខ ស្តែន និងបោះត្រាឌីជីថលសំណុំរឿងការកាត់ទោសមេដឹកនាំខ្មែរក្រហមដោយតុលាការប្រជាជនបដិវត្តកម្ពុជា ឆ្នាំ១៩៧៩ មានចំនួន២៥៧សំណុំ ស្មើនឹង១១២៣ទំព័រ<br>- បោះពុម្ពឯកសារសាលាក្តីខ្មែរក្រហម ករណី០០២ វគ្គ១ មាន១២២៦សំណុំ ស្មើនឹង១៤ ៨៩១ទំព័រ<br>- បញ្ចូលព័ត៌មានសៀវភៅឡើងវិញតាមកម្មវិធីញ៉ូដេលីបជាភាសាខ្មែរ និងភាសាអង់គ្លេស ៦៣ក្បាល។ |
| ២០២២ | - កត់ត្រាចម្លងចេញពីកាស្សែតសាក្សីក្នុងរឿងខ្មែរក្រហម ទៅជាទម្រង់ឯកសាររឹង៣២សំណុំ ៣៤៩ទំព័រ<br>- បញ្ចូលព័ត៌មានសៀវភៅឡើងវិញតាមកម្មវិធីញ៉ូដេលីបជាភាសាខ្មែរ និងភាសាអង់គ្លេស ១៦១ក្បាល |

**ខ- សមិទ្ធផលផ្នែកកិច្ចការសាធារណៈ**

| ល.រ | បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ១ | ឧទ្ទេសនាមតាមបណ្តាគ្រឹះស្ថានសិក្សា | - ៦ខេត្ត<br>- ២៣សាលា<br>- ២ ៤០៣នាក់ | - ១៣ខេត្ត<br>- ៤១សាលា<br>- ១២ ១៥២នាក់ | - ៥ខេត្ត<br>- ១៣សាលា<br>- ៨ ៣០៦នាក់ | 0 | - ២២ខេត្ត<br>- ៩១សាលា<br>- ៦ ៧២៧នាក់ | - ៤៦ខេត្ត<br>- ១៦៨សាលា<br>- ២៩ ៥៨៨នាក់ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | រៀបចំចូលរួមប្រជុំសិក្ខាសាលាបណ្តុះបណ្តាល | ១៣លើក | ១៦លើក | ៨លើក | ៨លើក | ១០លើក | ៥៥លើកទាំងក្នុងនិងក្រៅប្រទេស |
| ៣ | និស្សិតហាត់ការ | ១៥នាក់ ខ្មែរ | ០ | ៤នាក់ បរទេស | ០ | ១នាក់ ខ្មែរ | - ១៥នាក់ ខ្មែរ<br>- ៤នាក់ បរទេស |
| ៤ | អ្នកស្រាវជ្រាវ | - ៦នាក់ ខ្មែរ<br>- ៤នាក់ បរទេស | ៩នាក់ ខ្មែរ<br>- ១៩នាក់បរទេស | - ២នាក់ ខ្មែរ<br>-១នាក់បរទេស | ១ | - ៣នាក់ ខ្មែរ<br>- ៤នាក់ បរទេស | - ២០នាក់ ខ្មែរ<br>-២៩នាក់បរទេស |
| ៥ | ភ្ញៀវទស្សនកិច្ច | ខ្មែរ២០០៥នាក់<br>បរទេស<br>៤៥នាក់ | ខ្មែរ៥៩៧នាក់<br>បរទេស<br>៧៤នាក់ | ខ្មែរ១៣នាក់<br>បរទេស<br>២០នាក់ | ខ្មែរ១៣នាក់<br>បរទេស២២<br>នាក់ | ខ្មែរ៦៥នាក់<br>បរទេស<br>៣៥នាក់ | ខ្មែរ២៥៨៨នាក់<br>បរទេស<br>១៩៦នាក់ |
| ៦ | បោះពុម្ពព្រឹត្តិបត្រប្រចាំឆ្នាំ | ១ ០០០ | ២ ០០០ | ១ ០០០ | ៥០០ | ៥០០ | ៥ ០០០ក្បាល |
| ៧ | បោះពុម្ពខិត្តបណ្ណខ្នាតវែង និងខ្លី | ៨ ០០០ | ១២ ០០០ | ៤ ០០០ | ៤ ០០០ | ៦ ០០០ | ៣៤ ០០០<br>សន្លឹក |
| ៨ | បោះពុម្ពអាវយឺត | ០ | ០ | ០ | ១ ០០០ | ១ ០០០ | ២ ០០០អាវ |

**គ- សមិទ្ធផលផ្នែកគម្រោងអាណត្តិកេរដំណែល**

អនុវត្តសកម្មភាពគម្រោងអាណត្តិកេរដំណែល ឆ្នាំ២០១៩-២០២១ (ក្នុងនេះមានគម្រោងតូចៗចំនួន៤ សម្រាប់អនុវត្តរយៈពេល៣ឆ្នាំ) ដោយប្រើប្រាស់ថវិកាមូលនិធិបដិភាគជប៉ុន។ ក្នុងឆ្នាំ២០២២នេះ មជ្ឈមណ្ឌលបាន អនុវត្តការងារនិងគម្រោងចំនួន៣ ដូចខាងក្រោម៖

**គ.១- ការងារចុះផ្សព្វផ្សាយតាមបណ្តារាជធានី ខេត្ត**

ចុះឧទ្ទេសនាមនៅគ្រឹះស្ថានសិក្សានានាតាមបណ្តារាជធានី ខេត្ត ដោយធ្វើបានចំនួន២២ខេត្ត មាន៩១ វិទ្យាល័យ/សាលាគរុកោសល្យ/សាកលវិទ្យាល័យ មានអ្នកចូលរួមសរុប៦៧២៧នាក់ បានទិញរថយន្ត២គ្រឿង ឧបករណ៍សម្ភារៈផ្សព្វផ្សាយ និងបោះពុម្ព។

**គ.២- ការងារផ្តល់អាហារូបករណ៍**

បានផ្តល់អាហារូបករណ៍សរសេរសារណាដល់និស្សិតថ្នាក់បរិញ្ញាបត្រឆ្នាំទី៤ ចំនួន៣រូប លើប្រធានបទ ពាក់ព័ន្ធនឹងសម័យខ្មែរក្រហម សមិទ្ធផលរបស់តុលាការខ្មែរក្រហម និងប្រធានបទប្រហាក់ប្រហែល។

**គ.៣- ការងារអភិវឌ្ឍប្រព័ន្ធសាលាក្តីទូរនិម្មិត(Virtual Tribunal Improvement)**

មជ្ឈមណ្ឌលបានដេញថ្លៃជ្រើសរើសអ្នកជំនាញICT ដើម្បីអភិវឌ្ឍប្រព័ន្ធសាលាក្តីទូរនិម្មិត(Virtual Tribunal Improvement) ក្នុងគោលបំណងកែសម្រួល និងអភិវឌ្ឍបន្ថែមទៀតលើកម្មវិធីសាលាក្តីទូរនិម្មិត (ដែលមានស្រាប់) សម្រាប់បម្រើការស្រាវជ្រាវតាមប្រព័ន្ធអេឡិចត្រូនិក ដល់សាធារណជនទូទៅអាចចូលប្រើប្រាស់ បានដោយងាយស្រួល និងកាន់តែប្រសើរឡើង។

**៨- សកម្មភាពនិងសមិទ្ធផលសំខាន់ៗរយៈពេល៥ឆ្នាំ(២០១៧-២០២១) របស់រាជបណ្ឌិត្យសភាកម្ពុជាមានដូចខាងក្រោម៖**

ក្នុងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា រាជបណ្ឌិត្យសភាកម្ពុជាសម្រេចបានសមទ្ធផលសំខាន់ៗដូចខាងក្រោម៖

១- ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជាបានប្រជុំអនុម័តពាក្យដែលស្នើដោយ គណៈកម្មការបច្ចេកទេសបានចំនួន១៩០៤៣ពាក្យ។

២- គណៈកម្មការបច្ចេកទេសទាំង១៧ នៃក្រុមប្រឹក្សាជាតិភាសាខ្មែរប្រជុំអនុម័តពាក្យចំនួន ១១៨៦២ពាក្យ។

៣- ក្រុមប្រឹក្សាជាតិភាសាខ្មែរបានរៀបចំបោះពុម្ពព្រឹត្តិបត្រ៤លេខ គឺព្រឹត្តិបត្រលេខ៩ ដល់ព្រឹត្តិបត្រលេខ១២។

៤- បោះពុម្ពសទ្ទានុក្រមចំនួន៨ គឺសទ្ទានុក្រមភូមិវិទ្យានិងប្រវត្តិវិទ្យា សទ្ទានុក្រមវិទ្យាសាស្ត្រសេដ្ឋកិច្ច សទ្ទានុក្រមវេជ្ជសាស្ត្រ សទ្ទានុក្រមទស្សនវិជ្ជា សទ្ទានុក្រមអក្សរសិល្ប៍ សទ្ទានុក្រមគីមីវិទ្យានិងរូបវិទ្យា សទ្ទានុក្រមភាសាវិទ្យា និងសទ្ទានុក្រមកសិកម្ម។

៥- ក្រុមប្រឹក្សាជាតិភាសាខ្មែរក៏បានបោះពុម្ពសៀវភៅវេយ្យាករណ៍ភាសាខ្មែរ និងសៀវភៅគោលនយោបាយជាតិស្តីពីភាសាខ្មែរ។

៦- ពិនិត្យនិងអនុម័តពាក្យដែលស្នើដោយក្រសួងបរិស្ថាន ក្រសួងព័ត៌មាន។

៧- កិច្ចពិភាក្សានិងពិគ្រោះយោបល់ជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ លើការជ្រើសរើសឈ្មោះដែន «.kh» និង «.ខ្មែរ»។

៨- រៀបចំលិខិតគាំទ្រក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ លើការជ្រើសរើសឈ្មោះដែន «.kh» និង «.ខ្មែរ» ទៅអង្គការអន្តរជាតិICANN។

៩- ចូលរួមរៀបរៀងសេចក្តីព្រាងច្បាប់និងអនុក្រឹត្យនៅក្រសួងមហាផ្ទៃ ក្រសួងផែនការ និងក្រសួងយុត្តិធម៌។

១០- សហការជាមួយក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដើម្បីដោះស្រាយបញ្ហាអ្នកនិពន្ធវ័យក្មេងដែលបានយកអក្សរឡាតាំងកត់សូរភាសាខ្មែរ នៅក្នុងប្រលោមលោក។

១១- គម្រោងរៀបចំធ្វើបច្ចុប្បន្នកម្មវចនានុក្រមខ្មែរ គម្រោងការកែលម្អលើការប្រើភាសាខ្មែរនៅលើស្លាកយីហោ គម្រោងគោលនយោបាយជាតិភាសាខ្មែរ គម្រោងសុសវែរសទ្ទានុក្រមអនឡាញ។

១២- គម្រោងស្រាវជ្រាវ «សម្បត្តិបេតិកភណ្ឌវប្បធម៌រូបីនិងមរតកវប្បធម៌អរូបីនៅឧទ្យានរាជបណ្ឌិត្យសភាកម្ពុជាតេជោសែនឫស្សីត្រឹប និងការសិក្សាអង្កេតមរតកវប្បធម៌អរូបីដូចគ្នានៅខេត្តកំពង់ធំ ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ»។

១៣- គម្រោងស្រាវជ្រាវ «ចម្លាក់អប្សរានៅប្រាសាទអង្គរវត្ត : សិល្បៈតែងលម្អសក់និងការរចនាសំពត់»។

១៤- គម្រោងស្រាវជ្រាវ «ការដំឡើងរបាំច្បោះដំរ»។

១៥- គម្រោងស្រាវជ្រាវ «សិល្បៈចម្លាក់អប្សរានៅប្រាសាទអង្គរវត្ត»។

១៦- គម្រោងស្រាវជ្រាវ «ចម្លាក់អប្សរានៅប្រាសាទអង្គរវត្ត : សិល្បៈនិងលក្ខណៈរូបចម្លាក់» នៅជាន់ A2 ជាន់ក្រោមបាកាណ តាមជញ្ជាំងពេងថែវខាងក្នុង តាមរបៀងពេងថែវខាងក្រៅបណ្ណាល័យខាងជើង និងបណ្ណាល័យខាងត្បូង។

១៧- គម្រោងស្រាវជ្រាវ «ចម្លាក់អប្សរានៅប្រាសាទអង្គរវត្ត : សិល្បៈនិងលក្ខណៈរូបចម្លាក់»នៅជាន់ A3 (តាមពេងថែវ និងបណ្ណាល័យខាងជើង ខាងត្បូង) និងមណ្ឌលខ្វែង(Cruciform Gallery)។

១៨- គម្រោងស្រាវជ្រាវ «ការសិក្សាចរិតលក្ខណៈវប្បធម៌នៃជាតិពន្ធុខ្មែរអ៊ិស្លាម ចិន និងវៀតណាម នៅកម្ពុជា» ឆ្នាំ២០២២។

១៩- គម្រោងស្រាវជ្រាវ «កម្ពុជាក្នុងបរិបទពាណិជ្ជកម្មសេរីកម្ពុជា-ចិន : សក្តានុពល បញ្ហាប្រឈម និងឱកាសសម្រាប់សេដ្ឋកិច្ចនិងសង្គមកម្ពុជា» ឆ្នាំ២០២១។

២០- គម្រោងស្រាវជ្រាវ «លំហូរពលករទេសន្តរប្រវេសន៍កម្ពុជា : បញ្ហាប្រឈមនិងដំណោះស្រាយ» ឆ្នាំ២០១៩។

២១- គម្រោងស្រាវជ្រាវ«បច្ចុប្បន្នភាពនិងទស្សនវិស័យក្នុងការអភិវឌ្ឍអក្សរសិល្ប៍ខ្មែរ : ការបង្កើតចលនាអក្សរសិល្ប៍បណ្តុះស្មារតីសន្តិភាព និងភាពសុខដុមរមនាក្នុងសង្គមកម្ពុជា តាមគោលការណ៍សម្តេចតេជោ» ឆ្នាំ២០១៩ ។

២២- គម្រោងស្រាវជ្រាវ «ការស្ទង់មតិកម្មកររោងចក្រវាយនភណ្ឌចំពោះប្រព័ន្ធអនុគ្រោះពន្ធអ្វីៗគ្រប់យ៉ាងលើកលែងតែសព្វាវុធ» ឆ្នាំ២០១៩។

២៣- វចនានុក្រមគណិតវិទ្យានិងស្ថិតិ អង់គ្លេស-ខ្មែរ ពីអក្សរ A ដល់ Z។

២៤- ស្នាដៃសៀវភៅ ការសរសេរកម្មវិធីអូស៊ីអខ្មែរ និងអក្សរខ្មែរបុរាណក្នុងបច្ចេកវិទ្យាព័ត៌មាន ( Khmer intelligent OCR program and Ancient Khmer script in IT )។

២៥- បោះពុម្ពសៀវភៅស្រាវជ្រាវ«កត្តានិងបញ្ហាប្រឈមនៃការសិក្សាគណិតវិទ្យា នៅមធ្យមសិក្សានៃប្រទេសកម្ពុជា»។

២៦- ស្នាដៃសៀវភៅស្រាវជ្រាវ «ការយល់ដឹង ការប្រើប្រាស់កាំរស្មីអ៊ីយ៉ុងកម្មនិងវិទ្យុសកម្ម ព្រមទាំងផលប៉ះពាល់លើសុខភាព»។

២៧- ស្នាដៃសៀវភៅស្រាវជ្រាវ «បញ្ហាប្រឈមនិងដំណោះស្រាយ អំពីសេវាសុខាភិបាលសាធារណៈនៅកម្ពុជាដំណាក់កាលទី២»។

២៨- ការសិក្សាស្រាវជ្រាវ «ស្ថានភាពជំងឺកូវីដ-១៩» ឆ្នាំ២០២០។

២៩- ស្នាដៃសៀវភៅស្រាវជ្រាវ «បច្ចេកវិទ្យាផលិតជីវឧស្ម័នពីចំបើងនិងអនុវត្តលើវិស័យកសិកម្មនៅកម្ពុជា នៅខេត្តកំពង់ស្ពឺ»។

៣០- បោះពុម្ពសៀវភៅស្រាវជ្រាវ «បច្ចេកទេសដាំដុះដំណាំបន្លែសមស្របទៅនឹងបម្រែបម្រួលអាកាសធាតុនៅកម្ពុជា នៅខេត្តកំពង់ស្ពឺ»។

៣១- គម្រោងស្រាវជ្រាវ «ការអនុវត្តផលិតផលបាយអូឆា ជីបាយអូកំប៉ុស ផលិតដោយបច្ចេកវិទ្យាក្នុងស្រុក និងកសិកម្មឆ្លាតលើដំណាំកសិកម្ម»។

៣២- គម្រោងស្រាវជ្រាវ «ផលប៉ះពាល់នៃការផ្តល់សេវាសុខាភិបាលនិងយុទ្ធសាស្ត្រក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ-១៩នៅកម្ពុជា»។

៣៣- ស្នាដៃសៀវភៅសទ្ទានុក្រមពាក្យថ្មី ឆ្នាំ២០១៨។

៣៤- ទស្សនាវដ្តីវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា លេខ១០ ឆ្នាំ២០១៨។

៣៥- ស្នាដៃសៀវភៅសំនួនវោហារសព្ទនៃភាសាខ្មែរ ភាគ២ ឆ្នាំ២០១៨។

៣៦- ស្នាដៃសៀវភៅ សទ្ទានុក្រមឋានន្តរនាមតាមរយៈសិលាចារឹកសម័យអង្គរសតវត្សទី៩-១៤ ឆ្នាំ២០១៩។

៣៧- ស្នាដៃបោះពុម្ព កម្រងអត្ថបទស្រាវជ្រាវ ភាសា វប្បធម៌ និងអក្សរសាស្ត្រខ្មែរ ឆ្នាំ២០១៩។

៣៨- ស្នាដៃសៀវភៅ កម្មវិធីសិក្សាភាសាខ្មែរសម្រាប់ជនបរទេស ឆ្នាំ២០១៩។

៣៩- ស្នាដៃសៀវភៅ សំនួនវោហារសព្ទនៃភាសាខ្មែរ ភាគ៣ ឆ្នាំ២០១៩។

៤០- វចនានុក្រមភាសាខ្មែរបុរាណសម័យអង្គរតាមរយៈសិលាចារឹកសតវត្សទី៩-១៤ ឆ្នាំ២០២០។

៤១- ស្នាដៃសៀវភៅ សម្រង់ឈ្មោះភូមិ ឃុំ/សង្កាត់ ស្រុក/ខណ្ឌ និងរាជធានី/ខេត្ត នៅក្នុងប្រទេសកម្ពុជា ឆ្នាំ២០២០។

៤២- ស្នាដៃសៀវភៅបច្ចុប្បន្នកម្ម វចនានុក្រមអក្ខរាវិរុទ្ធភាសាខ្មែរ ឆ្នាំ២០២០។

៤៣- កម្រងទិន្នន័យភាសាខ្មែរ ឆ្នាំ២០២២។

៤៤- បោះពុម្ពស្នាដៃសៀវភៅវេយ្យាករណ៍ភាសាខ្មែរ ឆ្នាំ២០២០។

៤៥- បោះពុម្ពស្នាដៃសៀវភៅ ភាសា វប្បធម៌ និងសង្គមខ្មែរ ឆ្នាំ២០២០។

៤៦- បោះពុម្ពស្នាដៃសៀវភៅ វេយ្យាករណ៍ភាសាខ្មែរ ឆ្នាំ២០២១។

៤៧- វចនានុក្រមអក្ខរាវិរុទ្ធអេឡិចត្រូនិក ឆ្នាំ២០២១។

៤៨- ស្នាដៃសៀវភៅ ឈ្នាប់នៃភាសាខ្មែរទំនើប ឆ្នាំ២០២២។

៤៩- ស្នាដៃសៀវភៅ សុភាសិតក្នុងសង្គមខ្មែរ ឆ្នាំ២០២២។

៥០- ស្នាដៃសៀវភៅ សំយោគសញ្ញានៃមេពាក្យក្នុងវចនានុក្រមខ្មែរ ឆ្នាំ២០២២។

៥១- ស្នាដៃសៀវភៅ ពាក្យនិងសំនួនក្នុងសិលាចារឹកនគរវត្ត ឆ្នាំ២០២២។

៥២- គម្រោងស្រាវជ្រាវ «កម្ពុជាចន្លោះ ចិន អាម៉េរិក និងរុស្ស៊ី»។

៥៣- គម្រោងស្រាវជ្រាវ «ទំនាក់ទំនងការទូតផ្លូវការរបស់កម្ពុជាជាមួយបណ្តាប្រទេសនៅក្នុងតំបន់ និងពិភពលោក»។

៥៤- សន្និសីទអន្តរជាតិស្តីពី «៤០ឆ្នាំនៃកិច្ចសហប្រតិបត្តិការ អាស៊ាន-សហភាពអឺរ៉ុប : សមិទ្ធផល និងមាគ៌ាឆ្ពោះទៅមុខ»។

៥៥- សន្និសីទអន្តរជាតិស្តីពី «កម្ពុជា និងតំបន់និយមអាស៊ាន ក្នុងបរិបទឥណ្ឌូ-ប៉ាស៊ីហ្វិក»។

៥៦- សន្និសីទអន្តរជាតិស្តីពី«តួនាទីរបស់ចិនក្នុងសតវត្សទី២១ និងទំនាក់ទំនងរបស់ចិនជាមួយអាស៊ាន»។

៥៧- គម្រោងស្រាវជ្រាវ «ទំនាក់ទំនងកម្ពុជាជាមួយប្រទេសជិតខាង(ឆ្នាំ១៩៩៣-២០១៨)»។

៥៨- គម្រោងស្រាវជ្រាវ «ឥទ្ធិពលចិននិងសហរដ្ឋអាម៉េរិកនៅអាស៊ី»។

៥៩- គម្រោងស្រាវជ្រាវ «អាស៊ាននៅចន្លោះចិននិងសហរដ្ឋអាម៉េរិក»។

៦០- គម្រោងស្រាវជ្រាវ «ការកំណត់រកបរិមាណម្សៅសនៅក្នុងគ្រឿងអាហារ និងផលប៉ះពាល់សុខភាព»។

៦១-គម្រោងមន្ទីរពិសោធន៍ «បង្កាត់ពូជផ្កានៅរាជបណ្ឌិត្យសភាកម្ពុជា»។

៦២-រៀបចំគម្រោង «ការចិញ្ចឹមមាន់ និងចំណីមាន់» ។

៦៣-គម្រោងស្រាវជ្រាវ «មរតកវប្បធម៌រូបីនិងអរូបីក្នុងតំបន់ឧទ្យាន» ឆ្នាំ២០១៧។

៦៤-គម្រោងស្រាវជ្រាវ «កំណាយឡស្លដែកបុរាណ និងសង់សារមន្ទីរនិងស្ថានីយបុរាណវត្ថុវិទ្យា» ឆ្នាំ២០១៩។

៦៥- គម្រោងស្រាវជ្រាវ « ការធ្វើផែនទីគម្របព្រៃឈើ» ឆ្នាំ២០១៩។

៦៦- គម្រោងស្រាវជ្រាវ «សិក្សាពីផលប៉ះពាល់នៃការកសាងផ្លូវជុំវិញ និងក្នុងតំបន់ឧទ្យាន» ឆ្នាំ២០២០។

៦៧- ស្នាដៃចងក្រង «ទិន្នន័យសត្វស្លាបក្នុងតំបន់ឧទ្យាន» ឆ្នាំ២០២១-២០២២។

៦៨- ស្នាដៃចងក្រងឯកសារ «ការចិញ្ចឹមគោទឹកដោះ : ស្រាវជ្រាវនិងអនុវត្ត» ឆ្នាំ២០២២។

៦៩- ស្នាដៃចងក្រងឯកសារ «ការចិញ្ចឹមពពែ : ចៀម-ស្រាវជ្រាវនិងអនុវត្ត» ឆ្នាំ២០២២។

៧០- ស្នាដៃចងក្រងឯកសារ «ការកត់ត្រាព័ត៌មានពពែ-ចៀម» ភាគ១-២ ឆ្នាំ២០២២។

៧១- ស្នាដៃចងក្រងឯកសារ «ទិន្នន័យពពែ-ចៀម» ឆ្នាំ២០២២។

៧២- ស្នាដៃចងក្រងឯកសារ «ករណីជំងឺអុតក្តាមនៅក្នុងសេរ៉ូមឈាមគោទឹកដោះ» ឆ្នាំ២០២០។

៧៣- ស្នាដៃចងក្រងឯកសារ «ករណីសិក្សាជំងឺដុំពកស្បែកលើគោទឹកដោះ» ឆ្នាំ២០២១។

៧៤- ស្នាដៃចងក្រងឯកសារ «ករណី ENTEROCOCCUS SPPសុំានឹងឱសថអង់ទីប្យូទិកលើគោទឹកដោះ» ឆ្នាំ២០២១។

៧៥- ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ឆ្នាំទី១ លេខ១ និង២ ឆ្នាំ២០២១។

៧៦- ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ឆ្នាំទី១ លេខពិសេស ឆ្នាំ២០១៩។

៧៧- ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ឆ្នាំទី១ លេខ១ ត្រីមាសទី១ ឆ្នាំ២០១៩។

៧៨- ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ឆ្នាំទី១ លេខ២ ត្រីមាសទី២ ឆ្នាំ២០១៩។

៧៩- ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ឆ្នាំទី១ លេខ៣ ត្រីមាសទី៣ ឆ្នាំ២០១៩។

៨០-អត្ថបទស្រាវជ្រាវរបស់មន្ត្រីវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា ខែមិថុនា ខែកក្កដា ខែកញ្ញា ឆ្នាំ២០១៩ ចំនួន២៩អត្ថបទ។

៨១- ស្នាដៃសៀវភៅ ការរៀបចំនិងអនុវត្តគម្រោង ឆ្នាំ២០២១។

៨២- ស្នាដៃសៀវភៅ វិធីសាស្ត្រសរសេរកិច្ចការឧត្តមសិក្សា សម្រាប់ថ្នាក់បណ្ឌិត ឆ្នាំ២០២១។

៨៣- ស្នាដៃសៀវភៅ វិធីសាស្ត្រស្រាវជ្រាវសម្រាប់ថ្នាក់បរិញ្ញាបត្រ ឆ្នាំ២០២២។

៨៤- វចនានុក្រមអេឡិចត្រូនិកវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០២២។

៨៥- ស្នាដៃសៀវភៅ គោលនយោបាយសារពើពន្ធ ឆ្នាំ២០២០។

៨៦- ស្នាដៃសៀវភៅ ទស្សនវិជ្ជានយោបាយនិងសេដ្ឋកិច្ច ឆ្នាំ២០១៨។

៨៧- ស្នាដៃសៀវភៅ ពាណិជ្ជកម្មអន្តរជាតិ ឆ្នាំ២០២២។

៨៨- ស្នាដៃសៀវភៅ មូលដ្ឋានគ្រឹះនៃវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៨ ។

៨៩- ស្នាដៃសៀវភៅ ការវាស់ទិន្នផលក្នុងស្រុក ចំណូលជាតិ និងកម្រិតថ្លៃ ឆ្នាំ២០២០។

៩០- ស្នាដៃសៀវភៅ មេគង្គ-ឡានឆាងជាអ្វី?

៩១- ស្នាដៃសៀវភៅ គំនិតផ្តួចផ្តើមខ្សែក្រវាត់ និងវិថី។

៩២- ស្នាដៃសៀវភៅ យុទ្ធសាស្ត្រថ្មីនៃគោលនយោបាយថ្នាក់ដឹកនាំចិនជំនាន់ទី៥។

៩៣- ស្នាដៃសិក្សាប្រៀបធៀប មេគង្គ-ឡានឆាង និងមេគង្គ-ជប៉ុន។

៩៤- ស្នាដៃសៀវភៅ សក្តានុពល និងបញ្ហាប្រឈមនៃការវិនិយោគនៅកម្ពុជា។

៩៥- ស្នាដៃសៀវភៅ ឥរិយាបថវិនិយោគិនជនជាតិចិននៅកម្ពុជា ផ្នែកវប្បធម៌កម្ពុជា-ចិន។

៩៦- អត្ថបទវិភាគ «តួគីនៅចន្លោះចិន និងអាម៉េរិក»។

៩៧- អត្ថបទវិភាគ«គោលនយោបាយរបស់ចិនក្រោមការដឹកនាំរបស់លោក ស៊ី ជិនភីង»។

៩៨- អត្ថបទស្រាវជ្រាវ «ច្រករបៀងសេដ្ឋកិច្ចចិនប៉ាគីស្ថាន : សារៈសំខាន់និងបញ្ហាប្រឈមសម្រាប់ប៉ាគីស្ថាននិងចិន»។

៩៩- អត្ថបទស្រាវជ្រាវ «ឥរិយាបថជនជាតិភាគតិចចិននៅកម្ពុជា»។

១០០- អត្ថបទជំនួយស្មារតី «ហិរញ្ញវត្ថុចិននៅកម្ពុជា»។

១០១- អត្ថបទវិភាគ «ច្រករបៀងសេដ្ឋកិច្ចចិនប៉ាគីស្ថាន(CPEC)» និង «ឥរិយាបថនៃការវិនិយោគចិននៅកម្ពុជា : ឥទ្ធិពលលើវិស័យនយោបាយសន្តិសុខ»។

១០២- អត្ថបទស្រាវជ្រាវ «ឥរិយាបថនៃការវិនិយោគចិននៅកម្ពុជា»។

១០៣- Cam-Ch Trade relation in digital ageDigital age។

១០៤- Effect of Chinese Tourism in Cambodia។

១០៥- Monetary Policy of Cambodia's Central Bank and Some Evidences from VAR Impulse Response។

១០៦- Cam-EU Trade relation។

១០៧- Enhancing Intra-Asean trade in the context of BRI and Indo-Pacific Goal : Find key factors and mechanism for improving trade for intramural Asean។

១០៨- អត្ថបទស្រាវជ្រាវចំនួន១១ និងព័ត៌មានសកម្មភាពចំនួន៨ ចុះផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ RAC Media។

១០៩- ផ្សព្វផ្សាយអត្ថបទស្រាវជ្រាវចំនួន៩អត្ថបទ វីដេអូចំនួន៣ និងព័ត៌មានសកម្មភាពស្តីពីការសិក្សាស្រាវជ្រាវចំនួន២៦ព័ត៌មាន។

**៩- សកម្មភាពការងារអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស** (www.pressocm.gov.kh)

ចាប់ពីឆ្នាំ ២០១៨ ដល់ខែកញ្ញា ឆ្នាំ ២០២២ អង្គភាពព័ត៌មាននិងប្រតិកម្មរហ័ស បានរៀបចំប្រជុំ ពិភាក្សាជាញឹកញាប់នៃសប្តាហ៍នីមួយៗ(រួមមានការប្រជុំដោយកំណត់ចំនួនសមាជិកដែលចូលរួម និងប្រជុំតាមប្រព័ន្ធអនឡាញ) ធ្វើការពិភាក្សាសម្រិតសម្រាំង ដកស្រង់ព័ត៌មានធ្វើរបាយការណ៍ជាប្រចាំ គោរពជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីគោរពជូនជ្រាបនូវព្រឹត្តិការណ៍សំខាន់ៗប្រចាំថ្ងៃ។

**ក- ការងារព័ត៌មាន**

បានដកស្រង់អត្ថបទព័ត៌មានសំខាន់ៗចេញពីសារព័ត៌មានក្នុងស្រុក និងសារព័ត៌មានបរទេសដែលទាក់ទងនឹងភាពរីកចម្រើនលើវិស័យនានារបស់រដ្ឋាភិបាលកម្ពុជា ព្រឹត្តិការណ៍សំខាន់ៗកើតមានជុំវិញពិភពលោក បញ្ហាដែលកើតមានឡើងដែលពាក់ព័ន្ធនឹងជំងឺCovid-19 ព័ត៌មានទាក់ទងនឹងប្រទេសមីយ៉ាន់ម៉ា ព័ត៌មានទាក់ទងនឹងសង្គ្រាម

រវាងរុស្ស៊ីនិងអ៊ុយក្រែន និងការបោះឆ្នោតឃុំ សង្កាត់នៅកម្ពុជា ព្រមទាំងព័ត៌មានទាក់ទងនឹងបញ្ហារវាងចិន និងកោះតៃវ៉ាន់ បានចំនួន១០ ៥៨៤ អត្ថបទ។

**ខ- ការងារសារគមនាគមន៍**

នាយកដ្ឋានសារគមនាគមន៍បានថត ផលិត និងធ្វើការផ្សព្វផ្សាយនូវព្រះរាជសកម្មភាព**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** សកម្មភាព**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជាមួយចំនួន អញ្ជើញទទួលជួបបដិសណ្ឋារកិច្ចសំណេះសំណាលពិភាក្សាការងារផ្សេងៗទៀត ដែលក្នុងនោះរួមមាន៖

**១- ផ្នែកសោតទស្សន៍ :**

ផ្នែកសោតទស្សន៍បានថតសកម្មភាព**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សកម្មភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយក**រដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំរាជរដ្ឋាភិបាលមួយចំនួនទៀត អញ្ជើញទទួលជួបបដិសណ្ឋារកិច្ច សំណេះសំណាល ពិភាក្សាការងារ និងអញ្ជើញក្នុងកិច្ចប្រជុំនានាក្នុងរាជធានី និងតាមបណ្តាខេត្តផ្សេងៗ មានចំនួនសរុបទាំងអស់**៨៨៧លើក** ។

ជាមួយនោះដែរ បានផលិតនិងផ្សព្វផ្សាយនូវសារសំឡេងពិសេសរបស់**សម្តេចអគ្គមហាសេនា-បតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ពាក់ព័ន្ធស្ថានការណ៍នយោបាយថ្មីៗ ជាពិសេសអំពីបញ្ហាជំងឺCovid-19 បានចំនួន៩៥ដង។

**២- ផ្នែកគេហទំព័រ**

ផ្នែកគេហទំព័របានបង្ហោះអត្ថបទ រូបភាព និងវីដេអូ ជាភាសាខ្មែរ ភាសាអង់គ្លេសតាមគេហទំព័រផ្លូវការរបស់អង្គភាព(www.pressocm.gov.kh) គេហទំព័រព័ត៌មានគ្មានព្រំដែនGRAND NEWS ASI www.grandnewsasia.com) ខ្មែរតែមួយ khmer Unity (https://www.khmerunity.org/) កម្ពុជាពិត ហ្វេសប៊ុកផេក: http://www.facebook.com/KampucheaPit/) សរុបទាំងអស់មានចំនួន១៤១ ៥១៤មាតិកា។

**៣- បណ្តាញផ្សព្វផ្សាយសង្គមផ្សេងៗទៀត** (Facebook Page, YouTube)

អត្ថបទព័ត៌មាន បទវិចារណកថា បទអត្ថាធិប្បាយ ទស្សនៈវិភាគ ទស្សនៈនយោបាយ ពន្យល់បកស្រាយ បំភ្លឺឆ្លើយតបនឹងព័ត៌មានក្លែងក្លាយ និងព័ត៌មានផ្សេងទៀត ដែលសរុបទាំងអស់ចំនួន៥៣៧ ៤៤១មាតិកា។

**៤- ផ្នែកផលិត**

ការិយាល័យសោតទស្សន៍ និងការិយាល័យបច្ចេកទេសផលិត របស់នាយកដ្ឋានសារគមនាគមន៍ នៃអង្គភាពព័ត៌មាននិងប្រតិកម្មរហ័ស នៃទីស្តីការគណៈរដ្ឋមន្ត្រី បានផលិតជាវីដេអូឃ្លីប វីដេអូផ្លូវការ ផលិត ជាឌីវីឌីសម្រាប់ផ្សព្វផ្សាយតាមស្ថានីយទូរទស្សន៍រដ្ឋ និងឯកជន សម្រាប់បកស្រាយពន្យល់សាធារណមតិជាតិ និងអន្តរជាតិ សរុបទាំងអស់១៦ ៧២៣។

**៥- ផ្នែកនិពន្ធ**

ក្រុមផ្នែកនិពន្ធនៃនាយកដ្ឋានសារគមនាគមន៍ នៃអង្គភាពព័ត៌មាននិងប្រតិកម្មរហ័ស បានសម្រួល និងរៀបចំអត្ថបទព័ត៌មានសរុបទាំងអស់បានចំនួន២៩ ៥៩៩អត្ថបទ ។

**គ- ការងារបណ្ដាញផ្សព្វផ្សាយសង្គម**

ចាប់ពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២ នេះ នាយកដ្ឋានបណ្ដាញផ្សព្វផ្សាយសង្គមបានបំពេញភារកិច្ច ដែលក្នុងនោះ រួមមានៈ

**១- ក្រុមស្រាវជ្រាវបច្ចេកវិទ្យាព័ត៌មាន**

- បង្កើតកម្មវិធីទូរស័ព្ទដៃសម្រាប់ GN និងធ្វើការ Maintenance កម្មវិធីនេះ
- បង្កើតរូបរាងថ្មីសម្រាប់គេហទំព័រខ្មែរប៉ុស្ដិ៍ភាសាខ្មែរ និងអង់គ្លេស
- ថែទាំ Maintenance កម្មវិធីគ្រប់គ្រងឯកសារ(Database)
- ស្រង់ខ្លឹមសារនៃកម្មវិធី Open Cyber Talk
- បង្ហោះផ្សាយព័ត៌មានជាភាសាខ្មែរ និងអង់គ្លេសប្រចាំថ្ងៃ សម្រាប់សារព័ត៌មានខ្មែរប៉ុស្ដិ៍ទាំងលើវេបសាយ(Website) ហ្វេសប៊ុក(Facebook) យូធូប(Youtube) និងតេឡេក្រាម(Telegram)
- ស្រាវជ្រាវ និងតាមដានព័ត៌មានពីផលប៉ះពាល់ផ្នែកការងារ និងសេដ្ឋកិច្ចពីវិបត្តិCovid-19 នៅតាមប្រទេសសំខាន់ៗប្រចាំថ្ងៃ ដើម្បីគោរពរាយការណ៍ជូន**សម្ដេចតេជោ នាយករដ្ឋមន្ត្រី**
- បន្តធ្វើបច្ចុប្បន្នភាព និងមើលថែទាំកម្មវិធីទូរស័ព្ទដៃMobile app Grand News និងKhmer Post
- ជួយដោះស្រាយបញ្ហាផ្សេងៗពាក់ព័ន្ធនឹងបច្ចេកវិទ្យាសម្រាប់ក្រុមការងារOnline
- តាមដានអំពីការប្រើប្រាស់កម្មវិធីTik Tok និងបង្ហោះវីដេអូ ព្រមទាំងពង្រីកបណ្ដាញនៅលើកម្មវិធីTik Tok
- ស្រាវជ្រាវនិងបង្កើតកាណាល់(Channel) ដើម្បីពង្រីកបណ្ដាញលើTelegram
- ស្រាវជ្រាវបច្ចេកវិទ្យាថ្មីៗ សម្រាប់ជួយសម្រួលដល់ការងារក្នុងអង្គភាព និងពង្រឹងប្រសិទ្ធភាពការងារ
- ធ្វើរបាយការណ៍Live Show YouTube និងTik Tok ប្រចាំថ្ងៃជូន**សម្ដេចតេជោ នាយករដ្ឋមន្ត្រី**
- ស្រាវជ្រាវលើបច្ចេកទេសRSS feed ដើម្បីទាញយកព័ត៌មានដោយស្វ័យប្រវត្តិពីវេបសាយព័ត៌មាននានា
- Maintenance Website GN
- បានស្រាវជ្រាវ និងបានចងក្រងជាឯកសារស្ដីអំពីសុវត្ថិភាពដំបូងនៃការប្រើប្រាស់ហ្វេសប៊ុក បដិវត្តន៍ឧស្សាហកម្មទី៤ និងបច្ចេកវិទ្យាទី៥(5G)
- សិក្សាស្រាវជ្រាវ និងសាកល្បងអនុវត្តបច្ចេកទេសSEO (Search Engine Optimization) នៅលើYouTube។

**២- ក្រុមស្រាវជ្រាវនិងចងក្រងព័ត៌មាន**

ក្រុមការងារស្រាវជ្រាវនិងចងក្រង បានស្រាវជ្រាវនិងចងក្រងព័ត៌មានជាលាយលក្ខណ៍អក្សរ រូបភាព សំឡេង វីដេអូ បានសរុបទាំងអស់មានចំនួន១១ ៤៦៦។

**៣- ក្រុមចែកចាយនិងពង្រីកបណ្ដាញ**

បានធ្វើការចែកចាយលើផេក(Page) សំខាន់ៗចំនួន៥ ដែលសរុបទាំងអស់បាន១ ៦៦៩ ៦៦៣Share។

៤- ក្រុមតស៊ូមតិ

បានធ្វើការតស៊ូមតិ(Comments) តាមបណ្តាញផ្សព្វផ្សាយសង្គម សរុបទាំងអស់បាន៤៤៣ ៨២៣ Comments។

៥- ក្រុមការងារLive Show

- ស្រង់ខ្លឹមសារពីកម្មវិធីLive Show ដែលមានវាគ្មិនសំខាន់ៗទាំងក្នុងនិងក្រៅប្រទេស គាំទ្រសមិទ្ធផលនិងគោលនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់បម្រើឱ្យការងារផលិតវីដេអូ បានចំនួន១ ៣០២អត្ថបទ

- ធ្វើរបាយការណ៍សង្ខេបពីកម្មវិធីLive Show ដើម្បីគោរពរាយការណ៍ជូន**សម្តេចតេជោ នាយករដ្ឋមន្រ្តី** បានចំនួន២៤៧របាយការណ៍។

ក្រុមជំនួយការឯកឧត្តមរដ្ឋមន្ត្រី ប្រតិភូអមនាយករដ្ឋមន្ត្រី ទទួលបន្ទុកប្រធានអង្គភាពព័ត៌មាននិងប្រតិកម្ម-រហ័ស បានបំពេញការងារយ៉ាងសកម្មក្នុងការបកប្រែអត្ថបទជាភាសាខ្មែរ បានសម្រួលអត្ថបទចំនួន២ ៥២៤អត្ថបទ ព្រមទាំងបានធ្វើរបាយការណ៍ស្តីពីការសង្ខេបព័ត៌មានប្រចាំថ្ងៃ ស្តីពីជំងឺឆ្លងកូវីដ-១៩ រួមជាមួយនិងរបាយការណ៍ស្តីពីការធ្វើរបាយការណ៍Live Show ជូន**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ចំនួន៤៨៧ដង ព្រមទាំងបានធ្វើការបកប្រែអត្ថបទសំខាន់ៗជាច្រើនតាមការណែនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា។

## ៣- យន្តការដោះស្រាយបណ្តឹង

### ៣.១- ក្រសួងមហាផ្ទៃ (គេហទំព័រ https://www.interior.gov.kh ហ្វេសប៊ុកផេក Ministry of Interior Cambodia: https://www.facebook.com/ministry.interior.gov.kh)

ចាប់ពីឆ្នាំ២០១៨ ដល់បំណាច់ខែកញ្ញា ឆ្នាំ២០២២ ការងារអធិការកិច្ចនិងទទួលដោះស្រាយពាក្យបណ្តឹងក្នុងក្របខ័ណ្ឌក្រសួងមហាផ្ទៃ មានលទ្ធផលដូចខាងក្រោម៖

- **ការងារទទួល ដោះស្រាយពាក្យបណ្តឹង៖** បានទទួលពាក្យបណ្តឹងសរុបចំនួន ៤ ០៥១សំណុំរឿង (ផ្នែករដ្ឋបាល២ ៥១១សំណុំរឿង ផ្នែកនគរបាល១ ៥៤០សំណុំរឿង)។ ចំពោះលទ្ធផលនៃការដោះស្រាយពាក្យបណ្តឹងរួមមានបានដោះស្រាយបញ្ចប់ចំនួន៧៧១សំណុំរឿង បង្វែរពាក្យបណ្តឹងទៅសមត្ថកិច្ចពាក់ព័ន្ធនិងសាមីបណ្តឹងវិញ១ ៧៥១សំណុំរឿង រក្សាទុកតាមដានបន្ត៨៦៨សំណុំរឿង និងកំពុងអង្កេតស្រាវជ្រាវចំនួន៦៦១សំណុំរឿង។

- **អំពីរបាយការណ៍ស្រាយបំភ្លឺ៖** បានទទួលរបាយការណ៍ស្រាយបំភ្លឺពីអង្គភាពពាក់ព័ន្ធសរុបចំនួន៨៧០របាយការណ៍(ផ្នែករដ្ឋបាល៣៩៨របាយការណ៍ ផ្នែកនគរបាល៤៧២របាយការណ៍) ក្នុងនោះ បានពិនិត្យសម្រេចលើរបាយការណ៍ចំនួន៧២៥របាយការណ៍ ។

- **ការងារអធិការកិច្ច៖** ចុះធ្វើអធិការកិច្ចសរុប១៩០ករណី(អធិការកិច្ចតាមផែនការ២២ករណីនិងអធិការកិច្ចតាមវត្ថុបំណង១៦៨ករណី) ។

- **ការងារចុះតាមដានសេចក្តីជូនដំណឹងរបស់ក្រសួងមហាផ្ទៃ៖** បានចុះតាមដានសេចក្តីជូនដំណឹងនានាដែលក្រសួងមហាផ្ទៃដាក់ចេញនាពេលកន្លងមកចំនួន១៨៣ស.ជ.ណ។

**ការងារទទួលមតិយោបល់និងដោះស្រាយសំណើសំណូមពរ និងបញ្ហានានារបស់មហាជនក្នុងគេហទំព័រហ្វេសប៊ុករបស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ក្នុងគោលបំណងជំរុញការដោះស្រាយ និងឆ្លើយតបទាន់ពេលវេលានូវសំណើសំណូមពរ និងក្តីកង្វល់នានារបស់ប្រជាពលរដ្ឋស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលក្នុងខែមិថុនា ឆ្នាំ២០២០ ក្រសួងមហាផ្ទៃបាន

បង្កើតក្រុមការងារទទួលមតិយោបល់និងដោះស្រាយសំណើ សំណូមពរនិងបញ្ហានានារបស់មហាជនក្នុងគេហទំព័រហ្វេសប៊ុក**សម្តេចក្រឡាហោម ស ខេង** ជាមួយនិងការជំរុញក្រើនរំឭកជានិច្ចកាលដល់អង្គភាពជំនាញពាក់ព័ន្ធនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាប្រសិទ្ធភាពក្នុងការដោះស្រាយនូវរាល់បញ្ហាដែលពាក់ព័ន្ធនឹងដែនសមត្ថកិច្ចក្រសួងមហាផ្ទៃសំដៅបង្កើនភាពជឿជាក់និងការគាំទ្ររបស់ប្រជាពលរដ្ឋមកលើការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាអាជ្ញាធរមានសមត្ថកិច្ចផងដែរ។ បច្ចុប្បន្ននេះ គេហទំព័រហ្វេសប៊ុក **សម្តេចក្រឡាហោម ស ខេង** បាននិងកំពុងទទួលបានការគាំទ្រកាន់តែខ្លាំងឡើងពីមហាជនទូទៅ។

| **បរិយាយ/ឆ្នាំ** | **ខែកក្កដាដល់ខែធ្នូ ឆ្នាំ២០២០** | **២០២១** | **៩ខែ/២០២២** | **សរុប** |
|---|---|---|---|---|
| ចំនួនគណនីដែលទទួលបាន | ៧៦៨គណនី | ១ ៥៩២គណនី | ៧២២គណនី | ៣ ០៨៣គណនី |
| បានដោះស្រាយ និងឆ្លើយតប | ២៣៧ករណី | ៥៣៦ករណី | ១៩២ករណី | ៩៦៥ករណី |

__កត់សម្គាល់៖__ ក្នុងចំណោមខមិនដែលទទួលបាន មានករណីខ្លះគ្រាន់តែជាការជូនដំណឹងប៉ុណ្ណោះ។

### ៣.២- ក្រសួងយុត្តិធម៌

**ក្រសួងយុត្តិធម៌ សម្រេចការងារដូចខាងក្រោម**( ផេក : Ministry of Justice គេហទំព័រ www.moj.gov.kh )

#### ៣.២.១- យុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត

**ក- ស្ថិតិសំណុំរឿង**

១- សំណុំរឿងព្រហ្មទណ្ឌចាស់ដែលបានចាត់ការរួចនៅតាមសាលាដំបូងរាជធានី ខេត្ត៖

- ដំណាក់កាលអយ្យការ៦ ១១៦រឿង ស្មើនឹង៩៩% នៃចំនួនសំណុំរឿង៦ ១៥០រឿង
- ដំណាក់កាលស៊ើបសួរ១៩ ២០៣រឿង ស្មើនឹង៩៤% នៃចំនួនសំណុំរឿង២០ ៣៨០រឿង
- ដំណាក់កាលជំនុំជម្រះ១២ ៦៧៩រឿង ស្មើនឹង៩៧% នៃចំនួនសំណុំរឿង១៣ ០១៤រឿង។

២- សំណុំរឿងព្រហ្មទណ្ឌថ្មីដែលបានចាត់ការរួចនៅតាមសាលាដំបូងរាជធានី ខេត្ត៖

- ដំណាក់កាលអយ្យការ២៥ ៦៣៦រឿង ស្មើនឹង៨៩% នៃចំនួនសំណុំរឿង២៨ ៨៤៥រឿង
- ដំណាក់កាលស៊ើបសួរ១៣ ៦២៥រឿង ស្មើនឹង៦៧% នៃចំនួនសំណុំរឿង២០ ៣៥៦រឿង
- ដំណាក់កាលជំនុំជម្រះ២៣ ៦២៦រឿង ស្មើនឹង៧៦% នៃចំនួនសំណុំរឿង៣១ ២៦៧រឿង។

៣- លទ្ធផលជារួមទាំងបីដំណាក់កាល( ដំណាក់កាលអយ្យការ ស៊ើបសួរ និងជំនុំជម្រះ )៖

- សំណុំរឿងចាស់ចាត់ការបាន៣៧ ៩៩៨រឿង ស្មើនឹង៩៦,០៩% នៃចំនួនសំណុំរឿង៣៩ ៥៤៤រឿង
- សំណុំរឿងថ្មីចាត់ការបាន៦២ ៨៨៧រឿង ស្មើនឹង៧៨,១៥% នៃចំនួនសំណុំរឿង៨០ ៤៦៨រឿង។

យោងតាមសេចក្តីណែនាំលេខ០១ កយ.សណន/២០ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ បានជំរុញនិងលើកទឹកចិត្តដល់សាលាដំបូងនិងអយ្យការអមសាលាដំបូងទូទាំងប្រទេស ឱ្យពិចារណាប្រើប្រាស់នីតិវិធីព្រហ្មទណ្ឌមួយចំនួន ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយភាពចង្អៀតណែននៅក្នុងពន្ធនាគារ រួមមានការបង្ហាញខ្លួនភ្លាម (CI) ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់(CD) ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង។ ជាលទ្ធផល សាលាដំបូងនិងអយ្យការអមសាលាដំបូងរាជធានី ខេត្ត បានអនុវត្តតាមសេចក្តីណែនាំដូចខាងក្រោម៖

- ការបង្ហាញខ្លួនភ្លាម(CI) សរុបចំនួន១ ៣៨០សំណុំរឿង/១ ៣៤៥នាក់
- ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់(CD) សរុបចំនួន១ ៧០៦សំណុំរឿង/១ ៦៤៨នាក់

- ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ សរុបចំនួន៣ ៧០០សំណុំរឿង/៤ ៧៤៥នាក់
- ការព្យួរទោសសាកល្បង សរុបចំនួន៩២៥សំណុំរឿង/១ ៣៤៥នាក់
- ការព្យួរទោសធម្មតា សរុបចំនួន៥ ៤៧៤សំណុំរឿង/៥ ៧៤២នាក់។

**ខ- លទ្ធផលរយៈពេល៣៨៥ថ្ងៃ(កាត់បន្ថយការណែនចង្អៀតនៅពន្ធនាគារ)**

បន្ថែមពីលើការអនុវត្តតាមសេចក្តីណែនាំលេខ០១ខាងលើ មាននីតិវិធីព្រហ្មទណ្ឌមួយចំនួនដែលអាចជួយកាត់បន្ថយនូវការចង្អៀតណែននៅក្នុងពន្ធនាគារ រួមមាន១- ការសម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ហើយមិនដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ២- ការចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ៣- ការសម្រេចសេចក្តីឱ្យរួចផុតពីបទចោទ ៤- ការព្យួរទោសធម្មតា ៥- ការព្យួរទោសសាកល្បង និង៦- ការដោះលែងទណ្ឌិតដែលអនុវត្តទោសចប់។ យោងតាមការស្រង់ទិន្នន័យ និងបូកសរុបរបាយការណ៍របស់តុលាការទូទាំងប្រទេស នៅក្នុងរយៈពេល**៣៨០ថ្ងៃ** នៃយុទ្ធនាការនេះ ការចង្អៀតណែននៅក្នុងពន្ធនាគារត្រូវបានកាត់បន្ថយតាមរយៈ៖

- បុគ្គលដែលបានដោះលែងចេញពីពន្ធនាគារ ចំនួនប្រមាណ១៩ ៤៣០នាក់
- បុគ្គលនឹងត្រូវដោះលែង ចំនួនប្រមាណ៧ ០៨៧នាក់
- បុគ្គលដែលត្រូវបានសម្រេចមិនឃុំខ្លួន ចំនួនប្រមាណ៤ ០២០នាក់
- បុគ្គលដែលត្រូវបានបញ្ជូនទៅមណ្ឌលបន្សាបគ្រឿងញៀនជំនួសឱ្យការចោទប្រកាន់ និងបញ្ជូនទៅមណ្ឌលបន្សាបគ្រឿងញៀនដោយសមគ្គកិច្ច មានចំនួនប្រមាណ៨ ៧៦៤នាក់។

ជាសរុបនៅរយៈពេល៣៩៥ថ្ងៃនៃយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងតាមសាលាដំបូងរាជធានី ខេត្ត បានចូលរួមចំណែកក្នុងការកាត់បន្ថយភាពចង្អៀតណែន នូវបុគ្គលសរុបចំនួនប្រមាណ**៣៩ ៣០១នាក់**។

**៣.២.២- ការងារដោះស្រាយបណ្តឹងចូលមកក្រសួងយុត្តិធម៌**

**ក- ស្ថិតិសំណុំរឿងព្រហ្មទណ្ឌ**

**ក.១- ចំណាត់ការបណ្តឹងអន្តរាគមន៍**

| ប្រចាំឆ្នាំ | សល់ពីមុន | ចូលថ្មី | ចាត់ការរួច | កំពុងចាត់ការ |
|---|---|---|---|---|
| ២០១៨ | ៩៣រឿង | ៨៤រឿង | ១២១រឿង | ៥៦រឿង |
| ២០១៩ | ៥៦រឿង | ៥៤រឿង | ៨៨រឿង | ២២រឿង |
| ២០២០ | ២២រឿង | ១៩១រឿង | ១៨៧រឿង | ២៦រឿង |
| ២០២១ | ២៦រឿង | ១១៨រឿង | ៨៧រឿង | ៥៧រឿង |
| ២០២២ | ៥៧រឿង | ៤៨រឿង | ៥៦រឿង | ៤៩រឿង |
| សរុបរួម៖ | ៩៣រឿង | ៤៩៣រឿង | ៥៣៩រឿង | ៤៩រឿង |

**ក.២- ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី ខេត្ត**

| ឆ្នាំ | សល់ពីមុន | ចូលថ្មី | ចាត់ការរួច | កំពុងចាត់ការ |
|---|---|---|---|---|
| ២០១៨ | ១២ ០៥៨រឿង | ១៥ ៥៨៧រឿង | ១៥ ៩១៦រឿង | ១១ ៧២៩រឿង |
| ២០១៩ | ១១ ៧២៩រឿង | ១៧ ២៧៨រឿង | ១៧ ៧១៦រឿង | ១១ ២៩១រឿង |
| ២០២០ | ១១ ២៩១រឿង | ២៩ ៦២២រឿង | ៣៤ ៤២៥រឿង | ៦ ៤៨៨រឿង |
| ២០២១ | ៦ ៤៨៨រឿង | ១៩ ៣៥៦រឿង | ២០ ៣៦០រឿង | ៥ ៤៨៤រឿង |
| ២០២២(នព្វមាស) | ៥ ៤៨៤រឿង | ១៣ ៩៣១រឿង | ១៤ ២៨១រឿង | ៥ ១៣៤រឿង |

## ខ- ស្ថិតិសំណុំរឿងរដ្ឋប្បវេណី

### ខ.១- ចំណាត់ការបណ្តឹងអន្តរាគមន៍

| ប្រចាំឆ្នាំ | សល់ពីមុន | ចូលថ្មី | ចាត់ការរួច | កំពុងចាត់ការ |
|---|---|---|---|---|
| ២០១៨ | ៤៩ រឿង | ១៧៤ រឿង | ១៨១ រឿង | ៤២ រឿង |
| ២០១៩ | ៤២ រឿង | ២២៤ រឿង | ២២០ រឿង | ៤៦ រឿង |
| ២០២០ | ៤៦ រឿង | ២៧៧ រឿង | ២០២ រឿង | ១២១ រឿង |
| ២០២១ | ១២១ រឿង | ១៩៩ រឿង | ១៥០ រឿង | ១៧០ រឿង |
| ២០២២(ត្រឹមឆមាសទី១) | ១៧០ រឿង | ១១៥ រឿង | ៨៤ រឿង | ២០១ រឿង |
| សរុបរួម៖ | ៤៩ រឿង | ៩៨៩ រឿង | ៨៣៧ រឿង | ២០១ រឿង |

### ខ.២- ចំណាត់ការសំណុំរឿងរដ្ឋប្បវេណីរបស់សាលាដំបូងរាជធានី ខេត្ត

| ឆ្នាំ | សល់ពីមុន | ចូលថ្មី | ចាត់ការរួច | កំពុងចាត់ការ |
|---|---|---|---|---|
| ២០១៨ | ១៦ ០៩៤រឿង | ២៣ ៣២០រឿង | ២០ ៦២១រឿង | ១៨ ៧៩៣រឿង |
| ២០១៩ | ១៨ ៧៩៣រឿង | ២៧ ៧២៩រឿង | ២៦ ០៥៣រឿង | ២០ ៤៦៩រឿង |
| ២០២០ | ២០ ៤៦៩រឿង | ២៣ ០៥១រឿង | ២៣ ៥៨០រឿង | ១៩ ៩៤០រឿង |
| ២០២១ | ១៩ ៩៤០រឿង | ២២ ៦៥៣រឿង | ២២ ៤៩៨រឿង | ២០ ០៩៥រឿង |
| ២០២២(នព្វមាស) | ២០ ០៩៥រឿង | ២១ ៣៨០រឿង | ២០ ៨៣២រឿង | ២០ ៦៤៣រឿង |

### ៣.២.៣- ការងារដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងជំនួយផ្នែកច្បាប់

យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈមណ្ឌលសេវាកម្មយុត្តិធម៌ បានដាក់ឱ្យដំណើរការមណ្ឌលសេវាកម្មយុត្តិធម៌ចំនួន៦៨មណ្ឌលសេវាកម្មយុត្តិធម៌ ស្ថិតក្នុង១០រាជធានី ខេត្ត រួមមានរាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ មណ្ឌលគិរី កំពត កំពង់ឆ្នាំង បាត់ដំបង សៀមរាប រតនគិរី ព្រៃវែង ខេត្តបន្ទាយមានជ័យ។

តាមរយៈមណ្ឌលសេវាកម្មយុត្តិធម៌ ក្រសួងបានផ្តល់ការដោះស្រាយវិវាទ និងសម្រុះសម្រួលក្រៅប្រព័ន្ធតុលាការ សរុបមានចំនួន១០ ៤៦៨ករណី និងបានចាត់ការរួចចំនួន៩ ៨៨៨ករណី។

ចំពោះការផ្តល់សេវាសម្រុះសម្រួលវិវាទរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ សរុបមាន៦ ៣៧៤ករណី និងចាត់ការរួចចំនួន៦ ៣៥៥ករណី និងបានផ្តល់ការប្រឹក្សាយោបល់ផ្នែកច្បាប់ជូនប្រជាពលរដ្ឋសរុប៧ ២៩៧ដង។

ដើម្បីពង្រឹងកិច្ចការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈនាយកដ្ឋានសន្ទានកម្ម ក្រសួងបានរៀបចំវគ្គបណ្តុះបណ្តាលច្បាប់ និងនីតិវិធីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ៣១ដង រៀបចំសិក្ខាសាលាផ្សព្វផ្សាយព័ត៌មានមណ្ឌលសេវាកម្មយុត្តិធម៌៣៤ដង។

ការផ្តល់សេវាសម្រុះសម្រួលវិវាទរបស់មណ្ឌលសេវាកម្មយុត្តិធម៌

| ប្រចាំឆ្នាំ (មណ្ឌល) | សំណុំរឿងសល់ពីមុន | សំណុំរឿងចូលថ្មី | ចាត់ការរួច | | | កំពុងសម្រុះសម្រួល |
|---|---|---|---|---|---|---|
| | | | ព្រមព្រៀង | តម្កល់ | ចង្អុលបង្ហាញ | |
| ២០១៨ | ១៩៨ | ១ ១៥៧ | ៧៦៩ | ១៦៣ | ១៨៣ | ២៤០ |
| ២០១៩ | ២៤០ | ១ ៧៩៥ | ១ ០៧៩ | ៣៦៨ | ២៧៦ | ៣១២ |

| | | | | | | |
|---|---|---|---|---|---|---|
| ២០២០ | ៣១២ | ៣ ៧៩២ | ២ ០៣៤ | ៥២៣ | ៤៣១ | ១ ១១៣ |
| ២០២១ | ១ ១១៣ | ២ ១៨៣ | ១ ៦៥៧ | ៣៤០ | ៣៧៤ | ៩២៥ |
| ២០២២ (កញ្ញា) | ៩២៥ | ១ ៥៤១ | ១ ០៣៥ | ៤២១ | ២៣៥ | ៧៧៥ |

ការផ្តល់សេវាសម្រុះសម្រួលវិវាទរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់

| ប្រចាំឆ្នាំ (ឃុំសង្កាត់) | សំណុំរឿងសល់ពីមុន | សំណុំរឿងចូលថ្មី | ចាត់ការរួច | | | កំពុងសម្រុះសម្រួល |
|---|---|---|---|---|---|---|
| | | | ព្រមព្រៀង | តម្កល់ | ចង្អុលបង្ហាញ | |
| ២០១៨ | ២៧ | ១ ៣៧១ | ១ ០៨២ | ៦៩ | ១៨៨ | ៥៩ |
| ២០១៩ | ៥៩ | ១ ៥៦៦ | ១ ៣៨៣ | ៥៧ | ១៦១ | ២៤ |
| ២០២០ | ២៤ | ១ ៤៩០ | ១ ២៤៨ | ១៥ | ១៩៩ | ៥៣ |
| ២០២១ | ៥៣ | ១ ២៩១ | ១ ១០៩ | ១៨ | ១៣២ | ៨៥ |
| ២០២២(ខែកញ្ញា) | ៨៥ | ៦៥៦ | ៥៣៤ | ៧១ | ៨៩ | ៤៧ |

ការប្រឹក្សាយោបល់ផ្នែកច្បាប់ជូនប្រជាពលរដ្ឋ

| ប្រចាំឆ្នាំ | នាយកដ្ឋាន | មណ្ឌលសេវាកម្មយុត្តិធម៌ | គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ សង្កាត់ |
|---|---|---|---|
| ២០១៨ | ១១ | ១១៨៣ | ២៦១ |
| ២០១៩ | ១៤ | ១៨៥៦ | ៥៩៤ |
| ២០២០ | ២៨ | ១៦៨០ | ២៤២ |
| ២០២១ | ៣៤ | ១៥៨៩ | ៣៧៣ |
| ២០២២(ខែកញ្ញា) | ១៧ | ៩៨៩ | ៥៦០ |

### ៣.៣- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

(គេហទំព័រ www.monasri.gov.kh)

ក្រសួងបានទទួលពាក្យបណ្តឹងចំនួន៥៤៣បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន១៧១បណ្តឹង និងមន្ទីររាជធានី ខេត្តចំនួន៣៧២បណ្តឹង ក្នុងនោះ ឆ្នាំ២០១៨ ចំនួន៩២បណ្តឹង ឆ្នាំ២០១៩ ចំនួន១៣៥បណ្តឹង ឆ្នាំ២០២០ ចំនួន១២៩បណ្តឹង ឆ្នាំ២០២១ ចំនួន១១៨បណ្តឹង ឆ្នាំ២០២២ ចំនួន៦៩បណ្តឹង)៖

- ពាក្យបណ្តឹងរង់ចាំការសម្រេចពីថ្នាក់ដឹកនាំក្រសួង ចំនួន៤បណ្តឹង(ឆ្នាំ២០២២ ចំនួន៤បណ្តឹង)

- ពាក្យបណ្តឹងដែលជាសមត្ថកិច្ចមន្ទីររាជធានី ខេត្ត ចំនួន៣៥៤បណ្តឹង(ឆ្នាំ២០១៨ ចំនួន៥៨បណ្តឹង ឆ្នាំ២០១៩ ចំនួន៨៩បណ្តឹង ឆ្នាំ២០២០ ចំនួន៩៥បណ្តឹង ឆ្នាំ២០២១ ចំនួន៨០បណ្តឹង ឆ្នាំ២០២២ ចំនួន៣២បណ្តឹង)

- ពាក្យបណ្តឹងបានបញ្ជូនទៅស្ថាប័នផ្សេងដោះស្រាយ ចំនួន៨៩បណ្តឹង(អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៨១បណ្តឹង និងមន្ទីររាជធានី ខេត្ត ចំនួន៨បណ្តឹង ក្នុងនោះឆ្នាំ២០១៧ ចំនួន២បណ្តឹង ឆ្នាំ២០១៨ ចំនួន១៦

បណ្តឹង ឆ្នាំ២០១៩ ចំនួន១៩បណ្តឹង ឆ្នាំ២០២០ ចំនួន១៥បណ្តឹង ឆ្នាំ២០២១ ចំនួន២២បណ្តឹង ឆ្នាំ២០២២ ចំនួន១៥បណ្តឹង)

- ពាក្យបណ្តឹងដែលថ្នាក់ដឹកនាំក្រសួងសម្រេចតម្កល់ទុកមិនចាត់ការចំនួន១១បណ្តឹង (ឆ្នាំ២០១៨ ចំនួន២បណ្តឹង ឆ្នាំ២០១៩ ចំនួន១បណ្តឹង ឆ្នាំ២០២០ ចំនួន២បណ្តឹង ឆ្នាំ២០២១ ចំនួន២បណ្តឹង ឆ្នាំ២០២២ ចំនួន៤បណ្តឹង)

- ពាក្យបណ្តឹងដែលមន្ទីររាជធានី ខេត្តសម្រេចតម្កល់ទុកមិនចាត់ការ ចំនួន៥បណ្តឹង(ឆ្នាំ២០១៩ ចំនួន ២បណ្តឹង ឆ្នាំ២០២០ ចំនួន៣បណ្តឹង)

- ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងសុំដកវិញ ចំនួន១០បណ្តឹង (អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៣បណ្តឹង និងមន្ទីររាជធានី ខេត្ត ចំនួន៧បណ្តឹង ក្នុងនោះ ឆ្នាំ២០១៨ ចំនួន១បណ្តឹង ឆ្នាំ២០២០ ចំនួន២បណ្តឹង ឆ្នាំ២០២១ ចំនួន៤បណ្តឹង ឆ្នាំ២០២២ ចំនួន៣បណ្តឹង)

- ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងបានបោះបង់ចោល ចំនួន៥បណ្តឹង(មន្ទីររាជធានី ខេត្តចំនួន៥បណ្តឹង ក្នុងនោះ ឆ្នាំ២០២០ ចំនួន១បណ្តឹង ឆ្នាំ២០២១ ចំនួន២បណ្តឹង ឆ្នាំ២០២២ ចំនួន២បណ្តឹង)

- ពាក្យបណ្តឹងកំពុងសម្របសម្រួលថ្នាក់ក្រសួង ចំនួន៤បណ្តឹង(ឆ្នាំ២០២០ ចំនួន១បណ្តឹង ឆ្នាំ២០២១ ចំនួន៣បណ្តឹង)

- ពាក្យបណ្តឹងដែលបានចុះដំរុញខ្លឹមសារលិខិតរបស់រាជរដ្ឋាភិបាល ចំនួន១បណ្តឹង(ឆ្នាំ២០១៨ ចំនួន១បណ្តឹង)

- ពាក្យបណ្តឹងបានធ្វើរបាយការណ៍គោរពជូនឯកឧត្តមអភិបាលខេត្តកំពង់ស្ពឺ ពិនិត្យសម្រេច ចំនួន១១ បណ្តឹង(មន្ទីររាជធានី ខេត្តចំនួន១១បណ្តឹង ក្នុងនោះ ឆ្នាំ២០១៩ ចំនួន២បណ្តឹង ឆ្នាំ២០២០ ចំនួន៤បណ្តឹង ឆ្នាំ២០២១ ចំនួន៤បណ្តឹង ឆ្នាំ២០២២ ចំនួន១បណ្តឹង)

- ពាក្យបណ្តឹងកំពុងចុះអង្កេតស្រាវជ្រាវ ចំនួន៣១បណ្តឹង(អគ្គនាយកដ្ឋានអធិការកិច្ច ចំនួន១៧បណ្តឹង និងមន្ទីររាជធានី ខេត្ត ចំនួន១៤បណ្តឹង ក្នុងនោះឆ្នាំ២០១៦ ចំនួន១បណ្តឹង ឆ្នាំ២០១៩ ចំនួន២បណ្តឹង ឆ្នាំ២០២០ ចំនួន២បណ្តឹង ឆ្នាំ២០២១ ចំនួន៨បណ្តឹង ឆ្នាំ២០២២ ចំនួន១៨បណ្តឹង)

- ពាក្យបណ្តឹងបានទទួលការឆ្លើយតប ចំនួន៣៣បណ្តឹង(ឆ្នាំ២០១៤ ចំនួន១បណ្តឹង ឆ្នាំ២០១៦ ចំនួន ២បណ្តឹង ឆ្នាំ២០១៧ ចំនួន១បណ្តឹង ឆ្នាំ២០១៨ ចំនួន៦បណ្តឹង ឆ្នាំ២០១៩ ចំនួន១២បណ្តឹង ឆ្នាំ២០២០ ចំនួន២បណ្តឹង ឆ្នាំ២០២១ ចំនួន៦បណ្តឹង ឆ្នាំ២០២២ ចំនួន៣បណ្តឹង)

- ពាក្យបណ្តឹងដែលម្ចាស់បណ្តឹងសុំជំរុញការដោះស្រាយ ចំនួន២១បណ្តឹង(ឆ្នាំ២០១៦ ចំនួន៨បណ្តឹង ឆ្នាំ២០១៧ ចំនួន១បណ្តឹង ឆ្នាំ២០១៨ ចំនួន១បណ្តឹង ឆ្នាំ២០១៩ ចំនួន៦បណ្តឹង ឆ្នាំ២០២០ ចំនួន៣បណ្តឹង ឆ្នាំ២០២១ ចំនួន២បណ្តឹង)

- ពាក្យបណ្តឹងក្រសួងបានធ្វើលិខិតជំរុញការដោះស្រាយ ចំនួន១៨បណ្តឹង(ឆ្នាំ២០១៦ ចំនួន៧បណ្តឹង ឆ្នាំ២០១៧ ចំនួន១បណ្តឹង ឆ្នាំ២០១៩ ចំនួន៦បណ្តឹង ឆ្នាំ២០២០ ចំនួន៤បណ្តឹង)

- ពាក្យបណ្តឹងដែលបានចុះជំរុញការដោះស្រាយចំនួន១បណ្តឹង(ឆ្នាំ២០១៨ ចំនួន១បណ្តឹង)

- ពាក្យបណ្តឹងបានបញ្ចប់ការដោះស្រាយចំនួន១៩២បណ្តឹង(អគ្គនាយកដ្ឋានអធិការកិច្ចចំនួន៦១ បណ្តឹង និងមន្ទីររាជធានី ខេត្ត ចំនួន១៣១បណ្តឹង ក្នុងនោះ ឆ្នាំ២០១៤ ចំនួន៧បណ្តឹង ឆ្នាំ២០១៦ ចំនួន២បណ្តឹង ឆ្នាំ២០១៧ ចំនួន១០បណ្តឹង ឆ្នាំ២០១៨ ចំនួន៣៥បណ្តឹង ឆ្នាំ២០១៩ ចំនួន៤៣បណ្តឹង ឆ្នាំ២០២០ ចំនួន៥១ បណ្តឹង ឆ្នាំ២០២១ ចំនួន៣៦បណ្តឹង ឆ្នាំ២០២២ ចំនួន៨បណ្តឹង)។

**៣.៤- ក្រសួងធម្មការ និងសាសនា** (គេហទំព័រ www.mocar.gov.kh)

- ទទួលពាក្យបណ្ដឹង«អធិករណ៍» ក្នុងវិស័យសាសនា ចំនួន៧៦ករណី រួមមាន៖
  - សម្របសម្រួលដោះស្រាយបញ្ចប់អធិករណ៍ ចំនួន៤២ករណី
  - ចាត់បញ្ជូន បង្វែរអធិករណ៍ទៅអង្គភាពស្ថាប័នមានសមត្ថកិច្ចចំនួន២០ករណី
  - ម្ចាស់ដើមបណ្ដឹងបានសុំដកពាក្យបណ្ដឹង ចំនួន២ករណី
  - មិនចាត់ការពាក្យបណ្ដឹង «វិវាទសាសនា» ចំនួន១ករណី
  - កំពុងតាមដានការអនុវត្តសេចក្ដីសម្រេច ចំនួន១ករណី
  - កំពុងបន្តនីតិវិធីនៃការដោះស្រាយ ចំនួន៦ករណី
  - ចុះជំរុញដល់បណ្ដាមន្ទីររាជធានី ខេត្ត ដោះស្រាយអធិករណ៍រួច ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ ចំនួន៣ករណី
  - នៅសល់ពាក្យបណ្ដឹងនៃអធិករណ៍ ចំនួន១ករណី។
- បានទទួលរបាយការណ៍ពីមន្ទីរធម្មការ និងសាសនារាជធានី ខេត្ត ចំនួន៣៥ករណី
- ចូលបំភ្លឺករណីអធិករណ៍ជូនស្ថាប័នអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ និងខេត្តកំពង់ស្ពឺ សរុប ចំនួន៣ដង
- ចុះសម្រង់ទិន្នន័យករណីទំនាស់ដីធ្លីក្នុងវិស័យសាសនា ចំនួន៧ខេត្ត និងជំរុញពន្លឿនសម្រង់ទិន្នន័យចំនួន៤ខេត្ត។

**៣.៥- ការងារដោះស្រាយវិវាទដីធ្លី** (ផែក : Ministry of Land Management, Urban Planning and Construction Cambodia គេហទំព័រ www.mlmupc.gov.kh)

**៣.៥.១- ការដោះស្រាយវិវាទដីធ្លីដោយអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី**

| ឆ្នាំ | ករណីទទួលបាន | លទ្ធផល | | |
|---|---|---|---|---|
| | | បង្វែរ | ដោះស្រាយរួច | កំពុងដោះស្រាយ |
| ២០១៨ | ១ ៨១៥ | - | ១ ៧៦៤ | ៥១ |
| ២០១៩ | ៨៣ | ២ | ២ | ១៣០ |
| ២០២០ | ៤៥ | ៣ | ២៨ | ១៤៤ |
| ២០២១ | ១៦ | ១ | ៧ | ១៥២ |
| ៩ខែ ២០២២ | ២៧ | ១ | ៥ | ១៧៣ |
| **សរុប** | **១ ៩៨៦** | **៧** | **១ ៨០៦** | **១៧៣** |

គិតពីចាប់ផ្ដើមអនុវត្តដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានទទួលពាក្យបណ្ដឹងសរុបចំនួន១ ៩៨៦ករណី ដោះស្រាយបញ្ចប់នីតិវិធីសរុប១ ៨១៣ករណី(បញ្ចប់ស្ថាពរចំនួន១ ៨០៦ករណី បង្វែរចំនួន៧ករណី និងកំពុងដោះស្រាយ១៧៣ករណី)។

**៣.៥.២- ករណីវិវាទដីធ្លីដោយគណៈកម្មការសុរិយោដី**

| ឆ្នាំ | ករណីទទួលបាន | ករណីបានដោះស្រាយបញ្ចប់នីតិវិធី | ករណីកំពុងដោះស្រាយ | ចំនួនគ្រួសារដោះស្រាយបញ្ចប់ | ទំហំផ្ទៃដីដោះស្រាយបញ្ចប់ (ហិកតា) |
|---|---|---|---|---|---|
| ២០១៨ | ៥៤៤ | ៥១៥ | ៧៨៣ | ១ ៥១២ | ២៤៣,៩៦ |
| ២០១៩ | ៣៤៧ | ៣៥៩ | ៧៧១ | ១ ១៧៦ | ១៦៤,២៦ |

| | | | | | |
|---|---|---|---|---|---|
| ២០២០ | ២៦១ | ២៨០ | ៧៥២ | ៨៧២ | ៣៩,៣៧ |
| ២០២១ | ១៦៥ | ១៣៩ | ៧៧៨ | ២៤៧ | ៦០,០៧ |
| ៩ខែ ២០២២ | ២៤៤ | ១៩២ | ៨៣០ | ៣២០ | ៣១,៩៦ |
| **សរុប** | **១ ៥៦១** | **១ ៤៨៥** | **៨៣០** | **៤ ១២៧** | **៥៣៩,៦២** |

គិតពីចាប់ផ្តើមអនុវត្តដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ ទទួលពាក្យបណ្តឹងសរុបចំនួន៩ ៣៧០ករណី ដោះស្រាយបញ្ចប់នីតិវិធីសរុប៨ ៥៤០ករណី(បញ្ចប់ស្ពាពរចំនួន៤ ៤៤៧ករណី ច្រានចោលចំនួន៣ ០៨៤ករណី និងដកពាក្យបណ្តឹងចំនួន១ ០០៩ករណី) និងកំពុងដោះស្រាយ៨៣០ករណី។

**៣.៥.៣- ការដោះស្រាយវិវាទដីធ្លីដែលប្រជាពលរដ្ឋប្តឹងចូលមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

| ឆ្នាំ | ករណីទទួលបាន | ករណីដោះស្រាយបញ្ចប់ | ករណីបង្វែរទៅសមត្ថកិច្ចពាក់ព័ន្ធ និងឆ្លើយទៅសាមីសំណើ | ករណីកំពុងដោះស្រាយ |
|---|---|---|---|---|
| ២០១៨ | ៥៧១ | ៥២ | ៧៣ | ៨៤៨ |
| ២០១៩ | ៨៧៩ | ៨៤ | ២៥ | ១ ៦១៨ |
| ២០២០ | ៥៦៦ | ៥១ | ១៦ | ២ ១១៧ |
| ២០២១ | ២១១ | ៤២ | ១៣ | ២ ២៧៣ |
| ៩ខែ ២០២២ | ២៤៥ | ២៥ | ១២ | ២ ៤៨១ |
| **សរុប** | **២ ៤៧២** | **២៥៤** | **១៣៩** | **២ ៤៨១** |

គិតពីចាប់ផ្តើមអនុវត្តដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានទទួលពាក្យបណ្តឹងសរុបចំនួន៣ ១១៨ករណី ដោះស្រាយបញ្ចប់នីតិវិធីសរុប៦៣៧ករណី (បញ្ចប់ស្ពាពរចំនួន៣២៩ករណី ធ្វើលិខិតឆ្លើយតបទៅម្ចាស់បណ្តឹង និងបង្វែរទៅសមត្ថកិច្ចពាក់ព័ន្ធចំនួន៣០៨ករណី) និងកំពុងដោះស្រាយ២ ៤៨១ករណី។

- **លទ្ធផលនៃការដោះស្រាយវិវាទដីធ្លីដោយយន្តការទាំង៣**

| ឆ្នាំ | ករណីទទួលបាន | ករណីបានដោះស្រាយបញ្ចប់នីតិវិធី | ករណីកំពុងដោះស្រាយ |
|---|---|---|---|
| ២០១៨ | ២ ៩៣០ | ២ ៤០៤ | ១ ៦៨២ |
| ២០១៩ | ១ ៣០៩ | ៤៧២ | ២ ៥១៩ |
| ២០២០ | ៨៧២ | ៣៧៨ | ៣ ០១៣ |
| ២០២១ | ៣៩២ | ២០២ | ៣ ២០៣ |
| ៩ខែ ២០២២ | ៥១៦ | ២៣៥ | ៣ ៤៨៤ |
| **សរុប** | **៦ ០១៩** | **៣ ៦៩១** | **៣ ៤៨៤** |

គិតពីចាប់ផ្តើមអនុវត្តដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ ទទួលពាក្យបណ្តឹងសរុបចំនួន១៤ ៤៧៤ករណី ដោះស្រាយបញ្ចប់នីតិវិធីចំនួន១០ ៩៩០ករណី និងកំពុងដោះស្រាយចំនួន៣ ៤៨៤ករណី។

**៣.៦- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**(គេហទំព័រ www.mlvt.gov.kh)

ក្រសួងបានធ្វើការដោះស្រាយវិវាទការងារការនិងដោះស្រាយកូដកម្ម និងបាតុកម្ម សម្រេចលទ្ធផលដូចខាងក្រោមៈ

## ១- ការដោះស្រាយវិវាទការងារការ

| ល.រ | បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុបរួម |
|---|---|---|---|---|---|---|---|---|
| វិវាទបុគ្គល | | | | | | | | |
| ១ | ចំនួនវិវាទបុគ្គល | ករណី | ៤១៧ | ៥៧១ | ៥៥២ | ៦៩៥ | ៥៥៩ | **២ ៧៩៤** |
| ២ | សះជា | ករណី | ១៩៧ | ២៨៧ | ៣២៩ | ៤៥៣ | ២៨៧ | **១ ៥៥៣** |
| ៣ | មិនសះជា | ករណី | ១៦៣ | ២៥៤ | ១៨២ | ១៨២ | ២១៧ | **៩៩៨** |
| ៤ | មោឃៈ | ករណី | ៥៧ | ៣០ | ៤១ | ៦០ | ៥៥ | **២៤៣** |
| វិវាទការងាររួម | | | | | | | | |
| ១ | ចំនួនវិវាទការងាររួម | ករណី | ១៦៣ | ២៥៧ | ២៤៧ | ១៥៤ | ១៦៣ | **៩៨៤** |
| ២ | សះជា | ករណី | ៩៩ | ១២៨ | ១៥៦ | ១០០ | ១០១ | **៥៨៤** |
| ៣ | មិនសះជា | ករណី | ៦១ | ១២៣ | ៨៦ | ៤៨ | ៥៨ | **៣៧៦** |
| ៤ | មោឃៈ | ករណី | ៣ | ៦ | ៥ | ៦ | ៤ | **២៤** |
| សរុបរួម (១+២) | | | | | | | | |
| **១** | **ចំនួនវិវាទសរុប** | **ករណី** | **៥៨០** | **៨២៨** | **៧៩៩** | **៨៤៩** | **៧២២** | **៣ ៧៧៨** |
| **២** | **សះជា** | **ករណី** | **២៩៦** | **៤១៥** | **៤៨៥** | **៥៥៣** | **៣៨៨** | **២ ១៣៧** |
| **៣** | **មិនសះជា** | **ករណី** | **២២៤** | **៣៧៧** | **២៦៨** | **២៣០** | **២៧៥** | **១ ៣៧៤** |
| **៤** | **មោឃៈ** | **ករណី** | **៦០** | **៣៦** | **៤៦** | **៦៦** | **៥៩** | **២៦៧** |

## ២- ការដោះស្រាយកូដកម្ម និងបាតុកម្ម

| ល.រ | បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុបរួម |
|---|---|---|---|---|---|---|---|---|
| ក- ការដោះស្រាយករណីកូដកម្ម | | | | | | | | |
| ១ | ចំនួនកូដកម្ម | ករណី | ៤៧ | ៧៥ | ១៣៦ | ៦២ | ៣៨ | **៣៥៨** |
| ២ | អន្តរាគមន៍ | លើក | ៤៧ | ៧៥ | ១៣៦ | ៦២ | ៣៨ | **៣៥៨** |
| ៣ | សះជា | ករណី | ៤៧ | ៦៩ | ១៣២ | ៥៨ | ៣៦ | **៣៤២** |
| ៤ | មិនសះជា | ករណី | ០ | ៦ | ៤ | ៤ | ២ | **១៦** |
| ខ- ការដោះស្រាយករណីបាតុកម្ម | | | | | | | | |
| ១ | ចំនួនបាតុកម្ម | ករណី | ៥ | ១១ | ១៩ | ១៣ | ៤ | **៥២** |
| ២ | អន្តរាគមន៍ | លើក | ៥ | ១១ | ១៩ | ១៣ | ៤ | **៥២** |
| ៣ | សះជា | ករណី | ៥ | ៨ | ១៧ | ១៣ | ៤ | **៤៧** |
| ៤ | មិនសះជា | ករណី | ០ | ៣ | ២ | ០ | ០ | **៥** |

## ៤- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ (គេហទំព័រ www.mod.gov.kh)

### ៤.១- លទ្ធផលការងាររបស់កងយោធពលខេមរភូមិន្ទនៃក្រសួងការពារជាតិ

### ក- ការងារកែទម្រង់កងយោធពលខេមរភូមិន្ទ

ក្រសួងការពារជាតិបានបន្តយកចិត្តទុកដាក់អនុវត្តការធ្វើកំណែទម្រង់កងយោធពលខេមរភូមិន្ទ ស្របតាមផែនការនិងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីឆ្លើយតបវិធានការយុទ្ធសាស្ត្រនានាដែលបានដាក់ចេញនិងស្របតាមតម្រូវការចំពោះមុខ ដូចជាបានបង្កើតក្រុមការងារអ្នកច្បាប់ថ្នាក់ក្រសួង អគ្គបញ្ជាការដ្ឋាន ប្រភេទទ័ពនិងថ្នាក់យោធភូមិភាគ។ បង្កើតអង្គភាព**សេនាតេជោ** ចំណុះអគ្គនាយកដ្ឋាននយោបាយនិងកិច្ចការបរទេស។ បង្កើតកងវរសេនាតូចកាំភ្លើងធំ កងវរសេនាតូចកាំជ្រួចការពារអាកាសរយៈកម្ពស់ទាប កងវរសេនាតូចវិស្វកម្ម កងវរសេនាតូចកាំភ្លើងធំប្រតិកម្ម កងរុករកនិងសង្គ្រោះគ្រោះមហន្តរាយ កងកាំជ្រួចការពារអាកាសរយៈកម្ពស់មធ្យម ការិយាល័យជំនាញនានា សាលាហ្វឹកហ្វឺន បណ្ណាល័យ ផ្នែកទំនាក់ទំនងអន្តរជាតិ និងកងឯកភាពចាំបាច់ផ្សេងៗទៀតមួយចំនួន។ បានធ្វើការកែសម្រួលនិងប្តូរឈ្មោះក្បាលអង្គភាព សាលាហ្វឹកហ្វឺន ព្រមទាំងកែសម្រួលផ្ទេរក្រុមការងារទំនាក់ទំនងព្រំដែនកម្ពុជា ថៃ២៤ប្រក មកចំណុះកងទ័ពជើងគោក។ ក្រៅពីនេះ បានធ្វើការកែសម្រួលរចនាសម្ព័ន្ធនិងក្របខ័ណ្ឌចាត់តាំងចំនួនទ័ព ទីតាំងចំណុចឈរជើង និងពង្រឹងប្រព័ន្ធគ្រប់គ្រង ឋានានុក្រមដឹកនាំបញ្ជា ការងារហ្វឹកហ្វឺន ការងារអប់រំចិត្តសាស្ត្រ ការងារផ្សព្វផ្សាយព័ត៌មាន ការងាររដ្ឋបាល ការងារកសាងច្បាប់ និងការងារផ្សេងៗមួយចំនួន ព្រមទាំងយកចិត្តទុកដាក់គ្រប់គ្រងនិងពង្រឹងសមត្ថភាព គុណភាពយោធិនគ្រប់លំដាប់ថ្នាក់ គ្រប់ជំនាញនិងកសាងប្រភពនាយទាហានវ័យក្មេងសម្រាប់បន្តវេននាយទាហានដែលត្រូវចូលនិវត្តន៍។

បានបញ្ចប់ជាស្ថាពរការតាក់តែង«សៀវភៅ**សការពារជាតិ**ឆ្នាំ២០២២» **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់សច្ចាប័នរួច ព្រមទាំងបានបោះពុម្ពនិងធ្វើពិធីប្រកាសផ្សព្វផ្សាយជាផ្លូវការសៀវភៅ**សការពារជាតិ** ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ។**

ចំពោះការងារគ្រប់គ្រងស្ថិតិកងទ័ព ដោយមានការអនុញ្ញាតពីប្រមុខរាជរដ្ឋាភិបាល ក្រសួងការពារជាតិបានធ្វើការជ្រើសទ័ពថ្មីបំពេញក្របខ័ណ្ឌជូនបណ្តាកងឯកភាពមួយចំនួន និងជ្រើសរើសនិស្សិត សិស្សមកទទួលការបណ្តុះបណ្តាលនិងហ្វឹកហ្វឺនតាមរយៈការប្រឡងប្រជែងតាមផែនការឆ្នាំនីមួយៗ ដើម្បីជំនួសឱ្យយោធិនចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ យោធិនប្រភេទ២ សរុបចំនួន១៨ ៣២៨នាក់(ក្នុងនោះ បញ្ចូលក្របខ័ណ្ឌថ្មី ១០ ៤៤០នាក់និងបញ្ចូលក្របខ័ណ្ឌប្តូរជំនួសយោធិនអវត្តមានគ្មានមូលហេតុ ៧ ៨៨៨នាក់)។

បានធ្វើការតាមដាននិងស្រង់ព័ត៌មានប្រចាំថ្ងៃដែលប្រជាពលរដ្ឋសំណូមពរចូលក្នុងហ្វេសប៊ុករបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សរុបចំនួន៦៩៦សំណូមពរ និងបានយកចិត្តទុកដាក់ស្រាវជ្រាវឱ្យបានដាក់លាក់ ដើម្បីឆ្លើយតបបំភ្លឺនិងដោះស្រាយបានទាន់ពេលវេលា។

បន្ទាប់ពីវិមានអនុស្សាវរីយ៍**នយោបាយឈ្នះ ឈ្នះ** ដែលជានិមិត្តរូបនៃការបង្រួបបង្រួមជាតិ ឯកភាពជាតិ និងបញ្ចប់ទាំងស្រុងនូវភ្លើងសង្គ្រាម ត្រូវបានសម្ពោធជាផ្លូវការនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨ ក្រសួងការពារជាតិបានបន្តរៀបចំនិងកំពុងដំណើរការសាងសង់ស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ ៣កន្លែង និងវិមានសពយុទ្ធជន១កន្លែង នៅខេត្តកោះកុង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន និងបានចាត់តាំងប្រារព្ធពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៥ ទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត(២០ មិថុនា ១៩៧៧ - ២០ មិថុនា ២០២២) និងសម្ពោធសមិទ្ធផលនានាតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម(X16)

ស្ថិតនៅភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ទន្ទឹមនេះ បានចុះធ្វើការសិក្សាស្រាវជ្រាវរៀបចំកំណត់តំបន់ប្រវត្តិសាស្ត្រយោធាជាជំហានៗនៅតាមបណ្តាយោធភូមិភាគ និងសាងសង់ជាស្នាក់ការប្រវត្តិសាស្ត្រយោធាបានចំនួន១៣ទីតាំង ដើម្បីប្រមែប្រមូលតឹកតាងប្រវត្តិសាស្ត្រនានាមករក្សាទុកជាកេរដំណែលសម្រាប់កូនចៅជំនាន់ក្រោយសិក្សារៀនសូត្រ។

រាជរដ្ឋាភិបាលបានបង្កើនជាលំដាប់តាមការកែប្រែតម្លៃឯកតានៃសន្ទស្សន៍បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារកងយោធពលខេមរភូមិន្ទ ក្នុងនោះ បានអាទិភាពបង្កើនកម្រិតសន្ទស្សន៍ពីថ្នាក់ពលទាហានដល់ថ្នាក់វរសេនីយ៍ នាំឱ្យប្រាក់បៀវត្សប្រចាំខែរបស់ពលទាហានម្នាក់ៗគិតជាមធ្យមមកដល់ឆ្នាំ២០២០បានកើនដល់ ១ ១៥៨ ៥០០រៀល។ ដោយឡែកឆ្នាំ២០២១និងឆ្នាំ២០២២ បានរក្សាកម្រិតបៀវត្សនៅដដែលដោយសារវិបត្តិជំងឺកូវីដ-១៩។ ក្រៅពីនេះ ក៏មានការបង្កើនប្រាក់ហូបជូនយោធិនម្នាក់ៗក្នុងមួយថ្ងៃ៤ ២០០រៀល ការផ្តល់ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំថ្មី បុណ្យភ្ជុំបិណ្ឌជូនយោធិនគ្រប់រូប និងបានយកចិត្តទុកដាក់បន្តផ្តល់ប្រាក់ហូបបន្ថែមសមរភូមិមុខ ថែទាំបច្ចេកទេសគ្រឿងបំពាក់ ប្រេងឥន្ធនៈ ឯកសណ្ឋានកងទ័ព និងថវិកាជំនាញមួយចំនួនផងដែរ។

ការគ្រប់គ្រងសម្ភារៈគ្រឿងបំពាក់គ្រប់ប្រភេទនៅក្នុងកងយោធពលខេមរភូមិន្ទ ដូចជាយុទ្ធោបករណ៍ សម្ភារៈសឹក យន្តហោះ ឧទ្ធម្ភាគចក្រ នាវា រថយន្ត រថក្រោះ រថពាសដែក គ្រឿងចក្រ សម្ភារៈបញ្ជូនសារ សម្ភារៈសុខាភិបាល និងសម្ភារៈផ្សេងៗទៀតដែលមានស្រាប់ត្រូវបានធ្វើការថែទាំ ជួសជុលលើកកម្ពស់សុវត្ថិភាព គុណភាពសម្រាប់ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ក៏បានធ្វើការបំពាក់បន្ថែមថ្មីនិងកសាងនូវសមិទ្ធផលថ្មីៗមួយចំនួនដើម្បីបំពេញតម្រូវការចំពោះមុខ ដូចជាពង្រីកស្ថានីយវិទ្យុទាក់ទងនៅតាមយោធភូមិភាគ ពង្រីកប្រព័ន្ធរ៉ាដាការពារអាកាស រោងជាងជួសជុល ព្រមទាំងបំពាក់បន្ថែមយុទ្ធោបករណ៍ សម្ភារៈសឹក រថយន្តនិងគ្រឿងចក្រគ្រប់ប្រភេទ និងសម្ភារៈផ្សេងៗដែលទទួលបានពីការបញ្ជាទិញ ក៏ដូចជាកិច្ចសហប្រតិបត្តិការផ្តល់ជំនួយពីប្រទេសជាមិត្តនិងប្រទេសជាដៃគូបន្តបន្ទាប់ ដើម្បីធានាបាននូវប្រៀបការពារជាតិ។ ដោយឡែក នៅក្នុងរយៈ៩ខែដើមឆ្នាំ២០២២នេះ ក្រសួងការពារជាតិបានទទួលជំនួយពីសាធារណរដ្ឋកូរ៉េ នូវរថយន្តនិងគ្រឿងចក្រផ្សេងៗចំនួន៩៩គ្រឿង និងទទួលជំនួយឥតសំណងពីសាធារណរដ្ឋប្រជាមានិតចិន នូវការសាងសង់រោងជាងជួសជុលនាវា ផែសំចត និងស្ពានឃ្លាំងនៅមជ្ឈមណ្ឌលទំនើបកម្មមូលដ្ឋានសមុទ្ររាម និងទទួលរថយន្តគ្រប់ប្រភេទចំនួន៣លើកស្មើនឹង៣២៨គ្រឿង ព្រមទាំងសម្ភារៈផ្សេងៗជាច្រើន។

## ខ-ការកសាងបណ្តាញផ្លូវគមនាគមន៍ សំណង់អគារ

ក្រៅពីការបំពេញភារកិច្ចស្នូលខាងលើ កងយោធពលខេមរភូមិន្ទក៏មានកាតព្វកិច្ចចូលរួមចំណែកកសាងនិងជួសជុលបណ្តាញផ្លូវគមនាគមន៍ ស្ពាន លូ ប្រព័ន្ធធារាសាស្ត្រនិងសំណង់នានាដែលជាសមិទ្ធផលរបស់ជាតិមានការរីកចម្រើនដុះដាលពាសពេញទូទាំងផ្ទៃប្រទេស។ ចំពោះសមិទ្ធផលសំខាន់ៗរយៈពេល៥ឆ្នាំដែលសម្រេចបានមានដូចខាងក្រោម៖

- កសាងបណ្តាញផ្លូវគមនាគមន៍និងសំណង់ផ្សេងៗ

| ឆ្នាំ | ផ្លូវបេតុង | | ផ្លូវកៅស៊ូ | | ផ្លូវក្រួសក្រហម | | ស្ពានបេតុង | | ស្ពានដែក | | លូអ៊ុយ | | ដាទូឡូ | លូគ្រប់ប្រភេទ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខ្សែ | ម. | ខ្សែ | ម. | ខ្សែ | ម. | កន្លែង | ម | កន្លែង | ម. | ខ្សែ | ម. | | |
| ២០១៨ | ៥ | ៧ ៨២០ | ២៥ | ៩៧ ៦៥០ | ៦៤ | ៣៣០ ៥៥៧ | ៧ | ៩៩២ | | | | | ៣៤ | ៣៩៥ |
| ២០១៩ | ៨០ | ១៦ ៤៩១ | ៣០ | ១២១ ៣៥៧ | ៨០ | ៣៦២ ៩៥៥ | ១៤ | ៧២៥ | | | ៣ | ៤ ១៧០ | ៧០ | ៤៥៥ |
| ២០២០ | ៣២ | ៤៦ ៤៩១ | ៧១ | ៣២៦ ៦០៤ | ៨២ | ៤១០ ៩៦២ | ២១ | ៩៨៦ | ១ | ៩៦ | ២ | ២ ០០០ | ៦១ | ៦៣០ |

| | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០២១ | ១១ | ១៨ ៨៩៥ | ៤០ | ១៩៨ ៦៥៩ | ៧១ | ៤៣៩ ៤៣៧ | ១៨ | ៧៩០ | | | ៤ | ២ ៨០០ | ៧៥ | ៦៣៦ |
| ៩ខែ/២០២២ | ៧ | ៩ ៩២៩ | ២៥ | ១១០ ៣៧៣ | ២០ | ១០៥ ៥០០ | ១១ | ៥១៩ | | | ២ | ១ ៦០០ | ១៦ | ១៣៤ |
| **សរុប** | **១៣៥** | **៩៩ ៦២៦** | **១៩១** | **៨៥៤ ៦៤៣** | **៣១៧** | **១ ៦៤៩ ៤១១** | **៧១** | **៤០១២** | **១** | **៩៦** | **១១** | **១០ ៥៧០** | **២៥៦** | **២ ២៥០** |

- កសាងបណ្ដាញផ្លូវគមនាគមន៍តាមតំបន់ព្រំដែន ផ្លូវកៅស៊ូប្រវែង២៧ ៥៧០ម. ផ្លូវក្រួសក្រហមប្រវែង ៥៨៥ ៤៧៩ម. ផ្លូវកម្ទេចថ្មភ្នំប្រវែង១៨ ៨០០ម. ផ្លូវយោធាប្រវែង១៣៨ ៥០០ម. ស្ពានបេតុង៣២កន្លែងប្រវែង ១ ៥៨០ម. ស្ពានយោធា២២៨កន្លែង ប្រវែង១ ៩០១ម. លូជ្រុង៥៩កន្លែង ប្រវែង៤៥៩ម. លូមូលគ្រប់ប្រភេទ៧៦២ កន្លែង ទំនប់បង្ហៀរទឹក៣កន្លែងប្រវែង៣៩ម.។ ជួសជុលស្ដារឡើងវិញផ្លូវក្រួសក្រហមនិងផ្លូវកម្ទេចថ្មភ្នំប្រវែង ១៤១ ៨០០ម. ស្ពានបេតុង៧កន្លែងប្រវែង១៣៨ម. លូជ្រុង១៣កន្លែងប្រវែង៩៦ម.និងលូមូលគ្រប់ប្រភេទ៤៩កន្លែង។

ដោយឡែក ការកសាងនិងជួសជុលសំណង់ផ្សេងៗនៅក្នុងកងយោធពលខេមរភូមិន្ទ ដូចជាការកសាង អគារក្រសួងការពារជាតិ អគារមន្ទីរពេទ្យ អគារស្នាក់នៅ អគារសិក្សានិងអគារផ្សេងៗ ជំរុំជម្រក បន្ទាយ ផ្ទះសម្បែង កងទ័ពនិងគ្រួសារ ឃ្លាំងគ្រប់ប្រភេទ ផ្លូវយុទ្ធសាស្ត្រយោធា ទីលានបាញ់គ្រាប់ពិត និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ រួមទាំងការជួលជុលសំណង់គ្រប់ប្រភេទ មួយចំនួនបានមកពីការប្រើប្រាស់ថវិការដ្ឋ និងមួយចំនួនបណ្ដាអង្គភាព ម្ចាស់ការកសាងនិងការស្វះស្វែងរកធនធានថវិកាពីប្រភពផ្សេងៗ ដើម្បីអភិវឌ្ឍក្នុងអង្គភាព។

### គ-ការងារអតីតយុទ្ធជន

ក្រសួងការពារជាតិបានបើកផ្ដល់ប្រាក់ឧបត្ថម្ភគោលនយោបាយមួយលើកដំបូង ជូនយោធិនចូលនិវត្តន៍ ចេញពីជួរនិងយោធិនប្រភេទ២ និងផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖

| ឆ្នាំ | សោធននិវត្តន៍ | ចេញពីជួរ | ពលី មរណៈ | ពិការ | សរុប |
|---|---|---|---|---|---|
| ២០១៨ | ៥៤៩នាក់ | | ៤៧៦នាក់ | ៣៧០នាក់ | **១ ៣៩៥នាក់** |
| ២០១៩ | ៣ ៤៩៨នាក់ | ៧នាក់ | ២៧៨នាក់ | ១២៥នាក់ | **៣ ៩០៨នាក់** |
| ២០២០ | ២ ៣៧៣នាក់ | ១២នាក់ | ៣៣២នាក់ | ៦៥៨នាក់ | **៣ ៣៧៥នាក់** |
| ២០២១ | ១ ២៥៦នាក់ | | ៤៩៨នាក់ | ៣៩៨នាក់ | **២ ១៥២នាក់** |
| ២០២២ | ១១៩៦នាក់ | | ៤៣៩នាក់ | ៤០៨ | **២ ០៤៣នាក់** |
| សរុប | **៨ ៨៧២នាក់** | **១៩នាក់** | **២ ០២៣នាក់** | **១ ៩៥៩នាក់** | **១៣ ៨៧៣នាក់** |

សមាគមអតីតយុទ្ធជនកម្ពុជា បានទទួលអំណោយដ៏ថ្លៃថ្លារបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** នូវការសាងសង់ផ្ទះជូនសមាជិកអតីតយុទ្ធជនកម្ពុជា ដែលមានជីវភាពក្រីក្រលំបាក មានជម្រកស្នាក់នៅមិនសមរម្យ និងគ្មានដីគ្មានផ្ទះ រស់នៅលើដីសម្បទាន គិតត្រឹម ៩ខែដើមឆ្នាំ២០២២ ចំនួន៣ ៣៩៨ខ្នង។ បច្ចុប្បន្នសមាជិកអតីតយុទ្ធជនកម្ពុជា ដែលកំពុងទទួលរបបឧបត្ថម្ភ គោលនយោបាយរៀងរាល់ខែពីរដ្ឋ មានចំនួន៨០ ៦៦៧នាក់( និវត្តជន៣១ ០០៥នាក់ ជនបាត់បង់សមត្ថភាព ការងារ១ ៤៣៦នាក់ ជនពិការ២៦ ៩១៧នាក់ គ្រួសារពលី មរណៈ២១ ២៥៧នាក់ និងមន្ត្រីរាជការ៥២នាក់)។ ទន្ទឹមនេះ បានបើកប្រាក់បេឡាមរណៈសង្គ្រោះជូនគ្រួសារសពសមាជិកសមាគមអតីតយុទ្ធជនចំនួន៩ ១៧២សព (គិតត្រឹមថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២)។

ក្រសួងការពារជាតិមានមជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការចំនួន៣កន្លែង ស្ថិតនៅក្រោមការគ្រប់គ្រង។ បច្ចុប្បន្ន មានយោធិនពិការ គ្រួសារពលី នគរបាល គ្រួសារបញ្ជូនមកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង

យុវនីតិសម្បទា គ្រូបង្រៀននិងគ្រូពេទ្យរស់នៅសរុបចំនួន៩៩៨គ្រួសារ ក្នុងនោះ១- មជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ៣១៧ កោះស្លា ចំនួន១៧១គ្រួសារ ២- មជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ**សម្តេចតេជោ ហ៊ុន សែន** គូលែន៣១៧ ខេត្តសៀមរាបចំនួន២៩០គ្រួសារ និង៣- មជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ៣១៧ តេជោភ្នំធ្ងរ ចំនួន៥៣៧គ្រួសារ។

### ៤.២- លទ្ធផលការងាររបស់កងនគរបាលជាតិនៃក្រសួងមហាផ្ទៃ

ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ សភាពការណ៍សន្តិសុខសកលលោកមានការប្រែប្រួលយ៉ាងឆាប់រហ័សប្រកបដោយភាពស្មុគស្មាញនិងបង្កហានិភ័យនៅគ្រប់តំបន់បណ្តាលមកពីការប្រកួតប្រជែងកាន់តែស្រួចស្រាល់រវាងប្រទេសមហាអំណាចនានាការឆ្លងរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ និងមេរោគបំប្លែងថ្មីជាច្រើនប្រភេទបូករួមទាំងការផ្ទុះឡើងនៃសង្គ្រាមនៅអ៊ុយក្រែននិងការកើនឡើងនៃភាពតានតឹងនៅឆកសមុទ្រតៃវ៉ាន់ ឧបទ្វីបកូរ៉េនារយៈពេលចុងក្រោយនេះ។ ក្រៅពីនេះ បញ្ហាបម្រែបម្រួលអាកាសធាតុក៏បានបង្កភយន្តរាយយ៉ាងធ្ងន់ធ្ងរដល់អាយុជីវិតមនុស្សនិងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនានាស្ទើរគ្រប់តំបន់ផងដែរ។

បរិការណ៍ទាំងនេះ បានជះឥទ្ធិពលដោយផ្ទាល់និងប្រយោលដល់បរិយាកាសទូទៅនៅកម្ពុជា ជាពិសេសជុំវិញវិបត្តិនៃជំងឺកូវីដ-១៩ និងសង្គ្រាមនៅអ៊ុយក្រែនស្របពេលដែលនៅក្នុងផ្ទៃក្នុងប្រទេស សកម្មភាពប៉ុនប៉ងបង្កវិទ្ធង្សនាក្នុងសង្គមនៅមានលេចចេញអន្លើៗ បើទោះបីត្រូវរងការបរាជ័យជាច្រើនលើកច្រើនសាររួចមកហើយក្តី។ ថ្វីបើដូច្នេះមែន ក្នុងរយៈពេល៥ឆ្នាំនេះ កម្ពុជាមានមោទនភាពដោយនៅតែរក្សាបាននូវសុខសន្តិភាពពេញលេញ បរិបូណ៌ទូទាំងប្រទេស និងការឯកភាពផ្ទៃក្នុងជាតិ ស្ថាប័នកំពូលនានារបស់ជាតិនិងគ្រប់ព្រឹត្តិការណ៍នយោបាយ ព្រឹត្តិការណ៍ជាតិ អន្តរជាតិសំខាន់ៗត្រូវបានដំណើរការដោយរលូននិងមានសុវត្ថិភាពទាំងស្រុង បញ្ចៀសបាននូវអំពើភេរវកម្ម ខណៈដែលប្រទេសនៅក្នុងនិងក្រៅតំបន់រងការវាយប្រហារដោយអំពើនេះ ៥ ៧៩៤លើក/៥៥ ប្រទេស ព្រមទាំងទប់ស្កាត់បានដោយជោគជ័យនូវឧបាយកលនិងសកម្មភាពបដិវត្តន៍ពណ៌ដែលប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ខណៈសិទ្ធិសេរីភាពនៃការជួបជុំការសម្តែងមតិរបស់ប្រជាពលរដ្ឋគ្រប់ៗរូបត្រូវបានធានាស្របតាមរដ្ឋធម្មនុញ្ញ គោលការណ៍នីតិរដ្ឋនិងនិយាមនៃការលើកកម្ពស់យុត្តិធម៌សង្គម។

## ទី៤- ការពង្រឹងអភិបាលកិច្ចវិស័យឯកជន
## ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

**១- ការចុះធ្វើអធិការកិច្ចការងារ និងវិធានការចំពោះសហគ្រាសដែលប្រព្រឹត្តល្មើសច្បាប់**

| ល.រ | បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុបរួម |
|---|---|---|---|---|---|---|---|---|
| ១ | ការចុះអធិការកិច្ចការងារ | លើក | ៩ ៣៥០ | ៤ ៩២២ | ១ ៨២៤ | ១ ០៨២ | ៣ ៤៦៤ | **២០ ៦៤២** |
| ១.១ | ចុះធ្វើអធិការកិច្ចការងារសាមញ្ញ | លើក | ៨ ៤០២ | ៤ ០៩៥ | ១ ៦៥០ | ៩៩៣ | ៣ ៣៤៤ | **១៨ ៤៨៤** |
| ១.២ | ចុះធ្វើអធិការកិច្ចតាមដានការដាក់កំហិត | លើក | ៦១៩ | ៥៦១ | ៩០ | ៥ | ១០ | **១ ២៨៥** |
| ១.៣ | ចុះធ្វើអធិការកិច្ចពិសេស | លើក | ៣២៩ | ២៦៦ | ៨៤ | ៨៤ | ១១០ | **៨៧៣** |
| ២ | ដាក់កំហិត | សហ | ១ ០៥១ | ៩៧៧ | ៣១៨ | ៦៥ | ១៥៦ | **២ ៥៦៧** |

## ២- បច្ចុប្បន្នភាពការចុះបញ្ជិការោងចក្រ សហគ្រាស និងចំនួនកម្មករនិយោជិត

| បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| វិស័យកាត់ដេរ | សហគ្រាស | ១ ១៥៩ | ១ ២០៩ | ១ ១៩២ | ១ ២១៩ | ១ ៣១៣ |
| | កម្មករនិយោជិត | ៨២២ ០០៧ | ៨៥៥ ៤១៣ | ៨០២ ៧៦៥ | ៨៤ ៩៩៨៧ | ៩០១ ៦២៩ |
| | ស្រី | ៦៨៧ ៩៥២ | ៧១៦ ៨២៦ | ៦៦២ ៣១៥ | ៦៧៨ ៨៧៨ | ៧១៨ ៤៩៥ |
| ក្រៅពីវិស័យកាត់ដេរ | សហគ្រាស | ១១ ៦៣៧ | ១២ ៨៥១ | ១២ ៦១៥ | ១២ ៣៥២ | ១៥ ០៩៥ |
| | កម្មករនិយោជិត | ៤៩៨ ៥៤០ | ៥៧៨ ៥២២ | ៥៦ ៧៥៥០ | ៥៨៧ ២៩៤ | ៦៤៥ ១៦៤ |
| | ស្រី | ២០៩ ២៧៥ | ២៣១ ០៧៤ | ២៤០ ៣១៨ | ២៥២ ៥៤៧ | ២៧៥ ៥៧៦ |
| **សរុប** | **សហគ្រាស** | **១២ ៧៩៦** | **១៤ ០៦០** | **១៣ ៨០៧** | **១៣៥៧១** | **១៦៤០៨** |
| | **កម្មករនិយោជិត** | **១ ៣២០ ៥៤៧** | **១ ៤៣៣ ៩៣៥** | **១ ៣៧០ ៣១៥** | **១ ៤៣៧ ២៨១** | **១ ៥៤៦ ៧៩៣** |
| | **ស្រី** | **៨៩៧ ២២៧** | **៩៤៧ ៩០០** | **៩០២៦៣៣** | **៩៣១ ៤២៥** | **៩៩៤ ០៧១** |

## បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

បរិស្ថានគ្រប់ដណ្តប់ល្អប្រសើរ គឺជាមូលដ្ឋានគ្រឹះសម្រាប់អនុវត្តប្រកបដោយជោគជ័យនូវអាទិភាពគោលនយោបាយតាមផ្នែកនៃចតុកោណយុទ្ធសាស្ត្រទាំង៤ ដើម្បីធានាសម្រេចឱ្យបាននូវគោលដៅនៃការអភិវឌ្ឍ។ ជារួម កម្ពុជាត្រូវបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សុវត្ថិភាព និងពង្រឹងសណ្តាប់ធ្នាប់សាធារណៈ ដើម្បីបង្កលទ្ធភាពនិងការផ្តល់កាលានុវត្តក្នុងការបន្តដំណើរអភិវឌ្ឍន៍ទៅមុខ។

### ទី១- សន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សាធារណៈ

#### ១- កិច្ចការពារជាតិនិងថែរក្សាសន្តិសុខជាតិ

ស្ថិតក្រោមម្លប់ដ៏ត្រជាក់នៃ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** និងក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ព្រះរាជាណាចក្រកម្ពុជា ទទួលបាននូវសុខសន្តិភាពពេញលេញ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈល្អប្រសើរ ប្រទេសជាតិមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពកាន់តែរឹងមាំ បានកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជនជាបណ្តើរៗ។ ថ្វីបើនៅក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ កម្ពុជាទទួលរងផលប៉ះពាល់វិស័យមួយចំនួនពីវិបត្តិជំងឺកូវីដ-១៩ ប៉ុន្តែជារួម ស្ថិរភាពនយោបាយនិងសន្តិសុខសណ្តាប់ធ្នាប់សង្គមមានភាពល្អប្រសើរ ទទួលបាននូវការគាំទ្រពីមជ្ឈដ្ឋានជាតិនិងអន្តរជាតិ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការនានាជាបន្តបន្ទាប់ ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងបានខិតខំស្វែងរកវ៉ាក់សាំងជំងឺកូវីដ-១៩ មកចាក់ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃនៅទូទាំងប្រទេស ព្រមទាំងបានដោះស្រាយនូវផលប៉ះពាល់ដល់វិស័យឯកជន និងដាក់ចេញគោលនយោបាយឧបត្ថម្ភសាច់ប្រាក់ជូនកម្មករ កម្មការិនីដែលបាត់បង់ការងារក្នុងវិស័យកាត់ដេរ ទេសចរណ៍ គ្រួសារក្រីក្រនិងងាយរងគ្រោះ។

ព្រះរាជាណាចក្រកម្ពុជាបានបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៤ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨ បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ និងបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ ដែលព្រឹត្តិការណ៍ទាំងបីបានប្រព្រឹត្តទៅយ៉ាងរលូនប្រកបដោយជោគជ័យ ត្រូវបានមជ្ឈដ្ឋានជាតិ អន្តរជាតិវាយតម្លៃខ្ពស់ មានលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ គ្មានការគំរាមកំហែង គ្មានអំពើហិង្សា និងប្រកបដោយតម្លាភាព។ ទន្ទឹមនេះ ព្រះរាជាណាចក្រកម្ពុជាក្នុងនាមជាប្រធានអាស៊ានប្តូរវេនឆ្នាំ២០២២ បានដំណើរការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំនានាជាបន្តបន្ទាប់ទទួលបាននូវលទ្ធផលផ្លែផ្កា។

ដោយឡែក កងយោធពលខេមរភូមិន្ទ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចពិជ័យសេនា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** គ្រប់បណ្តាស្ថាប័ន អង្គភាពបានប្រមូលផ្តុំយកអស់ពីកម្លាំងកាយចិត្តអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់នូវតួនាទីភារកិច្ចរបស់ខ្លួនក្នុងវិស័យការពារជាតិនិងភារកិច្ចចាំបាច់មួយចំនួនដែលប្រមុខរាជរដ្ឋាភិបាលប្រគល់ជូន ពិសេសការបង្ក្រាបសកម្មភាពបំផ្លិចបំផ្លាញធនធានធម្មជាតិនានា ក៏ដូចជាការទន្ទ្រានកាន់កាប់ដីព្រៃលិចទឹកនៅតំបន់ទន្លេសាប ការនេសាទខុសច្បាប់ ព្រមទាំងការចូលរួមប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនកម្មករ កម្មការិនី និយោជក និងប្រជាពលរដ្ឋក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ និងតាមបណ្តាខេត្តផងដែរ។

### ១.១- កិច្ចការពារជាតិ និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

នៅក្នុងការអនុវត្តភារកិច្ចការពារជាតិមាតុភូមិ កងយោធពលខេមរភូមិន្ទបានពុះពារជម្នះគ្រប់ឧបសគ្គការពារ និងទប់ស្កាត់បានទាន់ពេលវេលានិងមានប្រសិទ្ធភាពពការប៉ុនប៉ងរំលោភបំពានពីសំណាក់ប្រទេសជិតខាងមកលើ អធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា នៅតាមខ្សែបន្ទាត់ព្រំដែន។ ថ្វីបើនៅពេលបច្ចុប្បន្ន សភាពការណ៍យោធានៅតាមតំបន់ព្រំដែនមានសភាពស្ងប់ស្ងាត់ ពុំមានអ្វីធំដុំគួរឱ្យកត់សម្គាល់ ក៏កងយោធពល ខេមរភូមិន្ទចាំបាច់នៅតែបន្តយកចិត្តទុកដាក់ពង្រឹងសមត្ថភាព និងត្រៀមខ្លួនជាប់ជានិច្ចដើម្បីឆ្លើយតបទៅនឹង សភាពការណ៍ណាមួយដែលអាចកើតឡើងជាយថាហេតុ ព្រមទាំងបានធ្វើការពង្រឹងនិងពង្រីកខឿនការពារជាតិ ដែលមានលក្ខណៈយុទ្ធសាស្ត្ររឹងមាំយូរអង្វែង ទាំងនៅតាមតំបន់ព្រំដែនគោកនិងបណ្តាកោះមួយចំនួន ដូចជា ការកសាង ថែទាំនិងជួសជុលផ្លូវយុទ្ធសាស្ត្រយោធានៅតាមតំបន់ព្រំដែន លេណដ្ឋានគ្រប់ប្រភេទ ជំរុំដម្រក បន្ទាយ កងទ័ព ភូមិឋាន ផ្ទះសម្បែង អណ្តូងទឹក ស្រះទឹក អាងស្តុកទឹក បោសសម្អាតគ្រាប់មីន ។ល។ ទន្ទឹមនេះបានធ្វើការ កែសម្រួលការគ្រប់គ្រងដឹកនាំបញ្ជា កែសម្រួលកម្លាំង កែសម្រួលទីតាំងឈរជើង និងធ្វើល្បាតជាប្រចាំត្រួតពិនិត្យ ភូមិសាស្ត្រទទួលខុសត្រូវ ដើម្បីគ្រប់គ្រងតាមដានសភាពការណ៍ប្រែប្រួល និងទប់ស្កាត់បង្ការបង្ក្រាបបទល្មើស គ្រប់ប្រភេទនៅតាមតំបន់ព្រំដែន និងសកម្មភាពឆ្លងដែនខុសច្បាប់ទៅវិញទៅមកនៃពលរដ្ឋទាំងសងខាង។

ដោយឡែក នៅក្នុងផ្ទៃប្រទេស កងយោធពលខេមរភូមិន្ទបានម្ចាស់ការនិងសហការចូលរួមយ៉ាងសកម្មបំផុត ក្នុងការគ្រប់គ្រងពង្រឹងការអនុវត្តច្បាប់ កសាងភូមិ ឃុំមានសុវត្ថិភាព ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការពារស្ថិរភាពនយោបាយ ទប់ស្កាត់និងបង្ការបង្ក្រាបសកម្មភាពល្មើសគ្រប់ប្រភេទ ភាពអនាធិបតេយ្យផ្សេងៗ ព្រមទាំងអនុវត្តបទបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាលក្នុងការបង្ក្រាបសកម្មភាពបំផ្លិចបំផ្លាញធនធានធម្មជាតិ ក៏ដូចជា ការទន្ទ្រានកាន់កាប់ដីព្រៃលិចទឹកនៅតំបន់ទន្លេសាប ការនេសាទខុសច្បាប់ និងសកម្មភាពគេចពន្ធ ដើម្បីរួមចំណែក កៀរគរបង្កើនប្រភពចំណូលថវិកាជាតិ។ ជាក់ស្តែង បានម្ចាស់ការស្រាវជ្រាវនិងបង្ក្រាបបទល្មើសឧក្រិដ្ឋ បទល្មើស មជ្ឈិមបានចំនួន១០ ៣០៣លើក ឃាត់ខ្លួនជនសង្ស័យបានចំនួន១៥ ៦០៩នាក់(ក្នុងនោះ រកឃើញជនពាក់ព័ន្ធ ចំនួន១៤ ៩១៩នាក់និងវត្ថុតាងមួយចំនួនបញ្ជូនទៅតុលាការ) រឹបអូសបាន ថ្នាំញៀនម្សៅស*ICE*ចំនួន២៥ ៦០១ កញ្ចប់ ស្មើ១០១ ៧១០,២៣ក្រាម ថ្នាំWYចំនួន១៣៣ ០៥១គ្រាប់និង៨កញ្ចប់ ស្មើ១៣ ០៩៨,២៤ក្រាម អ៊ិចស្តាស៊ី ២ ៤៧៧គ្រាប់ ១៦៤កញ្ចប់ និងប្រភេទទឹក១៣ដប ស្មើ៣ ៩១៤,៤២ក្រាម កូកាអ៊ីននិងហេរ៉ូអ៊ីន៧៣៩កញ្ចប់និង ៣ ០០៣គ្រាប់ ស្មើ១៣ ៩៦៤,៦ក្រាម កេតាមីន៧៥៧កញ្ចប់ ៨ ២៧១គ្រាប់ និងប្រភេទទឹក១៨១ដប ស្មើ ៦៦ ៨៩៥,៣៧ក្រាម កញ្ឆាក្រៀម១៧២,៤៧គ.ក្រ កញ្ឆាស្រស់១៥៥ ៩១៦ដើម ជញ្ជីងថ្លឹងថ្នាំញៀន១ ០៨៥ គ្រឿង ព្រមទាំងសម្ភារៈផ្សេងៗជាច្រើនទៀត ព្រមទាំងបានធ្វើការដោះស្រាយពាក្យបណ្តឹងផ្សេងៗបាន៦៥១បណ្តឹង និងអនុវត្តដីកាតុលាការបាន១១ ៣២៦ដីកា។

### ១.២- ការងារសង្គ្រោះ

ក្រសួងការពារជាតិមានមណ្ឌលស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន កងរាជអាវុធហត្ថខេត្តបាត់ដំបង ខេត្ត បន្ទាយមានជ័យ ខេត្តព្រះសីហនុ និងកងពលតូចលេខ៣១ យោធភូមិភាគទី៣ បានទទួលអ្នកញៀនគ្រឿងញៀន មកធ្វើការអប់រំនិងបន្សាបសារជាតុញៀន ជាសះស្បើយត្រឡប់ទៅលំនៅឋានវិញ បានចំនួន៥ ១៩៩នាក់។ ចូលរួម ជួយសង្គ្រោះប្រជាពលរដ្ឋជួបគ្រោះថ្នាក់ចរាចរណ៍ អគ្គិភ័យ គ្រោះធម្មជាតិនានា(គ្រោះរាំងស្ងួត ខ្យល់ព្យុះ ទឹកជំនន់ ។ល។) ពិសេស គ្រោះទឹកជំនន់ដ៏ធំធេងកាលពីឆ្នាំ២០២០ ដែលមានវត្តមានម្តងទៀតក្នុងរយៈពេល៧០ឆ្នាំកន្លងទៅ

និងករណីផ្សេងៗបានចំនួន២១ ៤១៨លើក ដឹកជញ្ជូនជនរងគ្រោះនិងអ្នកជំងឺទៅកាន់មន្ទីរពេទ្យបានចំនួន២ ៦៣៩ នាក់ សាកសពទៅកាន់លំនៅឋាននិងវត្តអារាមបានចំនួន៨០សព។

ទន្ទឹមនឹងការងារសង្គ្រោះគ្រោះមហន្តរាយនានា ក្រសួងការពារជាតិបានបញ្ជូនកម្លាំងទៅចូលរួមលំហាត់ហ្វឹកហ្វឺនសង្គ្រោះគ្រោះមហន្តរាយ៣ប្រទេស(កម្ពុជា ឡាវ វៀតណាម) នៅរដ្ឋធានីវៀងចន្ទន៍ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ រយៈពេល៥ថ្ងៃ(ពីថ្ងៃទី១០-១៥ ខែកញ្ញា ឆ្នាំ២០២២) ដែលមានកម្លាំងចូលរួមជាអាទិ៍វិស្វកម្ម ពេទ្យ ពិធីការ ដោយកម្ពុជាមានកម្លាំងចូលរួម៦០នាក់ ភាគីឡាវ២៩៣នាក់ និងភាគីវៀតណាម ១៥៧នាក់ និងមានការប្រើប្រាស់ឧទ្ធម្ភាគចក្រ ទូកល្បាត ទូកស្នាច់ ទូកខ្យល់ រថយន្តដឹកជញ្ជូន រថយន្តពេទ្យ រថយន្តគីមីសាស្ត្រ រថយន្តប្រតិបត្តិការផ្សេងៗ ព្រមទាំងឧបករណ៍សង្គ្រោះក្នុងទឹកនិងលើគោក។

**១.៣- ការងារកិច្ចការសង្គម**

បានចូលរួមយ៉ាងសកម្មជួយប្រជាពលរដ្ឋក្នុងការកសាង ជួសជុល និងរុះរើផ្ទះសម្បែង សំណង់ផ្សេងៗ ជួយកសាងផ្លូវ ស្ពាន បង្គន់អនាម័យ ស្រះទឹក អណ្ដូងទឹក ជួយការងារបង្កបង្កើនផល(ភ្ជួររាស់ ដកស្ទូង ច្រូតកាត់ បោកបែន ដាំដុះដំណាំនិងប្រមូលផល លើកភ្លឺស្រែ បូមទឹកដាក់ស្រែ) ជួយពិនិត្យព្យាបាលជំងឺ និងបានឧបត្ថម្ភជូនបងប្អូនប្រជាពលរដ្ឋដែលខ្វះខាតជួបការលំបាក ជាថវិកា ស្បៀងអាហារ សម្ភារៈផ្សេងៗ រួមទាំងសម្ភារៈការពារជំងឺកូវីដ-១៩មួយចំនួនផងដែរ។

**១.៤- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**

ក្នុងរយៈពេលពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ គ្រោះមហន្តរាយបានកើតមានជាបន្តបន្ទាប់ ហើយក៏មានគ្រោះមហន្តរាយថ្មីបន្ថែមទៀតដែលពុំធ្លាប់មាន ដូចជាការរលំបាក់អគារសំណង់ ជំងឺរាតត្បាតសកលកូវីដ-១៩ ជាដើម ហើយការគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានចូលរួមអនុវត្តយ៉ាងសកម្មពីគ្រប់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រប់តួអង្គពាក់ព័ន្ធ ក្រោមការដឹកនាំផ្ទាល់ពី**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។ ក្នុងការឆ្លើយតបសង្គ្រោះបន្ទាន់របស់រាជរដ្ឋាភិបាលក្នុងពេលគ្រោះមហន្តរាយម្តងៗត្រូវបាន **ព្រះករុណា ព្រះបាទព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គទាំងទ្វេទ្រង់សព្វព្រះរាជហឫទ័យចូលរួមជាមួយរាជរដ្ឋាភិបាល ប្រោសព្រះរាជទានព្រះរាជអំណោយដ៏ថ្លៃថ្លា ជួយសម្រាលទុក្ខលំបាករបស់កូនចៅព្រះអង្គដែលទទួលរងគ្រោះដោយគ្រោះមហន្តរាយ។ ហើយជាមួយនេះដែរ ក៏មានការបរិច្ចាគថវិកា សម្ភារៈ ដ៏ធំធេងចូលរួមជាមួយរាជរដ្ឋាភិបាល ដើម្បីរួមចំណែកជួយដល់ប្រជាជនរងគ្រោះដោយគ្រោះមហន្តរាយ ពីសំណាក់សម្តេច ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំ ស្ថាប័នជាតិ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ កាកបាទក្រហមកម្ពុជា អ្នកឧកញ៉ា ឧកញ៉ា សប្បុរសជន ក្រុមហ៊ុនឯកជន អង្គការជាតិ និងអន្តរជាតិ ប្រទេសជាមិត្តផងដែរ។

អាស្រ័យដោយស្មារតីសាមគ្គីភាពជួយគ្នាទៅវិញទៅមក និងការចូលរួមពេញលេញពីគ្រប់ភាគីពាក់ព័ន្ធក្រោមម្លប់សន្តិភាព ធ្វើឱ្យការគ្រប់គ្រងគ្រោះមហន្តរាយកន្លងមក អនុវត្តបានជោគជ័យ ដោះស្រាយចំគោលដៅ និងទាន់ពេលវេលា មិនមានប្រជាជនណាម្នាក់ស្លាប់ដោយខ្វះការទទួលខុសត្រូវ និងកាត់បន្ថយបានជាអតិបរមាពីផលប៉ះពាល់នៃព្រឹត្តិការណ៍អាក្រក់នានាដែលជាហានិភ័យគ្រោះមហន្តរាយ ព្រមទាំងការស្តារឡើងវិញ ផលិតកម្មកសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធជនបទបានទាន់ពេលវេលា ដើម្បីបម្រើសំណូមពរប្រជាជនរងគ្រោះ។

## ១.៥- ទឹកជំនន់ (ជំនន់ទឹកភ្លៀង «ជំនន់របស់» និងជំនន់ទឹកទន្លេ)

### ក- ផលប៉ះពាល់ទៅលើប្រជាជន

(គ្រ=គ្រួសារ, ន=នាក់)

| ផលប៉ះពាល់ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(៩ខែ) | សរុប |
|---|---|---|---|---|---|---|
| ប្រជាជនរងគ្រោះ | ១៩ ២០០គ្រ | ១១៩ ៣០០គ្រ | ២២២ ៨៩០គ្រ | ៤៩ ២៣៦គ្រ | ៨២ ២៩៦គ្រ | ៤៩២ ៩២២គ្រ |
| ប្រជាជនស្លាប់ | ១៧ន | ៣០ន | ៥៨ន | ១៤ន | ១៥ន | ១៣៤ន |

ប្រភព : គ.ជ.គ.ម.

ចំនួនប្រជាជនរងគ្រោះដោយទឹកជំនន់




ចំនួនប្រជាជនស្លាប់ដោយទឹកជំនន់




### ខ- ការខូចខាតវិស័យសង្គម

(ខ្ន=ខ្នង, ក=កន្លែង)

| ការខូចខាត | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(៩ខែ) | សរុប |
|---|---|---|---|---|---|---|
| ផ្ទះ | ២៤១ខ្ន | ២០៣ខ្ន | ៧៤ខ្ន | ០ | ១៨៩ខ្ន | ៧០៧ខ្ន |
| សាលារៀន | ១៤ក | ៧ក | ២ក | ០ | ៥ក | ២៨ក |
| មន្ទីរពេទ្យ/មណ្ឌលសុខភាព | ២៨ក | ៣៧ក | ៣៦ក | ១១ក | ១៦ក | ១២៨ក |

ប្រភព : គ.ជ.គ.ម.

### ការខូចខាតផ្ទះ សាលារៀន មន្ទីរពេទ្យមណ្ឌលសុខភាពដោយទឹកជំនន់




## គ- ការខូចខាតវិស័យកសិកម្ម

(ហ.ត.=ហិកតា)

| ការខូចខាត | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) | សរុប |
|---|---|---|---|---|---|---|
| សន្ទូង/ពង្រោះ (ហ.ត) | ៥ ៤៣៣ | ២០ ៦៦០ | ១២ ៧៦៣ | ៤៥ ២៤៩ | ៣០ ៥០៦ | ១១៤ ៦១១ |
| ដំណាំ(ហ.ត) | ១១ ៣៨០ | ២ ២៣០ | ៤៧ ៦២០ | ៥ ៥៦០ | ៤៥៥ | ៦៧ ២៤៥ |

ប្រភព : គ.ជ.គ.ម.

### ការខូចខាតសន្ទូងពង្រោះ និងដំណាំដោយទឹកជំនន់



### ឃ. ការខូចខាតលើវិស័យហេដ្ឋារចនាសម្ព័ន្ធ

(ម=ម៉ែត្រ ក=កន្លែង)

| ការខូចខាត | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(៩ខែ) | សរុប |
|---|---|---|---|---|---|---|
| ផ្លូវជាតិ ខេត្ត (ម) | ៣៦០ | ៣៥៤ | ២៣ ៤៥៧ | ០ | ០ | ២៤ ១៧១ |
| ផ្លូវលំ (ម) | ២៧៨ ៤២០ | ៣ ១៥៦ | ៣ ១៥៤ ១៤០ | ០ | ០ | ៣ ៤៣៥ ៧១៦ |
| ស្ពាន (ក) | ១៥៦ | ៧០ | ៥២ | ៤៥ | ៤៥ | ៣៦៨ |
| ទំនប់ (ម) | ៤,៣០០ | ១៥៩ ៧៩០ | ៦៦ ៩៨០ | ១៦ | ៤៤,៧១២ | ២៧៥ ៧៩៨ |

ប្រភព៖ គ.ជ.គ.ម.

## ១.៦- រាំងស្ងួត

(ហ.ត.=ហិកតា)

| ការខូចខាត | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) | សរុប |
|---|---|---|---|---|---|---|
| សន្ទូង/ពង្រោះ (ហ.ត) | ២៨ ៤១០ | ៦៧ ៦៦០ | ១៤ ១៦០ | ៣៤ ៣៧៩ | ០ | ១៤៤ ៦០៩ |
| ដំណាំផ្សេងៗ (ហ.ត) | ២ ៩៧០ | ៧ ៧៥០ | | ៣៧៩ | ០ | ១១ ០៩៩ |

ប្រភព៖ គ.ជ.គ.ម.

ការខូចខាតសន្ទូងពង្រោះ និងដំណាំផ្សេងៗដោយរាំងស្ងួត



## ១.៧- ខ្យល់កន្ត្រាក់

(ល=លើក, ន=នាក់, ត=តូប, ក=កន្លែង)

| ការខូចខាត | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(៩ខែ) | សរុប |
|---|---|---|---|---|---|---|
| កើតមាន | ១៩៩ល. | ៣៣៦ល. | ២៥០ល. | ២១០ល. | ១៥៦ល. | ១ ១៥១ល. |
| ស្លាប់មនុស្ស | ៦ន. | ៨ន. | ៦ន. | ៩ន. | ៣ន. | ៣២ន. |
| របួស | ៤៤ន. | ១៣១ន. | ៧៨ន. | ៧៦ន. | ៥៩ន. | ៣៨៨ន. |
| រលំផ្ទះ | ៦៤៥ខ្ន. | ១៦៤៥ខ្ន. | ១ ០៣២ខ្ន. | ១ ០២២ខ្ន. | ៩៤៣ខ្ន. | ៥ ២៨៧ខ្ន. |
| សាលារៀន | ២៩ខ្ន. | ១៣ខ្ន. | ៣៨ខ្ន. | ៤៨ខ្ន. | ៣៨ខ្ន. | ១៦៦ខ្ន. |
| តូបផ្សារ | | ៦៨ត. | ៦ត. | ១១២ត. | ១៣ត. | ១៩៩ត. |
| អគាររដ្ឋបាល | ១២ក. | ៩៣ក. | ៣០ក. | ២៣ក. | ៦ក. | ៧១ក. |

ប្រភព៖ គ.ជ.គ.ម.

### ចំនួនគ្រោះមហន្តរាយដែលកើតមានដោយសារខ្យល់កន្ត្រាក់




### ចំនួនមនុស្សស្លាប់និងរបួសដោយសារខ្យល់កន្ត្រាក់



## ការខូចខាតផ្ទះ សាលារៀន តូបផ្សារ និងអគាររដ្ឋបាលដោយសារខ្យល់កន្ត្រាក់




## ១.៨- រន្ទះបាញ់

(លៈ=លើក, នៈ=នាក់)

| ការខូចខាត | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(៩ខែ) | សរុប |
|---|---|---|---|---|---|---|
| កើតមាន | ១៤០ល. | ១៤១ល. | ១០១ល. | ១១៨ល. | ៩៥ល. | ៥៩៥ល. |
| ស្លាប់មនុស្ស | ១១០ន. | ៩៥ន. | ៦៩ន. | ៨៣ន. | ៥៣ន. | ៤១០ន. |
| របួស | ៨២ន. | ៨៣ន. | ៥៦ន. | ៥០ន. | ៤៩ន. | ៣២០ន. |

ប្រភព៖ គ.ជ.គ.ម.

### រូបភាពទី១ ចំនួនគ្រោះមហន្តរាយដែលកើតមានដោយរន្ទះបាញ់




### រូបភាពទី២ ចំនួនមនុស្សស្លាប់និងរបួសដោយរន្ទះបាញ់



## ១.៩- បាក់ច្រាំងទន្លេ និងស្ទឹង

(ម=ម៉ែត្រ ខ្ន=ខ្នង, ក=កន្លែង)

| ការខូចខាត | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(៩ខែ) | សរុប |
|---|---|---|---|---|---|---|
| ប្រវែង(ទទឹងមធ្យម១៥ម.) | ១១ ៤៦៤ម. | ២៥ ៦៧០ម. | ៤ ០៨០ម. | ២ ១៦៧ម. | ២ ៣៣៦ម. និង ទទឹង៥-២៥ម. | ៤៥ ៧១៧ម. |
| ផ្ទះបាត់បង់ | ២០ខ្ន. | ៩ខ្ន | ២ខ្ន. | ៩ខ្ន. | ១៥ខ្ន. | ៥៥ខ្ន. |
| ផ្ទះរុះរើ | ២៤១ខ្ន. | ១០៨ខ្ន. | ២៧ខ្ន. | ៥៧ខ្ន. | ៦២ខ្ន | ៤៩៥ខ្ន. |
| វត្ត | ៥ក. | ២ក. | ២ក. | ០ | ០ | ៩ក. |
| មណ្ឌលសុខភាព និងមន្ទីរពេទ្យ | ១ក. | | ១ក. | ០ | ០ | ២ក. |
| ស្លាប់មនុស្ស | ១ន. | | | ១ន. | ៤ន. | ៦ន. |

ប្រភព: គ.ជ.គ.ម.

**ចំនួនប្រវែងបាក់ច្រាំងទន្លេ ស្ទឹង**






## ១.១០- ការរលំបាក់អគារ

| ថ្ងៃ. ខែ. ឆ្នាំ. | ទីកន្លែង | សំណង់ | រងគ្រោះ | របួស | ស្លាប់ |
|---|---|---|---|---|---|
| ២២-៦-២០១៩ | ខេត្តព្រះសីហនុ | អគារ៧ជាន់ | ៥៤នាក់ | ២៦នាក់(ស្រី២) | ១៨នាក់(ស្រី៤) |
| ០២-១២-២០១៩ | ខេត្តសៀមរាប | សាលាធម្មសភា | ១៦អង្គ/នាក់ | ១៣នាក់ | ៣នាក់ |
| ០៣-០១-២០២០ | ខេត្តកែប | អគារ៦ជាន់ | ៥៩នាក់ | ២៣នាក់(ស្រី៨) | ៣៦នាក់(ស្រី១៤) |
| ១២-០៨-២០២០ | ខេត្តបន្ទាយមានជ័យ | ម៉ាស៊ីនស្ទូចបាក់លើផ្ទះ១ខ្នង | ១០នាក់ | ៥នាក់(ស្រី) | ៥នាក់(ស្រី) |
| ០៧-០៨-២០២១ | ខេត្តបន្ទាយមានជ័យ (ប៉ោយប៉ែត) | អគារបេតុងក្នុងគម្រោង៦ជាន់ | ៨នាក់ | ៨នាក់ | |
| ១០-០៨-២០២២ | រាជធានីភ្នំពេញ | ប្លង់សេរីវ៉េងដា | ២នាក់ | ១នាក់ | ១នាក់ |

ប្រភព៖ គ.ជ.គ.ម.

## ១.១១- ការងារប្រតិបត្តិការឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញ

### ១.១១.១- ការឆ្លើយតបសង្គ្រោះបន្ទាន់

**ឆ្នាំ២០១៩**

**ក- ការរលំបាក់អគារនៅខេត្តព្រះសីហនុ**

- ប្រើប្រាស់កម្លាំងរុករក សង្គ្រោះ និងការពារសណ្តាប់ធ្នាប់**១៦៥នាក់** នៃចំនួន**១២អង្គភាព** ប្រើប្រាស់រយៈពេលពីយប់បីថ្ងៃ

- ឧបត្ថម្ភសាច់ប្រាក់អ្នកស្លាប់ **២៨នាក់** x **៤០ ០០០ ០០០៛**/នាក់=**១ ១២០ ០០០ ០០០៛**

- ឧបត្ថម្ភសាច់ប្រាក់អ្នករបួស **២៦នាក់** x **៤០ ០០០ ០០០៛**/នាក់= **១៣០ ០០០ ០០០៛**

**សរុប = ១ ២៥០ ០០០ ០០០៛។**

**ខ- ការរលំបាក់សាលាធម្មសភានៅខេត្តសៀមរាប**

- ប្រើប្រាស់កម្លាំងរុករក សង្គ្រោះ ៧១១ ចំនួន **៨នាក់** រួមនឹងកម្លាំង គ.គ.ម.ខេត្ត

- ឧបត្ថម្ភសាច់ប្រាក់អ្នកស្លាប់ **៣នាក់** x **២៤ ៧០០ ០០០រៀល**/នាក់ = **៧៤ ០០០ ០០០រៀល**

- ឧបត្ថម្ភសាច់ប្រាក់អ្នករបួស **១៣នាក់** x **៤ ៤០០ ០០០រៀល**/នាក់ = **៥៧ ០០០ ០០០រៀល**

**សរុប = ១៣១ ០០០ ០០០រៀល។**

**គ- ទឹកជំនន់(ជំនន់ទន្លេនិងជំនន់ទឹកភ្លៀង)**

- ប្រើប្រាស់កម្លាំងកងយោធពលខេមរភូមិន្ទ នគរបាលជាតិ កងអង្គរក្ស កងរាជអាវុធហត្ថសរុប ៨២ ៥០០នាក់ រថយន្ត១ ១០៦គ្រឿង ម៉ូតូ១៩២គ្រឿង អូប័រ១៧៩គ្រឿង ទូកម៉ាស៊ីន៣២០គ្រឿង

- អង្ករប្រើប្រាស់អស់២៣៥តោន

-ថវិកាប្រើប្រាស់អស់២៧៥ ០០០ ០០០រៀល។

**ឆ្នាំ២០២០**

**ក- ការរលំបាក់អគារនៅខេត្តកែប**

- ប្រើប្រាស់កម្លាំងរុករក សង្គ្រោះ និងការពារសណ្តាប់ធ្នាប់**៣ ៧១៣នាក់** ប្រើប្រាស់រយៈពេល៤៣ម៉ោង និង២០នាទី

- ឧបត្ថម្ភសាច់ប្រាក់អ្នកស្លាប់ **៣៦នាក់** x **២១០ ០០០ ០០០៛**/នាក់= **៧ ៥៦០ ០០០ ០០០រៀល**

- ឧបត្ថម្ភសាច់ប្រាក់អ្នករបួសធ្ងន់ **១៦នាក់**x ៤០ ០០០ ០០០៛/នាក់ = **៦៤០ ០០០ ០០០រៀល**

- ឧបត្ថម្ភសាច់ប្រាក់អ្នករបួសស្រាល **៧នាក់** x ៨០ ០០០ ០០០៛/នាក់ = **៥៦០ ០០០ ០០០រៀល**

សរុប = ៨ ៧៦០ ០០០ ០០០រៀល។

**ខ- ទឹកជំនន់(ជំនន់ទឹកភ្លៀងនិងជំនន់រហ័ស)**

សរុបជំនួយសង្គ្រោះបន្ទាន់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មានអង្ករ ឃីត គ្រឿងឧបភោគបរិភោគ ថវិកាជូនជនរងគ្រោះចំនួន**១២៨ ៧១៩គ្រួសារ** អ្នកស្លាប់**៥៨នាក់** ជូនដល់រដ្ឋបាលខេត្ត**១០ខេត្ត** កម្លាំងអន្តរាគមន៍ និងដឹកជញ្ជូនសរុប**៦ ៤០៩ ៥៦៩ដុល្លារអាម៉េរិក**(គិតជាប្រាក់រៀល**២៥ ៦៣៨ ២៧០ ០០០ រៀល**)។

**ឆ្នាំ២០២១**

**ក- ទឹកជំនន់(ជំនន់ទឹកភ្លៀងនិងជំនន់រហ័ស)**

- ផ្តល់ថវិកាឧបត្ថម្ភជូនប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់ នៅខេត្តបន្ទាយមានជ័យចំនួន**១១ ០០០ គ្រួសារ** សម្រាប់រយៈពេល៣ខែ ដែលមានថវិកាសរុប **៥ ២៨០ ០០០លានរៀល** ស្មើនឹង**១ ៣២លានដុល្លារអាម៉េរិក**

- អំណោយជាស្បៀងនិងគ្រឿងឧបភោគបរិភោគ ចំនួន**៦៥០ឃីត** ដល់ខេត្តឧត្តរមានជ័យ សម្រាប់ចែកចាយដល់ប្រជាពលរដ្ឋក្រីក្រ និងថវិកាជូនស្រុកអន្លង់វែង**១២លានរៀល** និងស្រុកត្រពាំងប្រាសាទ**១២លានរៀល**

- ផ្តល់អំណោយជាស្បៀង និងគ្រឿងឧបភោគបរិភោគជូនគ្រួសារកងទ័ពនៅបញ្ជាការដ្ឋានការពារកោះធ្មេរ ចំនួន**១៦០គ្រួសារ** និងនៅបញ្ជាការដ្ឋានទ័ពពិសេស ចំនួន**២៩៣គ្រួសារ។**

- ផ្តល់អំណោយជូនប្រជាពលរដ្ឋរងគ្រោះដោយខ្យល់កន្ត្រាក់ ចំនួន**៥៦៥គ្រួសារ** នៅក្នុងខេត្តតាកែវ ដែលក្នុងនេះមានការចូលរួមចំណែកពីអង្គការកាកបាទក្រហមកម្ពុជា ចំនួន**៣០០គ្រួសារ** និងថវិកាឧបត្ថម្ភរបស់ឯកឧត្តមនាយឧត្តមសេនីយ៍ កិត្តិសង្គហបណ្ឌិតទេសរដ្ឋមន្ត្រី និងឯកឧត្តមអនុប្រធាន និងជាទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ចំនួន **៦០លានរៀល**

- ផ្តល់អំណោយជូនប្រជាពលរដ្ឋរងគ្រោះដោយទឹកជំនន់នៅខេត្តបន្ទាយមានជ័យ ចំនួន១ ១៩៨ គ្រួសារ និងប្រជាពលរដ្ឋរងគ្រោះនៅខេត្តរតនគិរី មានអង្ករ១០តោន មីកញ្ចប់៤០០កេស ត្រីខ៤០០យួរ ទឹកត្រី និងទឹកស៊ីអ៊ីវ៤០០យួរ។

**ឆ្នាំ២០២២**

**ក- ទឹកជំនន់(ជំនន់ទឹកភ្លៀងនិងជំនន់រហ័ស)**

សរុបជំនួយសង្គ្រោះបន្ទាន់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មានអង្ករ ឃីត គ្រឿងឧបភោគបរិភោគ ថវិកាជូនជនរងគ្រោះចំនួន**៤១ ៥៩៥គ្រួសារ** ថវិកា**៧៥០ ០០០ដុល្លារអាម៉េរិក។**

**១.១១.២- ការងាររុករកសង្គ្រោះ**

- បានបង្កើតក្រុមប្រតិបត្តិការរុករកនិងសង្គ្រោះចំនួន១៦កង ព្រមជាមួយការបំពាក់ឧបករណ៍ សម្ភារៈចំនួន១៥មុខ ក្នុង១កង(ដូចមានតារាងឧបសម្ព័ន្ធ)

- បានធ្វើលំហាត់សាកល្បងលើតុនិងតាមទីវាល ដើម្បីពង្រឹងសមត្ថភាពរុករក សង្គ្រោះ ឆ្លើយតបពេលទឹកជំនន់ រលំបាក់អគារ ដោយមានការចូលរួមពីកងយោធពលខេមរភូមិន្ទ នគរបាលជាតិ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

### ១.១១.៣- ការងារស្តារឡើងវិញ

- បានធ្វើសិក្ខាសាលាបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ ស្តីពីការប៉ាន់ប្រមាណតម្រូវការក្រោយគ្រោះមហន្តរាយ(PDNA) និងក្របខ័ណ្ឌស្តារឡើងវិញក្រោយគ្រោះមហន្តរាយ(DRF) លើវិស័យដឹកជញ្ជូន(ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២១)

- កសាងទីទួលសុវត្ថិភាពជាអគារសំណង់បាន**៦កន្លែង**(មានកន្លែងសម្រាក ផ្ទះបាយ បន្ទប់ទឹក ឃ្លាំង កន្លែងបោកគក់ លាងដៃ អណ្តូងទឹក អាងស្តុកទឹក បំពាក់ម៉ាស៊ីនភ្លើង ប្រព័ន្ធសូឡា ប្រព័ន្ធការពាររន្ទះ និងកន្លែងសម្រាប់សត្វពាហនៈ) ក្នុង១កន្លែងអាចនៅបាន**២ ០០០នាក់** នៅខេត្តកំពង់ឆ្នាំង កំពង់ធំ ពោធិ៍សាត់ ក្រោមគម្រោងឧបត្ថម្ភពីWFP។

- **ការស្តារឡើងវិញតាមប្រព័ន្ធស្បៀងបម្រុងកម្ពុជា**

| ល.រ | ការផ្តល់ជូន | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ១ | - ស្រូវពូជ<br>- គ្រួសារដែលបានទទួល | - ២២៥៧,៧ត.<br>- ៣៧,២៦៨គ្រ. | - ១១៥ត.<br>- ៥,៩៩០គ្រ. | - ៦៥៧៨ត.<br>- ៦៥,៧៨០គ្រ. | | - ៥៩៥៧ត.<br>- ១៩,៧៧២គ្រ. |
| ២ | - ពូជដំណាំ ពូជបន្លែ<br>- គ្រួសារដែលបានទទួល | - ៣៣,៦៦ត.<br>- ៩៩,០១៩គ្រ. | | - ៣២,៣៧ត<br>- ៩៧,៦៦៦គ្រ. | | |

<u>ប្រភព</u>៖ គ.ជ.គ.ម.

### ១.១២- ការងារអប់រំផ្សព្វផ្សាយ

បានធ្វើការផ្សព្វផ្សាយសារលិខិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយ ចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៩ ឆ្នាំ២០២០ ឆ្នាំ២០២១ និងឆ្នាំ២០២២ ។

| ល.រ | សកម្មភាព | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ១ | ធ្វើសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ | ៣លើក | ៣លើក | ៩លើក | ៣លើក | ៤លើក | ២២ លើក |
| ២ | ទទួលនិស្សិតអូស្ត្រាលី ១៤នាក់ មកស្វែងយល់ការគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា | | ១លើក | | | | ១លើក |
| ៣ | ពិភាក្សាការផ្លាស់ប្តូរទស្សនៈគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុជាមួយធនាគារពិភពលោក | | ១លើក | | | | ១លើក |
| ៤ | ពិភាក្សាស្វែងយល់ការគ្រប់គ្រងគ្រោះមហន្តរាយជាមួយ UNDP | | ១លើក | | | | ១លើក |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | រៀបចំវេទិកាថ្នាក់ជាតិស្ដីពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយលើកទី២៩ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ នៅរាជធានីភ្នំពេញដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ លេខាធិការដ្ឋានគ្រប់ គ្រងគ្រោះមហន្តរាយថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងអង្គការដៃគូ | | | | | ១លើក | ១លើក |
| ៦ | ធ្វើការផ្សព្វផ្សាយការងារត្រៀមបង្ការគ្រោះទឹកជំនន់នៅតាមបណ្ដាខេត្តតាមដងទន្លេមេគង្គ និងជុំវិញបឹងទន្លេសាប | | | | | ២លើក | ២លើក |
| ៧ | រៀបចំទិវាជាតិគ្រប់គ្រងគ្រោះមហន្តរាយថ្ងៃទី១៣ ខែតុលា រួមជាមួយទិវាអាស៊ានគ្រប់គ្រងគ្រោះមហន្តរាយ និងទិវាអន្តរជាតិកាត់គ្រោះមហន្តរាយ | | | | | ១លើក | |

## ២- គណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រឆាំងភេរវកម្ម(ល.គ.ជ.ប.ភ.) បានសម្របសម្រួលការរៀបចំបំពេញការងារតាមសូចនាករដែលបានគ្រោងទុកកន្លងមក ក្នុងនោះរួមមានការហ្វឹកហ្វឺន វគ្គបណ្ដុះបណ្ដាល សិក្ខាសាលា ទស្សនកិច្ច កិច្ចប្រជុំ ក្នុងស្រុកសរុប**ចំនួន២៣០លើក**(តាមប្រព័ន្ធអនឡាញចំនួន៤១លើក)។ អ្នកចូលរួមត្រូវបានអញ្ជើញពីបណ្ដាក្រសួង ស្ថាប័ន មន្ទីរពាក់ព័ន្ធ រួមមានក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងការពារជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស កងពលតូចលេខ៧០ អគ្គនាយកដ្ឋានស្រាវជ្រាវចារកិច្ចនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា បញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា កំពង់ផែស្វយ័តភ្នំពេញជាដើម។ ចំពោះការចុះបេសកកម្មក្រៅប្រទេស ល.គ.ជ.ប.ភ.បានរៀបចំបញ្ជូនថ្នាក់ដឹកនាំនិងមន្ត្រីជំនាញចូលរួមសរុប**ចំនួន១០១លើក** (តាមប្រព័ន្ធអនឡាញចំនួន២៣លើក) នៅតាមបណ្ដាប្រទេសមួយចំនួន ជាអាទិ៍សហរដ្ឋអាម៉េរិក ចិន អូស្ត្រាលី ជប៉ុន ថៃ អាល្លឺម៉ង់ អូទ្រីស អ៊ីតាលី សាធារណរដ្ឋកូរ៉េ ឥណ្ឌូណេស៊ី ម៉ាឡេស៊ី កេនយ៉ា វៀតណាម សិង្ហបុរី ហ្វីលីពីន ហ្វាំងឡង់ ឥណ្ឌា រុស្ស៊ី ម៉ាល់តា ហុងគ្រី កាណាដា ស្រីលង្កា បេឡារុស អ៊ូបេគីស្ថាន អារ៉ាប់រួម ឆេកូស្លូវ៉ាគី នេប៉ាល់។ ដោយឡែកចំពោះសមយុទ្ធលើតុ ក៏មានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីលេខាធិការដ្ឋាន និងស្ថាប័ននានា ដូចជាក្រសួងការពារជាតិ(អាជ្ញាធរជាតិអាវុធគីមី) ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋាន

កាំកុងត្រូល យោធភូមិភាគពិសេស នាយកដ្ឋានស្រាវជ្រាវចារកិច្ចយោធា ការិយាល័យទី២នៃអគ្គបញ្ជាការដ្ឋានកងទ័ពជើងគោក។

ក្រៅពីនេះ កងកម្លាំងពិសេសប្រឆាំងភេរវកម្មបានចូលរួមក្នុងការការពារសុវត្ថិភាពជូនថ្នាក់ដឹកនាំនិងឥស្សរជនជាន់ខ្ពស់ក្នុងការចុះបំពេញបេសកកម្ម ការចូលរួមក្នុងព្រឹត្តិការណ៍ជាតិអន្តរជាតិសំខាន់ៗក្នុងស្រុក**ចំនួន ៥១០លើក** រួមមានការយាងទៅក្រៅប្រទេសរបស់**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចព្រះមហាក្សត្រី** និងថ្នាក់ដឹកនាំ កម្មវិធីសំណេះសំណាលផ្សេងៗ កម្មវិធីសម្ពោធសមិទ្ធផលនានា កម្មវិធីបើក បិទសន្និបាត កិច្ចប្រជុំរដ្ឋសភា កិច្ចប្រជុំកំពូលអាស៊ាន ការបំពេញទស្សនកិច្ចជាផ្លូវការ ការចែកអំណោយមនុស្សធម៌កាកបាទក្រហម និងកម្មវិធីបុណ្យជាតិនានា។

**តារាងសូចនាករ លទ្ធផលការងាររបស់ល.គ.ជ.ប.ភ. រយៈពេល៥ឆ្នាំ(២០១៨-២០២២)**

| សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|
| ១- ការបង្ការទប់ស្កាត់រាល់សកម្មភាពភេរវកម្ម | | | | | | |
| + ក្នុងប្រទេស: វគ្គហ្វឹកហ្វឺនការបណ្តុះបណ្តាល សិក្ខាសាលាបេសកកម្ម | ២៥លើក ៨៨នាក់ | ៣១លើក ១០២នាក់ | ២១លើក ៧៣នាក់ | ៣៥លើក ១៣០នាក់ | ១១៨លើក ៤៤៦នាក់ | ២៣០លើក ៨៣៩នាក់ |
| + ក្រៅប្រទេស: វគ្គហ្វឹកហ្វឺន ការបណ្តុះបណ្តាល សិក្ខាសាលាបេសកកម្ម | ២១លើក ៥៦នាក់ | ៣៦លើក ១២៥នាក់ | ១១លើក ៣០នាក់ | ២១លើក ៣៨នាក់ | ១២លើក ២៧នាក់ | ១០១លើក ២៧៦នាក់ |
| + ការការពារសន្តិសុខ សុវត្ថិភាពជូនថ្នាក់ដឹកនាំនិងឥស្សរជនជាន់ខ្ពស់ | ១៥៤លើក | ១៦៦លើក | ៨៥លើក | ៣១លើក | ៧៤លើក | ៥១០លើក |
| ២- ការផ្សព្វផ្សាយ បង្កើនការយល់ដឹងអំពីការទប់ស្កាត់ភេរវកម្ម | | | | | | |
| + ការចុះផ្សព្វផ្សាយសៀវភៅផែនការជាតិប្រឆាំងភេរវកម្ម | | | | | ១៤លើក ៧២៧នាក់ | ១៤លើក ៧២៧នាក់ |
| + ការផ្សព្វផ្សាយព័ត៌មានភេរវកម្មតាមគេហទំព័រ | ៩៣៦ ព័ត៌មាន | ១៩៨២ ព័ត៌មាន | ១៤១១ ព័ត៌មាន | ៤៩៥ ព័ត៌មាន | ៣៦៧ ព័ត៌មាន | ៥១៩១ព័ត៌មាន |
| + ការផ្សព្វផ្សាយព័ត៌មាន សុវត្ថិភាពបច្ចេកវិទ្យា តាមគេហទំព័រ | ៨២៣ ព័ត៌មាន | ២០១៤ ព័ត៌មាន | ៨៦២ ព័ត៌មាន | ៨១៤ ព័ត៌មាន | ៧៤២ ព័ត៌មាន | ៥២៥៥ព័ត៌មាន |

ក្នុងការពង្រឹងផ្នែកច្បាប់ ល.គ.ជ.ប.ភ.បានធ្វើបច្ចុប្បន្នភាពសៀវភៅផែនការជាតិប្រឆាំងភេរវកម្ម (ឆ្នាំ២០២១) ដែលសៀវភៅនេះគឺជាឯកសារគោលមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ស្ថាប័ននិងភ្នាក់ងារពាក់ព័ន្ធទាំងអស់នៅក្នុងប្រទេសកម្ពុជា ដើម្បីរៀបចំ បង្ការ និងឆ្លើយតបចំពោះឧបទ្ទវហេតុភេរវកម្មគ្រប់រូបភាពទាំងអស់។ សៀវភៅនេះបានកំណត់មុខងារនិងភារកិច្ចសំខាន់ៗសម្រាប់ស្ថាប័ននិងទីភ្នាក់ងារពាក់ព័ន្ធទាំងអស់ ដើម្បីសហការគ្នាប្រកបដោយប្រសិទ្ធភាព។ ល.គ.ជ.ប.ភ.បានបើកវគ្គបណ្តុះបណ្តាលចំណេះដឹងស្តីពីសៀវភៅផែនការជាតិប្រឆាំងភេរវកម្ម ដល់ស្ថាប័ននៅក្នុងខេត្តចំនួន១៦ ហើយបន្តចុះបានចំនួន ៤ខេត្តទៀតសម្រាប់ឆ្នាំ២០២២ និងគ្រោងបន្តបើកវគ្គបណ្តុះបណ្តាលនៅទូទាំងប្រទេស (២៥ខេត្ត-ក្រុង)។ ទន្ទឹមនេះ ល.គ.ជ.ប.ភ. បាននិងកំពុងចូលរួមក្នុងកិច្ចពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីថាមពលនុយក្លេអ៊ែររបស់ក្រសួងរ៉ែនិងថាមពល ការរួមចំណែកជាមួយអង្គភាព

ស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា(CAFIU) ដើម្បីធ្វើការវាយតម្លៃគ្នាទៅវិញទៅមកលើហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

លើសពីនេះទៀត ល.គ.ជ.ប.ភ.បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលគម្រោងផ្តួចផ្តើមកំពង់ផែខ្នាតធំ ដើម្បីដំឡើងម៉ាស៊ីនត្រួតពិនិត្យជាតិវិទ្យុសកម្ម(RPM) នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ និងបំពាក់ឧបករណ៍រាវរកសារធាតុវិទ្យុសកម្ម(RPM) ដែលអាចយួរតាមខ្លួនបាន ដល់មន្ត្រីគយនៅតាមច្រកត្រួតពិនិត្យព្រំដែនគោក អន្តរជាតិ កំពង់ផែស្ងួត អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងអាកាសយានដ្ឋានអន្តរជាតិសៀមរាប ហើយក៏បានសម្របសម្រួលកម្មវិធីគ្រប់គ្រងការនាំចេញទំនិញយុទ្ធសាស្ត្រ និងការត្រួតពិនិត្យការនាំចេញជាមួយក្រសួងការបរទេសសហរដ្ឋអាមេរិក(DoS) សហភាពអឺរ៉ុបលើគម្រោងP2P។

ក្រៅពីនេះ ក៏មានការសហការពីភាគីដៃគូលើការងារបង្ការ ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងជាមួយនឹងភេរវកម្ម ដែលមានការសហការទាំងក្នុងប្រទេស ក្នុងតំបន់ និងអន្តរជាតិ ក៏ដូចជាការសម្របសម្រួលការទទួលភ្ញៀវអន្តរជាតិ ក្នុងភាពជាដៃគូ ជាមិត្ត ដែលបានចូលមកសហការលើការងារប្រឆាំងភេរវកម្ម។

ក្នុងរយៈពេល៥ឆ្នាំកន្លងមក នាយកដ្ឋានទាំងប្រាំចំណុះល.គ.ជ.ប.ភ.រួមទាំងបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្មបានបំពេញការងារតាមសូចនាករនិងការគ្រោងទុកនាពេលកន្លងមក រួមមានការចងក្រង និងបោះពុម្ពសៀវភៅគោលដៅទន់ រឹង បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់ល.គ.ជ.ប.ភ.(២០១៩-២០២៣) ផែនការយុទ្ធសាស្ត្របីឆ្នាំរំកិល កិច្ចការផ្សព្វផ្សាយព័ត៌មានភេរវកម្មជុំវិញពិភពលោកចំនួន៥ ១៩១ ព័ត៌មាន ព័ត៌មានសុវត្ថិភាពបច្ចេកវិទ្យាចំនួន៥ ២៥៥ព័ត៌មាន ដើម្បីផ្សព្វផ្សាយលើគេហទំព័រ www.nctc.gov.kh ការចុះប្រមូលព័ត៌មានចំហនិងព័ត៌មានចារកម្មនៅតាមបណ្តារាជធានី ខេត្ត ក្រុងនានា។

ល.គ.ជ.ប.ភ.ក៏បានត្រៀមនិងបន្តសកម្មភាពនៅក្នុងរបត់នៃជំងឺកូវីដ-១៩ថ្មី ដើម្បីបន្តការសហការ បង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងភេរវកម្ម ក៏ដូចជាការចូលរួមក្នុងការការពារសុវត្ថិភាពថ្នាក់ដឹកនាំជាបន្តទៀតដោយស្មារតីទទួលខុសត្រូវនិងកិច្ចសហប្រតិបត្តិការខ្ពស់។

## ៣- ការងារប្រជាធិបតេយ្យនីយកម្ម

### ៣.១- គណបក្សនយោបាយ

បច្ចុប្បន្ន (គិតត្រឹមខែកញ្ញា ឆ្នាំ២០២២) គណបក្សនយោបាយដែលក្រសួងមហាផ្ទៃទទួលស្គាល់ជាផ្លូវការមានចំនួន**៤៥គណបក្ស** គឺ (១) គណបក្សប្រជាជនកម្ពុជា (២) គណបក្សហ្វ៊ុនស៊ិនប៉ិច (៣) គណបក្សភ្លើងទៀន (៤) គណបក្សសិទ្ធិមនុស្ស (៥) គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ (៦) គណបក្សកម្ពុជាសេរីឯករាជ្យ-ប្រជាធិបតេយ្យ (៧) គណបក្សអភិវឌ្ឍន៍កម្ពុជា (៨) គណបក្សកសិករ (៩) គណបក្សចំរើននិយមខ្មែរ (១០) គណបក្សខ្មែរជួយខ្មែរ (១១) គណបក្សខ្មែរអង្គរ (១២) គណបក្សជាតិនិយម (១៣) គណបក្សមូលីណាកា (១៤) គណបក្សស្ត្រីដើម្បីស្ត្រី (១៥) គណបក្សធម្មាធិបតេយ្យ (១៦) គណបក្សចលនាប្រជាធិបតេយ្យ (១៧) គណបក្សមហានគរ (១៨) គណបក្សខ្មែរឈប់ក្រ (១៩) គណបក្សខ្មែរសាធារណរដ្ឋ (២០) គណបក្សអំណាចប្រជាពលរដ្ឋ (២១) គណបក្សសង្គមយុត្តិធម៌ (២២) គណបក្សសញ្ជាតិកម្ពុជា (២៣) គណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច (២៤) គណបក្សខ្មែរឈ្នះ (២៥) គណបក្សយុវជនកម្ពុជា (២៦) គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ (២៧) គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា (២៨) គណបក្សនគរប្រជាធិបតេយ្យ (២៩) គណបក្សប្រជាធិបតេយ្យមូលដ្ឋាន (៣០) គណបក្សខ្មែររួបរួមជាតិ (៣១) គណបក្សមាតុភូមិយើង (៣២) គណបក្សស្មើខេមរា

(៣៣) គណបក្សខ្មែរតែមួយ (៣៤) គណបក្សឆន្ទៈខ្មែរ (៣៥) គណបក្សពន្លឺថ្មី (៣៦)គណបក្សមហាសាមគ្គី-ជាតិខ្មែរ (៣៧) គណបក្សបំណងប្រជាពលរដ្ឋ (៣៨) គណបក្សខ្មែរអភិវឌ្ឍ (៣៩) គណបក្សប្រជាធិបតេយ្យថ្មី (៤០) គណបក្សខ្មែរក្រោក (៤១) គណបក្សខ្មែរស្រឡាញ់ជាតិ (៤២) គណបក្សឯកភាពជាតិខ្មែរ (៤៣) គណបក្សកម្លាំងប្រជាធិបតេយ្យ (៤៤) គណបក្សកែទម្រង់កម្ពុជា និង (៤៥) គណបក្សកម្ពុជានិយម។

**កត់សម្គាល់៖** ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ ក្រសួងមហាផ្ទៃបានសម្រេចអនុញ្ញាតឱ្យបង្កើតគណបក្សនយោបាយចំនួន៩ ចុះឈ្មោះក្នុងបញ្ជីគណបក្សចំនួន១៧ និងលុបឈ្មោះចេញពីបញ្ជីគណបក្សចំនួន៨ (រួមមាន(១) គណបក្សប្រជាធិបតេយ្យខ្មែរ (២) គណបក្សសង្គមប្រជាធិបតេយ្យ (៣) គណបក្សវង្កតខេមរៈមហានគរ (៤) គណបក្សប្រយោជន៍ខ្មែរ (៥) គណបក្សដើម្បីយើងទាំងអស់គ្នា (៦) គណបក្សអនាគតជាតិ (៧) គណបក្សបេះដូងជាតិ និង(៨) គណបក្សសំឡេងសហគមន៍កម្ពុជា។ ពាក់ព័ន្ធនឹងលំហសេរីភាពក្នុងការធ្វើនយោបាយក្នុងចំណោម១១៨រូប ដែលត្រូវបានហាមឃាត់ធ្វើសកម្មភាពនយោបាយដោយអំណាចសាលដីការបស់តុលាការកំពូល មានបុគ្គល៣៩រូប បានដាក់ពាក្យសុំនីតិសម្បទាសិទ្ធិធ្វើនយោបាយឡើងវិញ ក្នុងនោះ៣៣រូបទទួលបាននីតិសម្បទាសិទ្ធិធ្វើនយោបាយឡើងវិញ ខណៈ៦រូបទៀតត្រូវបានបដិសេធដោយសារបានធ្វើសកម្មភាពរំលោភបំពានសាលដីការបស់តុលាការកំពូល។

- ជារួម គណបក្សនយោបាយដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ គឺមានសិទ្ធិធ្វើសកម្មភាពដោយសេរី គ្មានការរើសអើង ឬទទួលរងនូវការគាបសង្កត់អ្វីឡើយ។ ជាក់ស្តែង ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ កន្លងទៅនេះ មានគណបក្សនយោបាយចូលរួមប្រកួតប្រជែងរហូតដល់១៧ គណបក្សដោយមានបេក្ខជនឈរឈ្មោះសរុបចំនួន៨៦ ០៩២នាក់ និងមានប្រជាពលរដ្ឋបានទៅបោះឆ្នោតចំនួន ៧ ៣៨២ ៤៤៩នាក់ ស្មើ៨០,១៩% នៃអ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ហើយជាលទ្ធផលមានគណបក្សនយោបាយចំនួន៩ទទួលបានអាសនៈក្នុងក្រុមប្រឹក្សាឃុំ សង្កាត់។

## ៣.២- ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់

ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៣២ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់។

**ក- ក្នុងឆ្នាំ២០១៩ ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់បានបើកកិច្ចប្រជុំចំនួន១៧លើក ដើម្បីពិភាក្សាលើ៖**

១- ការចុះសិក្សាដោយផ្ទាល់នៃទស្សនវិស័យស្វ័យសម្រេចរបស់ប្រតិភូគណបក្សសាមីនីមួយៗ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ម៉ម សូណង់ដូ** ប្រធានគណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ ជាមួយរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីទទួលបន្ទុកប្រធានលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩។

២- សមិទ្ធផលរបស់ក្រសួងយុត្តិធម៌ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ហួង ធៀមទៀង** ប្រធានគណបក្សខ្មែរសាធារណរដ្ឋ ជាមួយប្រតិភូក្រសួងយុត្តិធម៌ ដឹកនាំដោយឯកឧត្តម **អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។

៣- សមិទ្ធផលរបស់ក្រសួងពាណិជ្ជកម្ម ពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការទប់ស្កាត់នូវរាល់ការផ្សាយពាណិជ្ជកម្មនៃផលិតផលទំនិញ និងសេវាដែលមានលក្ខណៈភូតកុហកឆបោកក៏ដូចជាមានលក្ខណៈលើកទឹក

ចិត្តឱ្យប្រជាពលរដ្ឋ ជាពិសេស យុវជនសេពគ្រឿងស្រវឹង ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ពេជ្រ សូដេថ្លា** អនុប្រធានគណបក្សហ៊្វុនស៊ិនប៉ិច ជាមួយប្រតិភូក្រសួងពាណិជ្ជកម្ម ដឹកនាំដោយឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៩។

៤- ទិដ្ឋភាពជាក់ស្តែងចំពោះប្រសិទ្ធភាពនៃការទប់ស្កាត់ការផ្សាយព័ត៌មានមិនពិត រួមទាំងប្រសិទ្ធភាពនៃការទប់ស្កាត់ការផ្សាយលើកទឹកចិត្តឱ្យប្រជាពលរដ្ឋសេពគ្រឿងស្រវឹង និងបង្កប៉ះពាល់ដល់សន្តិសុខជាតិ សុវត្ថិភាពសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ពេជ្រ សូដេថ្លា** អនុប្រធានគណបក្សហ៊្វុនស៊ិនប៉ិច ជាមួយប្រតិភូក្រសួងព័ត៌មាន ដឹកនាំដោយឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩។

៥- ទិដ្ឋភាពជាក់ស្តែងពាក់ព័ន្ធនឹងការស្វែងរកការងារជូនប្រជាពលរដ្ឋ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ហួន រាជចំរើន** ប្រធានគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ជាមួយប្រតិភូក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដឹកនាំដោយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៩។

៦- សមិទ្ធផលការងារ ព្រមទាំងបញ្ហាប្រឈមមួយចំនួននៃប្រសិទ្ធភាពក្នុងការទប់ស្កាត់បទល្មើសនានា និងបរិបទផ្សេងៗក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ហួន រាជចំរើន** ប្រធានគណបក្សខ្មែរអភិវឌ្ឍន៍សេដ្ឋកិច្ច ជាមួយប្រតិភូក្រសួងរ៉ែនិងថាមពល ដឹកនាំដោយឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩។

៧- សមិទ្ធផលការងាររបស់ក្រសួងសុខាភិបាល ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ពេជ្រ ស្រស់** ប្រធានគណបក្សយុវជនកម្ពុជា ជាមួយប្រតិភូក្រសួងសុខាភិបាល ដឹកនាំដោយឯកឧត្តម **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។

៨- សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម(ប.ស.ស.) ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **គង់ មុនីកា** ប្រធានគណបក្សឆន្ទៈខ្មែរ ជាមួយប្រតិភូក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដឹកនាំដោយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេចក្តីព្រាងគោលនយោបាយជាតិស្តីពីភាសាខ្មែរ ជាមួយប្រតិភូរាជបណ្ឌិត្យសភាកម្ពុជា ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិត្យសភាកម្ពុជា កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១៩។

៩- សេចក្តីព្រាងច្បាប់ស្តីពីសំណង់ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **គង់ មុនីកា** ប្រធានគណបក្សឆន្ទៈខ្មែរ ជាមួយប្រតិភូក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដឹកនាំដោយឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៩។

១០- សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល២០២០-២០២៣ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **គង់ មុនីកា** ប្រធានគណបក្សឆន្ទៈខ្មែរ ជាមួយប្រតិភូក្រសួងផែនការ ដឹកនាំដោយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩។

១១- សេចក្តីព្រាងរបាយការណ៍ស្វ័យវាយតម្លៃ ស្តីពីការត្រួតពិនិត្យឡើងវិញនូវការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងអំពើពុករលួយ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **គង់ មុនីកា** ប្រធានគណបក្ស

ធនធានខ្មែរ ជាមួយប្រតិភូអង្គភាពប្រឆាំងអំពើពុករលួយ ដឹកនាំដោយឯកឧត្តម **ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រី ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ កាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩។

១២- ការធានារបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់គម្រោងទិញថាមពលអគ្គិសនីផលិតដោយធ្យូងថ្ម ២៤០០មេហ្គាវ៉ាត់ពីប្រទេសឡាវ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ស្រួយ ខេត** តំណាងគណបក្សជនជាតិដើមប្រជាធិបតេយ្យ ជាមួយប្រតិភូក្រសួងរ៉ែនិងថាមពល ដឹកនាំដោយឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩។

១៣- សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីសហជីព ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ស្រួយ ខេត** តំណាងគណបក្សជនជាតិដើមប្រជាធិបតេយ្យ ជាមួយប្រតិភូក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដឹកនាំដោយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ កាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩។

១៤- បរិបទនៃការកំណត់ខណ្ឌសីមា និងដំណើរការនៃការបោះបង្គោលព្រំដែនគោករវាងកម្ពុជានិងវៀតណាម ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **កែម រឹទ្ធិសិត** ប្រធានគណបក្សខ្មែរតែមួយ ជាមួយប្រតិភូអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដឹកនាំដោយឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការព្រំដែន កាលពីថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩។

១៥-សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០ និងសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **កែម រឹទ្ធិសិត** ប្រធានគណបក្សខ្មែរតែមួយ ជាមួយប្រតិភូក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី២២ខែតុលា ឆ្នាំ២០១៩។

១៦- កិច្ចប្រជុំពិភាក្សាទូទៅ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ឯក សំអុល** តំណាងគណបក្សប្រជាជនកម្ពុជា ជាមួយប្រតិភូក្រសួងធនធានទឹកនិងឧតុនិយម ដឹកនាំដោយឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម កាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩។

១៧- កិច្ចប្រជុំពិភាក្សាទូទៅដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ឯក សំអុល** តំណាងគណបក្សប្រជាជនកម្ពុជា ជាមួយប្រតិភូក្រសួងអប់រំ យុវជន និងកីឡា ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៩។

ក្រៅពីនេះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដឹកនាំប្រជុំចំនួន៣លើក៖

១- កិច្ចប្រជុំប្រចាំឆមាសលើកទី១នៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ដើម្បីស្តាប់របាយការណ៍សង្ខេបនិងសំណូមពរ កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩។

២- ដឹកនាំកិច្ចប្រជុំប្រចាំឆមាសលើកទី២នៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ដើម្បីស្តាប់របាយការណ៍សង្ខេប និងសំណូមពរ កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩។

៣- បិទសន្និបាតបូកសរុបការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០របស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៩។

**ខ- ក្នុងឆ្នាំ២០២០ ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់បានបើកកិច្ចប្រជុំចំនួន៥លើក ដើម្បីពិភាក្សាលើ៖**

១- កិច្ចប្រជុំពិភាក្សាលើការងាររបស់ក្រសួងយុត្តិធម៌ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ញឹក ប៊ុនឆៃ** ប្រធានគណបក្សខ្មែររួបរួមជាតិ ជាមួយប្រតិភូក្រសួងយុត្តិធម៌ ដឹកនាំដោយឯកឧត្តម **អង្គ វង្សវឌ្ឍនា** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ កាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០២០។

២- កិច្ចប្រជុំពិភាក្សាលើភាពមិនប្រក្រតីមួយចំនួនរួមទាំងបញ្ហាផ្សេងៗ ពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ដឹកនាំដោយប្រធានប្តូរវេន ឯកឧត្តម **នួន សុខាវី** ប្រធានគណបក្សពន្លឺថ្មី ជាមួយប្រតិភូក្រសួងសាធារណការនិងដឹកជញ្ជូន ដឹកនាំដោយឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន កាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០។

៣- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ របស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **នួន សុខាវី** ប្រធានគណបក្សពន្លឺថ្មី ជាមួយប្រតិភូក្រសួងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យានិងនវានុវត្តន៍ ដឹកនាំដោយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រួមទាំងពិភាក្សាលើគម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គិសនីដុតធ្យូងថ្មអានុភាព៧០០មេហ្គាវ៉ាត់ នៅស្រុកបុទុមសាគរ ខេត្តកោះកុង និងគម្រោងវិនិយោគសាងសង់រោងចក្រផលិតអគ្គិសនីដុតធ្យូងថ្មអានុភាព២៦៥មេហ្គាវ៉ាត់ នៅស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ និងគម្រោងអភិវឌ្ឍខ្សែបណ្តាញបញ្ជូនអគ្គិសនី២៣០គីឡូវ៉ុល ពីរោងចក្រអគ្គិសនីដុតធ្យូងថ្ម ខេត្តឧត្តរមានជ័យមកអនុស្ថានីយខាងកើតសៀមរាបរបស់ក្រសួងរ៉ែនិងថាមពល ដឹកនាំដោយឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល កាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២០។

៤- កិច្ចប្រជុំពិភាក្សាអំពីសុក្រឹតភាពការងារជំរឿនប្រជាជនឆ្នាំ២០១៩ ដើម្បីជាស្ថិតិមូលដ្ឋាននៃការរៀបចំផែនការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធផល ឆ្លើយតបនឹងសេចក្តីត្រូវការរបស់សង្គមជាតិ ព្រមទាំងបញ្ហាប្រឈមមួយចំនួននៃប្រសិទ្ធភាពការងារ និងការអនុវត្តច្បាប់ស្ថិតក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់ក្រសួងផែនការ ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **នួន សុខាវី** ប្រធានគណបក្សពន្លឺថ្មី ជាមួយប្រតិភូក្រសួងផែនការ ដឹកនាំដោយឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ឆាយ ថន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០។

៥- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រង ការប្រើប្រាស់និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋនិងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ដឹកនាំដោយប្រធានប្តូរវេនឯកឧត្តម **ចាន់ យ៉េត** តំណាងប្រតិភូគណបក្សនគរប្រជាធិបតេយ្យ ជាមួយប្រតិភូក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០។

ក្រៅពីនេះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដឹកនាំប្រជុំចំនួន២លើកៈ

១- កិច្ចប្រជុំប្រចាំឆមាសលើកទី៣ នៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ កាលពីថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ និងបានថ្លែងសារពិសេសជូនជនរួមជាតិស្តីពីវិធានការរបស់រាជរដ្ឋាភិបាល ដើម្បីដោះស្រាយនិងកាត់បន្ថយផលប៉ះពាល់លើសេដ្ឋកិច្ចកម្ពុជា ដែលបណ្តាលមកពីការព្យួរភាពអនុគ្រោះពន្ធលើទំនិញមួយចំនួន ក្រោមកម្មវិធីទំនិញគ្រប់មុខ លើកលែងតែអាវុធ(EBA)របស់សហភាពអឺរ៉ុប និងជំងឺកូវីដ-១៩ ព្រមទាំងដើម្បីជានាស្ថិរភាព

ម៉ាក្រូសេដ្ឋកិច្ចនិងជួយសម្រាលបន្ទុកប្រជាជនដែលប្រកបមុខរបរក្នុងវិស័យរងផលប៉ះពាល់ ជាអាទិ៍វិស័យទេសចរណ៍ វិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក៏បានផ្ញើសារផ្សព្វផ្សាយជូនជនរួមជាតិ អំពីវិធានការអនាម័យចាំបាច់មួយចំនួន ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងបើកឱកាសឱ្យប្រធាននិងប្រតិភូតំណាងគណបក្សនយោបាយ នីមួយៗ និងអ្នកសារព័ត៌មានលើកជាសំណួរមកទូលព្រះបង្គំជាខ្ញុំបកស្រាយពន្យល់បន្ថែមផងដែរ។

២- កិច្ចប្រជុំប្រចាំឆមាសលើកទី៤នៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០។ ក្នុងឱកាសនោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**បានជម្រាបជូនប្រតិភូគណបក្សនយោបាយលើកយកបញ្ហាទាក់ទងនឹងជំងឺកូវីដ-១៩ ធ្វើជាប្រធានបទនិងរួមយោបល់ចំពោះវិធានការដោះស្រាយរបស់រាជរដ្ឋាភិបាលកន្លងទៅដែលមានផលប៉ះពាល់ដល់វិស័យសេដ្ឋកិច្ច សង្គម ព្រមទាំងជួយលើកបញ្ហាដែលមិនទាន់បានធ្វើការដោះស្រាយនិងបញ្ហាផ្សេងៗមួយចំនួនទៀត។

## ៤- ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងការងារខណ្ឌសីមានិងបោះបង្គោលព្រំដែន

### ៤.១- ការងារច្រកទ្វារព្រំដែន និងការចងសម្ព័ន្ធមេត្រីភាពជាមួយខេត្ត ក្រុងនៃបណ្តាប្រទេសនានា

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាមានច្រកទ្វារព្រំដែនសរុបចំនួន**៨២ច្រក** រួមមានៈ

- **ច្រកទ្វារអន្តរជាតិ** ( ស្ថិតនៅផ្ទៃក្នុងព្រះរាជាណាចក្រកម្ពុជា )
  + អាកាសយានដ្ឋានអន្តរជាតិមាន៣ គឺអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាបនិងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ។
  + កំពង់ផែអន្តរជាតិមាន៤ គឺកំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ កំពង់ផែអន្តរជាតិស្ទឹងហាវនិងកំពង់ផែស្វយ័តអន្តរជាតិគ្រីស្តាល់រ៉ាយ ខេត្តកំពត ។
  + កំពង់ផែសមុទ្រមាន៩ គឺកំពង់ផែទំនប់រលក ស្រែអំបិល ប៉ាក់ខ្លង កោះស្តេច ថ្មស កំពង់ផែសមុទ្រទីរួមខេត្តកំពត ត្រពាំងល្ពៅ កោះសេះនិងកំពង់ផែទីក្រុងកែប។
- **បណ្តាច្រកទ្វារព្រំដែន** ( ស្ថិតនៅតាមព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជានិងប្រទេសជិតខាង )

| ច្រកទ្វារព្រំដែនអន្តរជាតិ | ច្រកទ្វារព្រំដែនទ្វេភាគី | ច្រកទ្វារតំបន់ព្រំដែន | ឈ្មោះរាជធានីខេត្ត |
|---|---|---|---|
| ច្រកទ្វារជាប់ព្រំដែនថៃ | | | |
| ចាំយាម | | | កោះកុង |
| ដូង ភ្នំដី | | សួនសុំ អូរបំដួល ភ្នំព្រឹក ច្រក៤០០ ពាមគា ស្វាយចេក បានសានចារ ច្រក២០៣ | បាត់ដំបង |
| ព្រំ | | | ប៉ៃលិន |
| ប៉ោយប៉ែត ស្ទឹងបត់ | | បឹងត្រកួន ម៉ាឡៃ ច្រក៤៣ | បន្ទាយមានជ័យ |
| អូរស្មាច់ ជាំ ជប់គគីរ | | ព្រះប្រឡាយ | ឧត្តរមានជ័យ |
| អានសេះ | ប្រាសាទព្រះវិហារ | | ព្រះវិហារ |
| ថ្មដារ | | ភ្នំឫស្សី ស្ពានជ័យជំនះ | ពោធិ៍សាត់ |

| ច្រកទ្វារជាប់ព្រំដែនវៀតណាម | | | |
|---|---|---|---|
| | ដាក់ដាំ ឡាប៉ាខេ ដីមៀត ណាំ | | មណ្ឌលគិរី |
| អូរយ៉ាដាវ | | | រតនគិរី |
| ត្រពាំងស្រែ | ជ័យឃ្លាំង ស្នួល | | ក្រចេះ |
| ត្រពាំងផ្លុង ដា | ចាន់មូល ទន្លេចាម | ដូនរ័ត្ន ដាំក្រវៀន ទន្លូង | ត្បូងឃ្មុំ |
| បាវិត សំរោង ព្រៃវល្លិ៍ | បុសមន | ស្រែបារាំង ដូង ព្រៃតាអី ខ្សែដែក | ស្វាយរៀង |
| ក្អមសំណ ជ្រៃធំ | | ព្រែកជ្រៃ ព្រែកទន្លា ព្រែកស្បូវ | កណ្ដាល |
| បន្ទាយចក្រី កោះរកា | កោះសំពៅ | ពាមមន្ទារ ស្វាយអាង៉ោង | ព្រៃវែង |
| ភ្នំឌិន | កំពង់ក្រសាំង បាក់ដៃ | | តាកែវ |
| ព្រែកចាក | តន់ហាន់ | | កំពត |
| ច្រកទ្វារជាប់ព្រំដែនឡាវ | | | |
| ត្រពាំងក្រៀល | | | ស្ទឹងត្រែង |

**កត់សម្គាល់៖** ក្នុងឆ្នាំ២០២១ ក្រសួងមហាផ្ទៃបានសហការសម្របសម្រួលជាមួយភាគីវៀតណាម រៀបចំពិធីសម្ពោធបើកឱ្យដំណើរការច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ តឹនណាមជាផ្លូវការក្នុងកម្រិតថ្នាក់ខេត្តជាប់ព្រំដែនកម្ពុជា វៀតណាម។

ក្រសួងមហាផ្ទៃបានយកចិត្តទុកដាក់លើកកម្ពស់ការគ្រប់គ្រងច្រកទ្វារព្រំដែន និងពង្រឹងការត្រួតពិនិត្យការធ្វើដំណើរនិងការដឹកជញ្ជូនចេញចូលឆ្លងកាត់ព្រំដែនទាំងអ្នកដំណើរ ទំនិញ និងមធ្យោបាយដឹកជញ្ជូនជាពិសេសខិតខំទប់ស្កាត់និងបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទនិងជំងឺរាតត្បាតនានា។ ទន្ទឹមនេះ ដើម្បីពង្រឹងយន្តការសហប្រតិបត្តិការក្នុងការគ្រប់គ្រងច្រកទ្វារព្រំដែន ក្រសួងមហាផ្ទៃបាននិងកំពុងសហការជាមួយភាគីវៀតណាម ដើម្បីពិនិត្យនិងសិក្សារៀបចំសេចក្ដីព្រាងកិច្ចព្រមព្រៀងស្ដីពីការគ្រប់គ្រងច្រកទ្វារព្រំដែនគោកកម្ពុជា វៀតណាម ព្រមទាំងកំពុងសហការជាមួយភាគីថៃសិក្សារៀបចំសេចក្ដីព្រាងកិច្ចព្រមព្រៀងស្ដីពីការសាងសង់ស្ពានឆ្លងកាត់អូរធម្មជាតិនៅច្រកទ្វារព្រំដែនអន្តរជាតិព្រំផងដែរ។

ជាមួយនេះ ដើម្បីលើកកម្ពស់ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការលើវិស័យនានាជាមួយខេត្ត ក្រុងនៃបណ្ដាប្រទេសជាមិត្តចាប់ពីឆ្នាំ២០១៨ដល់ខែកញ្ញា ឆ្នាំ២០២២ រដ្ឋបាលរាជធានី ខេត្តចំនួន១១បានចុះអនុស្សរណៈនៃការយោគយល់គ្នានិងកិច្ចព្រមព្រៀងស្ដីពីការចងសម្ព័ន្ធមេត្រីភាពជាមួយខេត្ត ក្រុងនៃបណ្ដាប្រទេសជាមិត្តចំនួន៤១។ ហើយក្រៅពីនោះ ក្រសួងមហាផ្ទៃក៏បានសហការរៀបចំកិច្ចប្រជុំស្ដីពី កិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍរវាងបណ្ដាខេត្តជាប់ព្រំដែនកម្ពុជា វៀតណាមចំនួន២លើក(ដែលជាយន្តការសហប្រតិបត្តិការទ្វេភាគីដ៏មានសារៈសំខាន់មួយក្នុងចំណោមយន្តការសហប្រតិបត្តិការនានារវាងប្រទេសទាំងពីរ) ព្រមទាំងរៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា ថៃ ចំនួន១លើកផងដែរ ។

## ៤.២- ការការពារដែនអធិបតេយ្យនិងបូរណភាពទឹកដីកម្ពុជា

**ក- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សម្រេចការងារដូចខាងក្រោម** (ហ្វេសប៊ុកផេក : Ministry of Foreign Affairs and International Cooperation Cambodia គេហទំព័រ www.mfaic.gov.kh)

ក្នុងការការពារបូរណភាពទឹកដី និងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាង ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ(ក.ប.ទ.ស.អ.) បានសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាព្រំដែនដែលនៅសេសសល់ សំដៅប្រែក្លាយតំបន់ព្រំដែនទៅជាព្រំដែនសន្តិភាព កិច្ចសហប្រតិបត្តិការល្អ និងការអភិវឌ្ឍ ដូចជា៖

១- **ជាមួយឡាវ** គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន(JBC)នៃប្រទេសទាំងពីរ បានធ្វើការត្រួតពិនិត្យខ្សែព្រំដែននិងខណ្ឌសីមា និងបានបោះបង្គោលព្រំដែនចំនួន១២១បង្គោល(លើបង្គោលសរុប១៤៥) លើដីជាក់ស្តែងប្រវែង៤៦៤,៥ គ.ម. ស្មើ៨៦% នៃខ្សែព្រំដែនរួម(ដែលមានប្រវែងប្រមាណ៥៤០គ.ម.)។ ចំពោះកំណាត់ព្រំដែនចំនួន១៤% ដែលសេសសល់ នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានឯកភាពគ្នាស្នើទៅភាគីបារាំងគូរចម្លងខ្សែព្រំដែន SGI ខ្នាត១/១០០ ០០០ ទៅលើផែនទីUTM ខ្នាត១/៥០ ០០០ រួមទាំងផ្តល់ឯកសារផ្លូវការនិងផែនទីសមស្រប ដទៃបន្ថែមទៀត។ បន្ថែមពីនេះ JBCនៃប្រទេសទាំងពីរបាននិងកំពុងចរចាធ្វើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋកម្ពុជាឡាវទទួលស្គាល់លទ្ធផលនៃការសម្រេចបានខណ្ឌសីមានិងការបោះបង្គោលព្រំដែនបាន៨៦%នេះ។

២- **ជាមួយថៃ** កម្ពុជានិងថៃមានព្រំដែនរួមប្រវែង៨០៣គ.ម. និងមានបង្គោលព្រំដែនចំនួន៧៤បង្គោលលើ៧៣ទីតាំង។ រហូតដល់បច្ចុប្បន្ននេះ គណៈកម្មាធិការចម្រុះកិច្ចការព្រំដែននៃប្រទេសទាំងពីរបានធ្វើការវាស់វែងនិងរុករកឃើញបង្គោលព្រំដែនទាំង៧៤នេះហើយ និងបានឯកភាពគ្នាលើទីតាំងបង្គោលព្រំដែនចំនួន៤៥សិន។ ចំណែកទីតាំងបង្គោលព្រំដែនចំនួន២៩ ដែលនៅសេសសល់ ភាគីទាំងពីរបាននិងកំពុងជំរុញការចរចាយ៉ាងយកចិត្តទុកដាក់។ ក្រៅពីនេះ កម្ពុជានិងថៃបាននិងកំពុងពន្លឿននីតិវិធីដំឡើងច្រកទ្វារព្រំដែនចំនួន៣បន្ថែម រួមមាន (១) ច្រកអានសេះ(ខេត្តព្រះវិហារ) អានម៉ា(អ៊ូប៊ុនរាជធានី) (២) ច្រកជប់គគីរ(ខេត្តឧត្តរមានជ័យ) សាយតាគូ (ខេត្តបូរីរ៉ាម) និង(៣) ច្រកថ្មដា(ខេត្តពោធិ៍សាត់) បានថាសេន(ខេត្តត្រាត)។

៣- **ជាមួយវៀតណាម** គណៈកម្មាធិការចម្រុះកិច្ចការព្រំដែននៃប្រទេសទាំងពីរបានធ្វើការវាស់វែងព្រំដែនប្រវែងប្រមាណ១ ០៤៥គ.ម.(លើចម្ងាយព្រំដែនសរុប១ ២៧០គ.ម.) និងបានបោះបង្គោលព្រំដែនមេបានចំនួន៣១៥(លើបង្គោលសរុបចំនួន៣៧៥) ស្មើនឹង៨៤%។ បច្ចុប្បន្ននេះ ក.ប.ទ.ស.អ.បាននិងកំពុងចូលរួមចរចាលើកំណាត់ព្រំដែន១៦% ដែលនៅសល់។ ក្រៅពីនេះ ក.ប.ទ.ស.អ.បាននិងកំពុងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងស្តីពីច្រកទ្វារព្រំដែនគោកកម្ពុជា វៀតណាម។

**ខ- អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន បានសម្រេចការងារដូចខាងក្រោម៖**

**១- ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម**

- ប្រទេសទាំងពីរកម្ពុជានិងវៀតណាម បានចុះសន្ធិសញ្ញាបំពេញបន្ថែមទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ១៩៨៥ និងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ និងពិធីសារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយនាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរ នាថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៩ នៅរដ្ឋធានីហាណូយ ដើម្បីទទួលស្គាល់លទ្ធផល៨៤% ដែលប្រទេសទាំងពីរសម្រេចបានលើការងារព្រំដែនគោក

- គណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកនៃប្រទេសទាំងពីរកម្ពុជានិងវៀតណាម បានសហការគ្នាយ៉ាងស្អិតរមួតបោះបង្គោលនិងខណ្ឌសីមាព្រំដែនបានប្រវែងប្រមាណ១ ០៤៥គ.ម. ស្មើនឹង៨៤% នៃខ្សែព្រំដែនរួមដែលមានប្រវែងប្រមាណជា១ ២៧០គ.ម.។ ក្នុងនោះ ភាគីទាំងពីរបោះបង្គោលព្រំដែនធំបានចំនួន៣៧៥បង្គោល បោះបង្គោលព្រំដែនបំពេញបន្ថែមបានចំនួន១ ៥១១បង្គោល បោះបង្គោលតម្រុយព្រំដែនបានចំនួន២២១បង្គោល និងចំណុចពិសេសបានចំនួន១ ០៣០ចំណុច។ សរុបជារួម ភាគីទាំងពីរបោះបង្គោលព្រំដែនទាំង៤ប្រភេទបានចំនួន៣ ១៣៧បង្គោល។ ក្នុងនោះ កម្ពុជាទទួលបន្ទុកបោះបង្គោលព្រំដែនលេខសេសចំនួន១ ៦២០បង្គោល និងវៀតណាមទទួលបន្ទុកបោះបង្គោលព្រំដែនលេខគូចំនួន១ ៥១៧បង្គោល។

- ក្នុងនាមរាជរដ្ឋាភិបាល **សម្តេចពិជ័យសេនាទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងឯកឧត្តម **វ៉ា គឹមហុង** ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការព្រំដែន និងជាប្រធានគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ បានប្រគល់ផែនទីឋានលេខាព្រំដែនគោកខ្នាត១/២៥ ០០០ ជូនទៅ៣៨ក្រសួង ស្ថាប័នដើម្បីប្រើប្រាស់តាមតម្រូវការចាំបាច់

- បន្ទាប់ពីប្រទេសទាំងពីរកម្ពុជានិងវៀតណាមបានផ្លាស់ប្តូរលិខិតុបករណ៍សច្ចាប័នលើសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០១៩ និងពិធីសារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងប្រទេសទាំងពីរបានចូលជាធរមានតាមផ្លូវច្បាប់រួចរាល់ នាថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០ ភាគីទាំងពីរបានធ្វើការផ្លាស់ប្តូរបញ្ចប់ការប្រគល់ដីឱ្យគ្នាទៅវិញទៅមកនៅតំបន់ដែលភាគីទាំងពីរបានខណ្ឌសីមា និងបោះបង្គោលព្រំដែនរួចក្នុង៨៤% ដែលសម្រេចបានរួចរាល់ទាំងស្រុងនៅដំណាច់ខែធ្នូ ឆ្នាំ២០២១

- ក្រៅពីសមិទ្ធផលការងារព្រំដែនដែលសម្រេចបានខាងលើ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនបានដឹកនាំត្រួតពិនិត្យការសាងសង់ផ្លូវក្រវ៉ាត់ព្រំដែន នៅតំបន់ឯកភាពគ្នា៨៤% ដែលប្រតិបត្តិករដោយបញ្ជាការកងវិស្វកម្ម អគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទ បានប្រវែងប្រមាណជា៦១៦គ.ម. និងធ្វើលូបេតុងបានចំនួន៤៨៨កន្លែង ស្ពានបានចំនួន៣០កន្លែង ក្នុងគោលដៅប្រែក្លាយតំបន់ព្រំដែនឱ្យទៅជាតំបន់សន្តិភាព មិត្តភាពសហប្រតិបត្តិការនិងការអភិវឌ្ឍលើគ្រប់វិស័យ ដើម្បីសុខដុមនីយកម្មរបស់ពលរដ្ឋនៅតំបន់ព្រំដែនក៏ដូចជាសម្រាប់កម្ពុជាទាំងមូល។

**២- ជាមួយព្រះរាជាណាចក្រថៃឡង់ដ៍**

- ក្រៅពីការចុះសិក្សាឯកតោភាគីខ្សែព្រំដែនកម្ពុជា ថៃ នៅតំបន់មិនទាន់ឯកភាពគ្នា ចំនួន២៨បង្គោល ក្រុមបច្ចេកទេសចម្រុះព្រំដែននៃប្រទេសទាំងពីរបានចុះជួសជុលបង្គោលព្រំដែនចាស់ បោះដោយគណៈកម្មការចម្រុះព្រំដែនបារាំង សៀម ដែលបាក់បែកខូចខាតបានចំនួន២៧បង្គោល នៅខេត្តបាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ

- គណៈកម្មការចម្រុះព្រំដែនគោកនៃប្រទេសទាំងពីរ បានបញ្ចប់ការវាស់វែងទ្វេភាគីតាមប្រព័ន្ធGPS និងបណ្តាញប្រថពីវិភាគ នៅតាមបណ្តោយព្រំដែនរួមកម្ពុជា ថៃ ដែលមានប្រវែងប្រមាណជា៨០៥គ.ម. និងបានបញ្ចប់ផងដែរការវាស់វែងទ្វេភាគីនៅច្រកទ្វារព្រំដែនអន្តរជាតិចំនួន៦ គឺនៅខេត្តព្រះវិហារ ឧបិនរាជធានី(អានសេះ ចុងអានម៉ា) ខេត្តបាត់ដំបង ស្រះកែវ(ភ្នំដី បានខៅឌីន) ខេត្តពោធិ៍សាត់ ត្រាត(ថ្មដា បានថាសេន) ខេត្តឧត្តរមានជ័យ បុរីរាំ(ជប់គគី សៃតាគូ) ខេត្តបាត់ដំបង ត្រាត(ឆករកា បានម៉ាមួង) និងខេត្តប៉ៃលិន ចន្ទបុរី(ព្រំ បានផាកាន) ក្នុងគោលដៅជំរុញនិងប្រែក្លាយតំបន់ព្រំដែនដែលជាតំបន់ក្តៅដោយសង្គ្រាមនិងគ្រាប់មីន ទៅជាតំបន់សេដ្ឋកិច្ច និងពាណិជ្ជកម្មរីកចម្រើនប្រែក្លាយជីវភាពរស់នៅរបស់ពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើងជាលំដាប់។

**៣- ជាមួយសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ**

- ទោះជាគណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរមិនទាន់ឈានដល់ការឯកភាពគ្នាលើសេចក្តីព្រាងសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋទទួលយកលទ្ធផល៨៦% ដែលភាគីទាំងពីរសម្រេចបាននិងការមិនទាន់ឯកភាពគ្នាលើ

សេចក្តីព្រាងTORស្តីពីការស្នើឱ្យបារាំងបញ្ជូនអ្នកបច្ចេកទេសមកគូរចម្លងខ្សែព្រំដែន១៤% ដែលនៅសល់ក្តីស្របពេលជាមួយគ្នានេះ គណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរបានបញ្ជូនក្រុមបច្ចេកទេសចម្រុះចុះជួសជុលបង្គោលព្រំដែនដែលបាក់បែក ខូចខាតបានចំនួន៨បង្គោល ក្នុងនោះមាន២បង្គោលនៅខេត្តព្រះវិហារ ចំប៉ាសាក់(លេខ០២៧និងលេខ០២៨) និង៦បង្គោលទៀត(លេខ០៣០ ០៣២ ០៣៧ ០៤៤ ០៦៣ និងលេខ០៦៦/១) នៅខេត្តស្ទឹងត្រែងនិងខេត្តចំប៉ាសាក់ ប្រទេសឡាវឱ្យបានល្អប្រសើរដូចដើមឡើងវិញ

- ក្រៅពីសមិទ្ធផលខាងលើ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនបានដឹកនាំចុះត្រួតពិនិត្យការសាងសង់ផ្លូវព្រំដែនដែលប្រតិបត្តិករដោយបញ្ជាការកងវិស្វកម្ម អគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទបានប្រវែងប្រមាណជាង៣៧គ.ម. ស្ពានចំនួន៣កន្លែងប្រវែង៦៣ម៉ែត្រនិងធ្វើលូបេតុងបានចំនួន៤៥កន្លែងផងដែរ។

## ៥- ការចាត់តាំងអនុវត្តគោលនយោបាយ«ភូមិ ឃុំ មានសុវត្ថិភាព»

ការជំរុញចលនាអនុវត្តគោលនយោបាយ"**ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព**" បានធ្វើឱ្យបរិយាកាសសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គមកាន់តែល្អប្រសើរ។ ជាក់ស្តែង យើងបានកាត់បន្ថយបទល្មើសដែលជះឥទ្ធិពលដល់ចិត្តសាស្ត្រសង្គមឱ្យថយចុះប្រមាណ១១% ខណៈដែលកិច្ចប្រតិបត្តិការបង្ក្រាបមានកម្រិតខ្ពស់រហូតដល់៩០% ធៀបទៅនឹងតួលេខនៃបទល្មើសដែលបានកើតឡើង។ ទន្ទឹមគ្នានេះ កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនខុសច្បាប់អំពើជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ រួមទាំងសកម្មភាពក្មេងទំនើងក៏ត្រូវបានចាត់អនុវត្តយ៉ាងសកម្មផុលផុសផងដែរ។ រីឯសណ្តាប់ធ្នាប់សាធារណៈនិងរបៀបរៀបរយសង្គមទៀតសោតក៏ត្រូវបានកែលម្អឱ្យកាន់តែប្រសើរជាងមុន ក្នុងនោះបានធ្វើឱ្យគ្រោះថ្នាក់ចរាចរណ៍ថយចុះ២៥% ខណៈអ្នកស្លាប់ថយ១៧% និងអ្នករងរបួសថយ២៤%។ ស្ថានភាពនេះ គឺជាចំណែកមួយដ៏សំខាន់ក្នុងការចូលរួមកាត់បន្ថយភាពក្រីក្រផងនិងជួយសម្រាលបន្ទុកការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលក្នុងការងាររបបសន្តិសុខសង្គមផង។

ចំពោះគ្រោះថ្នាក់អគ្គិភ័យ ទោះបីមានការកើនឡើងបន្តិច ប៉ុន្តែនៅក្នុងនោះហេតុការណ៍អគ្គិភ័យជាច្រើនត្រូវបានគ្រប់គ្រងនិងឆ្លើយតបបានទាន់ពេលវេលាខណៈដែលការឧបត្ថម្ភ គាំទ្រនិងការលើកកម្ពស់សមត្ថភាពភ្នាក់ងារពន្លត់អគ្គិភ័យ រួមទាំងការផ្សព្វផ្សាយអប់រំតាមគ្រប់មធ្យោបាយនិងគ្រប់រូបភាពត្រូវបានចាត់អនុវត្តយ៉ាងទូលំទូលាយនៅទូទាំងប្រទេស និងជាពិសេសការរៀបចំឱ្យមានក្រុមពន្លត់អគ្គិភ័យកាតព្វកិច្ចនិងក្រុមពន្លត់អគ្គិភ័យដោយស្ម័គ្រចិត្តនៅមូលដ្ឋាន។

កងកម្លាំងនគរបាលការពារព្រំដែនបានប្រកៀកស្មាយ៉ាងជិតស្និទ្ធជាមួយកងយោធពលខេមរភូមិន្ទការពារយ៉ាងគង់វង្សនូវអធិបតេយ្យជាតិ បូរណភាពទឹកដី ខិតខំបង្កើនទំនាក់ទំនងសហប្រតិបត្តិការជាមួយអាជ្ញាធរនិងកម្លាំងមានសមត្ថកិច្ចនៃប្រទេសជិតខាងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសឆ្លងដែន ព្រមទាំងចូលរួមអភិវឌ្ឍតំបន់ព្រំដែនកម្ពុជាជាតំបន់ព្រំដែនសន្តិភាព សហប្រតិបត្តិការនិងមានការរីកចម្រើនជឿនលឿនលើគ្រប់វិស័យ។

ស្នាដៃនិងពលិកម្មដ៏ធំធេងមួយទៀតរបស់កងកម្លាំងនគរបាលជាតិនាដំណាក់កាលចុងក្រោយនេះ គឺដៃម្ខាងពុះពាររួមចំណែកក្នុងការធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គមផង និងដៃម្ខាងទៀតចូលរួមនៅក្នុងគ្រប់ស្ថានការណ៍ជាមួយអាជ្ញាធរ ស្ថាប័នមានសមត្ថកិច្ចនិងយន្តការពាក់ព័ន្ធគ្រប់ថ្នាក់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩និងមេរោគបំប្លែងថ្មីផង។

## ៦- លទ្ធផលនៃការបង្ក្រាបបទល្មើស រក្សាសុវត្ថិភាពសង្គម

### លទ្ធផលនៃការបង្ក្រាបបទល្មើស ក្មេងទំនើង និងការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ

| បរិយាយ/ឆ្នាំ | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ/២០២២ | សរុប |
|---|---|---|---|---|---|---|---|
| បទល្មើសព្រហ្មទណ្ឌ(ករណី) | បង្ក្រាបរួម | ២ ៥៩៨ | ២ ៨៤២ | ២ ៩៤០ | ២ ៨៥៤ | ១ ៨៩៦ | ១៣ ១៣០ |
| | បទឧក្រិដ្ឋ | ៥២៨ | ៦០៥ | ៥៩៣ | ៥៤១ | ៤០០ | ២ ៦៦៧ |
| | បទមជ្ឈិម | ២ ០៧០ | ២ ២៣៧ | ២ ៣៤៧ | ២ ៣១៣ | ១ ៤៩៦ | ១០ ៤៦៣ |
| ក្មេងទំនើង(ករណី) | | ៨៨១ | ១ ០៤៦ | ១ ៤៩៥ | ១ ០៤៧ | ៧៩៦ | ៥ ២៦៥ |
| ការជួញដូរមនុស្សនិង<br>អាជីវកម្មផ្លូវភេទ (ករណី) | | ១០៤ | ១៦៣ | ១៤១ | ៣០០ | ១២៥ | ៨៣៣ |

### លទ្ធផលនៃការបង្ក្រាបបទល្មើសគ្រឿងញៀន

| បរិយាយ/ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ/២០២២ | សរុប |
|---|---|---|---|---|---|---|
| ការបង្ក្រាបបទល្មើសគ្រឿងញៀន (ករណី) | ៦ ១១១ | ៧ ៦៣៥ | ៨ ៨៦០ | ៥ ៩៧៤ | ៤ ៨១៣ | ៣៣ ៣៩៣ |
| ចាប់បានជនសង្ស័យ (នាក់) | ១១ ៧៩៥ | ១៥ ៦៦១ | ១៧ ៨៤៥ | ១២ ៦៧២ | ១១ ០៩២ | ៦៩ ០៦៥ |

**កត់សម្គាល់៖**

- បង្ក្រាបការជួញដូរចំនួន២១ ៣៦៦ករណី ឃាត់ខ្លួន៤០ ៣១៦នាក់ ស្រី៣ ០៩៤នាក់
- បង្ក្រាបការកែច្នៃផលិតសារធាតុញៀនចំនួន២៤ករណី ឃាត់ខ្លួន៧៥នាក់ ស្រី៨នាក់
- បង្ក្រាបការដាំដុះចំនួន១៥៩ករណី ឃាត់ខ្លួន៣២នាក់ ស្រី៩នាក់
- បង្ក្រាបការប្រើប្រាស់ចំនួន១១ ៨៤៤ករណី ឃាត់ខ្លួន២៨ ៦៤២នាក់ ស្រី១ ១៨៣នាក់
- បង្ក្រាបតាមដីកាចំនួន១ ៦៧២ករណី ឃាត់ខ្លួន១ ៦៥៩នាក់ ស្រី៦២នាក់
- វត្ថុតាងសារធាតុញៀនចំនួន១៧ ០៦០គីឡូក្រាម សារធាតុគីមីផ្សំ៥១៩ ៨០៣,៤៥គីឡូក្រាមម៉ូតូ៩ ២៧៧គ្រឿង រថយន្ត ៤៨៤គ្រឿង និងអាវុធចំនួន១៨២ដើម ។

### លទ្ធផលនៃការបង្ក្រាបល្បែងស៊ីសងគ្រប់ប្រភេទ

| បរិយាយ/ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ/២០២២ | សរុប |
|---|---|---|---|---|---|---|
| បង្ក្រាបរួម (លើក) | ៨៦៩ | ៨៧០ | ១ ២៩២ | ១ ៣៨៨ | ៧០២ | ៥ ១២១ |
| អនុវត្តវិធានការរដ្ឋបាល (លើក) | ៧៤០ | ៨០៧ | ១ ០៩១ | ១ ១៦២ | ៦០៧ | ៤ ៤០៧ |
| អនុវត្តវិធានការច្បាប់ (លើក) | ១២៩ | ៦៣ | ២០១ | ២២៦ | ៩៥ | ៧១៤ |

### ស្ថិតិគ្រោះថ្នាក់ចរាចរណ៍ អគ្គិភ័យ អាវុធជាតិផ្ទុះនិងគ្រោះថ្នាក់សង្គមផ្សេងទៀត

| បរិយាយ/ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ/២០២២ | សរុប |
|---|---|---|---|---|---|---|
| គ្រោះថ្នាក់ចរាចរណ៍ (លើក) | ៣ ២៦៧ | ៤.១២១ | ៣ ១៧៩ | ២ ៦៥៤ | ២ ៣១៩ | ១៥ ៥៤០ |
| គ្រោះអគ្គិភ័យ (លើក) | ៥៣៤ | ៧១៧ | ៩៣៧ | ៦៧០ | ៤៩៦ | ៣ ៣៥៤ |
| គ្រោះថ្នាក់ដោយអាវុធជាតិផ្ទុះ (លើក) | ២០ | ៤៧ | ៤២ | ៣១ | ៣០ | ១៧០ |
| គ្រោះថ្នាក់សង្គមផ្សេងទៀត (លើក) | ២ ៩៦០ | ៣ ៣៣៤ | ៣ ៦៦០ | ៣ ៩៩២ | ២ ៦៥៩ | ១៦ ៦០៥ |

## ៧- ការងារគ្រប់គ្រងពន្ធនាគារ

### ក- អំពីស្ថានភាពជនជាប់ឃុំ

| បរិយាយ/ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ១០/៩/២២ | ធៀបឆ្នាំ២០១៧ |
|---|---|---|---|---|---|---|
| ជនជាប់ឃុំសរុប | ៣១ ៦៨៦ | ៣៧ ០០៧ | ៣៩ ៣១៧ | ៣៨ ០៧០ | ៣៨ ០១៣ | កើន ៣៣,៧៨% |
| ទណ្ឌិត | ៩ ១១៥ | ១០ ៦៣៩ | ១២ ៦៦៤ | ១១ ៩៩២ | ១១ ៤៧១ | កើន ៥៩,៩៤% |
| ពិរុទ្ធជន | ១២ ០០៥ | ១១ ៦២០ | ១៦ ៧២១ | ១៥ ៥៧៣ | ១៥ ៩៣៩ | កើន ៣៩,៤៥% |
| អនុវត្តដីកាឱ្យដោះលែង | ១២ ៨០៨ | ១៦ ៥៦៩ | ១៩ ៧៦៨ | ១៩ ៩៩០ | ១៥ ០៦១ | កើន ៣៧,៧១% |
| ស្លាប់ | ៩៣ | ១២២ | ២១៣ | ២៨៩ | ១៦០ | កើន ១៨,៥១% |

**ខ- ស្ថានភាពជនជាប់ឃុំទទួលបានការអប់រំកែប្រែ និងការបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ**

| បរិយាយ/ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ១០/៩/២២ | សរុប |
|---|---|---|---|---|---|---|
| ទទួលបានការអប់រំកែប្រែ | ១៦៧ ១០១ | ១៧៩ ៩២៥ | ១០៣ ៨៩៨ | ១៧២ ៥០២ | ១៦៦ ៦៥០ | ៧៨៩ ៦៥០ |
| ទទួលបានការបណ្តុះបណ្តាល មុខជំនាញវិជ្ជាជីវៈ | ១ ០១៤ | ៣.៣៨៨ | ២.៨៩១ | ១.៩៧៨ | ១ ៨៩៥ | ១១ ១៦៦ |

**កត់សម្គាល់៖** ក្នុងជនជាប់ឃុំម្នាក់ អាចមានការចូលរួមកម្មវិធីអប់រំកែប្រែស្តារនីតិសម្បទាជាច្រើនលើកតាមស្ថានភាពជាក់ស្តែង។

## ៨- ការងារអត្តសញ្ញាណកម្ម

រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់លើការងារអត្តសញ្ញាណកម្ម ដោយបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្មរយៈពេល១០ឆ្នាំ(២០១៧-២០២៦) សំដៅពង្រឹងប្រព័ន្ធចុះបញ្ជីអត្រានុកូល-ដ្ឋាននិងអត្តសញ្ញាណកម្ម ដើម្បីសម្រេចឱ្យបាននូវគោលដៅ **"បុគ្គលម្នាក់មានអត្តសញ្ញាណតែមួយ"** និង **"មនុស្សទាំងអស់ត្រូវបានកំណត់អត្តសញ្ញាណ"** ដែលដឹកនាំអនុវត្តដោយយន្តការអន្តរស្ថាប័នថ្នាក់ជាតិមួយគឺគណៈកម្មាធិការជាតិដឹកនាំតម្រង់ទិសការងារអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម (គ.ជ.ដ.អ)។

ស្ថិតក្រោមទស្សនវិស័យដែលចង្អុលបង្ហាញក្នុងផែនការយុទ្ធសាស្ត្រ និងសម្រាប់ធ្វើជាមូលដ្ឋានទិន្នន័យក្នុងការផលិតស្ថិតិអត្រានុកូលដ្ឋានឱ្យបានល្អ ស្របតាមស្តង់ដាអន្តរជាតិគ.ជ.ដ.អ បានសម្រេចដាក់ឱ្យអនុវត្តសាកល្បងនូវការចុះបញ្ជីអត្រានុកូលដ្ឋាននិងការចុះបញ្ជីស្នាក់នៅដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការតភ្ជាប់ប្រព័ន្ធជូនដំណឹងអំពីកំណើតរស់និងមរណភាពពីមូលដ្ឋានសុខាភិបាលនៃក្រសួងសុខាភិបាលទៅប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងរបៀបរបបការងារផ្តល់សេវាអត្តសញ្ញាណកម្មនៅការិយាល័យច្រកចេញចូលតែមួយនៅឃុំ សង្កាត់មួយចំនួនក្នុងខេត្តកែប ខេត្តកំពត និងរាជធានីភ្នំពេញ ដោយមានកិច្ចសហការរវាងក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាលនិងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក្រោមការជួយគាំទ្រពីអ្នកជំនាញនៃអង្គការVital Strategies ។

លើការងាររៀបចំក្របខ័ណ្ឌច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្ម គ.ជ.ដ.អ. បានបង្កើតក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់នៅឆ្នាំ២០១៨ ដែលមានសមាសភាពចូលរួមពីមន្ត្រីជាន់ខ្ពស់របស់ក្រសួងយុត្តិធម៌និងក្រសួងមហាផ្ទៃ ដោយសហការជាមួយភាគីពាក់ព័ន្ធសំខាន់ៗ រួមមានក្រសួងសុខាភិបាល វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការក្រោមការគាំទ្រផ្នែកច្បាប់ពីអ្នកជំនាញនៃអង្គការVital Strategies ដោយបានរៀបចំបញ្ចប់នូវសេចក្តីព្រាងច្បាប់ដើម្បីធានាថាប្រព័ន្ធអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាននិងអត្តសញ្ញាណកកម្ម (Civil Registration Vital Statistics and Identification-CRVSID) ត្រូវបានអនុវត្តយ៉ាងពេញលេញនិងរួមបញ្ចូលគ្នាស្របតាម "គោលការណ៍ណែនាំស្តីពីក្របខ័ណ្ឌនីតិបញ្ញត្តិសម្រាប់ការចុះបញ្ជីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាននិងការគ្រប់គ្រងអត្តសញ្ញាណរបស់អង្គការសហប្រជាជាតិ" ។

**ការងារចុះបញ្ជីអត្រានុកូលដ្ឋាន**(ឯកតា: នាក់)

| ល.រ | សកម្មភាពការងារ/ឆ្នាំ | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ/២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ចំនួនប្រជាពលរដ្ឋដែលបានចុះបញ្ជីគ្រប់ប្រភេទ | សរុប | ៤៦៨ ១៤៦ | ៥០៨ ៥៨៨ | ៦១៤ ២២៤ | ៦៧១ ៧២៨ | ៦៤៣ ៥៨១ | ២ ៩០៦ ២៦៧ |
| | | ស្រី | ២៣០ ៥៨៦ | ២៤៥ ៨១៨ | ៣០១ ១៦២ | ៣២៨ ២៩៨ | ៣៣៣ ៥៥០ | ១ ៤៣៩ ៤១៤ |
| ២ | សំណុំឯកសារស្នើសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងបរទេស | សរុប (ច្បាប់) | ១ ៩១៨ | ២ ០២០ | ១ ០០៨ | ៥៨៥ | ១ ២៣២ | ៦ ៧៦៧ |
| | | សញ្ជាតិ | ៣៩ | ៣៧ | ៣១ | ២២ | ៣៤ | - |

**ការងារគ្រប់គ្រងស្ថិតិប្រជាពលរដ្ឋ**

| លរ | សកម្មភាពការងារ/ឆ្នាំ | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ/២០២២ | សរុប |
|---|---|---|---|---|---|---|---|---|---|
| ១ | ផ្តល់សៀវភៅស្នាក់នៅ (ឯកតាក្បាល) | ផ្តល់ថ្មី | លទ្ធផលក្នុងឆ្នាំ | ១២៦ ៧០៨ | ៨៤ ៨០២ | ១២៣ ៥៦៧ | ៩២ ៣១១ | ៨០ ១៥៤ | ៥០៧ ៥៤២ |
| | | | បូកយោង | ៣ ១៣៧ ២៣៤ | ៣ ២២២ ០៣៦ | ៣ ៣៤៥ ៦០៣ | ៣ ៤៣៧ ៩១៤ | ៣ ៥១៨ ០៦៨ | ៣ ៥១៨ ០៦៨ |
| | | ទុតិយតា | | ៧៦ ០៨៩ | ៥៧ ៣៩៨ | ១០១ ៣៧០ | ៦៧ ៣៤៨ | ៦៤ ៩៦២ | ៣៦៧ ១៦៧ |
| ២ | ផ្តល់សៀវភៅគ្រួសារ (ឯកតាក្បាល) | ផ្តល់ថ្មី | លទ្ធផលក្នុងឆ្នាំ | ៧៧ ២៨៩ | ៤៩ ៨៣៥ | ៧៣ ៨៧២ | ៧៤ ៦២៧ | ៦៩ ៨០៦ | ៣៤៧ ៤២៩ |
| | | | បូកយោង | ២ ៩៣៥ ១៤១ | ២ ៩៨៤ ៩៧៦ | ៣ ០៥៨ ៨៤៨ | ៣ ១៣៣ ៤៧៥ | ៣ ២០៣ ២៨១ | ៣ ២០៣ ២៨១ |
| | | ទុតិយតា | | ៤៥ ២៨៥ | ៣៣ ៩៧២ | ៦០ ៥១៥ | ៤៣ ៧១៤ | ៤៥ ៩០២ | ២២៩ ៣៨៨ |

**ការងារផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ**

| ល.រ | សកម្មភាពការងារ/ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ/២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ១ | ផលិតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរបាន(ឯកតាសន្លឹក) | ៣៩៣ ៥៩១ | ៥០៣ ០០៣ | ៥៨៤ ៧៤១ | ៤៧៩ ០៣០ | ៣២៨ ៣១២ | ២ ២៨៨ ៦៧៧ |
| ២ | ផ្តល់ជូនរាជធានី ខេត្តសម្រាប់ចែកជូនប្រជាពលរដ្ឋ(ឯកតាសន្លឹក) | ៣៦៨ ៥២៩ | ៤៧៦ ០៦៣ | ៦១៩ ៣៥៥ | ៤៦៩ ៥៧៨ | ៣២៩ ១៤២ | ២ ២៦២ ៦៦៧ |

**ការងារលិខិតឆ្លងដែន**

| ល.រ | សកម្មភាពការងារ/ឆ្នាំ | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ/២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | លិខិតឆ្លងដែន (ឯកតា ក្បាល) | ផលិតនិងផ្តល់ជូន | ៤៩៥ ៣៥០ | ៣៦០ ០៨៤ | ១០០ ៤៦២ | ៣៤ ១៧៧ | ១៥០ ៧០៧ | ១ ១៤០ ៧៨០ |
| ២ | លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅក្រៅប្រទេស (ឯកតា ក្បាល) | ផលិតនិងផ្តល់ជូន | ៤៩៣ ៧៣៤ | ៥៣ ៨៣៨ | ២១ ៧៧៣ | ១៣ ៨១៧ | ៥០ ៣៧១ | ៦៣៣ ៥៣៣ |

**ការងារសញ្ជាតិ**

| សកម្មភាពការងារ/ឆ្នាំ | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ/២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ទទួលព្រះរាជក្រឹត្យស្តីពី ការផ្តល់សញ្ជាតិតាមរយៈសញ្ជាតូបនីយកម្ម | សរុប | ១៩៥ | ៧៥៩ | ៣៦៧ | ២៨០ | ១៧៨ | ១.៧៧៩ |
| | ស្រី | ២៦ | ៨៦ | ៣៧ | ៣០ | ៣៣ | ២១២ |
| | សញ្ជាតិ | ១០ | ២០ | ១៦ | ១៣ | ១៦ | ៣០ |
| ទទួលព្រះរាជក្រឹត្យស្តីពី ការផ្តល់សញ្ជាតិតាមរយៈការទាមទារសញ្ជាតិ | សរុប | ៥ | ១៦ | ២០ | ២ | ៧ | ៥០ |
| | ស្រី | ២ | ៩ | ៦ | ១ | ០ | ១៨ |
| | សញ្ជាតិ | ៥ | ១១ | ១៣ | ២ | ៥ | ២២ |
| ទទួលព្រះរាជក្រឹត្យស្តីពី ការលះបង់សញ្ជាតិ | សរុប | ១៦ | ០ | ១១ | ១៩ | ៤ | ៥០ |
| | ស្រី | ១៣ | ០ | ៦ | ៩ | ២ | ៣០ |

## ៩- ការងារអន្តោប្រវេសន៍

ការងារអន្តោប្រវេសន៍បានសម្រេចនូវសមិទ្ធផលធំធេងជាច្រើនជូនជាតិមាតុភូមិ ក្នុងនោះបានធានាគត់មត់នូវអធិបតេយ្យជាតិ ទប់ស្កាត់មិនឱ្យកើតមានអំពើភេរវកម្មនៅកម្ពុជា ទប់ស្កាត់ការលួចលាក់ជ្រកកោនធ្វើសកម្មភាពរបស់អង្គការភេរវកម្មនានា ទប់ស្កាត់លំហូរជ្រៀតចូលស្នាក់នៅដោយខុសច្បាប់របស់ជនបរទេសអន្តោប្រវេសន្ត គ្រប់គ្រងដំណើរចេញចូលប្រទេសឆ្លើយតបជាវិជ្ជមានចំពោះនយោបាយទេសចរណ៍ជាតិ នយោបាយវិនិយោគ ពាណិជ្ជកម្ម ការអភិវឌ្ឍវិស័យការងារនិងវិស័យមួយចំនួនទៀត។

ឈរលើស្មារតីទទួលខុសត្រូវចំពោះជាតិមាតុភូមិនិងប្រវត្តិសាស្ត្រ ក្រសួងមហាផ្ទៃបានកំណត់នូវយុទ្ធសាស្ត្រសំខាន់ៗចំនួន៣ ដើម្បីគ្រប់គ្រងជនបរទេស រួមមាន១- ទប់ស្កាត់ម៉ឺងម៉ាត់មិនឱ្យមានកំណើនបន្ថែមទៀតនូវជនបរទេសស្នាក់នៅបែបអន្តោប្រវេសន៍ ដោយផ្តើមចេញពីការចុះធ្វើជំរឿនស្ថិតិជនបរទេសអន្តោប្រវេសន្តឡើងវិញ ២- យកចិត្តទុកដាក់ជំរុញដោះស្រាយបញ្ហាជនបរទេសដែលមានវត្តមានក្នុងប្រទេសឱ្យស្ថិតនៅក្រោមដំបូលនៃច្បាប់ និង ៣- គ្រប់គ្រងហ្មត់ចត់ការស្នាក់នៅបណ្តោះអាសន្នរបស់ជនបរទេសមិនមែនអន្តោប្រវេសន្តគ្រប់ប្រភេទ។

**ក- ស្ថិតិអ្នកដំណើរចេញ ចូលប្រទេសជាលក្ខណៈអន្តរជាតិ**

| បរិយាយ/ឆ្នាំ | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ/២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ជនបរទេស | ចូល | ៥ ៩០០ ២៨៤ | ៦ ២៩៥ ០៦២ | ១ ៥៨៤ ១៨២ | ១៤៧ ៧៣៧ | ៧១៥ ៥៩៧ | ១៤ ६४២ ៨៦៦ |
| | ចេញ | ៥ ៧៧៩ ៩៦៥ | ៦ ៣០៣ ២៤៦ | ១ ៩២៧ ៦៨៨ | ១៥០ ១៥១ | ៦៣១ ៦៥៥ | ១៤ ៧៩២ ៧០៤ |
| ពលរដ្ឋខ្មែរ | ចេញ | ១ ៩៨៥ ៨៥៤ | ២ ១៩៣ ៥៥៨ | ៤៥១ ៤៤០ | ២៩ ៣៦៥ | ៣២៨ ៥៥២ | ៤ ៩៨៨ ៧៦៩ |
| | ចូល | ១ ៧១២ ៩២៩ | ២ ០៣៦ ៦៦៨ | ៤៨៦ ១៣៣ | ១៤ ១៣២ | ៣០០ ៤៣១ | ៤ ៥៥០ ២៩៣ |

**ខ- ស្ថិតិការផ្តល់ទិដ្ឋាការចេញ ចូលនិងការអនុញ្ញាតឱ្យបន្តរយៈពេលស្នាក់នៅ**

| បរិយាយ/ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ២០២២ | សរុប |
|---|---|---|---|---|---|---|
| ទិដ្ឋាការចូល | ២ ៧៨២ ២៩៧ | ២ ៩១២ ៧៥១ | ៥៦២ ៣៣៨ | ១ ៨៨៨ | ១៧៧ ៨៦៩ | ៦ ៤៣៧ ១៤៣ |
| ទិដ្ឋាការចេញ | ៥ ៨១៥ | ១៥ ១៩៣ | ២ ៨៦២ | ៩៤៨ | ១ ១៦៤ | ២៥ ៩៨២ |
| បន្តរយៈពេលស្នាក់នៅ | ៤៥៣ ៤៦៦ | ៧៤៣ ៦២៥ | ៣៥៣ ១៥៥ | ២៩៥ ១៥៩ | ៣០១ ០៣៩ | ២ ១៤៦ ៤៤៣ |

**គ-ការទប់ស្កាត់ការចេញ ចូលខុសច្បាប់និងការអនុវត្តនីតិវិធីចំពោះបទល្មើសអន្តោប្រវេសន៍**

| បរិយាយ/ឆ្នាំ | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ ២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ផ្អាកដំណើរមិនឱ្យចេញ ចូលកម្ពុជា និងបញ្ជូនទៅប្រទេសដើមវិញ(នៅតាមព្រំដែន) | មនុស្ស | ៥៤០ | ១ ៤១៦ | ៤២៨ | ១០៥ | ៨០៨ | ៣ ១៩២ |
| | សញ្ជាតិ | ៦៩ | ៦៩ | ៦៩ | ៤១ | ៦០ | - |
| ការអនុវត្តនីតិវិធីបណ្តេញចេញក្រោយស្រាវជ្រាវ បង្ក្រាបបទល្មើសអន្តោប្រវេសន៍(ក្នុងប្រទេស) | មនុស្ស | ១ ៣០៣ | ១ ៨៧៨ | ៧៩៦ | ៣ ៥៩៤ | ៣ ៥៨៣ | ១១ ១០៩ |
| | សញ្ជាតិ | ៥២ | ៦៣ | ៤៩ | ៤៣ | ៣២ | ១០៧ |

## ទី២- បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច ការវិនិយោគ និងការអភិវឌ្ឍ ការងារកម្មសិទ្ធិបញ្ញា និងការចុះបញ្ជីម៉ាកនិងសេវាពាក់ព័ន្ធ

**ស្ថិតិនៃការចុះបញ្ជីនិងលុបចេញពីបញ្ជីពាណិជ្ជកម្ម** (គេហទំព័រwww.moc.gov.kh)

<table>
<tr><th>ល.រ.</th><th>យថាប្រភេទនៃការចុះបញ្ជីពាណិជ្ជកម្ម</th><th>២០១៨</th><th>២០១៩</th><th>២០២០</th><th>២០២១</th><th>២០២២ (៩ខែ)</th></tr>
<tr><td colspan="7">ក- ការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម(ថ្មី)</td></tr>
<tr><td>១</td><td>ក្រុមហ៊ុនមូលធន</td><td>១២ ២៧៦</td><td rowspan="3">៩ ៣៨៤</td><td rowspan="3">៥ ៦៧៧</td><td>៤ ៧០២</td><td>៣ ៧៨៥</td></tr>
<tr><td>២</td><td>ក្រុមហ៊ុនពាណិជ្ជកម្មបរទេស</td><td>១៥៩</td><td>៤៥</td><td>៣១</td></tr>
<tr><td>៣</td><td>ក្រុមហ៊ុនសហកម្មសិទ្ធ</td><td>០</td><td>៣</td><td>០</td></tr>
<tr><td>៤</td><td>សហគ្រាសឯកបុគ្គល</td><td>៣ ៦៩៥</td><td>៣ ៩១៥</td><td>២ ១៨៣</td><td>២ ៩២៧</td><td>៤ ៥២៨</td></tr>
</table>

| | | | | | | |
|---|---|---|---|---|---|---|
| សរុបស្នើសុំចុះបញ្ជីពាណិជ្ជកម្ម | | ១៦ ១៣០ | ១៣ ២៥៩ | ៧ ៨៦០ | ៧ ៦៧៧ | ៨ ៣៤៤ |
| ខ- ការស្នើសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម | | | | | | |
| ១ | ក្រុមហ៊ុនមូលធន | ១៣១ | ១៥៥ | ៤៧៤ | ៥៨៩ | ៥៥៩ |
| ២ | ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | ១១ | | | ២៨ | ១៧ |
| ៣ | ក្រុមហ៊ុនសហកម្មសិទ្ធិ | ០ | | | ០ | ០ |
| ៤ | សហគ្រាសឯកបុគ្គល | ៩ | ១៩ | ២៦ | ២៦ | ៤៨ |
| សរុបការលុបឈ្មោះចេញពីបញ្ជី | | ១៥១ | ១៧៤ | ៥០០ | ៦៤៣ | ៦២៤ |

- បានទទួលពាក្យស្នើសុំ លិខិតអនុញ្ញាតនិងអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកចំនួន៨ ៧៥៤ និងលិខិតជូនដំណឹងស្តីពីអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកចំនួន១៥ ៩៩៧(គិតត្រឹមខែកញ្ញា ឆ្នាំ២០២២)

- ក្នុងរយៈពេល៤ឆ្នាំ(២០១៨-២០២១) និង៩ខែ នៃឆ្នាំ២០២២ ក្រសួងពាណិជ្ជកម្មបានទទួលពាក្យស្នើសុំចុះបញ្ជីការពារម៉ាកសញ្ញាពាណិជ្ជកម្មបានចំនួន២២ ៩០៤ពាក្យស្នើសុំ ដោយក្នុងនោះសម្រាប់រយៈពេល៩ខែ នៃឆ្នាំ២០២២ បានចំនួន២ ៥៤៧ពាក្យស្នើសុំ។

## ស្ថិតិចុះម៉ាកសញ្ញាពាណិជ្ជកម្ម

| ល.រ. | យថាប្រភេទនៃការចុះបញ្ជីម៉ាក | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) | សរុប |
|---|---|---|---|---|---|---|---|
| ១ | ចុះបញ្ជីម៉ាក | ៤ ០៧០ | ៤ ២៧៣ | ៥ ៦២៨ | ៦ ៣៨៦ | ២ ៥៤៧ | ២២ ៩០៤ |
| ២ | បញ្ជាក់ប្រតិវេទន៍ចំនួន | ៣ ៧៨៤ | ៤ ៤៨១ | ៣ ៦៧៨ | ៣ ៦២៧ | ៣ ៣២១ | ១៨ ៨៩១ |
| ៣ | ចុះបញ្ជីម៉ាកតាមប្រព័ន្ធម៉ាឌ្រីត | ១ ៣៧៦ | ១ ៩០១ | ២ ៣៦៨ | ១ ៩៣៨ | ១ ៦៧១ | ៩ ២៥៤ |
| ៤ | ចុះបញ្ជីម៉ាកទំនិញសម្គាល់ភូមិសាស្ត្រ | ១ | ៤ | ០ | ៤ | ២ | ១១ |
| ៥ | ការចុះបញ្ជីម៉ាកសាឡើងវិញ | ១ ៧៨៤ | ១ ៧៧៦ | ២ ៥២៩ | ២ ៤១៩ | ៣ ២៩៣ | ១១ ៨០១ |
| ៦ | ការកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខ | ៧១ | ១៣២ | ១០៦ | ៨០ | ៥៩ | ៤៤៨ |
| ៧ | ការកត់ត្រាអាជ្ញាបណ្ណ | ៥៧ | ៣ | ១១១ | ៣៥ | ៣៤ | ២៤០ |
| ៨ | ការផ្លាស់ប្តូរផ្សេងៗ | ១ ៩៨៧ | ២ ១៣៣ | ១ ៧១២ | ២ ៦០៤ | ២ ២៨៧ | ១០ ៧២៣ |
| ៩ | ការធ្វើទុតិយតាវិញ្ញាបនបត្រ | ៨២៩ | ៩៩២ | ៥៨៦ | ៦៦២ | ៥២៦ | ៣ ៥៩៥ |

- បានចុះបញ្ជី និងសម្ពោធដាក់ឱ្យប្រើប្រាស់នូវម៉ាកសមូហភាព«គុយទាវភ្នំពេញ» «អំបុកកំពង់ធំ»«អង្ករព្រះវិហារ» និងកំពុងរៀបចំចុះបញ្ជីម៉ាកសមូហភាព«ចម្លាក់ប្រាក់ស្ពាន់ខេត្តកណ្តាល» «ក្រូចពោធិ៍សាត់» «ដូងខ្ទិះបាត់ដំបង» និង«នំបញ្ចុកសៀមរាប»

- បានចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ«ស្ករត្នោតកំពង់ស្ពឺ» «ក្រូចថ្លុងកោះទ្រង់» «ប្រហុកសៀមរាប» «បង្គាក្រៀមកោះកុង» «បង្គាក្រៀមកំពង់សោម» និង«ទឹកឃ្មុំព្រៃមណ្ឌលគិរី»

- កំពុងសិក្សាប្រមូលព័ត៌មាន និងរៀបចំចុះបញ្ជីម៉ាក«ទឹកត្រីកំពត កែប» «បង្កងតាកែវ» «អំបិល និងផ្កាអំបិលកំពត កែប» «ក្តាមថ្មកោះកុង» «ចម្លាក់ប្រាក់ស្ពាន់ខេត្តកណ្តាល» «ក្រូចពោធិ៍សាត់» «ដូងខ្ទិះបាត់ដំបង» «នំបញ្ចុកសៀមរាប» «ស្ពូនឆ្នាំងដីខេត្តកំពង់ឆ្នាំង» «ពងទាកូនស្រែរនោង ខេត្តតាកែវ» «សូត្រភ្នំស្រុក» «អង្ករស្មាច់ស្វាយរៀង» «ធុរេនកំពត» «ធុរេនសំឡូត» «មៀនប៉ៃលិន» និង«អង្ករនាងអំ» បានចុះបញ្ជីម៉ាកវិញ្ញាតកម្ម «MALYS ANGKOR» សម្រាប់ការនាំចេញអង្ករកម្ពុជា។

**ទី៣- ការពង្រឹងភាពជាម្ចាស់ ភាពជាដៃគូក្នុងការអភិវឌ្ឍ និងសហប្រតិបត្តិការអន្តរជាតិ**

**ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ(កបទ.សអ.) សម្រេចការងារបាន៖**

ស្ថានភាពតំបន់និងអន្តរជាតិ រួមទាំងនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិកក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ បានបន្តវិវត្តយ៉ាងឆាប់រហ័សនិងស្មុគស្មាញ ដោយសារតែការផ្លាស់ប្តូរតុល្យភាពអំណាចក្នុងចំណោមប្រទេសមហាអំណាច ក៏ដូចជាការកែសម្រួលយុទ្ធសាស្ត្ររបស់មហាអំណាចថ្នាក់កណ្តាល និងប្រទេសតូចៗ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលទាំងនោះ។ លើសពីនេះទៅទៀតបញ្ហាប្រឈមសន្តិសុខមិនប្រពៃណីកាន់តែមានភាពធ្ងន់ធ្ងរក្នុងខណៈដែលការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ បានបង្កនូវវិបត្តិពហុសណ្ឋាននិងពហុវិស័យ។ ស្របពេលដែលពិភពលោកព្យាយាមស្តារសេដ្ឋកិច្ច សង្គមពីវិបត្តិកូវីដ-១៩ សង្គ្រាមនៅអ៊ុយក្រែនបាននិងកំពុងបន្ថយល្បឿនកំណើនសេដ្ឋកិច្ចពិភពលោកទាំងមូលនិងរុញកំណើនអតិផរណាយ៉ាងលឿន ដោយសារតែការកើនឡើងនៃតម្លៃអាហារនិងថាមពល ភាពរអាក់រអួលនៃខ្សែច្រវាក់ផ្គត់ផ្គង់និងពាណិជ្ជកម្ម ការធ្លាក់ចុះនៃទំនុកចិត្តក្នុងការធ្វើអាជីវកម្មក៏ដូចជាភាពមិនប្រាកដប្រជានៅក្នុងការធ្វើវិនិយោគ។ វិបត្តិអ៊ុយក្រែនក៏បានប៉ះពាល់ទៅដល់ទំនុកចិត្តផ្នែកយុទ្ធសាស្ត្រនិងទិដ្ឋភាពសន្តិសុខ។ វិបត្តិនៅអ៊ុយក្រែននេះបានជំរុញឱ្យប្រទេសក្នុងតំបន់ចោទសួរអំពីប្រសិទ្ធភាពនៃការអនុវត្តគោលការណ៍ និងគោលបំណងដែលមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ (អ.ស.ប.) ជាពិសេសការគោរពអធិបតេយ្យនិងបូរណភាពទឹកដីរបស់រដ្ឋនិងការមិនប្រើប្រាស់កម្លាំងនៅក្នុងទំនាក់ទំនងអន្តរជាតិ។ សង្គ្រាមនៅអ៊ុយក្រែនបានរីករាលដាលក្លាយជាការប្រឈមមុខដាក់គ្នារវាងរុស្ស៊ី និងបស្ចិមលោកដែលកាន់ស្មុគស្មាញនិងពិបាករកច្រកចេញ។ ការព្រមានប្រើប្រាស់អាវុធនុយក្លេអ៊ែរពីសំណាក់ភាគីបដិបក្ខបានរុញច្រានវិបត្តិនេះចូលដល់ដំណាក់កាលដ៏ស្រួចស្រាល់និងគ្រោះថ្នាក់ដែលអាចនឹងប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សន្តិភាព សន្តិសុខ និងស្ថិរភាពអន្តរជាតិ។

ក្នុងបរិបទនេះ រដ្ឋតូចដូចកម្ពុជាបាននិងកំពុងជួបប្រឈមនូវការលំបាកកាន់តែខ្លាំងក្នុងការប្រកាន់និងរក្សាបន្ទាត់នយោបាយក្រៅប្រទេសដែលមានការថ្លឹងថ្លែង។ ទន្ទឹមគ្នានេះការពារបាននូវផលប្រយោជន៍ស្នូលរបស់ខ្លួនហើយកាន់តែមានភាពលំបាកខ្លាំងឡើងសម្រាប់កម្ពុជាក្នុងការអនុវត្តនយោបាយការបរទេស ដោយផ្អែកលើគោលការណ៍អព្យាក្រឹតអចិន្ត្រៃយ៍និងមិនចូលបក្សសម្ព័ន្ធ នៅក្នុងសណ្ដាប់ធ្នាប់តំបន់ដែលកំពុងតែបែកញែកចេញជាពីរនេះ។ កម្ពុជាបានទទួលរងនូវចំហាយក្តៅពីការមិនជ្រើសរើសយកគូភាគីម្ខាងណារួចទៅហើយតាមរយៈការរៀបចំសេណារីយ៉ូផ្សេងៗសំដៅបង្កើតបដិវត្តន៍ពណ៌ដើម្បីផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់។ ការអនុវត្តស្តង់ដាទ្វេចំពោះកម្ពុជាពីសំណាក់តួអង្គអន្តរជាតិ ជាពិសេសមហាអំណាចធំៗទាក់ទិននឹងការលើកកម្ពស់គុណតម្លៃលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ក៏បានបង្កផលប៉ះពាល់ដល់កិត្យានុភាពរបស់កម្ពុជាលើឆាកអន្តរជាតិ។ កម្ពុជាបានទទួលរងផលប៉ះពាល់ពីការប្រើប្រាស់ទណ្ឌកម្មសេដ្ឋកិច្ចនិងឧបករណ៍ច្បាប់ ដូចជាករណីEBA និងច្បាប់ម៉ាហ្គីតស្គីសកល (Global Magnitsky Act)។ កាន់តែគ្រោះថ្នាក់នោះ កម្ពុជាត្រូវបានគេចោទប្រកាន់ដោយមានចរិតមូលបង្កាច់ថាបានអនុញ្ញាតឱ្យមានមូលដ្ឋានយោធាចិននៅលើទឹកដីរបស់ខ្លួន។

ស្ថិតនៅចំពោះមុខសភាពការណ៍ពិភពលោកវិវត្តប្រែប្រួលស្មុគស្មាញឆាប់រហ័ស ប្រកបដោយគ្រោះថ្នាក់មិនអាចប៉ាន់ប្រមាណជាមុនបែបនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រក្នុងការដឹកនាំប្រទេសស្របតាមទិសស្លោក«**កែទម្រង់ខាងក្នុង បង្កើនមិត្តខាងក្រៅដោយឈរលើមូលដ្ឋានឯករាជ្យ**»។ ក្នុងន័យនេះ

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ (កបទ.សអ.) ក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) កន្លងមកនេះ បានខិតខំពង្រឹងនិងពង្រីកទំនាក់ទំនងជាមួយមិត្តចាស់និងថ្មីប្រកបដោយភាពបត់បែនវាងវៃ ការពារផលប្រយោជន៍ជាតិ អធិបតេយ្យ បូរណភាពទឹកដីនិងសេចក្តីថ្លៃថ្នូរជាតិចូលរួមពង្រឹងពហុភាគីនិយម និងសណ្តាប់ធ្នាប់ពិភពលោកដែលផ្អែកលើប្រព័ន្ធច្បាប់អន្តរជាតិ ប្រើប្រាស់មធ្យោបាយការទូតដើម្បីផលប្រយោជន៍សេដ្ឋកិច្ចនិងវប្បធម៌និងបង្កើនសមត្ថភាពការទូតកម្ពុជាតាមរយៈកំណែទម្រង់ឥតឈប់ឈរ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងច្បាស់តាមរយៈសមិទ្ធផលការងារធំៗទាំង៥របស់កបទ.សអ. ដូចខាងក្រោម៖

**១- ការការពារផលប្រយោជន៍ជាតិ ជាពិសេសការការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី** (ហ្វេសប៊ុកផេក : Ministry of Foreign Affairs and International Cooperation Cambodia គេហទំព័រwww.mfaic.gov.kh)

**១.១- ការការពារឯករាជ្យ អធិបតេយ្យ កិត្តិយស និងសេចក្តីថ្លៃថ្នូរជាតិ**

*ស្ថានភាពសិទ្ធិមនុស្សនិងការអនុវត្តលទ្ធិប្រជាធិបតេយ្យ៖*

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ទោះបីមានកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងនីតិរដ្ឋ និងធ្វើឱ្យសម្រេចបាននូវការអភិវឌ្ឍផ្នែកសង្គម សេដ្ឋកិច្ចគួរឱ្យកត់សម្គាល់យ៉ាងណាក្តី កម្ពុជានៅតែបន្តទទួលរងនូវការទិតៀនដែលមានលក្ខណៈលម្អៀងនិងបង្កប់ចេតនានយោបាយ ពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សនិងការអនុវត្តលទ្ធិប្រជាធិប-តេយ្យ។ ឆ្លើយតបនឹងស្ថានការណ៍នេះ កបទ.សអ. រួមទាំងស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជាប្រចាំអង្គការសហប្រជាជាតិ(អ.ស.ប.) បាន៖

- ធ្វើសេចក្តីថ្លែងការណ៍៥០លើក បដិសេធការចោទប្រកាន់ដែលខ្វះភាពសត្យានុម័តមិនគ្រប់ជ្រុងជ្រោយនិងមិនបានឆ្លុះបញ្ចាំងពីតថភាពពិតប្រាកដ
- ថ្លែងបទអន្តរាគមន៍១៦០លើក ក្នុងវេទិកាក្រុមប្រឹក្សាសិទ្ធិមនុស្ស និងជួបពិភាក្សាជាមួយតំណាងអចិន្ត្រៃយ៍បរទេស និងអង្គទូតជាង១២០លើក ដើម្បីលើកបង្ហាញពីវឌ្ឍនភាពនៃការអនុវត្តសិទ្ធិមនុស្សនៅកម្ពុជាដល់មជ្ឈដ្ឋានសហគមន៍អន្តរជាតិ
- ចងក្រងរបាយការណ៍ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ចំនួន៥ច្បាប់ ដើម្បីធ្វើជាមូលដ្ឋានឯកសារយោងក្នុងការពន្យល់ ផ្ទៀងផ្ទាត់និងវាយតម្លៃលើស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ជាពិសេសជាមូលដ្ឋានសម្រាប់ជំនួបពិភាក្សាជាមួយតំណាងអចិន្ត្រៃយ៍បរទេសនិងអង្គទូតនានា។

ជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងនេះ នៅក្នុង «កិច្ចសន្ទនាអន្តរសកម្មជាមួយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា» ចំនួនប្រទេសដែលបានថ្លែងគាំទ្រកម្ពុជា មានការកើនឡើងជាលំដាប់ (ក្នុងឆ្នាំ២០១៩៖ ប្រទេសចំនួន១៧ចូលរួម ក្នុងនោះប្រទេសចំនួន៦ បានថ្លែងគាំទ្រកម្ពុជា និងនៅក្នុងខែតុលាឆ្នាំ២០២២៖ ប្រទេសចំនួន៣៩ចូលរួម ក្នុងនោះប្រទេសចំនួន២៨ បានថ្លែងគាំទ្រកម្ពុជា)។ ជាងនេះទៅទៀត ចាប់តាំងពីឆ្នាំ២០២០ ប្រទេសមួយចំនួនដែលតែងតែរិះគន់កម្ពុជា បានចាប់ផ្តើមថ្លែងទទួលស្គាល់ពីកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការធ្វើឱ្យមានវឌ្ឍនភាពនៃលំហសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ ប្រព័ន្ធគាំពារសង្គម ការលើកកម្ពស់ការយល់ដឹងសមភាពយេនឌ័រ ការស្រឡាញ់ភេទដូចគ្នា និងសេរីភាពមូលដ្ឋាន។ល។

**ករណីប្រព័ន្ធអនុគ្រោះពន្ធគ្រប់មុខទំនិញលើកលែងសព្វាវុធ (EBA)៖**

មន្ត្រីការទូតកម្ពុជាបានតស៊ូយ៉ាងស្វិតស្វាញលើមុខព្រួញពីរ៖ (១) ការទាមទារភាពយុត្តិធម៌របស់កម្ពុជាចំពោះមុខការអនុវត្តវិធានការដែលមានលក្ខណៈស្តង់ដាពីរ និងបង្កប់ចរិតនយោបាយ និង(២) ការការពារប្រាក់ចំណូលនិងការងាររបស់ពលករនិងពលរដ្ឋខ្មែររាប់សែននាក់។ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់កិច្ចសហការល្អជាមួយសហភាពអឺរ៉ុប តាមរយៈកិច្ចសន្ទនាជាបន្តបន្ទាប់ក្នុងកម្រិតបច្ចេកទេសនិងនយោបាយការបញ្ជូនបេសកកម្មសុឆន្ទៈចំនួន៣លើកទៅកាន់សហភាពអឺរ៉ុប ការផ្តល់ចម្លើយឆ្លើយតបរបាយការណ៍ក៏ដូចជាការចេញសេចក្តីថ្លែង-ការណ៍របស់កបទ.សអ.ចំនួន៤លើក។ គួរឱ្យសោកស្តាយកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា មិនទទួលបានការសាទរ និងទទួលស្គាល់ដោយគណៈកម្មការអឺរ៉ុបនោះទេ ក៏ប៉ុន្តែផ្ទុយទៅវិញទទួលបានការសម្រេចការព្យួរមួយផ្នែកនៃEBA នៅពេលដែលកម្ពុជាកំពុងប្រឹងប្រែងតស៊ូជម្នះវិបត្តិនៃជំងឺរាត្បាតកូវីដ-១៩។ ទោះជាក្នុងកាលៈទេសៈណាក៏ដោយ កម្ពុជានៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំ **មិនដោះដូរអធិបតេយ្យជាតិដើម្បីជំនួយជាដាច់ខាត**និងប្តេជ្ញាការពារនូវមាគ៌ាដ៏ត្រឹមត្រូវនោះគឺការការពារអធិបតេយ្យនិងថែរក្សាសន្តិភាព ដែលទទួលបានដោយលំបាក ហើយដែលទទួលបានការអបអរសាទរយ៉ាងពេញទំហឹងពីប្រជាជនកម្ពុជាទូទាំងប្រទេស។

**ករណីការចោទប្រកាន់អំពីមូលដ្ឋានយោធាបរទេសនៅកម្ពុជា៖**

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ច្បាស់ពីរបបនយោបាយអព្យាក្រឹតភាពដែលត្រូវប្រកាន់យកនិងការមិនអនុញ្ញាតឱ្យមានវត្តមានមូលដ្ឋានទ័ពបរទេសនៅកម្ពុជា។ ក៏ប៉ុន្តែដើម្បីផលប្រយោជន៍នយោបាយរបស់ខ្លួនប្រទេសមហាអំណាចខ្លះនិងសម្ព័ន្ធមិត្ត ខិតខំបំភ្លៃនិងបំប៉ោងដោយគ្មានមូលដ្ឋានពីអ្វីដែលគេហៅថាវត្តមានបរទេសនៅមូលដ្ឋានរាមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ឆ្លើយតបនឹងបញ្ហានេះ ថ្នាក់ដឹកនាំកម្ពុជា រួមទាំងកបទ.សអ. បានធ្វើការបកស្រាយបំភ្លឺជាច្រើនលើកក្នុងជំនួបជាមួយឥស្សរជននយោបាយបរទេស រួមទាំងសមាជិកសភា វេទិកាអន្តរជាតិនិងការចេញសេចក្តីថ្លែងការណ៍ផ្សេងៗ។ ជាក់ស្តែងក្នុងឱកាសកិច្ចប្រជុំកំពូលពិសេសអាស៊ាន អាម៉េរិក កាលពីខែឧសភា ឆ្នាំ២០២២ និងជំនួបកំពូលទ្វេភាគីរវាង**សម្តេចតេជោ នាយករដ្ឋមន្ត្រី** និងប្រធានាធិបតីអាម៉េរិក**ចូ បៃដិន** នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២២ ក្នុងឱកាសនៃកិច្ចប្រជុំកំពូលអាស៊ានពាក់ព័ន្ធនៅភ្នំពេញ**សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់សាជាថ្មីជូនថ្នាក់ដឹកនាំអាម៉េរិកអំពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវរដ្ឋធម្មនុញ្ញកម្ពុជា ដែលមិនអនុញ្ញាតឱ្យមានមូលដ្ឋានយោធាបរទេសនៅលើទឹកដីកម្ពុជាឡើយលើកលែងប្រតិបត្តិការក្រោមឆត្រ អ.ស.ប.។

## ១.២- ការការពារផលប្រយោជន៍ពលរដ្ឋខ្មែរនៅបរទេស

គិតពីឆ្នាំ២០១៨រហូតដល់ខែវិច្ឆិកា ឆ្នាំ២០២២ កបទ.សអ.បានជួយសង្គ្រោះនិងធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរឱ្យត្រឡប់មកកម្ពុជាវិញបានចំនួនសរុបជាង**៦៨ ០០០នាក់** មកពីប្រទេសថៃ ម៉ាឡេស៊ី វៀតណាម ចិន ឡាវ សិង្ហបុរី ជាដើម។ ក្នុងឆ្នាំ២០២០ វិធានការបិទខ្ទប់ដើម្បីទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ ដែលប្រកាន់ដោយប្រទេសជាច្រើន បានធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ និងរាំងស្ទះដល់ការធ្វើដំណើររបស់ពលរដ្ឋខ្មែរនៅបរទេស។ កបទ.សអ. តាមរយៈស្ថានតំណាងកម្ពុជានៅបរទេស បានសម្របសម្រួលការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរដែលជាប់គាំងដោយការបិទជើងហោះហើរបានចំនួនប្រមាណ**២ ៩០០នាក់** និងបានជួយឧបត្ថម្ភគាំទ្រដែលរួមមាន

ការផ្តល់សេវារដ្ឋបាល សេវាកុងស៊ុលនិងការឧបត្ថម្ភសម្ភារៈផ្សេងៗដល់ពលករ សិស្ស និស្សិតបានចំនួនជាង **២៦ ០០០នាក់** ដែលរស់នៅក្នុងប្រទេសចិន ថៃ សាធារណរដ្ឋកូរ៉េ ជប៉ុន ម៉ាឡេស៊ី សិង្ហបុរី វៀតណាម ឡាវ អេហ្ស៊ីប។ល។

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះដែរ ក្រោមការណែនាំរបស់ កបទ.សអ. ស្ថានទូត/ស្ថានបេសកកម្មក្រៅប្រទេសបានយកចិត្តទុកដាក់ខ្ពស់និងសម្របសម្រួលដល់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ សិស្ស និស្សិតដែលកំពុងរស់នៅធ្វើការនិងសិក្សានៅបរទេស រួមមានសេវារដ្ឋបាល សេវាកុងស៊ុល និងការឧបត្ថម្ភផ្សេងៗ។

## ២- ការចូលរួមពីសហគមន៍ជាតិនិងអន្តរជាតិ

សប្បុរសជនក្នុងនិងក្រៅប្រទេស ដែលបានចូលរួមថវិកានិងសម្ភារៈក្នុងការកសាងអភិវឌ្ឍន៍មូលដ្ឋានលើគ្រប់វិស័យទាំងផ្នែកអាណាចក្រនិងពុទ្ធចក្រ កសាងរចនាសម្ព័ន្ធនានា ដូចជាផ្លូវ ស្ពាន ប្រព័ន្ធលូទឹក ប្រព័ន្ធទឹកស្អាត ជារាសាស្រ្តទំនប់ប្រឡាយ មន្ទីរពេទ្យ មណ្ឌលសុខភាព កសាងអន្តេវាសិកដ្ឋាន អគារសិក្សា សាលារៀនគ្រប់កម្រិត មណ្ឌលកុមារកំព្រា វត្តអារាម ព្រះវិហារ កុដិ សាលាបាលី សាលាឆាន់ វិហារអ៊ិស្លាម សារ៉ាវ។ល។

| បរិយាយ | ប្រាក់ដុល្លារអាម៉េរិក | ប្រាក់រៀល |
|---|---|---|
| ២០១៨ | ១៣ ៩២៩ ១០១ | **២៧១ ១១១ ១០០** |
| ២០១៩ | ១៦ ៧០៩ ០២៩ | **១៩១ ៥០០ ០០០** |
| ២០២០ | ១៨៤ ២០១ ១៩៩,៥០ | គ្មាន |
| ២០២១ | ៧០ ០២៧ ៧៦៨ | គ្មាន |
| ២០២២ | ១២៦ ៣២៦ ០១១ | គ្មាន |

ដើម្បីសម្តែងការដឹងគុណចំពោះសប្បុរសជនក្នុងនិងក្រៅប្រទេស រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ និងបានក្រាបបង្គំស្នើសុំព្រះរាជក្រឹត្យពីព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បំពាក់គ្រឿងឥស្សរិយយសជាបន្តបន្ទាប់ មាន៖

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| ព្រះរាជក្រឹត្យ(ឯកតា : គិតជាគ្រឿង) | | | | | |
| ព្រះរាជាណាចក្រកម្ពុជា | ១១ ៩៤៤ | ៨ ៣៤៤ | ៥ ២២៩ | ៣ ០៨៧ | **១ ៩៩៤** |
| ព្រះមហាក្សត្រីយានី | ៤២៣ | ៧៣ | ០ | ០ | **៥៤** |
| ការពារជាតិ | ២២០ | ៦៣៩៦ | ២៤ | ៦ ៧៨៤ | **២ ២៨២** |
| សហមេត្រី | ៨៥ | ១១៥ | ៥៦ | ៥ | **៦៧** |
| សុវត្ថារា | ៨១៨ | ២៤៣ | ១៩៧ | ១៧៨ | **១១៨** |
| មុនីសារាភ័ណ្ឌ | ១ ១៩៧ | ១ ០៤១ | ៩៤៨ | ៣៣០ | **៦១១** |
| ជាតូបការ | ៣៧៣ | ១៤៧ | ១៣១ | ៣០ | **២៣៣** |
| សេនាជ័យសិទ្ធ | ៣២៤ | ៨៧ | ៨៨ | ៤០ | **៥៦** |
| ឯករាជជាតិ | ០ | ២ | ០ | ០ | **០** |
| **ឧកញ៉ា** | ឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២២ ចំនួន**៣៥៩** | | | | |

| | | | | | |
|---|---|---|---|---|---|
| **អនុក្រឹត្យ (ឯកតា : គិតជាគ្រឿង)** | | | | | |
| សហមេត្រី | ៣០១ | ២០៦ | ៣៧៧ | ១៧៦ | **១៣២** |
| សុវត្ថារា | ២ ៣៥៨ | ១ ២៨៥ | ១ ០៧៩ | ៧៣៨ | **៧៤៩** |
| មុនីសារាភ័ណ្ឌ | ៣ ៤៨៤ | ៣ ៨៨៥ | ៤ ៩៤៥ | ១ ៦៧៩ | **៨២៧** |
| ស្ថាបនាជាតិ | ២ ៧០២ | ២ ០៣៥ | ៣ ២០៥ | ២ ២៧៧ | **១ ១៦៣** |
| ការងារ | ៣១ ១៨៥ | ១៦ ៧៩៩ | ២៦ ៧១៩ | ២៩ ៧៥៨ | **១១ ៥៣៦** |
| ស្ត្រីវឌ្ឍនា | ០ | ០ | ៦៥ | ១០៧ | **០** |

## ៣- ការងារសង្គមស៊ីវិល

### ៣.១- ការចុះឈ្មោះក្នុងបញ្ជីនៅក្រសួងមហាផ្ទៃ

- គិតត្រឹមខែកញ្ញា ឆ្នាំ២០២២ សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះឈ្មោះក្នុងបញ្ជីនៅក្រសួងមហាផ្ទៃ សរុបមានចំនួន៦ ០៧៤ (សមាគម២ ៥៩៨ អង្គការមិនមែនរដ្ឋាភិបាល៣ ៤៧៦) ហើយនៅក្នុងចំនួននេះ មានសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលសម្រាប់នីតិបុគ្គលចំនួន៤៤ និងសហគមន៍ជនជាតិដើមភាគតិច ចំនួន១៥២។ **កត់សម្គាល់ ៖** ចាប់ពីខែសីហា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២ នេះ ក្រសួងមហាផ្ទៃបានសម្រេចចុះឈ្មោះក្នុងបញ្ជីនូវសមាគម អង្គការមិនមែនរដ្ឋាភិបាលនិងសហគមន៍ជនជាតិដើមភាគតិច ចំនួន៨៩១ (សមាគម៤៩៨ អង្គការមិនមែនរដ្ឋាភិបាល៣៦៩ សហគមន៍ជនជាតិដើមភាគតិច ២៤) និងលុបឈ្មោះចេញពីបញ្ជីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ចំនួន១១២ (សមាគម៣១ អង្គការមិនមែនរដ្ឋាភិបាល៨១) ។ ផ្អែកតាមទិន្នន័យសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃបានបង្ហាញឱ្យឃើញថា ស្ថិតិសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលមានការកើនឡើងជារៀងរាល់ឆ្នាំ ហើយសិទ្ធិសេរីភាពក្នុងការធ្វើសកម្មភាពរបស់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ក៏ត្រូវបានធានានិងលើកស្ទួយជាប្រចាំខណៈដែលក្រសួងមហាផ្ទៃតែងយកចិត្តទុកដាក់រៀបចំវេទិកាពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិលទាំងនេះក្នុងលក្ខណៈបើកចំហរជាបន្តបន្ទាប់ ដើម្បីសម្របសម្រួលដោះស្រាយសំណើ សំណូមពរ និងបញ្ហានានាជុំវិញការអនុវត្តច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ដែលជាផ្នែកមួយដ៏សំខាន់សម្រាប់ការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសហការក្នុងភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល។

### ៣.២- ការចុះឈ្មោះក្នុងបញ្ជីនៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

តឹកតាងដ៏សំខាន់បង្ហាញពីសុឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយស្ថាប័នអ.ស.ប. ទទួលបន្ទុកបញ្ហាសិទ្ធិមនុស្ស រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបន្តសុពលភាពអនុស្សរណៈយោគយល់គ្នា(MoU) ជាមួយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអ.ស.ប.ប្រចាំកម្ពុជា ចំនួន៣លើកជាប់គ្នានៅចន្លោះឆ្នាំ២០១៧-២០២២ និងការផ្តល់ភាពស្របច្បាប់ដល់អង្គការមិនមែនរដ្ឋាភិបាលបរទេស(FNGOs)ដែលកំពុងប្រតិបត្តិការនៅកម្ពុជាចំនួន៣៤៥អង្គការ ក្នុងនោះអង្គការដែលបានបន្តMoU មានចំនួន៣១០ និងចុះបញ្ជីថ្មីចំនួន៣៥(គិតត្រឹមខែធ្នូ ឆ្នាំ២០២២)។

## ៤- គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា( គ.ជ.នា.)

ដើម្បីគាំទ្រការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ក្នុងនីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាល បានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ និងដឹកនាំការអនុវត្តគោលការណ៍ស្តីពីភាពជាដៃគូស្របតាមបរិការណ៍កម្ពុជា ព្រមទាំងការប្តេជ្ញា និងបទដ្ឋានសកលនានា សម្រាប់លើកកម្ពស់ស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍ។ លើមូលដ្ឋាននេះរាជរដ្ឋាភិបាលបានសម្រេចជោគជ័យក្នុងការកៀរគរ តម្រង់ទិសនិងគ្រប់គ្រងធនធានសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រអាទិភាពអភិវឌ្ឍន៍ជាតិ ។

**ការប្តេជ្ញាកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រអាទិភាពជាតិ**

ឈរលើគោលការណ៍ភាពជាម្ចាស់និងភាពជាដៃគូប្រកបដោយបរិយាបន្ន តាមរយៈការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ រាជរដ្ឋាភិបាល តាមរយៈគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា( គ.ជ.នា/ក.អ.ក.)៖

- បាននិងកំពុងបន្តអនុវត្តការតម្រឹមកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ជាមួយអាទិភាពជាតិ ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤
- បានពង្រឹងយន្តការភាពជាដៃគូ តាមរយៈការអនុវត្តសេចក្តីណែនាំស្តីពីឧបករណ៍ និងយន្តការកិច្ចពិគ្រោះយោបល់ភាពជាដៃគូ ដោយបានបន្តដឹកនាំកិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍសំខាន់ៗ ក្រុមការងារបច្ចេកទេសចម្រុះ និងកិច្ចពិគ្រោះយោបល់ដទៃទៀតកម្រិតជាតិ កម្រិតវិស័យ និងថ្នាក់ក្រោមជាតិ
- បានដាក់ឱ្យអនុវត្តសូចនាករតាមដានរួមគ្នាឆ្នាំ២០១៩-២០២៣ ដើម្បីតម្រង់ទិសកិច្ចសហប្រតិបត្តិការលើកកម្ពស់លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ និងធានាគណនេយ្យភាពទ្វេទិស ព្រមទាំងបានតាមដាននិងពិនិត្យវឌ្ឍនភាពនៃការអនុវត្ត
- បានពង្រឹងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការឱ្យកាន់តែមានសុក្រឹតភាព តាមរយៈការកែសម្រួលប្រព័ន្ធទិន្នន័យ ការធ្វើបច្ចុប្បន្នភាព និងសុពលភាពទិន្នន័យជាប្រចាំ ដើម្បីតាមដានលំហូរហិរញ្ញប្បទានសហប្រតិបត្តិការ។

**និន្នាការនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសរុប**

ជាលទ្ធផលនៃការប្តេជ្ញាកៀរគរហិរញ្ញប្បទាន ចាប់ពីឆ្នាំ២០១៨-២០២២ គ.ជ.នា/ក.អ.ក. បានកៀរគរហិរញ្ញប្បទានសរុប៨ ៦៣៥,៦លានដុល្លារអាម៉េរិក។ វិស័យហេដ្ឋារចនាសម្ព័ន្ធទទួលបានហិរញ្ញប្បទានច្រើនជាងគេ ៤១,៥% នៃហិរញ្ញប្បទានសរុប វិស័យសេដ្ឋកិច្ច២១,៥% វិស័យសង្គមកិច្ច១៩,៨% និងអន្តរវិស័យ១៦,៥%។ ក្នុងឆ្នាំ២០២០ ទំហំហិរញ្ញប្បទានបានកើនដល់២ ១៥៥,៤លានដុល្លារអាម៉េរិក ដោយសារការបើកផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រការឆ្លើយតបនឹងវិបត្តិកូវីដ-១៩ ពីជប៉ុន ធនាគារអភិវឌ្ឍន៍អាស៊ី និងសាធារណរដ្ឋប្រជាមានិតចិន។

**+ ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ( លានដុល្លារអាម៉េរិក)**

| វិស័យ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ ព្យាករណ៍ |
|---|---|---|---|---|---|
| វិស័យហេដ្ឋារចនាសម្ព័ន្ធ | ៤៣៨,៦ | ៧៦៧,៧ | ៦៩២,៤ | ៨២២,៥ | ៨២៥,៥ |
| វិស័យសេដ្ឋកិច្ច | ២៧៨,៣ | ៤១២,៩ | ៣២៦,០ | ៣៨៣,៦ | ៤៥៦,០ |

| | | | | | |
|---|---|---|---|---|---|
| វិស័យសង្គម | ២៦៦,២ | ៣១១,៤ | ៤៣៧,០ | ៣៧១,៤ | ៣១៩,៦ |
| អន្តរវិស័យ | ១៩៣,៤ | ១៩៧,៧ | ៦៩៤,៦ | ១៩២,៤ | ១៥០,៥ |
| ផ្សេងៗ | ៥,៦ | ១៥,០ | ៥,៤ | ៦,៤ | ២៥,៥ |
| **សរុប** | **១ ២២២,១** | **១ ៧០៤,៧** | **២ ១៥៥,៤** | **១ ៧៧៦,៣** | **១ ៧៧៧,១** |

**ហិរញ្ញប្បទានគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា**

គ.ជ.នា/ក.អ.ក. បានកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការដើម្បីគាំទ្រការងារអាទិភាពនិងវិធានការគន្លឹះនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។ ដៃគូអភិវឌ្ឍសំខាន់ៗដែលបានផ្តល់ការគាំទ្រ រួមមានសាធារណរដ្ឋប្រជាមានិតចិន ជប៉ុន ធនាគារអភិវឌ្ឍន៍អាស៊ី បារាំង និងអូស្ត្រាលី ។ ចាប់ពីឆ្នាំ ២០១៨-២០២២ ហិរញ្ញប្បទានគាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ មានទំហំ១ ៣០៤,៥លានដុល្លារអាមេរិក ក្នុងនោះហិរញ្ញប្បទាន៨៥៤,៦លានដុល្លារអាមេរិកបានគាំទ្រវិធានការគន្លឹះបួនជាក់ស្តែង។

**+ ហិរញ្ញប្បទានគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥ -២០២៥**

**(លានដុល្លារអាមេរិក)**

| វិធានការគោលនយោបាយ<br>និងវិធានការគន្លឹះបួនជាក់ស្តែង | ២០១៨ | ២០១៩ | ២០២០ | ២០២១<br>ប៉ាន់ស្មាន | ២០២២<br>ព្យាករណ៍ |
|---|---|---|---|---|---|
| វិធានការគន្លឹះបួនជាក់ស្តែង | ១០៤,៨ | ២០១,៩ | ២៣៨,២ | ១៩៣,៨ | ១១៥,៩ |
| ការសម្របសម្រួលគោលនយោបាយគាំទ្រ | ២៩,៣ | ៣៥,៣ | ៥២,៨ | ៦០,៨ | ៤៩,៧ |
| ការជំរុញការទាក់ទាញវិនិយោគ | ២,៣ | ៤៧,៦ | ១៥,៣ | ៣៤,៥ | ៤០,៧ |
| ការពង្រីកនិងទំនើបកម្មសហគ្រាសធុនតូចនិងមធ្យម | ៣,៩ | ៧,៣ | ៧,០ | ៨,១ | ១៦,០ |
| ការកែលម្អបរិស្ថាននិយតកម្ម | ៩,២ | ៨,៣ | ៥,០ | ៨,៨ | ៨,០ |
| **សរុប** | **១៤៩,៥** | **៣០០,៤** | **៣១៨,៣** | **៣០៦,០** | **២៣០,៣** |

**ហិរញ្ញប្បទានគាំទ្រការឆ្លើយតបនឹងវិបត្តិនៃជំងឺកូវីដ-១៩**

ក្នុងកិច្ចគាំទ្ររាជរដ្ឋាភិបាលលើការឆ្លើយតបនឹងវិបត្តិនៃជំងឺកូវីដ-១៩ គ.ជ.នា./ក.អ.ក. បានសម្របសម្រួលយន្តការភាពជាដៃគូដើម្បីកៀរគរហិរញ្ញប្បទានគាំទ្រការឆ្លើយតបបន្ទាន់និងការស្តារសង្គម សេដ្ឋកិច្ច។ ទិន្នន័យបង្ហាញថា ក្នុងឆ្នាំ២០២០-២០២១ ហិរញ្ញប្បទាន១៦២,៤លានដុល្លារអាមេរិក ព្រមទាំងវ៉ាក់សាំង ឧបករណ៍ និងសម្ភារៈបរិក្ខារវេជ្ជសាស្ត្រត្រូវបានគាំទ្រដល់ការឆ្លើយតបបន្ទាន់ពាក់ព័ន្ធនឹងវិស័យសុខាភិបាល និងហិរញ្ញប្បទាន ៨១២,៧លានដុល្លារអាមេរិក ត្រូវបានបើកផ្តល់ដល់ការស្តារសង្គម សេដ្ឋកិច្ច។

## ទី៤- ការពង្រឹងសមត្ថភាពកម្ពុជា ដើម្បីបន្តជំរុញសមាហរណកម្មខ្លួនចូលក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក

### ១- ការអនុវត្តគោលនយោបាយការបរទេសប្រកបដោយភាពបត់បែន ទាន់ពេល តបតទៅនឹងសម្ពាធភូមិសាស្ត្រនយោបាយ

#### ១.១- ទំនាក់ទំនងទ្វេភាគី

កម្ពុជាបានប្រកាន់យកគោលនយោបាយការបរទេសបត់បែននិងវាងវៃ ស្របតាមគោលការណ៍សន្តិសហវិជ្ជមាន សំដៅពង្រឹងនិងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយបណ្ដាប្រទេសទាំងអស់នៅក្នុងពិភពលោក។ ក្នុងរយៈពេល៥ឆ្នាំនេះកម្ពុជាបានភ្ជាប់ទំនាក់ទំនងការទូតបន្ថែមជាមួយប្រទេសចំនួន៥ រួមមាន បុរីក្សត្រម៉ូណាកូ បាបាដុស អ៊ូហ្គង់ដា បាហាម៉ាស និងសាំងឃីតនិងនេវីស (និងបានឯកភាពជាគោលការណ៍ក្នុងការភ្ជាប់ទំនាក់ទំនងការទូតជាមួយប្រទេសកាមេរូន) និងបើកដំណើរការស្ថានទូតកម្ពុជាប្រចាំនៅប្រទេស ចំនួន៣ បន្ថែមនៅតំបន់អឺរ៉ុប រួមមានតួកគី ស៊ែប៊ី និងប៊ុលហ្គារី។

**ក- ទំនាក់ទំនងការទូតកម្ពុជានិងប្រទេសនានា៖** កម្ពុជាបានបន្តពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីតាមរយៈការបង្កើតយន្តការជាច្រើនរួមមាន(គិតត្រឹមថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២)៖

| យន្តការទំនាក់ទំនង | ២០១៨-២០២២ | ចំនួនសរុប |
|---|---|---|
| ប្រទេសភ្ជាប់ទំនាក់ទំនងការទូតជាមួយកម្ពុជា | ៥ | ១៧៥ |
| ស្ថានទូត/ស្ថានតំណាងអចិន្ត្រៃយ៍កម្ពុជានៅបរទេស | ៣ | ៣១ |
| ស្ថានអគ្គកុងស៊ុលកម្ពុជានៅបរទេស | ២ | ១២ |
| កុងស៊ុលកិត្តិយសកម្ពុជានៅបរទេស | ៧ | ២៦ |
| ស្ថានទូតបរទេសនៅកម្ពុជា | គ្មាន | ៣១ |
| ស្ថានអគ្គកុងស៊ុល និងការិយាល័យកុងស៊ុលបរទេសនៅកម្ពុជា | គ្មាន | ៧ |
| កុងស៊ុលកិត្តិយសបរទេសនៅកម្ពុជា | ៩ | ១៥ |
| គណៈកម្មការអន្តររដ្ឋាភិបាល | គ្មាន | ២ |
| គណៈកម្មការចម្រុះ | ១ | ១២ |
| កិច្ចពិគ្រោះយោបល់ទ្វេភាគី | ១៦ | ៤០ |

**ខ- ការផ្លាស់ប្ដូរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំ**

ក្នុងរយៈពេល៥ឆ្នាំនេះ**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងឯកឧត្តម **ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ** បានយាងនិងអញ្ជើញទៅបំពេញទស្សនកិច្ចនៅប្រទេសចំនួន ១៨ប្រទេស រួមមានថៃ ឡាវ វៀតណាម មីយ៉ាន់ម៉ា សិង្ហបុរី ឥណ្ឌូនេស៊ី ចិន ជប៉ុន សាធារណរដ្ឋកូរ៉េ បារាំង អាល្លឺម៉ង់ បែលហ្សិក ហុងគ្រី ប៊ុលហ្គារី សហរដ្ឋអាម៉េរិក គុយបា ឆែក និងតួកគី។

ដោយឡែក កម្ពុជាក៏បានទទួលស្វាគមន៍ដំណើរទស្សនកិច្ចរបស់ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល និងប្រមុខការទូតមកពីប្រទេសចំនួន២៦ប្រទេស រួមមានចិន ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ស្រីលង្កា នេប៉ាល់ សាធារណរដ្ឋកូរ៉េ វៀតណាម ព្រុយណេ ទីម័រខាងកើត ជប៉ុន ឥណ្ឌា ឥណ្ឌូនេស៊ី ថៃ អូស្ត្រាលី សិង្ហបុរី បង់ក្លាដែស អារ៉ាប៊ីសាអូឌីត កាតា ហុងគ្រី រុស្ស៊ី សហរដ្ឋអាម៉េរិក អង់គ្លេស កាណាដា គុយបា និងអ៊ុយក្រែន។

ក្រៅពីការផ្លាស់ប្ដូរទស្សនកិច្ចរបស់ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល និងប្រមុខការទូតកម្ពុជា និងប្រទេសជាមិត្ត ក៏បានផ្លាស់ប្ដូរទស្សនកិច្ចក្នុងក្របខ័ណ្ឌព្រឹទ្ធសភានិងរដ្ឋសភាផងដែរ។ ការផ្លាស់ប្ដូរទស្សនកិច្ចទាំងនេះរួមមាន ទស្សនកិច្ចរបស់**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា និងសម្ដេចអគ្គមហា**

**ពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៅប្រទេសវៀតណាម ចិន និងសាធារណរដ្ឋកូរ៉េ និងការទទួលស្វាគមន៍ដំណើរទស្សនកិច្ចរបស់អនុប្រធាន និងសមាជិករដ្ឋសភានៃប្រទេសចិន អាមេរិក ជប៉ុន និងបារាំងនៅកម្ពុជា។

**គ- វឌ្ឍនភាពទំនាក់ទំនងទ្វេភាគីជាមួយប្រទេសក្នុងតំបន់នានាជុំវិញពិភពលោក (នៅចន្លោះឆ្នាំ២០១៨-២០២២)៖**

❖ **តំបន់អាស៊ីអាគ្នេយ៍៖** ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា និងប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ទាំងក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមនិងទំនាក់ទំនងរវាងប្រជាជននិងប្រជាជន។ ក្នុងនោះ ទំនាក់ទំនងជាមួយប្រទេសជិតខាងកម្ពុជា រួមមានឡាវ ថៃ និងវៀតណាម មានភាពល្អប្រសើរដែលស្តែងចេញតាមរយៈ

- **ឡាវ** ក្នុងរយៈពេល៥ឆ្នាំចុងក្រោយទំនាក់ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីត្រូវបានលើកកម្ពស់ទៅជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនិងយូរអង្វែងនៅខែកញ្ញា ឆ្នាំ២០១៩។ ភាគីទាំងពីរកំពុងរៀបចំសេចក្តីព្រាងផែនការសកម្មភាពសម្រាប់ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយនិងយូរអង្វែង ដែលគ្រោងនឹងចុះហត្ថលេខាដោយប្រមុខដឹកនាំកំពូលនាពេលខាងមុខ។ ទន្ទឹមនេះ ទំនាក់ទំនាក់ទំនងរវាងថ្នាក់ដឹកនាំអាជ្ញាធរគ្រប់លំដាប់ថ្នាក់នៃប្រទេសទាំងពីរកាន់តែមានភាពជិតស្និទ្ធនិងកិច្ចប្រជុំសំខាន់ៗរួមមាន៖ កិច្ចប្រជុំគណៈកម្មាការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី(JCBC) រវាងកម្ពុជា ឡាវនិងកិច្ចប្រជុំរវាងអាជ្ញាធរតាមបណ្តាខេត្តជាប់ព្រំដែនដើម្បីពង្រឹងទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការទ្វេភាគី

- **ថៃ** ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការទ្វេភាគីត្រូវបានពង្រឹងនិងពង្រីកលើគ្រប់វិស័យក្នុងកម្រិត «ភាពជាដៃគូដើម្បីសន្តិភាពនិងវិបុលភាព»។ ក្នុងឆ្នាំ២០២០ ប្រទេសទាំងពីរបានប្រារព្ធខួបអនុស្សាវរីយ៍លើកទី៧០នៃការបង្កើតទំនាក់ទំនងការទូត។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា ថៃមានការកើនឡើងដោយក្នុងឆ្នាំ២០១៧ ទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា ថៃ សម្រេចបាន២,៧៨ពាន់លានដុល្លារអាមេរិក រីឯឆ្នាំ២០២២ ទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា ថៃ សម្រេចបានដល់ទៅ៤,៦៣ពាន់លានដុល្លារអាមេរិក។ ក្នុងកាលៈទេសៈនៃការរីករាលដាលនៃជំងឺកូវីដ-១៩ កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរបានស្តែងចេញយ៉ាងច្បាស់អំពីទំនាក់ទំនងល្អ ការយោគយល់ និងគាំទ្រគ្នាទាំងផ្នែកសម្ភារៈ ថវិកា ស្មារតីនិងបច្ចេកទេស។ ប្រទេសទាំងពីរបានរៀបចំកិច្ចប្រជុំទ្វេភាគីសំខាន់ៗជាច្រើនរួមមានកិច្ចប្រជុំគណៈរដ្ឋមន្ត្រីចម្រុះលើកទី៣(JCR) កិច្ចប្រជុំគណៈកម្មការចម្រុះលើកទី១១(JC) កិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅលើកទី១៥ (GBC) គណៈកម្មាធិការចម្រុះកិច្ចការព្រំដែន(JBC) និងកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនលើកទី៧

ទោះជាមិនមានទស្សនកិច្ចផ្លូវការនៅក្នុងរយៈពេល៥ឆ្នាំនេះក៏ដោយ ក៏នាយករដ្ឋមន្ត្រីទាំងពីរតែងបានជួបពិភាក្សាគ្នាទាំងតាមប្រព័ន្ធវីដេអូនិងជំនួបដោយផ្ទាល់ក្នុងឱកាសចូលរួមកិច្ចប្រជុំតំបន់ផ្សេងៗ រួមមានកិច្ចប្រជុំកំពូលអាស៊ាន កិច្ចប្រជុំក្នុងក្របខ័ណ្ឌមេគង្គជាដើម។ ក្នុងជំនួបចុងក្រោយរវាង**សម្តេចតេជោ នាយករដ្ឋមន្ត្រី** និងនាយឧត្តមសេនីយ៍ **នាយករដ្ឋមន្ត្រីថៃ** កាលពីខែវិច្ឆិកា ឆ្នាំ២០២២ ក្នុងអំឡុងពេលកិច្ចប្រជុំកំពូលអាស៊ាននៅកម្ពុជា ថ្នាក់ដឹកនាំទាំងពីរបានឯកភាពជំរុញកិច្ចសហប្រតិបត្តិការរវាងបណ្តាខេត្តនៅតាមបណ្តោយព្រំដែន ការចរចាលើតំបន់សមុទ្រត្រួតស៊ីគ្នា ប្រតិបត្តិការលើការដោះមីន ការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ការតភ្ជាប់

និងហេដ្ឋារចនាសម្ព័ន្ធ ការតម្លើងនិងបើកច្រកអន្តរជាតិ ការអភិវឌ្ឍអប់រំនិងការបណ្តុះបណ្តាលធនធានមនុស្ស វប្បធម៌ សុខាភិបាលនិងទេសចរណ៍ជាដើម។

- **វៀតណាម** ទោះបីមានការរំខានដោយបញ្ហាព្រំដែនបន្តិចបន្តួច ទំនាក់ទំនងមិត្តភាពជាប្រពៃណីជាប្រទេសជិតខាងល្អនិងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងកម្ពុជា និងវៀតណាមត្រូវបានពង្រឹងនិងអភិវឌ្ឍប្រកបដោយផ្លែផ្កា។ ការផ្លាស់ប្តូរគណៈប្រតិភូជាន់ខ្ពស់និងការប្រាស្រ័យទាក់ទងគ្នាត្រូវបានប្រព្រឹត្តទៅយ៉ាងរលូនក្នុងគ្រប់កម្រិត។ កិច្ចប្រជុំគណៈកម្មការចម្រុះវៀតណាម កម្ពុជា ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ដែលជាយន្តការកិច្ចសហប្រតិបត្តិការទ្វេភាគីគ្រប់ជ្រុងជ្រោយបានប្រព្រឹត្តទៅ ចំនួន៤ លើកក្នុងរយៈពេល៥ឆ្នាំចុងក្រោយ។ កម្ពុជា វៀតណាម បានឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិនិងសន្តិសុខ ដោយផ្អែកលើគោលការណ៍មិនអនុញ្ញាតឱ្យកម្លាំងអមិត្តណាមួយប្រើប្រាស់ទឹកដីរបស់ខ្លួន ដើម្បីបង្កអន្តរាយដល់សន្តិសុខនិងផលប្រយោជន៍របស់ភាគីម្ខាងទៀត។ កម្ពុជានិងវៀតណាមនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពនូវកិច្ចព្រមព្រៀងនានាដែលបានចូលជាធរមាន និងប្រើប្រាស់ឱ្យមានប្រសិទ្ធភាពនូវយន្តការដែលមានស្រាប់លើកិច្ចសហប្រតិបត្តិការការពារជាតិ និងសន្តិសុខ ដើម្បីពង្រឹងការសម្របសម្រួលក្នុងការថែរក្សាស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងសុវត្ថិភាពនៅក្នុងប្រទេសនីមួយៗក៏ដូចជាលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការពារព្រំដែន។ ទោះបីជាមានការរីករាលដាលនៃជំងឺកូវីដ-១៩ ទំហំពាណិជ្ជកម្មទ្វេភាគីមិនត្រឹមតែមិនរងផលប៉ះពាល់ ប៉ុន្តែបានកើនយ៉ាងខ្លាំងទ្វេដងក្នុងរយៈពេល៥ឆ្នាំនេះគឺកើនឡើងពី៣,៨ពាន់លានដុល្លារអាម៉េរិក នៅឆ្នាំ២០១៨ ដល់៩,១ពាន់លានដុល្លារអាម៉េរិកនៅក្នុងរយៈពេល១០ខែ ក្នុងឆ្នាំ២០២២ រីឯវិនិយោគគិតត្រឹមឆ្នាំ២០២១ វិនិយោគវៀតណាមឈរលេខរៀងទី៤ក្នុងទំហំវិនិយោគចំនួន២,៥ពាន់លានដុល្លារអាម៉េរិក។

❖ **តំបន់អាស៊ីខាងត្បូង** កម្ពុជានិងឥណ្ឌាមានកិច្ចសហប្រតិបត្តិការជិតស្និទ្ធលើគ្រប់វិស័យ ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី តំបន់និងអន្តរជាតិ។ ថ្មីៗនេះ ក្នុងឱកាសកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធថ្នាក់ដឹកនាំប្រទេសទាំងពីរ បានផ្លាស់ប្តូរឯកសារ ចំនួន៤ ក្នុងគោលបំណងជំរុញកិច្ចសហប្រតិបត្តិការលើវិស័យសុខាភិបាល អប់រំ បរិស្ថាន និងវប្បធម៌។ ជាមួយបង់ក្លាដែស កម្ពុជាមានទំនាក់ទំនងល្អ និងកំពុងពិនិត្យលទ្ធភាពពង្រីកវិសាលភាពនៃកិច្ចសហប្រតិបត្តិការបន្ថែម។ នៅដើមឆ្នាំ២០២០ ថ្នាក់ដឹកនាំក្រសួងការបរទេស និងថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័នពាក់ព័ន្ធកម្ពុជាជាច្រើនរូបបានចូលរួមសម្ពោធផ្លូវ «King Norodom Sihanouk» ដែលមានទីតាំងនៅតំបន់ការទូតនៃទីក្រុងដាក្កា ប្រទេសបង់ក្លាដែសក្នុងឱកាសចូលរួមកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា បង់ក្លាដែសលើកទី១។ ដោយឡែក ទំនាក់ទំនងការទូតនិងកិច្ចសហប្រតិបត្តិការជាមួយប្រទេសដទៃទៀតក្នុងតំបន់អាស៊ីខាងត្បូងទោះបីមិនមានការរីកចម្រើនគួរឱ្យកត់សម្គាល់ កម្ពុជាបាននិងកំពុងពិនិត្យលទ្ធភាពពង្រីកបន្ថែមទៀត។ ទន្ទឹមនេះ កម្ពុជាបានខិតខំអនុវត្តនូវការទូតមនុស្សធម៌ តាមរយៈការផ្តល់ជំនួយគ្រឿងបរិក្ខារពេទ្យសម្រាប់ទប់ស្កាត់ជំងឺកូវីដ-១៩ ដល់នេប៉ាល់និងជំនួយមនុស្សធម៌ដល់ប្រជាជនប៉ាគីស្ថានដែលបានរងគ្រោះដោយមហន្តរាយទឹកជំនន់។

❖ **តំបន់អាស៊ីកណ្តាល** កម្ពុជារក្សាបាននូវទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយបណ្តាប្រទេសអាស៊ីកណ្តាល ជាពិសេសកាហ្សាក់ស្ថាន កៀហ្ស៊ីស៊ីស្ថាន តាហ្ស៊ីគីស្ថាន និងតួកម៉េនីស្ថានតាមរយៈ

ការប្រាស្រ័យទាក់ទងនិងការផ្លាស់ប្តូរទស្សនកិច្ចរវាងថ្នាក់ដឹកនាំកម្ពុជានិងបណ្តាប្រទេសទាំងនេះ។ ភាគីទាំងពីរបានផ្លាស់ប្តូរឯកសារកិច្ចសហប្រតិបត្តិការទ្វេភាគី រួមមានកិច្ចព្រមព្រៀង និងអនុស្សារណៈលើវិស័យកិច្ចសហប្រតិបត្តិការគន្លឹះនានា ដូចជា នយោបាយ អប់រំ សេដ្ឋកិច្ច ទេសចរណ៍ វប្បធម៌និងការលើកលែងទិដ្ឋាការ។ ភាគីទាំងពីរក៏បានប្តេជ្ញាធ្វើការរួមគ្នាដើម្បីពន្លឿនការចុះហត្ថលេខាលើកឯកសារទាំងនេះឱ្យបានឆាប់ ក្នុងទិសដៅលើកស្ទួយនិងពង្រឹងទំនាក់ទំនងទ្វេភាគីឱ្យកាន់តែរីកចម្រើនសម្រាប់ផលប្រយោជន៍ទៅវិញទៅមក។

❖ **តំបន់អូសេអានី៖**

- **អូស្ត្រាលី** ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ ទំនាក់ទំនងរវាងកម្ពុជានិងអូស្ត្រាលី បានបន្តរីកចម្រើនគួរឱ្យកត់សម្គាល់។ ក្នុងវិស័យសេដ្ឋកិច្ច ទំហំពាណិជ្ជកម្មទ្វេភាគីបានកើនឡើងពី១៣៣លានដុល្លារអាម៉េរិក នៅឆ្នាំ២០១៨ ដល់៥២៣លានដុល្លារអាម៉េរិក នៅឆ្នាំ២០២២។ ចាប់ពីឆ្នាំ២០១៩មក ក្រសួងការបរទេសនៃប្រទេសទាំងពីរបានរៀបចំកិច្ចពិគ្រោះយោបល់ថ្នាក់ឧត្តមមន្ត្រីជាទៀងទាត់ ដើម្បីរិះរកមធ្យោបាយពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការបន្ថែមទៀត។ បន្ថែមពីលើជំនួយអភិវឌ្ឍន៍ក្នុងវិស័យអប់រំ កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ និងបោសសម្អាតមីន អូស្ត្រាលីបានចូលរួមចំណែកយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅកម្ពុជា តាមរយៈការផ្តល់វ៉ាក់សាំងPfizer( សម្រាប់មនុស្សពេញវ័យនិងកុមារ ) ជិត៣លានដូស ទូត្រជាក់រក្សាវ៉ាក់សាំងជាង១០០គ្រឿង និងបរិក្ខារវេជ្ជសាស្ត្រផ្សេងទៀត។ នៅឆ្នាំ២០២២ ប្រទេសទាំងពីរបានប្រារព្ធខួបលើកទី៧០ នៃការបង្កើតទំនាក់ទំនងការទូត តាមរយៈការផ្លាស់ប្តូរទស្សនកិច្ចជាន់ខ្ពស់ទៅវិញទៅមក។

- **នូវែលសេឡង់** ទំនាក់ទំនងរវាងកម្ពុជាជាមួយនូវែលសេឡង់ក៏មានភាពប្រសើរឡើងផងដែរ។ ចាប់ពីឆ្នាំ២០១៩មក ក្រសួងការបរទេសនៃប្រទេសទាំងពីរបានរៀបចំកិច្ចពិគ្រោះយោបល់ក្រសួងការបរទេសកម្ពុជា នូវែលសេឡង់ ដើម្បីលើកកម្ពស់ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការទ្វេភាគីបន្ថែមទៀត។ លើសពីនេះ នូវែលសេឡង់ក៏បានផ្តល់ជំនួយដល់កម្ពុជាលើវិស័យកសិកម្ម បោសសម្អាតមីន និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការផ្តល់អាហារូបករណ៍រយៈពេលវែងនិងខ្លីដល់និស្សិតនិងមន្ត្រីរាជការកម្ពុជា។

❖ **តំបន់អាស៊ីបូព៌ា**

- **ចិន** ទំនាក់ទំនងទ្វេភាគីកម្ពុជា ចិនត្រូវបានពង្រឹងនិងអភិវឌ្ឍឥតឈប់ឈររហូតក្លាយជាកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ មិត្តភាពដូចដែកថែបនិងការកសាងសហគមន៍ជោគវាសនារួម ដោយឈរលើមូលដ្ឋានស្មើភាពគ្នា គោរពគ្នាទៅវិញទៅមក ផ្តល់ទំនុកចិត្តលើគ្នានិងកិច្ចសហប្រតិបត្តិការឈ្នះឈ្នះ។ ការផ្លាស់ប្តូរទស្សនៈកិច្ចនិងការប្រាស្រ័យទាក់ទងរវាងថ្នាក់ដឹកនាំជាន់ខ្ពស់ត្រូវបានធ្វើឡើងកាន់តែញឹកញាប់និងមានលក្ខណៈជាយុទ្ធសាស្ត្រ។ ជាក់ស្តែង**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** បានយាងទៅប្រទេសចិនចំនួន ១២លើកហើយ**សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានបំពេញទស្សនកិច្ចចំនួន៣លើក។ ទស្សនកិច្ចរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី**ទៅកាន់ប្រទេសចិន កាលពីខែកុម្ភៈ ឆ្នាំ២០២០ ដើម្បីបង្ហាញពីសាមគ្គីភាពជាមួយប្រទេសចិនដែលកំពុងផ្ទុះមេរោគកូវីដ-១៩ ហើយទទួលបានមកវិញនូវការស្ញើចសរសើរនិងស្រឡាញ់រាប់អានដ៏ខ្ពង់ខ្ពស់ពីសំណាក់ថ្នាក់ដឹកនាំចិននិងប្រជាជនចិនទាំងមូល ដែលជាកត្តាធ្វើឱ្យទំនាក់ទំនងកម្ពុជា ចិន

កាន់តែរឹងមាំនិងស៊ីជម្រៅ។**នាយករដ្ឋមន្ត្រីចិន** ក៏បានអញ្ជើញមកបំពេញទស្សនកិច្ចនិងចូលរួមកិច្ចប្រជុំនៅកម្ពុជាចំនួន២លើកខណៈដែលរដ្ឋមន្ត្រីការបរទេសចិន ចំនួន៣លើក

- ក្រៅពីជំនួយឥតសំណងដ៏ច្រើនជាពិសេសសម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធរចុះហត្ថលេខាលើកិច្ចព្រមព្រៀងនិងឯកសារកិច្ចសហប្រតិបត្តិការនានារហូតទៅដល់៧១ឯកសារ លើវិស័យសំខាន់ៗជាច្រើន អាចចាត់ទុកថាជាសមិទ្ធផលដ៏ធំធេងនៃកិច្ចសហប្រតិបត្តិការទ្វេភាគីដែលក្នុងនោះមានជាអាទិ៍ការចុះហត្ថលេខាលើ (១) ឯកសារផែនការសកម្មភាពស្ដីពីការបង្កើតសហគមន៍វាសនារួមកម្ពុជា ចិន នៅឆ្នាំ២០១៩ និង(២) កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលបានចូលជាធរមាន នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២

- ផ្ទុយនឹងការបារម្ភអំពីផលប៉ះពាល់នៃការរីករាលដាលជំងឺកូវីដ-១៩ ទំហំពាណិជ្ជកម្មទ្វេភាគីមិនត្រឹមតែមិនរងផលប៉ះពាល់ ប៉ុន្តែបានកើនយ៉ាងខ្លាំងទ្វេដងក្នុងរយៈពេល៥ឆ្នាំនេះ កើនឡើងពី៦,៩៧៧ លានដុល្លារអាម៉េរិក នៅឆ្នាំ២០១៨ ដល់១១,៦៨៦ លានដុល្លារអាម៉េរិក នៅឆ្នាំ២០២២ រីឯវិនិយោគពីចិនកម្ពុជាទទួលបានជាមធ្យមក្នុងមួយឆ្នាំគឺ២,៥ ពាន់លានដុល្លារអាម៉េរិក ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ។

- **ជប៉ុន** ទំនាក់ទំនងទ្វេភាគីកម្ពុជា ជប៉ុនត្រូវបានទទួលស្គាល់ដោយថ្នាក់ដឹកនាំកំពូល និងប្រជាជននៃប្រទេសទាំងពីរថា កំពុងស្ថិតក្នុងកម្រិតល្អបំផុតក្នុងប្រវត្តិសាស្ត្រ។ កិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្ការវាងប្រទេសទាំងពីរបានបន្តរីកចម្រើនគួរឱ្យកត់សម្គាល់ តាមរយៈការផ្លាស់ប្ដូរទស្សនកិច្ច និងការប្រាស្រ័យទាក់ទងយ៉ាងជិតស្និទ្ធរវាងថ្នាក់ដឹកនាំកំពូលដែលធ្វើឡើងជាញឹកញាប់ យន្តការប្រជុំទ្វេភាគី ជំនួយអភិវឌ្ឍន៍ផ្លូវការ និងកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗ ដូចជាការពារជាតិ និងសន្តិសុខពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធ អប់រំ ទេសចរណ៍និងការផ្លាស់ប្ដូររវាងប្រជាជននិងប្រជាជន។ ក្នុងឱកាសដែលប្រទេសទាំងពីរប្រារព្ធខួប៦៥ឆ្នាំនៃការបង្កើតទំនាក់ទំនងការទូតនៅដើមឆ្នាំ២០១៨ ជប៉ុនបានបើកការិយាល័យកុងស៊ុលនៅខេត្តសៀមរាប។ ខណៈដែលពិភពលោកទាំងមូល រួមទាំងកម្ពុជាកំពុងរងការគំរាមកំហែងនិងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ជប៉ុន បានជួយឧត្ដម្ភជាថវិកា វ៉ាក់សាំងនិងសម្ភារៈសម្រាប់រួមចំណែកដល់ការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតសកលនេះ និងការបើកប្រទេសឡើងវិញ។ ក្នុងឆ្នាំ២០២២ ដោយមានជំនួបកំពូលទ្វេភាគីញឹកញាប់មិនធ្លាប់មានរហូតដល់ទៅ៤ដង នាយករដ្ឋមន្ត្រីនៃប្រទេសទាំងពីរបានសម្រេចដំឡើងកម្រិតទំនាក់ទំនងកម្ពុជា ជប៉ុនទៅជា «ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ» នៅឆ្នាំ២០២៣ ដែលជាខួបលើកទី៧០នៃទំនាក់ទំនងការទូតកម្ពុជា ជប៉ុន។

- **សាធារណរដ្ឋកូរ៉េ** ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ទំនាក់ទំនងទ្វេភាគីត្រូវបានបន្តពង្រឹងនិងពង្រីកឥតឈប់ឈរដែលឆ្លុះបញ្ចាំងតាមរយៈការផ្លាស់ប្ដូរទស្សនកិច្ចញឹកញាប់រវាងថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ ទាំងក្នុងក្របខ័ណ្ឌនីតិបញ្ញត្តិ និងនីតិប្រតិបត្តិ។ កិច្ចសហប្រតិបត្តិការនានា ជាពិសេសលើវិស័យពាណិជ្ជកម្ម ការពារជាតិ ឱីជីថល សុខាភិបាល វប្បធម៌ ការងារ ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចនិងការផ្លាស់ប្ដូររវាងប្រជាជននិងប្រជាជន ត្រូវបានពង្រឹងនិងលើកកម្ពស់ជាបន្តបន្ទាប់។ សាធារណរដ្ឋកូរ៉េ បានផ្ដល់ការគាំទ្រជាច្រើន រួមមានការផ្ដល់ឥណទានសម្បទានរថយន្តសង្គ្រោះនិងសម្ភារៈជាបន្តបន្ទាប់ ដើម្បីគាំទ្រកម្ពុជាក្នុងការទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩។ ការនៅរក្សាជើងហោះហើរត្រង់កម្ពុជា សាធារណរដ្ឋកូរ៉េ ខណៈដែលប្រទេសដ៏ច្រើនលើសលប់បានបិទ គឺជាកាតាលីករមួយក្នុងការសម្រួលដល់ការធ្វើដំណើរចាកចេញពីកម្ពុជាទៅកាន់អឺរ៉ុប និងអាម៉េរិក ក៏ដូចជាការធ្វើមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរនៅបរទេសផងដែរ

- ក្នុងឆ្នាំ២០២២ កិច្ចព្រមព្រៀងជៀសវៀងការយកពន្ធត្រួតគ្នាត្រូវបានចូលជាធរមាន និងចាប់ផ្តើមអនុវត្ត ហើយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា សាធារណរដ្ឋកូរ៉េ(CKFTA) ដែលផ្តួចផ្តើមដោយ**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ត្រូវបានចូលជាធរមាននៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២២ គឺជារបត់ថ្មីមួយក្នុងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្មនិងបានបង្កើតនូវកាលានុវត្តភាពជាច្រើនក្នុងការជំរុញពាណិជ្ជកម្មទ្វេភាគីនិងការទាក់ទាញវិនិយោគិនកូរ៉េមកកម្ពុជាបន្ថែមទៀត។ នៅខែវិច្ឆិកា ឆ្នាំ២០២២ ក្រោមអធិបតីភាព**សម្តេចតេជោ នាយករដ្ឋមន្ត្រី** កិច្ចសម្របសម្រួលក្របខ័ណ្ឌស្តីពីការផ្តល់ឥណទានសម្បទាននៃមូលនិធិសហប្រតិបត្តិការអភិវឌ្ឍន៍សេដ្ឋកិច្ចសម្រាប់ឆ្នាំ២០២២-២០២៦ ក្នុងទឹកប្រាក់១,៥៣៨លានដុល្លារអាម៉េរិក ត្រូវបានចុះហត្ថលេខាដោយក្នុងពេលនោះក៏មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងគម្រោងសាងសង់ស្ពានមិត្តភាពកម្ពុជា សា.កូរ៉េ ឆ្លងកាត់ទន្លេសាប និងទន្លេមេគង្គ ដែលនឹងក្លាយជានិមិត្តរូបនៃភាពរឹងមាំក្នុងទំនាក់ទំនងជាប្រទេសដន្លងគ្នា។ សមិទ្ធផលទាំងអស់ខាងលើនេះបានឆ្លុះបញ្ចាំងឱ្យឃើញពីការអនុវត្តគោលនយោបាយការបរទេសដ៏ត្រឹមត្រូវរបស់កម្ពុជាជាមួយសា.កូរ៉េ ដែលបានផ្តួចផ្តើមឡើងនិងក្រោមកិច្ចខំប្រឹងប្រែងផ្ទាល់របស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** កាលពីទសវត្សរ៍ទី៩០។

- **តំបន់អាម៉េរិកខាងជើង៖**

- **សហរដ្ឋអាម៉េរិក** កិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា អាម៉េរិកមានភាពរីកចម្រើនគួរឱ្យកត់សម្គាល់លើវិស័យពាណិជ្ជកម្ម(កើនឡើងជាលំដាប់ដែលក្នុងរយៈពេល១០ខែដើមឆ្នាំ២០២២ មានទំហំ១១៣៨លានដុល្លារអាម៉េរិក) សុខាភិបាល(ជំនួយវ៉ាក់សាំង) វិស័យវប្បធម៌ អប់រំ បរិស្ថាន ការស្វែងរកអដ្ឋិធាតុទាហានអាម៉េរិកនិងសកម្មភាពមនុស្សធម៌ជាមួយនាវាទេសចរណ៍Westerdam។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី អាម៉េរិកនៅតែបន្តល្បិចកលនយោបាយកៀបសង្កត់មកលើកម្ពុជាឱ្យដើរតាមគន្លងនយោបាយរបស់ខ្លួន ដោយប្រើប្រាស់បញ្ហាសិទ្ធិមនុស្ស លិទ្ធិប្រជាធិបតេយ្យនិងបញ្ហាមូលដ្ឋានទ័ពរាមនៅកម្ពុជាជារបាំង។ ឆ្លើយតបនឹងបញ្ហានេះ កបទ.សអ.រួមទាំងស្ថានតំណាងកម្ពុជាប្រចាំអាម៉េរិកបានជួបពិភាក្សាជាមួយឥស្សរជននយោបាយ និងក្រុមមនុស្សមានឥទ្ធិពលលើការសម្រេចគោលនយោបាយអាម៉េរិកជាច្រើនលើកក្នុងគោលបំណងពាំនាំសេចក្តីថ្លែងការណ៍ពន្យល់បកស្រាយដើម្បីកាត់បន្ថយភាពជ្រុលនិយម និងការចោទប្រកាន់មិនត្រឹមត្រូវមកលើកម្ពុជា។ ជាសមិទ្ធផលផ្លែផ្កា នៅខែវិច្ឆិកា ឆ្នាំ២០១៩ ក្រសួងការបរទេសអាម៉េរិក បានសម្រេចយល់ព្រមចំពោះសំណើបង្កើតកម្មវិធីអប់រំ និងផ្លាស់ប្តូរវប្បធម៌សហរដ្ឋអាម៉េរិកកម្ពុជា ដែលបើកផ្លូវឱ្យមានដំណើរទស្សនកិច្ចសមាជិកសភាអាម៉េរិកមកកម្ពុជា ក្នុងគោលបំណងកសាងទំនុកចិត្តនិងបង្វិតគម្លាតមិនស្របគ្នា។ យោងតាមស្មារតីនេះ សមាជិកសភាអាម៉េរិកជាបន្តបន្ទាប់បានមកបំពេញទស្សនកិច្ចនៅកម្ពុជានិងជួបសម្តែងការគួរសមជាមួយ**សម្តេចតេជោ នាយករដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំកម្ពុជាមួយចំនួនទៀត។ ជាលទ្ធផល យោងតាមក្រុមហ៊ុនAkin Group «ទស្សនៈរបស់ពួកគេមកលើកម្ពុជាមានភាពវិជ្ជមានខ្លាំងដោយបានផ្លាស់ប្តូរគំនិតមើលកម្ពុជាជាប្រទេសមានសក្តានុពលផ្នែកសេដ្ឋកិច្ច»។ លើសពីនេះដំណើរទស្សនកិច្ចការងាររបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី**នៅក្រុងវ៉ាស៊ីនតោន វត្តមានប្រធានាធិបតីអាម៉េរិក**ចូ បៃដិន** នៅកម្ពុជារួមទាំងជំនួបទ្វេភាគីជាប្រវត្តិសាស្ត្ររបស់មេដឹកនាំទាំងពីរនៅភ្នំពេញនិងទស្សនកិច្ច**សម្តេចតេជោ នាយករដ្ឋមន្ត្រី**នៅស្ថានទូតអាម៉េរិកនៅភ្នំពេញនៅឆ្នាំ២០២២កន្លងទៅ ជាសក្ខីភាពបញ្ជាក់នូវការរឹតចំណងទំនាក់ទំនងរវាងប្រទេសទាំងពីរឱ្យកាន់តែប្រសើរ។

- **កាណាដា** កម្ពុជានិងកាណាដា បានពង្រឹងនិងពង្រីកទំនាក់ទំនងបានល្អប្រសើរលើកិច្ចសហប្រតិបត្តិការក្នុងវិស័យពាណិជ្ជកម្មនិងវិនិយោគ ការបោសសម្អាតមីន ការរក្សាសន្តិភាព ការអភិវឌ្ឍធនធានមនុស្ស និងបម្រែ-បម្រួលអាកាសធាតុជាដើមក្នុងកម្រិតទ្វេភាគីនិងក្នុងអង្គការហ្វ្រង់កូហ្វូនីក្របខ័ណ្ឌពហុភាគី។ ក្នុងឆ្នាំ២០២២ នាវាចម្បាំងរបស់កាណាដាឈ្មោះWINNIPEG បានត្រូវអនុញ្ញាតឱ្យចូលចតសុឆន្ទៈនៅកំពង់ផែខេត្តព្រះសីហនុ ដោយមានការអញ្ជើញតំណាងស្ថាប័នពាក់ព័ន្ធរបស់កម្ពុជា រួមទាំងក្រសួងការបរទេស ចូលរួមស្វាគមន៍ការចូលចតដោយសុឆន្ទៈរបស់នាវាចម្បាំងនេះ។

- **គុយបា៖** កម្ពុជា និងគុយបា មានទំនាក់ទំនងមិត្តភាពយូរអង្វែង និងដែលថ្មីៗនេះ ត្រូវបានពង្រឹងបន្ថែមតាមរយៈការផ្លាស់ប្តូរដំណើរទស្សនកិច្ចរបស់ប្រមុខរដ្ឋាភិបាលទាំងពីរនៅគុយបានិងកម្ពុជា នៅខែកញ្ញា និងតុលា ឆ្នាំ២០២២។ ក្នុងដំណើរទស្សនកិច្ចទាំងពីរនេះ កម្ពុជានិងគុយបា បានពង្រឹងនិងពង្រីកកិច្ចសហ-ប្រតិបត្តិការលើវិស័យកីឡា អប់រំ វប្បធម៌ សុខាភិបាល និងកសិកម្ម។

❖ **តំបន់អាម៉េរិកឡាទីន** កម្ពុជាបាននិងកំពុងបន្តខិតខំពិនិត្យលទ្ធភាពពង្រឹងទំនាក់ទំនង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសនៅតំបន់អាម៉េរិកឡាទីន ជាពិសេសតាមរយៈការបង្កើតកិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងកម្ពុជាជាមួយវេណេស៊ុយអេឡា(ឆ្នាំ២០១៩) អាហ្សង់ទីន(ឆ្នាំ២០២២) និងបានរៀបចំកិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយគុយបា ប្រេស៊ីល និងកូឡុំប៊ី(ឆ្នាំ២០២២)ផងដែរ។ ស្របតាមស្មារតីនៃកិច្ចពិគ្រោះយោបល់ទ្វេភាគីកម្ពុជា ប្រេស៊ីលលើកទី១ ភាគីទាំងពីរបានពិភាក្សាផ្លាស់ប្តូរយោបល់អំពីគម្រោងបើកស្ថានទូតរៀងខ្លួននៅទីក្រុងភ្នំពេញនិងប្រាស៊ីលីយ៉ា ដើម្បីបង្កើតលទ្ធភាពក្នុងការពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា ប្រេស៊ីលក៏ដូចជាកម្ពុជានិងប្រទេសក្នុងតំបន់អាម៉េរិកឡាទីនផ្សេងទៀត។

- **តំបន់អឺរ៉ុបខាងលិច** បើទោះជាមានទស្សនៈមិនសូវចុះសម្រុងគ្នាលើបញ្ហាសិទ្ធិមនុស្ស និងលទ្ធិប្រជា-ធិបតេយ្យក្តី ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជាជាមួយបណ្តាប្រទេសលោកខាងលិចមានដំណើរការល្អប្រសើរ ជាពិសេសជាមួយប្រទេសអាល្លឺម៉ង់ បារាំង អង់គ្លេស ន័រវេស លីចតេនស្តាញ ប៊ែលហ្សិក អេស្ប៉ាញ ស្វីស និងអ៊ីតាលី លើវិស័យអប់រំ កសិកម្ម សុខាភិបាល ការបោសសម្អាតមីន បរិស្ថាន កិច្ចគាំពារសង្គម ការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩។ល។

- **អាល្លឺម៉ង់** ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការទ្វេភាគីមានសន្ទុះរីកចម្រើនគួរឱ្យកត់សម្គាល់ដោយអាល្លឺម៉ង់នៅតែស្ថិតក្នុងចំណោមប្រទេសផ្តល់ជំនួយដល់កម្ពុជាច្រើនជាងគេ និងបន្តជាដៃគូពាណិជ្ជកម្មធំបំផុតក្នុងចំណោមសមាជិកសហភាពអឺរ៉ុប ដែលបាននិងកំពុងបន្តកើនឡើងដល់ជាង១៣ន់លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ។ ក្នុងឱកាសកិច្ចប្រជុំកំពូលអាស៊ាន អឺរ៉ុប នៅព្រុចសែល កាលពី ខែធ្នូ ឆ្នាំ២០២២ កន្លងទៅ**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានជួបជាមួយឯកឧត្តមអធិការបតីសហព័ន្ធអាល្លឺម៉ង់**អូឡាហ្វ ឆុលស៍** ពិភាក្សាអំពីការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី និងវិបត្តិសន្តិសុខក្នុងពិភពលោក។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ថ្នាក់ដឹកនាំជាន់ខ្ពស់ជាច្រើននៃប្រទេសទាំងពីរបានផ្លាស់ប្តូរទស្សនកិច្ចការងារ ដែលក្នុងនោះផងដែរក៏មានដំណើរទស្សនកិច្ចការងាររបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**ប្រាក់ សុខុន** នៅប្រទេសអាល្លឺម៉ង់ កាលពីដើមឆ្នាំ២០២២ ដែលជាទស្សនកិច្ចថ្នាក់រដ្ឋមន្ត្រីការបរទេសលើកទី១ ក្នុងរយៈពេល២៧ឆ្នាំចុងក្រោយ។ បន្ថែមពីនេះ ភាពរីកចម្រើននៃទំនាក់ទំនងទ្វេភាគី ក៏អាចឆ្លុះបញ្ចាំងតាមរយៈការបង្កើតកិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងក្រសួងការបរទេសទាំងពីរ ព្រមទាំងបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីលើកទី១

កាលពីដើមឆ្នាំ២០២២ នៅទីក្រុងភ្នំពេញ។ កាលពីខែវិច្ឆិកា ឆ្នាំ២០២២កន្លងទៅ ឯកឧត្តមបណ្ឌិត**ចែម វីឌ្យា** ក្នុងនាមជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**ប្រាក់ សុខុន** និងឯកឧត្តម**កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានអញ្ជើញទៅចូលរួមសន្និបាតពិភពលោកស្តីពីការប្រឆាំងនឹងទោសប្រហារជីវិតលើកទី៨ នៅរដ្ឋធានីប៊ែរឡាំង ព្រមទាំងបានជួបពិភាក្សាការងារជាមួយលោកជំទាវ Susane Baumann រដ្ឋលេខាធិការក្រសួងការបរទេសអាល្លឺម៉ង់ផងដែរ។

- **ចក្រភពអង់គ្លេស** ទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរបានស្គាល់នូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ស្របពេលដែលការចាកចេញពីសហភាពអឺរ៉ុបរបស់អង់គ្លេសបានជំរុញឱ្យប្រទេសនេះខិតខំពង្រឹងនិងពង្រីកដៃគូជុំវិញពិភពលោក។ វឌ្ឍនភាពនៃទំនាក់ទំនងត្រូវបានគូសបញ្ជាក់បន្ថែមដោយការសម្រេចបន្តផ្តល់ប្រព័ន្ធអនុគ្រោះពន្ធ(GSP) ដល់កម្ពុជា កាលពីឆ្នាំ២០២១ និងដំណើរទស្សនកិច្ចផ្លូវការលើកទី១របស់ឯកឧត្តម DominicRaab ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសអង់គ្លេស នៅកម្ពុជាកាលពីខែមិថុនា ឆ្នាំ២០២១ ដែលក្នុងនោះ ភាគីទាំងពីរបានពិភាក្សាលើការពង្រីកកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មទ្វេភាគី សំដៅឆ្ពោះទៅរកការសម្រេចកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងប្រទេសទាំងពីរ។ជាមួយគ្នានេះដែរ កបទ.សអ. បានរៀបចំកិច្ចពិភាក្សាស្តីពីសិទ្ធិមនុស្ស ជាមួយភាគីអង់គ្លេស ចំនួន៤លើក ហើយភាគីមិត្តបានយកចិត្តទុកដាក់ស្វែងយល់ពីស្ថានភាពពិតក៏ដូចជាភាពរីកចម្រើននៃវិស័យសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យដែលកម្ពុជាខំប្រឹងប្រែងសម្រេចបាន។ ក្រៅពីនេះ នៅខែមិថុនា ឆ្នាំ២០២២ចក្រភពអង់គ្លេសបានសម្រេចតែងតាំងឱ្យមានអនុព័ន្ធយោធាអង់គ្លេសប្រចាំកម្ពុជាដែលមាននិវេសនដ្ឋាននៅសិង្ហបុរី ហើយត្រូវបានទទួលស្គាល់ដោយក្រសួងការពារជាតិកម្ពុជានៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២។

- **បារាំង** កម្ពុជានិងបារាំងនៅតែបន្តរក្សាទំនាក់ទំនងស្និទ្ធស្នាលជាប្រពៃណី និងកិច្ចសហប្រតិបត្តិការក្នុងវិស័យចម្បងរួមមានហិរញ្ញវត្ថុ សុខាភិបាល វប្បធម៌ អប់រំ បរិស្ថាន និងជាពិសេសការការពារនិងការអភិរក្សតំបន់អង្គរ(ICC-Angkor)។ ក្នុងរយៈពេល៥ ឆ្នាំនេះ ថ្នាក់ដឹកនាំកម្ពុជាជាច្រើនបានអញ្ជើញនិងយាងទៅបំពេញទស្សនកិច្ចជាបន្តបន្ទាប់នៅប្រទេសបារាំង ដែលមានជាអាទិ៍៖**សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្តេចតេជោ នាយករដ្ឋមន្ត្រី** និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។ ជាពិសេស នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២២ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជាបំពេញទស្សនកិច្ចការងារ និងជួបពិភាក្សាការងារទ្វេភាគីជាមួយប្រធានាធិបតីបារាំង Emmanuel MACRON។ លើសពីនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**ប្រាក់ សុខុន** ក៏ត្រូវបានអញ្ជើញចូលរួមវេទិកាកិច្ចសហប្រតិបត្តិការក្នុងតំបន់ឥណ្ឌូប៉ាស៊ីហ្វិកនៅទីក្រុងប៉ារីសកាលពីខែកុម្ភៈ ឆ្នាំ២០២២។ បន្ថែមពីនេះ កម្ពុជាបាននិងកំពុងស្វែងរកលទ្ធភាពពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីបន្ថែម តាមរយៈការខិតខំសម្រេចនូវការបង្កើតកិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងក្រសួងការបរទេសទាំងពីរ ដែលនឹងត្រូវចុះហត្ថលេខានាពេលឆាប់ៗខាងមុខ។

- **រុស្ស៊ីនិងប្រទេសអតីតសហភាពសូវៀត** ទោះបីជារុស្ស៊ីមិនសូវសប្បាយចិត្តចំពោះការប្រកាន់ជំហររបស់កម្ពុជាពាក់ព័ន្ធនឹងសង្គ្រាមនៅអ៊ុយក្រែន ក៏ប្រទេសទាំងពីរជាទូទៅនៅរក្សាបានទំនាក់ទំនងល្អជាប្រពៃណី។ ជាក់ស្តែង ភាគីទាំងពីរបានចុះហត្ថលេខាលើឯកសារថ្មីៗសរុបចំនួន ៥៣ និងបន្តរក្សាកិច្ចសន្ទនានយោបាយក្នុង

កម្រិតខ្ពស់ដែលរួមមានកិច្ចពិគ្រោះយោបល់ទ្វេភាគីនិងកិច្ចប្រជុំគណៈកម្មការអន្តររដ្ឋាភិបាល ជាពិសេសការចុះហត្ថលេខាលើផែនការនៃកិច្ចពិគ្រោះយោបល់ឆ្នាំ២០២២-២០២៤ ដោយរដ្ឋមន្ត្រីការបរទេស Sergey Lavrov និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** កាលពីខែសីហា ឆ្នាំ២០២២កន្លងទៅ។

- នៅខែតុលាឆ្នាំ២០២២ **សម្តេចតេជោនាយករដ្ឋមន្ត្រី**ក្នុងនាមប្រធានគណបក្សប្រជាជនកម្ពុជា បានអញ្ជើញចូលរួមតាមប្រព័ន្ធវីដេអូក្នុងពិធីបើកសន្និសីទគណបក្សអន្តរជាតិក្រោមប្រធានបទ«គោលនយោបាយបរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព» ដែលបានប្រព្រឹត្តទៅនៅទីក្រុងYuzhno Sakhalinsk ក្រោមអធិបតីភាពរបស់ឯកឧត្តម Dmitry Medvedev ប្រធានគណបក្សរួបរួមរុស្ស៊ី។ ប្រធានព្រឹទ្ធសភារុស្ស៊ី បានអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០២២ ក្នុងឱកាសចូលរួមក្នុងកិច្ចប្រជុំចូលរួមក្នុងកិច្ចប្រជុំអន្តរសភាអាស៊ានលើកទី៤៣(AIPA) នៅទីក្រុងភ្នំពេញ។ ជាការគួរឱ្យកត់សម្គាល់កិច្ចប្រជុំកិច្ចពិគ្រោះយោបល់ទ្វេភាគីលើកទី៣ រវាងកម្ពុជានិងអាស៊ែបៃហ្សង់ កាលពីខែមិថុនា ឆ្នាំ២០២២នៅទីក្រុងបាគូ ភាគីទាំងពីរបានពីភាក្សាពីកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងបច្ចេកទេសបោសសម្អាតមីន វប្បធម៌ និងការបង្កើតសម្ព័ន្ធមេត្រីរវាងទីក្រុងភ្នំពេញនិងទីក្រុងបាគូដើម្បីជំរុញ «ការទូតទីក្រុង»។

- **ប្រទេសតួកគី** ទំនាក់ទំនងទ្វេភាគីជាមួយតួកគីមានកំណើនល្អប្រសើរ ផ្តើមចេញពីការផ្លាស់ប្តូរទស្សនកិច្ចថ្នាក់ខ្ពស់រវាងប្រទេសទាំងពីរការចុះហត្ថលេខាបង្កើតកិច្ចសហប្រតិបត្តិការលើវិស័យពន្ធដារ ការទូត សេដ្ឋកិច្ច អប់រំ ការបោសសម្អាតមីន សន្តិសុខ វិនិយោគ កីឡា វប្បធម៌និងទេសចរណ៍ រហូតឈានដល់ការសម្ពោធជាផ្លូវការនូវស្ថានទូតរៀងខ្លួននៅទីក្រុងភ្នំពេញនិងអង់ការ៉ា(ក្នុងឆ្នាំ២០២២)។ ម៉្យាងទៀត ដើម្បីលើកស្ទួយនិងបង្កើនទំនាក់ទំនងសេដ្ឋកិច្ចពាណិជ្ជកម្មកម្ពុជា តួកគីឱ្យកាន់តែរីកចម្រើនបន្ថែមទៀត នៅខែសីហា ឆ្នាំ២០២២ ថ្មីៗនេះភាគីតួកគីបានសម្រេចបង្កើតការិយាល័យតំណាងពាណិជ្ជកម្មរបស់ខ្លួននៅក្នុងស្ថានទូតតួកគីនៅភ្នំពេញ។

❖ **តំបន់អាហ្វ្រិក និងមជ្ឈិមបូព៌ា** ទោះបីមានការពង្រីកទំនាក់ទំនងការភ្ជាប់ទំនាក់ទំនងការទូតបន្ថែមជាមួយប្រទេសកាមេរូន និងអ៊ូហ្គង់ដា និងការបើកស្ថានទូតកម្ពុជានៅអេហ្ស៊ីបកាលពីឆ្នាំ២០១៦ ទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា និងប្រទេសនៅក្នុងតំបន់នេះ នៅមានកម្រិតនៅឡើយ។ ជាការគួរឱ្យកត់សម្គាល់ កាលពីថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានជួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីការបរទេសម៉ារ៉ុក Nasser Bourita តាមរយៈប្រព័ន្ធវីដេអូ ដែលក្នុងនោះភាគីទាំងពីរបានឯកភាពសហការគ្នាក្នុងការពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យមួយចំនួនដូចជាពាណិជ្ជកម្ម វិនិយោគ អាកាសចរណ៍ ទេសចរណ៍ អប់រំ និងការអភិវឌ្ឍធនធានមនុស្ស កិច្ចសហប្រតិបត្តិការទេសចរណ៍ ព្រមទាំងប្តេជ្ញាពន្លឿនការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាស្តីពីសេវាកម្មអាកាសចរណ៍រវាងកម្ពុជានិងម៉ារ៉ុក។ ក្រៅពីនេះ ភាគីម៉ារ៉ុកក៏បានអរគុណកម្ពុជាចំពោះការប្រកាន់ជំហរអព្យាក្រឹតពិសេសការបោះឆ្នោតនៅអ.ស.ប. ពាក់ពន្ធ័និងជម្លោះរវាងម៉ារ៉ុកជាមួយអាល់ហ្សេរីនិងម៉ូរីតានី។ ក្រៅពីនេះភាគីម៉ារ៉ុកក៏បានសន្យាគាំទ្រកម្ពុជា និងជួយជំរុញប្រទេសជាមិត្តផ្សេងទៀតឱ្យជួយគាំទ្រកម្ពុជា ក្នុងការចូលជាសមាជិកសង្កេតការណ៍នៅក្នុងអង្គការកិច្ចសហប្រតិបត្តិការឥស្លាម (OIC)។ បន្ថែមពីនេះ ក្នុងកិច្ចពិគ្រោះយោបល់នយោបាយកម្ពុជា អាល់ហ្សេរី កាលពីខែមិថុនា ឆ្នាំ២០២២ ភាគីទាំងពីរបានឯកភាពគ្នាបង្កើតយន្តការកិច្ចពិគ្រោះយោបល់ទ្វេភាគីរវាងក្រសួងការបរទេស កិច្ចព្រមព្រៀងស្តីពីការ

លើកលែងទិដ្ឋាការការទូតនិងផ្លូវការ និងMoU ស្តីពីកិច្ចសហប្រតិបត្តិការរវាងNIDIR និងវិទ្យាស្ថានការទូតអាល់ហ្សេរី។

## ១.២- ទំនាក់ទំនងពហុភាគី

❖ ក្នុងនាមជារដ្ឋតូច កម្ពុជាត្រូវការរស់និងអភិវឌ្ឍនៅក្នុងសណ្តាប់ធ្នាប់ពិភពលោកដែលផ្អែកលើប្រព័ន្ធច្បាប់អន្តរជាតិ និងចូលរួមកសាងសហគមន៍អន្តរជាតិតាមរយៈការចូលរួមយ៉ាងសស្រាក់សស្រាំក្នុងយន្តការពហុភាគីអនុតំបន់ តំបន់ និងពិភពលោកផ្សេងៗ ដែលកិច្ចការទាំងនោះរួមមាន៖

### ក- ក្របខ័ណ្ឌអាស៊ាន និងភាពជាប្រធានអាស៊ានរបស់កម្ពុជានៅឆ្នាំ២០២២៖

កម្ពុជាបាននិងកំពុងចូលរួមយ៉ាងសកម្មក្នុងកិច្ចការអាស៊ាន ចាប់តាំងពីចូលជាសមាជិកនៅឆ្នាំ១៩៩៩ និងបានរួមចំណែកក្នុងការកសាងសហគមន៍អាស៊ាន តាមរយៈការដាក់បញ្ចូលនូវវិស័យអាទិភាពរបស់កម្ពុជាទៅក្នុងផែនការសកម្មភាពនិងក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការនានារបស់អាស៊ាន។ ទន្ទឹមនេះ កម្ពុជាបានរក្សានិងការពារផលប្រយោជន៍ជាតិ  ការពារឯករាជ្យភាពនិងអធិបតេយ្យភាពរបស់ខ្លួន ដោយឈរលើគោលការណ៍គ្រឹះរបស់អាស៊ាននៃ «ការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងផងគ្នា និងរាល់ការធ្វើសេចក្តីសម្រេចចិត្តដោយឈរលើមូលដ្ឋានកុងសង់ស៊ីស»។

ចំពោះទំនាក់ទំនងអាស៊ានជាមួយដៃគូខាងក្រៅ៖ កម្ពុជាតែងតែផ្តល់សារៈសំខាន់លើការលើកកម្ពស់ទំនាក់ទំនងភាពជាដៃគូរបស់អាស៊ាន ជាមួយនឹងការរក្សានិងពង្រឹងតួនាទីស្នូលរបស់អាស៊ាន ក្នុងគំនិតផ្តួចផ្តើមស្តីពីនិម្មាបនកម្មតំបន់តាមរយៈយន្តការនាំមុខដោយអាស៊ាន ដោយឈរលើជំហរអព្យាក្រឹតនិងភាពជាដៃគូក្នុងផលប្រយោជន៍នៃទំនាក់ទំនងរួមទៅវិញទៅមកការមិនរើសអើង ការបើកចំហ បរិយាបន្ន ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ដោះស្រាយជម្លោះដោយសន្តិវិធីនិងការសម្លឹងឆ្ពោះទៅខាងក្រៅ។

ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ យើងបានផ្តោតលើរបៀបវារៈជាអាទិភាព៖

- ការបន្តជំរុញការកសាងសហគមន៍អាស៊ានស្របតាមទស្សនវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ និងការរៀបចំសេចក្តីព្រាងទស្សនវិស័យសហគមន៍អាស៊ានក្រោយឆ្នាំ២០២៥
- ការជំរុញការអនុវត្តបញ្ចប់នូវផែនការការងារទី៣នៃគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន (ឆ្នាំ ២០១៦-២០២០) និងការរៀបចំផែនការការងារទី៤ សម្រាប់ឆ្នាំ២០២១-២០២៥
- ការពង្រីកសមាជិកភាពរបស់អាស៊ាន៖ សំណើរបស់ទីម័រខាងកើតសុំចូលជាសមាជិកអាស៊ាន
- វិធានការឆ្លើយតបនឹងការរីករាលដាលនៃជំងឺកូវីដ-១៩
- ការពង្រឹងលេខាធិការដ្ឋានអាស៊ាន
- ក្នុងនាមជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនាអាស៊ាន នូវែលសេឡង់រយៈពេល៣ឆ្នាំ (២០១៨-២០២១)កម្ពុជាបានកៀគរនូវការគាំទ្រពីអាស៊ានលើសំណើរបស់នូវែលសេឡង់ស្តីពីការរៀបចំកិច្ចប្រជុំកំពូលរំលឹកខួបអាស៊ាន  នូវែលសេឡង់និងបានដឹកនាំការចរចាសម្រេចបាននូវឯកសារសំខាន់មាន៖ សេចក្តីប្រកាសទស្សនវិស័យរួមថ្នាក់ដឹកនាំអាស៊ាន នូវែលសេឡង់និងផែនការសកម្មភាពអាស៊ាន នូវែលសេឡង់ឆ្នាំ២០២១-២០២៥។ កម្ពុជាកំពុងបំពេញនាទីជាប្រទេសសម្របសម្រួលទំនាក់ទំនងដៃគូសន្ទនាអាស៊ាន រុស្ស៊ី រយៈពេល៣ឆ្នាំ(២០២១-២០២៤) និងបានដឹកនាំការចរចាសម្រេចបាននូវឯកសារសំខាន់ៗ

យ៉ាងតិចចំនួន៣ ដែលបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន រុស្ស៊ីលើកទី៤ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១

- កម្ពុជាក៏បានបំពេញតួនាទីជាប្រទេសសម្របសម្រួលសម្រាប់៖ (១) ទំនាក់ទំនងអាស៊ាន សហគមន៍នៃបណ្តារដ្ឋអាម៉េរិកឡាទីននិងការ៉ាប៊ីន(ឆ្នាំ២០១៨) (២) ទំនាក់ទំនងអាស៊ាន សម្ព័ន្ធភាពប៉ាស៊ីហ្វិក(ឆ្នាំ២០១៩) (៣) ទំនាក់ទំនងអាស៊ាន ក្រុមប្រឹក្សាសហប្រតិបត្តិការឈូងសមុទ្រ(ឆ្នាំ២០២០) និង (៤) ទំនាក់ទំនងអាស៊ាន អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច(ឆ្នាំ២០២១) និង(៥) ទំនាក់ទំនងអាស៊ាន អង្គការសហប្រជាជាតិក្នុងនាមកម្ពុជាជាប្រធានអាស៊ាន(ឆ្នាំ២០២២)
- ចំពោះបញ្ហាសមុទ្រចិនខាងត្បូង កម្ពុជាប្រកាន់ជំហរ៖ ការទាមទារអធិបតេយ្យត្រូវការដោះស្រាយដោយរដ្ឋភាគីពាក់ព័ន្ធផ្ទាល់ និងតាមរយៈកិច្ចសន្ទនាដោយសន្តិវិធី និងការពិគ្រោះយោបល់។ កម្ពុជាផ្តល់សារៈសំខាន់ចំពោះការអនុវត្តសេចក្តីប្រកាសស្តីពីការប្រតិបត្តិរបស់ភាគីនៅសមុទ្រចិនខាងត្បូង(DOC) ឱ្យបានពេញលេញនិងមានប្រសិទ្ធភាព និងរក្សាបរិយាកាសស្ងប់ស្ងៀមអំណោយផលដល់ការជំរុញល្បឿនវឌ្ឍនភាពនៃកិច្ចចរចាក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង(COC) ដោយប្រទេសសមាជិកអាស៊ាននិងចិន។

ក្នុងឆ្នាំ២០២២ កម្ពុជាត្រូវរែកពុនភារកិច្ចនិងទំនួលខុសត្រូវដ៏ធ្ងន់ក្នុងនាមជាប្រធានប្តូរវេនអាស៊ានក្រោមមូលបទ «**អាស៊ានរួមគ្នាធ្វើ ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា**»។ កម្ពុជាបានដឹកនាំអង្គការតំបន់មួយនេះហែលឆ្លងកាត់ព្យុះភ្លៀងនៃវិបត្តិសន្តិសុខ សេដ្ឋកិច្ចនិងសង្គមទាំងនៅក្នុងតំបន់និងពិភពលោកជាច្រើន ដូចជាវិបត្តិជំងឺកូវីដ-១៩ ភាពគ្មានច្រកចេញនៃវិបត្តិនយោបាយនៅមីយ៉ាន់ម៉ា ការបែកបាក់កាន់តែខ្លាំងរវាងមហាអំណាចដឹកនាំដោយអាម៉េរិកនិងម្ខាងទៀតដោយរុស្ស៊ីនិងចិនដែលបានឆ្លុះបញ្ចាំងឡើងតាមរយៈការកើនឡើងកម្តៅនៅច្រកសមុទ្រតៃវ៉ាន់ បញ្ហាឧបទ្វីបកូរ៉េសមុទ្រចិនខាងត្បូង សង្គ្រាមនៅអ៊ុយក្រែនជាដើម។ ទោះស្ថិតក្នុងបរិការណ៍ដ៏លំបាកនិងផុយស្រួយបែបនេះ កម្ពុជានៅតែអាចដឹកនាំអាស៊ានទទួលបានលទ្ធផលលើសការរំពឹងទុកនិងទទួលបានការស្ញើចសរសើរពីថ្នាក់ដឹកនាំកំពូលនានានៃប្រទេសសមាជិកអាស៊ាន ដៃគូអាស៊ាននិងមជ្ឈដ្ឋានអន្តរជាតិជាច្រើនគ្រប់មជ្ឈដ្ឋានសារព័ត៌មាននិងអ្នកវិភាគនយោបាយអន្តរជាតិ។ កម្ពុជាបានកំណត់វិស័យអាទិភាពជាច្រើនក្នុងនោះមាន ៖

(១) ការពង្រឹងមជ្ឈភាពអាស៊ាននៅក្នុងយន្តការដែលដឹកនាំដោយអាស៊ាន ដើម្បីរក្សានិងលើកកម្ពស់សន្តិភាពសន្តិសុខនិងវិបុលភាព។

(២) ការរួមចំណែកថ្នាក់តំបន់ ដើម្បីសន្តិភាពសកលតាមរយៈប្រតិបត្តិការរក្សាសន្តិភាព។

(៣) ការលើកកម្ពស់របៀបវារៈស្ត្រី សន្តិភាពនិងសន្តិសុខ។

(៤) ការលើកកម្ពស់ទំនាក់ទំនងខាងក្រៅរបស់អាស៊ាន។

(៥) ការចូលជាសមាជិកអាស៊ានរបស់ទីម័រខាងកើត។ល។

ការចូលជាធរមាននៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់(RCEP ឬអាសិប) នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២ និងការអនុវត្តដោយប្រសិទ្ធភាព ដើម្បីជាចលករជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ចតំបន់។ កម្ពុជាបន្តកិច្ចខិតខំប្រឹងប្រែងកៀរគរការគាំទ្រពីភាគីនៃសមាជិកអាសិប ដើម្បីរៀបចំដាក់លេខាធិការដ្ឋានអាសិបនៅកម្ពុជា។

**កិច្ចប្រជុំកំពូលអាស៊ានលើកទី៤០&៤១និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ រួមទាំងកិច្ចប្រជុំដទៃទៀត៖** បានប្រព្រឹត្តឡើងនៅថ្ងៃទី៨ ទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ។ កម្ពុជាបានទទួលស្វាគមន៍ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនិងប្រមុខដឹកនាំមកពីបណ្តាប្រទេសនិងស្ថាប័នអន្តរជាតិសំខាន់ៗចំនួន២៩ ដែលអញ្ជើញចូលរួមក្នុងកិច្ចប្រជុំកម្រិតកំពូលរបស់អាស៊ាន ដែលបានរៀបចំក្នុងទម្រង់ដោយផ្ទាល់ជាលើកដំបូងបន្ទាប់ពីការរីករាលដាលនៃជំងឺកូវីដ-១៩។ ប្រមុខរដ្ឋ/រដ្ឋាភិបាលអាស៊ានបានអនុម័តនិងដាក់ចេញនូវសេចក្តីថ្លែងការណ៍ស្តីពី៖ (១) ទស្សនវិស័យស្តីពី **«អាស៊ានរួមគ្នាធ្វើការដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា»** (២) របៀបវារៈតភ្ជាប់អាស៊ានក្រោយឆ្នាំ២០២៥ និង (៣) ការប្រារព្ធខួប ៥៥ឆ្នាំ នៃការបង្កើតអាស៊ាន។ ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលអាស៊ាន និងដៃគូបានអនុម័តនិងកត់សម្គាល់លើឯកសារលទ្ធផលចំនួន១០១ ក្នុងចំណោមឯកសារសមិទ្ធផលដទៃទៀតស្តីពីអាទិភាពចម្បងនានាក្នុងសសរស្តម្ភទាំងបី ព្រមទាំងលទ្ធផលលេចធ្លោសំខាន់ៗ រួមមាន៖

- ការឯកភាពជាគោលការណ៍ទទួលទីម័រខាងកើតជាសមាជិកទី១១ របស់អាស៊ាននិងឯកភាពអនុញ្ញាតឱ្យទីម័រខាងកើតចូលរួមរាល់កិច្ចប្រជុំរបស់អាស៊ានដោយរំពឹងថា ផែនទីចង្អុលវិថីសម្រាប់សមាជិកភាពពេញសិទ្ធិរបស់ទីម័រខាងកើតនឹងត្រូវរៀបចំរួចរាល់នៅឆ្នាំ២០២៣
- គំនិតផ្តួចផ្តើមរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ស្នើបង្កើត «កិច្ចព្រមព្រៀងបៃតងអាស៊ាន ASEAN Green Deal» ដែលទទួលបានការស្វាគមន៍និងកោតសរសើរយ៉ាងខ្លាំងពីប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលអាស៊ាននិងដៃគូនានា សំដៅរួមចំណែកក្នុងការជួយតម្រង់ទិសអាស៊ានឆ្ពោះទៅអនាគតបៃតងប្រកបដោយចីរភាពនិងភាពប្រកួតប្រជែងខ្ពស់ក្នុងទិដ្ឋភាពសេដ្ឋកិច្ច
- ការប្រកាសជាផ្លូវការ ស្តីពីការបញ្ចប់នៃការចរចាលើកកម្រិតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានអូស្ត្រាលី នូវែលសេឡង់( AANZFTA Upgrade Negotiations )។ ជាមួយគ្នានេះផងដែរ ថ្នាក់ដឹកនាំអាស៊ានបានបញ្ជាក់នូវការប្តេជ្ញាពង្រឹងពហុភាគីនិយមនិងសេដ្ឋកិច្ចទីផ្សារបើកចំហ តាមរយៈការត្រួតពិនិត្យឡើងវិញនិងការលើកកម្រិតកិច្ចព្រមព្រៀងស្តីពីតំបន់ពាណិជ្ជកម្មសេរីជាមួយដៃគូដែលមានស្រាប់ និងបន្តចរចាជាមួយដៃគូដទៃទៀត។
- ការចុះហត្ថលេខារបស់អ៊ុយក្រែនចូលជាភាគី នៃសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) ដែលធ្វើឱ្យចំនួនរដ្ឋភាគីនៃTAC បានកើនឡើងដល់៥០។

**កិច្ចប្រជុំកំពូលពិសេសអាស៊ាន សហរដ្ឋអាមេរិក៖** ចាប់ពីថ្ងៃទី១២ ទី១៣ ខែឧសភា ឆ្នាំ២០២២ នៅរដ្ឋធានីវ៉ាស៊ីនតោន ក្រោមអធិបតីភាពរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលជាសហប្រធានជាមួយប្រធានាធិបតីអាម៉េរិក**ចូ បៃដិន** បានដាក់ចេញនូវទិសដៅអនាគតនៃភាពជាដៃគូអាស៊ាន សហរដ្ឋអាម៉េរិកតាមរយៈការអនុម័តសេចក្តីប្រកាសទស្សនវិស័យរួម។ នៅក្នុងឱកាសនោះ**សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានគាំទ្រសំណើសហរដ្ឋអាម៉េរិកលើកកម្ពស់ទំនាក់ទំនងអាស៊ាន សហរដ្ឋអាម៉េរិកពីកម្រិតភាពជាដៃគូគ្រប់ជ្រុងជ្រោយទៅជា «ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ» ដែលគំនិតផ្តួចផ្តើមនេះត្រូវបានអនុម័តជាស្ថាពរនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានសហរដ្ឋអាម៉េរិក នៅភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០២២កន្លងទៅ។

**កិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន សហភាពអឺរ៉ុប៖** នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២ នៅទីក្រុងព្រុចសែលក្រោមអធិបតីភាពរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលជាសហប្រធានដឹកនាំកិច្ចប្រជុំកំពូលនេះជាមួយឯកឧត្តម**ឆាលស៍ មីឆែល** ប្រធានក្រុមប្រឹក្សាអឺរ៉ុប។ អង្គប្រជុំបានពិនិត្យឡើងវិញនិងកំណត់ទិសដៅ

អនាគតនៃកិច្ចសហប្រតិបត្តិការអាស៊ាន សហភាពអឺរ៉ុប តាមរយៈការអនុម័តសេចក្តីប្រកាសរួមរបស់ថ្នាក់ដឹកនាំ។ បន្ថែមពីនេះ ប្រមុខដឹកនាំទាំងអស់ក៏បានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការសម្រេចបាននូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន សហភាពអឺរ៉ុប នាពេលអនាគតនិងគូសបញ្ជាក់ពីសារៈសំខាន់នៃកិច្ចព្រមព្រៀងដឹកជញ្ជូនផ្លូវអាកាសដ៏ទូលំទូលាយអាស៊ាន សហភាពអឺរ៉ុប។

**កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធ៖** ចាប់ពីថ្ងៃទី៣០ ខែកក្កដា ដល់ថ្ងៃទី៦ ខែសីហា ឆ្នាំ២០២២ នៅភ្នំពេញ កម្ពុជាបានទទួលស្វាគមន៍តំណាងមកពីប្រទេសចំនួន៣៨ចូលរួមកិច្ចប្រជុំពាក់ព័ន្ធដែលសម្រេចបានលទ្ធផលធំៗ ដូចជា៖ (១) ការផ្តល់ឋានៈជាដៃគូសន្ទនាតាមវិស័យដល់ប្រទេសអេមីរ៉ាតអារ៉ាប់រួមនិងប្រេស៊ីល (២) ការចុះហត្ថលេខាចូលជាភាគីនៃTAC ដោយប្រទេសចំនួន៦ រួមមាន៖ ដាណឺម៉ាក ក្រិក ហូឡង់ អេមីរ៉ាតអារ៉ាប់រួម អូម៉ង់និងកាតា (៣) ការអនុម័តសេចក្តីថ្លែងការណ៍រួមរបស់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥(Joint Communiqué) និងឯកសារសរុបចំនួន២៨ផ្សេងទៀត ដែលក្នុងនោះឯកសារចំនួន៣ស្ថិតក្នុងក្របខ័ណ្ឌកិច្ចប្រជុំវេទិកាតំបន់អាស៊ានលើកទី២៩ រួមមាន៖

- សេចក្តីថ្លែងការណ៍ស្តីពីការលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាព តាមរយៈវិធានការកសាងទំនុកចិត្តនិងការបង្កាជម្លោះតាមផ្លូវការទូត

- ក្របខ័ណ្ឌវេទិកាតំបន់អាស៊ានស្តីពីដំណើរការបរិយាបន្ន សម្រាប់របៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខនិងរបៀបវារៈយុវជនសន្តិភាពនិងសន្តិសុខ ក្នុងវិធានការកសាងទំនុកចិត្ត ការបង្ការជម្លោះតាមផ្លូវការទូតនិងការដោះស្រាយជម្លោះនិង

-សេចក្តីថ្លែងការណ៍ស្តីពីការប្តេជ្ញាចិត្តឡើងវិញក្នុងការរក្សាតំបន់អាស៊ីអាគ្នេយ៍ជាតំបន់គ្មានអាវុធនុយក្លេអ៊ែរ។

**ការងារប្រេសិតពិសេសរបស់ប្រធានអាស៊ានស្តីពីបញ្ហានៅមីយ៉ាន់ម៉ា៖** ចាប់តាំងពីការទទួលតួនាទីជាប្រធានអាស៊ានភ្លាម កម្ពុជាបានខិតខំបន្តអនុវត្ត «**ការព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុច(5PC)**» របស់ថ្នាក់ដឹកនាំអាស៊ានដែលបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូលពិសេស កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២១ នៅទីក្រុងហ្សាការតា។ ដំណើរអញ្ជើញបំពេញទស្សនកិច្ចរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** នៅមីយ៉ាន់ម៉ាកាលពីខែមករា ឆ្នាំ២០២២ ធ្វើឡើងក្នុងគោលបំណងទម្លុះភាពជាប់គាំងគ្មានច្រកចេញនៃវិបត្តិនៅមីយ៉ាន់ម៉ា ព្រមទាំងបានជួបសន្ទនាតាមប្រព័ន្ធវីដេអូជាច្រើនលើកជាមួយឯកឧត្តមឧត្តមសេនីយ៍ជាន់ខ្ពស់Min Aung Hlaing ដើម្បីតាមដាននិងទទូចឱ្យមានវឌ្ឍនភាពនៃការអនុវត្តស្តីពីបញ្ហាមីយ៉ាន់ម៉ា

- កម្ពុជាប្រកាន់យកអភិក្រមដែលផ្អែកលើការអនុវត្តបែបជាក់ស្តែងនិយមនិងជាជំហានៗ ដើម្បីជួយមីយ៉ាន់ម៉ា ក្នុងការស្វែងរកសន្តិភាព ស្ថិរភាពត្រឡប់ទៅរកប្រក្រតីភាពនិងមាគ៌ាប្រជាធិបតេយ្យ និងនាំអាស៊ានឱ្យត្រឡប់ទៅដំណើរការជាប្រក្រតីឡើងវិញ។ កម្ពុជាបានខិតខំប្រឹងប្រែងធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីសម្រេចឱ្យបាននូវអាទិភាពសំខាន់ៗ៣ ដែលមានចែងក្នុង5PC៖ (១) ការបន្ថយ បញ្ឈប់អំពើហិង្សា (២) ការផ្តល់ជំនួយមនុស្សធម៌ដល់ប្រជាជនមីយ៉ាន់ម៉ាដោយមិនលម្អៀងនិងមិនរើសអើង និង(៣) ការពិភាក្សាជាមួយភាគីពាក់ព័ន្ធ ដើម្បីកសាងទំនុកចិត្តនិងបង្កបរិយាកាសអំណោយផលឈានទៅចាប់ផ្តើមដំណើរការពិភាក្សានយោបាយ ដើម្បីសន្តិភាពនិងការផ្សះផ្សាជាតិ

- ក្នុងនាមជាប្រេសិតពិសេសរបស់ប្រធានអាស៊ាន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**ប្រាក់ សុខុន** បានអញ្ជើញបំពេញបេសកកម្មនៅមីយ៉ាន់ម៉ា ចំនួន២លើក ដែលបានជួបជាមួយក្រុមជនជាតិភាគតិចប្រដាប់អាវុធ (EAO) ចំនួន៧ និងគណបក្សនយោបាយចំនួន៨ ដើម្បីពិគ្រោះយោបល់លើការបញ្ឈប់អំពើហិង្សានិងស្វែងរកដំណោះស្រាយ ព្រមទាំងបានបើកច្រកទ្វារសម្រាប់ការចរចាសន្តិភាពរវាងក្រុមប្រឹក្សារដ្ឋបាលរដ្ឋ(SAC) និងក្រុមទាំងឡាយដែលSAC ចាត់បានទុកជាភេរវករ

- កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាទទួលបាននូវការតបស្នងដោយការដោះលែងអ្នកទោសជនជាតិមីយ៉ាន់ម៉ានិងអន្តរជាតិជិត៦ ០០០នាក់ ដោយក្រុមប្រឹក្សារដ្ឋបាលរដ្ឋមីយ៉ាន់ម៉ា កាលពីខែវិច្ឆិកា ឆ្នាំ២០២២ ក្នុងនោះក៏មានលោកសាស្ត្រាចារ្យ**ហ្សូន ធីណែល** ដែលជាសញ្ញាណបង្ហាញពីចេតនាក្នុងការស្វែងរកដំណោះស្រាយដោយសន្តិវិធី។ ទោះបីអាណត្តិប្រធានអាស៊ានរបស់កម្ពុជាស្ទើរតែបញ្ចប់ក្តីឯកឧត្តមឧបនាយករដ្ឋមន្ត្រី**ប្រាក់ សុខុន** បានចូលរួមកិច្ចពិគ្រោះយោបល់ក្រៅផ្លូវការថ្នាក់រដ្ឋមន្ត្រី នៅប្រទេសថៃ កាលពីថ្ងៃទី២២ ខែធ្នូ ថ្មីៗនេះ ដើម្បីពិភាក្សាដោយបើកចំហជាមួយសហការីសមាជិកអាស៊ាន រួមទាំងមីយ៉ាន់ម៉ាលើវិធីសាស្ត្រជាក់ស្តែងក្នុងការអនុវត្ត5PC។ កិច្ចប្រជុំកំពូលអាស៊ានលើកទី៤០&៤១ ក៏បានពិភាក្សាស្ថានការណ៍នៅមីយ៉ាន់ម៉ានិងបានអនុម័ត «ការវាយតម្លៃរបស់ថ្នាក់ដឹកនាំអាស៊ាននិងសេចក្តីសម្រេចចិត្តស្តីពីការអនុវត្តលើការព្រមព្រៀងជាឯកច្ឆន្ទ៥ចំណុច»

- កម្ពុជាក្នុងនាមជាប្រធានអាស៊ានបានដាក់ចេញនូវឯកសារទស្សនាទាន ដើម្បីចូលរួមចំណែកដោះស្រាយវិបត្តិនយោបាយនៅមីយ៉ាន់ចំនួន៣ទៀត រួមមាន៖ (១) ការបង្កើតយន្តការត្រីភាគីអាស៊ាន (២) មិត្តមនុស្សធម៌អាស៊ានដើម្បីមីយ៉ាន់ម៉ា និង (៣) យុទ្ធសាស្ត្រច្រកចេញពីវិបត្តិនយោបាយនៅមីយ៉ាន់ម៉ា

- កម្ពុជាបានរៀបចំប្រកបភាពជោគជ័យនូវ «កិច្ចសន្ទនាសាកលអាស៊ានលើកទី២៖ ការស្តារឡើងវិញគ្រប់ជ្រុងជ្រោយក្រោយវិបត្តិជំងឺកូវីដ-១៩» ដែលចូលរួមពីប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនៃអាស៊ាន ដៃគូនានានិងប្រធានស្ថាប័ន អង្គការអន្តរជាតិដើម្បីបន្តអំពាវនាវនូវកិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងអាស៊ាននិងដៃគូខាងក្រៅ ក្នុងការដោះស្រាយផលប៉ះពាល់បណ្តាលមកពីជំងឺកូវីដ-១៩ ដូចជាបញ្ហាសន្តិសុខស្បៀងនិងថាមពល ស្ថិរភាពចង្វាក់ផ្គត់ផ្គង់ការពង្រឹងការងើបឡើងវិញនៃសេដ្ឋកិច្ចតំបន់

- កម្ពុជាក៏បានរៀបចំកិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី២ ក្រោមប្រធានបទ «ការកសាងអនាគតប្រកបដោយចីរភាព បរិយាបន្ននិងកាន់តែរឹងមាំ៖ ការបំផុសសហគ្រិនស្ត្រីអាស៊ាន» ក្នុងគោលដៅផ្តល់ជាវេទិកាសម្រាប់ការផ្លាស់ប្តូរមតិនិងការពិភាក្សារវាងមេដឹកនាំស្ត្រីអាស៊ាន និងប្រមុខដឹកនាំនៃប្រទេសសមាជិកអាស៊ានលើបញ្ហាប្រឈមនិងកាលានុវត្តភាព ដើម្បីអភិវឌ្ឍសហគ្រិនភាពស្ត្រីនិងលើកកម្ពស់បរិវត្តកម្មឆ្ពោះទៅរកការស្តារឡើងវិញដ៏រឹងមាំនៃសហគ្រាសធុនមីក្រូ ធុនតូចនិងមធ្យម ជាមួយនឹងការយកចិត្តទុកដាក់បំផុតទៅលើការគិតគូរពីភាពធន់និងចីរភាពក៏ដូចជាការពង្រឹងសេដ្ឋកិច្ចរបស់ស្ត្រីនិងការបញ្ជ្រាបយេនឌ័រ។

ស្របពេលកិច្ចប្រជុំកំពូលអាស៊ានកិច្ចប្រជុំកំពូលពាក់ព័ន្ធ និងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន**សម្តេចតេជោ នាយករដ្ឋមន្ត្រី** និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី**ប្រាក់ សុខុន** តែងបានឆ្លៀតឱកាសជួបពិភាក្សាការងារទ្វេភាគី ជាមួយប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនិងប្រមុខការទូតនៃប្រទេសនានា ដូចជាថៃ ឡាវ ព្រុយណេ វៀតណាម ហ្វីលីពីន ចិន សាធារណរដ្ឋកូរ៉េ ជប៉ុន អូស្ត្រាលី សហរដ្ឋអាមេរិក ឥណ្ឌា កាណាដា នូវែលសេឡង់ ចក្រភពអង់គ្លេស រុស្ស៊ី ទីម័រខាងកើត ប៉ាគីស្ថាន កាតា ហូឡង់ អ៊ុយក្រែន អគ្គលេខាធិការអាស៊ាន អគ្គលេខាធិការអ.ស.ប.

ក្រុមប្រឹក្សាសហភាពអឺរ៉ុប ព្រមទាំងប្រធានអង្គការអន្តរជាតិ ដូចជាអង្គការសហប្រតិបត្តិការសៀងហៃ វេទិកាសេដ្ឋកិច្ចតំបន់ធនាគារអភិវឌ្ឍន៍អាស៊ីក្នុងគោលបំណងពង្រឹងចំណងទំនាក់ទំនងការទូត និងកិច្ចសហប្រតិបត្តិការទ្វេភាគី។

**ខ- ក្របខ័ណ្ឌអង្គការសហប្រជាជាតិ**(អ.ស.ប)៖ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានពិភាក្សាការងារជាមួយឯកឧត្តមAntonio Guterres អគ្គលេខាធិការអ.ស.ប. ចំនួនពីរលើកក្នុងឆ្នាំ២០២២នេះ (១) ក្នុងឱកាសសម័យប្រជុំលើកទី៧៧ នៃមហាសន្និបាតអ.ស.ប. នៅទីក្រុងញូវយ៉កអំពីភាពជោគជ័យនៃការជំនុំជម្រះក្តីលើរបបប្រល័យពូជសាសន៍ កិច្ចសហប្រតិបត្តិការរក្សាសន្តិភាពក្រោមឆត្រអ.ស.ប. កិច្ចសហប្រតិបត្តិការអាស៊ានក្នុងដំណោះស្រាយលើបញ្ហាបម្រែបម្រួលអាកាសធាតុ និង(២) ក្នុងឱកាសកិច្ចប្រជុំកំពូលអាស៊ាននិងកិច្ចប្រជុំកំពូលពាក់ព័ន្ធនៅកម្ពុជាអំពីប្រធានបទបីសំខាន់ៗគឺ (១) កិច្ចប្រជុំកំពូលអាស៊ាននិងកិច្ចប្រជុំកំពូលពាក់ព័ន្ធ (២) ការចូលរួមរបស់កម្ពុជាក្នុងកិច្ចការអ.ស.ប. និង(៣) ការប្តេជ្ញាចិត្តរបស់អ.ស.ប.ចំពោះកម្ពុជា។

**គ- ក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ៖** កម្ពុជាបានបង្កើតលេខាធិការដ្ឋានជាតិនៃកិច្ចសហប្រតិបត្តិការមេគង្គ ឡានឆាង នៅឆ្នាំ២០១៧ និងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមូលនិធិពិសេសសម្រាប់គម្រោងកិច្ចសហប្រតិបត្តិការមេគង្គ ឡានឆាង(ឆ្នាំ២០១៧-២០២២) ដែលក្នុងនោះកម្ពុជាទទួលបានគម្រោងអនុម័តពីមូលនិធិពិសេសនេះ ចំនួន៨០គម្រោង ស្មើនឹងទំហំថវិកាសរុបប្រមាណ៣១លានដុល្លារអាម៉េរិក។ បន្ថែមពីនេះ កម្ពុជាក៏បានចូលរួមនិងដឹកនាំកិច្ចប្រជុំជ្រោមជ្រែងលើកស្ទួយគំនិតផ្តួចផ្តើមនៃការដំឡើងកម្រិត នៃយន្តការមេគង្គដល់កម្រិតកំពូលជាមួយប្រទេសកូរ៉េនិងជប៉ុន និងចូលរួមអនុម័តលិខិតូបករណ៍មួយចំនួនសំដៅឆ្ពោះទៅរកការរក្សាសន្តិភាព ការអភិវឌ្ឍនិងវិបុលភាពសម្រាប់ប្រជាជននៅក្នុងតំបន់មេគង្គ។ កម្ពុជាក៏បាននិងកំពុងជំរុញបង្កើតមូលនិធិអភិវឌ្ឍន៍អេកម៉ិកដែលនឹងក្លាយជាមូលនិធិដំបូងរបស់យន្តការអេកម៉ិក សំដៅចូលរួមកាត់បន្ថយគម្លាតអភិវឌ្ឍន៍និងលើកកម្ពស់ជីវភាពរបស់ប្រជាជន ដែលមានទុន សរុបចំនួន៥០០លានដុល្លារអាម៉េរិក(កម្ពុជាក៏បានសន្យាផ្តល់វិភាគទានចំនួន៧លានដុល្លារអាម៉េរិក)។

**ឃ- ក្របខ័ណ្ឌអង្គការហ្វ្រង់កូហ្វូនី(OIF)៖** មានការវិវត្តប្រកបដោយភាពប្រសើរ ដែលក្នុងនោះនៅក្នុងឱកាសនៃកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី១៨ នៅខែវិច្ឆិកា ឆ្នាំ២០២២ ប្រទេសទុយនីស៊ីកន្លងទៅឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអ៊ុច **បូរិទ្ធ** តំណាងដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ទទួលបាននូវការកោតសរសើរពីនាយករដ្ឋមន្ត្រីកាណាដា ប្រធានក្រុមប្រឹក្សាអឺរ៉ុបអំពីភាពជោគជ័យនៃការរៀបចំកិច្ចប្រជុំកំពូលអាស៊ាននិងកិច្ចប្រជុំកំពូលពាក់ព័ន្ធនិងសម្តែងការរីករាយនឹងជំនួបពិភាក្សាជាមួយថ្នាក់ដឹកនាំកំពូលកម្ពុជា នៅទីក្រុងភ្នំពេញ។ ជាមួយគ្នានេះ ប្រធានាធិបតីសាធារណរដ្ឋបារាំងក៏បានសម្តែងការរីករាយនិងឯកភាពជួបប្រជុំពិភាក្សាទ្វេភាគីជាមួយ**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ក្នុងអំឡុងពេលនៃកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន សហភាពអឺរ៉ុប ខែធ្នូ ឆ្នាំ២០២២ នៅទីក្រុងព្រុចសែល។ អគ្គលេខាធិការអង្គការOIF ក៏បានលើកឡើងពីការចូលរួមយ៉ាងសកម្មរបស់កម្ពុជានៅក្នុងគ្រប់អង្គភាពនិងប្រតិបត្តិកររបស់អង្គការOIF និងនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកជាពិសេសនៅក្នុងកិច្ចពិភាក្សាផ្តោតសំខាន់ទៅលើបញ្ហាប្រឈមរបស់តំបន់ហ្វ្រង់កូហ្វូន ដើម្បីស្វែងរកដំណោះស្រាយនិងស្នើឡើងនូវវិធានការសំដៅលើកកម្ពស់កិច្ចសហប្រតិបត្តិសេដ្ឋកិច្ចរវាងប្រទេសជាសមាជិកការប្រើប្រាស់ភាសាបារាំងសេដ្ឋកិច្ចនៅក្នុងតំបន់ហ្វ្រង់កូហ្វូន។ គណៈប្រតិភូកម្ពុជាក៏បានជួបប្រជុំពិភាក្សាអំពីការពង្រឹងការបង្កើតការងារ

សម្រាប់យុវជន ការពង្រឹងតួនាទីរបស់ស្ត្រី ការប្រើប្រាស់ឌីជីថល និងការពង្រឹងសមាហរណកម្មទំនាក់ទំនងកិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយរដ្ឋមន្ត្រីក្រសួងបរទេសអង់ដរ ទុយនីស៊ី កាណាដា និងកាមេរូន ព្រមទាំងតំណាងប្រទេសមួយចំនួនទៀត ដូចជារូម៉ានី ម៉ូណាកូ អេស្តូនីនិងលុចសំបួរ។

**ង- កិច្ចប្រជុំកំពូលអាស៊ី អឺរ៉ុបលើកទី១៣៖** កាលពីខែវិច្ឆិកា ឆ្នាំ២០២១ កម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ី អឺរ៉ុបលើកទី១៣ក្រោមមូលបទ «ការពង្រឹងពហុភាគីនិយម ដើម្បីកំណើនរួម» តាមរយៈប្រព័ន្ធវីដេអូក្នុងកាលៈទេសៈនៃការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ប្រកបដោយភាពជោគជ័យ និងលទ្ធផលផ្លែផ្កា។ កិច្ចប្រជុំកំពូលនេះ បានអនុម័តជាផ្លូវការនូវឯកសារលទ្ធផលសំខាន់ៗចំនួន៣ រួមមាន៖ (១) សេចក្តីថ្លែងការណ៍ប្រធានអង្គប្រជុំកំពូលASEM លើកទី១៣ (២) សេចក្តីថ្លែងការណ៍ទីក្រុងភ្នំពេញស្តីពីការស្តារសង្គមសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ និង (៣) ឯកសារសកម្មភាពអនាគតស្តីពីការតភ្ជាប់ASEM។

ក្រៅពីនេះ កម្ពុជាក៏បានបន្តចូលរួមយ៉ាងសកម្មក្នុងយន្តការពហុភាគីជាច្រើនទៀត ដើម្បីចូលរួមជាផ្នែកមួយក្នុងការកសាងសហគមន៍នៅក្នុងតំបន់និងសកលលោកប្រកបដោយសន្តិភាព សន្តិសុខនិងវិបុលភាពដូចជាយន្តការ NAM CICA SCO ADM BOAO CLV CLMVជាដើម។

## ២- ការអនុវត្តការងារការទូតសេដ្ឋកិច្ចនិងវប្បធម៌

ក្នុងរយៈពេល៥ឆ្នាំមកនេះកបទ.សអ. បានសម្រេចនូវសមិទ្ធផលជាច្រើន សំដៅចូលរួមចំណែកអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិក៏ដូចជាការផ្សព្វផ្សាយអំពីវប្បធម៌និងទំនៀមទំលាប់ដ៏ប្រពៃរបស់ខ្មែរលើឆាកអន្តរជាតិ ដែលកិច្ចការទាំងនោះ រួមមាន៖

**ក- ក្របខ័ណ្ឌគោលនយោបាយ៖** កបទ.សអ. បានដាក់ចេញនូវ «យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ ២០២១-២០២៣» ដែលបានបញ្ចូលនូវទិដ្ឋភាពសេដ្ឋកិច្ច ទៅក្នុងគោលនយោបាយការបរទេសរបស់រដ្ឋសំដៅបង្កើតឱ្យមានយន្តការអនុវត្តការទូតសេដ្ឋកិច្ចប្រកបដោយភាពប្រទាក់ក្រឡាគ្នា ប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពតាមរយៈការលើកកម្ពស់និងការពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅនិងជំទូលាយ ជាមួយស្ថាប័នជាតិនិងអន្តរជាតិ ដើម្បីឆ្ពោះទៅកាន់វិបុលភាពផ្នែកសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គម។ ស្របតាមស្មារតីនេះកបទ.សអ.បានបង្កើតក្រុមការងារអន្តរក្រសួងនិងវិស័យឯកជន ព្រមទាំងបានរៀបចំកិច្ចប្រជុំនិងកិច្ចពិគ្រោះយោបល់ចំនួន៣លើកក្នុងគោលបំណងពិភាក្សា ចែករំលែកព័ត៌មាន និងប្រមូលធាតុចូលពីគ្រប់ភាគីពាក់ព័ន្ធទាំងក្នុងវិស័យឯកជននិងរដ្ឋ។ ជាងនេះទៅទៀត ដើម្បីធានាដល់និរន្តរភាពនិងប្រសិទ្ធភាពការងារកបទ.សអ.បានបង្កើតរចនាសម្ព័ន្ធរឹងសម្រាប់ការងារការទូតសេដ្ឋកិច្ចដោយបានកែសម្រួលពីនាយកដ្ឋានគោលនយោបាយ និងផែនការយុទ្ធសាស្ត្រទៅជា «នាយកដ្ឋានគោលនយោបាយការទូតសេដ្ឋកិច្ចនិងផែនការយុទ្ធសាស្ត្រ»។

**ខ- ក្របខ័ណ្ឌបណ្តុះបណ្តាលធនធានអ្នកការទូត៖** ជាការពិតធនធានមនុស្សជាបច្ច័យដ៏ចាំបាច់បំផុតក្នុងការសម្រេចបានតាមទិសដៅនៃយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចដែលបានដាក់ចេញ។ ហេតុដូចនេះ កបទ.សអ. តាមរយៈវិទ្យាស្ថានជាតិការទូតនិងទំនាក់ទំនងអន្តរជាតិ បាននិងកំពុងរៀបចំកម្មវិធីនិងផ្តល់វគ្គបណ្តុះបណ្តាលដល់មន្ត្រីការទូត រួមមាន៖

- របាយការណ៍វាយតម្លៃតម្រូវការអភិវឌ្ឍធនធានមនុស្សសម្រាប់ការអនុវត្តការទូតសេដ្ឋកិច្ច( Training Needs Assessment)

- វគ្គបណ្តុះបណ្តាលគ្រូបង្គោល (Training of Trainers) សម្រាប់បណ្តុះបណ្តាលធនធានមនុស្ស

- បានសម្ពោធ «ផ្ទះបាយអង្គរ» ដែលជាទីកន្លែងបណ្តុះបណ្តាលវិធីចម្អិនម្ហូបអាហារ ពិធីការនិងបដិសណ្ឋារកិច្ចដល់មន្ត្រីការទូតកម្ពុជានិងសហព័ទ្ធរបស់ឯកអគ្គរាជទូត

- ការរៀបចំសិក្ខាសាលាសំខាន់ៗដូចជា៖ (១) សិក្ខាសិលាផ្សព្វផ្សាយច្បាប់វិនិយោគ និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ និង(២) សិក្ខាសិលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការទូតសេដ្ឋកិច្ចក្នុងគន្លងប្រក្រតីភាពថ្មី ក្រោមក្របខ័ណ្ឌគម្រោងមេគង្គ ឡានចាង និង(៣) សិក្ខាសិលាស្តីពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣» ។

**គ- សកម្មភាពការងារការទូតសេដ្ឋកិច្ច៖**

**កបទ.សអ. និងស្ថានតំណាងកម្ពុជាប្រចាំនៅបរទេសបាន៖**

- សម្របសម្រួលដំណើរទស្សនកិច្ចធុរកិច្ចដល់សភាពាណិជ្ជកម្មកម្ពុជានៅប្រទេសតួកគី និងដំណើរទស្សនកិច្ចធុរកិច្ចនិងអង្គទូតពីប្រទេសម៉ាឡេស៊ី ថៃ ជប៉ុន និងសាធារណរដ្ឋកូរ៉េនៅកម្ពុជា ដើម្បីសិក្សាស្វែងយល់ពីសក្តានុពលសេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍នៅកម្ពុជា ព្រមទាំងចូលរួមការផ្គូផ្គងធុរកិច្ចជាមួយសហគ្រិនខ្មែរក្នុងគោលបំណងបង្កើតលទ្ធភាពនៃកិច្ចសហប្រតិបត្តិការធុរកិច្ចជាមួយគ្នា។ កបទ.សអ.ក៏បានរៀបចំ៖ (១) ជំនួបធុរកិច្ចកម្ពុជា ស៊ែប៊ីដោយមានការចូលរួមពីតំណាងក្រសួងទេសចរណ៍ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានិងសភាពាណិជ្ជកម្មកម្ពុជា និង(២) បេសកកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មហ្វ្រង់កូហ្វូនីលើកដំបូងនៅអាស៊ីអាគ្នេយ៍ ដឹកនាំដោយលោកជំទាវអគ្គលេខាធិការនៃអង្គការOIF នាខែមីនា ឆ្នាំ២០២២ ដែលមានការចូលរួមពីប្រធានសហគ្រាសប្រតិបត្តិករ តួអង្គសេដ្ឋកិច្ចជាង២៥០នាក់ មកពីទ្វីបទាំងប្រាំ។ បេសកកម្មនេះ បានអនុញ្ញាតឱ្យក្រុមហ៊ុន និងប្រតិបត្តិករសេដ្ឋកិច្ចដែលចូលរួមស្វែងរកដៃគូកម្ពុជា សម្រាប់អនុវត្តគម្រោងសហប្រតិបត្តិការពាណិជ្ជកម្ម និងឧស្សាហកម្មរបស់ពួកគេនៅក្នុងវិស័យដែលមានសក្តានុពលខ្ពស់ ដូចជាវិស័យកសិ-ឧស្សាហកម្ម ថាមពលកកើតឡើងវិញ ទំនិញនិងសេវាកម្មឌីជីថលនិងវិស័យផ្សេងទៀត ព្រមទាំងសម្រាប់ការអភិវឌ្ឍកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៅក្នុងតំបន់ហ្វ្រង់កូហ្វូន។ ជាក់ស្តែង ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់រវាងសភាពាណិជ្ជកម្មកម្ពុជានិងសភាពាណិជ្ជកម្មបេណាំងកូតឌីវ័រនិងអាហ្វ្រិកខាងលិច និងការចុះហត្ថលេខាលើលិខិតបញ្ជាក់ពីគោលបំណងសហប្រតិបត្តិការពាណិជ្ជកម្មរវាងក្រសួងពាណិជ្ជកម្មកម្ពុជានិងហ្គាបុង ដែលគ្រោងនឹងធ្វើឡើងនៅដើមឆ្នាំ២០២៣នេះ

- រៀបចំចងក្រងនិងបោះពុម្ពសៀវភៅមុខម្ហូប «**កេរ្តិ៍ដំណែលស្នាដៃម្ហូបខ្មែរ**» សម្រាប់ធ្វើការផ្សព្វផ្សាយពីវប្បធម៌ម្ហូបអាហារខ្មែរនៅលើឆាកអន្តរជាតិដែលសៀវភៅនេះបានទទួល៖ (១) ពានរង្វាន់ជា «សៀវភៅមុខម្ហូបអាស៊ីដែលល្អផ្តាច់គេ» ពីរឆ្នាំជាប់ៗគ្នា (២០២១-២០២២) ក្នុងកម្មវិធីGourmand World Cookbook Award និង (២) ជ័យលាភីពីរ បន្ថែមទៀតជា «សៀវភៅម្ហូបអាស៊ីដ៏ល្អជាច់គេ» និងជា«សៀវភៅម្ហូបឆ្នើមដែលរៀបរៀងដោយថ្នាក់ដឹកនាំនៃរដ្ឋ» ក្នុងសន្និសីទម្ហូបអាហារអន្តរជាតិនៅប្រទេសស៊ុយអែត

- ជួបពិភាក្សាជាមួយសហគ្រិននិងមន្ត្រីអាជ្ញាធររដ្ឋបរទេសក្នុងគោលបំណងផ្សព្វផ្សាយ និងបង្កើតកាលានុវត្តភាពពាណិជ្ជកម្មនិងវិនិយោគលើវិស័យទេសចរណ៍ សំណង់ អចលនទ្រព្យ ឱសថ ហិរញ្ញវត្ថុ គ្រឿងសម្អាង ថាមពលថ្មី ដឹកជញ្ជូន កសិកម្ម ពង្រីកទីផ្សារផលិតផល ផ្សព្វផ្សាយវប្បធម៌និងម្ហូបអាហារកម្ពុជា។ល។

- រៀបចំតាំងពិព័រណ៍បង្ហាញផលិតផល ទេសចរណ៍និងវប្បធម៌ខ្មែរក្នុងកម្មវិធីអន្តរជាតិនានា។ ថ្មីៗនេះ កបទ.សអ. ក៏បានសហការរៀបចំការតាំងពិព័រណ៍ផលិតផលខ្មែរក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ និងកិច្ចប្រជុំពាក់ព័ន្ធ

- រៀបចំនិងផ្សព្វផ្សាយផ្ទាំងព័ត៌មានខ្លីៗស្ដីពីសេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍និងគម្រោងរៀបចំគេហទំព័រការទូតសេដ្ឋកិច្ច ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្សព្វផ្សាយ។

### ៣- ការចូលរួមក្នុងបុព្វហេតុសន្តិភាព ស្ថិរភាពនិងដំណោះស្រាយបញ្ហាប្រឈមនានានៅក្នុងពិភពលោក

ពីប្រទេសដែលធ្លាប់ទទួលរងគ្រោះដោយសារភ្នក់ភ្លើងសង្គ្រាម កម្ពុជាបានប្រែក្លាយទៅជាប្រទេសមានសុខសន្តិភាពពេញលេញ ព្រមទាំងបានចូលរួមយ៉ាងសកម្មក្នុងបុព្វហេតុសន្តិភាពតំបន់ និងពិភពលោករាប់ចាប់ពីបញ្ហាសន្តិសុខ នយោបាយរហូតដល់សង្គម សេដ្ឋកិច្ចនិងបរិស្ថានតាមរយៈ៖

**ក- ប្រតិបត្តិការរក្សាសន្តិភាពអ.ស.ប.៖** កម្ពុជាបានប្រែក្លាយពីប្រទេសដែលទទួលកងទ័ពមួកខៀវទៅជាប្រទេសដែលបញ្ជូនកងកម្លាំងទៅរក្សាសន្តិភាពក្នុងប្រទេសផ្សេងទៀតក្រោមឆត្រអ.ស.ប. ដែលការណ៍នេះសបញ្ជាក់នូវជោគជ័យដ៏ធំមួយនិងជាការផ្លាស់ប្ដូរមុខមាត់របស់ប្រទេសកម្ពុជាលើឆាកអន្តរជាតិ។ ចាប់ពីឆ្នាំ២០០៦ មកទល់បច្ចុប្បន្ន កម្ពុជាបានបញ្ជូនកងកម្លាំងរក្សាសន្តិភាពសរុបចំនួន៨ ៦៧១នាក់(ស្ត្រី៦៤៧នាក់) ទៅបំពេញសកកម្មរក្សាសន្តិភាពអ.ស.ប. នៅក្នុងប្រទេសចំនួន៩ រួមមានស៊ូដង់ ស៊ូដង់ខាងត្បូង ឆាដ សាធារណរដ្ឋអាហ្វ្រិកកណ្ដាល លីបង់ ស៊ីប ស៊ីរី ម៉ាលីនិងយ៉េមែន។ ក្នុងនោះ បានចលនាឱ្យមានការជ្រើសរើសលោកស្រីវរសេនីយ៍ទោ**ខា ម៉ែសារ៉ស់** ដែលជាស្ត្រីខ្មែរមួយរូបក្នុងចំណោមកងកម្លាំងរក្សាសន្តិភាពរបស់កម្ពុជា «ជាស្ត្រីក្លាហាន» នៅក្នុងយុទ្ធនាការ «ស្ត្រីដើម្បីពហុភាគីនិយម»ដែលបានប្រព្រឹត្តទៅនៅខែមីនា ឆ្នាំ២០២២នៅទីក្រុងហ្សឺណែវ។

**ខ- ជម្លោះនៅសមុទ្រចិនខាងត្បូង៖** កម្ពុជានៅតែរក្សាជំហរជំរុញការអនុវត្តស្មារតីនៃសេចក្ដីប្រកាសស្ដីពីការប្រតិបត្តិរបស់ភាគីនៅសមុទ្រចិនខាងត្បូង(DOC) និងចូលរួមដោយវិជ្ជមានក្នុងដំណើរការចរចាក្រមប្រតិបត្តិសមុទ្រចិនខាងត្បូង(COC) ដោយកម្ពុជាបានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំក្រុមការងាររួមអាស៊ាន ចិនដែលទទួលបន្ទុកចរចាឯកសារCOC ចំនួន២លើកជាប់គ្នារួចមកហើយនៅឆ្នាំ២០២២។

**គ- សង្គ្រាមរុស្ស៊ី អ៊ុយក្រែន៖** នៅក្នុងសំណុំរឿងនេះ កម្ពុជាយល់ពីក្ដីបារម្ភផ្នែកសន្តិសុខរបស់ភាគីទាំងអស់និងមិនប្រកាន់ជំហរប្រឆាំងភាគីណាមួយឡើយ។ កម្ពុជាបានប្រើប្រាស់សិទ្ធិនៃរដ្ឋអធិបតេយ្យបោះឆ្នោតគាំទ្រនិងធ្វើជាសហស្ថាបនិកលើសេចក្ដីសម្រេចចិត្តរបស់មហាសន្និបាតអ.ស.ប. មួយចំនួនក្នុងស្មារតីការពារគោលការណ៍ច្បាប់អន្តរជាតិ ដែលចែងក្នុងធម្មនុញ្ញអ.ស.ប. ការគោរពអធិបតេយ្យ បូរណភាពទឹកដីនិងឯករាជ្យភាពផ្នែកនយោបាយរបស់រដ្ឋសមាជិក។ ជាសក្ខីភាពបញ្ជាក់ពីអព្យាក្រឹតភាព និងស្មារតីចូលរួមបុព្វហេតុសន្តិភាពក្នុងពិភពលោក កម្ពុជាក៏បានបោះឆ្នោតអនុប្បវាទលើសេចក្ដីសម្រេចចិត្តពាក់ព័ន្ធនឹងការព្យួរបេក្ខភាពរុស្ស៊ីក្នុងក្រុមប្រឹក្សាសិទ្ធិមនុស្សអ.ស.ប. និងការទាមទារសំណងសង្គ្រាម លន់ នល់ កម្ពុជាយល់ឃើញថា មិនមែនជាទង្វើដែលមានលក្ខណៈស្ថាបនាដើម្បីរក្សាសន្តិភាពនិងស្ថិរភាពនោះទេ។ ជាងនេះទៀតកាលពីខែវិច្ឆិកា ឆ្នាំ២០២២ ក្នុងកិច្ចប្រជុំមហាសន្និបាតអ.ស.ប. លើកទី៧៧ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេច «គាំទ្រ» និងចូលជាCo-sponsor លើសេចក្ដីព្រាងសេចក្ដីសម្រេចចិត្តរបស់រុស្ស៊ីស្ដីពី «ការប្រយុទ្ធប្រឆាំងនឹងការលើកតម្កើងនៃលទ្ធិណាហ្ស៊ីនិយម

លទ្ធិណាហ្ស៊ីនិយមបែបថ្មីនិងការអនុវត្តផ្សេងៗទៀត ដែលរួមចំណែកជំរុញទម្រង់សហសម័យនៃការរើសអើងជាតិសាសន៍និយម ពណ៌សម្បុរ ការស្អប់ខ្ពើមជនបរទេសនិងការមិនអត់ឱនផ្សេងៗទៀត។

**ឃ- សមាជិកភាពកម្ពុជាក្នុងអង្គការអន្តរជាតិនានា៖** កម្ពុជាបានចូលជាសមាជិកស្ថាប័ន អ.ស.ប. និងអន្តរជាតិមួយចំនួន រួមមាន៖ (១) ក្រុមប្រឹក្សាប្រតិបត្តិអ.ស.ប មូលនិធិអ.ស.ប សម្រាប់ប្រជាជនការិយាល័យ អ.ស.ប. សម្រាប់សេវាកម្មគម្រោងសម្រាប់អាណត្តិ២០១៨-២០២០ (២) គណៈកម្មាធិការការពារសម្បត្តិវប្បធម៌ក្នុងគ្រាមានជម្លោះប្រដាប់អាវុធ សម្រាប់អាណត្តិ ២០១៧-២០២១ (៣) ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមអ.ស.ប. (ECOSOC) សម្រាប់អាណត្តិ២០១៩ (៤) អនុប្រធានមហាសន្និបាតអ.ស.ប.សម័យប្រជុំលើកទី៧៣ (៥) ក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលបណ្តុះបណ្តាល ដើម្បីការអភិវឌ្ឍបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មានអាស៊ីនិងប៉ាស៊ីហ្វិកនៃUN-ESCAP សម្រាប់អាណត្តិ២០១៨-២០២១ និង (៦) អ្នកជំនាញស្តង់ដាគណនេយ្យ និងការរាយការណ៍(ISAR) សម្រាប់អាណត្តិ២០១៩-២០២១។

ទន្ទឹមនេះ កម្ពុជាក៏បាននិងកំពុងស្វែងរកការគាំទ្រសម្រាប់សមាជិកភាពក្នុងស្ថាប័នអ.ស.ប.ចំនួន២ បន្ថែមទៀតរួមមាន៖ (ក) គណៈកម្មាធិការគ្រប់គ្រងនៃគណៈកម្មការកសាងសន្តិភាពអ.ស.ប.(OCPBC) សម្រាប់អាណត្តិ២០២៥-២០២៦ ដែលការបោះឆ្នោតនឹងប្រព្រឹត្តទៅនៅខែធ្នូ ឆ្នាំ២០២៤ និង (ខ) ក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម(ECOSOCC) សម្រាប់អាណត្តិ២០២៨-២០៣០ ដែលការបោះឆ្នោតនឹងប្រព្រឹត្តទៅនៅខែមិថុនា ឆ្នាំ២០២៧។

## ៤- ការចូលរួមរបស់កងយោធពលខេមរភូមិន្ទ ក្នុងការបំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ

កងយោធពលខេមរភូមិន្ទ បានបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការនិងទំនាក់ទំនងល្អជាមួយប្រទេសជិតខាង ប្រទេសក្នុងតំបន់ និងអន្តរជាតិ ពិសេសការលើកកម្ពស់កិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយបណ្តាប្រទេសជាដៃគូឱ្យកាន់តែស៊ីជម្រៅនិងគ្រប់ជ្រុងជ្រោយថែមទៀត ដើម្បីជំរុញបង្កើនសមត្ថភាពការពារជាតិ ពង្រឹងសាមគ្គីភាព ឈរលើគោលការណ៍ឯករាជ្យ អព្យាក្រឹត្យ គោរពផលប្រយោជន៍គ្នាទៅវិញទៅមក ដែលការអនុវត្តសកម្មភាពការងារទាំងនោះបានប្រព្រឹត្តទៅទទួលបាននូវលទ្ធផលផ្លែផ្កាគួរជាទីមោទនៈ។ ទន្ទឹមនេះ ការកើតឡើងនូវជំងឺកូវីដ-១៩ នៅទូទាំងពិភពលោក បានធ្វើឱ្យមានការផ្លាស់ប្តូរទស្សនកិច្ច ការធ្វើលំហាត់រួមគ្នា កិច្ចប្រជុំថ្នាក់តំបន់អន្តរជាតិស្ទើរតែទាំងស្រុងត្រូវបានផ្អាក និងបានផ្លាស់ប្តូរពីការចូលរួមដោយផ្ទាល់ទៅជាការចូលរួមតាមប្រព័ន្ធវីដេអូអនឡាញ ទោះជាយ៉ាងនេះក្តីកងយោធពលខេមរភូមិន្ទនៅតែបន្តរក្សាកិច្ចសហប្រតិបត្តិការល្អជាមួយប្រទេសដៃគូពាក់ព័ន្ធលើការងារមួយចំនួន ទាំងការចូលរួមដោយផ្ទាល់និងតាមប្រព័ន្ធវីដេអូអនឡាញ ប្រព័ន្ធទូរគមនាគមន៍ជាហូរហែ។ ក្រៅពីនេះ កងយោធពលខេមរភូមិន្ទក៏បានទទួលនូវការជួយឧបត្ថម្ភផ្សេងៗពីបណ្តាប្រទេសដៃគូជាស្មារតី ថវិកា សំណង់អគារ រថយន្ត គ្រឿងចក្រគ្រប់ប្រភេទ វ៉ាក់សាំងកូវីដ-១៩ ឱសថ សម្ភារៈបរិក្ខារពេទ្យ ព្រមទាំងសម្ភារៈផ្សេងៗ រួមទាំងការផ្តល់នូវអាហារូបករណ៍ដល់កងយោធពលខេមរភូមិន្ទទៅសិក្សានៅក្រៅប្រទេសផងដែរ។ ទាំងនេះគឺជាសមិទ្ធផលមួយផ្នែកដែលបានរួមចំណែកយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍកងយោធពលខេមរភូមិន្ទសមស្របទៅនឹងដំណាក់កាលវិវឌ្ឍន៍ថ្មីៗរបស់កម្ពុជាជាបន្តបន្ទាប់។

នៅក្នុងរយៈពេល៥ឆ្នាំមកនេះ ក្រសួងការពារជាតិបានចាត់តាំងគណៈប្រតិភូនិងនាយទាហានទៅបំពេញទស្សនកិច្ច ចូលរួមប្រជុំ សិក្ខាសាលា និងបំពេញការងារផ្សេងៗក្រៅប្រទេសដោយផ្ទាល់និងតាមប្រព័ន្ធវីដេអូអនឡាញ ប្រព័ន្ធទូរគមនាគមន៍ចំនួន១ ២២៧ប្រតិភូ/លើក ក្នុងនោះគណៈប្រតិភូជាន់ខ្ពស់ដឹកនាំដោយ**សម្តេច**

**ពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** អញ្ជើញទៅដោយផ្ទាល់ ២២ប្រតិភូ និងតាមប្រព័ន្ធវីដេអូអនឡាញនិងប្រព័ន្ធគមនាគមន៍១២ប្រតិភូ/លើក(ប្រទេសសិង្ហបុរី ថៃ ចិន ឡាវ សហរដ្ឋអាម៉េរិក តួកគី វៀតណាម អូស្ត្រាលី ជប៉ុន ព្រុយណេ ម៉ាឡេស៊ី និងរុស្ស៊ី)។ គណៈប្រតិភូយោធាបរទេសមកបំពេញទស្សនកិច្ច ចូលរួមប្រជុំនិងបំពេញការងារផ្សេងៗជាមួយកងយោធពលខេមរភូមិន្ទមានចំនួន២៥៩ប្រតិភូ/លើក ក្នុងនោះគណៈប្រតិភូដឹកនាំដោយ**សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** មានចំនួន៩ប្រតិភូ/លើក(ឥណ្ឌា វៀតណាម ចិន ថៃ ឡាវ ឥណ្ឌូណេស៊ី និងជប៉ុន) និងការចូលចតនាវាចម្បាំងចំនួន១៨លើកស្មើនឹងនាវា២៥គ្រឿង(ឥណ្ឌា វៀតណាម ថៃ រុស្ស៊ី ចិន ជប៉ុន អូស្ត្រាលី អ៊ិស្លាម ប៉ាគីស្ថាន និងកាណាដា)។

ក្នុងនាមជាប្រធានអាស៊ានប្តូរវេន ក្រសួងការពារជាតិបានរៀបចំកិច្ចប្រជុំផ្សេងៗបន្តបន្ទាប់ដោយផ្ទាល់ និងតាមប្រព័ន្ធវីដេអូអនឡាញ ពិសេសកិច្ចប្រជុំធំៗ ដូចជាកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ានលើកទី១៦ កិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន ជប៉ុន កិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការពារជាតិអាស៊ាន ចិន កិច្ចប្រជុំអគ្គ-មេបញ្ជាការកងទ័ពអាស៊ានលើកទី១៩ កិច្ចប្រជុំឧត្តមមន្ត្រីការពារជាតិអាស៊ាន កិច្ចប្រជុំឧត្តមមន្ត្រីការពារជាតិអាស៊ានបូក កិច្ចប្រជុំប្រតិបត្តិការយោធាអាស៊ានលើកទី១២ កិច្ចប្រជុំចារកម្មយោធាអាស៊ានលើកទី១៩ ដោយទទួលបានលទ្ធផលផ្លែផ្កាប្រកបដោយភាពរាក់ទាក់និងស្និតស្នាលបំផុត ស្របតាមទិសដៅនៃការជំរុញលើកកម្ពស់សាមគ្គីភាពក្នុងចំណោមបណ្តាប្រទេសអាស៊ាន រួមគ្នាដោះស្រាយបញ្ហាប្រឈមសន្តិសុខតំបន់ក្នុងពេលបច្ចុប្បន្ន និងបញ្ហាប្រឈមកំពុងលេចឡើងថ្មីៗក្រោមមូលបទ «**សាមគ្គីដើម្បីសន្តិសុខប្រកបដោយភាពសុខដុម**» ដែលក្រសួងការពារជាតិបានដាក់ចេញ។









**ពិធីបិទសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២១**
**និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ**
**កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២**









**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើក «កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥» នៅរាជធានីភ្នំពេញ កាលពីថ្ងៃទី៣ ខែសីហា ឆ្នាំ២០២២**









សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
អញ្ជើញធ្វើសេចក្តីថ្លែងការណ៍ក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ លើកទី៧៧
នៅទីក្រុងញូវយ៉ក សហរដ្ឋអាម៉េរិក កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២








សម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
ព្រះអង្គសព្វព្រះរាជហឫទ័យព្រះបរមរាជានុញ្ញាតជូនប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនៃ
បណ្តាប្រទេសអាស៊ាន ចូលក្រាបថ្វាយបង្គំគាល់ និងប្រទានព្រះរាជសវនាការ
នាព្រះទីនាំងទេវាវិនិច្ឆ័យព្រះបរមរាជវាំង កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២








**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង មេដឹកនាំអាស៊ានអញ្ជើញបើកកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០-៤១ និងទស្សនាពិព័រណ៍ ផលិតផលស្នាដៃអាស៊ាននៅសណ្ឋាគារសុខាភ្នំពេញ**
**កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២**










កិច្ចប្រជុំកំពូលអាស៊ានជាមួយដៃគូសន្ទនា រួមមាន ចិន ជប៉ុន កូរ៉េ
ឥណ្ឌា សហរដ្ឋអាម៉េរិក កាណាដា នៅរាជធានីភ្នំពេញ
កាលពីថ្ងៃទី១១ ទី១២ ទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២







សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
ជួបពិភាក្សាការងារជាមួយឯកឧត្តម Antonio Guterres អគ្គលេខាធិការអង្គការសហប្រជាជាតិ
នៅវិមានសន្តិភាព រាជធានីភ្នំពេញ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២









ពិធីបើកកិច្ចប្រជុំពេញអង្គនៃកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន
សហភាពអឺរ៉ុបលើកទី៤៥ នៅទីក្រុងព្រុចសែល ប្រទេសបែលហ្សិក
កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២










សម្តេចតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន
អញ្ជើញទទួលពានរង្វាន់សមិទ្ធផលពេញមួយជីវិតរបស់មេដឹកនាំឆ្នើម
ពិភពលោក នៅវិមានសន្តិភាព កាលពីថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២២









**ពិធីជូនដំណើរកងកម្លាំងកងយោធពលខេមរភូមិន្ទទៅចូលរួមបំពេញបេសកកម្ម រក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅសាធារណរដ្ឋម៉ាលី និងសាធារណរដ្ឋ ស៊ូដង់ខាងត្បូង កាលពីឆ្នាំ២០២២**

## យុទ្ធសាស្ត្រចតុកោណទី១
## ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្ស ត្រូវបានចាត់ទុកជាអាទិភាពនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ នៅគ្រប់ដំណាក់កាល ពិសេសបានក្លាយទៅជាអាទិភាពទី១ នៅដំណាក់កាលទី៣និងទី៤នេះ សំដៅលើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការស្នេហាជាតិ និងស្មារតីទទួលខុសត្រូវ សុខភាពនិងកាយសម្បទារឹងមាំ តួនាទីស្ត្រីនិងកិច្ចគាំពារសង្គម។

### មុំទី១- ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា

**១- ក្រសួងអប់រំ យុវជន និងកីឡាសម្រេចការងារបានដូចខាងក្រោម៖**

(ទំព័រហ្វេសប៊ុក៖ www.facebook.com/moeys.gov.kh) (YouTube ៖ www.youtube.com/moeys)

### ១.១- ការពង្រឹងនិងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្ដុះបណ្ដាលបច្ចេកទេស

រាជរដ្ឋាភិបាលបានផ្ដល់អាទិភាពចម្បងដល់ការអភិវឌ្ឍធនធានមនុស្ស ដូចមាននៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សំដៅលើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការស្នេហាជាតិ និងស្មារតីទទួលខុសត្រូវ សុខភាពនិងកាយសម្បទារឹងមាំ តួនាទីស្ត្រីនិងកិច្ចគាំពារសង្គម ដើម្បីគាំទ្រដល់ការសម្រេចបាន ចក្ខុវិស័យអភិវឌ្ឍកម្ពុជា ប្រែក្លាយកម្ពុជាជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ក្នុងទិសដៅនេះ ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ កំណែទម្រង់វិស័យអប់រំនិងសកម្មភាពដែលទទួលបានសមិទ្ធផលសំខាន់ៗគួរឱ្យកត់សម្គាល់ក្នុងរយៈពេល៥ឆ្នាំកន្លងមក ដូចខាងក្រោម៖

សាលារៀនគ្រប់កម្រិតសិក្សាបានកើនឡើងជាលំដាប់ស្ទើរតែគ្រប់ទីតាំងភូមិសាស្ត្រទូទាំងប្រទេស ក្នុងគោលដៅបង្កិតសាលារៀនឱ្យទៅជិតលំនៅដ្ឋានរបស់ប្រជាជន ស្របតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់**សម្ដេចតេជោនាយករដ្ឋមន្ត្រី**។ ជាលទ្ធផលនៅទូទាំងប្រទេស សាលាមត្តេយ្យសិក្សានិងសាលារៀនចំណេះទូទៅ សរុប ១៨ ៤៣០ ក្នុងនោះ សាលាមត្តេយ្យសិក្សាគ្រប់រូបភាព៨ ៣៣៤សាលា/កន្លែង សាលាបឋមសិក្សា៧ ៩៦១ អនុវិទ្យាល័យ១ ៣៦៥ និងវិទ្យាល័យ៧៧០។ ក្រសួងបានជួសជុលនិងសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តថ្មីនៅវិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ អគារសិក្សា១២០ខ្នង(៨៥២បន្ទប់) ទីចាត់ការ៥ខ្នងស្មើនិង២៥បន្ទប់ និងបណ្ណាល័យ១ខ្នង។ សាងសង់អគារធនធានថ្មី១៤ ក្នុងនោះមានបន្ទប់ពិសោធន៍ បណ្ណាល័យ និងបន្ទប់កុំព្យូទ័រ សាងសង់បន្ទប់ពិសោធន៍ថែមពីរបន្ទប់ក្នុងមួយសាលាសម្រាប់សាលាមធ្យមសិក្សាធនធាន៥០ សាងសង់សម្ភារៈរូបវន្តអនាម័យដល់សាលាធនធាន១៨ បំពាក់បន្ទះសូឡាដល់វិទ្យាល័យធនធាន២០ និងវិទ្យាល័យបណ្ដាញ៣០ ជួសជុលអគារសិក្សានៃវិទ្យាល័យបណ្ដាញ៨៧ទីតាំង បណ្ណាល័យ៨៧បន្ទប់ និងបន្ទប់ពិសោធន៍៨៧បន្ទប់ ជួសជុលអគារសិក្សាសាលាបឋមសិក្សា២ខ្នង(៨បន្ទប់) និងជួសជុលអន្តេវាសិកដ្ឋានក្នុងវិទ្យាល័យ៣ខ្នង(៥៤បន្ទប់)។ សាងសង់អគារមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវនិងបណ្ដុះបណ្ដាល១ខ្នង អន្តេវាសិកដ្ឋាន១ខ្នង ជួសជុលបន្ទប់ពិសោធន៍ និងកំពុងសាងសង់អគាររោងជាងនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ សាងសង់អន្តេវាសិកដ្ឋាន១ខ្នង អគារមជ្ឈមណ្ឌលបណ្ដុះបណ្ដាលពន្លកអាជីវកម្ម ជួសជុលបន្ទប់ពិសោធន៍

អគារAនិងអគារវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា(STEM) និងសាងសង់រោងបន្លែនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ បន្ទប់អគារធនធាន១៧ខ្នង(២៥៥បន្ទប់) ផ្ទះសំណាក់គ្រូ៥ខ្នង(១៥បន្ទប់) ផ្ទះសំណាក់សិស្ស១ខ្នង(៤៨បន្ទប់) បង្គន់អនាម័យ៣២ខ្នង(១៦០បន្ទប់) អណ្ដូងទឹក២៣ របងសាលារៀនប្រវែង៦១០ម. ផ្លូវបេតុងប្រវែង៧៥០ម. តារាងបាល់បោះ១៥កន្លែង និងតារាងបាល់ទាត់៨កន្លែង។

គិតមកត្រឹមថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២២ សំណង់អគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង**សម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** មាន៤ ៤៨៧ខ្នង ស្មើ២៨ ៨១០បន្ទប់។

ក្រសួងអប់រំ យុវជន និងកីឡាមានបុគ្គលិកអប់រំគ្រប់កម្រិតទូទាំងប្រទេស១១៦ ៦០៣នាក់(ស្រី៥៤ ២៨៥នាក់ស្មើនឹង៤៦,៥៥%) ក្នុងនោះថ្នាក់ជាតិ៥ ០៧២នាក់(ស្រី១ ៧៦១នាក់ ស្មើនឹង៣៤,៧២%) និងថ្នាក់ក្រោមជាតិ១១១ ៥៣១នាក់(ស្រី៥២ ៥២៤នាក់ ស្មើនឹង៤៧,០៩%)។ គ្រូមត្តេយ្យសិក្សា៣ ៦២៨នាក់(ស្រី៣ ៥៣៣នាក់ស្មើនឹង៩៧,៣៨%) គ្រូបឋមសិក្សា៤៦ ៧៦១នាក់(ស្រី២៥ ៣៥២នាក់ ស្មើនឹង៥៤,២១%) គ្រូបង្រៀនកម្រិតមូលដ្ឋាន៤២ ៥៥៦នាក់(ស្រី១៨ ២៣៩នាក់) (គ្រូបង្រៀនកម្រិតមូលដ្ឋានអប់រំកាយនិងកីឡា២ ៥២៤នាក់ស្រី៥៣០នាក់) គ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅវិទ្យាល័យ)១៤ ០០០នាក់(ស្រី៥ ០៤១នាក់ ស្មើនឹង៣៦%) គ្រូបង្រៀនកម្រិតឧត្តមបម្រើការងារនៅគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ១ ៦៥១នាក់(ស្រី ៣៩៩នាក់ ស្មើនឹង២៤,១៦%) អធិការបឋម៤០នាក់(ស្រី៦នាក់ ស្មើនឹង១៥%) អធិការមធ្យម២៧៩នាក់(ស្រី៤៣នាក់ ស្មើនឹង១៥,៤១%)។

ក្នុងរយៈពេល៥ឆ្នាំកន្លងមក ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តសកម្មភាព យុទ្ធសាស្ត្រ និងគោលនយោបាយ ជាពិសេសអាទិភាពកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ដែលមានអន្តរាគមន៍សំខាន់ៗដូចជាការធ្វើយុទ្ធនាការប្រមូលកុមារដល់វ័យសិក្សា ការសាងសង់អគារសិក្សា ការផ្ដល់គ្រូបង្រៀន ការផ្ដល់សៀវភៅសិក្សាគោល និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រការរៀននិងបង្រៀន ការផ្ដល់ថវិកាដំណើរការសាលារៀន ការផ្ដល់អាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្រ ដែលបានបង្កលក្ខណៈឱ្យសិស្សានុសិស្សនិងនិស្សិតមានលទ្ធភាពកាន់តែច្រើនក្នុងការទទួលបានការអប់រំនៅគ្រប់កម្រិត។ សមិទ្ធផលអប់រំសម្រេចបាន មកដល់ឆ្នាំសិក្សា២០២១-២០២២ សិស្សសរុប៣ ៣៩០ ០៩០នាក់ ស្រី១ ៧០៨ ០៦៧នាក់ ត្រូវជា៥០,៣៨% ក្នុងនោះសិស្សមត្តេយ្យសិក្សាសហគមន៍៧១ ៣៩៩នាក់ ស្រី៣៦ ៩៤៧នាក់ ត្រូវជា៥១,៧៤% សិស្សសាលារៀនសាធារណៈ៣ ៣១៨ ៦៩១នាក់ ស្រី១ ៦៧១ ១២០នាក់ ត្រូវជា៥០,៣៥% និងសិស្សសាលារៀនឯកជន២៣៨ ២៧១នាក់ ស្រី១១៦ ៩៧៩នាក់ ត្រូវជា៤៩,០៩%។

កុមារបានទទួលសេវាអប់រំកុមារតូចសរុប៣៣០ ៨០១នាក់ ស្រី១៦៤ ៥៤០នាក់ ស្មើនឹង៤៩,៧៣%។ កុមារអាយុ៥ឆ្នាំ បានទទួលសេវាអប់រំតាមគ្រប់រូបភាពមាន ១៩៨ ៩១៧នាក់ ស្មើ៥៩,៥៨% នៃចំនួនប្រជាជនអាយុ៥ឆ្នាំ ស្រី៥៩,២៧%នាក់ និងប្រុស៥៩,៨៨%។

សិស្សបឋមសិក្សាសរុប២ ១៦៧ ១៥២នាក់ (ស្រី១ ០៦៣ ០៥៩នាក់)។ ការចូលរៀននៅបឋមសិក្សារយៈពេល៥ឆ្នាំកន្លងមក សម្រេចបានអត្រាពិតនៃការសិក្សាក្នុងរង្វង់៩៨% ហើយថយចុះមក៩៣% នៅឆ្នាំសិក្សា២០២១-២០២២ និងអត្រាបញ្ចប់ការសិក្សា៩១,៧%។

សិស្សមធ្យមសិក្សាបឋមភូមិសរុប៧០៣ ០០៥នាក់ ស្រី៣៦៩ ៣៥១នាក់(៥២,៥៤%) និងសិស្សមធ្យមសិក្សាទុតិយភូមិសរុប ៣៨៥ ៧៨៨នាក់ ស្រី២០៩ ៥០៨នាក់(៥៤,៣%)។ ឆ្នាំ២០២១ ចំនួនបេក្ខជនប្រឡងជាប់

សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមាន៧២ ០៦៤នាក់(៦៥,៦៦%) ស្រី៤១ ៧៥៨ នាក់(៧១,២៧%)។ សិស្សជាប់និទ្ទេសA មាន១ ៧៥៣នាក់ ស្រី១ ០៥០នាក់(៥៩,៨៧%) បានទទួលរង្វាន់លើកទឹកចិត្តពី**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ សិស្សបច្ចេកទេស ៣ ២៩៤នាក់ ស្រី១ ១៤៩នាក់។

គ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសមាន១៣០ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ៤៨ និងឯកជន ៨២ ដែលមានទីតាំងស្ថិតនៅ២០ខេត្ត និងរាជធានី។ គ្រឹះស្ថានឧត្តមសិក្សាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងស្ថាប័ន១៦។ និស្សិតកំពុងសិក្សានៅឧត្តមសិក្សាទាំងអស់ មាន១៩៨ ៣៦៣នាក់ ស្រី៩៨ ៥៣៥នាក់(៤៩,៦៧%)។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររង១៨ ៦៧៤នាក់ ស្រី៩ ៥៤៣នាក់(៥១,១%) ក្នុងនោះ និស្សិតអាហារូបករណ៍ ២ ០២៥នាក់ ស្រី៩៤៩នាក់(៤៦,៨៦%)។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ១៧០ ២៤៦នាក់ ស្រី៨ ១៥៨នាក់(៥០,៦%) ក្នុងនោះ និស្សិតអាហារូបករណ៍២៦ ០៤៣នាក់ ស្រី១៣ ៦២៥នាក់(៥២,៣១%)។ និស្សិតកំពុងសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ៩ ៤៤៣នាក់ ស្រី២ ៨៣៤នាក់(៣០,០១%) ក្នុងនោះ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ៨ ៤៦៥នាក់ ស្រី២ ៧១៨នាក់(៣២,១១%) និងថ្នាក់បណ្ឌិត៩៧៨នាក់ ស្រី១១៦នាក់(១១,៨៦%)។

ក្នុងការលើកកម្ពស់គុណភាពអប់រំ ក្រសួងអប់រំ យុវជន និងកីឡាបានជំរុញការបណ្តុះបណ្តាលសមត្ថភាពគ្រូឧទ្ទេស គ្រូមុខវិជ្ជា អំពីវិធីសាស្ត្រវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស វិធីសាស្ត្របង្រៀននិងបច្ចេកវិទ្យាព័ត៌មានដូចជាការបង្រៀនអំណាននិងគណិតវិទ្យាថ្នាក់ដំបូងនៅបឋមសិក្សា និងវិធីសាស្ត្របង្រៀនតាមបែបរិះរក វិធីសាស្ត្របង្រៀនផ្តោតលើបញ្ញត្តិនៅកម្រិតមធ្យមសិក្សា រួមមានការផ្តល់ប្រឹក្សាគរុកោសល្យ ដើម្បីពង្រឹងដល់ការអនុវត្តរបស់គ្រូបង្រៀន។ យុទ្ធសាស្ត្រសហគមន៍សាលារៀនបានគាំទ្រដល់កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ជួយឱ្យគ្រូបង្រៀនមានចំណេះដឹងទាំងមុខវិជ្ជាឯកទេសនិងចិត្តសង្គម ធ្វើឱ្យថ្នាក់រៀនមានការប្រែប្រួល ពិសេសគឺជួយឱ្យសិស្សម្នាក់ៗមានចំណេះដឹងសមស្របតាមកម្រិតថ្នាក់របស់ខ្លួន។ ជាមួយគ្នានេះ កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន បានធ្វើឱ្យសាលារៀនកាន់តែមានភាពប្រសើរឡើងក្នុងការទទួលបានគុណភាពសិស្សទាំងចំណេះដឹង បំណិន ចរិយា និងក្លាយជាកូនល្អ សិស្សល្អ និងពលរដ្ឋល្អក្នុងសហគមន៍។ ក្រសួងកំពុងជំរុញការស្រាវជ្រាវ ដើម្បីផ្សារភ្ជាប់គ្រឹះស្ថានឧត្តមសិក្សាទៅនឹងឧស្សាហកម្ម ការបង្កើតមូលនិធិស្រាវជ្រាវនិងនវានុវត្តន៍ និងការរៀបចំវេទិកាស្រាវជ្រាវប្រចាំឆ្នាំ ជាពិសេសកំពុងរៀបចំគោលការណ៍ដើម្បីបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សា។ ក្រសួងបានធ្វើបច្ចុប្បន្នកម្មគណៈកម្មការកែសម្រួលឡើងវិញក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងបានពិភាក្សាកែសម្រួលក្របខ័ណ្ឌវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា ដោយផ្តោតលើការវាយតម្លៃស្ថាប័ន និងការវាយតម្លៃកម្មវិធី។ ការផ្តល់សៀវភៅសិក្សាគោល សិស្សបឋមសិក្សានិងសិស្សមធ្យមសិក្សាបឋមភូមិទទួលបាន ១០០%(សិស្ស១នាក់ទទួលបានសៀវភៅសិក្សាគោលមួយក្បាលគ្រប់មុខវិជ្ជា) និងសិស្សមធ្យមសិក្សាទុតិយភូមិទទួលបាន១០០%(សិស្ស២នាក់ទទួលបានសៀវភៅសិក្សាគោលមួយក្បាលគ្រប់មុខវិជ្ជា)។

### ១.១.១- ការអប់រំចំណេះទូទៅនិងឧត្តមសិក្សា

| ឆ្នាំសិក្សា | ២០១៧-២០១៨ | ២០១៨-២០១៩ | ២០១៩-២០២០ | ២០២០-២០២១ | ២០២១-២០២២ |
|---|---|---|---|---|---|
| មត្តេយ្យសិក្សា | | | | | |
| សាលារៀន/កន្លែងសរុប | ៧ ៥៨៧ | ៧ ៧៨០ | ៨ ០៦៧ | ៨ ០១២ | ៨ ៣៣៤ |
| **សិស្សសរុប** | ៤៣១ ៥១០ | ៤២៥ ៤០៣ | ៣៦៣ ៦៨១ | ៣៣៨ ៣០៧ | ៣៣០ ៨០១ |

| | | | | | |
|---|---|---|---|---|---|
| **មត្តេយ្យសិក្សា (រដ្ឋ)** | | | | | |
| សាលារៀន/កន្លែង | ៤ ១៧៦ | ៤ ៣០១ | ៤ ៤០៩ | ៤ ៤៩៣ | ៤ ៥៦៣ |
| សិស្ស(នាក់) | ២០៥ ៤៩២ | ២១៧ ៥០៩ | ២៣៣ ១៣២ | ២២៦ ៩៧៩ | ២១៧ ៧៨៧ |
| គ្រូបង្រៀន(នាក់) | ៥ ៣៩៨ | ៥ ៥៥៩ | ៥ ៦៧៨ | ៥ ៧១៧ | ៥ ៩៣៤ |
| **មត្តេយ្យសិក្សា(ឯកជន)** | | | | | |
| សាលារៀន/កន្លែង | ៤៥៦ | ៥០៩ | ៥៩៤ | ៥១៩ | ៦៨៨ |
| សិស្ស(នាក់) | ៤៧ ២៥១ | ៤៨ ៣១៨ | ៥៦ ០០៤ | ៣២ ៤៤៥ | ៤១ ៦១៥ |
| **មត្តេយ្យសិក្សា (សហគមន៍)** | | | | | |
| សាលារៀន/កន្លែង | ២ ៩៥៥ | ២ ៩៧០ | ៣ ០៦៤ | ៣ ០០០ | ៣ ០៨៣ |
| សិស្ស(នាក់) | ៦៥ ៤២២ | ៦៧ ១០៤ | ៧២ ៤១៤ | ៦៧ ៩៣១ | ៧១ ៣៩៩ |
| **បឋមសិក្សា** | | | | | |
| **សាលារៀន(សរុប)** | **៧ ៦២១** | **៧ ៧១៦** | **៧ ៨៥៦** | **៧ ៨៤៣** | **៧ ៩៦១** |
| សាលារៀន(រដ្ឋ) | ៧ ១៨៩ | ៧ ២២៨ | ៧ ២៨២ | ៧ ៣០៤ | ៧ ៣០៦ |
| សាលារៀន(ឯកជន) | ៤៣២ | ៤៨៨ | ៥៧៤ | ៥៣៩ | ៦៥៥ |
| **សិស្ស(សរុប)** | **២ ១៤០ ៤៩២** | **២ ១៦៣ ១៤៣** | **២ ១៦១ ១១០** | **២ ១២៨ ៧២២** | **២ ១៦៧ ១៥២** |
| សិស្ស(រដ្ឋ) | ២ ០២៨ ៦៩៤ | ២ ០៤០ ២៥៧ | ២ ០២៣ ៤៧៣ | ២ ០១០ ២៨៦ | ២ ០៣៦ ៥៦៦ |
| សិស្ស(ឯកជន) | ១១១ ៧៩៨ | ១២២ ៨៨៦ | ១៣៧ ៦៣៧ | ១១៨ ៤៣៦ | ១៣០ ៥៨៦ |
| គ្រូបង្រៀន(រដ្ឋ) | ៥៧ ៩១៥ | ៥៧ ៨១១ | ៥៧ ៣៤៧ | ៥៧ ៣០៤ | ៥៨ ០៤០ |
| **មធ្យមសិក្សាបឋមភូមិ** | | | | | |
| **អនុវិទ្យាល័យ(សរុប)** | **១ ៣០៣** | **១ ៣២៤** | **១ ៣៣៤** | **១ ៣០៨** | **១ ៣៦៥** |
| អនុវិទ្យាល័យ(រដ្ឋ) | ១ ២៣៧ | ១ ២៤៦ | ១ ២៤៧ | ១ ២៤៦ | ១ ២៥៣ |
| អនុវិទ្យាល័យ(ឯកជន) | ៦៦ | ៧៨ | ៨៧ | ៦២ | ១១២ |
| **សិស្ស(សរុប)** | **៦៣១ ១០១** | **៦៣៨ ៧១២** | **៦៥៥ ០៥៥** | **៦៦៨ ៦៣៧** | **៧០៣ ០០៥** |
| សិស្ស(រដ្ឋ) | ៦០៥ ១៧៣ | ៦១០ ២៦១ | ៦១៨ ៩៦៨ | ៦៣២ ៣០៣ | ៦៦២ ១០៦ |
| សិស្ស(ឯកជន) | ២៥ ៩២៨ | ២៨ ៤៥១ | ៣៦ ០៨៧ | ៣៦ ៣៣៤ | ៤០ ៨៩៩ |
| គ្រូបង្រៀន(រដ្ឋ) | ៣៣ ១៨១ | ៣៣ ៦៣៨ | ៣២ ៦២០ | ៣៣ ២៧៤ | ៣៣ ៣៨៦ |
| លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | | | | | |
| បេក្ខជនមកប្រឡង | ១៥០ ០៩៩ | ១៥៤ ៦៧៩ | ១៦៤ ៧៥៩ | ១៤៥ ៦៦៨ | ១៧៤ ៧២៦ |
| បេក្ខជនប្រឡងជាប់ | ១៤១ ៤១០ | ១៤៤ ៣៦៥ | ១៦៤ ៧៥៩ | ១៤១ ០៥៦ | ១៥៣ ៦៤៩ |
| **មធ្យមសិក្សាទុតិយភូមិ** | | | | | |
| **វិទ្យាល័យ(សរុប)** | **៦៣៣** | **៦៧២** | **៧១៥** | **៧៤១** | **៧៧០** |
| វិទ្យាល័យ(រដ្ឋ) | ៥១១ | ៥២៥ | ៥៤៤ | ៥៥៤ | ៥៥៩ |
| វិទ្យាល័យ(ឯកជន) | ១២២ | ១៤៧ | ១៧១ | ១៨៧ | ២១១ |

| | | | | | |
|---|---|---|---|---|---|
| **សិស្ស (សរុប)** | **៣២២ ០០០** | **៣៣៩ ៨៤៧** | **៣៥៨ ៥៥៣** | **៣៧៦ ៦៩២** | **៣៨៥ ៧៨៨** |
| សិស្ស(រដ្ឋ) | ៣០៣ ៨៩៣ | ៣២១ ១៤៥ | ៣៣៤ ៧១២ | ៣៥១ ៧៩៤ | ៣៦០ ៦១៧ |
| សិស្ស(ឯកជន) | ១៨ ១០៧ | ១៨ ៧០២ | ២៣ ៨៤១ | ២៤ ៨៩៨ | ២៥ ១៧១ |
| គ្រូបង្រៀន(រដ្ឋ) | ១៥ ១៧៦ | ១៥ ៧៦១ | ១៧ ៤៤២ | ១៧ ៨៧៩ | ១៨ ១៨៩ |
| លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | | | | | |
| បេក្ខជនមកប្រឡង | ១១៣ ៣៦៥ | ១១៥ ២០៦ | ១២១ ០៧៤ | ១០៩ ៦៩៥ | ១២៨ ១៣៤ |
| បេក្ខជនប្រឡងជាប់ | ៧៦ ០៣៤ | ៧៩ ០៥២ | ១២១ ០៧៤ | ៧២ ០៦៤ | ៩០ ៩៥០ |
| និទ្ទេស A | ៤០៨ | ៤៤៣ | មិនកំណត់ | ១ ៧៥៧ | ១ ០៥៩ |
| **ឧត្តមសិក្សា** | | | | | |
| **គ្រឹះស្ថានឧ.សរុប** | **១២១** | **១២៥** | **១២៤** | **១២៨** | **១៣០** |
| គ្រឹះស្ថានឧ.រដ្ឋ | ៤៨ | ៤៨ | ៤៨ | ៤៨ | ៤៨ |
| គ្រឹះស្ថានឧ.ឯកជន | ៧៣ | ៧៧ | ៧៦ | ៨០ | ៨២ |
| **និស្សិតសរុប** | **២០៧ ៤២៣** | **២១១ ៤៨៤** | **២២២ ៨៧៩** | **២០១ ៩០០** | **១៩៨ ៣៦៣** |
| បរិញ្ញាបត្ររង | ២០ ៥៧០ | ១៩ ៨៧១ | ១៩ ៥៧៥ | ១៩ ៧៨២ | ១៨ ៦៧៤ |
| បរិញ្ញាបត្រ | ១៦៥ ៣៥៩ | ១៦៨ ២៤២ | ១៧៩ ២៥៨ | ១៧១ ១៨៣ | ១៧០ ២៤៦ |
| បរិញ្ញាបត្រជាន់ខ្ពស់ | ២០ ២៧២ | ២២ ០២២ | ២៣ ២៥៦ | ៩ ៩៨៤ | ៨ ៤៦៥ |
| បណ្ឌិត | ១២២ | ១ ៣៤៩ | ៧៩០ | ៩៦១ | ៩៧៨ |

### ១.១.២- គ្រឹះស្ថានសិក្សាឯកជនភាសាខ្មែរនិងបរទេស

| ប្រភេទសាលា-ភាសា/ឆ្នាំសិក្សា | ២០១៧-២០១៨ | ២០១៨-២០១៩ | ២០១៩-២០២០ | ២០២០-២០២១ | ២០២១-២០២២ |
|---|---|---|---|---|---|
| សាលារៀនសរុប | ១ ០៧៦ | ១ ២២២ | ១ ៤២៦ | ១ ៣០៧ | ១ ៦៦៦ |
| **សាលាមត្តេយ្យសិក្សា** | **៤៥៦** | **៥០៩** | **៥៩៤** | **៥១៩** | **៦៨៨** |
| ខ្មែរ | ៣៣៧ | ៣៧៣ | ៤០៦ | ៤០១ | ៥២៨ |
| ចិន | ២១ | ១៩ | ៩៨ | ២១ | ៤ |
| ម៉ូស្លីម | ៤ | ៥ | ៤ | ៣ | ២១ |
| អង់គ្លេស | ៩៣ | ១១០ | ៨៥ | ៨៩ | ១២៨ |
| **សាលាបឋមសិក្សា** | **៤៣២** | **៤៨៨** | **៥៧៤** | **៥៣៩** | **៦៥៥** |
| ខ្មែរ | ៣៥៣ | ៤០៦ | ៤១៦ | ៤៤៤ | ៥៣៤ |
| ចិន | ២២ | ២៦ | ៩៥ | ២៣ | ២៧ |
| ម៉ូស្លីម | ១៣ | ១៧ | ២៨ | ២៤ | ២១ |
| អង់គ្លេស | ៤៣ | ៣៧ | ៣៤ | ៤៣ | ៦៧ |
| **អនុវិទ្យាល័យ** | **៦៦** | **៧៨** | **៨៧** | **៦២** | **១១២** |
| ខ្មែរ | ៥៤ | ៦២ | ៥៤ | ៥២ | ១១២ |
| ចិន | ៩ | ១០ | ២៨ | ៧ | ០ |
| ម៉ូស្លីម | ០ | ១ | ២ | ១ | ០ |
| អង់គ្លេស | ៣ | ៥ | ៣ | ២ | ០ |

| វិទ្យាល័យ | ១២២ | ១៤៧ | ១៧១ | ១៨៧ | ២១១ |
|---|---|---|---|---|---|
| ខ្មែរ | ១០៦ | ១៣៤ | ១៤៨ | ១៦៨ | ២១១ |
| ចិន | 0 | 0 | 13 | 0 | 0 |
| ម៉ូស្លីម | ២ | ៥ | ៤ | ៥ | 0 |
| អង់គ្លេស | ១៣ | ៨ | ៦ | ១៣ | 0 |

### ១.១.៣- **ការអប់រំឌីជីថល**

ឆ្លើយតបនឹងការដាក់ចេញនូវគោលនយោបាយជំរុញសេដ្ឋកិច្ចឌីជីថលរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជននិងកីឡា គិតចាប់ពីឆ្នាំ២០១៩ បានផលិតវីដេអូបម្រើឱ្យការបង្រៀននិងរៀនពីចម្ងាយ ផលិតសន្លឹកកិច្ចការសម្រាប់សិស្សស្វ័យសិក្សា និងវាយតម្លៃការសិក្សា រៀបចំព្រឹត្តិការណ៍ជាបន្តបន្ទាប់ផ្តោតលើការជំរុញការអប់រំតាមបែបឌីជីថលដូចជាការរៀបចំពិព័រណ៌ស្នែមប្រចាំឆ្នាំ ការរៀបចំសន្និសីទស្តីពីយុវជននិងបច្ចេកវិទ្យា ការដាក់ដំណើរការសាលារៀនជំនាន់ថ្មី ការប្រកួតប្រជែងស្នាដៃស្រាវជ្រាវ ការសរសេរកូដនិងការរៀបចំមជ្ឈមណ្ឌលអប់រំឌីជីថលនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាជាដើម។ ក្រសួងបានដាក់ចេញនូវវិធានការជា៣ដំណាក់កាលចំពោះការរៀបចំប្រព័ន្ធអប់រំអេឡិចត្រូនិកនិងការផ្តល់សេវារៀនពីចម្ងាយ។ ដំណាក់កាលបន្ទាន់ គឺផលិតវីដេអូបង្រៀនសម្រាប់មុខវិជ្ជាគោលនិងសម្រាប់ថ្នាក់ប្រឡង ព្រមទាំងបង្ហោះនិងផ្សព្វផ្សាយលើវេទិកាឌីជីថលដែលមានស្រាប់ ដំណាក់កាលមធ្យម គឺការលម្អវេទិកាឌីជីថលដែលមានស្រាប់ឱ្យកាន់តែប្រសើរ និងការផលិតវីដេអូបង្រៀនចាំបាច់បន្ថែមទៀត និងដំណាក់កាលវែង គឺការរៀបចំកែលម្អនិងអភិវឌ្ឍវេទិកាឌីជីថលសម្រាប់ការផ្តល់សេវាអប់រំតាមប្រព័ន្ធអេឡិចត្រូនិកដែលមានលក្ខណៈសមស្របនិងគ្រប់ជ្រុងជ្រោយ។ ជារួម លទ្ធផលសំខាន់ៗនៃការអប់រំឌីជីថលសម្រេចបានកន្លងមកជាពិសេសក្នុងបរិបទវិបត្តិកូវីដ-១៩ មានដូចខាងក្រោម៖

- ក្រសួងបានលើកកម្ពស់ការបង្រៀន និងរៀនពីចម្ងាយឬតាមប្រព័ន្ធអេឡិចត្រូនិកដល់គ្រឹះស្ថានសិក្សាចំណោះទូទៅ ដោយបានចេញសេចក្តីណែនាំ និងជំរុញការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ មាតាបិតា អ្នកអាណាព្យាបាល និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីអនុវត្តនិងធានាបាននូវគុណភាពនិងប្រសិទ្ធភាពក្នុងការបង្រៀននិងរៀន និងការវាយតម្លៃ

- ក្រសួងបានដាក់ចេញនូវវិធានការចាំបាច់នានាឆ្លើយតបនឹង«គន្លងជីវិតថ្មីក្នុងវិស័យអប់រំ» ដើម្បីធានាឱ្យការសិក្សារបស់សិស្សបានពេញលេញ តាមរយៈមធ្យោបាយអនុវត្តការអប់រំពីចម្ងាយមាន ដូចជាទូរទស្សន៍ ទូរសព្ទ កុំព្យូទ័រ កុំព្យូទ័របន្ទះ សន្លឹកកិច្ចការ សៀវភៅសិក្សាគោល ឯកសារផ្សេងៗ និងកម្មវិធី Zoom, Telegram, Messenger, Facebook, Google Meet, Google Classroom, E-Learning App, ប៉ុស្តិ៍ទូរទស្សន៍...។ ជាមួយនេះ សកម្មភាពបង្រៀន និងរៀន រួមមានផលិតនិងចែករំលែកវីដេអូមេរៀន សន្លឹកកិច្ចការផ្សេងៗ វាយតម្លៃកិច្ចការសិស្ស និងផ្តល់ព័ត៌មានត្រឡប់ បង្រៀននិងរៀនតាមអនឡាញ ការសិក្សាជាបណ្តុំ ស្វ័យសិក្សាជាមួយកម្មវិធី ឯកសារ សៀវភៅសិក្សាគោល។ល។

ក្រសួងបានបង្កើតវេទិកាឌីជីថលចំនួន៣ ដើម្បីដំណើរការអប់រំអេឡិចត្រូនិក៖

- ✓ បណ្តាញYouTubeផ្លូវការរបស់ក្រសួង៖ www.youtube.com/moeys មានវីដេអូបង្រៀនទាំងអស់សម្រាប់សិស្សអាចសិក្សាដោយខ្លួនឯងតាមពេលវេលាជាក់ស្តែង

- ✓ ទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួង www.facebook.com/moeys.gov.kh ផ្សព្វផ្សាយរៀងរាល់ថ្ងៃ
- ✓ មជ្ឈមណ្ឌលសិក្សាអេឡិចត្រូនិករបស់ក្រសួង www.elearning.moeys.gov.kh សិស្សអាចចូលទៅសិក្សាតាមរយៈការជ្រើសរើសវគ្គសិក្សាឬមេរៀនដែលត្រូវសិក្សាដោយឥតគិតថ្លៃ និងមិនចាំបាច់ចុះឈ្មោះ។

- ក្រសួងបានផលិតវីដេអូបង្រៀនសម្រាប់សិស្សគ្រប់កម្រិត៖

- ជាដំបូង ក្រសួងបានផលិតវីដេអូបង្រៀនសម្រាប់មុខវិជ្ជាគោលចំនួន៦ រួមមានភាសាខ្មែរ គណិត-វិទ្យា ប្រវត្តិវិទ្យា គីមីវិទ្យា រូបវិទ្យានិងជីវវិទ្យាសម្រាប់ថ្នាក់ទី៩និងទី១២។
- *មត្តេយ្យសិក្សា* ផលិតបានខ្សែវីដេអូបង្រៀនសម្រាប់កុមារតូចនៅថ្នាក់មត្តេយ្យសិក្សាចំនួន៥ មុខវិជ្ជារួមមានចិត្តចលភាព វិទ្យាសាស្ត្រ សិក្សាសង្គម បុរេគណិតនិងភាសាខ្មែរ។
- *បឋមសិក្សា* ដាក់ឱ្យអនុវត្តជាផ្លូវការនូវកម្មវិធី "កុមាររៀនកុមារចេះ" រួមមានកញ្ចប់សម្ភារៈអំណាននិងគណិតវិទ្យាកម្រិតថ្នាក់ដំបូងនៅបឋមសិក្សា ដូចជាសៀវភៅណែនាំសម្រាប់គ្រូនិងឯកសារបង្រៀននិងរៀន ព្រមទាំងបានផលិតវីដេអូបង្រៀនមុខវិជ្ជាភាសាខ្មែរនិងគណិតវិទ្យាសម្រាប់ថ្នាក់ទី៤ដល់ទី៦។
- *មធ្យមសិក្សា ៖* ផលិតបានខ្សែវីដេអូបង្រៀនសម្រាប់ថ្នាក់ទី៧ ដល់ ១២ និងសាលារៀនបានផ្តល់លទ្ធភាពឱ្យសិស្សខ្ចីសៀវភៅសិក្សាគោល ដើម្បីស្វ័យសិក្សាបន្ថែមទៀត។
- *ការអប់រំក្រៅប្រព័ន្ធ ៖* ដាក់ឱ្យដំណើរការកម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (BEEP) ដើម្បីពង្រីកការទទួលបានការអប់រំជាមូលដ្ឋានសម្រាប់យុវជននិងចូលរួមដោះស្រាយបញ្ហាបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ ឱ្យទទួលបាននូវចំណេះដឹងមូលដ្ឋាន និងជួយឱ្យយុវជនកម្ពុជាបញ្ចប់ការអប់រំមូលដ្ឋាន តាមរយៈការរៀនដោយខ្លួនឯង ដែលមានភាពបត់បែនទន់ភ្លន់ និងមានឱកាសអាចបន្តការសិក្សានៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស។ ជាមួយនេះ ក្រសួងបានដាក់ឱ្យដំណើរការការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិអប់រំក្រៅប្រព័ន្ធ និង ផលិតបានវីដេអូបង្រៀនចំនួន៣៣៩វីដេអូ ដោយបានបង្កើតប្រព័ន្ធគ្រប់គ្រងការសិក្សា និងដំណើរការសិក្សាតាមប្រព័ន្ធផ្សព្វផ្សាយផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ផលិតបានវីដេអូបង្រៀនចំនួន៨៤វីដេអូ សម្រាប់កម្មវិធីអក្ខរកម្មដល់កម្មករកម្មការនីតាមរោងចក្រ អ្នកសិក្សាតាមសហគមន៍ និងអ្នកសិក្សាក្នុងពន្ធនាគារ ព្រមទាំងកម្មវិធីសមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធ ដើម្បីផ្តល់ឱកាសឆ្ពោះទៅរកជំនាញមុខរបរនិងការសិក្សាបន្ត។ ផលិតបានស្ប៉តវីដេអូជារៀងរាល់ឆ្នាំ ដើម្បីអបអរសាទរពិធីប្រារព្ធទិវាអក្ខរកម្មជាតិ ៨កញ្ញា ក្នុងអត្ថន័យជំរុញប្រជាពលរដ្ឋកម្ពុជាគ្រប់រូបឱ្យទទួលបានឱកាសសិក្សាពេញមួយជីវិត គ្រប់ពេលវេលាគ្រប់ទីកន្លែង និងគ្រប់មធ្យោបាយប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទា។
- *ការអប់រំពិសេស ៖* បានផ្សាយផ្ទាល់ការបង្រៀនកម្មវិធីអប់រំពហុភាសាតាមស្ថានីយវិទ្យុផ្សាយសំឡេងរបស់ខេត្តរតនគីរី និងមណ្ឌលគិរី សម្រាប់កម្រិតមត្តេយ្យសិក្សា និងបឋមសិក្សាថ្នាក់ទី១ ដល់ទី៣ ជាភាសាទំពួន និងគ្រឹងក្នុងខេត្តរតនគីរី និងជាភាសាព្នងក្នុងខេត្តមណ្ឌលគិរី។

- ***ការអប់រំបច្ចេកទេស ៖*** បានណែនាំគ្រូជំនាញបច្ចេកទេសឱ្យរៀបចំមេរៀនសង្ខេបចែកជូនសិស្ស ថត វីដេអូបង្រៀន ការបង្រៀនតាមប្រព័ន្ធអេឡិចត្រូនិក។ គ្រូជំនាញបានបែងចែក ក្រុមសិស្សតាមជំនាញ និងតាមកម្រិតសិក្សា ដោយបានបង្កើតជាបណ្តាញសម្រាប់ទំនាក់ទំនងជាមួយសិស្ស និង ក្លឹបសិក្សាតាមជំនាញ។
- ***គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ៖*** វិទ្យាស្ថានជាតិអប់រំ និងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ បានបង្កើតបណ្តាញទំនាក់ទំនងរវាងគរុសិស្ស គរុនិស្សិតជាមួយនឹងគ្រូឧទ្ទេស។ គ្រូឧទ្ទេសបានផ្តល់ឯកសារមេរៀន ឬតំណភ្ជាប់ឯកសារផ្សេងៗជូនគរុសិស្ស គរុនិស្សិត ដើម្បីសិក្សាតាមពេលម៉ោងក្នុងកាលវិភាគប្រចាំថ្ងៃ។ គរុសិស្ស គរុនិស្សិត និងគ្រូឧទ្ទេសបានជួបពិភាក្សា ឆ្លើយឆ្លងគ្នាអំពីខ្លឹមសារមេរៀនឬកិច្ចការ។
- ***គ្រឹះស្ថានឧត្តមសិក្សា ៖*** គ្រឹះស្ថានឧត្តមសិក្សាមួយចំនួនបានរៀបចំកម្មវិធីសិក្សាតាមប្រព័ន្ធអេឡិច-ត្រូនិក រៀបចំបន្ទប់រៀន ផលិតមេរៀន និងបង្កើតបណ្តាញទំនាក់ទំនងសម្រាប់និស្សិតនិងសាស្ត្រាចារ្យ។ ក្រសួងបាននិងកំពុងជំរុញ និងលើកកម្ពស់ការអប់រំឌីជីថល ជាពិសេស ការផ្តល់ការគាំទ្រ និងការបង្កើនការចូលរៀនរបស់សិស្ស និស្សិតលើផ្នែកបច្ចេកវិទ្យាឌីជីថល និងការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា។ ជាលទ្ធផល នៅកម្រិតបរិញ្ញាបត្រ និស្សិតប្រមាណ ៦៩% សិក្សាផ្នែកវិទ្យាសាស្ត្រសង្គម ក្នុងនោះ៤២% សិក្សាជំនាញទាក់ទងនឹងធុរកិច្ច៦% សិក្សាជំនាញច្បាប់៩% សិក្សាជំនាញភាសាបរទេស៣% សិក្សាជំនាញទេសចរណ៍ និង៩% សិក្សាជំនាញវិទ្យាសាស្ត្រសង្គម និងសិល្បៈផ្សេងៗទៀត។ ចំណែកជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) មាន ៣០,៦៩% (ស្រី ១៧,៧៤% និង ប្រុស ៤៤,៩២%) ក្នុងនោះមានវិទ្យាសាស្ត្រមូលដ្ឋាន៥% បច្ចេកវិទ្យាព័ត៌មាន១០% វិស្វកម្ម៨% កសិកម្ម៣% និងសុខាភិបាល៥%។ ជារួម ក្នុងរយៈពេល៥ឆ្នាំ ការសិក្សាជំនាញSTEM បានកើនពី ២៦,៨៣% នៅឆ្នាំសិក្សា២០១៦-២០១៧ ដល់៣០,៦៩% នៅឆ្នាំសិក្សា២០២០-២០២១។

-ក្រៅពីនេះ ក្រសួងអប់រំ យុវជន និងកីឡានិងក្រសួងព័ត៌មានបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ស្តីពីការរៀបចំផលិតនិងផ្សព្វផ្សាយកម្មវិធីការសិក្សាពីចម្ងាយ និងការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីធានាសេវាអប់រំមានគុណភាពប្រកបដោយសមធម៌ ជាពិសេសសិស្សនៅតំបន់ជនបទ។ មេរៀនគ្រប់មុខវិជ្ជា និងគ្រប់ថ្នាក់ត្រូវបានផ្សាយកម្មវិធីតាមប្រព័ន្ធទូរទស្សន៍ផ្កាយរណប«តេជោជីវី» ដែលជាប៉ុស្តិ៍ទូរទស្សន៍អប់រំថ្មី «ទទក២»។

-ក្រសួងបានសហការជាមួយដៃគូឯកជននានា ដើម្បីធ្វើឱ្យកម្មវិធីអប់រំអេឡិចត្រូនិកកាន់តែមានភាពសម្បូរបែប។

### ១.១.៤- លទ្ធផលគន្លឹះនៃការអនុវត្តយុទ្ធសាស្ត្រកែទម្រង់វិស័យអប់រំ យុវជន និងកីឡា

ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃការកែទម្រង់តាមគ្រប់កម្រិត ក្រសួងបានដាក់ចេញ និងអនុវត្តកម្មវិធីកំណែទម្រង់ចំនួន៣កម្រិត (១) ការអនុវត្តកំណែទម្រង់គោលនយោបាយអប់រំកម្រិតជាតិ ក្នុងក្របខ័ណ្ឌសសរស្តម្ភទាំង៥ (២) ការអនុវត្តកំណែទម្រង់គ្រូបង្រៀននៅតាមសាលាគរុកោសល្យ និង(៣) ការអនុវត្តកំណែទម្រង់សាលារៀន។ លទ្ធផលសំខាន់ៗនៃការអនុវត្តកំណែទម្រង់ទាំងនេះ មានដូចខាងក្រោម៖

**ថ្នាក់ជាតិ**

- បានរៀបចំនិងអនុវត្តផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជាឆ្នាំ២០២២ ២០៣០ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃការអប់រំ

- បានរៀបចំនិងអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩ ២០២៣

- បានរៀបចំក្របខ័ណ្ឌគោលនយោបាយផ្តោតលើលទ្ធផល និងកម្មវិធីវិនិយោគសាធារណៈក្នុងវិស័យអប់រំ ឆ្នាំ២០២២-២០៣០

- បានសម្រេចគោលនយោបាយជាតិស្តីពី ការសិក្សាពេញមួយជីវិត

- បានសម្រេចគោលនយោបាយជាតិស្តីពី សុខភាពសិក្សា

- បានរៀបចំ និងអនុវត្តផែនទីបង្ហាញផ្លូវ ការអប់រំមធ្យមសិក្សាកម្ពុជា ឆ្នាំ២០៣០

- បាននិងកំពុងកែលម្អ និងអភិវឌ្ឍថ្មីសៀវភៅសិក្សាគោលកម្រិតបឋមសិក្សា និងមធ្យមសិក្សា ឱ្យឆ្លើយតបទៅនឹងក្របខ័ណ្ឌកម្មវិធីសិក្សាថ្មី

- បាននិងកំពុងអនុវត្តកម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស(PISA)

- បាននិងកំពុងរៀបចំផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២២-២០៣០

- បានដាក់ឱ្យអនុវត្តគោលការណ៍ស្តីពីកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ។

**ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀននិងការកែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ**

- បាននិងកំពុងកែសម្រួលកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀននៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ

- បានដាក់បញ្ចូលកម្មវិធីអំណានដំបូងនិងគណិតវិទ្យា ទៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋមសិក្សា

- បានសម្រេចក្របខ័ណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម បរិញ្ញាបត្រ+២

- បានសម្រេចលើសៀវភៅណែនាំស្តីពីការបង្កើតសហគមន៍សិក្សាវិជ្ជាជីវៈ នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ

- លើកកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេសវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបងទទួលបានបរិញ្ញាបត្រជាន់ខ្ពស់នៅប្រទេសជប៉ុន

- លើកកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេស មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាមធ្យមសិក្សាគរុកោសល្យទទួលបានបរិញ្ញាបត្រជាន់ខ្ពស់អប់រំនៅប្រទេសអូស្ត្រាលី

- បានរៀបចំនិងអនុវត្តសាកល្បងប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដោយផ្សារភ្ជាប់នឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស

- ដាក់ឱ្យប្រើប្រាស់ជាផ្លូវការការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង

- បំពាក់សម្ភារៈបច្ចេកវិទ្យាព័ត៌មានសម្រាប់ការរៀននិងបង្រៀន នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនិងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម

- ផ្តល់កុំព្យូទ័របន្ទះ ស៊ីមកាត និងផ្តល់ទិន្នន័យ សម្រាប់គាំទ្រការរៀននិងបង្រៀនតាមសាលាគរុកោសល្យនិងវិក្រឹតការខេត្ត។

**ការកែទម្រង់កម្រិតសាលារៀន**

ក្រសួងបាននិងកំពុងអនុវត្តកំណែទម្រង់វិស័យអប់រំកម្រិតសាលារៀន បានផ្តោតខ្លាំងលើការធានានូវការអប់រំប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា តាមរយៈកម្មវិធីកំណែទម្រង់សាលារៀន សាលារៀនជំនាន់ថ្មី សាលារៀនប្រកបដោយប្រសិទ្ធភាព និងកម្មវិធីសាលាមធ្យមសិក្សាធនធាន។

- បានអនុវត្តកម្មវិធីសាលាជំនាន់ថ្មីចំនួន១១(បឋមសិក្សា៤និងមធ្យមសិក្សា៧) បង្កើតការគ្រប់គ្រងតាមបែបចម្រុះដោយមានការចូលរួមពីដៃគូពាក់ព័ន្ធនិងគណៈគ្រប់គ្រងសាលារៀន។ អនុវត្តកម្មវិធីសិក្សាតាមបែបទន់ភ្លន់ ដើម្បីបង្រៀនសិស្សឱ្យមានចំណេះដឹងជំនាញបច្ចេកទេស បំណិនជីវិត ជំនាញទន់ និងមានអាកប្បកិរិយាល្អ។ រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូដោយបំប៉នសមត្ថភាពលើវិធីសាស្ត្របង្រៀនតាមបែបរិះរក និងប្រើប្រាស់បច្ចេក-វិទ្យាព័ត៌មានក្នុងការបង្រៀនសិស្ស។ រៀបចំឱ្យមានបន្ទប់ពិសោធន៍តាមមុខវិជ្ជា បន្ទប់កុំព្យូទ័រនិងបំពាក់កុំព្យូទ័របន្ទប់មុខវិជ្ជា បន្ទប់គ្រូបង្រៀន និងបណ្ណាល័យសតវត្សទី២១។ សាលារៀនជំនាន់ថ្មីបានអនុវត្តកម្មវិធីសិក្សាតាមបែបសិស្សចល័តទៅតាមបន្ទប់មុខវិជ្ជា និងពង្រឹងការបង្រៀននិងរៀន ការអប់រំបំណិនជីវិត ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ប្រឹក្សាអាជីព ក្រុមប្រឹក្សាយុវជន បន្ទប់សង្គ្រោះបឋម និងក្លឹបសិក្សាលើមុខវិជ្ជាគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា សារព័ត៌មាន បច្ចេកវិទ្យាព័ត៌មាន និងប្រវត្តិវិទ្យា

- បានអនុវត្តកម្មវិធីសាលារៀនប្រកបដោយប្រសិទ្ធភាពចំនួន១០០ ដោយផ្តោតលើ (ក) សាលារៀនមានគណនេយ្យភាពជាមួយសហគមន៍និងសម្រេចបានស្តង់ដាសាលារៀនមានប្រសិទ្ធភាព (ខ) សាលារៀនមានស្វ័យភាព ក្នុងការងារផែនការកែលម្អសាលារៀន និងផ្តល់ការអភិវឌ្ឍជាប្រចាំដល់គណៈគ្រប់គ្រងនិងគ្រូបង្រៀន (គ)សិស្សត្រូវបានធ្វើតេស្តស្តង់ដាប្រកបដោយតម្លាភាពនិងយុត្តិធម៌ ដើម្បីបម្រើដល់ការកែលម្អការបង្រៀននិងរៀន ការជួយសិស្សរៀនយឺត និងផ្តល់ព័ត៌មានដល់មាតាបិតានិងសហគមន៍ (ឃ)គ្រូបង្រៀនប្រើប្រាស់លទ្ធផលតេស្តដើម្បីកែលម្អការបង្រៀន និងទទួលបានការអភិវឌ្ឍគុណវុឌ្ឍិជាប្រចាំ (ង)មាតាបិតានិងសហគមន៍ចូលរួមគាំទ្រនិងអភិវឌ្ឍសាលារៀន

- បានអនុវត្តកម្មវិធីសាលាមធ្យមសិក្សាធនធានចំនួន៥០ ដោយផ្តោតលើអន្តរាគមន៍គាំទ្រនិងលើកទឹកចិត្តដល់សិស្សជួបការលំបាក កម្មវិធីសិក្សាទំនើប(ជំនាញទន់ បំណិនជីវិត និងអន្តរមុខវិជ្ជា) បុគ្គលិកអប់រំប្រកបដោយគុណភាពនិងវិជ្ជាជីវៈខ្ពស់ និងហេដ្ឋារចនាសម្ព័ន្ធនិងសម្ភារៈបរិក្ខារស្តង់ដា ដែលបម្រើដល់ការអប់រំពេញមួយជីវិត ការដឹកនាំនិងគ្រប់គ្រងប្រកបដោយស្វ័យភាពនិងគណនេយ្យភាពការ ស្រាវជ្រាវផ្តោតលើការជំរុញការសិក្សាមុខវិជ្ជាសង្គមនិងវិទ្យាសាស្ត្រ(វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា) ដើម្បីលើកកម្ពស់គុណភាពនៃការបង្រៀននិងរៀន ការបង្កើតថ្មី ផ្តោតលើការសិក្សាតាមបែបការសរសេរគម្រោង ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហានិងការរៀនផ្អែកលើការអភិវឌ្ឍខួរក្បាល ការកៀរគរធនធានតាមវិធានបើកទូលាយឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធដែលធានាបាននូវលទ្ធផល តម្លាភាព និងគណនេយ្យភាព ការទាក់ទាញសហគមន៍ដោយផ្តល់នូវជំនឿជាក់លើការដឹកនាំនិងគ្រប់គ្រង ដំណើរការបង្រៀននិងរៀន លទ្ធផលសិក្សា និងបង្កើនការគាំទ្រពីសហគមន៍។

### ១.១.៥- ការងារយុវជន អប់រំកាយ និងកីឡា

### ក- សមិទ្ធផលសំខាន់ៗនៃការងារយុវជន

ក្រសួងអប់រំ យុវជន និងកីឡាបាន៖

- អភិវឌ្ឍសមត្ថភាពយុវជនឱ្យក្លាយជាកម្លាំងបន្តវេនដ៏មានសក្តានុពលក្នុងការកសាង និងការពារជាតិមាតុភូមិ តាមរយៈគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជន ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០១១ និងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឆ្នាំ២០២២-២០២៦ ដែលជាផែនទីបង្ហាញផ្លូវ ដើម្បីប្រមូលផ្តុំកម្លាំងចូលរួមរបស់យុវជន និងការយកចិត្តទុកដាក់លើការអភិវឌ្ឍយុវជនកម្ពុជា

- ធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពរបស់យុវជនកម្ពុជា ដោយបានរៀបចំជា«របាយការណ៍ស្តីពីការវិភាគស្ថានភាពយុវជនកម្ពុជា» ដ៏មានសារៈសំខាន់ និងជាមូលដ្ឋានក្នុងការទទួលព័ត៌មានអំពីតម្រូវការរបស់យុវជន និងការតម្រង់ទិសដល់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល វិស័យឯកជន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីចូលរួមផ្តល់ការគាំទ្រដល់យុវជន និងការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឱ្យមានប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ

- ក្រសួងបាននិងកំពុងរៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងយុវជន តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីប្រមូលព័ត៌មាននិងទិន្នន័យស្តីពីស្ថានភាពរបស់យុវជនឱ្យបានជាក់លាក់ ដើម្បីរៀបចំកម្មវិធីគោលនយោបាយ និងអន្តរាគមន៍នានា ទៅតាមតម្រូវការជាក់ស្តែងរបស់យុវជនកម្ពុជាក្នុងពេលបច្ចុប្បន្ននិងពេលអនាគត ដោយប្រើប្រាស់ទិន្នន័យពីប្រព័ន្ធព័ត៌មានគ្រប់គ្រងយុវជនជាមូលដ្ឋាន

- គាំទ្រដល់ក្រុមប្រឹក្សាកុមារកម្ពុជា ក្រុមប្រឹក្សាយុវជនកម្ពុជា និងការពង្រឹងប្រព័ន្ធកងល្បាតកាយរឹទ្ធិនៅតាមគ្រឹះស្ថានសិក្សានិងសហគមន៍ ដោយជំរុញចលនាប្រឡងប្រណាំង៣ល្អ«កូនល្អ សិស្សល្អ មិត្តល្អ» ការបង្កើតក្លឹបសកម្មភាពយុវជន និងក្លឹបសិក្សាសម្រាប់ជួយបំប៉នបន្ថែមដល់សិស្សត្រៀមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដែលជាយន្តការដ៏មានសារៈសំខាន់ក្នុងការបណ្តុះយុវជនឱ្យក្លាយជាពលរដ្ឋល្អ និងយុវជនមានបុគ្គលិកលក្ខណៈពេញលេញនិងមានស្មារតីស្រឡាញ់ជាតិ ការពារមាតុភូមិ និងការអភិវឌ្ឍសង្គម

- អភិវឌ្ឍសមត្ថភាព និងបណ្តុះបណ្តាលយុវជនឱ្យមានជំនាញយ៉ាងតិចចំនួនមួយប្រចាំជីវិតប្រកបដោយគុណភាព ដែលអាចមានសមត្ថភាពឈានចូលទៅក្នុងទីផ្សារការងារ ការបង្កើតមុខរបរ និងអាជីវកម្មតាមរយៈការពង្រឹងនិងការបង្កើតកម្មវិធីសម្រាប់យុវជននៅមជ្ឈមណ្ឌលជាតិយុវជនកម្ពុជា មជ្ឈមណ្ឌលយុវជនរាជធានី ខេត្ត ដោយបានប្រែក្លាយមជ្ឈមណ្ឌលយុវជនចំនួន៥ ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។ លើសពីនេះក្រសួងបានរៀបចំកម្មវិធីជាច្រើន ដើម្បីលើកកម្ពស់បំណិនសហគ្រិនភាពនិងជំនាញទន់ដល់យុវជនកម្ពុជា ដែលជាចលករដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងសហគមន៍

- បណ្តុះបណ្តាលបំណិនសតវត្សរ៍ទី២១ដល់យុវជនដោយផ្តោតលើ (១) កម្មវិធី «បរិស្ថានល្អផ្តើមចេញពីខ្ញុំ» (២) កម្មវិធី «កាយរឹទ្ធិដើម្បីសន្តិភាពនិងការងារសហគមន៍» (៣) កម្មវិធី «ទិវាកាយរឹទ្ធិក្លាហាន» (៤) កម្មវិធីផ្លាស់ប្តូរបទពិសោធលើបំណិនបច្ចេកវិទ្យាព័ត៌មាន និងឌីជីថល ជាមួយអង្គការនិងសមាគមកាយរឹទ្ធិជាតិនានាក្នុងតំបន់និងពិភពលោក (៥) កម្មវិធីសមមូលអប់រំកម្រិតមូលដ្ឋានតាមអ៊ីនធឺណិត (៦) កម្មវិធីអក្ខរកម្មឌីជីថល (៧) កម្មវិធីជជែកដេញដោលយុវជនថ្នាក់ជាតិ២០២២ (៨) កម្មវិធីយុវជន២១(អភិវឌ្ឍសហគ្រិនបែបឌីជីថល) (៩) កម្មវិធីធុរកិច្ចជាតិសម្រាប់យុវជន និង(១០)កម្មវិធីការគ្រប់គ្រងផ្លូវចិត្តយុវជន។ កម្មវិធីទាំងនេះបានជួយលើកកម្ពស់សមត្ថភាពនិងជំនាញរបស់យុវជនឱ្យឆ្លើយតបនឹងការអភិវឌ្ឍសង្គមនិងជំនាញសតវត្សទី២១

- បង្កើតកម្មវិធីយុវជនជាច្រើន ដើម្បីអភិវឌ្ឍយុវជនឱ្យមានបំណិនច្នៃប្រឌិត នវានុវត្តន៍ ការគិតបែបស៊ីជម្រៅ ការដោះស្រាយបញ្ហា ការធ្វើសេចក្តីសម្រេចចិត្ត ការប្រាស្រ័យទាក់ទង សាមគ្គីភាព ការធ្វើការងារជាក្រុម អក្ខរកម្មព័ត៌មានវិទ្យា អក្ខរកម្មបច្ចេកវិទ្យាព័ត៌មាន ភាពជាពលរដ្ឋសកល បំណិនជីវិត និងការងារ និងការទទួលខុសត្រូវផ្ទាល់ខ្លួននិងក្នុងសង្គម រួមមានសមត្ថភាពនិងការយល់ដឹងពីវប្បធម៌ចម្រុះ ដើម្បីឱ្យឆ្លើយតបទៅនឹងបរិបទបដិវត្តន៍ឧស្សាហកម្ម៤.០ និងការប្រែប្រួលឥតឈប់ឈររបស់សង្គម ដែលយុវជនត្រូវមានបំណិនសតវត្សទី២១ ការបណ្តុះបំណិនទន់និងបំណិនបច្ចេកទេសសម្រាប់ការប្រកួតប្រជែងក្នុងទីផ្សារការងារ

- ផ្តល់ឱកាសដល់យុវជនចូលរួមក្នុងការដឹកនាំ ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងការពាររាល់សមិទ្ធផលរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការលើកកម្ពស់ការងារស្ម័គ្រចិត្តដើម្បីសហគមន៍ខ្ញុំ និងការចូលរួមរបស់យុវជនអ្នកនាំសារសន្តិភាពដើម្បីសហគមន៍ខ្ញុំ បរិស្ថានល្អផ្តើមចេញពីខ្ញុំ ការកសាងបណ្តាញអ្នកនាំសារសន្តិភាពក្នុងសហគមន៍ ការបោះជំរំយុវជនសកល ការបោះជំរុំកាយរឹទ្ធិ និងបណ្តាញអ្នកស្ម័គ្រចិត្តក្នុងការជួយសង្គ្រោះប្រជាជនរងគ្រោះដោយមហន្តរាយផ្សេងៗ។ លើសពីនេះ ក្រសួងបានបន្តពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកការងារយុវជន និងកាយរឹទ្ធិ

- បង្កើនការចូលរួមរបស់យុវជនលើឆាកអន្តរជាតិ តាមរយៈការចាត់បញ្ជូនយុវជនចូលរួមនៅក្នុងកម្មវិធីបណ្តុះបណ្តាល ការផ្លាស់ប្តូរវប្បធម៌ និងព្រឹត្តិការណ៍ថ្នាក់តំបន់និងពិភពលោក។ នៅក្នុងគំនិតផ្តួចផ្តើមឆ្នាំ២០២២ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកជា «ឆ្នាំយុវជនអាស៊ាន» ដែលជាគំនិតផ្តួចផ្តើមថ្មីមួយនៅក្នុងសសរស្តម្ភសង្គមវប្បធម៌ អាស៊ាន ក្នុងនោះព្រឹត្តិការណ៍អមចំនួន៤ បានរៀបចំឡើង ដូចជា(១) កិច្ចសន្ទនាយុវជនអាស៊ានលើកទី១ (២) ការប្រកួតវីដេអូយុវជនអាស៊ានលើកទី៦ (៣) ការប្រកួតរូបថតយុវជនអាស៊ាន និង(៤) ការប្រកួតជជែកដេញដោល យុវជនអាស៊ាន។

## ខ- សមិទ្ធផលសំខាន់ៗនៃការងារអប់រំកាយនិងកីឡា

ក្រសួងបានរៀបចំគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា និងបានធ្វើកំណែទម្រង់ស៊ីជម្រៅការងារអប់រំកាយនិងកីឡា ដើម្បីលើកកម្ពស់វិស័យអប់រំកាយនិងកីឡាឆ្ពោះទៅដណ្តើមមេដាយឱ្យបានច្រើននិងរៀបចំធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ ឆ្នាំ២០២៣ ឱ្យបានល្អនិងលើកកិត្តិយសជាតិលើឆាកអន្តរជាតិ។

ក្រសួងបានរៀបចំការប្រកួតកីឡាជាតិលើកទី២ ឆ្នាំ២០១៨ ចំនួន២៧ប្រភេទកីឡា ស្មើនឹង២៦៤វិញ្ញាសា ចូលរួមដោយក្រសួង៣និង២៥ខេត្ត រាជធានី នៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ កែប និងកំពត មានប្រតិភូកីឡាករ៤ ១៦៣នាក់ ស្រី១ ០០៤នាក់។

### ការប្រកួតកីឡាជាលក្ខណៈអន្តរជាតិក្នុងប្រទេស

ក្រសួងបានសហការរៀបចំការប្រកួតកីឡាកាយវប្បកម្ម ជ្រើសរើសជើងឯកអាស៊ីអាគ្នេយ៍ឆ្នាំ២០១៨ នៅខេត្តសៀមរាប មានប្រទេសចូលរួម៨ កម្ពុជា វៀតណាម សិង្ហបុរី ឥណ្ឌូណេស៊ី ឡាវ មីយ៉ាន់ម៉ា ថៃ និងម៉ាឡេស៊ី មានកីឡាករ៤៣នាក់ ស្រី៥នាក់ ជាលទ្ធផលកម្ពុជាទទួលបានមេដាយមាស៤ មេដាយប្រាក់៣ និងមេដាយសំរឹទ្ធិ២។ ឆ្នាំ២០១៩ ក្រសួងបានសហការរៀបចំការប្រកួតកីឡាលក្ខណៈអន្តរជាតិក្នុងប្រទេស ហែលទឹកជ្រើសរើសជើងឯកយុវជនអាស៊ីអាគ្នេយ៍លើកទី៤៣ កីឡាករ៣១៥នាក់ ស្រី១៤៩នាក់ នៅពហុកីឡដ្ឋានមរតកតេជោ។ ប៉េតង់ជ្រើសរើសជើងឯកពិភពលោកយុវជននិងស្ត្រីលើកទី១៧ ប្រទេសចូលរួម៤៩ កីឡាករ៤៣៣នាក់ ស្រី១១៥នាក់

នៅពហុកីឡដ្ឋានជាតិ ជាលទ្ធផលកម្ពុជាទទួលមេដាយមាស១គ្រឿងនិងសំរឹទ្ធិ១គ្រឿង។ បាល់ទាត់វគ្គជម្រុះជម្រើសជើងឯកពិភពលោកឆ្នាំ២០២២ កាតា ជាលទ្ធផលកម្ពុជាយកឈ្នះប៉ាគីស្ថាន២ទល់០ នៅពហុកីឡដ្ឋានជាតិ។ កីឡាវ៉ូវីណាមជ្រើសរើសជើងឯកពិភពលោកលើកទី៦ ប្រទេសចូលរួម២៤ កីឡាករ២៧០នាក់ ស្រី៧០នាក់ នៅពហុកីឡដ្ឋានជាតិ ជាលទ្ធផលកម្ពុជាទទួលមេដាយមាស៩គ្រឿង ប្រាក់១០គ្រឿងនិងសំរឹទ្ធិ១២គ្រឿង។ ការប្រកួតជើងឯកអាស៊ីអាគ្នេយ៍ឆ្នាំ២០២១ កីឡាទូកក្តោងនៅខេត្តព្រះសីហនុ មានប្រតិភូ និងកីឡាករ កីឡាការិនី២៩នាក់ ស្រី៣នាក់ មកពីប្រទេសសិង្ហបុរី ម៉ាឡេស៊ីនិងកម្ពុជា។ ការប្រកួតនេះ ជាលទ្ធផលកម្ពុជាទទួលបានមេដាយ៨គ្រឿង ក្នុងនោះមេដាយមាស១គ្រឿង មេដាយប្រាក់៤គ្រឿងនិងមេដាយសំរឹទ្ធិ៣គ្រឿង។

**ការប្រកួតកីឡាជាលក្ខណៈអន្តរជាតិក្រៅប្រទេស**

កម្ពុជាបានបញ្ជូនប្រតិភូ គ្រូបង្វឹក ជំនួយការគ្រូបង្វឹក កីឡាករចូលរួមការប្រកួតកីឡាលក្ខណៈអន្តរជាតិដែលទទួលបានលទ្ធផលដូចក្នុងតារាងខាងក្រោម៖

**លទ្ធផលនៃការប្រកួតកីឡាលក្ខណៈអន្តរជាតិឆ្នាំ២០១៩**

| ប្រភេទកីឡា | ប្រតិភូ (នាក់) | កីឡាករ (នាក់) | កីឡាការិនី (នាក់) | មេដាយ | | | សរុប (គ្រឿង) |
|---|---|---|---|---|---|---|---|
| | | | | មាស | ប្រាក់ | សំរឹទ្ធិ | |
| ការប្រកួតជើងឯកពិភពលោក | ៥០ | ៧៨ | ៣៩ | ១៤ | ១៣ | ១៥ | ៤២ |
| ការប្រកួតជើងឯកអាស៊ី | ៣៩ | ៥២ | ៣៩ | ១២ | ៨ | ១២ | ៣២ |
| ការប្រកួតជើងឯកអាស៊ីអាគ្នេយ៍ | ១១ | ២០ | ១៦ | ០០ | ០០ | ៧ | ៧ |
| ការប្រកួតកីឡាបើកទូលាយ | ៣៥ | ៧៩ | ៣១ | ៩ | ២ | ៥ | ១៦ |
| ការប្រកួតកីឡាជនពិការ | ៩ | ៣៤ | ២ | ០០ | ១ | ២ | ៣ |
| ការប្រកួតកីឡាស៊ីហ្គេមលើកទី៣០ | ១២៣ | ២០៦ | ៧០ | ៤ | ៦ | ៣៦ | ៤៦ |
| **សរុប** | | | | **៣៩** | **៣០** | **៧៧** | **១៤៦** |

**លទ្ធផលនៃការប្រកួតកីឡាលក្ខណៈអន្តរជាតិឆ្នាំ២០២១**

| ប្រភេទកីឡា | ប្រតិភូ (នាក់) | កីឡាករ (នាក់) | កីឡាការិនី (នាក់) | មេដាយ | | | សរុប (គ្រឿង) |
|---|---|---|---|---|---|---|---|
| | | | | មាស | ប្រាក់ | សំរឹទ្ធិ | |
| ការប្រកួតប៉េតង់ជើងឯកពិភពលោក | ០៤ | ០៤ | ០៤ | ០១ | ០ | ០ | ០១ |
| ការប្រកួតជើងឯកអាស៊ី | ១១ | ០៨ | ០៧ | ០ | ០ | ០២ | ០២ |
| ការប្រកួតអាស៊ីប៉ារ៉ាហ្គេម | ០១ | ០១ | ០ | ០ | ០១ | ០ | ០១ |
| ការប្រកួតទូកក្តោងជើងឯកអាស៊ីអាគ្នេយ៍ | ០៣ | ១១ | ០១ | ០១ | ០៤ | ០៣ | ០៨ |
| **សរុប** | | | | **០២** | **០៥** | **០៥** | **១២** |

ការចូលរួមប្រកួតកីឡាស៊ីហ្គេមលើកទី៣០ នៅហ្វីលីពីនទទួលបានមេដាយមាស៤គ្រឿង ប្រាក់៦គ្រឿងនិងសំរឹទ្ធិ៣៦គ្រឿង។ ការប្រកួតកីឡាប៉េតង់ជ្រើសរើសជើងឯកពិភពលោកយុវជននិងស្ត្រី កីឡាការិនី **ឆៃ ឡេង** ទទួលបានមេដាយមាសចំនួន៤ដងជាប់ៗគ្នាមុនគេលើពិភពលោក។

ក្រសួងអប់រំ យុវជន និងកីឡាបានបញ្ជូនប្រតិភូកីឡាករកម្ពុជាចូលរួមការប្រកួតជើងឯកប៉េតង់ពិភពលោក ចាប់ពីថ្ងៃទី១២ ដល់ទី២១ ខែវិច្ឆិកា ឆ្នាំ២០២១ នៅប្រទេសអេស្ប៉ាញ។ ជាលទ្ធផល កម្ពុជាទទួលបានមេដាយមាស ១គ្រឿង វិញ្ញាសាវាយយកពិន្ទុ នៅវគ្គផ្តាច់ព្រ័ត្រ ដោយកីឡាការិនី អ៊ុក ស្រីមុំ ឈ្នះកីឡាករថៃ លទ្ធផល៣៧ ទល់២៩។ ការទទួលបានមេដាយលើកនេះ ធ្វើឱ្យកម្ពុជាឈ្នះមេដាយមាស៥ ជំនាន់ជាប់ៗគ្នាគឺ ឆ្នាំ២០១៣ ២០១៥ ២០១៧, ២០១៩ និង២០២១។

**ការលើកកម្ពស់សកម្មភាពរៀននិងបង្រៀន អប់រំកាយក្នុងម៉ោងសិក្សា និងហ្វឹកហាត់កីឡាក្រៅម៉ោងសិក្សា**

ក្រសួងបានអនុវត្តមុខវិជ្ជាអប់រំកាយក្នុងម៉ោងសិក្សានិងកីឡាក្រៅម៉ោងសិក្សានៅគ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សា ព្រមទាំងចេញសេចក្តីណែនាំលេខ២៨២ អកសន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីគោលការណ៍រៀបចំការប្រកួតកីឡាសិស្សថ្នាក់ជាតិនិងការប្រកួតកីឡាសាកលវិទ្យាល័យថ្នាក់ជាតិរៀងរាល់២ឆ្នាំម្តង។ ក្រសួងបានចងក្រងសៀវភៅគ្រូមុខវិជ្ជាអប់រំកាយមធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ដល់ថ្នាក់ទី១២ ចំនួន១៥មុខវិជ្ជារង។

ក្រសួងបានប្រឡងបញ្ចប់ការសិក្សារបស់គរុសិស្សជំនាន់ទី២៩ ចំនួន១៥១នាក់ ស្រី១៤នាក់ តាមប្រព័ន្ធអនឡាញ និងប្រឡងជ្រើសរើសគរុសិស្សឱ្យចូលរៀនថ្នាក់មូលដ្ឋានជំនាន់ទី៣០ ចំនួន១២៥នាក់ ស្រី៤១នាក់ និងថ្នាក់បរិញ្ញាបត្រជំនាន់ទី៣ ចំនួន២៥នាក់ ស្រី៨នាក់ តាមប្រព័ន្ធអនឡាញ។

**ការកសាងលិខិតបទដ្ឋានស្តីពីការអប់រំកាយនិងកីឡា**

ក្រសួងបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអនុវិស័យអប់រំកាយនិងកីឡា។ ក្រសួងបានបង្កើតនាយកដ្ឋានថ្មី២ ចំណុះអគ្គនាយកដ្ឋានកីឡា តាមរយៈអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២០។ ក្រសួងបានកែលម្អប្រកាសអន្តរក្រសួងលេខ៧១៦ ប្រក.សហវ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីគោលការណ៍សម្រាប់ប្រមូលផ្តុំហ្វឹកហាត់ក្រុមជម្រើសជាតិនិងការប្រកួតលក្ខណៈអន្តរជាតិផ្លូវការប្រចាំឆ្នាំ។

**ការលើកកម្ពស់សមត្ថភាពគ្រូបង្វឹកនិងកីឡាករ**

ក្រសួងបានប្រមូលផ្តុំគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករថ្នាល៥០៩នាក់ ស្រី១០៨នាក់ លើ៣២ប្រភេទកីឡាមកធ្វើការហ្វឹកហាត់បង្កើនសមត្ថភាពបច្ចេកទេសត្រៀមលក្ខណៈឆ្ពោះទៅស៊ីហ្គេមឆ្នាំ២០២៣ និងប្រមូលផ្តុំគ្រូបង្វឹក គ្រូជំនួយ អនុរក្ស កីឡាករជម្រើសជាតិ៥០៩នាក់ ស្រី១០៤នាក់ លើ៣៣ប្រភេទកីឡា និង១ប្រភេទកីឡាជនពិការមកធ្វើការប្រមូលផ្តុំ ដើម្បីបង្កើនសមត្ថភាពបច្ចេកទេសសម្រាប់ត្រៀមលក្ខណៈចូលរួមប្រកួតកីឡាស៊ីហ្គេមលើកទី៣១ ឆ្នាំ២០២១ នៅវៀតណាមនិងចូលរួមការប្រកួតជាលក្ខណៈអន្តរជាតិនានា។

**២- ការងារកីឡានៃក្រសួងការពារជាតិ**

ក្រសួងការពារជាតិបានចាត់បញ្ជូនកីឡាករ កីឡាការិនីកងយោធពលខេមរភូមិន្ទទៅចូលរួមប្រកួតកីឡាផ្សេងៗ ដូចជាការប្រកួតដណ្តើមពានរង្វាន់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រកួតលក្ខណៈមិត្តភាព ប្រកួតជ្រើសរើសជើងឯកថ្នាក់ជាតិទូទាំងប្រទេស ប្រកួតដណ្តើមពានរង្វាន់ផ្សេងៗក្របខ័ណ្ឌជាតិនិងអន្តរជាតិនៅក្នុងប្រទេសនិងការចូលរួមប្រកួតលក្ខណៈអន្តរជាតិនៅក្រៅប្រទេស ថ្នាក់អាស៊ី ថ្នាក់អាស៊ីអាគ្នេយ៍ និងថ្នាក់ពិភពលោក ជាលទ្ធផល៖

- ការប្រកួតលក្ខណៈជាតិនិងអន្តរជាតិក្នុងប្រទេសទទួលបានពាន**៤០៣ន** មេដាយមាស**២៣០គ្រឿង** មេដាយប្រាក់**១២៦គ្រឿង** មេដាយសំរឹទ្ធ**១០៦គ្រឿង** ខ្សែក្រវាត់**១៩ខ្សែ** ម៉ូតូ**៤គ្រឿង** ថវិកា**២៤១លានរៀលនិង ១០៧ ៥០០ដុល្លារអាម៉េរិក**។

- ការចូលរួមប្រកួតថ្នាក់អន្តរជាតិនៅក្រៅប្រទេស(វៀតណាម បារាំង ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ចិន ហ្វីលីពីន ឥណ្ឌា ថៃ កាតា ជប៉ុន អេស្ប៉ាញ កាហ្សាក់ស្ថាន ដាណាម៉ាក សហរដ្ឋអាម៉េរិក) ទទួលបាន**៦៣ន** មេដាយមាស**២២ គ្រឿង** មេដាយប្រាក់**៣១គ្រឿង** មេដាយសំរឹទ្ធ**៤១គ្រឿង** និងខ្សែក្រវាត់**២**(ក្នុងនោះពានពិភពលោកឯកត្តជន ១៣ន ពានប៉េតង់ជើងឯកពិភពលោក១៣ន មេដាយសំរឹទ្ធពិភពលោក១គ្រឿង និងមេដាយសំរឹទ្ធអាស៊ី១គ្រឿង)។

## មុំទី២- ការបណ្តុះបណ្តាលជំនាញបច្ចេកទេស

### ១- ការបណ្តុះបណ្តាលធនធានមនុស្សរបស់ក្រសួង ស្ថាប័ន (គិតជានាក់)

| ក្រសួង ស្ថាប័ន | ឆ្នាំ២០១៨ | | ឆ្នាំ២០១៩ | | ឆ្នាំ២០២០ | | ឆ្នាំ២០២១ | | ៩ខែឆ្នាំ២០២២ | |
|---|---|---|---|---|---|---|---|---|---|---|
| | ក្នុងប្រទេស | ក្រៅប្រទេស | ក្នុងប្រទេស | ក្រៅប្រទេស | ក្នុងប្រទេស | ក្រៅប្រទេស | ក្នុងប្រទេស | ក្រៅប្រទេស | ក្នុងប្រទេស | ក្នុងប្រទេស |
| ១- ទីស្តីការគណៈរដ្ឋមន្ត្រី | ៥៧២ | ២៣ | ១៨១ | ៦៣ | ១០ | ១ | ២៦ | ២ | ១៧ | ២ |
| ២- ក្រសួងមហាផ្ទៃ | ៣ ៧៤៦ | ៦៤៥ | ៤ ២៧២ | ៦៧៨ | ២ ១១៦ | ៩៤ | ១៦០ | ០ | ០ | ០ |
| ៣- ក្រសួងការពារជាតិ | ៨ ៣៧០ | ៣ ១៣៧ | ៨ ៥០៨ | ៣ ៧៩៦ | ៩ ៩០៦ | ៣១១៥ | ៧ ៩១៨ | ២ ៧៩៥ | ៨៧០៨ | ២៣២៩ |
| ៤- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២៥៨ | ១១០ | ៣៥២ | ៧៨ | ១៣៧ | ៣១ | ១១៩ | ៥ | ១៥៦ | ១៤ |
| ៥- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ៦៦ | ០ | ២១៥ | ២៦៣ | ៧០ | ២៨ | ១៥៧ | ២៩ | ២៧៧ | ៨៦ |
| ៦- ក្រសួងអភិវឌ្ឍន៍ជនបទ | ៤ ៣៣១ | ១៨ | ១ ០៧០ | ៤១ | ៩៥៤ | ៧ | ៨៧ | ១ | ៥៨៤ | ០ |
| ៧- ក្រសួងមុខងារសាធារណៈ | ៧២៥ | ៤៧ | ១ ៧៣១ | ៩៧ | ១៨៥ | ២៣ | ២២៤ | ៥២ | ៤៩ | ៤៨ Online |
| ៨- ក្រសួងផែនការ | ៥០ | ១០ | ៨១ | ២១ | ៦៨ | ១ | ២០៥ | ៣ | ៤២ | ១៥ |
| ៩-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ៦ ៧៨០ | ៣០០ | ១០២៩ | ២៨១ | ២ ៣០៦ | ១៣២ | ៥៦៤ | ២៥៦ | ១ ០៥៧ | ១២៣ |
| ១០- ក្រសួងទេសចរណ៍ | ៤៤ | ៦៦ | ៥០ | ៣៩ | ២៣ | ០ | ៤៧ | ១ | ៥៨ | ០ |
| ១១- ក្រសួងធនធានទឹក និងឧតុនិយម | ១៩១ | ១៧ | ២៣៧ | ១៩ | ១៦៩ | ៥ | ៩៤ | ០ | ៤១៩ | ៧ |
| ១២- ក្រសួងរ៉ែនិងថាមពល | ៨៨១ | ១២៨ | ១៩៥៧ | ១៦២ | ១ ៣២៣ | ២៥ | ១ ២០២ | ៣៤ | ១ ៩៣២ | ៤៩ |
| ១៣- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៦៤៦ | ១២៣ | ៥៥៤ | ១៩១ | ១១២ | ១ | ៨០ | ១ | ១៣៥ | ០ |
| ១៤- ក្រសួងបរិស្ថាន | ៨២១ | ៩២ | ៩៦៦ | ៨៤ | ៣០៣ | ២៣ | ២៦៥ | ៧ | ៩៤១ | ១៦ |
| ១៥- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២ ២៨០ | ៦៣៦ | ១៣៥២ | ៩១៦ | ២ ៣៤១ | ៣៩៣ | ១០៥១ | ៤៦ | ២០៦៣ | ១៣១ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១៦- ក្រសួងកិច្ចការនារី | ២៤ | ២១ | ០ | ០ | ១៣ | ៨ | ៥៤ | ១៦ | ១៨ | ១២ |
| ១៧- ក្រសួងពាណិជ្ជកម្ម | ២៣២ | ៨ | ១០៧ | ៧០ | ៥៥ | ៩ | ៦៩ | ៧ | ៣២ | ៦ |
| ១៨- ក្រសួងអប់រំ យុវជន និងកីឡា | ១៣៦ | ១២០ | ៣២ | ៧៧ | ៨៤ | ៨៦ | ១២៧ | ៦៤ | ៥៧ | ៩ |
| ១៩- ក្រសួងការងារនិង បណ្តុះបណ្តាលវិជ្ជាជីវៈ | ១ ០១៤ | ៤២៧ | ៦០៦ | ៤៥១ | ៣ ៤៨២ | ៦១ | ៤ ៦៧២ | ៩៣ | ៤ ៦៧១ | ៨៧ |
| ២០- ក្រសួងយុត្តិធម៌ | ២ | ៣ | ២៩ | ២៤ | ០ | ០ | ០ | ០ | ០ | ០ |
| ២១-ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | ០ | ០ | ៣៤៩ | ៥ | ០ | ០ | ៦៦ | ០ | ១៣៦ | ២៤ |
| ២២- ក្រសួងវប្បធម៌និង វិចិត្រសិល្បៈ | ៥៣៩ | ១៩ | ៧៦៨ | ១១ | ៧៣៦ | ៣ | ៥៦៦ | ៥ | ១០៩ | ៧ |
| ២៣- ក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ | ១ ៣៧២ | ៨០ | ១ ២១៧ | ៨៨ | ១ ២១៩ | ៣៤ | ១២២២ | ៣០៣ | ៥៥២ | ២៤ |
| ២៤- ក្រសួងធម្មការ និងសាសនា | ១៥០ | ០ | ២២០ | ០ | ៥៧ | ០ | ១៧០ | ០ | ០ | ០ |
| ២៥-ក្រសួងសាធារណការ និងដឹកជញ្ជូន | ៩៥ | ០ | ២៤ | ០ | ១៦២ | ០ | ៤៧ | ១៣ | ២៤ | ២៩ |
| ២៦-ក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ | ៩៩៤ | ៨ | ១៨១ | ១៦ | ៧១២ | ៣ | ១ ៦១៩ | ៨ | ២៧៥ | ១១ |
| ២៧-ក្រសួងសុខាភិបាល | ០ | ៧១៧ | ០ | ៩៤៣ | ០ | ១០៤ | ៥៤ | ២៣៣ | ១៨២ | ២៥៩ |
| ២៨- រដ្ឋលេខាធិការដ្ឋាន អាកាសចរស៊ីវិល | ២៨៩ | ៤៤ | ៥០៦ | ៩៧ | ២០៥ | ៨ | ៤០ | ០ | ១៧៥ | ១២ |

## ២- ការងារបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ

### ២.១- ក្រសួងមហាផ្ទៃ

គិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០២២ មន្ត្រីរាជការចំណុះក្រសួងមហាផ្ទៃ ចំនួន៦៨ ៧៣៦នាក់(ស្រី៧ ៤៤៨នាក់) ក្នុងនោះ មន្ត្រីនគរបាលជាតិចំនួន៦១ ៦១១នាក់(ស្រី៦ ១៧៣នាក់) មន្ត្រីរដ្ឋបាលស៊ីវិលចំនួន៤ ១៥៥នាក( ស្រី៨៣១នាក់) និងមន្ត្រីពន្ធនាគារចំនួន២ ៩៧០នាក់(ស្រី ៤៤៤នាក់)។ ក្នុងរយៈពេល៥ឆ្នាំនេះ មន្ត្រីចូលនិវត្តន៍ចំនួន៦ ៥៦៣នាក់ (មន្ត្រីរដ្ឋបាលស៊ីវិល៧៥២នាក់ មន្ត្រីពន្ធនាគារ១៩១នាក់ និងមន្ត្រីនគរបាល៥ ៦២០នាក់) មន្ត្រីទទួលមរណភាពចំនួន១ ១៨៩នាក់(មន្ត្រីរដ្ឋបាលស៊ីវិល៦៨នាក់ មន្ត្រីពន្ធនាគារ៥២នាក់ និងមន្ត្រីនគរបាល១ ០៦៩នាក់) មន្ត្រីលាឈប់ពីក្របខ័ណ្ឌមានចំនួន ៧៨នាក់(មន្ត្រីរដ្ឋបាលស៊ីវិល២៨នាក់ មន្ត្រីពន្ធនាគារ១១នាក់ និងមន្ត្រីនគរបាល៣៩នាក់) មន្ត្រីត្រូវបានបណ្តេញចេញពីក្របខ័ណ្ឌមានចំនួន៣១២នាក់(មន្ត្រីរដ្ឋបាលស៊ីវិល៧នាក់ និងមន្ត្រីនគរបាល៣០៥នាក់) និងមន្ត្រីចូលក្របខ័ណ្ឌថ្មីមានចំនួន១៥ ០២០នាក់(មន្ត្រីរដ្ឋបាលស៊ីវិល៩៩៨នាក់ មន្ត្រីពន្ធនាគារ៧៤៣នាក់ និងមន្ត្រីនគរបាល១៣ ២៧៩នាក់)។

ក្នុងគោលដៅលើកកម្ពស់គុណភាព សមត្ថភាពស្ថាប័ន និងធនធានមនុស្ស ដើម្បីរ៉ាប់រងប្រកបដោយការទទួលខុសត្រូវក្នុងការបន្តថែរក្សា ការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គមស្របតាមសភាពការណ៍វិវត្តប្រែប្រួលនៃបទល្មើសសង្គម និងការវិវត្តប្រែប្រួលនៃសភាពការណ៍សន្តិសុខទាំងក្នុងតំបន់និងសកលលោក ក៏ដូចជាលើកកម្ពស់សមត្ថភាពរ៉ាប់រង ដឹកនាំសម្របសម្រួល និងអនុវត្តការងារកំណែទម្រង់ដែលមានលក្ខណៈកាន់តែស៊ីជម្រៅទាំងកំណែទម្រង់រដ្ឋបាលនិងវិសហមជ្ឈការ និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ព្រមទាំងរ៉ាប់រងអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពនូវកិច្ចការនានា ដែលស្ថិតក្រោមសមត្ថកិច្ចនិងការទទួលខុសត្រូវរបស់ខ្លួន ក្រសួងមហាផ្ទៃបាននិងកំពុងខិតខំជំរុញកិច្ចការជាច្រើនជាមួយនឹងការទទួលបានលទ្ធផលផ្លែផ្កាជាបន្តបន្ទាប់ ក្នុងនោះមានជាអាទិ៍៖

- ការបង្កើតគណៈកម្មការកំណែទម្រង់នគរបាលជាតិកម្ពុជា និងគណៈកម្មការកំណែទម្រង់មន្ត្រីរដ្ឋបាលស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃក្នុងគោលបំណងសិក្សាកំណត់មុខងារនិងរៀបចំកែសម្រួលរចនាសម្ព័ន្ធ សំដៅកំណត់តម្រូវការក្របខ័ណ្ឌ មុខតំណែង ឋានន្តរសក្តិ បំពាក់មធ្យោបាយសម្ភារៈបម្រើការងារ និងការបណ្តុះបណ្តាលកសាងធនធានមនុស្ស ដើម្បីជាមូលដ្ឋានឈានទៅធ្វើការកែទម្រង់មន្ត្រី នគរបាលជាតិកម្ពុជា មន្ត្រីរដ្ឋបាលស៊ីវិល និងមន្ត្រីពន្ធនាគារសម្រាប់រយៈពេលចំពោះមុខនិងរយៈពេលពីមធ្យមទៅរយៈពេលវែង ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

- ការពិនិត្យឡើងវិញ និងកែសម្រួលនូវអនុក្រឹត្យលេខ១០៩ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ ការកែសម្រួលរចនាសម្ព័ន្ធ និងដំឡើងកម្រិតសាលាជាតិរដ្ឋបាលមូលដ្ឋានឱ្យស្មើនឹងអគ្គនាយកដ្ឋាន និងការកែសម្រួលរចនាសម្ព័ន្ធនៅតាមអង្គភាពនានាជាច្រើនទៀត។

**១- ការបណ្តុះបណ្តាលមន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារ**

- ដើម្បីជំរុញលើកកម្ពស់ការងារបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារឱ្យកាន់តែមានប្រសិទ្ធផល ទាំងថ្នាក់ដឹកនាំ គ្រូនគរបាលជាតិ និងមន្ត្រីជំនាញពាក់ព័ន្ធត្រូវបានយកចិត្តទុកដាក់បំពាក់បំប៉នពង្រឹងសមត្ថភាពបន្ថែមជាបន្តបន្ទាប់ តាមរយៈការរៀបចំបើកវគ្គបណ្តុះបណ្តាលផ្ទៃក្នុងផងនិងការចាត់បញ្ជូនទៅចូលរួមសិក្ខាសាលាថ្នាក់ជាតិ អន្តរជាតិនិងវគ្គសិក្សានៅក្រៅប្រទេសផង។ តួយ៉ាងនៅក្នុងកំលុងពេល៥ឆ្នាំនេះ មានថ្នាក់ដឹកនាំគ្រូនគរបាលជាតិ និងមន្ត្រីជំនាញចំនួន១ ៥៥៦នាក់ ត្រូវបានចាត់ឱ្យចូលរួមក្នុងកម្មវិធីនានាខាងលើ ដើម្បីពង្រីកចំណេះដឹងក៏ដូចជាទទួលយកនូវបទពិសោធន៍ថ្មីៗ មកអភិវឌ្ឍលើការងារដឹកនាំការងារចងក្រងឯកសារស្រាវជ្រាវ និងការងារបង្ហាត់បង្រៀន។ល។ គិតមកដល់បច្ចុប្បន្ននេះ ថ្នាក់ដឹកនាំគ្រូនគរបាលជាតិនិងមន្ត្រីពាក់ព័ន្ធនៃបណ្ឌិត្យសភានគរបាលកម្ពុជាមាន ចំនួន១ ១០៩នាក់ ដែលក្នុងនោះ កម្រិតសញ្ញាបត្របណ្ឌិត មានចំនួន១៤នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន៣៣៦នាក់ បរិញ្ញាបត្រ ចំនួន៤៨៣នាក់ និងសញ្ញាបត្រផ្សេងៗមានចំនួន២៧៦នាក់

- ពីឆ្នាំ២០១៨ដល់ឆ្នាំ២០២២ បណ្ឌិត្យសភានគរបាលកម្ពុជានៃក្រសួងមហាផ្ទៃ បានបើកវគ្គបណ្តុះបណ្តាលលើជំនាញនគរបាលនិងពន្ធនាគារសរុប១៤០វគ្គ មាននិស្សិត សិក្ខាកាម និងសិស្សនគរបាលចូលរួមចំនួន១៣ ៩៤៨នាក់(ស្រី២ ០៦០នាក់) ក្នុងនោះនិស្សិត សិក្ខាកាម និងសិស្ស នគរបាលដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលជាស្ថាពរចំនួន១២៣វគ្គ ស្មើនឹង១២ ៩៣៥នាក់(ស្រី១ ៨៤៩នាក់)។ សម្រាប់លទ្ធផលនៃការបណ្តុះបណ្តាលមន្ត្រីនគរបាលជាតិនិងមន្ត្រីពន្ធនាគារតាមឆ្នាំនីមួយៗ រួមមាន៖

| បរិយាយ/ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ/២០២២ | សរុប |
|---|---|---|---|---|---|---|
| វគ្គសិក្សា | ៤២វគ្គ | ៤២វគ្គ | ១០វគ្គ | ៣វគ្គ | ២៦វគ្គ | ១២៣វគ្គ |
| និស្សិត សិក្ខាកាម និងសិស្សនគរបាល | ៣ ២៦៦នាក់ ស្រី៣៥៥នាក់ | ៣ ៨៥៧នាក់ ស្រី៤៦៣នាក់ | ១ ៧៩៦នាក់ ស្រី៣៧៥នាក់ | ៣០៦នាក់ ស្រី៦៤នាក់ | ៣ ៧១០នាក់ ស្រី៥៩២នាក់ | ១២ ៩៣៥នាក់ ស្រី១ ៨៤៩នាក់ |

## ២- អំពីការបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិល

- ដើម្បីលើកកម្ពស់សមត្ថភាពធនធានមនុស្សផ្នែករដ្ឋបាលស៊ីវិល ទាំងនៅទីស្តីការក្រសួងមហាផ្ទៃនិងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងការវិវឌ្ឍប្រែប្រួលនៃចរន្តសកលភាវូបនីយកម្ម តំបន់ភាវូបនីយកម្ម ការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មាននិងសេដ្ឋកិច្ចសង្គមឌីជីថល ក្រសួងមហាផ្ទៃបានផ្តោតការយកចិត្តទុកដាក់ទៅលើការពង្រឹងជាប្រចាំនូវយន្តការនៃការអភិវឌ្ឍសមត្ថភាពនិងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលតាមស្តង់ដា រួមទាំងសកម្មភាពអភិវឌ្ឍសមត្ថភាពនានាផងដែរ។

- ពីឆ្នាំ២០១៨ដល់ឆ្នាំ២០២២ សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាលជូនដល់មន្ត្រីរាជការស៊ីវិលនិងក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិចំនួន៣៨១វគ្គ លើប្រធានបទសំខាន់ៗដូចជាការផ្តល់សេវាសាធារណៈ ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍមូលដ្ឋាន ការរៀបចំផែនការសកម្មភាពនិងថវិកាការងាររដ្ឋបាល និងការងារគ្រប់គ្រងដឹកនាំអង្គភាពជាដើម។ គោលចម្បងៗនៃការរៀបចំវគ្គបណ្តុះបណ្តាលទាំងនេះគឺដើម្បីពង្រឹងទាំងសមត្ថភាពដឹកនាំនិងសមត្ថភាពបំពេញការងាររបស់ក្រុមប្រតិបត្តិករនេះ សំដៅឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពសម្រាប់គ្រប់តម្រូវការរបស់ប្រជាពលរដ្ឋនិងការអភិវឌ្ឍមូលដ្ឋាន។

| បរិយាយ/ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ/២០២២ |
|---|---|---|---|---|---|
| វគ្គបណ្តុះបណ្តាល (វគ្គ) | ៣០ | ៥៣ | ១៥៥ | ៤៤ | ៩៩ |
| សិក្ខាកាមចូលរួម (នាក់) | ១ ៥៨២ (ស្រី៤៩៤) | ៣ ៤០៦ (ស្រី៨៤៤) | ៧ ០៣៨ (ស្រី១ ៧៤៦) | ១ ៤២៣ (ស្រី៤១៣) | ៥ ៦១០ (ស្រី១ ២៤៨) |

## ២.២- ក្រសួងការពារជាតិ

ក្រសួងការពារជាតិ បានបន្តធ្វើការកែសម្រួលពង្រឹងគុណភាពហ្វឹកហ្វឺន ដើម្បីលើកកម្ពស់សមត្ថភាពប្រសិទ្ធភាពការងារនិងសេចក្តីត្រូវការធនធានមនុស្ស និងបានធ្វើការហ្វឹកហ្វឺន បណ្តុះបណ្តាលនិងបំប៉នជំនាញផ្សេងៗជូនដល់កងយោធពលខេមរភូមិន្ទ លទ្ធផលសរុបទាំងវគ្គចាស់និងវគ្គថ្មីសម្រេចបាន៖

ការសិក្សាបង់ថ្លៃវគ្គវេជ្ជបណ្ឌិត វគ្គទន្តបណ្ឌិត វគ្គបរិញ្ញាបត្រឱសថ វគ្គបរិញ្ញាបត្ររងគិលានុបដ្ឋាក វគ្គបរិញ្ញាបត្ររងឆ្មប វគ្គបរិញ្ញាបត្ររងមន្ទីរពិសោធន៍ នៅវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល កងយោធពលខេមរភូមិន្ទ

| ឆ្នាំសិក្សា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| ចំនួនសិក្ខាកាម | ១ ១៥៩នាក់ | ១ ១៣៣នាក់ | ១ ២៤១នាក់ | ១ ៤០៥នាក់ | ១ ៧១៥នាក់ |

ក្រៅពីនេះ បានចាត់តាំងធ្វើលំហាត់ហ្វឹកហ្វឺន៦លើក(នាគមាសឆ្នាំ២០១៨ ឆ្នាំ២០១៩ និងឆ្នាំ២០២០ រវាងកងយោធពលខេមរភូមិន្ទនិងកងទ័ពរំដោះប្រជាជនចិន មហារំអិល២០១៩ និងហនុមានមាស២០១៨ និង២០១៩) និងបានចាត់តាំងហ្វឹកហ្វឺនបណ្តុះបណ្តាលនិងបំប៉នជំនាញផ្សេងៗនៅតាមបណ្តាស្ថាប័ន អង្គភាពមួយចំនួនធំផងដែរ។

កងយោធពលខេមរភូមិន្ទត្រូវបានធ្វើការបំពាក់បំប៉នជាប្រចាំនូវការអប់រំចិត្តសាស្ត្រ ស្មារតីសតិអារម្មណ៍ ច្បាប់ផ្សេងៗ និងសភាពការណ៍ថ្មីៗ ពិសេសច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

និងអនុក្រឹត្យស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទសរុបចំនួន**៤៨ ២៨២លើក** ស្មើនឹង**៧ ១៥៦ ៧១៧ លើក/នាក់** ដើម្បីលើកកម្ពស់យល់ដឹងការគោរពអនុវត្តច្បាប់ បទបញ្ជា និងទឹកចិត្តស្នេហាជាតិមាតុភូមិប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងការពារនិងស្មោះត្រង់ដាច់ខាតចំពោះរាជរដ្ឋាភិបាល។

## ២.៣- ក្រសួងមុខងារសាធារណៈ

**ចំនួននៃការបណ្តុះបណ្តាលសិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការ សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខ័ណ្ឌថ្មី និងសិស្សមន្ត្រីក្រមការក្របខ័ណ្ឌថ្មី** (គិតជានាក់)

| ឆ្នាំ / បរិយាយ | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១០ ទី១១ និងទី១២ | ៦០ | ១៥ | ០ | ០ | ៩០ | ២៨ | ០ | ០ | ៩២ | ៣១ |
| សិស្សមន្ត្រីក្រមការជំនាន់ទី៨ និងទី៩ | ០ | ០ | ១១៩ | ៣២ | ០ | ០ | ១២១ | ៤៣ | ០ | ០ |
| សិស្សមន្ត្រីគ្រប់គ្រងរដ្ឋបាលក្របខ័ណ្ឌថ្មីឆ្នាំ២០១៦ ២០១៧ ២០១៨ ២០១៩ និង២០២០ | ៦១៩ | ២៤៥ | ៧០១ | ២៦៩ | ៥២៨ | ២២១ | ៦៤១ | ២២៧ | ៩៨៣ | ៣៦៧ |
| សិស្សមន្ត្រីក្រមការក្របខ័ណ្ឌថ្មី ២០១៩ និង ២០២០ | ០ | ០ | ០ | ០ | ០ | ០ | ៨៦ | ៣៦ | ១៦ | ១៣ |
| **សរុប** | **៦៧៩** | **២៦០** | **៨២០** | **៣០១** | **៦១៨** | **២៤៩** | **៨៤៨** | **៣០៦** | **១០៩១** | **៤១១** |

**ចំនួននៃការបណ្តុះបណ្តាលវគ្គវិក្រឹតការ** (គិតជានាក់)

| ឆ្នាំ / បរិយាយ | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ | ២៨៧ | ៣៤ | ០ | ០ | ១០៦ | ១២ | ១៥១ | ៣៧ | ១៥២ | ២១ |
| វគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល | ០ | ០ | ០ | ០ | ១៦៤ | ២៦ | ៥៣៥ | ១៣៤ | ៨២ | ១៩ |
| វគ្គវិក្រឹត្យការមន្ត្រីមធ្យម | ១១៥ | ២៤ | ០ | ០ | ៣៩ | ១១ | ៩០ | ២៧ | ២៦៦ | ៧៥ |
| វគ្គវិក្រឹត្យការមន្ត្រីក្រមការ | ០ | ០ | ០ | ០ | ៤៣ | ៦ | ៨៨ | ២៤ | ២៥ | ១៤ |
| **សរុប** | **៤០២** | **៥៨** | **០** | **០** | **៣៥២** | **៥៥** | **៨៦៤** | **២២២** | **៥២៥** | **១២៩** |

**ចំនួននៃការបណ្តុះបណ្តាលវគ្គខ្លី** (គិតជានាក់)

| ឆ្នាំ / បរិយាយ | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| វគ្គបណ្តុះបណ្តាលមន្ត្រីក្រសួងបរិស្ថាន | ៦០ | ១៧ | ៤៧ | ៦ | ០ | ០ | ៤៨ | ៧ | ២៤ | ២ |
| វគ្គថ្នាក់ដឹកនាំជាស្ត្រីថ្នាក់រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក និងអគ្គនាយករង | ០ | ០ | ១០៣ | ១០៣ | ០ | ០ | ០ | ០ | ០ | ០ |
| វគ្គបណ្តុះបណ្តាលថ្នាក់គ្រប់គ្រងគ្រឹះស្ថានសិក្សាជានាយកសាលានៃក្រសួងអប់រំ យុវជន និងកីឡា | ១៥៩ | ១៥ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា | ៣៧ | ១១ | ៣៧ | ១៨ | ០ | ០ | ០ | ០ | ០ | ០ |
| វគ្គបណ្តុះបណ្តាលខ្លីជំនាញរដ្ឋបាលសាធារណៈ | ១១២ | ២១ | ៤០៥ | ៩៥ | ០ | ០ | ១៦៣ | ៣៣ | ៣៧៩ | ៨៧ |
| វគ្គបណ្តុះបណ្តាលខ្លីជំនាញគ្រប់គ្រងអង្គភាពសាធារណៈ | ១៣៧ | ៣២ | ៨០ | ៨ | ០ | ០ | ៧៦ | ១៥ | ១១១ | ១២ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| វគ្គបណ្តុះបណ្តាលខ្លីជំនាញនវានុវត្តន៍ក្នុងរដ្ឋបាលសាធារណៈ | ១២៧ | ២៨ | ៤៧៦ | ១១៧ | ៨០ | ១៩ | ៧២ | ៨ | ៨៣ | ៨ |
| វគ្គបណ្តុះបណ្តាលស្តីពីតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលស្រុកពាមរក៍ខេត្តព្រៃវែង | ០ | ០ | ២៦ | ៥ | ០ | ០ | ០ | ០ | ០ | ០ |
| វគ្គបណ្តុះបណ្តាលមន្ត្រីបណ្ណាញខុទ្ទកាល័យ | ០ | ០ | ៤០ | ៩ | ០ | ០ | ០ | ០ | ០ | ០ |
| វគ្គបណ្តុះបណ្តាលជំនាញការរៀបចំថវិកាក្នុងអង្គភាពសាធារណៈ | ០ | ០ | ៨០ | ២៤ | ០ | ០ | ០ | ០ | ០ | ០ |
| វគ្គបណ្តុះបណ្តាលខ្លីជំនាញការតាក់តែងលិខិតរដ្ឋបាលនិងគតិយុត្ត | ០ | ០ | ៨០ | ២៣ | ០ | ០ | ១៥៤ | ៣០ | ១៩៧ | ៥០ |
| វគ្គបណ្តុះបណ្តាលមន្ត្រីក្រសួងយុត្តិធម៌ | ០ | ០ | ២៩ | ៩ | ០ | ០ | ០ | ០ | ០ | ០ |
| វគ្គបណ្តុះបណ្តាលកសាងសមត្ថភាពគណៈគ្រប់គ្រងអង្គភាពសាធារណៈ(មន្ត្រីអាជ្ញាធរជាតិ ប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអង្គភាពការងារពាក់ព័ន្ធ) | ០ | ០ | ០ | ០ | ០ | ០ | ១១២ | ២០ | ០ | ០ |
| វគ្គបណ្តុះបណ្តាលភាពជាអ្នកដឹកនាំនិងនវានុវត្តន៍(វគ្គ១ វគ្គ២ វគ្គ៣) | ០ | ០ | ០ | ០ | ០ | ០ | ១៤៦ | ២២ | ៣៣១ | ៥៥ |
| វគ្គបណ្តុះបណ្តាលគ្រូបង្គោលជំនាញនវានុវត្តន៍ក្នុងរដ្ឋបាលសាធារណៈ | ០ | ០ | ០ | ០ | ០ | ០ | ៩ | ០ | ០ | ០ |
| សរុប | **៦៣២** | **១២៤** | **១៤០៣** | **៤១៧** | **៨០** | **១៩** | **៧៨០** | **១៣៥** | **១ ១២៥** | **២១៤** |

**ចំនួននៃការបណ្តុះបណ្តាលតាមរយៈកម្មវិធីបាឋកថានិងសិក្ខាសាលា** (គិតជានាក់)

| ឆ្នាំ / បរិយាយ | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| សិក្ខាសាលាបណ្តុះបណ្តាលសម្រាប់មុខតំណែងចាប់ពីអគ្គនាយក អគ្គនាយករងរបស់សិង្ហបុរី | ០ | ០ | ៤៥ | ១២ | ៥០ | ១១ | ៤៥ | ៨ | | |
| រៀបចំកម្មវិធីបាឋកថានិងធម្មកថា (អនឡាញ/ផ្ទាល់) | ០ | ០ | ១ ៩៤២ | ៥២៥ | **២ ៥៤៤** | ៧៤៤ | ៥ ៤៦៣ | ១ ៦៤៧ | ៦៤៦៩ | ៨១៨ |
| រៀបចំកម្មវិធីសិក្ខាសាលាស្តីពី "ការអភិវឌ្ឍភាពជាអ្នកដឹកនាំដើម្បីការកែទម្រង់" | ០ | ០ | ០ | ០ | ០ | ០ | ១៦៨ | ២២ | ០ | ០ |
| រៀបចំទស្សនៈកិច្ចសិក្សានៅសាលាបឋមសិក្សាវត្តបូព៌ | ០ | ០ | ៦១៩ | ១៣២ | ៧២ | ៣៦ | ១០៨ | ៤៥ | ០ | ០ |
| រៀបចំសិក្ខាសាលាអន្តរជាតិ | ០ | ០ | ៦០៦ | ២៥០ | ០ | ០ | ១ ០៨២ | ២៩៨ | ២៤៣ | ៥៣ |
| សរុប | **០** | **០** | **៣ ២១២** | **៩១៩** | **២ ៦៦៦** | **៧៩១** | **៦ ៨៦៦** | **២ ០២០** | **៦ ៧១២** | **៨៧១** |

## ២.៤- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

- ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ក្រសួងបានបណ្តុះបណ្តាលមន្ត្រីសរុបចំនួន៥ ៦៣៦នាក់(ក្នុងប្រទេស ៥ ៣៤៩នាក់ និងក្រៅប្រទេស២៨៧នាក់) និងបញ្ចូលក្របខ័ណ្ឌមន្ត្រីថ្មី ចំនួន១៣០នាក់

- វិទ្យាស្ថានការទូតនិងទំនាក់ទំនងអន្តរជាតិ បានចូលរួមចំណែកដល់ការអភិវឌ្ឍធនធានមនុស្សរបស់ក្រសួង តាមរយៈការរៀបចំ (១) វគ្គតម្រង់ទិស (Orientation Course) ចំនួន១៥វគ្គ (២)វគ្គចែករំលែកចំណេះដឹងបន្តចំនួន៣វគ្គ (៣)វគ្គបណ្តុះបណ្តាលផ្សេងៗចំនួន២៧វគ្គ (៤)វគ្គបណ្តុះបណ្តាលភាសាអង់គ្លេសចំនួន១២វគ្គ បារាំង

ចំនួន៦វគ្គ ចិនចំនួន១៣វគ្គ ថៃចំនួន៩វគ្គ និងអេស្ប៉ាញចំនួន៣វគ្គ និង(៤)ការរៀបចំវេទិកានិងកម្រងបាឋកថា និងកិច្ចសហប្រតិបត្តិការផ្សេងៗទៀត និង(៥) ការវាយតម្លៃតម្រូវការបណ្តុះបណ្តាលមន្ត្រី។

### ២.៥- ក្រសួងសុខាភិបាល

ធនធានមនុស្ស គឺជាសមាសភាគដ៏សំខាន់សម្រាប់ប្រតិបត្តិការក្នុងប្រព័ន្ធសុខាភិបាល ជាពិសេស ការផ្តល់សេវាសុខាភិបាលមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព ប្រកបដោយសមធម៌ជូនប្រជាជនគ្រប់រូប។ ការអភិវឌ្ឍធនធានមនុស្សសុខាភិបាល ផ្តោតលើប្រព័ន្ធនិងអភិក្រមនៃការបណ្តុះបណ្តាលវិជ្ជាជីវៈសុខាភិបាល សំដៅលើសមត្ថភាព(ចំណេះដឹង ជំនាញសម្បទា និងចរិយាសម្បទា) ការជ្រើសរើស ការបែងចែកបុគ្គលិក ការពង្រាយបុគ្គលិក ការរក្សាទុកបុគ្គលិកនៅនឹងកន្លែងធ្វើការ ការលើកទឹកចិត្ត ការគ្រប់គ្រងនិងអភិបាលកិច្ច។ រហូតមកដល់បច្ចុប្បន្ននេះ គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលទាំងសាធារណៈនិងឯកជនមានចំនួន១៩ គ្រឹះស្ថាន។ និស្សិតបញ្ចប់ការសិក្សាក្នុងវិស័យសុខាភិបាល រយៈពេល៥ឆ្នាំ មានចំនួន**២១ ២៨៥នាក់**។

**ការបណ្តុះបណ្តាលមុនពេលបម្រើការងារនៃនិស្សិតពេទ្យរវាងឆ្នាំ២០១៨ ២០២១** (គិតជានាក់)




**ការបណ្តុះបណ្តាលតាមប្រភេទជំនាញនៅគ្រឹះស្ថានសាធារណៈពីឆ្នាំ២០១៨-២០២២** (គិតជានាក់)

| ប្រភេទជំនាញបច្ចេកទេស | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | |
|---|---|---|---|---|---|---|---|---|---|---|
| | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា |
| វេជ្ជបណ្ឌិតឯកទេស | ៧៦០ | ១៧៨ | ៤៧១ | ១៩៨ | ៤៥៩ | ១៨០ | ៣៣៥ | ១៥៧ | ៥៣៥ | ១៣៥ |
| វេជ្ជសាស្ត្រ | ២ ៥៣០ | ២៦៨ | ២ ៤០០ | ២១៨ | ២ ៤៣៥ | ៣០៣ | ២ ៥៩៣ | ៣០០ | ២៣៤៩ | ២៤២ |
| ទន្តសាស្ត្រ | ៦១៣ | ៩៨ | ៦៥៧ | ១២២ | ៦៣១ | ១១៨ | ៧៣៩ | ៤១ | ៧៣៧ | ៧០ |
| ឱសថសាស្ត្រ | ៦៧៤ | ២១៦ | ៧៨៣ | ១៧០ | ៩៩៤ | ១៦២ | ១០១៥ | ១៨១ | ១៤០៣ | ២០៥ |
| បរិញ្ញាបត្រសុខភាពសាធារណៈ | ១៦ | - | ២១ | - | ៧ | ១៤ | ៧ | ៧ | - | - |
| បរិញ្ញាបត្រគិលានុបដ្ឋាក | ២០៥ | ១៨ | ២៤៧ | ២៧ | ២១៥ | ៦៥ | ២៧២ | ១៣៥ | ៣៣៣ | ៨៨ |
| | - | - | ៤៩ | - | ១០៩ | - | ១៦២ | - | ១៧៥ | ៦០ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| បរិញ្ញាបត្រគិលានុបដ្ឋាកបែបពាក់កណ្តាលពេល | | | | | | | | | | |
| បរិញ្ញាបត្រគិលានុបដ្ឋាក-ឆ្មប | ២៧ | ៩៤ | ១៥១ | ៥៩ | ៧០ | ២០៨ | ១០៥ | ៧២ | ១៣១ | ៦៩ |
| បរិញ្ញាបត្រឆ្មប | - | - | - | - | - | - | - | - | ១៤២ | ៥០ |
| បរិញ្ញាបត្រព្យាបាលចលនា | - | - | ២០ | - | - | ២១ | ៦៥ | ២១ | ២១ | - |
| បរិញ្ញាបត្ររងគិលានុបដ្ឋាក | ១ ៦៣៥ | ១ ៣៥១ | ១ ០៧៣ | ៨៣៦ | ១ ៨៨៩ | ៦៧៣ | ២ ៤៦៤ | ៥៣៤ | ២ ២៤១ | ១ ៥៥៧ |
| បរិញ្ញាបត្ររងឆ្មប | ១ ០៨៣ | ៧៥៣ | ៦២១ | ៦២៧ | ៥៧២ | ៣៨៦ | ៧២៨ | ១៩៣ | ៨៦៧ | ៣៥៥ |
| ចក្ខុគិលានុបដ្ឋាក | - | ៤១ | - | - | - | ២៩ | - | - | ៤៨ | - |
| បរិញ្ញាបត្រមន្ទីរពិសោធន៍ | - | - | - | - | ៦៨ | ៥៦ | - | ៦៨ | ៦៤ | - |
| បរិញ្ញាបត្ររងមន្ទីរពិសោធន៍ | ២៣៩ | ១៧១ | ១៣៧ | ៨៧ | ២១៩ | ៩៤ | ២៦០ | ៥០ | ១៨៨ | ១៥៥ |
| បរិញ្ញាបត្ររងទន្តគិលានុបដ្ឋាក | ១០១ | ២១ | ៦៦ | ៤២ | ១៥៦ | ៤៦ | ២៣៨ | ៣៣ | ២១២ | ៩៦ |
| បរិញ្ញាបត្ររងព្យាបាលចលនា | ៥៣ | ៧ | ៣៦ | ២០ | ៦១ | ១៥ | - | - | ៦១ | ៣៤ |
| បរិញ្ញាបត្ររងវិទ្យុសាស្ត្រ | - | - | ២១ | ៣ | ៤៥ | ១០ | ៦៩ | ៩ | ៧៨ | ៣២ |
| បរិញ្ញាបត្ររងបច្ចេកទេសវិស្វកម្មវេជ្ជជីវសាស្ត្រ | - | - | - | - | ១៨ | - | ៥ | - | ២៣ | - |
| សរុប | ៧ ៩៣៦ | ៣ ២១៦ | ៦ ៧៥៣ | ២ ៤០៩ | ៧ ៩៨៨ | ២ ៣៨០ | ៩ ០៩៧ | ១ ៨០២ | ១០០០៨ | ៣ ១៤៨ |

## ការបណ្តុះបណ្តាលតាមប្រភេទជំនាញនៅគ្រឹះស្ថានឯកជនពីឆ្នាំ២០១៨-២០២២ (គិតជានាក់)

| ប្រភេទជំនាញបច្ចេកទេស | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | |
|---|---|---|---|---|---|---|---|---|---|---|
| | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា | កំពុងសិក្សា | បញ្ចប់ការសិក្សា |
| វេជ្ជបណ្ឌិតឯកទេស | - | - | ១២៩ | - | ១៩០ | - | ១០៨ | ៣៩ | ២៦២ | - |
| វេជ្ជសាស្ត្រ | ១៨៦៤ | ៣៦១ | ១ ៩៦២ | ៣៤៩ | ១ ៩៥៤ | ២១៥ | ១ ៨៦៥ | ១៨៧ | ២២៣១ | ៤៩១ |
| ទន្តសាស្ត្រ | ២៩៦ | ៤៤ | ៣៨១ | ៧៧ | ៣៥៥ | ៧២ | ៤៨០ | ១២ | ៥៣៩ | ១៧ |
| បរិញ្ញាបត្រឱសថសាស្ត្រ | ១ ០៩៣ | ១៥២ | ៥៨៦ | ៩៥ | ៦១៥ | ១២៤ | ១ ៣៥៣ | ៣៣០ | ១ ៥៣២ | ៥០៦ |
| បរិញ្ញាបត្រគិលានុបដ្ឋាក | ២២៣ | ៣៧ | ៣២២ | ១២៤ | ២៦៨ | ១៨១ | ២៤៧ | ១០៧ | ៣៥៥ | ៦៣ |
| បរិញ្ញាបត្រឆ្មប | ៦០ | ២៨ | ២០៥ | ២ | ៤៤ | ៣៧ | ៤៧ | ៣៤ | ៤៧ | ៤៣ |
| បរិញ្ញាបត្រគិលានុបដ្ឋាក-ឆ្មប | ១៦ | ៥ | ៤៥ | ២៩ | ៨ | ១៨ | ៧ | ២ | ១៦ | ៤០ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| បរិញ្ញាបត្រគិលានុបដ្ឋាក ពាក់កណ្ដាលពេល | - | - | ១៩ | - | ៦១ | ១៧ | ៧១ | ២៨ | ១៣៧ | ៦៦ |
| បរិញ្ញាបត្រមន្ទីរ ពិសោធន៍ | - | - | - | - | - | - | - | - | ២២ | - |
| ឱសថការីមធ្យម | - | ៥៧៦ | - | - | - | ២៤ | - | - | - | - |
| បរិញ្ញាបត្ររងគិលា នុបដ្ឋាក | ៥៦៤ | ១៣៥២ | ៣៧០ | ២៧៧ | ៤៦៤ | ១០៧ | ៧៧៨ | ១២៨ | ១ ២៨៨ | ៣៣៤ |
| បរិញ្ញាបត្ររងឆ្មប | ១២៧ | ៧៤៣ | ២៨ | ៧៣ | ៣០ | ២៦ | ៨៧ | ៩ | ១៩៤ | ២៣ |
| បរិញ្ញាបត្ររងមន្ទីរ ពិសោធន៍ | ៧៦ | ២៤០ | ៣៥ | ៤៦ | ៥២ | ១៧ | ៧៩ | ១៨ | ១១៥ | ២៨ |
| បរិញ្ញាបត្ររងទន្តគិលា នុបដ្ឋាក | ១១១ | ១៣៨ | ៩៥ | ៦៧ | ១១៨ | ៤៥ | ១៩៦ | ៤៣ | ២៥០ | ៨៤ |
| សរុប | ៤ ៤៣០ | ៣ ៦៧៦ | ៤ ០៧៧ | ១ ១៣៩ | ៤ ១៥៩ | ៨៨៣ | ៥ ៣១៨ | ៩៣៧ | ៦ ៩៨៨ | ១៦៩៥ |

## ២.៦- ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

### ក្រសួងបានការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

- បានពង្រឹងគុណភាពវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ សំដៅអភិវឌ្ឍធនធានមនុស្សប្រកបដោយចំណេះដឹងនិងជំនាញបច្ចេកទេសវិជ្ជាជីវៈ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហកម្មនិងការធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជា ដោយដាក់ចេញនូវគោលដៅអាទិភាពស្តីពីការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៩-២០២៣ និងបានដាក់ចេញផែនការយុទ្ធសាស្ត្រសកម្មភាពការធ្វើទំនើបកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣ ផែនការមេសម្រាប់អភិវឌ្ឍន៍គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ២០២១-២០២៥។ ក្រសួងបានអនុវត្តគម្រោងសាកល្បងមូលនិធិជាតិអភិវឌ្ឍន៍ជំនាញដើម្បីលើកកម្ពស់ជំនាញ និងផលិតភាពពង្រីកការបណ្តុះបណ្តាលជំនាញរយៈពេលវែងសម្រាប់គាំទ្រវិស័យអាទិភាព រួមមានសំណង់ អគ្គិសនី មេកានិករថយន្ត កម្មន្តសាល និងធុរកិច្ច/ព័ត៌មានវិទ្យា។ ជាមួយនេះ ក្រសួងបានដាក់ឱ្យដំណើរការប្រព័ន្ធជាតិអ.ប.វ. ពីចម្ងាយ ឬតាមអនឡាញ(National TVET E-Learning Platform) ដើម្បីឆ្លើយតបទៅនឹងបរិបទនៃការបណ្តុះបណ្តាលក្នុងកំលុងពេលរីករាលដាលនៃជំងឺកូវីដ-១៩ និងភាពបត់បែននៃការបណ្តុះបណ្តាលក្នុងដំណាក់កាលឌីជីថលបនីយកម្ម។ ទន្ទឹមនេះ ក្រសួងបានកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីឱ្យការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ កាន់តែមានភាពទាក់ទាញដល់យុវជនដែលត្រៀមចូលទីផ្សារការងារឱ្យកាន់តែជ្រួតជ្រាបបន្ថែមទៀត ហើយក្រសួងក៏បានរៀបចំនូវគោលការណ៍ប្រតិបត្តិស្តង់ដា(SOP) សម្រាប់ដំណើរការគ្រឹះស្ថានអ.ប.វ. ឡើងវិញ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងនិងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅតាមគ្រឹះស្ថានអ.ប.វ.

- បានបង្កើនការវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាបន្តបន្ទាប់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃវិស័យឯកជន និងគាំទ្រដល់ដំណើរការនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច ដោយបានវិនិយោគលើការសាងសង់អគារក្រោម៣ជាន់ចំនួន១៦៨អគារ លើ៣ជាន់ចំនួន២៩អគារ រោងជាង និងមន្ទីរពិសោធន៍ចំនួន២៣៥ អន្តេវាសិកដ្ឋានចំនួន៣៧ និងការបំពាក់សម្ភារៈបរិក្ខារ។ ក្រសួងបានបន្តអភិវឌ្ឍកញ្ចប់ស្តង់ដាបណ្តុះបណ្តាលផ្អែកលើសមត្ថភាពចំនួ១៦៨គុណវុឌ្ឍិ លើ៧មុខរបរ(ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា កម្រិត១ ២ និងកម្រិត៣) សម្រាប់វិស័យសំណង់ អគ្គិសនី និងកម្មន្តសាល បានលើកកម្ពស់សមត្ថភាពគ្រូបច្ចេកទេស ទាំងផ្នែកជំនាញបច្ចេកទេសថ្មី និងវិធីសាស្ត្របណ្តុះបណ្តាលថ្មីផ្អែកលើសមត្ថភាព(CBT) ចំនួន ៨៥១នាក់ (ស្រី១៧៤នាក់) កម្មវិធីត្រឡប់ទៅឧស្សាហកម្មវិញ(IRS) ចំនួន៧០៦នាក់ (ស្រី៦៣នាក់) និងការបណ្តុះបណ្តាលក្រៅប្រទេសចំនួន១៥៣នាក់ (ស្រី ១៣នាក់)។ ការធានាគុណភាពបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈត្រូវបានពង្រឹងតាមរយៈការវាយតម្លៃគ្រឹះស្ថានបណ្តុះបណ្តាល ចំនួន៣៧ ដោយផ្អែកលើលក្ខណវិនិច្ឆ័យ៦ ដោយក្នុងនោះ គ្រឹះស្ថានចំនួន២៨ បានទទួលវិញ្ញាបនបត្របញ្ជាក់គុណភាពកម្រិតអន្តរជាតិ(ISO) និងបានបង្កើតមជ្ឈមណ្ឌលឧត្តមភាពចំនួន៤សម្រាប់ធ្វើជាគំរូ និងក្រុមប្រឹក្សាតាមវិស័យចំនួន៤សម្រាប់ផ្តល់ការពិគ្រោះយោបល់។ បានរួមចំណែកលើកកម្ពស់វិជ្ជាជីវៈវិស្វកម្មឱ្យកាន់តែល្អប្រសើរ ធានាឱ្យការប្រកបវិជ្ជាជីវៈវិស្វកម្មមានគុណភាព ប្រសិទ្ធភាព សុវត្ថិភាពនិងការទទួលខុសត្រូវខ្ពស់ ព្រមទាំងបានលើកស្ទួយគុណភាពវិស្វករកម្ពុជាឱ្យមានគោរមងារជាវិស្វករអាជីពជាតិនិងអន្តរជាតិ។

- បានបង្កើនកម្លាំងពលកម្មជំនាញបន្ថែម តាមរយៈការពង្រីកការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ដោយគ្រឹះស្ថានអ.ប.វ. ក្រោមឱវាទក្រសួងចំនួន១០៧ បានបណ្តុះបណ្តាល សិស្ស និស្សិត និងសិក្ខាកាមបញ្ចប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ សរុបចំនួន**២៧៣ ១៩៤នាក់** (ស្រី១២០ ១២៨នាក់) ក្នុងនោះ វគ្គខ្លីមានចំនួន**១៧១ ១៦៨នាក់** (ស្រី៨៤ ២៧០នាក់) និងវគ្គវែង ចំនួន**១០២ ០២៦នាក់**(ស្រី៣៥ ៨៥៨នាក់)។ ជាមួយនេះ ក្រសួងបានផ្តល់ការបណ្តុះបណ្តាលជំនាញឡើងវិញដល់កម្មករនិយោជិត ដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ក្រោមវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល សរុបចំនួន**១៤ ០០០នាក់** និងបានផ្តល់ឱកាសដល់ការហ្វឹកហ្វឺនកូនជាងចំនួន**១១៦ ៩៦៨នាក់** (ស្រី៨៥ ៧១៥នាក់) និងការចុះកម្មសិក្សា/ទស្សនកិច្ចសិក្សានៅតាមរោងចក្រ សហគ្រាស ដល់សិស្ស និស្សិតចំនួន**១៦ ១១៦នាក់** (ស្រី៤ ១០៨នាក់) បានធ្វើតេស្តទទួលស្គាល់ការសិក្សាដែលបានបញ្ចប់ពីមុន ចំនួន**១ ៣៩១នាក់** (ស្រី៦៤នាក់) ព្រមទាំងលទ្ធភាពក្នុងការពង្រីកការបណ្តុះបណ្តាលឆ្លើយតបតាមតម្រូវការទីផ្សារការងារ ដូចជានៅក្នុងតំបន់សេដ្ឋកិច្ចពិសេសជាដើម។ ទន្ទឹមនេះ ការយល់ដឹងពីសារៈសំខាន់នៃបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈកាន់តែត្រូវបានលើកកម្ពស់ ដោយក្រសួងបានរៀបចំទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ(TVET DAY) ចំនួន៥លើក ដែលមានអ្នកចូលរួមសរុបចំនួន**២៩៨ ២៧០នាក់** (ស្រី១១៣ ៧៩១នាក់)។ ក្រោមកម្មវិធីភាពជាដៃគូនេះ ក្រសួងបានសហការបង្កើតវិទ្យាស្ថានពហុបច្ចេកទេសមិត្តភាពកម្ពុជា ចិន នៅខេត្តព្រះសីហនុនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ និងចាប់ផ្តើមផ្តល់ការបណ្តុះបណ្តាលចាប់ពីឆ្នាំ២០១៨ លើមុខជំនាញមេកានិករថយន្ត អគ្គិសនី សំណង់ ព័ត៌មានវិទ្យា ទេសចរណ៍ បដិសណ្ឋារកិច្ច។

### ១- សិក្ខាកាម សិស្ស និស្សិតបានបញ្ចប់ការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថាន អ.ប.វ. សាធារណៈ ឯកជន និងអង្គការសមាគម(២០១៨ ២០២២) (គិតជានាក់)

| កម្រិត | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | | ២០២១-២០២២ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | បណ្ឌិតបច្ចេកវិទ្យា/ឯកទេស | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ២ | បរិញ្ញាបត្រជាន់ខ្ពស់បច្ចេកវិទ្យា/ឯកទេស | ៥១ | ៧ | ២១៣ | ៦១ | ១៧៧ | ៣៥ | ១១៧ | ២៥ | ២៦៤ | ៤០ |
| ៣ | បរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស សញ្ញាបត្រវិស្វករ | ៥ ៥២២ | ២ ២៣១ | ៥ ៨៨១ | ១ ៥៨៣ | ៥ ១៩៩ | ២ ៥៥១ | ៥ ១១៧ | ១ ៤៦១ | ៦ ៥៧៦ | ២ ០៧៩ |
| ៤ | សញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររងបច្ចេកទេស/ឯកទេស | ៤ ៩០៨ | ១ ៣៣៥ | ៥ ៨៨៤ | ១ ៧៦៤ | ៤ ៦៧៣ | ១ ៦២៦ | ៤ ៥៩៩ | ១ ០១៥ | ៦ ៥៦៧ | ១ ៤៧៤ |
| ៥ | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ (CQF4) | ៣៩៨ | ១៥៤ | ៥៩០ | ៩៦ | ៨៤០ | ២២២ | ៦៨៤ | ១៦៤ | ១ ៨៤៥ | ៥៩៨ |
| ៦ | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ២ (CQF3) | ៥១៣ | ១៥៦ | ១១៤១ | ៣៣៨ | ៩៨៦ | ២៥២ | ២១៤៣ | ៧០៣ | ២២០៥ | ៧៣២ |
| ៧ | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (CQF2) | ១ ៩៧៣ | ៥៨៦ | ២ ៥៦៤ | ៧៥២ | ៣ ២០៥ | ១០៣២ | ១២៨៤៧ | ៥៧៣៣ | ១៤៤៦១ | ៧ ០៥៣ |
| ៨ | វិញ្ញាបនបត្រវិជ្ជាជីវៈ | ៣៨ ៨៨៧ | ២១ ២៤៩ | ៤៦ ១៣៨ | ២៣ ៤០៦ | ៣៦ ២២១ | ១៧ ៨១៧ | ២៥ ១៨៧ | ១២ ៨៥១ | ២៤ ៧៣៥ | ៨ ៩៤៧ |
| សរុបរួម | | ៥២ ២៥២ | ២៥ ៧១៨ | ៦២ ៣៤៨ | ២៨ ០០០ | ៥១ ២៥១ | ២៣ ៥៣៥ | ៥០ ៦៩០ | ២១ ៩៥២ | ៥៦ ៦៥៣ | ២០ ៩២៣ |

### ២- ចំនួនសិក្ខាកាមដែលបានទទួលការបណ្តុះបណ្តាលរយៈពេលខ្លី (គិតជានាក់)

| កម្រិត | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | វិញ្ញាបនបត្រវិជ្ជាជីវៈ | ៣៨ ៨៨៧ | ២១ ២៤៩ | ៤៦ ១៣៨ | ២៣ ៤០៦ | ៣៦ ២២១ | ១៧ ៨១៧ | ២៥ ១៨៧ | ១២ ៨៦១ | ២៤ ៧៣៥ | ៨ ៩៤៧ |
| ១.១ | កម្មវិធីស្ពានចម្លងបន្តជំនាញ | ២ ៥២១ | ៧៩៥ | ២ ៤៦៤ | ១ ០៦៦ | ៣ ៤០០ | ១ ៥៥០ | ១ ៥៥២ | ៧០៩ | ១០០ | ១៥ |
| ១.២ | កម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ | ១១ ៣៣៥ | ៦ ៧០១ | ២៣ ៩៤៧ | ១៣ ៤២៧ | ១២ ៤០៣ | ៦ ៨៣៨ | ២ ៨២១ | ២ ២៥៩ | ០ | ០ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ១.៣ | ការបណ្តុះបណ្តាលតាមកម្មវិធីបឹប | ០ | ០ | ០ | ០ | ២០៥ | ៧៥ | ១២០ | ៣៧ | ១១២ | ៣៥ |
| ១.៤ | កម្មវិធីបណ្តុះបណ្តាលភាពជាដៃគូរវាងរដ្ឋឯកជន | ០ | ០ | ០ | ០ | ៤៨៦ | ៣៤ | ៩៦៧ | ៣២៩ | ៩១៥ | ៩០ |
| ១.៥ | កម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី (១សប្តាហ៍ ៤ខែ) | ២៥០៣១ | ១៣៧៥៣ | ១៩៧២៧ | ៨ ៩១៣ | ១ ៧២៧ | ៩ ៣២០ | ១៩៧២៧ | ៩៥១៧ | ២៣៦០៨ | ៨ ៨០៨ |

**៣- ការធ្វើអធិការកិច្ចហ្វឹកហ្វឺនកូនជាង** (គិតជានាក់)

| ល.រ | បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុបរួម |
|---|---|---|---|---|---|---|---|---|
| ១ | ចំនួនសហគ្រាសបានចុះអធិការកិច្ចហ្វឹកហ្វឺនកូនជាង | សហគ្រាស | ៣៨៣ | ៦៧២ | ០ | ០ | ០ | **១០៥៥** |
| ២ | ចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន | សហគ្រាស | ៥៣១ | ៥៨៤ | ៤៣៣ | ៤៧៨ | ៥៥២ | **២៥៧៨** |
| ៣ | ចំនួនកូនជាងត្រូវបានហ្វឹកហ្វឺន | ក្រុមហ៊ុន | ៥៣១ | ៥៨៤ | ៤៣៣ | ៤៧៨ | ៥៥២ | **២៥៧៨** |
| | | សរុប | ២៧ ៧០០ | ២៥ ៨៣៥ | ១៨ ៤០៦ | ២១ ៣១៩ | ២៣ ៧០៨ | ១១៦ ៩៦៨ |
| | | ស្រី | ១៩ ៨៤៦ | ១៩ ៣៥៣ | ១៣ ៨៧៨ | ១៥ ៥៧២ | ១៧ ០៦៦ | **៨៥ ៧១៥** |
| ៤ | ធ្វើតេស្តកូនជាងបានហ្វឹកហ្វឺនចប់ | ក្រុមហ៊ុន | ៥៣១ | ៥៨៤ | ៤៣៣ | ៤៧៨ | ៥៥២ | **២៥៧៨** |
| | | សរុប | ១០ ៨៩៧ | ២៥ ៨៣៥ | ១៨ ៤០៦ | ២១ ៣១៩ | ២៣ ៧០៨ | **១០០ ១៦៥** |
| | | ស្រី | ៧ ៧៥៩ | ១៩ ៣៥៣ | ១៣ ៨៧៨ | ១៥ ៥៧២ | ១៧ ០៦៦ | **៧៣ ៦២៨** |
| ៥ | ផ្តល់វិញ្ញាបនបត្រនិងបានទទួលស្គាល់ជំនាញ | ក្រុមហ៊ុន | ៥០១ | ៥៤៧ | ៥៤៩ | ៤៧៨ | ៥៥២ | **២៦២៧** |
| | | សរុប | ២៥ ៦៣៣ | ២៩ ៦៦៩ | ២២ ៨៦៨ | ២១ ៣១៩ | ២៣ ៧០៨ | **១២៣ ១៩៧** |
| | | ស្រី | ១៩ ០៥០ | ២៥ ០៧១ | ១៩ ០៥០ | ១៥ ៥៧២ | ១៧ ០៦៦ | **៩៥ ៨០៩** |

## ២.៧- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

បានអប់រំបណ្តុះបណ្តាលធនធានមនុស្សដើម្បីគាំទ្រដល់ការអភិរក្ស លើកស្ទួយនិងអភិវឌ្ឍវប្បធម៌ជាតិ សរុបចំនួន១៣ ៣៥៦នាក់ (ស្រី ៣ ៧១៧នាក់) ក្នុងនោះរួមមាន៖

- ផ្នែកអភិរក្សវប្បធម៌មានចំនួន៣ ០៧០នាក់(ផ្នែកវប្បធម៌អរូបីចំនួន២ ២២១នាក់)
- ផ្នែកអភិវឌ្ឍវប្បធម៌មានចំនួន៥ ៣១៨នាក់(ផ្នែកវប្បធម៌អរូបីចំនួន៣ ៦៩៩ នាក់)
- ការបណ្តុះបណ្តាលរយៈពេលវែងមានចំនួន២ ៧២៥នាក់(កម្រិតឧត្តមចំនួន២ ០០៧នាក់ និងកម្រិតមធ្យមចំនួន៧១៨នាក់)
- ការបណ្តុះបណ្តាលរយៈពេលខ្លីមានចំនួន១០ ៦៣១នាក់
- ជំនាញដែលបានបណ្តុះបណ្តាលរួមមានកម្មវិធីអប់រំបេតិកភណ្ឌ សម្រាប់កុមារនៅសាលាបឋមសិក្សានិងអនុវិទ្យាល័យនានាក្នុងឧទ្យានអង្គរ វគ្គបណ្តុះបណ្តាលនៅការដ្ឋាននិងនៅប្រទេសកូរ៉េ វគ្គបណ្តុះបណ្តាលផ្នែករៀបចំប្លង់និងអភិរក្សនៅតាមប្រាសាទ វគ្គបណ្តុះបណ្តាលអំពីការប្រើម៉ាស៊ីនGPS និងការបង្ហោះដ្រូន វិធានការនិងការការពារសកម្មភាពទន្រ្ទានទីទួលបុរាណ ការជីកកកាយ ការទប់ស្កាត់អំពើចោរកម្ម និងជួញដូរសម្បត្តិវប្បធម៌ដោយខុសច្បាប់ ការអភិរក្សប្រាសាទឥដ្ឋនៅតំបន់ប្រាសាទសំបូរព្រៃគុក ការរៀបចំផែនការមេសម្រាប់កិច្ចអភិរក្សប្រាសាទបុរាណ វគ្គបណ្តុះបណ្តាលស្តីពីការពិសោធន៍វិទ្យាសាស្ត្រ លើការងារអភិរក្ស

ក្បាច់បាត របាំប្រពៃណីនិងរបាំបុរាណ ក្បាច់ហ្គូន ល្ខោនបាសាក់ ឆៃយ៉ាំ ចម្លាក់ឈើ ជំនាញធ្វើមេដំបែ និងបិតស្រាពាង ជំនាញត្បាញសាស់(ឆាស់)។ល។

ចំនួនធនធានមនុស្សដែលបានអប់រំបណ្តុះបណ្តាលដើម្បីអភិរក្ស លើកស្ទួយនិងអភិវឌ្ឍវប្បធម៌ជាតិ




ប្រភព៖ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ឆ្នាំ២០២២

## ២.៨- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

### ១- ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ

| ឆ្នាំ | វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រវងសុរិយោដី | វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រវងរៀបចំដែនដី |
|---|---|---|
| ២០១៨ | ជំនាន់ទី៩ មានចំនួន៣៤នាក់ (ស្ត្រី៣នាក់) | ជំនាន់ទី៣ មានចំនួន១៨នាក់/ស្ត្រី១នាក់ |
| ២០១៩ | ជំនាន់ទី១០ មានចំនួន១៩នាក់ (ស្ត្រី១នាក់) | - |
| ២០២០ | ជំនាន់ទី១១ មានចំនួន៣៣នាក់ (ស្ត្រី៥នាក់) | - |
| ២០២១ | - | - |
| ៩ខែ ២០២២ | ជំនាន់ទី១២ មានចំនួន៣៥នាក់ (ស្ត្រី៣នាក់) | - |
| **សរុប** | **៤វគ្គ សិក្ខាកាមសរុប១២១នាក់ (ស្ត្រី១២នាក់)** | **១វគ្គ សិក្ខាកាមសរុប១៨នាក់ (ស្ត្រី១នាក់)** |

គិតពីចាប់ផ្តើមអនុវត្តដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បាន៖ ១- បើកវគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រវងសុរិយោដីចំនួន១២វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន៣៩៤នាក់ (ស្ត្រី៤០នាក់) និង២- វគ្គបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រវងរៀបចំដែនដីចំនួន៣វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន៧៤នាក់ (ស្ត្រី៣នាក់)។

### ២- ការងារបណ្តុះបណ្តាលនិងការអប់រំផ្សព្វផ្សាយ (រយៈពេលខ្លី)

| ឆ្នាំ | ចំនួនវគ្គ | ចំនួនអ្នកចូលរួម (នាក់) |
|---|---|---|
| ២០១៨ | ៧២ | ៩ ២៨៣ |
| ២០១៩ | ៨២ | ១៥ ៦៧៦ |
| ២០២០ | ២៤ | ៧ ៧៥២ |
| ២០២១ | ៣ | ៨១៥ |
| ៩ខែ ២០២២ | ២២ | ២ ៤៧១ |
| សរុប | ២០៣ | ៣៥ ៩៩៧ |

គិតពីចាប់ផ្តើមអនុវត្តដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានបើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា ផ្សព្វផ្សាយអំពីច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារជំនាញរបស់ក្រសួងបានចំនួន ២ ០៣៧វគ្គ មានអ្នកចូលរួមសរុបចំនួន១៦៧ ៥០៨រូប (ស្ត្រី៦ ០២៥រូប)។

## ២.៩- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ក- សាកលវិទ្យាល័យភូមិន្ទកសិកម្ម

**ស្ថិតិនិស្សិតសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទកសិកម្មតាមមហាវិទ្យាល័យតាមឆ្នាំនីមួយៗ** (គិតជានាក់)

| ល.រ. | មហាវិទ្យាល័យ | ឆ្នាំ | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៧ | | ២០១៨ | | ២០១៩ | |
| ក. | ថ្នាក់បរិញ្ញាបត្រ | **សរុប** | **ស្រី** | **សរុប** | **ស្រី** | **សរុប** | **ស្រី** |
| ១ | កសិកម្ម | ៩៦៧ | ៣០០ | ៧០៩ | ២៤៩ | ៨១២ | ២៩៨ |
| ២ | កៅស៊ូ | ៥៧ | ១៥ | ៣៨ | ២០ | ២៩ | ១៩ |
| ៣ | វិទ្យាសាស្ត្រសត្វ | ១៨២ | ៤៦ | ១៦៤ | ៣២ | ១៦២ | ៤០ |
| ៤ | វេជ្ជសាស្ត្រសត្វ | ៨៥៦ | ១៦៩ | ៦២៥ | ១៤២ | ៥៥៩ | ១៤៥ |
| ៥ | ព្រៃឈើ | ៦៩ | ២៨ | ៦៥ | ២៨ | ៨៦ | ៣៥ |
| ៦ | ជលផល | ៨៧ | ៣០ | ១០០ | ៣៦ | ១០៩ | ៤៧ |
| ៧ | វិស្វកម្មកសិកម្ម | ១១៤ | ២១ | ១០៣ | ២៣ | ៩៩ | ២៤ |
| ៨ | កសិ-ឧស្សាហកម្ម | ៤៩៤ | ២៩៩ | ៤៥៦ | ២៨៥ | ៥៤៨ | ៣៤០ |
| ៩ | សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ | ៣៤០ | ១៣៦ | ២៣៥ | ១១១ | ២១០ | ១០០ |
| ១០ | រៀបចំដែនដីនិងរដ្ឋបាលដីធ្លី | ១៨១ | ៥៨ | ២២២ | ៨០ | ៣៣៥ | ១២១ |
| ខ. | ថ្នាក់បរិញ្ញាបត្ររង | ១៥៣ | ៤២ | ១៣៧ | ៣១ | ១៣៥ | ៤២ |
| គ. | ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ | ១១១ | ៤០ | ៤៤ | ១៦ | ៤០ | ១៥ |
| ឃ. | ថ្នាក់បណ្ឌិត | ២៧ | ៣ | ២៦ | ៣ | ៣៣ | ៣ |
| **សរុប** | | **៣ ៦៣៨** | **១ ១៨៧** | **៣ ០១៣** | **១ ០៥៦** | **៣ ១៥៧** | **១ ២២៩** |

| ល.រ. | មហាវិទ្យាល័យ | ឆ្នាំ | | | | ស្ថិតិនិស្សិតសរុប | |
|---|---|---|---|---|---|---|---|
| | | ២០២០ | | ២០២១ | | | |
| ក | ថ្នាក់បរិញ្ញាបត្រ | **សរុប** | **ស្រី** | **សរុប** | **ស្រី** | **សរុប** | **ស្រី** |
| ១ | កសិកម្ម | ៨៤៣ | ៣០៦ | ៩៤៩ | ៣៥៩ | ៤ ៣៦៩ | ១ ៥១០ |
| ២ | កៅស៊ូ | ២៦ | ១៨ | ១១ | ៦ | ១៦១ | ៧៨ |
| ៣ | វិទ្យាសាស្ត្រសត្វ | ១៨០ | ៣៧ | ២៧៦ | ៦២ | ៩៦៤ | ២១៧ |
| ៤ | វេជ្ជសាស្ត្រសត្វ | ៥៦៨ | ១៤៩ | ៦៧១ | ១៩៦ | ៣ ២៧៩ | ៨០១ |
| ៥ | ព្រៃឈើ | ៧៣ | ៣៣ | ៥៥ | ៣១ | ៣៤៨ | ១៥៥ |
| ៦ | ជលផល | ១០២ | ៤៧ | ៨៨ | ៣៤ | ៤៨៦ | ១៩៤ |
| ៧ | វិស្វកម្មកសិកម្ម | ៩៨ | ៣៦ | ៧៤ | ១៥ | ៤៨៨ | ១១៩ |
| ៨ | កសិឧស្សាហកម្ម | ៥៣៤ | ៣៤៣ | ៥២១ | ៣៤១ | ២ ៥៥៣ | ១ ៦០៨ |
| ៩ | សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ | ១៩៤ | ៩៨ | ១៤៦ | ៧៣ | ១ ១២៥ | ៥១៨ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១០ | រៀបចំដែនដីនិងរដ្ឋបាលដីធ្លី | ៤៩៧ | ១៩២ | ៥៩១ | ២៣៤ | ១ ៨២៦ | ៦៨៥ |
| ខ | ថ្នាក់បរិញ្ញាបត្ររង | ១៣៥ | ៥៦ | ៧៤ | ២៧ | ៦៣៤ | ១៩៨ |
| គ | ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ | ៩០ | ៣០ | ១៦៧ | ៥២ | ៤៥២ | ១៥៣ |
| ឃ | ថ្នាក់បណ្ឌិត | ៣០ | ២ | ៣៣ | ៦ | ១៤៩ | ១៧ |
| សរុប | | ៣ ៣៧០ | ១ ៣៤៧ | ៣ ៦៥៦ | ១ ៤៣៤ | ១៦ ៨៣៤ | ៦ ២៥៣ |

## ស្ថិតិនិស្សិតបញ្ចប់ការសិក្សាដោយជោគជ័យ តាមមហាវិទ្យាល័យនិងតាមឆ្នាំនីមួយៗ (គិតជានាក់)

| ល.រ. | មហាវិទ្យាល័យ | ឆ្នាំ | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៧ | | ២០១៨ | | ២០១៩ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ក- ថ្នាក់បរិញ្ញាបត្រ | | | | | | | |
| ១ | កសិកម្ម | ២២៥ | ៧៣ | ១២០ | ២៥ | ១៧៦ | ៦៩ |
| ២ | កៅស៊ូ | ៣១ | ៤ | ១២ | ៣ | ១ | ០ |
| ៣ | វិទ្យាសាស្ត្រសត្វ | ៣៦ | ១០ | ៣៣ | ៥ | ៣១ | ៨ |
| ៤ | វេជ្ជសាស្ត្រសត្វ | ២០៦ | ៤៩ | ១៣៣ | ៣២ | ១៤២ | ៣២ |
| ៥ | ព្រៃឈើ | ២៦ | ១១ | ០ | ០ | ១៦ | ៨ |
| ៦ | ជលផល | ១៥ | ៦ | ៩ | ៦ | ២២ | ៩ |
| ៧ | វិស្វកម្មកសិកម្ម | ២៥ | ៤ | ១៣ | ៣ | ១៨ | ៣ |
| ៨ | កសិឧស្សាហកម្ម | ៨៥ | ៤៧ | ៦៧ | ៤៤ | ៨៩ | ៥៣ |
| ៩ | សេដ្ឋកិច្ចកសិកម្ម-អភិវឌ្ឍន៍ជនបទ | ៨៥ | ៣៤ | ៤៧ | ១៦ | ៦៤ | ៣៤ |
| ១០ | រៀបចំដែនដីនិងរដ្ឋបាលដីធ្លី | ៣៥ | ៥ | ២៦ | ៩ | ២៩ | ១២ |
| ខ | ថ្នាក់បរិញ្ញាបត្ររង | ៤៣ | ៩ | ៣៦ | ១២ | ២២ | ៦ |
| គ | ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ | ១៣ | ៣ | ២២ | ៤ | ១៧ | ៦ |
| ឃ | ថ្នាក់បណ្ឌិត | ០ | ០ | ០ | ០ | ០ | ០ |
| **សរុប** | | **៨២៥** | **២៥៥** | **៥១៨** | **១៥៩** | **៦២៧** | **២៤០** |

| ល.រ. | មហាវិទ្យាល័យ | ឆ្នាំ | | | | ស្ថិតិនិស្សិតសរុប | |
|---|---|---|---|---|---|---|---|
| | | ២០២០ | | ២០២១ | | | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ក- ថ្នាក់បរិញ្ញាបត្រ | | | | | | | |
| ១ | កសិកម្ម | ១៧៩ | ៦១ | ២០២ | ៧៧ | ៩០២ | ៣០៥ |
| ២ | កៅស៊ូ | ៥ | ៤ | ៥ | ៤ | ៥៤ | ១៥ |
| ៣ | វិទ្យាសាស្ត្រសត្វ | ៣០ | ៨ | ៣០ | ៧ | ១៦៩ | ៣៨ |
| ៤ | វេជ្ជសាស្ត្រសត្វ | ១២៤ | ៣៦ | ១៣១ | ៣៥ | ៧៣៦ | ១៨៤ |
| ៥ | ព្រៃឈើ | ១៤ | ៤ | ១៩ | ១១ | ៧៥ | ៣៤ |
| ៦ | ជលផល | ១៤ | ៧ | ១៤ | ៦ | ៧៤ | ៣៤ |
| ៧ | វិស្វកម្មកសិកម្ម | ១៧ | ៥ | ២១ | ៣ | ៩៤ | ១៨ |
| ៨ | កសិឧស្សាហយកម្ម | ១១៥ | ៦៧ | ១២៨ | ៧១ | ៤៨៤ | ២៨២ |
| ៩ | សេដ្ឋកិច្ចកសិកម្ម-អភិវឌ្ឍន៍ជនបទ | ៤៧ | ២៥ | ៥៣ | ២៦ | ២៩៦ | ១៣៥ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១០ | រៀបចំដែនដីនិងរដ្ឋបាលដីធ្លី | ៦៣ | ២០ | ៧០ | ២១ | ២២២ | ៦៧ |
| ខ | ថ្នាក់បរិញ្ញារង | ២៨ | ១០ | ២០ | ៦ | ១៤៩ | ៤៣ |
| គ | ថ្នាក់បរិញ្ញាជាន់ខ្ពស់ | ៤៨ | ២០ | ១៧ | ៨ | ១១៧ | ៤១ |
| ឃ | ថ្នាក់បណ្ឌិត | ២ | ០ | ៣ | ០ | ៥ | ០ |
| **សរុប** | | **៦៨៥** | **២៦៧** | **៧១៣** | **២៧៥** | **៣ ៣៦៨** | **១ ១៩៦** |

## ខ- វិទ្យាស្ថានជាតិកសិកម្ម កំពង់ចាម

### ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្ររង បច្ចេកទេសកសិកម្ម(អាហារូបករណ៍)ឆ្នាំ២០១៧-២០២១ (គិតជានាក់)

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | វិទ្យាសាស្ត្រកសិកម្ម | ៣១ | ១៧ | ៣៤ | ១៦ | ៤១ | ២០ | ១៦ | ១០ |
| ២ | វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | ៤១ | ៩ | ៣៣ | ៧ | ៣៦ | ៩ | ១១ | ៤ |
| ៣ | វិទ្យាសាស្ត្រដំណាំកៅស៊ូ | ១៦ | ៦ | ៩ | ៣ | ៣ | ១ | ១ | ១ |
| ៤ | វិទ្យាសាស្ត្រជលផល | ២១ | ១០ | ១០ | ៤ | ៨ | ២ | ២ | ២ |
| ៥ | សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម | ២៥ | ១០ | ២២ | ៩ | ១៨ | ៦ | ៨ | ៤ |
| **សរុបរួម** | | **១៣៤** | **៥២** | **១០៨** | **៣៩** | **១០៦** | **៣៨** | **៣៨** | **២១** |

### ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្ររង បច្ចេកទេសកសិកម្ម(បង់ថ្លៃ)ឆ្នាំ២០១៧-២០២១ (គិតជានាក់)

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | វិទ្យាសាស្ត្រកសិកម្ម | ០ | ០ | ១០ | ៣ | ២ | ១ | ៥ | ៣ |
| ២ | វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ | ២៣ | ២ | ០ | ០ | ០ | ០ | ៤ | ២ |
| ៣ | វិទ្យាសាស្ត្រដំណាំកៅស៊ូ | ០ | ០ | ០ | ០ | ០ | ០ | 0 | 0 |
| ៤ | វិទ្យាសាស្ត្រជលផល | ០ | ០ | ០ | ០ | ០ | ០ | 0 | 0 |
| ៥ | សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម | ០ | ០ | ០ | ០ | ០ | ០ | 0 | 0 |
| **សរុបរួម** | | **២៣** | **២** | **១០** | **៣** | **២** | **១** | **៩** | **៥** |

### ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រកសិកម្ម (អាហារូបករណ៍)ឆ្នាំ២០១៧-២០២១ (គិតជានាក់)

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | វិទ្យាសាស្ត្រកសិកម្ម | ៩១ | ៦០ | ១២៧ | ៧៦ | ១៦៦ | ៨៣ | ១៧៤ | ៩៥ |
| ២ | វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ | ១១៤ | ៤៣ | ១០៥ | ១២ | ១០០ | ២៧ | ១៣០ | ៣៧ |
| ៣ | វិទ្យាសាស្ត្រដំណាំកៅស៊ូ | ២២ | ១១ | ១៣ | ៥ | ១១ | ៥ | ៤ | ៣ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៤ | វិទ្យាសាស្ត្រជលផល | ៤២ | ២១ | ៣៤ | ១៧ | ២៧ | ៩ | ២៥ | ១៣ |
| ៥ | សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម | ៧០ | ៤៣ | ៩១ | ៦២ | ១១៣ | ៦១ | ៧៨ | ៤៨ |
| សរុបរួម | | ៣៣៩ | ១៧៨ | ៣៧០ | ១៧២ | ៤១៧ | ១៨៥ | ៤១១ | ១៩៦ |

## ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម(បង់ថ្លៃ) ពីឆ្នាំ២០១៧-២០២១ (គិតជានាក់)

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | វិទ្យាសាស្ត្រកសិកម្ម | ១៧ | ១០ | ៤៤ | ២០ | ៨១ | ៣៧ | ៦០ | ២៨ |
| ២ | វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | ៥៩ | ១០ | ៩៧ | ១៨ | ៩០ | ១៦ | ៥៥ | ១២ |
| ៣ | វិទ្យាសាស្ត្រដំណាំកៅស៊ូ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៤ | វិទ្យាសាស្ត្រជលផល | ៧ | ៣ | ២១ | ១០ | ២០ | ៩ | ១៥ | ៧ |
| ៥ | សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម | ៨ | ៦ | ៩ | ៦ | ៣ | ០ | ០ | ០ |
| សរុបរួម | | ៩១ | ២៩ | ១៧១ | ៥៤ | ១៩៤ | ៦២ | ១៣០ | ៤៧ |

## ស្ថិតិនិស្សិតបញ្ចប់ការសិក្សាពីឆ្នាំ២០១៧-២០២១ (គិតជានាក់)

| ល.រ. | កម្រិត | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | និស្សិតថ្នាក់បរិញ្ញាបត្ររង បច្ចេកទេសកសិកម្ម | ៣៣ | ១៥ | ៤៣ | ១៦ | ៤២ | ១៥ | ១៨ | ១១ |
| ២ | និស្សិតថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រកសិកម្ម | ១៤១ | ៥៤ | ៧៨ | ២៩ | ៩៧ | ៣៩ | ១៤៣ | ៥៧ |
| សរុបរួម | | ១៧៤ | ៦៩ | ១២១ | ៤៥ | ១៣៩ | ៥៤ | ១៦១ | ៦៨ |

## ស្ថិតិមន្ត្រីរាជការ សាស្ត្រាចារ្យនិងគ្រូបង្រៀនឆ្នាំ២០១៧-២០២១ (គិតជានាក់)

| ល.រ. | មន្ត្រីរាជការ សាស្ត្រាចារ្យ និងគ្រូបង្រៀន | ឆ្នាំបំពេញការងារ | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | ថ្នាក់ដឹកនាំ/មន្ត្រីរាជការ | ៥៣ | ១៤ | ៥៦ | ១៦ | ៥៧ | ១៦ | ៦០ | ១៦ |
| ២ | មន្ត្រីជាប់កិច្ចសន្យា/ពលករ អណ្តែត | ១៦ | ៦ | ២១ | ៧ | ២១ | ៧ | ២១ | ៧ |
| ៣ | សាស្ត្រាចារ្យ/គ្រូបង្រៀនទាំង ក្នុងនិងក្រៅអង្គភាព | ១៥៣ | ១៧ | ១៥៤ | ១៩ | ១៥៤ | ១៩ | ១៥៩ | ៤២ |

## គ- វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

### ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្ររង (អាហារូបករណ៍) ឆ្នាំ២០១៧-២០២១ (គិតជានាក់)

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | ក្សេត្រសាស្ត្រ | ២៥ | ៧ | ២៦ | ១៥ | ១៥ | ៦ | ៦ | ២ |
| ២ | ផលិតកម្មនិងបសុព្យាបាល | ២០ | ៥ | ១៤ | ៥ | ៩ | ៥ | ១០ | ៥ |
| ៣ | ជលផល | ១៣ | ៨ | ៥ | ៣ | ១១ | ៦ | ៥ | ៣ |
| ៤ | រុក្ខកម្ម | ១៧ | ៩ | ៩ | ១ | ១ | ០ | ០ | ០ |
| ៥ | សាកវប្បកម្ម | ២ | ២ | ០ | ០ | ០ | ០ | ០ | ០ |
| ៦ | សេដ្ឋកិច្ចកសិកម្ម | ៣ | ២ | ១ | ០ | ០ | ០ | ០ | ០ |
| ៧ | កែច្នៃអាហារ | ៣ | ២ | ០ | ០ | ០ | ០ | ០ | ០ |
| ៨ | សុរិយោដីនិងការគ្រប់គ្រងដី | ៦ | ២ | ៩ | ៣ | ៧ | ០ | ៥ | ០ |
| ៩ | ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ | ៦ | ៥ | ៥ | ៤ | ១ | ១ | ០ | ០ |
| ១០ | វិស្វកម្មកសិកម្ម | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| សរុបរួម | | **៩៦** | **៤២** | **៦៩** | **៣១** | **៤៤** | **១៨** | **២៦** | **១០** |

### ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្ររង (សិក្សាបង់ថ្លៃ)ឆ្នាំ២០១៧-២០២១ (គិតជានាក់)

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | ក្សេត្រសាស្ត្រ | ២៨ | ៧ | ២១ | ៦ | ២២ | ៥ | ១៥ | ២ |
| ២ | ផលិតកម្មនិងបសុព្យាបាល | ៥៤ | ៧ | ៥២ | ១០ | ១៦ | ៤ | ៥ | ៣ |
| ៣ | ជលផល | ៤ | ៨ | ១ | ០ | ៣ | ០ | ០ | ០ |
| ៤ | រុក្ខកម្ម | ៤ | ៩ | ២ | ១ | ១ | ១ | ០ | ០ |
| ៥ | សាកវប្បកម្ម | ២ | ២ | ០ | ០ | ០ | ០ | ០ | ០ |
| ៦ | សេដ្ឋកិច្ចកសិកម្ម | ៦ | ២ | ៣ | ២ | ០ | ០ | ០ | ០ |
| ៧ | កែច្នៃអាហារ | ១ | ២ | ០ | ០ | ០ | ០ | ០ | ០ |
| ៨ | សុរិយោដីនិងការគ្រប់គ្រងដី | ១៨ | ៦ | ៤៤ | ១២ | ២០ | ២ | ៥៦ | ១២ |
| ៩ | ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ | ៤ | ៥ | ៤ | ១ | ១ | ១ | ០ | ០ |
| ១០ | វិស្វកម្មកសិកម្ម | ០ | ០ | ១ | ០ | ០ | ០ | ០ | ០ |
| សរុបរួម | | **១២១** | **៣៣** | **១២៨** | **៣២** | **៦៣** | **១៣** | **៨២** | **១៧** |

### ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រ (អាហារូបករណ៍)ឆ្នាំ២០១៧-២០២១ (គិតជានាក់)

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | វិទ្យាសាស្ត្រកសិកម្ម | ៤៨ | ២១ | ៦២ | ២៩ | ៥២ | ២៩ | ៧៤ | ៤៣ |
| ២ | វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | ៤៦ | ១២ | ២៤ | ៩ | ០ | ០ | ១០ | ២ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣ | វិទ្យាសាស្ត្រសត្វ | ០ | ០ | ១១ | ៥ | ៣៤ | ១២ | ៣៦ | ១៧ |
| ៤ | វេជ្ជសាស្ត្រសត្វ | ០ | ០ | ១៦ | ៧ | ៣០ | ១៥ | ៥២ | ២១ |
| ៥ | វិទ្យាសាស្ត្រជលផល | ៣៥ | ១២ | ៣៩ | ១៩ | ៣៤ | ១៦ | ៣៩ | ១៧ |
| ៦ | វិទ្យាសាស្ត្រព្រៃឈើ | ១៩ | ១០ | ២៤ | ១៣ | ២៩ | ២០ | ២៥ | ១៨ |
| ៧ | សាកវប្បកម្ម | ២១ | ១៣ | ២១ | ១៥ | ១៨ | ៨ | ៣៥ | ១៧ |
| ៨ | សេដ្ឋកិច្ចកសិកម្ម | ៣៧ | ១៨ | ៤៦ | ២០ | ៤៧ | ២៥ | ៤៣ | ២២ |
| ៩ | កែច្នៃអាហារ | ៣៦ | ២៣ | ៤២ | ២៧ | ៦៤ | ៤៥ | ៥០ | ៣៤ |
| ១០ | សុរិយោដីនិងការគ្រប់គ្រងដី | ៤១ | ១៣ | ៦៨ | ២០ | ៨២ | ៣៦ | ៨៦ | ៣០ |
| ១១ | ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ | ៣៩ | ២១ | ៥០ | ២៩ | ៤៤ | ២៦ | ៣១ | ២១ |
| ១២ | វិស្វកម្មកសិកម្ម | ១២ | ១ | ១០ | ១ | ២៣ | ១០ | ៧ | ១ |
| ១៣ | អាហារូបត្ថម្ភនិងសុខភាព | ១៥ | ១២ | ១០ | ៦ | ៩ | ៦ | ០ | ០ |
| ១៤ | កុំព្យូទ័រ | ១០ | ១ | ៨ | ១ | ១៨ | ៦ | ១៣ | ៣ |
| ១៥ | សេដ្ឋកិច្ចនយោបាយនិងស្បៀង | ៩ | ៣ | ៩ | ៤ | ១១ | ៤ | ៨ | ៣ |
| ១៦ | ភាសាអង់គ្លេស | ៨ | ៧ | ១១ | ១០ | ១២ | ៥ | ៤ | ២ |
| ១៧ | មីក្រូហិរញ្ញវត្ថុ | ៨ | ៣ | ១០ | ៦ | ១១ | ៤ | ២ | ០ |
| ១៨ | ធុរកិច្ចកសិកម្ម | ០ | ០ | ០ | ០ | ៥ | ៣ | ០ | ០ |
| **សរុបរួម** | | **៣៨៤** | **១៧០** | **៤៦១** | **២២១** | **៥២៣** | **២៧០** | **៥១៥** | **២៥១** |

**ស្ថិតិនិស្សិតសិក្សាថ្នាក់បរិញ្ញាបត្រ (សិក្សាបង់ថ្លៃ)ឆ្នាំ២០១៧-២០២១** (គិតជានាក់)

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | វិទ្យាសាស្ត្រកសិកម្ម | ៨៨ | ៣០ | ៦២ | ២៤ | ៤៤ | ១៤ | ៤៣ | ១៣ |
| ២ | វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ | ១០៥ | ២២ | ៨២ | ១៦ | ៥២ | ៩ | ៤១ | ៩ |
| ៣ | វិទ្យាសាស្ត្រសត្វ | ០ | ០ | ១ | ០ | ៣០ | ៧ | ៩ | ១ |
| ៤ | វេជ្ជសាស្ត្រសត្វ | ០ | ០ | ៣ | ២ | ៩ | ២ | ២៥ | ៤ |
| ៥ | វិទ្យាសាស្ត្រជលផល | ២ | ១ | ១២ | ៦ | ៧ | ៥ | ៦ | ២ |
| ៦ | វិទ្យាសាស្ត្រព្រៃឈើ | ៥ | ០ | ៩ | ៤ | ១១ | ៤ | ៦ | ១ |
| ៧ | សាកវប្បកម្ម | ២ | ១ | ៣ | ២ | ២ | ១ | ៥ | ១ |
| ៨ | សេដ្ឋកិច្ចកសិកម្ម | ១ | ០ | ៤ | ២ | ៦ | ២ | ៤ | ១ |
| ៩ | កែច្នៃអាហារ | ៨ | ២ | ៧ | ៣ | ៦ | ២ | ២ | ០ |
| ១០ | សុរិយោដីនិងការគ្រប់គ្រងដី | ៣៦ | ១០ | ១៥ | ៤ | ៦១ | ១៧ | ៨១ | ២៣ |
| ១១ | ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ | ៩ | ២ | ៦ | ៣ | ៥ | ២ | ៥ | ៣ |
| ១២ | មីក្រូហិរញ្ញវត្ថុ | ១ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ១៣ | វិស្វកម្មកសិកម្ម | ០ | ០ | ១ | ០ | ០ | ០ | ១ | ០ |
| **សរុបរួម** | | **២៥៧** | **៦៨** | **២០៥** | **៦៦** | **២៣៣** | **៦៥** | **២២៨** | **៥៨** |

ស្ថិតិនិស្សិតបញ្ចប់ការសិក្សាឆ្នាំ២០១៧-២០២១ (គិតជានាក់)

| ល.រ. | ជំនាញ | ឆ្នាំសិក្សា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ២០១៧-២០១៨ | | ២០១៨-២០១៩ | | ២០១៩-២០២០ | | ២០២០-២០២១ | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | និស្សិតថ្នាក់បរិញ្ញាបត្ររង | ១៥៤ | ៥៦ | ១៤៩ | ៤០ | ៣៦ | ១៦ | ៨៦ | ២៤ |
| ២ | និស្សិតថ្នាក់បរិញ្ញាបត្រ | ២០៦ | ៨១ | ១៩៧ | ៧២ | ១០៣ | ៤៥ | ១២៦ | ៤៩ |
| **សរុបរួម** | | **៣៦០** | **១៣៧** | **៣៤៦** | **១១២** | **១៣៩** | **៦១** | **២១២** | **៧៣** |

## ២.១០- ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា

ក្រសួងបានពង្រឹងនិងពង្រីកសកម្មភាពវិទ្យាស្ថានជាតិសង្គមកិច្ច សំដៅបណ្តុះបណ្តាលធនធានមនុស្ស សម្រាប់ស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការ សមាគម មិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសដែលពាក់ព័ន្ធនឹងការងារសង្គមកិច្ច។ វិទ្យាស្ថានបាននិងកំពុងបណ្តុះបណ្តាលនិស្សិតកម្រិតឧត្តមសិក្សាដែលសិក្សាលើជំនាញសង្គមកិច្ច ជំនាញសង្គមវិទ្យា ជំនាញកិច្ចគាំពារសង្គម ជំនាញវិស្វកម្មសិប្បនិម្មិតនិងរណប ជំនាញគ្រប់គ្រងសាធារណៈ ជំនាញរដ្ឋបាលសាធារណៈ ជំនាញគោលនយោបាយសង្គម ជំនាញគោលនយោបាយសាធារណៈ និងជំនាញអក្សរសាស្ត្រអង់គ្លេសសរុបចំនួន៤៦៣នាក់ និស្សិតបរទេស១៤នាក់។ និស្សិតដែលបានប្រឡងជាប់ជាស្ថាពរថ្នាក់បរិញ្ញាបត្រ៣៥០នាក់ ស្រី១៩០នាក់ និស្សិតបរទេស១០នាក់ និងសិក្ខាកាមដែលបានបញ្ចប់ការសិក្សាជំនាញផ្សេងៗរយៈពេលខ្លី៦២៨នាក់ និងបណ្តុះបណ្តាលជំនាញអ្នកជំនួយបច្ចេកទេសឧបករណ៍បច្ចេកទេសសិប្បនិម្មិតនិងរណប២៦នាក់។

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ខែកញ្ញា ឆ្នាំ២០២២ | |
| ១ | និស្សិតដែលបានចុះឈ្មោះចូលរៀនឆ្នាំទី១ | នាក់ | ១៦៧ | ៩៦ | ១៣២ | ៩២ | ០ | ៤៨៧ |
| ២ | និស្សិតដែលកំពុងសិក្សាកម្រិតបរិញ្ញាបត្រ | នាក់ | ៤៨៩ | ៤០០ | ៤៤១ | ៤៦៣ | ៣០៦ | ២០៩៩ |
| ៣ | និស្សិតដែលបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ | នាក់ | ២០ | ៩១ | ៧០ | ០ | ០ | ១៨១ |
| ៤ | សិក្ខាកាមដែលបានបញ្ចប់ការសិក្សាកម្រិតវិញ្ញាបនបត្រ | នាក់ | ៧៥ | ២២៥ | ២០៨ | ៥៨ | ៣៦ | ៦០២ |

## ២.១១- ក្រសួងផែនការ

ក្រសួងផែនការ បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការពង្រឹងសមត្ថភាពរបស់មន្ត្រី ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង និងបានរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំផ្សេងៗ នៅក្នុងប្រទេស និងក្រៅប្រទេស ដោយផ្តោតលើជំនាញការរៀបចំធ្វើផែនការ ការវិភាគស្ថិតិ និងការរៀបចំគោលនយោបាយប្រជាជន ព្រមទាំងវគ្គបណ្តុះបណ្តាលផ្សេងៗទៀតទាក់ទងនឹងការងាររបស់ក្រសួងផែនការ។

ក្រសួងផែនការតាមរយៈមជ្ឈមណ្ឌលបណ្តុះបណ្តាលផែនការស្ថិតិ ដែលជាមជ្ឈមណ្ឌលមួយសម្រាប់បណ្តុះបណ្តាលដល់មន្ត្រីរាជការមកពីក្រសួង ស្ថាប័ននានា និងសិស្សដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដោយឆ្លងកាត់ការប្រឡងជ្រើសរើសឱ្យចូលរៀនលើមុខជំនាញឯកទេស

ពីរគឺផែនការសេដ្ឋកិច្ច និងស្ថិតិសេដ្ឋកិច្ច។ បច្ចុប្បន្នមាននិស្សិតកំពុងសិក្សាចំនួនពីរជំនាន់គឺជំនាន់ទី៣០ និងជំនាន់ទី៣១ ដែលមានសិក្ខាកាម និស្សិតសរុបចំនួន១០៧នាក់(ស្រី៣៥នាក់)។

## ២.១២- ក្រសួងអភិវឌ្ឍន៍ជនបទ

ក្រសួងអភិវឌ្ឍន៍ជនបទ បានធ្វើការបណ្តុះបណ្តាលរយៈពេលខ្លី វែង សិក្ខាសាលាផ្សេងៗ ដូចជាជំនាញផ្នែកសេដ្ឋកិច្ច អភិវឌ្ឍន៍សហគមន៍ បច្ចេកទេសសាងសង់ផ្លូវថ្នល់ កសិកម្ម ការគ្រប់គ្រង កាអភិវឌ្ឍន៍ជនបទ បច្ចេកទេស គ្រប់គ្រងព័ត៌មាន រៀបចំផែនការយុទ្ធសាស្ត្រ គ្រប់គ្រងទឹកស្អាត អនាម័យ បរិស្ថាន ការប្រែប្រួលអាកាសធាតុ យេនឌ័រ។ល។ សម្រាប់មន្ត្រីរាជការ ក្រសួងដោយសហការជាមួយដៃគូ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងបណ្តាប្រទេសជាមិត្ត។ នៅតាមមូលដ្ឋានក្រសួងមានមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមូលដ្ឋានចំនួន១៣រាជធានីខេត្ត មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា កូរ៉េ ដោយបានបណ្តុះបណ្តាល ១ ៥៣៧វគ្គ ដែលមានសិក្ខាកាមចូលរួមសរុប២៣ ០៥៥នាក់(ស្រី៤ ១៥០នាក់)ដោយបានបណ្តុះបណ្តាលជាច្រើន ដែលមានសិក្ខាកាមចូលរួមសរុប ១៣ ៧៨៦នាក់(ស្រី២ ២៥៦នាក់)។

## ២.១៣- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

### ក- ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី

| បរិយាយ | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ៩ខែ២០២២ | |
|---|---|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| ១.វគ្គបណ្តុះបណ្តាលជំនាញឌីជីថលចាំបាច់ (Digital Skill Essential) | ៥៩៥ | ១២៧ | ៥៤៩ | ១០៥ | ៣៨៥ | ១០៣ | ៤៧២ | ១១៥ | ១០៨៤ | ៥៧២ |
| ២.វគ្គបណ្តុះបណ្តាលស្តីពីICTសម្រាប់ការងាររដ្ឋបាលនិងកម្មវិធីទូរស័ព្ទឆ្លាតវៃតាមរយៈកម្មវិធីអ្នកស្ម័គ្រចិត្ត ICTកម្ពុជា | ១ ២២២ | ៨២០ | ១ ៩២៩ | ១២១៣ | ១ ៩០៧ | ១៣៧០ | - | - | - | - |
| ៣.វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈលើវិស័យ ICT | - | - | ២៥០ | ២០ | ២៤០ | ៣៥ | - | - | ១២០ | ២០ |
| សរុប(នាក់) | **១ ៨១៧** | **៩៤៧** | **២ ៧២៨** | **១ ៣៣៨** | **២ ៥៣២** | **១៥០៨** | **៤៧២** | **១១៥** | **១២០៥** | **៥៩២** |

**បញ្ជាក់:**-វគ្គបណ្តុះបណ្តាលស្តីពីICTសម្រាប់ការងាររដ្ឋបាលនិងកម្មវិធីទូរសព្ទឆ្លាតវៃតាមរយៈកម្មវិធីអ្នកស្ម័គ្រចិត្ត ICT កម្ពុជាបានខកខានមិនបានរៀបចំចំនួន២ឆ្នាំ(២០២១និង២០២២)ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍។

-វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈលើវិស័យ ICT ត្រូវបានចាប់ផ្តើមរៀបចំពីឆ្នាំ២០១៩ និងបានខកខាន មិនបានរៀបចំនៅឆ្នាំ ២០២១ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍។

### ខ- ការបណ្តុះបណ្តាលក្រៅប្រទេសរយៈពេលខ្លី

| សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុបនាក់ |
|---|---|---|---|---|---|---|
| អាហារូបករណ៍ទៅប្រទេសឥណ្ឌា(មន្ត្រី) | ៥ | ៦ | ១ | - | - | **១២** |
| អាហារូបករណ៍ទៅប្រទេសឥណ្ឌា(និស្សិត) | ៥ | ១៣ | ៣ | - | - | **២១** |
| អាហារូបករណ៍ទៅប្រទេសជប៉ុន(គ្រូបង្គោល) | - | ១ | - | - | - | **១** |

| | | | | | | |
|---|---|---|---|---|---|---|
| អាហារូបករណ៍ទៅប្រទេសកូរ៉េ(គ្រូបង្គោល) | - | - | - | ១ | - | ១ |
| អាហារូបករណ៍ទៅប្រទេសចិន(គ្រូបង្គោល) | - | - | ២ | - | ១ | ៣ |
| អាហារូបករណ៍ទៅប្រទេសបែលហ្សិក(គ្រូបង្គោល) | - | - | ១ | - | - | ១ |
| អាហារូបករណ៍ទៅប្រទេសបារាំង(គ្រូបង្គោល) | - | ៣ | ៣ | ១ | ៤ | ១១ |
| **សរុប(៥០ នាក់ស្រី ២ នាក់)** | **១០** | **២៣** | **១០** | **២** | **៥** | **៥០** |

## ២.១៤- ក្រសួងកិច្ចការនារី

ក្រសួងកិច្ចការនារីបានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីរាជការ ស្ត្រីមេម៉ាយ ស្ត្រីក្រីក្រ ទណ្ឌិត ស្ត្រីបោះបង់ចោលការសិក្សា ប្រជាពលរដ្ឋក្រីក្រ ក្មេងស្រីបោះបង់ចោលការសិក្សា និងជនជាតិដើមភាគតិច ដូចខាងក្រោម៖

- គណៈគ្រប់គ្រងមុខដំណែង អគ្គនាយករង អគ្គាធិការរង អគ្គលេខាធិការរង ដល់រដ្ឋលេខាធិការ ប្រធាននាយកដ្ឋាន និងប្រធានមន្ទីរជាស្ត្រី ចំនួន៣២នាក់ (ស្រី៣១នាក់) បានចូលរួមវគ្គបណ្តុះបណ្តាល១៣០ម៉ោង និងកម្មវិធីភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ និងលក្ខណវិនិច្ឆ័យភាពជាអ្នកដឹកនាំគំរូ។ មន្ត្រីរាជការចំនួន២០នាក់ (ស្ត្រី១៦ នាក់)បានចូលរួមវគ្គបណ្តុះបណ្តាលបន្ត និងមន្ត្រីរាជការក្របខ័ណ្ឌថ្មីចំនួន១៤នាក់ (ស្ត្រី៩នាក់) បានចូលរួមវគ្គបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល

- ថ្នាក់ដឹកនាំ និងមន្ត្រីរាជការចំនួន៧១នាក់ (ស្ត្រី៥៨នាក់) បានទទួលការបណ្តុះបណ្តាលនៅក្រៅប្រទេស (ប្រទេសឥណ្ឌា ២នាក់ជាស្ត្រី ប្រទេសអ៊ីស្រាអែល ១នាក់ជាស្ត្រី ប្រទេសសឹង្ហបុរី១៧នាក់ (ស្ត្រី៨នាក់) ប្រទេសថៃ២នាក់ជាស្ត្រី ប្រទេសហ្វីលីពីន៤នាក់ជាស្ត្រី ប្រទេសជប៉ុន៣នាក់ជាស្ត្រី ប្រទេសនូវែលហ្សេឡង់២នាក់ជាស្ត្រី សាធារណរដ្ឋកូរ៉េ៣២នាក់ (ស្ត្រី២៩នាក់) ប្រទេសវៀតណាម២នាក់ជាស្ត្រី ប្រទេសស៊ុយអែត១នាក់ជាស្ត្រី ប្រទេសម៉ាឡេស៊ី១នាក់ជាស្ត្រី ប្រទេសអូស្ត្រាលី២នាក់ (ស្ត្រី១នាក់ ) និងប្រទេសចិន២នាក់ជាស្ត្រី

- មន្ត្រីទទួលបន្ទុកការងាររដ្ឋបាលទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិសរុបចំនួន ៤៧៨នាក់ (ស្ត្រី ៤០១នាក់) ទទួលបានការបណ្តុះបណ្តាល និងមានសមត្ថភាពក្នុងការអនុវត្តការងារប្រចាំថ្ងៃរបស់ខ្លួនទាក់ទងការគ្រប់គ្រងរដ្ឋបាល បុគ្គលិក ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

- មន្ត្រីការិយាល័យកិច្ចការនារីក្រុង ស្រុកចំនួន២៧០នាក់ (ស្រី ២៦១នាក់) និងមន្ត្រីជាប់កិច្ចសន្យាចំនួន១៨នាក់ជាស្ត្រីបានធ្វើសមាហរណកម្មមុខតំណែងគ្រប់គ្រងក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

- មន្ត្រីក្របខ័ណ្ឌថ្មីចំនួន៨៦នាក់(ស្រី ៥៩នាក់) បានចូលបម្រើការងារក្រសួងតាមរយៈការប្រលងជ្រើសរើសនិងមន្ត្រីរាជការចំនួន១០៥នាក់ (ស្រី ១០០នាក់)បានដាក់ឱ្យចូលនិវត្តន៍តាមអតីតភាពការងារ

- ស្ត្រីមេម៉ាយ ស្ត្រីក្រីក្រ ទណ្ឌិតស្ត្រីបោះបង់ចោលការសិក្សា និងជនជាតិដើមភាគតិច ចំនួន១៥ ៦១១នាក់ ទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ កាត់ដេរ អ៊ុតសក់ សម្អាងការ តម្បាញ តាមរយៈមន្ទីរកិច្ចការនារី និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីនៅរាជធានីភ្នំពេញ ខេត្តមណ្ឌលគិរី ស្ទឹងត្រែង បាត់ដំបង ព្រះសីហនុ រតនគិរី កណ្តាល បន្ទាយមានជ័យ កំពង់ឆ្នាំង ព្រះវិហារ ត្បូងឃ្មុំ កោះកុង ប៉ៃលិន កែប សៀមរាប ក្រចេះ កំពត កំពង់ចាម ព្រៃវែង និងខេត្តឧត្តរមានជ័យ

- ប្រជាពលរដ្ឋក្រីក្រ ស្ត្រីម៉េម៉ាយ ស្ត្រីក្រីក្រ ក្មេងស្រីបោះបង់ចោលការសិក្សានិងជនជាតិដើមភាគតិចដែលប្រកបមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ សរុបចំនួន១៧ ៧១៨នាក់ (ស្ត្រី១៣ ៩៦៦នាក់)ទទួលបានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ កែច្នៃចំណីអាហារនិងកែច្នៃផលិតផលកសិកម្ម សហគ្រិនភាព ការរៀបចំផែនការអាជីវកម្ម។

## ២.១៥- ក្រសួងធម្មការនិងសាសនា

**ក- ការបណ្តុះបណ្តាលអាចារ្យ អាចារិនី និងដូនជី** (គិតជានាក់)

| សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| ចំនួនអាចារ្យ អាចារិនី | ៥៤៣ | ៦៧២ | ១៧៣ | ៣៤៨ | ៣៦៤ |

**ខ- នាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់សង្គម** (គិតជានាក់)

| សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| ចំនួនអ្នកចូលរួម | ៦ ៥៧៦ | ៥ ០៥៣ | ៣ ៥៣០ | ១ ០៨៥ | ១ ៤៥១ |
| ចំនួនស្ថានីយ៍វិទ្យុបានផ្សាយជាស៊ីឌី | ៨៤០ | ៨៤០ | ៨៤០ | ៣៨៥ | ៣៥០ |
| ចំនួនទូរទស្សន៍បានផ្សាយជាឌីវីឌី | ១២០ | ១២០ | ៥៥ | ៥០ | ៦៩ |
| ចំនួនផលិតឌីវីខេម | ១ ១០៤ | ១ ១០៤ | ១ ១០៤ | ៥០៦ | ៤៦០ |

- ចូលរួមកិច្ចប្រជុំនិងសិក្ខាសាលាចំនួន១៧៨លើក
- រៀបចំកម្មវិធីនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់សង្គមចំនួន៩៣លើក ប្រធានបទចំនួន២៧៩ប្រធានបទ
- បាននិមន្តធម្មថិកាចារ្យសម្តែងព្រះធម៌ទេសនាចំនួន២៧៩ព្រះអង្គ ដែលមានអ្នកចូលរួមស្តាប់ចំនួន ១៧ ៣៩៣អង្គ/នាក់ ក្នុងនោះមានព្រះសង្ឃ ចំនួន១ ០១០អង្គ និងស្ត្រីចំនួន១ ១៤០នាក់
- ផលិត Dvcam ចំនួន៤ ២៧៨ Dvcam, CD សំឡេង ចំនួន៣ ២៥៥បន្ទះ និង DVD ចំនួន៤៦៥ដុំកាសែត
- បើកវគ្គបណ្តុះបណ្តាលតួនាទី ភារកិច្ច និងក្រមសីលធម៌អាចារ្យខ្មែរចំនួន១៣វគ្គ សិក្ខាកាមចូលរួមចំនួន២ ១០០អង្គ/នាក់ ក្នុងនោះមានព្រះសង្ឃ២៨៥អង្គ និងស្ត្រីចំនួន៣៩នាក់
- ចេញវិញ្ញាបនបត្របញ្ជាក់ការបណ្តុះបណ្តាលតួនាទី ភារកិច្ច និងក្រមសីលធម៌អាចារ្យខ្មែរជូនដល់សិក្ខាកាមសរុបចំនួន២ ១០០អង្គ/នាក់
- ចុះធ្វើកម្មវិធីទស្សនាទានព្រះពុទ្ធសាសនាចំនួន ៣៣លើក សរុបចំនួន៣៦ ០៦៧អង្គ/នាក់ (ស្ត្រី ១៥ ៤២៣នាក់)
- រៀបចំសិក្ខាសាលាទស្សនាទានព្រះពុទ្ធសាសនា និងពង្រឹងការផ្សព្វផ្សាយព្រះធម៌ចំនួន៥លើក និងចេញវិញ្ញាបនបត្របញ្ជាក់ប្រគេនជូនសិក្ខាកាមចំនួន៧៤៨អង្គ/នាក់
- រៀបចំពិធីសំណេះសំណាលជាមួយអាចារ្យ អាចារិនីចំនួន២លើក សរុបចំនួន២ ០០០រូប
- ចុះបញ្ចីមជ្ឈមណ្ឌលដែលមានចរិតពុទ្ធសាសនាថេរវាទចំនួន១កន្លែង។

## ២.១៦- ក្រសួងសាធារណការនិងដឹកជញ្ជូន

**ការបណ្តុះបណ្តាលមន្ត្រីរាជការក្រសួងសាធារណការនិងដឹកជញ្ជូនក្នុងនិងក្រៅប្រទេស** (គិតជានាក់)

| ល.រ | បណ្តុះបណ្តាលមន្ត្រីរាជការ | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|---|
| ១ | ក្នុងប្រទេស | ផ្ទាល់ | **៩៥**(ស្រី១៣) | **២៤** (ស្រី២) | **១៦២**(ស្រី៣១) | **៤៧**(ស្រី៦) | **២៤**(ស្រី៥) |
| | | អនឡាញ | | | | **២៨**(ស្រី៧) | **២១**(ស្រី៣) |
| **សរុប** | | | **៩៥**(ស្រី១៣) | **២៤** (ស្រី២) | **១៦២**(ស្រី៣១) | **៧៥**(ស្រី១៣) | **៤៥**(ស្រី៨) |
| ២ | ក្រៅប្រទេស | ផ្ទាល់ | | | | **១៣**(ស្រី២) | **២៩**(ស្រី៥) |
| | | អនឡាញ | **៩៧**(ស្រី១៤) | **៧៨**(ស្រី១៤) | **១០**(ស្រី១) | **១៣**(ស្រី៣) | **២**(ស្រី០) |
| **សរុប** | | | **៩៧**(ស្រី១៤) | **៧៨**(ស្រី១៤) | **១០**(ស្រី១) | **២៦**(ស្រី៥) | **៣១**(ស្រី៥) |

## ២.១៧- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍

ក្រសួងបានធ្វើការបណ្តុះបណ្តាលទៅតាមជំនាញនិងចែករំលែកចំណេះដឹង ជំនួយបច្ចេកទេស និងបទពិសោធន៍ ដូចខាងក្រោម៖

- រៀបចំវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ ស្តីពីការគ្រប់គ្រងសុវត្ថិភាពឧស្សាហកម្ម ការធ្វើឱ្យប្រសើរឡើងសុវត្ថិភាពប្រតិបត្តិការរបស់កម្មករ និងលក្ខណៈបច្ចេកទេសសុវត្ថិភាពឧស្សាហកម្ម ជូនវិស័យឯកជនចំនួន៥៦លើក ដែលមានសិក្ខាកាមចូលរួមចំនួន៩ ២០៩នាក់ មកពីរោងចក្រ សិប្បកម្មចំនួន២ ២២៤ ក្នុងគោលបំណងចែករំលែកចំណេះដឹងនិងបទពិសោធន៍ ស្តីពីការគ្រប់គ្រង ការថែទាំ ការត្រួតពិនិត្យ និងផ្សព្វផ្សាយពីបទប្បញ្ញត្តិនានានៃការគ្រប់គ្រង គ្រឿងចក្រ គ្រឿងម៉ាស៊ីន ដែលមានហានិភ័យខ្ពស់ក្នុងរោងចក្រ សិប្បកម្ម ជាពិសេសចំពោះបុគ្គលិក កម្មករ អ្នកបញ្ជាគ្រឿងចក្រ តាមបណ្តារោងចក្រ សហគ្រាស ឱ្យបានយល់ដឹងពីការគ្រប់គ្រងសុវត្ថិភាព និងប្រសិទ្ធភាពក្នុងការអនុវត្ត ការងារឱ្យស្របតាមលក្ខណៈបច្ចេកទេស ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព

- រៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាក្នុងប្រទេស ពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញាចំនួន ៣២លើក មានអ្នកចូលរួមពីស្ថាប័នរដ្ឋនិងឯកជន (សមាគមភ្នាក់ងារកម្មសិទ្ធិបញ្ញា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យ) បានចំនួន២ ៣៦២នាក់

- មជ្ឈមណ្ឌលផលិតភាពជាតិ បានបើកវគ្គផ្សព្វផ្សាយ និងបណ្តុះបណ្តាលនៅក្នុងប្រទេស និងបញ្ជូនបេក្ខជនទៅចូលរួមកម្មវិធីក្រៅប្រទេសចំនួន ២៤៦គម្រោង មានបេក្ខជនសរុបចំនួន៧ ៧៦៤នាក់

- បានសហការជាមួយអង្គការមូលនិធិសង្គ្រោះកុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ (UNICEF) លើគម្រោងការពង្រឹងគុណភាពទឹកពិសាជប ដែលបានធ្វើសិក្ខាសាលាស្តីពីអត្ថប្រយោជន៍ និងនីតិវិធីទទួលបានសញ្ញាស្តង់ដាទឹកពិសាជបដល់ម្ចាស់រោងចក្រ សិប្បកម្មផលិតទឹកពិសាជបនិងមន្ត្រីមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ទាំង២៥រាជធានី ខេត្តចំនួន២៥លើក និងតាមប្រព័ន្ធអនឡាញចំនួន២លើក ដែលមានសិក្ខាកាមចូលរួមសរុបចំនួនប្រមាណ១ ០៩៥នាក់។ ក្នុងកិច្ចសហប្រតិបត្តិការនេះ ក៏បានផលិតជាវីដេអូអប់រំខ្លី ស្តីពីគុណភាពនិងសុវត្ថិភាពទឹកពិសាជប និងមានរៀបចំកម្មវិធី Radio Talk Show ចំនួន៤លើក

- បានធ្វើបច្ចុប្បន្នភាពបញ្ជីធនធានមនុស្សដែលជាអ្នកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាកម្ពុជា អង្គភាពចំនួន៥០ បានឆ្លើយតបនិងផ្ញើទិន្នន័យ៖ ធនធានមនុស្សសរុប១២ ០៦នាក់ (ស្ត្រី២ ៨៥៨នាក់) កម្រិតបរិញ្ញាបត្រ ៨ ៣៤៥នាក់ បរិញ្ញាបត្រជាន់ខ្ពស់២ ០៣២នាក់ វេជ្ជបណ្ឌិត៨៧៥នាក់ និងបណ្ឌិត៨១០នាក់។ បានបញ្ចប់ការសិក្សានៅទ្វីបអាស៊ី១១ ៥៣៧នាក់ (កម្ពុជា១០ ៣៩១រូប) ទ្វីបអឺរ៉ុប៤៨០នាក់ និងទ្វីបអាម៉េរិក៤៥នាក់

- បានរៀបចំវគ្គបណ្តុះបណ្តាលដំបូងជូនសិស្សមន្ត្រី ដែលបានប្រឡងជាប់ជាស្ថាពរចូលបម្រើការងារក្នុងក្របខ័ណ្ឌឆ្នាំ២០១៨(២០នាក់) ក្របខ័ណ្ឌឆ្នាំ២០១៩(២៧នាក់) ក្របខ័ណ្ឌពិសេសឆ្នាំ២០២០(៤៥នាក់) ក្របខ័ណ្ឌឆ្នាំ២០២១(៨០នាក់) សរុបចំនួន១៧២រូប ដើម្បីស្វែងយល់ពីឋានានុក្រម តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានវិទ្យាស្ថាន មជ្ឈមណ្ឌល និងអង្គភាពនានារបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ ពិសេសគឺដើម្បីយល់ដឹងពីច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។

## ២.១៨-ក្រសួងទេសចរណ៍

ក្រសួងទេសចរណ៍ បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន៤ប្រភេទ ចាប់ពីឆ្នាំ២០១៦-២០២២ រួមមានៈ

- វគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងមន្ត្រីរាជការនិងកិច្ចការរដ្ឋបាល សរុប១៧៦រូប (ស្រី៨១រូប)
- វគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងមន្ត្រីរាជការ និងកិច្ចការរដ្ឋបាល សរុប៤៤៨រូប ស្រី១៧៣រូប
- វគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងប្រសិទ្ធភាពការងារ៦០០រូប ស្រី២៣៦រូប
- វគ្គបណ្តុះបណ្តាល ស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការក្នុងបរិបទឌីជីថល៦៥រូប ស្រី៣៣រូប។

ក្រសួងក៏បានធ្វើការការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈក្នុងវិស័យទេសចរណ៍ ដើម្បីចូលរួមអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ និងឆ្លើយតបទៅនឹងកំណើនភ្ញៀវទេសចរដែលកើនជារៀងរាល់ឆ្នាំ ក្រសួងទេសចរណ៍បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងបដិសណ្ឋារកិច្ចដល់បុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍ តាមរយៈការបណ្តុះបណ្តាលដោយផ្ទាល់ និងការបណ្តុះបណ្តាលតាមប្រព័ន្ធឌីជីថល ជាពិសេសក្នុងដំណាក់កាលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ ដូចខាងក្រោមៈ

| ឆ្នាំ | វគ្គបណ្តុះបណ្តាលផ្ទាល់ | វគ្គបណ្តុះបណ្តាលឌីជីថល |
|---|---|---|
| ឆ្នាំ២០១៨ | ៧១៤នាក់ | |
| ឆ្នាំ២០១៩ | ១ ២២៧នាក់ | |
| ឆ្នាំ២០២០ | ២៤០នាក់ | ១១ ៥២១ នាក់ (គិតជាសិក្ខាកាម ៤៧ ៤០៥សិក្ខាកាម) |
| ឆ្នាំ២០២១ | ៣៥៧នាក់ | ២ ០១១ នាក់ (គិតជាសិក្ខាកាម ៨ ៥៧៤សិក្ខាកាម) |
| ឆ្នាំ២០២២ | ២៧៥នាក់ | ១ ១១៤នាក់ (គិតជាសិក្ខាកាម ៣ ៤០០សិក្ខាកាម) |

## ២.១៩- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

### ក- ការអភិវឌ្ឍធនធានមនុស្សនិងពង្រឹងសមត្ថភាពស្ថាប័ន

ការបណ្តុះបណ្តាលនិងអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអាកាសចរស៊ីវិល គឺជាកិច្ចការចាំបាច់និងមានសារៈសំខាន់ណាស់ដែលតម្រូវឱ្យមន្ត្រីជំនាញបច្ចេកទេសមានសមត្ថភាពគ្រប់គ្រាន់ មានជំនាញអាកាសចរស៊ីវិលសម្រាប់បម្រើការងារលើការត្រួតពិនិត្យសុវត្ថិភាព សន្តិសុខ និងការផ្តល់សេវាកម្មអាកាសចរស៊ីវិល ដើម្បីធានាបាននូវសុវត្ថិភាពនិងសន្តិសុខ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ជាពិសេសស្របតាមស្តង់ដារបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ(ICAO)។

**តារាងទី១ ស្ថិតិមន្ត្រីរាជការឆ្នាំ២០១៨ ដល់ឆ្នាំ២០២២**

| ល.រ | បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ១ | ចំនួនមន្ត្រីរាជការសរុប | ៧៤៦ | ៧៧៨ | ៧៧៧ | ៧៩៨ | ៧៩៦ |
| ២ | មន្ត្រីមានក្របខ័ណ្ឌ | ៧៣៤ | ៧៤៨ | ៧៣៨ | ៧៥៤ | ៧៥១ |
| ៣ | មន្ត្រីគ្មានក្របខ័ណ្ឌ | ១២ | ៣០ | ៣៩ | ៤៤ | ៤៥ |

**ការបណ្តុះបណ្តាលមន្ត្រីរាជការ ឆ្នាំ២០១៨ ដល់ឆ្នាំ២០២២**

| ល.រ | បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ១ | ចំនួនមន្ត្រីបណ្តុះបណ្តាលសរុប | ៣៣០ | ៦០៥ | ២៦៤ | ១៩៧ | ១៩៧ |
| ២ | ក្នុងប្រទេស | ២៨៩ | ៤៩៥ | ២៤៥ | ១៤៨ | ១៧៥ |
| ៣ | ក្រៅប្រទេស | ៤១ | ១០០ | ០៩ | ៣៩ | ១២ |
| ៤ | រយៈពេលវែង(បន្តវេន) | ០០ | ១០ | ១០ | ១០ | ១០ |

### ខ- វិទ្យាស្ថានជាតិអាកាសចរស៊ីវិល

យោងលើអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការប្រែក្លាយនិងដំឡើងមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិលទៅជាវិទ្យាស្ថានជាតិអាកាសចរស៊ីវិល មានថ្នាក់ស្មើអគ្គនាយកដ្ឋានមានតួនាទីជាសេនាធិការឱ្យរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល លើការងារបណ្តុះបណ្តាលស្រាវជ្រាវ និងនវានុវត្តន៍ក្នុងវិស័យអាកាសចរស៊ីវិលដល់សិស្ស និស្សិត មន្ត្រីរាជការ និងបុគ្គលិកក្រុមហ៊ុនឯកជន ស្របតាមតម្រូវការជាតិនិងអន្តរជាតិ។ ក្នុងការរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦នៃរដ្ឋសភា វិទ្យាស្ថានជាតិអាកាសចរស៊ីវិលបានខិតខំប្រឹងប្រែងពង្រឹងការបណ្តុះបណ្តាល និងបន្តអភិវឌ្ឍនិរន្តរភាពការងារ ក្នុងគោលបំណងបង្កើននូវសក្តានុពលវិស័យអាកាសចរស៊ីវិលថែមមួយកម្រិតទៀត ក្នុងនោះវិទ្យាស្ថានសម្រេចបានសមិទ្ធផលជាផ្លែផ្កាមួយចំនួនដូចតទៅ៖

- បានទទួលគណៈប្រតិភូមកទស្សនកិច្ចនៅវិទ្យាស្ថានជាតិអាកាសចរស៊ីវិល រួមមានមជ្ឈមណ្ឌលអាកាសចរបាងកក(BAC) សភាអាកាសចរវៀតណាម(VAA) វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា(NPIC) អង្គការអាកាសចរស៊ីវិលអន្តរជាតិ(ICAO COSCAP) ក្រុមហ៊ុនសេវាកម្មអាកាសចរណ៍(CATS) ក្រុមហ៊ុន Cambodia Airport(CAMS) Korean International Cooperation Agency (KOICA), Deviation Training Centre (Malaysia), Lancang-Mekong Delegations from Laos and Myanmar, Build Bright University, BELTEI International University
- បានរៀបចំសិក្ខាសាលាជួបជុំលោកគ្រូ អ្នកគ្រូ ប្រចាំឆ្នាំដើម្បីពង្រឹងកិច្ចការងារបណ្តុះបណ្តាល
- បានធ្វើការផ្សព្វផ្សាយពីកម្មវិធីសិក្សា ទៅកាន់អង្គភាព ស្ថាប័ន ក្រុមហ៊ុនពាក់ព័ន្ធនានា
- បន្តរៀបចំ ស្នើសុំចូលជាសមាជិក ICAO Train Air Plus
- បានសម្របសម្រួលនិងសហការបើកវគ្គបណ្តុះបណ្តាលរបស់ Boeing Company នៅវិទ្យាស្ថានជាតិអាកាសចរស៊ីវិល
- បានរៀបចំឯកសារចុះអនុស្សរណៈរវាងវិទ្យាស្ថានជាតិអាកាសចរស៊ីវិល និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា កូរ៉េ ស្តីពីការបណ្តុះបណ្តាល Drone
- បានទៅធ្វើទស្សនកិច្ចនៅវិទ្យាស្ថានជាតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**វគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអាកាសចរស៊ីវិលពីឆ្នាំ២០១៨-២០២២**

| ឆ្នាំ | ចំនួនវគ្គ | ចំនួនសិក្ខាកាម | សិក្ខាកាមជាស្ត្រី | សិក្ខាកាមជាបុរស |
|---|---|---|---|---|
| ២០១៨ | ២២ | ៣៧០ | ១១៨ | ២៥២ |
| ២០១៩ | ៣៣ | ៤៦០ | ១៣២ | ៣២៨ |
| ២០២០ | ១២ | ២០៣ | ៧៨ | ១៤០ |
| ២០២១ | ៥ | ៩៤ | ៦៦ | ២៨ |
| ២០២២ | ១៤ | ១៨៧ | ១២៦ | ៦១ |
| **សរុប** | **៨៦វគ្គ** | **១៣១៤នាក់** | **៥២០នាក់** | **៨០៩នាក់** |

## ២.២០- ក្រសួងធនធានទឹកនិងឧតុនិយម

ដើម្បីពង្រឹងស្ថាប័ននិងសមត្ថភាពចំណេះដឹងថ្មីៗដល់មន្ត្រីរាជការ ក្រសួងធនធានទឹកនិងឧតុនិយមបានបញ្ជូនមន្ត្រីរាជការចូលរួមក្នុងសិក្ខាសាលា និងបានបណ្តុះបណ្តាលដល់មន្ត្រីគ្រប់លំដាប់ថ្នាក់នូវមុខវិជ្ជាពាក់ព័ន្ធ

ដល់កិច្ចអភិវឌ្ឍវិស័យធនធានទឹកនិងឧតុនិយមទាំងក្នុងប្រទេសនិងក្រៅប្រទេស ដោយមានការយកចិត្តទុកដាក់និងលើកទឹកចិត្តដល់មន្ត្រីជាស្ត្រីឱ្យចូលរួមផងដែរ។ លទ្ធផលសម្រេចបានរួមមានតាមបណ្ដាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | បណ្ដុះបណ្ដាល (នាក់) | | | សិក្ខាសាលា (នាក់) | | |
|---|---|---|---|---|---|---|
| | ក្នុងប្រទេស | ក្រៅប្រទេស | សរុប | ក្នុងប្រទេស | ក្រៅប្រទេស | សរុប |
| ២០១៨ | ១៩១ | ១៧ | ២០៨ | ២៧៤ | ៣៣ | ៣០៧ |
| ២០១៩ | ២៣៧ | ១៩ | ២៥៦ | ២៩៦ | ៣២ | ៣២៨ |
| ២០២០ | ១៦៩ | ៥ | ១៧៤ | ១៥៦ | ៧ | ១៦៣ |
| ២០២១ | ៩៤ | ០ | ៩៤ | ១៣៣ | ០ | ១៣៣ |
| ២០២២ | ១៦២ | ៨ | ១៧០ | ៣១២ | ៣ | ៣១៥ |
| **សរុប** | **៨៥៣** | **៤៩** | **៩០២** | **១ ១៧១** | **៧៥** | **១ ២៤៦** |

ក្រៅពីនេះក្រសួងបានបើកវគ្គបណ្ដុះបណ្ដាលបង្កើនសមត្ថភាពមន្ត្រីនិងសិក្ខាសាលា មានដូចខាងក្រោម៖

| ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|
| ចំនួន | ២៤លើក | ២៩លើក | ១១លើក | ២ លើក | ០ លើក | ៦៦លើក |

## ២.២១- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភានិងអធិការកិច្ច

ក្រសួងបានធ្វើការបណ្ដុះបណ្ដាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេសលើមុខជំនាញ មានជាអាទិ៍ អធិការកិច្ចការងារគ្រប់គ្រងគម្រោងអាស៊ាន ការប្រាស្រ័យទាក់ទងជាមួយប្រព័ន្ធផ្សព្វផ្សាយនិងសាធារណៈ ការកែលម្អគុណភាពសេវាសាធារណៈ មូលដ្ឋានគ្រឹះនៃការប្រើប្រាស់(ICT)និងទូរសព្ទឆ្លាតវៃ បច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីអភិវឌ្ឍន៍ភាពជាអ្នកដឹកនាំនយោបាយ ជំនាញការទូតនិងទំនាក់ទំនងអន្តរជាតិ លទ្ធកម្មសាធារណៈ គណនេយ្យសាធារណៈ និងនីតិវិធីគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទិន្នន័យបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ។ល។ ដែលមានមន្ត្រីរាជការចូលរួមចំនួន ៧២៤នាក់(ក្រៅប្រទេស ២៨នាក់)។

## ២.២២- ក្រសួងបរិស្ថាន

ក្រសួងបានពង្រឹងសមត្ថភាពមន្ត្រីរាជការ និងមន្ត្រីឧទ្យានុរក្សតាមរយៈការបណ្ដុះបណ្ដាលសម្រេចបានដូចខាងក្រោម៖

### ក- ការបណ្ដុះបណ្ដាលនៅសាលាភូមិន្ទរដ្ឋបាល

- វគ្គបណ្ដុះបណ្ដាលមន្ត្រីជាន់ខ្ពស់ចំនួន៣វគ្គ សរុបចំនួន៧៧នាក់(ស្រី១៤នាក់)
- វគ្គបណ្ដុះបណ្ដាលមន្ត្រីមធ្យមថ្នាក់ជាតិចំនួន២វគ្គ សរុបចំនួន៥៥នាក់(ស្រី១១នាក់)
- វគ្គបណ្ដុះបណ្ដាលមន្ត្រីមធ្យមថ្នាក់មន្ទីរបរិស្ថានរាជធានីខេត្តចំនួន២វគ្គ សរុប៥០នាក់(ស្រី៦នាក់)។

### ខ- ការបណ្ដុះបណ្ដាលមន្ត្រីឧទ្យានុរក្សនៅសាលានាយទាហានសកម្ម

- វគ្គបណ្ដុះបណ្ដាលមន្ត្រីឧទ្យានុរក្ស ចំនួន២វគ្គ សរុបចំនួន១២០នាក់
- វគ្គហ្វឹកហ្វឺនមន្ត្រីឧទ្យានុរក្ស ចំនួន២វគ្គ សរុបចំនួន១២០នាក់
- វគ្គពិសេសថ្នាក់ប្រតិបត្តិការមន្ត្រីឧទ្យានុរក្សចំនួន២វគ្គ សរុបចំនួន៥៩នាក់។

គ- ការបណ្ដុះបណ្ដាលមន្ត្រីរាជការនៅក្រសួងបរិស្ថាន សរុបចំនួន១០វគ្គ ដូចជា៖

(១)ការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិចំនួន៣វគ្គ (២)ការពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីរាជការតាមបណ្ដាមន្ទីរបរិស្ថានរាជធានី ខេត្ត (៣)ការពង្រឹងសមត្ថភាពជំនាញបច្ចេកទេសដល់មន្ត្រីរាជការតាមការិយាល័យបរិស្ថាន ក្រុង ស្រុក (៤)កិច្ចការរដ្ឋបាល និងការតាក់តែងលិខិតស្នាមផ្សេងៗ (៥)ការរៀបចំផែនការថវិកា លទ្ធកម្ម និងនីតិវិធីអនុវត្តថវិកាកម្មវិធី (៦)ការគ្រប់គ្រងនិងអភិរក្សធម្មជាតិធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិ (៧)យុទ្ធសាស្ត្រគាំពារបរិស្ថាន (៨)ការពង្រឹងសមត្ថភាពជំនាញក្នុងវិស័យបរិស្ថាន សរុបសិក្ខាកាមចូលរួមចំនួន៨៥៥នាក់។

### ២.២៣- ក្រសួងរ៉ែនិងថាមពល

ដើម្បីអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការឱ្យទទួលបាននូវចំណេះដឹងនិងបទពិសោធន៍ការងារបន្ថែមក្នុងគោលដៅពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យរ៉ែ ប្រេងកាត និងថាមពលឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ក្រសួងបានរៀបចំនិងបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្ដុះបណ្ដាលនៅក្នុងនិងក្រៅប្រទេស ដូចជាជំនាញបច្ចេកទេស បច្ចេកវិទ្យាព័ត៌មាន រដ្ឋបាល ហិរញ្ញវត្ថុនិងជំនាញផ្សេងៗទៀត។




| | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ |
|---|---|---|---|---|---|
| ក្នុងប្រទេស | 197 | 604 | 96 | 125 | 249 |
| ក្រៅប្រទេស | 78 | 119 | 24 | 31 | 39 |

### ២.២៤- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្នុងរយៈពេល៥ឆ្នាំកន្លងមក(ពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២) អគ្គលេខាធិការដ្ឋាននៃ ក.ស.ហ.វ. បានចាត់បញ្ជូនមន្ត្រីរាជការទៅទទួលការបណ្ដុះបណ្ដាលទាំងក្នុងនិងក្រៅប្រទេស សរុបចំនួន**៣ ៨២៧រូប** ក្នុងនោះស្រីចំនួន១ ៥៤១រូប។ ការបណ្ដុះបណ្ដាលមន្ត្រីរាជការនៅក.ស.ហ.វ. ចែកចេញជា២គឺ៖

- ការបណ្ដុះបណ្ដាលនៅក្រៅប្រទេស តាមរយៈការទទួលបានអាហារូបករណ៍ពីសាកលវិទ្យាល័យនៃបណ្ដាប្រទេសជាមិត្ត និងតាមរយៈគម្រោងនានា

- ការបណ្តុះបណ្តាលក្នុងប្រទេស រួមមានវគ្គបណ្តុះបណ្តាលតម្រង់ទិសដំបូងវគ្គបន្ត និងវគ្គបណ្តុះបណ្តាលរយៈពេលខ្លីនៅសាលាភូមិន្ទរដ្ឋបាល វគ្គបណ្តុះបណ្តាលតម្រង់ទិសដំបូងនៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងវគ្គបណ្តុះបណ្តាលមន្ត្រីដែលមានកម្រិតសញ្ញាបត្រត្រឹមបរិញ្ញាបត្ររងចុះ។

ជាលទ្ធផលក្នុងរយៈពេល៥ឆ្នាំនេះក.ស.ហ.វ. បានចាត់មន្ត្រីទទួលការបណ្តុះបណ្តាលនិងអភិវឌ្ឍសមត្ថភាពមន្ត្រីទាំងក្នុងនិងក្រៅប្រទេស ដូចខាងក្រោម៖

- ឆ្នាំ២០១៨ មាន៥វគ្គ សរុបចំនួន១ ០០២រូប ក្នុងនោះស្រី ចំនួន៤៤២រូប
- ឆ្នាំ២០១៩ មាន៧វគ្គ សរុបចំនួន១៩៧រូប ក្នុងនោះស្រីចំនួន៦៤រូប
- ឆ្នាំ២០២០ មាន៤វគ្គ សរុបចំនួន៧១៥ ក្នុងនោះស្រីចំនួន៣០៦រូប
- ឆ្នាំ២០២១ មាន៧វគ្គ សរុបចំនួន១៦២៧រូប ក្នុងនោះស្រីចំនួន៦២០រូប
- ត្រឹមខែកញ្ញា ឆ្នាំ២០២២ មាន៨វគ្គ សរុបចំនួន២៨៦រូប ក្នុងនោះស្រី១០៩រូប។

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា(អ.គ.រ.)** បានរៀបចំនិងបញ្ជូនមន្ត្រីគយនិងរដ្ឋាករចូលរួមវគ្គបណ្តុះ-បណ្តាល សិក្ខាសាលា វិក្រឹតការនិងកម្មវិធីសិក្សានៅក្នុងនិងក្រៅប្រទេស ដូចខាងក្រោម៖

- ក្នុងឆ្នាំ២០១៨ មានចំនួន១៣៩វគ្គ ដែលមានមន្ត្រីចូលរួមចំនួន១ ៣៤០នាក់
- ក្នុងឆ្នាំ២០១៩ មានចំនួន១២៦វគ្គ ដែលមន្ត្រីចូលរួមចំនួន១ ៣៨៣នាក់
- ក្នុងឆ្នាំ២០២០ មានចំនួន៤៣ វគ្គ មន្ត្រីចូលរួមចំនួន៦៩៤ នាក់និង
- ក្នុងឆ្នាំ២០២១ មានចំនួន១០០វគ្គ មន្ត្រីចូលរួមចំនួន១ ០១៩នាក់
- ក្នុងរយៈពេល៩ខែ ឆ្នាំ២០២២ មានចំនួន១០៣វគ្គ មន្ត្រីចូលរួមចំនួន២ ៥៣០នាក់ ។

ទន្ទឹមនឹងការបណ្តុះបណ្តាលមន្ត្រីគយនិងរដ្ឋាករគិតចាប់ពីឆ្នាំ២០១៨មក អ.គ.រ.ក៏បានរៀបចំវគ្គបណ្តុះបណ្តាលដល់រូបវន្តបុគ្គលដែលមានបំណងចង់ទទួលបាននីតិសម្បទាជាជើងសាគយចំនួន២វគ្គ ដែលមានអ្នកចូលរួមចំនួន៣២៧រូប និង៣០៨រូប បានប្រឡងជាប់ជសស្តាពរនិងវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយអំពីលិខិតនិងបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការងារគយដល់អ្នកផ្តល់សេវាជើងសារគយមួយចំនួនទៀត។ សាលាជាតិគយបានក្លាយជាទីតាំងសម្រាប់បណ្តុះបណ្តាលទាំងក្នុងកម្រិតស្ថាប័នអ.គ.រ.ផង អន្តរស្ថាប័នផង និងក្នុងគោលដៅសម្រេចឱ្យបានប្រែក្លាយជាមជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់តំបន់ផងដែរ។

- **ការបណ្តុះបណ្តាលមន្ត្រីពន្ធដារ**(ឆ្នាំ២០១៨-២០២២) បានធ្វើសិក្ខាសាលានិងបណ្តុះបណ្តាលដល់មន្ត្រីបានចំនួន២ ៣៨០លើក មានសិក្ខាកាមចូលរួមចំនួន២២៨ ០៥៧នាក់។

## ២.២៥- ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្មជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្មនិងស្រាវជ្រាវ បានដើរតួនាទីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់មន្ត្រីក្រសួងពាណិជ្ជទាំងថ្នាក់ជាតិនិងក្រោមជាតិ ព្រមទាំងវិស័យឯកជន។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ គិតត្រឹមដំណាច់ឆ្នាំ២០២២ វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ នៃក្រសួងពាណិជ្ជកម្មធ្វើការបើកវគ្គបណ្តុះបណ្តាល បានចំនួនសរុប **៧ ៩៣៣នាក់** ក្នុងនោះស្រីសរុបចំនួន៣ ២២២នាក់ សំដៅបំប៉នសមត្ថភាពជូនមន្ត្រីរាជការថ្នាក់ជាតិនិងក្រោមជាតិដែលមានមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត និងវិស័យឯកជនដែលមានការងារពាក់ព័ន្ធជាមួយនឹងក្រសួងពាណិជ្ជកម្ម ដូចជាការចុះបញ្ជីពាណិជ្ជកម្មនិងច្បាប់សហគ្រាសពាណិជ្ជកម្ម ការចុះបញ្ជីម៉ាកកម្មសិទ្ធិបញ្ញាដែល

ត្រូវបម្រើការងារជាអ្នកតំណាងស្របច្បាប់ក្នុងការទទួលចុះម៉ាកនិងវិធានដើមកំណើតទំនិញ ដែលមានអ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំឯកសារនាំចេញនាំចូលនៅក្រសួងពាណិជ្ជកម្ម។ វិទ្យាស្ថានក៏បានធ្វើការបណ្តុះបណ្តាលស្តីពីអង្គការពាណិជ្ជកម្មពិភពលោក(WTO) ឧបាស្រ័យពាណិជ្ជកម្ម ការធ្វើពាណិជ្ជកម្មអន្តរជាតិ លក្ខខណ្ឌពាណិជ្ជកម្មអន្តរជាតិ២០២០(Incoterm 2020) ការអភិវឌ្ឍនវិស័យឯកជន ការតាំងពិព័រណ៍ពាណិជ្ជកម្ម ការអភិវឌ្ឍទីផ្សារ ការស្រាវជ្រាវនិងការប្រើប្រាស់ឧបករណ៍វិភាគទីផ្សារអន្តរជាតិ(ITC) កិច្ចសម្រួលពាណិជ្ជកម្ម ការជំរុញពាណិជ្ជកម្ម ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក(E-Commerce) កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីពហុភាគី កិច្ចព្រមព្រៀងពាណិជ្ជកម្មថ្នាក់តំបន់ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ជាពិសេសឯកសារផែនការយុទ្ធសាស្ត្រទាញយកអត្ថប្រយោជន៍ជាអតិបរមាពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ វគ្គបណ្តុះ បណ្តាលទាំងនោះសំដៅលើកកម្ពស់សមត្ថភាពជំនាញរបស់មន្ត្រី ក៏ដូចជាលើកកម្ពស់សមត្ថភាពការយល់ដឹងរបស់វិស័យឯកជនទៅតាមជំនាញដែលមានវគ្គបណ្តុះបណ្តាលមានដូចតទៅៈ

| ល.រ | ជំនាញ | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | នីតិវិធីនាំចេញនាំចូល | ៧៥ | ៣៣ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ២ | លក្ខខណ្ឌច្បាប់ពាណិជ្ជកម្មអន្តរជាតិ ២០១០ | ៧៥ | ៣១ | ៨០ | ២៨ | ០ | ០ | ១៧១ | ៧៧ | ០ | ០ |
| ៣ | មជ្ឈត្តការពាណិជ្ជកម្ម និងច្បាប់សហគ្រាសពាណិជ្ជកម្មនៅកម្ពុជា | ៧៦ | ៣៥ | ៧០ | ១៧ | ០ | ០ | ១២៦ | ៤៧ | ០ | ០ |
| ៤ | ច្បាប់ពាណិជ្ជកម្មអន្តរជាតិក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក | ៦០ | ១៥ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៥ | ពាណិជ្ជកម្មហិរញ្ញវត្ថុអន្តរជាតិ និងការអភិវឌ្ឍចង្វាក់តម្លៃសាកល | ១៥០ | ៥៥ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៦ | ការប្រើប្រាស់កម្មសិទ្ធិបញ្ញាដើម្បីជំរុញអាជីវកម្មខ្នាតតូចនិងមធ្យម៥លើក | ២៩៦ | ១០១ | ១០៣៩ | ៤០៤ | ០ | ០ | ៣៥១ | ១២៤ | ០ | ០ |
| ៧ | ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម | ១៥០ | ៦១ | ០ | ០ | ០ | ០ | ០ | ០ | ៣០ | ១១ |
| ៨ | ព័ត៌មានទីផ្សារ | ៦០ | ៣៨ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ៩ | ខ្សែចង្វាក់តម្លៃសាកលនៅក្នុងចរន្តសេដ្ឋកិច្ចប្រទេសមហាអនុតំបន់ទន្លេមេគង្គ | ១០០ | ៤៥ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ១០ | ការស្វែងរកទីផ្សារកសិផល ដំឡូងមីនិងពោត | ៣០២ | ១១៣ | ២០១ | ១១១ | ០ | ០ | ០ | ០ | ០ | ០ |
| ១១ | នីតិវិធីនាំចេញនាំចូលនិងការប្រើប្រាស់កម្មសិទ្ធិបញ្ញាដើម្បីជំរុញអាជីវកម្មខ្នាតតូចនិងមធ្យម | ៧០ | ៣២ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| ១២ | អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំឯកសារនាំចេញនាំចូលចំនួន៦លើក | ៣៤៩ | ១៣៥ | ៣៦៩ | ១៤៩ | ៩៣ | ៣៧ | ២៩ | ៩ | ២៩២ | ១៤៥ |
| ១៣ | ការជំរុញពាណិជ្ជកម្ម | ០ | ០ | ១៤១ | ៩២ | ០ | ០ | ០ | ០ | ០ | ០ |
| ១៤ | ភស្តុភារពាណិជ្ជកម្ម | ០ | ០ | ៧៧ | ២៥ | ០ | ០ | ១០៧ | ៣៧ | ០ | ០ |
| ១៥ | ការជំរុញលើកទឹកចិត្តនិងក្រមសីលធម៌មន្ត្រីរាជការ (សៀមរាប) | ០ | ០ | ៣៣ | ១៤ | ០ | ០ | ០ | ០ | ០ | ០ |
| ១៦ | អង្គការពាណិជ្ជកម្មពិភពលោក | ០ | ០ | ៨២ | ២៧ | ០ | ០ | ០ | ០ | ៧០ | ១៦ |
| ១៧ | ផលិតកម្មកសិកម្មតាមកិច្ចសន្យា | ០ | ០ | ៩៣ | ២៣ | ០ | ០ | ០ | ០ | ០ | ០ |
| ១៨ | កិច្ចសម្រួលពាណិជ្ជកម្ម | ០ | ០ | ១៣១ | ៦៣ | ០ | ០ | ០ | ០ | ០ | ០ |
| ១៩ | ការចរចាពាណិជ្ជកម្ម | ០ | ០ | ០ | ០ | ០ | ០ | ២៥២ | ១២៣ | ២៤៦ | ៧៨ |
| ២០ | ការគ្រប់គ្រងគម្រោង | ០ | ០ | ០ | ០ | ០ | ០ | ៦៨ | ២៣ | ០ | ០ |
| ២១ | ការគ្រប់គ្រងហានិភ័យនិងស្តង់ដារពាណិជ្ជកម្ម | ០ | ០ | ០ | ០ | ០ | ០ | ១០៧ | ៤១ | ០ | ០ |
| ២២ | ស្តង់ដាអនាម័យនិងភូតគាមអនាម័យ | ០ | ០ | ០ | ០ | ០ | ០ | ១០៩ | ៤១ | ០ | ០ |
| ២៣ | ការស្រាវជ្រាវនិងឧបករណ៍វិភាគទីផ្សារអន្តរជាតិ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៨៣ | ៣៣ |
| ២៤ | ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់៖ ផលប៉ះពាល់ បញ្ហាប្រឈម និងកំណើនសេដ្ឋកិច្ចនាពេលអនាគតសម្រាប់តំបន់អាស៊ីប៉ូស៊ិហ្វិក និងអាស៊ាន | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ២០០ | ៩០ |
| ២៥ | នីតិវិធីនៃការស្រាវជ្រាវ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ២៩២ | ១៤៥ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ២៦ | ផលប៉ះពាល់ដល់សេដ្ឋកិច្ច និងពាណិជ្ជកម្ម៖ករណីសង្គ្រាមរុស្សីនិងអ៊ុយក្រែន | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១៣២ | ៦៥ |
| ២៧ | កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី៖ការទាញយកប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១២០ | ៤៥ |
| ២៨ | ការកើនឡើងនូវចំណាយពាណិជ្ជកម្ម ការផ្លាស់ប្តូរឧត្តមភាពប្រៀបធៀប និងតំបន់នីយកម្មនិយម | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៥១ | ២២ |
| ២៩ | ការចុះបញ្ជីពាណិជ្ជកម្មនិងច្បាប់សហគ្រាសពាណិជ្ជកម្ម | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៦០ | ២៥ |
| ៣០ | អនុវត្តនៃការចេញវិញ្ញាបនបត្រដើមកំណើតក្រោមកិច្ចព្រមព្រៀងអាសិប | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៣០០ | ១៣៩ |
| ៣១ | ការចូលរួមរបស់និស្សិតក្នុងការសិក្សាស្រាវជ្រាវវិស័យពាណិជ្ជកម្មកម្ពុជា | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ២១២ | ១១៥ |
| ៣២ | វេទិកាជាន់ខ្ពស់ស្តីពី"គម្រប់ខួបអនុស្សាវរីយ៍១០ឆ្នាំនៃកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់(អាសិប)និងការប្រកាសជាផ្លូវការនៃសៀវភៅទីពីររបស់វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន និងអាស៊ីបូព៌ា" | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ៣៥៣ | ៨៧ |
| | **សរុប** | ១ ៧៦៣ | ៦៩៤ | ២ ៣១៦ | ៩៥៣ | ៩៣ | ៣៧ | ១ ៣២០ | ៥២២ | ២ ៤១១ | ១០១៦ |

## ២.២៦- រាជបណ្ឌិត្យសភាកម្ពុជា

-បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ចំនួន៥ជំនាន់ ដែលមាននិស្សិតសរុបចំនួន២៩១នាក់ (ស្រី៦១នាក់)។ និស្សិតបានបញ្ចប់ការសិក្សាដោយការពារសារណា មានចំនួន២៨នាក់(ស្រី៨នាក់)

-បណ្តុះបណ្តាលនិស្សិតថ្នាក់បណ្ឌិត ចំនួន៥ជំនាន់ ដែលមាននិស្សិតសរុបចំនួន៣៦៣នាក់ (ស្រី៤៤នាក់)។ និស្សិតបានបញ្ចប់ការសិក្សាដោយការពារនិក្ខេបបទ មានចំនួន២១នាក់(ស្រី៤នាក់)

-វិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជាបង្កើតសាខានៅទូទាំងប្រទេសចំនួន២៣សាខា

-វិទ្យាស្ថានខុងជឺនៃរាជបណ្ឌិត្យសភាកម្ពុជាបានបណ្តុះលបណ្តាលសិស្សភាសាចិនសរុបចំនួន ២៦២១៤នាក់

-ការបណ្តុះបណ្តាលកម្រិតបច្ចេកទេសនិងវិជ្ជាជីវៈ ជំនាញចុងភៅនិងភេសជ្ជៈ ចំនួន៣១នាក់

-ការបណ្តុះបណ្តាលភាសាខ្មែរដល់ជនបរទេសនិងបណ្តុះបណ្តាលភាសាបរទេស ចំនួន៥២នាក់

-ធ្វើកិច្ចសហប្រតិបត្តិការជាមួយដៃគូមានស្ថាប័នជាតិនិងអន្តរជាតិ ចំនួន៣៧ស្ថាប័ន(៩ប្រទេស)។

**មុំទី៣- ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ**

**ក្រសួងសុខាភិបាល សម្រេចការងារបាន ដូចខាងក្រោម៖** (គេហទំព័រ www.moh.gov.kh)

ក្នុងដំណើរឈានទៅសម្រេចចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០៣០ រាជរដ្ឋាភិបាលកម្ពុជាក្នុងនីតិកាលទី៦ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃនិងប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានកំណត់គោលដៅយុទ្ធសាស្ត្រ៤ នៅក្នុង **«យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤»** ដើម្បីតម្រង់ទិសដៅនៃការអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយចីរភាព នៅក្នុងរយៈពេលមធ្យមនិងរយៈពេលវែង តាមរយៈការលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធាន។

ក្នុងការសម្រេចគោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្រសួងសុខាភិបាល បាននិងកំពុងអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ២០១៦-២០២០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ក្របខ័ណ្ឌជាតិនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ ដោយមានសង្គតិភាពជាមួយនឹងយុទ្ធសាស្ត្រចតុកោណ តាមរយៈពង្រឹងការគ្រប់គ្រងប្រព័ន្ធសុខាភិបាល ជាពិសេសការលើកកម្ពស់ការផ្តល់សេវាថែទាំសុខភាពមានគុណភាព សុវត្ថិភាព ប្រសិទ្ធភាព និងប្រកបដោយសមធម៌ ជូនប្រជាពលរដ្ឋកម្ពុជា នៅក្នុងគ្រប់ភូមិសាស្ត្រទូទាំងប្រទេស ដោយមិនគិតពីលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គមកិច្ច។

**១- ការផ្តល់សេវាសុខាភិបាល**

គោលបំណងចម្បងនៃការផ្តល់សេវាសុខាភិបាល គឺកាត់បន្ថយការឈឺ ស្លាប់ បន្ថយបន្ទុកជំងឺឆ្លង ជំងឺមិនឆ្លង បង្ការហានិភ័យសុខភាពសាធារណៈ និងជួយបន្ថយបន្ទុកចំណាយលើការថែទាំសុខភាពរបស់ប្រជាពលរដ្ឋ ដោយផ្តោតជាចម្បងលើការផ្តល់សេវាបង្ការជំងឺ អប់រំលើកកម្ពស់សុខភាព ធ្វើរោគវិនិច្ឆ័យ ផ្តល់ការព្យាបាលថែទាំ និងស្តារនីតិសម្បទា ពង្រឹងនិយ័តកម្ម ការផ្តល់សេវាសុខាភិបាល គ្រប់គ្រងហានិភ័យលើសុខភាពដែលបង្កដោយគ្រោះមហន្តរាយ និងចលនាប្រជាពលរដ្ឋឱ្យចូលរួមយ៉ាងសកម្មក្នុងការរក្សាសុខភាព និងសុខុមាលភាពផ្ទាល់ខ្លួន/គ្រួសារ។

ក្នុងរយៈពេល៥ឆ្នាំ (២០១៨-២០២២) ក្រសួងសុខាភិបាល សម្រេចបានសមិទ្ធផលសុខាភិបាលចម្បងៗតាមកម្មវិធីសុខាភិបាល ដូចខាងក្រោម៖

ស្ថានភាពសុខភាព និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា ត្រូវបានធ្វើឱ្យប្រសើរឡើងគួរឱ្យកត់សម្គាល់ តាមរយៈការពង្រឹងនិងពង្រីកប្រព័ន្ធផ្តល់សេវាថែទាំសុខភាពមានគុណភាព សុវត្ថិភាព ប្រសិទ្ធភាព ប្រកបដោយសមធម៌ និងពង្រីកការគ្របដណ្តប់នៃប្រព័ន្ធគាំពារសុខភាពសង្គម។ លទ្ធផលជំរឿនប្រជាជនទូទៅឆ្នាំ២០១៩បានបង្ហាញថា ជីវិតរំពឹងទុកនៅពេលកើតក្នុងឆ្នាំ២០១៩ គឺ ៧៥,៥ឆ្នាំ (បុរស ៧៤,៣ឆ្នាំ ស្ត្រី ៧៦,៨ឆ្នាំ) គឺបានកើនឡើងស្ទើរតែ ១៩ឆ្នាំខ្ពស់ជាងជីវិតរំពឹងទុក ៥៦,៧ឆ្នាំ នៅឆ្នាំ១៩៩៨។

យោងលទ្ធផលបឋមនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០២១-២០២២ ប្រៀបធៀបនឹងលទ្ធផលនៃការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១៤ បង្ហាញថា អត្រាមរណភាពមាតា ទារក និងកុមារបានបន្តធ្លាក់ចុះជាបន្តបន្ទាប់ ក្នុងនោះ អត្រាមរណភាពមាតាធ្លាក់ចុះពី ១៧០នាក់ ក្នុងចំណោមទារកកើតរស់ ១០០ ០០០នាក់ នៅឆ្នាំ២០១៤ មកនៅ ១៥៤នាក់ ក្នុងទារកកើតរស់ ១០០ ០០០នាក់ នៅឆ្នាំ២០២១-២០២២ (រូបភាពទី១) ។

**រូបភាពទី១៖ និន្នាការមរណភាពមាតាក្នុង១០០ ០០០ ទារកកើតរស់ ពីឆ្នាំ២០០០ ដល់ឆ្នាំ២០២១-២០២២**




ចំពោះអត្រាមរណភាពទារកបានធ្លាក់ចុះពី ១៨ មកត្រឹម ៨ អត្រាមរណភាពកុមារអាយុក្រោម១ឆ្នាំពី ២៨ មកត្រឹម ១២ និងកុមារអាយុក្រោម ៥ឆ្នាំពី ៣៥ មកត្រឹម ១៦ ក្នុងចំណោមទារកកើតរស់ ១ ០០០នាក់ រវាងឆ្នាំ ២០១៤ និង២០២១-២០២២ (រូបភាពទី២)។

**រូបភាពទី២៖ និន្នាការអត្រាមរណភាពក្នុង១ ០០០ ទារកកើតរស់ពីឆ្នាំ២០០០ ដល់ឆ្នាំ២០២១ ២០២២**




ការវិនិយោគធនធានរបស់រាជរដ្ឋាភិបាល នៅក្នុងបណ្តាឆ្នាំកន្លងមក រហូតមកដល់បច្ចុប្បន្ននេះ លើការពង្រឹងប្រព័ន្ធសន្តិសុខសុខភាពជាតិ (ប្រព័ន្ធអង្កេតតាមដាន និងឆ្លើយតបជំងឺឆ្លង និងគ្រោះអាសន្នសុខភាពសាធារណៈ) ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធមន្ទីរពេទ្យនិងមណ្ឌលសុខភាព ការរក្សានិរន្តរភាពនៃការផ្តល់សេវាថែទាំសុខភាពសារវន្តជាប្រចាំ នៅក្នុងបរិបទនៃការរាតត្បាតដោយជំងឺឆ្លង បានធ្វើឱ្យប្រទេសកម្ពុជាមានសមត្ថភាពឆ្លើយតបនឹងកូវីដ-១៩។

## ១.១- ការប្រើប្រាស់សេវាសុខភាព

**សេវាពិនិត្យពិគ្រោះជំងឺនិងសម្រាកព្យាបាល៖** ការប្រើប្រាស់សេវាថែទាំសុខភាពជាសារវ័ន្តនៅតាមមូលដ្ឋានសុខាភិបាលជាទូទៅរយៈពេល៥ឆ្នាំ ប្រជាជនគ្រប់វ័យទាំងពីរភេទបានមកពិនិត្យពិគ្រោះជំងឺមានចំនួនសរុប៦០ ៦៩២ ៦៣៤ករណី ក្នុងនោះករណីថ្មី មានចំនួន៤៩ ៧៩៣ ០៥១ករណី និងអ្នកជំងឺសម្រាកព្យាបាលមានចំនួន ៤ ៤៥៤ ៨១៥នាក់(រូបភាពទី៣)។ គិតជាមធ្យមប្រចាំឆ្នាំ ប្រជាជនគ្រប់វ័យទាំងពីរភេទបានមកពិនិត្យពិគ្រោះជំងឺករណីថ្មីចំនួន១០ ៤៨២ ៣៦៤ករណី និងអ្នកជំងឺសម្រាកពេទ្យចំនួន៩៣៧ ៤០៨នាក់។

រូបភាពទី ៣៖ និន្នាការនៃការប្រើប្រាស់សេវាពិនិត្យជំងឺក្រៅឆ្នាំ២០១៨-២០២២( ៩ខែ )




**ការលើកកម្ពស់គុណភាពសេវា៖** ក្រសួងសុខាភិបាល បានដាក់ឱ្យដំណើរការប្រព័ន្ធពិនិត្យតាមដាន និងលើកកម្ពស់គុណភាព (ទាំងគុណភាពបច្ចេកទេសនិងគុណភាពនៃការគ្រប់គ្រង) តាំងពីឆ្នាំ២០១៧ ដោយធ្វើការវាយតម្លៃមន្ទីរសុខាភិបាលរាជធានី ខេត្ត ទាំង២៥ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ១០៣មន្ទីរពេទ្យបង្អែកខេត្ត ស្រុក ១១៨ និងមណ្ឌលសុខភាព ១ ២៥៣កន្លែង ជាប្រចាំរៀងរាល់ត្រីមាស។ លទ្ធផលនៃការវាយតម្លៃក្នុងត្រីមាសទី៤ ឆ្នាំ២០២១ បានបង្ហាញថាពិន្ទុគុណភាពជាមធ្យមប្រមាណ ៨០% ទាំងនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកដោយកើនឡើងពី ៤០% នៅឆ្នាំ២០១៧។

**តារាងទី១៖ សូចនាករនិងលទ្ធផលនៃការផ្តល់សេវាសុខាភិបាល**

| ល.រ | សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) |
|---|---|---|---|---|---|---|
| | ការពិនិត្យពិគ្រោះជំងឺករណីថ្មីសម្រាប់ប្រជាជនម្នាក់ក្នុងមួយឆ្នាំ | ០,៧២ | ០,៧៤ | ០,៦៨ | ០,៥៣ | ០,៤២ |
| | អត្រាប្រើប្រាស់គ្រែ | ១០០,៥ | ១០៦,៨ | ៨៧,៩៧ | ៦១,០២ | ៦១,៤១ |
| | អត្រាស្លាប់នៅមន្ទីរពេទ្យ | ០,៧២ | ០,៦២ | ០,៧៥ | ១,៤០ | ០,៨៧ |

## ១.២- ការលើកកម្ពស់សុខភាពបន្តពូជ សុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភ

### ១.២.១- ការលើកកម្ពស់សុខភាពបន្តពូជ

ស្ត្រីវ័យបន្តពូជដែលបានរៀបការកំពុងប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបជាប្រចាំក្នុងឆ្នាំនីមួយៗប្រមាណជាមធ្យមចំនួន **៦២៤ ០៩៦នាក់** រវាងឆ្នាំ២០១៨-២០២២។ គួរកត់សម្គាល់ថា អតិថិជនថ្មីបានប្រើប្រាស់

មធ្យោបាយពន្យារកំណើតក្នុងរយៈពេល៥ឆ្នាំ ចំនួន**៦៩៥ ៤២៩នាក់** ដោយមានកំណើនអតិថិជនថ្មីជាមធ្យម ប្រចាំឆ្នាំប្រមាណ៥,០%។

**និន្នាការនៃការប្រើប្រាស់មធ្យោបាយពន្យារកំណើត**




### ១.២.២- ការលើកកម្ពស់សុខភាពមាតានិងទារក

ស្ត្រីមានគភ៌បានមកទទួលការពិនិត្យថៃទាំគភ៌លើកទីពីរមានចំនួន**១ ៦០៣ ៣៤៦ករណី** និង ការពិនិត្យថៃទាំគភ៌លើកទីបួនមានចំនួន**១ ២០៦ ២១៥ករណី** ចាប់ពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២។ បើគិតជាមធ្យមប្រចាំឆ្នាំ ស្ត្រីមានគភ៌បានទទួលការថៃទាំមុនសម្រាលលើកទី២ ចំនួន**៣៣៧ ៤៥៦នាក់** និង លើកទី៤ ចំនួន **២៥៣ ៩៤០នាក់**។ ទន្ទឹមនឹងនេះ ការសម្រាលកូននៅមូលដ្ឋានសុខាភិបាលក្នុង៥ឆ្នាំមានចំនួន **១ ៣៨៧ ៣១៩នាក់** រីឯការសម្រាលដោយបុគ្គលិកសុខាភិបាលមានចំនួន**១ ៤៨៥ ៦១៣**នាក់។ ចំពោះស្ត្រីក្រោយសម្រាលបានទទួលការពិនិត្យថៃទាំក្រោយសម្រាលលើកទី១ នៅមូលដ្ឋានសុខាភិបាលប្រចាំឆ្នាំនីមួយៗ ប្រមាណ**២៣១ ៤៦០នាក់** និងចំនួនសរុប**១ ០៩៩ ៤៣៦នាក់** ក្នុងរយៈពេល៥ឆ្នាំ២០១៨-២០២២។ ចំណែកទារកបានទទួលការពិនិត្យថៃទាំក្រោយសម្រាលលើកទី១ មានចំនួន**១ ០៨៣ ០៣២នាក់**។

**និន្នាការការសម្រាលកូនដោយបុគ្គលិកសុខាភិបាល**




### ១.២.៣- ការលើកកម្ពស់សុខភាពកុមារ

ប្រទេសកម្ពុជា សម្រេចបានជោគជ័យក្នុងការលុបបំបាត់ ជំងឺគ្រុនស្វិតដៃជើងនៅឆ្នាំ២០០០ និង លុបបំបាត់ជំងឺកញ្ជ្រឹលនៅឆ្នាំ២០១៥ ដែលបានទទួលស្គាល់ដោយអង្គការសុខភាពពិភពលោក។ រយៈពេល៥ឆ្នាំ ២០១៨-២០២២កុមារអាយុក្រោម១ឆ្នាំ បានទទួលវ៉ាក់សាំងពេញលេញមានចំនួន១ ៥៩៥ ៦៣៣នាក់ គិតជា

មធ្យមប្រចាំឆ្នាំមានចំនួន៣៣៥ ៩២២នាក់ ឬស្មើនឹង៩៥% សម្រេចបានតាមគោលដៅនៃផែនការយុទ្ធសាស្ត្រសុខាភិបាល។

ការពិនិត្យជំងឺក្រៅករណីថ្មីរបស់កុមារអាយុក្រោម៥ឆ្នាំ នៅមូលដ្ឋានសុខាភិបាលសាធារណៈ ក្នុងរយៈពេល៥ឆ្នាំ មានចំនួនសរុប១២ ៤៦០ ២៦៩ករណី ដោយគិតជាមធ្យមប្រចាំឆ្នាំ មានចំនួន២ ៦២៣ ២១៥ករណី។ បើគិតជាចំនួនលើកនៃការពិគ្រោះជំងឺក្រៅករណីថ្មីជាមធ្យមលើកុមារអាយុក្រោម៥ឆ្នាំ លើសពី១ដងក្នុង១ឆ្នាំ។

**និន្នាការនៃការប្រើប្រាស់សេវាថែទាំសុខភាពរបស់កុមារអាយុក្រោម៥ឆ្នាំ**




### ១.២.៤-ការកែលម្អកង្វះអាហារូបត្ថម្ភ

ទារកកើតរស់បានទទួលការបំបៅដោយទឹកដោះម្ដាយនៅក្នុងម៉ោងដំបូងក្រោយកំណើតបានចំនួន ៩២១ ៤២០ទារក ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២។ រីឯកុមារអាយុពី១២-៥៩ខែ ដែលបានទទួលថ្នាំទម្លាក់ព្រូន (ម៉េបង់ដាហ្សុលដូសទី២ ៦ខែចុងឆ្នាំ) សម្រេចបានចំនួន **៧ ០៧៤ ៦៤៤នាក់** ក្នុងរយៈពេល៤ឆ្នាំ ២០១៨-២០២១។

តារាងទី២៖ សូចនាករនិងលទ្ធផលនៃការលើកកម្ពស់សុខភាពបន្តពូជ សុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភ

| ល.រ | សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) |
|---|---|---|---|---|---|---|
| ១ | អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប (%) | ២១,៩២ | ២០,៨៤ | ២០,៤២ | ១៨,៩៥ | ១៨,០២ |
| ២ | សមាមាត្រនៃការសម្រាលដោយបុគ្គលិកសុខាភិបាលមានជំនាញ (%) | ៩០,៩៥ | ៨៩,៤៨ | ៩៣,៣៣ | ៨៥,៧៩ | ៥៧,១៨ |
| ៣ | សមាមាត្រការសម្រាលនៅមូលដ្ឋានសុខាភិបាល(%) | ៨៤,០៥ | ៨៨,១៨ | ៩០,៦៥ | ៨២,៧៧ | ៥៦,១៣ |
| ៤ | អត្រាសម្រាលដោយវិធីវះកាត់ (%) | ៦,៧៧ | ៧,១៣ | ៧,៦៧ | ៦,៥៨ | ៧,២៨ |
| ៥ | ស្ត្រីមានគភ៌ទទួលការថែទាំមុនសម្រាលពីរលើកដោយបុគ្គលិកសុខាភិបាល (%) | ៩៧,៨៤ | ១០០ | ១០០ | ៨០,៦២ | ៦៥,៣៩ |
| ៦ | ស្ត្រីមានគភ៌ទទួលការថែទាំមុនសម្រាលបួនលើកដោយបុគ្គលិកសុខាភិបាល (%) | ៧៧,២១ | ៧៩,០៨ | ៧៥,៣៧ | ៥៧,៤៧ | ៤៤,៦៦ |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | ភាគរយនៃកុមារបានទទួលការបំបៅដោយទឹកដោះម្តាយក្នុងកំលុងម៉ោងទីមួយនៃកំណើត | ៦៧ | ៦៥,៣៦ | ៧១,១៤ | ៧២,២២ | ៣៧,៤០ |
| ៨ | ភាគរយស្ត្រីមានគភ៌បានទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក៩០គ្រាប់ | ៧៩,៩៩ | ៩១,០៥ | ៨៩,៤៧ | ៧៦,១៦ | ៥៩,៦៦ |
| ៩ | ភាគរយស្ត្រីក្រោយសម្រាលបាន ទទួលគ្រាប់ជីវជាតិដែក/អាស៊ីតហ្វូលិក៤២គ្រាប់ | ៧០ | ៧៨,៦៩ | ៨០,៩៦ | ៧៧,១៦ | ៥១,៨០ |
| ១០ | អត្រាគ្របដណ្តប់នៃវ៉ាក់សាំង៣ដូស បង្ការជំងឺខាន់ស្លាក់ ស្វិតដៃជើង តេតាណូស រលាកថ្លើមប្រភេទបេ រលាកសួត/រលាកស្រោមខួរ (%) | ៩៨ | ៩៩,០ | ១០៦,៦ | ៩៨,៣១ | ៧០,៥១ |
| ១១ | អត្រាគ្របដណ្តប់នៃវ៉ាក់សាំងបង្ការកញ្ជ្រឹល-ស្អូច ដូសទី ១ (នៅខែទី៩) (%) | ១០៣ | ១០២ | ១០៧,៣ | ១០២,៧ | ៧៦,០២ |
| ១២ | ពិនិត្យពិគ្រោះជំងឺករណីថ្មីលើកុមារអាយុក្រោម ៥ឆ្នាំ | ១,៦២ | ១,២៩ | ១,២៦ | ១,២៥ | ១,០៩ |

## ១.៣- កាត់បន្ថយការឈឺនិងស្លាប់ដែលបណ្តាលមកពីជំងឺឆ្លង

### ១.៣.១- ការបង្ការនិងទប់ស្កាត់ជំងឺកូវីដ-១៩

រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ប៉ិនប្រសប់ ឈ្លាសវៃ និងម៉ឺងម៉ាត់របស់**សម្តេចអគ្គមហា-សេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវយុទ្ធសាស្ត្រ យន្តការ និងវិធានការចាំបាច់នានា ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីគ្រប់គ្រងនិងទប់ស្កាត់ការចម្លងរាតត្បាតនៃជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ ជាពិសេសសម្រាប់ការរស់នៅ និងបើកដំណើរការសកម្មភាពសង្គមសេដ្ឋកិច្ចឡើងវិញជាជំហានតាមគន្លងប្រក្រតីភាព។ ការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ មានការចូលរួមយ៉ាងសកម្មពីក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច (រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីភូមិ) និងកងកម្លាំងប្រដាប់អាវុធគ្រប់ជាន់ថ្នាក់ ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ដៃគូអភិវឌ្ឍ វិស័យឯកជន និងអង្គការសង្គមស៊ីវិល ជាពិសេសការខិតខំប្រឹងប្រែងរបស់គ្រូពេទ្យស្ម័គ្រចិត្តយុវជន**សម្តេចតេជោ ធីតា** ក្រោមការដឹកនាំរបស់លោកជំទាវបណ្ឌិត**ពេជ ចន្ទមុន្នី** ក្នុងការអនុវត្តបទបញ្ជានិងវិធានការណែនាំរបស់រាជរដ្ឋា-ភិបាលកម្ពុជា និងក្រសួងសុខាភិបាល។

ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យច្បាស់លាស់ ស្មារតីទទួលខុសត្រូវ និងបុរេសកម្មខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវ «ផែនការយុទ្ធសាស្ត្រយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សំដៅបង្កើនឱ្យបាននូវភាពស៊ាំសង្គម-សេដ្ឋកិច្ចនៅកម្ពុជា» តាមរយៈការប្រើប្រាស់អភិក្រម «**ផ្ការីក**» ដោយប្រមូលផ្តុំកម្លាំងសរុបរបស់ជាតិមកចូលរួមក្នុងការអនុវត្ត និងចាប់ផ្តើមពីចំណុចកណ្តាលនៃប្រទេស ផ្តើមចេញពីរាជធានីភ្នំពេញ និងតំបន់ទីប្រជុំសំខាន់ៗជុំវិញរាជធានីភ្នំពេញ ហើយពង្រីកទៅកាន់តំបន់ផ្សេងទៀត ស្របតាមលំដាប់លំដោយនៃការធ្វើអាទិភាវូបនីយកម្ម។ ជាលទ្ធផល កម្ពុជាសម្រេចជោគជ័យក្នុងយុទ្ធនាការជាតិចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ទាំងដូសមូលដ្ឋាន ទាំងដូសជំរុញ ដើម្បីបង្កើតនូវភាពស៊ាំសហគមន៍រឹងមាំពិតប្រាកដមួយ និងការគ្រប់គ្រងបានល្អកម្រិតហានិភ័យលើសុខភាពសាធារណៈ។ ជាក់ស្តែង គិតត្រឹមថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២២ ប្រជាជនគោលដៅចំនួន

១៦លាននាក់ដែលបានចាក់វ៉ាក់សាំងដូសទី១ ចំនួន១៥ ២២១ ៥៨០នាក់ គិតជាភាគរយ ៩៥,១៣% ដូសទី២ (ដូសមូលដ្ឋានពេញលេញ) ចំនួន ១៤ ៥៨៤ ២៦៣នាក់ គិតជាភាគរយ ៩១,១៥% ដូសទី៣ចំនួន ១០ ៣៣០ ២៩៤នាក់ គិតជាភាគរយ ៦៤,៥៦% និងដូសទី៤ចំនួន ៤ ៥៩៥ ៣៨៩នាក់ គិតជាភាគរយ ២៨,៧២% និង ដូសទី៥ចំនួន ១ ០៩៦ ៩១៤នាក់ គិតជាភាគរយ ៦,៨៥%។

**និន្នាការនៃការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ នៃប្រជាជនគោលដៅ**




**១.៣.២-ការចូលរួមប្រយុទ្ធប្រឆាំងកូវីដ-១៩ នៃក្រសួងការពារជាតិ**

- នៅក្នុងកាលៈទេសៈព្រះរាជាណាចក្រកម្ពុជាជួបវិបត្តិជំងឺកូវីដ-១៩ កងយោធពលខេមរភូមិន្ទបានចូលរួមបរិច្ចាគថវិកាយ៉ាងផុលផុសជូនដល់គណៈកម្មាធិការអន្តរក្រសួងដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ សរុបទឹកប្រាក់ **៩ ៧៦៥ ៨១៩ ០០០រៀល** និង**៤៥ ៦៤០ដុល្លារអាម៉េរិក**

-បានចាក់វ៉ាក់សាំងកូវីដ-១៩នៅទូទាំងប្រទេសគិតត្រឹមថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ ចាក់ដូសទី១បាន **១៥ ១៥៧ ៥៣២នាក់** ដូសទី២បាន**១៤ ៤៨៩ ៥៥៦នាក់** ដូសទី៣បាន**៩ ៩៤៩ ០៩៥នាក់** ដូសទី៤បាន ៣ **៨៧២ ៥៧១នាក់** និងដូសទី៥ បាន**៥៨១ ៥៥៧នាក់**។ ដោយឡែកការចាក់វ៉ាក់សាំងកូវីដ-១៩ដែលអនុវត្តដោយកងយោធពលខេមរភូមិន្ទចាក់ដូសទី១បាន**២ ៧៥៩ ៨៤៤នាក់** ដូសទី២បាន**២ ៧៣២ ៣៨០នាក់** ដូសទី៣បាន**២ ០៨៩ ៦៨២នាក់** ដូសទី៤បាន**៦៩៧ ៩៥៨នាក់** និងដូសទី៥បាន**១៣៥ ៩១៤នាក់**។

**១.៤.- ការកាត់បន្ថយការឈឺនិងស្លាប់ដែលបណ្ដាលមកពីជំងឺឆ្លងផ្សេងទៀត**

**១.៤.១- បន្ថយបន្ទុកមេរោគអេដស៍/ជំងឺអេដស៍ និងជំងឺកាមរោគ**

ប្រទេសកម្ពុជាបានទទួលជោគជ័យក្នុងការកាត់បន្ថយប្រេវ៉ាឡង់ នៃការចម្លងមេរោគអេដស៍ពី០,៩% នៅឆ្នាំ២០០៦ មកត្រឹម ០,៦ នៅឆ្នាំ២០២១។ ប្រេវ៉ាឡង់នៃអ្នកផ្ទុកមេរោគអេដស៍បានថយចុះក្នុងចំណោមប្រជាជនទូទៅ ប៉ុន្តែក្រុមប្រជាជនចំណុចដូចជាស្ត្រីបម្រើសេវាកំសាន្ត អ្នកចាក់គ្រឿងញៀន និងក្រុមបុរសស្រឡាញ់បុរសនៅតែជាក្រុមគោលដៅក្នុងការផ្ដល់សេវាបង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍។

តារាងទី៣៖ ចំនួនអ្នកជំងឺដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ និងអ្នកជំងឺសកម្មកំពុងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ រវាងឆ្នាំ២០១៨ ដល់ឆ្នាំ២០២២

| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| អ្នកជំងឺដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍ | ៥៩ ៨៣៧ | ៦១ ២៩៩ | ៦២ ២៣៩ | ៦២ ៨៣៨ | ៦៤ ២០៩ |
| អ្នកជំងឺកំពុងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ | ៥៩ ៥២៦ | ៦១ ១៩៣ | ៦២ ១៦៤ | ៦២ ៧៨១ | ៦៤ ១៩៣ |

### ១.៤.២- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍(ឆ្នាំ២០១៨-២០២២)

ប្រទេសកម្ពុជាបានប្តេជ្ញាក្នុងការបញ្ចប់អេដស៍ ដែលជាការគំរាមកំហែងសុខភាពសាធារណៈនៅឆ្នាំ២០២៥ គឺមុន៥ឆ្នាំនៃការកំណត់របស់អង្គការសហប្រជាជាតិ ដែលបានកំណត់យកឆ្នាំ២០៣០។ ទន្ទឹមនឹងនោះ យើងបានដាក់ចេញនូវផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥បានកំណត់ថាត្រូវសម្រេចគោលដៅ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ ដោយឈរលើគោលការណ៍ការចូលរួមប្រកបដោយថាមវន្តនៃភាគីពាក់ព័ន្ធ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣។ នៅឆ្នាំ២០២១ ក្នុងមហិច្ឆតាឆ្ពោះទៅសម្រេចគោលដៅ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥ និងធានានិរន្តរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានដឹកនាំរៀបចំពិនិត្យ វាយតម្លៃពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ដោយបានកំណត់នូវអនុសាសន៍ចំនួន៣០បន្ថែមសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាពនិងប្រសិទ្ធផល។ លើសពីនេះ យើងបាន និងកំពុងអនុវត្តនូវវិធានការ៦ចំណុច ដើម្បីធានាចីរភាពក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលតាមសេចក្តីជូនដំណឹងលេខ២១៣ សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

ផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ បានឈរលើគោលការណ៍បីមួយ គឺស្ថាប័នសម្របសម្រួលតែមួយ ផែនការយុទ្ធសាស្ត្រជាតិតែមួយ និងប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃតែមួយ ដោយគោរពគោលការណ៍មិនទុកនរណាម្នាក់ចោលដោយមិនបានយកចិត្តទុកដាក់ឡើយ។

សមិទ្ធផលសំខាន់ៗនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ បានឈរលើមូលដ្ឋានគ្រឹះនៃសសរស្តម្ភបី រួមមាន ៖ (១) មគ្គុទ្ទេសក៍ភាព និងភាពជាម្ចាស់ (២) ភាពជាដៃគូ និង (៣) ការវិនិយោគ។

១- មគ្គុទ្ទេសក៍ភាព និងភាពជាម្ចាស់ក្នុងការដឹកនាំ ពង្រឹងការទទួលខុសត្រូវនិងភាពជាម្ចាស់ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ទូលំទូលាយ និងពហុវិស័យ ដើម្បីសម្រេចគោលដៅក្នុងការបញ្ចប់អេដស៍នៅឆ្នាំ២០២៥។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ថា **"ខ្ញុំសូមអំពាវនាវដល់ជនរួមជាតិទាំងអស់ ឱ្យចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងចរន្តជាតិតែមួយ ឆ្ពោះទៅការបញ្ចប់អេដស៍នៅឆ្នាំ២០២៥"**។ ដើម្បីធានាចីរភាពនៃកម្មវិធីនាពេលអនាគត ក្នុងពេលដែលជំនួយអន្តរជាតិកាន់តែមានការថយចុះ រាជរដ្ឋាភិបាលបានខិតខំបង្កើនថវិកាជាតិជួយទិញឱសថព្យាបាលអ្នកជំងឺអេដស៍ជាមួយនឹងការពង្រីកថវិកាសេវាសង្គមនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ យើងក៏បានរៀបចំនូវផែនទីបង្ហាញផ្លូវសម្រាប់ចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ផងដែរ (Sustainability Road Map)។

២- ភាពជាដៃគូ៖ ការចូលរួមប្រកបដោយថាមវន្ត និងការធ្វើការងារជិតស្និទ្ធពីគ្រប់ដៃគូពាក់ព័ន្ធ ពីស្ថាប័នរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងក្រុមប្រជាជនគន្លឹះ។ ក្នុងនោះ យើងបានបញ្ចូលតំណាងក្រុមប្រជាជនគន្លឹះទៅក្នុងយន្តការនៃការឆ្លើយតបនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ជាមួយក្រសួងសុខាភិបាល យើងបានធ្វើការងារសមាហរណកម្មឆ្លើយតបនឹងជំងឺអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាល។ ក្រៅពីនោះ ជាមួយក្រសួងផែនការ យើងបានធ្វើការងារផ្តល់បណ្ណសមធម៌ដល់អ្នកផ្ទុកមេរោគអេដស៍ ដើម្បីទទួលបានប្រយោជន៍បន្ថែមក្នុងការថែទាំសុខភាព និងការគាំទ្រសង្គម។ ជាមួយនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា បានធ្វើការងារលើកិច្ចគាំពារសង្គមដល់អ្នកផ្ទុកមេរោគអេដស៍។ ក្រសួងមហាផ្ទៃបានធ្វើការងារលើកដាក់បញ្ចូលការឆ្លើយតបមេរោគអេដស៍ទៅក្នុងគោលនយោបាយ "ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព" និងដាក់សំណុំសកម្មភាពឆ្លើយតបមេរោគអេដស៍ ការបង្កបរិយាកាសអំណោយផល និងផ្តល់ការគាំទ្រសង្គមដល់គ្រួសារអ្នកផ្ទុកមេរោគអេដស៍ ចូលក្នុងផែនការសកម្មភាពរាជធានី ខេត្ត ប្រឈមខ្ពស់ចំនួន៤(រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យនិងសៀមរាប) និងផែនការអភិវឌ្ឍន៍ ព្រមទាំងផែនការវិនិយោគឃុំ សង្កាត់។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក៏បានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងឡាយបន្តជំរុញការផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងការអប់រំបង្ការការឆ្លងមេរោគអេដស៍ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងចំណោមក្រុមប្រជាជនគន្លឹះក្រុមយុវវ័យ បុគ្គលិក សហគ្រាស គ្រឹះស្ថាននានា ពលរដ្ឋចំណាកស្រុកនិងវិស័យទេសចរណ៍។

៣- ការវិនិយោគ ៖ ទាន់ពេលវេលា និងជាបន្តបន្ទាប់ទាំងធនធានមនុស្សនិងថវិកាសម្រាប់ការឆ្លើយតបមេរោគអេដស៍ ដោយផ្លាស់ប្តូរពីភាពពឹងផ្អែកទៅការឆ្លើយតបប្រកបដោយនិរន្តរភាពចំពោះការឆ្លងរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈការអនុវត្តវិធានការ៦ចំណុចទាក់ទងនឹងការឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ ដែលមានចែងក្នុងសេចក្តីជូនដំណឹងលេខ ២១៣សជណ.សស ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។ ផែនការយុទ្ធសាស្ត្រជាតិលើកទី៥ បានបញ្ជាក់ពីការផ្តល់កិច្ចគាំពារសង្គមដល់អ្នកផ្ទុកមេរោគអេដស៍ ការងារសមាហរណកម្មកម្មវិធីអេដស៍ទៅក្នុងប្រព័ន្ធសុខាភិបាល និងការងារកិច្ចសន្យាសង្គមលើការងារផ្តល់សេវាឆ្លើយតបមេរោគអេដស៍។ អាជ្ញាធរជាតិបានសម្របសម្រួល និងចលនាធនធានពីគ្រប់ដៃគូអភិវឌ្ឍ រួមមានមូលនិធិសកល អង្គការសហប្រជាជាតិ ទីភ្នាក់ងារផ្តល់ជំនួយសហរដ្ឋអាម៉េរិក ក្រសួងការបរទេសនិងពាណិជ្ជកម្មអូស្ត្រាលី(GF, UN, USAID, DEFAT)។ ចាប់តាំងពីឆ្នាំ២០១៥មក រាជរដ្ឋាភិបាលបានចូលរួមនូវថវិកាជាតិ ចំនួន១,៥លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ ហើយបានបន្តចូលរួមក្នុងបរិមាណដូចគ្នារហូតដល់ឆ្នាំ២០២០ ព្រមទាំងយល់ព្រមទទួលយកបន្ទុកចំណាយលើបុគ្គលិកកិច្ចសន្យា ក្នុងទំហំទឹកប្រាក់ចំនួនប្រមាណ១លានដុល្លារអាម៉េរិកថែមទៀត។ ជារួម រាជរដ្ឋាភិបាលបានចូលរួមថវិកាបដិភាគចំនួន៩,៤៥លានដុល្លារអាម៉េរិកសម្រាប់បីឆ្នាំ(ឆ្នាំ២០១៨-២០២០) និងថវិកាបដិភាគចំនួន១៣,៧៥លានដុល្លារសហរដ្ឋអាម៉េរិក ទៅក្នុងមូលនិធិសកលចំនួន៤១,៦លានដុល្លារអាម៉េរិក ដែលធ្វើឱ្យថវិកាមានចំនួន៥៤,៨៥លានដុល្លារសហរដ្ឋអាម៉េរិក សម្រាប់បីឆ្នាំ(ឆ្នាំ២០២១-២០២៣)។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានចូលរួមថវិកាបដិភាគលើការឆ្លើយតបមេរោគអេដស៍បានចំនួន៨,៣លានដុល្លារអាម៉េរិក គឺស្មើនឹង២៤% នៅឆ្នាំ២០១៧ និងប្រមាណជា៣៥% នៅឆ្នាំ២០២០ ហើយប្តេជ្ញាបង្កើនរហូតដល់៥០% នៅឆ្នាំ២០២៣។

ក្នុងឆ្នាំ២០២២ ក្នុងគោលបំណងចីរភាពនៃការឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលបានផ្តល់ថវិកាចំនួន៨០លានរៀលក្នុងមួយឆ្នាំដល់រាជធានី ខេត្តនីមួយៗ រួមមានរាជធានីភ្នំពេញ

បាត់ដំបង សៀមរាប និងខេត្តបន្ទាយមានជ័យ សម្រាប់អនុវត្តការងារប្រយុទ្ធនឹងជំងឺអេដស៍។ ជាបន្ថែម នៅឆ្នាំ២០២៣ខាងមុខនេះ រាជរដ្ឋាភិបាលបានសម្រេចផ្តល់ថវិកា៦០លានរៀលក្នុងមួយឆ្នាំ ដល់ខេត្តនីមួយៗ សម្រាប់១១ខេត្ត ក្នុងការអនុវត្តការងារប្រយុទ្ធនឹងជំងឺអេដស៍។

**សមិទ្ធផលទៅតាមសូចនាករសំខាន់ៗ**

១- កម្ពុជាបានសម្រេចបានគោលដៅ៩០-៩០-៩០ នៅឆ្នាំ២០១៧ មុនកាលកំណត់ ក្នុងចំណោមប្រទេសចំនួន៧ នៅក្នុងពិភពលោក ដែលប្រកាសទទួលស្គាល់ដោយកម្មវិធីអង្គការសហប្រជាជាតិ UNAIDS។

២- កម្ពុជាសម្រេចបានគោលដៅពីរមុនកាលកំណត់ក្នុងចំណោមគោលដៅទាំងបីនៃគោលដៅ៩៥-៩៥-៩៥ នៅឆ្នាំ២០២៥។ ជាលទ្ធផលនៅឆ្នាំ២០២១ សម្រេចបាន៨៤%(៩៥ ទី១) បាន៩៩%(៩៥ ទី២) និងបាន ៩៧%(៩៥ ទី៣)។

៣- អ្នកផ្ទុកមេរោគអេដស៍ចំនួន៦៤ ១៩៦នាក់ បានទទួលការថែទាំ និងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍(ARV) ពីមន្ទីរពេទ្យរដ្ឋដោយឥតបង់ថ្លៃ។

៤- អ្នកផ្ទុកមេរោគអេដស៍១០០ភាគរយ ត្រូវបានផ្តល់នូវប័ណ្ណសមធម៌ និងទទួលបានការគាំពារសង្គមពីរាជរដ្ឋាភិបាល។

៥- ការមាក់ងាយ និងរើសអើងពីខាងក្រៅលើអ្នកផ្ទុកមេរោគអេដស៍មានការធ្លាក់ចុះ ជាពិសេសការបដិសេធមិនផ្តល់ការងារគឺមានប្រមាណពី៤៦% នៅឆ្នាំ២០១០ មកនៅត្រឹមតែប្រមាណ២% នៅឆ្នាំ២០១៩។ ការបំពានជាពាក្យសម្តីមានប្រមាណពី១៤% នៅឆ្នាំ២០១០ មកនៅតែប្រមាណ២% នៅឆ្នាំ២០១៩។ ប៉ុន្តែការមាក់ងាយ និងរើសអើងដោយខ្លួនឯង ជាពិសេសអារម្មណ៍ខ្មាសអៀន នៅតែជាបញ្ហាគួរឱ្យព្រួយបារម្ភនៅឡើយដោយមានអត្រា៧១,៥% (Stigma Index 2010) និង៦២,៧% (Stigma Index 2019)។ ដោយឡែក អត្រាអ្នកផ្ទុកមេរោគអេដស៍ ដែលស្វែងរកការព្យាបាលក្រៅពីស្រុកកំណើតបានធ្លាក់ចុះពី២៤% នៅឆ្នាំ២០១០ មកនៅត្រឹម១១% នៅឆ្នាំ២០២០។

៦- តាមរយៈការអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល រហូតមកដល់ពេលនេះ អ្នកផ្ទុកមេរោគអេដស៍ប្រមាណ៤៧% បានទទួលការគាំពារសុខភាពសង្គម ដែលក្នុងនោះ ៩៨% ទទួលបានមូលនិធិសមធម៌ (HEF) និងមាន៥៤%ទៀត ទទួលបានបណ្ណសមធម៌ (តាមរយៈ Stigma Index 2019)។

៧- ដោយក្នុងនោះតាមរយៈការអនុវត្តនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងជនងាយរងគ្រោះ (មានគ្រួសារអ្នកផ្ទុកមេរោគអេដស៍) ក្នុងកំលុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩(ចំនួនគ្រួសារផ្ទុកមេរោគអេដស៍ដែលទទួលបានការបើកសាច់ប្រាក់ក្នុងកំលុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ មានសរុបចំនួន៥៤ ៦៣២គ្រួសារ (ចាប់ពីខែមិថុនា ឆ្នាំ២០២០-ខែកក្កដា ឆ្នាំ២០២២) ដែលក្នុងនោះ៖

- គ្រួសារផ្ទុកមេរោគអេដស៍ដែលមានបណ្ណសមធម៌កម្រិត១ មានចំនួន១៧ ៤៥៨គ្រួសារ
- គ្រួសារផ្ទុកមេរោគអេដស៍ដែលមានបណ្ណសមធម៌កម្រិត២ មានចំនួន៣៧ ១៧៩គ្រួសារ
- ថវិកាដែលបានបើកសាច់ប្រាក់ក្នុងកំលុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ជូនគ្រួសារដែលមានផ្ទុកមេរោគអេដស៍សរុបចំនួន១៨ ០៨១ ៩៧៦រៀល។

៨- បានដឹកនាំសម្របសម្រួល និងចលនាប្រភពធនធាន បច្ចេកទេសនិងថវិកា ក្នុងការឆ្លើយតបមេរោគអេដស៍ ដោយយើងទទួលបានថវិកាពីមូលនិធិសកលចំនួន៤១លានដុល្លារសហរដ្ឋអាម៉េរិក សម្រាប់រយៈពេលបីឆ្នាំ (ឆ្នាំ២០១៨-២០២០) និង៤១,៦លានដុល្លារសហរដ្ឋអាម៉េរិក សម្រាប់បីឆ្នាំបន្ត(ឆ្នាំ២០២១-២០២៣)។

៩- ធានាឱ្យបាននូវចីរភាព នៃការឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍ ដោយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ ទាំងថ្នាក់ជាតិ និងទាំងថ្នាក់ក្រោមជាតិធ្វើការបញ្ជ្រាប និងបញ្ចូលការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងផែនការរួមរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ស្រុក ខណ្ឌ និងឃុំ សង្កាត់។

១០- កម្ពុជា ជាប្រទេសឈរលំដាប់លេខ១ ក្នុងចំណោមបណ្ដាប្រទេសទាំងអស់នៃតំបន់អាស៊ីប៉ាស៊ីហ្វិក លើការគ្របដណ្ដប់សេវាព្យាបាលមេរោគអេដស៍និងជំងឺអេដស៍។

១១-ក្នុងការអនុវត្តគម្រោងមូលនិធិសកលៈ

- PUDR1 (មករា-មិថុនា-ឆ្នាំ២០២១)៖ ៩២%
- PUDR2 (កក្កដា-ធ្នូ-ឆ្នាំ២០២១) ៖ ៩៥%
- PUDR3 (មករា-មិថុនា ឆ្នា-២០២២)៖ ៩៩%។

១២-មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានទទួលបន្ទុកថែទាំអ្នកជំងឺអេដស៍ជាង ៥ ០០០នាក់ ដែលផ្ទេរមកពីមន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត និងគ្លីនិកសង្គម ដែលត្រូវបានប្រើប្រាស់ជាទីកន្លែងទទួលព្យាបាលជំងឺកូវីដ-១៩។

១៣- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចលនាធនធានពីប្រទេសអូស្ត្រាលីក្នុងគម្រោងDFAT បានថវិកាចំនួន១,១លានដុល្លារអាម៉េរិកពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៣។

១៤-កាកបាទក្រហមកម្ពុជា តាមរយៈកម្មវិធីឥស្សរជនថ្នាក់ជាតិនៃវេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ និងការអភិវឌ្ឍនៅកម្ពុជា(APLF)បានចូលរួមយ៉ាងសកម្មក្នុងការអប់រំ ផ្សព្វផ្សាយ បណ្ដុះបណ្ដាលតាមរយៈការផលិតកម្មវិធីផ្សេងៗ រួមមានកម្មវិធីទូរទស្សន៍ ការងារសង្គម និងការគាំពារឧបត្ថម្ភដល់អ្នកដែលរងគ្រោះដោយមេរោគអេដស៍ និងជំងឺអេដស៍។

ប្រទេសកម្ពុជា បាននិងកំពុងដំណើរការពង្រឹងប្រព័ន្ធជាតិ ភាពជាម្ចាស់ តាមរយៈការបង្កើនការផ្ដល់ថវិកាជាតិជារៀងរាល់ឆ្នាំ និងការធ្វើវិមជ្ឈការនិងវិសហមជ្ឈការដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរួមមានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ឱ្យចំលើការងារជាអាទិភាព ពិសេសក្រុមប្រជាជនគន្លឹះដែលប្រឈមមុខខ្ពស់ក្នុងការឆ្លង និងចម្លងមេរោគអេដស៍ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ ធានាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍និងជំងឺអេដស៍។

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ |
|---|---|---|---|---|
| អត្រាផ្ទុកមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យដែលមានអាយុពី១៥ ទៅ៤៩ឆ្នាំ | ០,៧០% | ០,៦% | ០,៦% | ០,៦% |
| ចំនួនអ្នកឆ្លងមេរោគអេដស៍ថ្មី/ឆ្នាំ | ១ ២០០ | ១ ១០០ | ១ ១០០ | ១ ១០០ |
| ចំនួនអ្នកស្លាប់ដោយសារជំងឺអេដស៍/ឆ្នាំ | ១ ៦០០ | ១ ៤០០ | ១ ២០០ | ១ ១០០ |
| អត្រាគ្របដណ្ដប់ដោយកម្មវិធីបង្ការការចម្លងមេរោគអេដស៍ពីម្ដាយទៅកូន (PMTCT) | ៩៣% | ៨៤% | ៩៦% | ៨០% |
| អត្រាចម្លងមេរោគអេដស៍ពីម្ដាយទៅកូន | ១៤,៣% | ១១,១% | ៨,៧% | ១៣.៦% |

| | | | | |
|---|---|---|---|---|
| ភាគរយនៃបដិភាគថវិកាជាតិសម្រាប់ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ | ២៨% | ៣១% | ៣៥% | ពុំទាន់មានតួលេខ |

### ១.៤.៣- បន្ថយបន្ទុកជំងឺរបេង

យោងតាមរបាយការណ៍ស្តីពីជំងឺរបេងសកលលោកឆ្នាំ២០២១ ( *Global Tuberculosis report* 2021 ) ដែលចេញផ្សាយដោយអង្គការសុខភាពពិភពលោក ( *WHO)* ពីទីក្រុងហ្សឺណែវ បានបញ្ជាក់យ៉ាងច្បាស់ជាថ្មីទៀតថា **«កម្ពុជាបាននិងកំពុងទទួលបានជោគជ័យយ៉ាងល្អប្រសើរក្នុងសកម្មភាពប្រយុទ្ធនឹងជំងឺរបេង»**។

ជាក់ស្តែងតាមរបាយការណ៍ក្នុងរយៈពេល២១ឆ្នាំកន្លងមកនេះ អត្រាឈឺនិងអត្រាស្លាប់ដោយជំងឺរបេងនៅកម្ពុជាបានធ្លាក់ចុះយ៉ាងខ្លាំងបើប្រៀបធៀបនឹងបណ្តាប្រទេសដទៃទៀត។ ពីឆ្នាំ២០០០ ដល់ឆ្នាំ២០២១ អត្រាស្លាប់ដោយជំងឺរបេងបានធ្លាក់ចុះ ៥០% ពី ៤២នាក់ ក្នុងចំណោមប្រជាជន ១០០ ០០០នាក់ នៅឆ្នាំ២០០០ មកនៅត្រឹម ២១នាក់ នៅឆ្នាំ២០២១ ក្នុងចំណោមប្រជាជន ១០០ ០០០នាក់។ រីឯអាំងស៊ីដង់ ឬករណីជំងឺរបេងថ្មីបានថយចុះ ៥០% ផងដែរ ក្នុងកំលុងពេលដូចគ្នា ពី៥៧៩នាក់ នៅឆ្នាំ២០០០ មកនៅត្រឹម២៨៨នាក់ នៅឆ្នាំ២០២១ ក្នុងចំណោមប្រជាជន១០០ ០០០នាក់។

ក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) អត្រាព្យាបាលជោគជ័យនៃជំងឺរបេង រក្សាបានខ្ពស់ជាង៩០%។ ជាក់ស្តែងក្នុងឆ្នាំ២០២១និងឆ្នាំ២០២២ កម្មវិធីជាតិកំចាត់រោគរបេងសម្រេចបានអត្រាព្យាបាលជោគជ័យ៩៦% ដែលលើសពីគោលដៅចំណុច៩០%។ ចំពោះការស្រាវជ្រាវរកករណីជំងឺរបេងក្នុងរយៈពេល៥ឆ្នាំ(២០១៨-ខែកញ្ញា ២០២២)ចំនួន១៣៣ ៤៩០ករណី ក្នុងនោះបានរកឃើញអ្នកជំងឺរបេងថ្មីវិជ្ជមានបេកាបូកចំនួន៤៧ ០៣២ករណី។

### ១.៤.៤- បន្ថយបន្ទុកជំងឺគ្រុនចាញ់និងជំងឺគ្រុនឈាម

ប្រទេសកម្ពុជាកំពុងស្ថិតនៅលើមាគ៌ាវឌ្ឍនភាពឆ្ពោះទៅកាន់ការលុបបំបាត់ជំងឺគ្រុនចាញ់ នៅឆ្នាំ២០២៥ តាមគោលដៅដែលបានកំណត់ក្នុងផែនការជាតិលុបបំបាត់ជំងឺគ្រុនចាញ់២០១១-២០២៥ ក្រោមគំនិតផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ គួរកត់សម្គាល់ថា ករណីឈឺនៃជំងឺគ្រុនចាញ់បានថយចុះពី ៦៥ ១១៤ករណី នៅឆ្នាំ២០១៨ មកនៅត្រឹម ៣ ០៩១ករណី នៅឆ្នាំ២០២២ (រយៈពេល៩ខែ) និងគ្មានករណីស្លាប់ដោយជំងឺគ្រុនចាញ់ ចាប់ពីឆ្នាំ២០១៨ រហូតមកដល់ឆ្នាំ២០២២។ ករណីជំងឺគ្រុនឈាមដែលបានទទួលការព្យាបាល ក្នុងរយៈពេល៥ឆ្នាំ មានសរុបចំនួន ១០៧ ១៦១ករណី ក្នុងនោះបានស្លាប់ ៩៥ករណី។

តារាងទី៤៖ សូចនាករនិងលទ្ធផលនៃការកាត់បន្ថយការឈឺនិងស្លាប់ដោយជំងឺឆ្លង

| ល.រ | សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) |
|---|---|---|---|---|---|---|
| ១ | ករណីឆ្លងថ្មីនៃមេរោគអេសដ៍ក្នុងចំណោមប្រជាជនដែលគ្មានផ្ទុកមេរោគអេដស៍ ១០០០នាក់ | ០,០៨ | ០,០៧ | ០,០៧ | ០,០៧ | ០.០៧ |
| ២ | ភាគរយនៃអ្នកផ្ទុកមេរោគអេដស៍(មនុស្សពេញវ័យនិងកុមារ) ដែលកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានធ្វើតេស្ត viral load ហើយមានលទ្ធផល viral load suppressed ក្នុងរយៈពេល១២ខែកន្លងមក | ៨៤,៦៣ | ៨៩,០ | ៩៧,០៥ | ៩៧,៣២ | ៩៧,៥៧ |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | ភាគរយនៃអ្នកផ្ទុកមេរោគអេដស៍ (មនុស្សពេញវ័យនិងកុមារ)បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ | ៩៩,៤៨ | ៩៩,៨២ | ៩៩,៨៧ | ៩៩,៩១ | ៩៩,៩៧ |
| ៤ | អត្រាព្យាបាលជោគជ័យនៃជំងឺរបេង (%) | ៩៣ | ៩៤ | ៩៤ | ៩៦ | ៩៦ |
| ៥ | ចំនួនករណីស្រាវជ្រាវជំងឺរបេងដែលបានរាយការណ៍ | ២៨ ៧៥៧ | ៣០ ០១៧ | ២៩ ១៣៦ | ២១ ៦២៧ | ២៣ ៩៥៣ |
| ៦ | អាំងស៊ីដង់នៃជំងឺគ្រុនចាញ់ (ករណីថ្មី) | ៤ | ១,៩ | ០,៦៥ | ០,២៦ | ០,១៨ |
| ៧ | អត្រាស្លាប់នៃអ្នកជំងឺគ្រុនចាញ់ដែល សម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ | ០,០ | ០,០ | ០,០ | ០,០ | ០,០ |
| ៨ | អត្រាស្លាប់ដោយជំងឺគ្រុនឈាម (%) | ០,០៩ | ០,០៧ | ០,១៣ | ០,៤២ | ០,០២ |

## ១.៥- កម្មវិធីគ្រប់គ្រងជំងឺមិនឆ្លងនិងបញ្ហាសុខភាពសាធារណៈ

### ១.៥.១- ជំងឺទឹកនោមផ្អែម បេះដូងសរសៃឈាម មហារីក

អ្នកជំងឺទឹកនោមផ្អែមដែលបានមកពិនិត្យ និងពិគ្រោះជំងឺនៅមូលដ្ឋានសុខាភិបាលសាធារណៈ បានចំនួន**៤០០ ៤៨៣ករណី** និងអ្នកជំងឺទឹកនោមផ្អែមបានសម្រាកព្យាបាល មានចំនួន៣៨ ៨៣០នាក់ ក្នុងរយៈពេល៥ឆ្នាំ។ ករណីពិគ្រោះពិនិត្យជំងឺឡើងសម្ពាធឈាមបឋមជារៀងរាល់ឆ្នាំ រវាងឆ្នាំ២០១៨ និងឆ្នាំ២០២២ មានចំនួនជាមធ្យមប្រមាណ**២៣៦ ២៣៨ករណី** និងអ្នកជំងឺឡើងសម្ពាធឈាមបឋមដែលបានសម្រាកពេទ្យជាមធ្យមប្រមាណ**១២ ៧៦១នាក់** ក្នុង១ឆ្នាំ។ ស្ត្រីអាយុក្រោម៣០ឆ្នាំ ដែលបានពិនិត្យស្រាវជ្រាវរកមហារីកមាត់ស្បូនមានចំនួនសរុប**១៥ ២៨២នាក់** ក្នុងនោះមានករណីសង្ស័យវិជ្ជមាន(*VIA test*)៥៣៨នាក់ ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដើម្បីធ្វើរោគវិនិច្ឆ័យបន្ថែមនិងទទួលការព្យាបាល។ ចំពោះស្ត្រីអាយុពី៣០ ដល់៤៩ឆ្នាំ បានមកពិនិត្យស្រាវជ្រាវរកមហារីកមាត់ស្បូនមានចំនួន៥៧ ៩០២នាក់ ក្នុងនោះមាន*VIA test*វិជ្ជមាន ចំនួន១ ២១៨នាក់ ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដើម្បីធ្វើរោគវិនិច្ឆ័យបន្ថែមនិងទទួលបានការព្យាបាលក្នុងរយៈពេល៥ឆ្នាំនេះ។

### ១.៥.២- ជំងឺផ្លូវចិត្តនិងភាពញៀនគ្រឿងញៀន

អ្នកជំងឺផ្លូវចិត្តមកទទួលសេវាពិនិត្យពិគ្រោះ និងព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈមានប្រមាណ៤៦៥ ៣៣២នាក់ និងអ្នកញៀនគ្រឿងញៀនបានទទួលសេវាពិនិត្យ ពិគ្រោះ និងព្យាបាលបានចំនួន២២ ៨៣៤នាក់ ក្នុងរយៈពេល៥ឆ្នាំ។

### ១.៥.៣- សេវាបង្ការនិងគ្រប់គ្រងពិការភាពភ្នែក

ករណីពិគ្រោះពិនិត្យជំងឺភ្នែកទូទៅបានចំនួន២ ០១៨ ៦៩៦ករណី។ រីឯការវះកាត់ជំងឺភ្នែកបានចំនួន២២៧ ៨៣៤ករណី ក្នុងនោះការវះកាត់ភ្នែកឡើងបាយបានចំនួន១៦២ ២៨៧នាក់ ដែលបានរាយការណ៍ពីមូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជន ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២។

តារាងទី៥៖ ទិន្នន័យពិនិត្យព្យាបាលជំងឺភ្នែកពីឆ្នាំ២០១៨-២០២២ (គិតជានាក់)

| សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) |
|---|---|---|---|---|---|
| ពិគ្រោះពិនិត្យជំងឺភ្នែកទូទៅ | ២៨៦ ៨៣៦ | ៤២៨ ៥២២ | ៣៣៥ ៥៩៣ | ៤១៥ ៥០២ | ៥៥២ ២៤៣ |
| វះកាត់ភ្នែកទូទៅ | ៤៥ ៥៤១ | ៥៨ ៤៦៥ | ៤៨ ១៣៧ | ៣២ ៩០៥ | ៤២ ៧៧៦ |
| វះកាត់ភ្នែកឡើងបាយ | ៣៤ ២៨៨ | ៤១ ៨៦៤ | ៣៥ ៦៨២ | ២១ ៩៣៤ | ២៨ ៥១៤ |

តារាងទី៦៖ សូចនាករនិងលទ្ធផលនៃការបង្ការនិងគ្រប់គ្រងជំងឺមិនឆ្លង

| ល.រ | សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) |
|---|---|---|---|---|---|---|
| ១ | ភាគរយនៃប្រជាជនអាយុពី ២៥-៦៤ឆ្នាំ មានជំងឺលើសសម្ពាធឈាមដំបូងបានទទួលការព្យាបាល | ៣០ | ២៣,១២ | ២៩,០៧ | ៣២,១០ | ២០,២៨ |
| ២ | ភាគរយនៃប្រជាជនអាយុពី ២៥-៦៤ឆ្នាំ មានជំងឺទឹកនោមផ្អែមបានទទួលការព្យាបាល | ៣២ | ២៨,៦ | ៤៣,១៩ | ៤៣,៨២ | ៣៤,៩០ |
| ៣ | ភាគរយនៃស្ត្រីអាយុ៣០-៤៩ឆ្នាំបានទទួលការស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូន | ០,២៦ | ០,៣១ | ៦,៣៣ | ៧,០២ | ៨,០៩ |
| ៤ | ភាគរយនៃប្រជាជនពេញវ័យមានជំងឺធ្លាក់ទឹកចិត្តបានទទួលសេវាព្យាបាល(%) | ១,៧១ (៩ ៦៦២) | ២,២ (១១ ៧៧៨) | ១,៩ (១០ ៥៣២) | ១,៦ (៨ ៩០៣) | ១,១ (៦ ៣៧៩) |
| ៥ | ចំនួនប្រជាជនប្រើប្រាស់គ្រឿងញៀនបានទទួលសេវាព្យាបាល | ៥ ៣៩៦ នាក់ | ៥ ៨៧៨ នាក់ | ៦ ៤៣៦ នាក់ | ៥ ១២៤ នាក់ | ៣២ ៥៤ នាក់ |
| ៦ | អត្រាវះកាត់ជំងឺភ្នែកឡើងបាយក្នុងប្រជាជន១លាននាក់ | ២ ២៨៦ | ២ ៥៦២ | ២ ៣៣៤ | ១ ៣៧៩ | ១ ៦៦៤ |

## ១.៦- ហិរញ្ញប្បទានប្រព័ន្ធសុខាភិបាល

### ១.៦.១- ការគ្រប់គ្រងថវិកាជាតិ

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនការវិភាជន៍ថវិកាជាតិជារៀងរាល់ឆ្នាំ ដោយមានកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ៦%។ ការចំណាយថវិកាជាតិនៅថ្នាក់កណ្តាលនិងថ្នាក់រាជធានី ខេត្ត បានតម្រង់ឆ្ពោះទៅគាំទ្រការផ្តល់សេវាសុខភាពនៅមូលដ្ឋានសុខាភិបាល ដោយធ្វើការកែលម្អលើកកម្ពស់ការផ្តល់សេវានិងគុណភាពសេវាសុខាភិបាលដល់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព។

តារាងទី៧៖ និន្នាការនៃថវិកាសុខាភិបាលវិភាជន៍រវាងឆ្នាំ២០១៨-២០២២ (ឯកតាជាលានរៀល)

| ផែនការថវិកាដែលអនុម័ត | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| ថ្នាក់វិស័យទាំងមូល | ១ ៣៩៣ ៩៧៤ | ១ ៥៤៥ ៥២៥ | ១ ៦៣៦ ៤៩៨ | ១ ៧២០ ៦៨៤ | ២ ០៨៧ ០៩៦ |
| ថ្នាក់កណ្តាល (ថ្នាក់ជាតិ) | ៨២០ ៣០៤ | ៩៣១ ៥៧២ | ៩៦១ ៤៦២ | ១ ០៣០ ២៩០ | ១ ៣២៩ ១០០ |
| ថ្នាក់រាជធានី-ខេត្ត | ៥៧៣ ៦៧០ | ៦១៣ ៩៥៣ | ៦៧៥ ០៣៦ | ៦៩០ ៣៩៤ | ៧៥៧ ៩៩៦ |

### ១.៦.២- បង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុ

រាជរដ្ឋាភិបាលកម្ពុជា បានបន្តវិនិយោគធនធានលើការពង្រីកការគ្របដណ្តប់កែលម្អគុណភាពសេវាសុខាភិបាល និងបង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុ ក្នុងគោលបំណងផ្តល់ការគាំពារផ្នែកហិរញ្ញវត្ថុក្នុងការប្រើប្រាស់សេវាថែទាំសុខភាពរបស់ប្រជាជនគោលដៅ តាមរយៈយន្តការគាំពារសុខភាពសង្គមដែលកំពុងត្រូវបានអនុវត្តដូចជាគោលនយោបាយលើកលែងការបង់ថ្លៃសម្រាប់សេវាសុខភាព កម្មវិធីមូលនិធិសមធម៌សម្រាប់ប្រជាជនក្រីក្រ និងជនងាយរងគ្រោះ កម្មវិធីមូលនិធិសមធម៌សម្រាប់កម្មករ/និយោជិតក្រៅប្រព័ន្ធ ក្រុមប្រឹក្សាឃុំ/សង្កាត់ មេភូមិ

អនុភូមិ និងសមាជិកភូមិ បុគ្គលិកនិងអ្នកជំនាញដោះមីន កីឡាករ កីឡាការិនី និងកម្មករត្រីចក្រយាន្ត របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងារសម្រាប់កម្មករ និយោជិតក្នុងប្រព័ន្ធនិងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន និងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់ស្ត្រីមានគភ៌និងកុមារអាយុក្រោមពីរឆ្នាំជាដើម។ គិតត្រឹមឆ្នាំ២០២១ ប្រជាជន ៣៩,៧% នៃប្រជាជនកម្ពុជាសរុប(ប្រមាណ១៦,៨លាននាក់) ត្រូវបានគ្របដណ្តប់ដោយមូលនិធិសមធម៌ និងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព (មិនរាប់បញ្ចូលការធានារ៉ាប់រងសុខភាពឯកជន)។

ក្នុងរយៈពេល៥ឆ្នាំ២០១៨-២០២២ ប្រជាពលរដ្ឋក្រីក្រដែលបានប្រើប្រាស់សេវាមូលនិធិសមធម៌មានចំនួនសរុប១៤ ៤៦០ ០២៨ករណី កម្មករនិយោជិតក្រៅប្រព័ន្ធ (ក្រុមប្រឹក្សាឃុំ/សង្កាត់ មេភូមិ អនុភូមិនិងសមាជិកភូមិ បុគ្គលិកនិងអ្នកជំនាញដោះមីន កីឡាករ កីឡាការី និងកម្មករត្រីចក្រយាន) បានប្រើប្រាស់សេវាថែទាំសុខភាពបានចំនួន៣២០ ១០៤ករណី កម្មករនិយោជិត និងមន្ត្រីសាធារណៈ បានប្រើប្រាស់សេវាថែទាំសុខភាពនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព បានចំនួន១០ ៤៦៣ ២៤៩ករណី។

តារាងទី៨៖និន្នាការប្រើប្រាស់សេវាថែទាំសុខភាពរបស់ប្រជាជនគោលដៅគាំទ្រដោយកម្មវិធីមូលនិធិសមធម៌និងប.ស.ស.

| ប្រជាជនគោលដៅ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) |
|---|---|---|---|---|---|
| ប្រជាជនក្រីក្រ | ៣ ០៩៧ ២២៣ | ២ ៨៨១ ២៥៤ | ៣ ២៧៧ ១២៨ | ៣ ០១៨ ៧៩៨ | ២ ១៨៥ ៦២៥ |
| កម្មករ និយោជិតក្រៅប្រព័ន្ធ | ៤៣ ៩៣២ | ៦៦ ៩១១ | ៧៩ ៦៩០ | ៧៣ ១៦៤ | ៥៦ ៤០៧ |
| កម្មករនិយោជិតនិងមន្ត្រីសាធារណៈ | ១ ៦៧៣ ៧៥២ | ២ ៣៩៩ ៤២៦ | ២ ៤០៦ ៨៩៧ | ១ ៨៩៦ ៨៥៨ | ២ ០៨៦ ៣១៦ |

## ១.៧- ការងារគ្រប់គ្រងបុគ្គលិក

ឆ្នាំ២០២២ មន្ត្រីសុខាភិបាលកំពុងបម្រើការក្នុងវិស័យសុខាភិបាលធារណៈមានចំនួនសរុប**៣២ ២៤០នាក់** (ស្រី១៧ ០៧៩នាក់) ក្នុងនោះនៅថ្នាក់ជាតិមានចំនួន**៧ ០៦៦នាក់** និងថ្នាក់ក្រោមជាតិមានចំនួន**២៥ ១៧៤នាក់**។

**និន្នាការចំនួនមន្ត្រីសុខាភិបាលសាធារណៈរវាងឆ្នាំ២០១៨-២០២២**




### ១.៧.១- សេវាគាំទ្រជាសារវ័ន្ត

ការផ្គត់ផ្គង់ឱសថបរិក្ខារគ្រប់គ្រាន់ និងទាន់ពេលវេលារួមជាមួយការប្រើប្រាស់បច្ចេកវិទ្យាវេជ្ជសាស្ត្រផ្តល់នូវមធ្យោបាយប្រកបដោយសក្តានុពល សម្រាប់អន្តរាគមន៍ក្នុងការបង្ការជំងឺ ធ្វើរោគវិនិច្ឆ័យ ព្យាបាល ថែទាំនិងស្តារនីតិសម្បទាប្រកបដោយគុណភាព សុវត្ថិភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពសម្រាប់អ្នកជំងឺ។ ឃ្លាំងឱសថកណ្តាល ក្រសួងសុខាភិបាល បានផ្គត់ផ្គង់និងបែងចែកឱសថ ប្រតិករ បរិក្ខារពេទ្យ និងវ៉ាក់សាំងដល់ស្រុក

ប្រតិបត្តិ (ដើម្បីផ្គត់ផ្គង់បន្តដល់មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ) មន្ទីរពេទ្យបង្អែករាជធានី-ខេត្ត និងមន្ទីរពេទ្យជាតិ សមស្របតាមតម្រូវការជាក់ស្តែងនៃការប្រើប្រាស់ ការរៀបចំឯកសារបញ្ចេញ ការវេចខ្ចប់ ការដឹកជញ្ជូនប្រព្រឹត្តទៅយ៉ាងទៀងទាត់រៀងរាល់បីខែម្តង តាមផែនការបែងចែកដែលបានកំណត់។

រយៈពេល៥ឆ្នាំ ពីឆ្នាំ២០១៨-២០២២ ក្រសួងសុខាភិបាល បានទទួលអំណោយឈាមដែលបានពីក្រុមគ្រួសារអ្នកជំងឺ (បរិច្ចាគជំនួស) និងអំណោយឈាមស្ម័គ្រចិត្តចំនួនសរុប **៤៨៣ ៧២៦ថ្លោក**។

### ១.៧.២- ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល

ក្រសួងសុខាភិបាល បានអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការសុខភាពជាមូលដ្ឋាន និងបង្កើតសេវាថែទាំសុខភាពឱ្យបានជិតប្រជាជនងាយនឹងមកទទួលយកសេវា។ គិតត្រឹមខែកញ្ញា ឆ្នាំ២០២២ មូលដ្ឋានសុខាភិបាលសាធារណៈបានកើនឡើងជាបន្តបន្ទាប់ ដោយមានមណ្ឌលសុខភាព **១ ២៨៣** កន្លែង ប៉ុស្តិ៍សុខភាព **១១៧កន្លែង** និងមន្ទីរពេទ្យបង្អែក **១៣១កន្លែង** (ក្នុងនោះមានមន្ទីរពេទ្យជាតិ ១១ មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ២៥ និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ៩៥ នៅក្នុងស្រុកប្រតិបត្តិ ១០៣ នៃរាជធានី ខេត្តទាំង ២៥)។ រូបភាពទី៩ បង្ហាញពីកំណើនចំនួនមូលដ្ឋានសុខាភិបាលរវាងឆ្នាំ២០១៨-២០២២។ ទន្ទឹមនឹងនេះ ក្រសួងសុខាភិបាល បានសាងសង់មណ្ឌលសុខភាពថ្មីចំនួន ១០៣កន្លែង និងមន្ទីរពេទ្យដែលសាងសង់ថ្មី ឬកែលម្អហេដ្ឋារចនាសម្ព័ន្ធឱ្យមានលក្ខណៈទំនើប រួមមានមន្ទីរពេទ្យខេត្តឧត្តរមានជ័យ មន្ទីរពេទ្យខេត្តប៉ៃលិន មន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យខេត្តមិត្តភាពកម្ពុជា-ចិនត្បូងឃ្មុំ មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ និងមន្ទីរពេទ្យហ្លួងម៉ែ។ ក្រៅពីនេះ មន្ទីរពេទ្យខេត្តមួយចំនួនក៏ត្រូវបានកែលម្អហេដ្ឋារចនាសម្ព័ន្ធ ដូចជាពង្រីកអគារនិងបំពាក់ឧបករណ៍ពេទ្យបន្ថែម។

**កំណើនចំនួនមូលដ្ឋានសុខាភិបាលរវាងឆ្នាំ២០១៨-២០២២**




### ១.៧.៣- ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានសុខាភិបាល

ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានសុខាភិបាល ដើម្បីធានាមានទិន្នន័យព័ត៌មានសុខាភិបាលត្រឹមត្រូវ គុណភាពខ្ពស់និងទាន់ពេល ព្រមទាំងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការក្នុងការប្រមូលចងក្រង វិភាគ បកស្រាយ និងប្រើប្រាស់ទិន្នន័យព័ត៌មានសម្រាប់ការកសាងគោលនយោបាយ ឬយុទ្ធសាស្ត្រសុខាភិបាល ផែនការនិងការ

ផ្សព្វផ្សាយ។ រហូតដល់បច្ចុប្បន្ននេះ ប្រព័ន្ធគ្រប់គ្រងទិន្នន័យ/ព័ត៌មានសុខាភិបាលធំ ដែលកំពុងដំណើរការក្នុងប្រព័ន្ធសុខាភិបាលសាធារណៈ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ រួមមានប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលតាមគេហទំព័រដែលកត់ត្រាទិន្នន័យនៃការផ្តល់សេវាសុខាភិបាលប្រចាំខែពីមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាពនិងមូលដ្ឋានសុខាភិបាលឯកជន ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សសុខាភិបាល ប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកជំងឺប្រព័ន្ធចុះទិដ្ឋាការបញ្ជិកាឱសថ ឧបករណ៍ បរិក្ខារពេទ្យ គ្រឹះស្ថាន ផលិតផលឱសថ និងចុះប្រវេទន៍គ្រឿងសម្អាងតាមអនឡាញ ប្រព័ន្ធព័ត៌មានគ្រប់គ្រង ឱសថ បរិក្ខារពេទ្យ និងការដឹកជញ្ជូន ប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ទីរពិសោធន៍សុខាភិបាល ប្រព័ន្ធតាមដាននិងកែលម្អគុណភាពសេវាសុខាភិបាល ប្រព័ន្ធគ្រប់គ្រងទិន្នន័យជំនួយ ប្រព័ន្ធគ្រប់គ្រងទិន្នន័យឧបករណ៍វេជ្ជសាស្ត្រ ប្រព័ន្ធព័ត៌មានគ្រប់គ្រងជំងឺរបេង ប្រព័ន្ធព័ត៌មានគ្រប់គ្រងជំងឺគ្រុនចាញ់ ប្រព័ន្ធព័ត៌មានគ្រប់គ្រងមេរោគ/ជំងឺអេដស៍ ប្រព័ន្ធកត់ត្រានិងគ្រប់គ្រងទិន្នន័យអ្នកចាក់វ៉ាក់សាំងកូវីដ១៩។ល។

**១.៧.៤- អភិបាលកិច្ចប្រព័ន្ធសុខាភិបាល**

អាជីវកម្មឱសថនិងផលិតផលសុខភាព គ្រឹះស្ថានផលិតឱសថ ផលិតឧបករណ៍បរិក្ខារពេទ្យ ផលិតគ្រឿងសម្អាង ផលិតផលិតផលជំនួយសុខភាព គ្រឹះស្ថាន សាខាគ្រឹះស្ថានអាហរណ៍នីហរណ៍ឱសថ គ្រឹះស្ថាន សាខាគ្រឹះស្ថានអាហរណ៍នីហរណ៍គ្រឿងសម្អាង មជ្ឈមណ្ឌលថែរក្សាសម្ផស្សនិងឱសថស្ថាន ឱសថស្ថានរងបានកើនឡើងពី៣ ៤៩១កន្លែង នៅឆ្នាំ២០១៨ ដល់៥ ៥២៤កន្លែង នៅឆ្នាំ២០២២។ ឆ្នាំ២០១៨-២០២២ គ្រឹះស្ថានអាហរណ៍នីហរណ៍ឱសថ គ្រឹះស្ថានអាហរណ៍នីហរណ៍ផលិតផលគ្រឿងសម្អាង អគារលក់ឱសថបុរាណនិងឱសថស្ថានដែលមិនបានគោរពតាមច្បាប់ស្តីពីការគ្រប់គ្រងឱសថត្រូវបានពិន័យអន្តរការណ៍៥៤០ករណី។ សេវាសុខាភិបាលឯកជនបានកើនឡើង១២ ៧៨៥ ដល់១៦ ១៨៥កន្លែង និងបានបិទទីតាំងដែលបានល្មើសច្បាប់១៤៧កន្លែង។

**- វិមជ្ឈការនិងវិសហមជ្ឈការ៖** ក្រសួងសុខាភិបាល បានអនុវត្តអនុក្រឹត្យលេខ១៩៣ អនក្រ.បក ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩របស់រាជរដ្ឋាភិបាលស្តីពីការប្រគល់មុខងារគ្រប់គ្រងនិងផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាល ស្តីពីលក្ខខណ្ឌបច្ចេកទេសនិងនីតិវិធីហិរញ្ញវត្ថុ សម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានី ខេត្ត និងប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត។ ត្រឹមឆ្នាំ២០២០ ក្រសួងសុខាភិបាល បានផ្ទេរទៅឱ្យរដ្ឋបាលរាជធានី ខេត្ត៖ ២៥ មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ១០៣ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ២៥ មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ៩៤ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ១ ២៥០ មណ្ឌលសុខភាព និង ១២៩ ប៉ុស្តិ៍សុខភាព និងមន្ត្រីរាជការសុខាភិបាលថ្នាក់ក្រោមជាតិ សរុបចំនួន **១៩ ៩៩៥នាក់**។

**- ការចូលរួមរបស់សហគមន៍ និងរដ្ឋបាលមូលដ្ឋានក្នុងការលើកកម្ពស់សុខភាព៖** គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព ជាយន្តការជំរុញការប្រើប្រាស់សេវាមណ្ឌលសុខភាព និងអភិវឌ្ឍមណ្ឌលសុខភាព។ គណៈកម្មការនេះ មានសមាសភាពពីក្រុមប្រឹក្សាឃុំ មណ្ឌលសុខភាព និងតំណាងសហគមន៍ និងមានភារកិច្ចចូលរួមអភិវឌ្ឍការផ្តល់សេវាសុខាភិបាលនៅមណ្ឌលសុខភាព ដូចជាជួយលើកទឹកចិត្តក្រុមទ្រទ្រង់សុខភាពភូមិ អប់រំផ្សព្វផ្សាយ និងសារសុខភាពដល់ប្រជាជន។ ក្នុងឆ្នាំ២០២១ គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពទូទាំងប្រទេសបានដំណើរការមុខងាររបស់ខ្លួនពេញលេញ តាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ដោយក្រសួងសុខាភិបាល សម្រេចលទ្ធផលបាន ៨៤,៩២% (គោលដៅចំណុចឆ្នាំ២០២១ គឺ ៨៥%)។

## ២- ការលើកកម្ពស់សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

**ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ សម្រេចលទ្ធផលការងារបានដូចខាងក្រោម៖**

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ មានតួនាទីជាគណៈបញ្ជាការឯកភាពមួយជួយរាជរដ្ឋាភិបាលក្នុងកិច្ចសម្របសម្រួលការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ ដោយសហការគ្នាយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជននិងមានភារកិច្ចទទួលបន្ទុកចាត់ចែង សម្របសម្រួល តាមដាន វាយតម្លៃនិងផ្តល់យោបល់លើការរៀបចំការអនុវត្តកម្មវិធី និងគោលនយោបាយ ព្រមទាំងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល លើការអភិវឌ្ឍវិស័យកសិកម្មនិងជនបទ និងវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា ស្របតាមគោលដៅអភិវឌ្ឍដោយចីរភាពឆ្នាំ២០៣០ពិសេសគោលដៅទី២នៃគោលដៅអភិវឌ្ឍដោយចីរភាពគឺ"បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបាននូវសន្តិសុខស្បៀង លើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ និងកសិកម្មប្រកបដោយចីរភាព" និងស្របតាមយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពដំណាក់កាលទី៤ ពិសេសចតុកោណទី១ មុំទី៣ ការលើកកម្ពស់សេវាសុខភាពសាធារណៈនិងអាហារូបត្ថម្ភ និងចតុកោណទី៤ មុំទី១ ការលើកស្ទួយវិស័យកសិកម្មនិងការអភិវឌ្ឍជនបទ។

ក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២)នេះ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដែលជាប្រធានក្រុមការងារបច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ បានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ បណ្តាញអង្គការសហប្រជាជាតិ បណ្តាញប្រទេសផ្តល់ជំនួយ បណ្តាញសម្ព័ន្ធអង្គការសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភនៅកម្ពុជា គ្រឹះស្ថានសិក្សា និងវិស័យឯកជនធ្វើការសម្រប-សម្រួល រៀបចំ និងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រនានាលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សម្រេចបានលទ្ធផលគួរជាទីមោទនៈ។ ជាក់ស្តែង ពិន្ទុសន្ទស្សន៍ នៃភាពអត់ឃ្លានសកលបានធ្លាក់ចុះពី៤៣,៥% នៅឆ្នាំ២០០០ មកត្រឹម២០,៦%នៅឆ្នាំ២០២០ អត្រាក្រិសក្រិនរបស់កុមារអាយុ៥ឆ្នាំបានធ្លាក់ចុះពី៣២%នៅឆ្នាំ២០១៤ មកត្រឹម២២%នៅឆ្នាំ២០២១-២០២២ ហើយអត្រាមិនគ្រប់ទម្ងន់របស់កុមារអាយុ៥ឆ្នាំបានធ្លាក់ចុះពី២៤%នៅឆ្នាំ២០១៤ មកត្រឹម១៦%នៅឆ្នាំ២០២១-២០២២។ សមិទ្ធផលសំខាន់ៗ រួមមាន៖

១- បានសម្របសម្រួលរៀបចំយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី២ ឆ្នាំ២០១៩-២០២៣ និងដាក់ឱ្យប្រើប្រាស់និងរៀបចំសូចនាករតាមដានរួមគ្នារបស់ក្រុមការងារបច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយផ្តោតលើការធ្វើអន្តរាគមន៍បន្ទុកទ្វេនៃបញ្ហាអាហារូបត្ថម្ភ ដើម្បីកាត់បន្ថយអត្រាក្រិសក្រិន និងអត្រាស្គមស្គាំង ព្រមទាំងទប់ស្កាត់ការកើនឡើងនៃអត្រាលើសទម្ងន់ និងធាត់ជ្រុលរបស់កុមារអាយុក្រោម៥ឆ្នាំ និងស្ត្រីក្នុងវ័យបន្តពូជ។

២- បានអនុវត្តសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ៩៣៤ស.ជ.ណ. ចុះថ្ងៃទី២០ ខែតុលាឆ្នាំ២០២០ ស្តីពីអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សម្រាប់អនុវត្តយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហា-រូបត្ថម្ភលើកទី២ ឆ្នាំ២០១៩-២០២៣។

៣- បានរៀបចំទិវាជាតិអាហារូបត្ថម្ភបាន៥លើក ក្រោមប្រធានបទ "ផ្តល់អាហារូបត្ថម្ភល្អ ដល់កូនអ្នក គឺជាការវិនិយោគដ៏ប្រសើរបំផុតក្នុងឆ្នាំ២០១៨" "ការបំបៅកូនដោយទឹកដោះម្តាយ គឺជាជម្រើសដ៏ប្រសើរសម្រាប់អភិវឌ្ឍន៍មូលធនមនុស្សនិងសេដ្ឋកិច្ចជាតិក្នុងឆ្នាំ២០១៩" "ការពង្រឹងប្រព័ន្ធស្បៀងដើម្បីរបបអាហារសុខភាព ក្នុងឆ្នាំ២០២០" "ការពង្រឹងប្រព័ន្ធស្បៀងដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពក្នុងឆ្នាំ២០២១" និង"ម្ហូបអាហារ

កាន់តែមានសុវត្ថិភាព សុខភាពកាន់តែល្អប្រសើរ"ក្នុងឆ្នាំ២០២២ និងបានរៀបចំទិវាអាហារូបត្ថម្ភថ្នាក់ក្រោមជាតិ ទៅតាមប្រធានបទនីមួយៗនៅតាមបណ្តាខេត្តមួយចំនួន ដើម្បីផ្សព្វផ្សាយសារលិខិត**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

៤- បានរៀបចំកិច្ចសន្ទនាជាតិស្តីពីប្រព័ន្ធស្បៀងចំនួន៣០លើក ដែលមានអ្នកចូលរួមប្រមាណ២០០០នាក់ ដើម្បីប្រមូលធាតុចូលរៀបចំផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជាឆ្នាំ២០៣០ និងសម្រាប់កិច្ចប្រជុំកំពូលពិភពលោកស្តីពីប្រព័ន្ធស្បៀង ដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិនៅទីក្រុងញូវយក កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ និងកិច្ចប្រជុំកំពូលស្តីពីអាហារូបត្ថម្ភដើម្បីកំណើននៅទីក្រុងតូក្យូ ប្រទេសជប៉ុន កាលពីថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២១ ។

៥- បានរៀបចំបង្កើតក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភរាជធានីខេត្ត ទាំង២៥ និងបានបណ្តុះបណ្តាលដល់ក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភថ្នាក់ខេត្ត និងក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីបញ្ជ្រាបការងារសន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលឃុំ សង្កាត់។

៦- បានកសាងសមត្ថភាពដល់មន្ត្រី និងគ្រូបង្គោលលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភតាមរយៈការចូលរួមព្រឹត្តិការណ៍និងកិច្ចប្រជុំអន្តរជាតិ ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងបានធ្វើការកែសម្រួលកម្មវិធីបណ្តុះ-បណ្តាលគ្រូបង្គោល បានរៀបចំឯកសារបណ្តុះបណ្តាលសន្តិសុខស្បៀងនិងអាហារូបត្ថម្ភសម្រាប់សិក្ខាកាម និងរៀបចំឯកសារជំនួយស្មារតីស្តីពីការបញ្ជ្រាបការងារសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ក្នុងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលឃុំ សង្កាត់។

៧- បានលើកកម្ពស់បញ្ហាយេនឌ័រយុវជន និងបរិស្ថានក្នុងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភតាមរយៈការរៀបចំវេទិកាយុវជនស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភតាមគ្រឹះស្ថានសិក្សា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ កម្មវិធីបោះជំរុំយុវជនអាហារូបត្ថម្ភ និងរៀបចំឱ្យមានក្រុមយុវជនជើងឯកអាហារូបត្ថម្ភ និងក្រុមអ្នកសារព័ត៌មានអាហារូបត្ថម្ភដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយពីសារៈសំខាន់នៃវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ សុវត្ថិភាពម្ហូបអាហារជូនដល់សាធារណជនឱ្យបានយល់ដឹងកាន់តែទូលំទូលាយ និងចូលរួមជាមួយនឹងរាជរដ្ឋាភិបាលក្នុងការអនុវត្តច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ និងឯកសារគតិយុត្តនានា។

៨- បានពង្រឹងយន្តការស្ថាប័នដើម្បីលើកកម្ពស់អភិបាលកិច្ចលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភទាំងថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការចូលរួមអនុវត្តផែនការសកម្មភាព នៃចលនាបង្កើនអាហារូបត្ថម្ភពិភពលោក ដោយបង្កើតបាននូវបណ្តាញធុរកិច្ច បង្កើនអាហារូបត្ថម្ភ នៅកម្ពុជា និងបានកែសម្រួលនិងបន្តដំណើរការក្រុមការងារបច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ បានរៀបចំវេទិកាសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ វេទិកានានា និងបង្កើតក្រុមការងារដឹកនាំសម្របសម្រួលវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភតាមខេត្ត។

៩- បានលើកកម្ពស់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយផ្តោតលើភាពមានស្បៀង ភាពទទួលបានស្បៀង ការប្រើប្រាស់និងការបឺតស្រូបស្បៀង ស្ថិរភាពស្បៀង ដោយផ្តោតការយកចិត្តទុកដាក់លើការសម្របសម្រួលពហុវិស័យ ដូចជារបបអាហារសុខភាព ទឹកស្អាត និងអនាម័យ ដែលគិតគូរដល់អាហារូបត្ថម្ភ ខ្សែច្រវាក់តម្លៃស្បៀងសុវត្ថិភាពស្បៀង និងការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ អាហារូបត្ថម្ភដឹកនាំដោយសហគមន៍ជំនួយសង្គមនិងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ សន្តិសុខស្បៀងនិងអាហារូបត្ថម្ភក្នុងបរិបទនៃការគ្រប់គ្រងគ្រោះមហន្តរាយនិងការប្រែប្រួលអាកាសធាតុ។

១០- បានពង្រឹងការគ្រប់គ្រងប្រព័ន្ធព័ត៌មាននិងចំណេះដឹងស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភតាមរយៈការប្រមូលចងក្រងនិងវិភាគទិន្នន័យដើម្បីបង្ហាញព័ត៌មានសន្តិសុខស្បៀង និងអាហារូបត្ថម្ភជូនដល់អ្នកធ្វើសេចក្តីសម្រេចចិត្តដោយបានរៀបចំកែលម្អនិងធ្វើបច្ចុប្បន្នភាពជាប្រចាំលើគេហទំព័រសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា (www.foodsecurity.gov.kh) និងបានរៀបចំនិងធ្វើបច្ចុប្បន្នភាពជាប្រចាំFacebook page: Cambodia Food Security and Nutrition Information System Office (https://web.facebook.com/fsncu2016) និងFacebook page: អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ព្រមទាំងបានវិភាគពីស្ថានភាពសន្តិសុខស្បៀងជាទៀងទាត់។

១១- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ** បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយៈ

- អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ និងតំណាងស្ថានទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ប្រចាំព្រះរាជាណាចក្រកម្ពុជា លើសេចក្តីថ្លែងការណ៍ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងកំលុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩
- អង្គការជីអាយហ្សីតនៅកម្ពុជា លើកិច្ចព្រមព្រៀងស្តីពីការអនុវត្តគម្រោងពហុវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា (MUSEFO) និងសម្រាប់អនុវត្តគម្រោងចាប់ពីឆ្នាំ២០១៨ ដល់ខែមិថុនា ឆ្នាំ២០២២។
- កម្មវិធីស្បៀងអាហារពិភពលោកប្រចាំកម្ពុជា លើកិច្ចព្រមព្រៀងស្តីពីការសម្របសម្រួលលើសកម្មភាពរួមពហុវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ។

១២- បានដឹកនាំសម្របសម្រួលរៀបចំវាយតម្លៃពាក់កណ្តាលអាណត្តិរបស់វិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ដាក់ជូនក្រសួងផែនការដើម្បីរៀបចំវាយតម្លៃពាក់កណ្តាលអាណត្តិផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ ។

១៣- រៀបចំធ្វើការវាយតម្លៃពាក់កណ្តាលអាណត្តិនៃការអនុវត្តយុទ្ធសាស្រ្តជាតិ ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី២ឆ្នាំ២០១៩-២០២៣ ដើម្បីពិនិត្យលើវឌ្ឍនភាពសម្រេចបាន បញ្ហាប្រឈម និងដាក់ចេញនូវអនុសាសន៍សម្រាប់រៀបចំយុទ្ធសាស្រ្តជាតិស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភលើកទី៣ ឆ្នាំ២០២៤-២០២៨។

១៤- បានកែសម្រួលឈ្មោះ តួនាទី ភារកិច្ច និងសមាសភាពក្រុមការងារបច្ចេកទេសលើវិស័យគាំពារសង្គម សន្តិសុខស្បៀង និងអាហារូបត្ថម្ភទៅជាក្រុមការងារបច្ចេកទេសចម្រុះលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដើម្បីឱ្យសមស្របទៅនឹងសភាពការណ៍វិវត្តនាពេលបច្ចុប្បន្ន និងបានរៀបចំប្រជុំក្រោមអធិបតីភាព**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ** ជាទៀងរាល់ឆមាស ដើម្បីដាក់ចេញនូវទិសដៅអនុវត្តលើវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។

១៥- បានរៀបចំរបាយការណ៍សង្ខេបស្តីពីវឌ្ឍនភាពរយៈពេល២០ឆ្នាំ លើវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជាដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា ដើម្បីអបអរសាទរពិធីប្រារព្ធខួប២០ឆ្នាំនៃគោលនយោបាយឈ្នះឈ្នះរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

១៦- បានដឹកនាំនិងសម្របសម្រួលអនុវត្តផែនការសកម្មភាពនិងរៀបចំរបាយការណ៍ប្រចាំឆ្នាំជាទៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៧ដល់២០២២ របស់ចលនាបង្កើនកិច្ចអន្តរាគមន៍អាហារូបត្ថម្ភនៅកម្ពុជា ដើម្បីដាក់ជូន

ចលនាបង្កើនកិច្ចអន្តរាគមន៍អាហារូបត្ថម្ភពិភពលោក ដែលសម្របសម្រួលដោយតំណាងពិសេសអគ្គលេខាធិការ អង្គការសហប្រជាជាតិទទួលបន្ទុកការងារសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។

១៧- បានរៀបចំវេទិកាសន្តិសុខស្បៀងជាទៀងទាត់រៀងរាល់២ខែម្តង ដើម្បីផ្តល់ឱកាសឱ្យអ្នកពាក់ព័ន្ធចូលរួមពិភាក្សាផ្លាស់ប្តូរយោបល់និងចែករំលែកបទពិសោធន៍លើការងារផ្សេងៗ ដែលទាក់ទងវិស័យសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា។

១៨- បានដឹកនាំនិងសម្របសម្រួលកិច្ចប្រជុំអនុក្រុមការងារទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ រៀបចំសន្និសីទជាតិលើកទី២ ស្តីពីសមាហរណកម្មវិស័យទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ ក្រោមប្រធានបទ "បទពិសោធន៍នៅកម្ពុជា លទ្ធផលអនុវត្តកម្មវិធីសមាហរណកម្មដើម្បីលើកកម្ពស់អាហារូបត្ថម្ភ" និងបានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីការផ្សព្វផ្សាយឯកសារស្វែងយល់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដែលគិតគូរពីអាហារូបត្ថម្ភ។

១៩- បានដឹកនាំនិងសម្របសម្រួលកិច្ចប្រជុំក្រុមការងារអន្តរក្រសួងសម្រាប់វាយតម្លៃការងារគាំពារសង្គម និងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភដោយប្រើប្រាស់ឧបករណ៍កម្មវិធី Inter-Agency Social Protection Assessment (ISPA) និងបានរៀបចំសិក្ខាសាលាស្តីពីកិច្ចប្រឹក្សាយោបល់អ្នកពាក់ព័ន្ធ ដើម្បីពិនិត្យមើលរបាយការណ៍នៃការសាកល្បងអនុវត្តឧបករណ៍ ISPA/FSN នៅកម្ពុជា ។

២០- បានសហការផលិតនិងចាក់ផ្សាយស្ពតវីដេអូថ្មី ស្តីពីការអប់រំអាហារូបត្ថម្ភជាមួយអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ដើម្បីលើកកម្ពស់ការយល់ដឹងនិងការអនុវត្តប្រកបដោយភាពវិជ្ជមានលើវិស័យកសិកម្ម សុខភាព អាហារូបត្ថម្ភ ទឹកស្អាត និងអនាម័យ។

២១- បានរៀបចំគោលនយោបាយ ការវិភាគ និងបោះពុម្ពឯកសាររួមមាន៖

- សេចក្តីថ្លែងការណ៍ស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភក្នុងកំលុងពេលរាតត្បាតនៃជំងឺកូវីដ-១៩។
- សន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅក្នុងបរិបទនៃជំងឺកូវីដ-១៩ សម្រាប់ប្រទេសកម្ពុជា
- ការវាយតម្លៃរហ័សនៃផលប៉ះពាល់កូវីដ-១៩ លើវិស័យកសិកម្ម និងសន្តិសុខស្បៀងនៅកម្ពុជាដែលឆ្លើយតបទៅនឹងគោលនយោបាយ
- ការវិភាគពីគម្លាតគោលនយោបាយដែលទាក់ទងនឹងប្រព័ន្ធស្បៀង សម្រាប់ជាមូលដ្ឋានរៀបចំផែនការសកម្មភាពអនុវត្តផែនទីបង្ហាញផ្លូវស្តីពីប្រព័ន្ធស្បៀងសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជាឆ្នាំ២០៣០។
- បានធ្វើការវិភាគសាកល្បងស្តីពីផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ដោយបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលស្តីពីការប្រមូលព័ត៌មាននៃផលប៉ះពាល់ពីជំងឺកូវីដ-១៩ នៃគម្រោងប្រមូលទិន្នន័យផលប៉ះពាល់ពីជំងឺកូវីដ-១៩ ថ្នាក់ក្រោមជាតិនៅឃុំស្រុកគោលដៅនៃខេត្តកំពង់ធំនិងខេត្តកំពត ហើយនឹងពង្រីកការប្រើប្រាស់ឧបករណ៍តាមដានត្រួតពិនិត្យនេះទៅខេត្តផ្សេងៗទៀត
- បានធ្វើការសិក្សាវាយតម្លៃបែបគុណភាពនៃប្រព័ន្ធត្រួតពិនិត្យម្ហូបអាហារនៅកម្ពុជា និងដាក់ចេញអនុសាសន៍សម្រាប់អ្នកបង្កើតគោលនយោបាយ អ្នកធ្វើសេចក្តីសម្រេច និងកំណត់អាទិភាពដើម្បីកែលម្អប្រព័ន្ធត្រួតពិនិត្យម្ហូបអាហារសម្រាប់ប្រទេសកម្ពុជា។

## មុំទី៤- ការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម

### ១- ការពង្រឹងសមភាពយេនឌ័រ

**ក្រសួងកិច្ចការនារីសម្រេចការងារដូចខាងក្រោម៖ (ហ្វេសប៊ុកផេក** : Ministry of Women's Affairs of Cambodia គេហទំព័រ www.mowa.gov.kh )

ក្រសួងកិច្ចការនារីជាយន្តការថ្នាក់ជាតិសម្រាប់លើកកម្ពស់ស្ថានភាព ឋានៈ តួនាទីរបស់ស្ត្រីនៅកម្ពុជា តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រ៥ឆ្នាំនារីរតនៈទី៥ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាដំណាក់កាលទី៤ នីតិកាលទី៦នៃរដ្ឋសភា **ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** កសាងមូលដ្ឋានឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ដោយផ្តោតលើការលើកកម្ពស់ចំណេះដឹងជំនាញវិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការស្នេហាជាតិ ការងារអប់រំសុខភាព និងកាយសម្បទារឹងមាំ តួនាទីស្ត្រីនិងកិច្ចគាំពារសង្គម។ ក្នុងនោះមុំទី៤ នៃចតុកោណទី១ ផ្តោតលើការពង្រឹងសមភាពយេនឌ័រនិងកិច្ចគាំពារសង្គម ដោយបន្តធ្វើបច្ចុប្បន្នភាពនិងអនុវត្តផែនការនារីរតនៈ តាមរយៈការបន្តជំរុញសមភាពយេនឌ័រទៅក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍគ្រប់ផ្នែក គ្រប់វិស័យនិងគ្រប់កម្រិត បន្តលើកកម្ពស់សហគ្រិនភាពស្ត្រី តាមរយៈការពង្រីកកម្មវិធីអប់រំនិងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដល់ស្ត្រី ព្រមទាំងបន្តលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរ។

### ២- ការពង្រឹងសមភាពយេនឌ័រនិងការគាំពារសង្គម

#### ២.១- ការពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចនិងសហគ្រិនភាពរបស់ស្ត្រី

- មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី បានបង្កើតនិងដំណើរការពីឆ្នាំ២០២១ ក្នុងការគាំទ្រដល់ការអភិវឌ្ឍសហគ្រិនភាពដល់ស្ត្រី ជាពិសេសអាជីវករកម្រិតមីក្រូនិងលក្ខណៈគ្រួសារ។ ជាលទ្ធផល នៅឆ្នាំ២០២១ ស្ត្រីជាអាជីវករ ចំនួន១០៨នាក់ បានទទួលការគាំទ្រនិងអភិវឌ្ឍអាជីវកម្ម មជ្ឈមណ្ឌលអភិវឌ្ឍន៍សហគ្រិនភាពស្ត្រី បានបង្កើតភាពជាដៃគូរយៈពេលវែងជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍ ក្នុងការគាំទ្រនិងអភិវឌ្ឍសហគ្រិនភាពសម្រាប់ស្ត្រី និងក្មេងស្រីនៅក្នុងវិស័យធុរកិច្ច។ សហគ្រិនស្ត្រីកម្ពុជា បានចូលរួមជាសមាជិកបណ្តាញសហគ្រិនស្ត្រីអាស៊ាន និងទទួលបានពានរង្វាន់សហគ្រិនស្ត្រីឆ្នើមអាស៊ាន ចំនួន៤៣រូប
- ភាពជាដៃគូរវាងក្រសួងកិច្ចការនារី និងធនាគារជាតិនៃកម្ពុជា គាំទ្រពីក្រុមហ៊ុនវីសា បានលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុសម្រាប់ស្ត្រីពីឆ្នាំ២០២០ ដល់ឆ្នាំ២០២២ តាមរយៈកម្មវិធីបណ្តុះបណ្តាលចំណេះដឹង និងសមត្ថភាពគ្រប់គ្រងនិងប្រើប្រាស់សេវាហិរញ្ញវត្ថុបែបឌីជីថល ដើម្បីអភិវឌ្ឍអាជីវកម្មដល់ស្ត្រី ចំនួន១ ៤៣១នាក់ នៅក្នុងខេត្តគោលដៅចំនួន៤
- មជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី១៤ និងមន្ទីរកិច្ចការនារី២៥រាជធានី ខេត្ត បានគាំទ្រនិងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងការចាប់ផ្តើមអាជីវកម្មនិងមុខរបរដល់ស្ត្រីនៅតាមសហគមន៍ ចំនួន១៨ ៧០០នាក់ ក្នុងរយៈពេល ៥ឆ្នាំ (ឆ្នាំ២០១៨-២០២២) នៅក្នុងនោះមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រី ចំនួន៤(ខេត្តសៀមរាប កំពង់ស្ពឺ កំពង់ចាម និងខេត្តស្ទឹងត្រែង) បានជ្រើសរើសនិងធ្វើពិពិធកម្មមុខងារដោយផ្តោតលើមុខងារថ្មី ១- ការគាំទ្រដល់សហគ្រិនស្ត្រីនៅតាមបណ្តាខេត្ត ២- ការអភិវឌ្ឍអាជីវកម្មផ្នែកឌីជីថល និង៣- ការអភិវឌ្ឍមុខរបរដល់ស្ត្រីដែលងាយរងគ្រោះនៅតាមទីជនបទ

- គម្រោងបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ក្នុងខេត្តចំនួន៥(ខេត្តកំពង់ឆ្នាំង កំពង់ចាម សៀមរាប កំពង់ធំ និងខេត្តត្បូងឃ្មុំ) បានអនុវត្តដោយផ្តល់ជំនាញនិងបច្ចេកទេសចិញ្ចឹមមាន់ ដាំបន្លែ សិប្បកម្ម សេវាកម្ម ទេសចរណ៍ និងសេវាកម្មផ្សេងៗ ក្នុងការលើកកម្ពស់សេដ្ឋកិច្ចគ្រួសារដល់ប្រជាជនចំនួន៤៧៣នាក់(ស្រី២៥៤ នាក់) និងផ្តល់កុំព្យូទ័របន្ទះចំនួន៣១គ្រឿង

- ក្រសួងកិច្ចការនារី ទទួលបានគម្រោងថ្នាក់តំបន់មេគង្គ-ឡានឆាង ស្តីពីការពង្រឹងភាពអង់អាចផ្នែក សេដ្ឋកិច្ចដល់ស្ត្រីក្នុងយុគសម័យឌីជីថល សម្រាប់ការអនុវត្តក្នុងឆ្នាំ២០២២-២០២៣។ ក្រសួងដឹកនាំការអនុវត្ត គម្រោងជាមួយប្រទេសវៀតណាមនិងថៃ ដើម្បីសិក្សាស្រាវជ្រាវនិងអនុវត្តគំនិតផ្តួចផ្តើមនានាដើម្បីយកទៅប្រើប្រាស់ សម្រាប់ការបង្កើតវិធានការគោលនយោបាយ ក្នុងការពង្រឹងសក្តានុពលផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីនៅក្នុងយុគសម័យ ឌីជីថលនៅក្នុងប្រទេសទាំងបី(កម្ពុជា វៀតណាមនិងថៃ)។

## ២.២- ការលើកកម្ពស់ស្ត្រីនិងក្មេងស្រីក្នុងការសិក្សាអប់រំ

- ផែនការយុទ្ធសាស្ត្រជាតិវិស័យអប់រំបានឆ្លើយតបយេនឌ័រនិងគម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ ត្រូវបាន កាត់បន្ថយគួរឱ្យកត់សម្គាល់ ជាពិសេសនៅកម្រិតបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។ ជាក់ស្តែង ឆ្នាំសិក្សា២០២០-២០២១ សិស្សស្រីប្រឡងជាប់មធ្យមសិក្សាបឋមភូមិ មាន៥៣% និងមធ្យមសិក្សា ទុតិយភូមិ៥៤,៣% ហើយទទួលបាននិទ្ទេសA មាន៥៩,៧%

- ក្រសួងកិច្ចការនារី បានដឹកនាំនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការអភិវឌ្ឍ ផែនការសកម្មភាពស្តីពីការបង្ការទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារនៅកម្ពុជា ២០១៧-២០២១ និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៧

- បានផ្តួចផ្តើមនិងដឹកនាំបង្កើតយុទ្ធសាស្ត្រស្តីពីការចិញ្ចឹមកូនបែបវិជ្ជមាន ពីឆ្នាំ២០១៤ និងបន្តអនុវត្ត កម្មវិធីអភិវឌ្ឍសមត្ថភាពមន្ត្រីនិងអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ព្រមទាំងបានបញ្ជ្រាបទៅក្នុង គោលនយោបាយ ផែនការសកម្មភាព និងកម្មវិធីសិក្សា ដើម្បីលើកកម្ពស់ការយល់ដឹងរបស់មាតាបិតា អាណា-ព្យាបាល និងអ្នកថែទាំតាមសហគមន៍នៅក្នុងខេត្តគោលដៅ ដើម្បីកែប្រែផ្នត់គំនិតនិងផ្លាស់ប្តូរឥរិយាបថអំពីការ ចិញ្ចឹមកូនតាមបែបវិជ្ជមាននិងវប្បធម៌អហិង្សា និងចូលរួមលើកកម្ពស់សីលធម៌សង្គម។ ជាលទ្ធផល មាតាបិតា អាណាព្យាបាល និងអ្នកថែទាំចំនួន២០ ៥៤៩នាក់ (ស្រី១៧ ៣៦៧នាក់) នៅក្នុងរាជធានីខេត្តគោលដៅចំនួន ៦ គឺរាជធានីភ្នំពេញ ខេត្តកណ្តាល បាត់ដំបង សៀមរាប រតនគិរី និងខេត្តក្រចេះ បានទទួលចំណេះដឹង និង ឥរិយាបថចិញ្ចឹមកូនបែបវិជ្ជមាន អប់រំកូនៗដោយក្តីស្រឡាញ់និងភាពកក់ក្តៅ បង្កើនទំនាក់ទំនងកាន់តែល្អនិង កាត់បន្ថយការប្រើប្រាស់អំពើហិង្សា

- បានចូលរួមចំណែកក្នុងការលើកកម្ពស់ប្រសិទ្ធភាពការងារនិងរក្សាសុខុមាលភាពរបស់មន្ត្រីរាជការ ក្នុងការអភិវឌ្ឍកុមារតូច ក្រសួងកិច្ចការនារីបានបង្កើត និងដំណើរការថ្នាក់ទារកដ្ឋានចាប់តាំងពីឆ្នាំ២០១៨ ព្រមទាំង រៀបចំសេចក្តីណែនាំស្តីពីដំណើរការថ្នាក់ទារកដ្ឋានទុកជាគំរូដល់ក្រសួង ស្ថាប័នដទៃទៀត

- គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរបានដឹកនាំ និងសម្រប សម្រួលជាមួយក្រសួង ស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អាជ្ញាធរមានសមត្ថកិច្ច សង្គមស៊ីវិល និងដៃគូ អភិវឌ្ឍ ដើម្បីអនុវត្តវិធានការគ្រប់មធ្យោបាយ រួមទាំងកម្មវិធីនិងវិធានការតាមប្រព័ន្ធឌីជីថល ក្នុងការលើកកម្ពស់

ការគោរពសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងលើកកម្ពស់ការគោរពច្បាប់និងកាត់បន្ថយការរើសអើងការរំលោភបំពាន និងទប់ស្កាត់រាល់រូបភាពដែលបង្កនិងប៉ះពាល់ជាអវិជ្ជមានដល់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ជាពិសេសឆ្លើយតបនឹងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជានិងជាប្រធានកិត្តិយសនៃគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ

-ក្រសួងកិច្ចការនារី សហការជាមួយក្រុមប្រឹក្សាសកម្មភាពជនពិការ បានបញ្ជ្រាបយេនឌ័រទៅក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព២០១៩-២០២៣ និងបានអនុវត្តកម្មវិធីបណ្តុះបណ្តាល និងស្វែងរកការគាំទ្រមតិក្នុងការបញ្ជ្រាបយេនឌ័រនិងពិការភាពក្នុងគោលនយោបាយនិងផែនការសកម្មភាពរបស់វិស័យពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

### ២.៣- ការលើកកម្ពស់សុខភាពរបស់ស្ត្រីនិងក្មេងស្រី

- បានសហការជាមួយវិទ្យាស្ថានជាតិស្ថិតិ ដោយបានដាក់បញ្ចូលជំពូកស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រក្នុងអង្កេតប្រជាសាស្ត្រនិងសុខភាពនៅកម្ពុជា ឆ្នាំ២០២១-២០២២

- ផែនការយុទ្ធសាស្ត្រជាតិនារីរតនៈស្តីពីការលើកកម្ពស់សមភាពយេនឌ័រនិងសុខភាព ត្រូវបានអនុវត្តតាមរយៈកម្មវិធីកាត់បន្ថយគម្លាតយេនឌ័រ និងលើកកម្ពស់សុខភាពបន្តពូជ សុខភាពមាតា ទារក អាហារូបត្ថម្ភ ប្រយុទ្ធនឹងជំងឺឆ្លង(ជំងឺកាមរោគ និងជំងឺអេដស៍) និងជំងឺមិនឆ្លង (មហារីកមាត់ស្បូន មហារីកសុដន់ សុខភាពភ្នែក) ដើម្បីបង្កើនចំណេះដឹង និងធ្វើការអប់រំផ្សព្វផ្សាយទៅដល់ប្រជាពលរដ្ឋទូទៅឱ្យចេះថែទាំសុខភាពសមាជិកគ្រួសារ និងទៅទទួលយកសេវាថែទាំសុខភាពនៅមូលដ្ឋានសុខាភិបាលឱ្យបានទាន់ពេលវេលា ជាការឆ្លើយតបទៅគោលដៅរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលក្នុងការកាត់បន្ថយអត្រាមរណភាពមាតា និងកុមារ។ ជាលទ្ធផល អត្រាមរណភាពមាតាមានការថយចុះពី១៧០នាក់(នៅឆ្នាំ២០១៤) មក១៥៤នាក់ ក្នុងចំណោម១០០ ០០០កំណើតរស់(នៅឆ្នាំ២០២២) និងមរណភាពកុមារមានការថយចុះពី៣៥នាក់(នៅឆ្នាំ២០១៤) មកត្រឹម១៦នាក់(នៅឆ្នាំ២០២២) ក្នុងចំណោម១ ០០០កំណើតរស់ និងមរណភាពទារកមានការថយចុះពី២៨នាក់(នៅឆ្នាំ២០១៤) មកត្រឹម១២នាក់(នៅឆ្នាំ២០២២) ក្នុងចំណោម១ ០០០នាក់រស់។

- បានសហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ ទីស្តីការគណៈរដ្ឋមន្ត្រី(អាហារូបត្ថម្ភ សន្តិសុខស្បៀង) ក្រសួងអប់រំ យុវជន និងកីឡា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងការបញ្ជ្រាបយេនឌ័រនិងសុខភាពទៅក្នុងផែនការយុទ្ធសាស្ត្រ ផែនការប្រតិបត្តិ កម្មវិធី សៀវភៅបណ្តុះបណ្តាលសិស្សផ្នែកសុខភាព និងសម្ភារៈអប់រំផ្សព្វផ្សាយ តាមបណ្តាញសង្គម Social Media ស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា (ស្ពតវីដេអូ វេទិកាជជែកពិភាក្សា និងកម្មវិធីសិក្សាMy TV study ជាមួយនិស្សិត តាមគេហទំព័រហ្វេសប៊ុក និងវិទ្យុរបស់ក្រសួងកិច្ចការនារី ដែលមានអ្នកចូលរួមដោយផ្ទាល់និងដោយប្រយោលចំនួនរាប់ពាន់នាក់

- ក្រសួងបានអនុវត្តកម្មវិធីអប់រំសុខភាពបន្តពូជ សុខភាពមាតា ទារក អាហារូបត្ថម្ភ អនាម័យ ទឹកស្អាត ជំងឺឆ្លង (ជំងឺកាមរោគនិងជំងឺអេដស៍) និងជំងឺមិនឆ្លង (មហារីកមាត់ស្បូន មហារីកសុដន់ សុខភាពភ្នែក) តាមរយៈការអភិវឌ្ឍន៍សមត្ថភាពមន្ត្រីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិចំនួន៨៥៥នាក់ (ស្ត្រី៨០១នាក់) ដើម្បីអប់រំផ្សព្វផ្សាយទៅដល់ប្រជាពលរដ្ឋឱ្យចេះថែទាំសុខភាពសមាជិកគ្រួសារ និងទៅទទួលយកសេវាថែទាំសុខភាពនៅមូលដ្ឋានសុខាភិបាលឱ្យបានទាន់ពេលវេលា។ ជាលទ្ធផល ប្រជាពលរដ្ឋចំនួន៦៧ ៧៨៣នាក់ (ស្ត្រី៥០ ២៦២នាក់) បានទទួលការអប់រំអំពីការថែទាំសុខភាពសមាជិកគ្រួសារនិងបានបញ្ជូនទៅទទួលយកសេវាសុខភាព។

## ២.៤- ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងការពារសិទ្ធិស្ត្រី

- ក្រសួងកិច្ចការនារី បានដឹកនាំរៀបចំផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ ២០១៩-២០២៣ ដោយមានការអនុម័តពីសម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី៩ ខែតុលា ឆ្នាំ ២០២០ និងបានផ្សព្វផ្សាយជាផ្លូវការពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២១។ ផែនការសកម្មភាពជាតិនេះ ផ្តោតលើយុទ្ធសាស្ត្រគន្លឹះ ចំនួន៤៖ ១- ការបង្ការទប់ស្កាត់ ២- កិច្ចការពារផ្លូវច្បាប់និងសេវាពហុវិស័យ ៣- ការបង្កើតនិងការអនុវត្តច្បាប់និងគោលនយោបាយ និង៤- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។ ផែនការសកម្មភាពនេះមានការចូលរួមពីភាគីពាក់ព័ន្ធ (១៧ក្រសួង ស្ថាប័ន ៤ដៃគូអភិវឌ្ឍ និង ៣០អង្គការសង្គមស៊ីវិល) ក្នុងការទប់ស្កាត់និងផ្តល់កិច្ចអន្តរាគមន៍ជួយជនរងគ្រោះប្រកបដោយប្រសិទ្ធភាពនិងបរិយាប័ន្ន ដើម្បីសម្រេចសូចនាករ នៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា «មិនទុកនរណាម្នាក់ឱ្យនៅឯកោ» និងគោលដៅនៃផែនការសកម្មភាព ស្តីពីប្រជាជននិងការអភិវឌ្ឍដែលកម្ពុជាបានប្តេជ្ញាចិត្តនៅកម្រិតអន្តរជាតិ ក្នុងការលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រឱ្យនៅកម្រិតទាបបំផុត(Zero GBV) នៅឆ្នាំ២០៣០។ ជាលទ្ធផលនៃការអនុវត្តផែនការសកម្មភាពជាតិនេះ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍចំនួន២០ បានរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ។ នៅថ្នាក់ក្រោមជាតិ ក្រុមការងារជាពហុវិស័យឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានបង្កើតនិងកំពុងដំណើរការក្នុងខេត្តចំនួន៩ និងស្រុកចំនួន៣៧ និងកំពុងពង្រីកទៅរាជធានីភ្នំពេញនិងខេត្តដទៃទៀត

-ក្រសួងកិច្ចការនារី បានផ្តួចផ្តើមបង្កើតទីកន្លែងផ្តល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ(One Stop Service Center) តាមរយៈកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលកំពុងដំណើរការនៅក្នុងមន្ទីរពេទ្យខេត្តចំនួន៤ និងកំពុងពង្រីកនៅរាជធានីភ្នំពេញ និងខេត្តបាត់ដំបង ក្នុងការជួយជនរងគ្រោះឱ្យបានទាន់ពេលវេលាប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ (សេវាចម្រុះនៅទីកន្លែងតែមួយ ឬសេវាចម្រុះតាមបណ្តាញដៃគូដែលបានរៀបចំឡើង)

-មន្ត្រីក្រសួង និងមន្ទីរកិច្ចការនារី និងអ្នកផ្តល់សេវាពាក់ព័ន្ធទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិចំនួន ៣១ ៣៥៧នាក់ (ស្រី ៨ ៧៣៩នាក់) ទទួលបានការបណ្តុះបណ្តាលពង្រឹងសមត្ថភាពទាក់ទងនឹងជំនាញស្តីពីការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការផ្តល់សេវាឆ្លើយតបជូនស្ត្រីនិងក្មេងស្រីដែលរងគ្រោះដោយហិង្សាទាក់ទងនឹងយេនឌ័រ បរិយាប័ន្នពិការភាព ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទ ការជួញដូរមនុស្ស ការប្រើប្រាស់គ្រឿងញៀន

-ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បានផ្តល់សេវាជំនួយផ្នែកច្បាប់ដល់ស្ត្រីនិងក្មេងស្រីក្រីក្ររងគ្រោះដោយអំពើហិង្សានៅទូទាំង២៥រាជធានី ខេត្ត មានចំនួនសរុប៦២៤ករណី។ ក្នុងនោះ សេវាមេធាវីការពារសិទ្ធិតាមផ្លូវច្បាប់ចំនួន៣៥១ករណី ដោយកិច្ចសហប្រតិបត្តិការជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានមេធាវីស្ម័គ្រចិត្តចំនួន ១៦៣រូប ភាគច្រើនមេធាវីជាស្ត្រីបានចូលរួមការពារក្តីលើសំណុំរឿងក្តីស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សា។ លទ្ធផលនៃការផ្តល់សេវាជំនួយផ្នែកច្បាប់ បានជួយឱ្យជនរងគ្រោះជាស្ត្រីកាន់តែច្រើនទទួលបានការការពារសិទ្ធិចំពោះមុខច្បាប់ ប្រកបដោយទំនុកចិត្តក្នុងការស្វែងរកយុត្តិធម៌បានទាន់ពេល

-កាលពីឆ្នាំ២០១៧ ក្រសួងកិច្ចការនារី និងក្រសួងព័ត៌មាន បានចេញសេចក្តីប្រកាសរួមស្តីពីក្រមប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់ការរាយការណ៍អំពើហិង្សាលើស្ត្រី និងបានបណ្តុះបណ្តាលនិងចងបណ្តាញទំនាក់ទំនងជាមួយបណ្តាញសារព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដើម្បីជំរុញប្រសិទ្ធភាពក្នុងការអនុវត្តក្រម

ប្រតិបត្តិប្រព័ន្ធផ្សព្វផ្សាយសម្រាប់រាយការណ៍អំពើហិង្សាលើស្ត្រី។ បណ្តាញសារព័ត៌មានផ្លូវការ ដែលអនុវត្តតាមក្រមប្រតិបត្តិមានការកើនឡើង

-ប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញរបស់ក្រសួងបានដាក់ឱ្យដំណើរការ តាមរយៈបណ្តាញទំនាក់ទំនងសង្គម ដោយរៀបចំយុទ្ធនាការឌីជីថល លើទិវាអន្តរជាតិនារី ៨មីនា និងយុទ្ធនាការ១៦ថ្ងៃ បំពាក់បូពណ៌ស បញ្ឈប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីជារៀងរាល់ឆ្នាំ។ គិតចាប់ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ យុទ្ធនាការឌីជីថលបានទៅដល់មហាជន ចំនួនជាង៣,៩លាននាក់ និងអ្នកដែលចូលរួម ចំនួនជាង ១,៥លាននាក់

-ក្រសួងកិច្ចការនារី បានផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារខេត្តរតនគិរី ក្នុងការអភិវឌ្ឍ និងអនុវត្តផែនការសកម្មភាពស្តីពីអាពាហ៍ពិពាហ៍កុមារនិងការមានផ្ទៃពោះវ័យជំទង់។ ផែនការសកម្មភាពនេះបានអនុវត្តគ្រប់ស្រុកទូទាំងខេត្ត ដើម្បីបន្តនិរន្តរភាពរដ្ឋបាលខេត្តបានដាក់បញ្ចូលផែនការសកម្មភាពនេះទៅក្នុងផែនការវិនិយោគរបស់ខេត្ត និងបានបែងចែកកញ្ចប់ថវិកាសម្រាប់អនុវត្ត

-ទិន្នន័យស្តីពីស្ថានភាពរបស់ស្ត្រី ដែលកំពុងជាប់ពន្ធនាគារក្នុងរាជធានី ខេត្តទាំង២៥ ត្រូវបានប្រមូលនិងចងក្រង។ ជាលទ្ធផល ស្ត្រីដែលកំពុងជាប់ពន្ធនាគារសរុបចំនួន១ ៧៩៨នាក់ ក្នុងនោះមានទណ្ឌិតចំនួន ៧៨៩នាក់ ពិរុទ្ធជនចំនួន១ ០០៩នាក់ ស្ត្រីកំពុងមានផ្ទៃពោះចំនួន៣០នាក់ និងស្ត្រីមានកូនតូចតាមចំនួន ១១៨នាក់

-សម្របសម្រួល និងផ្តល់សេវាជូនដល់ស្ត្រីនិងក្មេងស្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការរំលោភសេពសន្ថវៈ និងការជួញដូរមនុស្សសរុបចំនួន៣ ០៤៥ករណី (អំពើហិង្សាក្នុងគ្រួសារចំនួន១ ៧៥៧ករណី ករណីរំលោភសេពសន្ថវៈចំនួន១ ២៥៨ករណី និងករណីអំពើជួញដូរមនុស្សចំនួន៣០ករណី)។

## ២.៥- ស្ត្រីក្នុងនាពជាអ្នកដឹកនាំ និងអភិបាលកិច្ច

ក្រសួងកិច្ចការនារី បានដឹកនាំការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងដៃគូពាក់ព័ន្ធ (ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃ និងដៃគូអភិវឌ្ឍ) បានផ្តួចផ្តើមកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំដល់ស្ត្រី និងយុវជនរបស់ក្រសួង ជាបន្តបន្ទាប់ទាំងនៅថ្នាក់ជាតិនិងក្រោមជាតិ ។ ជាលទ្ធផល សមាមាត្រស្ត្រីនៅក្នុងការដឹកនាំ និងថ្នាក់ធ្វើសេចក្តីសម្រេចនៅថ្នាក់ជាតិនិងក្រោមជាតិ មានការកើនឡើងជាបន្តបន្ទាប់ដូចតទៅ៖

-នៅលើឆាកអន្តរជាតិ កម្ពុជាមានចំណាត់ថ្នាក់ទី២ ក្នុងសហគមន៍អាស៊ាន និងចំណាត់ថ្នាក់លេខ១៩ ក្នុងចំណោមប្រទេស១២០ ដែលបានបញ្ជូនកងទ័ពជាស្ត្រីចូលរួមប្រតិបត្តិការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ

-ក្នុងអង្គនីតិបញ្ញត្តិ៖ ស្ត្រីជាសមាជិការដ្ឋសភា បានកើនឡើងពី៥,៨៣% (ឆ្នាំ១៩៩៣) ដល់ ២០,៨០% (ឆ្នាំ២០១៩)។ បច្ចុប្បន្ន មានស្ត្រី១រូប ជាអនុប្រធានរដ្ឋសភា ស្ត្រី២រូប ជាប្រធានគណៈកម្មការជំនាញ និងស្ត្រី៤រូប ជាអនុប្រធានគណៈកម្មការជំនាញ។ ស្ត្រីជាសមាជិកាព្រឹទ្ធសភា បានកើនឡើងពី ១៤,៧៥%(ឆ្នាំ១៩៩៩) ដល់១៦,១៣%(ឆ្នាំ២០១៩)។ បច្ចុប្បន្ន មានស្ត្រី២រូប ជាប្រធានគណៈកម្មការជំនាញ។

-ក្នុងអង្គនីតិប្រតិបត្តិ៖ បច្ចុប្បន្ន មានស្ត្រីជាឧបនាយករដ្ឋមន្ត្រី១រូប ក្នុងចំណោម១០រូប ស្ត្រីជារដ្ឋមន្ត្រី ៣រូប ក្នុងចំណោម២៩រូប ស្ត្រីជាអគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ ចំនួន១រូប (ឋានៈស្មើទេសរដ្ឋមន្ត្រី)

-វិស័យមុខងារសាធារណៈ៖ មន្ត្រីរាជការជាស្ត្រីបានកើនឡើងពី៣២% នៅឆ្នាំ២០០៧ ដល់៤២% នៅឆ្នាំ២០២១។ សមាមាត្រស្ត្រីជាមន្ត្រីរាជការក្នុងតួនាទីធ្វើសេចក្តីសម្រេចកើនឡើងដល់២៦% នៅឆ្នាំ២០២១។

**សមាមាត្រមន្ត្រីរាជការជាស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច គិតត្រឹមខែធ្នូ ឆ្នាំ២០២១**




**សមាមាត្រមន្ត្រីរាជការជាស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច នៅថ្នាក់ក្រោមជាតិ**

- ស្ត្រីជាអភិបាលខេត្ត២រូប (៨%) ក្នុងចំណោម២៥រូប
- ស្ត្រីជាអភិបាលក្រុង ស្រុក ខណ្ឌ៧រូប (៣.៤៤%) ក្នុងចំណោម២០៣រូប




គិតត្រឹមខែមករា ឆ្នាំ២០២១, នាយកដ្ឋានសមភាពយេនឌ័រ ក្រសួងកិច្ចការនារី

- ស្ត្រីជាមេឃុំ ចៅសង្កាត់បានកើនឡើងពី៤២រូប(២,៦%) ក្នុងឆ្នាំ២០០២ មក១៣០រូប(៧,៨៩%) ក្នុងចំណោម ១៦៤៦រូប ក្នុងឆ្នាំ២០១៧និងកើនឡើងដល់១៧៣រូប(១០.៤៧%) ក្នុងចំណោម១៦៥២រូប ក្នុងឆ្នាំ២០២២
- ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ បានកើនឡើងពី១៧,៧% នៅឆ្នាំ២០១៧ ដល់ ២២% នៅឆ្នាំ២០២២។

## ២.៦-ការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយ និងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល

- យន្តការថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ រួមមានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រសួងកិច្ចការនារី គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរ ក្រុមការងារបច្ចេកទេសយេនឌ័រ ក្រុម-

ការងារទទួលបន្ទុកទប់ស្កាត់អំពើហិង្សាលើស្ត្រី ក្រុមការងារបញ្ជ្រាបយេនឌ័រក្រសួង ស្ថាប័ន មន្ទីរកិច្ចការនារីរាជធានី ខេត្ត គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ បានដំណើរការយ៉ាងសកម្ម ក្នុងការជំរុញការឆ្លើយតបសមភាពយេនឌ័រ សិទ្ធិស្ត្រី និងការទប់ស្កាត់អំពើហិង្សាលើស្ត្រីនៅគ្រប់កម្រិត

- ឯកសារៈសំខាន់ៗ ក្នុងការលើកកម្ពស់សមភាពយេនឌ័រ និងទប់ស្កាត់អំពើហិង្សាលើស្ត្រីនៅកម្ពុជាត្រូវបានបង្កើតនិងអនុវត្ត រួមមានៈ ១- ផែនការយុទ្ធសាស្ត្រនារីរតនៈទី៥ ២០១៩-២០២៣ ២- ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ ៣-ផែនការយុទ្ធសាស្ត្របង្កើនចំនួនស្ត្រីក្នុងមុខតំណែងគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ៤- គោលនយោបាយស្តីពីសមភាពយេនឌ័រក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ៥- យុទ្ធសាស្ត្រនិងឧបករណ៍សម្រាប់ផ្សព្វផ្សាយកម្មវិធីចិញ្ចឹមកូនបែបវិជ្ជមាន និង៦- ផែនការសកម្មភាពស្តីពីអាពាហ៍ពិពាហ៍កុមារនិងការមានផ្ទៃពោះវ័យជំទង់ខេត្តរតនគីរី

- គោលនយោបាយនិងកម្មវិធីជាតិសំខាន់ៗ ដែលបានបញ្ចូលនិងឆ្លើយតបនឹងការពង្រឹងសមភាពយេនឌ័ររួមមាន ១- ក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីសេដ្ឋកិច្ចនិងសង្គមឌីជីថល២០២១-២០៣៥ ២- គោលនយោបាយរដ្ឋាភិបាលឌីជីថល២០២២-២០៣៥ ៣- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ៤- ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ៥- ប្រព័ន្ធគ្រប់គ្រងទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ៦- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ៧- ផែនការសកម្មភាពគោលនយោបាយប្រជាជន ២០១៩-២០២១ និង៨- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា២០១៦-២០៣០

- ចាប់ពីឆ្នាំ២០១៨ រហូតមកដល់ឆ្នាំ២០២២ ក្រសួង ស្ថាប័ន ចំនួន១៥ បានធ្វើបច្ចុប្បន្នភាពក្រុមការងារបញ្ជ្រាបយេនឌ័រ ក្រសួង ស្ថាប័នចំនួន១០ បានអនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្តីពីការបញ្ជ្រាបយេនឌ័រ និងក្រសួង ស្ថាប័នចំនួន៨ បានធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ។

### ២.៧- យេនឌ័រនិងការប្រែប្រួលអាកាសធាតុ

- ផែនការមេស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ២០១៨-២០៣០ ត្រូវបានបង្កើតនិងដាក់ឱ្យដំណើរការផែនការសកម្មភាពស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ២០១៩-២០២៣។ លទ្ធផលសំខាន់ៗក្នុងការអនុវត្តផែនការនេះ ក្រសួងកិច្ចការនារី បានអនុវត្តដោយជោគជ័យនូវគម្រោងសាកល្បងចំនួន៤ ជាមួយក្រុមផលិតជាស្ត្រី សរុប៨៥នាក់ ក្នុងការដំណើរការនិងគាំទ្រអាជីវកម្មខ្នាតតូចចម្រុះ និងផ្នែកកសិកម្មដោយលើកកម្ពស់ជីវភាពគ្រួសាររបស់ស្ត្រីនៅក្នុងបរិបទនៃការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

- ឆ្នាំ២០២២ ក្រសួងកិច្ចការនារីទទួលបានគម្រោងថ្នាក់តំបន់មេគង្គ-ឡានឆាង ស្តីពីការបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពប្រែប្រួលអាកាសធាតុ ដើម្បីពង្រឹងសមត្ថភាពធន់របស់ស្ត្រី តាមរយៈការលើកកម្ពស់ជីវភាពរស់នៅ និងការទទួលបានទឹកស្អាត ដែលអនុវត្តក្នុងឆ្នាំ២០២២-២០២៣។ ក្រសួងនឹងដឹកនាំការអនុវត្តគម្រោងជាមួយប្រទេសឡាវ តាមរយៈការសិក្សាស្រាវជ្រាវនិងអនុវត្តសកម្មភាពសាកល្បងលើការលើកកម្ពស់តួនាទីស្ត្រីក្នុងសកម្មភាពប្រែប្រួលអាកាសធាតុ នៅក្នុងប្រទេសទាំងពីរ (កម្ពុជានិងឡាវ)។

## ២.៨- ស្ត្រីក្នុងកិច្ចការអាស៊ាននិងកិច្ចសហប្រតិបត្តិការអន្តរជាតិ

- ក្រសួងកិច្ចការនារី បានដឹកនាំកិច្ចប្រជុំ ចំនួន២លើក ស្តីពីឧត្តមមន្ត្រីលើកទី១៤ នៃប្រទេសអនុតំបន់មេគង្គ (Cambodian COMMIT Taskforce) ក្រោមប្រធានបទ «អភិក្រមគ្រប់ជ្រុងជ្រោយដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស» និង «កិច្ចប្រជុំក្រុមការងារខមមីតប្រឆាំងអំពើជួញដូរមនុស្ស» នៅមហាអនុតំបន់មេគង្គនិងកិច្ចប្រជុំឧត្តមមន្ត្រីលើកទី១៤ ដែលមានអ្នកចូលរួមសរុប៧៤នាក់ (ស្រី២៥នាក់)

- ក្នុងនាមកម្ពុជា ជាប្រធានតាមវេនរបស់គណៈកម្មាធិការអាស៊ានស្តីពីស្ត្រី(ACW) ក្រសួងកិច្ចការនារីបានដឹកនាំកិច្ចប្រជុំស្តីពីការជំរុញឱ្យមានស្ត្រីជាថ្នាក់ដឹកនាំនិងការចូលរួមក្នុងឆាកនយោបាយ និងកិច្ចប្រជុំពាក់ព័ន្ធរបស់គណៈកម្មការអាស៊ានដើម្បីស្ត្រី បូកបី(ចិន ជប៉ុន និងកូរ៉េ)និងកិច្ចប្រជុំរវាងACW និងគណៈកម្មាធិការអាស៊ានដើម្បីការលើកកម្ពស់និងការពារសិទ្ធិស្ត្រីនិងកុមារ សិក្ខាសាលាស្តីពីការងារគ្មានប្រាក់កម្រៃនិងការងារផ្ទះសម្បែង និងកិច្ចប្រជុំប្រចាំឆ្នាំ និងកិច្ចប្រជុំពាក់ព័ន្ធ

- កម្ពុជាបានដឹកនាំរៀបចំវេទិកាអាស៊ី-អឺរ៉ុប(ASEM) ស្តីពីស្ត្រី សន្តិសុខនិងសន្តិភាព និងបញ្ចូលរបៀបវារៈស្តីពីស្ត្រី សន្តិសុខ និងសន្តិភាពទៅក្នុងកិច្ចប្រជុំកំពូលASEM លើកទី១៣

- ក្រសួងកិច្ចការនារី បានដឹកនាំសម្របសម្រួលរៀបចំកិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី២ ក្រោមប្រធានបទការកសាងអនាគតប្រកបដោយចីរភាព បរិយាប័ន្ននិងកាន់តែរឹងមាំ៖ បំផុសសហគ្រិនភាពរបស់ស្ត្រីក្នុងអាស៊ាន និងដឹកនាំសម្របសម្រួលរៀបចំសេចក្តីថ្លែងការណ៍អាស៊ានស្តីពីការបំផុសសហគ្រិនភាពរបស់ស្ត្រីក្នុងអាស៊ាន និងដាក់ជូនថ្នាក់ដឹកនាំអាស៊ាន អនុម័តនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០និងទី៤១ ឆ្នាំ២០២២

-ក្រសួងកិច្ចការនារី បានរៀបចំវេទិកាអាស៊ាន និងពិធីប្រគល់ពានរង្វាន់សហគ្រិនអាស៊ាន ដែលមានការចូលរួមពីតំណាងក្រសួង ស្ថាប័ន វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍក្នុងតំបន់ ក្នុងការប្រមូលធាតុចូលលើការលើកកម្ពស់សហគ្រិនភាពស្ត្រីក្នុងអាស៊ាន។ សហគ្រិនស្ត្រីឆ្នើមចំនួន៣៨រូប មកពីបណ្តាប្រទេសអាស៊ានបានទទួលពានរង្វាន់ពិសេសសហគ្រិនស្ត្រី ឆ្នាំ២០២២

-ក្រសួងកិច្ចការនារី បានរៀបចំវេទិកាស្តីពីការលើកកម្ពស់សហគ្រិនភាពស្ត្រីនៅអាស៊ានតាមរយៈគោល-នយោបាយគាំពារសង្គមនិងគាំពារគ្រួសារ ដោយមានអ្នកចូលរួមពីដៃគូពាក់ព័ន្ធក្នុងប្រទេសអាស៊ាន និងទទួលបានធាតុចូលសម្រាប់ការរៀបចំកិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី២ និងសេចក្តីថ្លែងការអាស៊ានស្តីពីការកសាងអនាគតប្រកបដោយចីរភាព បរិយាប័ន្ន និងកាន់តែរឹងមាំ៖ បំផុសសហគ្រិនភាពរបស់ស្ត្រីក្នុងអាស៊ាន។

## ៣- ការលើកកម្ពស់ការគាំពារសង្គម

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ.) សម្រេចការងារដូចខាងក្រោម៖**

(Facebook page:Mosvy Cambodia, គេហទំព័រ Homepage: mosvy.gov.kh)

របាយការណ៍សង្ខេបរយៈពេល ៥ឆ្នាំ ២០១៨-២០២២ នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គឺជារបាយការណ៍ដែលបានឆ្លុះបញ្ចាំងពីលទ្ធផលការងារសំខាន់ៗដែលក្រសួងសម្រេចបានក្នុងរយៈពេល៥ឆ្នាំ និងការដាក់ចេញនូវគោលនយោបាយនិងទិសដៅការងារសម្រាប់បន្តអនុវត្តរយៈពេល៥ឆ្នាំបន្ទាប់។

គោលបំណងនៃការរៀបចំរបាយការណ៍នេះគឺដើម្បីផ្សព្វផ្សាយការងារ៥ឆ្នាំ ២០១៨-២០២២ ដែលសម្រេច និងទិសដៅការងារអនុវត្តបន្តរបស់ក្រសួងជូនសាធារណៈជននិងអ្នកពាក់ព័ន្ធយកទៅប្រើប្រាស់ស្របតាមតម្រូវការនិងគោលបំណងរៀងៗខ្លួន។

ដោយសារការផ្ទុះឡើងនិងការបន្តរីករាលដាលនៃជំងឺកូវីដ-១៩ បានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរបំផុតមកលើសេដ្ឋកិច្ចនិងសង្គម នៃបណ្តាប្រទេសស្ទើរតែទាំងអស់នៅលើពិភពលោក រួមទាំងប្រទេសកម្ពុជាយើងផងដែរ ធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាថមថយសន្ទុះបាត់បង់កំណើន ដែលក្នុងរយៈពេល៥ឆ្នាំ ២០១៨-២០២២ កំណើនសេដ្ឋកិច្ចកម្ពុជាគិតជាមធ្យមកើនឡើងប្រមាណ៤,០២% ក្នុងមួយឆ្នាំប៉ុណ្ណោះ។

ផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ចតុកោណទី១ "ការអភិវឌ្ឍធនធានមនុស្ស" ត្រង់មុំទី៤៖ ការពង្រឹងសមភាពយេនឌ័រ និងកិច្ចគាំពារសង្គម ដើម្បីលើកស្ទួយស្ថានភាពសង្គម សេដ្ឋកិច្ច និងពង្រឹងតួនាទីស្ត្រី បានបង្ហាញយ៉ាងច្បាស់អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងនូវបណ្តាញសុវត្ថិភាពសង្គម និងកិច្ចគាំពារសង្គម រួមចំណែកក្នុងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជន ជាពិសេសជនរងគ្រោះនិងងាយរងគ្រោះ ឱ្យរួចផុតពីហានិភ័យទាំងឡាយ។ ក្រសួង ស.អ.យ. បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ ផ្តោតលើកម្មវិធីសំខាន់ៗចំនួនបីគឺ១- ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ២- ការបង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គមនិងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ និង៣- ការពង្រឹងសមត្ថភាពស្ថាប័ន និងអភិវឌ្ឍភាពជាដៃគូ និងអនុកម្មវិធីចំនួន១២ រួមមាន ១- ការអភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ និងកិច្ចការគ្រួសារ ២- ការអភិវឌ្ឍសុខុមាលភាពកុមារនិងយុវនីតិសម្បទា ៣- ការអភិវឌ្ឍសុខុមាលភាពជនពិការ ៤- ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់ ៥- ការអភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន ៦- ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គមរាជធានី ខេត្ត ៧- ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ៨- ការបង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន ៩- ការបន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនពិការ ១០- ការពង្រឹងសមត្ថភាពស្ថាប័ននិងភាពជាដៃគូ ១១- ការអភិវឌ្ឍធនធានមនុស្ស និង១២- ការពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូរាជធានី ខេត្ត។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រេចបានសមិទ្ធផលជាច្រើននៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ឆ្នាំ២០១៩-២០២៣។ សមិទ្ធផលសំខាន់ៗទាំងនោះ រួមមាន៖

១- ក្នុងរយៈពេល ៥ឆ្នាំនេះ ប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិ ប្រជាជនរងគ្រោះនិងងាយរងគ្រោះ ប្រជាជនក្រីក្រ ទុរគតជន សរុបចំនួន២៣០ ៦៩៧គ្រួសារ បានទទួលជំនួយសង្គ្រោះបន្ទាន់ពីកម្មវិធីសង្គ្រោះបន្ទាន់។ រាជរដ្ឋាភិបាលបានបង្កើតនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ចំនួន៤ បន្ថែមលើកម្មវិធីដែលមានស្រាប់ ដើម្បីគាំពារសន្តិសុខប្រាក់ចំណូលជូនដល់ក្រុមជនដែលងាយរងគ្រោះ និងការអភិវឌ្ឍធនធានមនុស្សរយៈពេលវែង។ កម្មវិធីទាំងនោះ រួមមាន៖ ១- កម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ប្រជាជនក្រីក្រនិងងាយរងគ្រោះក្នុងកំលុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ដែលបានប្រកាសដាក់ឱ្យអនុវត្ត កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ អនុវត្តបាន ១០ជុំមាន២៧លើក ដែលមានប្រជាជនក្រីក្រ និងងាយរងគ្រោះដោយសារជំងឺកូវីដ-១៩ បានមកចុះឈ្មោះទទួលសេវាសរុបចំនួន៦៩១ ៧០៩គ្រួសារ ដែលចំណាយថវិកាសរុបចំនួន៣ ២២២ ៨២៧ ២០៧ ០០០រៀល

ស្មើប្រមាណ៨០៥លានដុល្លារអាមេរិក ក្នុងនោះមនុស្សវ័យចាស់អាយុពី៦០ឆ្នាំ ចំនួន៣៦០ ៧៦២នាក់ ជនមានពិការភាពចំនួន៦៣ ៦៩៧នាក់ កុមារអាយុពី០-៥ឆ្នាំ ចំនួន១៥៩ ០០៦នាក់ និងគ្រួសារផ្ទុកមេរោគអេដស៍ ចំនួន ២ ០២៨គ្រួសារ ២- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ បានផ្តល់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះ ចំនួន១៧៧ ១៦៧នាក់ និងកុមារអាយុក្រោម២ឆ្នាំ ចំនួន១០៩ ៦៥៧នាក់ ដែលចំណាយថវិកាសរុបចំនួន៨១ ៦២៤ ២៤០ ០០០រៀល ៣- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យក្នុងកំលុងពេលមានសម្ពាធអតិផរណាសម្រាប់២៥រាជធានី ខេត្ត ដែលគ្រួសារទទួលផលចំនួន២៦០ ៥១៨ គ្រួសារ ចំណាយថវិកាសរុបចំនួន៣៦ ៤៦៣ ៩០១ ៨០០រៀល និង៤- កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសាររងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់សម្រាប់រាជធានី ខេត្តចំនួន១៦ ដែលគ្រួសារទទួលផលសរុបចំនួន៩៩ ១៦៩គ្រួសារ ចំណាយថវិកាសរុបចំនួន១៥ ៥៩៩ ៦៩៦ ០០០រៀល ដែលកម្មវិធីទី៣និងទី៤ ចាប់ផ្តើមអនុវត្តពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២នេះ។

២- បានកសាងមណ្ឌលសម្រាប់ទទួលជនរងគ្រោះមួយចំនួនបន្ថែមទៀត ក្នុងនោះមាន ១- មជ្ឈមណ្ឌលជនវិបល្លាសស្មារតីស្ថិតនៅភូមិបាគូ ឃុំបាគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និងកំពុងទទួលជនវិបល្លាសស្មារតីឱ្យស្នាក់នៅចំនួន១១៥នាក់ និងបានសមាហរណកម្មទៅសហគមន៍វិញចំនួន១៩នាក់ ២- មណ្ឌលយុវនីតិសម្បទាស្ថិតនៅភូមិបាគូ ឃុំបាគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល និងកំពុងទទួលអនីតិជនទំនាស់នឹងច្បាប់ចំនួន ១៤០នាក់ ស្នាក់នៅ ៣- មណ្ឌលសំចតប៉ោយប៉ែតសម្រាប់ទទួលទុកដាក់ជនរងគ្រោះ និងងាយរងគ្រោះដែលទទួលបានពីអាជ្ញាធរថៃ គិតមកដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ បានទទួលពលករចំណាកស្រុកសរុបចំនួន **១៣១ ៥៩៥នាក់** និងបានសម្ភាសកំណត់អត្តសញ្ញាណរកឃើញជនរងគ្រោះនិងងាយរងគ្រោះចំនួន៦៨៨នាក់ ៤- មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍នៅភូមិឬទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ បានកំពុងផ្តល់សេវាព្យាបាល បន្សាប និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ៥- មជ្ឈមណ្ឌលជាតិជនពិការកម្ពុជា បានកំពុងសាងសង់នៅស្រុកអង្គស្នួលជាមជ្ឈមណ្ឌលប្រមូលផ្តុំសេវាកម្មបម្រើឱ្យជនមានពិការភាពគ្រប់រូប។

៣- បានកែទម្រង់កិច្ចការពារកុមារសំដៅការពារឧត្តមប្រយោជន៍របស់កុមារ ជាអាទិ៍ ការផ្ទេរមុខងារការគ្រប់គ្រងមណ្ឌលថែទាំកុមារពីក្រសួងទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការបង្វែរការចិញ្ចឹមកុមារក្នុងមណ្ឌលទៅការថែទាំក្នុងគ្រួសារនិងសហគមន៍ ការបង្កើតប្រព័ន្ធព័ត៌មានវិទ្យាដើម្បីគ្រប់គ្រងនិងតាមដានស្ថានភាពរបស់កុមារ ការធ្វើអធិការកិច្ចនិងកែលម្អកន្លែងថែទាំកុមារ និងការពង្រឹងសមត្ថភាពដល់មន្ត្រីនិងម៉ែដោះដែលធ្វើការក្នុងមណ្ឌលថែទាំកុមារ។

៤- មណ្ឌលព្យាបាល បន្សាប និងស្តារនីតិសម្បទាទាំង ៩កន្លែង ទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន៥១ ៦៨៦នាក់ និងបញ្ជូនជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន៣៥ ៥១៨នាក់ នៅសល់ដាក់ស្តែងសរុបចំនួន១៦ ១៦៨នាក់។

៥- ជនមានពិការភាព ចំនួន៣ ៧៤៨នាក់ កំពុងបម្រើការងារតាមក្រសួង ស្ថាប័នរដ្ឋទាំង៤៣ និងជនមានពិការភាពចំនួន៥ ៨៣៩នាក់ កំពុងបម្រើការងារនៅក្នុងរោងចក្រ សហគ្រាសវិស័យឯកជន។ ជនមាន-ពិការភាពក្រីក្រនៅតាមសហគមន៍ ចំនួន១៩ ៧៧២នាក់ កំពុងទទួលរបបឧបត្ថម្ភជនពិការក្រីក្រនៅតាមសហគមន៍ដោយមួយខែៗឧបត្ថម្ភ២០ ០០០រៀល។ ផ្តល់សេវាស្តារលទ្ធភាពពលកម្មប្រកបដោយគុណភាពដោយឥតគិត

ថ្លៃជូនជនមានពិការភាព៣១៦ ៥៨៣នាក់ ក្នុងនោះសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ២១២ ៦៩១នាក់ និងស្តារលទ្ធភាពពលកម្មកាយសម្បទាបាន១០៣ ៨៩២នាក់។

៦- រដ្ឋបានឧបត្ថម្ភថវិកាចំនួន៤ពាន់លានរៀល/ឆ្នាំ ជូនដល់សមាគមអតីតយុទ្ធជនកម្ពុជា ដើម្បីប្រគល់ជូនដល់សមាជិកសមាគមអតីតយុទ្ធជនកម្ពុជាដែលបានទទួលមរណភាព។ ក្នុងរយៈពេល៥ឆ្នាំ សមាគមអតីតយុទ្ធជនកម្ពុជាបានប្រគល់ប្រាក់បេឡាមរណៈសង្គ្រោះជូនដល់គ្រួសារសពចំនួន៨ ២០៥សព។ បើគិតពីឆ្នាំ២០០៨ រហូតដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២ សមាគមអតីតយុទ្ធជនកម្ពុជាបានប្រគល់ប្រាក់បេឡាមរណៈសង្គ្រោះជូនដល់គ្រួសារសពសរុបចំនួន១៩ ០៤៥សព។

៧- បានកែសម្រួលប្រាក់សោធនជូនជនពិការ និវត្តជន និងជនបាត់បង់សមត្ថភាពការងារ បច្ចុប្បន្នប្រាក់សោធនអប្បបរមាត្រូវបានដំឡើងដល់៦៩០ ០០០រៀល/ខែ និងកំពុងបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជននិងគ្រួសារប្រមាណ៩៣ ៤៨៤នាក់ និងអ្នកនៅក្នុងបន្ទុក១៣៨ ៦០៤នាក់ តាមប្រព័ន្ធធនាគារ។

៨- និវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈក៏មិនខុសគ្នានឹងអតីតយុទ្ធជនដែរ គឺប្រាក់សោធនត្រូវបានកែសម្រួលសោធនអប្បបរមា ដំឡើងដល់៦៩០ ០០០រៀលក្នុងមួយខែ និងកំពុងបើកផ្តល់ជូនអតីតមន្ត្រីរាជការស៊ីវិល ចំនួន៥៦ ០៤៩នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន៣៣ ២៨៥នាក់ ដែលចំណាយថវិការដ្ឋប្រមាណ៦៩៦ ពាន់លានរៀល ប្រហែល១៦៩លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ។

៩- ដើម្បីពង្រឹងនិងបង្កើនប្រសិទ្ធភាពការងារ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៩៤អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២ ដែលបានកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយបានកែសម្រួលអង្គការលេខរបស់ក្រសួងឱ្យសមស្របទៅតាមទំហំការងារ និងស្ថានភាពជាក់ស្តែង មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលកម្ពុជាក៏បានចេញអនុក្រឹត្យស្តីពីការបង្កើតមូលនិធិជាតិជំនួយសង្គមជាគ្រឹះស្ថានរដ្ឋបាលសាធារណៈ កាលពីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ក្នុងគោលបំណងអនុវត្តកិច្ចគាំពារសង្គមសម្រាប់ជនរងគ្រោះនិងងាយរងគ្រោះ។

១០- បានចុះកិច្ចព្រមព្រៀងគម្រោងការជាមួយអង្គការ១៤៩អង្គការ ដែលមានថវិកាគម្រោងសរុបចំនួន ៣២១ ៩៦៨ ៤៤៩,៥០ដុល្លារអាម៉េរិក។

១១- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដាក់ចេញនូវគោលនយោបាយ "ការលើកកម្ពស់កិច្ចគាំពារសង្គម និងសេវាសង្គមដើម្បីលើកស្ទួយស្ថានភាពសង្គមសេដ្ឋកិច្ច" ក្នុងគោលបំណង "លើកកម្ពស់គុណភាព ប្រសិទ្ធភាព និងសមធម៌សេវាសង្គមកិច្ច និងកិច្ចគាំពារសង្គមសម្រាប់គ្រួសារក្រីក្រ ជនរងគ្រោះនិងងាយរងគ្រោះ"។

១២- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដាក់ចេញនូវ ក- កម្មវិធីចំនួន៤គឺ ១- លើកកម្ពស់សេវាសង្គមកិច្ច ២- ការគ្រប់គ្រងសេវាស្តារជនរងគ្រោះ ៣- ការអនុវត្តកម្មវិធីគាំពារសង្គម និង៤- អភិបាលកិច្ចវិស័យសង្គមកិច្ច និងខ- អនុកម្មវិធីចំនួន១៨ គឺ ១- លើកកម្ពស់សេវាគាំពារមនុស្សចាស់និងអតីតយុទ្ធជន ២- លើកកម្ពស់សេវាកិច្ចការពារកុមារ ៣- លើកកម្ពស់កិច្ចការគ្រួសារ ៤- លើកកម្ពស់សេវាគាំពារជនរងគ្រោះ ៥- លើកកម្ពស់សេវាស្តារនីតិសម្បទាអនីតិជន ៦- លើកកម្ពស់សេវាស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ៧- លើកកម្ពស់សុខុមាលភាពជនមានពិការភាព ៨- កៀរគរ និងប្រើប្រាស់មូលនិធិសង្គមកិច្ច ៩- លើកម្ពស់សេវាស្តារលទ្ធភាពពលកម្មជូនជនមានពិការភាព ១០- លើកកម្ពស់សេវាបើកផ្តល់តាវកាលិកនិងរបបគោលនយោបាយ ១១- លើកកម្ពស់សមត្ថភាពស្ថាប័ន និងការផ្សព្វផ្សាយ ១២- រៀបចំគោលនយោបាយនិងកិច្ចការនីតិកម្មជំនួយសង្គម

១៣- សេវាគាំទ្រកិច្ចដំណើរការអនុវត្តកម្មវិធីគាំពារសង្គម ១៤- លើកកម្ពស់សមត្ថភាពស្ថាប័ន និងអភិបាលកិច្ច ១៥- អភិវឌ្ឍធនធានមនុស្សវិស័យសង្គមកិច្ច ១៦- លើកកម្ពស់ការអភិវឌ្ឍគោលនយោបាយសង្គមកិច្ច ១៧- លើកកម្ពស់ការត្រួតពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ និង១៨- លើកកម្ពស់ការត្រួតពិនិត្យតាមដានការអនុវត្តសិទ្ធិជនមានពិការភាព។

### ៣.១- ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម

#### ៣.១.១- អភិវឌ្ឍសុខុមាលភាពសម្រាប់ជនរងគ្រោះ និងងាយរងគ្រោះ និងកិច្ចការគ្រួសារ

- បានអនុវត្តកម្មវិធីសង្គ្រោះបន្ទាន់ ដោយសហការជាមួយកាកបាទក្រហមកម្ពុជា និងអង្គការនានា ផ្តល់ជំនួយសង្គ្រោះបន្ទាន់ ជាស្បៀងនិងសម្ភារៈផ្សេងៗ ដល់ប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិ ប្រជាជនរងគ្រោះ និងងាយរងគ្រោះ ប្រជាជនក្រីក្រ ទុរគតជនសរុបចំនួន ២៣០ ៦៩៧គ្រួសារ

- ដើម្បីជួយគាំទ្រផ្នែកជីវភាព និងសុខុមាលភាពរបស់ប្រជាជនក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់សម្រាប់ប្រជាជនក្រីក្រនិងងាយរងគ្រោះក្នុងកំលុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០។ មិនតែប៉ុណ្ណោះ រាជរដ្ឋាភិបាលបានបង្កើតកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់សម្រាប់ប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋដែលមានការលំបាកផ្នែកជីវភាពប្រជាពលរដ្ឋ និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកឆ្លងជំងឺកូវីដ-១៩ និងមានការលំបាកផ្នែកជីវភាព និងគ្រួសារប្រជាពលរដ្ឋដែលមានអ្នកស្លាប់ដោយសារជំងឺកូវីដ-១៩ ក្នុងព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ ចំនួន២លើក ដោយមានគ្រួសារដែលបានទទួលប្រាក់ឧបត្ថម្ភសរុបចំនួន១២៩ ៦៦៦គ្រួសារ ចំណាយថវិកាសរុបចំនួន៣៤ ៧១៥ ១៨៣ ៦០០រៀល។

- បានប្រកាសដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ។ បើគិតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២ រាជរដ្ឋាភិបាលបានផ្តល់ប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះចំនួន១៧៧ ១៦៧នាក់ និងកុមារអាយុក្រោម២ឆ្នាំ ចំនួន១០៩ ៦៥៧នាក់ ដែលចំណាយថវិកា សរុបចំនួន ៨១ ៦២៤ ២៤០ ០០០រៀល

- បានសង្គ្រោះ អប់រំផ្លូវចិត្ត ពិគ្រោះយោបល់ ថែទាំសុខភាពជូនជនអនាថាសរុបចំនួន៨ ៧៣៧នាក់ ក្រៅពីទទួលបានសេវាខាងលើ ជនអនាថាចំនួន**៥ ០០៦នាក់** បានទទួលសេវាស្តារនីតិសម្បទា បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍

- មជ្ឈមណ្ឌលជនវិបល្លាសស្មារតីស្ថិតនៅភូមិបាគូ ឃុំបាគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ត្រូវបានបង្កើតឡើងនិងសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៩ ក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ**។ មជ្ឈមណ្ឌលនេះបានទទួលជនវិបល្លាសស្មារតីឱ្យស្នាក់នៅចំនួន ១១៥នាក់ និងបានសមាហរណកម្មទៅសហគមន៍វិញចំនួន១៩នាក់

- បានរៀបចំនិងប្រកាសដាក់ឱ្យប្រើប្រាស់សៀវភៅគោលការណ៍ណែនាំ ស្តីពីការជួយជនអនាថា និងសៀវភៅស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព

- បានផ្តល់សេវាថែទាំនិងគាំទ្រនៅសហគមន៍ដល់ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗបានចំនួន **៩ ២៤៦នាក់** ក្នុងនោះ មានការអប់រំផ្សព្វផ្សាយ វគ្គបំណិនជីវិត អប់រំសុខភាព សេវាប្រឹក្សាយោបល់ និងការបង្កើតមុខរបរខ្នាតតូចដល់គ្រួសារ និងកុមារដែលរងផលប៉ះពាល់ដោយសារជំងឺអេដស៍

- បានបង្កើតនិងអនុវត្តកម្មវិធី ស្តីពីការអភិវឌ្ឍគ្រួសារ បំផុសលើកទឹកចិត្តការកសាងគ្រួសារល្អ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ តាមរយៈការរៀបចំទិវាជាតិនិងអន្តរជាតិ ស្តីពីគ្រួសារ ១៥ឧសភា ជារៀងរាល់ឆ្នាំ និងចុះផ្សព្វផ្សាយទិវាអន្តរជាតិស្តីពីគ្រួសារ ១៥ឧសភា ដល់សិស្សនិស្សិតនៅតាមវិទ្យាល័យ និងសាកលវិទ្យាល័យផងដែរ។ បានបញ្ជ្រាបការងារយេនឌ័រទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ លើកកម្ពស់តួនាទីស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្តតាមរយៈការផ្សព្វផ្សាយទស្សនាទានយេនឌ័រ និងអនុសញ្ញាស៊ី-ដ (CEDAW) ដល់មន្ត្រីបង្គោលទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងការផ្សព្វផ្សាយការយល់ដឹង ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារដល់សហគមន៍

- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីចិញ្ចឹមកូនបែបវិជ្ជមាន ដល់មន្ត្រីនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មន្ត្រីការិយាល័យសុខុមាលភាពសង្គមទាំង២៥ រាជធានី ខេត្ត

- បានរៀបចំនិងដាក់ឱ្យអនុវត្តនូវបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល និងឧបករណ៍ត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយនិងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះ។ តាមរយៈគោល-នយោបាយនិងបទដ្ឋាន ជនរងគ្រោះដោយអំពើជួញដូរមនុស្ស **៦ ២២២នាក់** ត្រូវបានសង្គ្រោះ អប់រំប្រឹក្សាយោបល់ បញ្ជូនទៅស្ថានីតិសម្បទា និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមមណ្ឌលរបស់អង្គការ និងជនរងគ្រោះចំនួន ១ ២៦០នាក់ ត្រូវធ្វើសមាហរណកម្មទៅសហគមន៍ និងតាមដានបន្តចំនួន៤១៩នាក់ និងបិទករណីចំនួន២៧០នាក់

- បានទទួលជនរងគ្រោះមាតុភូមិនិវត្តន៍ពីប្រទេសនានាចំនួន**១ ៣៩៧នាក់** និងបានធ្វើមាតុភូមិនិវត្តន៍ដោយអំពើជួញដូរមនុស្សត្រឡប់ទៅប្រទេសកំណើតវិញចំនួន៤០នាក់។

**តារាងទី១.លទ្ធផលសម្រេចបានអនុកម្មវិធីទី១.១**

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | គិតត្រឹមខែកញ្ញា ឆ្នាំ២០២២ | |
| ១ | គ្រួសាររងគ្រោះដោយដាច់ស្បៀងទីទ័លក្រ គ្រោះមហន្តរាយនៅតាមសហគមន៍បានទទួលជំនួយសង្គ្រោះបន្ទាន់ | គ្រួសារ | ៥៦ ១៩៩ | ៣១ ៤២៨ | ១០១ ៤៧៣ | ៣២ ៨៤១ | ៦ ៣៦៣ | ២៣០ ២៤២ |
| ២ | ប្រជាជនក្រីក្រនិងងាយរងគ្រោះដែលរងផលប៉ះពាល់ក្នុងកំលុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ | គ្រួសារ | - | - | ៦៨១ ៩៩៩ | ៦៨៤ ៧៧១ | ៦៨៩ ៦៥៧ | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣ | ជនអនាថាដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ ឬបញ្ជូនត្រឡប់ទៅសហគមន៍វិញ | នាក់ | ២ ៥០៩ | ១ ២៩១ | ៥៤៥ | ៥៤១ | ១៤០ | ៥ ០២៦ |
| ៤ | ជនអនាថាដែលទទួលបានសេវាគាំពារ | នាក់ | ២ ០៨៥ | ១ ៧៥៨ | ៣០៤៥ | ១២៩៥ | ៥៥៤ | ៨៧៣៧ |
| ៥ | ជនរងគ្រោះនិងរងផលប៉ះពាល់ដោយសារផ្ទុកមេរោគអេដស៍ជំងឺអេដស៍ដែលទទួលសេវាថែទាំគាំទ្រ | នាក់ | ៤ ២៨៥ | ១ ៨៦៧ | ៣៣៦ | ៣៣១ | ២១ | ៦ ៨៤០ |
| ៦ | ជនវិបល្លាសស្មារតីទទួលបានសេវាព្យាបាល និងថែទាំ | នាក់ | - | ៤៧ | ៦៥ | ៧០ | ១១៥ | |
| ៧ | ជនវិបល្លាសស្មារតីទទួលបានការបញ្ជូនត្រឡប់ឬសមាហរណកម្មទៅគ្រួសារឬសហគមន៍ | នាក់ | - | - | ៣ | ៤ | ១៤ | ២១ |
| ៨ | ស្ត្រីមានផ្ទៃពោះនៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | នាក់ | - | - | ៧២ ៩៧០ | ៧១ ៦៥០ | ៣២ ៥៤៧ | ១៧៧ ១៦៧ |
| ៩ | កុមារអាយុ០-២ឆ្នាំនៅក្នុងគ្រួសារក្រីក្រទទួលបានប្រាក់ឧបត្ថម្ភពីកម្មវិធីគាំពារស្ត្រីមានផ្ទៃពោះ | នាក់ | - | - | ៥២ ៨២៤ | ៤៦ ៧៧៧ | ១០ ០៥៦ | ១០៩ ៦៥៧ |
| ១០ | ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ រំលោភបំពានផ្លូវភេទទទួលបានការស្តារនីតិ-សម្បទា | នាក់ | ៨៤៨ | ៩៦៨ | ៣៧១ | ១ ៨០៨ | ២ ២២៧ | ៦ ២២២ |
| ១១ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលត្រូវបានគាំពារនិងជួយសង្គ្រោះ | នាក់ | ០ | ៥៧៩ | ៤៦ | ១៤៣ | ២៧១ | ១ ០៣៩ |
| ១២ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសខ្លួនវិញ | នាក់ | ២ | ៩ | ១៥ | ៥ | ៩ | ៤០ |
| ១៣ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានធ្វើមាតុភូមិនិវត្តន៍ពីក្រៅប្រទេស | នាក់ | ២២២ | ២៩០ | ២២០ | ៤០៤ | ២៦១ | ១ ៣៩៧ |
| ១៤ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវទទួលបានការធ្វើសមាហរណកម្មទៅតាមសហគមន៍វិញ | នាក់ | ៣៤៥ | ៤០៣ | ១០៤ | ៣១៧ | ៩១ | ១ ២៦០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៥ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានផ្ដល់នូវសេវាក្រោយធ្វើសមាហរណកម្ម | នាក់ | ១១៧ | ០ | ១២២ | ៥៧ | ១២៣ | ៤១៩ |
| ១៦ | ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានបិទករណី | នាក់ | ៦៩ | ២៧ | ២៣ | ៨០ | ៧១ | ២៧០ |

(ប្រភព៖ ទិន្នន័យរដ្ឋបាលក្រសួង ស.អ.យ.)

### ៣.១.២- អភិវឌ្ឍសុខុមាលភាពកុមារនិងយុវនីតិសម្បទា

- ក្រសួងបានរៀបចំទិវាកុមារអន្តរជាតិ ១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ និងទិវាកុមារកម្ពុជាទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ជារៀងរាល់ឆ្នាំ

- បានពង្រឹងពង្រីកយន្តការតាមដាននិងអនុវត្តសិទ្ធិកុមារ តាមក្រសួង ស្ថាប័ន និងរាជធានី ខេត្ត និងបានចេញគោលការណ៍ណែនាំស្ដីពីការអនុវត្តអនុសាសន៍របស់អង្គការសហប្រជាជាតិ ស្ដីពីការអនុវត្តអនុសញ្ញាស្ដីពីសិទ្ធិកុមារ

- បានរៀបចំរបាយការណ៍ ស្ដីពីស្ថានភាពនៃការអនុវត្តសិទ្ធិកុមារជារៀងរាល់ឆ្នាំ និងរៀបចំរបាយ-ការណ៍ឆ្លើយតបទៅនឹងកម្រងសំណួររបស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិពាក់ព័ន្ធនឹងរបាយការណ៍ជាតិលើកទី១និងទី២ ស្ដីពីការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងស្ដីពីការជួញដូរកុមារ ការធ្វើពេស្យាចារកុមារនិងរូបភាពអាសអាភាសកុមារ និងរបាយការណ៍ឆ្លើយតបទៅនឹងសេចក្ដីសម្រេចចិត្តមហាសន្និបាត អ.ស.ប លេខ ៦៩/១៥៩ ស្ដីពីការការពារកុមារពីការសម្លុតគម្រាមកំហែង ដើម្បីផ្ញើទៅតំណាងពិសេសអង្គការសហប្រជាជាតិ និងរបាយការណ៍ជាតិគួបលើកទី៤ ទី៥ និងទី៦ ស្ដីពីការអនុវត្តអនុសញ្ញា ស្ដីពីសិទ្ធិកុមារ និងបានចាត់ប្រតិភូជំនាញដើម្បីការពាររបាយការណ៍ជាតិនៃកិច្ចប្រជុំលើកទី៩០ របស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ

- ដើម្បីលើកកម្ពស់ការគោរពសិទ្ធិកុមារ និងការពារឧត្តមប្រយោជន៍កុមារ សេចក្ដីព្រាងច្បាប់ស្ដីពីកិច្ចការពារត្រូវបានតាក់តែងឡើង និងពិនិត្យ កែសម្រួលជាបន្តបន្ទាប់តាមរយៈសិក្ខាសាលានិងកិច្ចប្រជុំនានា។ ក្រៅពីនេះឯកសារមួយចំនួនទៀតក៏ត្រូវបានរៀបចំនិងប្រកាសដាក់ឱ្យអនុវត្ត មានជាអាទិ៍ ផែនការសកម្មភាពជាតិស្ដីពីការអភិវឌ្ឍកុមារ ឆ្នាំ២០១៦-២០១៨ គោលនយោបាយជាតិស្ដីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ផែនការសម្រាប់អនុវត្តគោលនយោបាយជាតិស្ដីពីប្រព័ន្ធកិច្ចការពារកុមារ និងផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ២០២១-២០២៥។ បានពង្រឹងសមត្ថភាពមន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធតាមរយៈការរៀបចំសិក្ខាសាលានិងវគ្គបណ្ដុះបណ្ដាល និងបានរៀបចំកិច្ចពិភាក្សាតុមូលតាមស្ថានីយ៍វិទ្យុ និងទូរទស្សន៍ សំដៅផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងអំពីសិទ្ធិកុមារឱ្យបានកាន់តែទូលំទូលាយ ជាពិសេស ការបញ្ជ្រាបអំពីតួនាទីគ្រួសារ និងសហគមន៍ ក្នុងការធានានូវឧត្តមប្រយោជន៍របស់កុមារ

- គណៈកម្មាធិការអាស៊ានដើម្បីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រីនិងកុមារ(ACWC) ផ្នែកសិទ្ធិកុមារបានអនុវត្តគម្រោង "យុទ្ធនាការផ្សព្វផ្សាយ ស្ដីពីផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុមកលើស្ត្រី និងកុមារក្នុងតំបន់អាស៊ាន" ដោយផលិតបានសៀវភៅផ្ទត់(Booklet) និងវីដេអូអប់រំជាគំនូរជីវចល ស្ដីពីផលប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុមកលើស្ត្រី និងកុមារក្នុងតំបន់អាស៊ាន ព្រមទាំងបានផ្សព្វផ្សាយទៅគ្រប់អង្គភាពអាស៊ាន និងតាមគេហទំព័ររបស់ ACWC

- បានប្រគល់មុខងារ ការគ្រប់គ្រងមណ្ឌលថែទាំកុមារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅជានាការគ្រប់គ្រងកាន់តែប្រសើរ ព្រមទាំងដោះស្រាយកិច្ចការបន្ទាន់បានទាន់ពេលវេលា។ បច្ចុប្បន្ន មណ្ឌលថែទាំចំនួន ១៩៩មណ្ឌល មានកុមារសរុបចំនួន៥ ៤៤០នាក់ (កុមារី២ ៥៦៩នាក់) និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ១ ៧១៦នាក់ (ស្រី៨៨៧នាក់) ក្នុងនោះមណ្ឌលថែទាំដែលគ្រប់គ្រងនិងគាំទ្រដោយអង្គការមិនមែនរដ្ឋាភិបាល មានចំនួន១៧៨មណ្ឌលមានកុមារ៤ ៧៣៤នាក់ (កុមារី២ ២៧៩នាក់) និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ១ ៣៩០នាក់ (ស្រី៧២២នាក់) មណ្ឌលថែទាំរបស់រដ្ឋមានចំនួន២១ មានកុមារចំនួន៧០៨នាក់ (កុមារី២៩០នាក់) និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ចំនួន៣២៦នាក់ ស្រី១៦៥នាក់។ កន្លែងថែទាំបែបសហគមន៍មានចំនួន១០១កន្លែង មានកុមារចំនួន២ ១៨៦នាក់ (កុមារី១ ០៤៧នាក់) និងយុវជនវ័យក្មេង (អាយុ១៨ឆ្នាំឡើង) ៥២១នាក់ (ស្រី២៧២នាក់)

- ដើម្បីពង្រឹងប្រសិទ្ធភាពនិងគុណភាពការគ្រប់គ្រងមណ្ឌលថែទាំកុមារ ក្រសួងបានបង្កើតប្រព័ន្ធទិន្នន័យអធិការកិច្ចកន្លែងថែទាំកុមារដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងបង្កើតប្រព័ន្ធគ្រប់គ្រងករណីកុមារតាមប្រព័ន្ធបច្ចេកវិទ្យា Primero និងបានបណ្តុះបណ្តាលដល់មន្ត្រីទទួលបន្ទុកនៅតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត និងការិយាល័យសង្គមកិច្ចនិងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស ព្រមទាំងបានធ្វើអធិការកិច្ចមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល។ តាមរយៈពិន្ទុអធិការកិច្ចឆ្នាំ២០១៩ បានបង្ហាញថា មណ្ឌលចំនួន៩៨ ស្មើនឹង៤២,២% អនុវត្តស្របតាមបទដ្ឋាន មណ្ឌលចំនួន៥៩ អនុវត្តមិនស្របតាមបទដ្ឋាន និង មណ្ឌលចំនួន៧៥ អនុវត្តក្រោមបទដ្ឋានអប្បបរមាធ្ងន់ធ្ងរ

- បានអនុវត្តផែនការសកម្មភាព ដើម្បីធ្វើឱ្យប្រសើរឡើងនូវការថែទាំកុមារ និងសមាហរណកម្មកុមារចំនួន៣០% ពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសាររបស់ពួកគេវិញដោយសុវត្ថិភាព។ គិតត្រឹមឆ្នាំ២០១៩ មណ្ឌលថែទាំកុមារនៅសល់ចំនួន ២៣២មណ្ឌល ដែលមានកុមារសរុបចំនួន៦ ៧៧៨នាក់ (ស្រី៣ ៣១៧នាក់)។ ដូច្នេះ បើធៀបនឹងឆ្នាំ២០១៥ មណ្ឌលថែទាំកុមារបានថយចុះចំនួន១៧៤កន្លែង (៤៣%) និងកុមាររស់នៅក្នុងមណ្ឌលថែទាំបានថយចំនួន៩ ៨០២នាក់ (៥៩%)។ ក្នុងចំណោមមណ្ឌលថែទាំកុមារ១៧៤ ដែលថយចុះដោយសារមណ្ឌលថែទាំចំនួន៧៧ បានបិទលែងដំណើរការ (ក្នុងនោះមណ្ឌលចំនួន២ បានបិទដោយសារការអនុវត្តមិនស្របតាមបទដ្ឋានអប្បបរមា ស្តីពីការថែទាំជំនួសចំពោះកុមារ មណ្ឌលចំនួន៤៣ បានបិទដោយសារខ្វះមូលនិធិ និងមណ្ឌលចំនួន៣២ផ្សេងទៀត បានបិទដោយសារមូលហេតុផ្សេងៗ មណ្ឌលចំនួន២៤ បានបង្វែរទៅជាសេវាថែទាំតាមសហគមន៍ និងមណ្ឌលចំនួន៧៣ បានផ្លាស់ទៅជាសេវាថែទាំដែលពុំមែនជាមណ្ឌល។ កុមារចំនួន ១ ៤១៩នាក់ ស្មើនឹង១២% ធៀបនឹងកុមារចំនួន១១ ៧៨៨នាក់ រស់នៅក្នុងមណ្ឌលថែទាំនៅក្នុងរាជធានី ខេត្តគោលដៅទាំង៥ ត្រូវបានជួយគាំទ្រដើម្បីសមាហរណកម្ម។ ទន្ទឹមនោះ ក្រសួងបានចេញសេចក្តីណែនាំ ស្តីពីតួនាទីភារកិច្ចរបស់មន្ត្រីសង្គមកិច្ច ក្រុង ស្រុក ខណ្ឌ

- បានចុះពិនិត្យវាយតម្លៃគម្រោងកម្មវិធីអង្គការនិងមណ្ឌល និងផ្តល់វិញ្ញាបនបត្រទទួលស្គាល់មណ្ឌលថែទាំកុមារជូនអង្គការមិនមែនរដ្ឋាភិបាលចំនួន១០០មណ្ឌល

- ដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារនៅឆ្នាំ២០១៩ កម្ពុជាបានចូលជាសមាជិកដៃគូសកលដើម្បីបញ្ចប់អំពើហិង្សាលើកុមារ ក្រសួងបានរៀបចំនិងផ្សព្វផ្សាយផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ បង្កើតយន្តការដឹកនាំការងារ និងបើកយុទ្ធនាការ "គ្រួសាររឹងមាំ" នៃយុទ្ធសាស្ត្រ Cambodia Protect ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ និងទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដោយមិន

ចាំបាច់។ យុទ្ធនាការនេះ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈវិទ្យុ ទូរទស្សន៍ សារសម្លេងតាមទូរសព្ទ បណ្ដាញសង្គមហ្វេសប៊ុក Strong Family និងគេហទំព័រ www.strongfamily.mosvy.gov.kh បានរៀបចំសន្និសីទថ្នាក់តំបន់ឆ្ពោះទៅអនុវត្តយុទ្ធសាស្ត្រ INSPIRE (I : Implementation and enforcement of laws; N : Norms and values; S : Safe environments; P : Parent and caregiver support; I : Income and economic strengthening; R : Response and support services; and E : Education and life skills) ដែលមានអ្នកចូលរួមចំនួន១៥០នាក់ មកពីប្រទេសចំនួន២១ ដើម្បីសិក្សានិងចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមក

- បានទទួលរបាយការណ៍តាមដានវឌ្ឍនភាពកូនចិញ្ចឹមចំនួន១ ៥២៥ករណី ។ តាមរបាយការណ៍ស្ថានភាពកុមារដែលបានសុំទៅក្រៅប្រទេសមានលក្ខណៈល្អប្រសើរទាំង សុខភាព ការរស់នៅ និងការសិក្សារៀនសូត្រ

- បានសហការជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រៀបចំសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមជ្ឈមណ្ឌលជាតិព្យាបាលនិងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ នៅភូមិម៉ុងឬទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តម កែ គឹមយ៉ាន ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** និងបានចេញប្រកាសអន្តរក្រសួងស្ដីពីលក្ខខណ្ឌនិងទម្រង់បែបបទនៃការស្នើសុំបង្កើតមណ្ឌលសម្រាប់ការព្យាបាលនិងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគោលការណ៍ណែនាំស្ដីពីការព្យាបាលនិងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។ មណ្ឌលព្យាបាល បន្សាប និងស្ដារនីតិសម្បទាទាំង៩កន្លែង ទទួលជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន៥៥ ៣០៧នាក់ និងបញ្ចេញជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន៣៥ ២២៣នាក់ នៅសល់ជាក់ស្ដែងចំនួន២០ ០៨៤នាក់

- ច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ត្រូវបានផ្សព្វផ្សាយដល់មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ដើម្បីជំរុញអនុវត្តច្បាប់នេះ ក្រសួងបានរៀបចំផែនការយុទ្ធសាស្ត្រនិងផែនការប្រតិបត្តិ ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សាងសង់មណ្ឌលយុវនីតិសម្បទា កសាងលិខិតបទដ្ឋានគតិយុត្តជាច្រើន ព្រមទាំងបានតែងតាំង និងទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច២៥រាជធានី ខេត្តចំនួន៥០នាក់

- មណ្ឌលយុវនីតិសម្បទាបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** កាលពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ស្ថិតនៅភូមិបាគូ ឃុំបាគូ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល និងកំពុងទទួលអនីតិជនទំនាស់នឹងច្បាប់ចំនួន ១៤០នាក់ស្នាក់នៅ

- បានអនុវត្តកម្មវិធីបង្វែរអនីតិជនទំនាស់នឹងច្បាប់ ដោយក្នុងនោះ

* ដំណាក់កាលរៀបចំរបាយការណ៍ស្ដីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនទំនាស់នឹងចំនួន៩៣ករណី
* ដំណាក់កាលចូលរួមស្ដាប់ចម្លើយក្នុងសវនាការចំនួន១៨៩ករណី
* ដំណាក់កាលបើកការគ្រប់គ្រងករណីអនីតិជនទំនាស់នឹងច្បាប់ចំនួន១២៧ករណី
* និងបានបិទករណីអនីតិជនទំនាស់នឹងច្បាប់ចំនួន១២ករណី។

- បានអប់រំកុមារ យុវជន ទប់ស្កាត់បាតុភាពអសកម្មនានាក្នុងសង្គម រួមចំណែកលើកស្ទួយសីលធម៌ សុជីវធម៌និងការពារសិទ្ធិកុមារ និងជនរងគ្រោះដែលប្រើប្រាស់គ្រឿងញៀន។ បានសហការជាមួយក្រសួងមហាផ្ទៃ

អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ផ្តល់សេវាអប់រំក្រៅប្រព័ន្ធ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់អនីតិជនទំនាស់នឹងច្បាប់ និងបានផ្តល់សេវាសង្គមកិច្ចដល់កូនតាមម្តាយក្នុងពន្ធនាគារដែលមានអាយុលើសពី៣ឆ្នាំចំនួន២៥នាក់។

តារាងទី២.លទ្ធផលសម្រេចបានអនុកម្មវិធីទី១.២

| ល.រ. | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ខែកញ្ញា ឆ្នាំ២០២២ |
| ១ | កុមារកំព្រា និងកុមារងាយរងគ្រោះដែលរស់នៅក្នុងមណ្ឌលថែទាំកុមារ | នាក់ | ៧ ៦៣៤ | ៦ ៧៧៨ | ៦ ៧៧៨ | ៦ ៨៥៥ | ៦ ៥២៤ |
| ២ | កុមារកំព្រា និងកុមារងាយរងគ្រោះដែលបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ១ ១៤០ | ១ ៤១៩ | ១ ៤៤៧ | ១ ៤៤៧ | ១ ៧៣៦ |
| ៣ | កុមាររងគ្រោះដែលទទួលបានការថែទាំដោយក្រុមគ្រួសារ និងសហគមន៍ | នាក់ | ១០ ៧៤៨ | ២ ៨០០ | ២ ៨០០ | ២៨០០ | ២ ៩៤០ |
| ៤ | កុមារដែលត្រូវបានសុំកូនអន្តរប្រទេស | នាក់ | ០០ | ០០ | ០០ | ០០ | |
| ៥ | ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលបានការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស | ទីភ្នាក់ងារ | ០០ | ០០ | ០០ | ០០ | |
| ៦ | អនីតិជនប្រព្រឹត្តល្មើសច្បាប់ដែលជាប់ក្នុងពន្ធនាគារ ឬមណ្ឌលអប់រំកែប្រែនិងមណ្ឌលយុវនីតិសម្បទាទទួលបានសេវាស្តារនីតិសម្បទា | នាក់ | ១ ៥៦៥ | ១ ៦៨១ | ១ ៦២១ | ១ ២៨៣ | ១ ៤២២ |
| ៧ | កូនតាមម្តាយដែលមានអាយុចាប់ពី៣(បី) ឆ្នាំឡើងទៅនៅក្នុងពន្ធនាគារត្រូវបានទទួលសេវាសង្គមកិច្ច | នាក់ | ៧ | ៨ | ៧ | ១០ | ០០ |
| ៨ | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានស្តារនីតិសម្បទា | នាក់ | ៨ ០៩៧ | ១១ ៩១៣ | ១១ ៥៣៦ | ១១ ៨៤៣ | ១១ ៩១៨ |
| ៩ | ជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀនបានធ្វើសមាហរណកម្មទៅសហគមន៍វិញ | នាក់ | ៧ ៦៧៧ | ៧ ៩០៥ | ៧ ៥៥១ | ៥ ០៦៧ | ៧ ០២៣ |

(ប្រភព៖ ទិន្នន័យរដ្ឋបាលក្រសួង ស.អ.យ.)

### ៣.១.៣-ការអភិវឌ្ឍសុខុមាលភាពជនពិការ

- បានរៀបចំសេចក្ដីព្រាងដំបូងនៃច្បាប់ស្ដីពីកិច្ចគាំពារសិទ្ធិជនមានពិការភាព

- បានរៀបចំនិងផ្សព្វផ្សាយរបាយការណ៍ជាតិនិងអន្តរជាតិស្ដីពីការអនុវត្តអនុសញ្ញា ស្ដីពីសិទ្ធិជនមានពិការភាព យុទ្ធសាស្ត្រអ៊ីនឈាន់ ផែនការយុទ្ធសាស្ត្រជាតិ ច្បាប់ស្ដីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ បទដ្ឋានបច្ចេកទេស និងបង្កើតឧបករណ៍ផ្សព្វផ្សាយស្ដីពីផាសុកវត្ថុ

- បានដាក់ឱ្យប្រើប្រាស់ប្រកាសអន្តរក្រសួង ស្ដីពីលក្ខខណ្ឌនៃការចេញបណ្ណបើកបរយានយន្តសម្រាប់ជនមានពិការភាព រួមទាំងសៀវភៅគោលការណ៍ណែនាំ ស្ដីពីជំនួយផ្នែកច្បាប់សម្រាប់ជនមានពិការភាព និងប្រកាសស្ដីពីការដាក់ឱ្យអនុវត្តបទដ្ឋានបច្ចេកទេសផាសុកវត្ថុ

- បានអនុវត្តគម្រោងសាកល្បងបរិយាបន្នពិការភាព និងGender ដល់ក្រុមប្រឹក្សាសកម្មភាពជនមានពិការភាពខេត្តចំនួន៥ គឺខេត្តបាត់ដំបង សៀមរាប កំពង់ចាម ត្បូងឃ្មុំ និងខេត្តកំពង់ស្ពឺ

- បានបង្កើតក្រុមការងារសកម្មភាពជនពិការ(ក.ស.ជ.) តាមក្រសួង ស្ថាប័ន និងក្រុមប្រឹក្សាសកម្មភាពជនមានពិការភាពតាមរាជធានី ខេត្ត និងបានរៀបចំសិក្ខាសាលាបញ្ជ្រាបការយល់ដឹងអំពីអនុសញ្ញាស្ដីពីសិទ្ធិជនមានពិការភាព ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកឆ្នាំ២០១៣-២០២២ ផែនការយុទ្ធសាស្ត្រជាតិស្ដីពីជនមានពិការភាព បើកវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលជំនាញបរិយាបន្នជនមានពិការភាពរបៀបធ្វើបរិយាបន្នជនមានពិការភាពដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋានក.ស.ជ. ក្រុមការងារក.ស.ជ. តាមក្រសួង ស្ថាប័ន និងក.ស.ជ. ថ្នាក់រាជធានី ខេត្តយ៉ាងទូលំទូលាយ

- បានចូលរួមកិច្ចប្រជុំក្រុមការងារក្នុងក្របខ័ណ្ឌអាស៊ានចំនួន៦លើក ស្ដីពីការកសាងផែនការមេសម្រាប់ការបញ្ជ្រាបសិទ្ធិជនមានពិការភាពក្នុងសហគមន៍អាស៊ានឆ្នាំ២០២៥

- បានចូលរួមសន្និសីទលើកទី១១ នៃរដ្ឋភាគីអនុសញ្ញាស្ដីពីសិទ្ធិជនមានពិការភាពនៅអង្គការសហប្រជាជាតិ ការិយាល័យកណ្ដាលទីក្រុងញូវយ៉ក សហរដ្ឋអាម៉េរិក កាលពីថ្ងៃទី១២ដល់១៤ ខែមិថុនា ឆ្នាំ២០១៨ ក្រោមប្រធានបទ **"មិនអនុញ្ញាតឱ្យនរណាម្នាក់នៅក្រៅការអនុវត្តយ៉ាងពេញលេញនៃអនុសញ្ញាស្ដីពីសិទ្ធិជនពិការ"** ក្នុងនោះ កម្ពុជាទទួលបានការគាំទ្រ១៨៣សម្លេង លើ១៨៨សម្លេង ចូលជាសមាជិក ECOSOC នៃអង្គការសហប្រជាជាតិ

- បានរៀបចំទិវាជនពិការកម្ពុជា និងទិវាជនពិការអន្តរជាតិ ទិវាគថ្លង់ និងទិវាអូទីហ្ស៊ីមនិងដោនស៊ីនដ្រូមសម្រាប់ជនមានពិការភាពទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិជារៀងរាល់ឆ្នាំ

- បានបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងផ្ដួចផ្ដើមបង្កើតមុខរបរនៅតាមសហគមន៍ដល់ជនមានពិការភាពបាន៣៥៩នាក់ លើជំនាញកាត់ដេរសម្លៀកបំពាក់និងកាបូប អេឡិចត្រូនិក ជួសជុលម៉ាស៊ីន អ៊ុតសក់ធ្វើមុខនិងសម្អាងការ ចម្លាក់ កសិកម្ម ជួសជុលទូរស័ព្ទ និងជំនាញគ្រប់គ្រងអាជីវកម្មនិងអនាម័យ

- អនុវត្តតាមអនុក្រឹត្យ ស្ដីពីការជ្រើសរើសជនមានពិការភាពចូលបម្រើការងារ ក្រសួង ស្ថាប័នរដ្ឋចំនួន៤៣ បានទទួលជនមានពិការភាពចូលបម្រើការងារចំនួន៣ ៧៤៨នាក់ និងជនមានពិការភាពចំនួន៥ ៨៣៩នាក់ កំពុងបម្រើការងារនៅក្នុងរោងចក្រ សហគ្រាសវិស័យឯកជន

- បានផ្ដល់របបគោលនយោបាយចំពោះជនពិការក្រីក្រនៅតាមសហគមន៍១៩ ៧៧២នាក់ ជា២កម្រិត កម្រិត១ឧបត្ថម្ភ១២ខែ និងកម្រិត២ឧបត្ថម្ភ៦ខែ ដោយមួយខែៗឧបត្ថម្ភ២០ ០០០រៀល

- ដើម្បីអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ក្រសួងបានកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការកំណត់អត្តសញ្ញាណជនមានពិការភាពតាមបែបគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ដែលរហូតមកដល់ពេលនេះ ជនមានពិការភាពសរុបចំនួន២៤៥ ០៦៣នាក់ (ស្រី១១៤ ៥៩៣នាក់) ត្រូវបានសម្ភាសដើម្បីកំណត់អត្តសញ្ញាណជនមានពិការភាពតាមបែបគំរូសង្គម និងសិទ្ធិជាមូលដ្ឋាននៅតាមឃុំ សង្កាត់

- បានផលិតសៀវភៅមគ្គុទ្ទេសក៍គតិយុត្ត ស្តីពីកាតព្វកិច្ចរបស់និយោជកក្នុងការជ្រើសរើសនិយោជិតពិការចូលបម្រើការងារជាបីភាសា (ខ្មែរ អង់គ្លេស និងចិន) ចំនួន១០ ០០០ក្បាល ដើម្បីចែកជូនដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស ទូទាំងប្រទេស

-បានចេញប្រកាស ស្តីពីការដាក់ឱ្យប្រើប្រាស់នូវឯកសារណែនាំគោល នីតិវិធីចុះបញ្ជិកា ស្តីពីនីតិវិធីអធិការកិច្ចលើវិស័យពិការភាពនៃព្រះរាជាណាចក្រកម្ពុជា និងបានផ្សព្វផ្សាយទៅតាមរាជធានី ខេត្ត ព្រមទាំងគិតមកដល់ចុងខែកញ្ញា ឆ្នាំ២០២២នេះ ក្រសួងបានចុះបញ្ជិកាជូនរោងចក្រ សហគ្រាសសរុបចំនួន ២៧៥អង្គភាព និងមានអង្គភាពចំនួន ១២ បានបង់ភាគទានជូនមូលនិធិជនមានពិការភាព។

តារាងទី៣.លទ្ធផលសម្រេចបានអនុកម្មវិធីទី១.៣

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ខែកញ្ញា ឆ្នាំ២០២២ |
| ១ | ជនមានពិការភាពទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ | នាក់ | ១១៧ | ១១៩ | ៥៣ | ៣៥ | ៣៥ |
| ២ | ជនមានពិការភាពត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមស្ថាប័នរដ្ឋ (២%) | នាក់ | ២ ៨៣៩ | ២ ៨៦០ | ៣ ០៩៥ | ៣ ៦២១ | ៣ ៦២១ |
| ៣ | ជនមានពិការភាពត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារនៅតាមស្ថាប័នឯកជន (១%) | នាក់ | ៣ ០៥៥ | ៣ ៣១៥ | ៣ ៨៩១ | ៥ ២៣៥ | ៥ ២៣៥ |
| ៤ | ជនមានពិការភាពក្រីក្រនៅតាមសហគមន៍ទទួលបានរបបឧបត្ថម្ភគោលនយោបាយ | នាក់ | ១៣ ៤៦៦ | ១៤ ១១៦ | ១៦ ៣៧៣ | ១៦ ៨០២ | ១៦ ៥៨៦ |

(ប្រភពៈ ទិន្នន័យរដ្ឋបាលក្រសួងស.អ.យ.)

### ៣.១.៤- ការអភិវឌ្ឍសុខុមាលភាពមនុស្សចាស់

- បានរៀបចំនិងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ និងបានរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយនេះផងដែរ

- បានចេញប្រកាសស្តីពីលក្ខខណ្ឌ និងទម្រង់បែបបទនៃការស្នើសុំអនុញ្ញាតបង្កើតមជ្ឈមណ្ឌលថែទាំមនុស្សវ័យចាស់ និងប្រកាសស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការបង្កើតមជ្ឈមណ្ឌល និងការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំមនុស្សវ័យចាស់

-បានរៀបចំទិវាមនុស្សចាស់កម្ពុជានិងមនុស្សចាស់អន្តរជាតិ ១តុលា ជារៀងរាល់ឆ្នាំ ដើម្បីលើកស្ទួយដល់កិត្តិយសនិងសេចក្តីថ្លៃថ្នូររបស់មនុស្សវ័យចាស់

-ដើម្បីលើកកម្ពស់សេចក្តីថ្លៃថ្នូរ ជំរុញលើកទឹកចិត្តឱ្យមនុស្សចាស់ចេះសាមគ្គីគ្នា ជួយគ្នាទៅវិញទៅមក ក្រសួងបានបង្កើតសមាគមមនុស្សចាស់១ ៦៤៦ មានសមាជិកសរុបចំនួន២៩៤ ៤៤០នាក់ នៅតាម រាជធានី ខេត្តទាំង២៥

-បានសាងសង់មជ្ឈមណ្ឌលជាតិគាំពារមនុស្សចាស់រាជធានីភ្នំពេញ ដោយបានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីនិងភ្នាក់ងារវិស័យឯកជនអំពីជំនាញថែទាំមនុស្សវ័យចាស់។

តារាងទី៤.លទ្ធផលសម្រេចបានអនុកម្មវិធីទី១.៤

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ខែកញ្ញា ឆ្នាំ២០២២ |
| ១ | អត្រាមនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំនៅតាមសហគមន៍ | % | 00 | 00 | 00 | 00 | 00 |
| ២ | មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានសេវាថែទាំក្នុងមជ្ឈមណ្ឌលគាំពារមនុស្សចាស់ | នាក់ | 00 | 00 | 00 | 00 | 00 |
| ៣ | មនុស្សចាស់ក្រីក្រគ្មានទីពឹងទទួលបានគោលនយោបាយរបបគាំពារសង្គម | នាក់ | | - | - | ៣៣៨ ០៧៦ | ៣៥៩ ៨៦៨ |

(ប្រភព៖ ទិន្នន័យរដ្ឋបាលក្រសួង សអយ)

### ៣.១.៥- អភិវឌ្ឍសុខុមាលភាពអតីតយុទ្ធជន

- បានបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជនឃុំ សង្កាត់១ ០២៣ មានសមាជិកសរុបចំនួន២៤ ៤០៤នាក់ ដែលបានជួយកែលម្អជីវភាពរស់នៅរបស់អតីតយុទ្ធជន និងគ្រួសារឱ្យកាន់តែប្រសើរឡើងជាបន្តបន្ទាប់

- បានបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីនីតិវិធីប្រមូលទិន្នន័យពីស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារចំនួន៤០០នាក់ នៅខេត្តកែប ស្វាយរៀង ត្បូងឃ្មុំ និងខេត្តកំពត

- សមាគមអតីតយុទ្ធជនកម្ពុជាបានទទួលថវិកាពីរាជរដ្ឋាភិបាលចំនួន ៤ពាន់លានរៀល/ឆ្នាំ ជូនដល់សមាគមអតីតយុទ្ធជនកម្ពុជា ដើម្បីប្រគល់ជូនដល់សមាជិកសមាគមអតីតយុទ្ធជនកម្ពុជាដែលបានទទួលមរណភាពចាប់តាំងពីឆ្នាំ២០១៦

- បានសហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជា(ស.អ.ក.) រៀបចំប្រារព្ធទិវាអតីតយុទ្ធជនកម្ពុជា ២១មិថុនា ជារៀងរាល់ឆ្នាំ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ក្នុងរយៈពេល៥ឆ្នាំ សមាគមអតីតយុទ្ធជនកម្ពុជាបានទទួលសំណុំបែបបទស្នើសុំប្រាក់បេឡាមរណៈសង្គ្រោះ និងបានចេញសេចក្តីសម្រេចប្រគល់ប្រាក់បេឡាមរណៈសង្គ្រោះជូនដល់គ្រួសារសព៨ ២០៥សព។ បើគិតពីឆ្នាំ២០០៨ រហូតដល់ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២២ សមាគម

អតីតយុទ្ធជនកម្ពុជា បានចេញសេចក្តីសម្រេចប្រគល់ប្រាក់បេឡាមរណសង្គ្រោះជូនដល់គ្រួសារសពសរុបចំនួន ១៩ ០៤៥សព។ បច្ចុប្បន្ន ស.អ.ក. មានសមាជិកសរុបចំនួន៨០ ៦៩១នាក់

-បានសហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជា រៀបចំកម្មវិធីបើកមហាសន្និបាតសហព័ន្ធអតីតយុទ្ធជនអាស៊ាន (VECONAC) លើកទី១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា និងកម្មវិធីបិទមហាសន្និបាតដោយឯកឧត្តមនាយឧត្តមសេនីយ៍ **គន់ គីម** ទេសរដ្ឋមន្ត្រី អនុប្រធានអគ្គលេខាធិការ ស.អ.ក. និងជាប្រធានសហព័ន្ធអតីតយុទ្ធជនអាស៊ានឆ្នាំ២០១៩។

## ៣.២- បង្កើនប្រសិទ្ធភាពប្រព័ន្ធសន្តិសុខសង្គម និងផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជនពិការ

### ៣.២.១- អភិវឌ្ឍសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលប្រកបដោយប្រសិទ្ធភាព

- បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល(ប.ជ.ស.) បានដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមដែលមានតាវកាលិកចំនួន៦ គឺការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ មរណភាព និងអ្នកនៅក្នុងបន្ទុក ។ ប.ជ.ស. កំពុងបើកប្រាក់របបសន្តិសុខសង្គមជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈចំនួន**៥៦ ០៤៩នាក់** និងអ្នកនៅក្នុងបន្ទុកចំនួន**៣៣ ២៨៥នាក់** ដែលចំណាយថវិការដ្ឋប្រមាណ**៦៩៦ ពាន់លានរៀល** ប្រហែល**១៦៩លានដុល្លាអាម៉េរិក** ក្នុងមួយឆ្នាំ

- បានដំឡើងបន្ថែមប្រាក់សោធនប្រចាំខែតាមកម្រិតជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈជារៀងរាល់ឆ្នាំ មកដល់ឆ្នាំ២០២២នេះ ប្រាក់របបសន្តិសុខសង្គមប្រចាំខែទាបបំផុតចំនួន៦៩ម៉ឺនរៀល/ខែ។

តារាងទី៥.លទ្ធផលសម្រេចបានអនុកម្មវិធី ២.១

| ល.រ. | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ខែកញ្ញា ឆ្នាំ២០២២ |
| ១ | និវត្តជនជនបាត់បង់សម្បទាវិជ្ជាជីវៈនិងអ្នកនៅក្នុងបន្ទុកដែលទទួលរបបសន្តិសុខសង្គម | នាក់ | ១០០ ៣៨៦ | ១០២ ៤១១ | ១០៤ ៣៣៤ | ១០២ ៩២៩ | ៨៩ ៣៣៤ |
| ២ | និវត្តជនដែលទទួលរបបសោធន | នាក់ | ៥៤ ០២៨ | ៥៥ ១៩៣ | ៥៦ ៨៥៤ | ៥៦ ២៤១ | ៥៤ ៥០៨ |
| | ជនបាត់បង់សម្បទាវិជ្ជាជីវៈដែលទទួលរបបសោធន | នាក់ | ២ ៣២៥ | ២ ១០៩ | ២ ០១០ | ១ ៨៤៧ | ១ ៥៤១ |
| | អ្នកនៅក្នុងបន្ទុក | នាក់ | ៤៤ ០៣៣ | ៤៥ ១០៩ | ៤៧ ៤៧០ | ៤៤ ៨៤១ | ៣៣ ២៨៥ |

(ប្រភព៖ បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល)

### ៣.២.២- បង្កើនប្រសិទ្ធភាពសេវាបើកផ្តល់របបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន និងគ្រួសារ

បានកែសម្រួលប្រាក់សោធនជូនជនមានពិការភាព និវត្តជន និងជនបាត់បង់សមត្ថភាពការងាររហូតមកដល់ឆ្នាំ២០២២ ប្រាក់សោធនអប្បបរមាត្រូវបានដំឡើងដល់៦៩០ ០០០រៀល/ខែ។ បានកំពុងបើកផ្តល់របបសន្តិសុខសង្គមជូនអតីតយុទ្ធជននិងគ្រួសារប្រមាណ៩៣ ៤៨៤នាក់ និងអ្នកនៅក្នុងបន្ទុក១៣៨ ៦០៤នាក់ កំពុងទទួលរបបសន្តិសុខសង្គម តាមប្រព័ន្ធធនាគារ។

តារាងទី៦.លទ្ធផលសម្រេចបានអនុកម្មវិធី ២.២

| ល.រ. | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ខែកញ្ញា ឆ្នាំ២០២២ |
| ១ | អតីតយុទ្ធជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ៨៨ ៥២៦ | ៩១ ៣១៩ | ៩៨ ៥៧៩ | ១០២ ៦៦៨ | ១០៦ ៣២១ |
| ២ | និវត្តជនដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ២៧ ១០១ | ២៨ ៣៣៨ | ៣៣ ៣៨៨ | ៣៦ ៦៥៧ | ២៧ ១១៩ |
| | ជនបាត់បង់សមត្ថភាពការងារដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ១ ៥៦៤ | ១ ៥២៧ | ១ ៤៩៩ | ១ ៤៨៣ | ១០ ១៧៥ |
| | ជនមានពិការភាពដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ២៧ ២០៥ | ២៧ ៤៣៧ | ២៨ ៣២៧ | ២៨ ៥៨៤ | ២៩ ៥១៦ |
| | ជនពលីដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ២៥ ៧៣២ | ២៦ ២៦៧ | ២៦ ៧៤៣ | ២៦ ៧៨៩ | ៣៨ ០៦៦ |
| | ជនមរណៈដែលកំពុងទទួលរបបសន្តិសុខសង្គម | នាក់ | ៦ ៩២៤ | ៧ ៧៥០ | ៨ ៦២២ | ៩ ១៥៥ | ១ ៤៤៥ |
| ៣ | អ្នកនៅក្នុងបន្ទុកអតីតយុទ្ធជន | នាក់ | ១៣០ ៤៤១ | ១៣៥ ៣៨៨ | ១៤៦ ០២៤ | ១៤៨ ៦៩៩ | ១៥២ ៧៨៦ |

(ប្រភព៖ បេឡាជាតិអតីតយុទ្ធជន)

### ៣.២.៣- បន្តនិរន្តរភាពការផ្តល់សេវាស្តារលទ្ធភាពពលកម្មជូនជនមានពិការភាព

- មូលនិធិជនមានពិការភាពបានសហការជាមួយអង្គការដៃគូ ផ្តល់សេវាស្តារលទ្ធភាពពលកម្មប្រកបដោយគុណភាពដោយឥតគិតថ្លៃជូនជនមានពិការភាព៣១៦ ៥៨៣នាក់ ក្នុងនោះសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ២១២ ៦៩១នាក់ និងស្តារលទ្ធភាពពលកម្មកាយសម្បទា បាន១០៣ ៨៩២នាក់។ ទន្ទឹមនេះ ជនមានពិការភាពដែលមកទទួលសេវាពីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម បានទទួលការឧបត្ថម្ភជាប្រាក់អាហារនិងថ្លៃធ្វើដំណើរទៅមកផងដែរ។ ក្រៅពីការផ្តល់សេវានៅតាមមណ្ឌលស្តារលទ្ធភាពពលកម្ម មូលនិធិជនមានពិការភាពក៏បានផ្តល់សេវាសហគមន៍ជូនជនមានពិការភាព ដូចជាការជួសជុលឧបករណ៍សិប្បនិម្មិតនិងរណប ការសម្របសម្រួលជូនជនមានពិការភាពទៅទទួលសេវាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបញ្ជូនទៅសេវាសុខាភិបាលសរុបចំនួន៣៧ ១៩៩នាក់
- បានផ្តល់ប្រាក់ឧបត្ថម្ភរបបគោលនយោបាយសម្រាប់ពិនិត្យ និងថែទាំសុខភាពជូនដល់ជនមានពិការភាពក្រីក្រនៅតាមសហគមន៍បាន២៩ ៣៤៨នាក់ ដោយម្នាក់ៗទទួលបានថវិកា៣០ ០០០រៀល

- បានសាងសង់ផ្ទះជូនគ្រួសារជនមានពិការភាពក្រីក្រចំនួន៣៨ខ្នង និងបានផ្តល់កញ្ចប់អំណោយសប្បុរសធម៌របស់មូលនិធិជនពិការជូនជនពិការក្រីក្រសរុបចំនួន២ ៦៥៣នាក់

- បានទទួលប្រាក់ភាគទានដោយស្ម័គ្រចិត្តពីការមិនបានអនុវត្តតាមអត្រាកំណត់នៃការជ្រើសរើសជនមានពិការភាពចូលបម្រើការងារពីក្រុមហ៊ុននិងរោងចក្រ សរុបចំនួន៨២៨ ៣៨៣ ៣៦៥រៀល និងទទួលបានប្រាក់ពីហិបប្រាក់វិភាគទានសប្បុរសធម៌មូលនិធិជនពិការ សរុបចំនួន៧១៧ ៤១៦ ១០០រៀល។

តារាងទី៧.លទ្ធផលសម្រេចបានអនុកម្មវិធីទី២.៣

| ល.រ | សូចនាករ | ឯកតា | លទ្ធផលសម្រេចបានក្នុងឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ខែកញ្ញា ឆ្នាំ២០២២ | |
| ១ | ជនមានពិការភាពដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មកាយសម្បទានៅតាមមជ្ឈមណ្ឌល | នាក់ | ២៨ ០៤៥ | ២៦ ៣១០ | ១៨១៩៨ | ១២ ៦១៧ | ១៦ ៥០៧ | ១០៣ ៨៩២ |
| ២ | ជនមានពិការភាពដែលទទួលបានសេវាស្តារលទ្ធភាពពលកម្មនៅសហគមន៍ | នាក់ | ១១ ៨៨៦ | ៩ ៨៨៩ | ៥ ១៣៩ | ៣ ៧៧៣ | ៥៦៧៦ | ៣៧ ១៩៩ |
| ៣ | ជនមានពិការភាពក្រីក្រទទួលបានរបបគោលនយោបាយឧបត្ថម្ភសេវាស្តារនិងពិនិត្យថែទាំសុខភាព | នាក់ | ២ ៦៤៤ | ៥ ២៨៧ | ៦ ៨៩៨ | ៩ ២៥២ | ៣ ៥៤៥ | ២៩ ៣៤៨ |
| ៤ | ជនមានពិការភាពទទួលបានសេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រ | នាក់ | ៦០ ៤០០ | ៥៩ ០៦៣ | ៤៤ ៦១៣ | ២០ ៧០១ | ២៤ ៧២១ | ២១២ ៦៩១ |

## ៣.៣- ពង្រឹងសមត្ថភាពស្ថាប័ននិងអភិបាលកិច្ចល្អ

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រេចការងារបានដូចខាងក្រោម៖**

- បានចុះអធិការកិច្ច និងសវនកម្ម ដើម្បីពិនិត្យ កែលម្អការបំពេញមុខងារ តួនាទី របៀបរបបការងារ ការដោះស្រាយជម្លោះ ការគ្រប់គ្រងចំណាយថវិការដ្ឋ និងទ្រព្យសម្បត្តិរដ្ឋ នៅតាមមន្ទីរ ស.អ.យ. រាជធានី ខេត្ត សំដៅលើកកម្ពស់គណនេយ្យភាព តម្លាភាព ប្រសិទ្ធភាពនៃការផ្តល់សេវាសង្គមកិច្ចជូនជនរងគ្រោះនិងងាយរងគ្រោះគ្រប់ប្រភេទ

- បានបង្រួមប្រព័ន្ធនៃការផ្តល់សេវារដ្ឋបាល សេវាតម្រូវការ និងសេវាសំណូមពរតាមច្រកចេញចូលតែមួយ កាត់បន្ថយភាពយឺតយ៉ាវ គ្រប់គ្រង និងរក្សាបាននូវការសម្ងាត់ប្រកបដោយភាពគត់ហ្មត់ ស្របតាមកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ។ បានលើកទឹកចិត្តមន្ត្រីរាជការតាមរយៈការបណ្តុះបណ្តាលពង្រឹងសមត្ថភាព ការដំឡើងថ្នាក់ ឋានន្តរសក្តិ និងការបើកផ្តល់បៀវត្សទាំងពីរលើកបានទាន់ពេលវេលា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

- បានពង្រឹងការងារផែនការនិងផ្សព្វផ្សាយ តាមរយៈការរៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ របាយការណ៍ពាក់កណ្តាលអាណត្តិ ឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០២៣ របាយការណ៍លទ្ធផលការងាររយៈពេល៥ឆ្នាំ ២០១៧-២០២១ ផែនការសកម្មភាពបីឆ្នាំរំកិល ២០២២-២០២៤ ផែនការសកម្មភាពអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ និងកម្រងសេវាសាធារណៈរបស់ក្រសួងដែលមានសេវាជាអាទិភាពសរុបចំនួន២២សេវា

- បានអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងកម្មវិធីអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៧ ស្តីពីការប្រគល់មុខងារ "ការគ្រប់គ្រងមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ" ឱ្យទៅរដ្ឋបាលរាជធានី ខេត្ត "ការធ្វើអធិការមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល" ឱ្យទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមុខងារ "ការគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះនិងងាយរងគ្រោះនៅសហគមន៍" ឱ្យរដ្ឋបាលរាជធានី និងរដ្ឋបាលឃុំ សង្កាត់ ដោយក្នុងនោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទាបានផ្ទេរមន្ត្រីចំនួន៥៦នាក់ និងផ្ទេរអចលនទ្រព្យរួមមានអគារ សម្ភារៈអចលនទ្រព្យមួយចំនួនទៀតទៅឱ្យរដ្ឋបាលរាជធានី ខេត្ត នៅសល់តែការផ្ទេរការគ្រប់គ្រងដីរបស់មណ្ឌលថែទាំកុមារទាំង២១កន្លែង នៃរាជធានីខេត្តទាំង១៨ កំពុងស្ថិតក្នុងដំណើរការផ្ទេរជាជំហានៗ

- បានអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការគ្រប់គ្រងការបើកផ្តល់បានត្រឹមត្រូវនិងទាន់ពេលវេលា។ ការគ្រប់គ្រងសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងការបែងចែកសម្ភារៈប្រកបដោយស័ក្តិសិទ្ធភាព គណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ

- ក្រសួងបានលើកទឹកចិត្តនិងសហប្រតិបត្តិការជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស និងដៃគូអភិវឌ្ឍនានា ក្នុងស្មារតីសាមគ្គីធម៌ និងកៀរគរប្រភពធនធានទាំងសម្ភារៈ ថវិកា និងបច្ចេកទេស បម្រើឱ្យសំណូមពររបស់ជនរងគ្រោះនិងងាយរងគ្រោះគ្រប់ប្រភេទក្នុងសង្គម ជាអាទិ៍ បានចុះកិច្ចព្រមព្រៀងគម្រោងការជាមួយអង្គការ១៤៩អង្គការ ដែលមានថវិកាគម្រោងសរុបចំនួន**៣២១ ៩៦៨ ៤៤៩,៥០ ដុល្លារអាម៉េរិក**។ ទន្ទឹមនេះ ក៏បានធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធក្នុងក្របខ័ណ្ឌទ្វេភាគីកម្ពុជា-ថៃ ពាក់ព័ន្ធនឹងការសាងសង់មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដែលគម្រោងនេះកំពុងចាប់ផ្តើមសាងសង់ក្នុងត្រីមាសទី១ នៃឆ្នាំ២០២២ កម្ពុជា-វៀតណាម ពាក់ព័ន្ធនឹងការផ្តល់ថវិកាដោយភាគីវៀតណាម ដើម្បីសាងសង់អគារចំនួន៤ នៅក្នុងមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍កែវផុស ខេត្តព្រះសីហនុ។ ក្នុងក្របខ័ណ្ឌតំបន់អាស៊ាន ពាក់ព័ន្ធនឹងវិស័យសុខុមាលភាពសង្គមនិងការអភិវឌ្ឍ រួមមានសេចក្តីថ្លែងការណ៍រួមស្តីពីការលើកកម្ពស់សិទ្ធិស្ត្រី សន្តិភាព និងសន្តិសុខនៅតំបន់អាស៊ាន ផែនការមេអាស៊ានឆ្នាំ២០២៥៖ ការបញ្ជ្រាបសិទ្ធិជនមានពិការភាព សេចក្តីប្រកាសអាស៊ានស្តីពីសិទ្ធិកុមារក្នុងបរិបទនៃការធ្វើទេសន្តរប្រវេសន៍ សេចក្តីប្រកាសស្តីពីការការពារកុមារពីគ្រប់ទម្រង់នៃការកេងប្រវ័ញ្ចតាមប្រព័ន្ធអ៊ិនធឺណេត និងការរំលោភបំពាននៅអាស៊ាន សេចក្តីថ្លែងការណ៍រួម ស្តីពីការបញ្ជាក់ជាថ្មីនៃការប្តេជ្ញាចិត្តដើម្បីលើកកម្ពស់សិទ្ធិកុមារក្នុងតំបន់អាស៊ាន សេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ាន ស្តីពីសុខុមាលភាពសង្គមនិងអភិវឌ្ឍន៍លើកទី១០ សេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានបូកបី ស្តីពីសុខុមាលភាពសង្គម និងអភិវឌ្ឍន៍លើកទី៦ សេចក្តីថ្លែងការណ៍រួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ាន ស្តីពីសុខុមាលភាពសង្គម និងអភិវឌ្ឍន៍ ស្តីពីការកាត់បន្ថយផលប៉ះពាល់ដោយកូវីដ-១៩ លើក្រុមជនងាយរងគ្រោះក្នុងអាស៊ាន រៀបចំវេទិកាកុមារអាស៊ានលើកទី៦ ស្តីពីផលប៉ះពាល់នៃកូវីដ-១៩ និងស្ថានភាពបច្ចុប្បន្នចំពោះកុមារ ក្របខ័ណ្ឌថ្នាក់តំបន់និងផែនការសកម្មភាពដើម្បីអនុវត្តសេចក្តីប្រកាសអាស៊ានស្តីពីការពង្រឹងកិច្ចគាំពារសង្គម សេចក្តីប្រកាសហាណូយ ស្តីពីការពង្រឹងការងារសង្គមឆ្ពោះទៅរកសហគមន៍អាស៊ាន ដែលមានភាពស្អិតរមួត និងមានការឆ្លើយតបរបាយការណ៍លើកទី២ ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការមេអាស៊ានឆ្នាំ២០២៥៖ ការបញ្ជ្រាបសិទ្ធិជនមានពិការភាពឆ្នាំ២០១៩-២០២០ ផែនការសកម្មភាពថ្នាក់តំបន់ដើម្បីអនុវត្តសេចក្តីប្រកាស

កូឡាឡាំពួរ ស្តីពីមនុស្សចាស់៖ការផ្តល់សិទ្ធិអំណាចដល់មនុស្សចាស់ក្នុងតំបន់អាស៊ាន និងក្របខ័ណ្ឌប្រតិបត្តិនៃពានរង្វាន់ការងារផ្ដើមលើវិស័យសុខុមាលភាពសង្គមនិងអភិវឌ្ឍន៍អាស៊ាន។

**៤- ការអនុវត្តគោលនយោបាយជាតិប្រជាជន** (www.mop.gov.kh)

ក្រសួងផែនការ បានខិតខំប្រឹងប្រែងបំពេញការងារយ៉ាងសកម្មប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុតក្នុងការអនុវត្តការងារជំនាញនីមួយៗ តាមបណ្ដាអង្គភាពក្រោមឱវាទក្រសួង ស្របតាមតួនាទី និងភារកិច្ចរបស់ក្រសួងផែនការ សម្រេចការងារបានសមិទ្ធផលសំខាន់ៗពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ ដូចខាងក្រោម៖

**៤.១- ការងារផែនការជាតិនិងគោលនយោបាយ**

- បានរៀបចំទស្សនាទានសម្រាប់ដំណើរការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៩-២០២៣
- ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (ផ.យ.អ.ជ) ២០១៩-២០២៣ ត្រូវបានរៀបចំនិងប្រកាសដាក់ឱ្យប្រើប្រាស់ផ្លូវការ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា**
- ក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (ក្របខណ្ឌ ក.អ.ច.ក.) ២០១៦-២០៣០ ត្រូវបានរៀបចំនិងអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា
- របាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ២០១៩-២០៣០ ត្រូវបានរៀបចំ
- កែសម្រួលបញ្ជីចំណុចដៅ និងសូចនាករ គ.អ.ច.ក. ឆ្នាំ ២០១៦-២០៣០ បោះពុម្ពនិងផ្សព្វផ្សាយ
- អនុវត្តកម្មវិធីកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជា និងUNICEF ឆ្នាំ២០១៩-២០២៣
- បានរៀបចំគោលនយោបាយណែនាំស្តីពីការតាមដានត្រួតពិនិត្យនិងវាយតម្លៃ
- រៀបចំបោះពុម្ពនិងផ្សព្វផ្សាយកូនសៀវភៅស្តីពី គ.អ.ច.ក.។

**៤.២- ការរៀបចំកម្មវិធីវិនិយោគសាធារណៈ**

- កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០១៩-២០២១
- កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០២០-២០២២
- កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០២១-២០២៣
- កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០២២-២០២៤
- កម្មវិធីវិនិយោគសាធារណៈ បីឆ្នាំរំកិល ២០២៣-២០២៥។

**៤.៣- ការរៀបចំរបាយការណ៍ជាតិ**

- បានរៀបចំរបាយការណ៍ត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តឆ្នាំ២០១៩ និងរបាយការណ៍វឌ្ឍនភាពនៃការសម្រេចបាន គ.អ.ច.ក
- បានរៀបចំរបាយការណ៍ស្តីពីស្ថានភាពនៃភាពក្រីក្ររបស់ប្រជាជនកម្ពុជា ឆ្នាំ២០១៩-២០២០
- របាយការណ៍វឌ្ឍនភាពឆ្នាំ២០១៩ នៃការសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០២៣

- របាយការណ៍នៃការអនុវត្តសូចនាករតាមដានរួមគ្នា រវាងក្រសួងផែនការជាមួយដៃគូអភិវឌ្ឍ ឆ្នាំ២០១៩-២០២០

- របាយការណ៍វឌ្ឍនភាពឆ្នាំ២០២០ នៃការសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០២៣

- របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០២១ នៃការអនុវត្ត ផ.យ.អ.ជ. ឆ្នាំ២០១៩-២០២៣។

## ៤.៤- ការងារផែនការតាមវិស័យ

- គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យ
- ផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៨ នៃការអនុវត្តផែនការ ផ.យ.ផ.ក ២០១៤-២០១៨
- ផែនការយុទ្ធសាស្ត្រក្រសួងផែនការ (ផ.យ.ផ.ក) ២០១៩-២០២៣
- ផែនការប្រតិបត្តិប្រចាំឆ្នាំ២០១៩ នៃការអនុវត្តផែនការ ២០១៩-២០២៣
- ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ នៃការអនុវត្តផែនការ ២០១៩-២០២៣
- ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២១ នៃការអនុវត្តផែនការ ២០១៩-២០២៣
- ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២២ នៃការអនុវត្តផែនការ ២០១៩-២០២៣
- ផែនការយុទ្ធសាស្ត្របញ្ច្រាបយេនឌ័រ ក្រសួងផែនការ (ផ.យ.ប.យ.ផ.ក) ២០១៩-២០២៣
- សេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល នៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ឯកសារព័ត៌មានពីស្ថានភាព និងតារាងពិន្ទុវិស័យរបស់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌសម្រាប់បណ្តារាជធានី ខេត្តនៃឆ្នាំនីមួយៗពីឆ្នាំ២០១៨-២០២២
- របាយការណ៍ទិន្នន័យប្រជាជននិងសន្ទស្សន៍ភាពក្រីក្រតាមបណ្តាឃុំ សង្កាត់ និងក្រុង ស្រុក ខណ្ឌ តាមបណ្តាឆ្នាំនីមួយៗសម្រាប់ជាមូលដ្ឋាន ដើម្បីវិភាជថវិកាដល់មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់។

## ៤.៥- ការងារកិច្ចសហប្រតិបត្តិការ

-បានទទួលគណៈប្រតិភូក្រសួងផែនការនិងវិនិយោគនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រី **ង្វៀង ជីយ៉ុង** មកធ្វើទស្សនកិច្ចនិងបំពេញការងារនៅកម្ពុជា និងបានរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីលើកទី៨ ស្តីពីកិច្ចសហប្រតិបត្តិការរវាងក្រសួងផែនការនៃព្រះរាជាណាចក្រកម្ពុជាជាមួយក្រសួងផែនការនិងវិនិយោគនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-ឯកឧត្តម **ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** បានចុះហត្ថលេខាជាមួយឯកឧត្តម **ង្វៀង ជីយ៉ុង** រដ្ឋមន្ត្រីក្រសួងផែនការ និងវិនិយោគវៀតណាម លើក្របខ័ណ្ឌកិច្ចព្រមព្រៀងរួមស្តីពីការតភ្ជាប់សេដ្ឋកិច្ចកម្ពុជា វៀតណាមនៅវិមានសន្តិភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

-គណៈប្រតិភូក្រសួងផែនការកម្ពុជា ដឹកនាំដោយឯកឧត្តម **ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ** ទៅចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៩ ស្តីពីកិច្ចសហប្រតិបត្តិការរវាងក្រសួងផែនការនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងផែនការនិងវិនិយោគនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

- បង្កើតនិងដំណើរការគេហទំព័រតំបន់ត្រីកោណអភិវឌ្ឍន៍ និងការប្រមូលព័ត៌មានស្តីពីការអភិវឌ្ឍគ្រប់វិស័យក្នុងខេត្ត សម្រាប់បង្ហោះចូលគេហទំព័រតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា វៀតណាម ឡាវ

- បានចូលរួមកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាម (JC) លើកទី១៦ ទី១៧ និងទី១៨ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

- របាយការណ៍វឌ្ឍនភាពនិងលទ្ធផលនៃការអនុវត្តគម្រោងនានាក្នុងក្របខ័ណ្ឌCLV-DTA លើវិស័យសន្តិសុខនិងការបរទេស។

### ក- ការងារសហប្រតិបត្តិការជាមួយប្រព័ន្ធស្ថិតិអាស៊ាននិងសកល

១- វិទ្យាស្ថានជាតិស្ថិតិ មានកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងសហគមន៍ប្រជាជាតិអាស៊ានចំនួន១០ប្រទេស តាមរយៈការផ្លាស់ប្តូរ ប្រៀបធៀបទិន្នន័យ និងតាមរយៈកិច្ចប្រជុំក្រុមតូចៗ និងគណៈកម្មាធិការស្ថិតិអាស៊ានរៀងរាល់ឆ្នាំ តាមការផ្លាស់ប្តូរវេនធ្វើជាម្ចាស់ផ្ទះដឹកនាំកិច្ចប្រជុំ (ឆ្នាំនេះកម្ពុជាយើងជាអ្នកដឹកនាំ)។

២- វិទ្យាស្ថានជាតិស្ថិតិ ក៏មានកិច្ចសហប្រតិបត្តិការជាមួយប្រព័ន្ធស្ថិតិសកលជិត២០០ប្រទេសផងដែរ តាមរយៈការផ្លាស់ប្តូរបទពិសោធន៍តាមកិច្ចប្រជុំតាមវិស័យជំនាញនៅតាមបណ្តាប្រទេសខ្លះ និងតាមរយៈកិច្ចប្រជុំប្រព័ន្ធស្ថិតិជាតិគ្រប់បណ្តាប្រទេសជារៀងរាល់ឆ្នាំនៅទីក្រុងញូយ៉ក សហរដ្ឋអាម៉េរិក។

### ខ- ការងារសហប្រតិបត្តិការជាមួយចិន អាស៊ាន

១- វិទ្យាស្ថានជាតិស្ថិតិក៏មានកិច្ចសហប្រតិបត្តិការយ៉ាងល្អជាមួយអគ្គនាយកដ្ឋានស្ថិតិ នៃសាធារណៈរដ្ឋ-ប្រជាមានិតចិនផងដែរ តាមរយៈការរៀបចំផ្តល់ទិន្នន័យជូនភាគីចិនជារៀងរាល់ឆ្នាំ ដើម្បីខាងភាគីស្ថិតិនៃសាធារណៈ-រដ្ឋប្រជាមានិតចិនរៀបរៀងជាកម្រងទិន្នន័យស្ថិតិចិន អាស៊ានប្រចាំឆ្នាំ។

២- លើសពីនោះទៀត ភាគីស្ថិតិនៃសាធារណៈរដ្ឋប្រជាមានិតចិន ធ្លាប់បានផ្តល់វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាដល់មន្ត្រីនៃប្រព័ន្ធស្ថិតិជាតិកម្ពុជាជារៀងរាល់ឆ្នាំរហូតដល់ឆ្នាំ២០១៩ មុនការផ្ទុះជំងឺកូវីដ-១៩។

### គ- កិច្ចសហប្រតិបត្តិការជាមួយក្រសួងមហាផ្ទៃនិងអង្គការ

១-វិទ្យាស្ថានជាតិស្ថិតិបានសហការជាមួយក្រសួងមហាផ្ទៃ ដោយបានចូលរួមរៀបចំច្បាប់ស្តីពីអត្រា-នុកូលដ្ឋាន ស្ថិតិអត្រានុគោលដ្ឋាន និងអត្តសញ្ញាណកម្មដោយបែងចែកតួនាទី ភារកិច្ចច្បាស់លាស់រវាងក្រសួងមហាផ្ទៃ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងក្រសួងសុខាភិបាល។

២-ទន្ទឹមនឹងការរៀបចំច្បាប់ វិទ្យាស្ថានជាតិស្ថិតិក៏បានសហការជាមួយក្រសួងមហាផ្ទៃ ផលិតចេញនូវរបាយការណ៍មួយ ស្តីពីស្ថិតិអត្រានុកូលដ្ឋានរបស់ខេត្តកែប ក្រោមការឧបត្ថម្ភរបស់អង្គការ Vital Strategy និងត្រៀមផលិតចេញនូវរបាយការណ៍ស្តីពី (១) អត្រាមរណភាពស្ត្រី និងកុមារ (២) អត្រាលទ្ធភាពបង្កើតកូន និង (៣) អំពើហិង្សាក្នុងគ្រួសារ ដោយផ្អែកលើលទ្ធផលអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាឆ្នាំ២០២១។

## ៤.៦- វិទ្យាស្ថានជាតិស្ថិតិ

យោងតាមច្បាប់ស្តីពីស្ថិតិ វិទ្យាស្ថានជាតិស្ថិតិ មានតួនាទីយ៉ាងសំខាន់ក្នុងការប្រមូល ចងក្រង វិភាគ និងផ្សព្វផ្សាយនូវទិន្នន័យ សូចនាករសំខាន់ៗសម្រាប់បម្រើជូនដល់បណ្តាអ្នកប្រើប្រាស់ ដូចជារាជរដ្ឋាភិបាល អង្គការជាតិ និងអង្គការអន្តរជាតិ ដៃគូអភិវឌ្ឍ សិស្ស និស្សិត អ្នកស្រាវជ្រាវ អ្នករៀបចំផែនការ គោលនយោបាយ ពិសេសគោលនយោបាយជាតិកាត់បន្ថយភាពក្រីក្រ គោលនយោបាយជាតិប្រជាជន និងគោលនយោបាយសំខាន់ៗតាម

វិស័យផ្សេងទៀត។ ទិន្នន័យស្ថិតិ គឺជារង្វាស់នៃការវាស់វែងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល ក៏ដូចជារង្វាស់នៃការអនុវត្តសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។ ដើម្បីទទួលបាននូវទិន្នន័យទាំងអស់នោះ វិទ្យាស្ថានជាតិស្ថិតិ ត្រូវដឹកនាំការធ្វើជំរឿន អង្កេត និងការប្រមូលទិន្នន័យរដ្ឋបាលតាមប្រព័ន្ធស្ថិតិ តាមបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធផងដែរ។

## ៤.៧- ការងារអង្កេតនិងជំរឿន

១- ដឹកនាំធ្វើជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩(លើកទី៣)

២- ជំរឿនសេដ្ឋកិច្ចកម្ពុជាលើកទី២ ឆ្នាំ២០២២

៣- ដឹកនាំធ្វើអង្កេតសេដ្ឋកិច្ច សង្គមកិច្ច(ប្រចាំឆ្នាំ)

៤- អង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ និងអង្កេតកសិកម្មប្រចាំឆ្នាំ

៥- អង្កេតប្រជាសាស្ត្រសុខភាពកម្ពុជាឆ្នាំ ២០២១(លើកទី៥)

៦- អង្កេតកម្លាំងពលកម្មឆ្នាំ២០១៩

៧- អង្កេតសហគ្រាសឧស្សាហកម្មឆ្នាំ២០១៩

៨- អង្កេតកម្រិតជីវភាពរស់នៅរបស់គ្រួសារឆ្នាំ២០២០។

## ៤.៨- ការប្រមូលទិន្នន័យក្រៅពីការធ្វើជំរឿននិងអង្កេត

១- ធ្វើការប្រមូលទិន្នន័យពីបណ្តាក្រសួងពាក់ព័ន្ធ និងស្ថិតិផ្លូវការដែលបានចាត់តាំង ដើម្បីយកមកចងក្រងជាសៀវភៅស្ថិតិប្រចាំឆ្នាំ Year Book សៀវភៅស្ថិតិយេនឌ័រ និងចងក្រងទិន្នន័យស្ថិតិពាណិជ្ជកម្មអន្តរជាតិឆ្នាំ២០១៩។

២- បានប្រមូលទិន្នន័យបរិស្ថាន ទិន្នន័យអំពីគ្រោះថ្នាក់មហន្តរាយ និងទិន្នន័យអំពីការប្រែប្រួលអាកាសធាតុ ដើម្បីរៀបចំរបាយការណ៍ជូនក្រុមសង្កេតការភពផែនដី UN-GEO។

៣- ប្រមូលទិន្នន័យសម្រាប់ធ្វើបច្ចុប្បន្នកម្មទិន្នន័យស្ថិតិតាមបណ្តារាជធានី ខេត្ត សម្រាប់គាំទ្របច្ចេកទេសរៀបចំប្លង់គោល និងផែនការប្រើប្រាស់ដីធ្លី។

៤- រាល់គ្រប់ជំរឿន អង្កេតទាំងអស់ វិទ្យាស្ថានជាតិស្ថិតិ សុទ្ធតែបានផលិតចេញជារបាយការណ៍លទ្ធផល និងរបាយការណ៍វិភាគស៊ីជម្រៅតាមប្រធានបទផ្សេងៗជាច្រើន រួមទាំងរបាយការណ៍វិភាគអំពីយេនឌ័រនៅកម្ពុជាផងដែរ។

៥- ជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០១៩ យើងបានផលិតចេញនូវរបាយការណ៍លទ្ធផល និងរបាយការណ៍វិភាគស៊ីជម្រៅតាមប្រធានបទចំនួន១៦ប្រធានបទដូចជា៖ (១)លទ្ធភាពបង្កកំណើត និងអាពាហ៍ពិពាហ៍ (២)មរណភាព និងមរណភាពមាតា (៣)កំណើនប្រជាជន និងរបាយប្រជាជន (៤) របាយប្រជាជននិងទីប្រជុំជន (៥)សមាសភាពភេទនិងអាយុ (៦)ពិការភាព (៧)ជនជាតិដើមភាគតិច (៨) ចំណាកស្រុក (៩)អក្ខរភាព និងការអប់រំ (១០)កម្លាំងពលកម្ម និងការងារ (១១)សម្ភារៈប្រើប្រាស់ក្នុងគ្រួសារ (១២)ទឹកស្អាត និងអនាម័យ (១៣)ចំណោលប្រជាជនកម្ពុជា (១៤)យេនឌ័រនៅកម្ពុជា (១៥)មនុស្សចាស់ និងស្ថានភាពរស់នៅ និង(១៦)ស្ថានភាពកុមារនៅកម្ពុជា។

### ៤.៩- ការងារចងក្រងទិន្នន័យសូចនាករគោលអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDG) ២០៣០

១-ដូចបានជម្រាបពីមុនមក វិទ្យាស្ថានជាតិស្ថិតិមានតួនាទីប្រមូលទិន្នន័យផ្តល់ជូនដល់អ្នកប្រើប្រាស់ក្នុងការរៀបចំផែនការ ការតាក់តែងគោលនយោបាយនានា និងសម្រាប់ការវាស់វែងសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពSDG ២០៣០ ដោយបានសហការជាមួយដៃគូអភិវឌ្ឍជាច្រើន ដើម្បីពិនិត្យមើលអំពីលទ្ធភាពអាចរកបានទិន្នន័យ និងប្រាកដថាមានទិន្នន័យគ្រប់គ្រាន់សម្រាប់គាំទ្រដល់ដំណើរការតាមដាននិងវាយតម្លៃអំពីវឌ្ឍនភាពនៃការសម្រេចបានក្របខ័ណ្ឌអភិវឌ្ឍន៍ទាំងនេះ ក្នុងនោះមានអង្គការ UNFPA, UNDP, WB, ESCAP, ADB, ILO, Sida, EU, USAID, Australia-DEFAT, FAO, WFP និង UNSD។ ក្នុងចំណោមអង្គការដៃគូអភិវឌ្ឍទាំងអស់ UNSD ជាដៃគូមួយយ៉ាងសំខាន់ក្នុងការជួយរៀបចំបង្កើតឱ្យមាននូវថ្នាលទិន្នន័យSDG (SDG Data Platform) នៅវិទ្យាស្ថានជាតិស្ថិតិឈ្មោះថា "CAMSTAT" មានតួនាទីដែលមិនត្រឹមតែសម្រាប់រក្សានិងផ្សព្វផ្សាយទិន្នន័យSDGប៉ុណ្ណោះទេ ប៉ុន្តែគឺសម្រាប់រាយការណ៍ទិន្នន័យសូចនាករអភិវឌ្ឍន៍គ្រប់ផ្នែកនិងគ្រប់វិស័យតាមរយៈ Platformនេះ។ បច្ចុប្បន្ន វិទ្យាស្ថានជាតិស្ថិតិក៏បាននិងកំពុងពិនិត្យលទ្ធភាពក្នុងការភ្ជាប់ថ្នាលទិន្នន័យCAMSTAT ជាមួយថ្នាលទិន្នន័យCAMDX របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផងដែរ។

២-ទន្ទឹមនឹងនេះយើងក៏បានធ្វើបច្ចុប្បន្នភាពទិន្នន័យតាមរយៈកម្មវិធី CAMSTAT នេះជាប្រចាំ ដែលរួមមានដូចជា NSDP, CSDG/SDG និងទិន្នន័យសូចនាករតាមវិស័យ ត្រូវបានផ្សព្វផ្សាយតាមអនឡាញភ្ជាប់នៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងបានរៀបចំពិធីសារស្ថិតិ គោលការណ៍ណែនាំសម្រាប់ការផ្លាស់ប្តូរទិន្នន័យរវាងវិទ្យាស្ថានជាតិស្ថិតិ ជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធនៃប្រព័ន្ធស្ថិតិជាតិផងដែរ។

៣-ដើម្បីជំរុញឱ្យវិទ្យាស្ថានជាតិស្ថិតិមានលទ្ធភាពក្នុងការប្រមូលទិន្នន័យ សូចនាករបានគ្រប់គ្រាន់ទាន់ពេលវេលាបម្រើឱ្យតាមតម្រូវការរបស់អ្នកប្រើប្រាស់ ក៏ដូចជាមានលទ្ធភាពក្នុងការតាមដានត្រួតពិនិត្យ និងវាស់វែងការអនុវត្តសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ អង្គការPARIS21, WB, NFPA និង Sida បានជួយរៀបចំយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍ស្ថិតិឆ្នាំ២០១៩-២០២៣ ហើយដែលវិទ្យាស្ថានជាតិស្ថិតិកំពុងអនុវត្តតាមយុទ្ធសាស្ត្រនេះ រយៈពេល៤ឆ្នាំមកហើយ។

៤-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានមើលឃើញពីសារៈសំខាន់ និងតម្រូវការទិន្នន័យស្ថិតិ និងបានផ្តល់ថវិកាដល់វិទ្យាស្ថានជាតិស្ថិតិ សម្រាប់ដំណើរការការងារស្ថិតិឱ្យមាននិរន្តរភាពក្រោយពីជំនួយឧបត្ថម្ភពីអង្គការដៃគូត្រូវបានកាត់ផ្តាច់នាឆ្នាំ២០១៥។

### ៤.១០- ការងារស្ថិតិគណនេយ្យជាតិ(ពាក់ព័ន្ធម៉ាក្រូសេដ្ឋកិច្ច)

១- គណនាកំណើនសេដ្ឋកិច្ច និងអតិផរណា ៥ឆ្នាំកន្លងមកនេះ នាយកដ្ឋានបានគណនាទំហំនិងកំណើនសេដ្ឋកិច្ច ដែលជាសូចនាករម៉ាក្រូសេដ្ឋកិច្ចដ៏សំខាន់ក្នុងការវាស់វែងចំណូលសម្រាប់មនុស្សម្នាក់ (GDP per capita) និងជាអនុបាតវាស់វែងប្រសិទ្ធភាពចំណូល ចំណាយ បំណុល និងសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រនានា ដូចជា Industry Development Programme IDP...។ល។

២- ឆ្នាំកន្លងមកនេះ នាយកដ្ឋានបានប្តូរឆ្នាំគោលគណនេយ្យជាតិពីឆ្នាំ២០០០ មកឆ្នាំ ២០១៤ ឱ្យស្របទៅនឹងបរិបទសេដ្ឋកិច្ចកម្ពុជា និងគ្រោងផ្សព្វផ្សាយប្រើប្រាស់ចាប់ពីឆ្នាំ២០២៣ តទៅ។ ការផ្លាស់ប្តូរឆ្នាំគោលនេះ

នឹងពង្រឹងសង្គតិភាពស្ថិតិម៉ាក្រូសេដ្ឋកិច្ចកម្ពុជាកាន់តែមានគុណភាពប្រសើរឡើង ជាធាតុចូលសម្រាប់រៀបចំគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល និងវិស័យផ្សេងទៀតកាន់តែប្រសើរឡើង ។

### ៤.១១- ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

-ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅតាមរាជធានី ខេត្ត ត្រូវបានអនុវត្តទាំងនីតិវិធីអត្តសញ្ញាណគ្រួសារក្រីក្រនៅទីប្រជុំជន និងទាំងនីតិវិធីអត្តសញ្ញាណគ្រួសារក្រីក្រនៅទីជនបទ ចាប់តាំងពីឆ្នាំ២០១៦មក។ ចាប់តាំងពីឆ្នាំ២០១៧ កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃអគ្គនាយកដ្ឋានផែនការ បានដំណើរការធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រួសារក្រីក្រតាមជុំចំនួន៥ជុំ។

**តារាងទិន្នន័យគ្រួសារក្រីក្រជុំទី១០**

| ល.រ. | ខេត្ត | គ្រួសារសរុប | ក្រ១ | | ក្រ២ | | សរុប ក្រ១ និងក្រ២ | |
|---|---|---|---|---|---|---|---|---|
| | | | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ |
| ១ | បាត់ដំបង | ២៧៤ ៥៤២ | ១៧ ៩៣៥ | ៦,៥៣% | ៣៩ ២៩៥ | ១៤,៣១% | ៥៧ ២៣០ | ២០,៨៥% |
| ២ | កំពង់ឆ្នាំង | ១៤៣ ៦០៧ | ១០ ០១៣ | ៦,៩៧% | ១៤ ៥៥៦ | ១០,១៤% | ២៤ ៥៦៩ | ១៧,១១% |
| ៣ | កណ្ដាល | ៣០៦ ៣៨៦ | ៨ ២៣៩ | ២,៦៩% | ១៨ ៦៨១ | ៦,១០% | ២៦ ៩២០ | ៨,៧៩% |
| ៤ | ប៉ៃលិន | ១៩ ១៦២ | ១ ៣៩៣ | ៧,២៧% | ២ ១២៥ | ១១,០៩% | ៣ ៥១៨ | ១៨,៣៦% |
| ៥ | ព្រះវិហារ | ៥៨ ៧០៤ | ៣ ១៦៦ | ៥,៣៩% | ៦ ៤៧១ | ១១,០២% | ៩ ៦៣៧ | ១៦,៤២% |
| ៦ | ពោធិ៍សាត់ | ១២៨ ៧៥៧ | ៩ ៣៤៧ | ៧,២៦% | ១២ ៦០១ | ៩,៧៩% | ២១ ៩៤៨ | ១៧,០៥% |
| ៧ | រតនគិរី | ៤៧ ៨៣៨ | ១ ៩៧២ | ៤,១២% | ៥ ១១៦ | ១០,៦៩% | ៧ ០៨៨ | ១៤,៨២% |
| ៨ | តាកែវ | ២៣០ ៩២៥ | ១០ ៥៩៧ | ៤,៥៩% | ១៩ ០១៣ | ៨,២៣% | ២៩ ៦១០ | ១២,៨២% |
| សរុបជុំទី១០ | | ១ ២០៩ ៩១៩ | ៦២ ៦៦២ | ៥,១៨% | ១១៧ ៨៥៨ | ៩,៧៤% | ១៨០ ៥២០ | ១៤,៩២% |

**តារាងទិន្នន័យគ្រួសារក្រីក្រជុំទី១១**

| ល.រ. | ខេត្ត | គ្រួសារសរុប | ក្រ១ | | ក្រ២ | | សរុប ក្រ១ និងក្រ២ | |
|---|---|---|---|---|---|---|---|---|
| | | | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ |
| ១ | កំពង់ស្ពឺ | ១៨៤ ៤៨២ | ៨ ៧៥៥ | ៤,៧៥% | ១២ ៤០៥ | ៦,៧២% | ២១ ១៦០ | ១១,៤៧% |
| ២ | កំពត | ១៥៥ ១០៦ | ៧ ៩៤៣ | ៥,១២% | ១០ ០៧៩ | ៦,៥០% | ១៨ ០២២ | ១១,៦២% |
| ៣ | កោះកុង | ២៩ ៨២៥ | ២ ៤៣៥ | ៨,១៦% | ៣ ៣៥៣ | ១១,២៤% | ៥ ៧៨៨ | ១៩,៤១% |
| ៤ | មណ្ឌលគិរី | ១៧ ៤៤៥ | ៨៤០ | ៤,៨២% | ២ ០៨០ | ១១,៩២% | ២ ៩២០ | ១៦,៧៤% |
| ៥ | ព្រៃវែង | ២៨៩ ១៦១ | ១៨ ៥៩៤ | ៦,៤៣% | ២៨ ៤៩៥ | ៩,៨៥% | ៤៧ ០៨៩ | ១៦,២៨% |
| ៦ | ព្រះសីហនុ | ៣០ ៩៨៥ | ១ ០៤៧ | ៣,៣៨% | ២ ១៨២ | ៧,០៤% | ៣ ២២៩ | ១០,៤២% |
| ៧ | ស្វាយរៀង | ១៤៥ ៩៨៧ | ៥ ៨៦៦ | ៤,០២ | ១១ ៨៥៦ | ៨,១២% | ១៧ ៧២២ | ១២,១៤% |
| ៨ | កែប | ៤ ៥០៥ | ៣១២ | ៦,៩៣% | ៥៧៦ | ១២,៧៩% | ៨៨៨ | ១៩,៧១% |
| សរុបជុំទី១១ | | ៨៥៧ ៤៩៦ | ៤៥ ៧៩២ | ៥,៤៥% | ៧១ ០២៦ | ៩,២៧% | ១១៦ ៨១៨ | ១៤,៧២% |

## តារាងទិន្នន័យគ្រួសារក្រីក្រជុំទី១២

| ល.រ. | ខេត្ត | គ្រួសារសរុប | ក្រ១ | | ក្រ២ | | សរុប ក្រ១ និងក្រ២ | |
|---|---|---|---|---|---|---|---|---|
| | | | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ |
| ១ | បន្ទាយមានជ័យ | ១៥៥ ៧៤៣ | ៦ ៧០២ | ៤,៣% | ១៣ ២២២ | ៨,៥% | ១៩ ៩២៤ | ១២,៨% |
| ២ | កំពង់ចាម | ២៥៣ ៦៨១ | ១៣ ៨៧៩ | ៥,៥% | ២១ ៩៩២ | ៨,៧% | ៣៥ ៨៧១ | ១៤,១% |
| ៣ | កំពង់ធំ | ១៦២ ២៣៦ | ១១ ១៥៥ | ៦,៩% | ១៩ ៤៧៦ | ១២% | ៣០ ៦៣១ | ១៨,៩% |
| ៤ | ក្រចេះ | ៧៨ ៦៦៩ | ៧ ៣៤៨ | ៩,៣% | ៩ ៩៣៤ | ១២,៦% | ១៧ ២៨២ | ២២% |
| ៥ | ភ្នំពេញ(៨ខណ្ឌ) | ១៨៤ ៦៩២ | ៥ ៤២៣ | ២,៩% | ១០ ៧០១ | ៥,៨% | ១៦ ១២៤ | ៨,៧% |
| ៦ | សៀមរាប | ១៨៦ ៤៥៥ | ៩ ៣៤២ | ៥% | ១៧ ០៩៤ | ៩,២% | ២៦ ៤៣៦ | ១៤,២% |
| ៧ | ស្ទឹងត្រែង | ២៧ ៧៩១ | ១ ៩៣៣ | ៧% | ៣ ៩០១ | ១៤% | ៥ ៨៣៤ | ២១% |
| ៨ | ឧត្តរមានជ័យ | ៥៨ ២៤២ | ៣ ០៧៥ | ៥,៣% | ៥ ០១២ | ៨,៦% | ៨ ០៨៧ | ១៣,៩% |
| ៩ | ត្បូងឃ្មុំ | ១៧៩ ០៥៤ | ១០ ១៤៦ | ៥,៧% | ១៩ ៥៦៦ | ១០.៩% | ២៩ ៧១២ | ១៦,៦% |
| សរុបជុំទី១២ | | ១ ២៨៦ ៥៦៣ | ៦៩ ០០៣ | ៥,៨% | ១២០ ៨៩៨ | ១០% | ១៨៩ ៩០១ | ១៥,៨% |

## តារាងទិន្នន័យគ្រួសារក្រីក្រជុំទី១៣

| ល.រ. | ខេត្ត | គ្រួសារសរុប | ក្រ១ | | ក្រ២ | | សរុប ក្រ១ និងក្រ២ | |
|---|---|---|---|---|---|---|---|---|
| | | | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ |
| ១ | បាត់ដំបង | ២៧៤ ៥៤២ | ១៧ ៩៣៥ | ៦,៥៣% | ៣៩ ២៩៥ | ១៤,៣១% | ៥៧ ២៣០ | ២០,៨៥% |
| ២ | កំពង់ឆ្នាំង | ១៤៣ ៦០៧ | ១០ ០១៣ | ៦,៩៧% | ១៤ ៥៥៦ | ១០,១៤% | ២៤ ៥៦៩ | ១៧,១១% |
| ៣ | កណ្ដាល | ៣០៦ ៣៨៦ | ៨ ២៣៩ | ២,៦៩% | ១៨ ៦៨១ | ៦,១០% | ២៦ ៩២០ | ៨,៧៩% |
| ៤ | ប៉ៃលិន | ១៩ ១៦២ | ១ ៣៩៣ | ៧,២៧% | ២ ១២៥ | ១១,០៩% | ៣ ៥១៨ | ១៨,៣៦% |
| ៥ | ព្រះវិហារ | ៥៨ ៧០៤ | ៣ ១៦៦ | ៥,៣៩% | ៦ ៤៧១ | ១១,០២% | ៩ ៦៣៧ | ១៦,៤២% |
| ៦ | ពោធិ៍សាត់ | ១២៨ ៧៥៧ | ៩ ៣៤៧ | ៧,២៦% | ១២ ៦០១ | ៩,៧៩% | ២១ ៩៤៨ | ១៧,០៥% |
| ៧ | រតនគិរី | ៤៧ ៨៣៦ | ១ ៩៧២ | ៤,១២% | ៥ ១១៦ | ១០,៦៩% | ៧ ០៨៨ | ១៤,៨២% |
| ៨ | តាកែវ | ២៣០ ៩២៥ | ១០ ៥៩៧ | ៤,៥៩% | ១៩ ០១៣ | ៨,២៣% | ២៩ ៦១០ | ១២,៨២% |
| សរុបជុំទី១៣ | | ១ ២០៩ ៩១៩ | ៦២ ៦៦២ | ៥,១៨% | ១១៧ ៨៥៨ | ៩,៧៤% | ១៨០ ៥២០ | ១៤,៩២% |

## តារាងទិន្នន័យគ្រួសារក្រីក្រជុំទី១៤

| ល.រ. | ខេត្ត | គ្រួសារសរុប | ក្រ១ | | ក្រ២ | | សរុប ក្រ១ និងក្រ២ | |
|---|---|---|---|---|---|---|---|---|
| | | | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ | ចំនួនគ្រួសារ | ភាគរយ |
| ១ | កំពង់ស្ពឺ | ១៨៤ ៤៨២ | ៨ ៧៥៥ | ៤,៧៥% | ១២ ៤០៥ | ៦,៧២% | ២១ ១៦០ | ១១,៤៧% |
| ២ | កំពត | ១៥៥ ១០៦ | ៧ ៩៤៣ | ៥,១២% | ១០ ០៧៩ | ៦,៥០% | ១៨ ០២២ | ១១,៦២% |
| ៣ | កោះកុង | ២៩ ៨២៥ | ២ ៤៣៥ | ៨,១៦% | ៣ ៣៥៣ | ១១,២៤% | ៥ ៧៨៨ | ១៩,៤១% |
| ៤ | មណ្ឌលគិរី | ១៧ ៤៤៥ | ៨៤០ | ៤,៨២% | ២ ០៨០ | ១១,៩២% | ២ ៩២០ | ១៦,៧៤% |
| ៥ | ព្រៃវែង | ២៨៩ ១៦១ | ១៨ ៥៩៤ | ៦,៤៣% | ២៨ ៤៩៥ | ៩,៨៥% | ៤៧ ០៨៩ | ១៦,២៨% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៦ | ព្រះសីហនុ | ៣០ ៩៨៥ | ១ ០៤៧ | ៣,៣៨% | ២ ១៨២ | ៧,០៤% | ៣ ២២៩ | ១០,៤២% |
| ៧ | ស្វាយរៀង | ១៤៥ ៩៨៧ | ៥ ៨៦៦ | ៤,០២% | ១១ ៨៥៦ | ៨,១២% | ១៧ ៧២២ | ១២,១៤% |
| ៨ | កែប | ៤ ៥០៥ | ៣១២ | ៦,៩៣% | ៥៧៦ | ១២,៧៩% | ៨៨៨ | ១៩,៧១% |
| **សរុបជុំទី១៤** | | **៨៥៧ ៤៩៦** | **៤៥ ៧៩២** | **៥,៤៥%** | **៧១ ០២៦** | **៩,២៧%** | **១១៦ ៨១៨** | **១៤,៧២%** |

- ដើម្បីគាំទ្រដល់កិច្ចអន្តរាគមន៍ជាបន្ទាន់ដល់ប្រជាពលរដ្ឋទាំងអស់ដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ជាពិសេសគ្រួសារក្រីក្រនិងគ្រួសារទទួលរងផលប៉ះពាល់ខ្លាំងជាងគេតាមរយៈកម្មវិធីឧបត្ថម្ភសាច់ប្រាក់ អគ្គនាយកដ្ឋានផែនការបានដំណើរការការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំ និងបានផ្តល់ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមជុំ(ជុំទី១២ ទី១៣ និងទី១៤) និងទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើសុំក្នុងកំឡុងពេលកូវីដ-១៩ ចំនួន១៣លើក ដល់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានគ្រួសារក្រីក្រសរុប ចំនួន៦៦៥ ២៩២គ្រួសារ និងទិន្នន័យនៃការដកគ្រួសារក្រីក្រចេញពីបញ្ជីគ្រួសារក្រីក្រ ចំនួន២៧ ៣៧១គ្រួសារ ជូនដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីប្រើប្រាស់ក្នុងកម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រនិងងាយរងគ្រោះ។

**តារាងទិន្នន័យគ្រួសារក្រីក្រតាមជុំ និងតាមការស្នើសុំ ក្នុងកំឡុងពេលកូវីដ-១៩**

| ល.រ. | បរិយាយ | ក្រកម្រិត ១ | | ក្រកម្រិត ២ | | សរុប | |
|---|---|---|---|---|---|---|---|
| | | គ្រួសារ | សមាជិក | គ្រួសារ | សមាជិក | គ្រួសារ | សមាជិក |
| ១ | តាមជុំ ជុំទី១២,១៣,១៤ | ១៥៦ ៩៣៨ | ៥៩៣ ២៨១ | ២៩៦ ៥៩៣ | ១២៣០៣៩៤ | ៤៥៣ ៥៣១ | ១៨២៣៦៤៤ |
| ២ | តាមការស្នើសុំលើកទី១ | ២២ ៩៣៤ | ៨២ ៤១១ | ៣០ ២៥២ | ១១៩ ៥១៣ | ៥៣ ១៨៦ | ២០១ ៩២៤ |
| ៣ | តាមការស្នើសុំលើកទី២ | ២១ ៨២៨ | ៨០ ៨៧៣ | ២៩ ០៥០ | ១១៦ ៨៤៣ | ៥០ ៨៧៨ | ១៩៧ ៧១៦ |
| ៤ | តាមការស្នើសុំលើកទី៣ | ២២ ៣២០ | ៧៦ ៩២០ | ៣៣ ៦៩៦ | ១៣១ ១៣៤ | ៥៦ ០១៦ | ២០៨ ០៥៤ |
| ៥ | តាមការស្នើសុំលើកទី៤ | ៨ ៦៥៧ | ៣០ ៤១៥ | ១១ ៧៣៦ | ៤៥ ៦៨១ | ២០ ៣៩៣ | ៧៦ ០៩៦ |
| ៦ | តាមការស្នើសុំលើកទី៥ | ៣ ២២៥ | ១១ ៣៨៣ | ៤ ៣៧៩ | ១៧ ១២១ | ៧ ៦០៤ | ២៨ ៥០៤ |
| ៧ | តាមការស្នើសុំលើកទី៦ | ២ ៥៨១ | ៩ ៥៧០ | ៣ ៩៧៧ | ១៦ ១៨៤ | ៦ ៥៥៨ | ២៥ ៧៥៤ |
| ៨ | តាមការស្នើសុំលើកទី៧ | ១ ៥២០ | ៥ ៤៣១ | ២ ៥០៩ | ១០ ១១៣ | ៤ ០២៩ | ១៥ ៥៤៤ |
| ៩ | តាមការស្នើសុំលើកទី៨ | ១ ១១៨ | ៣ ៩១៥ | ១ ៦៣៨ | ៦ ៥១២ | ២ ៧៥៦ | ១០ ៤២៧ |
| ១០ | តាមការស្នើសុំលើកទី៩ | ១ ២៨៥ | ៤ ៦២៦ | ២ ២៨៦ | ៩ ០២១ | ៣ ៥៧១ | ១៣ ៦៤៧ |
| ១១ | តាមការស្នើសុំលើកទី១០ | ៦៣៩ | ២ ២១៥ | ១ ០៤៥ | ៣ ៩៥៣ | ១ ៦៨៤ | ៦ ១៩៩ |
| ១២ | តាមការស្នើសុំលើកទី១១ | ៧៩៨ | ២ ៨៩៦ | ៨៣៨ | ៣ ២៤១ | ១ ៦៣៦ | ៦ ១៣៧ |
| ១៣ | តាមការស្នើសុំលើកទី១២ | ៣៦៦ | ១ ៣៥៦ | ៥៥៩ | ២ ២៣៩ | ៩២៥ | ៣ ៥៩៥ |
| ១៤ | តាមការស្នើសុំលើកទី១៣ | ១ ០៣៤ | ៣ ៣៧៩ | ១ ៤៩១ | ៥ ៣១៣ | ២ ៥២៥ | ៨ ៦៩២ |
| **សរុបរួម** | | **២៤៥២៤៣** | **៩០៨ ៦៧១** | **៤២០ ០៤៩** | **១៧១៧២៦២** | **៦៦៥ ២៩២** | **២៦២៥៩៣៣** |

## ៤.១២- ទិន្នន័យគ្រួសារក្រីក្រតាមការស្នើសុំក្នុងអំឡុងពេលជំងឺកូវីដ-១៩

**តារាងទិន្នន័យគ្រួសារក្រីក្រតាមការស្នើសុំក្នុងកំលុងពេលជំងឺកូវីដ-១៩**

| ល.រ. | ឈ្មោះរាជធានី/ខេត្ត | ចំនួនកំណើននៃការស្នើសុំ | ចំនួនគ្រួសារសម្ភាសន៍ | ចំនួនគ្រួសារក្រីក្រ | | | ភាគរយការសម្ភាសន៍ | ភាគរយគ្រួសារក្រីក្រ |
|---|---|---|---|---|---|---|---|---|
| | | | | ក្រកម្រិត១ | ក្រកម្រិត២ | សរុប | | |
| ១ | បន្ទាយមានជ័យ | ២ ៥៤៩ | ២ ៣៦១ | ៩០១ | ១ ២១៤ | ២ ១១៥ | ៩២,៦២ | ៨២,៩៧ |

| ល.រ. | ឈ្មោះរាជធានី/ខេត្ត | ចំនួនកំណើននៃការស្នើសុំ | ចំនួនគ្រួសារសម្ភាសន៍ | ចំនួនគ្រួសារក្រីក្រ | | | ភាគរយការសម្ភាសន៍ | ភាគរយគ្រួសារក្រីក្រ |
|---|---|---|---|---|---|---|---|---|
| | | | | ក្រកម្រិត១ | ក្រកម្រិត២ | សរុប | | |
| ២ | បាត់ដំបង | ៦ ៤៥៨ | ៦ ៣១៩ | ១ ៨១៧ | ៤ ២៩៦ | ៦ ១១៣ | ៩៧,៨៥ | ៩៤,៦៦ |
| ៣ | កំពង់ចាម | ៤ ៣៨៧ | ៤ ១៧០ | ១ ៥៩០ | ២ ២១៣ | ៣ ៨០៣ | ៩៥,០៥ | ៨៦,៦៩ |
| ៤ | កំពង់ឆ្នាំង | ១ ៥៧៤ | ១ ០១៩ | ៤២៧ | ៥១០ | ៩៣៧ | ៦៤,៧៤ | ៥៩,៥៣ |
| ៥ | កំពង់ស្ពឺ | ៣ ៦៣១ | ៣ ៥០៥ | ១ ៧៣៦ | ១ ៥៨០ | ៣ ៣១៦ | ៩៦,៥៣ | ៩១,៣២ |
| ៦ | កំពង់ធំ | ៣ ៩៦៩ | ៣ ៩០៣ | ១ ៧៩០ | ១ ៨៩៥ | ៣ ៦៨៥ | ៩៨,៣៤ | ៩២,៨៤ |
| ៧ | កំពត | ៣ ០៨៩ | ២ ៩២០ | ១ ៤៩១ | ១ ២៩៥ | ២ ៧៨៦ | ៩៤,៥៣ | ៩០,១៩ |
| ៨ | កណ្តាល | ៥ ៣៦០ | ៥ ១០៦ | ១ ៨៣០ | ២ ៨៣៦ | ៤ ៦៦៦ | ៩៥,២៦ | ៨៧,០៥ |
| ៩ | កោះកុង | ១ ៦៨០ | ១ ៦៥២ | ៨៧៤ | ៧៤៩ | ១ ៦២៣ | ៩៨,៣៣ | ៩៦,៦១ |
| ១០ | ក្រចេះ | ៣ ៧៤៥ | ៣ ៦៥៦ | ១ ៧១៦ | ១ ៨០៨ | ៣ ៥២៤ | ៩៧,៦២ | ៩៤,១០ |
| ១១ | មណ្ឌលគិរី | ៨៨៥ | ៨៧៣ | ២៤២ | ៥៨៧ | ៨២៩ | ៩៨,៦៤ | ៩៣,៦៧ |
| ១២ | រាជធានីភ្នំពេញ | ៥ ៥៧១ | ៥ ៣៧៩ | ២ ០០១ | ២ ៩៥៤ | ៤ ៩៥៥ | ៩៦,៥៥ | ៨៨,៩៤ |
| ១៣ | ព្រះវិហារ | ១ ៥៥៥ | ១ ៣៣៨ | ៤៩៨ | ៦៩៩ | ១ ១៩៧ | ៨៦,០៥ | ៧៦,៩៨ |
| ១៤ | ព្រៃវែង | ៦ ០៧៥ | ៥ ៨០៨ | ៣ ០០៩ | ២ ៤៥៣ | ៥ ៤៦២ | ៩៥,៦០ | ៨៩,៩១ |
| ១៥ | ពោធិ៍សាត់ | ១ ៥០១ | ១ ៤៥៥ | ៦៥៧ | ៦៩៤ | ១ ៣៥១ | ៩៦,៩៤ | ៩០,០១ |
| ១៦ | រតនគិរី | ១ ៤៦៩ | ១ ៥១៨ | ៣៤២ | ៩៣៨ | ១ ២៨០ | ៩៦,៥៣ | ៨៧,១៣ |
| ១៧ | សៀមរាប | ៨២៥ | ៧៩៧ | ៣០៣ | ៤៥០ | ៧៥៣ | ៩៦,៦១ | ៩១,២៧ |
| ១៨ | ព្រះសីហនុ | ១ ៤៩២ | ១ ៤០៥ | ៦៦៥ | ៦៧១ | ១ ៣៣៦ | ៩៤,១៧ | ៨៩,៥៤ |
| ១៩ | ស្ទឹងត្រែង | ៨២៥ | ៧៩៧ | ៣០៣ | ៤៥០ | ៧៥៣ | ៩៦,៦១ | ៩១,២៧ |
| ២០ | ស្វាយរៀង | ២ ៩៨៣ | ២ ៨១១ | ១ ២៤៣ | ១ ៣២៨ | ២ ៥៧១ | ៩៤,២៣ | ៨៦,១៩ |
| ២១ | តាកែវ | ៣ ៤៤៩ | ៣ ៣៩២ | ១ ៤៤៩ | ១ ៧៤៧ | ៣ ១៩៦ | ៩៨,៣៥ | ៩២,៣៦ |
| ២២ | ឧត្តរមានជ័យ | ១ ៩៦០ | ១ ៨១៦ | ៤៨២ | ១ ០៤២ | ១ ៥២៤ | ៩២,៦៥ | ៧៧,៧៦ |
| ២៣ | កែប | ១៨៣ | ១៨០ | ៥៥ | ១០៦ | ១៦១ | ៩៨,៣៦ | ៨៧,៩៨ |
| ២៤ | ប៉ៃលិន | ៥០៣ | ៤៣០ | ១៧៦ | ២២៦ | ៤០២ | ៨៥,៤៩ | ៧៩,៩២ |
| ២៥ | ត្បូងឃ្មុំ | ៤ ៧២៦ | ៤ ៦៧៨ | ១ ៦៩៦ | ២ ៧៦១ | ៤ ៤៥៧ | ៩៨,៩៨ | ៩៤,៣១ |
| **សរុប** | | **៧៦ ៧៧៤** | **៧៣ ០៨៩** | **២៩ ៣១៣** | **៣៨ ៨៣៥** | **៦៨ ១៤៨** | **៩៥,២០** | **៨៨,៧៨** |

## ៤.១៣- សូចនាករសេដ្ឋកិច្ច សង្គមកិច្ចសំខាន់ៗ

### ៤.១៣.១- ប្រជាសាស្ត្រ

ក- ចំនួនប្រជាជនពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០៥០(គិតជាលាននាក់)



## ខ- ពីរ៉ាមីតប្រជាជនសម្រាប់កម្ពុជា

### ឆ្នាំ១៩៩៦




ប្រភព: វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ ១៩៩៦

### ឆ្នាំ ១៩៩៨




ប្រភព: វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ ១៩៩៦

### ឆ្នាំ២០០៤




ប្រភព: វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ ២០០៥

### ឆ្នាំ២០០៨




ប្រភព: វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ ២០០៩




ប្រភព: វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ២០១៣




ប្រភព: វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការឆ្នាំ២០២០




*ប្រភព: CDHS 2014*

## គ- អត្រាលទ្ធភាពបង្កើតកូនសរុប




សម្គាល់ ÷ - ឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩ ទិន្នន័យជំរឿនប្រជាជន

- ឆ្នាំ ២០០០, ២០០៥,២០១០,២០១៤ និង ២០២១/២០២២ ទិន្នន័យអង្កេតប្រជាសាស្ត្រ និងសុខភាព
- ឆ្នាំ ២០២៥ ឡើង ទិន្នន័យព្យាករណ៍។

## ឃ- អាយុសង្ឃឹមរស់គិតជាមធ្យម




សម្គាល់៖ ឆ្នាំ១៩៩៨, ២០០៨ និង ២០១៩ ទិន្នន័យជំរឿនប្រជាជន ក្រៅពីឆ្នាំ ទាំង៣នេះ ជាទិន្នន័យព្យាករណ៍។

### ង- អត្រាមរណភាពរបស់កុមារ និងទារក




សម្គាល់៖ *អត្រាស្លាប់ក្នុងចំណោម ១.០០០ កំណើតរស់៥ ឆ្នាំ មុនអង្កេត*

ប្រភព៖ អង្កេតប្រជាសាស្ត្រ និងសុខភាព

### ច- អត្រាមរណភាពរបស់មាតា




*សំគាល់៖ អត្រាស្លាប់របស់មាតាក្នុងចំណោម ១០០.០០០ កំណើតរស់*

ប្រភព៖ អង្កេតប្រជាសាស្ត្រ និងសុខភាពសម្រាប់ឆ្នាំ២០០០, ២០០៥, ២០១០, ២០១៤ និង២០២១-២០២២

លើកលែងតែឆ្នាំ២០០៨ និង២០១៩ ប្រភពទិន្នន័យជំរឿនប្រជាជន។

## ៤.១៣.២- ស្ថានភាពការងារ

### ក- អត្រាអ្នកមានការងារធ្វើ




### ខ- អត្រាអ្នកមានការងារធ្វើតាមវិស័យសេដ្ឋកិច្ច




ប្រភព៖ -ទិន្នន័យជំរឿនប្រជាជនឆ្នាំ ១៩៩៨, ២០០៨ និង ២០១៩

-ទិន្នន័យអង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ ២០០៤ និង ២០១៣

### គ. អ្នកមានការងារ និងអ្នកគ្មានការងារធ្វើអាយុ១៥ឆ្នាំឡើង



## ឃ- វិស័យការងារតាមប្រព័ន្ធ និងក្រៅប្រព័ន្ធ (អ្នកមានការងារធ្វើអាយុ១៥ឆ្នាំឡើង)




ប្រភព៖ អង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ ២០១៩

### ៤.១៣.៣- ចំណូលចំណាយ

#### ក- ចំណូលនិងចំណាយគិតជាមធ្យមប្រចាំខែក្នុងមួយគ្រួសារ




ប្រភព៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា

#### ខ- ភាគរយនៃប្រភពចំណូលប្រចាំខែរបស់គ្រួសារ




ប្រភព៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០២០

### គ- ភាគរយនៃប្រភេទចំណាយរបស់គ្រួសារ




ប្រភព៖ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជាឆ្នាំ២០១៩/២០២០

## ៤.១៣.៤- គណនេយ្យជាតិ

### ក- ផលិតផលក្នុងស្រុកសរុប( គិតតាមថ្លៃបច្ចុប្បន្ន )






## ខ- ផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាជនម្នាក់



## ត្រាកំណើនតាមសកម្មភាពសេដ្ឋកិច្ច គិតតាមថ្លៃថេរឆ្នាំ ២០០០(ភាគរយ)

| ឆ្នាំ | កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | ឧស្សាហកម្ម | សេវាកម្ម | ផលិតផលក្នុងស្រុកសរុប |
|---|---|---|---|---|
| ១៩៩៨ | ៤,៤ | ៦,២ | ៥ | ៤,៧ |
| ១៩៩៩ | ៣,៧ | ២១,២ | ១៤,៦ | ១២,៧ |
| ២០០០ | ៤,៤ | ៣១,២ | ៨,៩ | ១០,៧ |
| ២០០១ | ១,៧ | ១១,២ | ១១,១ | ៧,៤ |
| ២០០២ | -២,៥ | ១៧,១ | ៧,៧ | ៦,៦ |
| ២០០៣ | ១០,៥ | ១២ | ៥,៩ | ៨,៥ |
| ២០០៤ | -០,៩ | ១៦,៦ | ១៣,២ | ១០,៣ |
| ២០០៥ | ១៥,៧ | ១២,៧ | ១៣,១ | ១៣,៣ |
| ២០០៦ | ៥,៥ | ១៨,៣ | ១០,១ | ១០,៨ |
| ២០០៧ | ៥ | ៨,៤ | ១០,១ | ១០,២ |
| ២០០៨ | ៥,៧ | ៤ | ៩ | ៦,៧ |
| ២០០៩ | ៥,៥ | -៩,៥ | ២,៣ | ០,១ |
| ២០១០ | ៤ | ១៣,៦ | ៣,៣ | ៦ |
| ២០១១ | ៣,១ | ១៤,៥ | ៥ | ៧,១ |
| ២០១២ | ៤,៣ | ៩,៣ | ៨,១ | ៧,៣ |
| ២០១៣ | ១,៦ | ១០,៧ | ៨,៧ | ៧,៤ |
| ២០១៤ | ០,៣ | ១០,១ | ៨,៧ | ៧,១ |
| ២០១៥ | ០,២ | ១១,៥ | ៧,១ | ៧ |
| ២០១៦ | ១,៣ | ១០,៦ | ៦,៨ | ៦,៩ |
| ២០១៧ | ១,៧ | ៩,៧ | ៧ | ៧ |
| ២០១៨ | ១,១ | ១១,៦ | ៦,៨ | ៧,៥ |
| ២០១៩ | -០,៥ | ១១,៣ | ៦,២ | ៧,១ |
| ២០២០ | ០,៨ | -២,៨ | -៥,៤ | -៣,១ |
| ២០២១ | ១,១ | ៨,១ | -១,៩ | ៣ |





អត្រាកំណើនសេដ្ឋកិច្ច
ភាគរយ
14.0
12.0
10.0
8.0
6.0
4.0
2.0
0.0
-2.0
-4.0
4.7
10.7
13.3
6.0
7.0
6.9
7.0
7.5
7.1
-3.1
3.0
1998
2000
2005
2010
2015
2016
2017
2018
2019
2020
2021


## ឃ- អត្រាអតិផរណា



ភាគរយ
20
15
10
5
0
-5
2000
2001
2002
2003
2004
2005
2006
2007
2008
2009
2010
2011
2012
2013
2014
2015
2016
2017
2018
2019
2020
2021

## ៤.១៣.៥- អត្រាប្តូរប្រាក់

### ក- អត្រាប្តូរប្រាក់តាមខែនៃឆ្នាំនីមួយៗ




ប្រភព៖ គេហទំព័រផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ( https://www.nbc.org.kh/ )

### ខ- អត្រាប្តូរប្រាក់គិតជាមធ្យមប្រចាំឆ្នាំ




សម្គាល់៖ អត្រាប្តូរប្រាក់គិតជាមធ្យមឆ្នាំ ២០២២គិតត្រឹមខែមិថុនា។

## ៤.១៣.៦- ស្ថានភាពនៃភាពក្រីក្រ

### ក- កម្រិតនៃភាពក្រីក្រនៅកម្ពុជា




### ខ- អត្តសញ្ញាណគ្រួសារក្រីក្រ




ប្រភព៖ នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ក្រសួងផែនការ)

## គ- ចំនួនសមាជិកគ្រួសារក្រីក្រ




ប្រភព៖ នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ក្រសួងផែនការ)

## ៤.១៣.៧- ស្ថានភាពកូវីដ-១៩

### ក. ស្ថានភាពកូវីដ-១៩ នៅលើពិភពលោក

**ស្ថានភាពជំងឺកូវីដ-១៩ ទូទាំងពិភពលោក**




ប្រភព៖ទិន្នន័យអង្គការសុខភាពពិភពលោក (គិតត្រឹមថ្ងៃទី១២ខែ មិថុនាឆ្នាំ ២០២២)

## ខ- ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា




ប្រភព៖ក្រសួងសុខាភិបាល គិតត្រឹមថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២

### កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ
### និងងាយរងគ្រោះក្នុងកំលុងពេលប្រយុទ្ធនឹងកូវីដ-១៩ ចាប់តាំងពីឆ្នាំ២០២០
### ចំនួនគ្រួសារក្រីក្រ និងសមាជិកដែលទទួលសាច់ប្រាក់ពីរាជរដ្ឋាភិបាលកម្ពុជា

ចំនួនជនងាយរងគ្រោះក្នុងកំលុងពេលកូវីដ-១៩ ដែលទទួលសាច់ប្រាក់ពីរាជរដ្ឋាភិបាលកម្ពុជា






ប្រភព៖ នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ក្រសួងផែនការ)

## ការឧបត្ថម្ភដល់គ្រួសារគោលដៅដែលបានមានការលំបាកផ្នែកជីវភាពក្នុងតំបន់បិទខ្ទប់នៅរាជធានីភ្នំពេញ ក្រុងតាខ្មៅ ខេត្តកណ្តាល និងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ




ប្រភព៖ នាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ក្រសួងផែនការ)









**ពិធីបិទសន្និបាតអប់រំ យុវជន និងកីឡា**

**កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២**








ពិធីសំណេះសំណាលជាមួយសិស្សនិទ្ទេស A ក្នុងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០២១ កាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២








ពិធីអបអរសាទរ ព្រឹត្តិការណ៍ដំណើរទេសចរណ៍ពានបាល់ទាត់ ពិភពលោក FIFA World Cup ឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២








**ពិធីសំណេះសំណាលជាមួយគ្រូពេទ្យសម្តេចតេជោ ប្រឆាំងកូវីដ-១៩**
**កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២២**








**ពិធីបិទវគ្គបណ្តុះបណ្តាលឆ្នាំ២០២០ ២០២១ និងបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០២២ របស់សាលាភូមិន្ទរដ្ឋបាល កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២**










កិច្ចប្រជុំក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ានប៉ារ៉ា និងក្រុមប្រឹក្សាសហព័ន្ធអាស៊ីអាគ្នេយ៍
កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២







ពិធីប្រគល់សញ្ញាបត្របណ្ឌិតកិត្តិយស ផ្នែកអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
ជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
កាលពីថ្ងៃទី៥ ខែសីហា ឆ្នាំ២០២២








**អបអរសាទរពិធីទទួលទង់សហព័ន្ធកីឡាជនពិការអាស៊ាន និងជ័យលាភី**
**កីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១១ នៅទីក្រុងសូឡូ ឥណ្ឌូណេស៊ី**
**កាលពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០២២**







ពិធីបើកការប្រកួតកីឡាជាតិ លើកទី៣ និងកីឡាជនពិការ លើកទី១
នៅពហុកីឡដ្ឋានជាតិមរតកតេជោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២២







មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ



មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនត្បូងឃ្មុំ

**វេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍ នៅកម្ពុជា អញ្ជើញចុះសួរសុខទុក្ខកម្មករ កម្មការិនី និងបន្តក់ថ្នាំដល់កុមារ**









ពិធីប្រគល់ ទទួលវ៉ាក់សាំងកូវីដ-១៩ ពីបណ្ដាប្រទេសនានា
ជូនដល់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៩-២០២២

# យុទ្ធសាស្ត្រចតុកោណទី២
# ការធ្វើពិពិធកម្មសេដ្ឋកិច្ច

ការធ្វើពិពិធកម្មសេដ្ឋកិច្ច គឺជាដំណើរការចាំបាច់នៃការបង្កើតជន្ទល់ឱ្យបានច្រើនសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច សំដៅពង្រឹងការនាំចេញ ឬបង្កើតតម្លៃបន្ថែមពីសកម្មភាពសេដ្ឋកិច្ចដែលមានស្រាប់ ដើម្បីអាចរក្សាកំណើនសេដ្ឋកិច្ចនៅក្នុងកម្រិតខ្ពស់ ក្នុងរយៈពេលមធ្យមនិងវែងនាពេលខាងមុខ។

## មុំទី១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល

### ១- ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន

#### ១.១- ការងារដឹកជញ្ជូនផ្លូវគោក

សមិទ្ធផលសំខាន់ៗស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន មកទល់នឹងដំណាច់ឆ្នាំ២០២២នេះ មានដូចខាងក្រោម៖ ( ផេក : Ministry of Public Works and Transport - MPWT គេហទំព័រ www.mpwt.gov.kh )

##### ១.១.១- ការងារសាធារណការ

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| ផ្លូវជាតិ និងផ្លូវខេត្ត (ឯកតា៖ គិតជា គ.ម) | | | | | |
| ផ្លូវជាតិកម្រិត១(៩ខ្សែ) | ២ ២៥៤ | ២ ២៥៤ | ២ ២៥៤ | ២ ២៥៤ | ២ ២៥៤ |
| ផ្លូវជាតិកម្រិត២(៧១ខ្សែ) | ៥ ០០៧ | ៥០០៧ | ៥ ០០៧ | ៥ ១៧៨ | ៥ ១៧៨ |
| ផ្លូវខេត្ត(៦៦៧ខ្សែ) | ៩ ០៣១ | ៩ ៣០៨ | ១០ ៨៦៤ | ១១ ៣៧១ | ១១ ៣៧១ |
| សរុបផ្លូវជាតិនិងផ្លូវខេត្ត | ១៦ ២៩២ | ១៦ ៥៧០ | ១៨ ១២៥ | ១៨ ៨០៣ | ១៨ ៨០៣ |
| ផ្លូវជាតិដែលបានស្តារដោយក្រាលកៅស៊ូ និងបេតុង ផ្លូវកម្រិត១និងកម្រិត២ | ៥ ៨៧៥ | ៥ ៩២៩ | ៥ ៩៧៨ | ៦ ០១៨ | ៦ ០១៨ |
| ផ្លូវដែលបានស្តារដោយក្រាលកៅស៊ូនិងបេតុងផ្លូវកម្រិត១កម្រិត២និងផ្លូវខេត្ត | ៨ ៦២០ | ៩ ២១០ | ៩ ៨៩៦ | ១០ ២៨២ | ១០ ២៨២ |
| ផ្លូវល្បឿនលឿន(ភ្នំពេញ-ក្រុងព្រះសីហនុ) | - | - | - | ១៨៧,០៥ | ១៨៧,០៥ |

| ស្ពានធំៗឆ្លងកាត់ទន្លេនិងសមុទ្រដែលបានស្ថាបនារួចនិងដាក់ឱ្យប្រើប្រាស់ (ឯកតា៖គិតជា ម.) | | | | | | | | |
|---|---|---|---|---|---|---|---|---|
| មុនឆ្នាំ២០១៣ | | | | | | | | |
| ល.រ | ឈ្មោះស្ពាន | ឆ្នាំ | ប្រវែង | ប្រភេទ | ផ្លូវជាតិ | ទីតាំង | ឆ្លងកាត់ | ផ្សេងៗ |
| ១ | ស្ពានព្រះមុនីវង្សចាស់ | ១៩៦០ | ២៦៩ | បេតុង | ១ | ភ្នំពេញ | ទន្លេបាសាក់ | ជាតិ |
| ២ | ស្ពានជ្រោយចង្វារទី១ | ១៩៦៦ | ៧០០ | បេតុង | ៦ | ភ្នំពេញ | ទន្លេសាប | ជប៉ុន |
| ៣ | ស្ពានគីហ្សូណា | ២០០០ | ១ ៣៦០ | បេតុង | ៧ | កំពង់ចាម | ទន្លេមេគង្គ | ជប៉ុន |
| ៤ | ស្ពានកោះកុង | ២០០២ | ១៩០០ | បេតុង | ៤៨ | កោះកុង | ដៃសមុទ្រ | ជាតិ |
| ៥ | ស្ពានសេកុង | ២០០៨ | ១០៥៧ | បេតុង | ៧ | ស្ទឹងត្រែង | ទន្លេមេគង្គ | ចិន |
| ៦ | ស្ពានព្រះមុនីវង្សថ្មី | ២០០៩ | ២៦៩ | បេតុង | ១ | ភ្នំពេញ | ទន្លេបាសាក់ | ជាតិ |
| ៧ | ស្ពានព្រែកព្នៅ | ២០១០ | ៩៩៦ | បេតុង | ៥ | ភ្នំពេញ | ទន្លេសាប | ជាតិ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៨ | ស្ពានព្រែកក្ដាម | ២០១០ | ៩៨១ | បេតុង | ៥ | កណ្ដាល | ទន្លេសាប | ចិន |
| ៩ | ស្ពានព្រែកតាមាក់ | ២០១១ | ១០៦៦ | បេតុង | ៨ | កណ្ដាល | ទន្លេមេគង្គ | ចិន |
| ១០ | ស្ពានកោះពស់ | ២០១១ | ៩០០ | បេតុង | | ព្រះសីហនុ | សមុទ្រ | ឯកជន |
| ក្រោយឆ្នាំ២០១៣ | | | | | | | | |
| ១១ | ស្ពានតាខ្មៅ | ២០១៥ | ៨៥៥ | បេតុង | ២១A | កណ្ដាល | ទន្លេបាសាក់ | ចិន |
| ១២ | ស្ពានមេគង្គ | ២០១៥ | ១៧៣១ | បេតុង | ៩ | ស្ទឹងត្រែង | ទន្លេមេគង្គ | ចិន |
| ១៣ | ស្ពានអ្នកលឿង | ២០១៥ | ២ ២១៥ | ខ្សែកាប | ១ | កណ្ដាល-ព្រៃវែង | ទន្លេមេគង្គ | ជប៉ុន |
| ១៤ | ស្ពានជ្រោយចង្វារទី២ | ២០១៥ | ៧១៩ | បេតុង | ៦ | ភ្នំពេញ | ទន្លេសាប | ចិន |
| ១៥ | ស្ពានកោះធំ | ២០១៦ | ៤១៥ | បេតុង | ២១ | កណ្ដាល | ទន្លេបាសាក់ | ចិន |
| ១៦ | ស្ពានជ្រៃធំ | ២០១៧ | ២១៦ | បេតុង | ២១ | កណ្ដាល | ទន្លេបាសាក់ | វៀតណាម |
| ក្រោយឆ្នាំ២០១៧ | | | | | | | | |
| ១៧ | ស្ពានកោះប៉ែន | ២០១៨ | ៧៧៩ | បេតុង | ៧ថ្មី | កំពង់ចាម | ទន្លេមេគង្គ | ជាតិ |
| ១៨ | ស្ពានស្ទឹងបត់ | ២០១៩ | ៦០៥ | បេតុង | ៥ | បន្ទាយមានជ័យ | ស្ទឹងបត់ | កម្ពុជា-ថៃ |
| ១៩ | ស្ពានស្ទឹងត្រង់-ក្រូចឆ្មារ | ២០២១ | ១១៣១ | បេតុង | ៧១សេ | កំពង់ចាម-ត្បូងឃ្មុំ | ទន្លេមេគង្គ | ចិន |

### ១.១.២- ការងារដឹកជញ្ជូនផ្លូវគោក សុវត្ថិភាពចរាចរណ៍ និងដឹកជញ្ជូនសាធារណៈ

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| ការងារចុះបញ្ជីយានយន្ត (ឯកតា៖ គិតជា គ្រឿង) | | | | | |
| រថយន្តធុនធ្ងន់ | ៩ ៧៧២ | ១៦ ២៧៥ | ១៥ ៣៤២ | ១៣ ០០៧ | ១២ ៦៦៦ |
| រថយន្តធុនស្រាល | ៦៧ ៤២៣ | ៨៩ ១៧៧ | ៧០ ៦៣១ | ៦០ ៩៦៤ | ៥៧ ៦៤៧ |
| រថយន្តអគ្គិសនី EV | - | - | - | ២៦២ | ២៦២ |
| ត្រីចក្រយានយន្តអគ្គិសនី | - | - | - | ២៨៤ | ២៨៤ |
| ទោចក្រយានយន្តអគ្គិសនី | - | - | - | ១១ | ១១ |
| ម៉ូតូ | ៥០២ ៧០១ | ៥៤០ ៦២១ | ៣៧០ ៦០១ | ៤៣២ ២៥៥ | ៣៧៥ ៤៦២ |
| **សរុប** | **៥៧៩ ៨៩៦** | **៦៤៦ ០៧៣** | **៤៥៦ ៥៧៤** | **៥០៦ ៧៨៣** | **៤៤៦ ៣៣២** |
| បើគិតចាប់ពីឆ្នាំ១៩៩០ដល់ ខែកញ្ញា ឆ្នាំ២០២២ យានយន្តបានចុះបញ្ជីសរុបចំនួន ៦ ៨០២ ៤២៨គ្រឿង (ម៉ូតូចំនួន ៥ ៧៨២ ២០៣គ្រឿង រថយន្តធុនស្រាលចំនួន ៧៣៣ ៧៤៤គ្រឿង និងរថយន្តធុនធ្ងន់ចំនួន ២៨៦ ៤៨១គ្រឿង) | | | | | |
| ការប្រឡងយកបណ្ណបើកបរ (ឯកតា៖ គិតជាគ្រឿង) | | | | | |
| រថយន្តគ្រប់ប្រភេទ | ១២៣ ៣៩១ | ១៥៤ ៩៦៨ | ២១០ ០៦៨ | ១០៦ ២០៩ | ៨១ ២៤៣ |
| ម៉ូតូ | ៤៩៥ | ១៤ ២៦១ | ៤២ ០១៥ | ៨៤ ១១៧ | ១០២ ២៧៧ |
| **សរុប** | **១២៣ ៨៨៦** | **១៦៩ ២២៩** | **២៥២ ០៨៣** | **១៩០ ៣២៦** | **១៨៣ ៥២០** |
| បើគិតចាប់ពីឆ្នាំ១៩៩០ដល់ខែកញ្ញា ឆ្នាំ២០២២ ការប្រឡងយកបណ្ណបើកបរសរុបមានចំនួន ២ ១៤៧ ២៤៨គ្រឿង (ក្នុងនោះរួមមាន៖ ម៉ូតូចំនួន ៤០៦ ៤១៥គ្រឿង និងរថយន្តគ្រប់ប្រភេទចំនួន ១ ៧៤០ ៨៣៣គ្រឿង) | | | | | |
| ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ (ផ្លូវគោក) | | | | | |

| | | | | | |
|---|---|---|---|---|---|
| ចំនួនគ្រោះថ្នាក់(លើក) | ៣ ៣៥២ | ៤ ១១៩ | ៣ ១៧៨ | ២ ៦៧០ | ២ ២៨៦ |
| ស្លាប់ (នាក់) | ១ ៨៧១ | ១ ៩៨២ | ១ ៦៤៥ | ១ ៤៩៧ | ១ ៣៤២ |
| របួសសរុប (នាក់) | ៩ ៦៤១ | ៦ ១៣១ | ៤ ៦៨៨ | ៣ ៦១៥ | ៣ ១៧៣ |
| អត្រាស្លាប់ក្នុងយានយន្ត ១០០០០គ្រឿង | ៤,៤៩ | ៤,១៧ | ២,៨១ | ២,៣៦ | ១,៩៧ |
| អត្រាស្លាប់ក្នុងប្រជាជន ១០០ ០០០នាក់ | ១១,៦៩ | ១២,២៣ | ៩,៩៧ | ៨,៩៦ | ៧,៨៩ |
| **សាលាបង្រៀនបើកបរយានយន្តទូទាំងប្រទេស** | | | | | |
| ចំនួនសាលា (កន្លែង) | ៧ | ១១ | ៣៣ | ៥០ | ៥២ |
| សាខាសាលាបង្រៀនបើកបរ (កន្លែង) | - | - | ១៨៤ | ១៨៦ | ១៨៦ |
| **ស្ថិតិមណ្ឌលត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត និងឡៀកចល័ត តាមឆ្នាំនីមួយៗ** | | | | | |
| មណ្ឌលសរុប (កន្លែង) | ១២ | ១៣ | ១៥ | ១៩ | ២១ |
| ឡៀកចល័ត (គ្រឿង) | ២ | ៣ | ៤ | ៤ | ៤ |

-ដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធស្វ័យប្រវត្តិកម្មដឹកជញ្ជូនផ្លូវគោក (ចុះបញ្ជីយានយន្តប្រឡងយកប័ណ្ណបើកបរយានយន្ត និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ)

-ដាក់ឱ្យប្រើប្រាស់ ចុះបញ្ជីយានយន្តផ្លាកលេខសញ្ញាពិសេស និង ផ្លាកលេខផ្ទាល់ខ្លួន

-រៀបចំប្រព័ន្ធQR Code ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃឯកសារសេវាដឹកជញ្ជូនផ្លូវគោក

-ធ្វើទំនើបកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋអាចជ្រើសរើសលេខនិងដាក់ពាក្យចុះបញ្ជីយានយន្តនិងត្រួតពិនិត្យលក្ខណៈបច្ចេកទេសតាមប្រព័ន្ធអនឡាញ (Online)

-ធ្វើសមាហរណកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីផ្តល់ប័ណ្ណសម្គាល់និងផ្លាកលេខយានយន្តជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់អគ្គនាយកដ្ឋានពន្ធដារនិងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

-ដាក់ឱ្យដំណើរការស្ថានីយបញ្ចូលថាមពលយានយន្តដើរដោយថាមពលអគ្គិសនី (Electric Vehicles) ចំនួន ៥ទីតាំងដែលក្នុងនោះ ១ទីតាំងស្ថិតនៅទីស្តីការក្រសួង និង៤ទីតាំងទៀតស្ថិតនៅតាមបណ្តារាជធានី-ខេត្ត ក្រោមកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP)។

## ១.២- ការងារដឹកជញ្ជូនផ្លូវទឹក ផ្លូវសមុទ្រនិងកំពង់ផែ

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| **☼ការងារអាជីវកម្ម និងហិរញ្ញវត្ថុនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ** | | | | | |
| ទំនិញឆ្លងកាត់ផែ(ពាន់តោន) | ៥ ៣២៨ | ៦ ៥៤៧ | ៦ ៦០២ | ៦ ៩៩០ | ៥ ៤០៧ |
| នាវាឆ្លងកាត់(គ្រឿង) | ១ ៤៥១ | ១ ៦៦២ | ១ ៥៨២ | ១ ៤៤៨ | ១ ១០២ |
| កុងតឺន័រឆ្លងកាត់(TEU) | ៥៤១ ២២៨ | ៦៣៩ ២១១ | ៦៤១ ៨៤២ | ៧៣២ ៣៨៧ | ៥៩១ ០៤៤ |
| ចំណូលអាជីវកម្ម(ពាន់ដុល្លារ) | ៧២ ៧៦១ | ៨៨ ៤៣២ | ៨១ ៩៩៩ | ៩០ ៥០៥ | ៧០ ២៦៣ |
| **☼ការងារអាជីវកម្ម និងហិរញ្ញវត្ថុនៅកំពង់ផែស្វយ័តភ្នំពេញ** | | | | | |
| ទំនិញឆ្លងកាត់ផែ(ពាន់តោន) | ៣ ១៣៥ | ៣ ៧៨៩ | ៣ ៧៨០ | ៣ ៨៥១ | ៣ ០៨១ |
| នាវាឆ្លងកាត់(គ្រឿង) | ២ ៣៩៩ | ២ ៨០៦ | ២ ៤៨៩ | ២ ៣០២ | ២ ៧៦៣ |
| កុងតឺន័រឆ្លងកាត់(TEU) | ២១៣ ៥៧១ | ២៨១ ០៤៥ | ២៩០ ៨៥៧ | ៣៤៨ ៨៩៨ | ៣២៩ ០៤៣ |
| ចំណូលអាជីវកម្ម(ពាន់ដុល្លារ) | ២០ ៧២២ | ២៧ ១៩០ | ២៧ ០៤៨ | ៣០ ៧៨៣ | ២៨ ៤៥៧ |

| | | | | | |
|---|---|---|---|---|---|
| **ការងារសេវាកម្មដឹកជញ្ជូនផ្លូវទឹក** | | | | | |
| ផ្តល់បណ្ណសម្គាល់ដលយាន្តគ្រប់ប្រភេទ(គ្រឿង) | ២៩ | ១៨ | ៦៤ | ១១៤ | ៣៩ |
| ផ្ទេរម្ចាស់កម្មសិទ្ធិ(ច្បាប់) | ៧ | ៩ | ១៤ | ៣៧ | ២៤ |
| ប្តូរបណ្ណនិងទុតិយតា(ច្បាប់) | ១៦ | ៧ | ៦ | ៧ | ៤ |
| ផ្តល់បណ្ណបើកបរថ្មី(បណ្ណ) | ១៧ | ២៦ | ៦៣ | ២ | ៧ |
| ផ្តល់បណ្ណបើកបរបន្ត(បណ្ណ) | ៩ | ២៥ | ២៥ | ២ | ៤ |
| ត្រួតពិនិត្យលក្ខណៈបច្ចេកទេសប្រភេទទេសចរណ៍មានបន្ទប់ (គ្រឿង) | ១១ | ៩ | ៣ | ១ | ៩ |
| ត្រួតពិនិត្យលក្ខណៈក្នុងស្រុក (គ្រឿង) | ១៨២ | ១៩៨ | ២១៤ | ៣១១ | ១៥០ |
| ត្រួតពិនិត្យលក្ខណៈបច្ចេកទេសដចម្លង(គ្រឿង) | ១៥ | ១៦ | ២៥ | ២៣ | ១៤ |
| ផ្តល់លិខិតអាជីវកម្មដឹកជញ្ជូនទេសចរណ៍/ស្នាក់នៅ(ច្បាប់) | ២៤ | ២៤ | ៣ | ០ | ១៩ |
| ផ្តល់លិខិតអនុញ្ញាតនាវាដឹកជញ្ជូនឆ្លងដែន(ច្បាប់) | ១៣ | ១២ | ៣ | ៣ | ២៥ |
| ផ្តល់លិខិតអនុញ្ញាតនាវាដឹកជញ្ជូនទំនិញ(ច្បាប់) | ១៤៤ | ១៦៤ | ១៧០ | ២៦៩ | ១០៩ |
| ផ្តល់លិខិតអាជីវកម្មសាឡាងដឹកទំនិញ(ច្បាប់) | ៦ | ៤ | ១៣ | ១៧ | ១៦ |
| ផ្តល់លិខិតអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ(ច្បាប់) | ៣៨ | ៣០ | ១៥ | ៤ | ៥ |
| ផ្តល់លិខិតអាជីវកម្មដឹកជញ្ជូនដចម្លង(ច្បាប់) | ១៧ | ១៧ | ២៥ | ២២ | ១៥ |
| ផ្តល់លិខិតអនុញ្ញាតនាវាដឹកជញ្ជូននាវាសណ្តោង(ច្បាប់) | ៩ | ៥ | ១៤ | ១៣ | ១៦ |
| លិខិតបង្កើតការដ្ឋានសាងសង់ ឬជួសជុលជលយាន(ច្បាប់) | ០ | ០ | ០ | ០ | ១ |
| លិខិតអនុញ្ញាតធ្វើអាជីវកម្មការដ្ឋានសាងសង់ជួសជុលជលយាន(ច្បាប់) | ០ | ០ | ០ | ០ | ១ |
| ចំណូលសេវាកម្ម(ពាន់រៀល) | ១៥១ ៤៥៣ | ១៧៥ ៦៤៣, ៥០០ | ១៨៣ ៨៥២,៥០០ | ២៨៩ ៧០៧,៥០០ | ១៤៩ ៧៦២,៥០០ |
| **ការងារសេវាកម្មដឹកជញ្ជូនផ្លូវសមុទ្រ** | | | | | |
| ផ្តល់វិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក-យន្តការី(ថ្មី)(បណ្ណ) | ០ | ៣២ | ១៧ | ៣៦ | ៤០ |
| បន្តសុពលភាពវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក(បណ្ណ) | ៨ | ១១ | ៧ | ៣ | ០ |

| | | | | | |
|---|---|---|---|---|---|
| ការផ្តល់វិញ្ញាបនបត្របង្ហិលេខ សម្រាប់នាវិកលើនាវាឆ្លងកាត់ព្រំដែន(បណ្ណ) | ០ | ០ | ៣ | ០ | ០ |
| ផ្តល់សៀវភៅវិជ្ជាជីវៈនាវិក(ក្បាល) | ៤៩ | ១១ | ១ | ១៩ | ១៣ |
| ពន្យារពេលប្រើប្រាស់សៀវភៅវិជ្ជាជីវៈនាវិក(ក្បាល) | ២១ | ១៩ | ២ | ០ | ៣ |
| ទុតិយតាវិញ្ញាបនបត្រសមត្ថភាពជំនាញនាវិក(បណ្ណ) | ០ | ០ | ២ | ០ | ០ |
| ផ្តល់សៀវភៅត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា(បណ្ណ) | ០ | ០ | ៤៣ | ១៧ | ១៣ |
| ផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មនាវា(ថ្មី)(បណ្ណ) | ៦ | ២២ | ១៣ | ១ | ១៧ |
| ការផ្តល់បណ្ណសម្គាល់នាវា (លើកដំបូង ផ្ទេរកម្មសិទ្ធិ កែច្នៃ លក្ខណៈសម្គាល់នាវា)(បណ្ណ) | ០ | ២៧ | ១៧ | ៨ | ១៣ |
| ច្បាប់អនុញ្ញាតស្ថាបនានាវា(បណ្ណ) | ០ | ២ | ៥ | ០ | ០ |
| បន្តសុពលភាពលិខិតអនុញ្ញាតប្រតិបត្តិការ(បណ្ណ) | ១ | ០ | ១ | ១ | ១ |
| លិខិតអនុញ្ញាតឱ្យនាវាបរទេសចូល-ចេញកំពង់ផែ(ទទួលផ្ទាល់ និងអនឡាញ) (គ្រឿង) | ០ | ០ | ២ ៥៣០ | ៣ ៨៧៤ | ៣ ០១៨ |
| ចំណូលសេវាកម្ម(ពាន់រៀល) | ៤២ ៧៤៩ | ៣៩ ៥៤៩ | ១ ០៤៥ ៣២៤ | ១ ៥៧៣ ០២១ | ១ ២៥៤ ៤៤៨ |

## ១.៣- ការងារផ្លូវដែក

-ផ្លូវដែកមេកម្ពុជាមានចំនួនពីរខ្សែ ទិសខាងជើងមានប្រវែង ៣៨៦គ.ម (ភ្នំពេញ-ប៉ោយប៉ែត) និងខាងត្បូងប្រវែង ២៦៦គ.ម (ភ្នំពេញ-ក្រុងព្រះសីហនុ)

| **បរិយាយ** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** |
|---|---|---|---|---|---|
| **ការងារផ្លូវដែក** | | | | | |
| ផ្លូវដែកភាគខាងជើង(ភ្នំពេញ-ប៉ោយប៉ែត) | ៣៨៦ | ៣៨៦ | ៣៨៦ | ៣៨៦ | ៣៨៦ |
| ផ្លូវដែកភាគខាងត្បូង(ភ្នំពេញ-ក្រុងព្រះសីហនុ) | ២៦៦ | ២៦៦ | ២៦៦ | ២៦៦ | ២៦៦ |
| **សរុប (គ.ម)** | **៦៥២** | **៦៥២** | **៦៥២** | **៦៥២** | **៦៥២** |
| **ការដឹកជញ្ជូនតាមខ្សែផ្លូវដែក** | | | | | |
| ការដឹកទំនិញគ្រប់ប្រភេទ (តោន) | ៥២៨ ៦០៨ | ៩៤៣ ៤៣១ | ១ ១១០ ២៦៨ | ១ ០១៦ ៤៦៦ | ៦៤៤ ៣៥២ |
| ការដឹកអ្នកដំណើរ (នាក់) | ១០៩ ០៥៩ | ៦២ ៤៨៥ | ២៤ ៩៩៤ | ៣ ៦១៤ | ៣៦ ៩៣៨ |

-ចំនួនស្ថានីយ និងជំហាប់សរុបមានចំនួន ៨២កន្លែង (ក្នុងនោះរួមមាន៖ ផ្លូវដែកភាគខាងជើងមានចំនួន ៥៣កន្លែង និងផ្លូវដែកភាគខាងត្បូងមានចំនួន ២៩កន្លែង)

-ទិញក្បាលរថភ្លើងចំនួន ១០គ្រឿង

-បញ្ចប់ការសិក្សាផ្លូវរថភ្លើងក្រោមដីក្នុងរាជធានីភ្នំពេញដោយក្រុមហ៊ុន CRBC

-បន្តសហការជាមួយស្ថាប័នជំនាញពាក់ព័ន្ធ ដើម្បីចុះបញ្ជីដីស្ថានីយចំនួន ៩០កន្លែង នៃផ្លូវដែកទាំងពីរទិស ក្នុងនោះធ្វើប្លង់រឹងបាន ១៤កន្លែង ស្មើនឹង ១៦% ។

**១.៤- ការងាររដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល** (www.civilaviation.gov.kh)

វិស័យអាកាសចរស៊ីវិល គឺជាឧស្សាហកម្មមួយប្រភេទដែលកំពុងតែមានការរីកលូតលាស់ទាំងក្នុងតំបន់ និងក្នុងពិភពលោកទាំងមូល ដោយសារតែវិស័យនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយសម្រួលដល់ការធ្វើដំណើរនិងដឹកជញ្ជូនទំនិញតាមផ្លូវអាកាសក្នុងរយៈពេលដ៏ខ្លី និងជាមធ្យោបាយក្នុងការជំរុញសកម្មភាពធុរកិច្ចពាណិជ្ជកម្ម ទេសចរណ៍ ការលើកកម្ពស់ទំនាក់ទំនងសង្គម ការចូលរួមចំណែកបង្កើនចំណូលជូនជាតិសម្រាប់អភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ តាមរយៈ **«គោលនយោបាយបើកចំហជើងមេឃ»** របស់រាជរដ្ឋាភិបាលកម្ពុជាបានធ្វើឱ្យវិស័យអាកាសចរស៊ីវិលមានការរីកចម្រើនគួរជាទីមោទនៈ ដោយសម្រេចបាននូវស្នាដៃសមិទ្ធផលធំៗជាច្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធនាំផ្លូវហោះហើរ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិសៀមរាប ការពង្រីកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ការកសាងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរថ្មី អាកាសយានដ្ឋានអន្តរជាតិតារាសាគរ គម្រោងសាងសង់អាកាសយានដ្ឋានខេត្តមណ្ឌលគិរី បានពង្រីកស្ថានីយអ្នកដំណើរ ព្រមទាំងការពង្រឹងក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិបច្ចេកទេស ដើម្បីរក្សាបាននូវការពង្រឹងសន្តិសុខ សុវត្ថិភាព លើវិស័យអាកាសចរស៊ីវិល ដែលមុនវិបត្តិកូវីដ-១៩ យើងរក្សាបាននូវកំណើនអ្នកដំណើរតាមផ្លូវអាកាសប្រមាណ ១៨% ចាប់តាំងពីឆ្នាំ២០០៨ មក និងមានចំនួនអ្នកដំណើរតាមផ្លូវអាកាសប្រមាណជាង ១១ លាននាក់ក្នុងឆ្នាំ២០១៩ ដោយហេតុថាប្រទេសយើងជាមជ្ឈមណ្ឌលទេសចរណ៍ដែលមានភាពទាក់ទាញខ្លាំងទាំងក្នុងតំបន់និងពិភពលោក។ ដោយស្ថានភាពនៃវិបត្តិកូវីដ-១៩ ចរាចរណ៍អ្នកដំណើរតាមផ្លូវអាកាសពិភពលោកក៏ដូចជានៅប្រទេសកម្ពុជាយើងផងដែរ គឺសឹងតែជួបរលំជាមួយការធ្លាក់ចុះចំនួនអ្នកដំណើរដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រ។

ក្រោមការដឹកនាំដ៏ប្រកបដោយគតិបណ្ឌិតឈ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រួមជាមួយកម្លាំងមហាសាមគ្គីជាតិខ្មែរពីគ្រប់មជ្ឈដ្ឋានដែលបង្កើតបាននូវលទ្ធភាព សមត្ថភាព និងលទ្ធផលដ៏ល្អត្រចះត្រចង់ពាក់ព័ន្ធដល់ជោគវាសនាស្លាប់រស់របស់ជាតិ និងប្រជាជននាំឱ្យយើងទទួលបាននូវកត្តាជោគជ័យលើការគ្រប់គ្រងហានិភ័យដែលបង្កឡើងដោយជំងឺកូវីដ-១៩ នៅកម្ពុជាបានយ៉ាងល្អប្រសើរប្រកបដោយប្រសិទ្ធភាព។

ចំណុចជាអាទិភាពដែលត្រូវបានស្តារឡើងវិញនោះ គឺការជំរុញឱ្យមានការបើកជើងហោះហើរជាប្រក្រតីឡើងវិញបន្តិចម្តងៗ និងការពង្រឹងការអនុវត្តបទដ្ឋានសុវត្ថិភាព ការការពារជំងឺកូវីដ-១៩ និងជំងឺឆ្លងផ្សេងៗទៀតសម្រាប់ការធានាបាននូវការបើកឱ្យមានដំណើរការឡើងវិញក្នុងប្រទេសចំពោះក្រុមហ៊ុនអាកាសចរណ៍ទាំងអស់។ យើងអាចនិយាយបានថា គឺជាការត្រៀមខ្លួនឱ្យបានរួចរាល់ជាមុនក្នុងការបើកជើងហោះហើរជាប្រក្រតីឡើងវិញ **"នេះជាចំណុចអាទិភាពមុនគេបង្អស់"** ស្របគ្នានឹងការប្រកាសរបស់សមាគមដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ

(IATA) បានឱ្យដឹងថា បន្ទាប់ពីវិបត្តិកូវីដ-១៩ ការធ្វើដំណើរតាមផ្លូវអាកាសបានបន្តងើបឡើងវិញយ៉ាងខ្លាំង នៅក្នុងខែមេសា ឆ្នាំ២០២២ កន្លងទៅនេះ ទោះបីជាមានសង្គ្រាមនៅអ៊ុយក្រែន និងការរឹតបន្តឹងការធ្វើដំណើរក្នុងប្រទេសចិនក៏ដោយ។

ដើម្បីចូលរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានបន្តអនុវត្ត ការពង្រឹងការលើកកម្ពស់ផ្នែកសុវត្ថិភាព សន្តិសុខអាកាសចរណ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានជាតិនិងអន្តរជាតិ ការពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ ការជំរុញឱ្យមានការហោះហើរត្រង់មកកាន់ព្រះរាជាណាចក្រកម្ពុជា ការជំរុញឱ្យមានកំណើនអ្នកធ្វើដំណើរតាមផ្លូវអាកាស និងការចូលរួមបង្កើនសកម្មភាពពាណិជ្ជកម្ម ទេសចរណ៍ ការបង្កើនចំណូលថវិកាជាតិ ការលើកកម្ពស់ទំនាក់ទំនងសង្គមព្រមទាំងផ្តល់នូវអត្ថប្រយោជន៍ផ្សេងៗជាច្រើនទៀត។

**ក្នុងរយៈពេល៥ឆ្នាំ ២០១៨-២០២២រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលសម្រេចការងារបានដូចខាងក្រោម៖**

## ក- ការដឹកជញ្ជូនតាមផ្លូវអាកាស

### ១- ការដឹកជញ្ជូនតាមផ្លូវអាកាសរបស់ក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុកនិងអន្តរជាតិ

#### ១.១- ស្ថិតិក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុកនិងអន្តរជាតិ(ឆ្នាំ២០១៨-២០២២)

| ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | |
|---|---|---|---|---|---|---|---|---|---|
| ក្រុមហ៊ុនក្នុងស្រុក | ក្រុមហ៊ុនក្រៅស្រុក | ក្រុមហ៊ុនក្នុងស្រុក | ក្រុមហ៊ុនក្រៅស្រុក | ក្រុមហ៊ុនក្នុងស្រុក | ក្រុមហ៊ុនក្រៅស្រុក | ក្រុមហ៊ុនក្នុងស្រុក | ក្រុមហ៊ុនក្រៅស្រុក | ក្រុមហ៊ុនក្នុងស្រុក | ក្រុមហ៊ុនក្រៅស្រុក |
| ៧ | ៣៤ | ៦ | ៣៩ | ៦ | ៣១ | ៦ | ១៧ | ៥ | ២១ |
| ៤៥ ក្រុមហ៊ុន | | ៤៥ ក្រុមហ៊ុន | | ៣៧ ក្រុមហ៊ុន | | ២៣ ក្រុមហ៊ុន | | ២៦ ក្រុមហ៊ុន | |
| កើន (១០%) | | កើន (០%) | | ថយចុះ (-១៨%) | | ថយចុះ (-៣៨%) | | កើន (១៣%) | |

#### ១.២- ទិន្នន័យស្ថិតិដឹកជញ្ជូនអ្នកដំណើរតាមផ្លូវអាកាស (ឆ្នាំ២០១៨-២០២២)

| ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ (៩ខែ, ១-៩) | |
|---|---|---|---|---|---|---|---|---|---|
| ក្នុងស្រុក (នាក់) | ក្រៅស្រុក (នាក់) | ក្នុងស្រុក (នាក់) | ក្រៅស្រុក (នាក់) | ក្នុងស្រុក (នាក់) | ក្រៅស្រុក (នាក់) | ក្នុងស្រុក (នាក់) | ក្រៅស្រុក (នាក់) | ក្នុងស្រុក (នាក់) | ក្រៅស្រុក (នាក់) |
| ៦៣៦៧២៥ | ៩,៣៧៦,៣៩៣ | ៦៩៩,៤៥៣ | ១០,៣២៥,៥៣៧ | ២៥៧,៤៣៣ | ១,៩១៣,១៧៦ | ១២,៦២៣ | ២៥៦,៩៣៥ | ៤៦.៣៩០ | ១,៣៦១,៥៨២ |
| ១០ ០១៣ ១១៨ | | ១១ ០២៤ ៩៩០ | | ២ ១៧០ ៦០៩ | | ២៦៩ ៥៥៨ | | ១ ៤០៧ ៩៧២ | |
| កើន (២២%) | | កើន (១០%) | | ថយចុះ (-៨០%) | | ថយចុះ (-៨៨%) | | កើន (១៣៤%) | |

#### ១.៣- ទិន្នន័យស្ថិតិដឹកជញ្ជូនទំនិញតាមផ្លូវអាកាស(ឆ្នាំ២០១៨-២០២២)

| ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ (៩ខែ, ១-៩) | |
|---|---|---|---|---|---|---|---|---|---|
| ក្នុងស្រុក (តោន) | ក្រៅស្រុក (តោន) | ក្នុងស្រុក (តោន) | ក្រៅស្រុក (តោន) | ក្នុងស្រុក (តោន) | ក្រៅស្រុក (តោន) | ក្នុងស្រុក (តោន) | ក្រៅស្រុក (តោន) | ក្នុងស្រុក (តោន) | ក្រៅស្រុក (តោន) |
| ៣៨៥ | ៧៣ ២០៧ | ២៣៩ | ៦៨ ៤៣៧ | ៧៥ | ៥៥ ២៦៨ | ០ | ៧០ ៨២២ | ០ | ៨៤ ១៨៩ |
| ៧៣ ៥៩២ | | ៦៨ ៦៧៨ | | ៥៥ ៣៤៣ | | ៧០ ៨២២ | | ៨៤ ១៨៩ | |
| កើន (១៥%) | | ថយចុះ (-៧%) | | ថយចុះ (-១៩%) | | កើន (២៨%) | | កើន (៦៥%) | |

#### ១.៤- ទិន្នន័យជើងហោះហើរ(ឆ្នាំ២០១៨-២០២២)

| ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ (៩ខែ, ១-៩) | |
|---|---|---|---|---|---|---|---|---|---|
| ក្នុងស្រុក (ជើង) | ក្រៅស្រុក (ជើង) | ក្នុងស្រុក (ជើង) | ក្រៅស្រុក (ជើង) | ក្នុងស្រុក (ជើង) | ក្រៅស្រុក (ជើង) | ក្នុងស្រុក (ជើង) | ក្រៅស្រុក (ជើង) | ក្នុងស្រុក (ជើង) | ក្រៅស្រុក (ជើង) |
| ១៦ ៨៧៨ | ៨២ ៣១៩ | ១៣ ៩០៤ | ៩០ ៩២៩ | ៥ ៧២៨ | ២៣ ៥២០ | ៩៧២ | ១០ ០១៦ | ១ ៧១៩ | ១៦ ៦៣៩ |

| | | | | |
|---|---|---|---|---|
| ៩៩ ១៩៧ | ១០៤ ៨៣៣ | ២៩ ២៤៨ | ១០ ៩៨៨ | ១៨ ៣៥៨ |
| កើន (១៧%) | កើន (៦%) | ថយចុះ (-៧២%) | ថយចុះ (-៦២) | កើន (១៣៣%) |

**១.៥- ទិន្នន័យជើងហោះហើររំលង (ឆ្នាំ២០១៨-២០២២)**

| ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|
| ៦៦ ០៩២ | ៧២ ០០៨ | ៣១ ៤១២ | ២២ ៧៣៥ | ៣៤ ២០៣ |
| កើន (១៣%) | កើន (៩%) | ថយចុះ (-៥៦%) | ថយចុះ (-២៨%) | កើន(១០៧%) |

## ២- កិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស

ដើម្បីជំរុញកំណើនក្រុមហ៊ុនអាកាសចរណ៍ ជើងហោះហើរ អ្នកដំណើរតាមផ្លូវអាកាស និងការហោះហើររំលងដែនអាកាសកម្ពុជា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល កំណត់គោលដៅដ៏ច្បាស់លាស់មួយ លើការពង្រឹងនិងពង្រីកកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាមួយបណ្តាប្រទេសសំខាន់ៗ តាមរយៈការចរចាជាលក្ខណៈទ្វេភាគីនិងពហុភាគីជាមួយបណ្តាប្រទេសជាសមាជិកអាស៊ាន។ រាល់ការចរចាកិច្ចព្រមព្រៀងទាំងអស់នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាសបានកំណត់យុទ្ធសាស្ត្រនិងយុទ្ធវិធីច្បាស់លាស់ លើបណ្តាសមាស-ធាតុសេដ្ឋកិច្ចសំខាន់ៗ ដូចជា ការចាត់តាំងក្រុមហ៊ុនអាកាសចរណ៍ ការកំណត់ចំណុះដឹកជញ្ជូន ការកំណត់ផ្លូវហោះហើរ ការកំណត់បើកចំហ សហការជើងហោះហើរ (Code-Share Flights) ការប្រកួតប្រជែងដោយស្មើភាពនិងការកំណត់សំណាញ់សុវត្ថិភាពនៃប្រតិបត្តិការហោះហើរជាដើម។ មកដល់ឆ្នាំ២០២២នេះ កិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសត្រូវបានកែសម្រួល ឯកភាពលើខ្លឹមសារនិងបានចុះហត្ថលេខាជាច្រើន ដូចមានសេចក្តីលម្អិតសង្ខេបខាងក្រោម៖

**២.១- កិច្ចព្រមព្រៀងជាទ្វេភាគី** មកដល់ពេលបច្ចុប្បន្ននេះ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានចុះហត្ថលេខាកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ចុះហត្ថលេខាអនុស្សរណៈយោគយល់ និងឯកភាពជាគោលការណ៍លើខ្លឹមសារនៃកិច្ចព្រមព្រៀង បានចំនួន៤៧ ប្រទេស ដែលរួមមាន៖

-កិច្ចព្រមព្រៀងបានចុះហត្ថលេខាសម្គាល់ចំនួន ១៨ ប្រទេស

-អនុស្សរណៈយោគយល់បានចុះហត្ថលេខាចំនួន ៤៥ ប្រទេស

-កិច្ចព្រមព្រៀងបានចុះហត្ថលេខាចំនួន ២៩ ប្រទេស។

**២.២- កិច្ចព្រមព្រៀងពហុភាគីអាស៊ាន** នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាស ដែលដើរតួនាទីជាអ្នកទទួលបន្ទុកផ្ទាល់រាល់ការចរចាកិច្ចព្រមព្រៀងពាក់ព័ន្ធការងារការដឹកជញ្ជូន តាមផ្លូវអាកាសនិងសម្របសម្រួលការងារបច្ចេកទេសពាក់ព័ន្ធនឹងវិស័យអាកាសចរស៊ីវិល បាននាំមកនូវដំណើរការរីកចម្រើនជាលំដាប់ ដោយមានរួមទាំងកិច្ចព្រមព្រៀងបានទទួលសច្ចាប័នរួចពីរដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា កិច្ចព្រមព្រៀងចុះហត្ថលេខារួចហើយ តែរង់ចាំការផ្តល់សច្ចាប័នពីរដ្ឋសភាជាតិ និងកិច្ចព្រមព្រៀងកំពុងដំណើរការចរចា។

-កិច្ចព្រមព្រៀងពហុភាគីអាស៊ាននិងដៃគូសន្ទនាអាស៊ានចំនួន៤ បានស្នើសុំរដ្ឋសភាជាតិផ្តល់សច្ចាប័នរួច តាមរយៈរាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦

-កិច្ចព្រមព្រៀងពហុភាគីអាស៊ាននិងពិធីសារចំនួន៥ បានចុះហត្ថលេខា កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧ បានស្នើសុំរដ្ឋសភាជាតិផ្តល់សច្ចាប័នរួច តាមរយៈរាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃទី០២ ខែមករា ឆ្នាំ ២០២១

-កិច្ចព្រមព្រៀងពហុភាគីអាស៊ានយ៉ាងតិចចំនួន៣ និងកិច្ចព្រមព្រៀងរវាងអាស៊ាននិងដៃគូអាស៊ាន យ៉ាងតិចចំនួន៤ នឹងត្រូវចុះហត្ថលេខានៅឆ្នាំខាងមុខជាបន្តបន្ទាប់។

**៣- ដំណើរការគាំទ្រឧស្សាហកម្មដឹកជញ្ជូនតាមផ្លូវអាកាស**

ក្រៅពីដំណើរការការងារជំរុញការហោះហើរ ការអនុញ្ញាតការហោះហើរ ការចរចាកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាលក្ខណៈទ្វេភាគីនិងពហុភាគីអាស៊ាន នាយកដ្ឋានដឹកជញ្ជូនតាមផ្លូវអាកាសក៏បានដើរតួនាទីសម្របសម្រួលនិងគាំទ្រសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

**៣.១- ការងារធានារ៉ាប់រងវិស័យអាកាសចរស៊ីវិល** រាល់អ្នកធ្វើដំណើរតាមផ្លូវអាកាសទាំងអស់រួមទាំងទំនិញនិងអីវ៉ាន់ ត្រូវបានធានាថា មានធានារ៉ាប់រងត្រឹមត្រូវ តាមរយៈក្រុមហ៊ុនអាកាសចរណ៍ជាតិនិងអន្តរជាតិ អាកាសយានដ្ឋាននិងចរាចរនាំផ្លូវអាកាស។ ប័ណ្ណធានារ៉ាប់រងរបស់ក្រុមហ៊ុនផ្តល់សេវាកម្មដឹកជញ្ជូនទាំងនេះ ត្រូវត្រួតពិនិត្យសុពលភាពជាប្រចាំ។

**៣.២- ការងារបោះពុម្ពផ្សព្វផ្សាយស្ថិតិដឹកជញ្ជូនតាមផ្លូវអាកាស** ព្រឹត្តិបត្រស្ថិតិប្រចាំឆ្នាំ ឆមាស ត្រីមាស និងប្រចាំខែ ត្រូវបានបោះពុម្ពផ្សព្វផ្សាយជាប្រចាំជូនថ្នាក់ដឹកនាំនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល (រ.ល.អ.ស.) បណ្តាអាជ្ញាធរនិងស្ថាប័នរដ្ឋពាក់ព័ន្ធ។

**៣.៣- ការងារដោះស្រាយបណ្តឹងនិងវិវាទ** បណ្តឹងរបស់អ្នកធ្វើដំណើរតាមផ្លូវអាកាស ជាមួយក្រុមហ៊ុនអាកាសចរណ៍ ក្រុមហ៊ុនអាកាសចរណ៍ជាមួយក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន និងក្រុមហ៊ុនចរាចរដែនអាកាស និងក្រុមហ៊ុនអាកាសចរណ៍ ត្រូវបានដោះស្រាយជាបន្តបន្ទាប់ ដោយឈរលើមូលដ្ឋានសាមគ្គីភាព បង្រួមបញ្ហានិងសុខដុមនីយកម្ម ក្រោមដំបូលឆត្រតែមួយនៃ រ.ល.អ.ស.។

**៣.៤- ទ្រទ្រង់វិស័យឯកជន** ផ្សព្វផ្សាយលទ្ធផលកិច្ចប្រជុំទ្វេភាគីនិងពហុភាគីអាស៊ាន ស្តីពីចំណុចខ្លាំងនិងខ្សោយនៃការអនុវត្តកិច្ចព្រមព្រៀងសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសថ្មីៗ ជាទៀងទាត់ជាមួយវិស័យឯកជន និងបើកកិច្ចប្រជុំពិភាក្សាផ្តល់យោបល់រវាង រ.ល.អ.ស. និងវិស័យឯកជន ដើម្បីស្វែងរកលទ្ធភាពជំរុញនិងគាំទ្រដល់ដំណើរការអាជីវកម្មឱ្យមាននិរន្តរភាពនិងតម្លាភាព។

**៣.៥- ការងារសេវាកម្មទ្រទ្រង់ការដឹកជញ្ជូនតាមផ្លូវអាកាស** បានរៀបចំសេចក្តីប្រកាសស្តីពីការគ្រប់គ្រងប្រតិបត្តិករផ្តល់សេវាកម្មគាំទ្រការដឹកជញ្ជូនតាមផ្លូវអាកាស និងកំពុងដំណើរការតម្រូវឱ្យក្រុមហ៊ុនដែលផ្តល់សេវាកម្មទាំង១៣ប្រភេទ មកចុះបញ្ជីជាមួយ រ.ល.អ.ស.។

**ខ- សុវត្ថិភាពនិងសន្តិសុខហោះហើរ**

**១- ក្រុមហ៊ុនសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសកម្ពុជាដែលកំពុងប្រតិបត្តិការមានចំនួន៦រួមមាន៖**

(១)-ក្រុមហ៊ុន Cambodia Angkor Air (២)-ក្រុមហ៊ុន Sky Angkor Airlines (៣)-ក្រុមហ៊ុន Bassaka Air (៤)-ក្រុមហ៊ុន JC (Cambodia) International Airlines (៥)-ក្រុមហ៊ុន Lanmei Airlines និង (៦)-ក្រុមហ៊ុន Cambodia Airways។

**២- ក្រុមហ៊ុនឧទ្ធម្ភាគចក្រដែលកំពុងដំណើរការមានចំនួន៤រួមមាន៖**

(១)-ក្រុមហ៊ុន Helicopter Cambodia (២)-ក្រុមហ៊ុន Helistar Cambodia (៣)-ក្រុមហ៊ុន Prince International Airlines និង (៤)-ក្រុមហ៊ុនHelitop Cambodia។

**៣- ក្រុមហ៊ុនសហគ្រាសដឹកជញ្ជូនតាមផ្លូវអាកាសបរទេសដែលកំពុងប្រតិបត្តិការមានចំនួន២៣រួមមាន៖**

(១)- ក្រុមហ៊ុនLAO AIRLINES (២)- ក្រុមហ៊ុនHONG KONG DRAGON AIR (៣)- ក្រុមហ៊ុន Malindo Airways (៤)- ក្រុមហ៊ុនQatar Airways Group (៥)- ក្រុមហ៊ុនMalaysia Airways (៦)- ក្រុមហ៊ុន Cebu Air (៧)- ក្រុមហ៊ុនJetstar Asia Airways (៨)- ក្រុមហ៊ុនBangkok Airways (៩)- ក្រុមហ៊ុនThai Airways International (១០)- ក្រុមហ៊ុនRuili Airlines (១១)- ក្រុមហ៊ុនKorea Airlines (១២)- ក្រុមហ៊ុន Philipines Airlines (១៣)- ក្រុមហ៊ុនPT.Citilink,Indonesia (១៤)- ក្រុមហ៊ុនAsiana Airlines Inc (១៥)- ក្រុមហ៊ុនEmirates Airlines (១៦)- ក្រុមហ៊ុន Silk Air (Singapore) (១៧)- ក្រុមហ៊ុនAir Busan (១៨)- ក្រុមហ៊ុនK-Mile Air (១៩)- ក្រុមហ៊ុនEva Airways Corperation (២០)- ក្រុមហ៊ុនAll Nippon Airways (២១)- ក្រុមហ៊ុនVietjet Aviation Joint Stock Compan (២២)- ក្រុមហ៊ុនSpring Airlines CO.,LTD និង (២៣)- ក្រុមហ៊ុនBABOO Airlines ។

## គ- ការងារសន្តិសុខនិងត្រួតពិនិត្យសន្តិសុខអាកាសចរស៊ីវិល

សន្តិសុខអាកាសចរស៊ីវិល គឺជាផ្នែកមួយដែលដើរតួនាទីសំខាន់ដើម្បីធានាសុវត្ថិភាពដល់អ្នកដំណើរក្រុមអាកាសយាន បុគ្គលិកបម្រើការងារនៅលើផ្ទៃដី និងសាធារណជនទូទៅ ទប់ទល់នឹងអំពើរំលោភបំពានច្បាប់មកលើអាកាសចរស៊ីវិល។ ដើម្បីសម្រេចបាននូវគោលដៅខាងលើ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានអនុវត្តសកម្មភាពការងារឱ្យស្របតាមស្តង់ដា និងអនុសាសន៍របស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ និងរៀបចំឱ្យមាននូវច្បាប់ បទប្បញ្ញត្តិ កម្មវិធីថ្នាក់ជាតិ ថ្នាក់ប្រតិបត្តិការអាកាសយាន អាកាសយានដ្ឋាននិងលិខិតបទដ្ឋានបច្ចេកទេសសន្តិសុខ។

**១- ការងារត្រួតពិនិត្យពង្រឹងគុណភាពសន្តិសុខ**

- បានចុះបំពេញបេសកកម្មពិនិត្យការសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី
- បានចុះសិក្សាវាយតម្លៃ(Security Survey) ឧបករណ៍សន្តិសុខ និងប៉ុស្តិ៍ត្រួតពិនិត្យសន្តិសុខនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
- បានចុះសិក្សាវាយតម្លៃ(Security Survey) ពិនិត្យបុគ្គលិកសន្តិសុខ(រ.ល.អ.ស.) ដែលបម្រើការងារនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
- បានចូលរួមធ្វើអធិការកិច្ចសន្តិសុខនៅអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប
- បានចុះធ្វើបច្ចុប្បន្នភាពឧបករណ៍និងកម្លាំងសន្តិសុខនៅអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប
- បានពិនិត្យកម្មវិធីសន្តិសុខអាកាសយានដ្ឋាននៅអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ
- បានពិនិត្យ និងផ្តល់ការយល់ព្រមលើបទដ្ឋានប្រើប្រាស់បណ្ណសម្រាប់សន្តិសុខចេញ ចូលអាកាស-យានដ្ឋានអន្តរជាតិខេត្តព្រះសីហនុសម្រាប់មនុស្ស និងរថយន្ត
- បានពិនិត្យលើការសិក្សាវាយតម្លៃការបណ្តុះបណ្តាលសន្តិសុខអាកាសចរស៊ីវិល និងធ្វើផែនការភាពអាសន្ន និងពិនិត្យលើ SOP នៅអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ
- បានចុះពិនិត្យកម្មវិធីសន្តិសុខអាកាសយាន ពិនិត្យទីតាំងនិងរៀបចំការងារបច្ចេកទេស នៅអាកាស-យានដ្ឋានអន្តរជាតិតារាសាគរ។

## ២- ការងារត្រួតពិនិត្យនិងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិ

- កម្មវិធីជាតិសន្តិសុខអាកាសចរស៊ីវិល ( National Civil Aviation Security Programme )
- កម្មវិធីជាតិត្រួតពិនិត្យគុណភាពសន្តិសុខអាកាសចរស៊ីវិល( National Civil Aviation Quality Control Programme )
- កម្មវិធីជាតិបណ្តុះបណ្តាលសន្តិសុខអាកាសចរស៊ីវិល( National Civil Aviation Security Training Programme )
- កម្មវិធីជាតិសម្របសម្រួលដឹកជញ្ជូនផ្លូវអាកាស ( National Air Transportation Facilitations Programmed )
- កម្មវិធីសន្តិសុខអាកាសយានដ្ឋាន ( Airport Security Programmed )
- បានរៀបចំសេចក្តីព្រាង ស្តីពីសវនកម្មផ្ទៃក្នុង ក្នុងការស្នើសុំគោលការណ៍សម្រេចពីថ្នាក់ដឹកនាំ រ.ល.អ.ស.ដើម្បីប្រកាសឱ្យប្រើ( Internal Audit Manual )
- បានរៀបចំសេចក្តីព្រាងកម្មវិធីសុវត្ថិភាពរដ្ឋ( SSP ) រួចរាល់ហើយ ដើម្បីឱ្យស្របទៅតាមផែនការសុវត្ថិភាពអាកាសចរណ៍ក្នុងតំបន់និងសកល
- បានរៀបចំសេចក្តីព្រាងផែនការសុវត្ថិភាពអាកាសចរណ៍ជាតិ ដើម្បីឱ្យស្របទៅតាមផែនការសុវត្ថិភាពអាកាសចរណ៍តំបន់សកល និងត្រៀមដាក់ជូនសេចក្តីព្រាងផែនការសុវត្ថិភាពអាកាសចរណ៍ជាតិ ដើម្បីស្នើសុំគោលការណ៍សម្រេចពីថ្នាក់ដឹកនាំរ.ល.អ.ស.
- បានរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យសុវត្ថិភាពអាកាសចរណ៍ទៅតាមចំណាត់ថ្នាក់នៃទិន្នន័យសុវត្ថិភាពអាកាសចរណ៍ឱ្យមានលក្ខណៈជាប្រព័ន្ធ ងាយស្រួលគ្រប់គ្រង និងវិភាគ
- បានបង្កើតក្រុមការងារSSP ដើម្បីឱ្យមានការវាស់ស្ទង់ពីកម្រិតនៃការអនុវត្តការងារសុវត្ថិភាពអាកាសចរណ៍របស់ប្រតិបត្តិករបម្រើសេវាកម្មអាកាសចរណ៍នានា នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពចម្រុះមកពីនាយកដ្ឋាន អង្គភាពពាក់ព័ន្ធស្ថិតក្រោមរ.ល.អ.ស. និងស្ថាប័នពាក់ព័ន្ធ ដើម្បីឱ្យស្របទៅនឹងផែនការសុវត្ថិភាពអាកាសចរណ៍ជាតិ តំបន់ និងសកល
- បន្តអនុវត្តក្នុងតួនាទីជា Point of Contact ( PoC RASG-APAC/APRAST ) នៃ ICAO-Asia Pacific ( APAC ) ក្នុងការសម្របសម្រួលការងារសុវត្ថិភាពអាកាសចរណ៍
- បន្តអនុវត្តការងារប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យសុវត្ថិភាពតាមប្រព័ន្ធ SMIS/SOMS
- បន្តតាមដានព័ត៌មាន និងអនុវត្តកិច្ចការនានាតាមរយៈការកែទម្រង់របស់រាជរដ្ឋាភិបាលនិងឱ្យស្របទៅតាម ICAO ក្នុងគោលបំណងពង្រឹងនិងលើកកម្ពស់សុវត្ថិភាពការដឹកជញ្ជូនតាមផ្លូវអាកាស។

# ឃ- ការអភិវឌ្ឍនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានអន្តរជាតិ

**ការអភិវឌ្ឍ និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋានអន្តរជាតិសំខាន់ៗរួមមាន៖**

## ១- ការសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មី (អាកាសយានដ្ឋានអន្តរជាតិតេជោ)

ជាការសាងសង់អាកាសយានដ្ឋានអន្តរជាតិខ្នាតធំកម្រិតលំដាប់ថ្នាក់ 4F គឺជាការកសាងហេដ្ឋារចនាសម្ព័ន្ធថ្មី( Greenfield )ទាំងស្រុង លើទំហំដី ២៦០០ ហិកតា។ តាមផែនការមេបានបង្ហាញឱ្យដឹងថា អាកាសយាន-ដ្ឋាននេះត្រូវបានរចនាឡើងដោយចែកចេញជា ៣ដំណាក់កាលអភិវឌ្ឍន៍៖

- ដំណាក់កាលទី១ បឋម (ជាដំណាក់កាលដំបូង«រយៈពេលខ្លី» ដោយគិតពីថ្ងៃចាប់ផ្តើមសាងសង់ឆ្នាំ២០១៩ រហូតដល់ថ្ងៃដាក់ឱ្យដំណើរការឆ្នាំ២០២៤)

- ដំណាក់កាលទី២ បន្ទាន់ (ជាដំណាក់កាលបន្ទាន់ ដែលត្រូវចាប់ផ្តើមបន្ទាប់ពីដំណាក់កាលទី១ បឋម "រយៈពេលខ្លី" ត្រូវបានបញ្ចប់ភ្លាម គិតចាប់ពីឆ្នាំ២០២៤ ដល់ឆ្នាំ២០៣០ "រយៈពេលមធ្យម" ដោយមានការសាងសង់ផ្លូវរត់ទី២(2nd Runway) និងហេដ្ឋារចនាសម្ព័ន្ធផ្លូវបរពាក់ព័ន្ធ (Associated Taxiway Infrastructure)

- ដំណាក់កាលទី២ (ជាដំណាក់កាល "រយៈពេលវែង" ដោយគិតចាប់ពីឆ្នាំ២០៣០ ដល់ឆ្នាំ២០៥០)

- ដំណាក់កាលទី៣ (ជាដំណាក់កាល "អនាគត" ដោយគិតចាប់ពីឆ្នាំ២០៥០ ឡើងទៅ)

- សម្រាប់អ្នកដំណើរប្រចាំឆ្នាំ រយៈពេលខ្លី មធ្យម (២០២៣-២០៣០) ១៣លាននាក់/ឆ្នាំ និងរយៈពេលវែង (២០៣០-២០៥០) ៣០លាននាក់/ឆ្នាំ

- សម្រាប់ទំនិញតាមផ្លូវអាកាសប្រចាំឆ្នាំ រយៈពេលខ្លី មធ្យម (២០២៣-២០៣០) ១៧៥ ០០០ តោន/ឆ្នាំ និងរយៈពេលវែង (២០៣០-២០៥០) ៥២៧ ០០០តោន/ឆ្នាំ

- បន្ទាប់ពីដំណាក់កាលទី១ ត្រូវបានបញ្ចប់អាកាសយានដ្ឋានអន្តរជាតិតេជោ(ភ្នំពេញថ្មី) នឹងមានសមត្ថភាពទទួលបានយន្តហោះរហូតដល់កូដអ៊ី (Code E: A-340-300, A350-900 and B777-200/300ER, B747-300/400...) មានចំណតយន្តហោះចំនួន២២ចំណត ទទួលអ្នកដំណើរបាន (២០២៤)១៥លាននាក់/ឆ្នាំ និងទំនិញតាមផ្លូវអាកាស/Air Cargo (២០២៤) ១៧៥ ០០០តោន/ឆ្នាំ។

**២- ការសាងសង់អាកាសយានដ្ឋានអន្តរជាតិសៀមរាបថ្មី**

ជាការកសាងហេដ្ឋារចនាសម្ព័ន្ធថ្មី(Greenfield)ទាំងស្រុងលើផ្ទៃដីទំហំ ៧០០,០៦ហិកតា នាពេលខាងមុខនឹងមានការកសាងតំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្មរណបឱ្យអាកាសយានដ្ឋានអន្តរជាតិថ្មី ដែលហៅថា "ទីក្រុងអាកាសយានដ្ឋាន/Airport City" ដែលមានដីបម្រុងប្រមាណ ១ ០០០ហិកតា។

- ជាប្រភេទអាកាសយានដ្ឋានអន្តរជាតិ កម្រិត/លំដាប់ថ្នាក់ ៤អ៊ី/4E (ដំណាក់កាល១)

- តាមផែនការមេឆ្នាំ២០២០ បានបង្ហាញឱ្យដឹងថា សមត្ថភាព/ចំណុះអាកាសយានដ្ឋាននេះត្រូវបានរចនា និងគណនាឡើង៖

- សម្រាប់អ្នកដំណើរប្រចាំឆ្នាំ រយៈពេលខ្លី មធ្យម៧លាននាក់/ឆ្នាំ(ដែលត្រូវចំណាយទុនជាង ៥០០ លានដុល្លារអាម៉េរិក) និងរយៈពេលវែង២០លាននាក់/ឆ្នាំ(ដែលត្រូវចំណាយទុនជាង៣០០លានដុល្លារអាម៉េរិក)

- សម្រាប់ទំនិញប្រចាំឆ្នាំ៖ រយៈពេលខ្លី-មធ្យម១០ ០០០តោន/ឆ្នាំ និងរយៈពេលវែង៦០ ០០០តោន/ឆ្នាំ

- បន្ទាប់ពីដំណាក់កាលទី១ ត្រូវបានបញ្ចប់អាកាសយានដ្ឋានអន្តរជាតិសៀមរាប អង្គរ នឹងមានសមត្ថភាពទទួលបានយន្តហោះរហូតដល់កូដអ៊ី (Code E: A-340-300, A350-900 and B777-200/300ER, B747-300/400..) ចំនួន៣៨ចំណត ទទួលអ្នកដំណើរបាន(២០២៣) ៧លាននាក់/ឆ្នាំ និងទំនិញតាមផ្លូវអាកាស (២០២៣) ១០ ០០០តោន/ឆ្នាំ។

**៣- អាកាសយានដ្ឋានអន្តរជាតិថ្មីតារាសាគរ**

គឺជាការកសាងហេដ្ឋារចនាសម្ព័ន្ធថ្មី (Greenfield) ទាំងស្រុងលើផ្ទៃដីទំហំ២១៨ហិកតា និងមានដីបម្រុងសម្រាប់ការអភិវឌ្ឍសម្រាប់រយៈពេលវែងទំហំជិត ១ ០០០ហិកតា។ ជាប្រភេទអាកាសយានដ្ឋានអន្តរជាតិ

កម្រិតលំដាប់ថ្នាក់ 4E (ជំណាក់កាល១) ដែលមានឈ្មោះសរសេរជាអក្សរកាត់ VDDS (ICAO code) និងDYS (IATA code)នឹងមានគម្រោងអភិវឌ្ឍទៅជា 4F (ជំណាក់កាល២-រយៈពេលវែង)។ តាមការសិក្សារបស់ផែនការមេ បានបង្ហាញឱ្យដឹងថា ចំណុះអាកាសយានដ្ឋាននេះត្រូវបានរចនាឡើង៖

- សម្រាប់អ្នកដំណើរប្រចាំឆ្នាំ រយៈពេលខ្លី មធ្យម(២០២១-២០៣០) ៧លាននាក់/ឆ្នាំ និងរយៈពេលវែង(២០៣០-២០៥០) ២០លាននាក់/ឆ្នាំ
- សម្រាប់ទំនិញតាមផ្លូវអាកាសប្រចាំឆ្នាំ រយៈពេលខ្លី មធ្យម (២០២១-២០៣០) ១ម៉ឺនតោន/ឆ្នាំ និងរយៈពេលវែង (២០៣០-២០៥០) ៦ម៉ឺនតោន/ឆ្នាំ។

**៤- ការស្តារនិងធ្វើឱ្យប្រសើរឡើងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ**

តាមផែនការមេដែលត្រូវបានធ្វើបច្ចុប្បន្នកម្មនៅឆ្នាំ២០១៩ បានបង្ហាញឱ្យឃើញថាអាកាសយានដ្ឋាននេះ ត្រូវការធ្វើឱ្យប្រសើរឡើង និងបង្កើនសមត្ថភាពហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារសំខាន់ៗមួយចំនួន ដើម្បីឆ្លើយតបទៅនឹងកំណើន និងតម្រូវការដែលត្រូវចំណាយទុនវិនិយោគប្រមាណ ២០០លានដុល្លារអាម៉េរិក៖

- សម្រាប់អ្នកដំណើរប្រចាំឆ្នាំ រយៈពេលខ្លី មធ្យម(២០៣០) ៣,៦លាននាក់/ឆ្នាំ និងរយៈពេលវែង (២០៤០) ៦លាននាក់/ឆ្នាំ
- សម្រាប់ទំនិញតាមផ្លូវអាកាសប្រចាំឆ្នាំ រយៈពេលខ្លី មធ្យម៣៥ ០០០តោន/ឆ្នាំ និងរយៈពេលវែង ៥២ ០០០តោន/ឆ្នាំ។

## ខ- ការផ្តល់អាជ្ញាបណ្ណនិងវិញ្ញាបនបត្រ

### ១- ផ្នែកអាកាសយានិក

| ល.រ | ក្រុមហ៊ុនអាកាសចរណ៍ | លទ្ធផលសម្រាប់ឆ្នាំ ២០១៨-២០២២ | | | | |
|---|---|---|---|---|---|---|
| | | Issue License | Issue Validation Certificate | Renewal Validation Certificate | Renewal PPC & IR | Exam (knowledge) |
| ១ | Sky Angkor Airlines | ១៧ | ២១ | ៤៥ | ៣៣ | ៣៨ |
| ២ | Cambodia Angkor Air | ១៤ | ៥១ | ៩៩ | ២១ | ៦៥ |
| ៣ | Bassaka Airlines | ៥ | ០ | ១១ | ១៦ | ៥ |
| ៤ | JC Airlines | ១៥ | ៤០ | ៩៣ | ៨ | ៥៥ |
| ៥ | Lanmei Airlines | ២១ | ៨២ | ១៩៥ | ៣០ | ១០៣ |
| ៦ | Cambodia Airways | ៧ | ៥៩ | ១០០ | ២១ | ៥៧ |
| ៧ | Helistar Cambodia | ២ | ៦ | ១៩ | ០ | ៨ |
| ៨ | Helicopter Cambodia | ០ | ០ | ០ | ០ | ០ |
| ៩ | Helitop Aviation (Cambodia) | ០ | ២ | ៧ | ០ | ២ |
| ១០ | Prince Int. Airlines | ១ | ៣ | ១ | ១ | ៤ |
| ១១ | Union Development Group | ១ | ០ | ០ | ៣ | ១ |
| ១២ | Chip Mong Airlines | ០ | ២ | ០ | ០ | ២ |
| សរុប | | ៨៣ | ២៦០ | ៥៧០ | ១៣៣ | ៣៤០ |

## ២- ផ្នែកវិស្វករថែទាំបច្ចេកទេសអាកាសយាន

| ល.រ | ក្រុមហ៊ុនអាកាសចរណ៍ | លទ្ធផលសម្រាប់ឆ្នាំ ២០១៨-២០២២ | | | | Exam | |
|---|---|---|---|---|---|---|---|
| | | Cambodian License | Renewal License | Validation Certificate | Add Type rating | Knowledge | ELP |
| ១ | Engineers (Cambodia) | ០ | ៤ | ០ | ០ | ០ | ០ |
| ២ | Sky Angkor Airlines | ៥ | ០ | ១ | ០ | ១១ | ១៨ |
| ៣ | Cambodia Angkor Air | ០ | ៨ | ៣ | ០ | ១២ | ២២ |
| ៤ | Bassaka Airlines | ០ | ៥ | ០ | ០ | ៤ | ៧ |
| ៥ | JC Airlines | ៦ | ០ | ៨ | ០ | ៣០ | ១៩ |
| ៦ | Lanmei Airlines | ២៥ | ៩ | ៧ | ០ | ៥១ | ៥៧ |
| ៧ | Cambodia Airways | ៣ | ៥ | ១០ | ០ | ២៤ | ១៦ |
| ៨ | Helistar Cambodia | ១ | ២ | ៣ | ០ | ៧ | ៥ |
| ៩ | Helicopter Cambodia | ០ | ០ | ១ | ០ | ២ | ១ |
| ១០ | Helitop Cambodia | ០ | ១ | ២ | ០ | ៥ | ០ |
| ១១ | Prince Int. Airlines | ៣ | ២ | ១ | ០ | ២ | ០ |
| ១២ | Union Development Group | ០ | ០ | ០ | ០ | ២ | ២ |
| ១៣ | Chip Mong Airlines | ១ | ២ | ០ | ០ | ២ | ៨ |
| ១៤ | KAMO | ០ | ៣ | ៥ | ០ | ១៥ | ០ |
| ១៥ | Other | | | | | | ៣ |
| **សរុប** | | **៤៤** | **៥៧** | **៦១** | **០** | **១៦៧** | **១៦៤** |

## ៣- ផ្នែកអ្នកបញ្ជាចរាចរណ៍ដែនអាកាស

| ល.រ | ក្រុមហ៊ុន សេវាកម្មអាកាសចរណ៍ | លទ្ធផលសម្រាប់ឆ្នាំ ២០១៨-២០២២ | | | | | |
|---|---|---|---|---|---|---|---|
| | | License | Certificate | Examiner Certificate | Add Type Rating | Renewal Rating | Exam |
| ១ | Student Air Traffic Control | ៥ | ១០ | ០ | ០ | ០ | ២២ |
| ២ | Aerodrome Control | ២៣ | ០ | ០ | ៥ | ២៤៩ | ៥១ |
| ៣ | Approach Control | ០ | ០ | ០ | ៧ | ១៥១ | ១២ |
| ៤ | Area Control | ០ | ០ | ០ | ០ | ៧២ | ១៦ |
| ៥ | Designated Examiner | ០ | ០ | ៦ | ០ | ០ | ៧ |
| ៦ | On-the-Job Training Instructor | ០ | ១១ | ០ | ០ | ០ | ១៤ |
| **សរុប** | | **២៨** | **២៤** | **៦** | **១២** | **៤៧២** | **១២២** |

## ច- សេវាកម្មអាកាសចរណ៍

### ១- ផ្នែកគ្រប់គ្រងចរាចរដែនអាកាស(Air Traffic Control)

ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ ដល់ ថ្ងៃទី៣០ ខកញ្ញា ឆ្នាំ២០២២ ការបញ្ជាយន្តហោះហោះហើរឡើងចុះនិងហោះឆ្លងកាត់ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សៀមរាប និងខេត្តព្រះសីហនុ សរុបមានចំនួន **៣៨៤ ៥៩៣ជើង** ក្នុងនោះមានៈ

-ក្នុងស្រុកចំនួន ៤៣ ៧៨៩ជើង

-អន្តរជាតិចំនួន ១១១ ៥៨៥ជើង

-ហោះហើរឆ្លងកាត់ចំនួន ២២៩ ២១៩ជើង។

### ២- ផ្នែកវិទ្យុទាក់ទង វិទ្យុនាំផ្លូវ និងវិទ្យុឃ្លាំមើល(CNS)

-បន្តដោះស្រាយបញ្ហាប្រេកង់ស័ឆ្លងរំខានចូលវិទ្យុទាក់ទងរបស់យន្តហោះ និងវិទ្យុទាក់ទងប៉មបញ្ជាហោះហើររយៈខ្លី មធ្យមនិងរយៈឆ្ងាយពីសំណាក់ស្ថានីយ៍ផ្សាយសម្លេងវិទ្យុFM ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងព័ត៌មាន និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

-បានបំពាក់ឧបករណ៍វិទ្យុនាំផ្លូវ និងវាស់ចម្ងាយ DVOR1150/DME1119 ថ្មី នៅអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ។

### ៣- ផ្នែកឧតុនិយម (Aviation Meteorological Service)

ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ ដល់ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ការផ្តល់សេវាកម្មអង្កេត និងព្យាករណ៍អាកាសធាតុ សម្រាប់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សៀមរាប និងខេត្តព្រះសីហនុ សរុបមានចំនួន **២៧៣ ៦០០**ដង។

- ការអង្កេតអាកាសធាតុ(METARs) ចំនួន២៥០ ៤៤០ដង
- ការផ្តល់ព័ត៌មានព្យាករណ៍អាកាសធាតុ (TAFs) ចំនួន២០ ៧៦០ដង
- ការផ្តល់ព័ត៌មានព្យាករណ៍បាតុភូតអាកាសធាតុលើផ្លូវហោះហើរអន្តរជាតិ(SIGMETs) ចំនួន២ ៤០០ដង
- បានតម្លើងម៉ាស៊ីន Lightning Sensor ថ្មីនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ(ដំបូលការិយាល័យឧតុនិយម) និងនៅអាកាសយានដ្ឋានខេត្តស្ទឹងត្រែង
- ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ អាជ្ញាធរអាកាសចរស៊ីវិលចិនបានផ្ទេរប្រគល់ជាផ្លូវការ SIGMET (SIGMET issued for Phnom Penh FIR) ឱ្យមករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលអ្នកធ្វើខ្លួនវិញ តាមរយៈប្រព័ន្ធអនឡាញ
- បានទទួលគណៈប្រតិភូនិងវិស្វករចិនមកតម្លើងសាកល្បងឧបករណ៍ផ្តល់ទិសទៅរន្ទះ (Lightning Detection Sensors) ចំនួន**៦ស្ថានីយ៍** អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិសៀមរាប អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ អាកាសយានដ្ឋានខេត្តស្ទឹងត្រែង និងអាកាសយានដ្ឋានកោះកុង
- ថ្ងៃទី២១-២៨ ខែកញ្ញា ឆ្នាំ២០២០ បានតម្លើងឧបករណ៍ផ្តល់ទិសទៅរន្ទះ (Lightning Detection Sensors) សម្រាប់ការហោះហើរជាតិ និងអន្តរជាតិនៅខេត្តកំពង់ធំ មណ្ឌលគិរី រតនគិរី ព្រះវិហារ បន្ទាយមានជ័យ ក្រចេះ និងខេត្តស្វាយរៀង ចំនួន**៧ស្ថានីយ៍** ដែលជាជំនួយរបស់សាធារណៈរដ្ឋប្រជាមានិតចិន

- ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ បានជួបប្រជុំពិភាក្សាជាមួយគណៈប្រតិភូរដ្ឋបាលអាកាសចរណ៍ស៊ីវិលចិន លើការផ្តល់ជំនួយឧបករណ៍រ៉ាដាអាកាសធាតុ X-Band Weather Doppler Radar, និងការបណ្តុះបណ្តាលមន្ត្រីព្យាករណ៍អាកាសធាតុ

- បានដំឡើងឧបករណ៍ផ្ទះទិសដៅរន្ទះ ចំនួន៧ស្ថានីយ៍ តាមបណ្តាខេត្តដូចជា ខេត្តស្វាយរៀង ក្រចេះ រតនគិរី មណ្ឌលគិរី ព្រះវិហារ កំពង់ធំ និងខេត្តបន្ទាយមានជ័យ

- ទទួលបានសេវាអ៊ីនធឺណែតសម្រាប់ការិយាល័យឧតុនិយម នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សៀមរាប និងខេត្តព្រះសីហនុ ដើម្បីទទួលទិន្នន័យឧតុនិយម World Area Forecast System ( WAFS ) ដែលបញ្ជូនទិន្នន័យពីប្រទេសជប៉ុន អង់គ្លេស និងសហរដ្ឋអាម៉េរិកតាមប្រព័ន្ធFiles Transfer Protocol ( FTP ), Satellite FY-2G Receiver, Satellite Himawari-8 និង Website អាកាសធាតុ

- ធ្វើទំនើបកម្មវិធី WAFS Software GST/USA ដើម្បីទទួលបាននូវទិន្នន័យថ្មីៗពី WAFC Center London ក្នុងការបម្រើសេវាកម្មហោះហើរឱ្យមានសុវត្ថិភាពខ្ពស់

- បានដោះស្រាយពីការផ្តល់ឯកសារហោះហើរព័ត៌មានឧតុនិយមលើបញ្ជីអសកម្មAP-MET-09 ( Briefing and Flight Document ) ជាមួយអង្គការអាកាសចរស៊ីវិលអន្តរជាតិ International Civil Aviation Organization-ICAO ( Meteorological Deficiency )

- បានដោះស្រាយពីការបង្កើត Meteorological Watch Office-MWO AP-MET-11 ជាមួយអង្គការ International Civil Aviation Organization-ICAO ( Meteorological Deficiency )។

**២- ការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យរ៉ែ និងថាមពល**( ផែក : Ministry of Mines and Energy Cambodia គេហទំព័រ www.mme.gov.kh )

នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលតម្រូវឱ្យក្រសួងរ៉ែ និងថាមពលអនុវត្តការងារពាក់ព័ន្ធការអភិវឌ្ឍវិស័យឧស្សាហកម្មនិស្សារណកម្ម(រ៉ែនិងប្រេងកាត) ជាមួយនឹងការគ្រប់គ្រងធនធានទាំងនេះប្រកបដោយចីរភាពនិងប្រសិទ្ធភាព និងការគ្រប់គ្រងនិងអភិវឌ្ឍវិស័យថាមពល ជាពិសេសថាមពលអគ្គិសនីដែលជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ និងជាចលករនៃឃ្នាស់សេដ្ឋកិច្ចជាតិទាំងមូល ក្នុងនោះ ( ១ ) វិស័យរ៉ែស្ថិតក្នុង**ចតុកោណទី៤ មុំទី២ អាទិភាពទី១**«ជំរុញការអនុវត្ត (គោលនយោបាយជាតិស្តីពីធនធានរ៉ែ ឆ្នាំ២០១៨-២០២៨) ដោយពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងធនធាន និងអាជីវកម្មរ៉ែ ទន្ទឹមនឹងការជំរុញការចូលរួមពីសហគមន៍ដើម្បីកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន សង្គម និងពង្រឹងការប្រមូលចំណូលថវិកាជាតិ» និង**អាទិភាពទី២ នៃមុំដដែល** «ការពង្រឹងយន្តការគ្រប់គ្រងធនធាន និងអាជីវកម្មខ្សាច់ដោយកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម» ( ២ ) វិស័យប្រេងកាតស្ថិតក្នុង**ចតុកោណទី២ មុំទី២ អាទិភាពទី៦** «ការជំរុញការអភិវឌ្ឍវិស័យប្រេងកាត និងឧស្ម័នជាពិសេសការដាក់ដំណើរការអណ្តូងប្រេងដំបូងឱ្យបានឆាប់ ទន្ទឹមគ្នានឹងការពង្រឹងការគ្រប់គ្រងចំណូល ដែលបានមកពីធនធានទាំងនេះប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព» ( ៣ ) វិស័យថាមពលស្ថិតក្នុង**ចតុកោណទី២ មុំទី១ អាទិភាពទី៣** «ការបន្តបញ្ចុះថ្លៃអគ្គិសនី ពង្រីកបណ្តាញគ្របដណ្តប់ និងការបង្កើនស្ថិរភាពអគ្គិសនីដោយសាងសង់អនុស្ថានីយ៍បន្ថែមឱ្យដល់តំបន់ប៉ូលសេដ្ឋកិច្ច និងតំបន់សក្តានុពលសេដ្ឋកិច្ចខ្ពស់» ក្នុង**ចតុកោណទី៣ មុំទី១ អាទិភាពទី៧** «ការបន្តពង្រីកការតបណ្តាញអគ្គិសនីដោយតម្លៃទាបជូនកម្មករ និយោជិត សិស្ស និស្សិត

នៅតាមផ្ទះដួល» ក្នុង**ចតុកោណទី៤ មុំទី១ អាទិភាពទី១០** «ការបន្តជំរុញការអភិវឌ្ឍជនបទឱ្យរស់រវើកដោយបន្តពង្រីកការគ្របដណ្តប់ការប្រើប្រាស់អគ្គិសនី» និង**មុំទី៤ អាទិភាពទី៨** «ការបន្តលើកទឹកចិត្ត និងបង្កើនការវិនិយោគលើថាមពលស្អាត និងថាមពលកកើតឡើងវិញ ជាពិសេសថាមពលពន្លឺព្រះអាទិត្យទន្ទឹមនឹងការកាត់បន្ថយការផលិតថាមពលប្រភពមិនស្អាត ដើម្បីធានាសន្តិសុខថាមពលរយៈពេលវែង»។ ខាងក្រោមគឺជាលទ្ធផលដែលក្រសួងរ៉ែនិងថាមពលបានអនុវត្តតាមកម្មវិធីការងារក្នុងវិស័យរបស់ខ្លួនដែលរួមមាន **១-ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យរ៉ែ ២-ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យប្រេងកាត និង៣-ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យថាមពល** មានខ្លឹមសារដូចខាងក្រោម៖

## ក- ការគ្រប់គ្រងនិងការអភិវឌ្ឍវិស័យរ៉ែ

### ១- ការវាយតម្លៃសក្តានុពលធនធានរ៉ែ

- បានសិក្សាកំណត់តំបន់សក្តានុពលធនធានរ៉ែថ្មសំណង់ចំនួន១តំបន់ និងរ៉ែថ្មអារចំនួន ១តំបន់នៅក្នុងខេត្តកំពង់ស្ពឺ

- បានសិក្សាសក្តានុពលធនធានរ៉ែខ្សាច់សំណង់ចំនួន៨តំបន់ នៅក្នុងខេត្តចំនួន៤ ដូចជាខេត្តកំពង់ចាម កណ្តាល ព្រះសីហនុ និងខេត្តកោះកុង

- បានសិក្សាសក្តានុពលធនធានរ៉ែលោហៈនៅឃុំអន្លង់ជ្រៃ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការរវាងក្រសួងរ៉ែនិងថាមពល និងសាជីវកម្មជាតិប្រេងកាត ឧស្ម័ន និងលោហធាតុប្រទេសជប៉ុន(JOGMEC)។ បច្ចុប្បន្ន ទីតាំងដែលបានសិក្សាត្រូវបានក្រុមហ៊ុននីតិស៊ីម៉ាញនីងកម្ពុជាចំកាត់(Nittetsu Mining (Cambodia) Ltd.) ទទួលបានអាជ្ញាបណ្ណស្វែងរុករករ៉ែដើម្បីបន្តការសិក្សាស្រាវជ្រាវ។

រយៈពេល៥ឆ្នាំ(ឆ្នាំ២០១៨ដល់ខែកញ្ញា ឆ្នាំ២០២២)នេះ ក្រសួងបានជំរុញការដាក់ឱ្យដំណើរការរោងចក្រឧស្សាហកម្មអាជីវកម្មធនធានរ៉ែចំនួន៦ ដូចខាងក្រោម៖

### ២- រោងចក្រផលិតស៊ីម៉ងត៍ដែលដំណើរការផលិតកម្មមានដូចខាងក្រោម៖

| ល.រ | ឈ្មោះក្រុមហ៊ុនស៊ីម៉ងត៍ | ទុនវិនិយោគ | សមត្ថភាពផលិត/ឆ្នាំ |
|---|---|---|---|
| ១ | សាជីវកម្ម ជីប ម៉ុង អ៊ិនស៊ី ស៊ីមេន | ២៦២លានដុល្លារ | ២លានតោន |
| ២ | ក្រុមហ៊ុនបាត់ដំបង ខនស៍ ស៊ីមេន ខមភេនី លីមីធីត | ២៤៥លានដុល្លារ | ២លានតោន |
| ៣ | ក្រុមហ៊ុន ស៊ីម៉ងត៍ ថៃ ប៊ុន រ៉ុង | ១១០លានដុល្លារ | ១លានតោន |

-រោងចក្រផលិតស៊ីម៉ងត៍របស់សាជីវកម្ម ជីបម៉ុង អ៊ិនស៊ី ស៊ីមេន(Chip Mong Insee Cement Corporation) មានទីតាំងស្ថិតនៅភូមិព្រៃតាព្រីក ឃុំស្តេចគង់ ស្រុកបន្ទាយមាស ខេត្តកំពត ត្រូវបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ សាជីវកម្ម ជីបម៉ុង អ៊ិនស៊ី ស៊ីមេន កើតចេញពីការវិនិយោគរួមរវាងពាណិជ្ជករខ្មែរនិងថៃ បានចំណាយដើមទុនវិនិយោគដំបូងប្រមាណ ២៦២ (ពីររយហុកសិបពីរ) លានដុល្លារអាមេរិក និងមានសមត្ថភាពផលិតស៊ីម៉ងត៍ប្រមាណជាង២លានតោនក្នុងមួយឆ្នាំនិងបានផ្តល់ការងារជូនប្រជាពលរដ្ឋខ្មែរចំនួន៣២១នាក់

-រោងចក្រផលិតស៊ីម៉ងត៍របស់ក្រុមហ៊ុនបាត់ដំបង ខនស៍ ស៊ីមេន ខមភេនី លីមីធីត (Battambang Conch Cement Company Limited) មានទីតាំងស្ថិតនៅតំបន់ភ្នំដូនម៉ាយ ភូមិបាណង់ ឃុំស្តៅ ស្រុករតនមណ្ឌល

ខេត្តបាត់ដំបង ត្រូវបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ ក្រុមហ៊ុនបាត់ដំបង ខនស៍ ស៊ីមេន ខមភេនី លីមីធីត កើតចេញពីការវិនិយោគរួមរវាងពាណិជ្ជករខ្មែរនិងចិន បានចំណាយដើមទុនវិនិយោគប្រមាណ២៤៥(ពីររយសែសិបប្រាំ) លានដុល្លារអាម៉េរិក និងមានសមត្ថភាពផលិតស៊ីម៉ងត៍ប្រមាណ២លានតោនក្នុងមួយឆ្នាំ និងបានផ្តល់ការងារជូនប្រជាពលរដ្ឋខ្មែរចំនួន៤០០នាក់

-រោងចក្រផលិតស៊ីម៉ងត៍របស់ក្រុមហ៊ុនស៊ីម៉ងត៍ថៃ ប៊ុន រ៉ុង (Thai Boon Roong Cement Co., Ltd) មានទីតាំងស្ថិតនៅតំបន់ភ្នំល្អាង ស្រុកដងទង់ ខេត្តកំពត ត្រូវបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ក្រុមហ៊ុនស៊ីម៉ងត៍ ថៃ ប៊ុន រ៉ុង កើតចេញពីការវិនិយោគរួមរវាងពាណិជ្ជករខ្មែរនិងចិន បានចំណាយដើមទុនវិនិយោគចំនួន១១០(មួយរយដប់) លានដុល្លារអាម៉េរិក និងមានសមត្ថភាពផលិតស៊ីម៉ងត៍ប្រមាណ១លានតោនក្នុងមួយឆ្នាំ និងបានផ្តល់ការងារជូនប្រជាពលរដ្ឋខ្មែរចំនួន១១០នាក់។

**៣- រោងចក្រចម្រាញ់រ៉ែមាស**

| ល.រ | ឈ្មោះក្រុមហ៊ុន | ទុនវិនិយោគ | សមត្ថភាពបាន |
|---|---|---|---|
| ១ | ក្រុមហ៊ុន រ៉ឺនេសង់ មីនើរ៉ល (ខេមបូឌា) លីមីធីត | ១២០លានដុល្លារ | ៤ ៩៨២,៩២២២គ.ក្រ. |
| ២ | ក្រុមហ៊ុនស៊ីនសាន អ៊ិនដាសស្ទ្រៀល (ខេមបូឌា) ខូអិធីឌី | ៥លានដុល្លារ | ៥៤,២៦១៩គ.ក្រ. |
| ៣ | ក្រុមហ៊ុន ដែលខុម (កម្ពុជា) ភីធីអី អិលធីឌី | ២០លានដុល្លារ | ១៨០,០២៧១គ.ក្រ. |
| ៤ | ក្រុមហ៊ុនសឹង យន្ត គ័ង យិក ខូអិលធីឌី | ៨,៥លានដុល្លារ | ៦១,២៦៤៦គ.ក្រ |

- រោងចក្រចម្រាញ់រ៉ែមាសរបស់ក្រុមហ៊ុនរ៉ឺនេសង់ មីនើរ៉ល (ខេមបូឌា) លីមីធីត (Renaissance Minerals (Cambodia) Limited) មានទីតាំងស្ថិតនៅតំបន់អូរខ្វាវ ស្រុកកែវសីមា ខេត្តមណ្ឌលគិរីត្រូវបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១ ក្រោមអធិបតីភាពឯកឧត្តម **ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល** ជាតំណាងដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី**។ ក្រុមហ៊ុនរ៉ឺនេសង់ មីនើរ៉ល(ខេមបូឌា) លីមីធីត ជាក្រុមហ៊ុនអូស្ត្រាលី បានចំណាយទុនវិនិយោគចំនួន១២០(មួយរយម្ភៃ)លានដុល្លារអាម៉េរិក និងបានផ្តល់ការងារជូនប្រជាពលរដ្ឋខ្មែរចំនួន៤៣៤នាក់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២នេះ ក្រុមហ៊ុនបានចម្រាញ់រ៉ែមាសចំនួន៣២៨ដុំ ស្មើនឹង៤ ៩៨២,៩២២២(បួនពាន់ប្រាំបួនរយប៉ែតសិបពីរ ក្បៀសប្រាំបួនពាន់ពីររយម្ភៃពីរ) គីឡូក្រាម

- រោងចក្រចម្រាញ់រ៉ែមាសរបស់ក្រុមហ៊ុនស៊ីនសាន អ៊ិនដាសស្ទ្រៀល(ខេមបូឌា) ខូអិលធីឌី XINSHAN INDUSTRIAL (CAMBODIA) CO., LTD. មានទីតាំងស្ថិតនៅតំបន់ភ្នំអន្លុង ឃុំមេទម ស្រុករវៀង ខេត្តព្រះវិហារត្រូវបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ ក្រោមអធិបតីភាព**ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**។ ក្រុមហ៊ុនស៊ីនសាន អ៊ិនដាសស្ទ្រៀល (ខេមបូឌា) ខូអិធីឌី ជាក្រុមហ៊ុនចិនបានចំណាយទុនវិនិយោគចំនួន៥(ប្រាំ)លានដុល្លារអាម៉េរិក និងបានផ្តល់ការងារជូនប្រជាពលរដ្ឋខ្មែរចំនួន៤៣នាក់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២នេះ ក្រុមហ៊ុនបានចម្រាញ់រ៉ែមាសចំនួន៥០ដុំ ស្មើនឹង៥៤,២៦១៩ (ហាសិបបួនក្បៀសពីរពាន់ប្រាំមួយរយដប់ប្រាំបួន) គីឡូក្រាម

-រោងចក្រចម្រាញ់រ៉ែមាសរបស់ក្រុមហ៊ុនដែលខុម(កម្ពុជា) ភីធីអី អិលធីឌី (DELCOM KAMPUCHEA PTE. LTD) មានទីតាំងស្ថិតនៅតំបន់ភ្នំអន្លុង ស្រុករវៀង ខេត្តព្រះវិហារ ត្រូវបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនៅ

ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២២ ក្រោមអធិបតីភាព**ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**។ ក្រុមហ៊ុន ដែលខុម(កម្ពុជា)ភីធីអី អិលធីឌី ជាក្រុមហ៊ុនចិនបានចំណាយទុនវិនិយោគចំនួន២០(ម្ភៃ) លានដុល្លារអាម៉េរិក និងបានផ្តល់ការងារជូនប្រជាពលរដ្ឋខ្មែរចំនួន៧០នាក់ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ក្រុមហ៊ុនបានចម្រាញ់រ៉ែមាសចំនួន១៨០ដុំ ស្មើនឹង១៨០,០២១៧១ (មួយរយប៉ែតសិបក្បៀសសូនពីរពាន់មួយរយចិតសិបមួយ) គីឡូក្រាម

- រោងចក្រចម្រាញ់រ៉ែមាសរបស់ក្រុមហ៊ុនស៊ីង យន្ត គ័ង យិក ខូអិលធីឌី XING YUAN KANNG YEAK CO.,LTD ដែលមានទីតាំងស្ថិតនៅតំបន់អូរខ្វិកខ្លក់ ស្រុកសំបូរ ខេត្តក្រចេះ ត្រូវបានសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ ក្រោមអធិបតីភាព**ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**។ ក្រុមហ៊ុនស៊ីង យន្ត គ័ង យិក ខូអិលធីឌី XING YUAN KANNG YEAK CO.,LTD ជាក្រុមហ៊ុនចិនបានចំណាយទុនវិនិយោគចំនួន៨ ៥០០ ០០០(ប្រាំបីលានប្រាំរយពាន់) ដុល្លារអាមេរិក និងផ្តល់ការងារជូនប្រជាពលរដ្ឋខ្មែរចំនួន៨៥នាក់។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ក្រុមហ៊ុនបានចម្រាញ់រ៉ែមាសបានចំនួន៣៩ដុំ ស្មើនឹង ៦១,២៦៤៦ (ហុកសិបមួយក្បៀសពីរពាន់ប្រាំមួយសែសិបប្រាំមួយ) គីឡូក្រាម។

### ៤- ស្ថានភាពវិនិយោគក្នុងវិស័យរ៉ែ

ចាប់ពីឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២២ ការធ្វើប្រតិបត្តិការធនធានរ៉ែក្រោមអាជ្ញាបណ្ណធនធានរ៉ែ ដែលផ្តល់ដោយក្រសួងរ៉ែនិងថាមពលមានស្ថានភាពដូចខាងក្រោម៖




### ៥- បរិមាណផលិតកម្មធនធានរ៉ែ

ការធ្វើអាជីវកម្មធនធានរ៉ែក្រោមអាជ្ញាបណ្ណធនធានរ៉ែ ដែលផ្តល់ដោយក្រសួងរ៉ែនិងថាមពលរយៈពេល៥ឆ្នាំ (២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២)នេះ បានផលិតនូវបរិមាណផលិតកម្មធនធានរ៉ែដូចខាងក្រោម៖

| ល.រ | ប្រភេទ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ធ្យូងថ្ម | តោន | ៣៤១៧២,៦០ | ១៣ ៥៩៧,០៦ | ១៩ ០៧៨,២៦ | ២៤ ៣៨៥,១៤ | ១៤ ៤៦២,០៩០ | **១០៥ ៦៩៥,៩៦** |

| ល.រ | ប្រភេទ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ២ | ខ្សាច់ស | តោន | ៧១៥ ៥០០ | ៣៥៦ ០០០ | 0 | 0 | 0 | **១ ០៧១ ៥០០,០០** |
| ៣ | ស៊ីម៉ងត៍ | តោន | ៥ ៩៦៦ ៥១៦,៦៤ | ៧៨៩៦៣៩១ | ៨ ៥០២ ២៩៣,៣៤ | ៨ ៩៤៤ ៧៥០ | ៤ ៦៥០ ៦៧០ | **២៩ ៩៩៤ ១០៤,៣៤** |
| ៤ | មាស (90%) | Kg | N/A | N/A | N/A | ១ ៣៨២,៧៦ | ២ ៦៣២,០១ | **៤ ០១៤,៧៧** |
| ៥ | ថ្មបំបែក | $M^3$ | ២ ៣៧៦ ៨៥៤ | ៤ ៧៥៣ ១៧៥ | ៣ ៦៧៦ ៣៣៣ | ៥ ២៣៦ ១៥០ | ៣ ២៤៩ ៣៦៦ | **១៩ ២៩១ ៨៧៨,០០** |
| ៦ | អាចម៍ដី | $M^3$ | ៦ ៥៧២ ៩៤៧ | ៨ ១៥២ ៥៧៣ | ៨ ១៨៦ ០០០ | ១០ ៣៨៦ ០០០ | ២ ៥៦០ ០០០ | **៣៥ ៨៥៧ ៥២០,០០** |
| ៧ | ដីក្រហម | $M^3$ | ១ ៣០០ ៩៤៧ | ២ ២០១ ៩០៩ | ១ ១៧៥ ២៤០ | ១ ៣១១ ០០០ | ៣៣០ ០០០ | **៦ ៣១៩ ០៩៦,០០** |
| ៨ | ខ្សាច់បក | $M^3$ | ១ ៤១៦ ០០០ | ១ ៧៨៨ ៥០២ | ១ ៩៥៤ ៦១១ | ២ ៤១០ ៨០០ | ៧០០ ០០០ | **៨ ២៦៩ ៩១៣,០០** |
| ៩ | ថ្មអារ | $M^3$ | ៦៥ ៦៣២ | ១៣៥ ២៣៧ | ៤០៨ ៦៤០ | ៤៧៨ ៧២០ | ៤៣១ ៩៤៥ | **១ ៥២០ ១៧៤,០០** |
| ១០ | ថ្មភក់ | $M^3$ | ១ ១៥០ | ២ ២១១ | ៣ ៦៥០ | ៥ ៦០០ | ២ ៧០០ | **១៥ ៣១១,០០** |
| ១១ | ថ្មកែវ | $M^3$ | ៦០០ | ៥៤២ | ២០០ | ២២០ | ២២០ | **១ ៧៨២,០០** |
| ១២ | ខ្សាច់សំណង់ | $M^3$ | ១ ៨២៨ ៣០០ | ២ ០១១ ៧០០ | ៣ ០១៤ ៥០០ | ២ ៨៤៦ ០០០ | ២ ១៦១ ១២៥ | **១២ ៧៦៧ ០០០,០០** |
| ១៣ | ដីល្បាយខ្សាច់ | $M^3$ | ៦ ៣០១ ០០០ | ៧ ៧១៧ ០០០ | ៩ ៣១៦ ០០០ | ១២ ១៨៦ ០០០ | ៩ ៩៦០ ៧៥០ | **៤៨ ២២៦ ០០០,០០** |
| ១៤ | ក្រួស | $M^3$ | ៣៨ ០០០ | ៣៨ ៤០០ | ៣៦ ៥០០ | ៤០ ០០០ | ៣០ ០០០ | **១៩២ ៩០០,០០** |
| ១៥ | ខ្សាច់នាំចេញ | $M^3$ | N/A | N/A | ៧៨ ៧៩៩ | ៤៩៦ ៣២០ | ១ ៩៨០ ០៧១,៦៧ | **២ ៥៥៥ ១៩០,៦៧** |
| ១៦ | ថ្មអារប្លុកនាំចេញ | $M^3$ | ២៨៣,៦៧ | ៤ ១៦៣,២២ | ៥១ ៣៥០,៥៤ | ៣៧៣ ៤៥៩,៩៧ | ៦៥ ៣១៤,៥៧ | **៤៩៥ ៥៧១,៩៧** |
| ១៧ | ថ្មអារសន្លឹកនាំចេញ | $M^2$ | ១២៦ ៨៤៤,៩៦ | ៥១ ៩១៦,៤៤ | ៣៣៦ ០២០,៣៤ | ១៦៨ ២០២,០៨ | ៣១០ ០០៥,៥៧ | **៩៩២ ៩៨៩,៣៩** |

## ៦- ការរៀបចំប្រព័ន្ធព័ត៌មានវិទ្យា

ក្រសួងរ៉ែ និងថាមពលបានអនុវត្តការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System-NRMIS) សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ ដើម្បីសម្រួលដល់ការប្រមូលចំណូល។ ប្រព័ន្ធខាងលើបានជួយសម្រួលដល់ការគណនាទឹកប្រាក់ដែលត្រូវបង់ និងចំណេញពេលវេលាក្នុងការចេញលិខិតបញ្ជាបង់ប្រាក់ជូនសម្បទានិក ព្រមទាំងងាយស្រួលតាមដានការបង់ចំណូល។ ទន្ទឹមនឹងនេះ ក្រសួងក៏បានរៀបចំ QR Code សម្រាប់តាមដានអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតធនធានរ៉ែនានា ដើម្បីផ្តល់ភាពងាយស្រួលក្នុងការតាមដាននិងត្រួតពិនិត្យអំពីព័ត៌មានលម្អិតរបស់អាជ្ញាបណ្ណធនធានរ៉ែ និងលិខិតអនុញ្ញាតនានា ក៏ដូចជាអាចឱ្យសាធារណជនទូទៅធ្វើការស្កេនដើម្បីដឹងពីព័ត៌មានអាជ្ញាបណ្ណធនធានរ៉ែ និងលិខិតអនុញ្ញាត ថាពិត ឬក្លែងក្លាយ។ ជាក់ស្តែងយើងសម្រេចបានការរៀបចំ QR Code នៅលើអាជ្ញាបណ្ណធនធានរ៉ែ និងលិខិតអនុញ្ញាតនានាដូចមានចំនួនខាងក្រោម៖

- អាជ្ញាបណ្ណចំនួន ១៩៣
- លិខិតអនុញ្ញាតឱ្យធ្វើប្រតិបត្តិការធនធានរ៉ែខ្សាច់ចំនួន ១២លិខិត
- លិខិតអនុញ្ញាត (កូតា) ចំនួន ១០៦ លិខិត
- វិញ្ញាបនបត្របញ្ជាក់ការនាំចេញចំនួន ៣ ៦១៨វិញ្ញាបនបត្រ។

### ៧- ការអភិវឌ្ឍសហគមន៍មូលដ្ឋាន

មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន (មូលនិធិរ៉ែ) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៥ ក្រោមការផ្តួចផ្តើមដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល** ដើម្បីអនុញ្ញាតឱ្យក្រុមហ៊ុនសហគ្រាសអាជីវកម្មរ៉ែបានចូលរួមចំណែកបង់វិភាគទានមូលនិធិរ៉ែសម្រាប់អភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ដែលមានប្រតិបត្តិការធនធានរ៉ែក្នុងគោលបំណងបង្កើនសុខដុមនីយកម្មរវាងសហគមន៍មូលដ្ឋានជាមួយនឹងការដ្ឋានរ៉ែ និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ តាមរយៈការផ្តល់ផលប្រយោជន៍ដោយផ្ទាល់ ឬដោយប្រយោលដល់សហគមន៍មូលដ្ឋាននោះ។ ជាក់ស្តែងរយៈពេល ៥ឆ្នាំ (២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២)នេះ ក្រសួង បានជំរុញការអភិវឌ្ឍសហគមន៍មូលដ្ឋាននៅខេត្តកណ្តាល ១៤គម្រោង ខេត្តតាកែវ ២គម្រោង ខេត្តក្រចេះ ២គម្រោង ខេត្តរតនគិរី ១គម្រោង ខេត្តប៉ៃលិន ១គម្រោង ខេត្តពោធិ៍សាត់ ១គម្រោង ខេត្តឧត្តរមានជ័យ ២គម្រោង ខេត្តព្រៃវែង ៤គម្រោង ខេត្តសៀមរាប ៤គម្រោង ខេត្តបាត់ដំបង ៣គម្រោង និងខេត្តបន្ទាយមានជ័យ ២គម្រោង សរុបបានចំនួន ៣៦គម្រោងដោយប្រើប្រាស់ថវិកាមូលនិធិរ៉ែចំនួន ១ ៦៦០ ២៧២,១៦ (មួយលានប្រាំមួយរយហុកសិបពាន់ពីរយចិតសិបពីរក្បៀសដប់ប្រាំមួយ) ដុល្លារអាម៉េរិក និងកំពុងបន្តអនុវត្តគម្រោងចំនួន ២៨គម្រោងដែលគ្រោងនឹងចំណាយថវិកាសរុបចំនួន ១ ១៥២ ៦១៦,៦៤ (មួយលានមួយរយហាសិបពីរពាន់ប្រាំមួយរយដប់ប្រាំមួយក្បៀសហុកសិបបួន) ដុល្លារអាម៉េរិក។

## ខ- ការអភិវឌ្ឍនិងការគ្រប់គ្រងវិស័យថាមពល

ចំពោះការអភិវឌ្ឍវិស័យថាមពលអគ្គិសនីសម្រាប់អាណត្តិទី៦ ខ្លឹមសារសង្ខេបនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលគឺ ១- ជំរុញការពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឱ្យដល់ភូមិទាំងអស់នៅឆ្នាំ២០២០ និងជំរុញភ្ជាប់បណ្តាញឱ្យគេហដ្ឋានប្រជាពលរដ្ឋចំនួន៧៥% ឱ្យមានអគ្គិសនីប្រើប្រាស់នៅឆ្នាំ២០២៣(ការអភិវឌ្ឍបណ្តាញអគ្គិសនីគ្រប់ប្រភេទ) ២- ជំរុញការអភិវឌ្ឍប្រភពអគ្គិសនីឱ្យទាន់ពេលវេលានិងគ្រប់គ្រាន់សម្រាប់កំណើននៃការប្រើប្រាស់(ការអភិវឌ្ឍប្រភពអគ្គិសនី) ៣- ពិនិត្យកំណើននៃតម្រូវការនិងរៀបចំផែនការអភិវឌ្ឍវិស័យថាមពលឡើងវិញ ដោយលើកទឹកចិត្តការអភិវឌ្ឍប្រភពថាមពលស្អាត និងបង្កើនស្ថិរភាពនៃការផ្គត់ផ្គង់អគ្គិសនី និងទី៤- បញ្ចុះថ្លៃលក់អគ្គិសនីសម្រាប់វិស័យឧស្សាហកម្មនិងពាណិជ្ជកម្ម និងបន្តអនុគ្រោះថ្លៃលក់អគ្គិសនីឱ្យប្រជាពលរដ្ឋ។

### ១- អភិវឌ្ឍគ្រប់គ្រងនិងរៀបចំផែនការយុទ្ធសាស្ត្រនិងការវិនិយោគវិស័យថាមពល

ក្នុងអាណត្តិទី៦នៃរដ្ឋសភានេះ សមិទ្ធផលរយៈពេល ៥ឆ្នាំនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍវិស័យថាមពល សម្រេចបាន ដូចខាងក្រោម៖

### ១.១- ការអភិវឌ្ឍបណ្តាញអគ្គិសនី

ការអភិវឌ្ឍប្រព័ន្ធបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ ក្នុងអាណត្តិទី៦ បានធ្វើឱ្យខ្សែបណ្តាញបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់កម្ពុជាកើនឡើងពី២ ១៤១គ.ម.នៅឆ្នាំ២០១៨ រហូតដល់៣ ៤៨៥,៥១គ.ម. នៅចុងឆ្នាំ២០២២ និងធ្វើឱ្យចំនួនអនុស្ថានីយកើនឡើងពី៣៣កន្លែង នៅឆ្នាំ២០១៨ រហូតដល់៦៣កន្លែង នៅចុងឆ្នាំ២០២២ ដែលធ្វើឱ្យការផ្គត់ផ្គង់អគ្គិសនីរបស់បណ្តាញជាតិដែលនៅឆ្នាំ២០១៨ គ្របដណ្តប់ត្រឹមតែរាជធានី ខេត្តចំនួន២០នៅឆ្នាំ២០២២នេះ បានគ្របដណ្តប់ផ្ទាល់លើរាជធានី ខេត្តទាំង២៥រួចហើយ។ កំណើននៃប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនីខាងលើនេះបានធ្វើឱ្យមានស្ថិរភាព គុណភាព និងនិរន្តរភាពនៃការផ្គត់ផ្គង់អគ្គិសនីនៃប្រព័ន្ធបណ្តាញជាតិកាន់តែប្រសើរឡើងថែមទៀត។

ការអភិវឌ្ឍប្រព័ន្ធបណ្តាញអគ្គិសនីតង់ស្យុងមធ្យម និងតង់ស្យុងទាប ក្នុងអាណត្តិទី៦ បានធ្វើឱ្យប្រវែងខ្សែបណ្តាញតង់ស្យុងមធ្យមកើនឡើងពី៣១ ៣៥៦គ.ម. នៅឆ្នាំ២០១៨ រហូតដល់៤២ ៧៥០គ.ម. នៅចុងឆ្នាំ២០២២ និងដែលធ្វើឱ្យប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងទាបកើនឡើងពី៣២ ១១៨គ.ម. នៅឆ្នាំ២០១៨ រហូតដល់៤៤ ៣២០គ.ម. នៅឆ្នាំ២០២២។ ការអភិវឌ្ឍខ្សែបណ្តាញតង់ស្យុងមធ្យមនិងតង់ស្យុងទាបដ៏លឿនខាងលើនេះ បានធ្វើឱ្យភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនីរបស់បណ្តាញជាតិ បានកើនឡើងពី១២ ៣០៥ភូមិ ត្រូវជា៨៦,៨៥% នៃចំនួនភូមិទូទាំងប្រទេសនៅឆ្នាំ២០១៨មក ១៣ ៩២៣ភូមិ ត្រូវជា៩៨,២៧% នៃចំនួនភូមិទូទាំងប្រទេសនៅឆ្នាំ២០២២នេះ។ បច្ចុប្បន្នភូមិពុំទាន់មានការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិ គឺមានចំនួន២៤៥ភូមិ ស្មើនឹង១,៧៣%។ ចំពោះការភ្ជាប់បណ្តាញឱ្យអ្នកប្រើប្រាស់គ្រប់ប្រភេទបានកើនឡើងពី២ ៦៤៥ ៦៣០ទីតាំងនៅឆ្នាំ២០១៨ រហូតដល់៣ ៥១២ ០២២ទីតាំងនៅឆ្នាំ២០២២ ដែលនៅក្នុងនោះការភ្ជាប់ចរន្តឱ្យលំនៅដ្ឋានរបស់ប្រជាពលរដ្ឋបានកើនឡើងពី២ ៥៣៧ ២៨២ខ្នងផ្ទះ នៅឆ្នាំ២០១៨ រហូតដល់**៣ ២៨៩ ៩៣២ខ្នងផ្ទះ** នៅឆ្នាំ២០២២។ តាមស្ថិតិចំនួនខ្នងផ្ទះសរុបទូទាំងប្រទេស**៣,៧២លានខ្នងផ្ទះ** ខ្នងផ្ទះដែលទទួលបានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិនៅចុងឆ្នាំ២០២២ មានចំនួន**៨៨,៤៥%** រួចហើយ។

ភូមិដែលបណ្តាញជាតិផ្គត់ផ្គង់អគ្គិសនីទៅមិនទាន់ដល់មានចំនួន ២៤៥ភូមិ ស្មើនឹង ១,៧៣% គឺជាភូមិដាច់ស្រយាល គ្មានផ្លូវធ្វើដំណើរ ជាតំបន់កោះ ជាភូមិបណ្តែតទឹក និងជាតំបន់លិចទឹកនៅរដូវវស្សាដែលពិបាកក្នុងការរៀបចំខ្សែបណ្តាញអគ្គិសនីឱ្យទៅដល់។ ទោះបីជាយ៉ាងនេះក៏ដោយ រាជរដ្ឋាភិបាលបានខិតខំជួយដោះស្រាយឱ្យលំនៅដ្ឋានប្រជាពលរដ្ឋមួយចំនួនធំនៅក្នុងភូមិដែលនៅសល់ទាំងនោះ មានអគ្គិសនីប្រើប្រាស់ជាបណ្តោះអាសន្ន តាមរយៈការផ្តល់ប្រព័ន្ធពន្លឺព្រះអាទិត្យតាមផ្ទះ ក្នុងក្របខ័ណ្ឌជំនួយឧបត្ថម្ភនៃកម្មវិធីគាំពារសង្គមរបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ និងការវិនិយោគផ្ទាល់ខ្លួន ហើយលំនៅដ្ឋានមួយចំនួនទៀតក៏បានប្រើប្រាស់អាគុយដែលមានកន្លែងសាកអាគុយរួមនៅក្នុងភូមិផងដែរ។ ក្រុមការងាររួមរបស់ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា កំពុងតែរួមគ្នាបន្តដោះស្រាយការផ្គត់ផ្គង់អគ្គិសនីឱ្យភូមិដែលនៅសល់ទាំងនេះតាមករណីនីមួយៗរហូតដល់បញ្ចប់។




| | បណ្តាញ HV (km) | បណ្តាញ MV និង LV (km) | បណ្តាញចែកចាយ LV (km) | ចំនួនអនុស្ថានីយ | គ្របដណ្តប់ (រាជធានី-ខេត្ត) | គ្របដណ្តប់ (ភូមិ) | ទីតាំងភ្ជាប់ (ពាន់ទីតាំង) | លំនៅដ្ឋាន (ពាន់ខ្នងផ្ទះ) |
|---|---|---|---|---|---|---|---|---|
| ឆ្នាំ២០១៨ | 2141 | 31356 | 32118 | 33 | 20 | 12305 | 2646 | 2537 |
| ឆ្នាំ២០២២ | 3486 | 42750 | 44320 | 63 | 25 | 13923 | 3512 | 3290 |

## ១.២- ការអភិវឌ្ឍប្រភពអគ្គិសនី

ក្នុងអាណត្តិទី៦ ការអភិវឌ្ឍប្រភពអគ្គិសនីកន្លងមកបានធ្វើឱ្យទំហំប្រភពអគ្គិសនីសរុបដែលបានអភិវឌ្ឍរួចកើនឡើងពី២ ៦៥០មេហ្គាវ៉ាត់ នៅឆ្នាំ២០១៨ រហូតដល់៤ ២៤៦,៧៧មេហ្គាវ៉ាត់ នៅចុងឆ្នាំ២០២២ ដែលស្មើនឹងកំណើន៦០% ធៀបទៅនឹងទំហំដែលមាននៅឆ្នាំ២០១៨។ លើមូលដ្ឋាននៃទំហំប្រភពអគ្គិសនីដែល

បានអភិវឌ្ឍខាងលើនេះ បរិមាណថាមពលអគ្គិសនីដែលប្រព័ន្ធបណ្តាញជាតិទូទាំងប្រទេស បានទទួលបានកើនឡើងពី៩ ៧៣៨,៧៨លានគីឡូវ៉ាត់ម៉ោង ក្នុងឆ្នាំ២០១៨ ដល់១៤ ១៣៣,៤២លានគីឡូវ៉ាត់ម៉ោង នៅឆ្នាំ២០២២ ដែលស្មើនឹងកំណើន៤៥% ធៀបទៅនឹងបរិមាណថាមពលដែលបានទទួលនៅឆ្នាំ២០១៨។ ក្នុងទំហំប្រភពអគ្គិសនីសរុបដែលមាននៅឆ្នាំ២០២២ នេះ មាន៣ ១១៦,០២មេហ្គាវ៉ាត់ ស្មើនឹង៧៣,៣៧% ជាប្រភពអគ្គិសនីដែលបានអភិវឌ្ឍក្នុងស្រុក និងមាន១ ១៣០,៧៥មេហ្គាវ៉ាត់ ស្មើនឹង២៦,៦៣% ជាប្រភពអគ្គិសនីដែលបាននាំចូលពីប្រទេសជិតខាង។

| តារាងបញ្ជីគម្រោងប្រភពអគ្គិសនីក្នុងស្រុកដែលដាក់ឱ្យដំណើរការ ២០១៨-២០២២ | | | | |
|---|---|---|---|---|
| ល.រ | ឈ្មោះគម្រោងក្រុមហ៊ុនវិនិយោគ | អានុភាព (មេហ្គាវ៉ាត់) | ទីតាំង | ថ្ងៃដាក់ដំណើរការ (COD) |
| I | **គម្រោងថាមពលពន្លឺព្រះអាទិត្យ** | **៤១២** | | |
| ១ | ស្ថានីយពន្លឺព្រះអាទិត្យ (Tay Seng SEZ Co., Ltd) | ៥ | ស្វាយរៀង | ២០១៨ |
| ២ | ស្ថានីយពន្លឺព្រះអាទិត្យ (Schneitec Renewable Co., Ltd) | ៨០ | កំពង់ស្ពឺ | ២០១៩ |
| ៣ | ស្ថានីយពន្លឺព្រះអាទិត្យ (Chip Mong Insee Cement Corporation) | ៧ | កំពត | ២០២០ |
| ៤ | ស្ថានីយពន្លឺព្រះអាទិត្យ (Schneitec Infinite Co., Ltd) | ៣០ | ពោធិ៍សាត់ | ២០២០ |
| ៥ | ស្ថានីយពន្លឺព្រះអាទិត្យ (Schneitec Sustainable Co., Ltd) | ៦០ | កំពង់ឆ្នាំង | ២០២០ |
| ៦ | ស្ថានីយពន្លឺព្រះអាទិត្យ (Ray Power Supply Co., Ltd) | ៣០ | បន្ទាយមានជ័យ | ២០២០ |
| ៧ | ស្ថានីយពន្លឺព្រះអាទិត្យ (Schneitec Sustainable Co., Ltd ) | ៦០ | ពោធិ៍សាត់ | ២០២១ |
| ៨ | ស្ថានីយពន្លឺព្រះអាទិត្យ (Risen Energy (Cambodia) Battambang Co., Ltd) | ៦០ | បាត់ដំបង | ២០២១ |
| ៩ | ស្ថានីយពន្លឺព្រះអាទិត្យ (Green Sustainable Ventures (Cambodia) Co., Ltd) | ២០ | ស្វាយរៀង | ២០២២ |
| ១០ | ស្ថានីយពន្លឺព្រះអាទិត្យ (Prime Road Alternative (Cambodia) Co., Ltd) | ៦០ | កំពង់ឆ្នាំង | ២០២២ |
| II | **គម្រោងថាមពលវារីអគ្គិសនី** | **៤០០** | | |
| ១១ | វារីអគ្គិសនីសេសានក្រោម២ (Hydro Power Sesan 2 Co.,Ltd) | ៤០០ | ស្ទឹងត្រែង | ២០១៨ |
| III | **គម្រោងថាមពលដុតធ្យូងថ្ម** | **៤៨៥** | | |
| ១២ | រោងចក្រអគ្គិសនីដុតធ្យូងថ្ម ( Cambodian Energy II Co., Ltd (CELII)) | ១៣៥ | ព្រះសីហនុ | ២០២០ |

| | | | | |
|---|---|---|---|---|
| ១៣ | រោងចក្រអគ្គិសនីដុតធ្យូងថ្ម ( Cambodia International Investment Development Group Co., Ltd ( CIIDG ) ) | ៣៥០ | ព្រះសីហនុ | ២០២២ |
| សរុប | | ១ ២៩៧ | | |

## ១.៣- ការពិនិត្យកំណើនតម្រូវការនិងរៀបចំផែនការអភិវឌ្ឍអគ្គិសនីឡើងវិញ

នៅឆ្នាំ២០១៩ ក្រសួងរ៉ែនិងថាមពលបានធ្វើសហប្រតិបត្តិការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ដើម្បីធ្វើការពិនិត្យកំណើននៃតម្រូវការអគ្គិសនី និងធ្វើការសិក្សារៀបចំផែនការមេអភិវឌ្ឍវិស័យអគ្គិសនីឡើងវិញ សម្រាប់ឆ្នាំ២០២១ដល់ឆ្នាំ២០៤០។ ក្នុងការរៀបចំផែនការមេនេះ ដើម្បីឆ្លើយតបនឹងបញ្ហាអាកាសធាតុ និងបរិស្ថានរួមជាមួយនឹងការធានាឱ្យមានថាមពលគ្រប់គ្រាន់ ស្ថិរភាពនិងតម្លៃសមរម្យសម្រាប់ប្រទេស ក្រសួងរ៉ែនិងថាមពលសម្រេចថា ការពង្រីកលទ្ធភាពទទួលបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយដែលទំនើបមានតម្លៃសមរម្យ អាចជឿទុកចិត្តបាននិងមាននៅគ្រប់ទីកន្លែង ក្នុងពេលជាមួយគ្នានោះ អាចបង្កើនប្រសិទ្ធភាពថាមពល បង្កើនការប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញនិងប្រភពថាមពលផ្សេងទៀតដែលមិនគ្រោះថ្នាក់ដល់បរិស្ថាន (ថាមពលជោយចីរភាព)ឱ្យកាន់តែច្រើនដើម្បីកាត់បន្ថយដង់ស៊ីតេនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ គឺជាការចាំបាច់ណាស់ សម្រាប់កម្ពុជា ក្នុងការសម្រេចគោលដៅនិងរបៀបវារៈនៃការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចផង និងគោលដៅអន្តរកាលថាមពលឆ្ពោះទៅកាន់ការកាត់បន្ថយឧស្ម័នកាបូនផង។ តាមរយៈការរៀបចំផែនការមេនេះ ក្រសួងរ៉ែនិងថាមពលបានពិនិត្យឃើញថា តាមកំណើនសេដ្ឋកិច្ចនិងតម្រូវការថាមពលដែលនឹងកើនឡើងបន្តទៀត ប្រព័ន្ធថាមពលកម្ពុជានឹងនៅបន្តពឹងផ្អែកលើការប្រើប្រាស់ឥន្ធនៈហ្វូស៊ីលខ្លះចៀសពុំរួចពាក់ព័ន្ធចំណុចនេះ រាជរដ្ឋាភិបាលបានសម្រេចថា មិនរៀបចំគម្រោងអភិវឌ្ឍរោងចក្រអគ្គិសនីដុតធ្យូងថ្មថ្មីបន្ថែមទៀតទេ ដោយប្តូរមកប្រើប្រាស់ប្រភពថាមពលកាបូនទាប ដូចជាឧស្ម័នធម្មជាតិនាំចូលប្រភេទ(LNG)ឬក៏អ៊ីដ្រូសែនជំនួសវិញ។ ជាមួយគ្នានេះដែរ នៅពេលអនាគត ដើម្បីគោលដៅអព្យាក្រឹត្យកាបូន កម្ពុជាក៏មានការចាំបាច់កែច្នៃគម្រោងមុនៗដែលប្រើឥន្ធនៈហ្វូស៊ីលឱ្យមានលក្ខណៈស្អាតផងដែរ។ ដោយប្រើប្រាស់បច្ចេកវិទ្យាថ្មី ដូចជាការចាប់យកកាបូន ការប្រើប្រាស់និងស្តុកទុកកាបូនឬបច្ចេកវិទ្យាអ៊ីដ្រូសែនជាដើម។ ចំពោះការអភិវឌ្ឍវារីអគ្គិសនី យោងតាមការគិតគូរដល់ប្រព័ន្ធអេកូឡូស៊ីផ្នែកជលសាស្ត្រ មច្ឆជាតិ និងនាវាចរលើដងទន្លេមេគង្គ រាជរដ្ឋាភិបាលបានសម្រេចថាមិនធ្វើការអភិវឌ្ឍទំនប់វារីអគ្គិសនីលើដងទន្លេមេគង្គទេ។

## ១.៤- ការបញ្ចុះថ្លៃនិងការងារសង្គមកិច្ចក្នុងវិស័យថាមពលអគ្គិសនី

ក្នុងអាណត្តិទី៦នេះ ចាប់តាំងពីឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២២ រាជរដ្ឋាភិបាលបានខិតខំបន្ថយ និងអនុគ្រោះថ្លៃអគ្គិសនីជាបន្តបន្ទាប់ ដូចខាងក្រោម៖

- ថ្លៃទិញអគ្គិសនីពីទ្វារចរន្តតង់ស្យុងខ្ពស់ ត្រូវបានកាត់បន្ថយចំនួន៥,៦៥% ពី0.1240$/kWh មក 0.1170$/kWh
- ថ្លៃទិញអគ្គិសនីពីទ្វារចរន្តតង់ស្យុងមធ្យម ត្រូវបានកាត់បន្ថយចំនួន៤% ពី0.1260$/kWh មក 0.1210$/kWh
- ឧស្សាហកម្មនិងកសិកម្មដែលទិញពីខ្សែបណ្តាញតង់ស្យុងមធ្យមកាត់បន្ថយចំនួន១៧% ពី0.1650$/kWh មក 0.1370$/kWh
- ពាណិជ្ជកម្មនិងរដ្ឋបាលដែលទិញពីខ្សែបណ្តាញតង់ស្យុងមធ្យម កាត់បន្ថយ៤,២% ពី0.1650$/kWh មក 0.1580$/kWh

- ឧស្សាហកម្ម និងកសិកម្ម ដែលទិញពីក្រោមត្រង់ស្វូចែកចាយ កាត់បន្ថយ១៧% ពី0.1719$/kWh មក 0.14248$/kWh

- ពាណិជ្ជកម្ម និងរដ្ឋបាលដែលទិញពីក្រោមត្រង់ស្វូចែកចាយ កាត់បន្ថយ៤,៤% ពី0.1719$/kWh មក 0.16432$/kWh

- អ្នកប្រើប្រាស់ទូទៅដែលទិញពីខ្សែបណ្តាញចែកចាយតង់ស្យុងទាបកាត់បន្ថយ៥,២% ពី770រៀល/kWh មក730រៀល/kWh

- បន្ថែមពីលើនោះ រាជរដ្ឋាភិបាលបានធ្វើការអនុគ្រោះថ្លៃលក់អគ្គិសនីឱ្យលំនៅដ្ឋានដែលប្រើប្រាស់ថាមពលមិនលើសពី១០គីឡូវ៉ាត់ម៉ោងក្នុងមួយខែឱ្យបង់ថ្លៃ៣៨០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង លំនៅដ្ឋានដែលប្រើប្រាស់ពី១១ ដល់៥០គីឡូវ៉ាត់ម៉ោង ក្នុងមួយខែឱ្យបង់ថ្លៃ៤៨០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង និងលំនៅដ្ឋានដែលប្រើប្រាស់ពី៥១ ដល់២០០គីឡូវ៉ាត់ម៉ោងក្នុងមួយខែឱ្យបង់ថ្លៃ៦១០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។ សាលារៀន មន្ទីរពេទ្យនិងមណ្ឌលសុខភាពនៅជនបទឱ្យបង់ថ្លៃត្រឹមតែ៦១០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។ ដើម្បីរួមចំណែកលើកស្ទួយក្នុងវិស័យការងារ រាជរដ្ឋាភិបាលបានជំរុញការពង្រីកខ្សែបណ្តាញអគ្គិសនីដោយតម្លៃទាបជូនកម្មករ និយោជិត សិស្ស និស្សិត នៅតាមផ្ទះជួល បន្ទប់ជួលដោយគិតមកដល់ត្រឹមចុងឆ្នាំ២០២២ បានចំនួន៣៤៩ ៨៥៨ បន្ទប់ជួល។

ចំពោះការងារសង្គមកិច្ចក្នុងវិស័យថាមពលអគ្គិសនីពីឆ្នាំ២០១៨ដល់ឆ្នាំ២០២២ មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ(ម.អ.ជ.) បានអនុវត្តកម្មវិធីសង្គមកិច្ចក្នុងវិស័យថាមពលបានចំនួន៧កម្មវិធី៖

១- កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រដោយការផ្តល់ប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់ដែលគោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទ ដើម្បីអាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់ឱ្យគ្រួសារជនបទខ្ចីយកទៅបង់ថ្លៃភ្ជាប់ចរន្តថ្លៃប្រាក់កក់ឱ្យអ្នកផ្គត់ផ្គង់ ចំណាយលើការទិញនិងរាយខ្សែពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះនិងចំណាយលើការរៀបចំខ្សែបណ្តាញនិងឧបករណ៍អគ្គិសនីក្នុងផ្ទះដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។ ប្រាក់កម្ចីនេះ គឺមិនលើសពី ៤៨០ ០០០រៀលក្នុងមួយគ្រួសារដែលមានគ្រួសារជនបទចំនួន៧១៧គ្រួសារ ស្មើនឹង៣ ២៩៨នាក់ បានទទួលផលប្រយោជន៍ដោយផ្ទាល់ក្រោមកម្មវិធីនេះ។

២- កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានបណ្ណសមធម៌ ដោយផ្តល់ថវិកាឧបត្ថម្ភធនចំនួន១០០ ដុល្លារអាម៉េរិកក្នុងមួយគ្រួសារសម្រាប់កាចំណាយលើសម្ភារៈនិងឈ្នួលពលកម្ម ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។ កម្មវិធីនេះ មានគ្រួសារជនបទក្រីក្រមានប័ណ្ណសមធម៌ចំនួន១៥ ១១២គ្រួសារ ស្មើនឹង៦៩ ៥១៥នាក់ បានទទួលផលប្រយោជន៍ដោយផ្ទាល់។

៣- កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រដោយផ្តល់ប្រាក់ឧបត្ថម្ភធន៥០ដុល្លារអាម៉េរិកក្នុងមួយគ្រួសារសម្រាប់ការចំណាយលើសម្ភារៈនិងឈ្នួលពលកម្មដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។ កម្មវិធីនេះមានគ្រួសារជនបទចំនួន២ ៩៤៦គ្រួសារ ស្មើនឹ១៣ ៥៥២នាក់ បានទទួលផលប្រយោជន៍ដោយផ្ទាល់។

៤- កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ ដោយផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន១០០ដុល្លារអាម៉េរិកក្នុង១ប្រព័ន្ធសម្រាប់ប្រព័ន្ធមានអានុភាព៥០វ៉ាត់និង៨០វ៉ាត់ និងឧបត្ថម្ភធនចំនួន២០០ដុល្លារអាម៉េរិកក្នុង១ប្រព័ន្ធសម្រាប់ប្រព័ន្ធមានអានុភាព២០០វ៉ាត់ និងប្រព័ន្ធមានអានុភាព៣២៥វ៉ាត់ មានផ្ទាំងដាំបាយអគ្គិសនីចំណុះ៤

លីត្រដល់គ្រួសារជនបទដែលបានទិញប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។ កម្មវិធីនេះ មានគ្រួសារជនបទចំនួន៦០ ៨៧០គ្រួសារ (១គ្រួសារ១ប្រព័ន្ធ) ស្មើនឹង២៨០ ០០២នាក់ បានទទួលផលប្រយោជន៍ដោយផ្ទាល់។

៥- កម្មវិធីជួយទុនសម្រាប់ពង្រីកនិងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទដែលគោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលដល់អ្នកផ្គត់ផ្គង់អគ្គិសនីជនបទ ដែលមានអាជ្ញាបណ្ណស្របច្បាប់អាចមានទុនសម្រាប់ធ្វើការវិនិយោគពង្រីកនិងកែលម្អការផ្គត់ផ្គង់អគ្គិសនីឱ្យពេញដែនអាជ្ញាបណ្ណចែកចាយរបស់ខ្លួន ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់គ្រួសារអាចតភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាព។ កម្មវិធីនេះ មានអ្នកកាន់អាជ្ញាបណ្ណចំនួន២៣៧ ស្មើនឹង១០ ១០៤គ.ម. រួមមានខ្សែបណ្ដាញតង់ស្យុងមធ្យមប្រវែង៣ ៦៧៣គ.ម. និងខ្សែចែកចាយតង់ស្យុងទាបប្រវែង៦ ៤៣១គ.ម. ដោយគ្របដណ្ដប់ចំនួន២៣ខេត្ត បានទទួលផលប្រយោជន៍ដោយផ្ទាល់។

៦- កម្មវិធីផ្ដល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនីដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយបណ្ដាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រ បន្ថយអត្រានិងគម្លាតថ្លៃលក់អគ្គិសនីសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២២ តាមបណ្ដាខេត្ត និងរាជធានី។ កម្មវិធីនេះ បានសម្រេចលទ្ធផលៈ (១)ផ្ដល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណចំនួន៣៩០ តំបន់អាជ្ញាបណ្ណ និង(២) ផ្ដល់ឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីចំនួន១ ៦៣៦ ៤០០ ៨៤៧ ៦៩៦រៀល ស្មើនឹង៥ ១៧៦ ៩០៥ ៩៦៨គីឡូវ៉ាត់ម៉ោង ដើម្បីបន្ថយថ្លៃលក់អគ្គិសនីតាមបណ្ដារាជធានី ខេត្ត។

៧- កម្មវិធីផ្ដល់ការផ្គត់ផ្គង់អគ្គិសនីដើម្បីបូមទឹកធ្វើកសិកម្មដែលគោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារជនបទទទួលបានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្ដាញជាតិផ្ទាល់ សម្រាប់ការបូមទឹកធ្វើកសិកម្មនៅតម្លៃអនុគ្រោះត្រឹមតែ៤៨០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់អគ្គិសនីបូមទឹកធ្វើកសិកម្មនៅពេលយប់ពីម៉ោង៩យប់ ដល់ម៉ោង៧ព្រឹក និងនៅតម្លៃធម្មតាសម្រាប់ការប្រើប្រាស់អគ្គិសនីបូមទឹកធ្វើកសិកម្មនៅពេលថ្ងៃពីម៉ោង៧ព្រឹកដល់ម៉ោង៩យប់។ កម្មវិធីនេះ បានសាងសង់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ដើម្បីបូមទឹកក្នុងវិស័យកសិកម្មដល់អ្នកកាន់អាជ្ញាបណ្ណចំនួន១៥ តំបន់អាជ្ញាបណ្ណសរុបបានប្រវែង៥៣៨គ.ម. រួមមានខ្សែបណ្ដាញតង់ស្យុងមធ្យមប្រវែង២៣៣គ.ម. និងខ្សែចែកចាយតង់ស្យុងទាបប្រវែង៣០៥គ.ម. ដែលគ្របដណ្ដប់លើខេត្តចំនួន៦បានទទួលផលប្រយោជន៍ដោយផ្ទាល់។

| ល.រ | ប្រភេទនៃអ្នកប្រើប្រាស់ និងលក្ខខណ្ឌទិញ | អាត្រាថ្លៃលក់ ២០១៨ | អាត្រាថ្លៃលក់ ២០២២ | ការកាត់បន្ថយអាត្រាថ្លៃលក់ |
|---|---|---|---|---|
| ១ | ថ្លៃទិញអគ្គិសនីពីទ្វារចរន្តតង់ស្យុងខ្ពស់ | 0.1240$/kWh | 0.1170$/kWh | -5.65% |
| ២ | ថ្លៃទិញអគ្គិសនីពីទ្វារចរន្តតង់ស្យុងមធ្យម | 0.1260$/kWh | 0.1210$/kWh | -4% |
| ៣ | ឧស្សាហកម្ម និងកសិកម្មដែលទិញពីខ្សែបណ្ដាញតង់ស្យុងមធ្យម | 0.1650$/kWh | 0.1370$/kWh | -17% |
| ៤ | ពាណិជ្ជកម្ម និងរដ្ឋបាលដែលទិញពីខ្សែបណ្ដាញតង់ស្យុងមធ្យម | 0.1650$/kWh | 0.1580$/kWh | -4.2% |
| ៥ | ឧស្សាហកម្ម និងកសិកម្មដែលទិញពីក្រោមត្រង់ស្វូចែកចាយ | 0.1719$/kWh | 0.14248$/kWh | -17% |
| ៦ | ពាណិជ្ជកម្ម និងរដ្ឋបាលដែលទិញពីក្រោមត្រង់ស្វូចែកចាយ | 0.1719$/kWh | 0.16432$/kWh | -4.4% |
| ៧ | អ្នកប្រើប្រាស់ទូទៅដែលទិញពីខ្សែបណ្ដាញចែកចាយតង់ស្យុងទាប | ៧៧០រៀល/kWh | ៧៣០រៀល/kWh | -5.2% |

២- អភិវឌ្ឍនិងគ្រប់គ្រងការងារបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម

ចំពោះការអភិវឌ្ឍនិងគ្រប់គ្រងការងារបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម ក្រសួងរ៉ែនិងថាមពលបានរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្តនៃថាមពលបរមាណូស៊ីវិល រួមមាន៖ ១- ប្រកាសលេខ០១២៦ រថ.វបប.រថ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រងការនាំចូលនិងការប្រើប្រាស់សារធាតុវិទ្យុសកម្មនិងប្រភពវិទ្យុសកម្ម ២- ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាស្តីពីជំនួយក្នុងករណីមានគ្រោះមហន្តរាយនុយក្លេអ៊ែរ ឬគ្រោះអាសន្នវិទ្យុសកម្ម ៣- សេចក្តីព្រាងច្បាប់បរមាណូនៃព្រះរាជាណាចក្រកម្ពុជាសម្រេចបាន៥៥% និង៤- សេចក្តីព្រាងបទដ្ឋានបច្ចេកទេសស្តីពីសុវត្ថិភាព និងសន្តិសុខសម្រាប់ការប្រើប្រាស់វិទ្យុសកម្មសម្រេចបាន៥០%។ ក្នុងការគ្រប់គ្រងលើការងារបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម ក្រសួងបានចុះធ្វើការត្រួតពិនិត្យក៏ដូចជាស្រង់ទិន្នន័យលើការប្រើប្រាស់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យាថាមពលបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្មនៅតាមទីតាំងនានា ដូចជាការដ្ឋានរ៉ែ រោងចក្រស៊ីម៉ងត៍ មន្ទីរពេទ្យ មន្ទីរពិសោធន៍ សរុបបានចំនួន៧៤ ទីតាំង ហើយបានធ្វើការវាយតម្លៃថាការប្រើប្រាស់ទាំងនោះ គឺមានសុវត្ថិភាព សន្តិសុខ និងក្នុងគោលបំណងសន្តិភាពពិតប្រាកដ។

៣- ពង្រឹងការអនុវត្តប្រសិទ្ធភាពការងារ និងគាំទ្រប្រតិបត្តិការអភិវឌ្ឍវិស័យថាមពលនិងផ្នែកបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម

-បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទក្នុងក្របខ័ណ្ឌអាស៊ាន និងអន្តរជាតិផ្សេងៗតាមរយៈអនឡាញ

-បានរៀបចំកិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ពាក់ព័ន្ធនឹងការងារវិស័យថាមពល និងបានចូលរួមសិក្ខាសាលា និងកិច្ចប្រជុំពាក់ព័ន្ធក្នុងប្រទេស

-ក្នុងកិច្ចគាំទ្រប្រតិបត្តិការអភិវឌ្ឍផ្នែកបរិមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម ក្រសួងបានដឹកនាំនិងសម្របសម្រួលអនុវត្តគម្រោងបច្ចេកទេសរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធជាមួយនឹងប្រទេស និងអង្គការអន្តរជាតិជាដៃគូ រួមមានទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ (IAEA) សហគមន៍អឺរ៉ុប សហរដ្ឋអាម៉េរិក ប្រទេសវៀតណាម ជាដើម ដោយទទួលបានជំនួយជាការបណ្តុះបណ្តាល និងឧបករណ៍សម្ភារៈបច្ចេកទេស គិតជាថវិកាសរុបប្រមាណ ៨០០ ០០០ ទៅ ១ ០០០ ០០០អឺរ៉ូក្នុងមួយឆ្នាំៗ។ ក្នុងបរិបទនៃជំងឺកូវីដ-១៩ ក្រសួងបានស្នើសុំអង្គការជាដៃគូផ្តល់ជំនួយឧបករណ៍និងបរិក្ខារតេស្តមេរោគកូវីដ-១៩ ប្រភេទPCR ចំនួន៥ឈុត គិតជាថវិកាសរុបប្រមាណជា ៤០០ ០០០អឺរ៉ូ ជូនវិទ្យាស្ថានសុខភាពសាធារណៈ នៃក្រសួងសុខាភិបាល (២ឈុត) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (១ឈុត) មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តសៀមរាប (១ឈុត) និងមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តពោធិ៍សាត់(១ឈុត)។ ជាមួយគ្នានេះដែរ តាមរយៈជំនួយជាឧបករណ៍បច្ចេកទេសក្រោមគម្រោងរបស់សហគមន៍អឺរ៉ុប ក្រសួងរ៉ែនិងថាមពលបានដំឡើងស្ថានីយវាស់កម្រិតវិទ្យុសកម្មក្នុងបរិយាកាសប្រភេទGDRMSចំនួន៤ស្ថានីយ កាលពីខែសីហា ឆ្នាំ២០២២នេះ។

## មុំទី២- ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ

### ១- ការត្រួតពិនិត្យនិងអធិការកិច្ចប្រតិបត្តិការធនធានរ៉ែ និងចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ

#### ១.១- ការត្រួតពិនិត្យនិងអធិការកិច្ចប្រតិបត្តិការធនធានរ៉ែ

ក្រសួងរ៉ែនិងថាមពលបានចុះត្រួតពិនិត្យនិងធ្វើអធិការកិច្ចប្រតិបត្តិការធនធានរ៉ែជាប្រចាំដើម្បីធានាថា ការធ្វើប្រតិបត្តិការធនធានរ៉ែមានអនុលោមភាពស្របតាមបទដ្ឋានបច្ចេកទេស និងលិខិតបទដ្ឋានគតិយុត្តនានា ក្នុងគោលដៅទប់ស្កាត់ផលប៉ះពាល់បរិស្ថាននិងសង្គម និងពង្រឹងប្រសិទ្ធភាព នៃការកៀរគរការប្រមូលចំណូល មិនមែនសារពើពន្ធពីវិស័យរ៉ែ។ ជាក់ស្តែងរយៈពេល ៣ឆ្នាំចុងក្រោយនេះ ក្រុមការងារបានចុះត្រួតពិនិត្យ និងអធិការកិច្ចប្រតិបត្តិការធនធានរ៉ែដោយបានកៀរគរចំណូលបន្ថែម សរុបចំនួន**៦ ១៧៣ ៨៧០,៧៦ដុល្លារអាម៉េរិក** និងបានពិន័យជាប្រាក់សរុបចំនួន៧៨៤លានរៀល និង១២ ៣៧៦ដុល្លារអាម៉េរិក តាមឆ្នាំដូចខាងក្រោម៖

- ឆ្នាំ២០២០ បានប្រមូលចំណូលបន្ថែមចំនួនប្រមាណ៩៥៦ ៩០៣,៧៣ដុល្លារអាម៉េរិក និងបានពិន័យជាប្រាក់ចំនួន ១៨៩លានរៀល
- ឆ្នាំ២០២១ បានប្រមូលចំណូលបន្ថែមចំនួនប្រមាណ៤ ២៦៧ ១៤៤,២៤ដុល្លារអាម៉េរិក និងបានពិន័យជាប្រាក់ចំនួន៣៦០លានរៀល
- ឆ្នាំ២០២២ បានប្រមូលចំណូលបន្ថែមចំនួន៩៤៩ ៨២២,៧៩ដុល្លារអាម៉េរិក និងបានពិន័យជាប្រាក់ចំនួន២៣៥លានរៀល និង១២ ៣៦៧ដុល្លារអាម៉េរិក។

### ១.២- ចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែ

រយៈពេល៥ឆ្នាំ នៃរាជរដ្ឋាភិបាលអាណត្តិទី៦នេះ អគ្គនាយកដ្ឋានធនធានរ៉ែ បានកៀរគរការប្រមូលចំណូលមិនមែនសារពើពន្ធពីវិស័យរ៉ែដូចខាងក្រោម៖




| | ២០១៧ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ច្បាប់ថវិកា | 58,966.90 | 54,916.20 | 75,120.25 | 81,070.82 | 102,399.88 | 140,923.72 |
| អនុវត្តន៍ជាក់ស្តែង | 58,250.98 | 72,849.74 | 85,983.90 | 110,145.86 | 141,236.47 | 159,332.04 |
| ធៀប (%) | 99% | 133% | 114% | 136% | 138% | 113% |

## ២- ការទាញអត្ថប្រយោជន៍ និងការគ្រប់គ្រងវិស័យប្រេងកាត

### ២.១- ការបង្កើតបន្ថែមខឿនឧស្សាហកម្មនិស្សារណកម្មពីវិស័យប្រេងកាត

រយៈពេល៥ឆ្នាំ នៃរាជរដ្ឋាភិបាលអាណត្តិទី៦នេះ ក្រសួងរ៉ែនិងថាមពលបានសម្រេចនូវសមិទ្ធផលធំៗលើការងារបង្កើតបន្ថែមខឿនឧស្សាហកម្មនិស្សារណកម្មវិស័យប្រេងកាតតាមការងារដូចខាងក្រោម៖

#### ២.១.១-ការងារសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ និងវាយតម្លៃសេដ្ឋកិច្ចនិងការរកឃើញធនធានប្រេងកាត

-លើដែនគោក៖ យើងបានបែងចែកជាប្លុកសម្រាប់ស្វែងរុករកប្រេងកាតចំនួន១៩ គឺចាប់ពីប្លុកVIII ដល់ XXVI ក្នុងនោះ ប្លុក VIII បានចុះកិច្ចព្រមព្រៀងប្រេងកាតជាមួយក្រុមហ៊ុន Enercam Resources Co., Ltd មក

ពីប្រទេសកាណាដា ដើម្បីធ្វើការសិក្សាស្វែងរុករកធនធានប្រេងកាត នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០២២។ ចំណែកប្លុកប្រេងកាតដ៏ទៃទៀតនៅទំនេររង់ចាំស្វាគមន៍អ្នកវិនិយោគ។

-លើដែនសមុទ្រ៖ យើងបានបែងចែកជាប្លុកសម្រាប់ស្វែងរុករកប្រេងកាតចំនួន ៦ គឺ A, B, C, D, E និង F ក្នុងនោះ ប្លុក A បានផលិតប្រេងលើកដំបូង និងជាប្រវត្តិសាស្ត្ររបស់កម្ពុជា នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ដោយបានផលិតប្រេងនិងលក់បានចំនួន **២៨០ ៦៥៦បារ៉ែល** ប៉ុន្តែដោយសារក្រុមហ៊ុនមេរបស់ក្រុមហ៊ុន KrisEnergy ជួបបញ្ហាក្ស័យធន បច្ចុប្បន្នក្រសួងរ៉ែ និងថាមពលកំពុងអនុញ្ញាតឱ្យក្រុមហ៊ុន Enercam Resources Co.Ltd. ធ្វើការសិក្សាទិន្នន័យនិងឋបនភណ្ឌរបស់ប្លុក A ទាំងអស់ ដើម្បីពិនិត្យលទ្ធភាពបន្តផលិតកម្មប្រេងកាតឡើងវិញ។ ចំណែកប្លុក B, C, D, E និង F នៅទំនេររង់ចាំស្វាគមន៍អ្នកវិនិយោគ។

-លើតំបន់ទាមទារដែនសមុទ្រត្រួតគ្នាជាមួយប្រទេសថៃ៖ យើងបានបែងចែកជា ៤តំបន់ គឺតំបន់ I, II, III និងIV ដោយបានចុះកិច្ចព្រមព្រៀងប្រេងកាតមានលក្ខខណ្ឌជាមួយក្រុមហ៊ុនចំនួន៥។ រហូតមកដល់ពេលនេះពុំទាន់មានសកម្មភាពស្វែងរុករកនៅតំបន់ទាំងនោះទេ ព្រោះពុំទាន់អាចស្វែងរកដំណោះស្រាយ ជាមួយភាគីថៃបាននៅឡើយ។

ទន្ទឹមនឹងការសិក្សា អង្កេត និងវាស់ស្ទង់ដោយក្រុមហ៊ុនដែលមានកិច្ចព្រមព្រៀងប្រេងកាត មន្ត្រីបច្ចេកទេសរបស់អគ្គនាយកដ្ឋានប្រេងកាតក៏បានចុះសិក្សា និងចងក្រងទិន្នន័យភូគព្ភសាស្ត្រប្រេងកាតពីសិលាប្រភពនៃសិលាសែលនៅខេត្តចំនួន១៦ ក្នុងតំបន់កូរ៉ាត តំបន់ជុំវិញបឹងទន្លេសាប អាងកំពង់សោម និងអាងព្រះ និងសិក្សាស្វែងរុករកទីតាំងជម្រាបប្រេងនៅក្នុងខេត្តចំនួន៤ នៃអាងសិលាកម្ទេចកំណកំពង់សោម ទន្លេសាប និងកូរ៉ាតដែនគោកកម្ពុជា និងបានកសាងមូលដ្ឋានទិន្នន័យរូបភូគព្ភសាស្ត្រប្រេងកាតរបស់អ្នកចុះកិច្ចព្រមព្រៀង ប្រេងកាតក្នុងប្លុក B, C, D, E, F, XI, XII, XV និង XVII ក៏ដូចជាការបោះពុម្ពផែនទីទិន្នន័យ 2D និង 3D ស៊ីស្មិកជាបណ្តើរៗ ដើម្បីជាមូលដ្ឋានក្នុងការទាក់ទាញអ្នកវិនិយោគឱ្យធ្វើការសិក្សាបន្ត។

កម្រងរូបភាពការចុះសិក្សា និងចងក្រងទិន្នន័យភូគព្ភសាស្ត្រប្រេងកាតពីសិលាប្រភពនៃសិលាសែលក្នុងតំបន់កូរ៉ាត តំបន់ជុំវិញបឹងទន្លេសាប អាងកំពង់សោម និងអាងព្រះ និងសិក្សាស្វែងរុករកទីតាំងជម្រាបប្រេងនៃអាងសិលាកម្ទេចកំណកំពង់សោម ទន្លេសាបនិងកូរ៉ាតដែនគោកកម្ពុជា៖

-ការកសាងមូលដ្ឋានទិន្នន័យរូបភូគព្ភសាស្ត្រ របស់អ្នកចុះកិច្ចព្រមព្រៀងប្រេងកាត

| ឆ្នាំ | ប្លុក | ប្រភេទនៃការវាស់ស្ទង់ | ចំនួនខ្សែ | ទំហំ | ប្រវែង/ទំហំ សរុប | ផែនទី |
|---|---|---|---|---|---|---|
| 2018 | D | 2D Seismic Survey | 105 Lines | | 5635.05 Km | Block D: 2D Seismic Base Map |
| | | 3D Seismic Survey | | 397 $Km^2$ | 397 $Km^2$ | Block D: 3D Seismic Base Map |
| 2019 | B | 2D Seismic Survey | 60 Lines | | 4646.262 Km | E92CB06 Seismic Survey Base Map |
| | | 3D Seismic Survey | | 755 $Km^2$ | 755 $Km^2$ | Block B: 3D Seismic Survey Base Map |
| 2020 | F | 2D Seismic Survey | 45 Lines | | 1416.129 Km | Block F: 2D Seismic Base Map |
| | XV | 2D Seismic Survey | 19 Lines | | 607.195 Km | Block XV: 2D Seismic Base Map |
| 2021 | C | 2D Seismic Survey | 70 Lines | | 4219.684 Km | Block C: 2D & 3D Seismic Base Map |
| | | 3D Seismic Survey | | 626.4 $Km^2$ | 626.4 $Km^2$ | |
| | XVII | 2D Seismic Survey | 7 Lines | | 293.075 Km | Block XVII: 2D Seismic Base Map |

| ឆ្នាំ | ប្លុក | ប្រភេទនៃការវាស់ស្ទង់ | ចំនួនខ្សែ | ទំហំ | ប្រវែង/ទំហំ សរុប | ផែនទី |
|---|---|---|---|---|---|---|
| 2022 | E | 2D Seismic Survey | 21 Lines | | 1260.60 Km | Block E: 2D Seismic Base Map |
| | | 3D Seismic Survey | | 397 $Km^2$ | 397 $Km^2$ | Block E: 3D Seismic Base Map |
| | XI | 2D Seismic Survey | 11 Lines | | 347.67 Km | Block XI: 2D Seismic Base Map |
| | XII | 2D Seismic Survey | 5 Lines | | 180.13 Km | Block XII: 2D Seismic Base Map |

**២.១.២- ការផ្សព្វផ្សាយព័ត៌មាននិងការទាក់ទាញវិនិយោគក្នុងវិស័យប្រេងកាត**

-បានចូលរួមពិព័រណ៌អំពីភូគព្ភសាស្ត្រតំបន់អាស៊ី និងរៀបចំសន្និសីទប្រេងនិងឧស្ម័នកម្ពុជាចំនួន៣លើកក្នុងការទាក់ទាញវិនិយោគិនក្នុងវិស័យប្រេងកាត

-បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីបច្ចុប្បន្នភាពនៃវិស័យប្រេងកាតជូនដល់សិស្ស និស្សិត យុវជន មន្ត្រីរាជការ គ្រូបង្រៀន និងព្រះសង្ឃ បានចំនួន៩ រាជធានី ខេត្ត មានអ្នកចូលរួម១ ៤៦៥នាក់

-បានជំរុញឱ្យមានការបណ្តាក់ទុនវិនិយោគសម្រាប់ផ្នែកអាប់ស្ទ្រីម (Upstream) បន្ថែមបានប្រមាណចំនួន១១៥ លានដុល្លារអាម៉េរិក ដូចខាងក្រោម៖

(ឯកតា៖លានដុល្លារអាម៉េរិក)

| ក្រុមហ៊ុន | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (ត្រឹមខែកញ្ញា) | សរុប |
|---|---|---|---|---|---|---|
| ក្រុមហ៊ុន គ្រីសអេននីជី (អប្សរា) ឯ.ក (KrisEnergy (Apsara) Company Limited) *(ប្លុក A)* | ៥,១៨ | ១៩,១៧ | ៥៩,២៧ | ២៩,៦៧ | 0,00 | **១១៣,២៩** |
| ក្រុមហ៊ុនខេមបូឌាន រីសសស៍ អេនើជី ឌីវឺឡុបមិន ឯ.ក (Cambodian Resource Energy Development Co., Ltd) *(ប្លុក D)* | | | ១,០៣ | ០,៣៧ | ០,០៥ | ១,៤៥ |
| **សរុប** | ៥,១៨ | ១៩,១៧ | **៦០,២៩** | **៣០,០៤** | **០,០៥** | **១១៤,៧៥** |

**២.១.៣- ការជំរុញប្រសិទ្ធភាពប្រតិបត្តិការប្រេងកាត ការលើកកម្ពស់ជីវភាពប្រជាជនមូលដ្ឋាន និងការលើកស្ទួយការប្រើប្រាស់ទំនិញ សេវាកម្ម និងពលកម្មក្នុងស្រុក៖**

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយជូនសាធារណជនស្តីពីទំនួលខុសត្រូវបរិស្ថាននិងសង្គមរបស់អ្នកចុះកិច្ចព្រមព្រៀងប្រេងកាតចំនួន៣ខេត្ត បានចំនួន៧ដង ដោយមានអ្នកចូលរួមប្រមាណចំនួន១ ៥០០នាក់
- បានចុះពិនិត្យកម្មវិធីទំនួលខុសត្រូវសង្គមរបស់អ្នកចុះកិច្ចព្រមព្រៀងប្រេងកាត នៅស្រុកស្ទឹងហាវ និងស្រុកព្រៃនប់ ខេត្តព្រះសីហនុចំនួន៥ដង។

**២.១.៤- ការងារដោះស្រាយតំបន់ទាមទារដែនសមុទ្រត្រួតគ្នាកម្ពុជា ថៃ**

- បានរៀបចំកិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំរវាងប្រទេសទាំងពីរ និងកិច្ចប្រជុំជាមួយអ្នកចុះកិច្ចព្រមព្រៀងប្រេងកាតមានលក្ខខណ្ឌខាងភាគីកម្ពុជាជាច្រើនលើកក្នុងកិច្ចខិតខំក្នុងការស្វែងរកដំណោះស្រាយតំបន់ទាមទារដែនសមុទ្រត្រួតគ្នាកម្ពុជា ថៃ
- បានរៀបចំទស្សនកិច្ចសិក្សាដកបទពិសោធនៅអាជ្ញាធរអភិវឌ្ឍរួមគ្នាម៉ាឡេស៊ី-ថៃ និងបានសិក្សាស្រាវជ្រាវស្តីពី "គំរូអភិវឌ្ឍរួមគ្នាម៉ាឡេស៊ី-ថៃ(MTJA)" "គំរូការស្វែងរកដំណោះស្រាយតំបន់ទាមទារដែនសមុទ្រត្រួតគ្នាអូស្ត្រាលី-ទីម័រខាងកើត" និង "នីតិសមុទ្រ" ផងដែរ។

## ២.២- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងលំហូរចំណូលជាតិពីវិស័យប្រេងកាត

- ចំណូលមិនមែនសារពើពន្ធពីវិស័យប្រេងកាតដែលប្រមូលបានចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ បានចំនួន៤៧ ២១២,០៨លានរៀល ដូចខាងក្រោម

(ឯកតា៖លានរៀល)

| ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|
| ២១ ២៥៨,៩២ | ៧ ៩៣៣,៨៩ | ១២ ៨៦៣,០៧ | ២ ២០២,០០ | ២ ៩៥៤,២០ | ៤៧ ២១២,០៨ |

- ថវិការដ្ឋបាលសម្រាប់គ្រប់គ្រងប្រតិបត្តិការប្រេងកាត ថវិកាបណ្តុះបណ្តាលធនធានមនុស្សនិងថវិកាជួលទីប្រឹក្សាដែលប្រមូលបានចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ បានចំនួន៥,២៧លានដុល្លារអាមេរិក

(ឯកតា៖លានដុល្លារអាមេរិក)

| ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|
| ០,៧២ | ០,៩៣ | ២,០៥ | ០,៨៥ | ០,៧២ | ៥,២៧ |

## ២.៣- ការការពារបរិស្ថាននិងសន្តិសុខក្នុងប្រតិបត្តិការប្រេងកាត

### ២.៣.១- ការងារគ្រប់គ្រង និងត្រួតពិនិត្យសកម្មភាពផ្នែកដោនស្ទ្រីម

-បានផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតដំណើរការបានចំនួន៧៩ ដល់សកម្មភាពពាណិជ្ជកម្មប្រេង និងឧស្ម័នឥន្ធនៈ ដូចជាការនាំចូល មណ្ឌលសន្និធិ ដឹកជញ្ជូន ការវេចខ្ចប់(បញ្ចូល)និងលក់ចែកចាយ ចាប់ពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២ ដូចខាងក្រោម៖

| លរ | ប្រភេទ | អាជ្ញាបណ្ណ | | | | | សរុប | លិខិតអនុញ្ញាតដំណើរការ | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | 2018 | 2019 | 2020 | 2021 | 2022 | | 2018 | 2019 | 2020 | 2021 | 2022 | |
| 1 | មណ្ឌលសន្និធិប្រេងឥន្ធនៈ | 3 | 2 | 3 | 1 | 4 | 13 | 2 | 1 | 5 | | 3 | 11 |
| 2 | មណ្ឌលសន្និធិឧស្ម័នឥន្ធនៈ | | 2 | 3 | 1 | 1 | 7 | | 1 | 3 | | 2 | 6 |
| 3 | មណ្ឌលសន្និធិរួមប្រេងនិងឧស្ម័នឥន្ធនៈ | | | 1 | | | 1 | | | 1 | | | 1 |
| 4 | ការនាំចូលប្រេង និងឧស្ម័នឥន្ធនៈ | | | 1 | 4 | 2 | 7 | | | | | | |
| 5 | ការដឹកជញ្ជូនឧស្ម័នឥន្ធនៈ | | | 1 | | 1 | 2 | | | | | | |
| 6 | ការវេចខ្ចប់ឧស្ម័នអិលភីជី | | | 7 | 5 | 2 | 14 | | | 2 | 3 | 2 | 7 |
| 7 | ការផ្គត់ផ្គង់ និងចែកចាយឧស្ម័នឥន្ធនៈ អិលភីជី តាមបំពង់បង្ហូរ | | | | 1 | | 1 | | | | 1 | | 1 |
| 8 | សន្និធិឧស្ម័នអិលភីជី ក្នុងកំប៉ុង/ធុង ដើម្បីលក់ | | | | 1 | | 1 | | | | 7 | | 7 |
| សរុបរួម | | 3 | 4 | 16 | 13 | 10 | 46 | 2 | 2 | 11 | 11 | 7 | 33 |

-បានផ្តល់វិញ្ញាបនបត្របញ្ជាក់បច្ចេកទេស និងលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងនិងឧស្ម័នឥន្ធនៈ ចំនួន ៣ ១៤៩ ចាប់ពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២ ដូចខាងក្រោម៖

| ល.រ | ប្រភេទ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ១ | វិញ្ញាបនបត្របញ្ជាក់បច្ចេកទេស | ១០០ | ៨៧ | ៤២ | ១១៦ | ៦៥ | ៤១០ |
| ២ | លិខិតអនុញ្ញាតដំណើរការ | ៩២ | ១១៥ | ៧៥៨ | ១ ២០០ | ៥៧៤ | ២ ៧៣៩ |
| សរុបរួម | | ១៩២ | ២០២ | ៨០០ | ១ ៣១៦ | ៦៣៩ | ៣ ១៤៩ |

-បានចុះផ្សព្វផ្សាយនិងជំរុញឱ្យស្ថានីយប្រេងនិងឧស្ម័នឥន្ធនៈ មកដាក់ពាក្យសុំច្បាប់និងមានច្បាប់កើនពី១៥% នៅឆ្នាំ២០១៨ មក៧៦% នៅត្រឹមខែកញ្ញា ឆ្នាំ២០២២ ដូចខាងក្រោម៖

| ឆ្នាំ | ចំនួនស្ថានីយសរុប | ចំនួនស្ថានីយបានដាក់ពាក្យស្នើសុំ និងមានច្បាប់ | ចំនួនស្ថានីយមិនទាន់បានដាក់ពាក្យស្នើសុំច្បាប់ | ភាគរយស្ថានីយបានដាក់ពាក្យស្នើសុំ និងមានច្បាប់ |
|---|---|---|---|---|
| ២០១៨ | ៣ ៧៧៨ | ៥៦៩ | ៣ ២០៩ | ១៥% |
| ២០១៩ | ៤ ២០០ | ៧០៥ | ៣ ៤៩៥ | ១៧% |
| ២០២០ | ៤ ៧៨៦ | ២ ៧០៧ | ២ ០៧៩ | ៥៧% |
| ២០២១ | ៥ ៣៦១ | ៣ ៥៣៥ | ១ ៨២៦ | ៦៦% |
| ២០២២ | ៥ ៦៨៨ | ៤ ៣២២ | ១ ៣៦៦ | ៧៦% |

## ៣- វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រេចការងារបានដូចខាងក្រោម៖

### ៣.១- កិច្ចការឧស្សាហកម្ម

#### ៣.១.១- ការងាររោងចក្រ

គិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០២២ នេះ ការងារគ្រប់គ្រងទិន្នន័យ ស្ថិតិរោងចក្រ មានដូចខាងក្រោម៖

-រោងចក្រធុនធំដំណើរការមានចំនួន**១ ៩៦២រោងចក្រ** ស្ថិតនៅក្នុង២៥ រាជធានី ខេត្ត មានការកើនឡើងចំនួន**៤៣៤រោងចក្រ** ស្មើនឹង២៨,៤០% បើប្រៀបធៀបទៅនឹងឆ្នាំ២០១៨

-រោងចក្រធុនធំកើតថ្មីមានចំនួន **៩៨៧រោងចក្រ** និងបិទទ្វារឈប់ដំណើរការមានចំនួន **៥៤៧ រោងចក្រ**។




#### ៣.១.២- កម្លាំងពលកម្ម

កម្លាំងពលកម្មសរុបគិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០២២ នេះ មានចំនួន**១ ០៤២ ៧៨២**នាក់ ក្នុងនោះស្រីចំនួន**៧៩០ ២១៦**នាក់ ស្មើនឹង**៧៥,៧៨%** កើនឡើងចំនួន**៦៩ ៦៥៣**នាក់ ស្មើនឹង**៧,១៦%** បើធៀបទៅនឹងឆ្នាំ២០១៨។ ក្នុងរយៈពេលពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២២ នេះ រួមមាន៖

- កម្លាំងពលកម្មកើតថ្មីមានចំនួន៩៥ ៣៦៣នាក់ (ស្រី៦២ ៤៣៣នាក់ ស្មើនឹង៦៥,៤៧%)

- កម្លាំងពលកម្មថយចុះមានចំនួន**៣៩ ២៥៨**នាក់ (ស្រីមានចំនួន**៣១ ២៧៥**នាក់ ស្មើនឹង**៧៩,៦៧%**)

- កម្លាំងពលកម្មបាត់បង់ការងារដោយសាររោងចក្របិទទ្វារឈប់ដំណើរការមានចំនួន**២៨ ៦៤០** នាក់ (ស្រីមានចំនួន**២១ ៥៤៦**នាក់ ស្មើនឹង**៧៥,២៣%**)។




ទុនវិនិយោគសរុបគិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០២២ នេះ មានចំនួនជាង**១៥ ៩៥៣,៤លានដុល្លារអាម៉េរិក** កើនឡើងចំនួនជាង**៥ ៧៤៥,៤លានដុល្លារអាម៉េរិក** ស្មើនឹង**៥៦,២៨%** បើធៀបទៅនឹងឆ្នាំ២០១៨។




### ៣.១.៤- តម្លៃបរិមាណផលិតផល

តម្លៃបរិមាណផលិតផលសរុបពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២២ នេះ មានចំនួនជាង**១១ ៩៩៦,១** លានដុល្លារអាម៉េរិក។ ក្នុងនោះតម្លៃបរិមាណផលិតផលសម្រាប់បម្រើទីផ្សារក្នុងស្រុក និងសម្រាប់ធ្វើការនាំចេញ មានដូចខាងក្រោម ៖

- **ក្នុងស្រុក** ៖ មានចំនួនជាង**៣ ៣៩១,៧លានដុល្លារអាម៉េរិក**
- **នាំចេញ** ៖ មានចំនួនជាង**៨ ៦០៤,៣លានដុល្លារអាម៉េរិក**។




### ៣.១.៥- កម្រងសេវាសាធារណៈ

ការផ្តល់សេវាសាធារណៈពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២២ នេះ មានចំនួន**៥៧៧**ឯកសារ។ ក្នុងរយៈពេល៥ឆ្នាំ (ឆ្នាំ២០១៨-ខែកញ្ញា ឆ្នាំ២០២២) ការផ្តល់សេវាសាធារណៈមានចំនួន**៣ ៣១១**ឯកសារ។






### ៣.១.៦- ការងារចុះបញ្ជី

គិតចាប់ពីឆ្នាំ២០១៨ ដល់ត្រឹមខែតុលា ឆ្នាំ២០២២ នេះ រួមមានដូចខាងក្រោម ៖

| ល.រ | សំណុំលិខិតស្នើសុំ និងផ្តល់ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ខែតុលា ឆ្នាំ២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ១ | ទទួលសំណុំលិខិតស្នើសុំប្រកាសនីយបត្រតក្កកម្ម | ១៦២ | ៣១២ | ២៥៣ | ១៣៣ | ១២៤ | ៩៨៤ |
| ២ | ផ្តល់ប្រកាសនីយបត្រតក្កកម្ម | ៥៦ | ៧៣ | ៩៦ | ១៣៣ | ៦១ | ៤១៩ |
| ៣ | ទទួលសំណុំលិខិតស្នើសុំផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ | ១៣ | ១៤ | ៨ | ១០ | ៣ | ៤៨ |
| ៤ | ផ្តល់វិញ្ញាបនបត្រម៉ូដែលមានអត្ថប្រយោជន៍ | ៣ | ០ | ៣ | ០ | ០ | ៦ |
| ៥ | ទទួលសំណុំលិខិតស្នើសុំចុះបញ្ជីគំនូរឧស្សាហកម្ម | ២៤៩ | ២៥២ | ១៤៥ | ១៥៦ | ៦៧ | ៨៦៩ |
| ៦ | បានចុះបញ្ជីគំនូរឧស្សាហកម្ម | ២៦៩ | ២៨២ | ២៦២ | ៤៣៤ | ១៤៧ | ១៣៩៤ |




## ៣.២- ការងារទឹកស្អាត

### ៣.២.១- ការងារផលិតកម្មទឹកស្អាតសាធារណៈរាជធានី ខេត្ត និងឯកជនទូទាំងប្រទេស

ក្នុងរយៈពេល៥ឆ្នាំ (២០១៨-២០២២) សកម្មភាពផលិតទឹកស្អាតសាធារណៈរាជធានី ខេត្ត និងឯកជននៅទូទាំងប្រទេសបានចំនួន**១ ៨០៤ ៥៣០ ៨៣៧ម៣** គឺមានការកើនឡើង**៦១%** បើធៀបទៅនឹងអណត្តិទី៥ (២០១៣-២០១៧) នៃរាជរដ្ឋាភិបាល ដែលមានត្រឹម**១ ១២៤ ៩២៧ ២០០ម៣**។ កំណើននេះ គឺដោយមានគម្រោងរបស់បណ្តាដៃគូអភិវឌ្ឍន៍នានា ជាពិសេសការពង្រីកប្រព័ន្ធ និងបណ្តាញចែកចាយ និងការពង្រឹងនិងពង្រីកសមត្ថភាពផលិតទឹកស្អាតរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតផងដែរ។

ជាមួយគ្នានេះដែរ ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជនបានកើនឡើងគួរឱ្យកត់សម្គាល់ជាពិសេសក្នុងកំលុងពេល៥ឆ្នាំក្នុងអណត្តិទី៦ នៃរាជរដ្ឋាភិបាលនេះ។ ប្រជាពលរដ្ឋចំនួន**១ ១៨៤ ៥២៨**គ្រួសារ ដែលស្មើប្រមាណ**៥ ៩២២ ៦៤០**នាក់ បានភ្ជាប់និងប្រើប្រាស់ទឹកស្អាត។

ទន្ទឹមនឹងនេះ ក្រសួងបានយកចិត្តទុកដាក់អនុវត្តគោលនយោបាយឧបត្ថម្ភធន សម្រាប់ប្រជាពលរដ្ឋក្រីក្រដែលមានប្រាក់ចំណូលទាប ដើម្បីទទួលបានការប្រើប្រាស់ទឹក ដែលមានតម្លៃថោកក្នុងកម្រិតអប្បបរមា ក្នុងនោះប្រជាពលរដ្ឋក្រីក្រចំនួន**៧៧ ៣៨២**គ្រួសារ បានទទួលនូវការឧបត្ថម្ភធនសម្រាប់ការតភ្ជាប់បណ្តាញទឹកស្អាត។ លើសពីនេះទៀត ក្រសួងបានកំណត់ថ្លៃលក់ទឹកស្អាតនៅក្នុងរាជធានីភ្នំពេញ និងចុះកិច្ចសន្យាជាមួយម្ចាស់ផ្ទះជួល**៧០០**រៀល/ម៣ ហើយ ម្ចាស់ផ្ទះជួលលក់ឱ្យកម្មករ កម្មការិនី សិស្ស និស្សិត ក្នុងតម្លៃ**៨០០**រៀល/ម៣។ បច្ចុប្បន្នសម្រេចតភ្ជាប់បណ្តាញទឹកស្អាតបានចំនួន**៤ ៩៩០**ផ្ទះ និងអគារដែលមានបន្ទប់ជួលចំនួន**១០៧ ៨៦៩**បន្ទប់។

**តារាងទី១៖ ក្នុងបរិមាណផលិតកម្មទឹកស្អាតរយៈពេល៥ឆ្នាំ**

| បរិយាយ | ២០១៨ (ម៣) | ២០១៩ (ម៣) | ២០២០ (ម៣) | ២០២១ (ម៣) | ២០២២ (ម៣) | សរុប ៥ ឆ្នាំ (ម៣) |
|---|---|---|---|---|---|---|
| រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | ២០៧ ៧៨៧ ៩៤៩ | ២២១ ៥០៩ ២១៤ | ២៣២ ៦៩១ ៦៤៣ | ២២៦ ៦៩០ ២២៨ | ២១៦ ៦០៤ ៩៣៤ | ៣ ២០៥ ២៨៣ ៩៦៨ |
| រដ្ឋាករទឹកស្វយ័តសៀមរាប | ៦ ១២៨ ៥១០ | ៦ ៩៧២ ០១០ | ៦ ៣៦២ ៨១០ | ៥ ៩២៨ ៩៥៧ | ៧ ០១៩ ៧១៦ | ៣២ ៤១២ ០០៣ |
| រដ្ឋាករទឹកសាធារណៈ | ៣១ ៧០៥ ១៤៤ | ៣៧ ៣៥១ ៣៥៨ | ២៩ ៣៤៩ ៩៧៦ | ៣១ ១៥៩ ៤៩៩ | ៣២ ០១១ ៣២៦ | ១៦១ ៥៧៧ ៣០៣ |
| ក្រុមហ៊ុនទឹកស្អាតឯកជន | ៦៣ ៣០១ ១៣១ | ៨១ ០៨៨ ៤៣៤ | ១០៨ ៦២៧ ៨៩២ | ១១៩ ៣៥៥ ៥៥៩ | ១៣៣ ០៣១ ៤០០ | ៤៨៨ ៤៣៣ ៣៩៦ |
| សរុប | ៣០៨ ៩២២ ៧៣៤ | ៣៤៦ ៩២១ ០១៦ | ៣៧៨ ០៥៥ ៩៤០ | ៣៨៣ ១៣៤ ២៤៣ | ៣៨៨ ៦៦៧ ៣៧៦ | ១ ៨០៤ ៥៣០ ៨៣៧ |

គិតត្រឹមឆ្នាំ២០២២ បណ្តាញចែកចាយទឹកស្អាតសរុបទូទាំងប្រទេស ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

**តារាងទី២៖ ប្រវែងបណ្តាញសរុបតាមបណ្តាឆ្នាំនីមួយៗ**

| ប្រតិបត្តិករ | ២០១៨(គម) | ២០១៩(គម) | ២០២០(គម) | ២០២១(គម) | ២០២២(គម) |
|---|---|---|---|---|---|
| ប្រវែងបណ្តាញសរុប | N/A | ១៥ ៣០៩ | ១៩ ៤១៧ | ២២ ៩១៩ | ៣០ ៥០៦ |

### ៣.២.២- ការផ្តល់ប្រកាសអនុញ្ញាត

ក្នុងរយៈពេល៥ឆ្នាំមកនេះ គោលការណ៍សិក្សាសមិទ្ធិលទ្ធភាព និងប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដែលបានផ្តល់ជូនប្រតិបត្តិករ រួមមាន ៖

- គោលការណ៍សិក្សាសមិទ្ធលទ្ធភាព ចំនួន២០២ទីតាំង
- ប្រកាសអនុញ្ញាតផ្ទាល់ឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ចំនួន១២១ទីតាំង
- ប្រកាសអនុញ្ញាតជំនួសឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ចំនួន៧៩ទីតាំង

- ប្រកាសអនុញ្ញាតអចិន្ត្រៃយ៍ឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ចំនួន៥ទីតាំង។

**តារាងទី៣៖ ទិន្នន័យចេញប្រកាសអនុញ្ញាត និងគោលការណ៍សិក្សាសមិទ្ធិលទ្ធភាពធៀបក្នុងឆ្នាំ២០១៨-២០២២**

| បរិយាយសកម្មភាព | អនុវត្តឆ្នាំ២០១៨ ដល់ ២០២២ |
|---|---|
| គោលការណ៍សិក្សាសមិទ្ធិលទ្ធភាព | ២០២ |
| ចេញប្រកាសអនុញ្ញាត | ១២១ |
| ចេញប្រកាសប្រកួតប្រជែង | ៤ |
| ចេញប្រកាសជំនួស | ៧៩ |
| ចេញប្រកាសអចិន្ត្រៃយ៍ | ៥ |

ក្រាហ្វិចកំណើនចំនួនប្រកាសអនុញ្ញាតសរុប




**តារាងទី៤៖ ស្ថិតិប្រកាសអនុញ្ញាតធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតសរុប**

| ប្រភេទនៃប្រកាសអនុញ្ញាតធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត | ចំនួនសរុប |
|---|---|
| ១- ប្រកាសអនុញ្ញាតអចិន្ត្រៃយ៍ | ១០ |
| ២- ប្រកាសអនុញ្ញាតផ្ទាល់ | ១៩៨ |
| ៣- ប្រកាសអនុញ្ញាតជំនួស | ១១៨ |
| ៤- ប្រកាសអនុញ្ញាតប្រកួតប្រជែង | ១៦ |
| ៥- ប្រកាសអនុញ្ញាត ៣ឆ្នាំ និងប្រកាសពីអតីតMIME | ១៩ |
| *សរុប (ត្រឹមខែកញ្ញា ឆ្នាំ២០២២)* | *៣៦១* |

### ៣.២.៣- ការងារគម្រោង និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ

**- គម្រោងអភិវឌ្ឍន៍សមត្ថភាព**

គម្រោងពាក់ព័ន្ធវិស័យទឹកស្អាតទាំងអស់ដែលកំពុងអនុវត្តមានចំនួន**១៩**គម្រោង ដែលក្នុងនោះគម្រោងកសាងសមត្ថភាពមានចំនួន **៥**គម្រោង និងគម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធមានចំនួន **១៤**គម្រោង។ សរុបថវិកា

ហិរញ្ញប្បទានរបស់គម្រោងទាំង១៩ មានចំនួនប្រមាណ**៧៤៧,៤៩លានដុល្លារអាម៉េរិក** ដែលក្នុងនោះហិរញ្ញប្បទានឥតសំណងមានចំនួនប្រមាណ**១២៩,៤៩លានដុល្លារអាម៉េរិក** និងហិរញ្ញប្បទានសម្បទានមានចំនួនប្រមាណ**៦១៨លានដុល្លារអាម៉េរិក**។

## ៣.៣- ការងារស្តង់ដារូបនីយកម្ម

ដោយឈរលើគោលការណ៍ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម សិប្បកម្ម និងសេវាកម្ម ដើម្បីបង្កើនសមត្ថភាពក្នុងការប្រកួតប្រជែងទាំងទីផ្សារក្នុងស្រុកនិងបរទេស តាមរយៈការពង្រឹងគុណភាព និងសុវត្ថិភាព ប្រសិទ្ធភាព ផលិតកម្ម និងសេវាកម្មស្របទៅតាមស្តង់ដាជាតិ និងអន្តរជាតិ ក៏ដូចជាចូលរួមចំណែកក្នុងការការពារសុវត្ថិភាព និងសុខុមាលភាព អ្នកប្រើប្រាស់សាធារណៈ បរិស្ថាន និងសេដ្ឋកិច្ចនោះ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ដោយគិតពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ វិទ្យាស្ថានស្តង់ដាកម្ពុជាដែលជាលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាស្តង់ដាជាតិ បានរៀបចំនិងបានដាក់ឱ្យក្រុមប្រឹក្សាស្តង់ដាជាតិអនុម័តនូវស្តង់ដាជាតិបានចំនួន**៩៧៨**ស្តង់ដា។ បរិមាណស្តង់ដាដែលបានអនុម័តនេះ មានការកើនឡើងរហូតដល់**២៦,៧**ដង បើប្រៀបធៀបទៅនឹងមុនឆ្នាំ២០១៨ ដែលមានតែ**៣៨**ស្តង់ដាប៉ុណ្ណោះ។ ជារួម មកទល់ពេលនេះ កម្ពុជាមានស្តង់ដាជាតិចំនួន**១០១៦** ស្តង់ដា ដែលស្តង់ដារទាំងនេះហៅកាត់ថា "ស្តង់ដាកម្ពុជា" ត្រូវបានគ្របដណ្តប់ទៅតាមវិស័យ ដូចខាងក្រោម៖

**លទ្ធផលនៃការអភិវឌ្ឍស្តង់ដាររយៈពេល ៥ ឆ្នាំ (២០១៨-២០២២)**

| ល.រ | ស្តង់ដារ | មុនឆ្នាំ២០១៨ | | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | Std | Rev | Std | Rev | Std | Rev | Std | Rev | Std | Rev | Std | Rev | |
| ១ | ម្ហូបអាហារ | 368 | 3 | 0 | 1 | 0 | 0 | 7 | 0 | 4 | 1 | 4 | 0 | 386 |
| ២ | អគ្គិសនីនិងអេឡិចត្រូនិច | 159 | 0 | 15 | 0 | 19 | 0 | 5 | 0 | 8 | 0 | 2 | 0 | 208 |
| ៣ | វិធីសាស្ត្រធ្វើតេស្ត | 172 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 172 |
| ៤ | សារធាតុគីមី | 13 | 0 | 0 | 0 | 4 | 0 | 0 | 0 | 6 | 0 | 2 | 0 | 25 |
| ៥ | សំណង់ | 28 | 0 | 0 | 0 | 0 | 0 | 0 | 0 | 3 | 0 | 0 | 0 | 31 |
| ៦ | ផលិតផលមេកានិច | 20 | 0 | 0 | 0 | 1 | 0 | 0 | 0 | 2 | 0 | 9 | 0 | 32 |
| ៧ | ផលិតផលកៅស៊ូ | 46 | 0 | 0 | 0 | 5 | 0 | 0 | 0 | 3 | 0 | 3 | 0 | 57 |
| ៨ | ផលិតផលពីឈើ | 46 | 0 | 11 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 57 |
| ៩ | ក្រមអនុវត្ត | 8 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 8 |
| ១០ | ស្តង់ដារវាក្យស័ព្ទ | 1 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1 |
| ១១ | ប្រព័ន្ធគ្រប់គ្រង | 4 | 0 | 1 | 0 | 2 | 0 | 11 | 0 | 6 | 0 | 4 | 0 | 28 |
| ១២ | នីជីថល | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 5 | 0 | 2 | 0 | 7 |
| ១៣ | គ្រឿងសំអាង | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 2 | 0 | 2 | 0 | 4 |
| សរុប | | 865 | 3 | 27 | 1 | 31 | 0 | 23 | 0 | 39 | 1 | 28 | 0 | 1016 |

### ៣.៣.១- ការងារវិញ្ញាបនបត្រកម្ម

នៅក្រោមឆត្រគ្រប់គ្រងរបស់វិទ្យាស្ថានស្តង់ដារកម្ពុជា នាយកដ្ឋានវិញ្ញាបនបត្រកម្ម ដែលជាអង្គភាពចេញវិញ្ញាបនបត្រជាតិ(National Certification Body) ទទួលបន្ទុកធ្វើការវាយតម្លៃភាពអនុលោមលើផលិតផល និងប្រព័ន្ធផលិតកម្ម ឬប្រព័ន្ធគ្រប់គ្រងដោយប្រៀបធៀបទៅនឹងការតម្រូវទាំងឡាយនៃស្តង់ដាជាតិ ដែលហៅកាត់ថា "ស្តង់ដាកម្ពុជា"។ បច្ចុប្បន្ននេះ នាយកដ្ឋានវិញ្ញាបនបត្រកម្ម បាននិងកំពុងអនុវត្តដំណើរការនៃការចេញវិញ្ញាបនបត្ររបស់ខ្លួនស្របទៅតាមការតម្រូវនៃស្តង់ដារអន្តរជាតិISO/IEC 17065 ការវាយតម្លៃភាពអនុលោមការតម្រូវ

សម្រាប់អង្គភាពចេញវិញ្ញាបនបត្របញ្ជាក់ផលិតផល ដំណើរការ និងសេវាកម្ម និងតាមស្តង់ដារអន្តរជាតិ ISO/IEC 17021 ការវាយតម្លៃភាព អនុលោម ការតម្រូវសម្រាប់អង្គភាពដែលធ្វើសវនកម្ម និងវិញ្ញាបនបត្រកម្មនៃប្រព័ន្ធគ្រប់គ្រង។

នៅក្នុងការបំពេញកាតព្វកិច្ច និងការអនុវត្តតាមការតម្រូវនៃស្តង់ដារអន្តរជាតិISO/IEC17065 និងISO/IEC17021 នាយកដ្ឋានវិញ្ញាបនបត្រកម្ម បានប្រឹងប្រែងរៀបចំនីតិវិធីសម្រាប់ការផ្តល់អាជ្ញាប័ណ្ណដល់អតិថិជន ដែលបានស្នើសុំ ដើម្បីមានសិទ្ធិប្រើប្រាស់សញ្ញាស្តង់ដាកម្ពុជាសម្រាប់បញ្ជាក់ថា ៖ ផលិតផលមួយ ឬប្រព័ន្ធផលិតកម្មមួយ ឬប្រព័ន្ធគ្រប់គ្រងមួយ ពិតជាឆ្លើយតបទៅនឹងការតម្រូវនៃស្តង់ដាកម្ពុជាដែលបានកំណត់ណាមួយ។

នៅក្នុងដំណើរការចេញវិញ្ញាបនបត្រ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ នាយកដ្ឋានវិញ្ញាបនបត្រកម្មបានអនុវត្តសកម្មភាពនិងសម្រេចលទ្ធផលមួយចំនួន ដូចខាងក្រោម ៖

**ក- ការងារជំរុញវិញ្ញាបនបត្រកម្ម**

- បានរៀបចំប្រជុំគណៈកម្មការវិញ្ញាបនបត្រកម្មផលិតផលចំនួន**២៥៦**លើក
- បានប្រជុំគណៈកម្មការវិញ្ញាបនបត្រកម្មប្រព័ន្ធចំនួន**៣៧**លើក
- បានរៀបចំបែបបទ និងនីតិវិធីនៃការចេញវិញ្ញាបនបត្របញ្ជាក់ការដាក់លក់ដោយសេរី
- បានរៀបចំបែបបទ និងនីតិវិធីនៃការចេញវិញ្ញាបនបត្របញ្ជាក់អនាម័យ
- បានចេញវិញ្ញាបនបត្រដាក់លក់ផលិតផលលើទីផ្សារដោយសេរីចំនួន**៣**មូលដ្ឋាន។

**ខ- ការងារវិញ្ញាបនបត្រកម្មផលិតផល**

- បានចុះយកគំរូផលិតផលបញ្ជូនទៅមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រួតពិនិត្យគុណភាពក្នុងការវាយតម្លៃភាពអនុលោមចំនួន**១១២៦**គំរូផលិតផល
- បានចេញលិខិតបញ្ជាក់គុណភាពសរុបចំនួន**៣០៩**លិខិត
- បានចុះត្រួតពិនិត្យខ្សែសង្វាក់ផលិតកម្មរោងចក្រ សិប្បកម្ម ដែលបានដាក់ពាក្យស្នើសុំវិញ្ញាបនបត្រអនាម័យកម្រិតបឋម វិញ្ញាបនបត្រអនាម័យកម្រិតមធ្យម និងវិញ្ញាបនបត្រផលិតផលបានចំនួន**២៣០**មូលដ្ឋាន
- ចេញវិញ្ញាបនបត្រអនាម័យកម្រិតបឋម ដែលបានផ្តល់ជូនរោងចក្រ សិប្បកម្មចំនួន**៣៩**វិញ្ញាបនបត្រ
- ចេញវិញ្ញាបនបត្រអនាម័យកម្រិតមធ្យម ដែលបានផ្តល់ជូនរោងចក្រ សិប្បកម្មចំនួន**៣១**វិញ្ញាបនបត្រ
- បានចេញវិញ្ញាបនបត្រផលិតផល ដែលបានផ្តល់ជូនរោងចក្រ សិប្បកម្មចំនួន**២៤៩**វិញ្ញាបនបត្រ
- បានចេញវិញ្ញាបនបត្របញ្ជាក់ភាពអនុលោម(CoC) ដែលបានផ្តល់ជូនក្រុមហ៊ុន រោងចក្រចំនួន**១០៥**វិញ្ញាបនបត្រ
- ចេញអាជ្ញាប័ណ្ណសម្រាប់ប្រើសញ្ញាបញ្ជាក់ផលិតផលសម្រាប់រោងចក្រ សិប្បកម្មចំនួន**៣២០**អាជ្ញាប័ណ្ណ។

**តារាងសរុបវិញ្ញាបនបត្រអនាម័យកម្រិតបឋម វិញ្ញាបនបត្រអនាម័យកម្រិតមធ្យម**
**វិញ្ញាបនបត្រផលិតផល វិញ្ញាបនបត្របញ្ជាក់ភាពអនុលោម (CoC)**
**និងអាជ្ញាប័ណ្ណសម្រាប់ប្រើសញ្ញាបញ្ជាក់ផលិតផល**




-បានផ្តល់និងបន្តផ្តល់សុពលភាពវិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងដល់ក្រុមហ៊ុន រោងចក្រ សហគ្រាសចំនួន **៣៨**វិញ្ញាបនបត្រ ដូចខាងក្រោម ៖

- ប្រព័ន្ធអនុវត្តផលិតកម្មល្អ (GMP)ចំនួន១០វិញ្ញាបនបត្រ
- ប្រព័ន្ធសុវត្ថិភាពម្ហូបអាហារ (HACCP)ចំនួន១១វិញ្ញាបនបត្រ
- ប្រព័ន្ធគ្រប់គ្រងគុណភាព (ISO 9001:2015)ចំនួន១០វិញ្ញាបនបត្រ
- ប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ (ISO 22000: 2018) ចំនួន៦វិញ្ញាបនបត្រ
- វិញ្ញាបនបត្របញ្ជាក់អនាម័យចំនួន១វិញ្ញាបនបត្រ។

**តារាងសរុបវិញ្ញាបនបត្រប្រព័ន្ធ ចាប់ពីឆ្នាំ២០១៨-២០២២ ដូចខាងក្រោម ៖**




នៅក្រោមឆត្រនៃការគ្រប់គ្រងរបស់វិទ្យាស្ថានស្តង់ដារកម្ពុជា នាយកដ្ឋានបញ្ញត្តកម្មបានដើរតួនាទីនិងបំពេញមុខងារជាអង្គភាពបញ្ញត្តករ និងអង្គភាពអធិការកិច្ចរបស់កម្ពុជា ដែលមានតួនាទីចំបង ដូចជាការចុះបញ្ជីផលិតផលដែលតម្រូវឱ្យអនុលោមតាមការតម្រូវនៃបទប្បញ្ញត្តិបច្ចេកទេស ការចុះបញ្ជីបុគ្គលឬអង្គភាព ដែលទទួល

បានវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធគ្រប់គ្រងណាមួយ និងការចេញលិខិតបញ្ជាក់នាំចេញ-នាំចូលទំនិញ ចំពោះផលិតផល ដែលត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ឬតាមការតម្រូវរបស់សមត្ថកិច្ចពាក់ព័ន្ធ និងចុះធ្វើអធិការកិច្ចនៅតាមបណ្តារោងចក្រ សហគ្រាស និងមូលដ្ឋានដែលកំពុងអនុវត្ត និងតម្រូវឱ្យអនុវត្តតាមស្តង់ដាកម្ពុជា និងបទប្បញ្ញត្តិបច្ចេកទេស។

### ៣.៣.២- ការងារបញ្ញត្តកម្ម

នៅក្នុងការបំពេញកាតព្វកិច្ច និងភារកិច្ចស្របច្បាប់របស់ខ្លួន នាយកដ្ឋានបញ្ញត្តកម្មបានអនុវត្ត និងសម្រេចការងារក្នុងរយៈពេល៥ឆ្នាំ កន្លងមកនេះ មានដូចខាងក្រោម៖

-បានរៀបចំកិច្ចប្រជុំផ្ទៃក្នុងជារៀងរាល់ខែ ដើម្បីពង្រឹងការងាររបស់នាយកដ្ឋានបញ្ញត្តកម្ម

-បានចូលរួមកិច្ចប្រជុំ គណៈកម្មាធិការសម្របសម្រួលអន្តរក្រសួងគ្រប់គ្រង និងត្រួតពិនិត្យទំនិញគ្រោះថ្នាក់ (គ.ទ.គ.ស) ចំនួន១លើក

-បានចូលរួមកិច្ចប្រជុំនៅបរទេសក្នុងគណៈកម្មការចរចាពាណិជ្ជកម្ម និងកិច្ចប្រជុំពាក់ព័ន្ធផ្សេងៗទៀត

-ចូលរួមកិច្ចប្រជុំជាមួយក្រសួងផ្សេងៗ ទាក់ទងទៅនឹងការងារបទប្បញ្ញត្តបច្ចេកទេសស្តង់ដា

-បានចូលរួមកិច្ចប្រជុំក្រុមការងារអាស៊ានផ្នែកសុវត្ថិភាពផលិតផលអគ្គីសនី និងកិច្ចប្រជុំពាក់ព័ន្ធ។ល។

-បានចុះបញ្ជិកា និងចេញទិដ្ឋាការ សម្រាប់ការទទួលបានវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធចំនួន៤៨ទិដ្ឋាការ។

**តារាងសរុបចុះបញ្ជិកា និងចេញទិដ្ឋាការ សម្រាប់ការទទួលបានវិញ្ញាបនបត្របញ្ជាក់ប្រព័ន្ធ ចាប់ពីឆ្នាំ២០១៨-២០២២**




-ចេញលិខិតបញ្ជាក់ការផ្លាស់ប្តូរផ្នែកណាមួយនៃផលិតផលយានយន្តបានចំនួន**៥៨**លិខិត

**តារាងសរុបនៃអាជ្ញាបណ្ណចុះបញ្ជីផលិតផលប្រើសញ្ញាស្តង់ដាកម្ពុជា ចាប់ពីឆ្នាំ២០១៨-២០២២**






### ៣.៣.៣- ការចូលរួមអនុវត្តកំណែទម្រង់ការងារស៊ីជម្រៅលើគ្រប់វិស័យ

១- បន្តជំរុញការផ្សព្វផ្សាយស្តង់ដាជាតិ បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោមតាមរយៈគេហទំព័រ ការបណ្តុះបណ្តាលផ្ទាល់ និងតាមប្រព័ន្ធអនឡាញ។

២- បន្តកែលម្អនីតិវិធីដើម្បីផ្តល់ភាពងាយស្រួលដល់ក្រុមហ៊ុន រោងចក្រ សិប្បកម្ម និងអាជីវករទាំងអស់ក្នុងការដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណប្រើសញ្ញាចុះបញ្ជីផលិតផល(ចបផ) ការផ្តល់អាជ្ញាប័ណ្ណប្រើសញ្ញាសុវត្ថិភាពសម្រាប់ផលិតផលអគ្គិសនីនិងអេឡិចត្រូនិក និងផលិតផលយានយន្ត ការចេញលិខិតបញ្ជាក់ទំនិញនាំចូលចំពោះផលិតផលទាំងឡាយណាដែលត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ក៏ដូចជាការចេញទិដ្ឋាការចុះបញ្ជីវិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងណាមួយ។

៣- បន្តរៀបចំនិងកែលម្អយន្តការ និងនីតិវិធី ដើម្បីពង្រឹងការគ្រប់គ្រងការប្រើប្រាស់សារធាតុគីមីស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម ដើម្បីការពារសុខុមាលភាពសាធារណៈ និងបរិស្ថាន ជាពិសេសការពារការបង្វែរសារធាតុគីមីផ្សំពីមុខជំនួញត្រឹមត្រូវស្របច្បាប់យកទៅផលិតគ្រឿងញៀន អាវុធគីមី អាវុធជីវសាស្ត្រនិងភេរវកម្ម។

៤- រៀបចំកែលម្អយន្តការ និងនីតិវិធី ព្រមទាំងវិធីសាស្ត្រពាក់ព័ន្ធនានា ឱ្យស្របតាមចរន្តនិងនិន្នាការទីផ្សារ អន្តរជាតិ សម្រាប់សកម្មភាពស្តង់ដារូបនីយកម្ម និងសកម្មភាពវាយតម្លៃភាពអនុលោមមានដូចជា ការចេញវិញ្ញាបនបត្រ បញ្ជាក់គុណភាព និងសុវត្ថិភាពផលិតផល វិញ្ញាបនបត្របញ្ជាក់ប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន ការធ្វើតេស្ត និងចូលរួមក្នុងកិច្ចការគាំពារសុវត្ថិភាព និងសុខមាលភាពសារធារណៈ។

៥- ពង្រឹងការងារអធិការកិច្ចនៅតាមក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម ដើម្បីពង្រឹងការអនុវត្តច្បាប់និងឯកសារគតិយុត្តនានាពាក់ព័ន្ធនឹងការងារអនុវត្តស្តង់ដាកម្ពុជា បទប្បញ្ញត្តិបច្ចេកទេស និងលទ្ធផលនៃការវាយតម្លៃ អនុលោមភាពក្នុងគោលដៅធានានូវសុខមាលភាពអ្នកប្រើប្រាស់និងតម្លាភាពក្នុងការធ្វើពាណិជ្ជកម្ម។

## ៣.៤- វិស័យមាត្រាសាស្ត្រជាតិ

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានជំរុញឱ្យសមត្ថកិច្ចគ្រប់គ្រង និងដឹកនាំអនុវត្តលើវិស័យមាត្រាសាស្ត្រ ប្រកបដោយភាពត្រឹមត្រូវ យុត្តិធម៌ និងភាពជឿជាក់ដោយមានការទទួលស្គាល់

សមត្ថភាពនៃមន្ទីរពិសោធន៍ព្យាសកម្មកម្រិតអន្តរជាតិ។ ដើម្បីធ្វើសុខដុមនីយកម្មជាមួយស្ថាប័នមាត្រាសាស្ត្រក្នុងតំបន់ និងអន្តរជាតិ ម.ម.ជ បានពង្រឹងសមត្ថភាពរហូតបានចូលជាសមាជិករបស់អង្គការអន្តរជាតិនានា។

**មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ** ដែលមានមន្ទីរពិសោធន៍ព្យាសកម្មនៃនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ ត្រូវបានទទួលការវាយតម្លៃទទួលស្គាល់ដោយជោគជ័យ ក្រោមកិច្ចសហការរវាង Department of Accreditation (DA) និង Bureau Of Accreditation (BoA) ឆ្លើយតបតាមតម្រូវការបទប្បញ្ញត្តិ និងលក្ខណវិនិច្ឆ័យសមត្ថភាពរបស់មន្ទីរពិសោធន៍ អនុលោមតាមស្តង់ដាISO/IEC17025:2005 និងច្បាប់ស្តីពីស្តង់ដាកម្ពុជា។ ការងារមាត្រាសាស្ត្រ ផ្តល់នូវការធានាឱ្យការធ្វើពាណិជ្ជកម្ម មានភាពយុត្តិធម៌ សមធម៌ និងត្រឹមត្រូវ ជានាផលប្រយោជន៍រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ ផលិតផលទំនិញ និងសេវាកម្ម ធ្វើឱ្យមានជំនឿ និងទំនុកចិត្តលើការប្រើប្រាស់ឧបករណ៍មាត្រាសាស្ត្រ ក្នុងសកម្មភាពពាណិជ្ជកម្ម និងវិស័យផ្សេងៗទៀត ដើម្បីសុខភាព សុវត្ថិភាព និងបរិស្ថាន។ ជាមួយនេះដែរ ការងារមាត្រាសាស្ត្រ គឺជាធាតុចូលមួយបន្ថែមទៀត រួមចំណែកក្នុងការរក្សានិរន្តរភាព និងសន្ទុះកំណើននៃសេដ្ឋកិច្ចជាតិ ដោយបានធ្វើឱ្យសម្រេចនូវសមិទ្ធផលជាច្រើន សំដៅលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ ឈានដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ក្នុងរយៈពេល៥ឆ្នាំ (២០១៨-២០២២) មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិបានសម្រេចនូវសមិទ្ធផលការងារមានដូចខាងក្រោម ៖

- **ការផ្តល់សេវាសាធារណៈ**

-បានផ្តល់វិញ្ញាបនបត្រព្យាសកម្មឧបករណ៍មាត្រាសាស្ត្រជូនក្រុមហ៊ុន រោងចក្រ សហគ្រាស និងអង្គភាពបានចំនួន៤ ៣៩៨គ្រឿង ដែលក្នុងនោះ រួមមាន ៖

- ព្យាសកម្មឧបករណ៍មាត្រាសាស្ត្រជូនក្រុមហ៊ុនឯកជន រោងចក្រ សហគ្រាសចំនួន**៣ ២៧៤**គ្រឿង
- ព្យាសកម្មឧបករណ៍មាត្រាសាស្ត្រជូនមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ និងមន្ទីរឧស្សាហកម្ម វិទ្យា-សាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្តចំនួន**១ ១២៤**គ្រឿង។

-ការត្រួតពិនិត្យផ្ទៀងផ្ទាត់រថយន្តស៊ីទែន បានចំនួន១៤៣គ្រឿង

-ការត្រួតពិនិត្យផ្ទៀងផ្ទាត់ជញ្ជីងរថយន្ត បានចំនួន២០៩គ្រឿង

-បានចេញវិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រចំនួន១ ២១៤មូលដ្ឋាន និងបន្តវិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រមូលដ្ឋាន និងបន្តវិញ្ញាបនបត្រចុះបញ្ជីមាត្រាសាស្ត្រចំនួន១ ២៧៦មូលដ្ឋានចំនួន ២ ៥៦៣មូលដ្ឋានជូនក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម និងមូលដ្ឋានធ្វើអាជីវកម្ម ដែលពាក់ព័ន្ធវិស័យមាត្រាសាស្ត្រដោយបែងចែក តាមប្រភេទអាជីវកម្ម ដូចខាងក្រោម ៖

- ចុះបញ្ជីមាត្រាសាស្ត្រ (ចុះបញ្ជីថ្មី**៩៨២**មូលដ្ឋាន និងបន្តសុពលភាពចុះបញ្ជី**១ ១២៦**មូលដ្ឋាន) លើផ្នែកស្ថានីយ៍ ដេប៉ូប្រេងឥន្ធនៈ ហ្គាសចំនួន**២ ១០៨**មូលដ្ឋាន
- ចុះបញ្ជីមាត្រាសាស្ត្រ(ចុះបញ្ជីថ្មី**២៤៣**មូលដ្ឋាន និងបន្តសុពលភាពចុះបញ្ជី**១៥៨**មូលដ្ឋាន) លើផ្នែកពាក់ព័ន្ធឧបករណ៍មាត្រាសាស្ត្រចំនួន**៤០១**មូលដ្ឋាន
- ចុះបញ្ជីមាត្រាសាស្ត្រ (ចុះបញ្ជីថ្មី**៦៨**មូលដ្ឋាន និងបន្តសុពលភាពចុះបញ្ជី**៩៣**មូលដ្ឋាន) លើផ្នែកទំនិញផលិត និងទំនិញវេចខ្ចប់ចំនួន**១៦១** មូលដ្ឋាន។

-បានចេញអាជ្ញាប័ណ្ណប្រើពាណិជ្ជសញ្ញាមាត្រាសាស្ត្រកម្ពុជាជូនក្រុមហ៊ុនចំនួន១៧ (អាជ្ញាប័ណ្ណថ្មីចំនួន៨ និងបន្តអាជ្ញាប័ណ្ណចំនួន៩)

-បានចេញអាជ្ញាប័ណ្ណផលិត ជួសជុលឧបករណ៍មាត្រាសាស្ត្រ ជូនក្រុមហ៊ុនចំនួន១១ (អាជ្ញាប័ណ្ណថ្មីចំនួន៧ និងបន្តអាជ្ញាប័ណ្ណចំនួន៤)។

**តារាង១៖ ការផ្តល់សេវាសាធារណៈព្យាសកម្មឧបករណ៍មាត្រាសាស្ត្រ**

| **ល.រ** | **បរិយាយ** | **ចំនួនឧបករណ៍ដែលបានធ្វើព្យាសកម្មប្រចាំឆ្នាំ** | | | | |
|---|---|---|---|---|---|---|
| | | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** | **ឆ្នាំ ២០២១** | **ឆ្នាំ ២០២២** |
| ១ | ក្រុមហ៊ុន រោងចក្រ សហគ្រាស | ៥៣១ គ្រឿង | ៥៦៤ គ្រឿង | ៧២៥ គ្រឿង | ៧០០ គ្រឿង | ៦៨៥ គ្រឿង |
| ២ | អង្គភាពរដ្ឋ | ១២១ គ្រឿង | ៣៧១ គ្រឿង | ២០៣ គ្រឿង | ៩៧ គ្រឿង | ៣៣២ គ្រឿង |
| **សរុបរួម** | | **៦៥២ គ្រឿង** | **៩៣៥ គ្រឿង** | **៩២៨ គ្រឿង** | **៧៩៧ គ្រឿង** | **១ ០១៧ គ្រឿង** |






## តារាង២៖ ការផ្តល់សេវាសាធារណៈត្រួតពិនិត្យផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រ

| ល.រ | បរិយាយ | ចំនួនសេវាដែលបានផ្តល់តាមឆ្នាំនីមួយៗ | | | | |
|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (ត្រឹមខែកញ្ញា) |
| ១ | ដៃបាញ់ប្រេង | ១៨ ២៩០ដៃ | ២៤ ៤៧៩ដៃ | ២៧ ៧៤២ដៃ | ២៦ ៩២០ដៃ | ២៥ ១៣៤ដៃ |
| ២ | រថយន្តស៊ីទែន | ១១៨គ្រឿង | ១០១គ្រឿង | ១១៤គ្រឿង | ៩៧គ្រឿង | ១៤៣គ្រឿង |
| ៣ | ជញ្ជីងថ្លឹងរថយន្ត | ៦១គ្រឿង | ១៦១គ្រឿង | ៧៥គ្រឿង | ១៣៣គ្រឿង | ២០៩គ្រឿង |
| ៤ | ឧបករណ៍ផ្សេងៗ | - | - | - | - | - |
| ៥ | ទំនិញវេចខ្ចប់ | ២៩ផលិតផល | ៣៧៤ផលិតផល | ៤៧៦ផលិតផល | ៤៥១ផលិតផល | ៣៥១ផលិតផល |
| ៦ | ជញ្ជីងមេកានិចតាមផ្សារ | ៨៧៧ជញ្ជីង | ១ ០៩៥ជញ្ជីង | ៤៧៦ជញ្ជីង | ២៧០ជញ្ជីង | ៣ ០១៣ជញ្ជីង |

### ផ្សាក្រាមការត្រួតពិនិត្យផ្ទៀងផ្ទាត់រថយន្តស៊ីទែននិងជញ្ជីងថ្លឹងរថយន្ត ២០១៨-២០២២




### ផ្សាក្រាមការត្រួតពិនិត្យផ្ទៀងផ្ទាត់ដៃបាញ់ប្រេង ទំនិញវេចខ្ចប់និងជញ្ជីងមេកានិចតាមផ្សារ ២០១៨-២០២២



តារាង៣៖ ការផ្តល់សេវាសាធារណៈចុះបញ្ជីមាត្រាសាស្ត្រ

ស្ថិតិចុះបញ្ជីមាត្រាសាស្ត្រ(ថ្មីនិងបន្តសុពលភាពចុះបញ្ជី) ចាប់ពីឆ្នាំ២០១៨-២០២២ (គិតត្រឹមរយៈពេល៩ខែ)




**៤- ការជំរុញវិស័យទេសចរណ៍និងផ្នែកសេវាកម្មវាន្ត**(ហ្វេសប៊ុកផេក : www.tourism.cambodia គេហទំព័រ www.cambodiatourismindustry.org)

**៤.១- ការអភិវឌ្ឍផលិតផលទេសចរណ៍**

**៤.១.១- រមណីយដ្ឋានទេសចរណ៍វប្បធម៌ ធម្មជាតិនិងកែច្នៃ**

រយៈពេល៥ឆ្នាំ (២០១៨-២០២២) រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងទេសចរណ៍ជាសេនាធិការ បានខិតខំប្រឹងប្រែងជំរុញការអភិរក្សនិងការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍នៅគ្រប់រាជធានីខេត្តទូទាំងប្រទេស។ បច្ចុប្បន្ន យើងមានរមណីយដ្ឋានទេសចរណ៍ដែលត្រូវបានចុះបញ្ជីផ្លូវការប្រមាណ៥៦០ កន្លែង រួមមានរមណីយដ្ឋានទេសចរណ៍ ១៨១កន្លែង រមណីយដ្ឋានទេសចរណ៍កែច្នៃ ៤២កន្លែង រមណីយដ្ឋានទេសចរណ៍ធម្មជាតិកែច្នៃ ២៧ កន្លែង រមណីយដ្ឋានទេសចរណ៍វប្បធម៌ ២៥កន្លែង រមណីយដ្ឋានទេសចរណ៍ប្រវត្តិសាស្ត្រ ៦៤កន្លែង រមណីយដ្ឋានទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ ១២៤កន្លែង រមណីយដ្ឋានកសិទេសចរណ៍ ១៤កន្លែង រួមជាមួយកន្លែងដែលមានសក្តានុពលទេសចរណ៍ជាច្រើនទៀតក្នុងការទទួលភ្ញៀវទេសចរ។

ទន្ទឹមនឹងនេះ ក្រសួងទេសចរណ៍ បានរៀបចំការប្រលងប្រណាំងរមណីយដ្ឋានទេសចរណ៍គំរូបានចំនួន ៣លើក ដោយជ្រើសរើសបានរមណីយដ្ឋានទេសចរណ៍ដែលមានលក្ខណៈស្តង់ដា ក្នុងនោះឆ្នាំ២០១៧ មានរមណីយដ្ឋានជ័យលាភីចំនួន ២២កន្លែង ឆ្នាំ២០១៨ មានរមណីយដ្ឋានជ័យលាភីចំនួន ២៦កន្លែង និងឆ្នាំ២០១៩ មានរមណីយដ្ឋានជ័យលាភីចំនួន ២៦កន្លែង។ ដោយឡែក ក្នុងបរិបទជំងឺកូវីដ-១៩ ក្រសួងទេសចរណ៍ បានដាក់ចេញវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា(SOP) សម្រាប់រមណីយដ្ឋានទេសចរណ៍ ដើម្បីធានាចរន្តភ្ញៀវទេសចរផ្ទៃក្នុងមិនឱ្យមានការរីករាលដាលនៃជំងឺកូវីដ-១៩។

ព្រមជាមួយនេះ តាមការប្រគល់ភារកិច្ចពីរាជរដ្ឋាភិបាល ក្រសួងទេសចរណ៍ បានរៀបចំផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ខេត្តសៀមរាប (*២០២១-២០៣៥*) ផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (*២០២១-២០៣៥*) និងផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ខេត្តកែប (២០២១-២០៣៥)។ ក្នុងន័យនេះ

រាជរដ្ឋាភិបាលបានអនុម័តដាក់ឱ្យប្រើប្រាស់ផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ខេត្តសៀមរាប (២០២១-២០៣៥) កាលពីខែមីនា ឆ្នាំ២០២១ និងផែនការមេអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី (២០២១-២០៣៥) កាលពីខែសីហា ឆ្នាំ២០២១។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានសម្រេចបង្កើតគណៈកម្មាធិការដឹកនាំអនុវត្តផែនការមេអភិវឌ្ឍន៍វិស័យទេសចរណ៍ខេត្តមណ្ឌលគិរី តាមរយៈអនុក្រឹត្យលេខ២១៤ អនក្រ.បក ចុះថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២១ ដែលមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ជាប្រធាន។

**៤.១.២-ការអភិវឌ្ឍតំបន់សមុទ្រ**

បន្ទាប់ពីបានជាប់ជាអនុប្រធានក្លឹបទទួលបន្ទុកតំបន់អាស៊ីប៉ាស៊ីហ្វិកសម្រាប់អាណត្តិទី១ កម្ពុជាបានបន្តជាប់ឆ្នោតជាអនុប្រធានក្លឹបទទួលបន្ទុកតំបន់អាស៊ីប៉ាស៊ីហ្វិកសម្រាប់អាណត្តិទី២(២០១៥-២០១៨)។ បន្ទាប់មក កម្ពុជាបានបន្តឈានមកកាន់អគ្គនាយករងក្លឹប (Directeur-Général Adjoint)សម្រាប់អាណត្តិទី៣ (២០១៨-២០២១) តាមរយៈអង្គមហាសន្និបាតក្លឹបលើកទី១៤ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៨។

ទន្ទឹមនឹងនេះ នាឱកាសប្រារព្ធពិធីបុណ្យសមុទ្រលើកទី៧ ឆ្នាំ២០១៨ នៅខេត្តកោះកុង **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានអនុញ្ញាតឱ្យលោក**ប្រ៊ូយណូ បូដាដ** (Bruno Bodard) អគ្គនាយកក្លឹប បានជួបសម្តែងការគួរសម និងពិភាក្សាការងារ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៨ នៅខេត្តកោះកុង។ ជាលទ្ធផលនៃជំនួបនេះ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានឯកភាពជាគោលការណ៍តាមសំណើរបស់លោក**ប្រ៊ូយណូ បូដាដ** (Bruno Bodard) រៀបចំមហាសន្និបាតក្លឹបលើកទី១៨ ចាប់ពីថ្ងទី៩-១៤ ខែធ្នូ ឆ្នាំ២០២២ នៅក្រុងព្រះសីហនុ និងកោះកុង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី**។

**៤.១.៣- ការងាររៀបចំសហគមន៍ទេសចរណ៍ សហគមន៍អេកូទេសចរណ៍**

រាជរដ្ឋាភិបាល បានបង្កើតក្រុមការងារអន្តរក្រសួងគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ក.គ.អ.អ. តាមរយៈសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១០០ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ដែលមានរដ្ឋមន្ត្រីក្រសួងទេសចរណ៍ជាប្រធាន រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាអនុប្រធានអចិន្ត្រៃយ៍ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអនុប្រធាន តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងគណៈអភិបាលរាជធានី ខេត្ត ជាសមាជិក។ ក្រោមកិច្ចខិតខំប្រឹងប្រែងបំពេញការងារក្នុងក្របខណ្ឌនៃក្រុមការងារអន្តរក្រសួងនេះ ការងារជាច្រើនត្រូវបានរៀបចំ និងដាក់ចេញ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានអនុម័តដាក់ឱ្យប្រើប្រាស់គោលនយោបាយជាតិអេកូទេសចរណ៍(២០១៩-២០៣០)កាលពីកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានកំណត់យកថ្ងៃទី១៩ ខែវិច្ឆិកា ជារៀងរាល់ឆ្នាំប្រារព្ធវេទិកាជាតិអេកូទេសចរណ៍ក្នុងនោះ វេទិកាជាតិអេកូទេសចរណ៍លើកទី១ អមជាមួយពិធីប្រកាសដាក់ឱ្យប្រើប្រាស់គោលនយោបាយជាតិអេកូទេសចរណ៍ ត្រូវបានរៀបចំឡើងក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាតំណាងដ៏ខ្ពង់ខ្ពស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញហើយវេទិកាជាតិអេកូទេសចរណ៍លើកទី២ ត្រូវបានរៀបចំឡើងនាថ្ងៃទី២៧ ទី២៨ ខែមករា ឆ្នាំ២០២១ នៅខេត្តសៀមរាប ក្រោមអធិបតីភាពឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានក្រុមការងារអន្តរក្រសួងក.គ.អ.អ. តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ហើយវេទិកាជាតិលើកទី៣នឹងប្រារព្ធឡើងនាថ្ងៃទី២១ ទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ ក្រោមអធិបតីភាពឯកឧត្តមអគ្គបណ្ឌិត

សភាចារ្យ**អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់**សម្តេច តេជោ នាយករដ្ឋមន្ត្រី**។

ជាលទ្ធផលការងារសំខាន់ៗនៃក្រុមការងារអន្តរក្រសួងនេះ រាជរដ្ឋាភិបាលបានសម្រេចបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍តាមរយៈអនុក្រឹត្យលេខ១២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ដោយមានរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ជាប្រធាន រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាអនុប្រធានអចិន្ត្រៃយ៍ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអនុប្រធាន និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ រួមជាមួយគណៈអភិបាលខេត្តជាសមាជិក។

ទន្ទឹមនឹងនេះ ក្រសួងទេសចរណ៍ បានរៀបចំការប្រលងប្រណាំងសហគមន៍ ទេសចរណ៍គំរូបានចំនួន ២លើក ដោយជ្រើសរើសបានរមណីយដ្ឋានទេសចរណ៍ដែលមានលក្ខណៈស្តង់ដា ក្នុងនោះ ឆ្នាំ២០១៨ មានសហគមន៍ជ័យលាភីចំនួន១៥កន្លែង និងឆ្នាំ២០១៩ មានសហគមន៍ជ័យលាភីចំនួន១៥កន្លែង ឆ្នាំ២០១៩ មានសហគមន៍ជ័យលាភីចំនួន១៨កន្លែង ហើយឆ្នាំ២០១២ មានសហគមន៍ជ័យលាភីចំនួន២១កន្លែង។ ព្រមជាមួយនេះ ក្រសួងទេសចរណ៍ បានដាក់ចេញវិធានសុវត្ថិភាពទេសចរណ៍ និងនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា (SOP) សម្រាប់សហគមន៍ទេសចរណ៍និងអេកូទេសចរណ៍ ដើម្បីជានាចរន្តភ្ញៀវទេសចរផ្ទៃក្នុងមិនឱ្យមានការរីករាលដាលនៃជំងឺកូវីដ-១៩។

### ៤.១.៤- ការងាររៀបចំព្រឹត្តិការណ៍ទេសចរណ៍

ក្នុងគោលដៅជំរុញចលនាទេសចរណ៍ក្នុងស្រុក ក៏ដូចជាការទាក់ទាញទេសចរអន្តរជាតិមកកាន់កម្ពុជាឱ្យកាន់តែច្រើនថែមទៀត ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ ក្រសួងបានរៀបចំឱ្យមានព្រឹត្តិការណ៍ទេសចរណ៍ធំៗជាច្រើនរួមមាន ពិធីបុណ្យអង្គរសង្ក្រាន្តនៅពេលបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ នៅរមណីយដ្ឋានអង្គរ ពិធីបុណ្យសមុទ្រចំនួន ៣លើក នៅតាមបណ្តាខេត្តជាប់មាត់សមុទ្រទាំង៤ រួមមាន ខេត្តកែប កំពត កោះកុង ដោយឡែកនៅខេត្តព្រះសីហនុក្នុងឆ្នាំ២០២០ ត្រូវបានលើកពេលដោយសារបញ្ហាការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ប៉ុន្តែត្រូវបានមកប្រារព្ធឆ្នាំ២០២២វិញ និងពិធីបុណ្យទន្លេចំនួន ៤លើក ក្នុងនោះរួមមានខេត្តស្ទឹងត្រែង កណ្តាល កំពង់ឆ្នាំង បាត់ដំបង និងត្រៀមរៀបចំនៅខេត្តកំពង់ធំ ក្នុងឆ្នាំ២០២៣ ព្រមទាំងព្រឹត្តិការណ៍ទេសចរណ៍ជាច្រើនទៀតដែលបានទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិរាប់សិបម៉ឺននាក់មកទស្សនា។

## ៤.២- ការគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

### ៤.២.១- ស្ថិតិឧស្សាហកម្មទេសចរណ៍

គិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០២២នេះ នៅព្រះរាជាណាចក្រកម្ពុជា មានសណ្ឋាគារសរុប៨០៩ទីតាំង ស្មើនឹង៤៨ ៩៨៧បន្ទប់ ផ្ទះភ្ញៀវមាន២ ១៤៧ទីតាំង ស្មើនឹង៣០ ២៣៣បន្ទប់ ភោជនីយដ្ឋានមាន២ ៦០៥ទីតាំង ស្មើនឹង១៥១ ២១២កៅអី ម៉ាស្សាមាន៤២២ទីតាំង ស្មើនឹង៣ ២៣៧គ្រែ/កៅអី សេវាកម្សាន្តទេសចរណ៍មាន ៩៧២កន្លែង ក្នុងនោះ(អាជីវកម្មខារ៉ាអូខេមានចំនួន៨២៨អាជីវកម្ម អាជីវកម្មរង្គសាល ឌីស្កូតែកមានចំនួន៦៩អាជីវកម្ម អាជីវកម្មបៀរហ្គាឌិនមានចំនួន៧៥អាជីវកម្ម) អាជីវកម្មកីឡាទេសចរណ៍មានចំនួន៣០អាជីវកម្ម។

ទីភ្នាក់ងារទេសចរណ៍មាន៦២៦កន្លែង ក្រុមហ៊ុនដឹកជញ្ជូនភ្ញៀវទេសចរ២៧ក្រុមហ៊ុន និងមគ្គុទ្ទេសក៍ទេសចរមាន៦ ៥១៦នាក់។

### ៤.២.២- មគ្គុទ្ទេសក៍ទេសចរណ៍

គិតត្រឹមឆ្នាំ២០២២ មានចំនួន៦៥១៦នាក់ និងមាន១២ភាសា

| ល.រ | ភាសា | សៀមរាប-អង្គរ | ភ្នំពេញ | ព្រះវិហារ | តំបន់ឆ្នេរ |
|---|---|---|---|---|---|
| ១ | ចិន | ១២៥៧ នាក់ | ២៦៦ នាក់ | - | ៥ នាក់ |
| ២ | អង់គ្លេស | ១៧១៨ នាក់ | ៣៨៦ នាក់ | - | ៣៣ នាក់ |
| ៣ | បារាំង | ៣២៤ នាក់ | ១៤៧ នាក់ | - | - |
| ៤ | អាល្លឺមង់ | ១១២ នាក់ | ៥៤ នាក់ | - | - |
| ៥ | អ៊ីតាលី | ២៩ នាក់ | ១៣ នាក់ | - | - |
| ៦ | ជប៉ុន | ៨៣៦ នាក់ | ៨៧ នាក់ | - | - |
| ៧ | កូរ៉េ | ២៦០ នាក់ | ១៣ នាក់ | - | - |
| ៨ | ម៉ាឡេស៊ី | ៥ នាក់ | ១០ នាក់ | - | - |
| ៩ | រុស្ស៊ី | ៨១ នាក់ | ២៧ នាក់ | - | - |
| ១០ | អេស្ប៉ាញ | ១៥៣ នាក់ | ២៩ នាក់ | - | - |
| ១១ | ថៃ | ៤៣៥ នាក់ | ១៥ នាក់ | - | ១ នាក់ |
| ១២ | វៀតណាម | ១២៤ នាក់ | ៨៤ នាក់ | - | ១២ នាក់ |
| **សរុប** | | **៥៣៣៤ នាក់** | **១១៣១ នាក់** | **-** | **៥១ នាក់** |

### ៤.២.៣- អំពីប្រព័ន្ធចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍

ប្រព័ន្ធចំណាត់ថ្នាក់នេះដាក់ឱ្យអនុវត្តដោយអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១១ ខែ មិថុនា ឆ្នាំ២០០៤ ស្តីពីចំណាត់ថ្នាក់សណ្ឋាគារនិងសេវាកម្មស្នាក់នៅទេសចរណ៍។

គិតត្រឹមឆ្នាំ២០២២ មានសណ្ឋាគារសរុបទូទាំងប្រទេសចំនួន៥៣សណ្ឋាគារ ត្រូវបានចាត់ថ្នាក់តាមលំដាប់ផ្កាយ ក្នុងនោះសណ្ឋាគារផ្កាយ៥ មានចំនួន១៩ទីតាំង ស្មើនឹង៥ ១៩៣បន្ទប់ សណ្ឋាគារផ្កាយ៤ មានចំនួន ១៩ទីតាំង ស្មើនឹង២ ៤៩៤បន្ទប់ សណ្ឋាគារផ្កាយ៣ មានចំនួន៩ទីតាំង ស្មើនឹង៩០៨បន្ទប់ សណ្ឋាគារផ្កាយ២ មានចំនួន៣ទីតាំង ស្មើនឹង១៤២បន្ទប់ និងសណ្ឋាគារផ្កាយ១ មាន ចំនួន៣ទីតាំង ស្មើនឹង១២៦បន្ទប់។

✡ស្ថិតិចំណាត់ថ្នាក់សណ្ឋាគារ និងសេវាស្នាក់នៅទេសចរណ៍

ស្ថិតិផលធៀបកំណើន ចំណាត់ថ្នាក់សណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍តាមលំដាប់ផ្កាយនៅទូទាំងរាជធានី ខេត្តឆ្នាំ២០១៨ ឆ្នាំ២០១៩ ឆ្នាំ២០២០ ឆ្នាំ២០២១ និងឆ្នាំ២០២២

| ល.រ. | រាជធានី ខេត្ត | ឆ្នាំ២០១៨ | | ឆ្នាំ២០១៩ | | ឆ្នាំ២០២០ | | ឆ្នាំ២០២១ | | ឆ្នាំ២០២២ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | បន្ទប់ | សរុប | បន្ទប់ | សរុប | បន្ទប់ | សរុប | បន្ទប់ | សរុប | បន្ទប់ |
| ១ | រាជធានីភ្នំពេញ | ៣៣ | ៤ ៤៩០ | ៤៥ | ៧ ១៤២ | ២៣ | ៥ ៣៧៣ | ២៥ | ៥ ៩០៨ | ២៧ | ៦ ៣៤៨ |
| ២ | ខេត្តសៀមរាប | ៦៣ | ៨ ៤៤០ | ៥៤ | ៧ ៣៨២ | ១៨ | ២ ៨៨៥ | ៧ | ៧១៥ | ៧ | ៨៨៤ |
| ៣ | ខេត្តព្រះសីហនុ | ៦ | ៨៦៥ | ១៩ | ២ ២៧០ | ១៨ | ១ ៧១៨ | ៩ | ១ ២០៧ | ១១ | ១ ២០៧ |
| ៤ | ខេត្តបាត់ដំបង | ៨ | ១ ៣០២ | ៩ | ៧២៣ | ៤ | ៤៨២ | ២ | ២៥៨ | ២ | ២៥៨ |
| ៥ | ខេត្តកំពត | ៤ | ៦៣៧ | ៥ | ៨២០ | ៥ | ៨២០ | ២ | ២០៨ | ៥ | ៨២៥ |
| ៦ | ខេត្តកែប | ៤ | ១៤៦ | ៤ | ១៤៦ | ៣ | ១២៨ | ២ | ៤២ | ២ | ៤២ |
| ៧ | ខេត្តកណ្តាល | ២ | ៧៦ | ២ | ៣៣ | ១ | ៣៣ | ០ | ០ | ០ | ០ |
| ៨ | ខេត្តកំពង់ចាម | ៨ | ៤១៤ | ១០ | ៥៥៧ | ៦ | ៣៨៦ | ០ | ០ | ០ | ០ |
| ៩ | ខេត្តស្វាយរៀង | ១ | ១៦១ | ១ | ១៨៤ | ០ | ០ | ០ | ០ | ០ | ០ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ១០ | ខេត្តមណ្ឌលគីរី | ៥ | ១៥០ | ៥ | ២៧១ | ៥ | ២៧១ | ០ | ០ | ០ | ០ |
| ១១ | ខេត្តកំពង់ធំ | ២ | ១០៧ | ២ | ១០៣ | ២ | ១០៣ | ១ | ៥៨ | ១ | ៥៨ |
| ១២ | ខេត្តពោធិ៍សាត់ | ៣ | ២៩០ | ២ | ១៨៤ | ១ | ១៤៤ | ១ | ១៤៤ | ១ | ១៤៤ |
| ១៣ | ខេត្តបន្ទាយមានជ័យ | ០ | ០ | ២ | ១០០ | ២ | ៤២ | ១ | ៤២ | ១ | ៤២ |
| **សរុប** | | ១៣៩ | ១៧ ៥១៨ | ១៦០ | ១៩ ៩៥៥ | ៨៨ | ១២ ៣៨៥ | ៥០ | ៨ ៥៨២ | ៥៧ | ៩ ៨០៨ |

ស្ថិតិសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ដែលមានចំណាត់ថ្នាក់តាមលំដាប់ផ្កាយនៅទូទាំងរាជធានីខេត្ត គិតត្រឹម១០ខែ ឆ្នាំ២០២២ មានសរុបចំនួន**៥៧ទីតាំង (ស្មើនឹង៩ ៨០៨បន្ទប់)** ដែលក្នុងនោះមានដូចជា៖

| លរ | រាជធានី ខេត្ត | ផ្កាយ១ | | ផ្កាយ២ | | ផ្កាយ៣ | | ផ្កាយ៤ | | ផ្កាយ៥ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | បន្ទប់ | សរុប | បន្ទប់ | សរុប | បន្ទប់ | សរុប | បន្ទប់ | សរុប | បន្ទប់ | សរុប | បន្ទប់ |
| ១ | រាជធានីភ្នំពេញ | ០ | ០ | ៣ | ១៤២ | ៦ | ៨៥៨ | ៩ | ១ ៥៩១ | ៩ | ៣ ៧៥៧ | ២៧ | ៦ ៣៤៨ |
| ២ | ខេត្តសៀមរាប | ០ | ០ | ០ | ០ | ០ | ០ | ៣ | ២០០ | ៤ | ៦៨៤ | ៧ | ៨៨៤ |
| ៣ | ខេត្តព្រះសីហនុ | ១ | ២៦ | ០ | ០ | ១ | ៤៦ | ៤ | ៤០៤ | ៥ | ៧៣១ | ១១ | ១ ២០៧ |
| ៤ | ខេត្តកំពត | ០ | ០ | ០ | ០ | ១ | ៥៨ | ៣ | ២០៣ | ១ | ៥៦៤ | ៥ | ៨២៥ |
| ៥ | ខេត្តកែប | ០ | ០ | ០ | ០ | ០ | ០ | ១ | ២១ | ១ | ២១ | ២ | ៤២ |
| ៦ | ខេត្តបាត់ដំបង | ០ | ០ | ០ | ០ | ១ | ១៣០ | ១ | ១២៨ | ០ | ០ | ២ | ២៥៨ |
| ៧ | ខេត្តកំពង់ធំ | ១ | ៥៨ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១ | ៥៨ |
| ៨ | ខេត្តបន្ទាយមានជ័យ | ១ | ៤២ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១ | ៤២ |
| ៩ | ខេត្តពោធិ៍សាត់ | ០ | ០ | ០ | ០ | ១ | ១៤៤ | ០ | ០ | ០ | ០ | ១ | ១៤៤ |
| **សរុប** | | ៣ | ១២៦ | ៣ | ១៤២ | ១០ | ១ ២៣៦ | ២១ | ២ ៥៤៧ | ២០ | ៥ ៧៥៧ | ៥៧ | ៩ ៨០៨ |

តារាងនេះបានបង្ហាញស្ថិតិនៅតាមបណ្តារាជធានីខេត្តត្រឹមចំនួន៩ មានន័យថាខេត្តចំនួន១៦ ផ្សេងទៀតដែលពុំមានរំលេចក្នុងតារាងនេះគឺនៅពុំទាន់មានសណ្ឋាគារ និងសេវាកម្មស្នាក់នៅទេសចរណ៍ដែលមានចំណាត់ថ្នាក់នៅឡើយទេ។

យោងតាមទិន្នន័យក្នុងតារាងខាងលើ យើងសង្កេតឃើញថា បច្ចុប្បន្នមានសណ្ឋាគារប្រមាណ៦% ប៉ុណ្ណោះ ដែលបានឆ្លងកាត់ការវាយតម្លៃនិងផ្តល់ចំណាត់ថ្នាក់ផ្កាយ។

### ៤.២.៤- ការជំរុញការអនុវត្តវិធានសុវត្ថិភាពទេសចរណ៍

បានដាក់ចេញវិធានសុវត្ថិភាពទេសចរណ៍ក្នុងជំហានទី១ មានចំនួន ៨សេវាកម្ម រួមមាន៖ (១) រមណីយដ្ឋានទេសចរណ៍(២) សហគមន៍ទេសចរណ៍ (៣) ភោជនីយដ្ឋាន និងអាហារដ្ឋានទេសចរណ៍(៤) សេវាកម្មស្នាក់នៅទេសចរណ៍ (៥) ដឹកជញ្ជូនទេសចរណ៍ផ្លូវទឹក (៦) ដឹកជញ្ជូនទេសចរណ៍ផ្លូវគោក (៧) ការីទេសចរណ៍ក្នុងស្រុក

និង (៨) មគ្គុទ្ទេសក៏ទេសចរណ៍ និងអ្នកបកប្រែភាសាបន្ត និងក្នុងជំហានទី២ មាន៦សេវាកម្ម រួមមាន៖ (១) សេវា មណ្ឌលកម្សាន្តទេសចរណ៍មនុស្សពេញវ័យ (បៀហ្គាឌិន ខារ៉ាអូខេ រង្គសាល និងឌីស្កូតែក) និង(២) សេវាកម្មស្ប៉ា និងម៉ាស្សា។

វិធានសុវត្ថិភាពទេសចរណ៍ គឺជាសូចនាករគន្លឹះជួយតម្រង់ទិសអនុវត្តរបស់អាជីវកម្មទេសចរណ៍ក្នុង "គន្លង ប្រក្រតីភាពថ្មី" ជាពិសេសការអនុវត្តវិធានការ "៣ការពារ និង៣កុំ"។

បន្ថែមលើនេះ ក្រសួងទេសចរណ៍ បានដាក់ចេញនូវនីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា សម្រាប់សេវាកម្ម នីមួយៗក្នុងទិសដៅសម្រួលដល់អាជីវកម្មអាចប្រើប្រាស់ឯកសារទាំងនេះជាឧបករណ៍ផ្សព្វផ្សាយ និងបណ្តុះបណ្តាល ដល់បុគ្គលិក។

### ៤.៣- ការខារជំរុញវិស័យទេសចរណ៍

#### ក្រសួងទេសចរណ៍

#### ក- ការសិក្សានិងផ្សព្វផ្សាយទេសចរណ៍ផ្ទៃក្នុង

ក្នុងគោលដៅជំរុញចលនាទេសចរណ៍ផ្ទៃក្នុង និងផ្សព្វផ្សាយបញ្ជ្រាបការយល់ដឹងអំពីទេសចរណ៍ឱ្យបាន កាន់តែទូលំទូលាយ ចាប់ពីឆ្នាំ២០១៧ ដល់ឆ្នាំ២០២១ ក្រសួងបានដាក់ចេញនូវយន្តការ និងការរៀបចំនិងផលិត ឯកសារផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងជាសាធារណៈជាច្រើនដែលមានដូចខាងក្រោម៖

**១- ការផ្សព្វផ្សាយទេសចរណ៍ផ្ទៃក្នុងតាមប្រព័ន្ធឌីជីថល**

ក្រសួងទេសចរណ៍បានដាក់ចេញនូវយន្តការផ្សព្វផ្សាយអំពីគោលដៅទេសចរណ៍ក្នុងស្រុក សំដៅជំរុញ ចលនាទេសចរណ៍និងផ្តល់ភាពងាយស្រួលសម្រាប់ភ្ញៀវទេសចរ ដែលមានដូចជា៖ កម្មវិធីទូរស័ព្ទចល័ត( Mobile App ) Visit Cambodia និងគេហទំព័រ Visitcambodia.com។ ទន្ទឹមនេះ ក្រសួងបានចងក្រងនិងផលិតឯកសារ អប់រំឌីជីថលដែលមានដូចជា E-journal សម្រាប់ផ្សព្វផ្សាយអំពីព័ត៌មាន និងចំណេះដឹងអំពីវិស័យទេសចរណ៍។ ជាងនេះទៅទៀត ក្រសួងបានសហការផ្សព្វផ្សាយកម្មវិធីទេសចរណ៍ជាមួយស្ថានីយទូរទស្សន៍ក្នុងស្រុកដែលមាន ដូចជាកម្មវិធី Tourism Talk Show និងកម្មវិធីខ្ញុំស្រលាញ់កម្ពុជា ជាមួយស្ថានីយទូរទស្សន៍ និងវិទ្យុអាស៊ីអាគ្នេយ៍ SEATV, កម្មវិធី "ផ្លូវទៅស្រុកវគ្គ៣" ជាមួយក្រុមហ៊ុនសប្បាយកម្រងវីដេអូផ្សព្វផ្សាយទេសចរណ៍កម្ពុជា ក្រោម ប្រធានបទ "កម្ពុជាអស្ចារ្យ-Amazing Cambodia" ជាមួយក្រុមហ៊ុន Amazing Trip Planner និងស្ប៉តវីដេអូ ផ្សព្វផ្សាយអំពីគោលដៅទេសចរណ៍ដែលមានសក្តានុពលទេសចរណ៍នានាជាច្រើនទៀត។

**២-ការជំរុញទេសចរណ៍ផ្ទៃក្នុង**

ដើម្បីជំរុញចលនាទេសចរណ៍ផ្ទៃក្នុង និងបង្កើនភាពទាក់ទាញនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងបាន រៀបចំនូវ "វិធានការគោលនយោបាយជំរុញចលនាទេសចរណ៍ផ្ទៃក្នុងឆ្នាំ២០២១-២០២៣" ដើម្បីជំរុញ និងស្តារ វិស័យទេសចរណ៍ផ្ទៃក្នុងឡើងវិញក្រោយវងវិបត្តិជំងឺកូវីដ-១៩ក៏ដូចជាបានសិក្សា និងរៀបចំ"ស្តង់ដាមណ្ឌលព័ត៌មាន ទេសចរកម្ពុជា" និងធ្វើការចុះផ្សព្វផ្សាយ សិក្សា និងពង្រឹងការគ្រប់គ្រងនៅតាមមណ្ឌលព័ត៌មានទេសចរកម្ពុជា នៅតាមបណ្តាខេត្ត។ ជាងនេះទៅទៀត ក្រសួងធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌតំបន់សក្តានុពលទេសចរណ៍ ទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលមានសក្តានុពលទេសចរណ៍ដែលបានធ្វើបច្ចុប្បន្នភាពចប់រួចរាល់មានចំនួន ១០៩៩កន្លែង ដើម្បីជំរុញចលនាទេសចរណ៍ទេសចរណ៍ផ្ទៃក្នុង។ ទន្ទឹមនេះ ក្រសួងបានរៀបចំផែនការអភិវឌ្ឍ ទេសចរណ៍សម្រាប់រមណីយដ្ឋានតេទឹកពុះ ទំនប់ស្ទឹងតាសាល និងអន្លង់កេតាពយដោយផ្តោតលើទេសចរណ៍ផ្ទៃក្នុង

និងក្រៅស្រុកការជានាឱ្យបាននូវនិរន្តរភាពនៃការអភិវឌ្ឍតាមសហគមន៍មូលដ្ឋាន ការគ្រប់គ្រងវិស័យទេសចរណ៍គ្រប់ជ្រុងជ្រោយ និងសមាហរណកម្មជាមួយផែនការអភិវឌ្ឍនានា។ ក្រសួងក៏បានបង្កើតគំរូផែនការទេសចរណ៍ទីក្រុងសម្រាប់សង្កាត់គំរូ និងបង្កើតគំរូមគ្គុទ្ទេសក៍ទេសចរណ៍វៃឆ្លាតសម្រាប់ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

## ៤.៤- ផ្នែកទេសចរជាតិនិងអន្តរជាតិ និងស្ថិតិទេសចរណ៍ និងការបង្កើតការងារ

### ៤.៤.១- អំពីស្ថិតិទេសចរណ៍ និងការបង្កើតការងារ

#### ៤.៤.១.១- អំពីស្ថានភាពទេសចរណ៍កម្ពុជា

បន្ទាប់ពីវិបត្តិ នៃជំងឺកូវីដ-១៩ យើងសង្កេតឃើញថា ទេសចរជាតិ និងអន្តរជាតិមានអត្រាកំណើនគួរឲ្យកត់សំគាល់ ជាក់ស្តែងឆ្នាំ២០២២នេះ កម្ពុជាទទួលបានទេសចរអន្តរជាតិ២,២៨លាននាក់ (២ ២៧៦ ៦២៦ នាក់) កើនឡើង១០៥៩% និងទេសចរជាតិប្រមាណ១៣,៩៣ លាននាក់ (១៣ ៩៣៤ ១៥០នាក់) កើនឡើង ១៩៩% ធៀបនឹងឆ្នាំ២០២១។

| សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ទេសចរអន្តរជាតិ | លាននាក់ | ៦,២០ | ៦,៦១ | ១,៣១ | ០,២០ | ២,២៨ |
| ទេសចរជាតិ | លាននាក់ | ១១,០៦ | ១១,៣២ | ៧,២៣ | ៤,៦៦ | ១៣,៩៣ |
| ទេសចរជាតិចេញក្រៅ | លាននាក់ | ១,៩៩ | ២,០៤ | ០,៣៣ | ០,០៣ | ០,៩៧ |
| មូលដ្ឋានអាជីវកម្មទេសចរណ៍ | អាជ្ញាប័ណ្ណ | ១៥.៨៣៩ | ១៦.២២១ | ១៥.៣៣១ | ១៤.៤៣៥ | ១៣.៥៩៧ |
| សេវាកម្មស្នាក់នៅ | បន្ទប់ | ៨១.៥៣៦ | ៨៤.៥២៨ | ៨០.២១៩ | ៨៤.៤៩៩ | ៨០.៧១៧ |
| មុខរបរ និងការងារទេសចរណ៍ | ពាន់នាក់ | ៦២០ | ៦៣០ | ៣០០ | ២២៥ | ៣២០ |
| ចំណូលទេសចរណ៍អន្តរជាតិ | លានដុល្លារ | ៤.៣៧៥ | ៤.៩១៩ | ១.០២៣ | ១៨៤ | ១.៤១៥ |

#### ៤.៤.១.២- សភាពការណ៍ទេសចរណ៍អន្តរជាតិ

យោងតាមរបាយការណ៍របស់អង្គការទេសចរណ៍ពិភពលោកឆ្នាំ២០១៩ ត្រូវបានចាត់ទុកជាឆ្នាំកំពូលនៃវិស័យទេសចរណ៍ ដែលបានចូលរួមចំណែកទៅក្នុងផលិតផលក្នុងស្រុកសរុប(GDP) ប្រមាណ១០,៣%។ ជាក់ស្តែងឆ្នាំ២០២២នេះ ទេសចរអន្តរជាតិដែលបានធ្វើដំណើរកម្សាន្តទូទាំងពិភពលោកមានប្រមាណ៩១៧លាននាក់ កើនឡើង១០១,៦% ធៀបនឹងឆ្នាំ២០២១ ប៉ុន្តែនៅថយចុះ៣៧,៤% ធៀបនឹងឆ្នាំ២០១៩។ យើងកត់សម្គាល់ឃើញថាក្នុងអំឡុងវិបត្តិនៃជំងឺកូវីដ-១៩ វិស័យទេសចរណ៍បានរងផលប៉ះពាល់យ៉ាងខ្លាំង ដោយបាត់បង់ទេសចរអន្តរជាតិ១,១២ប៊ីលាននាក់ ខាតបង់ចំណូលទេសចរណ៍អន្តរជាតិប្រមាណ១,៣ទ្រីលានដុល្លារអាម៉េរិក ប៉ះពាល់ការងារប្រមាណ១៤២,៦លានការងារ ស្មើនឹង៤៣% នៃឧស្សាហកម្មធ្វើដំណើរ និងផលិតផលក្នុងស្រុកសរុប ប្រមាណ ៣,៨១៥ ប៊ីលានដុល្លារអាម៉េរិក។

### ៤.៤.២- សភាពការណ៍ទេសចរណ៍អាស៊ាននិងតំបន់

ឆ្នាំ២០២១ អាស៊ានបានទទួលទេសចរអន្តរជាតិប្រមាណ២,៩លាននាក់ ថយចុះ៨៨,៥% ធៀបនឹងឆ្នាំ ២០២០ និងចំណូលទេសចរណ៍អន្តរជាតិថយចុះ៩៤,៣%។ ជាមួយគ្នានេះឆ្នាំ២០២១ ទេសចរអន្តរជាតិមកពី

ប្រទេសអាស៊ានបូកបីមានប្រមាណ៣៩,៤% នៃទេសចរសរុប។ សម្រាប់ឆ្នាំ២០២២នេះ ទេសចរអន្តរជាតិបានមកទស្សនាតំបន់អាស៊ានប្រមាណ៣៤,៩ លាននាក់ កើនឡើងជាង១ ០០០% ធៀបនឹងឆ្នាំ២០២១ និងថយចុះ ៧៤,៨% ធៀបនឹងឆ្នាំ២០១៩។

**៥- ស្ថិតិភ្ញៀវទេសចរអន្តរជាតិទិញបណ្ណចូលទស្សនារមណីយដ្ឋានអង្គរសៀមរាប**

| ចំនួនភ្ញៀវនិងចំណូលពីការលក់សំបុត្រចូលទស្សនាទីតាំងវប្បធម៌ | | | |
|---|---|---|---|
| ក- រមណីយដ្ឋានអង្គរ | | | |
| **ល.រ.** | **ប្រភេទភ្ញៀវ** | **ចំនួនភ្ញៀវ** | **ចំណូលពីការលក់សំបុត្រ** (គិតជាដុល្លារអាម៉េរិក) |
| **១.នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ** | | | |
| ១ | ភ្ញៀវទេសចរអន្តរជាតិ (បង់ថ្លៃចូលទស្សនា) | **២០១៨** | |
| | | ២ ៥៩០ ៨១៥នាក់ | ១១៦ ៦៤៦ ៦៨៥ដុល្លារអាម៉េរិក |
| | | **២០១៩** | |
| | | ១ ៦៦២ ៥១៣នាក់ | ៧៤ ៣៤០ ១៨១ដុល្លារអាម៉េរិក |
| | | **២០២០** | |
| | | ៣៩៦ ២៤១ នាក់ | ១៨ ៤៥៦ ៣០៧ដុល្លារអាម៉េរិក |
| | | **២០២១** | |
| | | ១២ ៨៧៣នាក់ | ៥២៨ ១២១ដុល្លារអាម៉េរិក |
| | | **២០២២**(**៩ខែ**) | |
| | | ១៣៤ ១៥២នាក់ | ៥ ៣៦១ ៩២៩ដុល្លារអាម៉េរិក |

**៦- ការងារចំណូលពីសេវាវិស័យដីធ្លីនិងសំណង់ ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ឯកតា ៖ រៀល

| ឆ្នាំ | សេវាសុរិយោដី | សេវាសំណង់ | ការជួលទីតាំងរោងចក្រ | សេវាព័ត៌មានសុរិយោដីតាមប្រព័ន្ធអេឡិចត្រូនិក | ពន្ធលើការផ្ទេរអលចនវត្ថុ |
|---|---|---|---|---|---|
| ២០១៨ | ៥៨ ៤៦៦ ១៩៦ ៧២៦ | ១៩ ០៦១ ៣៤៩ ៨៨៦ | ២៨១ ៦៤៨ ៨៨៨ | - | ៥៣៣ ៨៣៧ ៧៧៤ ៥១៣ |
| ២០១៩ | ៥៩ ០០០ ៤៨៥ ៦៧៣ | ៦៩ ៦២២ ៥៧៨ ៥៧១ | ២៨០ ៤៦៦ ៦១៦ | - | ៣៦២ ៧៥៨ ៦៨៦ ៤០៥ |
| ២០២០ | ៥៩ ១២២ ៨០៩ ៧៨១ | ៥៨ ៨២២ ៨៥៦ ២០១ | ២៨៣ ៣៩៦ ៥៣៩ | - | ៣៦១ ៥៥៥ ១០៦ ៨៤១ |
| ២០២១ | ៦០ ៤៧៦ ៦៩៣ ៦៤២ | ៤៦ ០២២ ៨៧៨ ៨២៥ | ២២ ៥៤៤ ៦៧៦ | ៧ ៩៧១ ៨០០ | ៣៦៥ ៧៤៥ ៨៩១ ១១៥ |
| ៩ខែ ២០២២ | ៥២ ៦៣៨ ៨២០ ៧០០ | ៤១ ២០៣ ០៤៨ ៥៨០ | ១១ ២៨២ ០៤០ | ៧ ២៣៧ ៥០០ | ១៨០ ៩៤៥ ០១០ ៥០០ |
| សរុប | **២៨៩ ៧០៥ ០០៦ ៥២៦** | **២៣៤ ៧៣២ ៧១២ ០៦៣** | **៨៧៩ ៣៣៨ ៧៥៩** | **១៥ ២០៩ ៣០០** | **១ ៨០៤ ៨៨២ ៤៦៩ ៣៧៤** |

គិតពីចាប់ផ្តើមអនុវត្តឆ្នាំ១៩៩៩ ដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ ក្រសួងបានប្រមូលចំណូលចូលថវិកាជាតិសរុបមានចំនួន៤ ៤៧៦ ៤៤៦ ០៧០ ៥៨៩រៀល (ក្នុងនោះ ចំណូលពីពន្ធប្រថាប់ត្រាលើការផ្ទេរអចលនទ្រព្យចំនួន៣ ៧០៣ ៩១៤ ៦៨៤ ៩១៩រៀល។

## ៧- ការងារហិរញ្ញវត្ថុនិងថវិកា( រដ្ឋបាលកណ្តាលក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ )

### ១- ការគ្រប់គ្រងការប្រមូលចំណូល

| ឆ្នាំអនុវត្ត | ផែនការ | អនុវត្តន៍ | | | ប្រៀបធៀបផែនការឆ្នាំ (%) |
|---|---|---|---|---|---|
| | KHM( រៀល ) | KHMER( រៀល ) | USD( ដុល្លារ ) | សរុបគិតជារៀល | |
| | ១ | ២ | ៣ | ៤ | ៥=៤/១ |
| ឆ្នាំ២០១៨ | ១៩៨ ៣៦៧ 000 000 | ១ ២០៨ ៨២៨ ២៧៣ | ៣៩ ៧៨៦ ៤៩៧,៥៩ | ១៦២ ៥៧០ ៨២៤ ៧៥០ | ៨១,៩៥% |
| ឆ្នាំ២០១៩ | ២០៧ ៧៨៤ 000 000 | ៦ ៦៧៣ ៨៨៦ ៥៣៤ | ៥៣ ០៣៥ ០៥៣,៦៧ | ២២២ ១១១ ៧២០ ២២៦ | ១០៦,៩០% |
| ឆ្នាំ២០២០ | ១៩០ ២៤១ 000 000 | ៦ ២៤១ ០៨០ ៧២២ | ៤៥ ៨៣៥ ៨៤២,៥៨ | ១៩២ ៣៩២ ៦១៨ ៨១៤ | ១០១,១៣% |
| ឆ្នាំ២០២១ | ៣១៤ ៦៨៩ 000 000 | ១ ៩១២ ៦០៦ ៤៥០ | ១២៦ ៩១១ ១១៩,៨០ | ៥៤៥ ២៥២ ៤៧៩ ៦៩៣ | ១៧៣,២៧% |
| ៩ខែ ឆ្នាំ២០២២ | ៣៩៩ ៣០៤ 000 000 | ១ ៤៥៧ ៩៦១ ១០០ | ១០៦ ៧១៦ ២៦២,៨៩ | ៤៣៧ ៨២៤ ៦៤៩ ៤៧៧ | ១០៩,៦៥% |

### ២-ការគ្រប់គ្រងចំណាយ

ឯកតា: រៀល

| ឆ្នាំអនុវត្ត | ផែនការ | | អនុវត្ត | ប្រៀបធៀប(%) /ឥណទានថ្មី |
|---|---|---|---|---|
| | ច្បាប់ហិរញ្ញវត្ថុ | ឥណទានថ្មី | | |
| ឆ្នាំ២០១៨ | ៥០ ៩៥៨ ១០០ 000 | ៦៧ ៤៤៩ ៧00 000 | ៦៤ ៣៩១ ៧៩៦ ៦៣៧ | ៩៥,៤៧% |
| ឆ្នាំ២០១៩ | ៥៦ ៩៤០ ១០០ 000 | ៩៨ ១៦៩ ១០០ 000 | ៩៥ ៥០៣ ៦៣៥ ២៨៩ | ៩៧,២៨% |
| ឆ្នាំ២០២០ | ៥៩ ៨២២ ៤០០ 000 | ៨៥ ៩៤១ ៩00 000 | ៨០ ៧៥៧ ៦៩១ ១៨៤ | ៩៣,៩៧% |
| ឆ្នាំ២០២១ | ៦០ ៦១៦ 000 000 | ១១៩ ៣៨៥ ៤៣៧ ៥00 | ១០១ ៧៧២ ៤៥០ ៥៩១ | ៨៥,២៥% |
| ៩ខែ ឆ្នាំ ២០២២ | ១០៨ ៧៣១ 000 000 | ១៤៨ ៨១០ 000 000 | ៦៩ ៤០៧ ៤៩៤ ៦៤២ | **៤៦,៦៤%** |

## មុំទី៣- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថលនិងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤

### ក្រសួងប្រៃណីយ៍និងទូរគមនាគមន៍ សម្រេចការងារដូចខាងក្រោម៖

( ផែក : Ministry of Post and Telecommunications គេហទំព័រ www.mptc.gov.kh )

ក្នុងការកិច្ចបន្តអភិវឌ្ឍប្រទេសឱ្យកាន់តែរីកចម្រើនទៅមុខ រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភាបានដាក់ចេញនូវយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ដែលវិស័យប្រៃសណីយ៍និងទូរគមនាគមន៍នៅតែដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល។ ការបន្តរៀបចំប្រព័ន្ធប្រៃសណីយ៍ឱ្យមានលក្ខណៈទំនើបទាន់សម័យមានគុណភាពខ្ពស់តាមស្តង់ដាអន្តរជាតិជាតម្រូវការចាំបាច់ សម្រាប់លើកកម្ពស់ចំណូលចិត្តរបស់ប្រជាជនឱ្យកាន់តែនិយមប្រើប្រាស់សេវាប្រៃសណីយ៍។ ទន្ទឹមនេះការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនា-គមន៍និងព័ត៌មាន តាមទំនើបកម្មនៃបច្ចេកវិទ្យាស្របតាមស្តង់ដាជាសកលនៅដំណាក់កាលផ្លាស់ប្តូរថ្មីគឺ បដិវត្តន៍ឧស្សាហកម្មទី៤ បានជំរុញឱ្យក្រសួងត្រូវយកចិត្តទុកដាក់ខ្ពស់ធ្វើកំណែទម្រង់ ដោយផ្តោតជាអាទិភាពអំពីគុណភាពអំពីតម្លៃប្រកួតប្រជែងអំពីសេវាគ្របដណ្តប់ទូទាំងប្រទេស ដើម្បីផ្តល់លទ្ធភាពឱ្យប្រជាជនទូទៅអាចប្រើប្រាស់បានគ្រប់ទីកន្លែង គ្រប់ពេលវេលាមានតម្លៃសមរម្យ។

សកម្មភាពទាំងនេះគឺជាចលករជួយជំរុញបន្ថែមទៀត ដើម្បីធ្វើយ៉ាងណាលើកកម្ពស់ជីវភាពគ្រួសារនិងសហគមន៍ក្នុងទិសដៅជួយកាត់បន្ថយចម្ងាយផ្លូវ ពេលវេលានិងការចំណាយដែលធ្លាប់មានពីមុនរបស់ប្រជាជនដែលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលមានទិសដៅពង្រីកការកសាងបណ្តាញហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍តភ្ជាប់រហូតដល់ភូមិ ឃុំ ទីជនបទ ដើម្បីជួយកាត់បន្ថយគម្លាតឌីជីថល។

## ១-វិស័យប្រៃសណីយ៍

### ១.១- ការងារគ្រប់គ្រង និងនិយ័តកម្មវិស័យប្រៃសណីយ៍

- បានដាក់ដំណើរការនៃការស្នើសុំអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតតាមប្រព័ន្ធអនឡាញ(Online)
- បានអនុវត្តដំណើរការឯកសាររដ្ឋបាលរបស់អគ្គនាយកដ្ឋានតាមប្រព័ន្ធអនឡាញ(Online)
- បានចូលរួមដោះស្រាយវិវាទរវាងប្រតិបត្តិករនិងអតិថិជន និងប្រតិបត្តិករនិងស្ថាប័នពាក់ព័ន្ធចំនួន៧ករណី
- បានចុះតាមដាននិងត្រួតពិនិត្យការអនុវត្តលក្ខខណ្ឌ នៃអាជ្ញាបណ្ណបញ្ញើឆាប់រហ័សអន្តរជាតិរបស់ប្រតិបត្តិករប្រៃសណីយ៍បានចំនួន៥២ក្រុមហ៊ុន
- បានផ្តល់អាជ្ញាបណ្ណនិងបន្តសុពលភាពអាជ្ញាបណ្ណសេវាបញ្ញើឆាប់រហ័សអន្តរជាតិជូនក្រុមហ៊ុនចំនួន៥៩ និងលិខិតអនុញ្ញាតបើកសាខាចំនួន១៧១
- បានចុះទៅត្រួតពិនិត្យបញ្ញើប្រៃសណីយ៍ដែលមានគ្រឿងញៀននៅតាមក្រុមហ៊ុនចំនួន ៨លើក
- បានចូលរួមបើកកញ្ចប់បញ្ញើប្រៃសណីយ៍ ដែលសង្ស័យមានសារជាតុញៀននៅសាលាដំបូងរាជធានីភ្នំពេញចំនួន ៧លើក និងនៅនាយកដ្ឋានសន្តិសុខផ្ទៃក្នុងនៃអគ្គស្នងការនគរបាលជាតិចំនួន ៦លើក។

បរិមាណផលិតផលរបស់បណ្តាប្រតិបត្តិករប្រៃសណីយ៍ អនុវត្តបានដូចមានក្នុងតារាងខាងក្រោម៖

ឯកតា: បញ្ញើ

| បញ្ញើ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ (ត្រឹមខែកញ្ញា) |
|---|---|---|---|---|---|
| បញ្ជូនចេញ | ៤០៧ ៩១២ | ៤២១ ០១៩ | ៥៨៣ ៦១៨ | ៨៦៣ ៩០០ | ៥០២ ៧៤០ |
| ទទួលបាន | ៥៧៧ ៥២៩ | ៥៣៩ ០៦៦ | ៤៩៧ ៥៦០ | ១ ៦៣៣ ៧៧៨ | ៣ ៦៧៤ ១០៦ |
| **សរុប** | **៩៨៥ ៤៤១** | **៩៦០ ០៨៥** | **១ ០៨១ ១៧៨** | **២ ៤៩៤ ៦៧៨** | **៤ ១៧៦ ៨៤៦** |

-ចំនួនក្រុមហ៊ុនប្រតិបត្តិករបម្រើសេវាបញ្ញើឆាប់រហ័សអន្តរជាតិ:

| ចំនួន | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ (ត្រឹមខែកញ្ញា) |
|---|---|---|---|---|---|
| ក្រុមហ៊ុន | ៣៤ | ៤៣ | ៤៧ | ៥៤ | ៥៩ |
| សាខា | ៦ | ២០ | ៣៣ | ១៣៤ | ១៧១ |

### ១.២- សហគ្រាសប្រៃសណីយ៍កម្ពុជា

- បានអភិវឌ្ឍឱ្យប្រសើរប្រព័ន្ធគ្រប់គ្រងអាជីវកម្មCounter Automation ដោយបន្ថែម(Core Post Management System, Office Exchange Management and Stock Delivery Management)
- បានអភិវឌ្ឍឱ្យប្រសើរប្រព័ន្ធគណនេយ្យ Sage 50 ទៅ QuickBook License with Cloud base
- តាមដានបញ្ញើក្នុង និងក្រៅប្រទេសតាមរយៈប្រព័ន្ធInternational Postal System (IPS)
- បង្កើតសេវាថ្មីE-Commerce E Solution ដោយសហការជាមួយក្រុមហ៊ុនTinh Tinh
- រថយន្តចែកបញ្ញើចំនួន៥៣គ្រឿង(បច្ចុប្បន្ន) និងម៉ូតូចែកបញ្ញើចំនួន៧២គ្រឿង(បច្ចុប្បន្ន)
- បង្កើតសេវាLogistic តាមរយៈរថយន្តប្រៃសណីយ៍

- សាងសង់អគារសាខាប្រៃសណីយ៍កម្ពុជា ស្រុកបាកាន ខេត្តពោធិ៍សាត់(២០១៨) ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង(២០១៨) ស្រុកជីក្រែង ខេត្តសៀមរាប(២០១៨) និងស្រុកព្រៃនប់ ខេត្តព្រះសីហនុ(២០១៨) អគារប្តូរបញ្ញើស្នាក់ការកណ្តាល(២០១៩)

- បានអនុវត្តគម្រោងORE(Operation readiness for E-Commerce)

- បានភ្ជាប់ការផ្តល់សេវាប្រៃសណីយ៍ Cambodiatrade.com.kh

- បំពាក់ប្រព័នX-ray ទំនើបដើម្បីបង្កើនសុវត្ថិភាពបញ្ញើ

- ចុះកិច្ចសន្យាជាមួយក្រុមហ៊ុនយន្តហោះដឹកបញ្ញើដែលមានEDI(Electronic Data Interchange) : Qatarairway, Cathay Pacific.

- បានកំពុងពង្រាងអនុស្សរណៈយោគយល់ជាមួយអគ្គនាយដ្ឋានគយ និងរដ្ឋាករពាក់ព័ន្ធសេវាបញ្ញើប្រៃសណីយ៍

- បានកែលម្អសាខាប្រៃសណីយ៍កម្ពុជារាជធានីភ្នំពេញចំនួន៧ រួមមានៈ សាខាទឹកល្អក់ សាខាដង្កោ សាខាអូឡាំពិច សាខាបឹងស្រឡាង សាខាច្បារអំពៅ សាខារោងចក្រកែវ ដោយឡែកសាខាបឹងព្រលឹត បានកែលម្អតាមបែបបទថ្មីទាំងស្រុង

- បើកបម្រើផ្តល់សេវាអាជីវកម្មប្រៃសណីយ៍ជូនអតិថិជន ៧ថ្ងៃក្នុងសប្តាហ៍

- ដើម្បីជួយពន្លឿនការចែកបញ្ញើ និងជួយសម្រួលដល់អតិថិជនរបស់ប្រៃសណីយ៍កម្ពុជាក្នុងការដោះស្រាយបញ្ញើជាប់ពន្ធគយ ប្រៃសណីយ៍កម្ពុជាបានសហការជាមួយក្រុមហ៊ុនអូស៊ីស៊ីអេស ឯ.ក.(OCCS CO.,LTD) ដែលជាក្រុមហ៊ុនផ្តល់សេវាដើងសារគយ

- បានកែលម្អចំណតរថយន្តនៅខាងមុខប្រៃសណីយ៍កម្ពុជានិងទីតាំងចតម៉ូតូបុគ្គលិកឱ្យមានរបៀបរៀបរយ

- រៀបចំនៅឃ្លាំងសម្រាប់ដាក់ឯកសារនិងសម្ភារៈផ្សេងៗ។

ឯកតាៈ ដុល្លារអាម៉េរិក

| ល.រ | **បរិយាយ** | ២០១៨ | ២០១៩ | ២០២០ | ២០២១ | **មករា-កញ្ញា** ២០២២ |
|---|---|---|---|---|---|---|
| ១ | ផលចំណូលអាជីវកម្មប្រៃសណីយ៍ | ១២ ៩៣០ ៨៤២ | ១១ ៧៦០ ៣៤៦ | ៦ ៥៣១ ១៥២ | ៧ ៤៧១ ៣៣៣ | ៤ ៧១៣ ០៧៥ |
| ២ | ថ្លៃដើមលក់ | ៦ ៩៥១ ៨៤៤ | ៦ ១២៣ ២០៨ | ៣ ២៤៨ ៥៥៧ | ៣ ១៥៤ ៤០៧ | ១ ៩៩៣ ០៤០ |
| ៣ | ចំណេញដុល | ៥ ៩៧៨ ៩៩៨ | ៥ ៦៣៧ ១៣៨ | ៣ ២៨២ ៥៩៥ | ៤ ៣១៦ ៩២៦ | ២ ៧២០ ០៣៥ |
| ៤ | ចំណាយប្រតិបត្តិការ | ៥ ២១៦ ៧៧១ | ៥ ៦១៣ ០៩៧ | ៤ ៦៤២ ៤៣០ | ៤ ២៩៧ ១២៣ | ២ ៩៨៣ ១៧៧ |
| ៥ | ចំណេញ/(ខាត) ពីប្រតិបត្តិការ | ៧៦២ ២២៧ | ២៤ ០៤១ | ១ ៣៥៩ ៨៣៥ | ១៩ ៨០៣ | ២៦៣ ១៤២ |
| ៦ | ផលចំណូលហិរញ្ញវត្ថុ | ៣៦៩ ២៤៨ | ៤៧៧ ១១៩ | ៤១៦ ៨៥៤ | ៣០៨ ៥៨១ | ៣៤៦ ៧៦៩ |
| ៧ | ចំណេញ/(ខាត) មុនបង់ពន្ធ | ១ ១៣១ ១៤៧ | ៥០១ ១៦០ | ៩៤២ ៩៨១ | ៣២៨ ៣៨៤ | ៨៣ ៦២៧ |
| ៨ | ពន្ធលើប្រាក់ចំណេញ | ២៨២ ០៣៦ | ២៣៤ ៩៧៧ | ៦៤ ៧១៧ | ៧៣ ៨០៨ | |
| ៩ | ចំណេញ/(ខាត) សុទ្ធប្រចាំឆ្នាំ | ៨៤៩ ៤៣៩ | ២៦៦ ១៨៣ | ១ ០០៧ ៦៩៨ | ២៥៤ ៥៧៦ | ៨៣ ៦២៧ |

ចំណូលពីអាជីវកម្មប្រៃសណីយ៍ រួមមានបញ្ញើធាប់រហ័ស ប្រៃសណីយ៍ភណ្ឌ បញ្ញើកញ្ចប់ និងលិខិតបែងចែកបញ្ញើអន្តរជាតិ ផលិតផលប្រៃសណីយ៍ សេវាអាណត្តិប្រៃសណីយ៍ រថយន្តដឹកអ្នកដំណើរ ចំណូលផ្សេងៗ ។ល។

## ២- វិស័យទូរគមនាគមន៍

### ២.១- ការខារផ្កាយរណប

- បានបង្កើតក្រុមការងារសិក្សាស្រាវជ្រាវបច្ចេកវិទ្យា និងប្រព័ន្ធផ្កាយរណបដែលសិក្សាផ្តោតលើលក្ខណៈបច្ចេកទេស និងបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ
- កំពុងសិក្សាស្រាវជ្រាវបច្ចេកវិទ្យាផ្កាយរណប និងក្រុមហ៊ុនប្រតិបត្តិករ ដែលអាចផ្តល់ដំណោះស្រាយលើអ៊ីនធឺណិតបំពេញបន្ថែមលើសេវាទូរសព្ទចល័តបាន
- បានសិក្សាស្រាវជ្រាវ និងបកប្រែឯកសារលក្ខន្តិកៈនៃអង្គការInternational Mobile Satellite Organisation( IMSO )
- បានរៀបចំសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិកាតព្វកិច្ចសេវាសកល
- បានបង្កើតលក្ខខណ្ឌក្នុងការឆ្លើយតបការស្នើសុំសម្របសម្រួលបណ្តាញផ្កាយរណបជាមួយប្រទេសនានា
- បានសិក្សាលើបច្ចេកទេសនិងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការព្រមព្រៀងប្តូរប្រភេទយន្តហោះគ្មានមនុស្សបើកក្នុងគម្រោងMeSIC រវាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍និងក្រុមហ៊ុនSpace Start Technology Co., Ltd.
- កំពុងសិក្សាកំណត់លក្ខខណ្ឌឆ្លើយតបក្នុងការស្នើសុំសម្របសម្រួលស្ថានីយ៍ផ្កាយរណបលើដី( Terrestrial Station )។

### ២.២- ទិន្នន័យការតភ្ជាប់របស់ប្រតិបត្តិករទូរគមនាគមន៍

- ប្រតិបត្តិករទូរគមនាគមន៍ដែលបានតភ្ជាប់មកមជ្ឈមណ្ឌលគ្រប់គ្រងសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា ( DMC )

-ធ្វើប្រតិបត្តិការ:

| ល.រ. | ការតភ្ជាប់ | គិតត្រឹមឆ្នាំ២០១៨ ដល់ ខែកញ្ញា ឆ្នាំ២០២២ | | | | |
|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
| ១ | ទូរស័ព្ទចល័ត-អចល័ត និងមាត់ច្រកអន្តរជាតិ | ៩ | ៨ | ៨ | ៧ | ៧ |
| ២ | ប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិត ( ISP ) | ១៦ | ១៧ | ១៧ | ៤០ | ៤០ |
| ៣ | ប្រតិបត្តិករផ្តល់សេវា ( Toll Free ) | - | - | - | ១ | ១ |
| ៤ | ប្រតិបត្តិករផ្តល់សេវាហេដ្ឋារចនាសម្ព័ន្ធ | - | - | - | ១ | ១ |

- ចំនួនអតិថិជនកំពុងប្រើប្រាស់:

| ល.រ | ចំនួនអតិថិជន | គិតត្រឹមឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២ | | | | |
|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
| ១ | ទូរសព្ទចល័ត-អចល័ត និងមាត់ច្រកអន្តរជាតិ | ២០ ១៧១ ៧៤២ | ២១ ៦៤៦ ២៥០ | ១៩ ៧២៥ ២៩៤ | ១៩ ៧៨២ ៦៦៨ | ១៩៦៧៧២៦១ |
| ២ | ប្រតិបត្តិករផ្តល់សេវាអ៊ីនធឺណិត( ISP ) | ១១២ ៩១២ | ១២៥ ៣៧៩ | ១៧១ ០៩៧ | ២៥៨ ៦៩១ | ៣៥៣ ៨០១ |

**-កិច្ចប្រជុំពិនិត្យវឌ្ឍនភាពនៃការគ្រប់គ្រង និងជំរុញការតភ្ជាប់បណ្តាញរវាងប្រតិបត្តិករឬបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍:**

| ល.រ | បរិយាយ | គិតត្រឹមឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២ | | | | |
|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
| ១ | រៀបចំកិច្ចប្រជុំផ្ទៃក្នុង | ១៤ | ១៦ | ១៤ | ១៦ | ១១ |
| ២ | រៀបចំកិច្ចប្រជុំជាមួយប្រតិបត្តិករ | ១១៨ | ១៦១ | ៩៤ (*) | ១០៥ (*) | ១៦០ |

សម្គាល់៖ (*) ការរីករាលដាលនៃជំងឺកូវីដ-១៩។

- ការបញ្ជូននិងទទួលឯកសារ បច្ចេកទេសរបស់ប្រតិបត្តិករៈ

| បរិយាយ | គិតត្រឹមឆ្នាំ២០១៨ ដល់ ខែកញ្ញា ឆ្នាំ២០២២ | | | | |
|---|---|---|---|---|---|
| | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
| បញ្ជូននិងទទួល ឯកសារបច្ចេកទេសទៅប្រតិបត្តិករ | | | | | |
| ការបញ្ជូនឯកសារ | ៩៣០ | ១ ១៧២ | ៩២០ | ១ ៥៤៩ | ៧១៦ |
| ការទទួលឯកសារ | ៤៨៤ | ៤៥០ | ៤៩៩ | ៩១៣ | ៤៩៥ |

## ២.៣- សហគ្រាសទូរគមនាគមន៍កម្ពុជា

### ក- ការងារអាជីកម្ម:

នៅចំពោះមុខទីផ្សារប្រកួតប្រជែងទូរគមនាគមន៍កម្ពុជាបានរៀបចំធ្វើផែនការអាជីវកម្មរយៈពេល៥ឆ្នាំសម្រាប់រំកិលមកអនុវត្តតាមឆ្នាំនីមួយៗ ជាក់ស្តែងការអនុវត្តផែនការឆ្នាំជាបន្តបន្ទាប់មកនេះគឺបានភ្ជាប់គ្នាទៅវិញទៅមក (Link)ជាមួយនឹងផែនការយុទ្ធសាស្ត្រមានសេវាទូរស័ព្ទអចល័ត សេវាអ៊ីនធឺណិតនិងTransmission ដែលកំពុងផ្តល់ជូនអតិថិជនប្រើប្រាស់ ដូចមានក្នុងតារាងខាងក្រោម៖

- ទូរស័ព្ទភ្នំពេញនិងខេត្ត(Line)

| ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ ឆ្នាំ២០២ |
|---|---|---|---|---|
| ៣០ ៧០៣ | ២៩ ៥០៣ | ២៨ ៨០៦ | ២៦ ០៣១ | ២៥ ៣៣២ |

- សេវាInternet ភ្នំពេញនិងខេត្ត(Users)

| ២០១៨ | ២០១៩ | ២០២០ | ២០២១ | | ៩ខែ ឆ្នាំ២០២២ | |
|---|---|---|---|---|---|---|
| | | | Users | Mbps | Users | Mbps |
| ៧ ៧១៣ | ៧ ២៤៤ | ៧ ១៨៩ | ៣ ៣៤៦ | ៤ ៦៥៤ | ៣ ៤១០ | ៧ ៦១៤ |

- Transmission ភ្នំពេញនិងខេត្ត(Users )

| ២០១៨ | ២០១៩ | ២០២០ | ២០២១ | | ៩ខែ ឆ្នាំ២០២២ | |
|---|---|---|---|---|---|---|
| | | | Mbps | Core | Mbps | Core |
| ៧២ | ៧៣ | ៨៦ | ៨៨៩ | ១១០ | ៦៦៣ | ២៧៨ |

- ចរន្តទូរស័ព្ទតភ្ជាប់ចូល (Fix to Fix) &(Mobile to Fix)(គិតជានាទី)

| ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ ឆ្នាំ២០២២ |
|---|---|---|---|---|
| ៦ ៦៩១ ២៨៤ | ៦ ១១៦ ១១១ | ៥ ២៧៤ ៥៨៣ | ៥ ២៩២ ៥៩៣ | ២ ៦៣៥ ៩០៤ |

- ចរន្តទូរស័ព្ទតភ្ជាប់ចេញ(Fix to Fix)&(Mobile to Fix)(គិតជានាទី)

| ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ ឆ្នាំ២០២២ |
|---|---|---|---|---|
| ១៥ ៥៨០ ២០១ | ១១ ០១៣ ៤០៤ | ៧ ២៤៥ ៥៥៨ | ៦ ៥៧៥ ៧១៥ | ៣ ៤១៧ ៧១១ |

- ចរន្តទូរស័ព្ទអន្តរជាតិចេញ ចូល

| Outgoing to International (គិតជានាទី) | | | | |
|---|---|---|---|---|
| ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ ឆ្នាំ២០២២ |
| ១ ១១៤ ២៧៧ | ៧២១ ១៣៨ | ៦៣៦ ៨៤៨ | ៣១៤ ២៣៣ | ១៩០ ២០៣ |

| Incoming from International ( គិតជានាទី ) | | | | |
|---|---|---|---|---|
| ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ ឆ្នាំ២០២២ |
| ៨០ ៥៩៣ ៤២៧ | ៦៤ ១៥៦ ២១៩ | ៣៧ ៤៦៦ ១៨៩ | ២៦ 4៤៧ ៦៨៨ | ១១ ៥២២ ៩៤៨ |

### ខ- ការងារហិរញ្ញវត្ថុនិងថវិកា

- ចំណូល( គិតជាដុល្លារអាម៉េរិក )

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ ឆ្នាំ២០២២ |
|---|---|---|---|---|---|
| ពីប្រតិបត្តិការ | ៩ ៩៦២ ៥៧៥,០២ | ៩ ៨៥៧ ៧៧២,៨៦ | ១០ ៣៥០ ០៨១,៤១ | ៧ ៣៣៦ ៨៥៩,៨៣ | ៥ ១៤០ ៥៣៦,៤៥ |
| ចំណេញពីអត្រាប្តូររបស់កម្ចី | ១ ៤៧២ ០៧៧,៩៣ | ២១៣ ៩២៦,១០ | | ២ ៨៩៥ ១៤៣,៩២ | ៧ ៨៤៩ ៧៩២,១១ |
| **ចំណូលសរុប** | ១១ ៤៣៤ ៦៥២,៩៥ | ១០ ០៧១ ៦៩៨,៩៦ | ១០ ៣៥០ ០៨១,៤១ | ១០ ២៣២ ០០៣,៧៥ | ១២ ៩៩០ ៣២៨,៥៦ |

- ចំណាយ( គិតជាដុល្លារអាម៉េរិក )

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ ឆ្នាំ២០២២ |
|---|---|---|---|---|---|
| ពីប្រតិបត្តិការ | ១៥ ២៤៥ ៩៤៨,៣៤ | ១៣ ៤៤១ ៥៨៨,៩១ | ១៤ ៥៣៥ ១៦៣,០៣ | ៩ ៣៥៨ ១៣៨,៤៣ | ៥ ៦៥៨ ០៣៩,៣៣ |
| ចំណេញ/ខាតពីអត្រាប្តូរប្រាក់កម្ចី | ១ ៤០០ ៥០៧,០៤ | ៣៧២ ៨២៧,៣៥ | ២ ៣៦៣ ២៥១,៨៤ | ៣៥៦ ៤៣៨,៧៦ | ១ ០១៣ ៨៧៥,៩៨ |
| ចំណាយសរុប | ១៦ ៦៤៦ ៤៥៥,៣៨ | ១៣ ៨១៤ ៤១៦,២៦ | ១៦ ៨៩៨ ៤១៤,៨៧ | ៩ ៧១៤ ៥៧៧,១៩ | ៦ ៦៧១ ៩១៥,៣១ |

- ចំណេញ ខាត( គិតជាដុល្លារអាម៉េរិក )

| សរុប | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ ឆ្នាំ២០២២ |
|---|---|---|---|---|---|
| | ៥ ២១១ ៨០២,៤៣ | -៣ ៧៤២ ៧១៧,៣០ | -៦ ៥៤៨ ៣៣៣,៤៦ | ៥១៧ ៤២៦,៥៦ | ៦ ៣១៨ ៤១៣,២៥ |

## ២.៤- វិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន

### ក- លទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤(ជូនក្រសួង ស្ថាប័ន)

| ល.រ | សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ ត្រឹមខែញ |
|---|---|---|---|---|---|---|---|
| ១ | តភ្ជាប់និងជួសជុលខ្សែកាប្លិ៍អុបទិកជូនក្រសួង ស្ថាប័ន | គ.ម | ១៤,១៣ | ៩,៨០ | ១៦,៤០ | ៣០,៥៣ | ១០,១៥ |
| ២ | អភិវឌ្ឍកម្មវិធីកុំព្យូទ័រជូនក្រសួង ស្ថាប័ន | កម្មវិធី | ៤ | ៤ | គ្មាន | ២ | ១ |
| ៣ | ផ្តល់វិញ្ញាបនបត្រជូនក្រុមហ៊ុនប្រកបអាជីវកម្មវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន | ចំនួនក្រុមហ៊ុន | ១៥ | ៧២ | ១៣០ | ៨៦ | ១០០ |
| ៤ | រៀបចំការបណ្តុះបណ្តាលនិងរៀបចំសិក្ខាសាលាបញ្ជ្រាបការយល់ដឹងជំនាញឌីជីថលខ្ចីៗជូនដល់ក្រសួង ស្ថាប័នរាជធានីខេត្ត | នាក់ | ២.៩៩៤ ស្រី៥១៥ | ២១៨២ ស្រី៣១៣ | ៧៥៣ ស្រី១៤១ | ១ ៥០៦ ស្រី៣០៦ | ៦២៣ ស្រី១០៧ |
| ៥ | រៀបចំការការបណ្តុះបណ្តាលជំនាញ ឌីជីថលខ្ចីៗនៃគម្រោងកាត់បន្ថយភាពក្រីក្រនិងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាបជំហានទី២ | នាក់ | គ្មាន | គ្មាន | ៨៦០ ស្រី៣៩៦ ៤៦,០៤% | ១ ០៣១ ស្រី៤៥៤ ៤៤,០៣% | ១ ០០៩ ស្រី៤៣៦ ៤៣,២១% |

- គ្រប់គ្រងប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាលចំនួន ៦៣ទីតាំង នៅតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស អង្គភាពនគរបាលជាតិ អង្គភាពកងទ័ពសំខាន់ៗ ក្រសួងស្ថាប័នពាក់ព័ន្ធដោយបានផ្សាយបន្តផ្ទាល់កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** តាមរយៈប្រព័ន្ធវីដេអូនៃសន្និសីទរបស់រាជរដ្ឋាភិបាលចំនួន២៥លើក កិច្ចប្រជុំតាមអនឡាញចំនួន១៩លើក ក្នុងនោះកិច្ចប្រជុំសំខាន់ៗ មានដូចជាៈ កិច្ចប្រជុំ( 1st Asia Europe Economic and Business Forum ),កិច្ចប្រជុំGMS 7th Summit, កិច្ចប្រជុំAsem13 និងកិច្ចប្រជុំនៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ចំនួន៤លើក

- ផ្តល់សេវាអ៊ីនធឺណិតជូនសាលាខេត្តចំនួន១០ និងក្រសួង ស្ថាប័នចំនួន៥២

- អភិវឌ្ឍកម្មវិធីកុំព្យូទ័រជូនក្រសួងស្ថាប័នដូចជាៈប្រព័ន្ធកម្មវិធីគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ ប្រព័ន្ធចុះបញ្ជីស្នើ

- សុំលិខិតឆ្លងដែនសម្រាប់មន្ត្រីរាជការតាមបច្ចេកវិទ្យាព័ត៌មាន កម្មវិធីគ្រប់គ្រងសន្និធិសម្ភារៈការិយាល័យ និងកម្មវិធីចុះបញ្ជីសេវាសាធារណៈឌីជីថលសម្រាប់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ កម្មវិធីគ្រប់គ្រងព័ត៌មានថ្នាក់ដឹកនាំ មន្ត្រីរាជការនិងនិយោជិត ដែលជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិនិងបំណុលនៃអង្គភាពប្រឆាំងអំពើពុករលួយ កម្មវិធីបណ្ណាល័យឌីជីថលនិងកម្មវិធីកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី( E-Meeting )ជាដើម

- ឆ្លើយតបរបាយការណ៍អំពីឧប្បត្តិហេតុ( Incident Reports )ផ្នែកសន្តិសុខបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានចំនួន២៥៦ករណី ភាគច្រើនទទួលបានពីក្រសួង ស្ថាប័ន ក្រុមហ៊ុន ធនាគារនៅក្នុងប្រទេសកម្ពុជា និងក្រុមឆ្លើយតបបន្ទាន់នៃបញ្ហាកុំព្យូទ័រ( Computer Emergency Response Team( CERT )របស់ប្រទេសជាង៤០ក្នុងពិភពលោកអំពីករណី ដូចជាការវាយប្រហារ Distribute Denial of Service ( DDoS ) ហេ្វសប៊ុក បោកបញ្ឆោតលក់ទំនិញតាមអនឡាញ វេបសាយបោកបញ្ឆោតផ្ទុកតំណភ្ជាប់ក្លែងបន្លំ( fraud )វេបសាយរបស់ក្រសួងស្ថាប័ន ក្រុមហ៊ុន ធនាគារត្រូវគេហែក( Hack )និងមានមេរោគ"Emotet"និងមេរោគ"Avalanche"រាលដាលក្នុងប្រទេសកម្ពុជាជាដើម

- ការងារអភិវឌ្ឍរដ្ឋាភិបាលអេឡិចត្រូនិកជូនក្រសួង ស្ថាប័ន និងរាជធានី ខេត្តៈ (១)ចុះឈ្មោះដែនជាតិ ( DNS )សរុបចំនួន១០៩ (២)ជួយអភិវឌ្ឍវេបសាយចំនួន១៨ (៣)បង្កើតប្រព័ន្ធបង្ហោះវេបសាយ និងប្រព័ន្ធបង្ហោះអ៊ីមែលចំនួន៤៧ (៤)ដាក់ដំណើរការប្រព័ន្ធវេបសាយចំនួន១០៩ និងប្រព័ន្ធអ៊ីមែលចំនួន៥៦ និងជួយអភិវឌ្ឍមុខងារសេវាឌីជីថល សម្រាប់វេបសាយរាជធានី ខេត្ត

- ថែទាំវេបសាយរបស់ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត ដែលកំពុងដំណើរការលើម៉ាស៊ីនសេវូបករណ៍ ( Server ) របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍សរុបចំនួន ១០១វេបសាយ

- ចុះអនុស្សរណៈយោគយល់គ្នា( MoU )និងកិច្ចព្រមព្រៀងមួយចំនួនជាមួយៈ ( ១ ) Singapore Cooperation Enterprise ( SCE ) គម្រោងកសាងសមត្ថភាពលើវិស័យបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានដំណាក់កាលទី២ ( ២ ) អគ្គនាយកដ្ឋានសន្តិសុខឆ្លើយតបបញ្ហាបន្ទាន់នៃកុំព្យូទ័រប្រទេសចិន( CNCERT/CC )លើកិច្ចសហប្រតិបត្តិការសន្តិសុខព័ត៌មាន ( ៣ ) ទីភ្នាក់ងារសន្តិសុខអ៊ីនធឺណិតនៃសាធារណរដ្ឋកូរ៉េ( KISA )លើកិច្ចសហប្រតិបត្តិការសន្តិសុខព័ត៌មាន ( ៤ ) ក្រសួងព័ត៌មាននិងគមនាគមន៍Ministry of Information and Communication ( MIC )នៃសាធារណរដ្ឋសង្គមនិយមវៀតណាម លើកិច្ចសហប្រតិបត្តិការសន្តិសុខព័ត៌មាន ( ៥ ) សាធារណរដ្ឋប្រជាមានិតចិន

តាមរយៈក្រុមហ៊ុនHuawei ផ្តល់ជំនួយឧបករណ៍កុំព្យូទ័រពពកFusion Cloud Desktop ចំនួន៥០០គ្រឿង និងម៉ាស៊ីនសេវ៉ូបករណ៍(Server) ចំនួន១ឈុតជូនរាជរដ្ឋាភិបាលកម្ពុជា

- គម្រោងមូលនិធិនៃការស្រាវជ្រាវ និងការអភិវឌ្ឍវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (មូលនិធិស.អ)បំពាក់កុំព្យូទ័រ និងសម្ភារៈបច្ចេកទេសគាំទ្រការបង្រៀនបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៅរាជធានី ខេត្តចំនួន១២ សម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិចំនួន ២០វិទ្យាល័យ សរុបកុំព្យូទ័រចំនួន៥០០គ្រឿង LCD projector ចំនួន២០ តុចំនួន២៦០ កៅអីចំនួន១ ០០០ និងកង្ហារចំនួន១៤០

- សហការជាមួយក្រសួងស្ថាប័នរៀបចំផ្សព្វផ្សាយតាមរយៈវីដេអូខ្លីៗហ្វេសប៊ុក វិទ្យុ ទូរទស្សន៍ ព្រមទាំងប្រព័ន្ធផ្សព្វផ្សាយដទៃទៀតនូវកម្មវិធីយុទ្ធនាការលើកកម្ពស់ការយល់ដឹងពីហានិភ័យលើប្រព័ន្ធអនឡាញ ចំពោះកុមារនៅកម្ពុជាកម្មវិធីគិតគូរកូន ជួយឱ្យមាតាបិតា អាណាព្យាបាលការពារហានិភ័យពេលកូនអនឡាញ

- រៀបចំនិងចូលរួមប្រកួតប្រជែងពានរង្វាន់(ICT Award)កម្រិតអន្តរជាតិនៅប្រទេសវៀតណាម ម៉ាឡេស៊ី និងឥណ្ឌូណេស៊ី ព្រមទាំងរៀបចំកម្មវិធីប្រកួតប្រជែងកម្រិតជាតិមានដូចជាៈ កម្មវិធីប្រកួតប្រជែងពានរង្វាន់(ICT Award) កម្មវិធីជ្រើសរើសស្ត្រីឆ្នើមក្នុងវិស័យបច្ចេកវិទ្យា កម្មវិធីប្រកួតប្រជែង"Mekong Lancang" និងកម្មវិធីប្រកួតសមត្ថភាពជំនាញបច្ចេកវិទ្យា។

**ខ- ការងារទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ**

| សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|
| កិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យ ក្រុមហ៊ុនជាតិ អន្តរជាតិ(MOU) | ១ | ៥ | ១៥ | ២ | ៦ | **២៩** |
| កិច្ចប្រជុំ និងសិក្ខាសាលាក្រៅប្រទេស | ២៣ | ១៥ | ១៨ | ៤ | ១៤ | **៧៤** |

**គ- ការងារស្រាវជ្រាវ និងនវានុវត្តន៍**

| សូចនាករ | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ | | សរុបរួម |
|---|---|---|---|---|---|---|---|---|---|---|---|
| | ជាតិ | អន្តរជាតិ | ជាតិ | អន្តរជាតិ | ជាតិ | អន្តរជាតិ | ជាតិ | អន្តរជាតិ | ជាតិ | អន្តរជាតិ | |
| គម្រោងស្រាវជ្រាវនិងអភិវឌ្ឍន៍(គម្រោង) | ៦ | - | ៧ | ៦ | ៥ | ៣ | ៥ | ៣ | ៩ | ២ | ៤៦ |
| សិក្ខាសាលាស្រាវជ្រាវនិងអភិវឌ្ឍន៍(សិក្ខាសាលា) | ២ | - | ១ | - | ១ | ២ | ១ | ១ | ១ | ១ | ១០ |
| ការកសាងសមត្ថភាពស្រាវជ្រាវនិងអភិវឌ្ឍន៍(នាក់) | - | - | - | ៩ | - | - | - | ៨ | ៨ | ១១ | ៣៦ |
| កម្មវិធីលើកកម្ពស់នវានុវត្តន៍និងសហគ្រិនភាព(កម្មវិធី) | ៩ | | ១១ | | ១៧ | | ២១ | | ៤៦ | | ១០៤ |

## ៣- និយ័តកម្មទូរគមនាគមន៍កម្ពុជា

### ៣.១- ការគ្រប់គ្រងហិរញ្ញវត្ថុ

ឯកតាៈ លានរៀល

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ឆ្នាំ២០២២ (ប៉ាន់ស្មាន៩ខែ) |
|---|---|---|---|---|---|
| -ចំណូល | ១១ ៣៩៩ | ៩ ៣៤១ | ៩ ៥៨០ | ១៣ ៤៤៩ | ១២ ៦៦០ |
| -ចំណាយ | ១៤ ៦១៣ | ១១ ៥២២ | ៩ ៥៨០ | ១៣ ៤៤៩ | ១៥ ១២២ |
| -បំណុល | ២០ ៩២២ | ១៨ ៩៩៥ | ១៤ ១៩១ | ១០ ៥៥៨ | ៦ ៩១០ |

## ៣.២- ការងារនិយតកម្មទូរគមនាគមន៍

### ៣.២.១- ស្ថិតិអាជ្ញាបណ្ណផ្ដល់សេវាទូរគមនាគមន៍

ឯកតា: ប្រតិបត្តិករ

| ល.រ | ប្រភេទអាជ្ញាបណ្ណ | គិតត្រឹម ខែកញ្ញា ឆ្នាំ២០២២ (ស្ថានភាពនៃប្រតិបត្តិករកំពុងដំណើរការ) | | | | |
|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
| ១ | អាជ្ញាបណ្ណប្រតិបត្តិការនិងផ្ដល់សេវាមាត់ច្រកទូរគមនាគមន៍អន្តរជាតិ | ២ | ២ | ២ | ២ | ២ |
| ២ | អាជ្ញាបណ្ណសេវាទូរស័ព្ទចល័ត | ៧ | ៧ | ៥ | ៥ | ៥ |
| ៣ | អាជ្ញាបណ្ណសេវាទូរស័ព្ទអចល័តមានខ្សែនិងគ្មានខ្សែ | ៧ | ៧ | ៦ | ៦ | ៦ |
| ៤ | អាជ្ញាបណ្ណប្រតិបត្តិការនិងផ្ដល់សេវាសំឡេងតាមរយៈអាយភី | ១៦ | ១៧ | ១១ | ៩ | ៩ |
| ៥ | អាជ្ញាបណ្ណប្រតិបត្តិការនិងផ្ដល់សេវាអ៊ីនធឺណិត | ៣៧ | ៤២ | ៤៨ | ៣៩ | ៣៨ |
| ៦ | អាជ្ញាបណ្ណប្រតិបត្តិការនិងផ្ដល់សេវាផ្កាយរណប | ០ | ០ | ០ | ០ | ០ |
| ៧ | អាជ្ញាបណ្ណប្រតិបត្តិការនិងផ្ដល់សេវាបង្គោលអង់តែន | ៣ | ៣ | ៣ | ២ | ៣ |
| ៨ | អាជ្ញាបណ្ណប្រតិបត្តិការនិងផ្ដល់សេវាខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រ | ២ | ២ | ២ | ២ | ២ |
| ៩ | អាជ្ញាបណ្ណប្រតិបត្តិការនិងផ្ដល់សេវាហេដ្ឋារចនាសម្ព័ន្ធបណ្ដាញខ្សែកាប្លិ៍ទូរគមនាគមន៍ | ៣ | ៣ | ៣ | ២ | ៣ |
| ១០ | អាជ្ញាបណ្ណប្រតិបត្តិការប្រព័ន្ធបណ្ដាញនិងសេវាកំណត់ទីតាំងនិងតម្រង់ទិសតាមផ្កាយរណប BeiDou | ១ | ១ | ០ | ០ | ០ |
| ១១ | អាជ្ញាបណ្ណប្រតិបត្តិការនិងផ្ដល់សេវាតម្លៃបន្ថែម | ១ | ១ | ១ | ១ | ១ |
| ១២ | អាជ្ញាបណ្ណប្រតិបត្តិការនិងផ្ដល់សេវាថ្ងៃលហ្វ្រី | ១ | ១ | ១ | ១ | ១ |
| ១៣ | អាជ្ញាបណ្ណសេវាសៀវភៅអាសយដ្ឋានកម្ពុជា | ១ | ១ | ០ | ០ | ០ |
| សរុប | | ៨១ | ៨៧ | ៨២ | ៦៩ | ៧០ |

### ៣.២.២- ការគ្រប់គ្រងប្លង់លេខទូរគមនាគមន៍

#### ក- ស្ថិតិលេខទូរសព្ទអចល័ត

ឯកតា : លេខ

| ល.រ | ប្រតិបត្តិករ | លេខកូដសម្គាល់ | ចំនួនលេខ | | | | |
|---|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
| ១ | Viettel | AC 6XX XXXX<br>AC 46X XXXX | ៨៣៥ ០០០ | ៨៣៥ ០០០ | ៨៣៥ ០០០ | ៨៣៥ ០០០ | ៥២២ ០០០ |
| ២ | Cam GSM | AC 50X XXXX<br>AC 51X XXXX<br>AC 52X XXXX<br>AC 53X XXXX<br>AC 54X XXXX<br>AC 55X XXXX | ១៥ ០០០ ០០០ | ១៥ ០០០ ០០០ | ១ ៣០៨ ០០០ | ១ ២៦៨ ០០០ | ១ ២៥៩ ០០០ |
| ៣ | Telecom Cambodia | AC 2XX XXX<br>AC 4XX XXX<br>AC 7XX XXX<br>AC 8XX XXX | ១៩៥ ០០០ | ១៩៥ ០០០ | ១៩៥ ០០០ | ១៩៥ ០០០ | ១៩៥ ០០០ |
| ៤ | Camintel | AC 9XX XXX | ១៦៩ ០០០ | ១៦៩ ០០០ | ១៥៨ ០០០ | ១៥៨ ០០០ | ១៥៨ ០០០ |
| ៥ | Xin Wei | AC 47X XXXX | ៦៦ ០០០ | ៦៦ ០០០ | ៦៦ ០០០ | ៦៦ ០០០ | ៦៦ ០០០ |
| ៦ | SEATel | AC 48X XXXX | ២ ៥០០ ០០០ | ២ ៥០០ ០០០ | ២ ៥០០ ០០០ | ១០ ០០០ | ១០ ០០០ |
| ៧ | Smart Axiata | AC 45XX XXX<br>AC 56XX XXX | ១ ៨៥០ ០០០ | ៣៩១ ០០០ | ០ | ០ | ០ |

សម្គាល់: AC( Area Code ) សម្គាល់លេខតំបន់, X សម្គាល់ពីលេខ 0 ដល់លេខ ៩។

#### ខ- ស្ថិតិលេខទូរស័ព្ទចល័ត

ឯកតា: ចំនួនលេខកូដ

| ល.រ | ប្រភេទសេវា | ចំនួនលេខកូដ | | | | |
|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
| ១ | ថូលហ្វ្រី | ៤ | ៤ | ៤ | ៤ | ៤ |
| ២ | មាត់ច្រកទូរគមនាគមន៍អន្តរជាតិ | ៣ | ៣ | ៣ | ៣ | ២ |
| ៣ | ចំណុចស៊ីញ៉ាល់អន្តរជាតិ | ១៤ | ១៤ | ១៤ | ១៣ | ១២ |
| ៤ | បណ្តាញចល័ត | ១១ | ១០ | ១០ | ៨ | ៨ |
| ៥ | ចំណុចស៊ីញ៉ាល់ជាតិ | ១៦៨ | ១២៧ | ១២៩ | ១០៦ | ១០០ |
| ៦ | លេខកូដខ្លីសម្រាប់ប្រតិបត្តិករ | ២៤១ | ១២៦ | ១០៨ | ៧០ | ២២៨ |
| ៧ | ព្រីមៀមរ៉េត | ៣ | ៣ | ៣ | ៣ | ៣ |
| ៨ | សំឡេងតាមរយៈអាយភី | ២២ | ១៦ | ១៧ | ១៣ | ១២ |
| ៩ | លេខកូដខ្លីសម្រាប់អតិថិជន | ២២ | ១៤ | ១៥ | ២១ | ២៦ |

## ៣.៣- ទិន្នន័យអតិថិជនប្រើសេវាទូរស័ព្ទចល័ត អចល័ត និងអ៊ីនធឺណិតចល័ត អចល័ត

### ៣.៣.១- អតិថិជនប្រើប្រាស់សេវាទូរស័ព្ទចល័តគិតត្រឹមខែកញ្ញាឆ្នាំ ២០២២

ឯកតា: ស៊ីមកាត

| ល.រ | ប្រតិបត្តិករ | ២០១៨ (១) | ២០១៩ (២) | ២០២០ (៣) | ២០២១ (៤) | ២០២២ (៥) | ប្រៀបធៀប ៦=(៥-១)/១ |
|---|---|---|---|---|---|---|---|
| ១ | Viettel | ៧ ៨៥៤ ៧៤២ | ៩ ២៩៦ ៦៥៣ | ៨ ៧១៥ ១៩១ | ៨ ៣២៤ ០៩៧ | ៨ ៣៣៨ ៤៧៧ | ៦,១៦% |
| ២ | CamGSM | ៣ ៤៥១ ៥២៥ | ៤ ៣៦៦ ៩៣៧ | ៤ ១៧២ ៤៧៥ | ៣ ៧៥៤ ០៣២ | ៣ ៨៩៧ ១៥៣ | ១២,៩១% |
| ៣ | Smart Axiata | ៧ ៤៦៥ ៧០១ | ៧ ៤៨៤ ៣៨៨ | ៧ ៤៣៦ ៧៨៨ | ៧ ៣៦៧ ៦០៧ | ៧ ១៨៩ ៥៧៩ | -៣,៧០% |
| ៤ | SEATel | ៣៨៥ ៨២១ | ៤៣៩ ១២៨ | ៤៨១ ០៣១ | ៤៥៣ ៦០៩ | ១៣១ ៤៥៨ | -៦៥,៩៣% |
| ៥ | XinWei | ២៤៧ ៦៥៨ | ៧៧ ៧១៧ | ២១ ៩៥០ | ៤៤៥ | ៤៤១ | -៩៩,៨២% |
| ៦ | Cadcomms | ១១ ៦៧៦ | ១០ ៧០០ | ០ | ០ | ០ | -១០០% |
| | សរុប | ១៩ ៤១៧ ១២៣ | ២១ ៦៧៥ ៥២៣ | ២០ ៨២៧ ៤៣៥ | ១៩ ៨៩៩ ៧៩០ | ១៩ ៥៥៧ ១០៨ | ០,៧២% |

### ៣.៣.២- អតិថិជនប្រើប្រាស់សេវាទូរស័ព្ទអចល័តគិតត្រឹមខែកញ្ញា ឆ្នាំ២០២២

ឯកតា: នាក់

| ល.រ | ប្រតិបត្តិករ | ២០១៨ (១) | ២០១៩ (២) | ២០២០ (៣) | ២០២១ (៤) | ២០២២ (៥) | ប្រៀបធៀប ៦=(៥-១)/១ |
|---|---|---|---|---|---|---|---|
| ១ | Viettel | ១០ ៩១៦ | ៦ ៥៩០ | ៥ ៧៦៨ | ២ ០៦២ | ១ ៦៥៣ | -៨៤,៨៦% |
| ២ | CamGSM | ១ ០៥៣ | ០ | ០ | ២៧៦ | ២១០ | -៨០,០៦% |
| ៣ | Smart Axiata | ១០០ | ១០០ | ០ | ០ | ០ | -១០០% |
| ៤ | SEATel | ៧១ | ៦៩ | ៥ | ៦ | ៣ | -៩៥,៧៧% |
| ៥ | Camintel | ២៦ ៣២៦ | ១៥ ០២៨ | ១២ ៨៨២ | ១១ ៤៣៩ | ១១ ១៩៥ | -៥៧,៤៨% |
| ៦ | Telecom Cambodia | ៣០ ៦៧១ | ២៩ ៦៨២ | ២៩ ០៤០ | ២៦ ៥១៣ | ២៥ ៨១៤ | -១៤,៨៤% |
| ៧ | XinWei | ១៩ ០២០ | ៥ ៩៦៩ | ១ ៦៨៦ | ០ | ០ | -១០០% |
| | **សរុប** | **៨៨ ១៥៧** | **៥៧ ៤៣៨** | **៤៩ ៣៨១** | **៤០ ២៩៦** | **៣៨៨៧៥** | **-៥៥,៩០%** |

### ៣.៣.៣- អតិថិជនប្រើប្រាស់សេវាអ៊ីនធឺណិតចល័តគិតត្រឹមខែកញ្ញា ឆ្នាំ២០២២

ឯកតា: ស៊ីមកាត

| ល.រ | ប្រតិបត្តិករ | ២០១៨ (១) | ២០១៩ (២) | ២០២០ (៣) | ២០២១ (៤) | ២០២២ (៥) | ប្រៀបធៀប ៦=(៥-១)/១ |
|---|---|---|---|---|---|---|---|
| ១ | Viettel | ៥ ៣៧០ ១៨៥ | ៦ ៨៥២ ៥៦៨ | ៦ ៥១៤ ២៦៨ | ៦ ៨៩១ ៧៤០ | ៧ ៣២៧ ២៥៨ | ៣៦,៤៤% |
| ២ | CamGSM | ១ ៦៧១ ០៨១ | ២ ៣៨៧ ៨១៣ | ២ ៥០៥ ១១៦ | ៣ ១៦៧ ១៨៦ | ៣ ០៩៩ ៤០៩ | ៨៥,៤៧% |
| ៣ | Emaxx Telecom | ២ ០៨៦ | ១ ៧៣១ | ០ | ០ | ០ | -១០០% |
| ៤ | Smart Axiata | ៥ ៨៧៩ ៦៦១ | ៦ ៣៩៨ ៤៤៦ | ៦ ៨១៧ ៧៤៤ | ៧ ០២៦ ២៣៥ | ៦ ៩៦៥ ២៦១ | ១៨,៤៦% |
| ៥ | SEATel | ៣៨៥ ៨២១ | ៤៣៩ ១២៨ | ៤៨១ ០៣១ | ៤៥០ ៦០៩ | ១៣១ ៤៥៨ | -៦៥,៩៣% |
| ៦ | Xin Wei | ១៤៨ ៥៩៥ | ៤៦ ៦៣០ | ១៣ ១៦៩ | ១៦០ | ៤៤១ | -៩៩,៧០% |
| ៧ | Cadcomms | ៦២១ | ៤០ | ០ | ០ | ០ | -១០០% |
| | សរុប | **១៣ ៤៥៨ ០៥០** | **១៦ ១២៦ ៣៥៦** | **១៦ ៣៣១ ៣២៨** | **១៧ ៥៣៥ ៩៣០** | **១៧ ៥២៣ ៨២៧** | **៣០,២១%** |

### ៣.៣.៤- អតិថិជនប្រើប្រាស់សេវាអ៊ីនធឺណិតអចល័តគិតត្រឹមខែកញ្ញា ឆ្នាំ២០២២

ឯកតាៈ នាក់

| ល.រ | ប្រតិបត្តិករ | ២០១៨ (១) | ២០១៩ (២) | ២០២០ (៣) | ២០២១ (៤) | ២០២២ (៥) | ប្រៀបធៀប ៦=(៥-១)/១ |
|---|---|---|---|---|---|---|---|
| ១ | Viettel | ៨០ ៥៨២ | ៩៤ ០៤៩ | ១២៧ ២២២ | ១៣០ ៦៨៨ | ២២៥ ៣៩៨ | ១៧៩,៧១% |
| ២ | Cogetel (Online) | ១៤ ៥៥១ | ១៥ ៨៤៤ | ១៦ ៤៤១ | ១៤ ៨១៩ | ១៧ ៨១៩ | ២២,៤៦% |
| ៣ | Telecom Cambodia | ៦ ៥០៦ | ៥ ៩៤៩ | ៥ ៦៦០ | ៣ ៣៣៧ | ៣ ៤០០ | -៤៧,៧៤% |
| ៤ | Ezecom | ៨ ០៧៣ | ៩ ៦៤៩ | ១១ ៥៦៧ | ១៥ ៦៨៧ | ១២៦ ០៤៥ | ១ ៤៦១,៣២% |
| ៥ | Xin Wei | ១២ ៩៧៩ | ១៣ ៧៨២ | ១៥ ៤៥៨ | ២ ៩១០ | ៣ ៥១១ | -៧២,៩៥% |
| ៦ | Camintel | ២ ៥៨៥ | ១ ៣១៩ | ១ ០១៨ | ៩៦៨ | ១ ០២៦ | -៦០,៣១% |
| ៧ | King Technologies | ៦ ១៤៧ | ១០ ១៦៩ | ១៦ ៩៣៤ | ៤៣ ៥៥៤ | ០ | -១០០% |
| ៨ | DTV Star (Digi) | ០ | ០ | ០ | ០ | ០ | ០ |
| ៩ | Cambodian Singmeng | ១៥ ១៩៣ | ២៤ ៤៨៦ | ១៦ ៦៧៩ | ១៣ ៤៧៧ | ០ | -១០០% |
| ១០ | ADCG (Mekong Net) | ១ ០៧២ | ៨៣៣ | ១ ៣២០ | ១ ៦៤៥ | ១១ ៥១០ | ៩៧៣,៦៩% |
| ១១ | Other | ៥ ៦៦០ | ៤៨ ០២៤ | ៧១ ២០៩ | ៦៩ ១៥៨ | ៩៥ ៦៨៩ | ១៥៩០,៦២% |
| | សរុប | ១៥៣ ៣៤៨ | ២២៤ ១០៤ | ២៨៣ ៥០៨ | ៣៣៦ ២៤៣ | ៤៨៤ ៣៩៨ | ២១៥,៨៨% |

### ៣.៣.៥- លិខិតទទួលស្គាល់ លិខិតអនុញ្ញាត និងវិញ្ញាបនបត្រ

ឯកតាៈ ច្បាប់

| ល.រ. | ប្រភេទលិខិត | ២០១៨ (១) | ២០១៩ (២) | ២០២០ (៣) | ២០២១ (៤) | ២០២២ (៥) | ប្រៀបធៀប ៦=(៥-១)/១ |
|---|---|---|---|---|---|---|---|
| ១ | វិញ្ញាបនបត្រទទួលស្គាល់ជាភ្នាក់ងារនាំចូលបរិក្ខារ | ៤ | ៤ | ៥ | ០ | - | - |
| ២ | លិខិតអនុញ្ញាតនាំចូលបរិក្ខារទូរគមនាគមន៍ | ៧៣ | ៩៣ | ៧០ | ៤៩ | - | - |
| ៣ | ទទួលស្គាល់បរិក្ខារទូរគមនាគមន៍ | ៦១ | ៤២ | ៣៤ | ២១៩ | - | - |
| ៤ | ចុះឈ្មោះដែនជាតិ | ៣ ៤៥៨ | ៣ ៧១៨ | ៣ ៨៧២ | ៣ ០៣១ | ៣ ០៩០ | -១០,៦៤% |
| ៥ | អ៊ីនធឺណិតកាហ្វេ | ១៥២ | ១១១ | ៣៦ | ៤ | ១ | -៩៩,៣៤% |

### ៣.៣.៦- ទិន្នន័យបណ្តាញខ្សែកាប្លិ៍អុបទិកមេលើគោក

ឯកតាៈ គ.ម.

| ល.រ. | ប្រតិបត្តិករ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ (ត្រីមាសទី២) |
|---|---|---|---|---|---|---|
| ១ | CFOCN | ១៦ ០៥៩ | ១៦ ៨៤១ | ១៧ ០៩៩ | ១៧ ០៩៩ | ១៧ ០៩៩ |
| ២ | Telecom Cambodia | ២ ៣២២ | ២ ២៩១,៦ | ២ ១៨០ | ២ ១៨០ | ២ ១៨០ |
| សរុប | | ១៨ ៣៨១ | ១៩ ១៣២,៦ | ១៩ ២៧៩ | ១៩ ២៧៩ | ១៩ ២៧៩ |

### ៣.៣.៧- ទិន្នន័យបណ្តាញខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រ

ឯកតា: គ.ម.

| ល.រ | ប្រតិបត្តិករ | សហគមន៍ Submarine Cable | ប្រវែងក្នុងដែនសមុទ្រកម្ពុជា | ប្រវែងពីឆ្នេរខ្មែរទៅ Branch Unit(BU) | ប្រវែងSubmarine Cableសរុប | កាលបរិច្ឆេទចាប់ផ្តើមដំណើរការ |
|---|---|---|---|---|---|---|
| ១ | CFOCN | AAE-1 | ១៧០ | ៣៨០ | ២៥ ០០០ | ត្រីមាសទី១ ឆ្នាំ២០១៧ |
| ២ | TelecoTech | MCT | ៤៧០ | ៥៤ | ១ ៣០០ | ខែកក្កដា ឆ្នាំ២០១៨ |

## ៤- ការងារនិយតកម្មប្រេកង់វិទ្យុ

### ៤.១- ការងារផ្តល់អាជ្ញាបណ្ណប្រេកង់វិទ្យុ

ឯកតា: អាជ្ញាបណ្ណ

| ល.រ | ប្រភេទលិខិត | គិតត្រឹមខែកញ្ញា ឆ្នាំ២០២២ | | | | |
|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
| ១ | អាជ្ញាបណ្ណប្រេកង់វិទ្យុយកកម្រៃ | ២ ៩៦៩ | ៣ ២០៣ | ៣ ១១១ | ១១ | ០ |
| ២ | អាជ្ញាបណ្ណប្រេកង់វិទ្យុអនុគ្រោះដោយមិនគិតកម្រៃ | ៤១៩ | ១១៤ | ៩៤ | ១២៨ | ១២៨ |

### ៤.២- ការងារនិយ័តកម្ម និងការផ្តល់លិខិតអនុញ្ញាតនិងវិញ្ញាបនបត្រ

| ល.រ | ប្រភេទលិខិត | គិតត្រឹមខែកញ្ញា ឆ្នាំ២០២២ | | | | |
|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
| ១ | វិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនៃគ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍(RF-Type Approval) | ២៧៣ | ៣២៤ | ៣៦០ | ៥៩៣ | ១ ១៤៨ |
| ១.១ | ការកែសម្រួលវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនៃគ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ | ០ | ០ | ០ | ៤ | ៣ |
| ១.២ | វិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនៃគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍(TR-Type Approval) | ០ | ០ | ០ | ០ | ២៨៩ |
| ២ | វិញ្ញាបនបត្រទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូល ផ្គត់ផ្គង់និងចែកចាយគ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍និងគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ | ១ | ៦ | ១ | ២៧ | ២១ |
| ៣.១ | លិខិតអនុញ្ញាតនាំចូលគ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ (RF-Import) | ៣០ | ២៥ | ២១ | ៥ | ៤៨ |
| ៣.២ | លិខិតអនុញ្ញាតនាំចូលគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ (TR-Import) | ០ | ០ | ០ | ០ | ១៦ |
| ៤ | លិខិតអនុញ្ញាតបើកលក់ និង/ឬជួសជុលគ្រឿងសម្ភារៈបរិក្ខារវិទ្យុគមនាគមន៍ | ១៨ | ៨ | ១១ | ០ | ០ |

### ៤.៣- ការងារត្រួតពិនិត្យប្រេកង់វិទ្យុ និងការផ្តល់លិខិតអនុញ្ញាត

| ល.រ. | ប្រភេទលិខិត | គិតត្រឹមខែកញ្ញា ឆ្នាំ២០២២ | | | | |
|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
| ១ | លិខិតអនុញ្ញាតបំពាក់គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ និងវិទ្យុគមនាគមន៍ | ០ | ០ | ០ | ០ | ២៩ |

| | | | | | | |
|---|---|---|---|---|---|---|
| ២ | លិខិតអនុញ្ញាតស្ថាបនាបង្គោលអង់តែនទូរគមនាគមន៍ | ០ | ០ | ០ | ០ | ១៥២ |
| ៣ | លិខិតអនុញ្ញាតរុះរើបង្គោលអង់តែនទូរគមនាគមន៍ | ០ | ០ | ០ | ០ | ៥ |

## ៥- ការងារប្រកួតប្រជែងនិងការពារអ្នកប្រើប្រាស់

### ៥.១- ការងារកម្រិតគុណភាពសេវា

- រៀបចំលិខិតទៅក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទឱ្យរៀបចំរថយន្ត ដែលមានបំពាក់ស្ថានីយ៍ទូរស័ព្ទចល័តចំនួន១០៣លើក

- ចុះបេសកកម្មវាស់ស្ទង់កម្រិតគុណភាពសេវានៅតាមបុរីក្នុងរាជធានីភ្នំពេញ និងតាមបណ្តាខេត្តចំនួន៩៥លើក។

### ៥.២- ការងារដោះស្រាយវិវាទ

- តាមដាន និងសិក្សាលើបណ្តាញសង្គមករណីវិវាទរបស់អ្នកប្រើប្រាស់លើវិស័យទូរគមនាគមន៍
- សម្របសម្រួលវិវាទរវាងក្រុមហ៊ុនជាមួយអ្នកប្រើប្រាស់ចំនួន ១០ករណី
- សម្របសម្រួលវិវាទរវាងក្រុមហ៊ុនជាមួយក្រុមហ៊ុនចំនួន ១៤ករណី។

### ៥.៣- ការងារប្រកួតប្រជែង

- ពិនិត្យលើពាក្យស្នើសុំឃោសនាពាណិជ្ជកម្មរបស់ក្រុមហ៊ុនចំនួន ៣២ច្បាប់
- អនុញ្ញាតឱ្យការធ្វើការឃោសនាពាណិជ្ជកម្មរបស់ក្រុមហ៊ុនចំនួន ១៨ច្បាប់
- ធ្វើលិខិតណែនាំទៅបណ្តាប្រតិបត្តិករផ្តល់សេវាទូរស័ព្ទចល័តចំនួន ៣៨លើក។

### ៥.៤- ការងារការពារអ្នកប្រើប្រាស់

- រៀបចំដំណើរការលេខកូដខ្លី១២០០ ឬ*១២០០# ជាភាសាខ្មែរនិងភាសាអង់គ្លេសដើម្បីផ្តាច់គម្រោងឬសេវាកម្មនានារបស់ប្រតិបត្តិករផ្តល់សេវាទូរស័ព្ទចល័តទាំងអស់

- រៀបចំដំណើរការលេខកូដរួម *១២០១#(ពិនិត្យមើលសមតុល្យ) *១២០២# (ពិនិត្យមើលអត្តសញ្ញាណអ្នកប្រើប្រាស់) *១២០៣ *PIN# (បញ្ចូលទឹកប្រាក់) និង១២០៤(ទំនាក់ទំនងសេវាបម្រើអតិថិជន)

- បញ្ឈប់រាល់ការរំខាននានាដល់អ្នកប្រើប្រាស់ ដោយការហៅចូលមកលេខទូរព្ទចល័តរបស់អតិថិជន
- សេវានោះពុំមានការចុះឈ្មោះប្រើប្រាស់ជាមុនពីអ្នកប្រើប្រាស់
- ពង្រឹងគុណភាពនៃការបោះពុម្ពសន្លឹកកាតកោសបញ្ចូលទឹកប្រាក់ទូរស័ព្ទ(Scratch Card) ដែលបានលក់ជូនអ្នកប្រើប្រាស់។

## មុំទី៤- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងធនាគារ

### ១-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចការងារបានដូចខាងក្រោយៈ

(Facebook page:https://www.facebook.com / ministry.economy.finance)

### ១.១- ការពង្រឹងអភិបាលកិច្ចល្អ

សមិទ្ធផល និងវឌ្ឍនភាពនៃការពង្រឹងអភិបាលកិច្ចល្អរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានដូចខាងក្រោមៈ

- បានរៀបចំនិងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំនូវផែនការសកម្មភាពពង្រឹងអភិបាលកិច្ចល្អ ព្រមទាំងបានអនុវត្តប្រកបដោយប្រសិទ្ធភាព
- បានបិទផ្សព្វផ្សាយនូវអភិក្រមការងារ៤ប្រការរបស់ ក.ស.ហ.វ.
- ការបើកផ្តល់ទូទាត់ជូនក្រសួង ស្ថាប័ន អត្ថគាហកៈ (អ្នកទទួលផល)៖ បានអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមរយៈការផ្ទេរត្រង់ចូលគណនីរបស់អត្ថគាហកៈបានលឿន និងទាន់ពេលវេលា លែងមានបំណុលកកស្ទះ អាស្រ័យដោយមានការគ្រប់គ្រងនិងធ្វើផែនការសាច់ប្រាក់បានយ៉ាងល្អប្រសើរនិងកាន់តែមានភាពសុក្រឹត្យ
- កិច្ចការសំខាន់មួយចំនួន ត្រូវបានរៀបចំរួចរាល់និងបន្តអនុវត្តៈ ការដាក់ឱ្យដំណើរការប្រអប់សំបុត្រទទួលពាក្យបណ្តឹង ការបិទផ្លាកសញ្ញាប្រឆាំងអំពើពុករលួយ ការអនុវត្តច្រកចេញចូលតែមួយ ការរៀបចំបញ្ជីអ្នកផ្តល់ព័ត៌មាន និងក្តារខៀនផ្តល់ព័ត៌មាន ការហាមឃាត់អ្នកក្រៅ (អ្នករត់ការ)ចេញចូលក្នុងកន្លែងធ្វើការ លើកលែងតែករណីខុស ឬខ្វះលិខិតយុត្តិការ
- បានរៀបចំបទបញ្ជាផ្ទៃក្នុងទាំងនៅតាមបណ្តានាយកដ្ឋាននៃអគ្គនាយកដ្ឋានថ្នាក់ជាតិ ក៏ដូចជានៅតាមបណ្តាមន្ទីររាជធានី ខេត្ត។

ទន្ទឹមនេះ ក.ស.ហ.វ. បានបន្តគ្រប់គ្រងការបើកបៀវត្សតាមប្រព័ន្ធធនាគារ ដែលមានវឌ្ឍនភាពល្អប្រសើរ ដោយបានបន្តរក្សាបានប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល យោធិន កងកម្លាំងនគរបាលជាតិ និងការបើកផ្តល់ប្រាក់របបសន្តិសុខសង្គមជូន ប.ជ.ស. និង ប.ជ.អ. បានទាន់ពេលវេលានៅក្នុង១ខែ ចំនួនពីរលើក ដែលលើកទី១ នៅសប្តាហ៍ទី២ និងលើកទី២ នៅសប្តាហ៍ទី៤ នៃខែនីមួយៗ ដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។

- មន្ត្រីរាជការស៊ីវិលទាំងអស់ (រាប់បញ្ចូលទាំងមន្ត្រីក្រសួងមហាផ្ទៃ-ផ្នែករដ្ឋបាលស៊ីវិល) បានបើកបៀវត្សតាមប្រព័ន្ធធនាគារពេញលេញ១០០%។ ចំពោះមន្ត្រីជាប់កិច្ចសន្យាក៏បានអនុវត្តតាមប្រព័ន្ធធនាគារផងដែរ
- ចំពោះក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ អនុវត្តបានចំនួន៦០ ៨០៦នាក់ (ក្នុងចំណោមកងកម្លាំងចំនួន៦១ ៥៣៣នាក់ ដែលបានអនុវត្តតាមប្រព័ន្ធធនាគារ។ ក្រៅពីនេះ មានមន្ត្រីចំនួន៧២៧នាក់ ដែលមិនទាន់បានបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារ។
- ក្រសួងការពារជាតិ(ក្នុងផែនការដំហានដំបូងចំនួន១០ ០០០នាក់) ទើបអនុវត្តបានចំនួន ៤ ៥៧៧នាក់
- ក្នុងការអនុវត្តការបើកបៀវត្សតាមប្រព័ន្ធធនាគារកន្លងមក បានរកឃើញមន្ត្រីមានភាពមិនប្រក្រតី សរុបចំនួន៤ ២៥៥នាក់ ក្នុងនោះបានលុបចេញពីក្របខ័ណ្ឌចំនួន២ ៨២១នាក់ និងបានដាក់ឱ្យព្យួរចំនួន១ ៤៣៤នាក់ ។

## ១.២- ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច

### ស្ថានភាពទូទៅនៃម៉ាក្រូសេដ្ឋកិច្ចកម្ពុជាពីឆ្នាំ ២០១៨-២០២៣

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ ប៉ាន់ | ២០២៣ គ្រោង |
|---|---|---|---|---|---|---|
| កំណើនសេដ្ឋកិច្ច (%) | ៧,៥ | ៧,១ | -៣,១ | ៣,០ | ៥,៤ | ៦,៦ |
| ទំហំសេដ្ឋកិច្ច (ប៊ីលានរៀល) | ៩៩ ៥៤៤ | ១១០ ០១៤ | ១០៥ ៨៩២ | ១១០ ៥០៦ | ១២០ ៣១០ | ១៣១ ២៦៥ |
| ផលិតផលក្នុងស្រុកសរុប (ផ.ស.ស) ក្នុងមនុស្សម្នាក់ | ១ ៥៦៣ | ១ ៧០០ | ១ ៦០៥ | ១ ៦៥៩ | ១ ៧៨៥ | ១ ៩២៤ |
| អត្រាអតិផរណា | ២,៥ | ១,៨ | ២,៩ | ២,៩ | ៥,០ | ២,៥ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ(២០១៨-២០២១) និងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២៣(២០២២-២០២៣)*

សេដ្ឋកិច្ចកម្ពុជាសម្រេចបានអត្រាកំណើនក្នុងរង្វង់ប្រមាណ៧,៥% និង៧,១%រៀងគ្នា សម្រាប់ឆ្នាំ២០១៨ និង២០១៩(មុនវិបត្តិកូវីដ-១៩) គាំទ្រដោយវិស័យចន្ទល់កំណើនសំខាន់ៗ រួមមាន កម្មន្តសាល(កាត់ដេរនិងមិនមែនកាត់ដេរ) សំណង់ និងអចលនទ្រព្យ កសិកម្ម និងទេសចរណ៍។ កំណើននេះ បានធ្វើឱ្យជីវភាពប្រជាជនគ្រប់ស្រទាប់មានភាពល្អប្រសើរដោយ ផ.ស.ស. សម្រាប់មនុស្សម្នាក់ បានកើនឡើងប្រមាណ១ ៥៦៣ និង១ ៧០០ ដុល្លារអាម៉េរិក រៀងគ្នាសម្រាប់ឆ្នាំ២០១៨ និង២០១៩។ គម្លាតនៃប្រាក់ចំណូលរបស់ប្រជាជនមានការធ្លាក់ចុះជាលំដាប់ ស្របពេលដែលអត្រាភាពក្រីក្រក៏បានធ្លាក់ចុះជាបន្តបន្ទាប់។ ទន្ទឹមនេះ អត្រាអតិផរណាសម្រេចបានក្នុងរង្វង់២,៥% និង១,៨% រៀងគ្នា សម្រាប់ឆ្នាំ២០១៨ និង២០១៩ ស្របពេលដែល អត្រាប្តូរប្រាក់គឺស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានក្នុងរង្វង់៤ ០៤៥ និង៤ ០៥៥ រៀលក្នុងមួយដុល្លារអាម៉េរិក។

ដោយឡែកក្នុងឆ្នាំ២០២០ កំណើនសេដ្ឋកិច្ចកម្ពុជា មិនខុសពីបណ្តាប្រទេសនានាលើសកលលោក បានធ្លាក់ចុះក្នុងអត្រា-៣,១% ដោយសារផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ លើវិស័យចន្ទល់កំណើនសេដ្ឋកិច្ច រួមមានវិស័យកាត់ដេរ សំណង់និងអចលនទ្រព្យ និងទេសចរណ៍។ ការណ៍នេះ បានធ្វើឱ្យ ផ.ស.ស.សម្រាប់មនុស្សម្នាក់បានធ្លាក់ចុះមកត្រឹមប្រមាណ១ ៦០៥ ដុល្លារអាម៉េរិកក្នុងឆ្នាំ២០២០ ។ យ៉ាងណាមិញ រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**បានដាក់ចេញនូវវិធានការអន្តរាគមន៍ប្រកបដោយបុរេសកម្ម ពោលទាំងវិធានការសុខាភិបាល និងរដ្ឋបាលនានា សំដៅកាត់បន្ថយ និងកាត់ផ្តាច់ប្រភពចម្លង និងវិធានការអន្តរាគមន៍ផ្សេងទៀត និងកាត់បន្ថយផលប៉ះពាល់ ឱ្យបានជាអតិបរមានៃវិបត្តិនេះមកលើសង្គម-សេដ្ឋកិច្ច ។

ជាក់ស្តែង រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការចំនួន១០ជុំ ក្នុងគោលដៅទ្រទ្រង់និងស្តារជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសកម្មភាពអាជីវកម្មដែលទទួលរងនូវផលប៉ះពាល់ ដែលក្នុងនោះវិធានការចំពោះមុខគឺទប់ស្កាត់ឱ្យបាននូវការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ព្រមទាំងរក្សាលំនឹងជីវភាពប្រជាជន រួមមានជនក្រីក្រជនងាយរងគ្រោះនិងកម្មករនិយោជិត ក្នុងស្ថានភាពដ៏លំបាកនេះ តាមរយៈការអនុវត្តនូវកម្មវិធីនិងវិធានការមួយចំនួនរួមមាន៖

- ការអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្មសម្រាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ និងការគាំទ្រកសិករសម្រាប់ឆ្នាំ២០២០-២០២២
- ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងកំលុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩

- ការផ្តល់ប្រាក់ឧបត្ថម្ភចំនួន៤០ដុល្លារអាមេរិកក្នុង១ខែ សម្រាប់កម្មករ និយោជិតម្នាក់ ដែលធ្វើការក្នុងវិស័យកាត់ដេរ(រោងចក្រវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង ផលិតផលធ្វើដំណើរ និងកាបូប) និងវិស័យទេសចរណ៍(សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន និងភ្នាក់ងារទេសចរណ៍) ដែលត្រូវបានព្យួរការងារ
- ការផ្តល់កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចសន្យាការងារ
- ការផ្តល់សេវាជួយរកការងារឱ្យកម្មករធ្វើតាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារ ។

ផ្អែកលើវិធានការអន្តរាគមន៍នានា គួបផ្សំនឹងការសម្រេចបាននូវអត្រាខ្ពស់នៃការចាក់វ៉ាក់សាំងសំដៅបង្កើតឱ្យមានភាពស៊ាំសហគមន៍ បានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាងើបឡើងវិញក្នុងអត្រា ៣,០% ក្នុងឆ្នាំ២០២១ ហើយបានឆ្ពោះទៅកាត់ផ្តាច់ ព្រឹត្តិការណ៍សហគមន៍២០ កុម្ភៈ ដោយជោគជ័យកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ កន្លងទៅនេះ។ ជាមួយគ្នានេះ ផ.ស.ស. ក្នុងមនុស្សម្នាក់កើនឡើងពី១ ៦០៥ ដុល្លារអាមេរិក ក្នុងឆ្នាំ២០២០ ដល់ ១ ៦៥៩ ដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ ។

ទន្ទឹមនេះ សកម្មភាពសេដ្ឋកិច្ចបានវិលត្រឡប់ទៅរកប្រក្រតីភាពឡើងវិញ ក្រោមការប្រកាសបើកប្រទេសឡើងវិញជាផ្លូវការ ដែលបានធ្វើឱ្យស្ថានភាពការងារ និងចំណូលជារួម ចាប់ផ្តើមមាននិន្នាការទៅរកភាពល្អប្រសើរឡើងវិញ ស្របនឹងការអនុវត្ត "**ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ២០២១-២០២៣**" ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីនេះមានគោលបំណងស្តារកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងពេលចំពោះមុខនិងរយៈពេលមធ្យមឱ្យត្រឡប់ទៅកំណើនសក្តានុពល និងពង្រឹងភាពធន់សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយចីរភាព និងបរិយាបន្នក្នុងរយៈពេលវែង ដែលការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីនេះផងដែរ ឈរលើសសរស្តម្ភចំនួន៣ (ឬហៅថា 3Rs) គឺ (១) ការស្តារឡើងវិញ(Recovery) (២) ការកែទម្រង់(Reform) និង(៣) ការកសាងភាពធន់ (Resilience)។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា(ថ្មី) ដែលមានភាពទាក់ទាញ ប៉ាន់ប្រមាណទុកជាមុននិងច្បាស់លាស់ ដើម្បីជំរុញលំហូរវិនិយោគថ្មី ដែលមានតម្លៃបន្ថែមខ្ពស់។ រាជរដ្ឋាភិបាលក៏កំពុងពន្លឿនការដាក់ចេញនូវអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជានេះ ក៏ដូចជាក្របខ័ណ្ឌគតិយុត្តនៃការវិនិយោគដទៃទៀត ដូចជាច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេសជាដើម។

សម្រាប់ឆ្នាំ២០២២ សេដ្ឋកិច្ចកម្ពុជារំពឹងថានឹងបន្តងើបឡើងក្នុងរង្វង់៥% ដោយសារការបន្តវិលទៅរកប្រក្រតីភាពវិញនៃសកម្មភាពសេដ្ឋកិច្ច(រួមមានវិស័យទេសចរណ៍ និងសេវាកម្មគាំទ្រផ្សេងទៀត) គួបផ្សំនឹងការបន្តនិន្នាការល្អប្រសើរនៃតម្រូវការខាងក្រៅ ដែលនឹងបន្តគាំទ្រដល់វិស័យកម្មន្តសាល(កាត់ដេរនិងមិនមែនកាត់ដេរ)។ ឈរលើមូលដ្ឋាននេះ ផ.ស.ស. សម្រាប់មនុស្សម្នាក់នឹងបន្តកើនឡើងដល់ ប្រមាណ១ ៧៨៥ ដុល្លារអាមេរិក។ ទោះជាយ៉ាងនេះក្តី អត្រាអតិផរណារំពឹងថានឹងកើនឡើងក្នុងរង្វង់៥,០% ដោយសារការកើនឡើងថ្លៃទំនិញ ជាពិសេសថ្លៃប្រេងអន្តរជាតិដែលបង្កឡើងដោយសង្គ្រាមរុស្ស៊ី អ៊ុយក្រែន។

## ១.៣- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ១.៣.១. ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

#### ១.៣.១.១- សមិទ្ធផលសម្រេចក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រយៈពេល ៥ឆ្នាំ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីកែទម្រង់ស្នូលមួយ នៃកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីឈានឆ្ពោះទៅពង្រឹងអភិបាលកិច្ច។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលកំណត់ចក្ខុវិស័យវែងឆ្ងាយ និងប្រាកដនិយមមួយនោះគឺ "*ការកែប្រែប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជាក្លាយជាប្រព័ន្ធមួយដែលផ្តោតលើលទ្ធផល សមិទ្ធកម្មនិងវិមជ្ឈការស្របតាមស្តង់ដានិងឧត្តមានុវត្តន៍អន្តរជាតិ*"។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានអនុវត្តក្នុងអភិក្រមជាខឿន (Platform Approach) ដែលសំដៅលើការអនុវត្តតាមដំណាក់កាលនីមួយៗជាលក្ខណៈបុរេលក្ខខណ្ឌចាំបាច់ មុននឹងការឈានទៅដំណាក់កាលថ្មី។ ក្នុងន័យនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានបែងចែកជា៤ដំណាក់កាល ដែលសម្រេចបានសមិទ្ធផលសំខាន់ៗក្នុងរយៈពេល៥ឆ្នាំចុងក្រោយ(២០១៨ ដល់ ២០២២) ដូចខាងក្រោម ៖

**ដំណាក់កាលទី១ គឺ "*ភាពជឿទុកចិត្តបាននៃថវិកា*"** ដែលបានដាក់ឱ្យអនុវត្តពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៨ និងបន្តការអនុវត្តរហូតដល់បច្ចុប្បន្ន។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ភាពជឿទុកចិត្តនៃថវិការក្សាបាននូវភាពរឹងមាំនិងឆ្លុះបញ្ចាំងពីភាពធន់នៃហិរញ្ញវត្ថុសាធារណៈ ដែលបានកសាងកន្លងមក។ ការអនុវត្តថវិកា (ចំណូល-ចំណាយ) ស្ថិតក្នុងរង្វង់+/-៥% នៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបង្ហាញពីភាពរលូន និងអាចប៉ាន់ប្រមាណក្នុងការឆ្លើយតបបានតាមសភាពការណ៍។ ជាក់ស្តែង ចំណូលថវិការដ្ឋមានការកើនពី២១,៩៧ ទ្រីលានរៀល ក្នុងឆ្នាំ២០១៨ ដល់២២,១៦ ទ្រីលានរៀល ក្នុងឆ្នាំ២០២១ (ស្មើនឹងប្រមាណ១០៤%) នៃច្បាប់ហិរញ្ញវត្ថុ ខណៈការអនុវត្តចំណាយមានទំហំប្រមាណ១៩,៦៣ទ្រីលានរៀល ក្នុងឆ្នាំ២០១៨(ស្មើនឹង៩៩%) នៃច្បាប់ហិរញ្ញវត្ថុនិង២៦,១៥ទ្រីលានរៀល ក្នុងឆ្នាំ២០២១(ស្មើនឹងប្រមាណ៩៥%) នៃច្បាប់ហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះ ការគ្រប់គ្រងសាច់ប្រាក់ក៏ស្ថិតក្នុងស្ថានភាពល្អប្រសើរ ពោលគឺគ្មានបំណុលកកស្ទះ ហើយប្រាក់បៀវត្សនិងប្រាក់បំណាច់ផ្សេងៗរបស់មន្ត្រីរាជការ និងបុគ្គលិករដ្ឋ ត្រូវផ្ទេរផ្ទាល់ចូលក្នុងគណនីធនាគារ ២ដង ក្នុងមួយខែ។ បន្ថែមពីនេះ កំណើនចំណូលចរន្តធៀបនឹងផ.ស.ស. រក្សាបានទំហំវិជ្ជមានក្នុងរង្វង់ជាមធ្យមប្រមាណ៣,០១% ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ប៉ុន្តែស្ថិតក្នុងកម្រិតអវិជ្ជមានប្រមាណ-២,៦៨ ពិន្ទុភាគរយនៃផ.ស.ស. ដោយសារវងផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩។ ទោះជាយ៉ាងណា ស្ថានភាពនេះចាប់ផ្តើមមានភាពប្រសើរឡើងវិញជាបណ្តើរៗចាប់ពីដើមឆ្នាំ២០២២តទៅ។ ចំពោះស្ថានភាពបំណុលសាធារណៈរបស់កម្ពុជាមានលក្ខណៈល្អប្រសើរជាលំដាប់ ពោលគឺមានចីរភាពនិងហានិភ័យកម្រិតទាប ព្រោះរាជរដ្ឋាភិបាលបានប្រកាន់ខ្ជាប់នូវស្មារតីប្រុងប្រយ័ត្នខ្ពស់ ដោយបានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍គន្លឹះទាំង៥ ដូចមានចែងក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ។

**ដំណាក់កាលទី២ "គណនេយ្យភាពហិរញ្ញវត្ថុ"** ដែលបានដាក់ឱ្យអនុវត្តពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥ និងបន្តការអនុវត្តរហូតដល់បច្ចុប្បន្ន ជាដំណាក់កាលដែលពាក់ព័ន្ធនឹងការដាក់ឱ្យអនុវត្តមាតិកាថវិកា ស្តង់ដាគណនេយ្យនិងប្លង់គណនី និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ ដំណាក់កាលនេះបានសម្រេចសមិទ្ធផលគន្លឹះៗមួយចំនួន។ ក្នុងនោះ ប្រព័ន្ធ

FMIS ត្រូវបានពង្រីកដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួងស្ថាប័ន និងបានពង្រីកដល់រដ្ឋបាលរាជធានីខេត្តទាំង២៥ ជាផ្លូវការសម្រាប់ប្រតិបត្តិការឆ្នាំ២០២២។ ចំពោះការធ្វើស្វ័យប្រវត្តិកម្មប្រព័ន្ធFMIS ពេញលេញត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការ ជាបណ្តើរៗ ដោយចាប់ផ្តើមពីក្រសួងចំនួន២ដំបូង គឺ ក្រសួងបរិស្ថាន និងក.ស.ហ.វ. ដែលក្នុងន័យនេះ ការអនុវត្តតាមប្រព័ន្ធ FMIS អាចជួយពន្លឿនការបើកផ្តល់សាច់ប្រាក់ និងបិទបញ្ជីគណនេយ្យទាន់ពេលវេលា។ ចំពោះការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាលកន្លងមក ជាពិសេសនៅឆ្នាំ២០២០ ត្រូវបានវាយតម្លៃដោយIMF និងនិយ័តករគណនេយ្យ និងសវនកម្មថាមានភាពល្អប្រសើរ និងសមស្របតាមIPSAS Cash Basis។ ក្រៅពីនោះ លិខិតបទដ្ឋានគតិយុត្តនានាដើម្បីពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុត្រូវបានរៀបចំជាបណ្តើរៗ ដើម្បីជំរុញការគ្រប់គ្រងនិងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងជំរុញការរៀបចំបណ្ណកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋជាដើម។

**ដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកានឹងគោលនយោបាយ"** បានដាក់ឱ្យអនុវត្តពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២២ ដោយផ្តោតសំខាន់លើការផ្សារភ្ជាប់រវាងគោលដៅនិងគោលបំណងនៃការរៀបចំនិងអនុវត្តថវិកាទៅនឹងគោលនយោបាយរបស់ក្រសួងស្ថាប័ន ។ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ការរៀបចំថវិកាកម្មវិធីរបស់ក្រសួងស្ថាប័នត្រូវបានពង្រឹងជាបណ្តើរៗ តាមរយៈការដាក់ឱ្យអនុវត្តក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ដែលជាមូលដ្ឋានរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួងស្ថាប័ននៅកម្រិតថវិកាថ្នាក់ជាតិក៏ដូចជាការជំរុញការធ្វើសមាហរណកម្មផែនការថវិការវាងថវិកាចរន្តនិងមូលធន។ ក្រៅពីនោះ លិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការវិនិយោគសាធារណៈ និងការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP ត្រូវបានរៀបចំ និងអនុម័តរួចរាល់។

**ដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម"** ជាដំណាក់កាលចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានគ្រោងដាក់ឱ្យអនុវត្តនៅឆ្នាំ ២០២៣ ដល់ ឆ្នាំ២០២៧ ក្នុងគោលដៅកសាង វប្បធម៌សមិទ្ធកម្ម ក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ។ ដំណាក់កាលនេះ ត្រូវបានកំណត់គោលដៅសម្រាប់ការងារបន្ត ដូចខាងក្រោម៖

### ១.៣.១.២- សមិទ្ធផលក្នុងការគ្រប់គ្រងប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានសម្រេចបាននូវសមិទ្ធផលជាច្រើន ក្នុងការបង្កើនប្រសិទ្ធភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS) ជាផ្លូវការនៅអង្គភាពថវិកាថ្នាក់ជាតិនិងអង្គភាពថវិកាថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រង និងកត់ត្រាប្រតិបត្តិការពាក់ព័ន្ធនឹងការធានាចំណាយថវិកា កិច្ចលទ្ធកម្ម ចំណាយថវិកា ចំណូលថវិកា ចលនាឥណទានថវិកា កិច្ចបញ្ជីការគណនេយ្យនិងប្រតិបត្តិការហិរញ្ញវត្ថុនានា ។

គិតចាប់ពីឆ្នាំ២០១៨ ដល់២០២២ ការដ្ឋានប្រើប្រាស់ប្រព័ន្ធFMIS កើនបន្ថែមសរុបចំនួន១២៣ និងអ្នកប្រើប្រាស់ប្រព័ន្ធ FMIS កើនបន្ថែមសរុបប្រមាណ១ ៦០០ រូប ដែលក្នុងនោះរួមមាន៖

- ២០១៨ ៖ ក្រសួង ស្ថាប័នចំនួន១០ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន១១ មានអ្នកប្រើប្រាស់ប្រមាណ២៧២រូប
- ២០១៩ ៖ ក្រសួង ស្ថាប័នចំនួន១០ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្តទាំង២៥ ដែលមានអ្នកប្រើប្រាស់ប្រមាណ៤៧០រូប

- ២០២០៖ ក្រសួង ស្ថាប័នចំនួន១៧ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន១៣ ដែលមានអ្នកប្រើប្រាស់ប្រមាណ៥៥០រូប
- ២០២១៖ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន២ ដែលមានអ្នកប្រើប្រាស់ប្រមាណ ៥២រូប
- ២០២២៖ រដ្ឋបាលរាជធានី ខេត្តទាំង២៥ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១០ ដែលមានអ្នកប្រើប្រាស់ប្រមាណ២៦២រូប ។

សមិទ្ធផលនៃការងាររៀបចំនិងអនុវត្តប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវឌ្ឍនភាពការងារផ្សេងទៀត ដែលសម្រេចបានរួមមាន៖

- ការដាក់ឱ្យអនុវត្តប្រព័ន្ធឯកសារឌីជីថល(FMIS Portal) ជំនាន់ទី១ នៅរដ្ឋបាលស្រុក និងរដ្ឋបាលឃុំ ជំហានទី១ យោងតាមសារាចរលេខ004 សហវ ចុះនៅថ្ងៃទី៩ ខែ ឧសភា ឆ្នាំ២០២២។ ជំហានបឋម នៃឌីជីថលូបនីយកម្មការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិបានដាក់ឱ្យដំណើរការសាកល្បងនូវប្រព័ន្ធឯកសារឌីជីថល(FMIS Portal V1)នេះ បានដាក់ឱ្យដំណើរការនៅរដ្ឋបាលស្រុកចំនួន៧៥ និងរដ្ឋបាលឃុំចំនួន១៨៥ ដែលមានអ្នកប្រើប្រាស់សរុបប្រមាណ៤៥២រូប ក្នុងទិសដៅពន្លឿនការអនុវត្តចំណូល ចំណាយថវិកានិងដើម្បីផ្តល់ភាពងាយស្រួលដល់រដ្ឋបាលស្រុកនិងរដ្ឋបាលឃុំ តាមរយៈការបញ្ជូនឯកសារជាលក្ខណៈឌីជីថលប្រើប្រាស់ប្រព័ន្ធឯកសារឌីជីថល ដំណើរការនៅលើទូរសព្ទវៃឆ្លាត ជំនួសដោយការដឹកជញ្ជូនឯកសារជាក្រដាសដោយផ្ទាល់មកកាន់រតនាគារខេត្ត
- ការកសាងពង្រឹកមជ្ឈមណ្ឌលទិន្នន័យរបស់គម្រោងFMIS បំពាក់ដោយបច្ចេកវិទ្យាទំនើបនិងឧបករណ៍ការពារសុវត្ថិភាពដ៏រឹងមាំស្របតាមស្តង់ដារមជ្ឈមណ្ឌលទិន្នន័យអន្តរជាតិ ព្រមទាំងតាមរយៈការដាក់ឱ្យដំណើរការសន្ធានកម្មទិន្នន័យជាមួយនឹងប្រព័ន្ធខាងក្រៅ។ ជារួមសន្ធានកម្មទិន្នន័យប្រព័ន្ធ FMIS ជាមួយនឹងប្រព័ន្ធខាងក្រៅ រួមមានដូចជា៖ ប្រព័ន្ធពន្ធដារ ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ(NRMIS) ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ(ASYCUDA) ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងបៀវត្សមន្ត្រីរាជការស៊ីវិល ប្រព័ន្ធរបស់ធនាគារជាតិ និង ធនាគារពាណិជ្ជ និង ការទូទាត់តាមEFT
- ការបោះជំហានទៅកាន់ទំនើបភាវូបនីយកម្មនៃការគ្រប់គ្រងថវិកាជាតិ ដោយការប្រើប្រាស់នូវមុខងាររបស់ប្រព័ន្ធ FMIS ក្នុងដំណើរការរៀបចំថវិកាជាតិ ការអនុវត្តចំណូលចំណាយថវិកា ការធ្វើកិច្ចលទ្ធកម្មសាធារណៈ ការធ្វើសវនកម្មហិរញ្ញវត្ថុនិងការផលិតចេញជារបាយការណ៍អនុវត្តថវិកានិងហិរញ្ញវត្ថុពីប្រព័ន្ធ។ មុខងាររបស់ប្រព័ន្ធFMIS មានដូចជា៖ មុខងារវិភាជន៍ថវិកា(BA) មុខងារការទិញ(PO) មុខងារគណនីត្រូវសង(AP) មុខងារគណនីត្រូវទារ(AR) មុខងារគ្រប់គ្រងសាច់ប្រាក់(CM) និងមុខងារសៀវភៅធំ(GL)។ មុខងារថ្មីបន្ថែមដែលទើបអភិវឌ្ឍ និងដាក់ដំណើរការ៖ មុខងាររៀបចំផែនការថវិកា(BP) និងមុខងារលទ្ធកម្មពេញលេញ(PR) ។ មុខងារថ្មីបន្ថែមគ្រោងនឹងអភិវឌ្ឍ៖ មុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ(AM) មុខងារគ្រប់គ្រងសន្និធិ(IM) និងមុខងារលទ្ធកម្មអេឡិចត្រូនិក(e-GP)។ របាយការណ៍អនុវត្តថវិកានិងហិរញ្ញវត្ថុ ផលិតចេញពីប្រព័ន្ធ FMIS(របាយការណ៍ចំនួន៣៨ ដែលបានអភិវឌ្ឍនិងដំណើរការបន្ថែមក្នុងឆ្នាំ២០១៨-២០២២)

មានដូចជា៖ របាយការណ៍តារាងតុល្យការ របាយការណ៍សង្ខេបពីចំណូលនិងចំណាយថវិកាថ្នាក់ជាតិ របាយការណ៍តាមដានឥណទានចំណាយថវិកាថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិរបាយការណ៍អនុវត្តថវិកាតាមចំណាត់ថ្នាក់កម្មវិធីនិងគម្រោង របាយការណ៍សមតុល្យសាច់ប្រាក់ក្នុងធនាគារ របាយការណ៍ធានាចំណាយ របាយការណ៍សម្រាប់ភ្ជាប់នឹងច្បាប់ទូទាត់និងរបាយការណ៍ផ្សេងៗជាច្រើនទៀតសម្រាប់តាមដានការអនុវត្តការងារហិរញ្ញវត្ថុប្រចាំថ្ងៃ

- ការសម្រេចបាននូវលទ្ធផលបឋមពីការទាញយកអត្ថប្រយោជន៍ជាអតិបរមា តាមរយៈការប្រើប្រាស់ប្រព័ន្ធ FMIS ទាំងស្រុងសម្រាប់នីតិវិធីចំណាយការទូទាត់បៀវត្ស និងការទូទាត់ត្រង់ទៅកាន់ក្រសួងស្ថាប័ន ដែលជាមូលដ្ឋានគ្រឹះនៃការកាត់បន្ថយនីតិវិធីពុំចាំបាច់ឬពុំផ្តល់នូវតម្លៃបន្ថែមដល់ដំណើរការនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកាត់បន្ថយការប្រើប្រាស់ធនធាន(ថវិកា ពេលវេលា ជំហានការងារមនុស្សនិងឯកសារជាក្រដាស)
- គិតពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ មន្ត្រីប្រមាណជាង១ ៨០០រូប ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធFMIS នៅក្នុងនោះក៏រួមមានបញ្ចូលនូវវគ្គបណ្តុះបណ្តាលមូលដ្ឋានគ្រឹះនៃការប្រើប្រាស់កុំព្យូទ័រផងដែរ
- ការសម្រេចបាននូវហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍រួមមួយ "តេជោអ៊ិនត្រាណិត" ដែលបានរៀបចំ និងកំពុងដំណើរការនៅក្នុងក្របខ័ណ្ឌគម្រោងអ៊ិនត្រាណិតរបស់ ក.ស.ហ.វ. ដំណាក់កាលទី១ ដោយមានបណ្តាញតភ្ជាប់រួមដែលតភ្ជាប់ដល់គ្រប់ក្រសួង ស្ថាប័ន អង្គភាពថវិកា អាណាប័កផ្ទេរសិទ្ធិនៅគ្រប់ការដ្ឋានប្រើប្រាស់ប្រព័ន្ធFMIS នៅបណ្តារាជធានី ខេត្ត ដែលជាបណ្តាញតភ្ជាប់អាចជំនួសគ្នាទៅវិញទៅមកនិងធានាបាននូវនិរន្តរភាពនៃការតភ្ជាប់ និងទ្រទ្រង់បានដល់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងសេវាអេឡិចត្រូនិកនិងឌីជីថលផ្សេងៗទៀត។

## ១.៣.២- ការអនុវត្តថវិកា

### ១.៣.២.១- ការប្រមូលចំណូល

បន្ទាប់ពីទទួលបានលទ្ធផលជោគជ័យនិងគួរជាទីមោទនៈលើការកៀរគរចំណូល ក្រោមការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រកៀរគរចំណូល២០១៩-២០២៣ ក្នុងការបន្តកែទម្រង់ជាយុទ្ធសាស្ត្រមួយដំណាក់កាលទៀត ដោយបានកំណត់ទស្សនវិស័យវែងឆ្ងាយក្នុងការធ្វើទំនើបភាវូបនីយកម្មរដ្ឋបាល និងគោលនយោបាយចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដោយបន្តផ្តោតសំខាន់លើការកសាងរដ្ឋបាលមួយដែលមានសមត្ថភាពរឹងមាំ ដើម្បីរួមចំណែកគាំទ្រការងារកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ជាពិសេសកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ យុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយប្រកាន់ខ្ជាប់នូវអភិក្រមចំនួន៤ គឺ៖ (១) ធានាចីរភាពកំណើនសេដ្ឋកិច្ច (២) រក្សាបាននូវចីរភាពចំណូលដែលឈានទៅដល់កម្រិតឧត្តមានុពល (៣) ធានានូវយុត្តិធម៌ក្នុងការអនុវត្តគោលនយោបាយសារពើពន្ធនិងមិនមែនសារពើពន្ធ ព្រមទាំងការប្រមូលចំណូល និង(៤) ធានានូវសមធម៌សង្គមដើម្បីចូលរួមចំណែកបន្ធូរបន្ថយបន្ទុកពន្ធដល់ប្រជាជនមានចំណូលទាបបង្កើនសុខុមាលភាពប្រជាពលរដ្ឋ និងរក្សាការពារបរិស្ថាន។ ជាងនេះទៅទៀត យុទ្ធសាស្ត្រនេះបានកំណត់គោលដៅចំនួន២ គឺ៖ (១) ប្រមូលចំណូលចរន្ត

សរុបឱ្យកើនបានយ៉ាងតិច០,៣ ពិន្ទុភាគរយនៃផ.ស.ស. ជាមធ្យមក្នុងមួយឆ្នាំ និង(២) បង្កើនគុណភាពសេវា និងផលិតភាពក្នុងការផ្តល់សេវាគ្រប់ប្រភេទនៃរដ្ឋបាលប្រមូលចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ។

| បរិយាយ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | គ្រោង ឆ្នាំ២០២២ | ឆ្នាំ២០២២* (អនុវត្តគិតត្រឹម ខែ៩ ឆ្នាំ២០២២) |
|---|---|---|---|---|---|---|
| សរុបរួមចំណូលថវិកា(I+II) | ២៤ ៩៩០,៤៨ | ៣១ ០៥២,១២ | ២៨ ៥០០,៣៧ | ២៦ ៩០៨,៩៨ | ៣០ ៥៤៤,៣៧ | ២៣៣៥៣,៥០ |
| I.សរុបចំណូលអនុវត្តឆ្លងកាត់រតនាគារជាតិ(ក+ខ) | ២០ ៦៦៨,២៧ | ២៦ ០២៥,០៣ | ២៣ ៣១២,៦៣ | ២១ ៥៩៥,៤១ | ២៤ ៧៣០,៤៨ | ២០ ២៨២,៥០ |
| ក.ចំណូលចរន្តថ្នាក់ជាតិ | ២០ ១៤៦,៧៤ | ២៥ ៣៩៥,០២ | ២១ ៤២០,៩៩ | ២០ ៤៦៧,០៩ | ២២ ១៥៧,៤៣ | ១៨ ៦១៨,១៤ |
| +ចំណូលសារពើពន្ធ | ១៧ ២៩៦,០៧ | ២២ ០៥២,៩៣ | ១៩ ៣២៩,៥១ | ១៨ ៤៩៦,៥៩ | ២០ ២២៧,០១ | ១៧ ១៤៩,៧៣ |
| -ចំណូលពន្ធគយនិងរដ្ឋាករ | ១០ ១០២,២៣ | ១២ ៨៣៩,៤១ | ៩ ៦៧២,២២ | ៩ ១៤០,៦១ | ១០៤០០,០១ | ៧ ៩៤២,៧២ |
| -ចំណូលពន្ធដារ | ៧ ១៩៣,៨៤ | ៩ ១៥៥,៥៣ | ៩ ៦៥៧,២៩ | ៩ ៣៥៥,៩៨ | ៩ ៨២៧,០០ | ៩ ២០៧,០០ |
| +ចំណូលមិនមែនសារពើពន្ធ | ២ ៨៥០,៦៧ | ៣ ៣៤២,០៩ | ២ ០៩១,៤៨ | ១ ៩៧០,៤៩ | ១ ៩៣០,៤៣ | ១ ៤៦៨,៤១ |
| ខ.ចំណូលមូលធន | ៥២១,៥៣ | ៦៣០,០១ | ១ ៨៩១,៦៤ | ១ ១២៨,៣២ | ២ ៥៧៣,៥៤ | ១ ៦៦៤,៣៦ |
| +ចំណូលមូលធនក្នុងប្រទេស | ១៩៤,៧៤ | ១៨១,៤៣ | ១៨៥,២៤ | ៥៦,៨៨ | ១ ៣០៥,២៦ | ៧៤,៦០ |
| +ចំណូលមូលធន (មូលនិធិទ្រទ្រង់ថវិកា) | ៣២៦,៧៩ | ៤៤៨,៥៨ | ១ ៧០៦,៤០ | ១ ០៧១,៤៤ | ១ ២៦៨,២៨ | ១ ៥៨៩,៧៦ |
| II. សរុបចំណូលអនុវត្ត មិនឆ្លងកាត់រតនាគារជាតិ | ៤ ៣២២,២១ | ៥ ០២៧,០៩ | ៥ ១៨៧,៧៤ | ៥ ៣១៣,៥៨ | ៥ ៨១៣,៤៨ | ៣ ០៧០,៦៤ |

ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានរតនាគារជាតិ ឯកតា៖ ប៊ីលានរៀល

### ❖ ការប្រមូលចំណូលពន្ធដារ

ការប្រមូលចំណូលថវិកាជាតិដោយអគ្គនាយកដ្ឋានពន្ធដារក្នុងរយៈពេល៥ឆ្នាំ ពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២ ទទួលបានលទ្ធផលល្អប្រសើរលើសផែនការកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ទោះបីជាមានការរីករាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ ក៏អគ្គនាយកដ្ឋានពន្ធដារនៅតែបន្តសម្រេចបាននូវចំណូលលើសផែនការ។ ជាក់ស្តែងអគ្គនាយកដ្ឋានពន្ធដារបានប្រមូលចំណូលពន្ធដារលើសផែនការ ជាអាទិ៍សម្រាប់ឆ្នាំ ២០១៨ លើសផែនការប្រមាណ១៤,២៧% សម្រាប់ឆ្នាំ២០១៩ លើសផែនការប្រមាណ២៣,២០% សម្រាប់ឆ្នាំ ២០២០ លើសផែនការប្រមាណ១,៣៦% សម្រាប់ឆ្នាំ២០២១ លើសផែនការប្រមាណ២៤,០២% និងសម្រាប់ឆ្នាំ ២០២២(គិតត្រឹមខែកញ្ញា) អគ្គនាយកដ្ឋានពន្ធដារទទួលបានប្រមាណ៩៥,៥៣% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ២០២២។ ជារួមលទ្ធផលគ្រប់គ្រងប្រមូលចំណូលពន្ធដារ គឺមានស្ថានភាពល្អប្រសើរ និងលើសផែនការប្រចាំឆ្នាំ ហើយនៅបន្តរក្សាបាននូវកំណើនជាបន្តបន្ទាប់សម្រាប់រយៈពេល៥ឆ្នាំ គិតចាប់ពីឆ្នាំ ២០១៨ ដល់ឆ្នាំ២០២២ ។

**តារាងលទ្ធផលចំណូលពន្ធដារ រយៈពេល៥ឆ្នាំពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២**

| ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ខែកញ្ញាឆ្នាំ២០២២ |
|---|---|---|---|---|---|
| ចំណូល (ប៊ីលានរៀល) | ៨ ៧៩១,៤០ | ១១ ២៧៧,៣២ | ១១៧០០,៥២ | ១១ ២៦៦,៧៩ | ១០ ៩០៨,១៩ |
| ចំណូល (លានដុល្លារ) | ២ ១៩៧,៨៥ | ២ ៨១៩,៣៣ | ២ ៨៨៩,០២ | ២ ៧៨១,៩២ | ២ ៦៩៣,៣៨ |
| ភាគរយនៃផែនការប្រចាំឆ្នាំ(%) | ១១៤,២៧ | ១២៣,២០ | ១០១,៣៦ | ១២៤,០២ | ៩៥,៥៣ |
| ភាគរយធៀបនឹងឆ្នាំមុន (%) | ១១១,១៩ | ១២៨,២៨ | ១០៣,៧៥ | ៩៦,២៩ | ១២៧,៥៨ |

ប្រភពទិន្នន័យៈ អគ្គនាយកដ្ឋានពន្ធដារ

❖ **ការប្រមូលចំណូលពន្ធគយ**

ការងារប្រមូលចំណូលពន្ធដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា(អ.គ.រ.) កន្លងមករហូតដល់ឆ្នាំ២០១៩ ទទួលបានលទ្ធផលល្អប្រសើរលើសផែនការកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។ ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ក្នុងឆ្នាំ២០២០ ការប្រមូលចំណូលថវិកាជាតិដោយអ.គ.រ. សម្រេចបានតែប្រមាណ៨៣% ប៉ុណ្ណោះនៃផែនការច្បាប់ និងបានប្រមាណ៩៦% ក្នុងឆ្នាំ២០២១។ សម្រាប់រយៈពេល៩ខែឆ្នាំ២០២២ ការប្រមូលចំណូលសម្រេចបានប្រមាណ៧៦% នៃផែនការច្បាប់ដែលតាមការប៉ាន់ប្រមាណលទ្ធផលចំណូលអាចនឹងសម្រេចបានតាមផែនការកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ២០២២។

**តារាងលទ្ធផលនៃការប្រមូលចំណូលសារពើពន្ធ (តួលេខរតនាគារជាតិ) ពីឆ្នាំ២០១៨-ឆ្នាំ២០២២៖**

| បរិយាយ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ៩ខែ ឆ្នាំ២០២២ |
|---|---|---|---|---|---|
| ផែនការ (ប្រចាំឆ្នាំ) | ៨ ៣៣០,០ | ៩ ០៩៤,០ | ១១ ៦៤៦,១ | ៩ ៤៩៦,០ | ១០ ៤០០,០ |
| **ចំណូលប្រមូលបាន** | **១០ ១០២,២៣** | **១២ ៨៩៧,៤១** | **៩ ៦៧២,២២** | **៩ ១៤០,៦១** | **៧ ៩៤២,៧០** |
| ធៀបនឹងផែនការ | ១២១% | ១៤២% | ៨៣% | ៩៦% | ៧៦% |

ឯកតាៈ ប៊ីលានរៀល

**តារាងលទ្ធផលចំណូលតាមប្រភេទពន្ធ (តួលេខរតនាគារជាតិ) ពីឆ្នាំ២០១៨-ឆ្នាំ២០២២៖**

| ប្រភេទពន្ធ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ៩ខែ ឆ្នាំ២០២២ |
|---|---|---|---|---|---|
| ពន្ធគយ | ១ ៨៤២,០៩ | ២ ៤០២,០៧ | ១ ៧៧៣,៧៩ | ១ ៦៦៩,០៤ | ១ ៥១១,៦៩ |
| អាករនាំចេញ | ៥១,៤៧ | ៤៨,៧៨ | ២៣,៨១ | ៤៣,៥២ | ៤៤,០៨ |
| អាករពិសេស (របបនាំចូល) | ៤ ១០៣,៧៤ | ៥ ៣៤៧,១៨ | ៣ ៦១៩,៨៦ | ៣ ៤៧៨,៦១ | ៣ ០៨១,៣០ |
| អាករលើតម្លៃបន្ថែម (របបនាំចូល) | ៣ ៦២៧,៥៨ | ៥ ៦៣៧,៣២ | ៣ ៨៤០,៥៣ | ៣ ៥១១,៤៤ | ៣ ០០៧,២៣ |
| អាករបន្ថែមលើផលិតផលប្រេង | ៣៤៨,០១ | ៣៨៣,១៣ | ៣៧៣,៣៣ | ៣៩៤,៤៦ | ២៥៣,៨៣ |
| ផ្សេងៗ | ១២៩,៣៥ | ៧៨,៩១ | ៤០,៩០ | ៤៣,៥៤ | ៤៤,៥៨ |
| សរុប | **១០ ១០២,២៣** | **១២ ៨៩៧,៤១** | **៩ ៦៧២,២២** | **៩ ១៤០,៦១** | **៧ ៩៤២,៧០** |

ឯកតាៈ ប៊ីលានរៀល

**តារាងនៃទំហំការនាំចេញ-ចូលរបស់កម្ពុជានារយៈពេល ៥ ឆ្នាំចុងក្រោយមានស្ថានភាពដូចខាងក្រោម៖**

| | ទំហំ<br>ការនាំចេញ | បម្រែបម្រួល<br>ការនាំចេញ | ទំហំ<br>ការនាំចូល | បម្រែបម្រួល<br>ការនាំចូល | ទំហំពាណិជ្ជកម្ម | បម្រែបម្រួលទំហំ<br>ពាណិជ្ជកម្ម |
|---|---|---|---|---|---|---|
| ឆ្នាំ២០១៨ | ១២ ៦២៥,៨០ | - | ១៧ ២៥៦,០០ | - | ២៩ ៨៨១,៨០ | - |
| ឆ្នាំ២០១៩ | ១៤ ៧៣៨,៧០ | +១៦,៧% | ២០ ១៤៧,០០ | +១៦,៨% | ៣៤ ៨៨៦,០០ | +១៦,៧% |
| ឆ្នាំ២០២០ | ១៥ ៣៣១,០០ | +៤,០% | ១៨ ២៣៥,៤០ | -៩,៥% | ៣៣ ៥៦៦,៤០ | -៣,៨% |
| ឆ្នាំ២០២១ | ១៩ ២៤១,៩០ | +២៥,៥% | ២២ ៧៦២,៥០ | +២៤,៨% | ៤២ ០០៤,៤០ | +២៥,១% |
| ៩ខែ ឆ្នាំ២០២២ | ១៤៧៣៨,៧០ | +៤,៧៣%* | ២០ ១៤៧,៣០ | +២១,៨៧%* | ៣៤ ៨៨៦,០០ | +១៤,០%* |

ឯកតា៖ លានដុល្លារអាម៉េរិក

❖ **ការកៀរគរហិរញ្ញវត្ថុពីការលក់មូលបត្ររដ្ឋពីការឱ្យប្រាក់គេខ្ចី និងពីក្រៅប្រទេស**

ក្នុងរយៈពេល ៥ឆ្នាំ កន្លងមកនេះ អគ្គនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល នៃ ក.ស.ហ.វ. បានកៀរគរហិរញ្ញប្បទានពីការបោះផ្សាយលក់មូលបត្ររដ្ឋ សរុបចំនួន៤១,៧២ ប៊ីលានរៀល និងបានប្រមូលចំណូលក្នុងក្របខ័ណ្ឌនៃការឱ្យប្រាក់គេខ្ចី សរុបប្រមាណ២៩៩,៤១ លានដុល្លារអាម៉េរិក ក្នុងនោះ៖ ប្រាក់ដើមប្រមាណ១៥៩,៤៥ លានដុល្លារអាម៉េរិក និងការប្រាក់និងកម្រៃផ្សេងៗ ប្រមាណ១៣៩,៩៦ លានដុល្លារអាម៉េរិក ដូចមានលម្អិតក្នុងតារាងខាងក្រោម៖

| **ឆ្នាំ** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **កញ្ញា-២០២២** | **សរុប** |
|---|---|---|---|---|---|---|
| **សរុប** | **៧៨,២១** | **៧៤,៨៤** | **៧១,៤៥** | **៣៨,៤៥** | **៣៦,៤៦** | **២៩៩,៤១** |
| ប្រាក់ដើម | ៤៧,២៨ | ៤៤,០៥ | ៤៤,៩៧ | ១៣,៨១ | ៩,៣៤ | ១៥៩,៤៥ |
| ការប្រាក់និង<br>កម្រៃផ្សេងៗ | ៣០,៩៣ | ៣០,៧៩ | ២៦,៤៨ | ២៤,៦៤ | ២៧,១២ | ១៣៩,៩៦ |

ឯកតា៖លានដុល្លារអាម៉េរិក

**ការកៀរគរហិរញ្ញវត្ថុពីក្រៅប្រទេស (ចុះហត្ថលេខាតាមវិស័យ)**

| វិស័យ | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២<br>(មករា-កញ្ញា)** |
|---|---|---|---|---|---|
| ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | ៨២៧ ៩៦២ ៧៨៨,៣ | ២៣៩ ៣១៨ ៣០០,៩ | ៧៦០ ៥០៣ ២០៤,៩ | ៣៣៥ ៧០៤ ៨៤៤,១ | ៨៣៤ ៧៩០ ៣៦២,៣ |
| អគ្គិសនី | ២៦០ ៤១៦ ១៦២,៤ | ៨០ ៥៥៧ ១៧៧,៩ | ៣១៧ ៩៤៦ ៧៨៩,០ | | |
| ធារាសាស្ត្រ | ១០០ ១៦០ ៤១៨,១ | ២៣៩ ៦៧១ ៥០៤,៣ | ៩៨៦២០ ៥១៩,១ | ១៦៥ ១២៤ ៧០៤,៧ | |
| ស្ថានីយ៍ប្រោះទឹកកខ្វក់ | ៦៣ ៨៨៦ ០០០,០ | | | ៩៧ ៧៩៧ ៧៤៩,១ | |
| ផ្គត់ផ្គង់ទឹកស្អាត | ២២៤ ៨៧៤ ៥៦៤,៤ | ២៧១ ៨០១ ៦៣១,៩ | | ៥៥ ៣៥០ ៥៧៤,៤ | |
| កសិកម្ម | ១១២ ០៦០ ០០០,០ | | | | |
| ហិរញ្ញវត្ថុ | | ៤០ ០០០ ០០០,០ | ១៣៥ ១៦៨ ៩១២,២ | ២២៨ ៤៨៤ ៨៣០,៧ | |
| អប់រំ | ១៣៦ ៣៧៨ ៤៩៦,៨ | ៨២ ៤២៥ ២៧៦,១ | | | ៥០ ៨៨១ ០៩៩,៨ |
| សុខាភិបាល | | ៨១ ៥៧៩ ៦៨៧,១ | ៥៩៤ ៧០១ ៩៧៧,៧ | ២៥ ០០០ ០០០,០ | ៣៣២ ២២៤ ៤៩៦,៣ |
| ទេសចរណ៍ | | ៥០ ៧២៣ ៨០៣,៧ | | | |
| ពហុវិស័យ | ១១៧ ៧៣០ ០០០,០ | ២០២ ១៨៧ ៩០១,៨ | ១១៥ ៥២២ ៨៣៦,៨ | | |
| សរុប | ១ ៨៤៣ ៤៦៨ ៤៣០,០ | ១ ២៨៨ ២៦៥ ២៨៣,៥ | ២០២២៤៦៤២៣៩,៧ | **៩០៧ ៤៦២ ៧០៣,០** | ១ ២១៧ ៨៩៥ ៩៥៨,៣ |

ឯកតា៖ដុល្លារអាម៉េរិក

## ១.៣.២.២- ការគ្រប់គ្រងចំណាយសាធារណៈ

### ការអនុវត្តចំណាយសរុប

| បរិយាយ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | គ្រោង ឆ្នាំ២០២២ | ឆ្នាំ២០២២* (អនុវត្តគិតត្រឹម ខែ៩ ឆ្នាំ២០២២) |
|---|---|---|---|---|---|---|---|
| I.ចំណាយចរន្ត ថ្នាក់ជាតិ | ១៣ ២៣៦,៦៣ | ១៤ ៩៧២,៥០ | ១៧ ៨៨៩,៤៩ | ១៧ ៣៤៥,៣៤ | ១៩ ៤៩៤,១៧ | ១៩ ១១១,៧០ | ១២ ២៥៣,១៨ |
| II. ចំណាយមូលធន ថ្នាក់ជាតិ | ២ ៥៥៩,៨៩ | ៣ ២៥៦,៦១ | ៤ ៤០០,២៧ | ៦ ៩៦៩,៦៦ | ៧ ១៧៦,៦៤ | ៧ ៦៥១,៦៨ | ៧ ២៨៧,៤៤ |
| +វិនិយោគសាធារណៈ ដោយហិរញ្ញប្បទាន ក្នុងប្រទេស | ១ ៩៩៣,៦៦ | ២ ៥២០,០៤ | ៣ ៥១៥,៨០ | ៥ ៨៨៧,៤២ | ៥ ៩៩២,៨១ | ៦ ១៧៧,០៣ | ២ ៩៥៤,៦៦ |
| -គម្រោងវិនិយោគ | ១ ៣៨៦,៩៣ | ១ ៧៧១,៧៣ | ២ ៨៩២,០៦ | ៤, ៩៨៤,០៩ | ៤ ៨២៦,៣៦ | ៤ ២១១,១៧ | ២ ៤៥២,៥០ |
| -បដិភាគវិនិយោគ | ៤៨៩,៩៣ | ៥៣៦,០៧ | ៥១៨,៦៨ | ៦៥៥,៩៩ | ៦២២,០២ | ៦៩៧,៥៨ | ២៩៧,៣៣ |
| -មូលនិធិ ទ្រទ្រង់ថវិកា | ១១៦,៧៩ | ២១២,២៤ | ១០៥,០៦ | ២៤៧,៣៤ | ៥៤៤,៤៣ | ១ ២៦៨,២៨ | ២០៤,៨៣ |
| +ការទូទាត់ការខ្ចី | ៥៦៦,២៤ | ៧៣៦,៥៧ | ៨៨៤,៤៨ | ១ ០៨២,២៤ | ១ ១៨៣,៨៣ | ១ ៤៧៧,៦៦ | ១ ២៦២,១៤ |
| +វិនិយោគសាធារណៈ ដោយហិរញ្ញប្បទាន ក្រៅប្រទេស | ៤ ២១៩,៤៩ | ៤ ៣២២,២១ | ៥ ០២៧,០៩ | ៥ ១៨៧,៧៤ | ៥ ៣១៣,៦៨ | ៥ ៨១៣,៤៨ | ៣ ០៧០,៦៤ |

ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានរតនាគារជាតិ ឯកតា៖ ប៊ីលានរៀល

### ការអនុវត្តថវិកាតាមវិស័យ

| បរិយាយ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | គ្រោង ឆ្នាំ២០២២ | ឆ្នាំ២០២២ (អនុវត្តគិតត្រឹម ខែ៩ ឆ្នាំ២០២២) |
|---|---|---|---|---|---|---|---|
| I-ចំណាយថវិកា ថ្នាក់ជាតិ (ក+ខ) | ១៥ ៧៩៦ ៥២១ | ១៨ ២២៩ ១១១ | ២២ ២៨៩ ៧៦៦ | ២៤ ៣១៥ ០០៣ | ២៦ ៦៧០ ៨០៣ | ២៦ ៧៦៣ ៣៨២ | ១៦ ៧២៧ ០១៩ |
| ក-ចំណាយចរន្ត | ១៣ ២៣៦ ៦២៩ | ១៤ ៩៧២ ៥០១ | ១៧ ៨៨៩ ៤៩៣ | ១៧ ៣៤៥ ៣៤៤ | ១៩ ៤៩៤ ១៦៧ | ១៩ ៩១១ ៧០៤ | ១២ ៤៦៦ ៧៨០ |
| ១.វិស័យ រដ្ឋបាលទូទៅ | ២ ៥៣៦ ០៥១ | ២ ៤៧១ ២១០ | ៣ ២៣៩ ៣១០ | ២ ៦៩០ ៩១០ | ២ ១៤៦ ៤៣៨ | ១ ៩១៦ ១៣១ | ១ ៣៨៧ ៦៩៣ |
| ២.វិស័យការពារជាតិ សន្តិសុខនិង សណ្តាប់ធ្នាប់ សាធារណៈ | ៣ ៤០៤ ៥៥០ | ៣ ៩៨៩ ២៩០ | ៤ ៤១៥ ៤៤០ | ៤ ៧៣៧ ៣៦០ | ៤ ៧៩៦ ៤៣២ | ៤ ៦៧៥ ២៨៧ | ៣ ១១៧ ១២២ |
| ៣.វិស័យ សង្គមកិច្ច | ៤ ៨៤០ ៥១៥ | ៥ ៧៥៦ ៣៦០ | ៦ ២៨០ ០០០ | ៦ ៨០០ ២៣០ | ៨ ៥២៤ ៥០៨ | ៦ ៤៥១ ៨១៣ | ៤ ៣៣១ ១០២ |
| ៤.វិស័យ សេដ្ឋកិច្ច | ១ ៣២៣ ៣៥៤ | ១ ៣៨៧ ២០០ | ១ ៥២២ ០០០ | ១ ៤៨១ ០៤០ | ១ ៤៨០ ៣៩៧ | ១ ៤៥៧ ២០៦ | ៨៩៨ ៧១២ |
| ៥.ចំណាយ មិនទាន់បែងចែក | ១ ១៣២ ១៥៩ | ១ ៣៦៨ ៤៤០ | ២ ៤៣២ ៧៣០ | ១ ៦៣៥ ៨១០ | ២ ៥៤៦ ៣៩២ | ៤ ៦១១ ២៦៧ | ២ ៧៣២ ១៥១ |
| ខ.ចំណាយ មូលធន | ២ ៥៥៩ ៨៩២ | ៣ ២៥៦ ៦១០ | ៤ ៤០០ ២៧៣ | ៦ ៩៦៩ ៦៥៩ | ៧ ១៧៦ ៦៣៦ | ៧ ៦៥១ ៦៧៨ | ៤ ២៦០ ២៣៩ |
| II-ចំណាយថវិកា ថ្នាក់ក្រោមជាតិ | ១ ៦៧៥ ៧៧០ | ២ ៤៩៦ ៩៥៧ | ៣ ១៣២ ៦២១ | ២ ៨៥៧ ៧២៣ | ២ ៨២៤ ៩៩៣ | ៤ ៣៣៨ ២៣១ | ២ ៥៦៦ ៨១៦ |

ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានរតនាគារជាតិ ឯកតា៖ លានរៀល

### ១.៣.២.៣- ការគ្រប់គ្រងបំណុល

អគ្គនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល នៃក.ស.ហ.វ. សម្រេចបានសមិទ្ធផលការងារក្នុងការគ្រប់គ្រងបំណុលជាតិ ដូចមានខាងក្រោម៖

- បានទូទាត់សេវាបំណុលជូនដៃគូអភិវឌ្ឍន៍ សរុបប្រមាណ១ ៧៩៨,៧៥លានដុល្លារអាម៉េរិក ក្នុងនោះ៖ ប្រាក់ដើមប្រមាណ១ ២៥០,១២លានដុល្លារអាម៉េរិក និងការប្រាក់និងកម្រៃផ្សេងៗ ប្រមាណ៥៤៨,៦៣លានដុល្លារអាម៉េរិក ដូចមានលម្អិតក្នុងតារាងខាងក្រោម៖

| ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | កញ្ញា-២០២២ | សរុប |
|---|---|---|---|---|---|---|
| សរុប | ២៧២,៨៦ | ៣២២,៣៥ | ៣៨០,៣៤ | ៤០៩,២៩ | ៤១៣,៩១ | ១ ៧៩៨,៧៥ |
| ប្រាក់ដើម | ១៧៨,៨២ | ២១៤,៧៣ | ២៦២,៧៤ | ២៨៧,៤១ | ៣០៦,៤២ | ១ ២៥០,១២ |
| ការប្រាក់និងកម្រៃផ្សេងៗ | ៩៤,០៤ | ១០៧,៦២ | ១១៧,៦០ | ១២១,៨៨ | ១០៧,៤៩ | ៥៤៨,៦៣ |

ឯកតា៖លានដុល្លារអាម៉េរិក

- បានបន្តគ្រប់គ្រងបំណុលសាធារណៈប្រកបដោយចីរភាពនិងហានិភ័យកម្រិតទាប ដោយសូចនាករបំណុលគន្លឹះៗទាំងអស់សុទ្ធតែស្ថិតក្រោមអនុបាតគោល ដូចមានលម្អិតក្នុងតារាងខាងក្រោម៖

| សូចនាករ | ពិតាន | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|---|
| តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈសរុប | | | | | | |
| *ធៀបនឹង ផ.ស.ស.* | **៥៥** | ២១,៤៨ | ២០,៧៨ | ២៤,០ | ២៤,៤ | ២៥,៩ |
| តម្លៃបច្ចុប្បន្ននៃបំណុលសាធារណៈក្រៅប្រទេស | | | | | | |
| *ធៀបនឹង ផ.ស.ស.* | **៤០** | ២១,៤៦ | ២០,៧៨ | ២៤,០ | ២៤,៤ | ២៤,៩ |
| *ធៀបនឹងការនាំចេញ* | **១៨០** | ២៨,៤ | ២៦,៧ | ៣២,៨ | ៣៥,៦ | ៣៣,៩ |
| សេវាបំណុលសាធារណៈក្រៅប្រទេស | | | | | | |
| *ធៀបនឹង ការនាំចេញ* | **១៥** | ១,៤ | ១,៥ | ១,៩ | ២ | ២,១ |
| *ធៀបនឹង ចំណូលថវិកាជាតិ* | **១៨** | ៤,៩ | ៤,៥ | ៦,២ | ៧ | ៧,៨ |

### ១.៣.៣-សមិទ្ធផលនៃការកែទម្រង់រដ្ឋបាលសារពើពន្ធ

#### ១.៣.៣.១. សមិទ្ធផលរបស់អគ្គនាយកដ្ឋានពន្ធដារ

ចំពោះសមិទ្ធផលសំខាន់ៗរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងរយៈពេល៥ឆ្នាំពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២នេះ រួមមានដូចខាងក្រោម៖

❖ **ការងារសេវាអ្នកជាប់ពន្ធ**

- រៀបចំសេវាពិគ្រោះយោបល់តាមទូរសព្ទ(Call Center 1277)៖ គឺជាសេវាឥតគិតថ្លៃ ដើម្បីដោះស្រាយ និងឆ្លើយតបទៅនឹងចម្ងល់ផ្សេងៗរបស់អ្នកជាប់ពន្ធ
- កម្មវិធីជជែកផ្ទាល់(Facebook Live)៖ មានផ្សាយផ្ទាល់ដើម្បីជួយបកស្រាយចម្ងល់ផ្សេងៗរបស់អ្នកជាប់ពន្ធ

- បង្កើតគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារនិងដំណើរការកម្មវិធីGDT Live Chat
- ប្រព័ន្ធសិក្សាពីចម្ងាយ(E-Learning)៖ ជាកម្មវិធីដែលផ្សព្វផ្សាយអំពីបទប្បញ្ញត្តិនានា មេរៀនស្តីពីពន្ធដារ
- ការដាក់ឱ្យដំណើរការកម្មវិធីត្រួតពិនិត្យនិងតាមដានឯកសារ(GDT Check & Track) ដែលអ្នកជាប់ពន្ធអាចតាមដានស្ថានភាពឯកសារដែលបានដាក់ចូលអគ្គនាយកដ្ឋានពន្ធដារ និងអាចផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃលិខិតចេញដោយ អ.ព.ដ. (លិខិតបញ្ជាបេសកកម្ម លិខិតឧទ្ទេសនាម ប័ណ្ណពន្ធប៉ាតង់ ឯកសារប្រថាប់ត្រាលតាបត្រពន្ធមធ្យោបាយដាដើម)
- បានចុះអនុស្សរណៈ(MOU) ជាមួយធនាគារមួយចំនួន ដើម្បីជួយសម្រួលក្នុងការបង់ពន្ធដែលអនុញ្ញាតឱ្យអ្នកជាប់ពន្ធអាចបង់ប្រាក់ពន្ធតាមធនាគារដៃគូចំនួន១០ ដែលបានចុះអនុស្សរណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានរៀបចំនូវច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារនិងលិខិតបទដ្ឋានគតិយុត្តជាច្រើន ដើម្បីជាឯកសារជំនួយស្មារតី
- បានរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីពន្ធដារ ភ្នាក់ងារសេវាកម្មពន្ធដារនៅសាលាជាតិពន្ធដារ
- បានរៀបចំនិងផ្សព្វផ្សាយបញ្ជ្រាបវប្បធម៌បង់ពន្ធដល់អ្នកជាប់ពន្ធតាមរយៈសិក្ខាសាលា និងការរៀបចំបង្កើតសៀវភៅណែនាំ ខិត្តប័ណ្ណនិងវីដេអូ ដើម្បីផ្សព្វផ្សាយការអនុវត្តកាតព្វកិច្ចសារពើពន្ធជូនអ្នកជាប់ពន្ធ។

**តារាងចំណាត់ថ្នាក់អ្នកជាប់ពន្ធ**

| ចំណាត់ថ្នាក់អ្នកជាប់ពន្ធ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | កញ្ញា-២០២២ | សរុបរួម |
|---|---|---|---|---|---|---|
| អ្នកជាប់ពន្ធធំ | ៩០០ | ១ ៣៣០ | ៧១១ | ៥៨១ | ៤៥៣ | ៣ ៩៧៥ |
| អ្នកជាប់មធ្យម | ៥ ៦១៦ | ៨ ៦២៨ | ៦ ៦៤៤ | ៥ ៤០៨ | ៣ ៩៧៩ | ៣០ ២៧៥ |
| អ្នកជាប់តូច | ៤ ០៩៣ | ៤ ៦៦០ | ៤ ១៧៣ | ៣ ០៥៦ | ៣ ៨៨៩ | ១៩ ៨៧១ |
| **សរុប** | **១០ ៦០៩** | **១៤ ៦១៨** | **១១ ៥២៨** | **៩ ០៤៥** | **៨ ៣២១** | **៥៤ ១២១** |

ប្រភពទិន្នន័យ៖ អគ្គនាយកដ្ឋានពន្ធដារ

## ❖ ការងារចាត់ចែងលិខិតប្រកាស និងទទួលប្រាក់ពន្ធ

- ការដាក់លិខិតប្រកាសពន្ធតាមប្រព័ន្ធអេឡិចត្រូនិកប្រចាំខែនិងប្រចាំឆ្នាំ(E-Filing)
- ការបង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិក(E-Payment System)
- ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទនិងពន្ធលើអចលនទ្រព្យ តាមទូរសព្ទដៃដោយប្រើប្រាស់កម្មវិធីGDT Taxpayer App(ដែលអាចទាញយកពី iOS និង Android)។

❖ **កិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA)**

ក្នុងរយៈពេល៥ឆ្នាំនេះ ប្រទេសដែលរាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នានិងមានប្រសិទ្ធភាពអនុវត្តចំនួន៩ប្រទេស ប្រទេសដែលបានបញ្ចប់និងចុះហត្ថលេខា មានចំនួន២ប្រទេស និងប្រទេសដែលបាននិងកំពុងចរចាកិច្ចព្រមព្រៀងDTA ជាបន្តបន្ទាប់ មានចំនួន៥ប្រទេស។

**១.៣.៣.២. សមិទ្ធផលរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា**

ចំពោះសមិទ្ធផលសំខាន់ៗរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្នុងរយៈពេល៥ឆ្នាំ ពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២នេះ រួមមានដូចខាងក្រោម៖

❖ **ការងារអនុលោមភាពនិងការអនុវត្តច្បាប់**

- ដាក់ឱ្យប្រើប្រាស់ម៉ាស៊ីនស្កេននៅសាខាកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ កំពង់ផែអន្តរជាតិភ្នំពេញ ការិយាល័យបាវិត ផែស្ងួតចូល ផែស្ងួតតេងឡាយនិងប៉ោយប៉ែត(សរុបមានចំនួន១០គ្រឿង) និងបន្តដាក់ពង្រាយនៅតាមសាខានិងការិយាល័យបំពេញបែបបទគយសំខាន់ៗថែមទៀត
- ដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធវាយតម្លៃហានិភ័យអ្នកដំណើរតាមផ្លូវអាកាស(Global Travel Assessment System-GTAS) នាថ្ងៃទី២២ ខែមេសា ឆ្នាំ២០២២
- ពង្រឹងអនុលោមភាពលើការនាំចេញ នាំចូលទំនិញជាប់កម្មសិទ្ធិបញ្ញាតាមរយៈការដាក់ចេញសេចក្តីណែនាំលេខ១៦៨១/២១ អ.គ.រ. ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២១ ស្តីពីការអនុវត្តប្រកាសស្តីពីវិធាន និងនីតិវិធីនៃការព្យួរការបំពេញបែបបទបញ្ចេញទំនិញពីគយ ចំពោះទំនិញនាំចេញនាំចូលល្មើសកម្មសិទ្ធិបញ្ញា(ប្រកាសលេខ១៩៦សហវ.ប្រក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)
- ចូលរួមអនុវត្តដោយជោគជ័យនូវផែនការសកម្មភាព និងអនុសាសន៍របស់ក្រុមការងារហិរញ្ញវត្ថុ (FATF) ពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដើម្បីដកកម្ពុជាចេញពីបញ្ជីប្រផេះ។ បច្ចុប្បន្ននេះ កម្ពុជាកំពុងត្រៀមខ្លួនធ្វើការជាមួយគណៈប្រតិភូនៃក្រុមត្រួតពិនិត្យរួម (JG) ដែលនឹងចុះមកវាយតម្លៃដោយផ្ទាល់(On-Site Visit) នៅកំលុងដើមឆ្នាំ២០២៣ខាងមុខ
- រៀបចំបង្កើតក្រុមអន្តរាគមន៍ពិសេសក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធតាមរយៈប្រកាសលេខ០៥៦ សហវ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុវត្តសេចក្តីជូនដំណឹងលេខ៤៨២ សជណ.ហជ.ចុះថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី លើការប្រមូលពន្ធនិងអាករលើរថយន្តគ្មានពន្ធមានស្រាប់ក្នុងប្រទេស
- រៀបចំនិងដាក់ឱ្យអនុវត្តឯកសារយុទ្ធសាស្ត្រគយស្តីពីអនុលោមភាពនិងការអនុវត្តច្បាប់ឆ្នាំ២០២០-២០២៣
- រៀបចំ និងអនុវត្តបទបញ្ជា០១ បប ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាល ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់និងការបង្ក្រាបអំពើរត់គេចពន្ធ
- ដាក់ឱ្យដំណើរការនូវការងារសវនកម្មផ្ទៃក្នុងអ.គ.រ. នៃលេខាធិការដ្ឋានក្នុងទិសដៅលើកកម្ពស់អនុលោមភាព អភិបាលកិច្ច និងប្រសិទ្ធភាពនៃការកៀរគរចំណូល
- ពង្រឹងក្រមសីលធម៌ជើងសាគយតាមរយៈការរៀបចំនិងអនុវត្តប្រកាសលេខ០៩៨ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

- ការងារទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងកិច្ចសម្រួលពាណិជ្ជកម្ម
- វិសិដ្ឋកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មគយ(អាស៊ីគូដា) ជាបន្តបន្ទាប់រហូតដល់មកជំនាន់៤.៣.៣ និងបានពង្រីកការប្រើប្រាស់ជាបន្តបន្ទាប់រហូតដល់បានគ្របដណ្តប់គ្រប់នាយកដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករបំពេញបែបនាំចេញ-នាំចូល
- ពង្រីកមុខងារប្រព័ន្ធអេឡិចត្រូនិកគយ(e-Customs) ជាបន្តបន្ទាប់ ដែលគិតមកដល់ត្រឹមឆ្នាំ២០២១ មានមុខងារសំខាន់ៗប្រមាណជាង៣០ ដែលក្នុងនោះមានមុខងារដូចជា មុខងារទូទាត់តាមមធ្យោបាយអេឡិចត្រូនិក(e-Payment) ប្រព័ន្ធគ្រប់គ្រងមធ្យោបាយធ្វើដំណើរភ្ញៀវទេសចរ ប្រព័ន្ធឆ្លងកាត់គយ (ការឆ្លងកាត់ជាតិ និងអន្តរជាតិ) មុខងារសន្ទានកម្មជាមួយប្រព័ន្ធFMIS មុខងារគ្រប់គ្រងទិន្នន័យយានយន្ត។ល។ ដែលត្រូវបានដាក់ឱ្យប្រើប្រាស់នៅគ្រប់អង្គភាពគយនិងរដ្ឋាករ
- ធ្វើការផ្លាស់ប្តូរទិន្នន័យតាមរយៈការធ្វើសន្ទានកម្មប្រព័ន្ធស្វ័យប្រវត្តិកម្មគយ ជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់អង្គភាពផ្សេងៗ (អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកនៃក្រសួងសាធារណការនិងដឹកជញ្ជូន)
- ពង្រីកមុខងារ និងវិសាលភាពប្រព័ន្ធបញ្ជរតែមួយ ជាដំណាក់កាលបន្តបន្ទាប់ ដោយបច្ចុប្បន្នស្ថិតនៅក្នុងដំណាក់កាលទី២ ដែលមានក្រសួង ស្ថាប័នចូលរួមអនុវត្ត ដូចជាក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តភ្ជាប់ប្រព័ន្ធបញ្ជរតែមួយជាតិ និងប្រព័ន្ធស្វ័យប្រវត្តិកម្មគយជាមួយនឹងប្រព័ន្ធបញ្ជរតែមួយអាស៊ាន
- រៀបចំដាក់ឱ្យអនុវត្តប្រព័ន្ធឆ្លងកាត់គយអាស៊ាន
- ដាក់ឱ្យប្រើប្រាស់កម្មវិធីទូរសព្ទដៃឆ្លាតវៃ សម្រាប់មន្ត្រីគយ និងសម្រាប់សាធារណៈជន ដែលគិតមកដល់បច្ចុប្បន្នមានដូចជា កម្មវិធីសម្រាប់មន្ត្រីគយនិងរដ្ឋាករ កម្មវិធីតារាងពន្ធគយកម្ពុជា កម្មវិធីផ្ទៀងផ្ទាត់បង្កាន់ដៃពន្ធយានយន្ត។ល។
- ក្នុងឆ្នាំ២០២១ គណៈកម្មាធិការជាតិកិច្ចសម្រួលពាណិជ្ជកម្ម ដែលមាន អ.គ.រ. ជាលេខាធិការដ្ឋានបានរៀបចំដាក់ចេញនូវឯកសារ "ផែនទីចង្អុលផ្លូវស្តីពីកិច្ចសម្រួលពាណិជ្ជកម្មឆ្នាំ២០២២-២០២៥" ដើម្បីជាជំនួយក្នុងការអនុវត្តគោលនយោបាយ និងវិធានការកិច្ចសម្រួលពាណិជ្ជកម្មផ្សេងៗរបស់រាជរដ្ឋាភិបាល ដែលរួមមានការអនុវត្តកាតព្វកិច្ចរបស់កម្ពុជា ដែលមានចែងក្នុងកិច្ចព្រមព្រៀងកិច្ចសម្រួលពាណិជ្ជកម្មរបស់អង្គការពាណិជ្ជកម្មពិភពលោកផងដែរ
- កែសម្រួលកញ្ចប់ប្រព្រឹត្តកម្មលើកទឹកចិត្តជូនសមាជិកក្រុមធុរជនល្អបំផុត(Best Traders) និងបានបន្តបង្កើនចំនួនសមាជិកក្រុមធុរជនល្អបំផុត។ អ.គ.រ. សហការជាមួយដៃគូអភិវឌ្ឍ បាននិងកំពុងរៀបចំបទដ្ឋានគតិយុត្តគាំទ្រ សម្រាប់ការអនុវត្តកម្មវិធីប្រតិបត្តិករសេដ្ឋកិច្ចទទួលបានការអនុញ្ញាត (Authorized Economic Operator Programme) ដែលគ្រោងនឹងដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០២៣
- កែលម្អប្រសិទ្ធភាពការងារគ្រប់គ្រងហានិភ័យ តាមរយៈការកែលម្អវិធីសាស្ត្រនិងលក្ខណវិនិច្ឆ័យជ្រើសរើសសូចនាករហានិភ័យ ។

❖ **ការងារកិច្ចសហប្រតិបត្តិការគយអន្តរជាតិ**

- ក្នុងកម្រិតទ្វេភាគីអ.គ.រ. បាននិងបន្តពង្រឹងកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងការងារគយជាមួយប្រទេសជាដៃគូពាណិជ្ជកម្មសំខាន់ៗ ដោយបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាទៅវិញទៅមកពាក់ព័ន្ធនឹងការងារគយ ជាមួយរដ្ឋបាលគយនៃប្រទេសថៃ វៀតណាម ឡាវ បារាំង និងចិន និងកំពុងរៀបចំសេចក្តីព្រាងឯកសារនេះជាមួយរដ្ឋបាលគយនៃប្រទេសផ្សេងទៀត
- កន្លងមកថ្មីៗនេះ អ.គ.រ. បានចូលរួមចរចាយ៉ាងសកម្ម និងបញ្ចប់ចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីដូចជា កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីរវាងកម្ពុជា-ចិន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីរវាងកម្ពុជា-កូរ៉េ
- ក្នុងកម្រិតពហុភាគីអ.គ.រ. ក៏បាននិងបន្តចូលរួមជាប្រចាំកិច្ចប្រជុំ និងការងារ កម្រិតអគ្គនាយកគយ និងក្រុមការងារបច្ចេកទេសគយក្នុងតំបន់អាស៊ាន តំបន់អាស៊ីប៉ាស៊ីហ្វិក តំបន់អាស៊ីអឺរ៉ុបដើម្បីចូលរួមតាមដានពិភាក្សានិងអនុម័តលើការងារគយសំខាន់ៗមួយចំនួន ក្នុងការកសាងនិងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍគយនិងពង្រឹងកិច្ចសហប្រតិបត្តិការគយដើម្បីសម្រួលពាណិជ្ជកម្មក្នុងតំបន់
- ក្នុងនាមជាសមាជិករបស់អង្គការគយពិភពលោក(WCO) អ.គ.រ. បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាកិច្ចសហប្រតិបត្តិការគយអន្តរជាតិ ក្នុងគោលបំណងចូលរួមតាមដានវឌ្ឍនភាពពាក់ព័ន្ធការងារបច្ចេកទេសគយ ការកសាងសមត្ថភាពមន្ត្រី អនុលោមភាព ការអនុវត្តច្បាប់ កិច្ចសម្រួលពាណិជ្ជកម្ម និងផែនការយុទ្ធសាស្ត្ររបស់អង្គការគយពិភពលោក
- ពាក់ព័ន្ធនឹងកិច្ចសម្រួលពាណិជ្ជកម្មកម្រិតតំបន់និងពហុភាគីអ.គ.រ. រួមជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏បានចូលរួមពិភាក្សា ចរចា និងអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា ដូចជាកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-បូក(ASEAN Plus) និងបញ្ចប់កិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់(RCEP) លើសពីនេះទៀតអ.គ.រ. ក៏បានពង្រឹងកិច្ចសហប្រតិបត្តិការផ្សេងៗទៀតជាមួយអង្គការអន្តរជាតិនិងដៃគូអភិវឌ្ឍលើការងារពាក់ព័ន្ធនឹងគយ
- រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការជាតិកិច្ចសម្រួលពាណិជ្ជកម្មក្នុងឆ្នាំ២០២០ ដែលមាន អ.គ.រ. ជាលេខាធិការដ្ឋាន ដើម្បីជាសេនាធិការរបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួល និងតាមដានការអនុវត្តបញ្ញត្តិនានា ដែលចែងក្នុងកិច្ចព្រមព្រៀងកិច្ចសម្រួលពាណិជ្ជកម្មនៃអង្គការពាណិជ្ជកម្មពិភពលោក(WTO TFA)ដែលកម្ពុជាបានផ្តល់សច្ចាប័នអនុវត្តកិច្ចព្រមព្រៀងនេះ ក្នុងឆ្នាំ២០១៦។

ទន្ទឹមនឹងនេះ អ.គ.រ. ក៏មានការសហការជាមួយផ្នែកឯកជនដើម្បីដោះស្រាយបញ្ហានានាពាក់ព័ន្ធការអនុវត្តនីតិវិធីគយតាមរយៈយន្តការភាពជាដៃគូគយផ្នែកឯកជន (CPPM) ដែលគិតត្រឹមឆ្នាំ២០២១ កិច្ចប្រជុំនៃយន្តការ CPPM ត្រូវបានរៀបចំឡើងចំនួន ៨លើក (ក្នុងនោះមុនឆ្នាំ២០១៨ មានចំនួន ៦លើក) ដើម្បីពិនិត្យនិងដោះស្រាយរាល់បញ្ហាពាក់ព័ន្ធនឹងការងារគយ បញ្ហាប្រឈមនានាក្នុងការធ្វើធុរកិច្ចរបស់ផ្នែកឯកជនឱ្យអស់លទ្ធភាពជាមុន មុននឹងឈានទៅដោះស្រាយកម្រិតអន្តរក្រសួង ឬដាក់ជូនវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន។ កិច្ចប្រជុំយន្តការ

CPPM លើកទី៩ ក៏គ្រោងនឹងធ្វើឡើងក្នុងដំណាច់ឆ្នាំ ២០២២ នេះ ផងដែរ ក្រោមកិច្ចសហការរវាង អ.គ.រ. និង សភាពាណិជ្ជកម្ម ដើម្បីបន្តពិនិត្យនិងដោះស្រាយបញ្ហា និងសំណូមពររបស់វិស័យឯកជនដោយយោងតាមស្ថានភាពវិវត្តថ្មីៗជាក់ស្តែង ។

ក្នុងស្ថានភាពនៃការរីករាលដាលជាសកលនៃវីរុសកូវីដ-១៩ កិច្ចប្រជុំពិសេសនៃយន្តការCPPM ត្រូវបានរៀបចំឡើងក្នុងគោលបំណងដោះស្រាយនូវសំណូមពរនិងបញ្ហានានាចំពោះមុខរបស់វិស័យឯកជន ពាក់ព័ន្ធនឹងប្រតិបត្តិការនាំចេញ នាំចូលទំនិញ។ ជាមួយគ្នានេះ អ.គ.រ. ក៏បានដឹកនាំកិច្ចប្រជុំក្នុងក្របខ័ណ្ឌៈ (១). គណៈកម្មការចំពោះកិច្ចទប់ស្កាត់ការរីករាលដាលនៃជំងឺឆ្លងកូវីដ-១៩ ពាក់ព័ន្ធនឹងការនាំចូលទំនិញមានហានិភ័យខ្ពស់ដែលមានប្រភពពីប្រទេសមានការរីករាលដាលខ្លាំងនូវជំងឺឆ្លងកូវីដ-១៩ (២). កិច្ចប្រជុំសម្របសម្រួលអន្តរស្ថាប័ននិងជាមួយភាគីប្រទេសជិតខាង សម្រួលក្នុងការដឹកជញ្ជូនទំនិញឆ្លងកាត់ក្នុងស្ថានភាពកូវីដ-១៩ (៣). កិច្ចប្រជុំជាមួយក្រសួងពាណិជ្ជកម្មអំពីការធ្វើសន្និធិប្រេងឥន្ធនៈ សំដៅធានាបាននូវការផ្គត់ផ្គង់ប្រកបដោយនិរន្តរភាព (៤). កិច្ចប្រជុំជាមួយសមាគមធុរកិច្ចពាក់ព័ន្ធ ដើម្បីរកវិធានការដោះស្រាយលើបញ្ហាប្រឈម ក្នុងការកាត់បន្ថយថ្លៃភស្តុភារកម្មកម្ពុជា(Logistic Cost) និងកិច្ចប្រជុំមួយចំនួនទៀតផងដែរ ។

ក្រៅពីកិច្ចប្រជុំយន្តការខាងលើ អ.គ.រ. បានសហការជាមួយសភាពាណិជ្ជកម្មកម្ពុជា រៀបចំ "វេទិកាស្តីពីគយកម្ពុជាលើកទី១" នាខែកុម្ភៈ ឆ្នាំ២០២០ ក្នុងគោលបំណងរួមចំណែកលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្មនិងបង្កើនអនុលោមភាពរបស់វិស័យឯកជន តាមរយៈការបញ្ជ្រាបបន្ថែមការយល់ដឹងលើប្រធានបទពាក់ព័ន្ធនឹងបច្ចេកទេសគយ នីតិវិធីបំពេញបែបបទបញ្ចេញទំនិញពីគយ ប្រព័ន្ធស្វ័យប្រវត្តិកម្មគយ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។ អ.គ.រ. កំពុងសហការជាមួយសភាពាណិជ្ជកម្មកម្ពុជា ដើម្បីរៀបចំ "វេទិកាស្តីពីគយកម្ពុជាលើកទី២" ក្នុងខែធ្នូ ឆ្នាំ២០២២ ឆាប់ៗខាងមុខនេះ ។

## ១.៤- ការចូលរួម និងអនុវត្តលើកិច្ចការងារសមាហរណកម្មអាស៊ាន និងសេដ្ឋកិច្ចកម្ពុជា

### ១.៤.១- ការចរចា និងអនុវត្តភាតព្វកិច្ចពាក់ព័ន្ធនឹងពាណិជ្ជកម្មទំនិញក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

- **ថ្ងៃទី២០-២៥ ខែកុម្ភៈឆ្នាំ ២០១៨** បានធ្វើជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលសម្រាប់ការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ានលើកទី២៦ (26th CCA) និង កិច្ចប្រជុំអនុគណៈកម្មាធិការវិធានដើមកំណើតទំនិញនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ានលើកទី២៦ (26th SCAROO) នៅរាជធានីភ្នំពេញ។
- **០៦ ខែមីនា ឆ្នាំ២០១៩** សម្រេចបានការរៀបចំអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់កម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ានឆ្នាំ២០១៧ក្រោមកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន (ATIGA)។
- **ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩** សម្រេចបានការរៀបចំអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់កម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ានឆ្នាំ២០១៧ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-កូរ៉េ ។

**ខែវិច្ឆិកា ឆ្នាំ ២០១២ ដល់ ខែវិច្ឆិកា ឆ្នាំ ២០១៩** បានរួមចំណែកក្នុងការចរចាកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់(RCEP) ដែលផ្ដោតលើពាណិជ្ជកម្មទំនិញ វិធានដើមកំណើត កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច សេវាហិរញ្ញវត្ថុ។ កិច្ចព្រមព្រៀង RCEP ត្រូវបានចុះហត្ថលេខានៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០ និងចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២។

- **ថ្ងៃ២៨ ខែមីនា ឆ្នាំ២០២០** សម្រេចបានការរៀបចំច្បាប់ស្ដីពីការអនុម័តយល់ព្រមលើពិធីសារទី១ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្ដីពីពាណិជ្ជកម្មទំនិញអាស៊ាន (ATIGA)។
- **ខែកក្កដា ឆ្នាំ ២០២០** បានបញ្ចប់ការចរចាកិច្ចព្រមព្រៀងភាពពាណិជ្ជកម្មសេរីកម្ពុជា-ចិន(CCFTA) ដោយផ្ដោតលើពាណិជ្ជកម្មទំនិញ។ កិច្ចព្រមព្រៀងនេះ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ។
- **ខែវិច្ឆិកា ឆ្នាំ ២០២០** បានបញ្ចប់ការចរចារៀបចំ "អនុស្សារណៈយោគយល់ស្ដីពីការអនុវត្តវិធានការមិនមែនពន្ធសម្រាប់មុខទំនិញចាំបាច់ ក្រោយផែនការសកម្មភាពពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាននិងការតភ្ជាប់ខ្សែច្រវាក់ផ្គត់ផ្គង់ ឆ្លើយតបនឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩" (MOU on Implementation of Measures for Essential Goods During COVID-19 Pandemic) ដែលបានចុះហត្ថលេខាកាលពីខែវិច្ឆិកា ឆ្នាំ២០២០និងដាក់ឱ្យអនុវត្តហូតដល់ឆ្នាំ២០២២ ។
- **ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២១** បានបញ្ចប់ការចរចាកិច្ចព្រមព្រៀងភាពពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ(CKFTA) ដោយផ្ដោតលើពាណិជ្ជកម្មទំនិញ។ កិច្ចព្រមព្រៀងនេះ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ ។
- **ខែកញ្ញា ឆ្នាំ ២០២១** បានបញ្ចប់ការរៀបចំ "ឧបករណ៍វាស់ស្ទង់ប្រសិទ្ធភាពនិងចំណាយវិធានការមិនមែនពន្ធ" (NTM Cost-Effectiveness Toolkit) សម្រាប់ការកែលម្អវិធានការមិនមែនពន្ធ ក្នុងន័យបម្រើដល់ការសម្រួលពាណិជ្ជកម្ម និងពង្រឹងភាពប្រកួតប្រជែងក្នុងតំបន់អាស៊ាន។ ឧបករណ៍ដែលត្រូវបានអនុម័តដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានកាលពីខែកញ្ញា ឆ្នាំ២០២១ និងដាក់ឱ្យអនុវត្តដោយស្ម័គ្រចិត្តចាប់ពីឆ្នាំ២០២២។
- **ថ្ងៃ១២ ខែ តុលា ឆ្នាំ ២០២១** សម្រេចបានការរៀបចំអនុក្រឹត្យស្ដីពីការដាក់ឱ្យអនុវត្តកម្មវិធីកាត់បន្ថយនិង/ឬលុបបំបាត់ពន្ធគយរបស់កម្ពុជា ស្របតាមនាមវលីនៃតារាងពន្ធគយសុខដុមរបស់អាស៊ានឆ្នាំ២០១៧ ក្រោមកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងជប៉ុន ។
- **ថ្ងៃទី២៥-២៦ ខែកក្កដា ឆ្នាំ ២០២២** បានរៀបចំកិច្ចប្រជុំរួមស្ដីពីការផ្ទេរវិធានជាក់លាក់សម្រាប់ផលិតផល (PSR)ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន ហុងកុង (AHKFTA) ពីប្រព័ន្ធសុខដុម HS 2012 ទៅ HS 2017 និង ពី HS 2017 ទៅ HS 2022 ។ បច្ចុប្បន្នមាន ហុងកុង និងប្រទេសសមាជិកអាស៊ានចំនួន៦ រួមមាន៖ កម្ពុជា ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ថៃ សិង្ហបុរី និងហ្វីលីពីន បានអនុវត្តប្រព័ន្ធសុខដុម HS 2022 រួចហើយ ។

- **ខែវិច្ឆិកា ឆ្នាំ ២០២២** បានធ្វើការផ្ទេរតារាងកាត់បន្ថយពន្ធគយ (TRS) ពី ប្រព័ន្ធសុខដុម HS ២០១៧ មក២០២២ ព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (ASEAN-Korea Free Trade Agreement-AKFTA) ទៅសមាជិកអាស៊ាន សម្រាប់ការបញ្ជាក់ពីសមាជិកទាំងអស់ ។
- **ឆ្នាំ ២០២២** គ្រោងនឹងបញ្ចប់ការចរចាលើការពិនិត្យឡើងវិញលើជំពូក ស្តីពីពាណិជ្ជកម្មទំនិញ និងជំពូកស្តីពីវិធានដើមកំណើត ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន អូស្ត្រាលី នូវែលសេឡង់(AANZFTA) នៅចុងឆ្នាំ ២០២២ នេះ ។

### ១.៤.២- វិធានការមិនមែនពន្ធ និងនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម

គណៈកម្មាធិការសម្រាប់វិធានការមិនមែនពន្ធ និងនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យចំនួនពីរ គឺ៖ (១) អនុក្រឹត្យលេខ ២៥៧. អនក្រ.បក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិសម្រាប់វិធានការមិនមែនពន្ធ និង(២) អនុក្រឹត្យលេខ ២៥៨. អនក្រ.បក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៤ ស្តីពីនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម។

ក្នុងរយៈពេលកន្លងមក នាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន ក្នុងនាមជាលេខាធិការដ្ឋាន បានរៀបចំ ចងក្រង និងបង្ហោះឯកសារ និងព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មទៅក្នុងនិហិតដ្ឋានវិធានព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម(cambodiantr.gov.kh) រួមមានតារាងនាមវលីដែលមានបន្ទាត់ពន្ធសរុបចំនួន៩ ៥៧៤ តារាងពន្ធប្រជាជាតិអនុគ្រោះបំផុត និងកម្មវិធីកាត់បន្ថយពន្ធគយក្រោមកិច្ចព្រមព្រៀមពាណិជ្ជកម្មសេរីជាមួយដៃគូនានា វិធានការមិនមែនពន្ធចំនួន៣៩០ច្បាប់ លិខិតបទដ្ឋានគតិយុត្តនិងសេចក្តីសម្រេចរដ្ឋបាលពាក់ព័ន្ធនឹងពាណិជ្ជកម្ម ជាភាសាខ្មែរនិងអង់គ្លេសចំនួន២១៤ នីតិវិធីនិងបែបបទចំនួន១០០ និងព័ត៌មានពាក់ព័ន្ធពាណិជ្ជកម្មចំនួន១៥៥។

### ១.៤.៣- កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាននិងអាស៊ានបូក

#### ១.៤.៣.១- ការធ្វើសេរីភាវូបនីយកម្មហិរញ្ញវត្ថុអាស៊ាន

- **ឆ្នាំ២០១៨** បញ្ចប់ការចរចាលើកាតព្វកិច្ចសេវាហិរញ្ញវត្ថុក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវា អាស៊ាន (ASEAN Trade in Services Agreement (ATISA) ដែលកិច្ចព្រមព្រៀងនេះ ត្រូវបានចុះហត្ថលេខាដោយសមាជិកអាស៊ាននៅខែតុលា ឆ្នាំ២០២០។
- **ឆ្នាំ២០១៩** បញ្ចប់ការចរចាលើពិធីសារដើម្បីអនុវត្តកញ្ចប់ទី៨ នៃការប្តេជ្ញាបើកចំហសេវាហិរញ្ញវត្ថុក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា(AFAS) ដែលកិច្ចព្រមព្រៀងនេះ ត្រូវបានចុះហត្ថលេខាក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី២៣ នៅខែមេសា ឆ្នា២០១៩ នៅខេត្តឈៀងរ៉ៃ ប្រទេសថៃ។ ពិធីសារដើម្បីអនុវត្តកញ្ចប់នៃការប្តេជ្ញាបើកចំហសេវាហិរញ្ញវត្ថុ ក្រោមAFASត្រូវបានចរចាក្នុងរយៈពេល២ឆ្នាំ(ក្នុងពិធីសារមួយ)។ បញ្ចប់ការចរចាលើកាតព្វកិច្ចសេវាហិរញ្ញវត្ថុ ក្រោមកិច្ចព្រមព្រៀង RCEP ។
- ឆ្នាំ២០២១ បញ្ចប់ការចរចាលើពិធីសារដើម្បីអនុវត្តកញ្ចប់ទី៩ នៃការប្តេជ្ញាបើកចំហសេវាហិរញ្ញវត្ថុក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា(AFAS) ដែលកិច្ចព្រមព្រៀងនេះ គ្រោងនឹងចុះហត្ថលេខាក្នុងឆ្នាំ២០២២ ឬ២០២៣។ កញ្ចប់ទី៩នេះ គឺជាកញ្ចប់ចុងក្រោយ មុនពេលផ្លាស់ប្តូរទៅអនុវត្តកិច្ចព្រមព្រៀងATISA ជំនួសវិញ ។

-ឆ្នាំ២០២២ បានរៀបចំដោយជោគជ័យនូវកិច្ចប្រជុំរដ្ឋមន្ត្រីរដ្ឋមន្ត្រីហិរញ្ញវត្ថុនិងទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី៨និងកិច្ចប្រជុំពាក់ព័ន្ធនៅថ្ងៃទី៧-៨ ខែមេសា ឆ្នាំ២០២២ តាមរយៈប្រព័ន្ធវីដេអូ។

-ឆ្នាំ២០២២ គ្រោងនឹងបញ្ចប់ការចរចាលើការពិនិត្យឡើងវិញលើការតេព្វកិច្ចសេវាហិរញ្ញវត្ថុ ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន អូស្ត្រាលី នូវែលសេឡង់(AANZFTA) នៅចុងឆ្នាំ២០២២នេះ។

**១.៤.៣.២- កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ានបូកបី**

- **ឆ្នាំ២០១៩** -បញ្ចប់ការកែសម្រួលលើកិច្ចព្រមព្រៀងស្តីពីយន្តការពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM)។
- **ឆ្នាំ២០២០** -ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ដើម្បីកែសម្រួលលើយន្តការពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ(CMIM)។
- **ចាប់តាំងពីឆ្នាំ២០១១ដល់បច្ចុប្បន្ន** - បានចូលរួមក្នុងដំណើរការពង្រឹងសមត្ថភាពរបស់អង្គភាពស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣(AMRO) ដើម្បីជានាប្រសិទ្ធភាពក្នុងការតាមដាន និងពង្រឹងស្ថិរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ចក្នុងតំបន់អាស៊ានបូក៣។
- **ឆ្នាំ២០២២** - បានសហការរៀបចំនិងធ្វើជាសហប្រធានកិច្ចប្រជុំរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាលអាស៊ានបូក៣ លើកទី២៥ ជាមួយប្រទេសចិន កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២២ ប្រកបដោយជោគជ័យ។

**៤.៣.៣- កិច្ចសហប្រតិបត្តិការអនុតំបន់**

- **ឆ្នាំ២០១៩** - បានចូលរួមរៀបចំទិសដៅសម្រាប់កិច្ចសហប្រតិបត្តិការលើសមត្ថភាពផលិតក្នុងរយៈពេល៣ឆ្នាំ២០១៩-២០២១ ក្រោមក្រខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។
- **ឆ្នាំ២០១៩** - បានចូលរួមរៀបចំសន្និសិទ្ធថ្នាក់រដ្ឋមន្ត្រីGMS លើកទី២៣ ដែលប្រព្រឹត្តទៅថ្ងៃទី១៧-១៨ វិច្ឆិកា ឆ្នាំ២០១៩ នៅភ្នំពេញ។
- **ឆ្នាំ២០២០** - បានចូលរួមរៀបចំផែនការនៃកិច្ចសហប្រតិបត្តិការតភ្ជាប់សម្រាប់ឆ្នាំ២០២០-២០៣០ ក្រោមក្រខ័ណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។
- **ឆ្នាំ២០២១** - បានចូលរួមរៀបចំ «ក្របខ័ណ្ឌយុទ្ធសាស្ត្រកម្មវិធីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចមហាអនុតំបន់មេគង្គឆ្នាំ២០៣០» (GMS 2030) និងចូលរួមរៀបចំកិច្ចប្រជុំកំពូល GMS លើកទី៧ កាលពីខែកញ្ញា ឆ្នាំ២០២១។

## ១.៤.៤- ការវាយតម្លៃលើអត្ថប្រយោជន៍

### ១.៤.៤.១- អត្ថប្រយោជន៍នៃការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី

- ពិធីសារទី១ ធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន (ATIGA)៖ ការអនុវត្តពិធីសារនេះ រំពឹងថាជួយលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្មក្នុងតំបន់អាស៊ាន ថែមមួយកម្រិតទៀត ស្របតាមផែនការមេសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ តាមរយៈការអនុវត្តស្វ័យបញ្ជាក់ដើមកំណើតទំនិញ

ទូទាំងអាស៊ាន ដែលជាយន្តការចូលរួមកាត់បន្ថយចំណាយពេលវេលា និងធនធាន លើនីតិវិធីនៃការចេញសំអាងដើមកំណើតទំនិញ។ បន្ថែមពីនេះ ពិធីសារនេះ ក៏នឹងជួយជំរុញសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក ក្នុងការបង្កើនលទ្ធភាពនាំចេញផលិតផលរបស់ខ្លួនទៅកាន់ទីផ្សារអាស៊ាន និងចូលរួមក្នុងខ្សែច្រវាក់ផលិតផលក្នុងតំបន់ផងដែរ

- កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយតំបន់(RCEP)៖ RCEP គឺជាកិច្ចព្រមព្រៀងដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងគុណភាពខ្ពស់ ដោយបានបញ្ចូលវិស័យថ្មីសំខាន់ៗ ដែលមិនធ្លាប់មានក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងអាស៊ានបូកកន្លងមក រួមមានពាណិជ្ជកម្មទំនិញ វិធានដើមកំណើត នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម អនាម័យនិងភូតគាមអនាម័យ ស្តង់ដាបទដ្ឋានបច្ចេកទេស និងនីតិវិធីវាយតម្លៃភាពអនុលោម ឧបាស្រ័យពាណិជ្ជកម្ម ពាណិជ្ជកម្មសេវាកម្ម សេវាហិរញ្ញវត្ថុ និងបំលាស់ទីរូបវន្តបុគ្គល វិនិយោគ ពាណិជ្ជកម្មអេឡិចត្រូនិក លទ្ធកម្មសាធារណៈ សហគ្រាសធុនតូចនិងមធ្យម កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេសជាដើម។ បន្ថែមពីនេះ កិច្ចព្រមព្រៀងនេះ ក៏ផ្តល់ភាពទន់ភ្លន់ និងស្របតាមបទប្បញ្ញត្តិ ជាពិសេសសម្រាប់ប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ផងដែរ។ តាមការសិក្សារបស់EIRA បន្ទាប់ពីកិច្ចព្រមព្រៀងនេះ ចូលជាធរមាន កម្ពុជារំពឹងថាមានកំណើនការនាំចេញចំនួន៧,៣%, វិនិយោគចំនួន២៣,៤% និងផលិតផលក្នុងស្រុកសរុប (GDP) ចំនួន៨,៩%
- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា ចិន (CCFTA)៖ ការសម្រេចបាននូវកិច្ចព្រមព្រៀង CCFTA បានចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាស្របតាមចំណុចទី៤ ស្តីពីការពង្រឹងសមត្ថភាពកម្ពុជា ដើម្បីបន្តសមាហរណកម្មខ្លួនចូលរួមក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។ កម្ពុជា នឹងទទួលបានអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងនេះ រួមមាន (១) ទទួលបានការបញ្ចុះពន្ធពីភាគីចិន ទៅ0% សម្រាប់ជំនិញ៨.៣៣៦ បន្ទាត់ពន្ធគយ ស្មើនឹង៩៧,៥៣% (២) ជំរុញលំហូរពាណិជ្ជកម្មសេវាកម្ម និងវិនិយោគរវាងភាគីទាំងពីរ កាន់តែប្រសើរឡើង (៣) ទទួលបានការផ្ទេរបច្ចេកវិទ្យា ចំណេះដឹង ចំណេះធ្វើ និងជំនាញពីការវិនិយោគផ្ទាល់ពីបរទេស និង(៤) ពង្រឹងការប្រកួតប្រជែងរបស់កម្ពុជា ក្នុងការនាំចេញទំនិញ និងសេវាកម្មទៅកាន់ប្រទេសចិន និងពិភពលោក
- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា កូរ៉េ (CKFTA) កិច្ចព្រមព្រៀងនេះនឹងជំរុញពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ដោយកូរ៉េខាងត្បូង បានយល់ព្រមដកពន្ធនាំចូល៩៥,៦% នៃទំនិញនាំចេញពីកម្ពុជា ចំណែកភាគីកម្ពុជាវិញ ក៏នឹងលុបចោលពន្ធលើទំនិញនាំចូលប្រមាណ៩៣,៨% ពីកូរ៉េខាងត្បូងផងដែរ។ បន្ថែមពីលើការបង្កើនពាណិជ្ជកម្ម កម្ពុជាសង្ឃឹមថាវិនិយោគរបស់ក្រុមហ៊ុនកូរ៉េខាងត្បូង នឹងជួយធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជាលើវិស័យសំខាន់ផ្សេងៗ បន្ថែមពីលើឧស្សាហកម្មកាត់ដេរ វាយនភ័ណ្ឌ និងទេសចរណ៍ ដែលកំពុងមានសព្វថ្ងៃ។ គិតត្រឹមឆ្នាំ២០២២ នេះ មានក្រុមហ៊ុនកូរ៉េខាងត្បូងប្រមាណ៣០០ក្រុមហ៊ុន កំពុងវិនិយោគលើឧស្សាហកម្មនៅកម្ពុជា ភាគច្រើនជាឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ស្បែកជើង កាបូបធ្វើដំណើរ គ្រឿងបង្គុំអគ្គិសនីនិងគ្រឿងបន្លាស់អេឡិចត្រូនិកជាដើម។ ចំណែកទំនិញនាំចេញទៅកាន់កូរ៉េខាងត្បូងរួមមានកៅស៊ូ ផ្លែឈើ ម្សៅមី និងគ្រឿងបង្គុំអគ្គិសនីជាដើម។

#### ១.៤.៤.២- អត្ថប្រយោជន៍នៃកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន និងអាស៊ានបូក

- ការចរចាលើពិធីសារដើម្បីអនុវត្តកញ្ចប់នៃការប្តេជ្ញាបើកចំហសេវាហិរញ្ញវត្ថុ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវា (AFAS)៖ សមាជិកអាស៊ាន រួមទាំងកម្ពុជា បានធ្វើសេរីភាវូបនីយកម្មសេវាហិញ្ញវត្ថុ ផ្តោតលើវិស័យធនាគារ ធានារ៉ាប់រង និងមូលបត្រ តាមរយៈពិធីសារស្តីពីការប្តេជ្ញាបើកចំហសេវាហិរញ្ញវត្ថុក្រោម AFAS ចំនួន ៨កញ្ចប់ ហើយកំពុងត្រៀមចុះហត្ថលេខាលើកញ្ចប់ទី៩ ដែលជាកញ្ចប់ចុងក្រោយក្នុងឆ្នាំ២០២២ ឬ ២០២៣។ ការចរចាលើពិធីសារទាំងនេះ មានគោលបំណងជំរុញការធ្វើសមាហរណកម្មហិញ្ញវត្ថុឱ្យកាន់តែស៊ីជម្រៅក្នុងតំបន់ និងសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងវិនិយោគក្នុងតំបន់ ដោយផ្អែកតាមដំណាក់កាលនៃការត្រៀមខ្លួន និងអភិវឌ្ឍសមត្ថភាព ព្រមទាំងការរៀបចំបទប្បញ្ញត្តិរបស់សមាជិកអាស៊ាននីមួយៗ
- កិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាអាស៊ាន (ASEAN Trade in Services Agreement (ATISA) តាមរយៈការផ្លាស់ប្តូរពីអភិក្រមវិជ្ជមាន (Positive Listing Approach) ទៅអនុវត្តអភិក្រមអវិជ្ជមាន (Negative Listing Approach) ជំនួសវិញ កិច្ចព្រមព្រៀងនេះ រំពឹងថានឹងធ្វើឱ្យកាន់តែស៊ីជម្រៅនូវការធ្វើសេរីភាវូបនីយកម្មសេវាកម្មក្នុងតំបន់អាស៊ាន ដោយរួមបញ្ចូលទាំងសេវាហិរញ្ញវត្ថុផងដែរ
- កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ានបូក៣៖ កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ានបូក៣ បានរួមចំណែកសំខាន់ក្នុងការធានាស្ថេរភាពហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ចក្នុងតំបន់ តាមរយៈយន្តការ CMIM ដែលត្រូវបានបង្កើតឡើងដើម្បីជួយដល់ប្រទេសសមាជិកអាស៊ានបូក៣ ក្នុងការដោះស្រាយវិបត្តិសេដ្ឋកិច្ច និងបញ្ហាសន្ទនីយភាព រយៈពេលខ្លី (Short term liquidity difficulty) ព្រមទាំង AMRO ដែលត្រូវបានចាត់ទុកថាជា "វេជ្ជបណ្ឌិតគ្រួសារ" របស់សមាជិកអាស៊ានបូក៣ ក្នុងការតាមដាន និងការពារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ានបូក៣។

#### ១.៤.៤.៣- អត្ថប្រយោជន៍នៃកិច្ចសហប្រតិបត្តិការអនុតំបន់

តាមរយៈការចូលរួមក្នុងកិច្ចសហប្រតិបត្តិការអនុតំបន់ ដូចជា GMS, Mekong-Lancang, ACMECS, etc កម្ពុជា ទទួលបានអត្ថប្រយោជន៍ជាច្រើន ជាពិសេសតាមរយៈការទទួលបានជំនួយបច្ចេកទេសនិងហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍវិស័យសំខាន់ៗ ដូចជាហេដ្ឋារចនាសម្ព័ន្ធ កសិកម្ម ថាមពល បរិស្ថាន ការអភិវឌ្ឍធនធានមនុស្ស ការវិនិយោគ ទូរគមនាគមន៍ ទេសចរណ៍ និងការសម្របសម្រួលពាណិជ្ជកម្ម និងការដឹកជញ្ជូន ជាដើម។

### ១.៥- ការអភិវឌ្ឍវិស័យគាំពារសង្គម

យោងព្រះរាជក្រឹត្យលេខ នស/រកត/០៦១៧/៤៨៨ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមឱ្យកាន់តែប្រសើរឡើង និងសម្របសម្រួល តម្រង់ទិសរួមលើការងាររៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាល។ ក្រុមប្រឹក្សាជាតិគាំពារសង្គម មានអគ្គលេខាធិការដ្ឋានមួយដែលទទួលភារកិច្ចលើការប្រតិបត្តិការងារប្រចាំថ្ងៃ ដែលមានឈ្មោះថា **"អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម"** ដែលត្រូវបានបង្កើតឡើងក្រោមចំណុះក.ស.ហ.វ. យោងអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៨ ស្តីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។ រយៈពេលកន្លងនេះ ដើម្បីសម្រេចឱ្យបាននូវអនុវត្តយុទ្ធសាស្ត្ររាជរដ្ឋាភិបាល អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម សម្រេចបាននូវសមិទ្ធផលលើការលើកកម្ពស់ប្រព័ន្ធគាំពារសង្គមជាច្រើន រួមមាន៖

### ១.៥.១- កម្មវិធីជំនួយ និងគាំពារសង្គមនានាដែលបានដាក់អនុវត្តកន្លងមក

- កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ បានដាក់ឱ្យអនុវត្តនៅខែមិថុនា ឆ្នាំ២០១៩។ គិតត្រឹមថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២ ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ សរុបចំនួន ២៨៧ ៥៦៥នាក់ បានទទួលផលពីកម្មវិធីនេះ ដោយបានចំណាយថវិការដ្ឋសរុបចំនួន៨១ ៩១២លានរៀល
- កម្មវិធីផ្តល់អាហារតាមសាលារៀន ដោយប្រើប្រាស់កសិផលក្នុងសហគមន៍ បានផ្លាស់ប្តូរមកជាកម្មវិធីជាតិនៅឆ្នាំ២០១៩។ បច្ចុប្បន្ន កម្មវិធីនេះអនុវត្តនៅតាមសាលារៀនគោលដៅចំនួន២៩០សាលា ក្នុងនោះមានសិស្សទទួលផលចំនួន៧៤ ៨៨៧នាក់ ដែលរាជរដ្ឋាភិបាលបានវិភាជថវិកាចំនួន១០ ៣២២ លានរៀល សម្រាប់ឆ្នាំ២០២២
- កម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រថ្នាក់បឋមសិក្សា និងមធ្យមសិក្សា។ ក្នុងឆ្នាំសិក្សា២០២១-២០២២ នេះ មានសិស្សក្រីក្រទទួលផលសរុបចំនួន២៥០ ៩០៤នាក់ ដោយរាជរដ្ឋាភិបាលបានវិភាជថវិកាចំនួន ៥៩ ០៦០,៩ លានរៀល ក្នុងឆ្នាំ២០២២
- កម្មវិធីឧត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះ ក្នុងកំលុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ចាប់ផ្តើមអនុវត្តពីខែមិថុនា ឆ្នាំ២០២០ រហូតមកដល់បច្ចុប្បន្ន គិតត្រឹមខែតុលា ឆ្នាំ២០២២ មានអ្នកទទួលផលសរុបចំនួន៧០៦ ០៦០គ្រួសារ ស្មើនឹង២ ៧៨៨ ០៦៣នាក់ និងបានបើកប្រាក់ឧបត្ថម្ភសរុបចំនួន **៣ ៣៤៨ ២០៣ ១១១ ០០០ រៀល**
- កម្មវិធីជំនួយសង្គមជាសាច់ប្រាក់ក្រោយពេលបិទខ្ទប់ បានដាក់ឱ្យដំណើរការនៅដើមខែមិថុនា ឆ្នាំ២០២១ ដែលការបើកផ្តល់សាច់ប្រាក់ឧបត្ថម្ភជូនប្រជាពលរដ្ឋនិងគ្រួសារប្រជាពលរដ្ឋគោលដៅសរុបចំនួន ១២១ ៣៩៧ គ្រួសារ ដោយចំណាយថវិកាសរុបចំនួន**៣១ ៦៥៩ ៦៦៦ ៦០០រៀល**

### ១.៥.២- សមិទ្ធផលនៃការអនុវត្តយុទ្ធសាស្រ្តរាជរដ្ឋាភិបាល នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម

- ផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករសន្តិសុខសង្គមឆ្នាំ២០២២-២០២៦ ដែលនឹងកំពុងដាក់ឆ្លងក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- សៀវភៅណែនាំស្តីពីការគ្រប់គ្រងនិងត្រួតពិនិត្យលើផ្នែកថែទាំសុខភាព និងផ្នែកហានិភ័យការងារ
- អនុក្រឹត្យស្តីពី "គោលការណ៍ណែនាំសម្រាប់ការវិនិយោគមូលនិធិសន្តិសុខសង្គម" ដែលនឹងកំពុងដាក់ឆ្លងក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ប្រកាសស្តីពីការកំណត់ប្រភេទនិងទម្រង់នៃរបាយការណ៍របស់ប្រតិបត្តិករសន្តិសុខសង្គម និងភាគីពាក់ព័ន្ធ ត្រឹមកម្រិតអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- ប្រកាសស្តីពី "លក្ខខណ្ឌនិងនីតិវិធីក្នុងការជ្រើសរើសក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងប្រព័ន្ធសន្តិសុខសង្គម" ត្រឹមកម្រិតអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- យុទ្ធសាស្រ្តទំនាក់ទំនងនិងផ្សព្វផ្សាយគាំពារសង្គមកម្ពុជា

- សេចក្តីសម្រេចស្តីពីនីតិវិធីនិងយន្តការនៃការដោះស្រាយវិវាទឬបណ្តឹងដោយនិយ័តករសន្តិសុខសង្គម ឆ្លងកិច្ចប្រជុំបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យន្តការដាននិងវាយតម្លៃប្រព័ន្ធគាំពារសង្គម និងបានអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់យន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ដែលជួយសម្រួលដល់ការប្រមូលទិន្នន័យនិងព័ត៌មានពីក្រសួង ស្ថាប័នពាក់ព័ន្ធសម្រាប់ធ្វើកាតាមដានវឌ្ឍនភាព ប្រសិទ្ធភាព គុណភាព និងវិភាគលើការអនុវត្តកម្មវិធីនិងរបបក្នុងប្រព័ន្ធគាំពារសង្គម
- ឯកសារទស្សនាទានស្តីពីការឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ត្រូវបានអនុម័តដោយក្រុមប្រឹក្សាជាតិគាំពារសង្គម កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២
- ការធ្វើកំណែទម្រង់របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់មន្ត្រីសាធារណៈ
- ការកែសម្រួលស្ថាប័នទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល (ទ.ប.ច.ស) ដោយពង្រីកវិសាលភាពគ្រប់ដណ្តប់លើរបបថែទាំសុខភាព និងរបបហានិភ័យការងារដែលកំពុងអនុវត្តដោយបេឡាជាតិសន្តិសុខសង្គម(ប.ស.ស) និងមុខងារពាក់ព័ន្ធថ្មីៗមួយចំនួនបន្ថែមលើមូលនិធិសមធម៌សុខាភិបាល
- ការអភិវឌ្ឍទស្សនាទានសម្រាប់ការអភិវឌ្ឍមូលដ្ឋានទិន្នន័យចុះបញ្ជីគាំពារសង្គម។

## ១.៦- ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ

### ១.៦.១- ការជំរុញការអភិវឌ្ឍវិស័យយានយន្ត

រាជរដ្ឋាភិបាល បានដាក់ចេញនូវលិខិតលេខ១៩០៦ សជណ.ហជ ស្តីពីការកំណត់គោលការណ៍រួមស្តីពីការផ្តល់ការលើកទឹកចិត្តសម្រាប់គម្រោងវិនិយោគផ្គុំនិងដំឡើងរថយន្ត និងលិខិតលេខ៣៤៦ សជណ.ហជ ស្តីពីការលើកទឹកចិត្តចំពោះគម្រោងវិនិយោគផ្គុំនិងដំឡើងទោចក្រយានយន្តនិងត្រីចក្រយានយន្ត ក្នុងគោលបំណងដើម្បីទាក់ទាញវិនិយោគលើវិស័យដំឡើងយានយន្តនៅក្នុងស្រុករយៈពេលវែង បង្កើនភាពប្រកួតប្រជែងនិងពិពិធកម្មសេដ្ឋកិច្ច ជំរុញការប្រើប្រាស់ជាតុផ្សំក្នុងស្រុកនិងជាពិសេសបង្កើតទីផ្សារសម្រាប់ឧស្សាហកម្មគាំទ្រ ដែលភាគច្រើនជាសហគ្រាសធុនតូចនិងមធ្យម ។

### ១.៦.២- ការជំរុញការអភិវឌ្ឍវិស័យកាត់ដេរ ផលិតស្បែកជើងនិងកាបូបកម្ពុជា

"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើងនិងកាបូប កម្ពុជា២០២២-២០២៧" មានចក្ខុវិស័យអភិវឌ្ឍវិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបនៅកម្ពុជា ឱ្យទៅជាឧស្សាហកម្មដែលមានចីរភាពបរិស្ថានមានភាពធន់ មានតម្លៃបន្ថែមខ្ពស់ ផ្តោតលើផលិតផលថ្លៃខ្ពស់និងមានលក្ខណៈពិសេសមានភាពប្រកួតប្រជែងខ្ពស់ និងជាមូលដ្ឋានគាំទ្រពិពិធកម្មសេដ្ឋកិច្ចនៅមុនដំណាច់ឆ្នាំ២០២៧។ ដើម្បីសម្រេចចក្ខុវិស័យនេះ យុទ្ធសាស្ត្រនេះបានដាក់ចេញនូវវិធានការមួយចំនួនទៅតាមគោលដៅចំនួន៥ រួមមានទី១)- បន្តពង្រឹងធនធានមនុស្សដើម្បីបង្កើនផលិតភាពនិងបង្កើតគន្លងអាជីពសម្រាប់កម្មករនិយោជិត ទី២)- បន្តធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារនិងសុខុមាលភាពរបស់កម្មករ និយោជិត ទី៣)- លើកកម្ពស់ការវិនិយោគក្នុងស្រុកនិងបរទេសក្នុងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ និងផ្តោតលើផលិតផលថ្លៃខ្ពស់និងមានលក្ខណៈពិសេស ទី៤)- ទាក់ទាញការវិនិយោគនៅក្នុងឧស្សាហកម្មគាំទ្រសម្រាប់បម្រើឱ្យវិស័យនេះ និងទី៥)- ជំរុញការធ្វើពិពិធកម្មទីផ្សារនាំចេញផលិតផលកាត់ដេរស្បែកជើងនិងកាបូប។

## ១.៧- ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តន៍ឧស្សាហកម្មទី៤

### ១.៧.១- ការរៀបចំសេដ្ឋកិច្ច និងសង្គមឌីជីថល

នៅខែឧសភា ឆ្នាំ២០២១ ដោយមានការឯកភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញឱ្យអនុវត្តជាផ្លូវការនូវ«ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា២០២១ដល់២០៣៥»។ ក្របខ័ណ្ឌគោលនយោបាយនេះ មានចក្ខុវិស័យ«កសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និងបរិវត្តកម្ម ឌីជីថលនៅក្នុងគ្រប់តួអង្គសង្គមទាំងរដ្ឋ ទាំងពលរដ្ឋ និងទាំងធុរជន ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីភាពថ្មី»។ ជាមួយគ្នានេះ គោលបំណងនៃគោលនយោបាយនេះផ្តោតលើ«ការកសាងសេដ្ឋកិច្ចឌីជីថលឱ្យក្លាយជាចន្ទល់កំណើនសេដ្ឋកិច្ចថ្មីផង និងជាប្រព័ន្ធអេកូឡូស៊ីរួមចំណែកបង្កើនផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋនៃសង្គមឌីជីថលកម្ពុជាផង»។ ក្នុងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា តាមចក្ខុវិស័យ និងគោលបំណងខាងលើ ក្របខ័ណ្ឌគោលនយោបាយនេះកំណត់យកគោលដៅចម្បងចំនួន៥ រួមមាន(១) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ (២) ការកសាងទំនុកចិត្ត និងភាពជឿជាក់លើប្រព័ន្ធឌីជីថល (៣) ការកសាងពលរដ្ឋឌីជីថល (៤) ការកសាងរដ្ឋាភិបាលឌីជីថល និង(៥) ការជំរុញធុរកិច្ចឌីជីថល។

### ១.៧.២- ការរៀបចំប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

យោងតាមអនុក្រឹត្យលេខ៨៤ អនក្រ.បក ស្តីពីចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដឹកនាំក្រុមការងារអន្តរក្រសួង ស្ថាប័ន ដែលមានមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី «តេជោ» (ម.ធ.ត.) អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.) និងក្រសួង-ស្ថាប័ន ពាក់ព័ន្ធបានបានបញ្ចប់ការរៀបចំដំណាក់កាលទី១ នៃប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០២០។ ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់បរិយាកាសធុរកិច្ច និងបង្កើតការប្រកួតប្រជែងរបស់កម្ពុជា ហើយមានគោលដៅបង្កើតបរិស្ថានល្អសម្រាប់ប្រកបអាជីវកម្ម និងជំរុញកំណើនអាជីវកម្មក្នុងកំលុងពេលមានវិបត្តិ។ នៅក្នុងដំណាក់កាលទី១ នៃការរៀបចំប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន គឺសំដៅជួយសម្រួលដល់អាជីវករ ធុរជន និងក្រុមហ៊ុនក្នុងការធ្វើការចុះបញ្ជីអាជីវកម្មរបស់ខ្លួន ដោយសម្រួលលើនីតិវិធីរដ្ឋបាលបន្ថយចំណាយ និងពេលវេលា តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានតែមួយ។ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ ដំណាក់កាលទី២ នៃប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវបានបញ្ចប់នឹងដាក់ឱ្យអនុវត្តជាផ្លូវការ យោងតាមអនុក្រឹត្យលេខ១៦៤ អនក្រ.បក ស្តីពីការផ្លាស់ប្តូរទិន្នន័យតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា។ ក្នុងដំណាក់កាលទី២ នេះដែរ ធុរជន អាជីវករ និងក្រុមហ៊ុនអាចធ្វើការស្នើអាជ្ញាបណ្ណ/លិខិតអនុញ្ញាតប្រកបអាជីវកម្មក្នុងវិស័យទេសចរណ៍ វិស័យហិរញ្ញវត្ថុមិនមែនធនាគារ វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ និងវិស័យឧស្សាហកម្ម។ លើសពីនេះ ក្រុមការងារកំពុងបន្តធ្វើកិច្ចសហការជាមួយក្រសួង ស្ថាប័នប្រមាណ៩ទៀត ដើម្បីរៀបចំពង្រីកវិសាលភាព និងអភិវឌ្ឍន៍ប្រព័ន្ធចុះបញ្ជីតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងដំណាក់កាលទី៣ និងគ្រោងនឹងបញ្ចប់នៅឆ្នាំក្រោយ។

## ១.៨- ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ សរសេរជាអក្សរកាត់ អ.ស.ហ. ត្រូវបានបង្កើតឡើងយោងតាមព្រះរាជក្រម នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ និង អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលមានគោលបំណងនិងធានាប្រសិទ្ធភាពនៃការគ្រប់គ្រង ការត្រួតពិនិត្យ និងអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធានាគារ រួមទាំងការលើកកម្ពស់ការអភិវឌ្ឍ និងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុមិនមែនធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ យោងតាមសម្មិទ្ធផលការងារនាពេលកន្លងមក អ.ស.ហ. បានបន្តអនុវត្តមុខងារ និងភារកិច្ចលើតួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យសេវាហិញ្ញវត្ថុមិនមែនធនាគារមានដូចជាៈ

- ប្រកាសស្តីពីការបង្កើតក្រុមការងារប្រតិបត្តិកិច្ចការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងអង្គភាពក្រោមចំណុះ
- ប្រកាសស្តីពីការបង្កើតក្រុមការងារប្រតិបត្តិកិច្ចការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ប្រចាំអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- ប្រកាសស្តីពីការបង្កើតក្រុមការងារមណ្ឌលហិរញ្ញវត្ថុ
- សេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាៈ រៀបចំសេចក្តីសម្រេចបង្កើត បង្កើតក្រុមការងារ ជំនួយស្មារតី បទបង្ហាញ និងរបាយការណ៍លទ្ធផលកិច្ចប្រជុំ ព្រមទាំងរៀបចំសេចក្តីព្រាងឯកសារទស្សនាទានជាមូលដ្ឋានរៀបចំសេចក្តីព្រាងគោលនយោបាយនេះ
- ការរៀបចំផតថលបច្ចេកវិទ្យាហិរញ្ញវត្ថុ(FinTech Portal) ដោយរៀបចំសំណើសុំរៀបចំគម្រោងនេះសម្រាប់រយៈពេល៣ឆ្នាំ ព្រមទាំងរៀបចំមូលដ្ឋានទិន្នន័យនិងការរចនាបឋម
- ឯកសារស្រាវជ្រាវអំពីបច្ចេកវិទ្យាហិរញ្ញវត្ថុៈ បាននិងកំពុងសិក្សាស្រាវជ្រាវអំពីក្របខ័ណ្ឌគោលនយោបាយ យុទ្ធសាស្ត្រ គតិយុត្ត/និយ័តកម្ម ស្ថាប័ន និងគំរូអាជីវកម្ម នៅប្រទេសកម្ពុជា សិង្ហបុរី ឥណ្ឌូណេស៊ី ថៃ ហ្វីលីពីន និងវៀតណាម បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ( FinTech Regulatory Sandbox) របស់បណ្តាប្រទេសអាស៊ាន
- ឯកសារទស្សនាទានស្តីពីសុខដុមនីយកម្មមុខងារបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា និងឯកសារទស្សនាទានស្តីពីនិយតកម្មបច្ចេកវិទ្យាហិរញ្ញវត្ថុៈ ប្រមូលផ្តុំឯកសារពាក់ព័ន្ធសម្រាប់រៀបចំឯកសារទស្សនាទានទាំងនេះ
- ការផ្សព្វផ្សាយបទប្បញ្ញត្តិគតិយុត្តនិងព័ត៌មានពាក់ព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយអនុវត្តតាមមធ្យោបាយផ្សព្វផ្សាយផ្សេងៗ
- ការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយ(Disaster Risk Financing Strategy -DRFS)
- ការរៀបចំកម្រងបទប្បញ្ញត្តិគតិយុត្តសម្រាប់ជាមូលដ្ឋានអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុៈ ប្រមូលផ្តុំអត្ថបទគតិយុត្តសរុបប្រមាណ ៣៥៣អត្ថបទ ដែលគ្របដណ្តប់លើវិស័យឌីជីថល វិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុមិនមែនធនាគារ និងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុធនាគារ ដោយបញ្ចូលទៅក្នុងមាតិកានុក្រមលម្អិតតាមកម្មវត្ថុ

គតិយុត្តនីមួយៗ និងស្នើសុំជាតុចូលជាតុពីនិយ័តករក្រោមឱវាទ អ.ស.ហ.(កម្រងបទប្បញ្ញត្តិគតិយុត្តសម្រាប់ជាមូលដ្ឋានអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ) ។

### ១.៨.១- ការងារធានារ៉ាប់រង

- នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលសម្រេចឱ្យមានការប្រែក្លាយនាយកដ្ឋានធានារ៉ាប់រង នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ទៅជានិយ័តករធានារ៉ាប់រងកម្ពុជា (ន.ធ.ក.)។ ការណ៍នេះ ជាចំណុចរបត់ដ៏សំខាន់មួយ សម្រាប់ការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជា ក៏ដូចជាការពង្រឹងតួនាទីនិយតកម្មទីផ្សារធានារ៉ាប់រងកម្ពុជា។ កន្លងមកនេះ ន.ធ.ក. សម្រេចបានសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់ ដែលនឹងជំរុញការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជាឱ្យកាន់តែរីកចម្រើន សមិទ្ធផលទាំងនោះមានដូចខាងក្រោម៖

❖ **ទិន្នន័យនៃការផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មធានារ៉ាប់រង**

គិតមកដល់ខែកញ្ញា ឆ្នាំ២០២២ ក្រុមហ៊ុនធានារ៉ាប់រងដែលទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្មធានារ៉ាប់រងមានទ្រព្យសកម្មសុរបប្រមាណ**៨៥១លានដុល្លារអាម៉េរិក** និងទ្រព្យអសកម្មធានារ៉ាប់រងសុរបប្រមាណ**៤៨១លានដុល្លារអាម៉េរិក** ក្នុងនោះរួមមាន៖

- ក្រុមហ៊ុនធានារ៉ាប់រងទូទៅចំនួន១៨
- ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន១៤
- ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចចំនួន៧
- ក្រុមហ៊ុនដើងសាធានារ៉ាប់រងមានចំនួន១៧
- ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងចំនួន២៦
- បុគ្គលភ្នាក់ងារធានារ៉ាប់រងចំនួនប្រមាណ១០ ០០០នាក់
- ក្រុមហ៊ុនធានារ៉ាប់រងបន្តចំនួន១ ដែលមានភាគហ៊ុនរដ្ឋចំនួន៦០,២១ % ដោយមានដើមទុននិងទ្រព្យសកម្មប្រមាណ៣៦,៥ លានដុល្លារអាម៉េរិក ។

### ១.៨.២- ការងារបរធនបាលកិច្ច

នៅក្នុងបរិបទនៃសកលភាវូបនីយកម្មនេះដែរ បច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) សេវានិងផលិតផលហិរញ្ញវត្ថុថ្មីៗជាច្រើនត្រូវបានបង្កើតឡើងដោយប្រតិបត្តិករហិរញ្ញវត្ថុកម្ពុជា ដែលធ្វើឱ្យកម្ពុជាត្រូវប្រឈមនឹងការលំបាកក្នុងការកំណត់ដែនសមត្ថកិច្ចរបស់បញ្ញត្តិករហិរញ្ញវត្ថុនីមួយៗ ក៏ដូចជាយន្តការគ្រប់គ្រង។ ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងខាងលើទាំងអស់នេះ រួមទាំងការលើកកម្ពស់ការអភិវឌ្ឍនិងការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដោយមើលឃើញអំពីសារៈសំខាន់និងអត្ថប្រយោជន៍នៃការពង្រឹងយន្តការស្ថាប័នសម្រាប់គ្រប់គ្រងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដែលរួមទាំងវិស័យបរធនបាលកិច្ចផងដែរនោះ រាជរដ្ឋាភិបាល ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តួចផ្តើមគិតគូរអំពីការធ្វើសមាហរណកម្មយន្តការគ្រប់គ្រងវិស័យហិរញ្ញវត្ថុមិនមែនធនាគារនេះ តាមរយៈការរៀបចំច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

អនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ឆ្នាំ២០២១ នាយកដ្ឋានទីផ្សារនិងស្ថាប័នហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ត្រូវបានធ្វើសមាហរណកម្មជា

**និយ័តករបរធនបាលកិច្ច** ហៅកាត់ថា (ន.ប.ធ.) ជានិយ័តករគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ច នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងត្រូវអនុវត្តសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងច្បាប់ស្តីពីបរធនបាលកិច្ច និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យបរធនបាលកិច្ច។

គិតត្រឹមខែកញ្ញា ឆ្នាំ២០២២ ន.ប.ធ. បានផ្តល់ការចុះបញ្ជីបរធនបាលកិច្ចចំនួន ៥៩ករណី ដែលមានទំហំបរធនសរុបចំនួន៣៣៣ ៣៣៤ ៤៣៩,៦៦ ដុល្លារអាម៉េរិក ក្នុងនោះរួមមាន៖

- បរធនបាលកិច្ចសាធារណៈ ចំនួន១ ទំហំបរធន៦៤ ២០០ ០៦៧ ដុល្លារអាម៉េរិក
- បរធនបាលកិច្ចហិរញ្ញវត្ថុ ចំនួន៩ ទំហំបរធន១៧៥ ៨១១ ៩៥៩ ដុល្លារអាម៉េរិក
- បរធនបាលកិច្ចពាណិជ្ជកម្ម ចំនួន៣៩ ទំហំបរធន៩២ ០១៥ ៨៩២ ដុល្លារអាម៉េរិក
- បរធនបាលកិច្ចបុគ្គល ចំនួន៣ ទំហំបរធន១ ៣០៦ ៥២០ ដុល្លារអាម៉េរិក។

គិតត្រឹមខែកញ្ញា ឆ្នាំ២០២២ ន.ប.ធ បានផ្តល់អាជ្ញាបណ្ណជូនប្រតិបត្តិករបរធនបាល និងបរធនបាលរូបវន្តបុគ្គលឯករាជ្យ ចំនួន១១ ក្នុងនោះរួមមាន ៖

- ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក ចំនួន១
- បរធនបាលរូបវន្តបុគ្គលឯករាជ្យ ចំនួន១០
- ប្រតិបត្តិករបរធនបាលដែលបានចុះបញ្ជី និងការស្នើសុំការអនុញ្ញាតបន្ថែមរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសនៃគម្រោងវិនិយោគរួមនិងភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រចំនួន១៣។

## ១.៨.៣- ការងារអាជីវកម្មអចលនវត្ថុ និងបញ្ចាំ

ចាប់តាំងពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២ ក្នុងវិស័យអាជីវកម្មអចលនវត្ថុនិងបញ្ចាំ និយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ(ន.អ.ប.) បានកត់សម្គាល់ឃើញមានភាពថយចុះក្នុងស្នើសុំអាជ្ញាបណ្ណសម្រាប់អាជីវកម្មអភិវឌ្ឍលំនៅឋាននិងអគារសហកម្មសិទ្ធិ និងអាជីវកម្មផ្នែកបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ដោយសារការរីករាលដាលនៃវិបត្តិជំងឺកូវីដ១៩។ បន្ទាប់ពីមានបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងនិងផ្តល់អាជ្ញាបណ្ណជូនប្រតិបត្តិករវិស័យសេវាកម្មវាយតម្លៃនិងគ្រប់គ្រងអចលនវត្ថុ មានការកើនឡើងក្នុងរយៈពេល៥ឆ្នាំ ។ ជាមួយគ្នានេះដែរ ក្នុងគោលបំណងនៃជួយសម្រួលជូនធុរកិច្ច ពាណិជ្ជកម្ម ក្រុមហ៊ុន/សហគ្រាស នៅក្នុងវិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន រាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យដំណើរការជាផ្លូវការនូវប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ក្នុងដំណាក់កាលទី២ នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១។ ក្នុងន័យនេះ ធុរជន អាជីវករ និងក្រុមហ៊ុនដែលមានបំណងធ្វើអាជីវកម្មក្នុងវិស័យបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន អាចស្នើសុំអាជ្ញាបណ្ណសម្រាប់ប្រកបអាជីវកម្មបញ្ចាំនិងប្រាតិភោគដោយអនុប្បទាន តាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដោយមានការសម្រួលនីតិវិធី កាត់បន្ថយពេលវេលា និងចំណាយ ។

ទិន្នន័យចំនួនក្រុមហ៊ុនចុះបញ្ជីស្នើសុំអាជ្ញាបណ្ណ សម្រាប់ប្រកបអាជីវកម្មក្នុងវិស័យអាជីវកម្មអចលនវត្ថុ និងបញ្ចាំគិតចាប់ពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២ មានដូចខាងក្រោម៖

- គម្រោងដែលទទួលបានអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍលំនៅឋាន និងអគារសហកម្មសិទ្ធិ ពីនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ មានចំនួន២៤៤គម្រោង
- ហ៊ុនដែលទទួលបានអាជ្ញាបណ្ណអាជីវកម្មអភិវឌ្ឍដីឡូត៍ មានចំនួន១ក្រុមហ៊ុន
- ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណគ្រប់គ្រងអចលនវត្ថុមានចំនួន១៨ក្រុមហ៊ុន
- ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណវាយតម្លៃ៧ក្រុមហ៊ុន

- ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណភ្នាក់ងារអចលនវត្ថុមានចំនួន១៩៥ក្រុមហ៊ុន
- ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណវាយតម្លៃនិងអាជ្ញាបណ្ណភ្នាក់ងារអចលនវត្ថុមានចំនួន៤៤ក្រុមហ៊ុន
- ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណវាយតម្លៃនិងអាជ្ញាបណ្ណភ្នាក់ងារអចលនវត្ថុ និងគ្រប់គ្រងអចលនវត្ថុ មានចំនួន៦ក្រុមហ៊ុន
- ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណភ្នាក់ងារអចលនវត្ថុនិងគ្រប់គ្រងអចលនវត្ថុ មានចំនួន១២ក្រុមហ៊ុន
- ក្រុមហ៊ុនដែលបានចុះបញ្ជីស្នើសុំអាជ្ញាបណ្ណអាជីវកម្មបញ្ចាំនិងប្រាតិភោគដោយអនុប្បទានមកនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ មានចំនួន២៩៨ក្រុមហ៊ុន/សហគ្រាស ។

### ១.៨.៤- ការងារគណនេយ្យនិងសវនកម្ម

នៅឆ្នាំ២០២១ ដោយមានការរីកចម្រើនខ្លាំងនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ និងដើម្បីសម្រេចបាននូវគោលបំណងរបស់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១៦-២០២៥ រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានស្នើអនុម័ត និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ តាមច្បាប់នេះ ក្រុមប្រឹក្សាជាតិគណនេយ្យបានប្រែក្លាយទៅជានិយ័តករគណនេយ្យនិងសវនកម្ម(ន.គ.ស.) ដែលជាសេនាធិការឱ្យអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ(អ.ស.ហ.) និងបានធ្វើឱ្យស្ថាប័ននិយ័តករនេះកាន់តែមានថាមពលក្នុងការធ្វើនិយតកម្មលើវិស័យវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម។ ន.គ.ស. បានបន្តអនុវត្តមុខងារ និងភារកិច្ចរបស់ ក.ជ.គ. លើតួនាទីដ៏សំខាន់ក្នុងការគ្រប់គ្រងនិងអភិវឌ្ឍន៍វិស័យ និងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម នៅព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅចូលរួមចំណែកកសាងមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចលើគ្រប់វិស័យ ទាំងធុរកិច្ចទូទៅ ទាំងវិស័យហិរញ្ញវត្ថុជាធនាគារនិងទាំងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។

ចំពោះទិន្នន័យចំនួនក្រុមហ៊ុនចុះបញ្ជី និងការផ្តល់អាជ្ញាបណ្ណ គិតមកដល់ត្រឹមខែតុលា ឆ្នាំ២០២២ ន.គ.ស បានផ្តល់អាជ្ញាបណ្ណប្រកបវិជ្ជាជីវៈគណនេយ្យ ដល់ក្រុមហ៊ុនចំនួន៨ និងអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈសវនកម្ម ដល់ក្រុមហ៊ុនចំនួន៤៨។ ចាត់តាំងពីការដាក់ឱ្យអនុវត្តជាផ្លូវការនៃប្រព័ន្ធE-filling ន.គ.ស. បានទទួលរបាយការណ៍ហិរញ្ញវត្ថុពីក្រុមហ៊ុនជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យចំនួន១ ៥៣៣ក្រុមហ៊ុននិងមិនរងសវនកម្មចំនួន១០ ៩៩១ក្រុមហ៊ុន ហើយអង្គភាពមិនស្វែងរកប្រាក់ចំណេញជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យចំនួន១៣១អង្គភាព និងមិនជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យចំនួន៣៥៣អង្គភាព។ ជាមួយគ្នានេះ វិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា(វ.គ.ស.ក.) ទទួលបានការចុះឈ្មោះសមាជិករូបវន្តបុគ្គលចំនួន២៤៥រូប (សមាជិកសកម្មមានចំនួន១៦៨រូបសមាជិកសមាគតមានចំនួន១រូប សមាជិកចូលរួមមានចំនួន៣៩រូប និងសមាជិកបម្រុងមានចំនួន៣៧រូប)។

### ១.៨.៥- វិស័យមូលបត្រកម្ពុជា

គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ដែលជានិយ័តករគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យមូលបត្រ ត្រូវបានបង្កើតឡើងក្រោមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧។ តាមរយៈច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ គ.ម.ក. ត្រូវ

បានប្តូរឈ្មោះជានិយ័តករមូលបត្រកម្ពុជា(ន.ម.ក.) ដែលស្ថិតក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ(អ.ស.ហ.)។ ខាងក្រោមគឺជាសមិទ្ធផលដែលន.ម.ក. សម្រេចបានក្នុងរយៈពេល៥ឆ្នាំ (ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២)។

**ទិន្នន័យជួញដូរមូលបត្របំណុល មូលបត្រកម្មសិទ្ធិ និងឧបករណ៍និស្សន្ទ**

| បរិយាយ | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ត្រឹមខែកញ្ញា ឆ្នាំ២០២២ | សរុបគិតត្រឹមត្រីមាសទី៣ ឆ្នាំ ២០២២ |
|---|---|---|---|---|---|---|---|
| **ទីផ្សារមូលបត្រកម្មសិទ្ធិ** | | | | | | | |
| ចំនួនបុគ្គលចុះបញ្ជីមូលបត្រកម្មសិទ្ធិ | | - | - | ២ | ១ | ១ | ៤ |
| ចំនួនសាច់ប្រាក់ដែលប្រមូលបានពីបោះផ្សាយ | រៀល (លាន) | - | - | ៨២ ៦៩៥,២១ | ១៥ ៣៧៨,៤៦ | ១៥ ៧៣៣,៩០ | ១១៣ ៨០៧,៥៧ |
| | ដុល្លារ (លាន) | - | - | ២០,៦៧ | ៣,៨៤ | ៣,៩៣ | ២៨,៤៥ |
| មូលធនូបនីយកម្មទីផ្សារ | រៀល (លាន) | ១ ៧៧១ ៦៧៨ | ២៨០៥៨០៧ | ៩ ៨២៧ ៧៤៦ | ៧ ១៧៩ ៨០៤ | ៧ ០៨៣ ១៣១ | ៧ ០៨៣ ១៣១ |
| | ដុល្លារ (លាន) | ៤៤២,៩២ | ៧០១,៤៥ | ២ ៤៥៦,៩៤ | ១ ៧៩៤,៩៥ | ១ ៧៧០,៧៨ | ១ ៧៧០,៧៨ |
| ទំហំជួញដូរសរុប (ភាគហ៊ុន) | | ៣ ៧៨១ ២៣១ | ១៥៤៨៩៩០៥ | ១១ ៣៤៥ ២៨៥ | ៥៥ ១២៣ ៧៤០ | ៤៦ ១៨៥ ២០០ | ១៣១ ៩២៥ ៣៦១ |
| តម្លៃជួញដូរសរុប | រៀល (លាន) | ២៤ ៩០២,៣២ | ១៤៨៨៧៨,៦៤ | ១១៣ ៧២៦,៧៥ | ២៥៦ ៧១៩,០១ | ៤៨២ ៧៦២,៥៥ | ១ ០២៦ ៩៨៩,២៦ |
| | ដុល្លារ (លាន) | ៦,២៣ | ៣៧,២២ | ២៨,៤៣ | ៦៤,១៨ | ១២០,៦៩ | ២៥៦,៧៥ |

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ត្រឹមខែកញ្ញា ឆ្នាំ២០២២ | សរុបគិតត្រឹមត្រីមាសទី៣ ឆ្នាំ ២០២២ |
|---|---|---|---|---|---|---|
| **ទីផ្សារមូលបត្របំណុល** | | | | | | |
| ចំនួនបុគ្គលចុះបញ្ជីមូលបត្របំណុល | ១ | ២ | ៣ | ១ | - | ៧ |
| ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ (លានរៀល) | ១២០ ០០០ | ១៦៤ ៨២១ | ២៨៧ ២០០ | ៨០ ០០០ | - | ៦៥២ ០២១ |
| ចំនួនសាច់ប្រាក់ដែលប្រមូលបានពីការបោះផ្សាយ (លានដុល្លារ) | ៣០ | ៤១,២១ | ៧១,៨ | ២០ | - | ១៦៣,០១ |
| ទំហំជួញដូរសរុប (ឯកតា) | - | ១៨០ | ៤៦០ ៥១២ | ៦០ | - | ៤៦០ ៧៥២ |
| តម្លៃជួញដូរសរុប (លានរៀល) | - | ១៨ | ៤៦ ០៥១,២ | ៦,០៣ | - | ៤៦ ០៧៥,២៣ |
| តម្លៃជួញដូរសរុប (ដុល្លារ) | | ៤ ៥០០ | ១១ ៥១២ ៨០០ | ១ ៥០៧,៥ | - | ១១ ៥១៨ ៨០៧,៥ |

## ទិន្នន័យវិនិយោគិន

| N | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ត្រឹមត្រីមាសទី៣ ឆ្នាំ ២០២២ | ២០១៨ ដល់ ត្រីមាសទី៣ ឆ្នាំ ២០២២ | ២០១២ ដល់ ត្រីមាសទី៣ ឆ្នាំ ២០២២ |
|---|---|---|---|---|---|---|---|
| ចំនួនវិនិយោគិន | ១១ ៧១៤ | ១ ៨៩៧ | ៤ ១៧៤ | ៤ ១៧៧ | ២ ៣៨៨ | ២៤ ៣៥០ | ៣៣ ១៨៦ |

## ក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យមូលបត្រ

| ល.រ | ប្រភេទអាជីវកម្ម | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ឆ្នាំ២០២២ ត្រឹមខែកញ្ញា | ២០១៨ ដល់ ត្រីមាសទី៣ ឆ្នាំ ២០២២ | ២០១០ ដល់ ត្រីមាសទី៣ ឆ្នាំ២០២២ |
|---|---|---|---|---|---|---|---|---|
| **អាជីវកម្មមូលបត្រ** | | | | | | | | |
| ១ | ក្រុមហ៊ុនធានាទិញមូលបត្រ | - | - | - | ១ | - | ១ | ៧ |
| ២ | ពាណិជ្ជករមូលបត្រ | - | - | - | - | - | - | - |
| ៣ | ឈ្មួញជើងសាមូលបត្រ | - | - | ១ | - | - | ១ | ៥ |
| ៤ | ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ | ១ | - | ២ | - | - | ៣ | ៣ |
| ៥ | ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ | - | - | - | - | ១ | ១ | ២ |
| ៦ | ក្រុមហ៊ុនចែកចាយលក់មូលបត្រ | - | ១ | ១ | - | - | ២ | ២ |
| ៧ | ក្រុមហ៊ុនផ្តល់សេវាសវនម្ម | ១ | ១ | | - | - | ២ | ៨ |
| ៨ | ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ | ១ | ២ | ១ | - | ១ | ៥ | ១៥ |
| ៩ | ក្រុមហ៊ុនផ្តល់សេវាបកប្រែក្នុងវិស័យមូលបត្រ | - | - | - | - | - | ០ | ១ |
| ១០ | ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ | - | - | - | - | - | ០ | ៣ |
| ១១ | ភ្នាក់ងារតំណាងម្ចាស់មូលបត្របំណុល | ១ | - | - | - | ១ | ២ | ២ |
| ១២ | ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រ | - | - | - | - | - | ០ | ១ |
| ១៣ | ភ្នាក់ងារវាយតម្លៃលទ្ធភាពសង | - | - | - | - | ១ | ១ | ១ |
| ១៤ | ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ | - | ២ | ១ | - | - | ៣ | ៦ |
| ១៥ | ភ្នាក់ងារបញ្ជិការ ភ្នាក់ចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ | - | - | - | - | - | ០ | ៣ |
| អាជីវកម្មឧបករណ៍និស្សន្ទ | | | | | | | | |
| ១៦ | ក្រុមហ៊ុនសមភាគីកណ្តាល | - | ១ | - | ១ | - | ២ | ៥ |
| ១៧ | ឈ្មួញជើងសាឧបករណ៍និស្សន្ទ | ១៣ | ៨ | ៤ | ៤ | ១៣ | ៤២ | ៣០ |
| អាជីវកម្មគម្រោងវិនិយោគរួម | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៨ | ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ | - | ៥ | ៤ | ៥ | ២ | ១៦ | ១៦ |
| ១៩ | ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស | - | ៤ | ៦ | ២ | ១ | ១៣ | ១៣ |
| ២០ | ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង | - | ១ | ២ | - | - | ៣ | ៣ |
| ២១ | ក្រុមហ៊ុនអភិបាលមូលនិធិ | - | - | ១ | - | - | ១ | ១ |

**ករណីស៊ើបអង្កេត និងការអនុវត្តច្បាប់ក្នុងវិស័យមូលបត្រ**

| ល.រ | បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ឆ្នាំ២០២២ ត្រឹមខែកញ្ញា | ២០១៨ ដល់ ត្រីមាសទី៣ ឆ្នាំ ២០២២ |
|---|---|---|---|---|---|---|---|
| ១ | ករណីស៊ើបអង្កេត | ៣៦ | ៤៤ | ៤៥ | ២១ | ២៩ | ១៧៥ |
| ២ | នីតិវិធីពង្រឹងការអនុវត្តច្បាប់លើករណីប្រព្រឹត្តអំពើល្មើស | ២៦ | ២១ | ៣៦ | ៤ | ៦ | ៩៣ |
| ៣ | ទទួលពាក្យបណ្ដឹងស្នើសុំដោះស្រាយវិវាទ | - | ១ | - | - | - | ១ |
| ៤ | អនុវត្តយន្តការដោះស្រាយ ដោយទទួលបានលទ្ធផលសះជា | - | - | ១ | - | - | ១ |

## ១.៩- ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម និងសហគ្រិនភាព

### ១.៩.១- ធនាគារសហគ្រាសធុនតូចនិងមធ្យមកម្ពុជា(ម.ក)

កាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ ២០២០ ធនាគារសហគ្រាសធុនតូចនិងមធ្យមកម្ពុជាម.ក (**ធ.ស.ក.**) ត្រូវបានផ្ដល់អាជ្ញាប័ណ្ណផ្លូវការជាធនាគារពាណិជ្ជ ដោយធនាគារជាតិនៃកម្ពុជា។ កន្លងមកនេះ ក្រោមការណែនាំផ្នែកបច្ចេកទេសពីក.ស.ហ.វ. និងការអនុវត្តស្របតាមគោលនយោបាយរាជរដ្ឋាភិបាល ធ.ស.ក. បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្ដល់ជំនួយ និងការយន្តការគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមដែលស្ថិតនៅក្នុងកំលុងពេលវិបត្តិជំងឺកូវីដ-១៩។ ចាប់ពីឆ្នាំ២០២០ រហូតដល់ខែកញ្ញា ឆ្នាំ២០២២ ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែ និងក្រោមកិច្ចសហប្រតិបត្តិការជាមួយក.ស.ហ.វ. ក៏ដូចជាក្រសួងស្ថាប័នផ្សេងទៀត ធ.ស.ក. បានផ្ដល់ឥណទានទៅសហគ្រាសធុនតូចនិងមធ្យម តាមរយៈគម្រោងហិរញ្ញប្បទានធំៗ ចំនួន២ ដូចជា៖

**ក- គម្រោងហិរញ្ញប្បទានដោយផ្ទាល់ (Direct Lending)៖** តាមរយៈគម្រោងនេះ ធ.ស.ក បានបញ្ចេញឥណទានសរុបចំនួន ៣៥,២៩ លានដុល្លារអាម៉េរិក ជូនទៅដល់សហគ្រាសធុនតូចនិងមធ្យម ចំនួន១៥០។

**ខ- គម្រោងសហហិរញ្ញប្បទាន (Co-Financing Scheme)៖** ធ.ស.ក បានសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុចូលរួម (PFIs) អនុវត្តនូវគម្រោងសហហិរញ្ញប្បទាន ចំនួន៣ រួមមាន៖

- គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូចនិងមធ្យម ដំហានទី១ មានកញ្ចប់ថវិកាបដិភាគសរុបចំនួន១០០លានដុល្លារអាម៉េរិក(ធ.ស.ក៥០លានដុល្លារអាម៉េរិកនិង PFIs ចំនួន៥០លានដុល្លារអាម៉េរិក)បានបញ្ចេញឥណទានសរុបចំនួន១០០លានដុល្លារអាម៉េរិកជូនទៅដល់សហគ្រាសធុនតូចនិងមធ្យមចំនួន៧៥៣
- គម្រោងសហហិរញ្ញប្បទានទ្រទ្រង់សហគ្រាសធុនតូចនិងមធ្យម ដំហានទី២ មានកញ្ចប់ថវិកាបដិភាគសរុបចំនួន២៤០លានដុល្លារអាម៉េរិក(ធ.ស.ក១២០លានដុល្លារអាម៉េរិកនិង

PFIs ចំនួន១២០លានដុល្លារអាម៉េរិក) បានបញ្ចេញឥណទានសរុបចំនួន២៤០លានដុល្លារអាម៉េរិកជូនទៅដល់សហគ្រាសធុនតូច និងមធ្យមចំនួន១ ៩៩២

- គម្រោងសហហិរញ្ញប្បទានស្តារនិងជំរុញកំណើនក្នុងវិស័យទេសចរណ៍ មានកញ្ចប់ថវិកាបដិភាគសរុបចំនួន១៥០លានដុល្លារអាម៉េរិក(ធ.ស.ក៧៥លានដុល្លារអាម៉េរិកនិង PFIs ចំនួន៧៥លានដុល្លារអាម៉េរិក) បានបញ្ចេញឥណទានសរុបចំនួន២៥.៣៥លានដុល្លារអាម៉េរិកជូនទៅដល់ សហគ្រាសធុនតូច និងមធ្យមចំនួន១៩០។

ជារួមក្រោមយន្តការការងារ ធនាគារសហគ្រាសធុនតូចនិងមធ្យមកម្ពុជា ម.ក បានបញ្ចេញឥណទានសរុបចំនួន៤០០,៦៤លានដុល្លារអាម៉េរិកជូនទៅដល់សហគ្រាសធុនតូចនិងមធ្យមចំនួន៣ ០៨៥។

### ១.៩.២- មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព/សហគ្រិនខ្មែរ

មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព/សហគ្រិនខ្មែរ គឺជាកម្មវិធីគាំទ្ររយៈពេលបីឆ្នាំ(២០១៩-២០២១) របស់រដ្ឋាភិបាលកម្ពុជា ដែលត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រង និងកៀរគរធនធានសម្រាប់គាំទ្រនិងសម្រួលដល់សកម្មភាពលើកកម្ពស់សហគ្រិនភាពនិងមានចក្ខុវិស័យ ដើម្បីជំរុញនិងលើកកម្ពស់សកម្មភាពសហគ្រិនប្រកបដោយប្រសិទ្ធភាព ក្នុងការគាំទ្រដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងនវានុវត្តន៍ ដើម្បីបង្កើនផលិតភាព និងការបង្កើតការងារសមរម្យ។ គោលការណ៍របស់កម្មវិធីនេះ គឺផ្តោតលើការកសាងប្រព័ន្ធអេកូឡូស៊ីរបស់សហគ្រិនភាព ក៏ដូចជាផ្តល់ការគាំទ្រដល់ធុរកិច្ចបង្កើតថ្មី និងសហគ្រាសធុនតូចនិងមធ្យម។ មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព/សហគ្រិនខ្មែរ បានកំណត់គោលដៅ ស្នូលចំនួន៣ គឺ៖ (១). ការផ្តល់សិទ្ធអំណាច (២). ការតភ្ជាប់ និង (៣). ការបំផុសគំនិត។ ក្នុងរយៈនៃការអនុវត្តផែនការសកម្មភាពកន្លងមក មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព/សហគ្រិនខ្មែរបានចូលរួមក្នុងការលើកកម្ពស់ ដោះស្រាយរាល់បញ្ហាប្រឈមនានា ជាពិសេសនៅក្នុងកំឡុងពេលឆ្លងរីករាលត្បាតជំងឺកូវីដ-១៩ ក្នុងសហគ្រិនខ្មែរ សម្រេចបាននូវសមិទ្ធផលរួមមាន៖

**ក- ការអនុវត្តកម្មវិធីលើកកម្ពស់វប្បធម៌សហគ្រិន៖** ដែលមានគោលដៅបញ្ជ្រាបការយល់ដឹងជាមូលដ្ឋានសហគ្រិនភាព និងគុណតម្លៃនានា ដូចជាការច្នៃប្រឌិត ការបង្កើតថ្មី ភាពជាដៃគូសហការ និងការដោះស្រាយបញ្ហានានាក្នុងសង្គម។ ដើម្បីសម្រេចបានការអនុវត្តកម្មវិធីលើកកម្ពស់វប្បធម៌សហគ្រិន សហគ្រិនខ្មែរបានរៀបចំបង្កើតឱ្យមាននូវអនុកម្មវិធីគាំទ្រមួយចំនួនរួមមាន៖

- **កម្មវិធីបង្កើតមាតិកាសង្គមអប់រំអំពីសហគ្រិនភាព** បង្កើតឡើងដើម្បីពង្រឹងគុណតម្លៃនៃភាពជាសហគ្រិន ដោយការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធទៅដល់ឱ្យចំបុគ្គលពាក់ព័ន្ធ
- **កម្មវិធីពានរង្វាន់សហគ្រិនខ្មែរកម្រិតវិទ្យាល័យ** គឺជាកិច្ចខិតខំប្រឹងប្រែងរបស់សហគ្រិនខ្មែរក្នុងការចូលរួម បង្កើតកម្មវិធីដែលជំរុញសមត្ថភាពប្រកួតប្រជែងពន្លកសហគ្រិនកម្ពុជា
- **កម្មវិធីពានរង្វាន់សហគ្រិនខ្មែរធុរកិច្ចបង្កើតថ្មី** គឺជាប្រភេទកម្មវិធីប្រកួតពានរង្វាន់ដែលសហគ្រិនខ្មែរបានសហការបង្កើត ដើម្បីផ្សារភ្ជាប់ទំនាក់ទំនង ផ្តល់ឱកាសឱ្យធុរកិច្ចថ្មីនៅកម្ពុជាបានបង្ហាញគំនិតអាជីវកម្មពិសេសៗរបស់ខ្លួន និងទាក់ទាញវិនិយោគិនបន្ថែម
- **កម្មវិធីពានរង្វាន់សហគ្រិនខ្មែរសហគ្រាសធុនតូច និងមធ្យម** បានដំណើរការដោយជោគជ័យ ហើយបានផ្តល់ ពានរង្វាន់ដល់ម្ចាស់អាជីវកម្មចំនួន៥រូប រួមមានពានរង្វាន់សហគ្រិនស្ត្រីឆ្នើម

វ័យក្មេង ពានរង្វាន់សហគ្រិនវ័យក្មេង ផ្នែកបច្ចេកវិទ្យា ពានរង្វាន់សហគ្រិនផ្ទើមវ័យក្មេងធុរកិច្ចបរិយាប័ន្ន ពានរង្វាន់សហគ្រិនផ្ទើមវ័យក្មេងផ្នែកសង្គម និងពានរង្វាន់សហគ្រិនផ្ទើមវ័យក្មេង

- **កម្មវិធីពានរង្វាន់សហគ្រិនថ្នាក់ជាតិ(NEA)** គឺជាកិច្ចសហការរវាងសហគ្រិនខ្មែរនិងវិទ្យាស្ថានជាតិសហគ្រិនភាពនិងនវានុវត្តន៍(NIEI) ដើម្បីរៀបចំប្រកួតនិងផ្តល់ពានរង្វាន់ដល់ម្ចាស់សហគ្រាសផ្ទើមនៅកម្ពុជា
- **កម្មវិធីសហគ្រិនជំនាន់ថ្មីNextGen Enterprise** គឺជាយុទ្ធនាការបណ្តុះបណ្តាលមូលដ្ឋានគ្រឹះសហគ្រិនភាព ដែលផ្តោតលើសិស្សានុសិស្សកម្រិតវិទ្យាល័យនៅថ្នាក់ទី១០និងទី១១ ។

**ខ. កម្មវិធីអភិវឌ្ឍន៍សហគ្រិនភាព៖** មានគោលបំណងលើកស្ទួយនិងពង្រឹងសមត្ថភាពនិងជំនាញសហគ្រិនភាព របស់សហគ្រិនធុរកិច្ចថ្មីនិងសហគ្រាសធុនតូចនិងមធ្យម។ កម្មវិធីអភិវឌ្ឍន៍សហគ្រិនភាព អនុវត្តក្រោមកិច្ចសហការ ជាមួយនឹងស្ថាប័នដៃគូក្នុងប្រព័ន្ធអេកូឡូស៊ី លើកម្មវិធីអប់រំសហគ្រិនភាព រួមមានភ្ញាស់គំនិតធុរកិច្ចថ្មីបណ្តុះធុរកិច្ចថ្មីពន្លឿនការលូតលាស់ធុរកិច្ចនិងការបណ្តុះបណ្តាលជំនាញគ្រប់គ្រងធុរកិច្ចផ្សេងទៀត ដើម្បីឱ្យយុវជនឬនិស្សិតសាកលវិទ្យាល័យ ពន្លកសហគ្រិនថ្មីៗ ស្ថាបនិកធុរកិច្ចថ្មីនិងម្ចាស់សហគ្រាសធុនតូចនិងមធ្យមអាចបង្កើនជំនាញធុរកិច្ចរបស់ខ្លួន ពង្រឹងសមត្ថភាពសហគ្រិននិងបង្កើតឬសម្រិតសម្រាំងគំរូផលិតផលឬផលិតផលសមស្របតាមទីផ្សារហៅថាMinimum-Viable-Products ឬ Product-Market-Fit ។

- **កម្មវិធីបណ្តុះធុរកិច្ចថ្មី** គឺជាកម្មវិធីពង្រឹងសមត្ថភាពសហគ្រិនភាព និងជំនាញគ្រប់គ្រងធុរកិច្ចទៅដល់សហគ្រិន ដែលគ្របដណ្តប់ពីដំណាក់កាលករកើតគំនិតធុរកិច្ចថ្មី ដំណាក់កាលបង្កើតថ្មីនិងដំណាក់កាលពន្លឿន ឬពង្រីកទីផ្សារ
- **កម្មវិធីជំរុញឌីជីថលូបនីយកម្ម និងបរិវត្តកម្មឌីជីថល** ជាកម្មវិធីដែលផ្តោតលើការជំរុញការចាប់យកដំណោះស្រាយនិងបំនិនឌីជីថលនានា ទៅក្នុងប្រតិបត្តិការក្នុងស្ថាប័ន ដើម្បីបង្កើនប្រសិទ្ធភាពប្រសិទ្ធិផល និងនវានុវត្តន៍
- **កម្មវិធីបណ្តុះបណ្តាលស្តីពីធុរកិច្ច ឌីជីថលដល់សហគ្រាសធុនតូចនិងមធ្យម** បានសហការជាមួយក្រសួងពាណិជ្ជកម្ម និងអង្គការ UNDP ក្នុងការបណ្តុះបណ្តាលដល់សហគ្រាសចំនួន ១៧១ ដើម្បីឱ្យសហគ្រាសមានមូលដ្ឋានក្នុងការចាប់យក ដំណោះស្រាយឌីជីថលដែលសមស្រប និងទទួលបានថវិកា ជំនួយដើម្បីធ្វើឌីជីថលូបនីយកម្ម
- **កម្មវិធីបណ្តុះបណ្តាលស្តីពី ការនាំមុខផ្នែកឌីជីថលូបនីយកម្មនិងបរិវត្តកម្មនៃសេដ្ឋកិច្ចកម្ពុជា** បានសហការជាមួយ សាកលវិទ្យាល័យអាម៉េរិកកាំងភ្នំពេញ(AUPP) និងសាកលវិទ្យាល័យស្ទែនហ្វដ(Stanford University) ដើម្បីបណ្តុះបណ្តាលដល់មន្ត្រីជាន់ខ្ពស់ចំនួន១០០នាក់ មកពីវិស័យសាធារណៈនិងឯកជន
- **កម្មវិធីអភិវឌ្ឍន៍ផលិតផលចំណីអាហារ** គឺជាកម្មវិធីដែលផ្តល់ការគាំទ្រទៅដល់សហគ្រាសចំណីអាហារក្នុងការពង្រឹងគុណភាពនិងការអភិវឌ្ឍផលិតផលសម្រាប់ដាក់លក់នៅក្នុងទីផ្សារ ស្របតាមស្តង់ដា សុវត្ថិភាពចំណីអាហារ តាមរយៈវេទិកាកិច្ចសហប្រតិបត្តិការរវាង វិស័យសាធារណៈវិស័យឯកជននិងគ្រឹះស្ថានស្រាវជ្រាវ
- **កម្មវិធីគាំទ្រវិស័យទេសចរណ៍** ជាកម្មវិធីដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលកើតមានក្នុងវិស័យទេសចរណ៍ដោយសារវិបត្តិជំងឺកូវីដ-១៩ ក្នុងគោលបំណងរកដំណោះស្រាយធុរកិច្ចក្នុង

បរិបទថ្មីនិងរក្សាទុកភ្ញាក់ងារទេសចរណ៍មួយចំនួនមិនឱ្យចាកចេញពីវិស័យទាំងស្រុង រួមមានកម្មវិធីទេសចរណ៍ខ្មែរសម័យថ្មី និងកម្មវិធីជំរុញចលនាទេសចរណ៍ផ្ទៃក្នុងនិងលើកកម្ពស់សកម្មភាពទេសចរណ៍ក្នុងសហគមន៍ទេសចរណ៍ក្នុងបរិបទវិបត្តិជំងឺកូវីដ-១៩

- **កម្មវិធីបណ្តុះបណ្តាលសហគ្រិនភាពតាមបណ្តាខេត្ត** ជាគំនិតផ្តួចផ្តើមរបស់សហគ្រិនខ្មែរក្នុងការពង្រីកវិសាលភាព កម្មវិធីបណ្តុះបណ្តាលសហគ្រិនភាពទៅដល់យុវជននិងសហគ្រិននៅតាមបណ្តាខេត្ត រួមមានកម្មវិធីសហគ្រិនក្នុងសហគមន៍កសិកម្ម កម្មវិធីអភិវឌ្ឍន៍សមត្ថភាពសម្រាប់សហគ្រិន កម្មវិធីសហគ្រិនសៀមរាបអ្នកស្វែងរកដំណោះស្រាយធុរកិច្ច និងកម្មវិធីសហគ្រិនបាត់ដំបងអ្នកចាប់ផ្តើម។

**គ- កម្មវិធីបណ្តាញនិងទំនាក់ទំនងធុរកិច្ច** បានរៀបចំឡើងក្នុងគោលបំណងផ្សារភ្ជាប់ភាគីពាក់ព័ន្ធក្នុងប្រព័ន្ធអេកូឡូស៊ី សហគ្រិនភាព ដើម្បីបង្កើនកិច្ចសហការ និងបង្កើតបរិយាកាស ឱ្យកាន់តែអំណោយផល ដល់ធុរកិច្ចថ្មី និងសហគ្រាសធុនតូចនិងមធ្យមក្នុងការទទួលបានឱកាសពង្រីកអាជីវកម្មបន្ថែម។ សកម្មភាពកន្លងមកបានផ្តោតលើការកសាងបណ្តាញទំនាក់ទំនងក្នុងស្រុកដែលបានធ្វើការជាមួយនឹងដៃគូស្ថាប័នសាធារណៈ អង្គការអនុវត្តគម្រោងសមាគមនិងក្លឹបវិនិយោគ ដើម្បីបង្កើតឱកាសទទួលបានការវិនិយោគ។ ការកសាងបណ្តាញទំនាក់ទំនងអន្តរជាតិ គឺដើម្បីផ្សព្វផ្សាយកម្មវិធីសហគ្រិនភាពក្នុងន័យកៀរគរនូវការវិនិយោគចូលក្នុងប្រទេសបន្ថែម។ សកម្មភាពបណ្តាញទំនាក់ទំនងក្នុងស្រុកនិងក្រៅស្រុកមានដូចជា៖

- **កម្មវិធីកសាងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព** គឺជាកម្មវិធីអនុវត្តមួយឆ្នាំពេញ ក្នុងគោលបំណងផ្សារភ្ជាប់ស្ថាប័នគាំទ្រសហគ្រិនភាព ដៃគូអភិវឌ្ឍ វិនិយោគិន ធុរកិច្ចថ្មីនិងសហគ្រាសធុនតូចនិងមធ្យមតាមរយៈកិច្ចប្រជុំប្រចាំខែ និងប្រចាំត្រីមាសដើម្បីកសាងទំនុកចិត្តតាមរយៈការចែករំលែកបទពិសោធន៍ក្នុងកិច្ចពិភាក្សា ដើម្បីជំរុញកិច្ចសហការប្រតិបត្តិការដែលមានស្រាប់ និងបង្កើតបន្ថែមនាពេលអនាគត ។
- **កម្មវិធីកិច្ចសហការជាមួយសហគមន៍អាជីវកម្មប្រចាំឆ្នាំ** មានគោលបំណងពង្រីកបណ្តាញទំនាក់-ទំនងជាមួយសហគ្រិនគោលដៅ អ្នកឯកទេសនៅតាមវិស័យការលើកកម្ពស់ការយល់ដឹងនិងចែករំលែកព័ត៌មានពាក់ព័ន្ធ។
- **កម្មវិធីតភ្ជាប់បណ្តាញធុរកិច្ចថ្មីទៅកាន់ទីផ្សារជាតិនិងអន្តរជាតិ** បានផ្តល់ឱកាសម្រាប់ធុរកិច្ចថ្មីក្នុងការធ្វើបទបង្ហាញ និងចូលរួមប្រកួតប្រជែងក្នុង និងក្រៅប្រទេស។
- **កម្មវិធីសហការជាមួយដៃគូក្នុងសហរដ្ឋអាម៉េរិក** គឺជាការសហការជាមួយក្រុមហ៊ុនវិនិយោគ ៥០០Global សម្រាប់បណ្តុះបណ្តាលសហគ្រិនតាមកម្មវិធីសិក្សាស្តង់ដារអន្តរជាតិក្នុងការពន្លឿនធុរកិច្ចថ្មីដោយប្រើប្រាស់បច្ចេកវិទ្យា។
- **កម្មវិធីសហការជាមួយដៃគូក្នុងតំបន់អាស៊ី** ប្រទេសកម្ពុជា៖ កិច្ចប្រជុំអាជីវកម្ម និងការវិនិយោគអាស៊ាន ដែលជាកិច្ចប្រជុំកំពូលពាណិជ្ជកម្ម និងការវិនិយោគ អាស៊ានដែលកម្ពុជាជាម្ចាស់ផ្ទះ។ ប្រទេសសិង្ហបុរី៖ ការបញ្ជូននិស្សិត និងសហគ្រិនចូលរួមក្នុងសន្និសិតអន្តរជាតិ ស្តីពីសហគ្រិនភាព និងវិនិយោគិន។ ប្រទេសកូរ៉េខាងត្បូង៖ ការប្រកួតប្រជែងគំរូអាជីវកម្ម សម្រាប់សហគ្រិនដែល

មានភាពច្នៃប្រឌិតទាក់ទងនឹងបរិស្ថាន។ ប្រទេសឥណ្ឌូនេស៊ីៈ កម្មវិធីផ្លាស់ប្តូរចំនេះដឹង ក្នុងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាពរវាងប្រទេសកម្ពុជា និងឥណ្ឌូនេស៊ីបានគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យកសិកម្ម និងកម្មន្តសាលចូលរួមពិភាក្សា និងផ្សាភ្ជាប់ទំនាក់ទំនងដើម្បីស្វែងរកឱកាសវិនិយោគ ។

- **កម្មវិធីសហការជាមួយដៃគូក្នុងតំបន់អឺរ៉ុប** ប្រទេសហូឡង់ៈ សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុកក្នុងវិស័យតុបតែងផ្ទះនិងវាយនភណ្ឌគេហដ្ឋានទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការបណ្តុះបណ្តាលដោយអ្នកជំនាញក្នុងការនាំផលិតផលកម្ពុជាទៅកាន់ទីផ្សារអឺរ៉ុប។ លើសពីនេះកម្មវិធីក៏បានបង្កើតឱកាសលក់តាមការផ្សព្វផ្សាយគំរូផលិតផល និងផ្តល់បណ្តាញទំនាក់ទំនងដល់សហគ្រិនតាមរយៈការចូលរួមតាំងពិព័រណ៍ពាណិជ្ជកម្មនៅអឺរ៉ុប។
- **កម្មវិធីសហការជាមួយដៃគូក្នុងទ្វីបអូសេអានី** ប្រទេសអូស្ត្រាលីៈ គម្រោងខ្សែសង្វាក់តំលៃកសិកម្មកម្ពុជា-អូស្ត្រាលី(CAVAC) ជាកិច្ចសហប្រតិបត្តិការណ៍ដៃគូរវាងវិស័យសាធារណៈ វិស័យឯកជននិងគ្រឹះស្ថានស្រាវជ្រាវ ដើម្បីកែច្នៃផលិតផលចំណីអាហារឱ្យស្របតាមស្តង់ដា ISO បង្កើនប្រាក់ចំនូលដល់ វិទ្យស្ថានស្រាវជ្រាវនិងមន្ទីពិសោធន៏តាមតម្រូវការធ្វើតេស្តផលិតផលពីវិស័យឯកជន។
- **កម្មវិធីសហការជាមួយដៃគូក្នុងតំបន់មជ្ឈិមបូព៌ាប្រទេសអ៊ីស្រាអែលៈ** កម្មវិធីផ្លាស់ប្តូរចំណេះដឹងក្នុងប្រព័ន្ធអេកូឡូស៊ី សហគ្រិនភាពប្រទេសកម្ពុជានិងអ៊ីស្រាអែលបានដឹកនាំធុរកិច្ចថ្មី និងសហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យបច្ចេកវិទ្យានិងកសិកម្មដែលមានសក្តានុពល ដើម្បីផ្លាស់ប្តូរចំណេះដឹងរវាងប្រទេសទាំងពីរក៏ដូចជាបង្កើតបណ្តាញទំនាក់ទំនងជាមួយនឹងក្រុមហ៊ុនវិនិយោគ។

**ឃ- កម្មវិធីទីផ្សារនិងវិនិយោគៈ** មានគោលបំណងបំពេញនូវកង្វះខាតផ្នែកហិរញ្ញប្បទាន ដែលធុរកិច្ចថ្មីនិងសហគ្រាសធុនតូចនិងមធ្យមជួបប្រទះ ដើម្បីពង្រីកអាជីវកម្ម។ កម្មវិធីទីផ្សារនិងវិនិយោគធ្វើការជាមួយភាគីពាក់ព័ន្ធនានារាប់ចាប់ពីគ្រឹះស្ថានហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារជំរុញការនាំចេញក្រៅប្រទេស សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងអាជ្ញាធរសាធារណៈ ដើម្បីបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទាន និងទីផ្សារ សម្រាប់សហគ្រិននិងធុរជន។ គោលដៅរបស់កម្មវិធីទីផ្សារ និងវិនិយោគ គឺជួយធុរកិច្ចថ្មី និងសហគ្រាសធុនតូចនិងមធ្យមទាំងនេះឱ្យទទួលបានជំនាញ ចំណេះដឹង និងថវិកាបន្ថែមដើម្បីអភិវឌ្ឍចំណែកទីផ្សាររបស់ខ្លួន។

- **កម្មវិធីកញ្ចប់ជំនួយថវិកាសហគ្រិនខ្មែរ** គឺដើម្បីឆ្លើយតបតាមអនុសាសន៍របស់ក្រុមប្រឹក្សាភិបាលកម្មវិធីទីផ្សារនិងវិនិយោគបានដាក់ដំណើរការកម្មវិធីកញ្ចប់ ជំនួយថវិកាទៅដល់ធុរកិច្ចបង្កើតថ្មី និងសហគ្រាសធុនតូចនិងមធ្យមដែលរងផលប៉ះពាល់ជាអវិជ្ជមានពីវិបត្តិជំងឺកូវីដ-១៩
- **កម្មវិធីកញ្ចប់ជំនួយថវិកាអភិវឌ្ឍន៍ទីផ្សារនាំចេញ** ផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់សហគ្រាសធុនតូចនិងមធ្យមដែលមានបំណងសិក្សាឬពង្រីកទីផ្សារនាំចេញរបស់ខ្លួន។ ថវិកាជំនួយនេះមានបំណងផ្តោតលើសហគ្រាសធុនតូចនិងមធ្យម ដែលត្រៀមលក្ខណៈនាំចេញរួចរាល់ឬមិនទាន់ត្រៀមលក្ខណៈនាំចេញហើយមានបំណងនាំផលិតផលទៅទីផ្សារអន្តរជាតិ
- **កម្មវិធីសហវិនិយោគក្នុងគម្រោងADB Frontier** មានគោលបំណងសំដៅទៅលើការកៀរគរថវិកាពីដៃគូពាក់ព័ន្ធនៅក្នុងប្រព័ន្ធអេកូឡូស៊ីសហគ្រិនភាព។ គម្រោងADB Frontierនឹងកៀរគរថវិកាពី

គម្រោងរបស់ដៃគូអភិវឌ្ឍផ្សេងៗនិងរដ្ឋាភិបាល ដែលជាដៃគូអភិវឌ្ឍយុទ្ធសាស្ត្រដូចជាប្រទេសអូស្ត្រាលី អង់គ្លេស ជប៉ុន និងកូរ៉េជាដើម

- **កម្មវិធីពិព័រណ៍ផលិតផលក្នុងស្រុក** គឺជាកម្មវិធីដើម្បីជំរុញការផ្សព្វផ្សាយផលិផលក្នុងស្រុកនៅផ្សារទំនើបអីអន(AEON) តាមរយៈការលើកកម្ពស់ការយល់ដឹងពីផលិតផលក្នុងស្រុក ដែលបច្ចុប្បន្នកំពុងដាក់លក់នៅផ្សារទំនើបអីអនម៉លភ្នំពេញ និងអីអនម៉លសែនសុខ ដែលក្នុងនោះមានដូចជាផ្លែឈើ បន្លែ ស៊ុត ទឹកដោះគោស្រស់ អង្ករនិងទំនិញប្រើប្រាស់ប្រចាំថ្ងៃក្នុងគ្រួសារផ្សេងៗទៀត
- **កម្មវិធីផ្សារភ្ជាប់អ្នកផលិតនិងទីផ្សារ** ជួយសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុកក្នុងវិស័យតុបតែងផ្ទះនិងវាយនភណ្ឌគេហដ្ឋានតភ្ជាប់ជាមួយទីផ្សារអឺរ៉ុបនិងពិភពលោក។ សហគ្រាសធុនតូចនិងមធ្យមបានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុ និងការបណ្តុះបណ្តាលក្នុងការអនុវត្តសកម្មភាពត្រៀមខ្លួនផ្នែកទីផ្សារ។

## ១.៩.៣- សាជីវកម្មធានាឥណទានកម្ពុជា(CGCC)

គោលបំណងនៃការបង្កើតសាជីវកម្មធានាឥណទានកម្ពុជា គឺដើម្បី (១) កាត់បន្ថយផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ ទៅលើអាជីវកម្ម និង(២) ជំរុញការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមក្នុងរយៈពេលវែង។ គោលដៅនៃការបង្កើតសាជីវកម្មធានាឥណទានកម្ពុជា គឺដើម្បីជួយអាជីវកម្មទទួលបានហិរញ្ញវត្ថុផ្លូវការ និងធានានិរន្តរភាពនៃប្រតិបត្តិការរបស់សាជីវកម្មធានាឥណទានកម្ពុជា ដែលត្រូវបានបែងចែកជា៣ ដូចជា (១) កំណើនឥណទានបន្ថែម (Credit additionality) (២) កំណើនសកម្មភាពសេដ្ឋកិច្ចបន្ថែម (Economic additionality) និង(៣) និរន្តរភាពនៃសាជីវកម្មធានាឥណទានកម្ពុជា (Self-sustainable)។

## ១.៩.៤- គោលនយោបាយសារពើពន្ធសម្រាប់ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម

### ១.៩.៤.១- ផ្នែកពន្ធដារ

សម្រាប់រយៈពេល៥ឆ្នាំ ពីឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២ អគ្គនាយកដ្ឋានពន្ធដារ (អ.ព.ដ.) បានរៀបចំច្បាប់និងបទប្បញ្ញត្តិទាក់ទិននឹងការលើកទឹកចិត្តផ្នែកពន្ធដារដល់សហគ្រាសធុនតូចនិងមធ្យម ដែលបានចុះបញ្ជីដោយស្ម័គ្រចិត្ត និងការលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់សហគ្រាសធុនតូចនិងមធ្យមក្នុងវិស័យអាទិភាព និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយយ៉ាងទូលំទូលាយទូទាំងប្រទេស ដែលមានសមិទ្ធផលការងារ សម្រេចបានដូចខាងក្រោម៖

- សិក្ខាសាលាជូនអ្នកជាប់ពន្ធ ស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យអាទិភាព ត្រូវបានរៀបចំឡើង៥៦លើក ដែលមានចូលរួម១៧ ៦២៦នាក់
- លិខិតបញ្ជាក់ការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះសហគ្រាសធុនតូចនិងសហគ្រាសធុនមធ្យម ដែលបានចុះបញ្ជីដោយស្ម័គ្រចិត្ត អ.ព.ដ. ទទួលបានស្នើសុំពីសហគ្រាសចំនួន១៤៦សហគ្រាស ក្នុងនោះបានលិខិតបញ្ជាក់ការលើកទឹកចិត្តដល់សហគ្រាសចំនួន៨៩សហគ្រាស
- វិញ្ញាបនបត្រលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់សហគ្រាសធុនតូចនិងមធ្យម ក្នុងវិស័យអាទិភាព អ.ព.ដ. ទទួលបានស្នើសុំពីសហគ្រាសចំនួន១០១សហគ្រាស ក្នុងនោះបានវិញ្ញាបនបត្រលើកទឹកចិត្តដល់សហ-គ្រាសចំនួន ៦៩សហគ្រាស។

### ១.៩.៤.២- ផ្នែកពន្ធគយ

ក្នុងរយៈពេល៥ឆ្នាំនេះ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា(អ.គ.រ.) បានចូលរួមយ៉ាងសកម្មក្នុងការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម តាមរយៈការរៀបចំគោលនយោបាយពន្ធអាករ និងយន្តការលើកទឹកចិត្តផ្នែកគយ ដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្ម និងបង្កើនលទ្ធភាពប្រកួតប្រជែងនៅទីផ្សារ។ ការងារដែលសម្រេចបានរួមមាន៖

- ក្នុងឆ្នាំ២០១៩ បានដាក់ពន្ធនិងអាករជាបន្ទុករបស់រដ្ឋលើការនាំចូលថាមពលអគ្គិសនី ធ្យូងថ្ម និងប្រេងខ្មៅ ដើម្បីចូលរួមកាត់បន្ថយថ្លៃផ្គត់ផ្គង់ថាមពលអគ្គិសនី
- ចាប់ពីចុងឆ្នាំ២០១៩មក បានអនុវត្តគោលនយោបាយលើកទឹកចិត្តផ្នែកគយសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដែលស្ថិតក្នុងវិស័យអាទិភាពចំនួន៨ ស្របតាមអនុក្រឹត្យលេខ៥០ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ និងប្រកាសលេខ៥៨០ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩។ រហូតមកដល់បច្ចុប្បន្ននេះ មានសហគ្រាសចំនួន១០ បានដាក់ពាក្យសុំការលើកទឹកចិត្ត ដែលមានតម្លៃនៃការនាំចូលប្រមាណ១១លានដុល្លារអាមេរិក ដែលក្នុងនោះមានសហគ្រាសចំនួន៦ ទទួលបានការលើកទឹកចិត្តនិងមានតម្លៃនៃការនាំចូលប្រមាណ២លានដុល្លារអាមេរិក
- ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២១ បានបញ្ចុះអត្រាពន្ធគយនិងអត្រាអាករពិសេសលើពូជដំណាំ បរិក្ខារកសិកម្ម សាកវប្បកម្ម រុក្ខកម្ម វត្ថុធាតុដើមផលិតចំណីអាហារនិងជាធាតុចូលផលិតកម្មគ្រឿងម៉ាស៊ីននិងគ្រឿងបន្លាស់បម្រើឱ្យវិស័យផលិតកម្ម និងកសិកម្ម
- ពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២២ បានដាក់ពន្ធនិងអាករជាបន្ទុករបស់រដ្ឋលើវត្ថុធាតុដើម និងសារធាតុបន្ថែមសម្រាប់ផលិតចំណីសត្វ ម៉ាស៊ីនបូមទឹកកសិកម្ម គ្រឿងបន្លាស់ត្រាក់ទ័រកសិកម្ម គ្រឿងបន្លាស់ម៉ាស៊ីនច្រូតស្រូវនិងគ្រឿងបន្លាស់គោយន្តកសិកម្ម។

## ១.៩.៥- ការជំរុញការអភិវឌ្ឍន៍ធុរកិច្ចថ្មី

មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី"តេជោ"(ម.ធ.ត.) បានក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាលយោងតាមអនុក្រឹត្យលេខ៩៦អនក្រ.បក ចុះថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០ ដែលមានក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាអាណាព្យាបាលបច្ចេកទេសនិងអាណាព្យាបាលហិរញ្ញវត្ថុ។ ម.ធ.ត. មានភារកិច្ចជាសេនាធិការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការសិក្សាស្រាវជ្រាវនានាទាក់ទងនឹងធុរកិច្ចថ្មី សេដ្ឋកិច្ចនវានុវត្តន៍ ផ្តល់ប្រឹក្សាលើគោលនយោបាយផែនការយុទ្ធសាស្ត្រលើការអភិវឌ្ឍន៍ធុរកិច្ចថ្មីនិងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មី។ ម.ធ.ត. ក៏មានតួនាទីយ៉ាងសំខាន់ជាបរធនបាលនៃបរធនបាលកិច្ចដើម្បីវិនិយោគនិងគាំទ្រធុរកិច្ចថ្មីសម្តៅផ្តល់ប្រយោជន៍ដល់ធុរជន អត្តគាហកៈនិងសាធារណជន ព្រមទាំងអភិវឌ្ឍនិងប្រតិបត្តិថ្នាលគ្រឹះនវានុវត្តន៍និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រនានាសម្រាប់ជាឃ្នាស់ចូលរួមសេដ្ឋកិច្ចឌីជីថលនិងពន្លឿនការបណ្តុះធុរកិច្ចថ្មី។

កន្លងមកនេះ ម.ធ.ត. បានសម្រេចនូវសមិទ្ធផលការងារគិតចាប់ពីពេលចាប់ផ្តើមប្រតិបត្តិការរហូតមកដល់ខែវិច្ឆិកា ឆ្នាំ២០២២ ដូចខាងក្រោម៖

### ១.៩.៥.១- ការងារពាក់ព័ន្ធវិស័យធុរកិច្ចថ្មី

- បានរៀបចំកម្មវិធីពន្លឿនអាជីវកម្មសរុបចំនួន៤កម្មវិធី រួមមាន៖
  - កម្មវិធីនវានុវត្តន៍បញ្ញាសរជូវកាលទី១(RI)

- o កម្មវិធីពន្លឿនអាជីវកម្មសហគ្រាសធុនតូច និងមធ្យម(DSA )
- o កម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថល(DPA)
- o កម្មវិធីនវានុវត្តន៍បញ្ញាសរដូវកាលទី២(RI2) រួមទាំងកម្មវិធី Hackathon ចំនួន៤។

- បានរៀបចំកម្មវិធីសហគមន៍ រួមមានៈ
  - o Spark Meet ចំនួន២០ដង
  - o Spark Hour ចំនួន១៩ដង
  - o Startup Journey ចំនួន១១ដង
  - o Startup Unboxing ចំនួន៥វគ្គ។
- បានដាក់ឱ្យដំណាក់ដំណើរការជាផ្លូវការនូវ Startup Cambodia Digital Platform ដំណាក់កាលទី២។

**១.៩.៥.២- ការងារស្រាវជ្រាវ**

- បានបញ្ចប់របាយការណ៍ស្រាវជ្រាវបច្ចេកទេស និងរបាយការណ៍ស្រាវជ្រាវសង្ខេបស្ដីពី "ទិដ្ឋភាពបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា"
- បានបញ្ចប់របាយការណ៍ស្រាវជ្រាវស្ដីពី "ប្រព័ន្ធអេកូឡូស៊ីធុរកិច្ចថ្មីផ្នែកបច្ចេកវិទ្យានៅកម្ពុជា"
- បានបញ្ចប់របាយការណ៍ស្រាវជ្រាវស្ដីពី "ឌីជីថលលូបនីយកម្មខ្សែច្រវ៉ាក់តម្លៃកសិកម្មនៅកម្ពុជា"
- បានបញ្ចប់ឯកសារទស្សនាទានស្ដីពី "ការចាប់យកបច្ចេកវិទ្យាឌីជីថលរបស់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា"
- បានបញ្ចប់សំណើអាជីវកម្មស្ដីពី "ថ្នាល Crowdfunding សម្រាប់ប្រទេសកម្ពុជា "
- បានបញ្ចប់គោលការណ៍ណែនាំស្ដីពី "ការចូលរួមក្នុងថ្នាល Crowdfunding"
- បានបញ្ចប់ការប្រមូលទិន្នន័យសម្រាប់ការស្រាវជ្រាវស្ដីពី "ការវាយតម្លៃតម្រូវការនៃការធ្វើឌីជីថលូបនីយកម្មសហគ្រាសក្នុងប្រទេសកម្ពុជា"
- បានរៀបចំសិក្ខាសាលា និងសេចក្ដីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា។

**១.៩.៥.៣- ការងារពាក់ព័ន្ធបច្ចេកវិទ្យា និងនវានុវត្តន៍**

- បានដាក់ឱ្យដំណើរការជាផ្លូវការនូវCamDigiKey2.0 និងបន្តគាំទ្រប្រតិបត្តិការជូនសាធារណជន
- បានបន្តគាំទ្រប្រតិបត្តិការថ្នាលផ្លាស់ប្ដូរទិន្នន័យCamDX ដែលមានប្រតិបត្តិការប្រមាណ១៣លានប្រតិបត្តិការ គិតចាប់ពីពេលដាក់ឱ្យដំណើរការរហូតមកដល់បច្ចុប្បន្ន ព្រមទាំងទទួលបានជ័យលាភីនៃពានរង្វាន់ការសម្របខ្លួនប្រើប្រាស់បច្ចេកវិទ្យាបើកចំហកូដប្រចាំឆ្នាំ២០២២(Open Source Adaptation of the Year 2022) ពីកម្មវិធីពានរង្វាន់អនាគតរដ្ឋាភិបាល(Future of Government Awards)
- បានរៀបចំ business.gov.kh
- បានដាក់ឱ្យដំណើរការជាផ្លូវការនូវថ្នាលឌីជីថលគន្លឹះCambodia Distributed Ledger (CamDL) នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២២
- បានដាក់ឱ្យដំណើរការAPI Semantic Search
- បានដាក់ឱ្យដំណើរការAPI OCR ។

## ១.១០- ការរៀបចំនិងអនុវត្តភាពជាដៃគូវិស័យសាធារណៈនិងវិស័យឯកជន

រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជននៃក.ស.ហ.វ. សម្រេចបានសមិទ្ធផលការងារ ដូចមានខាងក្រោម៖

- ការចូលរួមអនុវត្តឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០
- ការចូលរួមពិនិត្យច្បាប់ស្តីពីសម្បទាន និងបានរៀបចំកែសម្រួលច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បានរៀបចំគោលការណ៍ណែនាំ ដើម្បីគាំទ្រដល់ការអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន
- បានចូលរួមរៀបចំនិងអនុវត្តយុទ្ធសាស្ត្រ ស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ ២០១៩-២០២៥ និងចូលរួមរៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈ
- បានចូលរួមសហការជាមួយ Asian Development Bank(ADB) World Bank(WB) និងក្រុមការងារ Partnerships for Infrastructure(P4I) របស់រដ្ឋាភិបាលអូស្ត្រាលីក្នុងការរៀបចំការកសាងសមត្ថភាពស្ថាប័ននិងធនធានមនុស្សសម្រាប់យន្តការPPPនៅកម្ពុជា
- បានចូលរួមពិនិត្យនិងអនុវត្តគម្រោងតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងនោះរួម៖ ១.គម្រោងផ្លូវល្បឿនលឿនភ្នំពេញ ខេត្តព្រះសីហនុ ២.គម្រោងផ្លូវល្បឿនលឿនភ្នំពេញ បាវិត ៣.គម្រោងកស្តុភារកម្មក្រុងភ្នំពេញ ៤.គម្រោងកស្តុភារកម្មខេត្តព្រះសីហនុ ៥.គម្រោងអាកាសយានដ្ឋានខេត្តមណ្ឌលគិរី ៦.គម្រោងប្រព័ន្ធធារាសាស្ត្រព្រែកប្បាស ៧.គម្រោងE-buses ខេត្តសៀមរាប ៨.គម្រោងទឹកស្អាតខេត្តសៀមរាប ៩.គម្រោងកំពង់ផែទេសចរណ៍កំពត និង១០.គម្រោងសន្តិសុខនៅអាកាសយានដ្ឋាន
- ការរៀបចំនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងនោះរួមមាន៖
    - នីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជនភាគ១ ស្តីពីគោលនយោបាយនិងនីតិវិធី
    - នីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជនភាគ២ ស្តីពីគោលការណ៍ណែនាំ
    - នីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជនភាគ៣ ស្តីពីនីតិវិធីគ្រប់គ្រងលទ្ធកម្មគម្រោង។

## ១.១១- ការលើកស្ទួយកសិកម្មនិងការអភិវឌ្ឍជនបទ

ចាប់តាំងពីឆ្នាំ២០១៨ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានចូលរួមចំណែកយ៉ាងសកម្មក្នុងការជំរុញអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជា តាមរយៈផ្តល់កម្ចីឥណទានដល់សហគ្រាសធនតូចនិងមធ្យម សហគមន៍និងអាជីវកម្ម ដែលនៅក្នុងវិស័យកសិកម្ម ជាមួយនឹងអត្រាការប្រាក់ទាបដល់ម្ចាស់អាជីវកម្មនិងកសិករ។ លើសពីនេះ ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម បាននឹងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍក៏ដូចជា ការផ្តល់កម្ចីហិរញ្ញប្បទានសម្រាប់ដល់សហគ្រាសដែលបម្រើការក្នុងវិស័យកសិកម្មក្នុងកំលុងពេលឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ផងដែរ។ ក្នុងន័យនេះ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម សម្រេចបាននូវសមិទ្ធផលរួមមាន៖

១- **គម្រោងមូលនិធិសហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាលក្នុងពេលឆ្លងរីករាលដាល នៃជំងឺកូវីដ-១៩** ក្នុងរយៈពេលនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញគម្រោងសហហិរញ្ញប្បទានរវាងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងគ្រឹះស្ថានហិរញ្ញវត្ថុឯកជន ចំនួន២លើក ដែលលើកទី១ មានថវិកាសរុប**៧៣លានដុល្លារអាមេរិក** និងលើកទី២ មានថវិកាសរុប**៥០លានដុល្លារអាមេរិក**(សរុប**១២៣លានដុល្លារអាមេរិក**) ដែលមានគោលបំណងគាំទ្រដល់តួនាទីជាធនាគារគោលនយោបាយនាំមុខជំរុញដល់គ្រប់តួអង្គ ក្នុងខ្សែច្រវាក់ផលិតកម្មនិងកសិឧស្សាហកម្ម។ ក្នុងន័យនេះ មូលនិធិសហហិរញ្ញប្បទានត្រូវបានប្រើប្រាស់លើមុខសញ្ញាដូចជា៖ (១). ការផ្តល់ហិរញ្ញប្ប-ទានដល់វិស័យស្រូវអង្ករ (២). ការផ្តល់ហិរញ្ញប្បទានផ្ទាល់ និង(៣). សហហិរញ្ញប្បទានចែករំលែកហានិភ័យ។

២- **គម្រោងអភិវឌ្ឍន៍កសិកម្ម** (១) ជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច(AIMS) (២) គម្រោងការប្រកួតប្រជែងក្នុងខ្សែច្រវាក់តម្លៃកសិកម្មនិងការជំរុញសុវត្ថិភាពកសិកម្មឆ្នាំ២០២១-២០២៧ និង (៣) គម្រោងពិពិធកម្មកសិកម្មកម្ពុជា។

## ១.១២- ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម

### ១.១២.១- ការអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង

ក្រោមការដឹកនាំរបស់ ក.ស.ហ.វ., ផែនការមេដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូ ពហុបំណងនេះ គឺជាផែនការបែបយុទ្ធសាស្ត្រ ដែលមានចក្ខុវិស័យវែងឆ្ងាយ ច្បាស់លាស់ និងអាចអនុវត្តបាន ព្រមទាំងមានសង្គតិភាពជាមួយយុទ្ធសាស្ត្រថ្នាក់ជាតិនិងយុទ្ធសាស្ត្រអភិវឌ្ឍគន្លឹះនានា ដោយសំដៅប្រែក្លាយខេត្តព្រះសីហនុទៅជា (១) ទីក្រុងដ៏ល្បី និងសំខាន់មួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (២) តំបន់ដែលប្រើប្រាស់បច្ចេកវិទ្យាវៃឆ្លាត (Smart Technology) និងបំពាក់ដោយសេវាសាធារណៈ/បរិក្ខារសម្រាប់រស់នៅលំដាប់ពិភព-លោក (World Class Facility) (៣) តំបន់ប្រកបដោយបរិស្ថានបៃតង និងតំបន់ឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ ចូលរួមបម្រើឱ្យខ្សែច្រវាក់ផលិតកម្មក្នុងតំបន់ និងសកលលោក និង(៤) ប៉ូលសេដ្ឋកិច្ចដ៏សំខាន់ក្នុងការផ្តល់ការងារជូនដល់ប្រជាពលរដ្ឋ ប្រមូលចំណូលជូនរាជរដ្ឋាភិបាល និងអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាទាំងមូល ស្របតាមការកំណត់ក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា២០១៥-២០២៥។ ទន្ទឹមនេះ ផែនការមេនេះក៏នឹងគិតគូរពី (១) ការអភិវឌ្ឍធនធានមនុស្ស និងជំនាញដូចជារៀបចំបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្សដែលមានជំនាញវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ដើម្បីគាំទ្រវិស័យឧស្សាហកម្ម ដែលប្រើប្រាស់បច្ចេកវិទ្យាទំនើប (Technology) និងនវានុវត្តន៍ (២) ការបង្កើតតំបន់មជ្ឈមណ្ឌលហិរញ្ញវត្ថុ ខ្សែក្រវាត់បៃតងកសិកម្ម និងតំបន់លំនៅដ្ឋាន និង(៣) ការផ្គត់ផ្គង់សេវាសាធារណៈ។

### ១.១២.២- ការដោះស្រាយផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍

ក្នុងរយៈពេល៥ឆ្នាំកន្លង (ចន្លោះឆ្នាំ២០១៨ ដល់ ២០២២) អគ្គនាយដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានសម្រេចសមិទ្ធផលលើកិច្ចការដោះស្រាយផលប៉ះពាល់ និងការរៀបចំបទដ្ឋានគតិយុត្តរួមមាន៖

**កិច្ចការដោះស្រាយផលប៉ះពាល់**

គម្រោងដែលបានសម្រេចទាំងស្រុង មានចំនួន៣០គម្រោង រួមមាន(១) គម្រោងកែលម្អគ្រប់គ្រងបរិស្ថានក្រុងជុំវិញបឹងទន្លេសាបជំហាន១ (២) គម្រោងកែលម្អគ្រប់គ្រងបរិស្ថានក្រុងជុំបឹងទន្លេសាបជំហាន២ (៣) គម្រោងខ្សែច្រវាក់ផលិតកម្មប្រកបដោយភាតរៈបរិស្ថាន (៤) គម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យក្រុង (៥) គម្រោងគ្រប់គ្រង និងកាត់បន្ថយគ្រោះមហន្តរាយទឹកជំនន់ និងគ្រោះរាំងស្ងួតនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ (៦) គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងរបៀងភាគខាងត្បូង (៧) គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍សម្រាប់កំណើនប្រកបដោយបរិយាប័ន្ន ក្នុងមហាអនុតំបន់មេគង្គជំហានទី២ នៅខេត្តកែប (៨) គម្រោងកែលម្អវិស័យជាវាសាស្ត្រកសិកម្ម (៩) គម្រោងកម្មវិធីអភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្មស្រូវធន់អាកាសធាតុ (១០) គម្រោងមហាអនុតំបន់ទន្លេមេគង្គគម្រោងអភិវឌ្ឍន៍ក្រុងរបៀង២ (១១) គម្រោងលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ (១២) គម្រោងអភិវឌ្ឍន៍ទីប្រជុំជននៃទីរួមខេត្តត្បូងឃ្មុំ (១៣) គម្រោងសាងសង់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិម៉ឺនជ័យ (១៤) គម្រោងស្តារប្រឡាយទឹកស្អុយចំនួន៤ខ្សែ និងសាងសង់ស្ថានបេតុងព្រែកដើមលាប (១៥) គម្រោងសាងសង់ផ្លូវជាតិលេខ៥៥ (១៦) គម្រោងសាងសង់ផ្លូវជាតិលេខ១១ (១៧) គម្រោងអភិវឌ្ឍន៍ប្រព័ន្ធជាវាសាស្ត្រវ៉ៃកូជំហាន២ (១៨) គម្រោងសាងសង់ផ្លូវក្រវាត់ក្រុងទី២ (១៩) គម្រោងជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ (២០) គម្រោងអភិវឌ្ឍន៍ទំនប់ស្ទឹងពោធិ៍សាត់លេខ៣ និងលេខ៥ ជំហាន២ (២១) គម្រោងសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គស្ទឹងត្រង់ ក្រូចឆ្មា (២២) គម្រោងសាងសង់ស្ពានឆ្លងកាត់ស្ទឹងព្រែកត្នោត និងផ្លូវតភ្ជាប់ (២៣) គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវល្បឿនលឿនតភ្ជាប់ពីរាជធានីភ្នំពេញទៅខេត្តព្រះសីហនុ (២៤) គម្រោងការពារទឹកជំនន់ និងកែលម្អប្រព័ន្ធប្រឡាយ លូ ក្នុងរាជធានីភ្នំពេញជំហានទី៤ (២៥) គម្រោងអភិវឌ្ឍន៍ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ក្នុងរាជធានីភ្នំពេញ (២៦) គម្រោងសាងសង់ស្ពានឡើងវិញបន្ទាន់នៅតំបន់ប្រឈមនឹងទឹកជំនន់ (២៧) គម្រោងកែលម្អ និងស្តារឡើងវិញប្រព័ន្ធស្រោចស្រព និងប្រព័ន្ធដោះទឹកភាគនិរតីរាជធានីភ្នំពេញ (២៨) គម្រោងការស្តារឡើងវិញកំណាត់ផ្លូវជាតិលេខ៥ ផ្នែកខាងត្បូងផ្នែកខាងជើង ផ្នែកកណ្តាល និងផ្នែកចុងក្រោយ (ព្រែកក្តាម-ប៉ោយប៉ែត) (២៩) គម្រោងអភិវឌ្ឍន៍ទំនប់ទឹកដូនទ្រី និង(៣០) គម្រោងអភិវឌ្ឍន៍ទំនប់សាលាតាអន។

**គម្រោងដែលគ្រោងបញ្ចប់នាចុងឆ្នាំ២០២២ និងឆ្នាំ២០៣០** មាន៩គម្រោង រួមមាន (១) គម្រោងអភិវឌ្ឍន៍ទីប្រជុំជននៃទីរួមខេត្តត្បូងឃ្មុំ (២) គម្រោងរៀបចំច្រកទ្វារអន្តរជាតិស្ទឹងបត់ក្រុងប៉ោយប៉ែត (៣) គម្រោងសាងសង់ផ្លូវក្រវាត់ក្រុងទី៣ (៤) គម្រោងផ្លូវជាតិលេខ១០ (១៥៥១) (៥) គម្រោងអភិវឌ្ឍន៍អាងទឹករក្សា (៦) គម្រោងសាងសង់ផ្លូវជាតិលេខ៧១សេ (៧) គម្រោងសាងសង់ផ្លូវជាតិលេខ២និង២២ (៨) គម្រោងលើកកម្រិតគុណភាពផ្លូវជាតិលេខ៤៨ និង(៩) គម្រោងអភិវឌ្ឍន៍ប្រព័ន្ធជាវាសាស្ត្រ និងកាត់បន្ថយទឹកជំនន់ខេត្តបន្ទាយមានជ័យ។

**គម្រោងដែលកំពុងបន្តអនុវត្ត** មាន៤គម្រោង រួមមាន(១) គម្រោងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើទួលព្រេជ ស្រុកអង្គស្នួល (២) គម្រោងធ្វើឱ្យប្រសើរឡើងបណ្តាញផ្លូវថ្នល់ជំហាន២ (៣) គម្រោងអភិវឌ្ឍន៍ក្រុងរបៀង៤ នៃគម្រោងមហាអនុតំបន់ទន្លេមេគង្គ និង(៤) គម្រោងខ្សែច្រវាក់ផលិតកម្មប្រកបដោយភាតរៈបរិស្ថាន។

## ១.១៣- ការធានាចីរភាពបរិស្ថាន តាមរយៈការគ្រប់គ្រងសំរាមសំណល់រឹង

តាមរយៈក្របខ័ណ្ឌនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ក.ស.ហ.រ. បានចូលរួមក្នុងការរៀបចំនិងការដាក់ចេញគោលនយោបាយ

ជាច្រើន ដើម្បីជំរុញចីរភាពបរិស្ថាន ជាពិសេសតាមរយៈការរៀបចំប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ ជាក់ស្តែង ក.ស.ហ.វ. បានគាំទ្រឱ្យមានការបង្កើតប្រព័ន្ធប្រមូលសំរាម សំណល់រឹងទីប្រជុំជនថ្មីនៅរាជធានីភ្នំពេញ តាមរយៈការបង្កើតសហគ្រាសគ្រប់គ្រងសំរាម សំណល់រឹងរាជធានីភ្នំពេញ និងសហគ្រាសគ្រប់គ្រងស្ថានីយផ្ទេរ និងទីលានទុកដាក់សំរាម សំណល់រឹង ដែលនឹងដើរតួជាអាជ្ញាធរដើមខ្សែនិងចុងខ្សែ ដើម្បីធានាឱ្យការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនមានប្រសិទ្ធភាពខ្ពស់។ ជាមួយគ្នានេះ ក.ស.ហ.វ. ក៏នឹងជំរុញការប្រើប្រាស់យន្តការនេះ ជាគម្រូសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជននៅខេត្តដទៃទៀត ទូទាំងព្រះរាជាណាចក្រកម្ពុជា។ ក្រៅពីនេះ ក.ស.ហ.វ. បានចូលរួមក្នុងការដាក់ចេញគោលនយោបាយជាច្រើនទៀត ដូចជា៖ គោលនយោបាយគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ការគ្រប់គ្រងសំណល់ប្លាស្ទិក ការកែច្នៃសំរាម សំណល់រឹង និងការគិតគូរលើការគ្រប់គ្រងសំណល់សំណង់ និងសំណល់សរីរាង្គជាដើម។

### ២- ការអភិវឌ្ឍធនាគារ

ក្នុងរយៈពេល៥ឆ្នាំ កន្លងមកនេះ បើទោះបីជាប្រឈមនឹងវិបត្តិជំងឺកូវីដ-១៩ ធនាគារជាតិនៃកម្ពុជាសម្រេចបានសមិទ្ធផលសំខាន់ៗ ស្របតាមគោលដៅនិងបេសកកម្មក្នុងការរក្សាស្ថិរភាពថ្លៃ រក្សាស្ថិរភាពហិរញ្ញវត្ថុធ្វើទំនើបកម្មនិងអភិវឌ្ឍប្រព័ន្ធធនាគារ និងប្រព័ន្ធទូទាត់ សំដៅរួមចំណែកយ៉ាងសកម្មក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន និងដើម្បីកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល តាមរយៈការបន្តដឹកនាំនយោបាយរូបិយវត្ថុ នយោបាយម៉ាក្រូប្រុងប្រយ័ត្ន និងអភិវឌ្ឍប្រព័ន្ធទូទាត់នៅកម្ពុជា ប្រកបដោយភាពទន់ភ្លន់ និងបុរេសកម្ម។

### ២.១- ការរក្សាស្ថិរភាពថ្លៃ

អត្រាអតិផរណាត្រូវបានរក្សាឱ្យស្ថិតក្នុងកម្រិតទាប ស្របតាមក្របខ័ណ្ឌគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដែលបានអំណោយផលដល់ការលើកស្ទួយសកម្មភាពផលិតកម្មនិងពាណិជ្ជកម្ម ព្រមទាំងបានរួមចំណែកដ៏សំខាន់ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដោយក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ(២០១៨-២០២២) អត្រាអតិផរណាមានកម្រិតទាបជាមធ្យម៣,១%។ ដោយឡែក នៅក្នុងឆ្នាំ២០២២ នេះ ការកើនឡើងថ្លៃប្រេងនិងអាហារ ដោយសារការរាំងស្ទះខ្សែច្រវាក់ផ្គត់ផ្គង់សកល អាចនឹងជំរុញឱ្យអតិផរណាកើនឡើងដល់អត្រា៥,៣%។

### ២.២- ស្ថិរភាពអត្រាប្តូរប្រាក់

តម្លៃប្រាក់រៀលត្រូវបានរក្សាឱ្យមានស្ថិរភាពល្អប្រសើរ ដើម្បីការពារអំណាចទិញនៃប្រាក់រៀល ដែលនឹងរួមចំណែករក្សាស្ថិរភាពថ្លៃ។ អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាម៉េរិកមានកម្រិតជាមធ្យមត្រឹម៤ ០៧៩ រៀល ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ជាមួយនឹងការប្រែប្រួលតិចតួចទៅតាមកត្តារដូវកាល។ គួររំលេចផងដែរថា ប្រាក់រៀលបានរងសម្ពាធថយថ្លៃនៅក្នុងកំលុងនៃវិបត្តិកូវីដ-១៩ ដោយសារតម្រូវការប្រាក់រៀលបានថយចុះ ស្របតាមសកម្មភាពសេដ្ឋកិច្ចដែលបានរងផលប៉ះពាល់ គួបផ្សំនឹងលំហូរទុនបរទេសបានថមថយ និងចំណូលជាប្រាក់ដុល្លារអាម៉េរិកពីវិស័យទេសចរណ៍បានធ្លាក់ចុះគួរឱ្យកត់សម្គាល់។ ទោះយ៉ាងណា ជាមួយនឹងអន្តរាគមន៍របស់ធនាគារជាតិនៃកម្ពុជាដែលបានដាក់ចេញកន្លងមក សំដៅរក្សាស្ថិរភាពអត្រាប្តូរប្រាក់និងថ្លៃ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាម៉េរិកបន្តមានស្ថិរភាព ដោយបានប្រែប្រួលតិចជាង១%។

### ២.៣- ការគរពូនទុនបម្រុងអន្តរជាតិ

ការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បានផ្តល់បរិយាកាសអំណោយផលសម្រាប់ការវិនិយោគផ្ទាល់បរទេស ការពង្រីកអាជីវកម្មក្នុងស្រុក និងពាណិជ្ជកម្មឆ្លងដែនជាដើម។ ជាមួយនឹងការរក្សាបានកំណើនរឹងមាំនៃការនាំចេញ ទោះក្នុងគ្រាមានវិបត្តិ សមតុល្យជញ្ជីងទូទាត់កម្ពុជាបន្តរក្សាបានកំណើនអតិរេក និងបានរួមចំណែកគរពូនទុនបម្រុងអន្តរជាតិជាលំដាប់។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ទុនបម្រុងអន្តរជាតិបានកើនឡើងជាមធ្យមក្នុងអត្រា **៩,៣%** ក្នុងមួយឆ្នាំ ដោយបានកើនឡើងពីត្រឹម**១៤,៦ ប៊ីលានដុល្លារអាមេរិក** នៅចុងឆ្នាំ២០១៨ ដល់**១៧,៧ប៊ីលានដុល្លារអាមេរិក** គិតត្រឹមខែកញ្ញា ឆ្នាំ២០២២នេះ ដែលស្មើនឹងប្រមាណ៧ខែ នៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ខ្ពស់ជាងកម្រិតអប្បបរមាចំនួន៣ខែ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។ ការរក្សាបានកម្រិតខ្ពស់នៃទុនបម្រុងអន្តរជាតិបានបង្កើនជំនឿទុកចិត្តវិនិយោគិនមកលើសេដ្ឋកិច្ចកម្ពុជានិងបានអនុញ្ញាតឱ្យធនាគារជាតិនៃកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តនយោបាយអត្រាប្តូរប្រាក់ប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ២.៤- ការអភិវឌ្ឍប្រព័ន្ធធនាគារ

ប្រព័ន្ធធនាគារក៏បានទាក់ទាញវិនិយោគបរទេសចូលមកកម្ពុជាប្រមាណ**៦,២ប៊ីលានដុល្លារអាមេរិក** (សមាមាត្រនឹង២៣,២% នៃវិនិយោគបរទេសសរុបមកកម្ពុជា) កើនពីត្រឹម**១,៨ ប៊ីលានដុល្លារអាមេរិក**។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារមានកំណើន១៤,៣% ( រាល់ទិន្នន័យកំណើនជាកំណើនឆ្នាំលើឆ្នាំ) ដល់៣១០,៣ទ្រីលានរៀល(៧៥,៣ប៊ីលានដុល្លារអាមេរិក) ក្នុងនោះ ឥណទានទៅកាន់វិស័យឯកជនបានកើនឡើង២១,២% ដល់២១៨,៣ទ្រីលានរៀល(៥៣ប៊ីលានដុល្លារអាមេរិក)។ ទន្ទឹមនេះ ប្រាក់បញ្ញើរបស់អតិថិជនបានកើន១២,៧% ដល់១៧១,៧ទ្រីលានរៀល (៤១,៧ប៊ីលានដុល្លារអាមេរិក) និងដើមទុនមានកំណើន១៣,៦% ដល់៦០,៦ទ្រីលានរៀល(១៤,៧ប៊ីលានដុល្លារអាមេរិក)។ គណនីឥណទាន និងប្រាក់បញ្ញើបន្តកើនឡើងជាបន្តបន្ទាប់រហូតដល់៣,៦លានគណនីនិង១៤,៦លានគណនីរៀងគ្នា។ ទន្ទឹមនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏បានពង្រីក បណ្តាញប្រតិបត្តិការហិរញ្ញវត្ថុរហូតដល់ចំនួន២ ៦១០ទីតាំងនិងមានម៉ាស៊ីនដកនិងដាក់ប្រាក់ស្វ័យប្រវត្តិ(ATM) ចំនួន៤ ២៥០គ្រឿង ដើម្បីផ្តល់ភាពងាយស្រួលក្នុងការទទួលបាននិងប្រើប្រាស់សេវាហិរញ្ញវត្ថុកាន់តែទូលំទូលាយ។ ស្របគ្នានឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានធ្វើពិពិធកម្មសេវាហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីសម្រួលដល់ការប្រើប្រាស់សេវាហិរញ្ញវត្ថុរបស់អតិថិជនតាមរយៈការផ្តល់បណ្ណឥណពន្ធនិងបណ្ណឥណទាន ការផ្តល់សេវាផ្ទេរប្រាក់និងការទូទាត់សងប្រាក់តាមអេឡិចត្រូនិក ជាពិសេសប្រព័ន្ធទូទាត់សងប្រាក់ត្រូវបានធ្វើទំនើបកម្មឱ្យកាន់តែមានប្រសិទ្ធភាព សុវត្ថិភាពនិងតម្លៃសមរម្យ។

| ការអភិវឌ្ឍប្រព័ន្ធធនាគារ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ត្រីមាសទី៣ ២០២២ |
|---|---|---|---|---|---|
| កំណើនទ្រព្យសកម្ម | ២៣% | ២៣,១% | ១៤% | ១៧,២% | ១៤,៣% |
| កំណើនឥណទាន | ២៤,៤ | ២៥,៦% | ១៧% | ២២,៦% | ២១,២% |
| កំណើនប្រាក់បញ្ញើ | ២៨,៦% | ១៩% | ១៤,១% | ១៧,៧% | ១២,៧% |
| ទ្រព្យសកម្មធៀបផ.ស.ស | ១៧១% | ១៩២% | ២២៥% | ២២១,២% | ២៦១,៨% |
| ឥណទានធៀបផ.ស.ស | ១០៥% | ១១៩,៨% | ១៤៤,៥% | ១៧១% | ១៨៤% |
| ប្រាក់បញ្ញើធៀបផ.ស.ស | ១០១,៣% | ១០៨,១% | ១២៨,២% | ១៤៤,៥% | ១៤៤,៨% |

ប្រព័ន្ធធនាគារបានរួមចំណែកក្នុងការរក្សានិរន្តរភាពអាជីវកម្ម ពាណិជ្ជកម្ម តាមរយៈការរក្សានិរន្តរភាពក្នុងការផ្តល់ហិរញ្ញប្បទាន ដើម្បីកាត់បន្ថយផលប៉ះពាល់មកលើសេដ្ឋកិច្ច បន្ថយសម្ពាធអតិផរណានិងពង្រឹងស្ថិរភាពប្រព័ន្ធធនាគារ សំដៅស្តារនិងជំរុញកំណើនសេដ្ឋកិច្ច។ អនុវត្តតាមវិធានការគាំទ្ររបស់ធនាគារជាតិនៃកម្ពុជាក្នុងការជួយសម្រាលបន្ទុកប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបាន រៀបចំឥណទានឡើងវិញ ចំនួន១៩២ ៦៨៨គណនី ស្មើនឹង១៤,២ទ្រីលានរៀល (ស្មើ៣,៥ប៊ីលានដុល្លារអាមេរិក)។ ក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ច នយោបាយរូបិយវត្ថុវិគ្គារកម្មត្រូវបានបន្តអនុវត្ត តាមរយៈការកាត់បន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ចទាំងជាប្រាក់រៀលនិងដុល្លារអាមេរិក ដើម្បីបង្កើនសន្ទនីយភាពនៅក្នុងប្រព័ន្ធធនាគារ និងបានផ្តល់លទ្ធភាពដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្នុងការបែងចែកឥណទានដល់វិស័យអាទិភាព ការកាត់បន្ថយសម្ពាធលើអត្រាការប្រាក់ឥណទាន និងការរៀបចំឥណទានឡើងវិញសម្រាប់អតិថិជនដែលរងផលប៉ះពាល់ពីវិបត្តិ។ ក្រៅពីនេះ ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់បានរួមចំណែកសម្រួលដល់សកម្មភាពអាជីវកម្ម ពាណិជ្ជកម្មនិងការវិនិយោគ ស្របតាមចក្ខុវិស័យក្នុងការកសាងសេដ្ឋកិច្ចឌីជីថលដ៏រឹងមាំមួយ។

### ២.៥- លើកកម្ពស់បរិយាបន្ននិងចំណេះដឹងហិរញ្ញវត្ថុ

ទន្ទឹមនឹងការរីកចម្រើននៃប្រព័ន្ធធនាគារកម្ពុជា ផែនការនៃការត្រួតពិនិត្យផ្អែកលើហានិភ័យនិងទស្សនៈអនាគតក៏កំពុងត្រូវបានអនុវត្ត ដែលក្នុងនោះបានរៀបចំកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជាឡើងវិញ ដើម្បីលើកកម្ពស់ការងារត្រួតពិនិត្យឱ្យកាន់តែមានប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ ការកើនឡើងនៃការប្រើប្រាស់និងការបញ្ចូលព័ត៌មានឥណទានរបស់ឯកត្តជននិងក្រុមហ៊ុនទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន បានឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងហានិភ័យ ជាពិសេសការវិភាគគុណភាពឥណទានកាន់តែប្រសើរឡើង។ បន្ទាប់ពីយុទ្ធសាស្ត្រជាតិ ស្តីពីបរិយាបន្នហិរញ្ញវត្ថុ ឆ្នាំ២០១៩-២០២៥ ត្រូវបានអនុម័ត ផែនការសកម្មភាពនិងគំនិតផ្តួចផ្តើមផ្សេងៗនៃយុទ្ធសាស្ត្រនេះកំពុងត្រូវបានអនុវត្តក្រោមកិច្ចសហការជាមួយភាគីជាដៃគូពាក់ព័ន្ធនានា។ ទន្ទឹមនេះ ការផ្សព្វផ្សាយយុទ្ធនាការបញ្ជ្រាបចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជួយដោះស្រាយចម្ងល់និងបញ្ហាពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុ ក៏កំពុងត្រូវបានបន្តអនុវត្តនិងលើកកម្ពស់ជាប់ជាលំដាប់ តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា" និងបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការដាក់បញ្ចូលចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាទូទៅពីថ្នាក់ទី១-១២ និងបានសហការជាមួយក្រសួងកិច្ចការនារីក្នុងការរៀបចំសិក្ខាសាលា ស្តីពី "ការលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ស្ត្រី និងសហគ្រិនភាពស្ត្រី"។ ជាមួយគ្នានេះ អនុស្សរណៈនៃការយោគយល់ជាមួយអង្គការGood Return ត្រូវបានចុះហត្ថលេខា ដើម្បីបន្តកិច្ចសហប្រតិបត្តិការក៏ដូចជាអនុវត្តគម្រោងយុទ្ធនាការប្រើប្រាស់លុយដោយឆ្លាតវៃដែលមានឈ្មោះថាយុទ្ធនាការ "តោះ! និយាយពីលុយៈ តក់ៗពេញបំពង់" បន្តពីយុទ្ធនាការ "តោះ! និយាយពីលុយ" ដែលកំពុងអនុវត្តស្រាប់។

### ២.៦- ការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់

ការរាលដាលជំងឺកូវីដ-១៩ បានជះឥទ្ធិពលដល់ការអភិវឌ្ឍសេដ្ឋកិច្ចទូទាំងពិភពលោក រួមទាំងកម្ពុជា។ ក្នុងស្ថានភាពនេះ ប្រព័ន្ធធនាគារកម្ពុជាបានចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចឱ្យប្រែក្លាយទៅជាសេដ្ឋកិច្ចឌីជីថលតាមរយៈការទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យាថ្មីៗ ដែលមានការវិវត្តយ៉ាងឆាប់រហ័ស សម្រាប់កសាងហេដ្ឋា-

រចនាសម្ព័ន្ធជាតិដែលមានប្រសិទ្ធភាព សុវត្ថិភាព និងរួមចំណែកទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩។ ស្របពេលជាមួយគ្នានេះ ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ ត្រូវបានដាក់ឱ្យប្រើប្រាស់និងកំពុងបន្តអភិវឌ្ឍបន្ថែមទៀត សំដៅសម្រួលដល់ការប្រើប្រាស់ប្រព័ន្ធទូទាត់របស់សាធារណជន ស្របតាមគោលនយោបាយបក្សនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ជាក់ស្តែង ប្រព័ន្ធទូទាត់សងប្រាក់មួយចំនួន ត្រូវបានដាក់ឱ្យដំណើរការរួមមាន៖ ១- ប្រព័ន្ធផាត់ទាត់ជាតិ ២- ប្រព័ន្ធសេវាទូទាត់រហ័ស ៣- ប្រព័ន្ធធនាគារអនឡាញ ៤- ប្រព័ន្ធខេមបូឌានស៊ែស្វីច(CSS) ៥- ប្រព័ន្ធបាគង និង៦- ប្រព័ន្ធរីធលផេ ដែលអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចធ្វើប្រតិបត្តិការឆ្លងគ្រឹះស្ថានបាន។ ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យា ព្រមទាំងបំពេញតម្រូវការនៃការប្រើប្រាស់របស់សាធារណជនប្រព័ន្ធបាគង ក៏ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការកាលពីខែតុលា ឆ្នាំ២០២០ ដែលជាប្រព័ន្ធទូទាត់កន្លោងអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធ្វើប្រតិបត្តិការទូទាត់តាមយ្យូអរកូត និងផ្ទេរប្រាក់ឆ្លងគ្រឹះស្ថានទៅវិញទៅមក(Interoperability) ប្រកបដោយប្រសិទ្ធភាពនិងសុវត្ថិភាព។ ស្ថិតក្នុងបរិបទនៃការរាលដាលជំងឺកូវីដ-១៩ នេះ ការទូទាត់អេឡិចត្រូនិកតាមប្រព័ន្ធបាគងបានរួមចំណែករក្សាគម្លាតសង្គម តាមរយៈការទូទាត់អេឡិចត្រូនិកពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់(P2P) ដោយពុំប៉ះពាល់សាច់ប្រាក់ដោយផ្ទាល់។ ទន្ទឹមនេះ ប្រព័ន្ធសេវាទូទាត់រហ័ស និងប្រព័ន្ធផាត់ទាត់ជាតិក៏ត្រូវបានធ្វើបច្ចុប្បន្នកម្មឱ្យមានលក្ខណៈទំនើបជាងមុន និងរួមបញ្ចូលមុខងារថ្មីៗស្របតាមការរីកចម្រើននៃបច្ចេកវិទ្យានិងបង្កើនសុវត្ថិភាពក្នុងការប្រើប្រាស់។

ក្នុងគោលបំណងរក្សាបានសង្គតិភាព និងពង្រឹងសុវត្ថិភាពនៃការធ្វើប្រតិបត្តិការទូទាត់ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និងតម្រូវការទីផ្សារលើសេវានិងឧបករណ៍ទូទាត់ថ្មីៗ គំរូបរិច្ឆិនភាពបច្ចេកទេសខេអេចយ្យូអរកូតសម្រាប់ការទូទាត់សងប្រាក់និងការប្រើប្រាស់ស្តង់ដាEMV CHIP សម្រាប់បណ្ណទូទាត់ឥណពន្ធត្រូវបានដាក់ឱ្យប្រើប្រាស់ជាបន្តបន្ទាប់។ ចំពោះក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ ប្រកាសស្តីពីការគ្រប់គ្រងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីធានាបាននូវស្ថិរភាពនិងនិរន្តរភាពនៃដំណើរការប្រព័ន្ធកាត់បន្ថយហានិភ័យជាប្រព័ន្ធការពារផលប្រយោជន៍អតិថិជន លើកកម្ពស់ការប្រកួតប្រជែងប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនិងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ ចំណែកឯការត្រួតពិនិត្យលើគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ក៏ត្រូវបានអនុវត្តតាមរយៈការត្រួតពិនិត្យលើឯកសារ និងការត្រួតពិនិត្យដល់ទីកន្លែងដោយយកចិត្តទុកដាក់លើការអនុវត្តតាមបទប្បញ្ញត្តិជាធរមាន ជាពិសេសការវាយតម្លៃផ្អែកលើបទប្បញ្ញត្តិប្រុងប្រយ័ត្ន។ គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០២២ គ្រឹះស្ថានដែលទទួលបានអាជ្ញាប័ណ្ណផ្តល់សេវាទូទាត់សងប្រាក់មានសរុបចំនួន៣៤គ្រឹះស្ថាននិងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសរុបចំនួន២ ទទួលបានលិខិតអនុញ្ញាតធ្វើប្រតិបត្តិការទូទាត់សងប្រាក់ពីធនាគារជាតិនៃកម្ពុជា ព្រមទាំងភ្នាក់ងារសរុបមានចំនួន៥៩,៤៣៣ទីតាំង។ បន្ថែមពីនេះ ការទូទាត់តាមរយៈប្រព័ន្ធទូទាត់របស់ធនាគារជាតិនៃកម្ពុជា បានកើនដល់១៩,៩លានប្រតិបត្តិការជាមួយនឹងទំហំប្រាក់សរុប១០៩,២ប៊ីលានដុល្លារអាម៉េរិក ស្មើនឹងប្រមាណ៤ដងនៃផលិតផលក្នុងស្រុកសរុប។ ទន្ទឹមនេះ ប្រតិបត្តិការទូទាត់ធ្វើឡើង តាមរយៈមធ្យោបាយអេឡិចត្រូនិកដែលដាក់ឱ្យដំណើរការដោយគ្រឹះស្ថានធនាគារពាណិជ្ជ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ រួមមានប័ណ្ណទូទាត់ សេវាធនាគារអ៊ីនធើណិត សេវាធនាគារចល័ត សេវាទូទាត់ចល័តនិងការទូទាត់តាមយ្យូអរកូតក៏មានការកើនឡើងជាលំដាប់ដល់៥៨,៤លានប្រតិបត្តិការ ស្មើនឹង ២០២,៤៤ប៊ីលានដុល្លារអាម៉េរិក។ ការទូទាត់ឌីជីថលរំពឹងថាមាននិន្នាការកើនឡើងជាបន្តបន្ទាប់ដែលនឹងរួមចំណែកមួយភាគធំក្នុងការសម្រួលការទូទាត់ក្នុងសេដ្ឋកិច្ច ជាពិសេសមុននិងក្រោយពេលនៃការរីករាលដាលជំងឺកូវីដ-១៩

និងការបើកដំណើរការសេដ្ឋកិច្ចឡើងវិញ។ លើសពីនេះ ធនាគារជាតិនៃកម្ពុជាក៏បាននិងកំពុងផ្តួចផ្តើមភ្ជាប់ការទូទាត់ឆ្លងដែនជាមួយប្រទេសក្នុងតំបន់ ជាពិសេសតំបន់អាស៊ានដែលរួមមានការភ្ជាប់ការទូទាត់តាមរយៈឃ្យូអរកូដជាមួយប្រទេសថៃនិងការតភ្ជាប់ប្រព័ន្ធបាគងជាមួយធនាគារមេយប៊ែង ដើម្បីសម្រួលការផ្ទេរប្រាក់រវាងប្រទេសកម្ពុជានិងម៉ាឡេស៊ី។

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(៣) |
|---|---|---|---|---|---|
| អតិផរណា | ២,៥ | ១,៩ | ២,៩ | ២,៩ | ៥,៣ |
| អត្រាប្តូរប្រាក់រៀល/ដុល្លារអាមេរិក | ៤ ០៥១ | ៤ ០៦១ | ៤ ០៩៣ | ៤ ០៩៩ | ៤ ១០៣ |
| ធនាគារជាតិនៃកម្ពុជា | ១ | ១ | ១ | ១ | ១ |
| សាខាធនាគារជាតិនៃកម្ពុជា | ២១ | ២១ | ២១ | ២១ | ២១ |
| ធនាគារពាណិជ្ជ | ៤៣ | ៤៧ | ៥១ | ៥៣ | ៥៧ |
| សាខាធនាគារពាណិជ្ជបរទេស | ១៣ | ១៣ | ១២ | ១២ | ១២ |
| បុត្តសម្ព័ន្ធធនាគារបរទេស | ១៧ | ១៧ | ១៨ | ១៨ | ១៨ |
| ធនាគារពាណិជ្ជក្នុងស្រុក | ១៣ | ១៧ | ២១ | ២៣ | ២៨ |
| សាខាធនាគារពាណិជ្ជរាជធានី ខេត្ត | ៨៧៦ | ៩៤១ | ១ ២៨៩ | ១ ៣១៨ | ១ ៤៧០ |
| ការិយាល័យតំណាងធនាគារបរទេស | ៥ | ៦ | ៦ | ៦ | ៦ |
| ធនាគារឯកទេស | ១៤ | ១៥ | ១២ | ១០ | ៩ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ | ៧ | ៧ | ៦ | ៦ | ៥ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | ៧៤ | ៧៦ | ៧៥ | ៧៩ | ៨០ |
| ប្រតិបត្តិការឥណទានជនបទ | ២៧៣ | ២៤៥ | ២៤៥ | ២៣៤ | ២៣១ |
| ក្រុមហ៊ុនភតិសន្យា | ១៥ | ១៥ | ១៥ | ១៧ | ១៧ |








ពិធីត្រួតពិនិត្យវឌ្ឍនភាពគម្រោងសាងសង់អាកាសយានដ្ឋានអន្តរជាតិ
សៀមរាប អង្គរ កាលពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២






**ពិធីបិទសន្និបាតបូកសរុបការងារទេសចរណ៍ ការបូកសរុបផែនការស្តារ និងលើកស្ទួយវិស័យទេសចរណ៍កម្ពុជាក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ ដំណាក់កាលទី១ (២០២០-២០២១) និងឆមាសទី១ ឆ្នាំ២០២២ និងលើកទិសដៅផែនការស្តារឡើងវិញនូវវិស័យទេសចរណ៍ក្នុងដំណាក់កាលទី២ (ឆមាសទី២ ឆ្នាំ២០២២-២០២៣) កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២**





សកម្មភាពដឹកជញ្ជូននៅកំពង់ផែស្វយ័តភ្នំពេញ
រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១








# សកម្មភាពដឹកជញ្ជូននៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ
# ខេត្តព្រះសីហនុ ឆ្នាំ២០១៨






**ពិធីប្រកាសដាក់អនុវត្តជាផ្លូវការក្របខណ្ឌគោលនយោបាយជាតិផលិតភាព សេដ្ឋកិច្ចកម្ពុជា ២០២២-២០៣៥ នៅសណ្ឋាគារសូហ្វីតែល រាជធានីភ្នំពេញ កាលពីថ្ងៃទី៣ ខែវិច្ឆិកា ២០២២**









**ប្រព័ន្ធធនាគារកម្ពុជា បានចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចឱ្យប្រែក្លាយទៅ ជាសេដ្ឋកិច្ចឌីជីថល តាមរយៈការបន្តអភិវឌ្ឍនិងធ្វើទំនើបកម្មប្រព័ន្ធទូទាត់ ជាបន្តបន្ទាប់ ដោយបានទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ**









ពិធីសម្ពោធជានិមិត្តរូប ដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវល្បឿនលឿន
ភ្នំពេញ-ក្រុងព្រះសីហនុ នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី
កាលពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២២







**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
**ក្នុងពិធីបើកបុណ្យសមុទ្រលើកទី៩ ជុំទី៣ នៅក្នុងខេត្តព្រះសីហនុ**
**កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២**









**វារីអគ្គិសនីសេសានក្រោម២ ខេត្តស្ទឹងត្រែង ៤០០មេហ្គាវ៉ាត់**
**កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨**







ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ផ្លូវលេខ១៤៦បេ តភ្ជាប់ទៅផ្លូវលេខ១៤៨
នៅខេត្តព្រះសីហនុ កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២







ពិធីបើកការដ្ឋានសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គពីស្រុកចិត្របុរី
ទៅស្រុកព្រែកប្រសព្វប្រវែង ១ ៧៦១ម. និងផ្លូវតភ្ជាប់ប្រវែង ៣១,៦៩គ.ម
នៅខេត្តក្រចេះ កាលពីថ្ងៃទី២ ខែមករា ឆ្នាំ២០២៣

# យុទ្ធសាស្ត្រចតុកោណទី៣
# ការអភិវឌ្ឍវិស័យឯកជននិងការងារ

ក្រោមការដឹកនាំដ៏ប៉ិនប្រសប់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបំពេញតួនាទី ភារកិច្ចលើការដឹកនាំនិងគ្រប់គ្រងវិស័យការងារ វិស័យសន្តិសុខសង្គម និងវិស័យបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ព្រមទាំងមានចក្ខុវិស័យលើកកម្ពស់ជីវភាពរស់នៅ សេចក្តីថ្លៃថ្នូរ និងការគាំពារចំពោះកម្មករនិយោជិតនិងទេសន្តរប្រវេសន៍ខ្មែរ ពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងនីតិរដ្ឋស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ ដោយគិតពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ ក្រសួងបានសម្រេចនូវលទ្ធផលការងារសំខាន់ៗ ដូចខាងក្រោម៖

## មុំទី១- ការអភិវឌ្ឍទីផ្សារការងារ

### ១- ការអភិវឌ្ឍលក្ខខណ្ឌការងារនិងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ

(គេហទំព័ររបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ www.mlvt.gov.kh)

- បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០១៩-២០២៣ ដោយផ្តោតលើអាទិភាពចំនួន៥ សំដៅអនុវត្តឱ្យសម្រេចជោគជ័យនូវគោលដៅអាទិភាព ដែលកំណត់ដោយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤និងគោលនយោបាយពាក់ព័ន្ធ ដូចជាគោលនយោបាយជាតិស្តីពីមុខរបរនិងការងារឆ្នាំ២០១៥-២០២៥ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥ កម្មវិធីការងារសមរម្យរបស់អង្គការអន្តរជាតិខាងការងារឆ្នាំ២០១៩-២០២៣ គោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣ និងផែនការជាតិប្រឆាំងការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារឆ្នាំ២០១៦-២០២៥ជាដើម
- បានធ្វើសមាហរណកម្មនិងទំនើបកម្មការធ្វើអធិការកិច្ចការងារផ្ទៃក្នុងនិងអធិការកិច្ចអន្តរស្ថាប័ន សំដៅលើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែល្អប្រសើរឡើង និងកាត់បន្ថយការរំខានដល់ប្រតិបត្តិការអាជីវកម្ម ដោយបន្តពង្រឹងយន្តការក្រុមអធិការកិច្ចការងារតែមួយ សំដៅកាត់បន្ថយបន្ទុករបស់ម្ចាស់រោងចក្រ សហគ្រាស និងធានាប្រសិទ្ធភាពនិងអនុលោមភាពតាមច្បាប់ និងចុះអធិការកិច្ចការងារដោយផ្តោតលើចំណាត់ថ្នាក់នៃកម្រិតហានិភ័យរបស់រោងចក្រ សហគ្រាសនីមួយៗ។ ជាក់ស្តែង ក្រសួងបានចុះអធិការកិច្ចការងារសរុបចំនួន២០ ៦៤២លើក ដែលគិតជាមធ្យមចំនួន៤ ១២៨លើក ក្នុងមួយឆ្នាំ ដោយពិនិត្យឃើញថា អត្រាអនុលោមភាពរបស់រោងចក្រ សហគ្រាសបានអនុវត្តតាមច្បាប់ស្តីពីការងារនិងលិខិតបទដ្ឋានពាក់ព័ន្ធ មានអត្រាខ្ពស់ជាមធ្យមប្រមាណ៨៨%។ បន្ថែមលើនេះទៀត ក្រសួងបានដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារ និងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីគ្រប់គ្រងទិន្នន័យអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីពង្រឹងប្រសិទ្ធភាពនៃអធិការកិច្ចការងារ និងបានធ្វើសមាហរណកម្មអធិការកិច្ចអន្តរស្ថាប័នក្នុងវិស័យកម្មន្តសាល ឧស្សាហកម្ម ទេសចរណ៍ និងវិស័យកសិកម្ម។ ក្រសួងបានដាក់ឱ្យដំណើរការវិទ្យាស្ថានជាតិការងារនៅឆ្នាំ២០១៩ ដើម្បី

បណ្តុះបណ្តាលបុគ្គលិករដ្ឋបាលរោងចក្រ សហគ្រាស ថ្នាក់ដឹកនាំសហជីព និងសាធារណជន មន្ត្រីអធិការកិច្ចពេទ្យការងារ និងមន្ត្រីទទួលបន្ទុកដោះស្រាយវិវាទការងារ ព្រមទាំងអភិវឌ្ឍសមត្ថភាពអធិការការងារ ដោយបានធ្វើការបណ្តុះបណ្តាលចំនួន១៩វគ្គ មានមន្ត្រីចូលរួមសរុប២ ៥៩៨នាក់។ ជាមួយនេះ ក្រសួងបានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្តុះបណ្តាលនិងទស្សនកិច្ចសិក្សាទាំងក្នុងនិងក្រៅប្រទេសសរុបចំនួន១៥ ៥៦៤នាក់ (ស្រី ៣ ៥២១នាក់) ក្នុងនោះបណ្តុះបណ្តាលក្នុងប្រទេសចំនួន១៤ ២៥៦នាក់(ស្រី ៣ ២៤៦នាក់) ជាពិសេសបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាល១៨៩នាក់(ស្រី៤២នាក់) និងបណ្តុះបណ្តាលក្រៅប្រទេស១ ១១៩នាក់ (ស្រី ២៣៣នាក់)

- បានពង្រឹងការលើកកម្ពស់លក្ខខណ្ឌសុវត្ថិភាពនិងសុខភាពការងារ ដោយពង្រឹងប្រសិទ្ធភាពនៃការចុះអធិការកិច្ចសុវត្ថិភាពនិងសុខភាពការងារ ដោយបានពិនិត្យឃើញថា រោងចក្រ សហគ្រាសជាមធ្យមប្រមាណ ៨៥,៥២% មានសេវាសង្គ្រោះអប្បបរមា និងបានដាក់ឱ្យអនុវត្តផែនការមេលើកទី២ស្តីពីសុវត្ថិភាពនិងសុខភាពការងារ ឆ្នាំ២០១៨-២០២២ កម្រងព័ត៌មានជាតិលើកទី២ស្តីពីសុវត្ថិភាពនិងសុខភាពការងារ កម្រងព័ត៌មានជាតិលើកទី២ ស្តីពីសារជាតុអាសបេស្តូស និងគោលការណ៍ណែនាំស្តីពីសុវត្ថិភាពសារជាតុគីមីនៅកន្លែងធ្វើការនៅឆ្នាំ២០២២ និងបានកំពុងរៀបចំគោលនយោបាយជាតិស្តីពីសុវត្ថិភាពនិងសុខភាពការងារ និងបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលសុវត្ថិភាពនិងសុខភាពការងារ។ ព្រមជាមួយនេះ ក្រសួងបានអនុវត្តគោលការណ៍ប្រតិបត្តិស្តង់ដាក្នុងបរិបទនៃជំងឺកូវីដ-១៩ ដោយបានពង្រឹងការអនុវត្តនិងដាក់ចេញនូវវិធានការសុវត្ថិភាពនិងសុខភាពការងារបន្ថែមក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ-១៩ សំដៅលើកកម្ពស់ការបង្ការ ទប់ស្កាត់ កាត់បន្ថយ គ្រប់គ្រង និងដោះស្រាយបានទាន់ពេលវេលានូវការឆ្លងរាលដាលជំងឺកូវីដ-១៩ នៅតាមរោងចក្រ សហគ្រាស និងក្នុងចំណោមកម្មករនិយោជិត ដើម្បីគ្រប់គ្រងផលប៉ះពាល់ជាអវិជ្ជមានលើសុខភាពការងារ និងដំណើរការអាជីវកម្ម/ផលិតកម្ម

- បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការងារដោយបង្ខំ ដោយបានធ្វើអធិការកិច្ចការងារកុមារនៅវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិឧស្សាហកម្មចំនួន៥៥២លើក និងបានចុះអធិការកិច្ចការងារនៅតាមរោងចក្រ សហគ្រាស ដែលបានស្នើសុំប្រើប្រាស់កម្មករនិយោជិតវ័យក្មេងចំនួន៤៣លើក ព្រមទាំងបានដាក់កំហិតលើ រោងចក្រ សហគ្រាស ដែលមិនអនុវត្តត្រឹមត្រូវតាមច្បាប់ស្តីពីការងារនិងបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធការប្រើប្រាស់ពលកម្មកុមារចំនួន៦សហគ្រាស និងបានផាកពិន័យចំនួន២សហគ្រាស។ ព្រមទាំងបានចុះផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប សិប្បកម្មផលិតឥដ្ឋ ចម្ការដំឡូងមី និងចម្ការអំពៅចំនួន៣៧២លើក និងបានអនុវត្តកិច្ចអន្តរាគមន៍ស្នូលដកហូតទប់ស្កាត់ពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ នេសាទទឹកសាប ស្រែអំបិល និងកសិឧស្សាហកម្មចំនួន១ ១៥០នាក់ ក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប ត្បូងឃ្មុំ កណ្តាល កំពង់ចាម បាត់ដំបង ពោធិ៍សាត់ បន្ទាយមានជ័យ និងខេត្តកែប។ បានបង្កើត និងកែសម្រួលគណៈកម្មការប្រឆាំងពលកម្មកុមាររាជធានីខេត្ត បានរៀបចំទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា ជារៀងរាល់ឆ្នាំ និងបានរៀបចំផលិតវីដេអូឃ្លីៗ សម្រាប់ផ្សព្វផ្សាយ អប់រំដល់និយោជក កម្មករនិយោជិត និងប្រជាពលរដ្ឋ ក្នុងការទប់ស្កាត់ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនិងការងារដោយបង្ខំ

- បានលើកកម្ពស់សុខុមាលភាពរបស់បងប្អូនកម្មករនិយោជិត ត្រូវបានកែលម្អឱ្យប្រសើរឡើងជាបន្តបន្ទាប់តាមរយៈការពង្រឹងយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា ចាប់តាំងពីការអនុវត្តដំបូងនៅក្នុងឆ្នាំ២០០០

ហេតុត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយពីគ្រប់ភាគីពាក់ព័ន្ធថា ជាយន្តការដ៏គំរូមួយប្រកបដោយតម្លាភាព និងមានការចូលរួមយកចិត្តទុកដាក់ខ្ពស់ក្នុងការលើកកម្ពស់សុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ និងសុខុមាលភាពរបស់កម្មករនិយោជិត។ ក្រោមយន្តការត្រីភាគី និងក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា សម្រាប់វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ត្រូវបានដំឡើងជាបន្តបន្ទាប់ប្រកបដោយសុខដុម និងទៀងទាត់តាមកាលវិភាគពី១៧០ដុល្លារអាម៉េរិកក្នុងមួយខែ ក្នុងឆ្នាំ២០១៨ ដល់១៩៤ ដុល្លារអាម៉េរិកក្នុងមួយខែ ក្នុងឆ្នាំ២០២២ ហើយបានកើនដល់២០០ដុល្លារអាម៉េរិកក្នុងមួយខែ នៅឆ្នាំ២០២៣ ទោះបីជាកម្ពុជាទទួលរងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ ក៏ដោយហើយបើបូកនឹងប្រាក់អត្ថប្រយោជន៍បន្ថែម កម្មករនិយោជិតម្នាក់អាចទទួលប្រាក់ឈ្នួលពី២១៧ ដល់២២៨ដុល្លារអាម៉េរិកក្នុងមួយខែ។ បន្ថែមពីលើការដំឡើងប្រាក់ឈ្នួលអប្បបរមា រាជរដ្ឋាភិបាលបន្តធ្វើឱ្យប្រសើរឡើងនូវអត្ថប្រយោជន៍ និងសម្រាលបន្ទុកចំណាយរបស់បងប្អូនកម្មករនិយោជិតជាបន្តបន្ទាប់ដូចជាការផ្តល់ប្រាក់ថ្លៃបាយធ្វើការថែមម៉ោងដោយស្ម័គ្រចិត្ត ប្រាក់រង្វាន់ធ្វើការទៀងទាត់ ការអនុញ្ញាតឱ្យស្ត្រីខ្មែរអ៊ិស្លាមស្លៀកពាក់ប្រពៃណី ការអនុញ្ញាតឱ្យកម្មករនិយោជិតជាស្ត្រីដែលមានផ្ទៃពោះលើសពី៣ខែបានចេញមុនម៉ោងការងារ ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន ប្រាក់សោហ៊ុយធ្វើដំណើរនិងស្នាក់នៅ ប្រាក់រង្វាន់អតីតភាពការងារ ការពង្រីកការតបណ្តាញទឹកស្អាតនិងអគ្គិសនីដែលមានតម្លៃទាបនៅតាមផ្ទះជួល ការអនុញ្ញាតឱ្យកម្មករនិយោជិតជិះរថយន្តក្រុងដោយឥតគិតថ្លៃ និងការដំឡើងកម្រិតអប្បបរមានៃបៀវត្សជាប់ពន្ធដល់១លាន៥សែនរៀល និងលើកលែងពន្ធលើប្រាក់អត្ថប្រយោជន៍

- បានលើកកម្ពស់សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនជាបន្តបន្ទាប់នៃការចុះបញ្ជីរបស់អង្គការវិជ្ជាជីវៈ បន្ទាប់ពីប្រកាសឱ្យអនុវត្តច្បាប់ស្តីពីសហជីព ដោយអង្គការវិជ្ជាជីវៈបានចុះបញ្ជិកាសរុបបានកើនឡើងពី៤ ៨៣៨ នៅឆ្នាំ២០១៨ ដល់៥ ៩៥៩ នៅឆ្នាំ២០២២នេះ គឺកើនឡើងប្រមាណ២៣% ក្នុងនោះសហភាពសហជីពមានចំនួន៤០ សហព័ន្ធសហជីពមានចំនួន២៦៥ សហជីពមូលដ្ឋានមានចំនួន៥ ៦៤១ និងសមាគមនិយោជកមានចំនួន១៣។ ជាមួយនេះ យន្តការនៃការដោះស្រាយវិវាទការងារក៏ត្រូវបានលើកកម្ពស់តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងការពង្រឹងសមត្ថភាពមន្ត្រីផ្សះផ្សា ភាពជាដៃគូនៃកិច្ចសន្ទនាសង្គម យន្តការត្រីភាគី និងគាំទ្រនិរន្តរភាពនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។ តាមរយៈការពង្រឹងយន្តការដោះស្រាយវិវាទនេះ ពិនិត្យឃើញថាអត្រារោងចក្រ សហគ្រាសដែលមានវិវាទការងាររួមធៀបនឹងចំនួនរោងចក្រ សហគ្រាសសរុបមានអត្រាប្រមាណ១,៤% ហើយអត្រាដោះស្រាយសះជានៃវិវាទបុគ្គលនៅកម្រិតមន្ត្រីផ្សះផ្សាមានអត្រាប្រមាណ ៥៤,៩% និងការដោះស្រាយវិវាទការងាររួម អត្រាសះជានៅកម្រិតមន្ត្រីផ្សះផ្សាមានអត្រាប្រមាណ៥៩,៤% ឯអត្រាដោះស្រាយសះជានៃវិវាទការងារ ទាំងកម្រិតមន្ត្រីផ្សះផ្សា និងក្រុមប្រឹក្សាអាជ្ញាកណ្តាល មានអត្រាខ្ពស់ប្រមាណ ៨៣% ដែលឆ្លុះបញ្ចាំងអំពីប្រសិទ្ធភាពនៃយន្តការដោះស្រាយវិវាទការងារ និងភាពប្រសើរឡើងនៃសមត្ថភាពរបស់មន្ត្រីផ្សះផ្សា

- បានពង្រឹងយន្តការដោះស្រាយកូដកម្ម បាតុកម្ម ដែលឆ្លុះបញ្ចាំងតាមរយៈការថយចុះជាបន្តបន្ទាប់នៃអត្រារោងចក្រ សហគ្រាសដែលមានកូដកម្មត្រឹមក្រោម១% ការធ្វើអន្តរាគមន៍បានគ្រប់ករណីទាន់ពេលវេលា និងការដោះស្រាយកូដកម្មទទួលបានប្រសិទ្ធភាពខ្ពស់ប្រមាណ១០០% ហើយយន្តការដោះស្រាយបាតុកម្មមានប្រសិទ្ធភាពកាន់តែខ្ពស់ ដោយបានចុះធ្វើអន្តរាគមន៍គ្រប់ករណីនិងទាន់ពេលវេលា និងការដោះស្រាយបាតុកម្ម

ទទួលបានប្រសិទ្ធភាពខ្ពស់។ បន្ថែមលើនេះទៀត ក្រសួងបានដោះស្រាយករណីរោងចក្របិទទ្វារដោយវិបត្តិផ្សេងៗ សរុបចំនួន១១២ករណី មានកម្មករនិយោជិតសរុបចំនួន៥៦ ៣៧១នាក់។ ព្រមជាមួយគ្នានេះ ក្រសួងបានរៀបចំកម្មវិធីសំណេះសំណាលរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាមួយបងប្អូនកម្មករនិយោជិតទាំងក្នុងនិងក្រៅប្រព័ន្ធចំនួន៧៧លើក ដែលមានចំនួនប្រមាណ១លាននាក់ នៅកម្ពុជាដែលជាព្រឹត្តិការណ៍អច្ឆរិយៈ និងជាប្រវត្តិសាស្ត្រក្នុងការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ហើយដែលតាមរយៈកម្មវិធីសំណេះសំណាលនេះ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានដាក់ចេញនូវអនុសាសន៍ចំនួន១០ចំណុចក្នុងការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈនៅកម្ពុជា

- បានអនុវត្តប្រកបដោយជោគជ័យនូវកញ្ចប់វិធានការការអន្តរាគមន៍របស់រាជរដ្ឋាភិបាល ដើម្បីជួយទ្រទ្រង់លំនឹងជីវភាពរបស់កម្មករនិយោជិតក្នុងវិស័យវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប និងវិស័យទេសចរណ៍ ដែលទទួលរងឥទ្ធិពលអវិជ្ជមានពីជំងឺកូវីដ-១៩ តាមរយៈការបើកផ្តល់ប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិតដែលព្យួរកិច្ចសន្យាការងារចំនួន៣៥៣ ២៩០នាក់(ស្មើនឹងថវិកាចំនួន១៣២,៦ ប៊ីលានរៀល)។ ព្រមទាំងបានសម្របសម្រួល និងចូលរួមយុទ្ធនាការជាតិចាក់វ៉ាក់សាំងជំងឺកូវីដ-១៩ ក្រោមឆ័ត្រនៃគណៈកម្មការចំពោះកិច្ចសម្រាប់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ និងកងយោធពលខេមរភូមិន្ទជូនដល់ប្រជាពលរដ្ឋនិងកម្មករនិយោជិតនៅតាមរោងចក្រ សហគ្រាស សរុបប្រមាណ៥៩ម៉ឺននាក់ និងបានបើកផ្តល់សាច់ប្រាក់ក្រោមកម្មវិធីជំនួយសង្គមដល់បងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលរងផលប៉ះពាល់ពីការអនុវត្តវិធានការបិទខ្ទប់ចំនួន៣៤១ ៦៤២នាក់ ដែលបានរួមចំណែកដ៏សំខាន់ក្នុងការការពារអាយុជីវិត និងធានាបាននូវនិរន្តរភាពប្រវាក់ផលិតកម្ម ស្ថិរភាពការងារ និងប្រាក់ចំណូលរបស់កម្មករនិយោជិត និងចូលរួមស្តារនិងជំរុញកំណើនសេដ្ឋកិច្ច។ ជាមួយនេះ ក្រសួងបានរៀបចំវគ្គបណ្តុះបណ្តាលពិសេស ដោយឥតគិតថ្លៃដល់កម្មករនិយោជិតដែលបាត់បង់ការងារដោយសារផលប៉ះពាល់នៃជំងឺកូវីដ-១៩ ចំនួនប្រមាណ៦ ៥០០នាក់ និងបានរៀបចំការបណ្តុះបណ្តាលជំនាញទន់ដល់កម្មករនិយោជិតប្រមាណ៦៨ ០០០នាក់

- បានយកចិត្តទុកដាក់លើកម្មវិធីកំណែទម្រង់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលស្ថិតក្នុងអាណត្តិរបស់ក្រសួងត្រូវបានបន្តពង្រឹងការអនុវត្តរៀបចំបន្ថែម និងធ្វើវិសោធនកម្មជាបន្តបន្ទាប់ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនរបស់សង្គមនិងសេដ្ឋកិច្ច ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពការងារ ការការពារសិទ្ធិនិងផលប្រយោជន៍របស់កម្មករនិយោជិត ធានាការទុកចិត្តពីសំណាក់វិនិយោគនិងធុរកិច្ច ដោយក្នុងនោះច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមាត្រូវបានរៀបចំនិងប្រកាសឱ្យប្រើនៅឆ្នាំ២០១៨ ច្បាប់ស្តីពីរបបសន្តិសុខសង្គម នៅឆ្នាំ២០១៩។ ព្រមជាមួយគ្នានេះ ក្រសួងបានធ្វើវិសោធនកម្មច្បាប់ស្តីពីសហជីពចំនួន១លើក និងព្រមទាំងបានធ្វើវិសោធនកម្មច្បាប់ស្តីពីការងារចំនួន៣លើក ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពការងារ ការការពារសិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោជិត ធានាការទុកចិត្តពីសំណាក់វិនិយោគិននិងធុរកិច្ច។ ជាមួយនេះ ក្រសួងបាននិងកំពុងរៀបចំច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ច្បាប់ស្តីពីសុវត្ថិភាពនិងសុខភាពការងារ និងច្បាប់ស្តីពីទេសន្តរប្រវេសន៍ការងារ។

## ក- ការវិវត្តនៃប្រាក់ឈ្នួលអប្បបរមា និងប្រាក់អត្ថប្រយោជន៍ផ្សេងៗនៅកម្ពុជា(ជាដុល្លារអាម៉េរិក)

| កាលបរិច្ឆេទនៃការចាប់ផ្តើមអនុវត្ត | ប្រាក់ឈ្នួលអប្បបរមា | ប្រាក់រង្វាន់ធ្វើការទៀងទាត់ | ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅ | ប្រាក់ថែទាំសុខភាព | ប្រាក់ឧបត្ថម្ភជីវភាព | ប្រាក់រង្វាន់អតីតភាពការងារ | ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗ | |
|---|---|---|---|---|---|---|---|---|
| | | | | | | | តិចបំផុត | ច្រើនបំផុត |
| ១ មករា ២០២២ | **១៩៤** | **១០** | **៧** | **ម.អ.** | **ម.អ.** | (ពី ០ ទៅ ១១) | **២១១** | **២២២** |
| ១ មករា ២០២១ | ១៩២ | ១០ | ៧ | ម.អ | ម.អ | ពី០ ទៅ ១១ | ២០៩ | ២២០ |
| ១ មករា ២០២០ | ១៩០ | ១០ | ៧ | ម.អ | ម.អ | ពី០ ទៅ ១១ | ២០៧ | ២១៨ |
| ១ មករា ២០១៩ | ១៨២ | ១០ | ៧ | ម.អ | ម.អ | ពី០ ទៅ ១១ | ១៩៩ | ២១០ |
| ១ មករា ២០១៨ | ១៧០ | ១០ | ៧ | ម.អ | ម.អ | ពី០ ទៅ ១១ | ១៨៧ | ១៩៨ |
| ១ មករា ២០១៧ | ១៥៣ | ១០ | ៧ | ម.អ | ម.អ | ពី០ ទៅ ១១ | ១៧០ | ១៨១ |
| ១ មករា ២០១៦ | ១៤០ | ១០ | ៧ | ម.អ | ម.អ | ពី០ ទៅ ១១ | ១៥៧ | ១៦៨ |
| ១ មករា ២០១៥ | ១២៨ | ១០ | ៧ | ម.អ | ម.អ | ពី០ ទៅ ១១ | ១៤៥ | ១៥៦ |
| ១ កុម្ភៈ ២០១៤ | ១០០ | ១០ | ៧ | ម.អ | ម.អ | ពី០ ទៅ ១១ | ១១៧ | ១២៨ |
| ១ ឧសភា២០១៣ | ៨០ | ១០ | ៧ | ម.អ | ម.អ | ពី០ ទៅ ១១ | ៩៧ | ១០៨ |
| ១ កញ្ញា ២០១២ | ៦១ | ១០ | ៧ | ៥ | ម.អ | ពី០ ទៅ ១១ | ៨៣ | ៩៤ |
| ១ មករា ២០១២ | ៦១ | ៧ | ម.អ | ៥ | ម.អ | ពី០ ទៅ ១១ | ៧៣ | ៨៤ |
| ១ មីនា ២០១១ | ៦១ | ៧ | ម.អ | ម.អ | ម.អ | ពី០ ទៅ ១១ | ៦៨ | ៧៩ |
| ១ តុលា ២០១០ | ៦១ | ៥ | ម.អ | ម.អ | ម.អ | ពី០ ទៅ ៥ | ៦៦ | ៧១ |
| ១ មេសា ២០០៨ | ៥០ | ៥ | ម.អ | ម.អ | ៦ | ពី០ ទៅ ៥ | ៦១ | ៦៦ |
| ១ មករា ២០០៧ | ៥០ | ៥ | ម.អ | ម.អ | ម.អ | ពី០ ទៅ ៥ | ៥៥ | ៦០ |
| ១ សីហា ២០០០ | ៤៥ | ៥ | ម.អ | ម.អ | ម.អ | ពី០ ទៅ ៥ | ៥០ | ៥៥ |
| ១៩៩៧ | ៤០ | ម.អ | ម.អ | ម.អ | ម.អ | ពី០ ទៅ ៥ | ៤០ | ៤០ |

សម្គាល់៖ ម.អ មិនអនុវត្ត។

## ខ- ការផ្តល់សេវាសាធារណៈ ដល់កម្មករនិយោជិតខ្មែរ បរទេស

| ល.រ | បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុបរួម |
|---|---|---|---|---|---|---|---|---|
| ១ | សរុប ការផ្តល់សេវាពិនិត្យកាយសម្បទាកម្មករនិយោជិតខ្មែរ បរទេស | **សរុប** | ៤៥៦ ៨៤៨ | ៥៨៨ ៦៣៩ | ៤១៧ ៨៩១ | ៣៤២ ២២៥ | ៦២១ ៤០៧ | **២ ៤២៧ ០១០** |
| | | **ស្រី** | ១៧៩ ៦៨១ | ២២៦ ៩០៣ | ២៣១ ២៩៥ | ១៧៨ ៣៤២ | ៣៦៧ ៩០២ | **១ ១៨៤ ១២៣** |
| ១.១ | ការពិនិត្យកាយសម្បទាកម្មករនិយោជិតនៅពេទ្យការងារ | **សរុប** | ៣៤០ ៨៤៨ | ៣៩២ ៦៦៥ | ៣២៦ ៨៤២ | ៩៦ ៨៥២ | ៣៤ ៤៦៧ | **១ ១៩១ ៦៧៤** |
| | | **ស្រី** | ១៧៩ ៦៨១ | ២២៦ ៩០៣ | ២៣១ ២៩៥ | ៦៨ ៤៤៩ | ២១ ៦៦៣ | **៧២៧ ៩៩១** |
| ១.១.១ | *ចំនួនកម្មករនិយោជិតខ្មែរ* | សរុប | ៣២៣ ៨០៩ | ៣៨០ ២៦៤ | ៣១៧ ២១០ | ៩១ ៤៨៣ | ៣៣ ១៤៨ | **១១៤ ៥៩១៤** |
| | | ស្រី | ១៧១ ១៤១ | ២២០ ៦៦៣ | ២២៧ ៦៥៨ | ៦៦ ៥១៩ | ២១ ២៧៣ | **៧០៧ ២៥៤** |
| ១.១.២ | *ចំនួនជនបរទេស* | សរុប | ១៧ ០៣៩ | ១២ ៤០១ | ៩ ៦៣២ | ៥ ៣៦៩ | ១ ៣១៩ | **៤៥ ៧៦០** |
| | | ស្រី | ៨ ៥៤០ | ៦ ២៤០ | ៣ ៦៣៧ | ១ ៩៣០ | ៣៩០ | **២០ ៧៣៧** |
| ១.២ | ការបញ្ជាក់វិញ្ញាបនបត្រពិនិត្យកាយសម្បទាកម្មករនិយោជិតនៅមន្ទីរពេទ្យដៃគូ មូលដ្ឋានសុខាភិបាល | សរុប | **១១៦ ០០០** | ១៩៥ ៩៧៤ | ៩១ ០៤៩ | ២៤៥ ៣៧៣ | ៥៨៦ ៩៤០ | **១ ២៣៥ ៣៣៦** |
| | | ស្រី | - | - | - | ១០៩ ៨៩៣ | ៣៤៦ ២៣៩ | **៤៥៦ ១៣២** |
| ១.២.១ | *ចំនួនកម្មករនិយោជិតខ្មែរ* | សរុប | - | - | - | ១៥២ ១៥៥ | ៤៩១ ៣៦២ | **៦៤៣ ៥១៧** |
| | | ស្រី | - | - | - | ១០៩ ៨៩៣ | ៣៤៦ ២៣៩ | **៤៥៦ ១៣២** |
| ១.២.១ | *ចំនួនកម្មករនិយោជិតបរទេស* | សរុប | ១១៦ ០០០ | ១៩៥ ៩៧៤ | ៩១ ០៤៩ | ៩៣ ២១៨ | ៩៥ ៥៧៨ | **៥៩១ ៨១៩** |
| | | ស្រី | - | - | - | - | - | - |
| ២ | បញ្ជាក់លើវិញ្ញាបនបត្រសុខភាពសិក្ខាកាមខ្មែរទៅបរទេស | សរុប | ១១៣ | ៥៥០ | ៦២ | ៣ | ៨០ | **៨០៨** |
| | | ស្រី | ៥៧ | ១៥០ | ៣ | ២ | ៣៣ | **២៤៥** |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣ | ការបណ្ដុះបណ្ដាល ស្ដីពីសុខភាពនិងសុវត្ថិភាពការងារ ដល់ប្រតិភូ បុគ្គលិក និយោជកនិងសហជីព | សរុប | ៣ ២៥៧ | ២ ៤៣១ | ២ ១២០ | ១ ៤៥២ | ១ ៣២៩ | **១០ ៥៨៩** |
| | | ស្រី | ១ ៧៩៧ | ១ ១៤៧ | ១ ៤២០ | ៨៤៨ | ៦៩២ | **៥ ៩០៤** |
| ៤ | ការពិនិត្យសុខភាពពលករខ្មែរទៅបម្រើការនៅប្រទេសជប៉ុន | សរុប | ៣៣០ | ៤៧៨ | ២២០ | ១៥៤ | ១១២ | **១ ២៩៤** |
| | | ស្រី | ១៦២ | ២១៨ | ១០៩ | ៥០ | ១៩ | **៥៥៨** |
| ៥ | ការពិនិត្យសុខភាពពលករខ្មែរទៅបម្រើការនៅសាធារណរដ្ឋកូរ៉េ | សរុប | ១០ ៧៤៥ | ២ ៤០៨ | - | - | ៨ ៣៣៨ | **២១ ៤៩១** |
| | | ស្រី | ៣ ៩៤៦ | ៤៧៣ | - | - | ៣ ៦៥៦ | **៨ ០៧៥** |

### គ- ការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារដែលចូលរួមសកម្មភាពសេដ្ឋកិច្ច

| ល.រ | បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុបរួម |
|---|---|---|---|---|---|---|---|---|
| ១ | ចំនួនកុមារដកហូតនិងទប់ស្កាត់ | សរុប | ៤០០ | ០ | ៤០០ | ៣៥០ | ០ | **១ ១៥០** |
| | | ស្រី | ២១៧ | ០ | ២១៥ | ១៥៩ | ០ | **៥៩១** |
| ២ | ការផ្សព្វផ្សាយ | លើក | ៥ | ១៦៤ | ៥ | ១៧៦ | ២២ | **៣៧២** |
| | | សរុប | ៩៥០ | ៣ ៧២៧ | ១៦៧ | ២ ៤៦៨ | ៤ ០២២ | **១១ ៣៣៤** |
| | | ស្រី | ៦២៥ | ១ ៧៥៩ | ៧៦ | ១ ០៣៨ | ១ ៤៤៦ | **៤៩៤៤** |
| ៣ | បណ្ដុះបណ្ដាលគ្រូបង្គោល | វគ្គ | ០ | ២ | ១ | ០ | ៣ | **៦** |
| | | សរុប | ០ | ១៧៧ | ៥០ | ០ | ១៦៤ | **៣៩១** |
| | | ស្រី | ០ | ៣៨ | ៣១ | ៩ | ១០៦ | **១៧៥** |

## ២- ការរក្សានិងបង្កើនមុខរបរនិងការងារនៅក្នុងនិងក្រៅប្រទេស

| ១២ | សហភាពអឺរ៉ុប ( EU ) | ៣ ៨២២ | ៦៥៦ | ៤ ៤៧៨ | ៣ ៨៩៤ | ៧០១ | ៤ ៥៩៥ | ៣ ១២៩ | ៦៥៨ | ៣ ៧៨៧ |
| ១៣ | សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី ( EAEU ) | ៤១ | ៧០ | ១១២ | ៥២ | ៥ | ៥៧ | ៥៣ | ១៥ | ៦៨ |
| ១៤ | ប្រទេសផ្សេងៗ | ៧៣៥ | ១ ៦៥៩ | ២ ៣៩៤ | ៧១៩ | ១ ៦១៨ | ២ ៣៣៧ | ៨៧៤ | ១ ៨៦៨ | ២ ៧៤៣ |

| ល.រ | ទិសដៅនាំចេញ | ឆ្នាំ ២០២១ | | | បម្រែបម្រួល (%) (២០២១/២០២០) | | |
|---|---|---|---|---|---|---|---|
| | | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម |
| ១ | ពិភពលោក | ១៩ ៣០៩ | ២៨ ៧០៣ | ៤៨ ០១២ | ៥% | ៥០% | ២៨% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | អាម៉េរិក | ៧ ៤៩០ | ៣៣៦ | ៧ ៨២៦ | ៤១% | ៣៣% | ៤០% |
| ៣ | ជប៉ុន | ១ ០៩៤ | ៦៤១ | ១ ៧៣៤ | ៣% | -២% | ១% |
| ៤ | ចិន | ១ ៥១០ | ៩ ៦៨៤ | ១១ ១៩៥ | ៣៩% | ៣៧% | ៣៧% |
| ៥ | ចក្រភព អង់គ្លេស | ៧៣២ | ៥៧ | ៧៨៩ | -១២% | ១០% | -១១% |
| ៦ | កាណាដា | ៩៥៥ | ៤០ | ៩៩៥ | ២៧% | -២៨% | ២៣% |
| ៧ | កូរ៉េ | ១៩៤ | ៥៨០ | ៧៧៤ | ៥% | ៦% | ៥% |
| ៨ | អូស្ត្រាលី | ២០៥ | ១២០ | ៣២៥ | ៥៣% | ៥០% | ៥២% |
| ៩ | ឥណ្ឌា | ១២៦ | ១៨៥ | ៣១១ | ១០២% | ៤៣% | ៦៣% |
| ១០ | នូវែលសេឡង់ | ១៧ | ១៤ | ៣១ | ២៥% | -៦% | ៩% |
| ១១ | អាស៊ាន | ២ ៩១៤ | ១២ ៩២៤ | ១៥ ៨៣៨ | -៤០% | ៦៨% | ២៧% |
| | ថៃ | ៦២០ | ៣ ៤៦៣ | ៤ ០៨៤ | -៣១% | ២១% | ៩% |
| | វៀតណាម | ១ ៩៨៥ | ៣ ១៤៤ | ៥ ១២៩ | ៥៩% | ១៨% | ៣១% |
| ១២ | សហភាពអឺរ៉ុប (EU) | ៣ ២២៩ | ៩៦១ | ៤ ១៩០ | ៣% | ៤៦% | ១១% |
| ១៣ | សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី (EAEU) | ៦០ | ៤២ | ១០១ | ១៣% | ១៧៦% | ៤៩% |
| ១៤ | ប្រទេសផ្សេងៗ | ៧៨៣ | ៣ ១១៨ | ៣ ៩០១ | -១០% | ៦៧% | ៤២% |

## ស្ថិតិពាណិជ្ជកម្មជាមួយដៃគូសំខាន់ៗរយៈពេល៩ខែ ឆ្នាំ២០២២(ឯកតា: លានដុល្លារអាម៉េរិក)

| ល.រ | ទិសដៅនាំចេញ | រយៈពេល ៩ខែ ឆ្នាំ២០២១ | | | រយៈពេល ៩ខែ ឆ្នាំ២០២២ | | | បម្រែបម្រួល (%) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម |
| ១ | ពិភពលោក | ១៤ ១៣៩ | ២០ ៦២២ | ៣៤ ៧៦១ | ១៧ ២៥៨ | ២៣ ៧៦៤ | ៤១ ០២៣ | ២២% | ១៥% | ១៨% |
| ២ | អាម៉េរិក | ៥ ៤៤៦ | ២៥៧ | ៥ ៧០៣ | ៧ ០៤៧ | ២៥១ | ៧ ២៩៧ | ២៩% | -២% | ២៨% |
| ៣ | ជប៉ុន | ៨២៧ | ៤៧៥ | ១ ៣០៣ | ៨៩៨ | ៦០២ | ១ ៥០០ | ៨% | ២៧% | ១៥% |
| ៤ | ចិន | ១ ០៩៣ | ៦ ៩២៦ | ៨ ០១៩ | ៨៩៥ | ៧ ៩០១ | ៨ ៧៩៦ | -១៨% | ១៤% | ១០% |
| ៥ | ចក្រភព អង់គ្លេស | ៥២៨ | ៤៤ | ៥៧១ | ៧០៤ | ៦៨ | ៧៧២ | ៣៣% | ៥៦% | ៣៥% |
| ៦ | កាណាដា | ៧១៦ | ៣១ | ៧៤៧ | ៨៧៥ | ២៦ | ៩០១ | ២២% | -១៧% | ២១% |
| ៧ | កូរ៉េ | ១៤៤ | ៤៣៧ | ៥៨១ | ១៧៥ | ៤២៦ | ៦០០ | ២១% | -៣% | ៣% |
| ៨ | អូស្ត្រាលី | ១២២ | ៨០ | ២០២ | ២៨៤ | ១២១ | ៤០៤ | ១៣៣% | ៥១% | ១០០% |
| ៩ | ឥណ្ឌា | ៨៩ | ១៣០ | ២១៩ | ១៣៤ | ១៩០ | ៣២៣ | ៥១% | ៤៦% | ៤៨% |
| ១០ | នូវែលសេឡង់ | ១១ | ១១ | ២២ | ១៦ | ១៧ | ៣២ | ៤៥% | ៤៨% | ៤៦% |
| ១១ | អាស៊ាន | ២ ២៣១ | ៩ ៣៥៨ | ១១ ៥៨៩ | ២ ៤៣៦ | ១០ ២៩៧ | ១២ ៧៣៤ | ៩% | ១០% | ១០% |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ថៃ | ៤៧៦ | ២ ៣៧៥ | ២ ៨៥១ | ៦៥៥ | ២ ៩៧២ | ៣ ៦២៧ | ៣៨% | ២៥% | ២៧% |
| | វៀតណាម | ១ ៥១៣ | ២ ២៨៥ | ៣ ៧៩៧ | ១ ៥៦០ | ៣ ០៧៤ | ៤ ៦៣៤ | ៣% | ៣៥% | ២២% |
| ១២ | សហភាព អឺរ៉ុប(EU) | ២ ៣២៣ | ៧៩០ | ៣ ១១៣ | ៣ ១២១ | ៥៥៧ | ៣ ៦៧៩ | ៣៤% | -២៩% | ១៨% |
| ១៣ | សហភាព សេដ្ឋកិច្ច អឺរ៉ុប-អាស៊ី | ៤០ | ៣៩ | ៧៩ | ១១ | ៤១ | ៥២ | -៧២% | ៦% | -៣៤% |
| ១៤ | ប្រទេសផ្សេងៗ | ៥៦៩ | ២ ០៤៤ | ២ ៦១៣ | ៦៦៣ | ៣ ២៦៩ | ៣ ៩៣១ | ១៧% | ៦០% | ៥០% |

## ស្ថិតិនាំចេញមុខទំនិញសំខាន់ៗ (ឯកតា៖ លានដុល្លារអាម៉េរិក)

| ល.រ | មុខទំនិញ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | បម្រែបម្រួល (២០២១/២០២០) | |
|---|---|---|---|---|---|---|---|
| | | | | | | ទឹកប្រាក់ | (%) |
| ១ | សម្លៀកបំពាក់ | ៧ ៨២២ | ៨ ២៦៦ | ៧ ៣៨៧ | ៨ ០១៨ | ៦៣០ | ៩% |
| ២ | ស្បែកជើង | ១ ០៤០ | ១ ២៦៥ | ១ ១២៣ | ១ ៣៩២ | ២៦៩ | ២៤% |
| ៣ | សម្ភារៈធ្វើដំណើរ | ៥៥៦ | ១០៧៩ | ៩៧៨ | ១ ៤៩៥ | ៥១៧ | ៥៣% |
| ៤ | ម៉ាស៊ីនបរិធាននិង សម្ភារៈអគ្គិសនី | ៥០៨ | ៥៧៤ | ៧៦២ | ១ ០៨១ | ៣១៩ | ៤២% |
| ៥ | កង់ | ៣៧៦ | ៤១២ | ៥៣០ | ៦៣១ | ១០១ | ១៩% |
| ៦ | អង្ករ | ៤១៩ | ៤២០ | ៥០៦ | ៤២៥ | -៨១ | -១៦% |
| ៧ | គ្រឿងសង្ហារិមនិង បរិធានបំភ្លឺ | ១៣៥ | ៤១៩ | ៦៣៧ | ៨៧៣ | ២៣៦ | ៣៧% |
| ៨ | កៅស៊ូ និងផលិតផល ធ្វើពីកៅស៊ូ | ២២៤ | ២២៤ | ២៨២ | ៤២២ | ១៤០ | ៥០% |
| ៩ | ស្ករអំពៅ | ៦៩ | ៥៤ | ៤៦ | ៤៤ | -២ | -៥% |
| ១០ | បន្លែនិងផ្លែឈើ | ៤១ | ៦៦ | ៥៤៦ | ៨០៣ | ២៥៨ | ៤៧% |
| ១១ | មុខទំនិញផ្សេងទៀត | ១ ៤៣៨ | ១ ៩៦៨ | ៥ ៥៤៦ | ៤ ១២៦ | -១ ៤២០ | -២៦% |
| **សរុប៖** | | **១២ ៦២៩** | **១៤ ៧៤៩** | **១៨ ៣៤២** | **១៩ ៣០៩** | **៩៦៧** | **៥%** |

| ល.រ | មុខទំនិញ | ឆ្នាំ២០២១ (៩ខែ) | ឆ្នាំ២០២២ (៩ខែ) | បម្រែបម្រួល | |
|---|---|---|---|---|---|
| | | | | ទឹកប្រាក់ | (%) |
| ១ | សម្លៀកបំពាក់ | ៥ ៨២៩ | ៧ ១៧៥ | ១៣៤៦ | ២៣% |

| | | | | | |
|---|---|---|---|---|---|
| ២ | ស្បែកជើង | ៩៩៨ | ១ ៣២៥ | ៣២៦ | ៣៣% |
| ៣ | សម្ភារៈធ្វើដំណើរ | ១ ០៤៤ | ១ ៤១០ | ៣៦៧ | ៣៥% |
| ៤ | ម៉ាស៊ីនបរិធាន និងសម្ភារៈអគ្គិសនី | ៧៥៨ | ១ ២៨០ | ៥២២ | ៦៩% |
| ៥ | កង់ | ៤៧២ | ៧០០ | ២២៨ | ៤៨% |
| ៦ | អង្ករ | ២៨៦ | ២៩១ | ៥ | ២% |
| ៧ | គ្រឿងសង្ហារិម និងបរិធានបំភ្លឺ | ៧២០ | ៨២៧ | ១០៨ | ១៥% |
| ៨ | កៅស៊ូ និងផលិតផល ធ្វើពីកៅស៊ូ | ២៨៧ | ៣៤៨ | ៦១ | ២១% |
| ៩ | ស្ករអំពៅ | ៤២ | ៤២ | ១ | ១% |
| ១០ | បន្លែនិងផ្លែឈើ | ៦៧៥ | ៨៤៥ | ១៧០ | ២៥% |
| ១១ | មុខទំនិញផ្សេងទៀត | ៣ ០២៩ | ៣ ០១៥ | -១៤ | -0,៥% |
| **សរុបៈ** | | **១៤ ១៣៩** | **១៧ ២៥៨** | **៣ ១១៩** | **២២%** |

## ស្ថិតិនាំចូលមុខទំនិញសំខាន់ៗ (ឯកតា៖ លានដុល្លារអាម៉េរិក)

| ល.រ | មុខទំនិញ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | បម្រែបម្រួល (២០២១/២០២០) | |
|---|---|---|---|---|---|---|---|
| | | | | | | ទឹកប្រាក់ | (%) |
| ១ | វាយនភ័ណ្ឌ | ៤ ៩១០ | ៥ ០៣១ | ៤ ៤០៥ | ៥ ៤៣២ | ១ ០២៦ | ២៣% |
| ២ | សម្ភារៈសំណង់ | ៦៧៩ | ១ ០៨៨ | ១ ០២០ | ១ ៣៣៤ | ៣១៤ | ៣១% |
| ៣ | ដែក និងដែកថែប | ៣៨០ | ៥៥៧ | ៤០៥ | ៣៩១ | -១៤ | -៣% |
| ៤ | ស៊ីម៉ង់ត៍ | ៩០ | ១២៩ | ៦៦ | ៤៤ | -២៣ | -៣៤% |
| ៥ | ទឹក | ២៨៦ | ៣០៣ | ៣១០ | ២៦១ | -៤៨ | -១៦% |
| ៦ | ស្រាបៀរ និងស្រាចំរុះ | 32 | ៣៦ | ១៨ | ១១ | -៧ | -៣៩% |
| ៧ | រថយន្ត | ១ ១៣៤ | ១ ៧៣៤ | ១ ១០៥ | ១២០៧ | ១០២ | ៩% |
| ៨ | ផលិតផលឱសថ និង អាហារបំប៉ន | ៣៣២ | ៣៩៥ | ៣៩៤ | ៨២៤ | ៤៣០ | ១០៩% |
| ៩ | ជីកសិកម្ម និងថ្នាំ សម្លាប់សត្វល្អិតឬស្មៅ | ៣១៣ | ៣២៤ | ៣៣០ | ៤៥០ | ១២១ | ៣៧% |
| ១០ | គ្រឿងអេឡិចត្រូនិក និងសម្ភារៈអគ្គិសនី | ១ ៨១៣ | ២ ៤៧៧ | ២៤០៥ | ២ ៥៧១ | ១៦៥ | ៧% |
| ១១ | មុខទំនិញផ្សេងទៀត | ៧ ២៩៧ | ៨ ០៩៩ | ៨៦៤១ | ១៦ ១៧៨ | ៧ ៥៣៧ | ៨៧% |
| **សរុប** | | ១៧ ២៦៥ | ២០ ១៧២ | ១៩ ១០០ | ២៨ ៧០៣ | ៩ ៦០៣ | ៥០% |

| ល.រ | មុខទំនិញ | ឆ្នាំ២០២១ (៩ខែ) | ឆ្នាំ២០២២ (៩ខែ) | បម្រែបម្រួល | |
|---|---|---|---|---|---|
| | | | | ទឹកប្រាក់ | (%) |
| ១ | វាយនភ័ណ្ឌ | ៣ ៩២០ | ៤ ៣៤៥ | ៤២៥ | ១១% |

| | | | | | |
|---|---|---|---|---|---|
| ២ | សម្ភារៈសំណង់ | ៩៦០ | ៩៩៧ | ៣៧ | ៤% |
| ៣ | ដែក និងដែកថែប | ២៩៩ | ៣៦០ | ៦២ | ២១% |
| ៤ | ស៊ីម៉ង់ត៍ | ៣៨ | ២០ | -១៨ | -៤៧% |
| ៥ | ទឹក | ២០៧ | ១៨៩ | -១៨ | -៩% |
| ៦ | ស្រាបៀរ និងស្រាចំរុះ | ៨ | ២០ | ១២ | ១៦២% |
| ៧ | រថយន្ត | ៨៨៤ | ១ ១២៥ | ២៤១ | ២៧% |
| ៨ | ផលិតផលឱសថ និងអាហារបំប៉ន | ៥៤១ | ៣៩៦ | -១៤៥ | -២៧% |
| ៩ | ជីកសិកម្មនិង ថ្នាំសម្លាប់សត្វល្អិតឬស្មៅ | ៣៤៦ | ៣៦៩ | ២៣ | ៧% |
| ១០ | គ្រឿងអេឡិចត្រូនិក និងសម្ភារៈអគ្គិសនី | ១ ៧៩៥ | ២ ០៨៩ | ២៩៥ | ១៦% |
| ១១ | មុខទំនិញផ្សេងទៀត | ១១ ៦២៤ | ១៣ ៨៥២ | ២ ២២៨ | ១៩% |
| **សរុប៖** | | ២០ ៦២២ | ២៣ ៧៦៤ | ៣ ១៤៣ | ១៥% |

## ស្ថិតិនាំចូលមុខទំនិញសំខាន់ៗ(ឯកតាៈ លានដុល្លារអាម៉េរិក)

## ការនាំចេញ នាំចូល ត្បូងពេជ្រមិនទាន់កែច្នៃនិងសល់ពីការកែច្នៃ (ឯកតា៖ លានដុល្លារអាម៉េរិក)

| ល.រ | លិខិតបញ្ជាក់ | ឆ្នាំ២០១៨ | | ឆ្នាំ២០១៩ | | ឆ្នាំ២០២០ | | ឆ្នាំ២០២១ | | ឆ្នាំ២០២២(៩ខែ) | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួនច្បាប់ | ទឹកប្រាក់ | ចំនួនច្បាប់ | ទឹកប្រាក់ | ចំនួនច្បាប់ | ទឹកប្រាក់ | ចំនួនច្បាប់ | ទឹកប្រាក់ | ចំនួនច្បាប់ | ទឹកប្រាក់ |
| ១ | នាំចូល | ៦៨ | ៦៨ | ៥៥ | ៤៨,៦៨ | ២៣ | ២៣,៩០ | ១៦ | ១៧,៦២ | ១៥ | ៣០ |
| ២ | នាំចេញ | ៣៤ | ៣៩,៤៥ | ៣៩ | ៤២,៥៥ | ២២ | ១៩,៨២ | ២៧ | ១១,៤៣ | ២៦ | ១៨ |

## ស្ថិតិនៃការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

| ទម្រង់ CO | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ (៩ខែ) |
|---|---|---|---|---|---|
| A | ២២២ ៦៦២ | ១៦១ ១៦៦ | ៤១ ៣៧៧ | ៧៧ ៥៧៨ | ៦២ ១៣៦ |
| AB | ១៤ ៧៧៥ | ១២ ៥៣៩ | ១០ ៤០៥ | ១០ ៦០៦ | ៩ ៧៦៨ |
| N | ៤៣ ៣២០ | ៤៦ ០២២ | ៤៨ ២៨៣ | ៥៣ ២៧៩ | ៤៣ ៨១០ |
| AANZ | ៣ ៨៥២ | ៣ ៣៤៤ | ៤ ២៥៤ | ៧ ០២២ | ៦ ៧៥១ |
| AI | ៥ ៦៧២ | ៥ ៥៤១ | ៤ ១៧៩ | ៣ ៧១៥ | ៣ ៨៩៥ |
| AJ | ៦ ៣៥៤ | ៥ ៧៦៨ | ២ ៤៦២ | ២ ៦៥៣ | ២ ៤៣០ |
| AK | ៧ ៥៩០ | ៧ ១៨៥ | ៦ ០២៨ | ៦ ៣០១ | ៥ ៥៩៧ |
| CRF | ១៤៤ ២០៦ | ២០៣ ៦០៩ | ៣១៩ ២៣៨ | ២៩៨ ៦៣៥ | ២៥៧ ៥០៧ |

| | | | | | |
|---|---|---|---|---|---|
| D | ៣២ ០៥០ | ៣៤ ៧៦១ | ៣៣ ៥២៨ | ៤៨ ៩៨៣ | ៥១ ១២១ |
| DFTPILDC | ១៧១ | ២៥២ | ២៣០ | ៤០១ | ៣៣២ |
| E | ១៤ ៦៦៩ | ១៥ ០៤២ | ១៩ ៣៦១ | ២៨ ៣៤៥ | ២៣ ៥៥៨ |
| KLDC | ១ ១១៤ | ៨៣៤ | ៨៨៨ | ១ ១៦៨ | ៩២២ |
| SPT | - | - | - | - | - |
| S | - | ១៣ | ៣៦៣ | ១៩៨ | ៣៣ |
| CHILE | - | - | ៥៨ | ២៨៤ | ៣០៨ |
| AHK | - | - | - | - | - |
| RCEP | - | - | - | - | ២៦៤ |
| CCFTA | - | - | - | - | - |
| ANNEX (Japan) | - | - | ២ | ២៩ | ១០ |
| សរុប | ៤៩៦ ៤៣៥ | ៤៩៦ ០៧៦ | ៤៩០ ៦៥៦ | ៥៣៩ ១៩៧ | ៤៦៨ ៤៤២ |

ប្រភេទអាជ្ញាបណ្ណ និងលិខិតជូនដំណឹងសុំដឹកជញ្ជូនទំនិញឆ្លងកាត់ (ឯកតា៖ លានដុល្លារអាម៉េរិក)

| ល.រ. | ប្រភេទ | ឆ្នាំ២០១៨ | | ឆ្នាំ២០១៩ | | ឆ្នាំ២០២០ | | ឆ្នាំ២០២១ | | ឆ្នាំ២០២២ (៩ខែ) | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួនច្បាប់ | ទឹកប្រាក់ | ចំនួនច្បាប់ | ទឹកប្រាក់ | ចំនួនច្បាប់ | ទឹកប្រាក់ | ចំនួនច្បាប់ | ទឹកប្រាក់ | ចំនួនច្បាប់ | ទឹកប្រាក់ |
| ១ | អាជ្ញាបណ្ណនាំចេញ | ៥៤ | ៧,៧ | ៣៤ | ៣,៣៤ | ៥៦ | ៥,៤៤ | ៥៥ | ៦ | ៣១ | ២,៩ |
| ២ | ពន្យារអាជ្ញាបណ្ណនាំចេញ | ២២ | | ៩ | | ២៣ | | ២៣ | | ១២ | |
| ៣ | អាជ្ញាបណ្ណនាំចូល | ៣៨ | ៣,១៤ | ៩ | ១,០២ | ១០ | ១,២៤ | ១១ | ១,៣១ | ៧ | ០,៨៦ |
| ៤ | ពន្យារអាជ្ញាបណ្ណនាំចូល | | | ៤ | | ១ | | ៥ | | ១ | |
| ៥ | លិខិតជូនដំណឹង | ២៦ | | ១៧ | | ៣៤ | | ៣៣ | | ៤៧ | |

## ៣.២- ការងារពាណិជ្ជកម្មក្នុងប្រទេស

### ៣.២.១- ការជំរុញប្រើប្រាស់ទ្រព្យអរូបីក្នុងការជានាកម្មី

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(១០ខែ) | សរុប |
|---|---|---|---|---|---|---|
| ការងារតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា | ២៧៩២ច្បាប់ | ៧ ៨៥៤ ច្បាប់ | ៨ ០១៥ ច្បាប់ | ១២ ៧១៣ច្បាប់ | ៩ ៩៣១ច្បាប់ | ៤១ ៣០៥ច្បាប់ |

## ៣.២.២- ការអភិវឌ្ឍវិស័យឯកជន

| ល.រ. | បរិយាយការងារ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) | សរុប |
|---|---|---|---|---|---|---|---|
| ១ | បានចេញវិញ្ញាបនបត្រទទួលស្គាល់ការតម្កល់លក្ខន្តិកៈជូនសមាគមអាជីវកម្មក្នុងស្រុក និងបរទេស | ១០សមាគមអាជីវកម្មក្នុងស្រុក២សមាគមអាជីវកម្មបរទេស | | | | | ១០សមាគមអាជីវកម្មក្នុងស្រុក២សមាគមអាជីវកម្មបរទេស |
| ២ | បានផ្សព្វផ្សាយតួនាទីភារកិច្ចអត្ថប្រយោជន៍សមាគមនិងរៀបចំបោះឆ្នោតសមាគមអាជីវកម្មនិងសម្ព័ន្ធសមាគមអាជីវកម្ម | ៤សមាគមអាជីកម្ម | | | | ១ ខេត្ត | ៤ សមាគមអាជីវកម្ម(បោះឆ្នោត)១ខេត្ត (ផ្សព្វផ្សាយ) |
| ៣ | បានរៀបចំបោះឆ្នោតសភាពាណិជ្ជកម្មរាជធានីខេត្តសម្រាប់អាណត្តិថ្មីនិងអាណត្តិបន្ត | ២សភាពាណិជ្ជកម្ម | ១៦សភាពាណិជ្ជកម្ម | | | | ១៨ សភាពាណិជ្ជកម្ម |
| ៤ | បានរៀបចំប្រកាសទទួលស្គាល់សមាសភាពការិយាល័យប្រតិបត្តិសភាពាណិជ្ជកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជា | | ១៨សភាពាណិជ្ជកម្មនិង១សហព័ន្ធស្រូវអង្ករកម្ពុជា | | | | ១៨សភាពាណិជ្ជកម្មនិង១សហព័ន្ធស្រូវអង្ករកម្ពុជា |
| ៥ | បានរៀបចំអនុក្រឹត្យស្តីពីការបង្កើតសភាពាណិជ្ជកម្មថ្មី | | ៥សភាពាណិជ្ជកម្ម | | | | ៥សភាពាណិជ្ជកម្ម |
| ៦ | បានរៀបចំអនុក្រឹត្យស្តីពីការទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មរាជធានី-ខេត្តសម្រាប់អាណត្តិថ្មីនិងអាណត្តិបន្ត | | | ១៨សភាពាណិជ្ជកម្មរាជធានី ខេត្ត | | | ១៨សភាពាណិជ្ជកម្មរាជធានី-ខេត្ត |
| ៧ | បានចុះពង្រឹងការងារសភាពាណិជ្ជកម្មនិងសមាគមអាជីវកម្ម | | | | | | |
| ៨ | រៀបចំបោះឆ្នោតការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជានៅក្រៅប្រទេស | | | | | ១ ប្រទេស | ១ប្រទេស (កាណាដា) |
| ៩ | បានចុះពិនិត្យលទ្ធភាពបង្កើតសភាពាណិជ្ជកម្មនិងផ្សព្វផ្សាយយន្តការភាពជាដៃគូរវាងរដ្ឋបាលរាជធានីខេត្តនិងសភាពាណិជ្ជកម្មរាជធានី ខេត្ត | | | | | ៤ ខេត្ត | ៤ ខេត្ត |

| ល.រ. | បរិយាយការងារ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) | សរុប |
|---|---|---|---|---|---|---|---|
| ១០ | បានចុះត្រួតពិនិត្យនិងវាយតម្លៃបរិមាណសន្និធិប្រេងឥន្ធនៈនិងហ្គាសលើកទី១ និងលើកទី២ | ១០ក្រុមហ៊ុន | ១០ក្រុមហ៊ុន | ១០ក្រុមហ៊ុន | ១០ក្រុមហ៊ុន | ១០ក្រុមហ៊ុន | ១០ក្រុមហ៊ុន |
| ១១ | បានចេញសេចក្តីជូនដំណឹងស្តីពីថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ៍ប្រេងឥន្ធនៈ | ២ដងក្នុងមួយខែ | ២ដងក្នុងមួយខែ | ២ដងក្នុងមួយខែ | ២ដងក្នុងមួយខែ | ៣ដងក្នុងមួយខែត្រឹមខែមេសាឆ្នាំ២០២២ | ១១១លើក |
| ១២ | ចុះស្រាវជ្រាវកំណត់ទីតាំងភូមិសាស្ត្រផលិតផលដែលមានសក្តានុពលទៅលើការអភិវឌ្ឍខ្សែច្រវាក់តម្លៃនិងផលិតផល | ៤លើក | ៨លើក | ៨លើក | ៨លើក | ៦លើក | ៣៤លើក |
| ១៣ | បានរៀបចំសិក្ខាសាលាស្តីពីការផ្សព្វផ្សាយយុទ្ធសាស្ត្រវិស័យសូត្រកម្ពុជាឆ្នាំ២០១៦-២០២០ | ៣ខេត្ត | ១ខេត្ត | ១ខេត្ត | ១ខេត្ត | (ពុំមានក្នុងផែនការសកម្មភាព) | ៦ខេត្ត |
| ១៤ | បានចុះស្រាវជ្រាវប្រមូលទិន្នន័យផលិតផលសូត្រនិងធ្វើបច្ចុប្បន្នភាពកីតម្បាញ | | ៣លើក | ៤លើក | ៤លើក | ៦លើក | ១៧លើក |
| ១៥ | បានរៀបចំសិក្ខាសាលាស្តីពីការឆ្លើយតបរបាំងបច្ចេកទេសពាណិជ្ជកម្មសុវត្ថិភាពចំណីអាហារការវេចខ្ចប់ការដាក់ស្លាកសញ្ញានិងភស្តុភារ | ៣ខេត្ត | ២ខេត្ត | | | (ពុំមានក្នុងផែនការសកម្មភាព) | ៥ខេត្ត |
| ១៦ | បានជួយសម្របសម្រួលប្រមូលទិន្នន័យនិងរៀបចំរបាយការណ៍ស្តីពីទិន្នន័យនៃការដឹកជញ្ជូនទំនិញតាមការបញ្ជាទិញអនឡាញជូនប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ក្រហម | | | | ៥សង្កាត់ | | ៥សង្កាត់ |
| ១៧ | បានរៀបចំសិក្ខាសាលាស្តីពីចុះជំរុញការផ្សារភ្ជាប់រវាងអ្នកប្រមូលទិញអ្នកកែច្នៃ អ្នកនាំចេញនិងភាគីពាក់ព័ន្ធទៅនឹងអ្នកផលិត | | (ពុំមានក្នុងផែនការកម្មភាព) | | (ពុំមានក្នុងផែនការសកម្មភាព) | ២ខេត្ត | ២ខេត្ត |
| ១៨ | បានរៀបចំសិក្ខាសាលាស្តីពីការអភិវឌ្ឍខ្សែច្រវាក់តម្លៃ | | | | | ១ខេត្ត | ១ខេត្ត |

## ការអនុវត្តគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច AIMS

| ល.រ. | បរិយាយការងារ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (១០ខែ) | សរុប |
|---|---|---|---|---|---|---|---|
| ១ | ការកៀងគរកសិករចូលគម្រោង | ៧ ១៥៥ | ១៧ ៦៦១ | ៣១ ៧៣៣ | ១៨ ៨៦៩ | ១ ៩៩៩ | ៧៧ ៤១៧គ្រួសារ |
| ២ | ការចងក្រងជាក្រុមកសិករផលិត | ១៤៩ | ៣៧៧ | ៨៤៦ | ៥៣០ | ៦ | ១ ៩០៨គ្រួសារ |
| ៣ | ការសម្របសម្រួលកិច្ចសន្យាទិញ-លក់ | ២២ | ១២៤ | ៥៨៣ | ៥៣៧ | ១ ៦៣៤ | ២ ៩០០កិច្ចសន្យា |
| ៤ | ការផ្តល់មូលនិធិអភិវឌ្ឍន៍តាមវិស័យ (SDF) | ០ | ០ | ៣៣៣ | ១៥២ | ០ | ៤៨៥សំណើ |
| ៥ | ការអនុម័តមូលនិធិនវានុវត្តន៍ VCIF (Window I) | ០ | ៣៦ | ៧៤៥ | ១១៨៩ | ០ | ១ ៩៧០សំណើ |
| ៦ | បានចុះអនុស្សរណៈនៃការយោគយល់គ្នាក្នុងការអភិវឌ្ឍខ្សែច្រវាក់តម្លៃផលិតផលកសិពាណិជ្ជកម្មរវាងក្រសួងពាណិជ្ជកម្ម និងក្រុមហ៊ុន | ២ | ០ | ២ | ២ | ០ | ៦ ក្រុមហ៊ុន |
| ៧ | ការផ្តល់ចំណេះដឹងជំនាញបច្ចេកទេស ជូនកសិករ | ០ | ០ | ២ ២៥២ | ១៩ ៤៧៩ | ២៣ ៤៦៨ | ៤៥ ១៩៩គ្រួសារ |

## ៣.២.៣- ការងារផែនការស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម

| ល.រ | បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) | សរុប |
|---|---|---|---|---|---|---|---|
| ១ | បោះពុម្ព និងផ្សព្វផ្សាយព្រឹត្តិប័ត្រពាណិជ្ជកម្ម និងព័ត៌មានពាណិជ្ជកម្ម | ៧ ២០០ ក្បាល | ៧ ២០០ ក្បាល | ៧ ២០០ ក្បាល | ៧ ២០០ ក្បាល | ៧ ២០០ ក្បាល | ៣៦ ០០០ ក្បាល |
| ២ | ចងក្រងឯកសារគាំទ្រសម្រាប់រៀបចំ«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យពាណិជ្ជកម្មឆ្នាំ ២០២៤-២០២៨» | ចុះសម្ភាសន៍តាមអង្គភាពក្រោមឱវាទក្រសួងចំនួន ២០អង្គភាព | ០ | ០ | ០ | ចុះសម្ភាសន៍តាមអង្គភាពក្រោមឱវាទក្រសួង ចំនួន ៤៥ អង្គភាព | ៦៥អង្គភាព |
| ៣ | រៀបចំដំណើរការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលអាចគ្រប់គ្រងបាន និងមានស្ថេរភាព | មជ្ឈមណ្ឌលទិន្នន័យចំនួន១ | មជ្ឈមណ្ឌលទិន្នន័យចំនួន ១ | មជ្ឈមណ្ឌលទិន្នន័យចំនួន ១ | មជ្ឈមណ្ឌលទិន្នន័យចំនួន២ | មជ្ឈមណ្ឌលទិន្នន័យចំនួន ២ | មជ្ឈមណ្ឌលទិន្នន័យ៧ |
| ៤ | រៀបចំវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពជំនាញរៀបចំផែនការយុទ្ធសាស្ត្រស្ថិតិព័ត៌មានពាណិជ្ជកម្មព្រឹត្តិបត្រពាណិជ្ជកម្ម និងព័ត៌មានវិទ្យា | ០ | ០ | ០ | ២ | ២ | ៤ |
| ៥ | សិក្ខាសាលាផ្សព្វផ្សាយស្តីពីព័ត៌មានពាណិជ្ជកម្មស្ថិតិ ទាក់ទងនឹងវិស័យពាណិជ្ជកម្ម | ០ | ០ | ០ | ០ | ៤ | ៤ |

## ៤- ការងារជំរុញពាណិជ្ជកម្មនិងអភិវឌ្ឍន៍ទីផ្សារ

### ៤.១- ពិព័រណ៍ពាណិជ្ជកម្ម

| ល.រ. | បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) |
|---|---|---|---|---|---|---|
| ១ | រៀបចំពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស | ៧៧ | ៦២ | ១១ | ២ | ៧ |
| ២ | រៀបចំព្រឹត្តិការណ៍ពាណិជ្ជកម្មក្នុងប្រទេសនិងយុទ្ធនាការទិញផលិតផលខ្មែរ-ព្រឹត្តិការណ៍ភូមិមួយផលិតផលមួយ | ១៣ | ១១ | ៣ | ០ | ១ |
| ៣ | ចូលរួមពិព័រណ៍ក្រៅប្រទេសដោយផ្ទាល់និងអនឡាញ | ៣០ | ២៧ | ២ | ៦ | ៤ |
| ៤ | ចូលរួមពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិកម្រិតអន្តរក្រសួង(ប្រភេទពិព័រណ៍មានពន្លាជាតិនៅក្រៅប្រទេស) | ៣ | ៦ | ២ | ៣ | ១ |
| ៥ | ចូលរួមពិព័រណ៍ពិភពលោកកម្រិតអន្តរក្រសួង(ប្រភេទពិព័រណ៍មានពន្លាជាតិនៅក្រៅប្រទេស និងមានរយៈពេលយូរ៦ខែ) | ០ | ១ | ០ | ១ | ១ |
| ៦ | វេទិកាធុរៈកិច្ចនិងវិនិយោគកម្ពុជា-វៀតណាម ឆ្នាំ២០២២ | ០ | ០ | ០ | ០ | ១ |
| ៧ | ការតាំងបង្ហាញផលិតផលខ្មែរនៅក្នុងឱកាសកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥៥ | ០ | ០ | ០ | ០ | ១ |
| ៨ | ការតាំងបង្ហាញផលិតផលខ្មែរនៅក្នុងឱកាសកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៤ | ០ | ០ | ០ | ០ | ១ |

### ៤.២- ការអភិវឌ្ឍទីផ្សារ

| ល.រ. | បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) |
|---|---|---|---|---|---|---|
| ១ | សិក្ខាសាលាសំខាន់ៗរបស់នាយកដ្ឋាន | ៥ | ៦ | ៧ | ០ | ១៥ |
| ២ | បង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស៖១-ទីក្រុងហុងកុង ២-ទីក្រុងយានថាយ(ខេត្តសានតុង) ៣-ទីក្រុងគុនមីញ(ខេត្តយ៉ូណាន) ៤-ទីក្រុងសៀវមិន(ខេត្តហ្វូចៀន) ៥-ទីក្រុងឈិនទូ(ខេត្តស៊ីឈួន) ៦-ទីក្រុងហៃគូ(ខេត្តហៃណាន) ប្រទេសចិន និង៧-ទីក្រុងអាតស៊ូហ្គី(ខេត្តកាណាកាវ៉ា) ប្រទេសជប៉ុន។ | ១ | ២ | ០ | ៣ | ១ |
| ៣ | ការសាងសង់ផ្សារគំរូព្រំដែន | ០ | ១ | ០ | ០ | ០ |
| ៤ | ការរៀបចំជំនួបផ្គូផ្គងធុរកិច្ច | ៦៣ | ៣៩ | ១០ | ៥ | ៣ |
| ៥ | រៀបចំសម្របសម្រួលការចុះកិច្ចសន្យាពាណិជ្ជកម្មនិងអនុស្សរណៈនានា | ២ | ៤ | ០ | ១ | ៧ |
| ៦ | ដឹកនាំពាណិជ្ជករកម្ពុជា ទៅក្រៅប្រទេស | ០ | ៣ | ០ | ០ | ០ |
| ៧ | វេទិកាជំរុញពាណិជ្ជកម្មនិងវិនិយោគក្នុងនិងក្រៅប្រទេស(ចូលរួមពីប្រទេសវៀតណាម កូរ៉េខាងត្បូង ថៃ នេប៉ាល់ ស្រីលង្កា ឥណ្ឌូណេស៊ី ឥណ្ឌា និងចិន) | ៤ | ៥ | ០ | ០ | ២ |
| ៨ | សហការជាមួយដៃគូអភិវឌ្ឍពាណិជ្ជកម្ម(ដូចជាមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន អាស៊ាន-កូរ៉េ អាស៊ាន-ចិន និងឥណ្ឌា) | ៣ | ១ | ៤ | ១ | ២ |
| ៩ | ការតាំងបង្ហាញផលិផល | ៦ | ៦ | ០ | ០ | ០ |

### ៤.៣- តំណាងពាណិជ្ជកម្ម

ក្រៅពីនេះ ក្រសួងក៏បានរៀបចំឱ្យមានតំណាងពាណិជ្ជកម្មប្រចាំនៅ**១៦ប្រទេស** ដែលក្នុងនោះមាន១៩ស្ថានតំណាង រួមមានប្រទេសអូស្ត្រាលី សហព័ន្ធរុស្ស៊ី ថៃ សហរដ្ឋអាម៉េរិក វៀតណាម ជប៉ុន បែលហ្ស៊ិក កូរ៉េខាងត្បូង ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ស្វ៊ីស សិង្ហបុរី ហ្វីលីពីន ចក្រភពអង់គ្លេស តួកគី និងប្រទេសចិន មាន៤ស្ថានតំណាង

(ទីក្រុងប៉េកាំង ទីក្រុងណាននីង ទីក្រុងក្វាងចូវ និងទីក្រុងសៀងហៃ) ហើយនឹងស្ថានបេសកកម្មអចិន្ត្រៃយ៍មួយប្រចាំនៅទីក្រុងហ្សឺណែវ ប្រទេសស្វ៊ីស។

## ៥- ការងារពាណិជ្ជកម្មអន្តរជាតិ

### ៥.១- ក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក

- បានរៀបចំធ្វើបច្ចុប្បន្នភាពកម្មវិធីការងាររាជរដ្ឋាភិបាល ក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (WTO) ជារៀងរាល់ឆ្នាំ

- បានធ្វើការផ្តល់ព័ត៌មាន(Notifications)ជាប្រចាំ ទៅអង្គការពាណិជ្ជកម្មពិភពលោក(WTO) នូវរាល់ឯកសារបទប្បញ្ញត្តិ និងច្បាប់នានា ដែលក្រសួងនិងស្ថាប័នពាក់ព័ន្ធបានរៀបចំ

- បានផ្តល់ចម្លើយលើកម្រងសំណួរពាក់ព័ន្ធ ច្បាប់ឧបាស្រ័យពាណិជ្ជកម្ម របាយការណ៍ស្តីពីការងារផ្តួចផ្តើមរបស់ក្រុមប្រទេសG20 ក្នុងការគាំទ្រឧស្សាហូបនីយកម្ម ក្នុងប្រទេសអាហ្វ្រិក និងប្រទេសអភិវឌ្ឍន៍តិចតួច កិច្ចសម្រួលពាណិជ្ជកម្មឌីជីថល និងដោយចីរភាព ការធ្វើច្បាប់ពាក់ព័ន្ធនឹងការវិនិយោគកម្រិតជាតិ និងកិច្ចព្រមព្រៀងវិនិយោគអន្តរជាតិនានា

- បានបំពេញតួនាទីជាប្រទេសសម្របសម្រួល សម្រាប់ក្រុមប្រទេសអភិវឌ្ឍតិចតួចក្នុងក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក

- បានចូលរួមជាសមាជិកក្នុងការអនុវត្តគោលដៅការអភិវឌ្ឍប្រកបដោយចីរភាពសកល(SDGs)

- បានរៀបចំខ្លួននិងកសាងឯកសារពាក់ព័ន្ធចាំបាច់ក្នុងការត្រៀមឆ្លងផុតពីឋានៈប្រទេសអភិវឌ្ឍតិចតួច

- បានសម្របសម្រួលជាមួយអន្តរក្រសួង និងសហការជាមួយក្រុមការងារសន្និសីទអង្គការសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងអភិវឌ្ឍន៍(UNCTAD) រៀបចំកិច្ចប្រជុំពិភាក្សាសិក្សាពីភាពងាយរងគ្រោះ(Vulnerability Profile-VP) ក្រោយចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួច(LDCs) ក្នុងគោលបំណងផ្តល់ព័ត៌មានដល់ក្រសួងពាក់ព័ន្ធ អំពីលទ្ធភាពដែលអាចប៉ះពាល់ដល់កម្ពុជាក្រោយចាកចេញពីឋានៈប្រទេសអភិវឌ្ឍតិចតួច ដើម្បីត្រៀមរៀបចំយុទ្ធសាស្ត្រជាតិសម្រាប់រយៈពេលអន្តរកាលនៃការចាកចេញឱ្យបានរលូន(National Smooth Transition Strategy)

- បានពិនិត្យ និងផ្តល់យោបល់លើការងារក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក(WTO)៖
  - លើការស្នើសុំចូលសមាជិកភាពជាCo-sponsor របស់ស្វីសចំពោះសេចក្តីថ្លែងការណ៍ថ្នាក់រដ្ឋមន្ត្រី WTO ស្តីពី «កូវីដ-១៩ និងប្រព័ន្ធពាណិជ្ជកម្មពហុភាគី»
  - លើការស្នើសុំចូលសមាជិកភាពជាCo-sponsor របស់ប្រទេសហ្វីជី នាឱកាសដាក់ដំណើរការកិច្ចសន្ទនាក្រៅផ្លូវការរបស់WTO ស្តីពី"Plastics Pollution and Environmentally Sustainable Plastics Trade"
  - លើការស្នើសុំកម្ពុជាដើរតួនាទីជាប្រធានសម្របសម្រួលក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិក(APG) នៅអង្គការកម្មសិទ្ធបញ្ញាពិភពលោក(WIPO)
  - លើការស្នើសុំកម្ពុជាចូលរួមCo-Sponsor លើសេចក្តីព្រាងសំណើស្តីពី "Agriculture Export Prohibtions or Restrictions relating to the World Food Programme"
  - លើការពិនិត្យឡើងវិញឯកសារត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មរបស់ថៃនិងឥណ្ឌូណេស៊ី

- លើសេចក្តីព្រាងសេចក្តីថ្លែងការណ៍ក្រុមប្រទេសអភិវឌ្ឍន៍តិចតួច(LDCs) និងអាស៊ានក្នុងការគាំទ្រជ្រើសរើសអគ្គនាយកអង្គការពាណិជ្ជកម្មពិភពលោក(WTO)
- លើការស្នើសុំកម្ពុជា ចូលរួមជាសមាជិកគាំទ្រ(Co-Sponsor) លើកំណត់ទំនាក់ទំនងស្តីពី "Trade and Environmental Sustainability"
- លើករណីវេទិកាសេដ្ឋកិច្ចពិភពលោក(WEF) ស្នើសុំធ្វើបទបង្ហាញពី "គំនិតផ្តួចផ្តើមផែនទីបង្ហាញផ្លូវហិរញ្ញប្បទាន(CFRI)" ក្រោមគម្រោងភាពជាដៃគូវិនិយោគក្នុងការអភិវឌ្ឍដោយចីរភាព

- បានចូលរួមកិច្ចប្រជុំសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១២ របស់អង្គការពាណិជ្ជកម្មពិភពលោកស្តីពីៈ
- វិធានការឆ្លើយតបទៅនឹងផលវិបាកនៃជំងឺរាតត្បាតកូវីដ-១៩
- ករណីលើកលែងសម្រាប់ពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា
- បញ្ហាវិបត្តិស្បៀងអាហារនិងកម្មវិធីស្បៀងអាហារពិភពលោក
- ការឧបត្ថម្ភធនលើវិស័យជលផល
- ការឯកភាពចំពោះការព្យួរករណីយកពន្ធគយលើប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

- បានរៀបចំកិច្ចប្រជុំអន្តរក្រសួង ដើម្បីចងក្រងរបាយការណ៍ និងចូលរួមកិច្ចប្រជុំស្តីពីការត្រួតពិនិត្យឡើងវិញនូវគោលនយោបាយពាណិជ្ជកម្មកម្ពុជាលើកទី២ ក្នុងគោលបំណងបង្កើនតម្លាភាពនិងការយល់ដឹងអំពីគោលនយោបាយ និងការអនុវត្តគោលនយោបាយពាណិជ្ជកម្មរបស់កម្ពុជាតាមរយៈការត្រួតពិនិត្យទៀងទាត់តាមកាលវិភាគ ដើម្បីវាយតម្លៃជាពហុភាគីអំពីឥទ្ធិពលនៃគោលនយោបាយនេះ លើប្រព័ន្ធពាណិជ្ជកម្មពិភពលោក

- រៀបចំកិច្ចប្រជុំអន្តរក្រសួង ស្តីពីការធ្វើចំណាត់ថ្នាក់វិធានការនៃកិច្ចព្រមព្រៀងកិច្ចសម្រួលពាណិជ្ជកម្ម(TFA) និងបានធ្វើសេចក្តីជូនដំណឹង ស្តីពីការធ្វើចំណាត់ថ្នាក់វិធានការទាំងនេះទៅអង្គការពាណិជ្ជកម្មពិភពលោក

- បានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំតុមូលចិនលើកទី៥ នៅទីក្រុងសៀមរាប ក្នុងគោលបំណងផ្តល់ជាវេទិកាសម្រាប់ប្រទេសអភិវឌ្ឍតិចតួច ដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងប្រទេសអភិវឌ្ឍតិចតួចដែលកំពុងស្នើសុំចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ចែករំលែកបទពិសោធនានាពាក់ព័ន្ធនឹងការចូលជាសមាជិក

- រៀបចំសុន្ទរកថាគន្លឹះ ឯកសារពាក់ព័ន្ធ ថតវីដេអូទុកជាមុនជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងកិច្ចប្រជុំកំពូលកម្មន្តសាលនិងឧស្សាហូបនីយកម្មសកលឆ្នាំ២០២០ និងកិច្ចប្រជុំកំពូល ស្តីពី«ផលប៉ះពាល់លើការអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០២០» នៃវេទិកាសេដ្ឋកិច្ចពិភពលោក(WEF)

- បានរៀបចំកិច្ចប្រជុំពិភាក្សាជាច្រើនលើក ជាមួយមន្ត្រីជាន់ខ្ពស់ក្រសួងយុត្តិធម៌ និងក្រុមការងារគណៈមេធាវីស្តីពីវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ត្រង់មាត្រា៥ ពាក់ព័ន្ធនឹងសេវាផ្នែកច្បាប់និងមាត្រា៦ ពាក់ព័ន្ធនឹងលក្ខខណ្ឌបដិការ ផ្អែកលើការផ្តល់អាណត្តិការងាររបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

- បានសម្របសម្រួលនិងប្រជុំពិភាក្សាលើសេចក្តីព្រាងឯកសារ ស្តីពីជំហរចរចារបស់កម្ពុជា ទាក់ទងនឹងពាណិជ្ជកម្មអេឡិចត្រូនិកក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ជាមួយជំនាញការនៃក្រុមប្រឹក្សាផ្តល់យោបល់សម្រាប់អាស៊ីប៉ាស៊ីហ្វិក Trade Worthy

- បានរៀបចំឯកសារបច្ចេកទេស និងបញ្ជូនលិខិតទៅអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីផ្តល់ព័ត៌មានអំពីការបញ្ចប់នូវវិធានការបណ្តោះអាសន្នដែលបានដាក់ចេញក្នុងពេលរីករាលដាលនៃជំងឺឆ្លងកូវីដ-១៩ ពាក់ព័ន្ធនឹងការនាំចេញសាច់បង្កកនិងទំនិញបង្កកផ្សេងទៀតចូលមកកម្ពុជា

- សហការនិងផ្តល់យោបល់លើគម្រោងរបស់ARISE Plus ពាក់ព័ន្ធនឹងការសិក្សាស្តីពីការសន្យារបស់កម្ពុជានៅក្រោមអង្គការWTO និងASEAN ដោយបង្កើតម៉ាទ្រីសវាយតម្លៃមួយ ដែលបញ្ចូលការសន្យានៅក្នុងកម្មវិធីការងាររបស់រាជរដ្ឋាភិបាលកម្ពុជា និងការសន្យាផ្អែកលើកំណត់ហេតុនៃកិច្ចប្រជុំត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មឡើងវិញ

- សម្របសម្រួលអន្តរក្រសួងក្នុងការស្នើសុំផ្តល់ព័ត៌មានពីអង្គការWTO ស្តីពី (១) វិធានការពាណិជ្ជកម្ម និងវិធានការពាក់ព័ន្ធនឹងពាណិជ្ជកម្មទាំងអស់ និង(២) វិធានការផ្សេងទៀតដែលបានដាក់ចេញក្នុងអំឡុងពេលជំងឺឆ្លងកូវីដ-១៩

- បានរៀបចំឯកសារពាក់ព័ន្ធ និងចូលរួមកិច្ចប្រជុំលើកទី២ នៃគណៈកម្មាធិការជាតិស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម ក្នុងគោលបំណងពិនិត្យមើលពីការវិវត្តរីកចម្រើននៃផែនការសកម្មភាពឆ្នាំ២០២២-២០២៣ នៃផែនទីបង្ហាញផ្លូវកិច្ចសម្រួលពាណិជ្ជកម្មឆ្នាំ២០២២-២០២៥(WTO-TFA) និងសេចក្តីជូនដំណឹងWTO-TFA

- បានរៀបចំឯកសារស្នើសុំជំនួយបច្ចេកទេសពីធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងការបង្កើតអនុក្រឹត្យចំនួន៤ ដើម្បីអនុវត្តច្បាប់ឧបាស្រ័យពាណិជ្ជកម្មឱ្យមានប្រសិទ្ធភាព។

## ៥.២- ក្របខ័ណ្ឌតំបន់

- បានចូលរួមធ្វើវិសោធនកម្មច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី៣ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) និងសាធារណរដ្ឋកូរ៉េ

- ចូលរួមធ្វើវិសោធនកម្មច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងអាស៊ាននិងសាធារណរដ្ឋប្រជាមានិតចិន

- បានចូលរួមកសាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេវាកម្ម ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងអាស៊ាននិងឥណ្ឌា ប្រកាសឱ្យប្រើកាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨

- បានធ្វើជាម្ចាស់ផ្ទះរៀបចំអន្តរកិច្ចប្រជុំរដ្ឋមន្ត្រី នៃភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ កាលពីថ្ងៃទី២ ខែមីនា ឆ្នាំ២០១៩

- បានចូលរួមកសាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន ហុងកុង នៃសារធារណរដ្ឋប្រជាមានិតចិន ប្រកាសឱ្យប្រើកាលពីថ្ងៃទី១៤ ខែវិច្ឆិកាឆ្នាំ២០២០

- បានចូលរួមធ្វើវិសោធនកម្មច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទីមួយស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងអាស៊ាន និងជប៉ុន ប្រកាសឱ្យប្រើកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០

- បានចូលរួមកសាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម ប្រកាសឱ្យប្រើកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០

- បានចូលរួមកសាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់(RCEP) ប្រកាសឱ្យប្រើកាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១

- ចូលរួមកសាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារអាស៊ានស្តីពីការពង្រឹងយន្តការដោះស្រាយវិវាទ ប្រកាសឱ្យប្រើកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១

- បានចូលរួមចរចាលើ ASEAN Mutual Recognition Arrangement (MRA) on Type Approval for Automotive Products ដែលអនុញ្ញាតឱ្យផលិតផលយានយន្ត ដែលបានធ្វើតេស្តនិងបញ្ជាក់ដោយប្រទេសផលិត ហើយនាំចូលមកទីផ្សារប្រទេសជាសមាជិកដទៃទៀត មិនចាំបាច់ឆ្លងកាត់ការធ្វើតេស្តម្តងទៀតពីប្រទេសនាំចូល

- ចូលរួមចរចាលើ Memorandum of Understanding on the Implementation of Non-Tariff Measures on Essential Goods ដើម្បីជានាលំហូរដោយរលូននៃទំនិញសំខាន់ៗ ពង្រីកការតភ្ជាប់ខ្សែចង្វាក់ផ្គត់ផ្គង់ និងកាត់បន្ថយបន្ទុកចំណាយមិនចាំបាច់

- បានបញ្ចប់ការចរចាកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់(RCEP) ដែលបានចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២

- បានបញ្ចប់ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា ចិន ដែលបានចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២

- បានបញ្ចប់ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា សាធារណរដ្ឋកូរ៉េ ហើយបានបញ្ចប់នីតិវិធីផ្ទៃក្នុងទៅវិញទៅមកដើម្បីចូលជាធរមាននៅដើមខែធ្នូ ឆ្នាំ២០២២

- បាននិងបន្តបំពេញកាតព្វកិច្ចរបស់ខ្លួនជាសមាជិកអាស៊ាន តាមរយៈការចរចានិងសម្រេចបាននូវកិច្ចព្រមព្រៀងពាណិជ្ជកម្មនានាជាមួយបណ្តាប្រទេសជាដៃគូ ដោយកសាងបាននូវច្បាប់និងយន្តការដោះស្រាយវិវាទ ហើយបានអនុវត្តខ្ជាប់ខ្ជួននូវកាតព្វកិច្ចទាំងឡាយជាសមាជិកសហគមន៍សេដ្ឋកិច្ចអាស៊ាន

- បានធ្វើជាប្រធានរៀបចំកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធពេញមួយឆ្នាំ២០២២ ដើម្បីសម្រេចខ្លឹមសារបច្ចេកទេសសម្រាប់ដាក់ជូនស្នើសុំការអនុម័តពីកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន

- បានធ្វើជាប្រធានរៀបចំកិច្ចប្រជុំអាស៊ាន កាណាដា និងកិច្ចប្រជុំអាស៊ានដៃគូនានា និងកិច្ចប្រជុំដំឡើងកម្រិតកិច្ចព្រមព្រៀងអាស៊ាន អូស្ត្រាលី នូវែលសេឡង់

- បានធ្វើជាប្រធានរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៤ និងកិច្ចប្រជុំពាក់ព័ន្ធ ប្រកបដោយជោគជ័យ ដោយមានការចូលរួមជារូបវន្តពីសំណាក់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន និងរដ្ឋមន្ត្រីប្រទេសដៃគូពាក់ព័ន្ធនានាចំនួន២៣ប្រទេស

- អនុវត្តបានសម្រេចប្រកបដោយជោគជ័យនូវសមិទ្ធផលសេដ្ឋកិច្ចរំពឹងទុក(PEDs) ទាំង១៩ នៅពេលកម្ពុជាធ្វើជាប្រធានអាស៊ាន

- បានជំរុញបញ្ចប់របាយការណ៍ ការត្រួតពិនិត្យវាយតម្លៃស្ថានភាពនៃការស្នើសុំចូលជាសមាជិកភាពអាស៊ានរបស់ប្រទេសទីម័រខាងកើត

- បានដាក់បញ្ចូលរបៀបវារៈស្នើសុំបង្កើតលេខាធិការដ្ឋានRCEP នៅកម្ពុជា ដែលរបៀបវារៈនេះបានទទួលគាំទ្រពីអង្គប្រជុំទាំងមូល

- បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន(AECC) លើកទី២១ និងកិច្ចប្រជុំពាក់ព័ន្ធ (កិច្ចប្រជុំរវាងអាស៊ាន និងអូស្ត្រាលី នូវែលសេឡង់ និងកិច្ចប្រជុំរវាងអាស៊ាននិងចក្រភពអង់គ្លេស) ដែលប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ដើម្បីរៀបចំរបាយការណ៍និងអនុម័តឯកសារមួយចំនួនសម្រាប់ដាក់ជូនកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០-៤១ នៅពេលកម្ពុជាធ្វើជាម្ចាស់ផ្ទះក្នុងឆ្នាំ២០២២។

### ៥.៣- ក្របខ័ណ្ឌអនុតំបន់

- ក្នុងក្របខ័ណ្ឌអេម៉ិក(AMEICC) (១) កម្ពុជាទទួលបានលទ្ធផលសំខាន់ៗជាច្រើនក្នុងការជួយសម្រួលការធ្វើពាណិជ្ជកម្មឆ្លងកាត់ព្រំដែនកម្ពុជា ឡាវ វៀតណាម ការកសាងហេដ្ឋារចនាសម្ព័ន្ធរឹង ជាក់ស្តែងការកសាងកំណាត់ផ្លូវជាតិលេខ៥ ដែលតភ្ជាប់ពីច្រកអន្តរជាតិប៉ោយប៉ែតមកភ្នំពេញ ដែលបានបញ្ចប់ទាំងស្រុងនៅចុងឆ្នាំ២០២២ ក្នុងទំហំទឹកប្រាក់ប្រមាណ**៥០០លានដុល្លារអាមេរិក** និង(២) ជួយជំរុញកិច្ចសម្រួលពាណិជ្ជកម្មឆ្លងកាត់ប្រទេសសមាជិកអេម៉ិចទាំង៥(CLMVT) ដោយបានរួមចំណែកជួយដល់ពាណិជ្ជករ អាជីវករ កាត់បន្ថយការចំណាយទាំងថវិកានិងពេលវេលា

- ក្នុងក្របខ័ណ្ឌមហាអនុតំបន់មេគង្គ(GMS) បានទទួលគម្រោងមួយចំនួនលើវិស័យវិនិយោគទន់និងរឹងដែលផ្តល់អត្ថប្រយោជន៍ជាច្រើនដល់វិស័យពាណិជ្ជកម្ម និងការកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការតភ្ជាប់នានានៅក្នុងមហាអនុតំបន់មេគង្គ

- ក្នុងក្របខ័ណ្ឌតំបន់ត្រីកោណអភិវឌ្ឍន៍(CLV DTA) (១) សម្រេចបានច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីជំរុញនិងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា វៀតណាម ឡាវ ដែលត្រូវបានប្រកាសឱ្យប្រើកាលពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៨ សំដៅលើកកម្ពស់ជីវភាពរស់នៅប្រជាពលរដ្ឋរស់នៅតាមបណ្តោយព្រំដែនកម្ពុជា ឡាវ វៀតណាម (២) កសាងព្រំដែនសេដ្ឋកិច្ចសន្តិភាពរវាងប្រទេសទាំង៣ ដោយបានបង្កើតផ្សារព្រំដែនកម្ពុជា វៀតណាម នៅក្នុងខេត្តត្បូងឃ្មុំ និងបន្តកសាងផ្សារព្រំដែនបន្ថែមទៀតនៅខេត្តកំពតជាប់ព្រំដែនវៀតណាម និង(៣) បានបញ្ចប់ផែនការមេស្តីពីអភិវឌ្ឍន៍វិស័យកសិកម្មលើផលិតផលកៅស៊ូ និងទេសចរណ៍ ព្រមទាំងវិស័យអប់រំ សុខាភិបាល សន្តិសុខ និងទំនាក់ទំនងល្អរវាងប្រជាជននិងប្រជាជន ដើម្បីបង្កើនទំហំពាណិជ្ជកម្ម និងលើកកម្ពស់វិស័យទេសចរណ៍និងវិស័យពាក់ព័ន្ធនានារបស់ប្រទេសទាំង៣

- បានបញ្ចប់កិច្ចព្រមព្រៀងទំនិញឆ្លងកាត់កម្ពុជានិងវៀតណាម ដែលនឹងត្រូវដាក់ជូនប្រមុខរដ្ឋាភិបាលប្រទេសទាំង២ ចុះហត្ថលេខានៅកិច្ចប្រជុំកំពូលអាស៊ាន នាខែវិច្ឆិកា ឆ្នាំ២០២២

- បានបញ្ចប់ការចរចាទ្វេភាគីជាមួយប្រទេសថៃនិងឡាវ អំពីកិច្ចព្រមព្រៀងពាណិជ្ជកម្មឆ្លងព្រំដែន ដែលនឹងត្រូវចុះហត្ថលេខានាពេលដ៏ខ្លីខាងមុខ

- សម្រេចការកសាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការជំរុញ និងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា វៀតណាម ឡាវ ដែលប្រកាសឱ្យប្រើកាលពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៨

- ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំគណៈកម្មការសម្របសម្រួលចម្រុះ នៃតំបន់អភិវឌ្ឍន៍ត្រីកោណកម្ពុជា ឡាវ វៀតណាម លើកទី១២ កាលពីខែមីនា ឆ្នាំ២០១៩។

### ៥.៤- ក្របខ័ណ្ឌតំបន់អឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក

- បានចូលរួមកិច្ចប្រជុំលើកទី២ នៃក្រុមការងាររៀបចំសេចក្តីព្រាងគោលការណ៍សម្រាប់ចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន សហភាពអឺរ៉ុប

- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា សហភាពអឺរ៉ុបលើកទី១០ ស្តីពីពាណិជ្ជកម្ម និងការវិនិយោគដោយផ្តោតទៅលើះ

- ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា សហភាពអឺរ៉ុប

• ការចាកចេញពីប្រទេសអភិវឌ្ឍតិចតួច
• បញ្ហាការបើកច្រកទីផ្សារ
• បរិយាកាសវិនិយោគនៅកម្ពុជា
• ការអភិវឌ្ឍន៍ក្នុងតំបន់និងពិភពលោក។

- បានចុះហត្ថលេខាកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចកម្ពុជា ហុងគ្រី រវាងក្រសួងពាណិជ្ជកម្មកម្ពុជានិងក្រសួងការបរទេសនិងពាណិជ្ជកម្មហុងគ្រី នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩

- បានចុះហត្ថលេខាកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការវិស័យសេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេស រវាងកម្ពុជា ប៊ុលហ្គារី រវាងក្រសួងពាណិជ្ជកម្មកម្ពុជានិងក្រសួងសេដ្ឋកិច្ចប៊ុលហ្គារី នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩

- ចូលរួមកិច្ចប្រជុំលើកទី២ នៃគណៈកម្មការសេដ្ឋកិច្ចចម្រុះរវាងកម្ពុជា និងតួកគី ថ្ងៃទី១៧-១៨ ខែតុលា ឆ្នាំ២០១៩ ដោយបានពិភាក្សានិងបន្តពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗ ពាណិជ្ជកម្ម សេដ្ឋកិច្ច ធុរកិច្ច វិនិយោគ ឧស្សាហកម្ម ម្ហូបហាឡាល វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា សហគ្រាសធុនមីក្រូ តូចនិងមធ្យម កសិកម្ម ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល សុខាភិបាល អប់រំ និងទេសចរណ៍

- បានរៀបចំកិច្ចប្រជុំលើកទី៣ នៃគណៈកម្មាធិការចម្រុះស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងកម្ពុជានិងបេឡារុស នៅថ្ងៃទី២៥-២៦ ខែកក្កដា ឆ្នាំ២០១៩ ដោយបានពិភាក្សានិងបន្តពង្រីកកិច្ចសហប្រតិបត្តិការលើវិស័យសំខាន់ៗ ពាណិជ្ជកម្ម ធុរកិច្ច វិនិយោគ កសិកម្ម ឧស្សាហកម្ម វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា រ៉ែនិងថាមពល សុខាភិបាល អប់រំ ទេសចរណ៍ និងវប្បធម៌

- បានរៀបចំកិច្ចប្រជុំអនុក្រុមការងារពាណិជ្ជកម្មនិងវិនិយោគ(Subgroup on Trade and Investment) នៃកិច្ចប្រជុំលើកទី១១ នៃគណៈកម្មាធិការចម្រុះកម្ពុជា សហភាពអឺរ៉ុប($11^{th}$ Cambodia-EU Joint Committee)

- បានរៀបចំកិច្ចប្រជុំលើកទី១ នៃគណៈកម្មការចម្រុះ នៃកិច្ចសហប្រតិបត្តិការវិស័យសេដ្ឋកិច្ចកម្ពុជា ហុងគ្រី នៅថ្ងៃទី២០-២១ ខែមករា ឆ្នាំ២០២១ ដោយបានពិភាក្សាលើវិស័យសំខាន់ៗ សេដ្ឋកិច្ច ពាណិជ្ជកម្មនិងវិនិយោគ កសិកម្ម សេដ្ឋកិច្ចស្បៀង សុវត្ថិភាពម្ហូបអាហារ រុក្ខាប្រមាញ់និងនេសាទ ការគ្រប់គ្រងធនធានទឹក ការអប់រំ យុវជននិងកីឡា ទេសចរណ៍ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ អាកាសចរណ៍ស៊ីវិល

- បានរៀបចំកិច្ចប្រជុំលើកទី៣នៃក្រុមការងាររួម ស្តីពីកិច្ចសហប្រតិបត្តិការកម្ពុជា គណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប អាស៊ី នៅថ្ងៃទី៧-៨ ខែកញ្ញា ឆ្នាំ២០២១

- រៀបចំកិច្ចប្រជុំលើកទី២ នៃក្រុមការងារជាន់ខ្ពស់ ដើម្បីជំរុញគម្រោងវិនិយោគអាទិភាពរួមកម្ពុជា រុស្ស៊ី នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ ដើម្បីពិភាក្សាលើគម្រោងអាទិភាពចំនួន៥ រួមមាន៖

• គម្រោងផលិតកម្មដំបូលស៊ីប្រូ
• គម្រោងវិនិយោគបង្កើតផលិតកម្មដំឡើងយានយន្តម៉ាកKAMAZ
• គម្រោងវិនិយោគបំពាក់ឡដុតសំណល់រឹងសម្រាប់រាជធានីភ្នំពេញ
• គម្រោងសាងសង់ឡសម្ងួត ឬដុតកាកសំណល់កសិកម្ម អង្កាម ឬចំបើង
• គម្រោងផ្គត់ផ្គង់ឧបករណ៍បណ្តាញNetwork សម្រាប់ប្រព័ន្ធអ៊ីនធឺណិតរហ័ស។

- បានរៀបចំកិច្ចប្រជុំទ្វេភាគី ជាមួយគណៈប្រតិភូ នៃសាធារណរដ្ឋម៉ូរីស(Mauritius) ដោយផ្តោតសំខាន់លើការចែករំលែកបទពិសោធក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាណិជ្ជកម្ម ឧស្សាហកម្ម កសិកម្ម បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ និងអប់រំនិងវិនិយោគ

- បានរៀបចំវេទិកាជំនួបធុរកិច្ចរវាងកម្ពុជា ហុងគ្រីលើកទី១

- បានរៀបចំកិច្ចប្រជុំចរចាកម្រិតបច្ចេកទេសទ្វេភាគីរវាងកម្ពុជា កាតា ដើម្បីពិភាក្សានិងពន្លឿនបញ្ចប់សេចក្តីព្រាងនៃកិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងបច្ចេកទេស

- បានពិនិត្យកែសម្រួល និងបញ្ជូនសេចក្តីព្រាងតបនៃលិខិតបញ្ជាក់បំណងស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មរវាងកម្ពុជា ហ្គាបុង

- បានចាប់ផ្តើមការចរចាជុំទី១កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ(CEPA) កម្ពុជា អេមីរ៉ាតអារ៉ាប់រួម ដែលជាការចាប់ផ្តើមបើកច្រកទីផ្សារថ្មីរបស់កម្ពុជាទៅកាន់តំបន់មជ្ឈិមបូព៌ា។

## ៥.៥- ក្របខ័ណ្ឌតំបន់អាមេរិក

- បានចរចាជាមួយភាគីសហរដ្ឋអាម៉េរិក អំពីការបន្តឡើងវិញនៃប្រព័ន្ធអនុគ្រោះពន្ធទូទៅ(GSP) និងបានបន្តផ្សព្វផ្សាយជូនដល់រាល់ពាណិជ្ជករទាំងអស់ ដែលទិន្នន័យនៃការនាំចេញរបស់កម្ពុជាលើសម្ភារៈធ្វើដំណើរក្រោមប្រព័ន្ធនេះ មានតម្លៃសរុបប្រមាណ**១,២ប៊ីលានដុល្លាអាម៉េរិក**

- បានធ្វើការសិក្សាស្រាវជ្រាវច្បាប់ និងបទប្បញ្ញត្តិផ្សេងៗរបស់សហរដ្ឋអាម៉េរិក ទាក់ទងនឹងការផ្តល់ប្រព័ន្ធអនុគ្រោះពន្ធទូទៅ(GSP) ដើម្បីពិនិត្យឡើងវិញនូវប្រព័ន្ធអនុគ្រោះពន្ធទូទៅរបស់អាម៉េរិក នីតិវិធី និងលទ្ធភាពដែលកម្ពុជាអាចអនុវត្តបាន និងកិច្ចការដែលត្រូវអនុវត្តបន្ត

- បានដាក់ចេញនូវញត្តិតវ៉ាអំពីការដកអង្គរចេញពីប្រព័ន្ធអនុគ្រោះពន្ធទូទៅ(GSP) របស់សហរដ្ឋអាម៉េរិកទៅកាន់តំណាងពាណិជ្ជកម្មសហរដ្ឋអាម៉េរិក(USTR) និងបានធ្វើលិខិតជូនដំណឹងទៅសហព័ន្ធស្រូវអង្ករកម្ពុជា (CRF) អំពីលទ្ធផលសម្រេចបាន

- បានរៀបចំកិច្ចប្រជុំពិភាក្សាជាមួយនឹងគណៈប្រតិភូក្រុមហ៊ុនផលិតកង់របស់អាម៉េរិក និងតៃវ៉ាន់ដើម្បីពង្រីកការធ្វើវិនិយោគលើគ្រឿងបន្លាស់ផ្សេងៗ សម្រាប់ដំឡើងកង់នាំចេញទៅកាន់ទីផ្សារអន្តរជាតិ

- បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាចម្រុះលើកទី៥ ស្តីពីកិច្ចព្រមព្រៀងក្របខ័ណ្ឌវិនិយោគនិងពាណិជ្ជកម្មរវាងរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលសហរដ្ឋអាម៉េរិក(5th TIFA) ដោយបានពិភាក្សាលើការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក ស្តង់ដាយានយន្ត និងការដំឡើងរោងចក្រថ្មីរបស់ក្រុមហ៊ុនCoca-Cola នៅកម្ពុជា

- បានរៀបចំកិច្ចប្រជុំជាមួយគណៈប្រតិភូក្រុមប្រឹក្សាធុរកិច្ចសហរដ្ឋអាម៉េរិក អាស៊ាន(US-ABC) ដោយពិភាក្សាលើតួនាទីកម្ពុជាជាប្រធានអាស៊ាននៅឆ្នាំ២០២២ កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម សេដ្ឋកិច្ចទ្វេភាគី ការចូលរួមរបស់វិស័យឯកជនក្នុងការស្តារឡើងវិញនូវខ្សែចង្វាក់ផ្គត់ផ្គង់និងផលិតកម្មសកលពាណិជ្ជកម្មឌីជីថល និងជំរុញវិនិយោគលើវិស័យថាមពល ឧស្សាហកម្ម សុខាភិបាល ហិរញ្ញវត្ថុ និងការនាំចេញ នាំចូល

- បានរៀបចំកិច្ចប្រជុំជាមួយនឹងស្ថានទូតកាណាដា ដើម្បីពិភាក្សាលើពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសកម្ពុជា កាណាដា និងការចរចាពាណិជ្ជកម្មសេរីអាស៊ាន កាណាដា ស្តីពីគម្រោងជំនួយបច្ចេកទេសរបស់ប្រទេសកាណាដា និងការជំរុញវិនិយោគកាណាដានៅកម្ពុជា

- បានជួយសម្របសម្រួលឱ្យក្រុមហ៊ុនផលិតរថយន្តFord បង្កើតរោងចក្រដំឡើងរថយន្តនៅខេត្តពោធិ៍សាត់ និងសម្របសម្រួលឱ្យក្រុមហ៊ុននេះនាំចូលផ្តាច់មុខនូវរថយន្តម៉ាកCHANGAN ម៉ូដែលCS35 PLUS និងCS75 PLUS មកកាន់ទីផ្សារប្រទេសកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការ។

### ៥.៦- កិច្ចសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំប្រកាសស្តីពីការបង្កើតគណៈកម្មការតាមដានការអនុវត្តយុទ្ធសាស្ត្រពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក និងតម្រង់ទិសគម្រោងអភិវឌ្ឍន៍ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនេះ បានបង្កើតឡើងនិងសម្ពោធជាផ្លូវការ នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០

- បង្កើតនិងរៀបចំពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការផ្សារខេមបូឌាត្រេដ(Cambodiatrade.com) ដែលជាថ្នាល នៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ បានទទួលការដាក់ពាក្យចំនួន៤៥៥ និងអនុមតដល់សហគ្រាសចំនួន១២៧ អាចដាក់លក់ផលិតផលលើផ្សារខេមបូឌាត្រេដ(ដោយមានផលិតផលជាង១ ០០០មុខ)។ ដែលបច្ចុប្បន្ននេះ ផ្សារពាណិជ្ជកម្មខេមបូឌាត្រេដ បានចុះអនុស្សរណៈជាមួយធនាគារចំនួន៤ និងក្រុមហ៊ុនផ្តល់សេវាដឹកជញ្ជូនចំនួន២ ដូចជាធនាគារវឌ្ឍនៈអាស៊ីចំកាត់(ABA Bank) ធនាគារវីង(Wing Bank) បាគង iPay88 ប្រៃសណីយ៍កម្ពុជា និងក្រុមហ៊ុនDHL

- គម្រោងសមាហរណកម្មតំបន់អាស៊ាន-ជំនួយពាក់ព័ន្ធពាណិជ្ជកម្មកម្ពុជា(ARISE Plus Cambodia) ត្រូវបានអនុវត្តដោយGIZ និងក្រសួងពាណិជ្ជកម្ម មានតួនាទីជាអ្នកសម្របសម្រួលក្នុងការអនុវត្តគម្រោង ដែលចាប់ផ្តើមពីខែមករា ឆ្នាំ២០១៩ និងគ្រោងបញ្ចប់នៅខែមិថុនា ឆ្នាំ២០២៣ ដោយបានសហការរៀបចំកិច្ចប្រជុំ និងប្រឹក្សាយោបល់ស្វែងរកធាតុចូល សម្រាប់គម្រោងស្រាវជ្រាវចំនួនពីរ ពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី គឺFTA Potential Study និង FTA Feasibility Study និងបានរៀបចំសំណើគម្រោងហិរញ្ញប្បទានឥតសំណងស្តីពីInstitutional Reform of Trade Training and Research Institute (TTRI) and Development of an FTA Knowledge and National Trade Negotiation Secretariat ទៅ GIZ ។ គម្រោងធ្វើឱ្យប្រសើរឡើងនូវការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៃកញ្ចប់ទំនិញខ្នាតតូចសម្រាប់ SMEs (Set4SMEs) ត្រូវបានអនុវត្តដោយSwisscontact និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិមានតួនាទីជាអ្នកសម្របសម្រួល ក្នុងការអនុវត្តគម្រោង ដែលត្រូវបានសម្ពោធជាផ្លូវការ។ គម្រោងនេះនឹងជួយសម្រួលដល់ការដឹកទំនិញឆ្លងកាត់ព្រំដែន ជួយពង្រឹងសមត្ថភាពដល់ប្រព័ន្ធបញ្ជាទំនិញគយ ដែលរៀបចំដោយសម្ព័ន្ធសកលសម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម នៃវេទិកាសេដ្ឋកិច្ចពិភពលោករបស់អង្គការSwisscontact

- បោះពុម្ពសៀវភៅនិងផលិតវីឌីអូខ្លី ស្តីពីយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទាំងភាសាអង់គ្លេសនិងភាសាខ្មែរ និងផ្សព្វផ្សាយនៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងសមាគមធុរកិច្ចនៃស្ថានកុងស៊ុលស្វីសប្រចាំនៅកម្ពុជា និងសហគ្រិនខ្មែរ(Khmer Enterprise) តាមប្រព័ន្ធវីឌីអូ

- រៀបចំបង្កើតប្រកាសស្តីពី«ការបង្កើតគណៈកម្មការតាមដានការអនុវត្តយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងតម្រង់ទិសគម្រោងអភិវឌ្ឍន៍ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក»

- រៀបចំរបាយការណ៍បញ្ចប់គម្រោងដើម្បីផ្ញើជូនលេខាធិការដ្ឋានEIF

- បានដាក់សម្ពោធឱ្យប្រើប្រាស់និងអនុវត្តយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (Cambodia Trade Integration Strategy) ឆ្នាំ២០១៩-២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** នៅលេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោកទីក្រុងហ្សឺណែវប្រទេសស្វីស

- ដាក់សម្ពោធឱ្យអនុវត្តយុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅខែវិច្ឆិកា ឆ្នាំ២០២០ នៅរាជធានីភ្នំពេញ។

## ៦- ការគ្រប់គ្រងគុណភាព សុវត្ថិភាពផលិតផលនិងសេវា កិច្ចការពារអ្នកប្រើប្រាស់ និងការប្រកួតប្រជែង

ដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាពប្រជាជន អគ្គនាយកដ្ឋានកិច្ចការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ(ក.ប.ប.) បានពង្រឹងការងារត្រួតពិនិត្យទំនិញចរាចរលើទីផ្សារ ទំនិញស្តុកទុក និងចែកចាយ តាមរយៈការដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងហានិភ័យ ដុតកម្ទេចទំនិញខូចគុណភាព ចុះត្រួតពិនិត្យគុណភាពទំនិញនៅតាមទីប្រជុំជន ណែនាំអាជីវករឱ្យយល់ពីសារៈសំខាន់នៃសុវត្ថិភាពម្ហូបអាហារ និងផលិតផលមិនមែនម្ហូបអាហារ ព្រមទាំងដាក់ឱ្យដំណើរការមន្ទីរពិសោធន៍ចល័ត(Mobile Lab) និងមន្ទីរពិសោធន៍ខ្នាតតូច(Mini Lab) នៅតាមបណ្តាខេត្ត ដើម្បីបម្រើដល់ការត្រួតពិនិត្យទំនិញនិងផលិតផលប្រើប្រាស់នៅទូទាំងប្រទេស ជាពិសេសទំនិញដែលធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន រួមទាំងប្រេងឥន្ធនៈផងដែរ។

| ល.រ. | ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(១០ខែ) | សរុប |
|---|---|---|---|---|---|---|---|
| ១ | ចំនួនផ្សារ | ១ ៧៧៦ | ៦៥៥ | ៦២៥ | ៥៦៩ | ៦០០ | **៤ ៣៣០** |
| ២ | បរិមាណទំនិញមិនមានអនុលោមភាព (គ.ក្រ.) | ៥២ ៩៩៩ | ១២ ២១៩ | ១០ ១៦៧ | ៣៦ ៤០០ | ២០ ៤៦៤ | **១៣៤ ១៩៨** |

**លទ្ធផលការត្រួតពិនិត្យទំនិញលើទីផ្សារ**

**លទ្ធផលការត្រួតពិនិត្យស្ថានីយ/ដេប៉ូលក់ប្រេងឥន្ធនៈ**

| ល.រ | ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (១០ខែ) | សរុប |
|---|---|---|---|---|---|---|---|
| ១ | ចំនួនស្ថានីយបានត្រួតពិនិត្យ | ៥២៩ | ២១៦ | ១៤៩ | ១ ៦៦១ | ២ ៦០២ | ៥ ១៥៧ |
| ២ | ចំនួនស្ថានីយមិនមានអនុលោមភាព | ៣០២ | ១០០ | ៩១ | ៧៩៦ | ៧៧៧ | ២ ០៦៦ |

ដើម្បីគាំទ្រដល់កិច្ចការត្រួតពិនិត្យអនុលោមភាពផលិតផល ក្រសួងពាណិជ្ជកម្មបានកសាងហេដ្ឋារចនាសម្ព័ន្ធមន្ទីរពិសោធន៍ និងដំណើរការវិភាគលើគំរូផលិតផល ដែលរួមមានមន្ទីរពិសោធន៍នៅអគ្គនាយកដ្ឋានក.ប.ប. មន្ទីរពិសោធន៍ខ្នាតតូចនៅតាមបណ្តាខេត្តចំនួន១៦ និងរថយន្តពិសោធន៍ចល័តផ្នែកម្ហូបអាហារ និងប្រេងឥន្ធនៈសរុបចំនួន៨គ្រឿង។

**លទ្ធផលវិភាគរបស់មន្ទីរពិសោធន៍**

| ល.រ. | ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (១០ខែ) | សរុប |
|---|---|---|---|---|---|---|---|
| ១ | ចំនួនគំរូប្រមូលបាន | ៥ ៩០៤ | ២ ៧២៥ | ៤ ៦៦៤ | ២ ២៨៨ | ១ ១៨៩ | ១៦ ៧៧០ |
| ២ | ចំនួនគំរូមិនអនុលោមភាព | ១៧៥ | ៥៥ | ៦១១ | ៣៧៣ | ៩៧ | ១ ៣១១ |

- បានរៀបចំប្រព័ន្ធទទួលនិងដោះស្រាយបណ្តឹងអ្នកប្រើប្រាស់ ដើម្បីដោះស្រាយនូវរាល់ទំនាស់ដែលកើតមានឡើងរវាងអ្នកលក់ឬអ្នកផ្តល់សេវានិងអ្នកប្រើប្រាស់

- បានធ្វើការបង្ក្រាបករណីទំនិញមិនអនុលោមផ្នែកគុណភាព មានសារធាតុគីមីហាមឃាត់ គ្មានស្លាកសញ្ញាត្រឹមត្រូវចំនួន២០ ៩៨៥គ.ក្រ. ករណីរំលោភកម្មសិទ្ធិបញ្ញា និងរំលោភសិទ្ធិផ្តាច់មុខដោយធ្វើការរឹបអូសខោទឹកនោម

ចំនួន១៧ ៤០២ខោ ភេសជ្ជៈ២១៥ ៧៤៦ដប/កំប៉ុង ប៊ីចេង២៩៤,៥០គ.ក្រ. ថ្នាំដុសធ្មេញ/ប្រេងកូឡាតាប៉ិ/ប្រេងខ្យល់/សាប៊ូ១៨ ៧២២ប្រអប់ បារីចម្រុះ១ ៣២០សុង និងបង្ក្រាបទីតាំងផលិត កែច្នៃ និងឃ្លាំងស្តុកផលិតផលក្លែងក្លាយ២៧២លើក ឃាត់ទុកផលិតផលក្លែងក្លាយ១ ៥០៣ ៥៩២គ.ក្រ. ដើម្បីបន្តនីតិវិធី

- បានសហការជាមួយនគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច និងមន្ទីរពាណិជ្ជកម្មរាជធានី ខេត្តដើម្បីកម្ទេចចោលទំនិញខូចគុណភាព៥៤តោន និង១៣៩គ.ក្រ.

- បានចុះត្រួតពិនិត្យបន្លែផ្លែឈើនាំចូលនៅតាមព្រំដែន ធ្វើការវិភាគតាមរយៈការប្រើប្រាស់រថយន្តមន្ទីរពិសោធន៍ចល័តបាន៥លើក និងបានរកឃើញបន្លែ ផ្លែឈើ១១មុខមានវត្តមានសារជាតុសំណល់ថ្នាំកសិកម្ម និងបានស្នើសុំផ្អាកការនាំចូល

- បានកោះអញ្ជើញក្រុមហ៊ុន៤៣ក្រុមហ៊ុន ដើម្បីធ្វើការបំភ្លឺនិងផ្តល់ឯកសារពាក់ព័ន្ធនឹងការផ្សាយពាណិជ្ជកម្ម លក់ផលិតផលភ្ជាប់ជាមួយរង្វាន់

- ចុះធ្វើការលើកកម្ពស់ការយល់ដឹងជាសាធារណៈ តាមរយៈការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ សន្និសីទបាន២៦លើក តាមរយៈការផ្សព្វផ្សាយអំពីសុវត្ថិភាពម្ហូបអាហារដល់សិស្សានុសិស្ស នៅតាមបណ្តាគ្រឹះស្ថានសិក្សា និងអាជីវករនៅតាមបណ្តាផ្សារក្នុងរាជធានី ខេត្ត២ ៤៨៧លើក និងបិទផ្ទាំងរូបភាពផ្សព្វផ្សាយ(Posters) អំពីសុវត្ថិភាពម្ហូបអាហារ ខិត្តបណ្ណផ្សព្វផ្សាយ(Flyer) អំពីអំពើមិនសុចរិតក្នុងធុរកិច្ចវិស័យប្រេងឥន្ធនៈ ខិត្តបណ្ណអប់រំលើការពុលស្រាស ស្រាថ្នាំ ខិត្តបណ្ណអប់រំផលប៉ះពាល់នៃសារជាតុអាសបេស្តុស(Asbestos) សរុបចំនួន ១៣១ ២១០ផ្ទាំង

- បានកសាងអគាររដ្ឋបាល និងមន្ទីរពិសោធន៍ខ្នាតតូចនៅតាមសាខាក.ប.ប. ខេត្តចំនួន១៦អគារ និងអគារចំនួន១ កម្ពស់៥ជាន់ នៅស្នាក់កណ្តាលនៃអគ្គនាយកដ្ឋានក.ប.ប.

- បានធ្វើការកសាងសមត្ថភាពមន្ត្រី ដោយបានរៀបចំវគ្គបណ្តុះបណ្តាលផ្ទៃក្នុង និងចូលរួមកម្មវិធីបណ្តុះបណ្តាលនៅក្រៅប្រទេស សរុបចំនួន១៤៧លើក ពង្រឹងសមត្ថភាពលើជំនាញនៃការអនុវត្តច្បាប់ក្នុងនាមជាមន្ត្រីស៊ើបអង្កេតដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ និងជំនាញបច្ចេកទេស

- បានសិក្សាស្រាវជ្រាវ ប្រមូលផ្តុំ និងជ្រើសរើសសេចក្តីជូនដំណឹងអំពីវិធានអនាម័យ និងភូតគាមអនាម័យចំនួន២ ៧៦២(ផ្នែកសុវត្ថិភាពផលិតផលម្ហូបអាហារចំនួន១ ៦១៨ ផ្នែកកិច្ចការពារដំណាំចំនួន៥៩០ និងផ្នែកកិច្ចការពារសុខភាពសត្វចំនួន៥៥៥) និងបន្តជូនដំណឹងទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីមានវិធានការបន្ត

- បានទទួលពាក្យបណ្តឹងអ្នកប្រើប្រាស់សរុបចំនួន៥១បណ្តឹង ក្នុងនោះមានចំនួន២១បណ្តឹងបានដោះស្រាយរួចរាល់ ១៧បណ្តឹងកំពុងដំណើរការដោះស្រាយ ៤បណ្តឹងបានបញ្ជូនទៅតុលាការ(រួមទាំងករណីបណ្តឹងក្រុមហ៊ុនNutrilatt) និង៩បណ្តឹងតម្កល់ទុកមិនចាត់ការ។

### ៧- ការអនុវត្តគោលនយោបាយស្រូវ-អង្ករ និងសន្និធិស្បៀងបម្រុងរដ្ឋ

ក្រសួងពាណិជ្ជកម្មមានក្រុមហ៊ុនគ្រីនត្រេដជាសេនាធិការក្នុងការអនុវត្តគោលនយោបាយស្រូវ អង្ករ និងសន្និធិស្បៀងបម្រុងរដ្ឋ។ ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ក្រុមហ៊ុនសម្រេចបានស្នាដៃដូចខាងក្រោម៖

## លទ្ធផលនៃការធ្វើប្រតិបត្តិការពាណិជ្ជកម្មអង្ករ

| ឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២(៩ខែ) | សរុប |
|---|---|---|---|---|---|---|
| ចំនួន (តោន) | ៣ ៧៤៦,៥០ | ២ ០២២,៥០ | ២ ០២៥ | ១០ ៥៣៣,១៤ | ៦ ៣៩៣,៨៧៥ | **២៤ ៧២១,០១៥** |

- ស្តុកត្រៀមបម្រុងរាជរដ្ឋាភិបាល គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ មាន៥ ០០៥,៩៤៨តោន ដែលក្នុងនោះស្តុកដែលអាចប្រើប្រាស់បានជាក់ស្តែងមាន៣ ៥៧៨,០៤៩តោន

- ក្រៅពីស្តុកសន្និធិបម្រុងជាអង្ករមានស្រាប់ ក្រុមហ៊ុនបានទទួលការគ្រប់គ្រងសន្និធិស្បៀងត្រៀមបម្រុងយុទ្ធសាស្ត្រជារូបវន្តបន្ថែមរបស់រាជរដ្ឋាភិបាល រួមមានទឹកសុទ្ធ មី ទឹកត្រី ទឹកស៊ីអ៊ីវ និងត្រីខកំប៉ុង ដើម្បីឆ្លើយតបតម្រូវការប្រជាពលរដ្ឋក្នុងកំលុងពេលគ្រោះមហន្តរាយនានា។ ជាក់ស្តែងក្រុមហ៊ុនបានបញ្ចេញស្តុកប្រើប្រាស់សម្រាប់គ្រោះមហន្តរាយ និងក្នុងបរិបទនៃជំងឺកូវីដ-១៩ មានជាបន្តបន្ទាប់ដូចខាងក្រោម៖

- អង្ករ ចំនួន ១២ ០០៦តោន
- ទឹកបរិសុទ្ធ ចំនួន ១៥១ ៦០០កេស
- មីកញ្ចប់ ចំនួន ៤៧២ ៣០០កេស
- ទឹកត្រី ចំនួន ១ ៧៥២ ៦០០ដប ស្មើនឹង២៩២ ១០០យួរ
- ទឹកស៊ីអ៊ីវ ចំនួន ១ ៩២០ ៦០០ដប ស្មើនឹង៣២០ ១០០យួរ
- ត្រីខកំប៉ុង ចំនួន ៣៧៧ ៥៣០កេស។

**សកម្មភាពការងារស្តីពីការអនុវត្តគោលនយោបាយស្រូវ-អង្ករ**

- បានចុះកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មអង្ករជាមួយប្រទេសឥណ្ឌូណេស៊ី ហ្វីលីពីន បង់ក្លាដែស និងចិន

- បាននិងកំពុងជំរុញការងារពាណិជ្ជកម្មអង្ករជាមួយប្រទេសទីម័រខាងកើត ដើម្បីឈានទៅដល់ការចុះអនុស្សរណយោគយល់ស្តីពីពាណិជ្ជកម្មអង្ករ

- សិក្សានិងរៀបចំគម្រោងជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករជាមួយរដ្ឋបាលស្បៀងខេត្តហ៊ឺណាននៃសាធារណរដ្ឋប្រជាមានិតចិន លើការងារសាងសង់ឃ្លាំងនិងឡសម្ងួត

- ជំរុញការលក់រាយ/ដុំអង្ករក្នុងស្រុក ដើម្បីជានាស្ថេរភាពតម្លៃអង្ករ ចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ

- បានសហការជាមួយដៃគូអភិវឌ្ឍស្ថាប័ននិងក្រុមហ៊ុនពាក់ព័ន្ធនានា ជាពិសេសកម្មវិធីស្បៀងអាហារពិភពលោកក្នុងការផ្គត់ផ្គង់ស្បៀង

- ស្វែងរកទីផ្សារនិងជួយជំរុញការនាំចេញអង្ករកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិ រួមមានសហគមន៍អឺរ៉ុប អាម៉េរិក ប្រទេសចិន អូស្ត្រាលី និងបណ្តាប្រទេសក្នុងសហគមន៍អាស៊ាន ឱ្យមានកំណើនបន្ថែមទៀតជាពិសេសប្រភេទអង្ករក្រអូប(អង្ករផ្កាម្លិះ ផ្ការំដួល...។ល។)។



ពិធីសម្ពោធបើកឲ្យប្រើប្រាស់ជាផ្លូវការចំណតផែពហុបំណងនៃ
កំពង់ផែស្វយ័តក្រុងព្រះសីហនុ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨







**ពិធីសំណេះសំណាលជាមួយកម្មករនិយោជិត នៅខេត្តកណ្ដាល**

**កាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨**








**កិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាអាណត្តិទី២ ឆ្នាំទី២**
**កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២**








**កិច្ចប្រជុំក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសុខសង្គម**
**កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០**

# យុទ្ធសាស្ត្រចតុកោណទី៤
# ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន

ទន្ទឹមនឹងការជំរុញកំណើនសេដ្ឋកិច្ចខ្ពស់ រាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន ជាពិសេសផ្សារភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។

## មុំទី១- ការលើកស្ទួយវិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទ

### ១- ការលើកស្ទួយវិស័យកសិកម្ម ( គេហទំព័រ www.moc.gov.kh )

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយ និងជំរុញការអនុវត្ត "យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦ នៃរដ្ឋសភា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣" ដែលនៅតែចាត់ទុកវិស័យកសិកម្ម ជាវិស័យអាទិភាពក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ជានាសមធម៌ ជានាសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដោយបានកំណត់យ៉ាងច្បាស់ថា ការលើកកម្ពស់ផលិតភាព ពិពិធកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ពិសេសធនធានដី ព្រៃឈើនិងជលផល គឺជាមុខព្រួញស្នូលដ៏សំខាន់ ដើម្បីចូលរួមជំរុញកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា។

អនុវត្តតាមគោលនយោបាយនិងយុទ្ធសាស្ត្រនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើការបន្តធ្វើទំនើបកម្មវិស័យកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ដោយបានជំរុញការអនុវត្តវិធានការចាំបាច់មួយចំនួនរួមមានការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធដែលបម្រើដល់ផលិតកម្មកសិកម្ម បង្កើនការផ្តល់សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ ការស្រាវជ្រាវបច្ចេកទេសកសិកម្មសំដៅបង្កើនទិន្នផលដំណាំ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងនិងបង្កើនដីជាតិដីកសិកម្ម ការពង្រឹងសហគមន៍កសិកម្ម ព្រមទាំងការកសាងនិងពង្រឹងសមត្ថភាពធនធានមនុស្ស និងស្ថាប័ន ដើម្បីជំរុញការអភិវឌ្ឍវិស័យកសិកម្ម។

ទន្ទឹមនឹងនេះ ក្រសួងក៏បានយកចិត្តទុកដាក់ខ្ពស់លើការចិញ្ចឹមសត្វនិងវារីវប្បកម្ម ព្រមទាំងខិតខំយ៉ាងខ្លាំងក្លាលើការអនុវត្តវិធានការច្បាប់ និងវិធានការបច្ចេកទេសសមស្រប ក្នុងការគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិ ព្រៃឈើ និងជលផលប្រកបដោយចីរភាព។ ការខិតខំប្រឹងប្រែងទាំងអស់នេះ គឺក្នុងទិសដៅចូលរួមចំណែកបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម ក៏ដូចជាការជួយបង្កើនប្រាក់ចំណូលជូនប្រជាកសិករ ការបន្តជំរុញការធ្វើកសិពាណិជ្ជកម្មនិងការបង្កើនចំណូលថវិកាជាតិ។

ដើម្បីសម្រេចបានទិសដៅគោលនយោបាយនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុវត្តកម្មវិធីជាយុទ្ធសាស្ត្រ ដែលបានបង្ហាញសមិទ្ធផលដូចខាងក្រោម ៖

### ២- សមិទ្ធផលក្នុងវិស័យកសិកម្មសម្រេចបានពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២

តម្លៃបន្ថែមសរុប ( គិតតាមតម្លៃបច្ចុប្បន្ន ) នៃវិស័យកសិកម្ម ( Agricultural Gross Value Added-GVA ) គឺមានការកើនឡើងជារៀងរាល់ឆ្នាំ។ តម្លៃបន្ថែមសរុបនៃវិស័យកសិកម្មបានកើនពី២១ ៩១៣ពាន់លានរៀលនៅឆ្នាំ២០១៨ និងបានបន្តកើនដល់២៤ ៧៥៥ពាន់លានរៀល នៅឆ្នាំ២០២១។

## ២.១- ការបង្កើនផលិតភាព ពិពិធកម្មដំណាំកសិកម្មនិងកសិធុរកិច្ច

### ២.១.១- ផលិតកម្មដំណាំស្រូវ

ក្នុងរយៈពេល៥ឆ្នាំ(ឆ្នាំ២០១៨-២០២២)កន្លងមក ផ្ទៃដីដាំដុះដំណាំស្រូវសម្រេចបានចំនួន៣,៣៤លាន ហ.ត. នៅឆ្នាំ២០១៨ និងមានការកើនឡើងដល់៣,៤០លានហ.ត. នៅឆ្នាំ២០២២ ដោយមានអត្រាកំណើនជាមធ្យមចំនួន០,៥០%ក្នុងមួយឆ្នាំ។ ផ្ទៃដីដាំដុះដំណាំស្រូវវស្សាសម្រេចបានចំនួន២,៧៤លានហ.ត. នៅឆ្នាំ២០១៨ នឹងកើនឡើងដល់ចំនួន២,៧៦លានហ.ត. នៅឆ្នាំ២០២២។ ដោយឡែក ផ្ទៃដីដាំដុះដំណាំស្រូវប្រាំងសម្រេចបានចំនួន០,៦០លានហ.ត. នៅឆ្នាំ២០១៨ នឹងកើនឡើងដល់ចំនួន០,៦៤លានហ.ត. នៅឆ្នាំ២០២២។

ទិន្នផលស្រូវមធ្យមបានកើនពី៣,៣៥តោនក្នុងមួយហ.ត. នៅឆ្នាំ២០១៨ ដល់៣,៤៤តោនក្នុងមួយហ.ត. នៅឆ្នាំ២០២២ ដោយមានអត្រាកំណើនជាមធ្យមចំនួន០,៦%ក្នុងមួយឆ្នាំ។ ទិន្នផលស្រូវវស្សាបានថយពី៣,០៩តោនក្នុងមួយហ.ត. នៅឆ្នាំ២០១៨ មកត្រឹមតែ៣,០៧តោនក្នុងមួយហ.ត. នៅឆ្នាំ២០២២។ ចំណែកឯទិន្នផលស្រូវប្រាំងទទួលបានពី៤,៥១តោនក្នុងមួយហ.ត. ទៅ៤,៦០តោនក្នុងមួយហ.ត. ក្នុងរយៈពេល៥ឆ្នាំនេះ។

បរិមាណស្រូវសរុបប្រចាំឆ្នាំបានកើនពី១០,៨៩លានតោន នៅឆ្នាំ២០១៨ ដល់១១,៤៣លានតោន នៅឆ្នាំ២០២២ ដោយមានអត្រាកំណើនជាមធ្យមចំនួន១,២%ក្នុងមួយឆ្នាំ។ បរិមាណផលស្រូវវស្សាបានកើនពី ៨,២១លានតោន នៅឆ្នាំ២០១៨ ដល់៨,៤៩លានតោន នៅឆ្នាំ២០២២ និងបរិមាណស្រូវរដូវប្រាំងទទួលបានកើនពី ២,៦៨លានតោន នៅឆ្នាំ២០១៨ ដល់២,៩៤៣លានតោន នៅឆ្នាំ២០២២។

តារាងទី១ ផលិតកម្មដំណាំស្រូវឆ្នាំ២០១៨-២០២២

| ឆ្នាំ/រដូវ | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ | | ២០២២ (ប៉ាន់ស្មាន) | |
|---|---|---|---|---|---|---|---|---|---|---|
| | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) |
| រដូវប្រាំង | ៥៩៦ ៤៨៣ | ២ ៦៧៨ ៨៤២ | ៥៩៧ ៥០៨ | ២៦១៦២៥៣ | ៥៩៧ ៥០៨ | ២ ៦១៦ ២៥២ | ៦៤៩ ៥៥២ | ២ ៩២៨៦៧២ | ៦៣៩១៣៨ | ២ ៩៣៧ ៣៤៩ |
| រដូវវស្សា | ២ ៧៣៩ ៤៤៦ | ៨ ២១២ ៨៩៣ | ២ ៧៣១ ៣៣៨ | ៨ ២៦៩ ៤៨០ | ២៨០៦៦២៣ | ៨ ៣១៩ ៣៦៥ | ២៩០៣១៨៦ | ៩ ២៧៨ ៣១៦ | ២៧៦៤០៤០ | ៨៤៨៥៦០៣ |
| សរុប | ៣ ៣៣៥ ៩២៩ | ១០ ៨៩១ ៧៣៥ | ៣ ៣២៨ ៨៦៤ | ១០៨៨៥៧៣៣ | ៣៤០៤១៣១ | ១០ ៩៣៥៦១៨ | ៣៥៥២៧៣៨ | ១២២០៦៩៨៨ | ៣៤០៣១៧៨ | ១១៤២២៩៥២ |

អតិរេកស្រូវបានកើនពី៥,៨៤លានតោន នៅឆ្នាំ២០១៨ នឹងកើនឡើងដល់៦,២១លានតោននៅឆ្នាំ២០២២ ឬគិតជាអង្ករមានចំនួន៣,៧៤លានតោន នៅឆ្នាំ២០១៨ នឹងកើនឡើងដល់៣,៩៨លានតោននៅឆ្នាំ២០២២ ហើយអត្រាកំណើនមធ្យមនៃអតិរេកស្រូវ ក៏ដូចជាអង្ករ មានចំនួន១,៦% ក្នុងមួយឆ្នាំ។

**តារាងទី២ អតិរេកស្រូវ/អង្កររយៈពេល៥ឆ្នាំ (២០១៧-២០២១)**

| អតិរេកស្រូវ/អង្ករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|
| បរិមាណអង្ករលើស(តោន) | ៣ ៧៣៥ ១៥៣ | ៣ ៦៨៦ ០៧៧ | ៣ ៧៩០ ១៦៧ | ៤៤៤៧ ៤៩៤ | ៣៩៧៦៥៧០ |
| បរិមាណស្រូវលើស(តោន) | ៥ ៨៣៦ ១៧៧ | ៥ ៧៥៩ ៤៩៥ | ៥ ៩២២១៣៦ | ៦៩៤៩ ២០៩ | ៦ ២១៣ ៣៩១ |

### ២.១.២- ផលិតកម្មដំណាំសាកវប្បកម្ម

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ផ្ទៃដីដាំដុះដំណាំសាកវប្បកម្មរយៈពេលខ្លី មានដូចជា ពោត ដំឡូងផ្វា បន្លែគ្រប់មុខ ម្ទេស និងឪឡឹក បានកើនពី៨៥,៣៥ពាន់ហ.ត. នៅឆ្នាំ២០១៨ នឹងកើនឡើងដល់៩៧,២៤ពាន់ហ.ត. នៅឆ្នាំ២០២២ ក្នុងអត្រាកំណើនជាមធ្យម៣,៤៨%ក្នុងមួយឆ្នាំ។ បរិមាណផលសរុបបានកើនឡើងពី០,៨៥លានតោន នៅឆ្នាំ២០១៨ នឹងកើនឡើងដល់១,១៨លានតោន នៅឆ្នាំ២០២២ កម្រិតកំណើនជាមធ្យម១០,២៤% ក្នុងមួយឆ្នាំ។

ដំណាំសាកវប្បកម្មរយៈពេលវែង មានដូចជាម្នាស់ ចេក ស្រកានាគ ស្វាយ មៀន មៀនប៉ៃលិន ទុរេន ខ្នុរ ក្រូចពោធិ៍សាត់ ក្រូចថ្លុង សារម៉ាវ ត្របែក ទៀប ទឹកដោះ ល្មុត មានផ្ទៃដីដាំដុះចំនួន១៨០ ៥៣៥ហ.ត. នៅឆ្នាំ២០១៨ បានកើនឡើងដល់ចំនួន៣០០ ៣៤៨ហ.ត. នៅឆ្នាំ២០២២ ដែលមានកំណើនជាមធ្យម១៨,៤៩%ក្នុងមួយឆ្នាំ។ បរិមាណផលទទួលបានចំនួន១ ៧៧៨ ០៦០តោន នៅឆ្នាំ២០១៨ នឹងកើនឡើងដល់ចំនួន៤ ៧៨៣ ៩១០ តោន ក្នុងកំណើនជាមធ្យម៣៩,០៨% ក្នុងមួយឆ្នាំ។

**តារាងទី៣ ផលិតកម្មដំណាំសាកវប្បកម្មរយៈពេលខ្លី ឆ្នាំ២០១៨-២០២២**

| ឆ្នាំ/ រដូវ | ២០១៧ | | ២០១៨ | | ២០១៩ | | ២០២០ | | ២០២១ (ប៉ាន់ស្មាន) | |
|---|---|---|---|---|---|---|---|---|---|---|
| | ផ្ទៃដី ដាំដុះ (ហ.ត.) | បរិមាណ ផល (តោន) | ផ្ទៃដី ដាំដុះ (ហ.ត.) | បរិមាណផល (តោន) | ផ្ទៃដី ដាំដុះ (ហ.ត.) | បរិមាណ ផល(តោន) | ផ្ទៃដី ដាំដុះ (ហ.ត.) | បរិមាណ ផល(តោន) | ផ្ទៃដី ដាំដុះ (ហ.ត.) | បរិមាណ ផល (តោន) |
| រដូវប្រាំង | ៣៤ ៩១១ | ៣៥៩ ៧៨៧ | ៣៧ ៦២៦ | ៣៦៧ ១២០ | ៣៧ ៦២៦ | ៣៦៧ ១១៨ | ៣៦ ៦៣៨ | ៤៤៧ ៣០១ | ៤៣២១៩ | ៥៥០៤៧២ |
| រដូវវស្សា | ៥០ ៤៣៤ | ៤៣៧ ៧៧២ | ៥៦ ៩១៥ | ៥១២៧០១ | ៦៧ ៦៦៥ | ៦៥៨ ៩៧២ | ៥៣ ៦៨៩ | ៥៩១ ៥២៥ | ៥៤០១៦ | ៦៣១៦៨២ |
| សរុប | **៨៥ ៣៤៥** | **៧៩៧ ៥៥៩** | **៩៤ ៥៤១** | **៨៧៩ ៨២១** | **១០៥ ២៩១** | **១ ០២៦ ០៩០** | **៩០ ៣២៨** | **១ ០៣៨ ៨២៦** | **៩៧២៣៥** | **១១៨៧៨២២** |

### ២.១.៣- ផលិតកម្មដំណាំឧស្សាហកម្ម

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ ផ្ទៃដីដាំដុះដំណាំឧស្សាហកម្មរយៈពេលខ្លី មានដូចជាពោតក្រហម ដំឡូងមី សណ្ដែកដី សណ្ដែកសៀង អំពៅ ក្រចៅ ល្ង និងថ្នាំជក់ មានការថយចុះពី១ ០០៦,៥៤ពាន់ហ.ត. នៅឆ្នាំ២០១៨ មកត្រឹម៩៨១,៣៩ពាន់ហ.ត. នៅឆ្នាំ២០២២ ក្នុងអត្រាថយចុះមធ្យម០,៦៣%ក្នុងមួយឆ្នាំ។ បរិមាណផលសរុប នឹងថយពី១៥,៨៥លានតោន នៅឆ្នាំ២០១៨ មកត្រឹម១៥,៤១លានតោន នៅឆ្នាំ២០២២ ក្នុងអត្រាថយចុះជាមធ្យម០,៤៥%ក្នុងមួយឆ្នាំ។

ដំណាំឧស្សាហកម្មរយៈពេលវែង មានដូចជាស្វាយចន្ទី ដូងប្រេង ដូង កាហ្វេ ម្រេច ដែលមានផ្ទៃដីដាំដុះចំនួន២២៨ ៤៣០ហ.ត. នៅឆ្នាំ២០១៨ នឹងកើនឡើងដល់៥៨៥ ០៤៣ហ.ត. នៅឆ្នាំ២០២២ មានការកើនឡើងជាមធ្យមប្រមាណ២០,៦៩%ក្នុងមួយឆ្នាំ។ បរិមាណផលដំណាំឧស្សាហកម្មរយៈពេលវែង មានចំនួន៦៣០ ៣៧៨ តោន នៅឆ្នាំ២០១៨ ហើយអាចនឹងកើនដល់១ ៣២២ ៩២៩តោន នៅឆ្នាំ២០២២(កើនឡើងប្រមាណ១៥,៩៨% ក្នុងមួយឆ្នាំ)។

### តារាងទី៤ ផលិតកម្មដំណាំឧស្សាហកម្មឆ្នាំ២០១៨-២០២០

| ឆ្នាំ/រដូវ | ២០១៨ | | ២០១៩ | | ២០២០ | |
|---|---|---|---|---|---|---|
| | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) | ផ្ទៃដីដាំដុះ (ហ.ត.) | បរិមាណផល (តោន) |
| រដូវប្រាំង | ៨៨ ៨៣៩ | ៩៧៥ ៤៩២ | ៧៩ ២៤៥ | ៨៦១ ៥៧១ | ៧៩ ២៤៥ | ៨៦២ ៧៨២ |
| រដូវវស្សា | ៩១៧ ៧០៣ | ១៤ ៨៧២ ៣០៩ | ៨៨៥ ៣៧៣ | ១៤ ២៧៧ ៩២១ | ៨៣៣ ៧៣០ | ១៣ ៣៤២ ៣០១ |
| សរុប | **១ ០០៦ ៥៤២** | **១៥ ៨៤៧ ៨០១** | **៩៦៤ ៦១៨** | **១៥ ១៣៩ ៤៩២** | **៩១២ ៩៧៥** | **១៤ ២០៥ ០៨៣** |

### តារាងទី៥ ផលិតកម្មដំណាំឧស្សាហកម្មរយៈពេលខ្លី ឆ្នាំ២០២១-២០២២

| ឆ្នាំ/រដូវ | ២០២១ | | ២០២២ (ប៉ាន់ស្មាន) | |
|---|---|---|---|---|
| | ផ្ទៃដីដាំដុះ(ហ.ត) | បរិមាណផល(តោន) | ផ្ទៃដីដាំដុះ(ហ.ត) | បរិមាណផល(តោន) |
| រដូវប្រាំង | ១២២ ៦១៤ | ១ ៦៥៩ ៦០៧ | ១០១ ៣៥១ | ១ ៧១៥ ១៨៦ |
| រដូវវស្សា | ៨០៧ ២៣៩ | ១៣ ៨៥០ ៥៤៥ | ៨៨០ ០៣៥ | ១៣ ៧០៦ ១៧៦ |
| សរុប | **៩២៩ ៨៥៣** | **១៥ ៥១០ ១៥២** | **៩៨១ ៣៨៦** | **១៥ ៤១២ ៣២១** |

### ២.១.៤- ការចងក្រង និងចុះបញ្ជីសហគមន៍កសិកម្ម

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ សហគមន៍កសិកម្មមានការកើនឡើងពីចំនួន១ ១១៦សហគមន៍ នៅឆ្នាំ២០១៨រហូតដល់ចំនួន១ ២១៧សហគមន៍ នៅឆ្នាំ២០២២។ ជាមួយគ្នានេះ សហគមន៍កសិកម្ម បានចុះកិច្ចសន្យាប្រតិបត្តិមុខរបរជាមួយក្រុមហ៊ុនឯកជនបានចំនួន២១២កិច្ចសន្យា ដោយផ្តោតលើដំណាំមៀន ដំណាំស្វាយ អង្ករស្ករត្នោត ម្រេច ស្វាយចន្ទី ពូជស្រូវក្រអូប ដំឡូងមី ពូជស្រូវផ្ការំដួល និងបន្លែសុវត្ថិភាព។

### ២.១.៥- ការងារកសិឧស្សាហកម្ម

ក្រសួងបានរៀបចំបង្កើតអនុគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ថ្នាក់រាជធានីខេត្ត បានចំនួន២៥រាជធានី/ខេត្ត និងបានរៀបចំផែនការយុទ្ធសាស្ត្រកសិឧស្សាហកម្មឆ្នាំ២០១៩-២០៣០។ ឆ្នាំ២០២០ សហគមន៍កសិកម្មចំនួន២៩២សហគមន៍ ក្រុមកសិករ និងក្រុមបណ្តុំអាជីវកម្មផ្សេងទៀតបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនចំនួន៩៣៦កិច្ចសន្យា និងឆ្នាំ២០២១ មានសហគមន៍កសិកម្មចំនួន១១សហគមន៍ ក្រុមកសិករ និងក្រុមបណ្តុំអាជីវកម្មផ្សេងទៀតបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនបានចំនួន១៣៦កិច្ចសន្យា។ ទន្ទឹមនឹងនេះ ក្រសួងក៏បានពង្រឹងការងារមន្ទីរពិសោធន៍ ដោយបានរៀបចំកម្រែសេវាកម្មវិភាគគុណភាព សុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារ ពង្រឹងសមត្ថភាពមន្ទីរពិសោធន៍ដើម្បីទទួលបានអនុលោមភាពក្នុងកម្រិតស្តង់ដា១៧០២៥។

### ២.១.៦- ការបង្កើនផលិតភាពដំណាំកៅស៊ូ

ផ្ទៃដីដំណាំកៅស៊ូឆ្នាំ២០២២សរុបមានចំនួន៤០៤ ០៤៤ហ.ត. បើប្រៀបធៀបទៅនឹងឆ្នាំ២០១៨ ដែលមានចំនួន៤៣៦ ៦៨២ហ.ត. គឺថយចុះចំនួន៣២ ៦៣៨ហ.ត. ស្មើនឹង៧,៤៧%។ ការថយចុះផ្ទៃដីនេះ ភាគច្រើន

កើតមាននៅលើក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដោយក្រុមហ៊ុនមួយចំនួនបានផ្លាស់ប្តូរមុខដំណាំ ព្រោះដីមិនសមស្របនឹងដំណាំកៅស៊ូ និងក្រុមហ៊ុនមួយចំនួនទៀតគ្រប់គ្រងចៃទាំកៅស៊ូមិនបានល្អ និងដោយសារភ្លើងឆេះនៅរដូវប្រាំង។ ផ្ទៃដីកៅស៊ូត្រូវបានបែងចែកជា២ផ្នែក គឺក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម(ផ្ទៃដីអតីតចម្ការកៅស៊ូរដ្ឋ និងផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) មានចំនួនសរុប២៤០ ៣៤៦ ហ.ត. ស្មើនឹង៥៩,៥% និងផ្ទៃដីចម្ការកៅស៊ូគ្រួសារមានចំនួន១៦៣ ៦៩៨ហ.ត. ស្មើនឹង៤០,៥%។ ផ្ទៃដីចៃទាំមានចំនួន៩៣ ៨៥១ហ.ត. ស្មើនឹង២៣,៣% និងផ្ទៃដីយកផលមានចំនួន៣១០ ១៩៣ហ.ត. ស្មើនឹង៧៦,៧%។

ផ្ទៃដីចម្ការកៅស៊ូគ្រួសារបានកើនពី១៦១ ១០៣ហ.ត. នៅឆ្នាំ២០១៨ ដល់១៦៨ ៦៩៨ហ.ត. នៅឆ្នាំ២០២២(កើនឡើងចំនួន៧ ៥៩៥ហ.ត. ស្មើនឹង៤,៧%)។ ផ្ទៃដីក្រុមហ៊ុនចម្ការកៅស៊ូកសិឧស្សាហកម្ម(ផ្ទៃដីអតីតចម្ការកៅស៊ូរដ្ឋ និងផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) បានថយចុះពី២៧៥ ៥៧៩ហ.ត. នៅឆ្នាំ២០១៨ ដល់២៤០ ៣៤៦ហ.ត. នៅរយៈពេល៥ខែដើមឆ្នាំ២០២២(ថយចុះចំនួនសរុប៣៥ ២៣៣ហ.ត. ស្មើនឹង១២,៨%)។

**តារាងទី៥ ផលិតកម្មដំណាំកៅស៊ូពីឆ្នាំ២០១៨-២០២២ (ហ.ត.)**

| ឆ្នាំ | ចម្ការកៅស៊ូកសិឧស្សាហកម្ម | | | ចម្ការកៅស៊ូគ្រួសារ ឯកជន | | | សរុបរួម | | |
|---|---|---|---|---|---|---|---|---|---|
| | ផ្ទៃដីយកផល | ចៃទាំ | សរុប | ផ្ទៃដីយកផល | ចៃទាំ | សរុប | ផ្ទៃដីយកផល | ចៃទាំ | សរុប |
| ២០១៨ | ៨២ ១១២ | ១៩៣ ៤៦៧ | ២៧៥ ៥៧៩ | ១១៩ ៨៣៧ | ៤១ ២៦៦ | ១៦១១០៣ | ២០១ ៩៤៩ | ២៣៤ ៧៣៣ | ៤៣៦ ៦៨២ |
| ២០១៩ | ១១៧ ២០៨ | ១២៧ ៣៦០ | ២៤៤ ៥៦៨ | ១៣៣ ២៦៩ | ២៧ ៨៣៤ | ១៦១ ១០៣ | ២៥០ ៤៧៧ | ១៥៥ ១៩៤ | ៤០៥ ៦៧១ |
| ២០២០ | ១៤២ ៧៤៦ | ១០០ ២៥៤ | ២៤៣ ០០០ | ១៤៩ ៧៥០ | ១១ ៤១០ | ១៦១១៦០ | ២៩២ ៥០០ | ១១១ ៦៦០ | ៤០៤ ១៦០ |
| ២០២១ | ១៥៦ ៩៤៤ | ៨៣ ៤០៣ | ២៤០ ៣៤៧ | ១៥៣ ២៥០ | ១០ ៤៤៨ | ១៦៣ ៦៩៨ | ៣១០ ១៩៣ | ៩៣ ៨៥១ | ៤០៤ ០៤៤ |
| ២០២២ | ១៥៦ ៩៤៤ | ៨៣ ៤០៣ | ២៤០ ៣៤៧ | ១៥៣ ២៥០ | ១០ ៤៤៨ | ១៦៣ ៦៩៨ | ៣១០១៩៣ | ៩៣ ៨៥១ | ៤០៤ ០៤៤ |

ការនាំចេញផលិតផលកៅស៊ូនៅឆ្នាំ២០២១ សម្រេចបានចំនួន៣៦៦ ៣០០តោន ទទួលបានទឹកប្រាក់ចំនួន៦១០ ២៥៥ ៨០០ដុល្លារអាម៉េរិក បើធៀបនឹងឆ្នាំ២០១៨ ការនាំចេញមានចំនួន២១៧ ៥០០តោន ទទួលបានទឹកប្រាក់ចំនួន២៨៦ ៩៤៤ ៥២៨ដុល្លារអាម៉េរិក មានការកើនឡើងចំនួន១៤៨ ៨០០តោន ស្មើ១៣,៩%។ តម្លៃកៅស៊ូនាំចេញនៅកម្ពុជាឆ្នាំ២០២១ ជាមធ្យម១ ៦៦៦ដុល្លារអាម៉េរិកក្នុងមួយតោន បើធៀបនឹងឆ្នាំ២០២០ តម្លៃមធ្យម១ ៣៨២ដុល្លារអាម៉េរិកក្នុងមួយតោន មានការកើនឡើង២៨៤ដុល្លារសហរដ្ឋអាម៉េរិកក្នុងមួយតោន ស្មើនឹង២១%។ ឆ្នាំ២០២១ ការនាំចេញឈើកៅស៊ូចំនួន៦ ២៩២ម.$^{៣}$ ទទួលបានទឹកប្រាក់ចំនួន១ ៥១៥ ០១៤,៨៤ ដុល្លារអាម៉េរិក។ ឆ្នាំ២០២២ ការនាំចេញផលិតផលកៅស៊ូមានចំនួន១០៥ ០៤៨តោន ទទួលបានទឹកប្រាក់ចំនួន ១៦៨ ៤៦៨ ៦៤០ដុល្លារសហរដ្ឋអាម៉េរិក និងការនាំចេញឈើកៅស៊ូពីការកាប់ដើមកៅស៊ូចាស់ៗចំនួន១២ ០៨១ម.$^{៣}$ ទទួលបានទឹកប្រាក់ចំនួន១ ៨១៣ ៣៩១ដុល្លារអាម៉េរិក។

ការងារស្រាវជ្រាវដំណាំកៅស៊ូ ការអភិវឌ្ឍពូជកៅស៊ូ ការងារដែលបានអនុវត្តនៅក្នុងផ្នែកបង្កាត់ពូជសំដៅធ្វើសុវត្ថិកម្មក្លូនកៅស៊ូតាមរយៈការនាំចូល ការប្តូរក្លូនជាមួយនឹងបណ្តាប្រទេសជាសមាជិកIRRDB ការបង្កាត់និងធ្វើជម្រើសពូជ ការពង្រឹងគុណភាពរុក្ខសម្ភារៈ ជាពិសេសការគ្រប់គ្រងច្បារពូជ ការអភិវឌ្ឍក្លូនកៅស៊ូកម្ពុជានិងការផ្តល់ជាអនុសាសន៍ក្លូនកៅស៊ូសម្រាប់ការដាំដុះតាមដំណាក់កាល ឆ្លើយតបទៅនឹងលក្ខខណ្ឌភូមិសាស្ត្រ

តាមតំបន់ ក្នុងគោលបំណងបង្កើននូវផលិតភាព បង្កើននូវចំណូលដល់អ្នកដាំដុះកៅស៊ូ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

**២.១.៧- ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យាកសិកម្ម**

វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា បានអនុវត្តសកម្មភាពការងារបានលទ្ធផលសម្រេចបានលេចធ្លោចម្បងៗ មានដូចខាងក្រោមៈ

**ក- ការងារសម្ភារកម្មនិងអភិរក្សកម្មពូជដំណាំ** ពូជដំណាំចំនួន៧៤០សំណាក ត្រូវបានប្រមូលបន្ថែមលើពន្ធុដំណាំដែលបាននិងកំពុងអភិរក្សក្នុងធនាគារពន្ធុដំណាំកើនឡើងដល់៩ ១១៦បញ្ជិក។ ទន្ទឹមនេះ ពូជស្រូវកម្ពុជាចំនួន៤ ៨៩៧បញ្ជិក បាននិងកំពុងរក្សាទុករយៈពេលយូរនៅធនាគារពន្ធុនៃវិទ្យាស្ថានអន្តរជាតិស្រាវជ្រាវដំណាំស្រូវដែលមានមូលដ្ឋាននៅឯប្រទេសហ្វីលីពីន និងមួយផ្នែកទៀតចំនួន២១៤បញ្ជិក ដែលបានអភិរក្សនៅធនាគារពន្ធុនៅប្រទេសកូរ៉េខាងត្បូង។

**ខ- ការងារអភិវឌ្ឍពូជថ្មីនៃដំណាំ និងការបញ្ចេញឱ្យកសិករនិងគ្រប់អ្នកពាក់ព័ន្ធប្រើប្រាស់**ពូជស្រូវផ្កាមាលតី ពូជស្រូវសែនក្រអូប១ និងពូជសណ្តែកដីខេប១ត្រូវបានបញ្ចេញជាផ្លូវការ បាននិងកំពុងស្នើសុំបញ្ចេញពូជស្រូវស្រាលដែលមានអាយុកាលខ្លីជាង១០០ថ្ងៃ មានក្លិនក្រអូបឈ្ងុយហើយមានសក្តានុពលទីផ្សារនៅចុងឆ្នាំ២០២២។

**គ- ការងារផលិតកម្មគ្រាប់ពូជស្រូវតាមចំណាត់ថ្នាក់បរិសុទ្ធភាព** ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះផលិតកម្មគ្រាប់ពូជស្រូវរួមមានគ្រាប់ពូជគ្រឹះ គ្រាប់ពូជវិញ្ញាបនបត្រនិងគ្រាប់ពូជសុទ្ធល្អនៃពូជស្រូវផ្ការំដួល សែនពិដោរ រាំងជ័យ ផ្ការមៀត ផ្ការំដេង ផ្កាចន្ទសែនសរ អ៊ីអ៊ែ៦៦ ជលសារ ដំណើបស្បៃមង្គល ខា៨ ខា១៤ ខា១៥ ខា១៦ ផ្កាមាលតី និងសែនក្រអូប១ សរុបចំនួន២៨២តោន ត្រូវបានផលិតនិងប្រើប្រាស់នៅទូទាំងប្រទេស។

**ឃ- ការងារផ្សព្វផ្សាយរបកគំហើញបច្ចេកទេសវិទ្យាសាស្ត្រកសិកម្ម** កសិករសរុប៨ ៩៩៨នាក់ត្រូវបានបណ្តុះបណ្តាលទេពកោសល្យផ្នែកផលិតភាពកសិកម្ម តាមរយៈការធ្វើពិសោធន៍ ការធ្វើទិវាស្រែបង្ហាញ ការចែកផ្សាយព្រឹត្តិបត្រព័ត៌មានកសិករ និងការប្រឹក្សាក្នុងគេហទំព័ររបស់វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា។

**ង- ការងារធ្វើវិភាគសមាសភាគជីវជាតិមានគុណប្រយោជន៍ផ្នែកចំណីអាហារ នៅក្នុងគ្រាប់អង្កររបស់ប្រភេទពូជស្រូវមួយចំនួនមាន**អង្ករសម្រិតនិងអង្ករសម្រូបរបស់ពូជស្រូវផ្ការំដួល ផ្ការមៀត ផ្ការំដេង សែនពិដោរ និងផ្កាចន្ទសែនសរ និងអង្ករសម្រិតរបស់ពូជស្រូវដំណើបស្បៃមង្គលត្រូវបានយកទៅធ្វើការវិភាគផ្នែកអាហារូបត្ថម្ភ(Nutrition value) នៅមន្ទីរពិសោធន៍បរទេសស្តង់ដាអន្តរជាតិ។ លទ្ធផលនេះត្រូវបានបង្ហោះនៅក្នុងគេហទំព័ររបស់វិទ្យាស្ថាន(www.cardi.org.kh) សម្រាប់អ្នកពាក់ព័ន្ធយកទៅប្រើប្រាស់។

## ២.២- ការលើកកម្ពស់សុខភាពសត្វនិងផលិតកម្មសត្វ

អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅតែដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកធ្វើឱ្យប្រសើរឡើងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ កំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ ព្រមទាំងបង្កើតការងារ សន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់ប្រជាពលរដ្ឋកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦នៃរដ្ឋសភា ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានដាក់បញ្ចូលវិស័យកសិកម្ម ក្នុងចតុកោណទី៤ មុំទី១ ចំណុចអាទិភាពទី៧ ចែងពីការជំរុញ

ការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដើម្បីលើកកម្ពស់ការចិញ្ចឹមសត្វឱ្យកាន់តែមានលក្ខណៈទូលំទូលាយថែមទៀតតាមរយៈការបង្កើតក្របខ័ណ្ឌគោលនយោបាយ ផ្អែកលើខ្សែច្រវាក់តម្លៃ និងដោះស្រាយជាកញ្ចប់នូវឧបសគ្គដល់ការអនុវត្តអនុវិស័យនេះ ជាមួយការគិតគូរដល់បញ្ហាសុវត្ថិភាពចំណីអាហារលើកទឹកចិត្តដល់ការវិនិយោគរោងចក្រផលិតចំណីសត្វ កែលម្អការគ្រប់គ្រងសត្តឃាតដ្ឋាន អនាម័យសត្វ សាច់ និងផលិតផលសត្វ ដំណើរការទីផ្សារ ជាពិសេសអនាម័យ និងភូតគាមអនាម័យ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ បានកំណត់នូវទិសដៅជំរុញផលិតផលសាច់ក្នុងអត្រាកំណើន៣%ក្នុងមួយឆ្នាំ តាមរយៈការគ្រប់គ្រងនិងអភិវឌ្ឍការចិញ្ចឹមសត្វ កាត់បន្ថយហានិភ័យ ពង្រឹងការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលសត្វ។

**២.២.១- ការជំរុញការចិញ្ចឹមសត្វនិងបង្កើនផលិតភាពសត្វ**

**ក- ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ**

ឆ្នាំ២០១៨ ការចិញ្ចឹមសត្វលក្ខណៈគ្រួសារសរុបមានចំនួន៣៤,៤៧លានក្បាល កើនដល់៣៩,៣០លានក្បាល នៅឆ្នាំ២០២២ ដែលក្នុងនោះមានគោចំនួន២,៩៨លានក្បាល ក្របីចំនួន៤៣,៤៧ពាន់ក្បាល ជ្រូកចំនួន១,៣១លានក្បាល និងបក្សីចំនួន៣៤,៥២លានក្បាល។

បើប្រៀបធៀបឆ្នាំ២០២១និងឆ្នាំ២០២២ ស្ថិតិសត្វចិញ្ចឹមលក្ខណៈគ្រួសារសរុបកើនឡើងចំនួន៧,៤៥% ក្នុងនោះគោកើនចំនួន១% ក្របីកើន០,៥% ជ្រូកកើន៥% បក្សីកើន៨,២៥% ចៀមកើន២% និងពពែកើន២%។ ជារួមក្នុងរយៈពេល៥ឆ្នាំនេះ ការចិញ្ចឹមសត្វលក្ខណៈគ្រួសារមានអត្រាកំណើនជាមធ្យម២,៨២%ក្នុងមួយឆ្នាំ។

**ខ- ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម**

ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានការកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនពី១០,០៣លានក្បាល នៅឆ្នាំ២០១៨ ដល់២៦,៩០លានក្បាលនៅឆ្នាំ២០២២ ដែលក្នុងនោះគោ១៥,៣៧ពាន់ក្បាល ក្របី១៥០ក្បាល ជ្រូក១,៨៥លានក្បាល បក្សី២៤,៨២លានក្បាលចៀម១ ៨៩៩ក្បាល ពពែ១ ១៦១ក្បាល និងស្វាចំនួន៧០,០៤ពាន់ក្បាល។ ក្នុងឆ្នាំ២០២១នេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានមកំណើន១៥,០៤% ក្នុងនោះគោកើន ៥% ក្របីកើន២% ជ្រូកកើន១២,៥០% បក្សីកើន១៥,៣០% ចៀមកើន៥,៥% ពពែកើន១០% និងស្វាកើន ៣%។ ជារួមក្នុងរយៈពេល៥ឆ្នាំផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មកើនជាមធ្យម២៦,៦៧%ក្នុងមួយឆ្នាំ។ អត្រានៃកំណើនផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មនេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីការផ្លាស់ប្តូរបែបផែនផលិតកម្មសត្វជាវិជ្ជមាន ដើម្បីឈានទៅកែលម្អផលិតភាពសត្វ និងប្រសិទ្ធភាពសេដ្ឋកិច្ចឱ្យកាន់តែល្អប្រសើរឡើង។

**គ- ផលិតកម្មសត្វសរុប(លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម)**

ផលិតកម្មសត្វគ្រប់ប្រភេទមានការកើនឡើងពី៤៤,៣៧លានក្បាលនៅឆ្នាំ២០១៨ ដល់៦៥,២១លានក្បាល នៅឆ្នាំ២០២២ ដែលក្នុងនោះគោមានចំនួន៣,០៦លានក្បាល ក្របីចំនួន៤៤,៧៩ពាន់ក្បាល ជ្រូក ៣,៤៣លានក្បាល បក្សី៥៨,១៥លានក្បាល ចៀម៤ ៤៤២ក្បាល ពពែ៤៤,៥១ពាន់ក្បាល ដំរី៤៩ក្បាល ស្វាចំនួន៧០,២០ពាន់ក្បាល និងទន្សាយចំនួន៥៤៦ក្បាល។

ធៀបឆ្នាំ២០២១ ក្នុងឆ្នាំ២០២២នេះ ផលិតកម្មសត្វសរុបកើន១០,៤១% ក្នុងងនោះគោ១,០២% ក្របី ០,៥%ជ្រូក៩,៣៩% បក្សី១១,០៩% ចៀម៣,៤៧% ពពែ២,១៩% និងស្វា២,៩៩%។

# តារាងទី១ ស្ថិតិផលិតកម្មសត្វសរុបតាមបែបផែនផលិតកម្មពីឆ្នាំ២០១៨ដល់ឆ្នាំ២០២២

| លរ | បែបផែនផលិតកម្មសត្វ | ផលិតកម្មសត្វសរុបតាមបែបផែនផលិតកម្ម (២០១៨-២០២២) | | | | |
|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
| ១ | លក្ខណៈគ្រួសារ | ៣៤ ៣៣៩ ៨១០ | ៣២ ០៤៣ ៥៣៥ | ៣៤ ៩៨៣ ៧៤០ | ៣៦ ៥៧៦ ៦២២ | ៣៨ ៦៤៥ ៤៦៩ |
| ២ | លក្ខណៈពាណិជ្ជកម្ម | ១០ ០៣៥ ៥៨៥ | ១៣ ៨១១ ៦០៨ | ១៨ ៩២០ ០៧៧ | ២៣ ៣៨៥ ០៣៤ | ២៦ ៥៦០ ៤៧៣ |
| សរុប | | ៤៤ ៣៧៥ ៣៩៥ | ៤៥ ៨៥៥ ១៤៣ | ៥៣ ៩០៣ ៨១៧ | ៥៩ ៩៦១ ៦៥៦ | ៦៦ ២០៦ ១០៤ |

**ឃ- តម្រូវការសត្វនិងសាច់**

តាមរបាយការណ៍របស់អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិបញ្ជាក់ថា ការបរិភោគសាច់សត្វនៅព្រះរាជាណាចក្រកម្ពុជាសម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំហូបសាច់ជាមធ្យមប្រមាណ១៧,៦០គ.ក្រ. ក្នុងនោះសាច់គោ ក្របី៥គ.ក្រ. សាច់ជ្រូក៩,២៩គ.ក្រ. សាច់បក្សី៣,៣គ.ក្រ. និងសាច់សត្វផ្សេងៗទៀត០,០១គ.ក្រ.។

ដោយសារតែកំណើនប្រជាពលរដ្ឋក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ តម្រូវការសាច់សត្វសម្រាប់បរិភោគមានការកើនឡើងពី២៨៥ពាន់តោនក្នុងឆ្នាំ២០១៨ ដល់៣១០ពាន់តោន ក្នុងឆ្នាំ២០២១។ ជាក់ស្តែងផលិតកម្មសត្វក្នុងស្រុកមានលទ្ធភាពផ្គត់ផ្គង់បានក្នុងរង្វង់៨១%(២៣១ពាន់តោន) នៅឆ្នាំ២០១៨ ដល់៨៧%(២៦៩ពាន់តោន) នៅឆ្នាំ២០២១។ ដោយឡែកក្នុងឆ្នាំ២០២២នេះ តម្រូវការសាច់សម្រាប់បរិភោគចំនួន៣១០ពាន់តោន តាមការប៉ាន់ប្រមាណលទ្ធភាពអាចផ្គត់ផ្គង់បានប្រមាណ២៨៥ពាន់តោន ស្មើនឹង៩២%។ ជាក់ស្តែងរយៈពេល៦ខែដើមឆ្នាំ២០២២ តម្រូវការសាច់បរិភោគចំនួន១៥២ពាន់តោន ឯការផ្គត់ផ្គង់សាច់បានចំនួន១៤០ពាន់តោន ស្មើនឹង៩២%។

**ង- អំពីចំណីសត្វ**

ដើម្បីបង្កើនផលិតកម្មសត្វ អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ បានរៀបចំកម្មវិធីកែលម្អចំណីសត្វ ដោយធ្វើការផ្សព្វផ្សាយពូជស្មៅដែលសំបូរទៅដោយសារជាតុចិញ្ចឹមនិងផ្តល់ទិន្នផលខ្ពស់។ គិតត្រឹមរយៈពេល៩ខែដើមឆ្នាំ២០២២នេះ បានពង្រីកកម្មវិធីដាំដំណាំចំណីសត្វ នៅទូទាំងរាជធានី ខេត្ត មានកន្លែងធ្វើបង្ហាញស្មៅចំណីសត្វសរុបចំនួន២ ៦៤៩កន្លែង លើផ្ទៃដីចំនួន១ ៨៥២,៩៤ហ.ត. និងរុក្ខជាតិចំណីសត្វចំនួន២៨កន្លែង លើផ្ទៃដីចំនួន៨២,០៥តោន។

បច្ចុប្បន្ន មានក្រុមហ៊ុនដែលបានវិនិយោគសាងសង់រោងចក្រផលិតចំណីសត្វមានចំនួន២១ក្រុមហ៊ុន ដែលមានរោងចក្រផលិតចំណីសត្វចំនួន២៤រោងចក្រ ដែលមានសមត្ថភាពផលិតចំណីសត្វបានចំនួន២,៣១លានតោន ក្នុងមួយឆ្នាំ។ គិតត្រឹម៦ខែដើមឆ្នាំ២០២២នេះ ផលិតចំណីសត្វបានចំនួន៧០៤ ៥៩៦តោនស្មើនឹង៣០% នៃសមត្ថភាពផលិតប្រចាំឆ្នាំ។

**២.២.២- ការលើកកម្ពស់សុខភាពសត្វនិងសុខភាពសាធារណៈបសុព្យាបាល**

**ក- ការលើកកម្ពស់សុខភាពសត្វ**

ក្រសួងបានធ្វើយុទ្ធនាការចាក់ថ្នាំការពារជំងឺឆ្លងសំខាន់ៗលើសត្វគោ ក្របី ជ្រូក មាន់ ទា និងសត្វចិញ្ចឹមផ្សេងៗទៀតនៅទូទាំងប្រទេស។ ដោយឡែកសត្វគោ ក្របីបានចាក់ថ្នាំការពារជំងឺឆ្លងមួយចំនួនដូចជា ជំងឺអុតក្តាម

បូសខ្យល់និងជំងឺសារទឹក ព្រមទាំងជំងឺដុំពកស្បែក។ ក្នុងរយៈពេល៩ខែដើមឆ្នាំ២០២២នេះ បានចាក់ថ្នាំការពារជំងឺសត្វគោ ក្របីសរុបចំនួន៨៤៧ ៣៤៣ក្បាល ក្នុងនោះចាក់វ៉ាក់សាំងសារទឹកចំនួន៦៦៥ ៤៦៧ក្បាល វ៉ាក់សាំងអុតក្ដាមចំនួន៤៩ ៩០៧ក្បាល បូសខ្យល់ចំនួន២៣ ៤៤៣ក្បាល និងវ៉ាក់សាំងដុំពកស្បែកគោ ក្របីចំនួន ១០៨ ៥២៦ក្បាល ព្រមទាំងបានអនុវត្តជីវសុវត្ថិភាពនៅទូទាំងប្រទេស នៅកន្លែងចិញ្ចឹមសត្វ ទីផ្សារ ភូមិដ្ឋាន សត្តឃាតដ្ឋាន ផ្លូវជាតិ និងកន្លែងផ្ទុះជំងឺសរុបចំនួន១៤៧ ៥៦០លើក។

**ខ- ការពង្រឹងសុខភាពសាធារណៈបសុព្យាបាល**

គិតត្រឹម៩ខែដើមឆ្នាំ២០២២នេះ សត្តឃាតដ្ឋានមានចំនួន**២៣៣កន្លែង** ក្នុងនោះសត្តឃាតដ្ឋានអនុលោមតាមអនុក្រឹត្យលេខ១០៨ មានចំនួន១១៩កន្លែង សត្តឃាតដ្ឋានអនុលោមតាមអនុក្រឹត្យលេខ១០៨ និងវិនិយោគមានចំនួន៦៤កន្លែង និងសត្តឃាតដ្ឋានវិនិយោគទុនសុទ្ធមានចំនួន៥០កន្លែង។ ទោះបីជាសត្តឃាតដ្ឋានមានការកើនឡើងជាលំដាប់ក៏ដោយ ក៏អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វបានខិតខំរៀបចំសត្តឃាតដ្ឋានទាំងនោះឱ្យអនុវត្តអនាម័យស្របតាមបទដ្ឋានបច្ចេកទេស។

## ២.៣- ការគ្រប់គ្រងនិងអភិវឌ្ឍន៍ព្រៃឈើនិងសត្វព្រៃ

ធនធានព្រៃឈើ បានផ្តល់សារប្រយោជន៍យ៉ាងច្រើនក្រៃលែងដល់សង្គមជាតិយើងតាំងពីដើមហូតមកដល់បច្ចុប្បន្ននិងទៅអនាគត។ ព្រៃឈើពុំគ្រាន់តែមានតម្លៃសម្រាប់រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់តម្លៃខ្ពស់មិនអាចប៉ាន់ប្រមាណបានលើផ្នែកថែរក្សាការពារលំនឹងបរិស្ថានធម្មជាតិធ្វើឱ្យធាតុអាកាសមានភាពកាន់តែប្រសើរឡើងនិងខ្យល់បរិសុទ្ធ រក្សាបាននូវនិយ័តភាពប្រភពទឹកសម្រាប់ការធ្វើកសិកម្ម ការពារទីជម្រាលនិងជីវចម្រុះ ទ្រទ្រង់និងលើកកម្ពស់ជីវភាពរស់នៅសម្រាប់ប្រជាពលរដ្ឋដែលពឹងអាស្រ័យផលទៅលើផល អនុផលព្រៃឈើ និងជាប្រភពការពារភពផែនដីយើង ជីវិតយើង។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើការអនុវត្តកម្មវិធីកែទម្រង់វិស័យព្រៃឈើជាបន្តបន្ទាប់ ជាពិសេសបានដាក់ចេញនូវយុទ្ធសាស្រ្តច្បាស់លាស់ក្នុងគោលដៅដើម្បីលើកកម្ពស់ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើនិងសត្វព្រៃឱ្យមាននិរន្តរភាព។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ នឹងអាចសម្រេចបានគឺអាស្រ័យដោយមានការគ្រប់គ្រងផ្អែកលើចក្ខុវិស័យច្បាស់លាស់និងការអនុវត្តនូវបេសកកម្មចម្បងៗចំនួនបីគឺ (១) គ្រប់គ្រងធនធានព្រៃឈើសត្វព្រៃប្រកបដោយនិរន្តរភាព ដើម្បីផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន (២) ផ្តល់សេវាកម្មបច្ចេកទេសមានភាពទំនើប វិទ្យាសាស្រ្ត នវានុវត្តន៍ និងវិធានសមស្រប ដើម្បីអភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃប្រកបដោយប្រសិទ្ធផលខ្ពស់ និង(៣) អភិវឌ្ឍធនធានព្រៃឈើនិងសត្វព្រៃ ក្នុងនោះផ្តោតសំខាន់លើការបង្កើនការដាំឈើ និងឧស្សាហកម្មឈើ។

ទោះបីស្ថិតក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ១៩ ដែលបានអូសបន្លាយរហូតដល់ពេលបច្ចុប្បន្ន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានរដ្ឋបាលព្រៃឈើជាអង្គភាពប្រតិបត្តិផ្ទាល់ បានខិតខំបន្តអនុវត្តផែនការសកម្មភាពជាច្រើនដើម្បីរួមចំណែកដល់ការគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានព្រៃឈើដោយសម្រេចបាននូវសមិទ្ធផលសំខាន់ៗរួមមានៈ

### ២.៣.១- គម្របព្រៃឈើនិងសហគមន៍ព្រៃឈើ

នៅឆ្នាំ២០១៨ ផ្ទៃដីគម្របព្រៃឈើមានទំហំសរុប៨ ៥២៩ ៣៧២ហ.ត. ស្មើនឹង៤៦,៩៧% នៃផ្ទៃដីសរុប។ គិតពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២នេះ ក្រសួងបានចេញប្រកាសបង្កើតសហគមន៍ព្រៃឈើថ្មីចំនួន ៣០សហគមន៍

គ្របដណ្តប់លើផ្ទៃដី៦ ៧០៣ហ.ត.។ សូមបញ្ជាក់ថានាពេលបច្ចុប្បន្ននេះសហគមន៍ព្រៃឈើសរុបមានចំនួន៦៤៤សហគមន៍ គ្របដណ្តប់លើផ្ទៃដី៥២២ ៥០៥ហ.ត. ក្នុងនោះក្រសួងបានចេញប្រកាសចំនួន៥៣៧សហគមន៍លើផ្ទៃដី៤៤៩ ៧០៧ហ.ត. និងបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន៤៥៣សហគមន៍ លើផ្ទៃដី៣៧៧ ៧២២ហ.ត. លើសពីនេះបានអនុម័តផែនការគ្រប់គ្រងព្រៃសហគមន៍ចំនួន១០៦សហគមន៍ គ្របដណ្តប់លើផ្ទៃដីទំហំ៧២ ៦២១ហ.ត.។ ជាមួយគ្នានេះ បាននិងកំពុងយកចិត្តទុកដាក់លើការបង្កើតមុខរបរបន្ថែមដល់ប្រជាសហគមន៍ក្នុងការបង្កើនចំណូល លើកកម្ពស់ជីវភាពរស់នៅតាមរយៈការអនុវត្តប្រព័ន្ធកសិរុក្ខកម្ម និងការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យផលលើផលនិងអនុផលព្រៃឈើ។

**២.៣.២- ការងារដាំឈើ**

ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២នេះគឺ បានថែទាំចម្ការឈើចាស់ទំហំ៦៥២ហ.ត. ចម្ការពូជឈើទំហំ៩៤ហ.ត. និងឡូត៍បង្ហាញកសិរុក្ខកម្មទំហំ៣៩ហ.ត. និងបានដាំឈើជាចម្ការថ្មីទំហំ២៦ ៤៣៧ហ.ត. និងបានដឹកប្រឡាយការពារចម្ការឈើគ្រញូង និងតំបន់ប្រភពគ្រាប់ពូជឈើគ្រញូងប្រវែងសរុប៣៤ ០០០ម. នៅក្នុងខេត្តកំពង់ធំ ព្រះសីហនុ ស្វាយរៀង និងខេត្តសៀមរាប។ ជាមួយគ្នានេះ បានរៀបចំបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ដោយគិតមកទល់នឹងពេលបច្ចុប្បន្នមានចំនួន៨៤ទីតាំង លើផ្ទៃដីសរុបចំនួន៥០៣ ៥០១ ហ.ត. ក្នុងនោះ ២១ទីតាំង មានបណ្ណកម្មសិទ្ធិលើផ្ទៃដីទំហំ១០៦ ៩២២ហ.ត. ដើម្បីត្រៀមរៀបចំ និងជំរុញនូវការចូលរួមវិនិយោគរបស់វិស័យឯកជននិងដៃគូពាក់ព័ន្ធនានា លើការងារដាំដុះព្រៃឈើជានាបាននូវនិរន្តរភាពការប្រើប្រាស់ក្នុងស្រុក និងផ្គត់ផ្គង់ដល់ការនាំចេញឈើដាំនាពេលអនាគត។ សព្វថ្ងៃនេះមានការដាំឈើជាលក្ខណៈក្រុមហ៊ុនដៃគូសហការ និងលក្ខណៈគ្រួសារចំនួន២០ទីតាំង លើផ្ទៃដីសរុបចំនួន៨១ ៨០៥ហ.ត. និងគម្រោងដាំឈើក្នុងសម្បទានដីសេដ្ឋកិច្ចមានចំនួន១៧ក្រុមហ៊ុន លើផ្ទៃដីចុះកិច្ចសន្យាទំហំ២៨០ ៨៧០ហ.ត.។ លើសពីនេះបានបន្តជំរុញការផ្សព្វផ្សាយ និងលើកទឹកចិត្តឱ្យមានការចូលរួមដាំឈើតាមទីតាំងផ្សេងៗដូចជា ទីសាធារណៈ សាលារៀន វត្តអារាម លំនៅដ្ឋាន។ល។ ពិសេសបានធ្វើការរៀបចំនូវពិធីរុក្ខទិវាថ្នាក់ជាតិ និងតាមបណ្តារាជធានី ខេត្ត។

**២.៣.៣- ការងារគ្រប់គ្រងផល អនុផលព្រៃឈើ និងឧស្សាហកម្មឈើ**

រដ្ឋបាលព្រៃឈើបានយកចិត្តទុកដាក់ខ្ពស់លើការផ្តល់បណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត និងយានយន្ត ព្រមទាំងបានពិនិត្យយ៉ាងហ្មត់ចត់លើការផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ ផ្តល់ការអនុញ្ញាតបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ(ច្រកចេញចូលតែមួយ) ការពិនិត្យ និងអនុញ្ញាតបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើ ឡធ្យូង និងការផ្តល់ទិដ្ឋាការអាជ្ញាបណ្ណនាំចេញ នាំចូលផងដែរ។ បចុប្បន្ននេះ រោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ(ច្រកចេញចូលតែមួយ) ចំនួន៣៤កន្លែង រោងម៉ាស៊ីនអារកែច្នៃឈើ ផលិតគ្រឿងសង្ហារិមនិងឡធ្យូង ដែលបានបង្កើតនិងពន្យារសុពលភាពមានចំនួន១៩កន្លែង និងរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ និងរោងសន្និធិលក់គ្រឿងសង្ហារិមប្រភេទតូចទទួលបានការអនុញ្ញាតពីខណ្ឌរដ្ឋបាលព្រៃឈើរាជធានី/ខេត្ត មានចំនួន៨០៨កន្លែង។ លើសពីនេះ បានបន្តកិច្ចខិតខំប្រឹងប្រែងពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់ ពិសេសការត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងចាត់វិធានការម៉ឺងម៉ាត់ចំពោះការទប់ស្កាត់និងលុបបំបាត់ការកាប់បំផ្លាញព្រៃឈើ ការទន្ទ្រានយកដីព្រៃធ្វើជាកម្មសិទ្ធិ និងការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទ ដែលគ្មានការអនុញ្ញាត។

**១.៣.៤- ការងារស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ**

បានចុះអន្តរាគមន៍ទប់ស្កាត់និងបង្ក្រាបការជួញដូរសត្វព្រៃ ការដោះអន្ទាក់សត្វព្រៃ ការចុះសិក្សាស្រាវជ្រាវ និងធ្វើការតាមដានវត្តមានសត្វព្រៃ និងជំរុញការចុះបញ្ជិកាថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារ។ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២នេះ បានធ្វើការចុះបញ្ជិកាការចិញ្ចឹមសត្វត្រចៀកកាំបានចំនួន៣២១ទីតាំង និងការចិញ្ចឹមសត្វព្រៃផ្សេងៗបានចំនួន៨៩ទីតាំង។ លើសពីនេះបាននិងកំពុងថែរក្សានិងសង្គ្រោះសត្វព្រៃដែលទទួលបានពីតំបន់នានា ព្រមទាំងធ្វើការស្តារលទ្ធភាពជីវសាស្ត្ររួចលែងទៅព្រៃធម្មជាតិវិញ។ តាមទិន្នន័យចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២នេះ នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅបង្ហាញថា បានទទួលសត្វព្រៃយកមកសង្គ្រោះ និងព្យាបាលចំនួន៨ ១៨៧ក្បាល និងបានធ្វើការបង្កាត់ពូជប្រភេទសត្វព្រៃងាយរងគ្រោះបានកូនចំនួន៥២១ក្បាល ព្រមទាំងស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃនិងលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃចំនួន៥ ២៨១ក្បាល។

ទន្ទឹមនឹងការវិត្តទៅមុខឥតឈប់ឈរស្របតាមនិន្នាការជាសកលនៃការគ្រប់គ្រងព្រៃឈើ និងការអភិវឌ្ឍនូវបច្ចេកទេសថ្មីៗ ក្នុងដំណាក់កាលនៃសកលភាវូបនីយកម្ម រដ្ឋបាលព្រៃឈើបានបន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ កិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីក្នុងការរៀបចំគម្រោងសម្រាប់អនុវត្តជាច្រើន(បច្ចុប្បន្នមាន១៣គម្រោង) សំដៅបង្កើនការសិក្សាស្រាវជ្រាវនិងការបញ្ចូលនូវបច្ចេកទេសថ្មីក្នុងការអភិវឌ្ឍវិស័យព្រៃឈើនិងសត្វព្រៃ។

**១.៣.៥- ការងារពង្រឹងការអនុវត្តច្បាប់**

គិតចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២នេះ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃទទួលបានពីរដ្ឋបាលព្រៃឈើមូលដ្ឋាន និងក្រុមអន្តរាគមន៍បង្ក្រាបបទល្មើសសត្វព្រៃចល័តនៃរដ្ឋបាលព្រៃឈើសរុបមានចំនួន៥ ១៩៨ករណី ដែលក្នុងនោះសំណុំរឿងបទល្មើសព្រៃឈើត្រូវពិន័យអន្តរការណ៍ចំនួន២ ២៧៥ករណី និងសំណុំរឿងបទល្មើសព្រៃឈើដែលត្រូវបញ្ជូនទៅតុលាការចំនួន២ ៩២៣ករណី។ ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមានឈើមូល ជ្រុងសរុបមានចំនួន១ ០៤៨ម.៣ ឈើអារសរុប១២ ៨២២ម.៣ ឈើគ្រាក់គ្រញូងសរុប១៧ម.៣ និង៨៦០គ.ក្រ. សត្វព្រៃចម្រុះប្រភេទសរុប១៧ ០៤៥ក្បាលនិង៥ ០០២គ.ក្រ. និងផ្ទៃដីព្រៃឈើដែលបានកាប់រានទំហំ២៦ ៧៥៧ហ.ត. ព្រមទាំងមានវត្ថុតាងបទល្មើស ផ្សេងៗទៀត។

## ២.៤- ការគ្រប់គ្រងធនធានជលផលនិងការអភិវឌ្ឍវារីវប្បកម្ម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានខិតខំបំពេញភារកិច្ចយ៉ាងសកម្មទៅលើការងារគ្រប់ផ្នែកលើអនុវិស័យជលផល ក្នុងនោះរួមមានការរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ការពង្រឹងសហគមន៍នេសាទ ការគ្រប់គ្រងកន្លែងអភិរក្សជលផល ការគ្រប់គ្រងដែននេសាទ ការបង្ក្រាបបទល្មើសជលផល ការអភិវឌ្ឍវារីវប្បកម្ម ការសិក្សាស្រាវជ្រាវនិងការផ្សព្វផ្សាយ។ ទន្ទឹមនឹងនេះ ក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍនានា ក្នុងការផ្សព្វផ្សាយច្បាប់ ពង្រឹងសមត្ថភាពមន្ត្រី ពង្រឹងសហគមន៍នេសាទ ផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម និងការអភិរក្សធនធានជលផល ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**២.៤.១- ស្ថិតិផលនេសាទ**

**ក- ស្ថិតិផលនេសាទទឹកសាប**

ការនេសាទទឹកសាបសម្រេចបានចំនួន៥៣៥ ០០៥តោន ឆ្នាំ២០១៨ ថយចុះចំនួន៤០៦ ៤០០តោន នៅឆ្នាំ២០២២។

**ខ- ស្ថិតិផលនេសាទសមុទ្រ**

ការនេសាទសមុទ្រសម្រេចបានចំនួន១២១ ១០០តោន ក្នុងឆ្នាំ២០១៨ កើនឡើងចំនួន១២៥ ២០០ តោន នៅឆ្នាំ២០២២។

**២.៤.២- ផលវារីវប្បកម្ម**

ក្នុងឆ្នាំ២០១៨ វារីវប្បកម្មសម្រេចបាន ដូចខាងក្រោម៖

- ការចិញ្ចឹមត្រី បង្គា សម្រេចបានចំនួន២៥៤ ០៤៨តោន
- ការចិញ្ចឹមក្រពើ សម្រេចបានចំនួន៤១០ ០០០ក្បាល
- ការភ្ញាស់កូនត្រី សម្រេចបានចំនួន២១០ ០០០ ០០០កូន។

នៅឆ្នាំ២០២២នេះ វារីវប្បកម្មសម្រេចបាន ដូចខាងក្រោម៖

- ការចិញ្ចឹមត្រី បង្គា សម្រេចបានចំនួន៣០២ ១០០តោន
- ការចិញ្ចឹមក្រពើ សម្រេចបានចំនួន១៧៣ ៥០០ក្បាល
- ការភ្ញាស់កូនត្រី សម្រេចបានចំនួន២១៨ ៥០០ ០០០កូន។

**តារាងទី១ ផលនេសាទទឹកសាប សមុទ្រ និងវារីវប្បកម្មពីឆ្នាំ២០១៨ដល់ឆ្នាំ២០២២(តោន)**

| ល.រ. | បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ១ | ផលនេសាទទឹកសាប | ៥៣៥ ០០៥ | ៤៧៨ ៨៩០ | ៤១៣ ២០០ | ៣៨៣ ០៥២ | ៤០៦ ៤០០ |
| ២ | ផលនេសាទសមុទ្រ | ១២១ ១០០ | ១២២ ២៥០ | ១២២.៧០០ | ១២៥ ០០០ | ១២៥ ២០០ |
| ៣ | ផលវារីវប្បកម្ម | ២៥៤ ០៤៨ | ៣០៧ ៤០៨ | ៤០០ ៤០០ | ៣៤៨ ៣៥០ | ៣៣០ ៦០០ |
| | **សរុប** | **៩១០ ១៥៣** | **៩០៨ ៥៤៨** | **៩៣៦ ៣០០** | **៨៥៦ ៤០២** | **៨៦២ ២០០** |

**២.៤.៣- ការកែច្នៃផលផលិតផលជលផល**

ក្នុងឆ្នាំ២០១៨ ការកែច្នៃផលផលិតផលជលផលសម្រេចបានចំនួន៨៣ ៧៣៥តោន ស្មើនឹង៩២,០២% និងផលិតទឹកត្រីសម្រេចបានចំនួន៥៨ ០០០ ០០០លីត្រ ស្មើនឹង៩៦,៦៧% និងឆ្នាំ២០២២ ការកែច្នៃផលផលិតផលជលផលសម្រេចបានចំនួន៥៥ ១២០តោន ស្មើនឹង៥៩,៩១% និងផលិតទឹកត្រីសម្រេចបានចំនួន៥៩,២ លានលីត្រ ស្មើនឹង៩៨,៣០%។

**២.៤.៤- ការនាំចេញផលផលិតផលជលផល**

ក្នុងឆ្នាំ២០១៨នេះ ការនាំចេញផលផលិតផលជលផលសម្រេចបានចំនួន១៤ ៥០០តោន ស្មើនឹង ៧២,៥% និងឆ្នាំ២០២២នេះ ការនាំចេញផលផលិតផលជលផលសម្រេចបានចំនួន២ ៥៤៦តោន ស្មើនឹង ២៥,៤៦%។

**២.៤.៥- ការការពារបង្ក្រាបបទល្មើសជលផល**

ក្នុងឆ្នាំ២០១៨ ការការពារបង្ក្រាបបទល្មើសជលផលសម្រេចបាន៣ ២០៤ករណី និងឆ្នាំ២០២២ ការការពារបង្ក្រាបបទល្មើសជលផលសម្រេចបាន២ ៣៨០ករណី។

**២.៤.៦- ការអភិវឌ្ឍសហគមន៍នេសាទ**

ពីឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២២ សហគមន៍នេសាទទូទាំងប្រទេសមានចំនួនសរុប៥១៦សហគមន៍ ក្នុងនោះសហគមន៍នេសាទទឹកសាបចំនួន៤៧៥ និងសហគមន៍នេសាទសមុទ្រចំនួន៤១ ដែលមានសមាជិក

សរុបចំនួន៣៣២ ១៦៨នាក់(ស្ត្រី៣៥%)។ ក្នុងចំណោមសហគមន៍ខាងលើនេះ មានសហគមន៍នេសាទចំនួន ៤៣៥ ត្រូវបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ចំពោះសហគមន៍នេសាទដែលផុតអាណត្តិមានចំនួន២០០ ត្រូវបានបោះឆ្នោតជ្រើសរើសគណៈកម្មការឡើងវិញ និងបានរៀបចំផ្សព្វផ្សាយដើម្បីបង្កើនការយល់ដឹងអំពីច្បាប់ និងសារៈសំខាន់នៃវិស័យជលផលដល់សមាជិកសហគមន៍នេសាទនិងអ្នកពាក់ព័ន្ធបានចំនួន៣៧៩វគ្គ មានអ្នកចូលរួមចំនួន២៤ ២៤១នាក់។

**២.៤.៧- ការងារកិច្ចការជលផល**

ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២នេះ ការងារកិច្ចការជលផលបានបោះបង្គោលបេតុងកំណត់ព្រំប្រទល់ការពារព្រៃលិចទឹកកម្ពស់៨ម. បានចំនួន២៤០បង្គោលនិងធ្វើជំរឿននាវានេសាទ និងបាញ់ស្លាកសម្គាល់នាវានេសាទបានចំនួន៧ ៥៥២គ្រឿង និងបានប្រជុំផ្សព្វផ្សាយប្រកាសស្តីពីការកំណត់ប្រភេទឧបករណ៍នេសាទជាលក្ខណៈគ្រួសារ ពីសារៈសំខាន់នៃព្រៃលិចទឹក និងច្បាប់ពាក់ព័ន្ធបានចំនួន៤២វគ្គ មានអ្នកចូលរួម ៥ ៨៣០នាក់។

**២.៤.៨- ការអភិរក្សធនធានជលផល**

ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២នេះ ការងារអភិរក្សជលផលបានរៀបចំកន្លែងអភិរក្សបានចំនួន៦៦កន្លែង សង់បង្គោលកំណត់ព្រំប្រទល់កន្លែងអភិរក្សបានចំនួន៣៨៨បង្គោល ទម្លាក់ប្រអប់បេតុងការពារកន្លែងអភិរក្សជលផលសមុទ្របានចំនួន១ ១៥០បង្គោល សាងសង់ស្នាក់ការល្បាតការពារកន្លែងអភិរក្សបានចំនួន៤៤ខ្នង ដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួន២ ៥២០ហ.ត. កែលំអទីជម្រកផ្កាថ្មនិងស្មៅសមុទ្របានចំនួន៨ ៥០០ហ.ត. និងការពារអភិរក្សសត្វផ្សោតទន្លេមេគង្គបានចំនួន៨៩ក្បាល។

ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចូលរួមយ៉ាងសកម្មជាមួយក្រុមការងារអន្តរក្រសួង ដែលដឹកនាំដោយឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការចុះពិនិត្យនិងមានវិធានការបង្ក្រាបការទន្ទ្រានដីរដ្ឋក្នុងដែនព្រៃលិចទឹកនៅតំបន់បឹងទន្លេសាបមួយចំនួនដោយជំរុញឱ្យរដ្ឋបាលខេត្តជុំវិញបឹងទន្លេសាបចេញលិខិតណែនាំដល់អាជ្ញាធរស្រុក ឃុំបញ្ឈប់ការពិនិត្យបញ្ជាក់លើលិខិតសុំកាន់កាប់ដី និងលិខិតផ្ទេរសិទ្ធិកាន់កាប់ដីក្នុងដែនព្រៃលិចទឹក ព្រមទាំងចេញលិខិតបដិសេធលើរាល់លិខិតដែលបានចេញរួចពីពេលមុន និងចាត់វិធានការបញ្ឈប់ការចូលទន្ទ្រានដីដែនព្រៃលិចទឹកបន្តទៀត ធ្វើអត្តសញ្ញាណអ្នកដែលបានចូលទន្ទ្រាន ដើម្បីធ្វើការដកហូតដីនិងចាត់វិធានការតាមផ្លូវច្បាប់ ដោយត្រូវកសាងអង្គហេតុនិងដាក់បណ្តឹងអាជ្ញាទៅតុលាការ។

**២.៤.៩- ការសិក្សាស្រាវជ្រាវ**

ការសិក្សាស្រាវជ្រាវលើប្រភពធនធានជលផលទាំងទឹកសាប និងសមុទ្របានដំណើរការល្អ ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍនានា ដូចជា EU, UNIDO, FAO, WB, MRC, WWF, IUCN, World Fish Center ជាដើម។ល។ ដោយអនុវត្តលើសកម្មភាពមួយចំនួនដូចជាការសិក្សាស្រាវជ្រាវជីវសាស្ត្រវារីសត្វ សិក្សាតាមដានផលនេសាទតាមដាយត្រី សិក្សាតាមដានប្រភេទកូនត្រី សិក្សាស្រាវជ្រាវការធ្វើចរាចរណ៍និងការពងកូនរបស់ត្រីនៅតំបន់មេគង្គលើ សិក្សាតាមដានសុខភាពអេកូឡូស៊ីនៅកម្ពុជានិងសិក្សាតាមដានស្ថានភាពនេសាទសមុទ្រ។ល។ និងលទ្ធផលស្រាវជ្រាវត្រូវបានបោះពុម្ពសៀវភៅផ្សព្វផ្សាយជាច្រើនពាន់ក្បាល។

## ៣- លទ្ធផលនៃការបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម

ប្រទេសកម្ពុជាប្រឈមនឹងបញ្ហាជាច្រើនពាក់ព័ន្ធនឹងមីននិងសំណល់ជាតិផ្ទុះក្រោយសង្គ្រាម (ស.ផ.ស.) ដែលជាលទ្ធផលនៃសង្គ្រាមជាបន្តបន្ទាប់ក្នុងប្រទេសនិងក្នុងតំបន់ ដែលបានអូសបន្លាយពេលយ៉ាងយូរបង្កផលប៉ះពាល់ដល់ប្រទេសមួយនេះ ចាប់ពីដើមទសវត្សឆ្នាំ១៩៦០ រហូតដល់ចុងឆ្នាំ១៩៩៨។ ស្ថានភាពទូទៅនៃបញ្ហាមីននិងសំណល់ជាតិផ្ទុះក្រោយសង្គ្រាមនៅកម្ពុជា មានលក្ខណៈស្មុគស្មាញយ៉ាងខ្លាំងដោយសារកង្វះខាតកំណត់ត្រាព័ត៌មានអំពីកន្លែងបង្កប់គ្រាប់មីន ជម្លោះប្រដាប់អាវុធជាបន្តបន្ទាប់ដ៏រ៉ាំរ៉ៃ និងការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាម៉េរិក។ ក្នុងកំលុងពេលសង្គ្រាម ភាគីជម្លោះទាំងអស់សុទ្ធតែបានដាក់ពង្រាយគ្រាប់មីន ជាពិសេសនៅខេត្តភាគខាងលិចនិងភាគពាយព្យ ដែលតាមការប៉ាន់ស្មានគ្រាប់មីនប្រមាណពី៤ ទៅ ៦លានគ្រាប់ ត្រូវបានគេដាក់ពង្រាយ។ ចំណែកនៅខេត្តភាគខាងកើតនៃប្រទេសកម្ពុជា មានគ្រាប់បែកចង្កោមនិងស.ផ.ស. ផ្សេងទៀតដែលជាលទ្ធផលនៃការទម្លាក់គ្រាប់បែកយ៉ាងសន្ធឹកសន្ធាប់ក្នុងកំលុងពេលនៃសង្គ្រាមវៀតណាម។ យោងតាមព័ត៌មានពីក្រសួងការបរទេសសហរដ្ឋអាម៉េរិកបានឱ្យដឹងថា ចាប់ពីឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៧៣ សហរដ្ឋអាម៉េរិកបានទម្លាក់គ្រាប់បែកចំនួន ២,៧៥លានតោន ក្នុងនោះមានគ្រាប់បែកចង្កោមផងដែរ។ ជាលទ្ធផល ប្រទេសកម្ពុជាបានរងការខូចខាតខាងសេដ្ឋកិច្ចសង្គម និងផលវិបាកមនុស្សជាតិយ៉ាងធ្ងន់ធ្ងរ។

ចាប់ពីឆ្នាំ១៩៩២ ដល់ខែកញ្ញា ឆ្នាំ២០២២ ផ្ទៃដីប្រមាណ ២ ៤៩៦គ.ម.$^2$ ត្រូវបានបោសសម្អាត ព្រមទាំងបានរកឃើញនិងកម្ទេចចោលគ្រាប់មីនប្រឆាំងមនុស្សចំនួន១ ១៤៨ ៣៦៨គ្រាប់ មីនប្រឆាំងរថក្រោះចំនួន២៦ ០៧៩គ្រាប់ និងស.ផ.ស.ចំនួន៣ ០២២ ១៤៩គ្រាប់។ ទោះបីជាកម្ពុជាសម្រេចបាននូវសមិទ្ធផលដ៏ធំធេងលើការបោសសម្អាតមីននិងស.ផ.ស. ក៏កម្ពុជានៅតែប្រឈមនឹងបញ្ហាជាច្រើន ដែលពាក់ព័ន្ធនឹងគ្រាប់មីននិងស.ផ.ស.។ ដើម្បីបញ្ជាក់អំពីការប្តេជ្ញាចិត្តរបស់ខ្លួន រាជរដ្ឋាភិបាលបានបង្កើតគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពមួយទៀតរបស់កម្ពុជាគឺគោលដៅទី១៨ ស្តីពីការបញ្ចប់ផលប៉ះពាល់ជាអវិជ្ជមានរបស់គ្រាប់មីននិងស.ផ.ស. និងជំរុញការសង្គ្រោះជនរងគ្រោះ(CSDG18)។ ទន្ទឹមគ្នានេះ រាជរដ្ឋាភិបាលក៏មានចក្ខុវិស័យច្បាស់លាស់ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលគ្មានគ្រាប់មីននៅត្រឹមឆ្នាំ២០២៥ ហើយការគំរាមកំហែងពីស.ផ.ស. ត្រូវបានកាត់បន្ថយឱ្យនៅកម្រិតអប្បបរមា ដើម្បីការអភិវឌ្ឍមនុស្សនិងសេដ្ឋកិច្ចសង្គមប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព។ ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ កម្ពុជាត្រូវបោសសម្អាតតំបន់ទាំងអស់ដែលដឹងថាមានមីន និងគ្រាប់បែកចង្កោមជាអាទិភាព ព្រមទាំងកាត់បន្ថយហានិភ័យដែលនៅសេសសល់បណ្តាលមកពីស.ផ.ស.ផ្សេងទៀតនៅកម្ពុជា និងធ្វើការស្វែងរកការគាំទ្រមតិលើការលើកកម្ពស់សិទ្ធិ និងផ្តល់សេវាកម្មសម្រាប់អ្នករស់រានមានជីវិតពីគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ក៏ដូចជាជនរងគ្រោះដោយប្រយោល។

### ៣.១- ការបោសសម្អាតគ្រាប់មីននិងស.ផ.ស.សម្រេចបានដូចខាងក្រោម៖

គិតចាប់ពីខែមករា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២ ផ្ទៃដីដែលសង្ស័យមានមីននិងស.ផ.ស. ទំហំ ៧៧៤គ.ម.$^2$ ត្រូវបានបោសសម្អាតដើម្បីគាំទ្រការអភិវឌ្ឍនិងផ្តល់សុវត្ថិភាពដល់សហគមន៍ ព្រមទាំងបានរកឃើញនិងកម្ទេចចោលគ្រាប់មីនចំនួន១០៣ ៥៣៧គ្រាប់ និងស.ផ.ស. ចំនួន៣៥៨ ១៦៤គ្រាប់។ ក្នុងរយៈពេល៥ឆ្នាំនេះ ៨៧,២៣% នៃផ្ទៃដីសរុបដែលបានបោសសម្អាតរួច ស្មើនឹង៦២១គ.ម.$^2$ ត្រូវបានប្រើប្រាស់សម្រាប់វិស័យកសិកម្ម

ដែលមានអ្នកទទួលផលចំនួន៩៩៥ ២៧៩គ្រួសារ ស្មើនឹងប្រជាជនសរុបចំនួន៤ ៣៣៣ ៤៩៧នាក់ ក្នុងនោះមានស្ត្រីចំនួន២ ១៣០ ៩៩៨នាក់។ សមិទ្ធផលសំខាន់សរុបសម្រាប់រយៈពេល៥ឆ្នាំនេះ ត្រូវបានពិពណ៌នាលម្អិតដូចខាងក្រោម៖

| សូចនាករសំខាន់ៗ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|
| ផ្ទៃដីមានមីននិងស.ផ.ស. បានបោសសម្អាត (គម²) | ១៤១ | ១២៧ | ១៥៣ | ១៧៩ | ១៧៤ | **៧៧៤** |
| ភាគរយផ្ទៃដីសម្រាប់ធ្វើកសិកម្ម(%) | ៧៩,៧៥% | ៩២,៧៣% | ៩០,៧៣% | ៦៨,០០% | ៧៤.៦០% | **៨០,១៧%** |
| អ្នកទទួលផលសរុប(នាក់) | ៦៦៦ ៨៥៣ | ៨៨០ ២៧៤ | ៥៧៣ ៣៧០ | ១ ១០៤ ៦៥៦ | ១ ១០៨ ៣៤៤ | **៤៣៣៣៤៩៧** |
| គ្រាប់មីនរកឃើញនិងកម្ទេចចោល (ចំនួនគ្រាប់) | ១៦ ៧៤១ | ១៥ ៧៦៣ | ១៧ ៧០៩ | ២៣ ៥១៧ | ២៩ ៨០៨ | **១០៣ ៥៣៧** |
| ស.ផ.ស. រកឃើញនិងកម្ទេចចោល (ចំនួនគ្រាប់) | ៧៧ ៥៦២ | ៧៤ ៤៨៨ | ៦៩ ៣២២ | ៩៦ ៨៦១ | ៣៩ ៩៣១ | **៣៥៨ ១៦៤** |

សម្គាល់៖ ( * ) គិតពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២២

ផ្ទៃដីដែលត្រូវបានបោសសម្អាតទាំងនោះភាគច្រើនត្រូវបានប្រើប្រាស់សម្រាប់ធ្វើកសិកម្ម សាងសង់លំនៅដ្ឋាន និងបម្រើឱ្យគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រួមមានការសាងសង់សាលារៀន មណ្ឌល សុខភាព ផ្លូវថ្នល់និងប្រព័ន្ធស្រោចស្រព។ ការបោសសម្អាតមីននិងស.ផ.ស. បានផ្តល់អត្ថប្រយោជន៍ ដោយផ្ទាល់ដល់គ្រួសារជាច្រើនដែលរស់នៅក្នុងសហគមន៍ជនបទដាច់ស្រយាល ដែលនេះជាការរួមចំណែកកាត់បន្ថយភាពក្រីក្រ និងជំរុញកំណើនសេដ្ឋកិច្ច។

### ៣.២- ការអប់រំនិងការកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស.

ក្រៅពីការបោសសម្អាតមីននិងស.ផ.ស. ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិង ស.ផ.ស. នៅតែជាសកម្មភាពចាំបាច់ក្នុងការរួមចំណែកទប់ស្កាត់ការកើនឡើងនៃអត្រាគ្រោះថ្នាក់។ ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ក៏ជាសកម្មភាពមួយយ៉ាងសំខាន់ក្នុងការកាត់បន្ថយគ្រោះថ្នាក់។ គិតចាប់ខែមករា ឆ្នាំ២០១៨ ដល់ឆ្នាំ២០២១ ប្រជាពលរដ្ឋចំនួន៣ ៨៥៩ ២៤៧នាក់ បានទទួលសារអប់រំ កាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ពីប្រតិបត្តិករបណ្តាញអប់រំតាមសហគមន៍និងអាជ្ញាធរមានសមត្ថកិច្ច ក្នុងនោះមានស្ត្រីចំនួន១ ៤២១ ៤៨៧នាក់ កុមារាចំនួន៥៨០ ៨៧៥នាក់ និងកុមារីចំនួន៤៣១ ៤៨៧នាក់។ ជាមួយគ្នានេះ អាជ្ញាធរមីនបានសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការបញ្ជ្រាបការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ទៅក្នុងកម្មវិធីសិក្សាថ្នាក់ទី៧និងថ្នាក់ទី៨ និងបន្តពិភាក្សាអំពីលទ្ធភាពដាក់បញ្ចូលក្នុងកម្មវិធីសិក្សាថ្នាក់ទី៩ បន្ថែមទៀត។

តាមរបាយការណ៍ ព័ត៌មានជនរងគ្រោះដោយសារមីននិងស.ផ.ស.(CMVIS) សម្រាប់រយៈពេល៥ឆ្នាំ គិតចាប់ពីឆ្នាំ២០១៨ ដល់ខែតុលា ឆ្នាំ២០២២ ជនរងគ្រោះថ្នាក់ដោយសារមីននិងស.ផ.ស. ស្លាប់និងរបួសមានចំនួនសរុប២៨៤នាក់ ក្នុងនោះក៏មានស្ត្រីចំនួន១៨នាក់និងកុមារចំនួន៧៤នាក់។

| ជនរងគ្រោះដោយសារមីន និងស.ផ.ស.(ស្លាប់/របួស) | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (ត្រឹមខែតុលា) | សរុប |
|---|---|---|---|---|---|---|
| បុរស | ៣៦ | ៥៥ | ៤២ | ៣២ | ២៧ | **១៩២** |
| ស្ត្រី | ៦ | ៦ | ៤ | ១ | ១ | **១៨** |
| កុមារ | ១៦ | ១៦ | ១៩ | ១១ | ១២ | **៧៤** |
| សរុប | ៥៨ | ៧៧ | ៦៥ | ៤៤ | ៤០ | **២៨៤** |

## ៣.៣- កិច្ចសហប្រតិបត្តិការនិងតម្រូវការ

វិស័យសកម្មភាពមីននៅកម្ពុជា ពឹងផ្អែកទាំងស្រុងលើការផ្តល់ថវិកាគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជានិងដៃគូអភិវឌ្ឍ។ រាជរដ្ឋាភិបាលមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការផ្លាស់ប្តូរនៃការចាត់អាទិភាពថវិការបស់ប្រទេសម្ចាស់ជំនួយនិងដៃគូអភិវឌ្ឍមួយចំនួន។ ក្នុងស្ថានភាពនេះ តម្រូវឱ្យរាជរដ្ឋាភិបាលខិតខំប្រឹងប្រែងកៀរគរជំនួយនិងបង្កើនការផ្តល់ថវិកាជាតិបន្ថែម ដើម្បីធានានិរន្តរភាពនិងប្រសិទ្ធភាពនៃសកម្មភាពបោសសម្អាតមីនតាមផែនការដែលបានគ្រោងទុក។

## ៣.៤- ការគាំទ្រខាងផ្នែកសម្ភារៈដល់កងទ័ពជើងគោកនិងបោសសម្អាតមីនតាមព្រំដែន

ដើម្បីជួយសម្រួលដល់ពាណិជ្ជកម្មអន្តរជាតិ កម្ពុជាបានបង្កើតតំបន់សេដ្ឋកិច្ចពិសេសមួយចំនួននៅតាមតំបន់បណ្តោយព្រំដែនជាមួយប្រទេសជិតខាង ដែលនាំឱ្យមានកំណើនប្រជាជននិងការពង្រីកសហគមន៍នៅក្នុងតំបន់នោះ។ ដោយហេតុថាតំបន់ដែលមានមីនភាគច្រើនស្ថិតនៅតាមបណ្តោយព្រំដែនភាគពាយព្យគួបផ្សំនឹងកំណើនប្រជាជននិងសកម្មភាពអភិវឌ្ឍន៍នាំឱ្យមានហានិភ័យខ្ពស់នៅក្នុងតំបន់នោះ។ ដើម្បីដោះស្រាយបញ្ហាប្រឈមនេះ អាជ្ញាធរមីននឹងបន្តស្វែងរកជំនួយដើម្បីបំពាក់សម្ភារៈនិងផ្តល់ការហ្វឹកហ្វឺនដល់កងយោធពលខេមរ-ភូមិន្ទចំនួន២ ០០០នាក់ ឱ្យចូលរួមបោសសម្អាតមីនតាមតំបន់ព្រំដែន។ ប៉ុន្តែការងារនេះនៅមិនទាន់សម្រេចបានតាមផែនការនៅឡើយ។

## ៣.៥- ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងអាជ្ញាធរមីន និងក្រសួងពាក់ព័ន្ធ

អាជ្ញាធរមីននឹងជួបជាលក្ខណៈទ្វេភាគី ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងបរិស្ថាន ដើម្បីពិភាក្សាពីការបោសសម្អាតចម្ការមីននិងស.ផ.ស. នៅក្នុងតំបន់ដែលគ្រប់គ្រងដោយបណ្តាក្រសួងទាំងនោះ ក្នុងគោលបំណងប្រែក្លាយកម្ពុជាជាប្រទេសដែលគ្មានមីនត្រឹមឆ្នាំ២០២៥។

## ៣.៦- ការកៀរគរនិងតម្រូវការធនធាន

ដើម្បីសម្រេចបានតាមគោលបំណងកម្ពុជាគ្មានមីនត្រឹមឆ្នាំ២០២៥ វិស័យមីនកម្ពុជាត្រូវការថវិកាប្រមាណ៥២លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ។ ប៉ុន្តែជាក់ស្តែង ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២១ វិស័យនេះ ទទួលបានថវិកាប្រមាណ៣០លានដុល្លារអាម៉េរិកតែប៉ុណ្ណោះក្នុងមួយឆ្នាំ ឬប្រមាណ៦០%នៃតម្រូវការថវិកាប្រចាំឆ្នាំ។ ដើម្បីសម្រេចនូវគោលបំណងត្រឹមឆ្នាំ២០២៥ គិតចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥ វិស័យមីនត្រូវការថវិកាចំនួន **៦៦,៦៥លានដុល្លារអាម៉េរិក** ក្នុងមួយឆ្នាំៗ ដែលក្នុងនោះថវិកាចំនួន៤៥លានដុល្លារអាម៉េរិក ដើម្បីបោសសម្អាតផ្ទៃដីដែលមានមីន ១៥លានដុល្លារអាម៉េរិកសម្រាប់បោសសម្អាតផ្ទៃដីដែលមានគ្រាប់បែកចង្កោម និង០,៦៥លានដុល្លារអាម៉េរិក សម្រាប់ដោះស្រាយបញ្ហាស.ផ.ស.ផ្សេងទៀត ហើយ៦លានដុល្លារអាម៉េរិកសម្រាប់កិច្ចការគ្រប់គ្រងសម្របសម្រួល និងត្រួតពិនិត្យទូទាំងវិស័យ។ ហេតុនេះ អាជ្ញាធរមីននឹងបង្កើនកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលជាមួយដៃគូអភិវឌ្ឍដែលមានស្រាប់ ដៃគូអភិវឌ្ឍថ្មីៗ វិស័យឯកជន និងសមាគមនានា ដើម្បីកៀរគរធនធានតាមផែនការពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥។ ជាមួយគ្នានេះ យើងនឹងបន្តពិភាក្សាជំរុញការបន្ថែមថវិកាចូលរួមរបស់រាជរដ្ឋាភិបាលតាមលទ្ធភាពដែលអាចធ្វើទៅបាន។

**ក្រៅពីនេះ ក្រសួងការពារជាតិ សម្រេចការងារដូចខាងក្រោម**( គេហទំព័រ www.mod.gov.kh )

បោសសម្អាតគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះសម្រេចបានផ្ទៃដី១០១ ៦៦៥ ៨០៤ម.[២] រកឃើញគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះគ្រប់ប្រភេទ១១ ៩៤៧គ្រាប់ គ្រាប់១០៧មម គ្រាប់១៥២មម និងគ្រាប់ប៊ុមបីសរុប១៤គ្រាប់ ក្បាលផ្ទុះនិងក្បាលគ្រាប់គ្រប់ប្រភេទ២២៧គ្រាប់ កន្ទុយគ្រាប់និងសម្បកគ្រាប់១៦៦ ចម្រូងដែក ២៦៥ដើម បំណែកគ្រាប់និងលោហធាតុ៨៨ ៥៩២ដុំ និង២៩ ៧៦២គ.ក្រ.។

## ៤- វឌ្ឍនភាពនៃការអនុវត្តលើវិស័យធនធានទឹកនិងឧតុនិយមក្នុងរយៈពេល៥ឆ្នាំ

( ផែក : Ministry of Water Resources and Meteorology  គេហទំព័រ www.mowram.gov.kh )

វិស័យធនធានទឹកនិងឧតុនិយម គឺជាវិស័យមួយដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ( ឆ្នាំ២០១៩-២០២៣) និងគោលនយោបាយជាតិស្តីពីការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ ការអភិវឌ្ឍវិស័យធនធានទឹកបានជួយកាត់បន្ថយនូវគ្រោះមហន្តរាយដែលកើតឡើងពីធម្មជាតិ និងធានាដល់ការផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ សម្រាប់ការបង្កបង្កើនផលស្រូវ ដំណាំគ្រប់ប្រភេទ ដែលជាផ្នែកមួយជួយលើកស្ទួយដល់គោលនយោបាយជាតិ ស្តីពីសន្តិសុខស្បៀងប្រកបដោយប្រសិទ្ធភាព និងយុទ្ធសាស្ត្រនាំស្រូវ អង្ករចេញរបស់រាជរដ្ឋាភិបាល ព្រមទាំងជួយបង្កើនលទ្ធភាពផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋរស់នៅតាមទីក្រុង និងតាមជនបទ។

ក្នុងការអនុវត្តភារកិច្ចនិងតួនាទីរបស់ខ្លួន ក្រសួងធនធានទឹកនិងឧតុនិយម បានប្រមូលផ្តុំនិងប្រើប្រាស់យ៉ាងពេញទំហឹងនូវធនធាននានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រទេសជាតិដូចជា៖

- ការស្តារឡើងវិញ ជួសជុល សាងសង់និងថែទាំប្រចាំនូវប្រព័ន្ធធារាសាស្ត្រ ក្នុងគោលបំណងផ្តល់ទឹកគ្រប់គ្រាន់ដល់ដំណាំកសិកម្ម ការប្រើប្រាស់ទឹកប្រចាំថ្ងៃរបស់ប្រជាជននិងសត្វពាហណៈព្រមទាំងទេសចរណ៍។
- ការស្តារឡើងវិញ ជួសជុល សាងសង់និងថែទាំប្រចាំនូវទំនប់ការពារទប់ស្កាត់ទឹកជំនន់ និងទំនប់ការពារទប់ស្កាត់ទឹកប្រៃក្នុងគោលដៅការពារផ្ទៃដីកសិកម្ម ការពារទ្រព្យសម្បត្តិសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តរបស់ជាតិ។

ក្រសួងបានអនុវត្តការងារលើការគ្រប់គ្រងនិងការអភិវឌ្ឍលើវិស័យធនធានទឹកនិងឧតុនិយម ក្នុងរយៈពេល៥ឆ្នាំ( ឆ្នាំ២០១៨-២០២២) ក៏ដូចជាការរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៥ឆ្នាំ( ឆ្នាំ២០១៩-២០២៣) ហើយក្រសួងសម្រេចបាននូវសមិទ្ធផលយ៉ាងច្រើនគួរជាទីមោទនៈ។

### ៤.១- ការស្តារនិងការសាងសង់ប្រព័ន្ធធារាសាស្ត្រ

**ក្រសួងធនធានទឹកនិងឧតុនិយម សម្រេចបាននូវសមិទ្ធផលការងារដូចខាងក្រោម៖**

**ក- ជួសជុល ស្តារឡើងវិញ និងសាងសង់ប្រព័ន្ធធារាសាស្ត្រ ដើម្បីបង្កើនលទ្ធភាពស្រោចស្រព**

បានធ្វើការជួសជុល ស្តារឡើងវិញ និងសាងសង់ប្រព័ន្ធធារាសាស្ត្រទាំងតូចទាំងធំ នៅទូទាំងប្រទេសក្នុងរយៈពេល៥ឆ្នាំ( ឆ្នាំ២០១៨-២០២២) សម្រេចបាន២៤០គម្រោង ដែលបានបង្កើនលទ្ធភាពស្រោចស្រពលើផ្ទៃដីដំណាំស្រូវសរុប១៣៧ ២១០ ហ.ត. ក្នុងនោះ( ស្រូវវស្សា៩០ ៣៥៥ ហ.ត. និងស្រូវវដូវប្រាំង

៤៦ ៨៥៥ហ.ត.) និងស្រោចស្រពដំណាំរួមផ្សំបាន៤ ៥០៧ហ.ត. ព្រមទាំងចម្ការចំនួន៨១៦ហ.ត. ដែលបានចំណាយថវិកាសរុប៧២២ ២៣០ ៣៧៨ ០០០រៀល និង១៤០ ០០០ ដុល្លារអាម៉េរិក។ លទ្ធផលសម្រេចបានរួមមានតាមបណ្ដាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនគម្រោង | ថវិកាចំណាយ | | បង្កើនលទ្ធភាពស្រោចស្រព(ហ.ត.) | | | |
|---|---|---|---|---|---|---|---|
| | | ជារៀល | ជាដុល្លារ | វស្សា | ប្រាំង | សរុប | ដំណាំរួមផ្សំ |
| ២០១៨ | ៦៦ | ១៥២ ៨៨៦ ៤០៥ ០០០ | | ១៦ ៧០២ | ៦ ២៩៣ | ២២ ៩៩៥ | ៤៥១ |
| ២០១៩ | ៥២ | ១៦១ ០៤០ ៩៥៨ ០០០ | | ២២ ៣១៥ | ១០ ៧៤៨ | ៣៣ ០៦៣ | ៤១២ |
| ២០២០ | ៥៩ | ១៥០ ៧៥៨ ១៣២ ០០០ | ១៤០ ០០០ | ១៩ ៣០១ | ១១ ៨០១ | ៣១ ១០២ | ៥៣៥ |
| ២០២១ | ២៧ | ១២០ ៧៣២ ៥០០ ០០០ | | ១៥ ៦០១ | ៦ ៩៨៧ | ២២ ៥៨៨ | ១ ២៦១ |
| ២០២២ | ៣៦ | ១៣៦ ៨១២ ៣៨៣ ០០០ | | ១៦ ៤៣៦ | ១១ ០២៦ | ២៧ ៤៦២ | ១ ៨៤៨ ចំការ៨១៦ |
| **សរុប** | **២៤០** | **៧២២ ២៣០ ៣៧៨ ០០០** | **១៤០ ០០០** | **៩០ ៣៥៥** | **៤៦ ៨៥៥** | **១៣៧ ២១០** | **៤ ៥០៧ ចម្ការ៨១៦** |

### ខ- កិច្ចដំណើរការថែទាំប្រព័ន្ធធារាសាស្ត្រជាប្រចាំនិងខួប ដើម្បីរក្សានិរន្តរភាពស្រោចស្រព

បានអនុវត្តកិច្ចដំណើរការថែទាំប្រព័ន្ធធារាសាស្ត្រជាប្រចាំនិងខួបទាំងតូចទាំងធំនៅទូទាំងប្រទេស ក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) ហើយសម្រេចបាន៩៤៤គម្រោង ដែលបានរក្សានិរន្តរភាពនៃលទ្ធភាពស្រោចស្រពលើផ្ទៃដីដំណាំស្រូវសរុប៦៩១ ២២១ហ.ត. ក្នុងនោះ(ស្រូវរដូវវស្សា៥៧៥ ៧៦៥ហ.ត. និងស្រូវរដូវប្រាំង ១១៥ ៤៥៦ហ.ត.) និងស្រោចស្រពដំណាំរួមផ្សំបាន៣ ៦៤៦ ហ.ត. ព្រមទាំងចម្ការចំនួន១ ៩០៤ហ.ត. ដែលបានចំណាយថវិកាសរុប៣៤៧ ៤៤២ ៨៨០ ០០០រៀល។ លទ្ធផលសម្រេចបានរួមមានតាមបណ្ដាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនគម្រោង | ថវិកាចំណាយ | | រក្សានិរន្តរភាពនៃលទ្ធភាពស្រោចស្រព (ហ.ត) | | | |
|---|---|---|---|---|---|---|---|
| | | រៀល | ដុល្លារ | វស្សា | ប្រាំង | សរុប | ដំណាំរួមផ្សំ |
| ២០១៨ | ១៩២ | ៤១ ៧៣៥ ៤៤០ ០០០ | | ៣៩៥ ២៣៩ | ៩០ ៤៥៩ | ៤៨៥ ៦៩៨ | ១ ៥៥៦ |
| ២០១៩ | ១៩៩ | ៥៨ ៤០៤ ៨៧៣ ០០០ | | ៤០៩ ២៦៧ | ៩០ ៤៧៣ | ៤៩៩ ៧៤០ | ១ ៩២៤ |
| ២០២០ | ១៦៥ | ៦៣ ០៤០ ៦៨៧ ០០០ | | ៤៣៣ ០៩៥ | ៨៨ ៦៧២ | ៥២១ ៨៥៧ | ២ ៣១៩ |
| ២០២១ | ២០៥ | ១០៤ ១៨៦ ៩៩៣ ០០០ | | ៥៧៥ ៧៦៥ | ១១៥ ៤៥៦ | ៦៩១ ២២១ | ៣ ៦៤៦ |
| ២០២២ | ១៨៣ | ៨០ ០៧៤ ៨៨៧ ០០០ | | ៤០២ ១៨៦ | ៨៨ ៥៥៥ | ៤៩០ ៧៤១ | ៣ ៤៤៧ ចម្ការ១ ៩០៤ |
| **សរុប** | **៩៤៤** | **៣៤៧ ៤៤២ ៨៨០ ០០០** | | | | | |

## ៤.២- ការជួសជុល ថែទាំសំណង់សិល្បការ

ក្រសួង និងមន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្ត បានធ្វើការជួសជុល ថែទាំសំណង់សិល្បការតាមបណ្ដាប្រព័ន្ធធារាសាស្ត្រក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) សម្រេចបានរួមមានសំណង់ទ្វារទឹកសរុប **១៥២កន្លែង** សំណង់លូទឹកសរុប **៩៩កន្លែង** សំណង់ស្នាក់ទឹកសរុប **៤៩កន្លែង** និងសំណង់បង្ហៀរទឹកសរុប**១៨កន្លែង** ថវិកាចំណាយ**១ ២៣៤ ១១៩ ៥០០រៀល**។ លទ្ធផលសម្រេចបានរួមមានតាមបណ្ដាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ទ្វារទឹក (កន្លែង) | លូទឹក (កន្លែង) | ស្នាក់ទឹក (កន្លែង) | បង្ហៀរ (កន្លែង) | ថវិកាចំណាយ | |
|---|---|---|---|---|---|---|
| | | | | | ជារៀល | ជាដុល្លារ |
| ២០១៨ | ២២ | ២៥ | ២ | ៥ | ៩៣២ ៥៦៦ ០០០ | |
| ២០១៩ | ៣៤ | ៤២ | ៣៧ | ៣ | ២៩១ ៥០០ ៥០០ | |
| ២០២០ | ៤០ | ៥ | ៣ | ១ | ១០ ០៥៣ ០០០ | |
| ២០២១ | ៨ | ១៥ | ១ | ៤ | - | |

| | | | | | | |
|---|---|---|---|---|---|---|
| ២០២២ | ៤៨ | ១២ | ៦ | ៥ | - | |
| សរុប | ១៥២ | ៩៩ | ៤៩ | ១៨ | ១ ២៣៤ ១១៩ ៥០០ | |

## ៤.៣- ការជួសជុល ថែទាំប្រព័ន្ធធារាសាស្ត្រដោយមានប្រជាពលរដ្ឋចូលរួម

### ក- ការជួសជុល ថែទាំទំនប់

បានធ្វើការជួសជុលថែទាំទំនប់ក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) នៅតាមបណ្តាខេត្តសរុប៩៥កន្លែង ប្រវែង១១៦ ០៥៧ម. សាច់ដីសរុប៧១ ៤២០ម.$^{3}$ ប្រើប្រាស់គ្រឿងចក្រដែលបានចំណាយថវិកា ១ ២៧៥ ០០០ រៀល និង៩២ ១៥៨ដុល្លារអាម៉េរិក។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនកន្លែង | ប្រវែង(ម.) | សាច់ដី(ម.$^{3}$) | គ្រឿងចក្រ/ពលករ (នាក់) | ថវិកាចំណាយ | |
|---|---|---|---|---|---|---|
| | | | | | ជារៀល | ជាដុល្លារ |
| ២០១៨ | ៩ | ៨ ៩៨០ | - | គ្រឿងចក្រ | - | - |
| ២០១៩ | ១៥ | ២៦ ៧២៤ | ១ ០៤៤ | គ្រឿងចក្រ | ១ ២៧៥ ០០០ | ២ ០០០ |
| ២០២០ | ៣១ | ៣៩ ៨៤០ | - | គ្រឿងចក្រ | - | - |
| ២០២១ | ២១ | ១០ ៧៦៧ | ៤០៤ | គ្រឿងចក្រ | - | ៩០ ១៥៨ |
| ២០២២ | ១៩ | ២៩ ៧៤៦ | ៦៩ ៩៧២ | គ្រឿងចក្រ | - | - |
| **សរុប** | **៩៥** | **១១៦ ០៥៧** | **៧១ ៤២០** | | **១ ២៧៥ ០០០** | **៩២ ១៥៨** |

### ខ- ការងារជីក ស្តារប្រឡាយ

បានធ្វើការងារជីក ស្តារប្រឡាយក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) នៅតាមបណ្តាខេត្តចំនួន២៧៤ខ្សែ ប្រវែង៦០៤ ៥៨៩ម. សាច់ដីចំនួន៥៧១ ៨៨៣ម.$^{3}$ ប្រើប្រាស់គ្រឿងចក្រ បានចំណាយថវិកា ៤៣១ ៧៩០ ០០០រៀល និង៨ ៥០០ដុល្លារអាម៉េរិក។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនខ្សែ | ប្រវែង(ម.) | សាច់ដី(ម.$^{3}$) | គ្រឿងចក្រ | ថវិកាចំណាយ | |
|---|---|---|---|---|---|---|
| | | | | | ជារៀល | ជាដុល្លារ |
| ២០១៨ | ៧២ | ១៧៧ ០៣៨ | ១២៥ ៥៣៤ | | ៣២៣ ៤៩៤ ០០០ | ៨ ៥០០ |
| ២០១៩ | ៥២ | ៩៨ ៦០៧ | ២៦ ៧២៤ | គ្រឿងចក្រ | ៤៣ ៥៦៨ ០០០ | - |
| ២០២០ | ៧១ | ១៤១ ៩៦៨ | ២៨៦ ០៤៣ | គ្រឿងចក្រ | ៦៤ ៧២៨ ០០០ | - |
| ២០២១ | ៤៣ | ១២០ ០៨៤ | ១០០ ៣៥៧ | គ្រឿងចក្រ | - | - |
| ២០២២ | ៣៦ | ៦៦ ៨៩២ | ៣៣ ២២៥ | គ្រឿងចក្រ | - | - |
| **សរុប** | **២៧៤** | **៦០៤ ៥៨៩** | **៥៧១ ៨៨៣** | | **៤៣១ ៧៩០ ០០០** | **៨ ៥០០** |

## ៤.៤- ការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក

### ក- រៀបចំបង្កើតសហគមន៍កសិកប្រើប្រាស់ទឹក

ក្រសួងនិងមន្ទីរបានរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក នៅតាមប្រព័ន្ធធារាសាស្ត្រ ក្នុងរយៈពេល៥ឆ្នាំ (២០១៨-២០២២) នៅតាមបណ្តាខេត្ត ហើយសម្រេចបានចំនួន៨៧សហគមន៍ ដែលមានផ្ទៃដីស្រូវសរុប

២១៦ ០៧៩ហ.ត. ក្នុងនោះ(ផ្ទៃដីស្រូវវស្សា១៥០ ៤៥៣ហ.ត. ស្រូវប្រាំង៦៥ ៦២៦ហ.ត. និងមាន៦៤ ២១៥ គ្រួសារ)។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនសហគមន៍ | ផ្ទៃដីដំណាំស្រូវ | | | ចំនួនគ្រួសារ | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | ស្រូវវស្សា(ហ.ត.) | ស្រូវប្រាំង(ហ.ត.) | សរុប(ហ.ត.) | | |
| ២០១៨ | ២៧ | ៣២ ៣៧៧ | ១៣ ៩៧៧ | ៤៦ ៣៥៤ | ១៤ ០៣៦ | |
| ២១០៩ | ១៣ | ២៨ ៩៥៥ | ៤ ៤០៣ | ៣៣ ៣៥៨ | ២១ ៣០៨ | |
| ២០២០ | ២២ | ២១ ៥២៧ | ៣ ៥៣១ | ២៥ ០៥៨ | ៥ ៨៣៧ | |
| ២០២១ | ១២ | ៥៧ ០៥១ | ៣៨ ០៥៧ | ៩៥ ១០៨ | ៤៤០ | |
| ២០២២ | ១៣ | ១០ ៥៤៣ | ៥ ៦៥៨ | ១៦ ២០១ | ២២ ៥៩៤ | |
| **សរុប** | **៨៧** | **១៥០ ៤៥៣** | **៦៥ ៦២៦** | **២១៦ ០៧៩** | **៦៤ ២១៥** | |

**ខ- ការងារចុះពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក ដែលបានបង្កើតរួច**

មន្ទីរធនធានទឹកនិងឧតុនិយមតាមបណ្តារាជធានី ខេត្ត បានធ្វើការចុះពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹក នៅតាមប្រព័ន្ធធារាសាស្ត្របានចំនួន១៤៤កន្លែង ក្នុងនោះខេត្តស្វាយរៀង៧កន្លែង ព្រៃវែង៨កន្លែង ត្បូងឃ្មុំ៨កន្លែង កំពង់ចាម១០កន្លែង កណ្តាល៧កន្លែង រាជធានីភ្នំពេញ២កន្លែង តាកែវ៥កន្លែង កំពត៩កន្លែង កំពង់ស្ពឺ១២កន្លែង កែប៣កន្លែង ព្រះសីហនុ៥កន្លែង កោះកុង២កន្លែង កំពង់ឆ្នាំង១០កន្លែង ពោធិ៍សាត់១១កន្លែង បាត់ដំបង១១ កន្លែង ប៉ៃលិន២កន្លែង បន្ទាយមានជ័យ៤កន្លែង ឧត្តរមានជ័យ៤កន្លែង កំពង់ធំ៤កន្លែង ព្រះវិហារ៣កន្លែង ក្រចេះ ៣កន្លែង ស្ទឹងត្រែង៣កន្លែង រតនគិរី៣កន្លែង មណ្ឌលគិរី៣កន្លែង និងខេត្តសៀមរាប៥កន្លែង។

### ៤.៥- ការគ្រប់គ្រងគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត(ក្នុងយុទ្ធសាស្ត្រទី៣របស់ក្រសួង)

**ក្រសួងសម្រេចបាននូវសមិទ្ធផលដូចខាងក្រោម៖**

**ក- ការគ្រប់គ្រងនិងកាត់បន្ថយគ្រោះទឹកជំនន់ ទឹកប្រៃ**

ទឹកជំនន់ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ បានបណ្តាលឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសេដ្ឋកិច្ចសង្គមជាច្រើន ដោយសារការប្រែប្រួលអាកាសធាតុ។ ក្រសួងធនធានទឹកនិងឧតុនិយមបានធ្វើការ ជួសជុលទំនប់ទប់ស្កាត់ទឹកជំនន់ និងទឹកប្រៃ ដូចមានខាងក្រោម៖

**១- ទប់ស្កាត់ទឹកជំនន់** ការសាងសង់ទំនប់ការពារទប់ស្កាត់ទឹកជំនន់(ដើម្បីបង្កើនលទ្ធភាពការពារ)

បានធ្វើការជួសជុលទំនប់ការពារទប់ស្កាត់ទឹកជំនន់ស្រុកពញាឮ ខេត្តកណ្តាល ក្នុងរយៈពេល៥ឆ្នាំ (២០១៨-២០២២) បានចំនួន១គម្រោង ដែលមានលទ្ធភាពការពារផ្ទៃដីចំនួន១០០ហ.ត. ដែលបានចំណាយ ថវិការាជរដ្ឋាភិបាលចំនួន៧០០ ៥០០ ០០០រៀល។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនគម្រោង | ចំណាយ | | រក្សានិរន្តរភាពលទ្ធភាពការពារ(ហ.ត.) | | | |
|---|---|---|---|---|---|---|---|
| | | រៀល | ដុល្លារ | លំនៅដ្ឋាន | ស្រូវ | ដំណាំ | សរុប |
| ២០១៨ | ០ | - | | - | - | - | - |
| ២០១៩ | ១ | ៧០០ ៥០០ ០០០ | | ១០០ | - | - | ១០០ |
| ២០២០ | ០ | - | | - | - | - | - |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២០២១ | 0 | - | | - | - | - | - |
| ២០២២ | 0 | - | | - | - | - | - |
| **សរុប** | **១** | **៧០០ ៥០០ ០០០** | | **១០០** | **-** | **-** | **១០០** |

### ២- ការជួសជុល ថែទាំទំនប់ជាប្រចាំ(ដើម្បីរក្សានិរន្តរភាពនៃការពារទប់ស្កាត់ទឹកជំនន់)

បានធ្វើការជួសជុល ថែទាំ ទំនប់ការពារទប់ស្កាត់ទឹកជំនន់ នៅរាជធានីភ្នំពេញ និងខេត្តកណ្ដាល ក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) បានចំនួន៧គម្រោង រក្សានិរន្តរភាពការពារសរុប៤ ៩០១ហ.ត. ដែលបានចំណាយថវិការបស់រាជរដ្ឋាភិបាលចំនួន៩ ៩៤៣ ១៨៨ ០០០រៀល។ លទ្ធផលសម្រេចបានរួមមានតាមបណ្ដាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួន គម្រោង | ចំណាយ | រក្សានិរន្តរភាពលទ្ធភាពការពារ(ហ.ត.) | | | |
|---|---|---|---|---|---|---|
| | | រៀល | លំនៅដ្ឋាន | ស្រូវ | ដំណាំ | សរុប |
| ២០១៨ | ១ | ៥៧៤ ៥៦០ ០០០ | ២ ៣២០ | ១ ៤៨១ | 0 | ៣ ៨០១ |
| ២០១៩ | ២ | ៩៣២ ៣២១ ០០០ | ៣ ៤២០ | ១ ៤៨១ | 0 | ៤ ៩០១ |
| ២០២០ | ១ | ៥២៦ ៨៣០ ០០០ | ២ ៣២០ | ១ ៤៨១ | 0 | ៣ ៨០១ |
| ២០២១ | ១ | ៤៤៨ ៩៧៧ ០០០ | ២ ៣២០ | ១ ៤៨១ | 0 | ៣ ៨០១ |
| ២០២២ | ២ | ៧ ៤៦០ ៥០០ ០០០ | ៣០០ | - | - | ៣០០ |
| **សរុប** | **៧** | **៩ ៩៤៣ ១៨៨ ០០០** | | | | |

### ៣- ការការពារច្រាំងទន្លេ ដើម្បីការពារទប់ស្កាត់ទឹកជំនន់

ក្រសួងបានអនុវត្តការងាររៀបចំការពារច្រាំងទន្លេនៅក្នុងខេត្តកណ្ដាល កំពង់ចាម ត្បូងឃ្មុំ និងខេត្តក្រចេះ ក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) សម្រេចបានចំនួន២៩គម្រោង ដែលសរុបមានប្រវែង៣១ ១២៨ម. ហើយបានចំណាយថវិការាជរដ្ឋាភិបាលសរុបចំនួន២១៤ ០៧៨ ៥០០ ០០០រៀល។ លទ្ធផលសម្រេចបានរួមមានតាមបណ្ដាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនគម្រោង | ចំណាយថវិកា(រៀល) | លទ្ធផលសម្រេចបានប្រវែង(ម.) | ផ្សេងៗ |
|---|---|---|---|---|
| ២០១៨ | ១ | ២ ២៤៨ ០០០ ០០០ | ១៤៨ | |
| ២០១៩ | ៧ | ៨៤ ០៦២ ០០០ ០០០ | ១៣ ៥៩៥ | |
| ២០២០ | ៨ | ៤៤ ៣៤៩ ០០០ ០០០ | ៧ ២៦០ | |
| ២០២១ | ៧ | ៤១ ៤៥៥ ០០០ ០០០ | ៥ ៨៤៥ | |
| ២០២២ | ៦ | ៤១ ៩៦៤ ៥០០ ០០០ | ៤ ២៨០ | |
| សរុប | ២៩ | ២១៤ ០៧៨ ៥០០ ០០០ | ៣១ ១២៨ | |

### ខ- ទប់ស្កាត់ទឹកប្រៃ

### ១- ការសាងសង់ទំនប់ការពារទប់ស្កាត់ទឹកប្រៃ

ក្រសួងបានធ្វើការសាងសង់ទំនប់ការពារទប់ស្កាត់ទឹកប្រៃ ក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) បានចំនួន៦គម្រោងនៅខេត្តកោះកុង ចំណាយថវិកាចំនួន១៥ ៥៥៩ ៥០០ ០០០រៀល ហើយការពារទប់ស្កាត់ទឹកប្រៃកុំឱ្យប៉ះពាល់ផ្ទៃដីចំនួន៣ ៣២៧ហ.ត. ក្នុងនោះ(លំនៅដ្ឋាន៩៧ហ.ត. ស្រូវវស្សា៣ ១១៣ហ.ត. ស្រូវប្រាំង ៣០ហ.ត.និងដំណាំ៨៧ហ.ត.)។ លទ្ធផលសម្រេចបានរួមមានតាមបណ្ដាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនគម្រោង | ចំណាយ | បង្កើនលទ្ធភាពការពារ(ហ.ត) | | | | |
|---|---|---|---|---|---|---|---|
| | | រៀល | លំនៅដ្ឋាន | ស្រូវវស្សា | ស្រូវប្រាំង | ដំណាំ | សរុប |
| ២០១៨ | ១ | ២ ៥២៩ ០០០ ០០០ | ០ | ៧៨ | ០ | ០ | ៧៨ |
| ២០១៩ | ២ | ៦ ៦៣៩ ០០០ ០០០ | ០ | ៦២៥ | ៣០ | ២០ | ៦៧៥ |
| ២០២០ | ១ | ២ ១៨២ ០០០ ០០០ | ០ | ៤៦៣ | ០ | ៧ | ៤៧០ |
| ២០២១ | ១ | ២ ១១១ ៥០០ ០០០ | ៩៧ | ៩៣៣ | ០ | ៦០ | ១ ០៩០ |
| ២០២២ | ១ | ២ ០៩៨ ០០០ ០០០ | ០ | ១ ០១៤ | ០ | ០ | ១ ០១៤ |
| សរុប | ៦ | ១៥ ៥៥៩ ៥០០ ០០០ | ៩៧ | ៣ ១១៣ | ៣០ | ៨៧ | ៣ ៣២៧ |

**២- ការជួសជុល ថែទាំទំនប់ជាប្រចាំ ដើម្បីរក្សានិរន្តរភាពនៃការពារទប់ស្កាត់ទឹកប្រៃ**

បានធ្វើការជួសជុល និងថែទាំជាប្រចាំនូវបណ្តាទំនប់ការពារទប់ស្កាត់ទឹកប្រៃក្នុងរយៈពេល៥ឆ្នាំ (២០១៨-២០២២) បានចំនួន៦៧គម្រោង នៅខេត្តកោះកុងនិងខេត្តព្រះសីហនុ រក្សានិរន្តរភាពការពារទឹកប្រៃចំនួន១៥ ៨៩៩ ហ.ត. ចំណាយថវិការបស់រាជរដ្ឋាភិបាលចំនួន១១ ២៦៦ ៤៤៣ ០០០រៀល។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ចំនួនគម្រោង | ចំណាយ | រក្សានិរន្តរភាពនៃលទ្ធភាពការពារ(ហ.ត) | | | | |
|---|---|---|---|---|---|---|---|
| | | រៀល | លំនៅដ្ឋាន | ស្រូវវស្សា | ស្រូវប្រាំង | ដំណាំ | សរុប |
| ២០១៨ | ១៦ | ១ ២៥៩ ២០០ ០០០ | ៣៨៦ | ១៥ ៤០៣ | ០ | ១១០ | ១៥ ៨៩៩ |
| ២០១៩ | ១៦ | ១ ២៦៨ ២៨០ ០០០ | ៣៨៦ | ១៥ ៤០៣ | ០ | ១១០ | ១៥ ៨៩៩ |
| ២០២០ | ១២ | ៥ ៨១៧ ២៤០ ០០០ | ៣៨៦ | ១៤ ០៥៦ | ៣០ | ១២០ | ១៤ ៥៩២ |
| ២០២១ | ១២ | ១ ៧១៩ ២២៣ ០០០ | ០ | ១៣ ៧២៨ | ០ | ៣៥ | ១៣ ៧៦៣ |
| ២០២២ | ១១ | ១ ២០២ ៥០០ ០០០ | - | ១១ ៤០៣ | - | - | ១១ ៤០៣ |
| សរុប | ៦៧ | ១១ ២៦៦ ៤៤៣ ០០០ | | | | | |

## ៤.៦- ការគ្រប់គ្រងនិងការអន្តរាគមន៍សង្គ្រោះស្រូវពេលមានគ្រោះរាំងស្ងួត

គ្រោះរាំងស្ងួតតែងកើតមានឡើង ដោយការប្រែប្រួលអាកាសធាតុ និងធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលិតផលកសិកម្ម ដែលជាហេតុបណ្តាលឱ្យទិន្នផលស្រូវធ្លាក់ចុះ ធ្វើឱ្យប្រជាកសិករមានចំណូលទាប។ ក្នុងន័យនេះ ការអន្តរាគមន៍ដោយម៉ាស៊ីនបូមទឹក ដែលជួយដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើរតួយ៉ាងសំខាន់ក្នុងការសង្គ្រោះ បន្ធូរបន្ថយ និងកែលម្អដំណាំកសិកម្មដែលរងផលប៉ះពាល់ពីគ្រោះរាំងស្ងួត។

**ក- ការអន្តរាគមន៍សង្គ្រោះស្រូវពេលមានគ្រោះរាំងស្ងួត**

ក្រសួងធនធានទឹកនិងឧតុនិយម បានប្រមូលផ្តុំនូវម៉ាស៊ីនបូមទឹកនិងមធ្យោបាយចាំបាច់នានាក្នុងការអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវ ដែលប៉ះពាល់ពីគ្រោះរាំងស្ងួតក្នុងរយៈពេល៥ឆ្នាំ(២០១៨-២០២២) បានចំណាយប្រេងម៉ាស៊ូតចំនួន៤ ៧១០ ៧០០លីត្រ និងប្រេងម៉ាស៊ីនចំនួន៣៩ ៤៥០លីត្រ។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ការប្រើប្រាស់ប្រេង | | ផ្ទៃដីស្រូវសង្គ្រោះបាន | | |
|---|---|---|---|---|---|
| | ប្រេងម៉ាស៊ូត(លីត្រ) | ប្រេងរំអិល(លីត្រ) | ប្រាំង(ហត.) | វស្សា(ហ.ត.) | សរុប |
| ២០១៨ | ១ ០៦០ ០០០ | ៨ ៩០០ | ៣៧ ៥៦៨ | ៥៥ ៧១៩ | ៩៣ ២៨៧ |
| ២០១៩ | ១ ១៤០ ០០០ | ៥ ៦០០ | ៤៧ ៨៩២ | ៤២ ២៩៧ | ៩០ ១៨៩ |

| | | | | | |
|---|---|---|---|---|---|
| ២០២០ | ១ ១៥០ ៧០០ | ១១ ៣៥០ | ៥៨ ៧៣៩ | ៣៤ ៤៤៥ | ៩៣ ១៨៤ |
| ២០២១ | ៨៩៥ ០០០ | ៨ ៩៥០ | ៥០ ២៧៣ | ៣៣ ០៥៥ | ៨៣ ៣២៨ |
| ២០២២ | ៤៦៥ ០០០ | ៤ ៦៥០ | ៤៤ ៩៧៨ | ៩ ៧៣៥ | ៥៤ ៧១៣ |
| សរុប | ៤ ៧១០ ៧០០ | ៣៩ ៤៥០ | | | |

ក្រៅពីការងារអន្តរាគមន៍សង្គ្រោះស្រូវ ដោយម៉ាស៊ីនបូមទឹកក៏មានការងារសង្គ្រោះស្រូវដោយប្រព័ន្ធធារាសាស្ត្រ (បង្ហូរ) មានដូចបណ្តាឆ្នាំខាងក្រោម៖

| ឆ្នាំ | លទ្ធផលបង្ហូរសង្គ្រោះ | | | ផ្សេងៗ |
|---|---|---|---|---|
| | ប្រាំង(ហ.ត.) | វស្សា(ហ.ត.) | សរុប | |
| ២០១៨ | ២ ៥៣២ | ៩០០ | ៣ ៤៣២ | |
| ២០១៩ | ៥៨២ | ៨៣៩ | ១ ៤២១ | |
| ២០២០ | ៥៤៩ | ១ ២៥៧ | ១ ៨០៦ | |
| ២០២១ | ៨៩៧ | ៦៥០ | ១ ៥៤៧ | |
| ២០២២ | ៣០៨ | ១ ០៩៥ | ១ ៤០៣ | |

**ខ- ការជំរុញ ជួសជុល ស្ថានីយបូមទឹកនិងម៉ាស៊ីនបូមទឹក**

ដើម្បីឱ្យការងារអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវបានសម្រេច ក្រសួងបានធ្វើការសាងសង់ស្ថានីយបូមទឹកចំនួន២កន្លែង ជួសជុលស្ថានីយបូមទឹកចំនួន១៦កន្លែង និងធ្វើការជួសជុលម៉ាស៊ីនបូមទឹកចល័តចំនួន១២៩គ្រឿង ដោយចំណាយថវិការបស់រាជរដ្ឋាភិបាលចំនួន៣ ៥០៤ ២៩៨ ០០០រៀល។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | សាងសង់ស្ថានីយ (កន្លែង) | ជួសជុលស្ថានីយ (កន្លែង) | ជួសជុលម៉ាស៊ីន (កន្លែង) | ចំណាយថវិកា | | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | រៀល | ដុល្លារ | |
| ២០១៨ | | ២ | ២១ | ៦៧៤ ៥០០ ០០០ | | |
| ២០១៩ | | ៣ | ៤៩ | ៧២៧ ៥៥៨ ០០០ | | |
| ២០២០ | ២ | ៦ | ២៣ | ៦៨១ ៧៤០ ០០០ | | |
| ២០២១ | | ៣ | ២៣ | ៧០៩ ៥០០ ០០០ | | |
| ២០២២ | | ២ | ១៣ | ៧១១ ០០០ ០០០ | | |
| សរុប | ២ | ១៦ | ១២៩ | ៣ ៥០៤ ២៩៨ ០០០ | | |

## ៤.៧- ការគ្រប់គ្រងព័ត៌មានស្តីពីធនធានទឹកនិងឧតុនិយម(ក្នុងយុទ្ធសាស្ត្រទី៤)

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ការប្រែប្រួលអាកាសធាតុបានបណ្តាលឱ្យកើតមានឡើងនូវគ្រោះរាំងស្ងួត និងទឹកជំនន់ ដែលជាគ្រោះធម្មជាតិដ៏ធំបានធ្វើឱ្យបាត់បង់ដល់អាយុជីវិតមនុស្ស សត្វ ខូចខាតទ្រព្យសម្បត្តិសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើន។ ដើម្បីទប់ទល់និងកាត់បន្ថយនូវគ្រោះមហន្តរាយធម្មជាតិនេះ ទាមទារឱ្យមានការជំរុញស្ថានីយឧតុនិយម និងស្ថានីយជលសាស្ត្រនៅតាមទន្លេ ដងទន្លេ និងស្ទឹងសំខាន់ៗ ដើម្បីទទួលបាននូវទិន្នន័យធាតុអាកាសជាក់លាក់ និងកម្រិតកម្ពស់ទឹក ទិន្នន័យធារទឹក សម្រាប់ធ្វើការព្យាករណ៍ស្ថានភាពឧតុនិយម និងស្ថានភាពជលសាស្ត្រឱ្យបានទៀងទាត់ សុក្រឹត និងផ្សព្វផ្សាយជូនដំណឹងទាន់ពេលជូនដល់សាធារណជនឱ្យបានមុនពេលគ្រោះមហន្តរាយពីធម្មជាតិកើតឡើង ដូចជាភាពរាំងស្ងួត ខ្យល់ព្យុះ រន្ទះ និងទឹកជំនន់។ សមិទ្ធផលការងារខាងលើ ក្រសួងសម្រេចបានដូចខាងក្រោម៖

### ៤.៧.១- ការងារជលសាស្ត្រ

សាងសង់ស្ថានីយជលសាស្ត្រ១២កន្លែង ជួសជុលស្ថានីយជលសាស្ត្រ៥១កន្លែង ដំឡើងក្តារម៉ែត្រវាស់កម្ពស់ទឹកចំនួន៦កន្លែង ជួសជុលក្តារម៉ែត្រវាស់កម្ពស់ទឹកចំនួន៦កន្លែង និងបំពាក់ឧបករណ៍ស្វ័យប្រវត្តនៅតាមស្ថាននីយជលសាស្ត្របាន៨កន្លែង ដោយបានចំណាយថវិកាសរុបចំនួន៣ ៥៣៨ ០០០រៀល។ លទ្ធផលសម្រេចបានរួមមានតាមបណ្តាឆ្នាំដូចខាងក្រោម៖

| ឆ្នាំ | ស្ថានីយជលសាស្ត្រ(កន្លែង) | | ក្តារម៉ែត្រវាស់កម្ពស់ទឹក(កន្លែង) | | ឧបករណ៍ស្វ័យប្រវត្ត (កន្លែង) | ថវិកា(រៀល) |
|---|---|---|---|---|---|---|
| | ដំឡើង | ជួសជុល | ដំឡើង | ជួសជុល | | |
| ២០១៨ | | ៣ | | ៤ | ៨ | |
| ២០១៩ | | ១ | ១ | ១ | | ៣ ៥៣៨ ០០០ |
| ២០២០ | ១ | ៥ | ១ | | | |
| ២០២១ | ៩ | ៣៣ | ៣ | | | |
| ២០២២ | ២ | ៩ | ១ | ១ | ០ | |
- បានបង្កើតសហគមន៍ទេសចរណ៍ធម្មជាតិចំនួន៤៨សហគមន៍ គ្របដណ្តប់លើទំហំផ្ទៃដី៦៨ ១១៤ហ.ត.

- បានបានបញ្ចប់គោលការណ៍ណែនាំ ស្តីពីការអនុវត្តគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចដែលមានទំហំផ្ទៃដីក្រោម១០ហ.ត. ស្ថិតនៅក្នុងតំបន់ការពារធម្មជាតិនិងរបៀងអភិរក្សជីវៈចម្រុះ

- បានសម្របសម្រួលនិងសហការជាមួយសហគមន៍តំបន់ការពារធម្មជាតិ ដូចជាសហគមន៍តាតៃក្រោម សហគមន៍អន្លង់ស្វាយ សហគមន៍ភ្នំដើងលៀង សហគមន៍អន្លង់ព្រីង សហគមន៍បឹងយក្ខឡោម សហគមន៍បឹងលំកុដ ដើម្បីរៀបចំសេវាទេសចរណ៍ធម្មជាតិឱ្យកាន់តែទាក់ទាញភ្ញៀវទេសចរណ៍ទៅកម្សាន្ត

- ចុះសិក្សាលម្អិតអំពីប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធខូចខាត ដែលត្រូវជួសជុលនិងសាងសង់សម្រាប់បម្រើដល់ការផ្តល់សេវាកម្មទេសចរណ៍ធម្មជាតិ ស្ថិតក្នុងសហគមន៍តំបន់ការពារធម្មជាតិ ព្រៃធំអន្លង់ថ្ម ក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ភូមិសាស្ត្រខេត្តកំពង់ឆ្នាំង

- ចុះសិក្សាប្រមូលព័ត៌មានការគ្រប់គ្រងសំណល់រឹង រាវ នៅសហគមន៍តំបន់ការពារធម្មជាតិដែលកំពុងផ្តល់សេវាកម្មទេសចរណ៍ធម្មជាតិ ដូចជាសហគមន៍ចំបក់ សហគមន៍គោកមានទី សហគមន៍ពាមក្រសោប សហគមន៍តាតៃលើ សហគមន៍ជីផាត សហគមន៍ព្រៃធំអន្លង់ធំ សហគមន៍ព្រៃធំពពេល សហគមន៍ព្រែកទាល់ និងសហគមន៍ភ្នំដើងលៀង

- ចុះសិក្សាប្រមូលព័ត៌មានការប្រើប្រាស់ទឹកស្អាតនិងបង្គន់អនាម័យ របស់សហគមន៍តំបន់ការពារធម្មជាតិដែលកំពុងផ្តល់សេវាកម្មទេសចរណ៍ ដូចជាសហគមន៍គោកមានទី សហគមន៍លោក់កងជើង សហគមន៍អន្លង់ស្វាយ សហគមន៍ភ្នំដើងលៀង សហគមន៍ព្រៃភ្នំអន្លង់ធំ សហគមន៍ព្រៃធំពពេល សហគមន៍ព្រៃភ្នំក្តួច សហគមន៍ភ្នំម្នាស់ និងសហគមន៍ជប់តាសុខ

- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីមូលដ្ឋានគ្រឹះនៃការផ្តល់សេវាកម្មទេសចរណ៍ធម្មជាតិវគ្គបណ្តុះបណ្តាលការធ្វើបញ្ជីគណនេយ្យភាព វគ្គបណ្តុះបណ្តាលអ្នកនាំភ្ញៀវដល់គណៈកម្មការសហគមន៍តំបន់ការពារធម្មជាតិចំនួន១៥សហគមន៍ដែលកំពុងផ្តល់សេវាកម្មទេសចរណ៍ធម្មជាតិ

- បានចុះស្វែងយល់អំពីសក្តានុពល ការរៀបចំផលិតផល និងសេវាកម្មអេកូទេសចរណ៍ បញ្ហាប្រឈមសំណូមពរ និងតម្រូវការចាំបាច់ក្នុងការជំរុញលើកទឹកចិត្ត និងប្រែក្លាយសហគមន៍ឱ្យកាន់តែមានភាពទាក់ទាញបន្ថែមទៀតសម្រាប់គោលដៅទេសចរណ៍បែបធម្មជាតិ នៅសហគមន៍តំបន់ការពារធម្មជាតិអន្លង់ស្វាយស្ថិតក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ខេត្តកំពង់ឆ្នាំង សហគមន៍តំបន់ការពារធម្មជាតិរាំងខ្វាវ ស្ថិតក្នុងដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ខេត្តពោធិ៍សាត់ និងសហគមន៍តំបន់ការពារធម្មជាតិអូរជាំ ស្ថិតក្នុងដែនជម្រកសត្វព្រៃភ្នំសំកុស ខេត្តបាត់ដំបង។

## ១.៤- ការគ្រប់គ្រងចំណេះដឹងនិងព័ត៌មានបរិស្ថាន

### ១- ការងារព័ត៌មានភូមិសាស្ត្រ

បានបញ្ចប់ការកសាងរបាយការណ៍ស្ថានភាពបរិស្ថានចំនួន២ គឺរបាយការណ៍ស្ថានភាពបរិស្ថានលើកទី៣ និងលើកទី៤ និងបានបោះពុម្ពរបាយការណ៍ស្ថានភាពបរិស្ថានសរុបចំនួន៧៦២ក្បាល សម្រាប់ឆ្នាំ២០២២នេះ

បាននិងកំពុងរៀបចំរបាយការណ៍ស្ថានភាពបរិស្ថានលើកទី៥ បានធ្វើការវាយតម្លៃធនធានគម្របព្រៃឈើជាតិ ដោយផលិតជាទិន្នន័យនិងបានបោះពុម្ពជាសៀវភៅសរុបចំនួន១ ៨០០ក្បាល បានផលិតផែនទីសហគមន៍តំបន់ការពារធម្មជាតិចំនួន៤២ផ្ទាំង ផែនទីតំបន់ទេសចរណ៍ធម្មជាតិចំនួន២៩២ផ្ទាំង ផែនទីបេតិកភណ្ឌវប្បធម៌និងធម្មជាតិចំនួន១២ផ្ទាំង និងផែនទីកំណត់និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិចំនួន៣ផ្ទាំង។

| សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| កសាងរបាយការណ៍ស្ថានភាពបរិស្ថាន | លើក | ១ | - | - | ១ | - |
| វាយតម្លៃធនធានគម្របព្រៃឈើជាតិ(ផលិតទិន្នន័យ) | Dataset | - | - | ១ | - | - |
| បោះពុម្ពរបាយការណ៍ស្ថានភាពបរិស្ថាន | ក្បាល | ៣០០ | - | - | ៤៦២ | - |
| បោះពុម្ពសៀវភៅធនធានគម្របព្រៃឈើជាតិ | ក្បាល | - | - | ១៥០០ | - | ៣០០ |
| ផលិតផែនទីសហគមន៍តំបន់ការពារធម្មជាតិ | ផ្ទាំង | ៦ | ៣០ | ២ | ២ | ២ |
| ផលិតផែនទីតំបន់ទេសចរណ៍ធម្មជាតិ | ផ្ទាំង | ២៧ | ៥៨ | ៧២ | ៣៥ | ១០០ |
| ផលិតផែនទីបេតិកភណ្ឌវប្បធម៌និងធម្មជាតិ | ផ្ទាំង | - | - | ០៩ | - | ៣ |
| រៀបចំផែនទីកំណត់ និងបែងចែកតំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ | ផ្ទាំង | - | ១ | - | - | ២ |

## ២- ការងារអប់រំបរិស្ថាន

បានផ្សព្វផ្សាយនិងជំរុញការអនុវត្តកម្មវិធីសាលាមេត្រីបរិស្ថានសរុបចំនួន៥៧៦ និងជំរុញវត្តអារាមអនុវត្តកម្មវិធីអារាមមេត្រីបរិស្ថាន សរុបចំនួន១៤៨ បានបោះពុម្ពសៀវភៅគោលការណ៍សាលាមេត្រីបរិស្ថានសរុបចំនួន ៤ ០០០ក្បាល និងសៀវភៅគោលការណ៍វត្តអារាមមេត្រីបរិស្ថានសរុបចំនួន២ ០០០ក្បាល ដើម្បីចែកជូនដល់សាលារៀននិងវត្តអារាមចូលរួមអនុវត្តកម្មវិធីសាលាមេត្រីបរិស្ថាន និងកម្មវិធីអារាមមេត្រីបរិស្ថាន បានរៀបចំវេទិកាយុវជនជជែកពិភាក្សា អំពីបរិស្ថានដោយមានសិស្សចូលរួមសរុបចំនួន២ ៣៩៦នាក់ បានដាក់បញ្ចូលមេរៀនអប់រំបរិស្ថានក្នុងប្រព័ន្ធសរុបចំនួន២៥មេរៀន ផលិតវីដេអូអប់រំបរិស្ថានសរុបចំនួន២វីដេអូ និងបោះពុម្ពសម្ភារៈអប់រំបរិស្ថានដូចជាposters calendar សរុបចំនួន៣ ៤០០ និងបានចូលរួមផ្តល់ជាតុចូលជាមេរៀនអប់រំបរិស្ថានសម្រាប់គ្រប់កម្រិតសិក្សាក្នុងកម្មវិធីសុខភាពសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡាបានចំនួន១៨មេរៀន រួមមានមេរៀនស្តីពីការថែរក្សាបរិស្ថាននៅផ្ទះ ការថែរក្សាបរិស្ថាននៅសាលារៀន សុវត្ថិភាពពេលទឹកជំនន់ សារៈសំខាន់នៃព្រៃឈើចំពោះសុខភាព គ្រោះថ្នាក់នៃការប្រើប្រាស់បរិក្ខារអេឡិចត្រូនិក គ្រោះថ្នាក់ដោយសារមីននិងអាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះ ការបំពុលបរិស្ថាននិងផលប៉ះពាល់សុខភាព ការបំពុលដោយសំឡេងនិងរំញ័រមកលើសុខភាព គ្រោះថ្នាក់នៃការប្រើផលិតផលបង្កើនសម្ផស្ស ផលប៉ះពាល់នៃសំណល់សារជាតុគីមី ផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ សំណល់រឹង ប្លាស្ទិក និងផលប៉ះពាល់សុខភាពមនុស្សនិងបរិស្ថាន។

| សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| កម្មវិធីសាលាមេត្រីបរិស្ថាន | សាលា | ២០៨ | ១១០ | ៧០ | ១០៨ | ៨០ |
| កម្មវិធីអារាមមេត្រីបរិស្ថាន | វត្ត | - | - | - | ៥០ | ៩៨ |
| បោះពុម្ពសៀវភៅគោលការណ៍សាលាមេត្រីបរិស្ថាន | ក្បាល | ១ ០០០ | ១ ០០០ | ១ ០០០ | ១ ០០០ | - |

| | | | | | | |
|---|---|---|---|---|---|---|
| បោះពុម្ពសៀវភៅគោលការណ៍វត្តអារាមមេត្រីបរិស្ថាន | ក្បាល | - | - | ១០០០ | - | ១០០០ |
| វេទិកាយុវជនដដែកពិភាក្សាអំពីបរិស្ថាន | សិស្ស | ៥៥៨ | ៥២០ | ២៤០ | ១៦៥ | ៩១៣ |
| ដាក់បញ្ចូលមេរៀនអប់រំបរិស្ថានក្នុងប្រព័ន្ធ | មេរៀន | - | - | ១៨ | ៧ | - |
| ផលិតវីដេអូអប់រំបរិស្ថាន | ចំនួន | ២ | - | - | - | - |
| បោះពុម្ពសម្ភារអប់រំបរិស្ថានផ្សេងៗ | ចំនួន | - | - | - | ៤០០ | ៣០០០ |

## ៣- ការងារព័ត៌មានបរិស្ថាន

បានរៀបចំទិវាបរិស្ថានដូចជា ទិវា១ម៉ោង នៃភពផែនដី ទិវាភពផែនដី ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥មិថុនា និងទិវាអនាម័យបរិស្ថានជាតិ ២៣វិច្ឆិកា ជារៀងរាល់ឆ្នាំ បានផលិតព័ត៌មានបរិស្ថានប្រចាំថ្ងៃនិងប្រចាំសប្តាហ៍សរុបចំនួន២៤៣៤អត្ថបទ បានផលិតវីដេអូឯកសារនិងវីដេអូខ្លីៗចំនួន១២វីដេអូ និងបទចម្រៀង បរិស្ថានចំនួន៣០បទ បានផលិតកម្មវិធីនិងបទយកការណ៍បរិស្ថានសម្រាប់ផ្សព្វផ្សាយតាមរយៈទូរទស្សន៍ វិទ្យុ និងតាមបណ្តាញសង្គមក្រសួងសរុបចំនួន៥៤ប្រធានបទ បោះពុម្ពផ្សាយទស្សនាវដ្តីបរិស្ថានប្រចាំឆ្នាំចំនួន៥ ៨៥០ច្បាប់ បោះពុម្ពសៀវភៅវឌ្ឍនភាពបរិស្ថានចំនួន៣០០ច្បាប់ បានបកប្រែអត្ថបទនិងវីដេអូអប់រំបរិស្ថានពីភាសាបរទេសចំនួន៦០អត្ថបទ បានគូរគំនូររូបភាពនិងរូបគំនូរអំពីសារអប់រំបរិស្ថាននៅតាមជញ្ជាំងសាលារៀនចំនួន១២២ផ្ទាំង។

| សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| រៀបចំទិវាបរិស្ថានដូចជា ទិវា១ម៉ោងនៃភពផែនដី ទិវាភពផែនដី ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា និងទិវាអនាម័យ បរិស្ថានជាតិ ២៣ វិច្ឆិកា | លើក | ៤ | ២ | ១ | ១ | ២ |
| ផលិតព័ត៌មានបរិស្ថានប្រចាំថ្ងៃប្រចាំសប្តាហ៍ | អត្ថបទ | ៦០០ | ៤៥០ | ៥២៤ | ៥៤៨ | ៣១២ |
| ផលិតវីដេអូឯកសារនិងវីដេអូខ្លីៗស្តីពីបញ្ហាបរិស្ថាននិងសក្តានុពលនៃតំបន់ការពារធនធានធម្មជាតិផ្សាយតាមបណ្តាញសង្គមរបស់ក្រសួង | វីដេអូ | ២ | ១ | ១ | ៤ | ៤ |
| ផលិតបទចម្រៀងបរិស្ថាន | ចំនួន | - | - | - | ២៥ | ៥ |
| ផលិតកម្មវិធីនិងបទយកការណ៍បរិស្ថានសម្រាប់ផ្សព្វផ្សាយតាមរយៈទូរទស្សន៍ វិទ្យុនិងតាមបណ្តាញសង្គមក្រសួង | ប្រធានបទ | ១៨ | ១៨ | ២៨ | - | - |
| បោះពុម្ពផ្សាយទស្សនាវដ្តីបរិស្ថានប្រចាំឆ្នាំ | ច្បាប់ | ១០៥០ | ១២០០ | ១២០០ | ១២០០ | ១២០០ |
| បោះពុម្ពសៀវភៅវឌ្ឍនភាពបរិស្ថាន | ច្បាប់ | ៣០០ | - | - | - | - |
| បកប្រែអត្ថបទ និងវីដេអូអប់រំបរិស្ថានពីភាសាបរទេស | អត្ថបទ | - | - | - | ៦០ | - |
| គូរគំនូរអំពីសារអប់រំបរិស្ថាននៅតាមជញ្ជាំងសាលារៀន(រូបភាពនិងរូបគំនូរលើជញ្ជាំង) | ផ្ទាំង | ១១០ | - | ១០ | - | ២ |

### ៤- ការងាររង្វាន់និងលើកទឹកចិត្ត

បានរៀបចំលិខិតបទដ្ឋានគតិយុត្តដូចជា អនុក្រឹត្យស្តីពីការលើកទឹកចិត្តក្នុងការប្រតិបត្តិមេត្រីបរិស្ថាន ប្រកាសស្តីពីបមាណីយមេត្រីបរិស្ថាន សេចក្តីណែនាំស្តីពីការវាយតម្លៃគុណវុឌ្ឍិនិងការផ្តល់បណ្ណសរសើរមេត្រីបរិស្ថានដល់រូបវន្តបុគ្គល និងនីតិបុគ្គលប្រតិបត្តិមេត្រីបរិស្ថានសម្រាប់មន្ទីរបរិស្ថានរាជធានី ខេត្ត គោលការណ៍ណែនាំស្តីពីចលនាប្រឡងប្រណាំងភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ក្នុងក្របខ័ណ្ឌលក្ខណៈសម្បត្តិទី៦ និងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការផ្តល់រង្វាន់និងលើកទឹកចិត្តមេត្រីបរិស្ថានបានចំនួន៦ច្បាប់ បានផ្តល់បណ្ណសរសើរ និងលិខិតថ្លែងអំណរគុណដល់នីតិបុគ្គល រូបវន្តបុគ្គល ព្រមទាំងមន្ត្រីឧទ្យានុរក្សដែលបានចូលរួមបំពេញការងារយ៉ាងសកម្មសរុបចំនួន២១២៣បណ្ណ បានផ្តល់បណ្ណជ័យលាភីចលនាប្រឡងប្រណាំង ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ក្នុងក្របខ័ណ្ឌលក្ខណសម្បត្តិទី៦«ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព មានអនាម័យ មានសោភណ្ឌភាពល្អ និងបរិស្ថានល្អ» សរុបចំនួន២០បណ្ណ បានប្រគល់សម្ភារៈគាំពារបរិស្ថានដល់សាលារៀននិងទីកន្លែងផ្សេងៗ ចំនួន១២២ធុង បានផលិតវីដេអូផ្សព្វផ្សាយមេត្រីបរិស្ថានចំនួន២៦វីដេអូ បានផលិតបទចម្រៀងមេត្រីបរិស្ថានចំនួន១៦បទ និងបានសម្របសម្រួលផ្តល់បណ្ណក្នុងកម្មវិធីប្រឡងប្រណាំងនានាចំនួន១៦៩បណ្ណ។

| សូចនាករ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| រៀបចំបទដ្ឋានគតិយុត្ត | ច្បាប់ | ១ | ១ | ១ | ២ | ១ |
| កម្មវិធីលើកទឹកចិត្តមេត្រីបរិស្ថាន | បណ្ណ | ១៨ | ៤៩៨ | ៤៨៤ | ៥៧៩ | ៥៤៤ |
| កម្មវិធីប្រឡងប្រណាំង«ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព» | បណ្ណ | - | - | - | - | ២០ |
| ប្រគល់សម្ភារៈគាំពារបរិស្ថានដល់សាលារៀននិងទីកន្លែងផ្សេងៗ | ចំនួន | - | - | ១២២ | - | - |
| ផលិតវីដេអូផ្សព្វផ្សាយមេត្រីបរិស្ថាន | វីដេអូ | ១ | ១ | ៧ | ១៥ | ២ |
| ផលិតបទចម្រៀងមេត្រីបរិស្ថាន | បទ | ៣ | ៣ | ៣ | ៣ | ៤ |
| សម្របសម្រួលផ្តល់បណ្ណក្នុងកម្មវិធីប្រឡងប្រណាំងនានា | បណ្ណ | - | ២០ | ២០ | ៩៤ | ៣៥ |

## ២- វប្បធម៌ សាសនានិងព័ត៌មាន

### ២.១- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សម្រេចការងារបានដូចខាងក្រោម៖** (គេហទំព័រ www.mcfa.gov.kh)

ស្របតាមចក្ខុវិស័យ "**អភិរក្សនិងអភិវឌ្ឍវប្បធម៌ជាតិដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គម**" ដែលបានកំណត់នៅក្នុងគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌ និងគោលបំណងគោលនយោបាយ "**ការអភិរក្សនិងអភិវឌ្ឍវប្បធម៌ជាតិ**" នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា៣ឆ្នាំរំកិលជាបន្តបន្ទាប់ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានខិតខំអនុវត្តការងារគ្រប់មុខព្រួញនៃយុទ្ធសាស្ត្រ និងសម្រេចបានលទ្ធផលការងារជាច្រើនគួរជាទីមោទនៈ។ សមិទ្ធផលទាំងនេះ គឺអនុលោមទៅតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៥ និងទី៦នៃរដ្ឋសភា ពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣និងទី៤ ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០១៤-

២០១៨ និង២០១៩-២០២៣ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

នៅក្នុងផ.យ.អ.ជ. ការងារវប្បធម៌និងវិចិត្រសិល្បៈស្ថិតនៅ**ផ្នែកទី៤** ត្រង់ចំណុចទី**៤.២- "ការអភិវឌ្ឍប្រកពកំណើនសេដ្ឋកិច្ចគន្លឹះនិងថ្មីៗ"**(ការធ្វើពិពិធកម្មសេដ្ឋកិច្ច) និងចំណុចទី**៦.២- "ការគ្រប់គ្រងធនធានធម្មជាតិនិងវប្បធម៌ប្រកបដោយចីរភាព"**(ការអភិវឌ្ឍប្រកបដោយចីរភាពនិងបរិយាបន្ន)។ ចំពោះវឌ្ឍនភាពការងារសំខាន់ៗរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្នុងរយៈពេល៥ឆ្នាំកន្លងទៅ ដោយគិតចាប់ពីខែមករា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ២០២២ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សម្រេចការងារដូចខាងក្រោម៖

**ក- ការអភិរក្សវប្បធម៌ជាតិ**

-បានអភិរក្សសំណង់បុរាណ/បេតិកភណ្ឌសរុបចំនួន៣៨០សំណង់ ស្មើនឹង៦៦២ទីតាំង/ផ្នែក/ចំណុច រួមមានសំណង់ដែលបានជួសជុលសរុបចំនួន២០៥**សំណង់** ស្មើនឹង៣២៥ទីតាំង/ផ្នែក/ចំណុច និងសំណង់ដែលបានអភិរក្សក្រៅពីការជួសជុល សរុបចំនួន១៧៥**សំណង់** ស្មើនឹង៣៣៧ទីតាំង/ផ្នែក/ចំណុច។

| ឆ្នាំ | សំណង់បុរាណ/បេតិកភណ្ឌ ដែលបានជួសជុល | | សំណង់បុរាណ/បេតិកភណ្ឌ ដែលបានអភិរក្សក្រៅពីការជួសជុល | |
|---|---|---|---|---|
| | ចំនួនសំណង់ | ចំនួនទីតាំង | ចំនួនសំណង់ | ចំនួនទីតាំង |
| ២០១៨ | ៣១ | ៦២ | ៣២ | ៩៦ |
| ២០១៩ | ៥៦ | ៨២ | ៣០ | ៨៤ |
| ២០២០ | ៣៧ | ៧២ | ៣០ | ៣២ |
| ២០២១ | ៥២ | ៧២ | ៣៣ | ៣៦ |
| ២០២២(៩ខែ) | ២៩ | ៣៧ | ៥០ | ៨៩ |
| សរុប | **២០៥** | **៣២៥** | **១៧៥** | **៣៣៧** |

- បានអភិរក្សវត្ថុបុរាណ វត្ថុសិល្បៈ និងវត្ថុជាតិពន្ធុសាស្ត្រ ដូចជា៖
  - អភិរក្សវត្ថុបុរាណ វត្ថុសិល្បៈ និងវត្ថុជាតិពន្ធុសាស្ត្រសរុបចំនួន ២១ ៥៣៩ មុខ រួមមានវត្ថុបុរាណ វត្ថុសិល្បៈ និងវត្ថុជាតិពន្ធុសាស្ត្រដែលបានជួសជុល ចំនួន ១ ៦០១ មុខ និងវត្ថុបុរាណ វត្ថុសិល្បៈ និងវត្ថុជាតិពន្ធុសាស្ត្រដែលបានអភិរក្សក្រៅពីការជួសជុលចំនួន ១៩ ៩៣៨ មុខ
  - ចុះបញ្ជីវត្ថុបុរាណ វត្ថុសិល្បៈនិងវត្ថុជាតិពន្ធុសាស្ត្រសរុបចំនួន ៨១ ៦៨៩មុខ(ចុះបញ្ជីសារពើភណ្ឌចំនួន ៧៥ ២៣៦មុខ និងចុះបញ្ជីទៅក្នុងប្រព័ន្ធ Database ចំនួន ៦ ៤៥៣មុខ)
  - សិក្សាវិភាគវត្ថុបុរាណ/វត្ថុសិល្បៈ សរុបចំនួន ១ ៥៨៣មុខ
  - រកឃើញនិងទទួលបានវត្ថុបុរាណ/វត្ថុសិល្បៈពីគ្រប់ប្រភពសរុបចំនួន ៧០ ២៦៧មុខ។

| ឆ្នាំ | វត្ថុបុរាណ វត្ថុសិល្បៈ និងវត្ថុជាតិពន្ធុសាស្ត្រដែលបានអភិរក្ស | | វត្ថុបុរាណ វត្ថុសិល្បៈ និងវត្ថុជាតិពន្ធុសាស្ត្រដែលបានចុះបញ្ជី | | វត្ថុបុរាណនិងវត្ថុសិល្បៈ ដែលបានរកឃើញនិង | វត្ថុបុរាណ វត្ថុសិល្បៈ ដែលបាន |
|---|---|---|---|---|---|---|
| | ចំនួនដែលបានជួសជុល | ចំនួនដែលបាន | ចំនួនចុះក្នុងបញ្ជីសារពើភណ្ឌ | ចំនួនចុះបញ្ជីក្នុង *Database* | | |

| | | អភិរក្សក្រៅពីការជួសជុល | | | ទទួលបានពីគ្រប់ប្រភព | សិក្សាវិភាគ |
|---|---|---|---|---|---|---|
| ២០១៨ | ៣៨០ | ៧៣៩ | ២ ៥៤៩ | ៤៦៣ | ៦២៤ | ១ ៥៨៣ |
| ២០១៩ | ៣០៨ | ៦៩៥ | ១៧ ៨៧១ | ៨៩៩ | ១៦ ០៥២ | |
| ២០២០ | ២៥៥ | ១៦ ១៦៨ | ៣ ៤១៣ | ៤៥៥ | ៦ ៨២៥ | |
| ២០២១ | ៤៦០ | ១ ៩២៤ | ៤០ ២៣៤ | ៩២៩ | ៤២ ៤៤១ | |
| ២០២២ (៩ខែ) | ១៩៨ | ៣៧២ | ១១ ១៦៩ | ៣ ៧០៧ | ៤ ៣២៥ | |
| **សរុប** | **១ ៦០១** | **១៩ ៩៣៨** | **៧៥ ២៣៦** | **៦ ៤៥៣** | **៧០ ២៦៧** | **១ ៥៨៣** |

- បានអភិរក្សបុរាណដ្ឋានដូចជា៖
  - ធ្វើសាលាកបត្រកាន់កាប់បុរាណដ្ឋានសរុបចំនួន១ ៥៨៨ បុរាណដ្ឋាន និងធ្វើប្លង់ ឬបណ្ណកម្មសិទ្ធិរដ្ឋកាន់កាប់បុរាណដ្ឋានសរុបចំនួន៩៨២បុរាណដ្ឋាន
  - បោះបង្គោលការពារបុរាណដ្ឋានសរុបចំនួន៨៣បុរាណដ្ឋាន ស្មើនឹង៩៥៦បង្គោល
  - ផ្ទៀងផ្ទាត់កំណត់និយាមការ ទំហំ និងដែនការពារបុរាណដ្ឋានសរុបចំនួន២ ២៥៤បុរាណដ្ឋាន
  - សម្អាតនិងរៀបចំសណ្តាប់ធ្នាប់នៅតាមបុរាណដ្ឋានសំខាន់ៗសរុបចំនួន៥១៨បុរាណដ្ឋាន
  - រកឃើញបុរាណដ្ឋានថ្មីសរុបចំនួន១ ១៩៨បុរាណដ្ឋាន។

| សកម្មភាព | | ឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (៩ខែ) | |
| រៀបចំឯកសារកាន់កាប់បុរាណដ្ឋាន | ចំនួនសាលាកបត្រ | ២០០ | ៥៥៦ | ៣០៤ | ១៤០ | ៣៨៨ | **១ ៥៨៨** |
| | ចំនួនប្លង់កម្មសិទ្ធិ | ៨៣ | ១៣៤ | ១៤៣ | ៥២៧ | ៩៥ | **៩៨២** |
| បោះបង្គោលការពារបុរាណដ្ឋាន | ចំនួនបុរាណដ្ឋាន | ៩ | ១០ | ១៣ | ២៦ | ២៥ | **៨៣** |
| | ចំនួនបង្គោល | ៩០ | ២១៥ | ៣៤៤ | ១៨០ | ១២៧ | **៩៥៦** |
| ផ្ទៀងផ្ទាត់និយាមការ ទំហំ និងដែនការពារបុរាណដ្ឋាន | | ២១៥ | ៩០២ | ៦៥៨ | ៤០២ | ៧៧ | **២ ២៥៤** |
| សម្អាតនិងរៀបចំសណ្តាប់ធ្នាប់ | | ១០៩ | ១១៩ | ៩៦ | ៧៥ | ១១៩ | **៥១៨** |
| រកឃើញបុរាណដ្ឋានថ្មី | | ២៧៥ | ៤១៤ | ២៣៥ | ១៥១ | ១២៣ | **១ ១៩៨** |

- បានគ្រប់គ្រងបញ្ហារំលោភដីធ្លីនិងសំណង់ខុសច្បាប់នៅក្នុងតំបន់បេតិកភណ្ឌដូចជា៖
  - ដោះស្រាយបញ្ហារំលោភបំពានដីធ្លីនិងសំណង់ខុសច្បាប់ក្នុងតំបន់បេតិកភណ្ឌនិងនៅតាមបុរាណដ្ឋាននានាសរុបចំនួន១១ ៩៧៦ករណី
  - ពិនិត្យនិងសម្រេចលើសំណើសុំសាងសង់ សំណើសុំជួសជុល និងសំណើសុំកែលម្អសំណង់ផ្សេងៗរបស់ប្រជាពលរដ្ឋ(ទទួលសំណើសុំសរុបចំនួន៩ ១៨៣ករណី បានអនុញ្ញាតតាមសំណើសុំចំនួន៦ ៤១១ករណី និងមិនអនុញ្ញាតតាមសំណើសុំចំនួន៤ ៣៦៦)។

- បានចុះបញ្ជីសារពើភណ្ឌមរតកវប្បធម៌អរូបីសរុបមានចំនួន១៣៦ទម្រង់ រួមមានល្ខោនបាសាក់ ឆៃយ៉ាំ របាំបុរាណ ភ្លេងពិណពាទ្យ របាំប្រពៃណី របាំចម្រុះ តន្ត្រីសម័យ ល្បែងប្រជាប្រិយ ល្ខោនមហោរី ភ្លេងអារក្ស ភ្លេង

ប្រពៃណី ល្ខោនយីកេ ស្បែកធំ ស្បែកតូច ត្បាញសាស់ ខ្លែងឯក ចាប៉ីដងវែង វាយគង១២ កេះគងរ៉េងខ្សែ៩ រកឃ្មុំព្រៃប្រកបដោយនិរន្តរភាព ច្នៃម៉ូដសម្លៀកបំពាក់ជនជាតិដើមភាគតិច ឧបករណ៍ប្រើប្រាស់ពីផ្តៅ ចម្លាក់បុរាណខ្មែរ ធ្វើម្ហូបជនជាតិ ពិធីបុណ្យម៉ាលុត ពីធីបុណ្យច្រត់ព្រះនង្គ័ល សិល្បៈតម្បាញកន្ទេលក្រហម ពិធីឆ្លងចេត្រ និងពិធីឡើងមាយ

- បានស្តារឱ្យរស់ឡើងវិញនូវវប្បធម៌អរូបីសរុបចំនួន៥០ទម្រង់ និង១២សហគមន៍សិល្បៈ រួមមាន ល្ខោនមហោរីរឿង(ព្រះបាទជ័យវរ្ម័នទី២) ល្ខោនបាសាក់រឿង(ឧសថទេវតាធីតាមុខងោះ) របាំចម្រុះ(ព្រាបសន្តិភាព) ល្បែងទាញព្រ័ត្រ ល្បែងប្រជាប្រិយ ជំនាញធ្វើមេជំបែរ វិធីសាស្ត្រចិតស្រាពាង តម្បាញសូត្រ ឌុកស្មាច់ ក្បាច់ចម្លាក់ខ្មែរ តន្ត្រីគង ល្ខោនយីកេ របាំចម្រុះ(ទិវាប្រពៃ៨ឧសភា) របាំប្រពៃណី(ក្ងួយរុំចន្លុះ) ល្ខោនបាសាក់(ថៅទំពាំងមាស) របាំប្រពៃណី(របាំតុំ) របាំប្រពៃណី(អកអំបុក) ចម្លាក់ស្បែក តម្បាញសូត្រ(ហូលពិតាន) គំនូរបុរាណ ក្បាច់ចម្លាក់ខ្មែរ ល្ខោនអាប៉េ ល្ខោនយីកេ ល្ខោនបាមោជូទ័យ សិល្បៈវប្បធម៌របស់សហគមន៍ជនជាតិដើមភាគតិច(របាំបុរាណរបាំប្រពៃណី ជំនាញផ្លុំខ្លុយ ជំនាញផ្លុំអំវ៉ាឡ ជំនាញប្រគំភ្លេងគងរ៉េង ជំនាញប្រគំភ្លេងគងបួន ល្ខោនបុរាណ និងល្ខោនយីកេ) និងសិល្បៈវប្បធម៌របស់សហគមន៍ផ្សេងៗ(របាំប្រពៃណី របាំបុរាណ រឿងកំប្លែង និងល្បែងទាញព្រ័ត្រ)។ល។

- បានពង្រឹងយន្តការផ្ទេរចំណេះ និងជំនាញប្រពៃណីដល់អ្នកជំនាន់ក្រោយតាមរយៈការដាក់បញ្ចូលអ្នកជំនាញផ្នែកសិល្បៈវប្បធម៌ជាមរតកមនុស្សរស់ និងជាវិរសិល្បករ/ការិនីមានចំនួន២៤នាក់(មរតកមនុស្សរស់ចំនួន១៥នាក់ និងវិរសិល្បករ/ការិនីចំនួន៩នាក់) និងកំពុងស្នើសុំដាក់បញ្ចូលជាមរតកមនុស្សរស់បន្ថែមចំនួន២៤នាក់

- បានអភិរក្សឯកសារបុរាណនិងឯកសារចាស់ៗដូចជាជួសជុលសាស្ត្រាស្លឹករឹតចំនួន៣១ ១០៦ខ្សែ ត្រួតពិនិត្យនិងសម្អាតសាស្ត្រាស្លឹករឹតចំនួន៣១ ១០៦ខ្សែ ថតសាស្ត្រាស្លឹករឹតចំនួន១៣១ ៦៧៣ប៉ុស្តិ៍ ស្តែនសៀវភៅចាស់ៗចំនួន៧៧៥ក្បាល(២៦២ ៥៤៩ទំព័រ) ស្តែនកាសែតចាស់ៗចំនួន១៤៨ក្បាល ត្រួតពិនិត្យនិងសម្អាតកាសែត SPK ចំនួន១ ៣២៤ក្បាល ថតកាសែត SPK ចំនួន២៧ ៤២០ប៉ុស្តិ៍ ជួសជុលឯកសារចំនួន១ ៧៤៥ទំព័រ ថតចម្លងឯកសារទៅក្នុងទម្រង់ឌីជីថលចំនួន៤១៣ ៤៥១ទំព័រ។ល។






| | ជួសជុលសាស្ត្រាស្លឹករឹត (ខ្សែ) | ត្រួតពិនិត្យនិងសម្អាតសាស្ត្រាស្លឹករឹត(ខ្សែ) | ថតសាស្ត្រាស្លឹករឹត(ប៉ុស្ដិ៍) | ស្កេនសៀវភៅចាស់ៗ (ក្បាល) | ស្កេនកាសែតចាស់ៗ (ទំព័រ) | ត្រួតពិនិត្យនិងសម្អាតកាសែត SPK(ក្បាល) | ថតកាសែត SPK(ប៉ុស្ដិ៍) | ជួសជុលឯកសារ(ទំព័រ) | ថតចម្លងឯកសារ(ទំព័រ) |
|---|---|---|---|---|---|---|---|---|---|
| ចំនួន | ៣១,១០៦ | ៣១,១០៦ | ១៣១,៦៧៣ | ៧៧៥ | ១៤៨ | ១,៣២៤ | ២៧,៤២០ | ១,៧៤៥ | ៤១៣,៤៥១ |

ប្រភពពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ឆ្នាំ២០២២

## ខ- ការអភិវឌ្ឍវប្បធម៌ជាតិ

បានបង្កើនភាពបៃតងក្នុងតំបន់បេតិកភណ្ឌសរុបចំនួន១ ០៧៤ ៤៨០ម.² រួមមាន៖

- បានដាំដើមឈើថ្មីសរុបចំនួន១៦៥ ៩៩០ដើម(ស្មើនឹង៤៧៨ ៥២៤ម.²)
- បានបង្ក្រាបបទល្មើសព្រៃឈើក្នុងតំបន់បេតិកភណ្ឌសរុបចំនួន៣៤៦ករណី
- បានដាំផ្កានិងស្មៅថ្មីសរុបចំនួន ២៨៦ ០៤៦ម.²
- បានរៀបចំប្រព័ន្ធទឹកស្រោចស្រពដើមឈើ ផ្កា និងស្មៅសរុបចំនួន៣០៩ ៩១០ម.²។

*ទំហំផ្ទៃដីដែលបានបង្កើនភាពបៃតងសរុប ១,០៧៤,៤៨០ ម៉ែត្រការ៉េ*



- បានថែរក្សានិងបង្កើនជីវចម្រុះក្នុងតំបន់បេតិកភណ្ឌដោយបានលែងសត្វទៅក្នុងព្រៃ ក្នុងតំបន់បេតិកភណ្ឌចំនួន៧២ក្បាល(ពស់ថ្លាន់ ស្វា ទោចមកុដ កេងកងតូច កេងកងធំ ញាំង ក្ងោក...) និងបានបង្ក្រាបបទល្មើសបំផ្លាញជីវៈចម្រុះ(នេសាទ បរបាញ់ និងទាក់សត្វព្រៃ..) ក្នុងតំបន់បេតិកភណ្ឌសរុបចំនួន៦៣ករណី

- បានអភិវឌ្ឍនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់បេតិកភណ្ឌដូចជា៖
  - បានសាងសង់និងកែលម្អផ្លូវសរុបប្រមាណ១៤៦ ១៥៣ម. និងស្ពានសរុបប្រមាណ៩២៥ម. រួមមាន៖
    - ផ្លូវដែលបានសាងសង់ថ្មីប្រមាណ៦ ០៣៧ម. ផ្លូវដែលបានកែលម្អប្រមាណ១១៧ ១១៦ម. និងផ្លូវកង់ដែលបានសាងសង់ប្រមាណ២៣ ០០០ម. ដើម្បីការពារភ្លើងនិងសម្រាប់ធ្វើដំណើរថ្មីនៅក្នុងតំបន់រមណីយដ្ឋានអង្គរ ព្រះវិហារ និងសំបូរព្រៃគុក ព្រមទាំងបានកែលម្អផ្លូវដើរដោយក្រាលដុំបេតុងមានដាំស្មៅប្រមាណ១ ៩៥៩,២ម.[២] នៅរមណីយដ្ឋានព្រះវិហារ
    - ស្ពានដែលបានក្រាលបេតុងនៅប្រាសាទនាគព័ន្ធប្រវែងប្រមាណ៣៧៣ម. ស្ពាននៅប្រាសាទបន្ទាយស្រីប្រវែងប្រមាណ៤០៥ម. និងស្ពានកាបផ្លូវកង់ប្រវែងប្រមាណ១៤៧ម. នៅរមណីយដ្ឋានអង្គរ។
  - បានរៀបចំវង់ទស្សនាសម្រាប់ទេសចរណ៍សរុបប្រមាណ១៤ ៦៧៧ម.
  - បានរៀបចំចំណតយានយន្តសម្រាប់ភ្ញៀវមកទស្សនាសរុបប្រមាណ២៧ ៥៣៦ម.[២]
  - រៀបចំមជ្ឈមណ្ឌលផ្តល់ព័ត៌មាននិងបដិសណ្ឋារកិច្ចភ្ញៀវទេសចរណ៍៩ទីតាំង(ស្មើនឹង១០៤ ៣៣៩ម.[២])។

- បានចូលរួមអភិវឌ្ឍសហគមន៍នៅក្នុងតំបន់បេតិកភណ្ឌ តាមរយៈ៖
  - ការរៀបចំវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈចំនួន២៦វគ្គ ដល់ប្រជាពលរដ្ឋសរុបចំនួន៥៧៨នាក់(ស្មើនឹងចំនួន៥៦៣គ្រួសារ) លើជំនាញកសិកម្មនិងជំនាញផ្សេងៗទៀត
  - ការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីជួយសម្រួលជីវភាពរបស់ប្រជាជននៅក្នុងសហគមន៍ រួមមានអណ្តូងស្នប់ចំនួន១១៣ និងស៊ីទែនទឹកចំនួន១ (ទឹកស្អាតសម្រាប់ប្រើប្រាស់) ស្រះទឹកសម្រាប់កសិកម្មចំនួន៤ និងបង្គន់អនាម័យចំនួន៩។

- បានជំរុញការបង្កើតផលិតផលនិងសេវាវប្បធម៌ថ្មីៗសរុបចំនួន១១ ៦៣៧ ៤៤២សេវា រួមមាន៖
  - សេវាផ្នែកវប្បធម៌រូបីចំនួន១០ ៨៣៥សេវា(សេវាពិនិត្យវត្ថុសិល្បៈនាំចេញ នាំចូលចំនួន១០ ១២៥សេវា) ដោយទទួលបានថវិកាសរុបចំនួន២៩៦ ៧២១ ២២០រៀល
  - សេវាផ្នែកវប្បធម៌អរូបីសរុបចំនួន១១ ៦២៧ ៨១៤សេវា( សេវាផ្នែកភាពយន្តនិងវីដេអូចំនួន ១១ ៦១៩ ៨៤៩ សេវាផ្នែកសិទ្ធិអ្នកនិពន្ធនិងប្រហាក់ប្រហែលចំនួន១ ៥៥៤ ផ្នែកសៀវភៅនិងការអានចំនួន២ ៩៨៧ សេវាការិយាល័យច្រកចេញចូលតែមួយចំនួន២ ៩២៧សេវាថតរូបភាពក្នុងតំបន់រមណីយដ្ឋានអង្គរចំនួន១៧៥ និងការរៀបចំពិធីសម្តែងសិល្បៈទទួលទានអាហារតាមប្រាសាទនានាក្នុងតំបន់អង្គរ៣២២) និងទទួលបានថវិកា១ ១៤៤ ៩៧៥ ៥៦៧ រៀល និង១ ០៥២ ៩៥១,៥០ ដុល្លារអាម៉េរិក(បង់ចូលថវិការដ្ឋ)។

- ទទួលភ្ញៀវចូលទស្សនាទីតាំងវប្បធម៌សរុប១២ ៦៧២ ០៥៥នាក់(ភ្ញៀវអន្តរជាតិ៧ ៥១០ ១៤៧នាក់) រួមមាន៖
  - បានទទួលភ្ញៀវចូលទស្សនានៅទីតាំងវប្បធម៌រូបីចំនួន១២ ៥៩៦ ០៣៣នាក់ (ភ្ញៀវអន្តរជាតិចំនួន ៧ ៥០៣ ៦២៧នាក់) នៅរមណីយដ្ឋានបេតិកភណ្ឌពិភពលោក(អង្គរ ព្រះវិហារ សំបូរព្រៃគុក) សារមន្ទីរ

នៅថ្នាក់ជាតិ(សារមន្ទីរជាតិ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង) ទីតាំងវប្បធម៌នានានៅតាមរាជធានី ខេត្ត(ប្រាសាទកោះកេរ ប្រាសាទផ្សេងៗសារមន្ទីរ និងរមណីយដ្ឋានវប្បធម៌នានានៅតាមរាជធានី ខេត្ត)

- បានទទួលភ្ញៀវចូលទស្សនានៅទីតាំងវប្បធម៌អរូបីសរុប៧៦ ០២២នាក់(ភ្ញៀវអន្តរជាតិ៦ ៥២០នាក់) ក្នុងនោះរួមមាននៅវិចិត្រសាល/សាលពិព័រណ៍៣៧ ១៤០នាក់ និងនៅទីតាំងវប្បធម៌អរូបីផ្សេងៗចំនួន៣៨ ៨៨២នាក់។

- បានដំឡើងស្នាដៃសិល្បៈទស្សនីយភាពថ្មីៗ(បុរាណ ប្រពៃណី សហសម័យ...) ចំនួន១៥៧ស្នាដៃ(កំពុងដំឡើងចំនួន១៣ស្នាដៃ) រួមមានរឿងដំណើរជីវិតនិងជីវិតខ្ញុំ ល្បែងតែងវិនាស មច្ឆរាជពណ៌ស របាំនេសាទថ្មីលើទឹកដីកោះជីវាំង របាំត្រុដិ របាំដងទឹករបស់ជនជាតិគ្រឹង របាំប្រពៃណីចចូត ល្ខោនខោល របាំព្រាបសន្តិភាព របាំកម្ពុជា ចិន សំណោកបរិស្ថាន របាំល្បុក្កតោ របាំកន្ត្រកជាងត្នោត។ល។

- បាននិងកំពុងផលិត ព្រមទាំងជំរុញឱ្យមានការផលិតភាពយន្តនិងវីដេអូនៅក្នុងប្រទេសកម្ពុជាសរុប ចំនួន៣ ៨១៧ចំណងជើង(កំពុងផលិតចំនួន១១) រួមមានភាពយន្តខ្មែរចំនួន២៨៨ចំណងជើង ភាពយន្តបរទេសចំនួន៩ចំណងជើង ភាពយន្តឬវីដេអូឯកសារផ្សព្វផ្សាយចំនួន៣០០ចំណងជើង កម្មវិធីទូរទស្សន៍(ខ្មែរនិងបរទេស) ចំនួន៣៧ចំណងជើង វីដេអូPre-Wedding ចំនួន៣ ១៤៧ចំណងជើង និងភាពយន្តឬវីដេអូផ្សេងៗចំនួន៣៦ចំណងជើង

- បានអនុញ្ញាតឱ្យភ្ញៀវចូលអានសៀវភៅក្នុងបណ្ណាល័យជាតិសរុបចំនួន១៨៥ ០៥១នាក់ និងឱ្យភ្ញៀវខ្ចីសៀវភៅចំនួន៨ ៩០៦ក្បាល។






## គ- សេវាគាំទ្រដល់ការអភិវឌ្ឍ លើកស្ទួយ និងអភិរក្សវប្បធម៌ជាតិ

### គ.១- ការចុះបញ្ជីមរតកវប្បធម៌ជាបេតិកភណ្ឌពិភពលោកនិងបេតិកភណ្ឌជាតិ

- បានរៀបចំចុះមរតកវប្បធម៌ជាបេតិកភណ្ឌពិភពលោក និងជាបេតិកភណ្ឌជាតិសរុបចំនួន១១៧ រួមមានបេតិកភណ្ឌពិភពលោកចំនួន១៥(បានចុះបញ្ជីរួចចំនួន១ កំពុងស្នើចុះបញ្ជីចំនួន៣ និងដាក់ក្នុងបញ្ជីត្រៀម "Tentative List" ចំនួន១១) និងបេតិកភណ្ឌជាតិចំនួន១០២ រួមមាន៖

- បញ្ជីបេតិកភណ្ឌពិភពលោកចំនួន៤ រួមមានល្ខោនខោលវត្តស្វាយអណ្តែត(បានចុះបញ្ជីរួច) តំបន់រមណីយដ្ឋានកោះកេរ(កំពុងស្នើសុំចុះបញ្ជី) គុនល្បុក្កតោខ្មែរ(កំពុងស្នើសុំចុះបញ្ជី) និងនំបញ្ចុក(កំពុងស្នើសុំចុះបញ្ជី) ព្រមទាំងកំពុងរៀបចំបញ្ជីត្រៀម(Tentative List) នៃមរតកវប្បធម៌ដែលត្រូវស្នើសុំចុះបញ្ជីនាពេលអនាគតសរុបចំនួន១១ រួមមានក្រុមប្រាសាទបន្ទាយឆ្មារ ក្រុមប្រាសាទបេងមាលា ក្រុមប្រាសាទព្រះខ័នកំពង់ស្វាយ រមណីយដ្ឋានអង្គរបុរីនិងភ្នំដា រមណីយដ្ឋានភ្នំឧដុង្គ រមណីយដ្ឋានភ្នំគូលេន បន្ទាយព្រៃនគរ មន្ទីរស.២១ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង មជ្ឈមណ្ឌលប្រល័យពូជសាសន៍ ជើងឯក និងព្រះរាជពិធីបុណ្យអុំទូក អកអំបុក បណ្តែតប្រទីប និងសំពះព្រះខែ។ល។
- បញ្ជីបេតិកភណ្ឌជាតិចំនួន១០២(បានចុះបញ្ជីរួចចំនួន៩៨ និងកំពុងពិនិត្យចុះបញ្ជីចំនួន៤) រួមមានព្រះវិហារ ចេតិយ កុដិ ធម្មមន្ទីរ ហោត្រ័យ បណ្ណាល័យ ព្រះមេរុ សាលាឆាន់ស្លូបមរតកភាសា សិល្បៈទស្សនីយភាព ទំនៀមទម្លាប់និងកិច្ចពិធី ចំណេះចំណាំអំពីធម្មជាតិនិងចក្រវាឡ សិប្បកម្មប្រពៃណី ពិធីសែនដែករបស់សហគមន៍ជនជាតិកួយ ពិធីច្រត់ព្រះនង្គ័លក្នុងតំបន់ប្រាសាទសំបូរព្រៃគុក សម្លប្រហុង និងសម្លម្ជូរ។ល។

ចំនួនមរតកវប្បធម៌ជាបេតិកភណ្ឌលោក និងជាបេតិកភណ្ឌជាតិដែលបានចុះបញ្ជី




ប្រភពពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ឆ្នាំ២០២២

### គ.២- ការផ្សព្វផ្សាយនិងលើកស្ទួយវប្បធម៌ជាតិ

- បានរៀបចំនិងសហការរៀបចំកម្មវិធីនិងព្រឹត្តិការណ៍សរុបចំនួន៧៣៤ ដោយមានអ្នកចូលរួមសរុប ចំនួន ១ ៦២០ ៩៨៦នាក់ ក្នុងនោះកម្មវិធីនិងព្រឹត្តិការណ៍នៅក្រៅប្រទេសមានចំនួន២៨១(មានអ្នកចូលរួមចំនួន៥២១ ០២៩ នាក់) កម្មវិធីនិងព្រឹត្តិការណ៍ដើម្បីគាំទ្រដល់ការផ្សព្វផ្សាយនិងលើកស្ទួយវប្បធម៌ជាតិមានចំនួន៣៩៥ (មានអ្នកចូលរួម ១ ៥៣៤ ៦៣៥នាក់) និងកម្មវិធីនិងព្រឹត្តិការណ៍ ដើម្បីគាំទ្រដល់ការអភិវឌ្ឍតាមរយៈការជំរុញដល់ការបង្កើតផលិតផលនិងវប្បធម៌ថ្មីៗចំនួន៣៣៩(មានអ្នកចូលរួម៨៦ ៣៩១នាក់)។ កម្មវិធីនិងព្រឹត្តិការណ៍ទាំងនោះ រួមមាន៖

- មហោស្រពចំនួន៣៥២ អ្នកចូលរួមចំនួន១១២នាក់
- ពិព័រណ៍ចំនួន៦៥ អ្នកចូលរួមចំនួន៧៥៣ ៥៤៨នាក់
- សិក្ខាសាលា/បាឋកថាចំនួន១៣៦ អ្នកចូលរួមចំនួន៨ ៦៦០នាក់
- ទិវានិងបុណ្យវប្បធម៌ផ្សេងៗចំនួន១៨១ អ្នកចូលរួមចំនួន១៩០ ៦៦៦នាក់។

| | | | |
|---|---|---|---|
| កម្មវិធី/ព្រឹត្តិការណ៍ | នៅក្រៅប្រទេស | ចំនួនលើក | ២៨១ |
| | | ចំនួនអ្នកចូលរួម | ៥២១ ០២៩ |
| | គាំទ្រដល់ការផ្សព្វផ្សាយនិងលើកស្ទួយវប្បធម៌ជាតិ | ចំនួនលើក | ៣៩៥ |
| | | ចំនួនអ្នកចូលរួម | ១ ៥៣៤ ៦៣៥ |
| | គាំទ្រដល់ការអភិវឌ្ឍតាមរយៈការជំរុញដល់ការបង្កើតផលិតផល និងវប្បធម៌ថ្មីៗ | ចំនួនលើក | ៣៣៩ |
| | | ចំនួនអ្នកចូលរួម | ៨៦ ៣៩១ |
| | មហោស្រព | ចំនួនលើក | ៣៥២ |
| | | ចំនួនអ្នកចូលរួម | ៦៦៨ ១១២ |

| | | | |
|---|---|---|---|
| | ពិព័រណ៍ | ចំនួនលើក | ៦៥ |
| | | ចំនួនអ្នកចូលរួម | ៧៥៣ ៥៤៨ |
| | សិក្ខាសាលា/បាឋកថា | ចំនួនលើក | ១៣៦ |
| | | ចំនួនអ្នកចូលរួម | ៨ ៦៦០ |
| | ទិវានិងបុណ្យវប្បធម៌ផ្សេងៗ | ចំនួនលើក | ១៨១ |
| | | ចំនួនអ្នកចូលរួម | ១៩០ ៦៦៦ |

- បានផ្សព្វផ្សាយកម្មវិធី ព្រឹត្តិការណ៍ និងសកម្មភាពការងារនៅលើបណ្ដាញសង្គមហ្វេសប៊ុកសរុបចំនួន ៨០០ ៩៤៤លើក(អ្នកចូលមើលចំនួន១១៤ ៩០២ ៣៤១នាក់) ដើម្បីលើកស្ទួយវប្បធម៌រូបីចំនួន៧៩៩ ៦៦១ លើក(អ្នកចូលមើលចំនួន១១២ ៩៩៩ ០៨១នាក់) និងលើកស្ទួយវប្បធម៌អរូបីចំនួន១ ២៨៣លើក(អ្នកចូលរួមមើលចំនួន១ ៩០៣ ២៦០នាក់)

- បានរៀបចំនិងសហការរៀបចំការសម្ដែងសិល្បៈនិងប្រគំតន្ត្រីខ្មែរសរុបចំនួនប្រមាណ២ ៨៩៣លើក ដោយមានអ្នកទស្សនាសរុបប្រមាណ៩៨៨ ២៨៦នាក់ រួមមាននៅក្រៅប្រទេសប្រមាណ៦៨លើក(មានអ្នកទស្សនាប្រមាណ២០ ២០៧នាក់) និងនៅក្នុងប្រទេសចំនួន២ ៨២៥លើក(មានអ្នកទស្សនាប្រមាណ៩៦៨ ០៧៩នាក់)

- បានអនុញ្ញាតឱ្យបរទេសខ្ចីវត្ថុបុរាណចំនួនសរុប១៤៩រូប/វត្ថុ និងកំពុងពិនិត្យសំណើសុំខ្ចីវត្ថុបុរាណថ្មីៗដើម្បីយកទៅតាំងពិព័រណ៍និងកម្មវិធីផ្សេងៗចំនួនសរុប១២៧រូប/វត្ថុ។

| | | | | |
|---|---|---|---|---|
| សកម្មភាពដើម្បីលើកស្ទួយវិស័យវប្បធម៌ | បានផ្សព្វផ្សាយកម្មវិធី ព្រឹត្តិការណ៍ និងសកម្មភាពការងារ | ចំនួនលើកស្ទួយវប្បធម៌រូបី | | ៧៩៩ ៦៦១ |
| | | ចំនួនលើកស្ទួយវប្បធម៌អរូបី | | ១ ២៨៣ |
| | បានរៀបចំនិងសហការរៀបចំសម្ដែងសិល្បៈនិងប្រគំតន្ត្រី | នៅក្រៅប្រទេស | ចំនួនលើក | ៦៩ |
| | | | ចំនួនអ្នកទស្សនា | ២០ ២០៧ |
| | | នៅក្នុងប្រទេស | ចំនួនលើក | ២ ៨២៥ |
| | | | ចំនួនអ្នកទស្សនា | ៩៦៨ ០៧៩ |
| | កម្ចីវត្ថុបុរាណទៅក្រៅប្រទេស | ចំនួនបានអនុញ្ញាតឱ្យខ្ចី | | ១៤៩ |
| | | ចំនួនកំពុងពិនិត្យសំណើសុំខ្ចីវត្ថុបុរាណថ្មីៗ | | ១២៧ |

### គ.៣- ការសិក្សាស្រាវជ្រាវ ចងក្រង បកប្រែ និងបោះពុម្ព

- ប្រធានបទដែលបាននិងកំពុងសិក្សាស្រាវជ្រាវមានចំនួនសរុប១២៦ (ប្រធានបទដែលបានបោះពុម្ពរួចចំនួន៧៦ និងមិនទាន់បានបោះពុម្ពចំនួន៥០) រួមមាន៖

  ▪ ផ្នែករូបីចំនួន១៨ប្រធានបទ ដូចជាសៀវភៅកំពង់ធំ(ប្រវត្តិសាស្ត្រ និងប្រាសាទបុរាណ) តារាងស្ថិតិស្ថានីយបុរាណទូទាំងខេត្តកណ្ដាល សាលាកបត្រស្ថានីយបុរាណទូទាំងខេត្តកណ្ដាល បញ្ជីសារពើភណ្ឌស្ថានីយបុរាណប្រទេសកម្ពុជា ក្នុងរាជធានីភ្នំពេញ២០១៤ ពិចារណាលើតួនាទីសំខាន់ៗរបស់ព្រះនាងប្រាជ្ញាបារមីតានៅកម្ពុជាសម័យអង្គរ២០២២ (អត្ថបទសម្រាប់ដាក់ក្នុងទស្សនាវដ្ដីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ) ការសិក្សាស្រាវជ្រាវអំពីសម្បត្តិបេតិកភណ្ឌជាតិក្នុងខេត្តឧត្តរមានជ័យ ភាគ១ ឯកសារប្រាសាទបន្ទាយឆ្មារ ដើម្បីដាក់បញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ប្រវត្តិសាស្ត្រប្រទេសកម្ពុជាសម័យមុនអង្គរ ស្ថានភាពប្រជាជន លំនៅឋាននិងដីលំនៅឋាន(ភូមិអូរគ្រូកែ ភូមិជាយសំពៅ ភូមិសំបូរ ភូមិ

អាត់ស៊ូនិងភូមិកំពង់ឈើទាល) បញ្ជីបម្រុងបេតិកភណ្ឌ(ប្រាសាទបេងមាលា ប្រាសាទ បាកាណ ក្រុងឧត្តុង្គ និងក្រុងអង្គរបុរី)។ល។

- ផ្នែកអរូបីចំនួន១០៨ប្រធានបទ ដូចជាពិធីចូលម្លប់ ពិធីសែនដេញក្រពើចាប់ត្រី ពិធីរៀបគ្រូមេមត់ ពិធីលៀងមេមត់ ភ្លេងលៀងមេមត់ ពិធីឡើងអ្នកតា ចម្រៀងនិងភ្លេងអារក្ស ម្ហូបប្រចាំតំបន់ ផ្គើរក្រវាញ ភ្លេងក្លយ ល្បែងប្រជាប្រិយខ្មែរ ប្រវត្តិអំបុកខ្មែរ ប្រវត្តិចម្លាក់ខេត្តពោធិ៍សាត់ ពិធីឡើងរោងលោកឧកញ៉ាឃ្លាំងមឿង ប្រវត្តិបុណ្យពូនភ្នំស្រូវ ប្រវត្តិខ្លែងខ្មែរបុណ្យសង្ឃ័យនា(បុណ្យបើកព្រះនេត្រ) សិក្សាអំពីប្រវត្តិរបាំក្ងោក សិក្សាអំពីប្រវត្តិជនជាតិកូឡានិងតាំងយូ តម្បាញក្រណាត់(ជនជាតិទំពួន) តម្បាញឫស្សី(ជនជាតិគ្រឹង) វង់តន្ត្រីពិណពាទ្យ ប្រវត្តិខ្លែងខ្មែរ សិល្បៈខ្នុកស្មាច់ សិល្បៈចម្លាក់ស្បែក សិល្បៈតម្បាញសូត្រ សម្ភារៈប្រើប្រាស់ផ្ទះខ្មែរ ក្បាច់មូលដ្ឋានរបាំប្រពៃណី ក្បាច់បាតនាយរោង ក្បាច់បាតយក្សខ្លីមេដំបែស្រា កន្ទេលផ្កាវ ពិធីអកអំបុក ខេត្តសៀមរាប សៀវភៅបញ្ជីសារពើភណ្ឌមរតកវប្បធម៌អរូបីវង់តន្ត្រីពិណពាទ្យ គំនូរព្រះពុទ្ធ។ល។

- បានបកប្រែឯកសារពីភាសាបរទេសមកជាភាសាខ្មែរ សរុបចំនួន១៤៨ឯកសារ(បានបោះពុម្ពរួចចំនួន១៣ឯកសារនិងមិនទាន់បោះពុម្ពចំនួន ១៣៥ឯកសារ) រួមមានអនុសញ្ញាសាកលស្តីពីសិទ្ធិអ្នកនិពន្ធ អនុសញ្ញាស្តីពីកិច្ចការពារបេតិកភណ្ឌពិភពលោកឆ្នាំ១៩៧២(Basic Texts of the 1972 World Heritage Convention) នីតិវិធីដំណើរបញ្ចូលសម្បត្តិក្នុងបញ្ជីបេតិកភណ្ឌពិភពលោក(Procedures for the Inscription of Properties on the World Heritage List) នីតិវិធីស្តីពីការដាក់បញ្ចូលបេតិកភណ្ឌអរូបីទៅក្នុងបញ្ជីអតិរក្សបន្ទាន់ និងបញ្ជីតំណាងបេតិកភណ្ឌ អរូបីនៃមនុស្សជាតិ(Procedures for Inscription on the List of Intangible Cultural Heritage in Need of Urgent Safeguarding and on the Representation List of the Intangible Cultural Heritage of Humanity) អនុសញ្ញាស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌អរូបី ឆ្នាំ២០០៣ (Basic Texts of the 2003 Convention for the Safeguarding of the Intangible Cultural Heritage) ការគ្រប់គ្រងទេសចរណ៍នៅរមណីយដ្ឋានបេតិកភណ្ឌវប្បធម៌ និងធម្មជាតិពិភពលោក ការរៀបចំឯកសារស្នើចុះបញ្ជីបេតិកភណ្ឌពិភពលោក (Preparing World Heritage Nominations) ទេសចរណ៍ដោយនិរន្តរភាពនិងបេតិកភណ្ឌធម្មជាតិពិភពលោក(Sustainable tourism and natural World Heritage) ឯកសារកំពង់ធំ(ប្រវត្តិសាស្ត្រនិងប្រាសាទបុរាណ) ការគ្រប់គ្រងបេតិកភណ្ឌពិភពលោក (Managing Cultural World Heritage)បេតិកភណ្ឌពិភពលោកនិងតំបន់ការពារ(World Heritage and Buffer Zones) ការប្រកួតប្រជែងស្តីពីការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌(Competence from work for Cultural Heritage Management) កម្រងពាក្យបច្ចេកទេសទាក់ទងនឹងដំណើរពុកផុយថ្មរបស់ ICOMOS-ISCS។ល។

### គ.៤- កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ

ទទួលការចូលរួមសហការពីដៃគូជាតិនិងអន្តរជាតិសរុបចំនួន៣១ដៃគូ(ដៃគូជាតិចំនួន៧ និងដៃគូអន្តរជាតិចំនួន២៤) ព្រមទាំងបានចូលរួមសហការនិងគាំទ្រដល់សកម្មភាពរបស់ដៃគូជាតិនិងអន្តរជាតិសរុបចំនួន៦៤(កំពុងចូលរួមសហការគាំទ្រចំនួន១១) រួមមានរបាំតន្ត្រីគង១២ផ្លែ របាំតន្ត្រីគងភូមិខ្ញុំរស់ឡើងវិញ គូរគំនូរចម្លាក់ស្បែកពណ៌រឿងចៅគីង្កក់ចំនួន១៤ផ្ទាំង សិល្បៈគំនូរសហសម័យរបស់ភាគីសមាគមកម្ពុជា ជប៉ុន ល្ខោនអប់រំខ្លី(សំណោកប្រើសមេ) គម្រោងស្រាវជ្រាវកំណត់ធនធានមនុស្សក្នុងវិស័យវប្បធម៌ និងឧស្សាហកម្មច្នៃប្រឌិតក្រៅប្រព័ន្ធរបស់

អង្គការសិល្បៈខ្មែរអមតៈ បង្ហាត់បាំប្រពៃណីដល់បុរីកុមារ របាំកាប់ក្របីផឹកសែនភូមិ ពិព័រណ៍សូត្រនិងព្រឹត្តិការណ៍សូត្រ ពិព័រណ៍ផលិតផលសូត្រនិងព្រឹត្តិការណ៍សូត្រកម្ពុជា ពិព័រណ៍សំលៀកបំពាក់ខ្មែរក្នុងកម្មវិធីមហោស្រពអប់រំនិងវប្បធម៌យុវជនអន្តរជាតិ កម្មវិធីតាំងពិព័រណ៍ 9th Asian International Art Exhibition Qingdao គម្រោង "ASEAN Small and Medium Sized Enterprises Caravan Project" «ព្រឹត្តិការណ៍ពិព័រណ៍ចិន អាស៊ាន និងសប្តាហ៍សិល្បៈចិនអាស៊ាន» និងពិព័រណ៍សិល្បៈមិនអចិន្ត្រៃយ៍ស្តីពីសិល្បៈគំនូរសហសម័យរបស់ភាគីសមាគមកម្ពុជាជប៉ុន កិច្ចពិភាក្សាលើប្រធានបទស្តីពី«ការស្ទាបស្ទង់នៃការសិក្សាសិលាចារឹកនៅលើផែនដីអាស៊ីអាគ្នេយ៍នៅមជ្ឈមណ្ឌលខេមរៈភាសា(CKS)»ចូលរួមការតាំងពិព័រណ៍ការងារ«អង្គការសម្រេចសុបិន្តកុមារកម្ពុជា» ព្រឹត្តិការណ៍«រំលឹកគុណអង្គរ»។ល។

**២.២- ការងារសាសនា**( គេហទំព័រ www.mocar.gov.kh )

**ក្រសួងធម្មការនិងសាសនា សម្រេចការងារបានដូចខាងក្រោម៖**

**ក- ការងារកិច្ចការព្រះពុទ្ធសាសនា**

**ស្ថិតិវត្តអារាម និងព្រះសង្ឃ**

| សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| ចំនួនវត្តអារាម | ៤ ៩៨៥ | ៥ ០២៥ | ៥ ០៤៥ | ៥ ០៥៥ | ៥ ០៥៦ |
| ចំនួនព្រះសង្ឃ | ៧០ ៨៥៣ | ៦៨ ៧១៦ | ៦៨ ៩៤០ | ៧០ ៩០៥ | ៧០ ៩០៥ |

- រៀបចំអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសចំនួន៣លើក
- រៀបចំទិវាព្រះពុទ្ធសាសនាអន្តរជាតិ៨ មេសា ចំនួន៣លើក( ក្នុងឆ្នាំ២០១៨)
- ជូននិងទទួលព្រះរាជដំណើរ សម្តេចសង្ឃទាំងពីរគណៈយាងបំពេញបេសកកម្មក្រៅប្រទេស ចំនួន១៦៧លើក
- រៀបចំប្រកាសនីយបត្រតែងតាំងមន្ត្រីសង្ឃចំនួន៧ ៦៣១អង្គ
- អនុញ្ញាតឱ្យរៀបចំពិធីបុណ្យបញ្ចុះខណ្ឌសីមាចំនួន៥៩វត្ត
- ថ្នាក់ដឹកនាំអញ្ជើញចូលរួមពិធីបុណ្យវិសាខបូជា នាភ្នំព្រះរាជទ្រព្យចំនួន៤លើក
- រៀបចំនិងចេញប្រកាសអនុញ្ញាតឱ្យបង្កើតវត្តចំនួន១៣០វត្ត
- រៀបចំនិងចេញប្រកាសអនុញ្ញាតឱ្យប្រែក្លាយពីអាស្រមទៅជាវត្តចំនួន១១វត្ត
- អនុញ្ញាតឱ្យរុះរើឧបដ្ឋានសាលាចាស់ក្នុងវត្តចំនួន៣វត្ត និងកសាងព្រះវិហារថ្មីចំនួន១៤វត្ត
- ចុះស្រង់ស្ថិតិវត្តដែលបានចុះបញ្ជីដីវត្តទូទាំងប្រទេស( សម្រាប់ឆ្នាំ២០២២) និងចងក្រងស្ថិតិវត្តល្បីៗនៅទូទាំងប្រទេសចំនួន១៤៤វត្ត
- ស្រង់ស្ថិតិព្រះសង្ឃទូទាំងប្រទេស ដែលមានព្រះជន្មពី១៨ ដល់៥៩វស្សា ជូនអនុគណៈកម្មការចំពោះកិច្ចសម្រាប់ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ចំនួន៦៤ ៨៦៤អង្គ
- រៀបចំនិងជូនរបាយការណ៍ស្តីពីគ្រោះមហន្តរាយសម្រាប់ឆមាសទី១(ឆ្នាំ២០២២) ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

- ធ្វើសេចក្តីណែនាំផ្សេងៗ រួមមានព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម**ព្រះករុណាព្រះបាទ សម្តេចបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ចំនួន៥លើក **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គលចំនួន៥លើក ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់**ព្រះករុណាព្រះបាទសម្តេចបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ចំនួន៥លើក និងទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ**ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** ចំនួន៥លើក ស្តីពីពីធីបុណ្យមាឃបូជាចំនួន៥លើក វិសាខបូជាចំនួន៥លើក បុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌចំនួន៥លើក និងទិវាប្រកាសរដ្ឋធម្មនុញ្ញចំនួន៥លើក។

## ខ- ការងារពាហិរសាសនា

### ស្ថិតិពាហិរសាសនា

| សូចនាករ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| **អ៊ិស្លាមសាសនា** | | | | | |
| វិហារ | ៥១៦ | ៥៦៨ | ៥៧០ | ៥៧៦ | ៥៩៣ |
| ស្នាក់ការថ្វាយបង្គំ/ស៊ូរ៉ាវ | ៦៧៥ | ៧៦២ | ៧៩២ | ៧៩៧ | ៨២៨ |
| សាលារៀនសាសនា | ៥១៨ | ៥២៩ | ៥៤១ | ៥៥៧ | ៥៩៨ |
| អង្គការ សមាគម | ១៥ | ២១ | ២៣ | ២៤ | ៤០ |
| បរិស័ទ | ៤៤៧ ៩៨៧ | ៤១៤ ៧៥៤ | ៥០៧ ៨៥១ | ៥៣០ ៥៣៧ | ៥៣៧ ៣៧០ |
| **គ្រិស្តសាសនា** | | | | | |
| **កាតូលិក** | | | | | |
| វិហារ | ៦៤ | ៦៨ | ៦២ | ៦៣ | ៦៦ |
| ស្នាក់ការថ្វាយបង្គំ | ៤៤ | ៣៩ | ៤១ | ៤៨ | ៤២ |
| សាលារៀនសាសនា | ៦០ | ៦១ | ៦០ | ៥៩ | ៥៨ |
| បរិស័ទ | ១២ ៣៤០ | ១៣ ៤០៧ | ១៣ ៤៤៦ | ១២ ៧៣៩ | ១៣ ១៦៥ |
| **ប្រូតេស្តង់** | | | | | |
| វិហារ | ៥៨៩ | ៦២៦ | ៦៧៥ | ៧២៦ | ៦០១ |
| ស្នាក់ការថ្វាយបង្គំ | ១ ៣៤៧ | ១ ៣៤០ | ១ ៤១២ | ១ ៤៣៩ | ១ ៥២២ |
| សាលារៀនសាសនា | ៧៦៧ | ៨២៩ | ៨៦៩ | ១០១៣ | ៨៨៣ |
| អង្គការ សមាគម (កាតូលិក និងប្រូតេស្តង់) | ១១៧ | ១១៥ | ១៣១ | ១១៧ | ៩២ |
| បរិស័ទ | ៩៧ ៣៧៤ | ៩៦ ៥៩២ | ៩៨ ៩៧០ | ១០២ ៣៨៤ | ៩៦ ៥៨៧ |
| **មហាយាន** | | | | | |
| វិហារ | ១៤៨ | ១៤៩ | ១៥៣ | ១៦៣ | ១៥២ |
| ស្នាក់ការថ្វាយបង្គំ | ៣៦ | ២៩ | ៤៨ | ៤៩ | ៥១ |
| សាលារៀនសាសនា | ៣៦ | ៤៥ | ៤០ | ៥៧ | ៤៦ |

| | | | | | |
|---|---|---|---|---|---|
| អង្គការ សមាគម | - | - | - | - | - |
| បរិស័ទ | ១៦ ៩៦៩ | ១៧ ៩៨៦ | ២២ ៩៦៥ | ៣៦ ៧២៨ | ២២ ២៩៦ |
| **បាហៃ** | | | | | |
| វិហារ | ៥ | ៣ | ៥ | ២ | ៣ |
| ស្នាក់ការថ្វាយបង្គំ | ១៥ | ១៥ | ១៤ | ១៥ | ២៣ |
| សាលារៀនសាសនា | ៤ | ៣ | ៨ | ៥ | ៦ |
| អង្គការ សមាគម | - | - | - | - | - |
| បរិស័ទ | ៤ ០០៣ | ២ ៦៥៥ | ៥ ៤១៧ | ២ ៨០៤ | ២ ៩៩១ |
| **កៅដាយ និងសាសនាផ្សេងៗ** | | | | | |
| វិហារ | ៣ | ២ | ៣ | ២ | ២ |
| ស្នាក់ការថ្វាយបង្គំ | - | ១ | - | ១ | ១ |
| សាលារៀនសាសនា | ១ | - | - | - | - |
| អង្គការ សមាគម | - | - | - | - | - |
| បរិស័ទ | ១ ៨២៨ | ៤៨៩ | ៥០៥ | ៤៤០ | ៤៦០ |

- រៀបចំសិក្ខាសាលាស្ដីពីកិច្ចសន្ទនាអន្តរជំនឿសាសនា ដើម្បីសុខដុមនីយកម្មសាសនាចំនួន៣លើក ដែលមានថ្នាក់ដឹកនាំគ្រប់សាសនាតាមបណ្តារាជធានី ខេត្ត ចូលរួមចំនួន២ ៧០០អង្គ/នាក់ ដោយផ្តោតលើប្រធានបទពាក់ព័ន្ធនឹងបញ្ហាប្រឈមដូចជាចរាចរណ៍ គ្រឿងញៀន និងជំងឺកូវីដ-១៩ ជាដើម

- សហការរៀបចំពិធីសំណេះសំណាល និងពិសាអាហារសាមគ្គីរវាង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាមួយថ្នាក់ដឹកនាំគ្រិស្តបរិស័ទនៅកម្ពុជាចំនួន២លើក មានអ្នកចូលរួមឆ្នាំ២០១៨ ចំនួន៣ ០០០នាក់ ឆ្នាំ២០១៩ ចំនួន៣ ០០០នាក់

- សហការរៀបចំពិធីសំណេះសំណាលនិងពិសាអាហារស្រាយបួស **«ខែរ៉ាម៉ាឌន»** រវាង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាមួយសាសនិកអ៊ិស្លាមនៅកម្ពុជាចំនួន២លើក ដែលមានអ្នកចូលរួមក្នុងនោះ ឆ្នាំ២០១៨ ចំនួន៣ ៥០០នាក់ និងឆ្នាំ២០១៩ ចំនួន៥ ០០០នាក់

- បញ្ឈប់ការចុះបញ្ជីនិងតម្កល់លក្ខន្តិកៈសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល គ្រប់ប្រភេទនៅក្រសួង និងណែនាំឱ្យទៅចុះបញ្ជីស្របតាមច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល

- សម្រេចចេញសារាចរណែនាំស្តីពីការចុះបញ្ជីពាហិរសាសនា ដើម្បីពង្រឹងការគ្រប់គ្រង ជានាសេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនាក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿឬសាសនាដទៃដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ

- សម្រេចអនុញ្ញាតឱ្យចុះបញ្ជីចំនួន២២៣កន្លែងថ្វាយបង្គំ ក្នុងនោះអ៊ិស្លាម២កន្លែង គ្រិស្តចំនួន១៨៧ មហាយាន៣៤កន្លែង(បើគិតតាម ឆ្នាំ២០១៨ ចំនួន៤៦កន្លែង ឆ្នាំ២០១៩ ចំនួន៧៤កន្លែង ឆ្នាំ២០២០ ចំនួន២៣កន្លែង ឆ្នាំ២០២១ ចំនួន២៦កន្លែង និងឆ្នាំ២០២២ ចំនួន៥៤កន្លែង)

- សម្រេចអនុញ្ញាតឱ្យចុះបញ្ជីបន្តសុពលភាពចំនួន៧០៧កន្លែង ក្នុងនោះអ៊ិស្លាមចំនួន២៩កន្លែង គ្រិស្តចំនួន៦០៧កន្លែង មហាយានចំនួន៧១កន្លែង បាហៃចំនួន២៥កន្លែង កៅដាយចំនួន១កន្លែង និងផ្សេងៗ ចំនួន

៣កន្លែង(បើគិតតាម ឆ្នាំ២០១៨ ចំនួន១៦០កន្លែង ឆ្នាំ២០១៩ ចំនួន១២៤កន្លែង ឆ្នាំ២០២០ ចំនួន១៨៧កន្លែង ឆ្នាំ២០២១ ចំនួន៦៩កន្លែង និងឆ្នាំ២០២២ ចំនួន១៦៧កន្លែង)

- សម្រេចអនុញ្ញាតឱ្យសាងសង់វិហារសាសនាចំនួន៥កន្លែង ក្នុងនោះអ៊ិស្លាមចំនួន១កន្លែង គ្រិស្តចំនួន៣កន្លែង មហាយាន១កន្លែង(បើគិតតាម ឆ្នាំ២០១៨ ចំនួន២កន្លែង ឆ្នាំ២០១៩ ចំនួន២កន្លែង ឆ្នាំ២០២០ គ្មាន ឆ្នាំ២០២១ ចំនួន១កន្លែង និងឆ្នាំ២០២២ គ្មាន)

- សម្របសម្រួលការទទួលអំណោយមនុស្សធម៌និងការនាំចូលគម្ពីរ ឯកសារ និងសម្ភារៈសាសនាចំនួន៤៣លើក ក្នុងនោះអ៊ិស្លាមចំនួន១១លើក គ្រិស្តចំនួន២៧លើក មហាយាចំនួន៥លើក(បើគិតតាម ឆ្នាំ២០១៨ ចំនួន៨លើក ឆ្នាំ២០១៩ ចំនួន១៥លើក ឆ្នាំ២០២០ ចំនួន៨លើក ឆ្នាំ២០២១ ចំនួន៤លើក និងឆ្នាំ២០២២ ចំនួន៨លើក)

- ស្រង់ស្ថិតិផ្នែកពាហិរសាសនាសម្រាប់រយៈពេល៥ឆ្នាំជាប់ៗគ្នា ឃើញថាមានការប្រែប្រួលគួរឱ្យកត់សម្គាល់ ដែលការប្រែប្រួលនេះបណ្តាលមកពីការធ្វើចំណាកស្រុក ការផ្លាស់ប្តូរកន្លែងការងារឬធុរកិច្ច ការបាត់ជំនឿរបស់សាសនិកឬបរិស័ទ និងគោលការណ៍នៃការធ្វើសម្រង់ស្ថិតិជាដើម។ សម្រាប់ឆ្នាំ២០២២នេះ សម្រង់តួលេខស្ថិតិដែលទទួលបានមានដូចតទៅបើធៀបនឹងរយៈពេល៥ឆ្នាំ កន្លែងថ្វាយបង្គំចំនួន៣ ៨៨៤កន្លែង កើនឡើងចំនួន៣កន្លែង សាលាចំនួន១ ៥៩១កន្លែង ថយចុះចំនួន១០០កន្លែង បរិស័ទថ្វាយបង្គំចំនួន៦៧២ ៨៦៩នាក់ ថយចុះចំនួន១២ ៧៦៣នាក់ ក្នុងនោះ(១-សាសនាអ៊ិស្លាមមានកន្លែងថ្វាយបង្គំចំនួន១ ៤២១កន្លែង កើនឡើងចំនួន៤៨កន្លែង សាលាចំនួន៥៩៨កន្លែង កើនឡើងចំនួន៤១កន្លែង មានបរិស័ទថ្វាយបង្គំចំនួន៥៣៧ ៣៧០នាក់ កើនឡើងចំនួន៦ ៨៣៣នាក់ ២- សាសនាគ្រិស្តមានកន្លែងថ្វាយបង្គំចំនួន២ ២៣១កន្លែង ថយចុះចំនួន៤៥កន្លែង សាលាចំនួន៩៤១ ថយចុះ១៣១កន្លែង មានបរិស័ទថ្វាយបង្គំចំនួន១០៩ ៧៥២នាក់ ថយចុះចំនួន៥ ៣៧១នាក់ ៣- មហាយាន និងសាសនាផ្សេងៗមានចំនួន២៣២កន្លែង នៅថេរ បរិស័ទថ្វាយបង្គំចំនួន២៥ ៧៤៧នាក់ ថយចុះចំនួន១៤ ២២៥នាក់ សាលាចំនួន៥២ ថយចុះចំនួន១០កន្លែង)។

**ខ- ការងារពុទ្ធសាសនបណ្ឌិត្យនិងបណ្ណាល័យ**

- រៀបចំការប្រឡងប្រជែងស្នាដៃពានរង្វាន់អក្សរសិល្ប៍ពុទ្ធសាសនបណ្ឌិត្យចំនួន៥លើក មានប្រធានបទចំនួន៥ (១) សុខដុមនីយកម្មក្នុងសង្គមតាមរយៈសាសនា(២០១៨) (២) ពុទ្ធទស្សនៈក្នុងការអភិវឌ្ឍសង្គមខ្មែរ (២០១៩) (៣) ទោសនៃសុរា(២០២០) (៤) ការមិនមានរោគ ជាលាភដ៏ប្រសើរ(២០២១) និង(៥) សីលធម៌នៃការរស់នៅ(២០២២)

- រៀបចំបាឋកថាប្រចាំខែ ចំនួន៥០លើក វាគ្មិន៥០រូប និងប្រធានបទ៥០ផ្សេងៗគ្នា

- បោះពុម្ពសៀវភៅទស្សនាវដ្តីកម្ពុជសុរិយាចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ ចំនួន៣៩ ០០០ក្បាល និងសៀវភៅផ្សេងៗ ចំនួន១១ ០០០ក្បាល

- រៀបចំសិក្ខាសាលាប្រពៃណីទំនៀមទម្លាប់ចំនួន១លើក សិក្ខាសាលា«ការអភិរក្សសាស្ត្រាស្លឹករឹតក្រាំងនៃព្រះរាជាណាចក្រកម្ពុជា» ចំនួន១លើក និងសិក្ខាសាលាផ្សព្វផ្សាយសៀវភៅណែនាំស្តីពីការងារពុទ្ធិកបណ្ណាល័យចំនួន២លើក

- រៀបចំសន្និសីទព្រះពុទ្ធសាសនា ក្រោមប្រធានបទ«គំហើញក្នុងអតីតកាល» ចំនួន១លើក និងសន្និសីទក្រោមប្រធានបទ«ព្រះពុទ្ធសាសនានិងប្រវត្តិសាស្ត្រខ្មែរ» ចំនួន១លើក

- ប្រារព្ធពិធីបុណ្យខួប៩០ឆ្នាំ នៃការបង្កើតពុទ្ធសាសនបណ្ឌិត្យ ចំនួន១លើក ក្នុងឆ្នាំ២០២០

- រៀបចំពិធីប្រគល់ជ័យលាភីប្រកួតប្រជែងស្នាដៃពានរង្វាន់អក្សរសិល្ប៍ពុទ្ធសាសនបណ្ឌិត្យ លើកទី១ ឆ្នាំ២០១៨ និងលើកទី២ ឆ្នាំ២០១៩ ចំនួន១លើក

- បញ្ចូលអត្ថបទទៅក្នុងគេហទំព័ររបស់ពុទ្ធសាសនបណ្ឌិត្យ www.budinst.gov.kh បានចំនួន៤៨៤ ចំណងជើង

- អ្នកទស្សនាក្នុងគេហទំព័រពុទ្ធសាសនបណ្ឌិត្យមានចំនួន៧២ ៤៤៣ដង និងមានអ្នកចុចឡៃក(Like) ផេកហ្វេសប៊ុកពុទ្ធសាសនបណ្ឌិត្យ មានចំនួនជាង២៥ ០០០ដង

- អ្នកចូលអានក្នុងបណ្ណាល័យ ចំនួនសរុប៧ ៧៧៩អង្គ/នាក់

- ទទួលអំណោយសៀវភៅពីសប្បុរសជន និងស្ថាប័ននានាចំនួន៤៧៣ក្បាល

- ទទួលទស្សនាវដ្ដីនានាចំនួន២៨៥ ក្បាល

- ទិញសៀវភៅថ្មីចំនួន១ ៥០៦ក្បាល ស្មើនឹង៨៦២ចំណងជើង ដើម្បីដាក់ជូនសាធារណជនអាន

- បញ្ចូលកូដសៀវភៅក្នុងប្រព័ន្ធkoha database បានចំនួន២៧ ៥៩៨ក្បាល

- បានចងក្រងទស្សនាវដ្ដីកម្ពុជសុរិយាចំនួន១៩លេខ

- សហការជាមួយក្លឹបអ្នកកាសែតកម្ពុជាក្នុងការធ្វើកម្មវិធីបណ្ដុះបណ្ដាល ដោយមានការចូលរួមពីអ្នកកាសែតជើងចាស់ចំនួន៣លើក

- បានប្រគេន ជូនសៀវភៅទៅព្រឹទ្ធសភា រដ្ឋសភាជាតិ ក្រសួង ស្ថាប័ន មន្ទីរធម្មការ និងសាសនា បណ្ណាល័យ និងវត្តអារាមនានាចំនួន៣០ ៥០០ក្បាល។

**គ- ការងារពុទ្ធិកសិក្សា**

**- ស្ថិតិសាលាពុទ្ធិកសិក្សានិងសមណសិស្ស និស្សិត**

| **ធម្មវិន័យ** | | | | | |
|---|---|---|---|---|---|
| **សូចនាករ** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** |
| ចំនួនសាលា | ៤៩១ | ៤៥៦ | ៥៣៦ | ៤៥៥ | ៥១០ |
| ចំនួនសមណសិស្ស | ៩ ៨៥០ | ៩ ២៣៥ | ២០ ១៣៤ | ៨ ៨៥៦ | ១០ ២០០ |
| ចំនួនគ្រូជួល | ៥៣៧ | ៥០០ | ៦៩៣ | ៥៦៣ | ៦៥៩ |
| ចំនួនសមណសិស្សប្រឡងជាប់ | ១៤ ៥៦០ | ១៣ ៥១៧ | ១១ ១៣១ | ១៣ ៧៧១ | ១៣ ៧៧១ |
| **ពុទ្ធិកបឋមសិក្សា** | | | | | |
| ចំនួនសាលា | ៧៩៦ | ៩១៥ | ១០០៥ | ៩៦៩ | ៩៣៦ |
| ចំនួនសមណសិស្សរៀនទាំង៣ថ្នាក់ | ២២ ៩៣០ | ២៤ ២០៩ | ២៤ ៩១៩ | ២៤ ០៣២ | ២៤ ៤៥៧ |
| ចំនួនគ្រូក្របខ័ណ្ឌ | ១៨៦ | ១៧៧ | ១៨៨ | ១៧២ | ១៨១ |
| ចំនួនគ្រូកិច្ចសន្យា | ១ ៣៥០ | ១ ៣៨៩ | ១ ៧២៩ | ១ ៣៩០ | ១ ៣៧៣ |
| ចំនួនគ្រូជួល | ៥៥៣ | ៥២០ | ៥៤១ | ៦៨៧ | ៧១១ |

| | | | | | |
|---|---|---|---|---|---|
| ចំនួនសមណសិស្ស ប្រឡងសម្រាប់ថ្នាក់ទី៣ | ៤ ៣៨១ | ៤ ១៩០ | ៤ ១៨៩ | ៤ ១៨៩ | ៣ ៧០៧ |
| ចំនួនសមណសិស្សសិស្ស ប្រឡងជាប់ | ៣ ២៥១ | ២ ៧៣៧ | ២ ៨២១ | ៤ ១៨៩ | ៣ ០៦៦ |
| **ពុទ្ធិកមធ្យមសិក្សាបឋមភូមិ** | | | | | |
| **សូចនាករ** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** |
| ចំនួនសាលា | ៤០ | ៤០ | ៣៨ | ៣៩ | ៣៩ |
| ចំនួនសមណសិស្ស | ៥ ៥៥១ | ៥ ៦៤២ | ៥ ៦៣៣ | ៦ ៣០២ | ៥ ៩៨២ |
| ចំនួនគ្រូក្របខ័ណ្ឌ | ១៤៧ | ១២៥ | ១៣៦ | ១២៦ | ១២៣ |
| ចំនួនគ្រូកិច្ចសន្យា | ៩៥ | ៥២ | ៥៤ | ៥៤ | ៧៤ |
| ចំនួនគ្រូជួល | ៤២១ | ៣៨៨ | ២៥៧ | ២៣១ | ៣៦៦ |
| ចំនួនសមណសិស្ស ប្រឡងសម្រាប់ថ្នាក់ទី៣ | ៩៩៣ | ១ ០១៩ | ១ ២០០ | ១ ២៥៤ | ១ ១៦៩ |
| ចំនួនសមណសិស្សសិស្ស ប្រឡងជាប់ | ៨៨០ | ៨០៨ | ១ ០០៥ | ១ ២៥៤ | ៩២០ |
| **ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ** | | | | | |
| ចំនួនសាលា | ១៤ | ១៤ | ១៤ | ១៣ | ១៤ |
| ចំនួនសមណសិស្ស | ១ ៨៧២ | ១ ៧២៧ | ១ ៩៣៧ | ២ ៣៤៧ | ២ ១៩៥ |
| ចំនួនគ្រូក្របខ័ណ្ឌ | ៣៥ | ៤០ | ៣៦ | ២៥ | ៣៥ |
| ចំនួនគ្រូកិច្ចសន្យា | ១៧ | ១៥ | ១៦ | ១៨ | ១៥ |
| ចំនួនគ្រូជួល | ២១០ | ២០២ | ១២៩ | ៧៤ | ២០៣ |
| ចំនួនសមណសិស្ស ប្រឡងសម្រាប់ថ្នាក់ទី៣ | ៣៨៥ | ៤១៥ | ៤៤៥ | ៤៨៩ | ៤២៤ |
| ចំនួនសមណសិស្សសិស្ស ប្រឡងជាប់ | ៣៥១ | ៣៧២ | ៣២៥ | ៤៨៩ | ៣៩១ |

**- សមណសិស្សដែលប្រឡងចូលរៀននៅតាមពុទ្ធិកអនុវិទ្យាល័យនានាពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២**

| **សូចនាករ** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** |
|---|---|---|---|---|---|
| ចំនួនសមណសិស្សចូលរួមប្រឡងសរុប | ៣ ០០១ | ២ ៨៤៧ | ២ ៧៤១ | ៣ ១៨៩ | ២ ៦៨៧ |
| ចំនួនសមណសិស្ស ប្រឡងជាប់ | ២ ៤៥៦ | ២ ៤៨១ | ២ ៤២៥ | ៣ ១១០ | ២ ៥៤៥ |
| **ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ (ថ្នាក់បរិញ្ញាបត្រ)** | | | | | |
| **សូចនាករ** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** |
| ចំនួនសមណនិស្សិត | ១ ០៨៥ | ១ ៣៥៥ | ១ ៨៤៩ | ១ ៥២៤ | ១ ៩១៦ |
| ចំនួនគ្រូក្របខ័ណ្ឌ | ៤៤ | ៤៥ | ៥០ | ៤២ | ៥០ |

| | | | | | |
|---|---|---|---|---|---|
| ចំនួនគ្រូជួល | ១៧៩ | ១៨៣ | ១៩៧ | ១០២ | ១៦៨ |
| ចំនួនសមណនិស្សិត បានបញ្ចប់បរិញ្ញាបត្រ | ២៩៨ | ១៩០ | ២០០ | ៣៤៣ | ៣៧៨ |
| ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ (ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់) | | | | | |
| ចំនួនសមណនិស្សិត | ៦៤ | ៦៦ | ៣៤៥ | ៤៥៤ | ៤៥៤ |
| ចំនួនគ្រូក្របខ័ណ្ឌ | ០ | ០ | ០ | ០ | ០ |
| ចំនួនគ្រូជួល | ២៤ | ១១ | ២៦ | ៧៤ | ៦៨ |
| ចំនួនសមណនិស្សិត បានបញ្ចប់បរិញ្ញាបត្រ | ១៤ | ០ | ១៣ | ០ | ៣១ |
| ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន (ថ្នាក់បរិញ្ញាបត្រ) | | | | | |
| **សូចនាករ** | **២០១៨** | **២០១៩** | **២០២០** | **២០២១** | **២០២២** |
| ចំនួនសមណនិស្សិត | ៦១៧ | ៨៩២ | ៥១០ | ៦៤០ | ៨៣២ |
| ចំនួនគ្រូក្របខ័ណ្ឌ | ៥ | ៥ | ៥ | ៦ | ៦ |
| ចំនួនគ្រូជួល | ៤៥ | ៥៦ | ៥១ | ៦១ | ៥៨ |
| ចំនួនសមណនិស្សិត បានបញ្ចប់បរិញ្ញាបត្រ | ៣៧ | ៣០៣ | ១៤៧ | ១៤៤ | ១០៥ |
| ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន (ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់) | | | | | |
| ចំនួនសមណនិស្សិត | ០០ | ៧៤ | ៧៦ | ១៥២ | ១៣៤ |
| ចំនួនគ្រូក្របខ័ណ្ឌ | ០០ | ០០ | ០០ | ០០ | ០០ |
| ចំនួនគ្រូជួល | ០០ | ៣២ | ១៦ | ១៧ | ១៦ |
| ចំនួនសមណនិស្សិត បានបញ្ចប់បរិញ្ញាបត្រ | ០០ | ០០ | ០០ | ០០ | ០០ |
| **ថ្នាក់បណ្ឌិត** (គ្មាន) | | | | | |

❖ **ផ្នែកពុទ្ធិកបឋមសិក្សា និងធម្មវិន័យ**

- បានតែងតាំងគណៈគ្រប់គ្រងចំនួន២៣៤រូប
- ប្រកាសបើកសាលាចំនួន៥២៩សាលា
- ផលិតវិញ្ញាបនបត្រធម្មវិន័យចំនួន៤៥ ៨៧៨សន្លឹក
- ផលិតវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សាចំនួន១០ ៩២៨សន្លឹក
- រៀបចំវគ្គវិក្រឹត្យការគ្រូបង្រៀនពុទ្ធិកបឋមសិក្សាចំនួន៣លើក សិក្ខាកាមចូលរួមចំនួន២៧១រូប
- ចុះធ្វើអធិការកិច្ចចំនួន២៤រាជធានី ខេត្ត
- ចុះអធិការកិច្ចបច្ចេកទេស និងធ្វើបទបង្ហាញស្តីពីការសិក្សាពីចម្ងាយនិងតាមប្រព័ន្ធអនឡាញ(ZOOM) ចំនួន១៧ទីតាំង ស្មើនឹង២៣រាជធានី ខេត្ត
- បង្កើតស្ទូឌីយ៉ូ(STUDIO) ដើម្បីផលិតវីដេអូ និងការចាក់ផ្សាយបន្តផ្ទាល់តាមរយៈគេហទំព័រហ្វេសប៊ុក និងប្រព័ន្ធយូធូប ផ្លូវការរបស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

- ផលិតបានវីដេអូសរុបចំនួន២៧៦ឃ្លីប លើមុខវិជ្ជាចំនួន៦ គឺភាសាបាលី ភាសាខ្មែរ គណិតវិទ្យា ពុទ្ធវិន័យ ពុទ្ធប្បវត្តិ និងពុទ្ធសាសនា

- បានបែងចែកសៀវភៅភាសាបាលី ពុទ្ធវិន័យ ពុទ្ធប្បវត្ត ពុទ្ធសាសនា ទាំងបីថ្នាក់ចំនួន៣ ២៤៣ក្បាល សៀវភៅសិក្ខាគារិកចំនួន១៩ ៦០២ក្បាល និងសៀវភៅតាមដានការសិក្សាចំនួន២៤ ២៨៥ក្បាល ដល់សាលាពុទ្ធិកបឋមសិក្សាតាមរាជធានី ខេត្ត។

❖ **ផ្នែកពុទ្ធិកមធ្យមសិក្សា**

- រៀបចំប្រកាសតែងតាំងគណៈគ្រប់គ្រងចំនួន៣០រូប

- ចែកសៀវភៅសិក្ខាគារិកពុទ្ធិកមធ្យមសិក្សាបឋមភូមិចំនួន១២ ២០០ក្បាល និងមធ្យមសិក្សាទុយតិភូមិចំនួន៤ ៧៣៤ក្បាល

- ចែកសៀវភៅតាមដានការសិក្សាពុទ្ធិកមធ្យមសិក្សាបឋមភូមិចំនួន៣០ ៦២០ក្បាល និងពុទ្ធិកមធ្យមសិក្សាទុតិយភូមិចំនួន១២ ១៦៣ក្បាល

- ចែកសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិចំនួន១ ៧០៩សន្លឹក និងមធ្យមសិក្សាទុតិយភូមិចំនួន៥៨៥សន្លឹក

- ធ្វើសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិបណ្តោះអាសន្នចំនួន១ ៥៣១សន្លឹក និងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិចំនួន១ ៤៦៧សន្លឹក

- បញ្ជាក់ភាពត្រឹមត្រូវលើសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិចំនួន៩សន្លឹក និងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិចំនួន ៥៩៣សន្លឹក

- រៀបចំវគ្គវិក្រឹត្យការគ្រូនិងគណៈគ្រប់គ្រងពុទ្ធិកមធ្យមសិក្សាចំនួន២លើក សិក្ខាកាមចូលរួមចំនួន២៨៣រូប

- ចុះធ្វើអធិការកិច្ចបានចំនួន១៥លើក តាមបណ្តារាជធានី ខេត្តចំនួន១០ខេត្ត

- ដោយសារស្ថានភាពនៃជំងឺកូវីដ-១៩ ឆ្នាំ២០២០-២០២១ សមណសិស្ស សិស្សនៃពុទ្ធិកមធ្យមសិក្សាបឋមភូមិចំនួន១ ២៤៥អង្គ/នាក់ និងសមណសិស្ស សិស្សនៃពុទ្ធិកមធ្យមសិក្សាទុតិយភូមិចំនួន៤៨៩អង្គ/នាក់ មិនបានប្រឡងទេ គឺស្នើសុំគោលការណ៍ជាប់ដោយស្វ័យប្រវត្តិ

- ចុះធ្វើអធិការកិច្ចបច្ចេកទេស និងធ្វើបទបង្ហាញស្តីពីការសិក្សាពីចម្ងាយ និងតាមប្រព័ន្ធអនឡាញ(ZOOM) ចំនួន៥ទីតាំង ស្មើនឹង៥រាជធានី ខេត្ត

-បានបង្កើតស្ទូឌីយ៉ូ(STUDIO) ដើម្បីផលិតវីដេអូចាក់ផ្សាយសម្រាប់ទូរសិក្សា ក្នុងវិបត្តិនៃជំងឺកូវីដ-១៩ ផលិតចំនួន២១៧ឃ្លីប លើមុខវិជ្ជាចំនួន៤ គឺ១- ភាសាបាលី ២- ភាសាសំស្រ្កឹត ៣- ពុទ្ធសាសនា និងព្រះអភិធម្ម និង៤- ពុទ្ធវិន័យសម្រាប់ពុទ្ធិកមធ្យមសិក្សាបឋមភូមិ។ ដោយឡែកសម្រាប់ពុទ្ធិកមធ្យមសិក្សាទុតិយភូមិ ក៏បានផលិតវីដេអូលើមុខវិជ្ជាចំនួន៤ គឺ១- ភាសាបាលី ២- ភាសាសំស្រ្កឹត ៣- សាសនាប្រៀបធៀប និង៤- ព្រះអភិធម្ម។

❖ **ពុទ្ធិកវិទ្យាល័យព្រះរាម្រឹត**

- ចេញបណ្ណសរសើរចំនួន២១១សន្លឹក

- ប្រជុំតាមប្រព័ន្ធអនឡាញ (ZOOM) ចំនួន១៨លើក

- បង្កើតស្ទូឌីយ៉ូ(STUDIO) ដើម្បីផលិតវីដេអូ និងការចាក់ផ្សាយបន្តផ្ទាល់តាមរយៈគេហទំព័រហ្វេសប៊ុក និងប្រព័ន្ធយូធូបផ្លូវការរបស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

- ផលិតបានវីដេអូសរុបចំនួន២ ១៦២ឃ្លីប លើមុខវិជ្ជាចំនួន៦ គឺភាសាបាលី ភាសាខ្មែរ គណិតវិទ្យា ពុទ្ធវិន័យ ពុទ្ធប្បវត្តិ និងពុទ្ធសាសនា

- រៀបចំជួសជុលហេដ្ឋារចនាសម្ព័ន្ធដោយចំណាយថវិកាចំនួន៩ ៩៤១ដុល្លារអាម៉េរិក។ បណ្ណាល័យបានទទួលសៀវភៅចំនួន៦ ៥១០ក្បាល

- ការចំណាយលើការផលិតវីដេអូ ការចាក់ផ្សាយ និងការចំណាយសម្រាប់សប្បុរសធម៌ផ្សេងៗចំនួន ៧៣ ៣៣៥ ៨០០រៀល និងថវិកាគិតជាដុល្លារចំនួន២ ៩០៤ដុល្លារអាម៉េរិក

- ផ្នែកពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សាចុះធ្វើអធិការកិច្ចទៅតាមពុទ្ធិកសាកលវិទ្យាល័យទាំង ៣កន្លែង ទៅតាមផែនការប្រចាំឆ្នាំចំនួន១៥លើក

- ប្រជុំផ្ទៃក្នុងនិងខាងក្រៅចំនួន៨លើក។

❖ **ពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ**

- ចេញវិញ្ញាបនបត្រថ្នាក់មូលដ្ឋានចំនួន៥៨៩ច្បាប់
- ចេញព្រឹត្តិបត្រពិន្ទុប្រគេន ជូនសមណនិស្សិត និស្សិតចំនួន១១ច្បាប់
- រៀបចំធ្វើសិក្ខាសាលានិងបាឋកថាចំនួន៣០លើក
- ចូលរួមប្រជុំទាំងថ្នាក់ជាតិនិងអន្តរជាតិ ដើម្បីលើកម្ពស់ការអប់រំកម្រិតពុទ្ធិកឧត្តមសិក្សាចំនួន២៦១លើក
- ចេញលិខិតបញ្ជាក់ការសិក្សាចំនួន២១៦ច្បាប់
- ចេញសញ្ញាបត្របរិញ្ញាបត្របណ្តោះអាសន្នចំនួន២៩៤សន្លឹក
- ចេញសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់បណ្តោះអាសន្នចំនួន២៤សន្លឹក
- ផ្តល់អាហារូបករណ៍ដល់សមណនិស្សិត និស្សិតថ្នាក់បរិសញ្ញាបត្រជាន់ខ្ពស់ចំនួន៧៩កន្លែង។
- ចុះអនុស្សរណៈនៃការយោគយល់(MOU) ជាមួយសាកលវិទ្យាល័យនិងស្ថាប័ននានាចំនួន១០រួមមាន៖
  - ស្ថានទូតឥណ្ឌាប្រចាំកម្ពុជា
  - សាកលវិទ្យាល័យទីក្រុងព្រៃនគរនៃប្រទេសវៀតណាម
  - សាកលវិទ្យាល័យមហាចូឡាឡុងកនរាជវិទ្យាល័យនៃព្រះរាជាណាចក្រថៃ
  - វិទ្យាស្ថានហិណ្ឌូជាម៉ានេហ្គីរីជេនផាសានៃប្រទេសឥណ្ឌូណេស៊ី
  - ក្រុមប្រឹក្សាទំនាក់ទំនងវប្បធម៌ឥណ្ឌានៃប្រទេសឥណ្ឌា
  - សាកលវិទ្យាល័យមហាមង្គុតនៃព្រះរាជាណាចក្រថៃ
  - សាកលវិទ្យាល័យមហាខនគេននៃព្រះរាជាណាចក្រថៃ
  - សាកលវិទ្យាល័យពុទ្ធសាសនាថេរវាទអន្តរជាតិនៃប្រទេសមីយ៉ាន់ម៉ា
  - សាកលវិទ្យាល័យកល្យាណីនៃប្រទេសស្រីលង្កា
  - អង្គការForum FZD។

- ទទួលអំណោយសៀវភៅចំនួន៥៥០ក្បាល ដើម្បីដាក់តម្កល់នៅក្នុងបណ្ណាល័យ និងមានសមណនិស្សិត និស្សិត៦ ៥១៦អង្គ/នាក់ បានចូលធ្វើការសិក្សាស្រាវជ្រាវ និងអានសៀវភៅនៅបណ្ណាល័យ។

❖ **ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា**

- ចេញវិញ្ញាបនបត្រថ្នាក់មូលដ្ឋានចំនួន១ ១២៥ច្បាប់

- ចេញព្រឹត្តិបត្រពិន្ទុប្រគេន ជូនសមណនិស្សិត និស្សិតចំនួន៨០០ច្បាប់
- រៀបចំធ្វើសិក្ខាសាលា និងបាឋកថាចំនួន១៥០លើក
- ចូលរួមប្រជុំទាំងថ្នាក់ជាតិនិងអន្តរជាតិសរុបចំនួន៩០លើក
- ចេញលិខិតបញ្ជាក់ការសិក្សាសរុបចំនួន៥១២ច្បាប់
- ចេញសញ្ញាបត្របរិញ្ញាបត្របណ្តោះអាសន្នសរុបចំនួន៥៩៣សន្លឹក
- ចេញសញ្ញាបត្របរិញ្ញាបត្រសរុបចំនួន៤១០សន្លឹក
- ចេញសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់សរុបចំនួន២១៥សន្លឹក
- ផ្តល់អាហារូបករណ៍សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន១០កន្លែង ដល់សមណនិស្សិត និស្សិត
- ចុះអនុស្សរណៈនៃការយោគយល់(MOU) ជាមួយសាកលវិទ្យាល័យចំនួន៣ រួមមាន៖
  - វិទ្យាស្ថានអភិវឌ្ឍន៍នៃក្រសួងការពារជាតិ
  - National Sun Yatsen University នៃសាធារណរដ្ឋប្រជាមានិតចិន
  - ចូលជាសមាជិកAIU នៃសាកលវិទ្យាល័យអន្តរជាតិ។
- ចុះចែកអំណោយដល់គ្រួសារក្រីក្រចំនួន៦ ០៨០គ្រួសារ និងនិស្សិតក្រីក្រចំនួន៥៦០នាក់
- រៀបចំទទួលការវាយតម្លៃគុណភាពអប់រំរបស់គណៈកម្មការវាយតម្លៃគុណភាពអប់រំកម្ពុជា(ACC) ចំនួន១លើក។

❖ **ពុទ្ធិកសាកលវិទ្យាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

- រៀបចំធ្វើសិក្ខាសាលានិងបាឋកថាចំនួន១៥លើក
- ប្រជុំផ្ទៃក្នុង ចូលរួមប្រជុំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចំនួន៣៦០លើក
- ចែកសញ្ញាបត្របរិញ្ញាបត្រដល់សមណនិស្សិត និស្សិតចំនួន៧៣សន្លឹក។

❖ **ផ្នែករដ្ឋបាល និងគណនេយ្យ**

- បញ្ជូនលិខិតទៅកាន់អង្គភាពនិងការិយាល័យនានាចំនួន២ ១៥៩ច្បាប់

- ប្រមូលចងក្រងនិងបោះពុម្ពផ្សាយសៀវភៅស្ថិតិពុទ្ធិកសិក្សាគ្រប់កម្រិតចំនួន១០០ច្បាប់ និងសៀវភៅរបាយការណ៍ប្រចាំឆ្នាំ៨៣០ក្បាល

- រៀបចំការប្រឡងសូត្របាតិមោក្ខ សម្តែងធម៌ទេសនា និងសូត្រធម៌បទចំនួន៣លើក មានបេក្ខសមណៈ និងបេក្ខជនចូលរួមប្រឡងចំនួន២០៤រូប ដោយជ្រើសរើសបានបេក្ខភាពឆ្នើមចំនួន៥៩រូប

- ពិនិត្យនិងបញ្ជូនវិញ្ញាបនបត្រធម្មវិន័យចំនួន២៤ ៥២៩សន្លឹក វិញ្ញាបនបត្រពុទ្ធិកបឋមសិក្សាចំនួន ២ ៦២៩សន្លឹកទៅក្រសួងធម្មការនិងសាសនា

- ពិនិត្យនិងបញ្ជូនបន្តសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិចំនួន៣ ៧៣២សន្លឹក និងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិចំនួន១ ៥៩០សន្លឹក

- ពិនិត្យនិងបញ្ជូនសញ្ញាបត្របរិញ្ញាបត្រចំនួន៥៩៤សន្លឹក របស់ពុទ្ធិកសាកលវិទ្យាល័យ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**(កំពង់ចាម) ទៅក្រសួងធម្មការនិងសាសនា

- បើកវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សាបោះពុម្ពរួចចំនួន២៤ ០០០សន្លឹក ដល់ផ្នែកពុទ្ធិកបឋមសិក្សានិងធម្មវិន័យ សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិបោះពុម្ពរួចចំនួន៥ ៨៣០សន្លឹក និងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិបោះពុម្ពរួចចំនួន១ ៣០០សន្លឹក ដល់ផ្នែកពុទ្ធិកមធ្យមសិក្សា

- បើកសៀវភៅតាមដានការសិក្សា និងសៀវភៅសិក្ខាគារិកចំនួន៨៤ ៥២០ក្បាល ដល់ផ្នែកជំនាញ
- សរសេររបាយការណ៍បូកសរុបការងារវិស័យពុទ្ធិកសិក្សាសម្រាប់ឆ្នាំសិក្សា២០២១-២០២២
- ជូនសៀវភៅបាលីនិងពុទ្ធវិន័យ២០ក្បាល ដល់មន្ត្រីឧទ្ទកាល័យរបស់ក្រសួងធម្មការនិងសាសនា
- បើកសៀវភៅភាសាបាលី ពុទ្ធវិន័យ ពុទ្ធប្បវត្តិ និងពុទ្ធសាសនាចំនួន២៦ ៤៧៧ក្បាល ដល់ផ្នែកជំនាញ
- ចូលរួមកម្មវិធីសប្បុរសធម៌សរុបទាំងអស់មានចំនួន៨៣៤សកម្មភាព ដែលបានចំណាយថវិកាជាប្រាក់រៀលចំនួន១២៤ ៨០០ ០០០រៀល និងប្រាក់ដុល្លារចំនួន១៤៦ ៤០០ដុល្លារអាម៉េរិក។

**២.៣- ការងារព័ត៌មាន** ( ផេក : Ministry of information )

**ក្រសួងព័ត៌មាន សម្រេចការងារបានដូចខាងក្រោម៖**

រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណទាំងបីដំណាក់កាលរួចមកហើយ ដោយទទួលបានលទ្ធផលកំណើនការងារ សមធម៌សង្គម អនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍប្រកបដោយចីរភាពដែលធ្វើឱ្យកំណើនសេដ្ឋកិច្ចជាង៧% ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ព្រមទាំងរក្សាបាននូវសុខសន្តិភាពនាំឱ្យកម្ពុជាផ្លាស់ប្តូរមុខមាត់ថ្មីនៅលើឆាកអន្តរជាតិគួរជាទីមោទនៈ។

នីតិកាលទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ សម្រាប់អនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៣ ក្នុងការអភិវឌ្ឍប្រទេសជាតិលើវិស័យជាអាទិភាពនិងវិធានការដាក់ស្តែង បានដើរតួនាទីជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាព និងជាត្រីវិស័យសម្រាប់តម្រង់ទិសសកម្មភាពរបស់រាជរដ្ឋាភិបាលក្នុងការបន្តបំពេញភារកិច្ចបម្រើជាតិ សំដៅឆ្លើយតបទៅនឹងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាពលរដ្ឋ ព្រមទាំងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅគោលដៅចក្ខុវិស័យរបស់កម្ពុជា ឆ្នាំ២០៣០ និងឆ្នាំ២០៥០។

ផ្អែកលើមូលដ្ឋាននៃការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នីតិកាលទី៦ នៃរដ្ឋសភា និងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការសម្របសម្រួលខ្លួនទៅនឹងការវិវត្តនៃបដិវត្តឧស្សាហកម្មសកល តម្រូវឱ្យរាជរដ្ឋាភិបាលកម្ពុជា ចាប់យកកាលានុវត្តភាពនៃការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល និងត្រៀមខ្លួនឆ្លើយតបនឹងបញ្ហាប្រឈមដោយមានប្រសិទ្ធភាព។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលទាក់ទងនឹងវិស័យព័ត៌មាន **មុំទី៣ : ទាក់ទងនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងឆ្លើយតបបញ្ហាប្រឈមនឹងបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។**

**២.៣.១- សូចនាករសំខាន់ៗរបស់ក្រសួងព័ត៌មាន**

**ក- ការផ្លាស់ប្តូរប្រព័ន្ធទូរទស្សន៍ពីអាណាឡូក ទៅឌីជីថល**

កិច្ចប្រជុំរដ្ឋមន្ត្រីព័ត៌មានអាស៊ានលើកទី១៤ កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ នៅប្រទេសសិង្ហបុរី បានឯកភាពកំណត់កាលបរិច្ឆេទនៃការបិទការផ្សាយទូរទស្សន៍អាណាឡូកត្រឹមឆ្នាំ២០២០ ស្របតាមស្មារតីកិច្ច-សហប្រតិបត្តិការថ្នាក់តំបន់និងអាស៊ីប៉ាស៊ីហ្វិក ដើម្បីសុខដុមនីយកម្មនៃការអភិវឌ្ឍបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយឌីជីថលទាំងនៅក្នុងតំបន់ និងនៅលើសកលលោក។ ដោយឡែកព្រះរាជាណាចក្រកម្ពុជាបានពន្យារពេលបិទការផ្សាយទូរទស្សន៍អាណាឡូករហូតដល់ដំណាច់ឆ្នាំ២០២៥។

យោងតាមស្មារតីកិច្ចប្រជុំអាស៊ានលើកទី១៤ រាជរដ្ឋាភិបាលកម្ពុជាបានឯកភាពសម្រេចឱ្យក្រសួង

ព័ត៌មានបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន ដើម្បីរៀបចំផែនការបង្កើតហេដ្ឋារចនាសម្ព័ន្ធផ្សាយទូរទស្សន៍ឌីជីថលជាតិ( National Digital TV Platform ) និងបង្កើតស្ថាប័នសាធារណៈរដ្ឋបាល ដើម្បីគ្រប់គ្រងប្រតិបត្តិការផ្សាយទូរទស្សន៍ឌីជីថលជាតិ ដែលគ្រោងនឹងចាប់ផ្តើមអនុវត្តចាប់ពីដើមឆ្នាំ២០២៣ និងបញ្ចប់ត្រឹមដំណាច់ឆ្នាំ២០២៥ ក្នុងគោលដៅធ្វើសមាហរណកម្មនិងសុខដុមនីយកម្មប្រព័ន្ធទូរទស្សន៍ឌីជីថលនៅក្នុងតំបន់និងពិភពលោក។ តែបច្ចុប្បន្ននេះ ដោយយោងលើទំហំចំណាយនិងមានសំណើពីឯកជន រាជរដ្ឋាភិបាលបានឯកភាពឱ្យក្រុមហ៊ុនឯកជនជាអ្នករៀបចំផ្សាយDigitalនេះ។

**ខ- ការអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន**

បន្តការកសាងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ទាំងសារព័ត៌មានតាមបែបប្រពៃណី ទាំងប្រព័ន្ធផ្សព្វផ្សាយតាមរលកអាកាសវិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយតាមអនឡាញរបស់ស្ថាប័នរដ្ឋនិងស្ថាប័នឯកជនព្រមទាំងពង្រីកវិសាលភាពការផ្សាយឱ្យបានទូលំទូលាយគ្របដណ្តប់ទូទាំងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅក្នុងតំបន់និងនៅលើសកលលោក ដើម្បីផ្សព្វផ្សាយគោលនយោបាយរបស់រាជរដ្ឋាភិបាល ការអភិវឌ្ឍប្រទេសជាតិ កម្មវិធីអប់រំសេដ្ឋកិច្ច វប្បធម៌ កម្មវិធីកម្សាន្តផ្សេងៗ និងការផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋបានរហ័សទាន់ពេលវេលាទៅគ្រប់ច្រកល្ហកទូទាំងព្រះរាជាណាចក្រកម្ពុជា តាមទិសស្លោក ប្លែក លឿន ទុកចិត្តបាន ពេលណា ទីណាក៏បាន ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើននាពេលបច្ចុប្បន្ន។

ទន្ទឹមនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងពង្រីកវិសាលភាពប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឱ្យបានទូលំទូលាយ យើងត្រូវបង្កើនល្បឿនផ្សព្វផ្សាយព័ត៌មានឱ្យបានលឿនទាន់សភាពការណ៍ទាំងនៅក្របខ័ណ្ឌជាតិ និងនៅលើពិភពលោក ព្រមទាំងបង្កើននូវភាពជឿជាក់តាមរយៈការផ្សាយព័ត៌មានពិតដោយមានការទទួលខុសត្រូវលើវិជ្ជាជីវៈ។

**គ- ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងអភិវឌ្ឍធនធានមនុស្ស**

ការវិវត្តនៃបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយឌីជីថលតម្រូវឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធយកចិត្តទុកដាក់លើកកម្ពស់ការបណ្តុះបណ្តាលធនធានមនុស្សទាំងកម្រិតថ្នាក់ជាតិនិងអន្តរជាតិឱ្យមានសមត្ថភាពជំនាញច្បាស់លាស់ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ និងអាចដើរទាន់នូវការវិវត្តបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយទំនើប។ ស្ថិតនៅក្នុងបរិបទនេះ ក្រសួងព័ត៌មាននឹងបន្តកិច្ចសហការជាមួយក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធ និងស្ថាប័នសារព័ត៌មានរៀបចំបើកសិក្ខាសាលា និងបើកវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មាន និងជំនាញបច្ចេកទេសដល់មន្ត្រីរាជការទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអ្នកសារព័ត៌មាន ដើម្បីឱ្យពួកគេមានសមត្ថភាពបំពេញភារកិច្ចប្រកបដោយវិជ្ជាជីវៈនិងការទទួលខុសត្រូវ ព្រមទាំងមានសមត្ថភាពវិភាគព័ត៌មានស៊ីជម្រៅទាំងក្របខ័ណ្ឌជាតិ និងអន្តរជាតិនិងមានសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាទំនើបក្នុងការបញ្ជូនទិន្នន័យនិងការផ្សព្វផ្សាយព័ត៌មានបានទាន់ពេលវេលា។ មិនតែប៉ុណ្ណោះក្រសួងព័ត៌មានបានរួមចំណែកលើកស្ទួយប្រព័ន្ធអប់រំតាមបែបទំនើប ទទក២( TVK 2 ) ដើម្បីឱ្យសិស្សានុសិស្សអាចរៀនតាមអនឡាញ បានគ្រប់ពេលវេលានិងគ្រប់ទីកន្លែង។

**ឃ- ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ**

ការរីកចម្រើននៃបច្ចេកវិទ្យាយុគសម័យបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ បានធ្វើឱ្យមានការរីកលូតលាស់នៃបច្ចេកវិទ្យាប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននិងវិស័យផ្សេងៗទៀត ជាមួយនឹងកាលានុវត្តភាពនិងអត្ថប្រយោជន៍យ៉ាងច្រើនដល់សកលលោកយើងទាំងមូល។ ជាមួយគ្នានេះដែរ ក៏ធ្វើឱ្យយើងមានបញ្ហាប្រឈមជាច្រើន ដូចជាការ

អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការអភិវឌ្ឍធនធានមនុស្ស និងបញ្ហាប្រឈមនឹងព័ត៌មានក្លែងក្លាយជាសកល ដែលទាមទារឱ្យយើងទាំងអស់គ្នាចូលរួមទប់ស្កាត់ និងលុបបំបាត់រាល់ព័ត៌មានក្លែងក្លាយ បំភិតបំភ័យ ញុះញង់ឱ្យកើតមានការរើសអើងប្រកាន់ពូជសាសន៍ បង្កឱ្យមានការបែកបាក់សាមគ្គីភាពជាតិ ការបង្កទំនាស់ជាមួយប្រទេសជិតខាង ការបង្កចលាចលសង្គមជាដើម។ គោលដៅចំពោះមុខ ក្រសួងព័ត៌មាននឹងបន្តសហការជាមួយស្ថាប័នព័ត៌មានទាំងអស់ដើម្បីទប់ស្កាត់និងលុបបំបាត់រាល់ព័ត៌មានក្លែងក្លាយ ដោយជំរុញឱ្យស្ថាប័នព័ត៌មានទាំងអស់ផ្សាយព័ត៌មានពិត ដើម្បីបន្សាបព័ត៌មានមិនពិត និងបន្តសហការជាមួយស្ថាប័នជាតិនិងអន្តរជាតិដែលគ្រប់គ្រងបណ្តាញទំនាក់ទំនងសង្គម ដើម្បីរាំងខ្ទប់និងបិទចោលនូវគេហទំព័របុគ្គលណនីហ្វេសប៊ុកដែលផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ព្រមទាំងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីចាត់វិធានការចំពោះជនល្មើសតាមនីតិវិធីច្បាប់។

**ង- ពង្រឹងនិងបង្កើនប្រសិទ្ធភាពច្បាប់សារព័ត៌មាន**

ក្រសួងព័ត៌មានត្រូវបានរាជរដ្ឋាភិបាលសម្រេចប្រគល់ភារកិច្ចឱ្យដឹកនាំរៀបចំធ្វើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាននៅក្នុងនីតិកាលទី៥ នៃរដ្ឋសភាជាតិ និងសម្រេចប្រគល់សិទ្ធិឱ្យដឹកនាំកិច្ចប្រជុំអន្តរក្រសួងដើម្បីឆ្លងសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន។ កន្លងមក ក្រសួងព័ត៌មានបានឆ្លងអន្តរក្រសួងនូវសេចក្តីព្រាងច្បាប់នេះប្រកបដោយជោគជ័យ ហើយបន្តសហការជាមួយក្រសួងយុត្តិធម៌ឆ្លងទោសប្បញ្ញត្តិសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានដែលគ្រោងនឹងបញ្ចប់នៅក្នុងខែមីនា ដើម្បីដាក់ជូនរាជរដ្ឋាភិបាលនិងស្ថាប័ននីតិប្បញ្ញត្តិឱ្យបានរួចរាល់នៅក្នុងឆ្នាំ២០២៣នេះ។ ជាមួយគ្នានេះដែរ ក្រសួងព័ត៌មាន កំពុងសិក្សាធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន ដើម្បីឱ្យបទប្បញ្ញត្តិច្បាប់នេះ មានសង្គតិភាពទៅនឹងបទប្បញ្ញត្តិច្បាប់ដែលមានជាធរមាន និងស្របតាមតម្រូវការជាក់ស្តែងនាពេលបច្ចុប្បន្ន ដើម្បីជំរុញឱ្យស្ថាប័នព័ត៌មានទាំងអស់ប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន និងផ្សព្វផ្សាយព័ត៌មានប្រកបដោយការទទួលខុសត្រូវ។ ជាមួយគ្នានេះដែរ ក្រសួងព័ត៌មានបន្តខិតខំកសាងបទដ្ឋានគតិយុត្តថ្មីៗ តាមតម្រូវការជាក់ស្តែង ដើម្បីគ្រប់គ្រងវិស័យព័ត៌មាន និងសោតទស្សន៍ប្រកបដោយប្រសិទ្ធភាព និងធានាបាននូវសិទ្ធិសេរីភាពនៃការបញ្ចេញមតិសេរីភាពសារព័ត៌មានក្នុងក្របខ័ណ្ឌប្រទេសដែលកាន់របបលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

**ច- កិច្ចសហប្រតិបត្តិការអន្តរជាតិ**

ក្នុងកំលុងពេលពីឆ្នាំ ២០១៨ ដល់២០២២នេះ ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មានបានបំពេញការងារលើឆាកអន្តរជាតិយ៉ាងសកម្ម និងច្រើនសន្ទឹកសន្ធាប់ដែលបាននាំមកនូវជោគជ័យយ៉ាងត្រចះត្រចង់សម្រាប់ការអភិវឌ្ឍក្រសួងព័ត៌មាន ក៏ដូចជាការចូលរួមចំណែកដល់ការកសាងប្រទេសជាតិទាំងមូលលើវិស័យសារព័ត៌មាន។ ក្នុងបេសសកម្មក្រៅប្រទេស ឯកឧត្តមរដ្ឋមន្ត្រីនិងគណៈប្រតិភូបានកសាងនូវឧត្តមភាពយ៉ាងធំធេងនូវកេរ្តិ៍ឈ្មោះរបស់ប្រទេសកម្ពុជា ជាពិសេសវិស័យសារព័ត៌មានកម្ពុជានៅលើឆាកអន្តរជាតិ តាមរយៈការចូលរួមកិច្ចប្រជុំនានានៅលើកម្រិតអន្តរជាតិ និងការកសាងនូវទំនាក់ទំនងល្អជាមួយប្រទេសដៃគូនៅទូទាំងសកលលោក។ កិច្ចការដ៏ធំ និងមានអត្ថន័យធំធេញបំផុតសម្រាប់ព្រះរាជាណាចក្រកម្ពុជានាឆ្នាំ២០១៩ កន្លងទៅនេះ នោះគឺការទទួលរៀបចំធ្វើជាម្ចាស់ផ្ទះសន្និសីទកំពូលសារព័ត៌មានអាស៊ីលើកទី១៦(16th Asia Media Summit) នៅខេត្តសៀមរាបក្រោមវត្តមានដ៏ខ្ពង់ខ្ពស់បំផុត និងការថ្លែងសុន្ទរកថាបើកប្រកបដោយអត្ថន័យយ៉ាងជ្រាលជ្រៅពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

និងក្រោមការដឹកនាំនិងចាត់ចែងផ្ទាល់ពីឯកឧត្តមរដ្ឋមន្ត្រី **ខៀវ កាញារីទ្ធ** ដែលបានញុំាងសន្និសីទខាងលើនេះឱ្យទទួលបានជោគជ័យយ៉ាងត្រចះត្រចង់បំផុត និងល្បីរន្ទឺលើឆាកអន្តរជាតិ ក្រោមក្រសែភ្នែកអ្នកសារព័ត៌មានជាតិនិងអន្តរជាតិចំនួនជាង៦៥០នាក់ មកពីប្រទេសចំនួន៤៣ប្រទេស។ សកម្មភាពការងារជាក់ស្តែងក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិនិងអាស៊ាន កិច្ចសហប្រតិបត្តិការទ្វេភាគីជាមួយប្រទេសដៃគូ(កំពុងមានសុពលភាព) ចំនួន៦ប្រទេស(ថៃ វៀតណាម ឡាវ ម៉ាឡេស៊ី ហ្វីលីពីន ចិន) កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិចំនួន៤អង្គការ ការរៀបចំកិច្ចប្រជុំអន្តរជាតិចំនួន២លើក ការចូលរួមកិច្ចប្រជុំអន្តរជាតិ ដែលថ្នាក់ដឹកនាំនិងមន្ត្រីរាជការក្រសួងព័ត៌មានបានចូលរួមកិច្ចប្រជុំអន្តរជាតិនានា និងចូលរួមសកម្មភាពជាអន្តរជាតិចំនួន៤៧លើក។

**២.៣.២- សូចនាករស្តីពីសមិទ្ធផលសំខាន់ៗរបស់ស្ថាប័នចំណុះក្រសួងព័ត៌មាន**

**ក- ការងារព័ត៌មាននិងសោតទស្សន៍**

ក្នុងរយៈពេល៥ឆ្នាំ(២០១៨ ដល់២០២២) អគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍ បានដំណើរការការងារតាមប្រក្រតី ដោយបានធ្វើការសម្របសម្រួលលិខិតស្នាមផ្សេងៗ ជូនអ្នកសារព័ត៌មានក្នុងការចុះបំពេញការងារតាមមូលដ្ឋាន និងជូនព័ត៌មានអំពីកម្មវិធីនានា ព្រមទាំងចាត់មន្ត្រីឱ្យទៅសម្របសម្រួលអ្នកសារព័ត៌មានក្នុងកម្មវិធីនានា។ ជាមួយនេះ ក៏បានអនុញ្ញាតឱ្យសារព័ត៌មានដំណើរការបោះពុម្ពផ្សាយ បន្តអាជ្ញាបណ្ណ ប្តូរឈ្មោះសារព័ត៌មាន និងធ្វើការផ្អាកការចេញផ្សាយរបស់សារព័ត៌មានដែលផ្ទុយនឹងច្បាប់និងក្រមសីលធម៌។ ទន្ទឹមនឹងនេះ ក៏បានធ្វើការតាមដានជាប្រចាំនូវរាល់ព័ត៌មានដែលចេញផ្សាយតាមទំព័រសារព័ត៌មាន តាមវិទ្យុ ទូរទស្សន៍ និងតាមដានវិវាទនានារបស់អ្នកសារព័ត៌មាន ព្រមទាំងធ្វើការបញ្ជូនមន្ត្រីចូលរួមវគ្គជំនាញផ្សេងៗ និងបញ្ចូលព័ត៌មានទៅក្នុងគេហទំព័ររបស់ក្រសួងថែមទៀត។

ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២នេះ អគ្គនាយកដ្ឋានសម្រេចបានលទ្ធផលសង្ខេបដូចខាងក្រោម៖

- កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗផ្ទាល់និងតាមប្រព័ន្ធអនឡាញចំនួន៦៧២លើក ផ្នែកចេញអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតបន្តចំនួន៩៧៣អាជ្ញាបណ្ណ ចេញបណ្ណអ្នកសារព័ត៌មានជាតិនិងអន្តរជាតិចំនួន ១០ ០៣៣បណ្ណ ស្រង់និងថតរូបផ្ទាំងប៉ាណូរាជធានីភ្នំពេញចំនួន១៥៤ស្លាក អង្គភាពសារព័ត៌មានបានចុះបញ្ជីគេហទំព័រTV Online ចំនួន៦៦៩អង្គភាព(គេហទំព័រ៥៨៨ និងTV Online ៨១អង្គភាព និងចាងហ្វាងជាជនបរទេស ១៩អង្គភាព និងចាងហ្វាងជាស្ត្រី៦៨នាក់) កាសែតចំនួន៤៥០អង្គភាព(ក្នុងនោះមានចាងហ្វាងជាជនបរទេស ២៨អង្គភាព និងចាងហ្វាងជាស្ត្រី២១នាក់) សមាគមសារព័ត៌មានចំនួន៥១អង្គភាព(ក្នុងនោះមានចាងហ្វាងជាជនបរទេស១អង្គភាព និងចាងហ្វាងជាស្ត្រី១នាក់) ទស្សនាវដ្តីចំនួន១៩៣អង្គភាព(ក្នុងនោះមានចាងហ្វាងជាជនបរទេស៣១អង្គភាព និងចាងហ្វាងជាស្ត្រី៣៧នាក់) ព្រឹត្តិបត្រចំនួន២២អង្គភាព(ក្នុងនោះមានចាងហ្វាងជាជនបរទេស៧អង្គភាព និងចាងហ្វាងជាស្ត្រី៥នាក់) រោងពុម្ពចំនួន១១៧អង្គភាព(ក្នុងនោះមានចាងហ្វាងជាស្ត្រី ៣៩នាក់ លុប១អង្គភាព) សៀវភៅ២២អង្គភាព(ក្នុងនោះមានចាងហ្វាងជាជនបរទេស៥អង្គភាព និងចាងហ្វាងជាស្ត្រី៣នាក់) ទីភ្នាក់ងារសារព័ត៌មានបរទេស២៤អង្គភាព(អ្នកឆ្លើយឆ្លងព័ត៌មាន១អង្គភាព) ភ្នាក់ងារផ្សព្វផ្សាយពាណិជ្ជកម្ម១អង្គភាព ស្ថានីយវិទ្យុFM២២០ស្ថានីយ វិទ្យុAMជាតិ១ស្ថានីយ ទូរទស្សន៍អាណាឡូក១៩ស្ថានីយ ទូរទស្សន៍Digital៤ស្ថានីយ ទូរទស្សន៍ខ្សែកាបនៅទូទាំងប្រទេស២១២ស្ថានីយ ប្រព័ន្ធទូរទស្សន៍OTT មាន៤ស្ថានីយ ទូរទស្សន៍ផ្សាយតាមប្រព័ន្ធSatellite២(DTV SkyOne)

- បាននិងកំពុងសហការជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងវិស័យឯកជនរៀបចំបង្កើតថ្នាលទូរទស្សន៍ឌីជីថលជាតិ(National Digital TV Platform) ដើម្បីអភិវឌ្ឍប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកម្ពុជាឱ្យក្លាយទៅជាប្រព័ន្ធផ្សព្វផ្សាយទំនើបមានគុណភាពខ្ពស់ កម្មវិធីសម្បូរបែប សេវាគ្របដណ្តប់នៅគ្រប់ទិសទីនៃព្រះរាជាណាចក្រកម្ពុជា និងអាចទទួលបាននូវព័ត៌មានហ័ស ទាន់សភាពការណ៍ និងជាទីទុកចិត្តស្របតាមពាក្យស្លោក ប្លែក លឿន ទុកចិត្តបាន ពេលណា ទីណាក៏បាន

- បាននិងកំពុងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រៀបចំកសាងសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន ហើយបន្តជំរុញសេចក្តីព្រាងច្បាប់នេះដាក់ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន ព្រមទាំងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យព័ត៌មាននិងសោតទស្សន៍ ដើម្បីពង្រឹងការងារអនុវត្តច្បាប់និងគុណភាពនៃការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក

- បាននិងកំពុងសហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ ការរើសអើងប្រកាន់ពូជសាសន៍ ដេរប្រមាថ ញុះញង់បង្កចលាចល ដើម្បីបំពុលបរិយាកាសសង្គមនិងបង្កអស្ថេរភាពនយោបាយ សណ្តាប់ធ្នាប់របៀបរៀបរយសង្គម។ ចាប់តាំងពីឆ្នាំ២០១៨-២០២៣ អគ្គនាយកដ្ឋានព័ត៌មាននិងសោតទស្សន៍បានបញ្ជូនបទល្មើសនៃការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ការផ្សព្វផ្សាយព័ត៌មានញុះញង់បង្កចលាចលសង្គមទៅក្រសួងមហាផ្ទៃនិងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីចាត់ការតាមផ្លូវច្បាប់និងស្នើសុំអន្តរាគមន៍ទៅក្រុមហ៊ុនហ្វេសប៊ុក បិទគណនីហ្វេសប៊ុកបានចំនួន១៦៧ករណី។

**ខ- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ**

ក្នុងរយៈពេល៥ឆ្នាំ(២០១៨ ដល់២០២២) អគ្គនាយករដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ បានអនុវត្តយ៉ាងយកចិត្តទុកដាក់ ក្នុងការចរាចរលិខិតចេញ ចូល ពីក្រសួង ស្ថាប័ននានា និងអង្គភាពក្រោមឱវាទ និងបានធ្វើកំណត់បង្ហាញជូនថ្នាក់ដឹកនាំពិនិត្យសម្រេចនិងបានជ្រាបតាមឋានានុក្រម និងបានចាត់ការថតចម្លងជូនថ្នាក់ដឹកនាំក្រសួង និងតាមអង្គភាពនានា ដើម្បីចាត់ការអនុវត្ត ព្រមទាំងតម្កល់ទុកឯកសារបានត្រឹមត្រូវ និងធ្វើរបាយការណ៍បូកសរុបការងារតាមកាលកំណត់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ព្រឹទ្ធសភា រដ្ឋសភា បានទៀងទាត់។ ទន្ទឹមនេះក៏បានចាត់មន្ត្រីប្រចាំការនៅថ្ងៃបុណ្យនិងថ្ងៃឈប់សម្រាកទៀតផង ដើម្បីធានានូវភាពរលូនក្នុងការបំរើសេវារដ្ឋបាលជូនក្រសួង និងបានសម្របសម្រួលបើកបៀវត្សរ៍ជូនមន្ត្រីរាជការបានទៀងទាត់ ដោះស្រាយថវិកាតាមជំពូកនានាជូនអង្គភាពក្រោមឱវាទ សម្រាប់ដំណើរការការងារប្រចាំថ្ងៃ បែងចែកសម្ភារៈការិយាល័យ និងគ្រប់គ្រង ចុះផ្ទៀងផ្ទាត់បញ្ជីសារពើភណ្ឌលើទ្រព្យសម្បត្តិរដ្ឋ តាមនីតិវិធីហិរញ្ញវត្ថុ។

ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២នេះ អគ្គនាយកដ្ឋាន សម្រេចបានលទ្ធផលសង្ខេបដូចខាងក្រោមៈ

ការងាររដ្ឋបាល បានចំនួនសរុប១០ ៩៨០លិខិតចូល៨ ២២០លិខិតចេញ តាក់តែងលិខិតនៅក្នុងនិងក្រៅក្រសួង១ ៧២០លិខិត ការងារតម្កល់ឯកសារ៣ ៣៤៥លិខិត។

**គ- មន្ទីរព័ត៌មានរាជធានី ខេត្ត ប្រចាំឆ្នាំ២០១៨-២០២២**

មន្ទីរព័ត៌មានរាជធានី ខេត្តបានដំណើរការចុះយកព័ត៌មាន ថតរូបភាពយកមកតែងនិពន្ធ ចងក្រងអត្ថបទព័ត៌មានផលិតកម្មវិធីផ្សេងៗនិងស្ប៉តអប់រំខ្លីៗ ដើម្បីផ្សព្វផ្សាយតាមបណ្តាញវិទ្យុFM ទូរទស្សន៍ជាតិរាជធានី ខេត្ត ទូរទស្សន៍ខ្សែកាបឯកជននៅក្នុងរាជធានី ខេត្តរបស់ខ្លួន និងបានបញ្ជូនខ្លឹមសារមកវិទ្យុ និងរូបភាពមកទូរទស្សន៍ជាតិ

កម្ពុជា និងឯកជននៅរាជធានីភ្នំពេញឱ្យជួយផ្សព្វផ្សាយផងដែរ។ ទន្ទឹមនេះ គ្រប់មន្ទីរព័ត៌មានរាជធានីខេត្តក៏បាន យកចិត្តទុកដាក់ខ្ពស់ក្នុងការចាក់ផ្សាយបន្តពីវិទ្យុ ទូរទស្សន៍ជាតិកម្ពុជាជាប្រចាំ តាមរយៈវិទ្យុ ទូរទស្សន៍ ទូរទស្សន៍ ខ្សែកាបនៅក្នុងរាជធានី ខេត្ត នូវរាល់ព្រឹត្តិការណ៍និងព័ត៌មានសំខាន់ៗស្តីពីព្រះរាជសកម្មភាព និងសកម្មភាព របស់ព្រះមហាក្សត្រ ព្រឹទ្ធសភា រដ្ឋសភា ប្រមុខរាជរដ្ឋាភិបាល ព្រមទាំងបានរាយការណ៍នូវព័ត៌មានប្លែកៗ ទាន់ហេតុការណ៍ និងព្រឹត្តិការណ៍ដែលកើតមានក្នុងមូលដ្ឋានរបស់ខ្លួនមកក្រសួងបានទាន់ពេលវេលា និងធ្វើការ ត្រួតពិនិត្យជាប្រចាំគ្រប់ប្រព័ន្ធផ្សព្វផ្សាយក្នុងរាជធានី ខេត្តផងដែរ។

មន្ទីរព័ត៌មានរាជធានី ខេត្ត ជាសេនាធិការរបស់ក្រសួងព័ត៌មាន ដែលបំពេញតួនាទីទ្រទ្រង់ផ្នែកបច្ចេកទេស សម្រាប់ការងារព័ត៌មាននៅថ្នាក់ក្រោមជាតិដោយបាននូវលទ្ធផលដូចខាងក្រោម៖

ស្ថានីយទូរទស្សន៍ជាតិ ស្ថានីយវិទ្យុជាតិ ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ព័ត៌មាននិងសោតទស្សន៍ ប្រចាំ រាជធានី ខេត្ត បានផលិតកម្មវិធីចំនួន១០៥ ៦៦៦អត្ថបទ ចំនួន៦៥ ៩១៨លើក ចំនួន៤៧ ៧៩៩ម៉ោង ចំនួន ២០០វីដេអូ ចំនួន២៤កម្មវិធី ចំនួន៤ ៤០៥សន្លឹក និងចំនួន១ ១៥៨ទីតាំង ។

**ឃ- ការងារទូរទស្សន៍ជាតិកម្ពុជា**

ក្នុងរយៈពេល៥ឆ្នាំ(២០១៨ ដល់ឆ្នាំ២០២២) អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជាបានយកចិត្តទុកដាក់ អនុវត្តភារកិច្ចរបស់ខ្លួនយ៉ាងសកម្មក្នុងការចុះយកព័ត៌មានមកផ្សព្វផ្សាយ និងផលិតកម្មវិធីសម្បូរបែប បានយ៉ាង រស់រវើកលើគ្រប់វិស័យនិងទាន់ហេតុការណ៍ មានការអប់រំចំណេះដឹង កម្មវិធីកម្សាន្តសប្បាយជូនទូរទស្សនិកជន គ្រប់មជ្ឈដ្ឋានទាំងក្នុងនិងក្រៅប្រទេសទទួលបានលទ្ធផលគួរជាទីមោទនៈ។

ជាក់ស្តែងអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា បានទទួលជោគជ័យធំៗ ក្នុងការផ្សព្វផ្សាយរាល់ព្រឹត្តិការណ៍ ជាតិធំៗសំខាន់ៗ ដោយពុំមានខកខាននិងរាំងស្ទះឡើយ។

អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា បានផ្សព្វផ្សាយតាមរយៈ ទូរទស្សន៍ជាតិកម្ពុជាប៉ុស្តិ៍លេខ៧ គេហទំព័រ www.tvk.gov.kh ហ្វេសប៊ុកផេកផ្លូវការឈ្មោះ«ទូរទស្សន៍ជាតិកម្ពុជា ទទក-TVK» និង«ទទក២-TVK2» Youtube (ទូរទស្សន៍ជាតិកម្ពុជា ទទក-TVK) និងChannel Telegram ឈ្មោះ«អគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា»។

ការងារបច្ចេកទេស និងប្រព័ន្ធផ្សព្វផ្សាយ រថយន្តចល័តទំនើប១គ្រឿង សម្ភារៈចល័តតាមថ្នាក់ដឹកនាំ១ ឈុត ម៉ាស៊ីនផ្សាយផ្ទាល់ចល័តតូច៤គ្រឿង រថយន្តចល័តតូច១គ្រឿង ម៉ាស៊ីនCamera ចំនួន២៧គ្រឿង ម៉ាស៊ីន Computer១៨គ្រឿង Studio ចំនួន៣ឈុត ម៉ាស៊ីនចាក់ផ្សាយ៣ឈុត។

ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២នេះ អគ្គនាយកដ្ឋានសម្រេចបានលទ្ធផលសង្ខេបដូចខាងក្រោម៖

- ផ្សព្វផ្សាយព័ត៌មានស្តីពី**ព្រះរាជសកម្មភាពរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរម នាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** សរុបចំនួន៨៦៩ព័ត៌មាន ព្រះរាជសកម្មភាពព្រះមហាក្សត្រ និងសម្តេចម៉ែមាន ព្រះរាជឱង្ការផ្ទាល់សរុបចំនួន៩០លើក

- ព័ត៌មានជាសំឡេងដើមទាំងស្រុងរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** សរុបចំនួន៥៧៧លើក ក្នុងនោះប្រសាសន៍ដើមនៅក្នុង ប្រទេស៥៤១លើក និងប្រសាសន៍ដើមនៅក្រៅប្រទេស សរុបចំនួន៣៦លើក ស្មើនឹង២ ៣០៨ម៉ោង(ទាំងផ្សាយ ផ្ទាល់និងការផ្សាយឡើងវិញ)

- ផលិតចេញជាឃ្លីបវីដេអូសម្រង់ប្រសាសន៍**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានចំនួន៧០៨ឃ្លីបវីដេអូ ព័ត៌មានជាតិនៅគ្រប់វិស័យផលិតបានចំនួន៣៦ ៥០០អត្ថបទ និងព័ត៌មានអន្តរជាតិចំនួន២៧ ៣៧៥អត្ថបទ ផលិតបទយកការណ៍ចំនួន១ ៥៤២ អត្ថបទ ផលិតកម្មវិធីកិច្ចសម្ភាសបានចំនួន១៣៦កម្មវិធី បានផ្សព្វផ្សាយកម្មវិធីអប់រំចំណេះដឹងទូទៅថ្នាក់មធ្យមសិក្សាតាមរយៈទទក២

- ការផលិតកម្មវិធីនិងចាក់ផ្សាយចំនួន៥ ៦១៨កម្មវិធី ចំនួន៦ ៩១៧អត្ថបទ ការងារផ្សព្វផ្សាយទៅក្រៅប្រទេសចំនួន៤ ៣៩១អត្ថបទ គំនូរជីវចល១៦រឿង សរុប១ ០៥៦ភាគ កម្មវិធីចម្រៀង សរុប១៩៦កម្មវិធី ភាពយន្តភាគខ្មែរ ចិន២៨រឿង សរុប១ ១៦០ភាគ កម្មវិធីកម្សាន្ត សម័យ២៩កម្មវិធី ស្មើនឹង១០៣ភាគ។

**ង- ការងារវិទ្យុជាតិកម្ពុជា**

ក្នុងរយៈពេល៥ឆ្នាំ(២០១៨ ដល់២០២២) អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា(RNK) កន្លងមកបានយកចិត្តទុកដាក់បំពេញការងារទទួលបានលទ្ធផលល្អគួរឱ្យកត់សម្គាល់។ ដើម្បីរួមចំណែកក្នុងការអនុវត្តនូវគោលនយោបាយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា វិទ្យុជាតិកម្ពុជា បានផ្សព្វផ្សាយនូវព័ត៌មាន ដូចជាទិវាជាតិ អន្តរជាតិផ្សេងៗនិងព្រឹត្តិការណ៍សំខាន់ៗដែលកើតមានឡើងនៅព្រះរាជាណាចក្រកម្ពុជា ក្នុងតំបន់និងនៅលើសកលលោក ទន្ទឹមនេះក៏បានរៀបចំកម្មវិធីអប់រំនិងកម្សាន្តដើម្បីបម្រើអារម្មណ៍ប្រិយមិត្តអ្នកស្តាប់ទៀតផង។ វិទ្យុជាតិកម្ពុជាធ្វើការផ្សាយតាមប្រព័ន្ធវិទ្យុ (១) វិទ្យុAM ៩១៨KHz ថាមពលផ្សាយ៦០០KW (២) វិទ្យុFMវត្តភ្នំ១០៥.៧០MHz ថាមពលផ្សាយ៣០KW(៣) វិទ្យុFMជាតិ៩៦MHz ថាមពលផ្សាយ២០KW និង(៤) ផ្សាយតាមគេហទំព័រវិទ្យុជាតិកម្ពុជា(www.rnk.gov.kh) និងតាមរយៈហ្វេសប៊ុកផេក Facebook Page: Radio National of Kampuchea(RNK) និងផ្សាយតាមរលកជាតុអាកាសDTV។

ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២នេះ អគ្គនាយកដ្ឋានសម្រេចបានលទ្ធផលសង្ខេបដូចខាងក្រោមៈ

បានផលិតព័ត៌មានជាតិ អន្តរជាតិ ជាខេមរភាសា និងភាសាអង់គ្លេស បារាំងបានចំនួន៦២ ៥០៥អត្ថបទព័ត៌មាន ក្នុងនោះរួមមានព័ត៌មានក្នុងប្រទេសចំនួន៣៩ ០៣៥ព័ត៌មាន ព័ត៌មានអន្តរជាតិចំនួន៨ ១៤៩ព័ត៌មាន ភាសាអង់គ្លេស បារាំងចំនួន១៥ ៣២១ព័ត៌មាន ដោយសួរសព្ទ៥៨៩ព័ត៌មាន អត្ថាធិប្បាយ៦៣ព័ត៌មាន វិចារណកថា ១ ១២៣ព័ត៌មាន អត្ថបទយល់ដឹង៦២២ព័ត៌មាន កម្មវិធីអាស៊ាន៨៣៤អត្ថបទ អត្ថបទផ្សេងៗ៣៨២អត្ថបទ បទយកការណ៍៦០៦អត្ថបទ កម្មវិធីសន្ទនាមតិ៤០៨កម្មវិធី។ ចំពោះការងារផលិតកម្មវិធីផ្សាយបានចំនួន៨ ២០៨ កម្មវិធី និង៦៧អត្ថបទ រួមមានប្រសាសន៍**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ចំនួន២៨៩កម្មវិធី កម្មវិធីអាយ៉ៃ៥៣៧កម្មវិធី យីកេ៦៧អត្ថបទ ចាប៉ី៦៧ កម្មវិធី នាទីយល់ដឹង៥៤១កម្មវិធី នាទីអប់រំយុវជននិងកុមារ២១៣កម្មវិធី នាទីអប់រំនិងសុខភាព២៤៣កម្មវិធី អប់រំក្រៅប្រព័ន្ធ៣៨៩កម្មវិធី នាទីរតនៈ៣៧៧កម្មវិធី រឿងកម្សាន្ត៩១កម្មវិធី សួនកំណាព្យ១៦៦កម្មវិធី កសិកម្ម ២៧៧កម្មវិធី ស្រាវជ្រាវប្រពៃណីនិងវប្បធម៌ខ្មែរ៣៨៩កម្មវិធី សិល្បៈបុរាណ៣៣៤កម្មវិធី កម្មវិធីបទចម្រៀងអមដោយអត្ថាធិប្បាយ៣៣៩កម្មវិធី រឿងកម្សាន្ត៩១កម្មវិធី នាទីព្រះពុទ្ធសាសនាផ្សាភ្ជាប់នឹងសង្គម១៨៨កម្មវិធី កម្មវិធីធម្មទេសនាថ្ងៃសីល២៣៨កម្មវិធី នាទីសុវត្ថិភាពចរាចរណ៍៨៨៨កម្មវិធី ព្យាករណ៍អាកាសធាតុ២ ១០០កម្មវិធីព្យាករណ៍ទឹកជំនន់២ ១០០កម្មវិធី ការងារបច្ចេកទេសចំនួន១ ៩៧៥លើក ការងារមន្ទីរលិខិតចេញ ចូលចំនួន៥ ២៥៤ ច្បាប់។ អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា មានសហប្រតិបត្តិការអន្តរជាតិជាមួយអគ្គស្ថានីយ៍វិទ្យុ ទូរទស្សន៍មជ្ឈិមបក្សចិន

វិទ្យុឈូងសមុទ្រ ប៉ៃពូ ក្វាងស៊ីចិន វិទ្យុសំឡេងវៀតណាមVOV ទីភ្នាក់ងារសារព័ត៌មាន Sputnik ប្រទេសរុស្ស៊ី) ប្រព័ន្ធផ្សព្វផ្សាយអាស៊ីប៉ាស៊ីហ្វិកASIA-PACIFIC BROADCASTING UNION (ABU) និងវិទ្យាស្ថានដើម្បីអភិវឌ្ឍន៍ប្រព័ន្ធផ្សព្វផ្សាយអាស៊ីប៉ាស៊ីហ្វិក(AIBD)។

**ច- វិទ្យុជាតិFM ៩៦MHz**

តាមរយៈនៃការអនុវត្តតួនាទី និងភារកិច្ចប្រចាំថ្ងៃ សំខាន់ផ្តោតលើភ្ញៀវបរទេសនិងយុវជន រហូតដល់ពេលនេះបានកត់សម្គាល់ឃើញនូវការរីកចម្រើនរបស់វិទ្យុជាតិ FM ៩៦MHz ក្នុងរយៈពេល៥ឆ្នាំ(២០១៨ ដល់ ២០២២) មានដូចខាងក្រោមៈ

- អំពីរចនាសម្ព័ន្ធ : រៀបចំឱ្យមានមន្ត្រីជំនាញទទួលខុសត្រូវតាមមុខនាទីនិងជាប្រចាំដើម្បីជំរុញការអនុវត្តភារកិច្ចតាមជំនាញនិងវិជ្ជាជីវៈ ពង្រឹងនូវសមត្ថភាព បែងចែកវត្តមានតាមវេនប្រចាំការ ប្រកាន់ខ្ជាប់នូវវិន័យការងារទទួលខុសត្រូវភារកិច្ចរៀងៗខ្លួន

- ផ្នែកកម្មវិធី : បានយកចិត្តទុកដាក់បង្កើតនូវកម្មវិធីថ្មីៗប្រកបដោយខ្លឹមសារអប់រំសង្គម ការលើកកម្ពស់តម្លៃសីលធម៌រស់នៅ តាមរយៈផ្សាយនិងផលិតកម្មវិធីរឿងភាគនិទាន៥០រឿង កម្មវិធីផ្សាយផ្ទាល់បញ្ជ្រាបការយល់ដឹងអំពីផលប៉ះពាល់នៃគ្រឿងញៀន និងជាតិស្រវឹង១៦០កម្មវិធី និងសារអប់រំគ្រឿងញៀន៥០សារ ផ្សាយបន្តផ្ទាល់ពីទូរទស្សន៍ជាតិ និងផ្សាយឡើងវិញនូវកម្មវិធីចំណេះដឹងទូទៅ សុវត្ថិភាពចរាចរណ៍៤៣០កម្មវិធី សង្គមនិងសុខភាព ទូទៅ៦៧០អត្ថបទ ការផ្សព្វផ្សាយនូវប្រវត្តនៃរមណីយដ្ឋានទេសចរណ៍នានាទូទាំងព្រះរាជាណាចក្រកម្ពុជា៨៩០អត្ថបទ កម្មវិធីកុមារ១២៥រឿង ល្ខោននិយាយ១៧រឿង ល្ខោនភាគ៧រឿង កម្មវិធីផ្សាយផ្ទាល់សហការជាមួយក្រសួងបរិស្ថាន២១កម្មវិធី ព្រះពុទ្ធសាសនា៥ ៤៧៥កម្មវិធី កសិកម្ម១ ៣០០កម្មវិធី កម្មវិធីកម្សាន្តនានា៤០កម្មវិធី និងជ្រើសរើសនូវបទចម្រៀងពិរោះៗ និងមានខ្លឹមសារអប់រំកម្សាន្តបម្រើអារម្មណ៍ប្រិយមិត្តអ្នកស្តាប់

- ផ្នែកព័ត៌មាន : បានចូលរួមផ្សព្វផ្សាយនូវរាល់ព្រឹត្តការណ៍សំខាន់ៗរបស់ជាតិនិងអន្តរជាតិទាន់ពេលវេលា ចូលរួមបញ្ជូនព័ត៌មានទៅផ្សព្វផ្សាយក្នុងApp របស់ក្រសួងព័ត៌មាន៣ ១៥០ដំណឹង បានស្រាវជ្រាវនិងផ្សព្វផ្សាយនូវរាល់សមិទ្ធផលថ្មីៗរបស់រាជរដ្ឋាភិបាលអំពីសកម្មភាពរបស់ថ្នាក់ដឹកនាំ និងស្ថាប័នព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល៩៤០អត្ថបទ។ វិទ្យុជាតិFM ៩៦MHz បានពង្រឹងនូវគុណភាព នៃការផ្សព្វផ្សាយព័ត៌មានទាំងភាសាខ្មែរ អង់គ្លេស ចិន វៀតណាម កម្មវិធីភាសាអ៊ិស្លាម ធ្វើយ៉ាងណាឱ្យមិត្តអ្នកស្តាប់បានដឹងកាន់តែទូលំទូលាយ បន្សាបនូវរាល់ព័ត៌មានក្លែងបន្លំ និងភាពចម្រុះនៃកម្មវិធី ជូនដល់មិត្តអ្នកស្តាប់ សហគមន៍ និងសង្គមជាតិទាំងមូល។ ដំណឹងនិងព័ត៌មានព្រះមហាក្សត្រ៤៣០ដំណឹង ផ្សាយបន្តផ្ទាល់ពីទទក សកម្មភាពរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានចំនួន៥៧៧លើក ស្មើនឹង២ ៣០៨ម៉ោង ក្នុងនោះប្រសាសន៍នៅក្នុងស្រុកមាន៥៤១លើក និងក្រៅប្រទេសមាន៣៦លើក សម្រង់អនុសាសន៍**សម្តេចតេជោ**៩៥០ឃ្លីប គជប១២០កម្មវិធី និងផ្សាយលទ្ធផលឆ្នោត២២ម៉ោង

- ការបណ្តុះបណ្តាល : វិទ្យុជាតិFM ៩៦MHz បានចាត់បញ្ជូនមន្ត្រីតាមជំនាញចូលរួមសិក្ខាសាលាស្តីពីការផ្សាយព័ត៌មានប្រកបដោយវិជ្ជាជីវៈនិងក្រមសីលធម៌ ដែលរៀបចំដោយក្រសួងព័ត៌មាន ចូលរួមវគ្គខ្លីៗនៅសាធារណរដ្ឋប្រជាមានិតចិន៦លើក វគ្គវិជ្ជាជីវៈសារព័ត៌មាន នៅវៀតណាម៦លើក វគ្គបច្ចេកទេសម៉ាស៊ីនផ្សាយវិទ្យុចំនួន២លើក ម៉ាឡេស៊ី១លើក និងរុស្ស៊ី១លើក

- ផ្នែកបច្ចេកទេស ៖ ដោយបានទទួលនូវសម្ភារៈប្រព័ន្ធម៉ាស៊ីនផ្សាយពីរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម តាមរយៈវិទ្យុសំឡេងប្រជាជនវៀតណាម ក្រុមមន្ត្រីបច្ចេកទេសរបស់វិទ្យុជាតិFM ៩៦MHz បានសហការជាមួយអ្នកបច្ចេកទេសវៀតណាម នាំយកទៅដំឡើងតាមបណ្តាស្ថានីយវិទ្យុជាតិFM ខេត្តបានចំនួន១៩ស្ថានីយនិងទូរទស្សន៍ចំនួន៥ស្ថានីយ៍ មានដូចជាវិទ្យុជាតិFM ៩៦MHz (20KW) វិទ្យុជាតិខេត្តស្វាយរៀង(2KW) វិទ្យុជាតិខេត្តព្រៃវែង(2KW) វិទ្យុជាតិខេត្តតាកែវ(2KW) វិទ្យុជាតិខេត្តព្រះសីហនុ(2KW) វិទ្យុជាតិខេត្តកែប(2KW) វិទ្យុជាតិខេត្តកំពត(2KW) វិទ្យុជាតិខេត្តពោធិ៍សាត់(2KW) វិទ្យុជាតិខេត្តកំពង់ឆ្នាំង(2KW) វិទ្យុជាតិខេត្តព្រះវិហារ(2KW) វិទ្យុជាតិខេត្តបន្ទាយមានជ័យ(5KW) វិទ្យុជាតិខេត្តសៀមរាប(5KW) វិទ្យុជាតិខេត្តស្ទឹងត្រែង(2KW) វិទ្យុជាតិខេត្តរតនគិរី(2KW) វិទ្យុជាតិខេត្តមណ្ឌលគិរី(2KW) វិទ្យុជាតិខេត្តឧត្តរមានជ័យ(2KW) វិទ្យុជាតិខេត្តកំពង់ចាម(2KW) វិទ្យុជាតិខេត្តត្បូងឃ្មុំ(2KW) វិទ្យុជាតិខេត្តកំពង់ស្ពឺ(2KW) និងទូទស្សន៍ចំនួន៥គឺ ខេត្តកំពង់ចាម(5KW) ខេត្តបន្ទាយមានជ័យ(5KW) ខេត្តព្រះសីហនុ(5KW) ខេត្តស្វាយរៀង(5KW) និងខេត្តបាត់ដំបង(5KW)។

សរុបម៉ោងផ្សាយរបស់វិទ្យុជាតិFM ៩៦MHz : ៣២ ១២៤ម៉ោង(៥ឆ្នាំ)

+ Facebook: វិទ្យុជាតិFM ៩៦MHz
  - ចំនួនអ្នកស្គាល់Facebook FM ៩៦MHz : ១ ៩៦៥ ០០៨នាក់
  - ចំនួនអ្នកចែកFacebook FM ៩៦MHz : ៣៣ ០២២នាក់
  - ចំនួនអ្នកចូលចិត្តLike = ៤ ៦៣៥នាក់។
+ Telegram FM ៩៦MHz Channel : ១២៨Subscriber។

**ឆ- អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា**

ក្នុងរយៈពេល៥ឆ្នាំ(ឆ្នាំ២០១៨ ដល់ឆ្នាំ២០២២) អគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជា(AKP) បានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយជោគជ័យ ដោយបានចាត់បញ្ជូនមន្ត្រីយកព័ត៌មាននិងថតរូប តាមបណ្តាក្រសួង ស្ថាប័ននានា នៅបណ្តារាជធានី ខេត្ត ជិតឆ្ងាយក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្សព្វផ្សាយព័ត៌មាន/រូបថត ជាភាសាជាតិ អន្តរជាតិ(ខ្មែរ អង់គ្លេសនិងបារាំង) រូបថតប្រចាំសប្តាហ៍(ខ្មែរ អង់គ្លេស និងបារាំង) បទវិចារណកថា បទយកការណ៍ជាអត្ថបទ/វីដេអូ Poster និងInfographic តាមរយៈព្រឹត្តិបត្រព័ត៌មានប្រចាំថ្ងៃ គេហទំព័រ(www.akp.gov.kh)/AKP Gallery (www.akpgallery.gov.kh) ហ្វេសប៊ុកផេកផ្លូវការ(ទីភ្នាក់ងារសារព័ត៌មានកម្ពុជា-AKP) Youtube (Agence Kampuchea Presse) Twitter (Agence Kampuchea Presse) Channel Telegram (AKP News) និងទស្សនាវដ្តីកម្ពុជាប្រចាំខែផងដែរ បើទោះបីជាស្ថិតក្នុងស្ថានភាពខ្វះខាត ដូចជាមធ្យោបាយចុះយកព័ត៌មាន ប្រេងឥន្ធនៈ សម្ភារៈបច្ចេកទេស និងថវិកាដើម្បីផ្គត់ផ្គង់នៅក្នុងអគ្គនាយកដ្ឋានក៏ដោយ។

ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ នេះ អគ្គនាយកដ្ឋាន សម្រេចបានលទ្ធផលសង្ខេបដូចខាងក្រោម៖

ព័ត៌មានជាតិនិងអន្តរជាតិ ជាភាសាខ្មែរ ចំនួន៣៧ ៥១៩ដំណឹង ភាសាអង់គ្លេស ចំនួន១២ ៩៤៣ដំណឹង ភាសាបារាំងចំនួន៨ ៦០៤ដំណឹង ភាសាអារ៉ាប់ ចំនួន៤០០ដំណឹង ព័ត៌មានរូបថត ជាភាសាខ្មែរ៨៤ ៥០៦ដំណឹង ភាសាអង់គ្លេស៥៥ ៩២១ដំណឹង ភាសាបារាំងចំនួន៤៩ ១៩៣ដំណឹង ទស្សនាវដ្តីចំនួន៥៥លេខ ព្រឹត្តិបត្រព័ត៌មានចំនួន៥៣ ៤៦១ច្បាប់ បទវិចារណកថាចំនួន៣១អត្ថបទ បទយកការណ៍ជាវីដេអូចំនួន៨២បទយកការណ៍ជាអត្ថបទ

ចំនួន១៥៨រឿង Poster ចំនួន៨៣ Infographic ចំនួន១០៥ រូបថតប្រចាំសប្តាហ៍ចំនួន២១៣។ ចំនួនអ្នកមើល និងអ្នកអាន គេហទំព័រចំនួន៤២២ ៤៦០នាក់ ហ្វេសប៊ុកផេកចំនួន៧៧ ០៩០ Followers Channel Telegram ចំនួន៣ ០៦២ Subscribers YouTube ចំនួន៦៨២ Subscribers កិច្ចសហប្រតិបត្តិការជាមួយសារព័ត៌មានជាតិ ចំនួន៤ស្ថាប័ន និងទីភ្នាក់ងារអន្តរជាតិចំនួន១៣ទីភ្នាក់ងារមាន ចិន វៀតណាម ថៃ ឡាវ រុស្ស៊ី អ៊ីតាលី កូរ៉េខាងត្បូង គុយបា ប៊ុលហ្គារី អាមេរិកឡាទីន និងម៉ិកស៊ិក។

**ជ- APP ក្រសួងព័ត៌មាន**

រយៈពេល៥ឆ្នាំ(២០១៨ ដល់២០២២) ក្រុមការងារប្រតិបត្តិApp ក្រសួងព័ត៌មាន បានខិតខំប្រឹងប្រែង យ៉ាងសកម្មក្នុងការសិក្សាស្រាវជ្រាវអំពីបច្ចេកវិទ្យាទំនើបថ្មីៗ ដើម្បីបង្កើតបាននូវបណ្តាញផ្សព្វផ្សាយ មួយដែល អាចបញ្ជូនព័ត៌មានទៅកាន់ប្រជាពលរដ្ឋ ក្នុងនិងក្រៅប្រទេសគ្រប់កាលៈទេសៈ លើគ្រប់ទម្រង់នៃព័ត៌មាន រួមមាន អត្ថបទ រូបភាព វីដេអូ សារសំឡេង និងរូបភាពផ្សាយផ្ទាល់ពីទូរទស្សន៍និងវិទ្យុជាតិផងដែរ។ នៅក្នុងបណ្តាញ ផ្សព្វផ្សាយនោះ រួមមានMobile Application(Android & iOS) Website និងបណ្តាញសង្គមល្បីៗលើពិភពលោក មានដូចជាFacebook, Telegram, YouTube, TikTok, Instagram, Twitter, LinkedIn,.. ដែលកំពុង ដើរតួនាទីយ៉ាងសំខាន់ក្នុងការងារផ្សព្វផ្សាយក្នុងពេលបច្ចុប្បន្នស្របតាមបដិវត្តន៍ឧស្សាហកម្ម៤.០។

ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២នេះ Appក្រសួងព័ត៌មាន សម្រេចបានលទ្ធផលសង្ខេបដូចខាងក្រោម៖

ផ្សព្វផ្សាយព័ត៌មានខ្លីៗចំនួន១០ ៩៣០វីដេអូ និងបទយកការណ៍ចំនួន៤៦៦វីដេអូ ព័ត៌មានជាភាសា ខ្មែរចំនួន៣៥ ១៩០អត្ថបទ ព័ត៌មានភាសាអង់គ្លេសចំនួន១៣ ៦៧៣អត្ថបទ ព័ត៌មានភាសាបារាំងចំនួន១០ ៩៥៥ អត្ថបទ ភាសាអារ៉ាប់ចំនួន៦៥៩អត្ថបទ ព័ត៌មានជាភាសាចិនចំនួន៩៣អត្ថបទ និងទស្សនាវដ្តីកម្ពុជា៨៩លេខ។

បន្ថែមពីលើការងារផ្សព្វផ្សាយ ក្រុមការងារក៏បានរៀបចំនិងបង្កើតនូវម៉ឺនុយផ្សេងៗទៀតសម្រាប់ការផ្ទុក និងរក្សាទុកនូវបណ្តាឯកសារផ្សេងៗ ដូចជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ លិខិតផ្លូវការ កម្រងឯកសាររបស់ ព្រះករុណា ប្រសាសន៍ដើមរបស់ថ្នាក់ដឹកនាំ ក៏ដូចជាព្រឹត្តិការណ៍ជាតិសំខាន់ៗ។ លើសពីនេះទៀត ក្រុមការងារ បានផ្សាយបន្តក្នុងApp នូវទូរទស្សន៍ក្នុងស្រុកចំនួន១៥ប៉ុស្តិ៍ និងវិទ្យុចំនួន១១០ប៉ុស្តិ៍ ទូទាំងប្រទេស។

បណ្តាញផ្សព្វផ្សាយលើអ៊ីនធឺណេតរបស់ក្រសួង ទទួលបានការគាំទ្រច្រើនពីសំណាក់អ្នកប្រើប្រាស់រហូត មកទល់ពេលនេះ ចំនួនអ្នកដែលបានដំឡើងApp មានចំនួន៩២ម៉ឺននាក់ ទាំងAndroid & iOS ចំនួនអ្នកតាមដាន លើទំព័រFacebook ផ្លូវការរបស់ក្រសួងមានចំនួន១១លាននាក់ ចំនួនអ្នកជាវនៅលើ Telegram Channel មាន ៤ម៉ឺននាក់ ចំនួនអ្នកជាវនៅលើYouTube Channel មានចំនួន១៩ម៉ឺននាក់ និងអ្នកប្រើប្រាស់ប្រចាំថ្ងៃនៅលើ គេហទំព័រមានចំនួន៧៤៨ម៉ឺននាក់ក្នុងមួយខែ។

## មុំទី៣- ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម

### ១- លទ្ធផលការងារសំខាន់ៗរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់៖

**ការអភិវឌ្ឍរដ្ឋបាលឌីជីថល**

- បាននិងកំពុងអភិវឌ្ឍមុខងារបន្ថែមលើប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការតាមព័ត៌មានវិទ្យា
- បានបង្កើតសារអេឡិចត្រូនិក(E-mail) ជូនមន្ត្រីរាជការក្រសួងចំនួន២ ៤២៣រូប(ស្ត្រី៥៤៤រូប)
- បានបង្កើតកម្មវិធី«សំណង់នៅកម្ពុជា» ដែលត្រូវបានដាក់ឱ្យប្រើប្រាស់នៅលើប្រព័ន្ធទូរសព្ទចល័ត iOS និង Android និងទទួលបានពានរង្វាន់«សេវារដ្ឋបាលសាធារណៈអេឡិចត្រូនិកល្អបំផុតប្រចាំឆ្នាំ២០១៩» ក្នុងព្រឹត្តិការណ៍ ពិព័រណ៍បច្ចេកវិទ្យាឌីជីថលកម្ពុជាឆ្នាំ២០១៩ ដែលរៀបចំដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងទទួលបាន

«ការទទួលស្គាល់ពិសេសផ្នែកនវានុវត្តន៍ឌីជីថល» ក្នុងព្រឹត្តិការណ៍Cambodia Property Award 2019 រៀបចំដោយ Cambodia Guru Property Award។

**១.១- ការងាររដ្ឋបាលដីធ្លី**( ផេក : Ministry of Land Management, Urban Planning and Construction Cambodia គេហទំព័រ www.mlmupc.gov.kh )

**១.១.១- ការចុះបញ្ជីដីធ្លី**

**១- ការចុះបញ្ជីដីធ្លីដំបូង**

| ឆ្នាំ | ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ(បណ្ណ) | ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ(បណ្ណ) | | | សរុប (បណ្ណ) |
|---|---|---|---|---|---|
| | | ដីរដ្ឋ | ដីរបស់បុគ្គលឯកជន | ដីសហគមន៍ជនជាតិដើមភាគតិច | |
| ២០១៨ | ២៣២ ១១៩ | ១៣៧ | ២ ២៨៤ | ១៦៥ | ២៣៤ ៧០៥ |
| ២០១៩ | ៤៨៦ ១៦២ | ៨៥ | ១ ៤៨០ | ១៣៥ | ៤០៧ ៨៦២ |
| ២០២០ | ៤៤៨ ០៤៨ | ១១១ | ៣ ០៥៨ | ៧៥ | ៤៥១ ២៩២ |
| ២០២១ | ៣៣៥ ៦០៨ | ១៣១ | ២ ៦២៤ | - | ៣៣៨ ៣៦៣ |
| ៩ខែ ២០២២ | ២៤៦ ៣៥៩ | ១៧ | ២ ១៩៨ | ៩២ | ២៤៨ ៦៦៦ |
| **សរុប** | **១ ៧៥៨ ២៩៦** | **៤៨១** | **១១ ៦៤៤** | **៤៦៧** | **១ ៧៧០ ៨៨៨** |

គិតពីចាប់ផ្តើមអនុវត្តដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានចុះបញ្ជីនិងចេញបណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋសរុប៦ ៦៦៣ ៩៧៧បណ្ណ ស្មើនឹង៩៥,២% នៃក្បាលដីប៉ាន់ស្មានសរុបចំនួន៧លានក្បាលដី ក្នុងនោះ៖

- ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធចំនួន៦ ០៣៨ ១២០បណ្ណ
- ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំសម្រេចបាន៦២៥ ៨៥៧បណ្ណ ក្នុងនោះ (១) ដីរដ្ឋបាន១៩៥ទីតាំងចំនួន២ ១២១បណ្ណ ទំហំ៩២១ ៩០៣ហ.ត. ដោយរួមមានសម្បទានដីសេដ្ឋកិច្ច១៧៧ទីតាំង ចំនួន ២ ០២៧បណ្ណ ទំហំ៧០៣ ៤៣៤ហ.ត. ដីមិនទាន់ចុះសម្បទានដីសេដ្ឋកិច្ច២ទីតាំង ចំនួន៧បណ្ណ ទំហំ១ ៤១៣ ហ.ត. និងដីតំបន់ការពារ/ព្រៃស្តារឡើងវិញ១៦ទីតាំង ចំនួន៨៧បណ្ណ ទំហំ២១៧ ០៥៦ហ.ត. (ដីស្ថិតក្រោមការកាន់កាប់របស់ក្រសួងបរិស្ថាន៩ទីតាំង ចំនួន៦៦បណ្ណ ទំហំ១៩៥ ២៣៦ហ.ត. និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៧ទីតាំង ចំនួន២១បណ្ណ ទំហំ២១ ៨២០ហ.ត.) (២) ដីឯកជនរបស់បុគ្គលឯកជនបាន៦២២ ៧៨៨ បណ្ណ និង(៣) ដីសហគមន៍ជនជាតិដើមភាគតិចបានចំនួន៣៧សហគមន៍ ស្មើនឹង៩៤៨បណ្ណ ទំហំ៣៨ ៧១៨,៧៥ ហ.ត. សម្រាប់៣ ៦៥២គ្រួសារ។

**បញ្ជាក់៖**

ក- ការចុះបញ្ជីដីគរុភណ្ឌរបស់វត្ត បានចំនួន១ ៩៣៦វត្ត ស្មើនឹង២ ៤០៤បណ្ណ(ការចុះបញ្ជីជាប្រព័ន្ធចំនួន២ ០៨៥បណ្ណ និងការចុះបញ្ជីដាច់ដោយដុំចំនួន៣១៩បណ្ណ)។

ខ- ការចុះបញ្ជីដីធ្លីតាមប្រភេទទ្រព្យ គិតជាភាគរយតាមប្រភេទទ្រព្យមានទ្រព្យខាងប្តី៩% ស្មើនឹង៥៦៦ ១៥៣ បណ្ណ ទ្រព្យខាងប្រពន្ធ១៩% ស្មើនឹង១ ១៧៨ ០៤៩បណ្ណ ទ្រព្យលីវ៩% ស្មើនឹង៥៥៣ ៤៥៥បណ្ណ ទ្រព្យរួមប្តីប្រពន្ធ ៦០% ស្មើនឹង៣ ៧៦១ ៧៩៩បណ្ណ និងទ្រព្យផ្សេងៗ៣% ស្មើនឹង១៧០ ៩១២បណ្ណ។

២- ការចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិ

| ឆ្នាំ | ចុះបញ្ជីនិងចេញវិញ្ញាបនបត្រ | | | ចុះបញ្ជីផ្ទេរសិទ្ធិ | | |
|---|---|---|---|---|---|---|
| | រាជធានីភ្នំពេញ | ខេត្តព្រះសីហនុ | ខេត្តសៀមរាប | ខ្មែរ | ជនបរទេស | ក្រុមហ៊ុន |
| ២០១៨ | ៤ ៦៦២ | ៣២ | - | ៣៩០ | ១ ១៣៧ | - |
| ២០១៩ | ៣ ២៦៤ | ៤១ | - | ៤៣១ | ២ ៥២២ | ៨៥ |
| ២០២០ | ៧ ៥១៣ | ៦ ២៦២ | ១៣ | ៣៧៩ | ២ ១៤៨ | ១៦៥ |
| ២០២១ | ៥ ៨៥៦ | ១០០ | - | ៣២៧ | ៨៩០ | ៩៣ |
| ៩ខែ ២០២២ | ១០ ០៦០ | ៩២៤ | - | ៣៥៤ | ១ ១៩០ | ៧៦ |
| **សរុប** | **៣១ ៣៥៥** | **៧ ៣៥៩** | **១៣** | **១ ៨៨១** | **៧ ៨៣៧** | **៤១៩** |

គិតពីចាប់ផ្ដើមអនុវត្តដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានចុះបញ្ជីចំណែកឯកជននៃអគារសហកម្មសិទ្ធិចំនួន៥៤ ០១៨បណ្ណ(រាជធានីភ្នំពេញចំនួន៤៦ ៥៩៥បណ្ណ ខេត្តព្រះសីហនុចំនួន៧ ៤១០បណ្ណ និងខេត្តសៀមរាបចំនួន១៣បណ្ណ) និងចុះបញ្ជីផ្ទេរកម្មសិទ្ធិលើចំណែកឯកជននៃអគារសហកម្មសិទ្ធិចំនួន១២ ៧៥៣បណ្ណ(ខ្មែរចំនួន៣ ០៦០បណ្ណ ជនបរទេសចំនួន៩ ២៧៤បណ្ណ និងក្រុមហ៊ុនចំនួន៤១៩បណ្ណ)។

**១.១.២- ការគាំទ្រដល់ការងាររដ្ឋបាលដីធ្លី**

១- ការជំរុញពន្លឿនឯកសារពន្ធប្រថាប់ត្រាសូន្យ ដែលទាក់ទងនឹងការផ្ទេរកម្មសិទ្ធិរវាងញាតិជាមួយអង្គភាពពន្ធដារសម្រេចបាន៖

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ ២០២២ |
|---|---|---|---|---|---|
| បញ្ជូនសំណុំឯកសារទៅសាខាពន្ធដារ | - | - | ១១៧ ៩៣៥ | ៣ ១៦៤ | - |
| ចែកបណ្ណ | - | - | ១១៣ ៧៨៤ | ៣ ០៥៨ | - |
| សំណុំឯកសារសល់នៅពន្ធដារ | - | - | ៥៦៧ | ៤២៨ | - |
| ម្ចាស់កាន់ទៅប្រថាប់ត្រា(សំណុំឯកសារ) | - | - | ១ ៣១៦ | ៥៥៧ | - |
| សល់នៅមន្ទីរ(សំណុំឯកសារ) | - | - | ២ ១៨១ | ១ ៤៤២ | - |

គិតពីចាប់ផ្ដើមអនុវត្តឆ្នាំ២០២០ ដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ មន្ទីរដ.ន.ស.ស.រាជធានី ខេត្ត បានបញ្ជូនសំណុំឯកសារទៅសាខាពន្ធដារបានចំនួន១២១ ០៧៩សំណុំឯកសារ ហើយសាខាពន្ធដារបានប្រថាប់ត្រារួចចំនួន១២០ ៦៦៦សំណុំឯកសារ មន្ទីរបានរៀបចំឯកសារសម្រេចនិងបានចែកបណ្ណបានចំនួន១១៦ ៦៩០បណ្ណ។ សំណុំឯកសារដែលសល់នៅសាខាពន្ធដារមានចំនួន៤២៨សំណុំឯកសារ ម្ចាស់កាន់ទៅប្រថាប់ត្រាផ្ទាល់ចំនួន៥៥៧សំណុំឯកសារ និងសល់នៅមន្ទីរចំនួន១ ៤៤២សំណុំឯកសារ។

២- បានគាំទ្រការអនុវត្តការងារចុះបញ្ជីដីរដ្ឋ ចុះបញ្ជីដីឯកជនរបស់ប្រជាពលរដ្ឋ ចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច ដោះស្រាយវិវាទដីធ្លី និងកសាងផែនការប្រើប្រាស់ដីខេត្តមណ្ឌលគិរី នៃក្រុង ស្រុកគោលដៅចំនួន៥ រួមមានក្រុងសែនមនោរម្យ ស្រុកកែវសីមា ស្រុកកោះញែក ស្រុកអូររាំង និងស្រុកពេជ្រាដា ដើម្បីចុះស្រង់និងប្រមូលទិន្នន័យក្បាលដីចំនួន១២ភូមិ ដែលមានក្រុមការងារចុះបញ្ជីដីធ្លីចំនួន១២ក្រុម ស្មើនឹង១២០នាក់។ សរុបលទ្ធផលពីចាប់ផ្ដើមអនុវត្តថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ ដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២១ បានធ្វើការវាស់វែងបានចំនួន៧ ២៥៦ក្បាលដី បំពេញទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីបានចំនួន៦ ១៩០ក្បាលដី គូសបានចំនួន៧ ២៥៦ក្បាលដី និងបញ្ចូលទិន្នន័យបានចំនួន៤ ៧៧៦ក្បាលដី។ បានប្រគល់ទិន្នន័យក្បាលដីដែល

វាស់វែងនិងផែនទី(Hard Copy និង Soft Copy) ទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ដើម្បីពិនិត្យនិងផ្តល់យោបល់មកក្រសួងដ.ន.ស.វិញ។ ដោយឡែក ក្រសួងដ.ន.ស. បានទទួលការឆ្លើយតបពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន និងកំពុងបន្តអនុវត្តនីតិវិធី។

៣- ការចុះអនុវត្តវិធានការចំពោះការកាន់កាប់ដីព្រៃលិចទឹកតំបន់ជុំវិញបឹងទន្លេសាប

គិតពីចាប់ផ្តើមអនុវត្តដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ លទ្ធផលការអនុវត្តវិធានការទប់ស្កាត់ការទន្រ្ទានដីរដ្ឋក្នុងដែនព្រៃលិចទឹកតំបន់ទន្លេសាបនៃខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ធំ បាត់ដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប ដោយរាជរដ្ឋាភិបាលបានសម្រេចកែសម្រួលព្រំប្រទល់តំបន់៣និងតំបន់២នៃបឹងទន្លេសាបសរុបទំហំ២៤ ៩៤០ហ.ត. ៦២អា ៩៧សង់ទីអា ផ្តល់ជូនប្រជាពលរដ្ឋចំនួន១៥ ៦៦១គ្រួសារ ក្នុងនោះផ្ទៃដីទំហំ ១១ ២៥៥ហ.ត. ២៩សង់ទីអា ២៩អា ផ្តល់ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន១២ ០៤១គ្រួសារ និងផ្ទៃដីទំហំ ១៣ ៦៨៥ហ.ត. ៣៣អា ៦៨សង់ទីអា និងផ្តល់ជាសិទ្ធិកាន់កាប់និងអាស្រ័យផលជូនប្រជាពលរដ្ឋចំនួន៥ ៣០៨ គ្រួសារ ដូចខាងក្រោម៖

- **ខេត្តកំពង់ឆ្នាំង** កាត់ឆ្វៀលផ្ទៃដីទំហំ២៥៣ហ.ត. ១៨អា ២៩សង់ទីអា ចេញពីតំបន់៣ និងផ្តល់ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន១ ៦៨៨គ្រួសារ និងកែសម្រួលផ្ទៃដីទំហំ៣ ៣៩១ហ.ត. ចេញពីតំបន់៣ បញ្ចូលមកក្នុងតំបន់២ និងផ្តល់ជាសិទ្ធិប្រើប្រាស់និងអាស្រ័យផលជូនប្រជាពលរដ្ឋ១ ៦៨៨គ្រួសារខាងលើ ស្ថិតនៅឃុំសំរោងសែន និងឃុំផ្លូវទូក ស្រុកកំពង់លែង តាមលិខិតលេខ៤១៦សជណ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ ២០២២ និងអនុក្រឹត្យលេខ ១១២អនក្រ.បក ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២។ ជាមួយនេះ នៅក្នុងខេត្តកំពង់ឆ្នាំងនេះ (១) ប្រជាពលរដ្ឋស្ម័គ្រចិត្តប្រគល់ដីជូនរដ្ឋវិញចំនួន៧ ៥៣១គ្រួសារ ស្មើនឹង៣០ ៥៨៩ហ.ត. និងធ្វើការវាស់វែងដាក់ស្លែងបានចំនួន៥ ០៦១ គ្រួសារ ស្មើនឹង៥ ៥៨៦ក្បាលដី ទំហំ១៥ ២៨៥,២៧ហ.ត. (២) កប់គ្រាប់ត្នោតបានចំនួន២៣ ៨៩៤គ្រាប់ ដើមត្នោត៩ដើម ដើមរាំង២ ០០០ដើម ដើមឫស្សី៤ ៤៥០ដើម ដើមរំដេញ៥ ៣៥០ដើម ដើមសណ្តាន់១ ៩៣៥ដើម និងដើមផ្សេងៗ៩ ៥០០ដើម និង(៣) បង្កោះជ្រូនថតរូបភាពចំនួន៧៧ ៥៤៣ហ.ត. ស្មើនឹង១០០% និងថតវីឌីអូបានចំនួន១៩ ១៦៥ហ.ត. ស្មើនឹង២៥,៥៤%

- **ខេត្តពោធិ៍សាត់** បានកែសម្រួលផ្ទៃដីទំហំ៣ ៤៤៨ហ.ត. ៧៧អា ចេញពីតំបន់៣ បញ្ចូលមកក្នុងតំបន់២ និងផ្តល់ជាសិទ្ធិប្រើប្រាស់និងអាស្រ័យផលជូនប្រជាពលរដ្ឋចំនួន១ ៦៥៨គ្រួសារ ស្ថិតនៅឃុំកំពង់ពោធិ៍ ឃុំកំពង់ហ្លួង ឃុំអន្សាចំបក់ និងឃុំអូរសណ្តាន់ ស្រុកក្រគរ ឃុំកញ្ជរ ឃុំរាំងទិល ឃុំស្យា និងឃុំស្រែស្តុក ស្រុកកណ្តៀង និងឃុំបឹងបត់កណ្តាល ឃុំមេទឹក និងឃុំអូរតាប៉ោង ស្រុកបាកាន តាមលិខិតលេខ៣៩២សជណ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ និងតាមអនុក្រឹត្យលេខ១០១អនក្រ.បក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២។ ជាមួយនេះ នៅក្នុងខេត្តពោធិ៍សាត់នេះ (១) ប្រជាពលរដ្ឋស្ម័គ្រចិត្តប្រគល់ដីជូនរដ្ឋវិញចំនួន៣៧១គ្រួសារ ស្មើនឹង១ ២៧៦,២៣ ហ.ត. និងធ្វើការវាស់វែងដាក់ស្លែងបានចំនួន៣៧១គ្រួសារ ស្មើនឹង៣៨៨ក្បាលដី ទំហំ១ ២៧៦,២៣ហ.ត. (២) កប់គ្រាប់ត្នោតបានចំនួន៨២ ៨៣៩គ្រាប់ និង(៣) បង្កោះជ្រូនថតរូបភាពចំនួន១២ ៤៤៦ហ.ត. ស្មើនឹង១៣,២៣% និងថតវីឌីអូបានចំនួន៤ ២១០ហ.ត. ស្មើនឹង៤,៤៨%

- **ខេត្តកំពង់ធំ** បានកែសម្រួលផ្ទៃដីទំហំ១០ ០១៤ហ.ត. ១៦អា ចេញពីតំបន់២ បញ្ចូលមកក្នុងតំបន់១ និងផ្តល់ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន៩ ១៤៤គ្រួសារ ស្ថិតនៅភូមិសាស្រ្តស្រុកស្ទោង ស្រុកកំពង់ស្វាយ ស្រុកសន្ទុក និងស្រុកបារាយណ៍ តាមលិខិតលេខ២២៤សជណ.ដប ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ និងបាន

កែសម្រួលផ្ទៃដីទំហំ៦ ៣៨៥ហ.ត. ស្មើនឹង២ ០២៥ក្បាលដី ចេញពីតំបន់៣ បញ្ចូលមកក្នុងតំបន់២ និងផ្តល់សិទ្ធិកាន់កាប់និងអាស្រ័យផលជូនប្រជាពលរដ្ឋចំនួន១ ៧៤៩គ្រួសារ ស្ថិតនៅស្រុកតាំងគោក និងស្រុកកំពង់ស្វាយ តាមលិខិតលេខ៣៩៣សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ និងតាមអនុក្រឹត្យលេខ១០៥អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២។ ជាមួយនេះ នៅក្នុងខេត្តកំពង់ធំនេះ (១) ប្រជាពលរដ្ឋស្មគ្រចិត្តប្រគល់ដីជូនរដ្ឋវិញចំនួន២ ៧០០គ្រួសារ ស្មើនឹង១៣ ៩៥៦,៦៧ហ.ត. និងធ្វើការវាស់វែងដាក់ស្តែងបានចំនួន១ ៨១៨គ្រួសារ ស្មើនឹង៥១ ៨៨៨,៩៥ហ.ត. (២) កប់គ្រាប់ត្នោតបានចំនួន៥៤ ៣៨៤គ្រាប់ ដើមត្នោត១១៥ដើម ដើមរាំង២ ០០៩ដើម ដើមឫស្សី៥៦៥ដើម ដើមរំដេញ៥៣៤ដើម ដើមត្រស់៦៦៤ដើម ដើមអញ្ចាញ១៥៦ដើម ដើមផ្កាំ៦៥០ដើម ដើមថ្លឹមអណ្តើក៣៥៦ដើម ដើមបបួយ១៥០ដើម និងដើមខ្នាយមាន់៣៥០ដើម និង(៣) បង្កោះដ្រូនថតរូបភាពចំនួន២២ ៣៩១ហ.ត. ស្មើនឹង១៦,៩៥% និងថតវីឌីអូបានចំនួន២៩ ២១៦ហ.ត. ស្មើនឹង២២,១២%

- **ខេត្តបាត់ដំបង** បានកែសម្រួលផ្ទៃដីទំហំ៤០២ហ.ត. ៤០អា ចេញពីតំបន់៣ បញ្ចូលមកក្នុងតំបន់២ និងផ្តល់ជាសិទ្ធិប្រើប្រាស់និងអាស្រ័យផលជូនប្រជាពលរដ្ឋចំនួន១៩១គ្រួសារ ស្ថិតនៅឃុំព្រែកហ្លួង ឃុំព្រែកនរិន្ទ និងឃុំពាមឯក ស្រុកឯកភ្នំ តាមលិខិតលេខ៤១៣ សជណ ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២ និងតាមអនុក្រឹត្យលេខ១១០ អនក្រ.បក ចុះថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២ និងបានកែសម្រួលផ្ទៃដីទំហំ៩៨៧ហ.ត. ៩៥អា ចេញពីតំបន់២ បញ្ចូលមកក្នុងតំបន់១ និងផ្តល់ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន១ ២០៩គ្រួសារ ស្ថិតនៅឃុំព្រៃតូច ឃុំកកោះ ឃុំតាលាស់ និងឃុំជ្រៃ ស្រុកមោងឫស្សី តាមលិខិតលេខ៥០៦ សជណ.ជប ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២។ ជាមួយនេះ នៅក្នុងខេត្តបាត់ដំបងនេះ (១)ប្រជាពលរដ្ឋស្មគ្រចិត្តប្រគល់ដីជូនរដ្ឋវិញចំនួន២ ១៥២គ្រួសារ ស្មើនឹង៩ ៣៦៤,៣៧ហ.ត. និងធ្វើការវាស់វែងដាក់ស្តែងបានចំនួន២ ៧២៩គ្រួសារ ស្មើនឹង៣ ០១១ក្បាលដី ទំហំ១៣ ៨២៥ហ.ត. (២) កប់គ្រាប់ត្នោតបានចំនួន ១០៤ ៤៣២គ្រាប់ ដើមរាំង៥ ៧៥៤ដើម និងដើមឫស្សី១ ០២៤ដើម និង(៣) បង្កោះដ្រូនថតរូបភាពចំនួន២ ២៦៨ហ.ត. ស្មើនឹង១,១០% និងថតវីឌីអូបានចំនួន៦ ៣៥៩ហ.ត. ស្មើនឹង៣,០៧%

- **ខេត្តបន្ទាយមានជ័យ** បានកែសម្រួលផ្ទៃដីទំហំ៥៨ហ.ត. ១៦អា ៦៨សង់ទីអា ចេញពីតំបន់៣ បញ្ចូលមកក្នុងតំបន់២ និងផ្តល់ជូនជាសិទ្ធិប្រើប្រាស់និងអាស្រ័យផលជូនប្រជាពលរដ្ឋចំនួន២២គ្រួសារ ស្ថិតនៅភូមិកាបៅ និងភូមិកំពង់ក្រសាំង ឃុំលៀប ស្រុកព្រះនេត្រព្រះ តាមលិខិតលេខ៤០២ សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២ និងតាមអនុក្រឹត្យលេខ១០៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២២។ ជាមួយនេះ នៅក្នុងខេត្តបន្ទាយមានជ័យនេះ (១) ប្រជាពលរដ្ឋស្ម័គ្រចិត្តប្រគល់ដីជូនរដ្ឋវិញចំនួន៨០១គ្រួសារ ស្មើនឹង៤ ៧៦៧ហ.ត. និងធ្វើការវាស់វែងដាក់ស្តែងបានចំនួន៦៩៩គ្រួសារ ស្មើនឹង៣៤ក្បាលដី ទំហំ៤ ៧៦៧ហ.ត. (២) កប់គ្រាប់ត្នោតបានចំនួន១៨ ៦៦០គ្រាប់ ដើមត្នោត៥ដើម ដើមរាំង៦ ៩០០ដើម ដើមឫស្សី៧ ២២០ដើម និងដើមរំដេញ៦០០ដើម និង(៣) បង្កោះដ្រូនថតរូបភាពចំនួន២ ៧៤៩ហ.ត. ស្មើនឹង២២,៤២% និងថតវីឌីអូបានចំនួន១១ ៣៣០ហ.ត. ស្មើនឹង៩២,៩១%

- **ខេត្តសៀមរាប** (១) ប្រជាពលរដ្ឋស្មគ្រចិត្តប្រគល់ដីជូនរដ្ឋវិញចំនួន១ ៤៤៧គ្រួសារ ស្មើនឹង៣ ២៤១,៥២ហ.ត. (២) កប់គ្រាប់ត្នោតបានចំនួន៥៩ ១៩១គ្រាប់ ដើមត្នោត១០ដើម ដើមច្រកែង២០០ដើម ដើមរាំង២ ៣៥០ដើម ដើមឫស្សី៤៥០ដើម ដើមផ្ទោល២០០ដើម ដើមរំដេញ៤៥០ដើម ដើមសណ្តាន់១ ៥៥០ដើម ដើមត្រស់១០០

ដើម និងដើមកន្សែង២០០ដើម និង(៣) បង្ហោះជ្រូនថតរូបភាពចំនួន១ ៣៥៦ហ.ត. ស្មើនឹង១,០៧% និងថតវីឌីអូបានចំនួន២៦ ៦៧០ហ.ត. ស្មើនឹង២១,០២%។

៤- ការងារវាស់វែងនិងភូមិសាស្ត្រ

- គិតពីចាប់ផ្តើមអនុវត្តឆ្នាំ២០១៨ ដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានចុះបង្ហោះជ្រូន ដើម្បីថតរូបភាពផលិតជាផែនទីរូបថតអ័រតូហ្វូតូនិងវីដេអូសរុបចំនួន៨៤ទីតាំង ដែលផលិតជាផែនទីរូបថតអ័រតូហ្វូតូបានទំហំ ៤១៣ ១២៣ហ.ត.

- ពីឆ្នាំ២០១៨ ដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានផលិតអ័រតូហ្វូតូមាត្រដ្ឋាន១:៤០០០ ចំនួន៦ ៥០៧សន្លឹក ទំហំ២៧ ២៥៩គ.ម.$^{២}$ និងផ្តល់ទិន្នន័យអ័រតូហ្វូតូមាត្រដ្ឋាន១:៤០០០ ចំនួន៥ ៨៤៤សន្លឹក ទំហំ២៤ ៨៧៣គ.ម.$^{២}$ គាំទ្រដល់ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធទូទាំងប្រទេស(គិតពីចាប់ផ្តើមអនុវត្តដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានផលិតអ័រតូហ្វូតូចំនួន១៨ ៤៦៨សន្លឹក ទំហំ៣៩ ៧០៣គ.ម.$^{២}$ និងផ្តល់ទិន្នន័យអ័រតូហ្វូតូចំនួន ១៦ ៥៤០សន្លឹក ទំហំ២៥ ៣៨៩០គ.ម.$^{២}$)

- ពីឆ្នាំ២០១៨ ដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានបោះពុម្ពប្លង់សុរិយោដី អ័រតូហ្វូតូ និងបញ្ជីឈ្មោះម្ចាស់ដីទំហំ A0 បានចំនួន៨ ០២៧សន្លឹក (គិតពីចាប់ផ្តើមអនុវត្តដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានចំនួន ២២ ៧៤៥សន្លឹក)

- ពីឆ្នាំ២០១៨ ដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានរៀបចំទិន្នន័យភូមិសាស្ត្រជាទម្រង់ឌីជីថលដោយបានស្កេនផែនទីនិងរូបថតផែនទី ដែលផលិតដោយកងទ័ពឃោជាអាម៉េរិកក្នុងទសវត្សទី៧០ ចំនួន២៨០សន្លឹក និងផែនទីឋានលេខាព្រំដែនគោកកម្ពុជា វៀតណាម មាត្រដ្ឋាន១:២៥ ០០០ ចំនួន៩២ផ្ទាំង

- ពីឆ្នាំ២០១៨ ដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានកសាង (១) ស្ថានីយវាស់វែងអចិន្ត្រៃយ៍ (CORS) ចំនួន៦៥ស្ថានីយ នៅទូទាំងប្រទេស (២) បង្គោលបណ្តាញប្រឹថពីវិភាគផ្ទៃរាបចំនួន៣៦២បង្គោល ក្នុងនោះលំដាប់ទី២ ចំនួន៤១បង្គោល និងលំដាប់ទី៣ ចំនួន៣២១បង្គោល (៣) បង្គោលបណ្តាញរយៈកម្ពស់ លំដាប់ទី១ ចំនួន១៣៧បង្គោល និង(៤) បង្គោលទំនាញផែនដីចំនួន២៣៧បង្គោល ក្នុងនោះបង្គោលមូលដ្ឋានគ្រឹះចំនួន២បង្គោល លំដាប់ទី១ ចំនួន២០បង្គោល លំដាប់ទី២ ចំនួន៥៧បង្គោល និងលំដាប់ទី៣ ចំនួន១៥៨បង្គោល (គិតពីចាប់ផ្តើមអនុវត្តដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានកសាង (១) ស្ថានីយវាស់វែងអចិន្ត្រៃយ៍ចំនួន៦៨ស្ថានីយ (២) បង្គោលបណ្តាញប្រឹថពីវិភាគផ្ទៃរាបចំនួន២ ០៤២បង្គោល (៣) បង្គោលបណ្តាញរយៈកម្ពស់ចំនួន៩៧២បង្គោល និង(៤) បង្គោលទំនាញផែនដីចំនួន២៣៧បង្គោល)

គិតពីចាប់ផ្តើមអនុវត្តឆ្នាំ២០១៩ ដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ មានអ្នកចូលមើលព័ត៌មានសុរិយោដីតាមរយៈការស្កេនQR Code សរុបចំនួន២ ៧៦៤ករណី ក្នុងនោះអ្នកចូលមើលព័ត៌មានក្បាលដីមិនបង់សេវាចំនួន១ ៥៩០ករណី និងអ្នកចូលមើលព័ត៌មានពីបន្ទុកក្បាលដីដែលត្រូវបង់សេវាចំនួន១ ១៧៤ករណី។

៥- ធ្វើប្រតិភូកម្មជូនមេឃុំ ចៅសង្កាត់ នូវសមត្ថកិច្ចពេញលេញក្នុងការចុះហត្ថលេខាបញ្ជាក់លើលិខិតផ្សេងៗដូចជាលិខិតលក់ផ្តាច់ អំណោយផ្តាច់ ហ៊ីប៉ូតែក កិច្ចសន្យាបង្កើតសេវភាព ផលុបភោគ ដោយមិនតម្រូវឱ្យអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ចុះហត្ថលេខាឡើយ។

៦- បានណែនាំអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ឱ្យឈប់ធ្វើការបញ្ជាក់លើឯកសារផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យមិនទាន់ចុះបញ្ជីណាដែលពុំមានភ្ជាប់គំនូសប្លង់ទីតាំង មាននិយាមកាច្បាស់លាស់ដោយមានការបញ្ជាក់ទទួលស្គាល់ពីរដ្ឋបាលសុរិយោដី។

**១.១.៣- ការងាររៀបចំដែនដី និងនគរូបនីយកម្ម**

| ឆ្នាំ | ថ្នាក់រាជធានី ខេត្ត | ថ្នាក់ក្រុង ស្រុក ខណ្ឌ និងទីប្រជុំជន | ថ្នាក់ឃុំ សង្កាត់ |
|---|---|---|---|
| ២០១៨ | ២ | ៣ | ២ |
| ២០១៩ | - | ៦ | ២ |
| ២០២០ | - | ៣ | ៣៥ |
| ២០២១ | - | ៧ | ៦៩ |
| ៩ខែ ២០២២ | - | - | ៤ |
| **សរុប** | **២** | **១៩** | **១១២** |

គិតពីចាប់ផ្តើមអនុវត្តដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ ក្រសួងសម្រេចលទ្ធផលបានដូចខាងក្រោម៖

១- បានអនុម័តផែនការរូបវន្ត៖

- ថ្នាក់រាជធានី ខេត្តចំនួន៣ : ប្លង់គោលប្រើប្រាស់ដីរាជធានីភ្នំពេញ ផែនការរៀបចំដែនដីខេត្តបាត់ដំបង និងផែនការរៀបចំដែនដីខេត្តព្រះសីហនុ

- ថ្នាក់ក្រុង ស្រុក ខណ្ឌ និងទីប្រជុំជនចំនួន២៤ : ប្លង់គោលប្រើប្រាស់ដីទីប្រជុំជនទីរួមខេត្តត្បូងឃ្មុំ ក្រុងបាត់ដំបង ក្រុងតាខ្មៅ ក្រុងកំពត ក្រុងបូកគោ ក្រុងកែប ក្រុងខេមរភូមិន្ទ ក្រុងសៀមរាប ក្រុងប៉ោយប៉ែត ក្រុងបាវិត ក្រុងស្ទឹងត្រែង ស្រុកបរិបូណ៌ ខណ្ឌជ្រោយចង្វារ ខណ្ឌសែនសុខ ក្រុងព្រះសីហនុ ខណ្ឌព្រែកព្នៅ ខណ្ឌឫស្សីកែវ ខណ្ឌទួលគោក ខណ្ឌ៧មករា ខណ្ឌមានជ័យ ខណ្ឌដូនពេញ ទីប្រជុំជនកោះរ៉ុង ទីប្រជុំជនជ្រៃធំនៃស្រុកកោះធំ និងទីប្រជុំជនស្រុកស្វាយអន្ទរ

- ថ្នាក់ឃុំ សង្កាត់ : ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ចំនួន១៩០ឃុំ សង្កាត់ ក្នុង១៩ខេត្ត។

២- ផ្តល់លិខិតអនុញ្ញាតអភិវឌ្ឍដីបានចំនួន៨២គម្រោង។

៣- បានរៀបចំផែនទីព្រំប្រទល់រដ្ឋបាល ផែនទីហេដ្ឋារចនាសម្ព័ន្ធ និងផែនទីប្រើប្រាស់ដីបច្ចុប្បន្ននៃក្រុង ស្រុក ខណ្ឌចំនួន១៧៦ ស្មើនឹង៨៦% នៃចំនួនក្រុង ស្រុក ខណ្ឌ សរុប២០៣ នៅទូទាំងប្រទេស។

## ១.២- ការគ្រប់គ្រងនិងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

### ១.២.១- ការរៀបចំផែនការរូបវន្ត

| ឆ្នាំ | បរិយាយការងារ |
|---|---|
| ២០១៨ | -បានរៀបចំប្លង់គោលប្រើប្រាស់ដីកោះចំនួន ៣កោះ<br>-បានសិក្សាប្រព័ន្ធរំដោះទឹកកខ្វក់ និងស្ថានីយបូមទឹកកខ្វក់ទី១ ទី២ ទី៣ និងទី៤<br>-បានសិក្សាគម្រោងប្លង់កែលម្អឆ្នេរអូរឈើទាល ឆ្នេរអូរត្រេះ ឆ្នេរឯករាជ្យ និងឆ្នេរពេយកំពេញ។ |
| ២០១៩ | -បានរៀបចំប្លង់គោលប្រើប្រាស់ដីកោះចំនួន ៣កោះ |

| | |
|---|---|
| | -បានរៀបចំផែនទីដីចំណីឆ្នេរសមុទ្រកម្ពុជា<br>-បានបង្ហោះផ្សព្វផ្សាយវីដេអូស្ថានភាពជាក់ស្តែងនៃតំបន់ឆ្នេរសមុទ្រកម្ពុជា ខេត្តកំពត ខេត្តកែប និង ខេត្តព្រះសីហនុ<br>-បានសិក្សាគម្រោងប្លង់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន៣៤ខ្សែ ក្នុងខេត្តព្រះសីហនុ។ |
| ២០២០ | -បានរៀបចំប្លង់គោលប្រើប្រាស់ដីកោះចំនួន១កោះ<br>-បានរៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រក្រុងព្រះសីហនុ<br>-បានសិក្សាគម្រោងប្លង់អភិវឌ្ឍស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទី១និងទី២<br>-បានសិក្សាគម្រោងប្លង់កែលម្អឆ្នេរពយជំទាវម៉ៅ ឆ្នេរពយតាមូង និងឆ្នេរពយអូរឈើទាល<br>-បានសិក្សាគម្រោងប្លង់បង្គន់អនាម័យចំនួន១៤គំរូប្លង់ស្ថាបត្យកម្ម ក្នុងក្រុងព្រះសីហនុ។ |
| ២០២១ | -បានរៀបចំនិងសម្រេចដាក់ឱ្យប្រើប្រាស់នូវគម្រោងកែលម្អឆ្នេរភក់ទៅជាឆ្នេរខ្សាច់កម្សាន្តសាធារណៈកម្រិតខ្ពស់ ប្រវែង២ ៧០០ម. ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប<br>-បានរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីតំបន់បឹងធំកង្កែប ស្ថិតនៅភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ<br>-បានសិក្សាគម្រោងប្លង់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន៣ខ្សែ ក្នុងខេត្តព្រះសីហនុ<br>-បានសិក្សាគម្រោងប្លង់អភិវឌ្ឍស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទី៣។ |
| ៩ខែ ២០២២ | -បានរៀបចំផែនការយុទ្ធសាស្ត្រកែលម្អនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រក្រុងកោះរ៉ុង<br>-បានរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាខេត្តព្រះសីហនុ<br>-បាននិងកំពុងរៀបចំផែនទីដីចំណីឆ្នេរសមុទ្រកម្ពុជា ក្រុងព្រះសីហនុ<br>-បាននិងកំពុងរៀបចំផែនការកែលម្អតាមដងព្រែកកំពង់បាយ ក្នុងខេត្តកំពត<br>-បាននិងកំពុងសិក្សាគម្រោងប្លង់កែលម្អឆ្នេរព្រែកត្រែង។ |

## ១.២.២- ការសាងសង់

| ឆ្នាំ | បរិយាយការងារ |
|---|---|
| ២០១៨ | -បានសាងសង់បង្គោលកំណត់ព្រំដីចំណីឆ្នេរសមុទ្រកម្ពុជាចំនួន១០បង្គោល<br>-បានបោះបង្គោលប្រឹថពីវិភាគនិងរៀបចំផែនទីរូបថតពីលើអាកាសចំនួន៤កោះ។ |
| ២០១៩ | -បានសាងសង់បង្គោលកំណត់ព្រំដីចំណីឆ្នេរសមុទ្រកម្ពុជាចំនួន១៥បង្គោល<br>-បានអនុវត្តគម្រោងសាងសង់ស្ថានីយបូមទឹកកខ្វក់ទំនើបចំនួន៤កន្លែង នៅឆ្នេរឯករាជ្យ ឆ្នេរសុខា អូរសម្ភាត និង ឆ្នេរអូរឈើទាល, រៀបចំបណ្តាញលូបេតុងបានប្រវែង៧៦០ម. និងទុយោជ័រស្វិត HDPE បានប្រវែង៥ ៧៨១ម. ស្ពានព្រែកអូរឈើទាលបានប្រវែង២ ៤០០ម. និងអូរសម្ភាតបានប្រវែង១ ២២៤ម. ដាំដើមនាងនួនតាមដងវិថី និង ដាំដើមកោងកាងនៅព្រែកអូរឈើទាល។ |
| ២០២០ | -បានសាងសង់បង្គោលកំណត់ព្រំដីចំណីឆ្នេរសមុទ្រកម្ពុជាចំនួន១៥បង្គោល<br>-បានអនុវត្តគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងចំនួន៣៤ខ្សែ ប្រវែង៨២ ៤៥៣ម. ចែកចេញជាបីប្រភេទ រួម មានមហាវិថីមានចំនួន៣ខ្សែ, វិថីមានចំនួន១៦ខ្សែ, អនុវិថីមានចំនួន១៥ខ្សែ និងស្ពានចំនួន៩ទីតាំង ប្រវែង២៩៦ម. ព្រមទាំងរង្វង់មូលលម្អដោយរូបបដិមា ចំនួន៥ទីតាំង<br>-បានរៀបចំកែលម្អឆ្នេរអូរត្រេះ ឆ្នេរអូរឈើទាលII ឆ្នេរលំហែកាយ ឆ្នេរឯករាជ្យ បឹងព្រែកទប់ និងពយកំពេញ ដោយ បានសម្របសម្រួលរុះរើសំណង់បណ្តោះអាសន្នចំនួន១៥៦ទីតាំង នៅឆ្នេរអូរត្រេះ ចំនួន១២៦ទីតាំង នៅឆ្នេរអូរ ឈើទាលII និង១២ទីតាំងទៀត នៅឆ្នេរលំហែកាយ។ |
| ២០២១ | -បានអនុវត្តគម្រោងសាងសង់បង្គន់សាធារណៈតាមបណ្តោយឆ្នេរសមុទ្រក្រុងព្រះសីហនុ សម្រាប់សាធារណជននិង ទេសចរចំនួន៩ទីតាំង |

| | |
|---|---|
| | -បានអនុវត្តគម្រោងអភិវឌ្ឍស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទំនើបទី១(WWTP1)មានសមត្ថភាពចម្រោះទឹកកខ្វក់ចំណុះ៥ ២០០ម.គូបក្នុងមួយថ្ងៃ ស្ថិតនៅឆ្នេរឯករាជ្យ និងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទំនើបទី២(WWTP2) មានសមត្ថភាពចម្រោះទឹកកខ្វក់ចំណុះ៧ ២០០ម. គូបក្នុងមួយថ្ងៃ ស្ថិតនៅអូរសម្អាតនៃឆ្នេរសុខា ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើបMABR<br>-បានអនុវត្តគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវក្រុងថ្មីចំនួន៣ខ្សែបន្ថែមប្រវែង១ ៦១៣ម.<br>-បាននិងកំពុងអនុវត្តគម្រោងអភិវឌ្ឍស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ទំនើបទី៣(WWTP3) មានសមត្ថភាពចម្រោះទឹកកខ្វក់ចំណុះ២០ ០០០ម.គូបក្នុងមួយថ្ងៃ ស្ថិតនៅព្រែកអូរឈើទាល ដោយប្រើប្រាស់បច្ចេកវិទ្យាទំនើបMABR<br>-បាននិងកំពុងជំរុញសាងសង់បង្គោលកំណត់ព្រំដីចំណីឆ្នេរសមុទ្រកម្ពុជាចំនួន១០បង្គោល។ |
| ៩ខែ ២០២២ | -បាន និងកំពុងអនុវត្តគម្រោងកែលម្អឆ្នេរកក់ទៅជាឆ្នេរខ្សាច់កម្សាន្តសាធារណៈកម្រិតខ្ពស់ប្រវែង២ ៧០០ម. ស្ថិតនៅភូមិថ្មី សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប។ |

## ១.២.៣- ការណែនាំនិងការផ្សព្វផ្សាយ

| ឆ្នាំ | បរិយាយការងារ |
|---|---|
| ២០១៨ | -បានរៀបចំប្រឡងប្រណាំងឆ្នេរខ្សាច់កម្សាន្តស្អាតលើកទី១<br>-បានរៀបចំយុទ្ធនាការសម្អាតទីក្រុងនិងសម្អាតឆ្នេរសមុទ្រកម្ពុជាចំនួន៤លើក<br>-បានចែកផែនទីមគ្គុទេសចរណ៍ (Guide Map) សម្រាប់ទេសចរណ៍ខេត្តកែបចំនួន១ ៧៤០ច្បាប់<br>-បានផ្សព្វផ្សាយក្រមប្រតិបត្តិឆ្នេរសមុទ្រកម្ពុជា នៅខេត្តទាំង៤ ជាប់តំបន់ឆ្នេរសមុទ្រកម្ពុជា។ |
| ២០១៩ | -បានធ្វើលិខិតណែនាំម្ចាស់អគារខ្ពស់ ស្នើរៀបចំបំពាក់ប្រព័ន្ធនិងម៉ាស៊ីនប្រព្រឹត្តកម្មទឹកកខ្វក់ អាងបង្គន់អនាម័យ និងបណ្តាញលូទឹកកខ្វក់និងលូទឹកភ្លៀងនៅក្រុងព្រះសីហនុ ចំនួន១៤០ទីតាំង<br>-បានរៀបចំប្រឡងប្រណាំងឆ្នេរខ្សាច់កម្សាន្តស្អាតលើកទី២<br>-បានរៀបចំយុទ្ធនាការសម្អាតទីក្រុងនិងសម្អាតឆ្នេរសមុទ្រកម្ពុជាចំនួន៤លើក<br>-បានចែកខិតបណ្ណផ្សព្វផ្សាយស្តីពីការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាចំនួន៥ ០០០ច្បាប់<br>-បានចងក្រងនិងបោះពុម្ពសៀវភៅកម្រងឯកសារគតិយុត្តពាក់ព័ន្ធការងារគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាចំនួន៥០ក្បាល<br>-បានរៀបចំស្តង់ផ្សព្វផ្សាយសមិទ្ធផលការងារគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ក្នុងឱកាសបុណ្យសមុទ្រនៅខេត្តកំពត<br>-បានផ្សព្វផ្សាយក្រមប្រតិបត្តិឆ្នេរសមុទ្រកម្ពុជា នៅខេត្តទាំង៤ ជាប់តំបន់ឆ្នេរសមុទ្រកម្ពុជា។ |
| ២០២០ | -បានរៀបចំពិគ្រោះយោបល់លើការធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងឆ្នេរខ្សាច់កម្សាន្តនិងក្រមប្រតិបត្តិឆ្នេរ នៅខេត្តកែបចំនួន១លើក<br>-បានលើកប៉ាណូផ្សព្វផ្សាយអំពីការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាចំនួន៦ផ្ទាំង។ |
| ២០២១ | -បានរៀបចំពិគ្រោះយោបល់លើការធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងឆ្នេរខ្សាច់កម្សាន្តនិងក្រមប្រតិបត្តិឆ្នេរឱ្យស្របតាមស្ថានភាពបច្ចុប្បន្នក្នុងការចូលរួមទប់ស្កាត់នៃការរីករាលដាលនៃជំងឺកូវីដ-១៩ នៅខេត្តកោះកុងចំនួន១លើក។ |
| ៩ខែ ២០២២ | -បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយបទដ្ឋានគតិយុត្តនានាក្នុងការគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា នៅខេត្តកែបចំនួន១លើក<br>-បាននិងកំពុងរៀបចំប្រឡងប្រណាំងឆ្នេរខ្សាច់កម្សាន្តស្អាតប្រចាំឆ្នាំលើកទី៣។ |

### ១.៣- ការអភិវឌ្ឍវិស័យលំនៅឋាន

#### ១.៣.១- លំនៅឋានតម្លៃសមរម្យ

គិតសរុបពីចាប់ផ្តើមអនុវត្តឆ្នាំ២០១៧ ដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ មានគម្រោងអភិវឌ្ឍលំនៅឋានតម្លៃសមរម្យមានចំនួន៨គម្រោង សាងសង់លំនៅឋានចំនួន៨ ៣៣១ខ្នង និង២ ៩៦០ចំណែកឯកជន។

#### ១.៣.២- វឌ្ឍនភាពនៃការរៀបចំអាកាសយានដ្ឋានអន្តរជាតិតេជោក្រុងតាខ្មៅ

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ៩ខែ ឆ្នាំ២០២២ | ភាគរយ |
|---|---|---|---|---|---|---|
| ១.ការប្រមូលដីកម្មសិទ្ធិដើម្បីសាងសង់អាកាសយានដ្ឋាន | - | - | ១ ១៣៧,៥៩ហ.ត. | ១ ៤១៨,៤៤ហ.ត. | ១៦០៤,៣៦ហ.ត. | ៦១,៧១% |
| ២.ការដោះស្រាយជូនគ្រួសារប្រជាពលរដ្ឋដែលបានកាន់កាប់ និងស្រ័យផលលើដីរដ្ឋ | - | - | ៤០,៣៩ហ.ត. | ៦៤,៩៦ ហ.ត. | ៦៦,៤៦ហ.ត. | ៩៥,៣៦% |
| ៣.ការដោះស្រាយជូនគ្រួសារប្រជាពលរដ្ឋដែលរស់នៅក្នុងសំណង់បណ្តោះអាសន្ន | - | ផ្តល់ថវិកាគោលនយោបាយចំនួន ១១គ្រួសារ | ចុះពិនិត្យការរៀបចំដីឡូត៍និងលំនៅឋានចំនួន១៧១គ្រួសារ | ប្រគល់ដីឡូត៍ ៥ម x២០ម និងផ្ទះ១ខ្នងក្នុង១គ្រួសារចំនួន១៧១គ្រួសារ | ប្រគល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចំនួន១៧១គ្រួសារ | ១០០% |
| ៤.ការដោះស្រាយជូនគ្រួសាររងផលប៉ះពាល់ពីការសាងសង់ផ្លូវចូលទីតាំងដីឡូត៍សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋរស់នៅក្នុងសំណង់បណ្តោះអាសន្ន | - | ផ្តល់ថវិកានិងដីឡូត៍៥មX២០មជូនចំនួន៣៧គ្រួសារ | - | - | - | ១០០% |
| ៥.ការដោះស្រាយជូនគ្រួសារប្រជាពលរដ្ឋដែលជាម្ចាស់លំនៅឋានអចិន្ត្រៃយ៍ | - | ចុះស្រង់ស្ថិតិចំនួន៦៦ខ្នងផ្ទះ | បានចុះដំរឿន និងស្ទាបស្ទង់មតិគ្រួសារប្រជា-ពលរដ្ឋ | ចុះពិនិត្យវាយតម្លៃលំនៅឋានសំណង់ផ្សេងៗ និងផលដំណាំ | សុំការឯកភាពលើលទ្ធផលនៃការពិនិត្យ វាយតម្លៃ | - |
| ៦.ការដោះស្រាយវិវាទដីធ្លីក្នុងទីតាំងគម្រោង | - | - | - | - | សម្របសម្រួលបញ្ចប់វិវាទដីធ្លីចំនួន១៤គ្រួសារលើដីទំហំ៨១,៧៦ហ.ត. | - |

គិតពីចាប់ផ្តើមមកដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ គម្រោងសាងសង់អាកាសយានដ្ឋានអន្តរជាតិតេជោក្រុងតាខ្មៅ ទទួលកាន់កាប់ដីបានទំហំ១ ៦០៤,៣៦ហ.ត. ស្មើនឹង៦១,៧១% នៃផ្ទៃដីអនុវត្តគម្រោងសរុបទំហំ២ ៦០០ហ.ត.។ ដូចនេះផ្ទៃដីដែលត្រូវសម្របសម្រួលប្រមូលបន្ថែមមានទំហំ៩៩៥,៦៤ហ.ត. ស្មើ៣៨,២៩% ក្នុងនោះដីប្រជាពលរដ្ឋទំហំ៤៩៥,៤៧ហ.ត. ដីក្រុមហ៊ុនចំនួន៨ ទំហំ៤៧៤,៥៧ហ.ត. និងដីចំណីព្រៃកទំហំ២៥,៥៩ហ.ត.។

**១.៣.៣- ការដោះស្រាយបញ្ហាសំណង់និងដីធ្លីក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ផ្សេងទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិអប្សរា**

**លទ្ធផលសម្រេចបានចាប់ពីថ្ងៃទី១៨ ខែសីហា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ ដូចខាងក្រោម៖**

- បានបង្ហោះដ្រូនថតរូបពីលើអាកាសគ្របដណ្តប់លើផ្ទៃដីតំបន់១ និងតំបន់២ របស់អាជ្ញាធរជាតិអប្សរា ទំហំ៤០ ១១៨ហ.ត. និងផលិតជាផែនទីរូបថតអរតូហ្វូតូទំហំ៤០ ១១៨ហ.ត. សម្រេច១០០%វាស់វែងនិងស្រង់ព័ត៌មានអ្នកកាន់កាប់ដីសរុបចំនួន៩៧ ៩១៣ក្បាលដី បញ្ចូលទិន្នន័យក្បាលដី និងគូរក្បាលដីចូលក្នុងកុំព្យូទ័របានចំនួន៩៧ ៩១៣ក្បាលដី ទំហំ២៩ ១៨៥,០៤ហ.ត. ពាក់ព័ន្ធនឹងប្រជាពលរដ្ឋចំនួន៦៧ ៦៨២គ្រួសារ ក្នុងនោះ (១) ក្បាលដីលំនៅឋានចំនួន៥២ ០២១ក្បាលដី ទំហំ៨ ៤៥៣,៥២ហ.ត. (២) ក្បាលដីកសិកម្មចំនួន៤១ ១២៥ក្បាលដី ទំហំ១៨ ៨៣៤,៦៥ហ.ត. និង(៣) ក្បាលដីផ្សេងៗ(ដីសាលារៀន ដីវត្ត និងដីសាធារណៈផ្សេងៗ) មានចំនួន៤ ៧៦៧ក្បាលដី ទំហំ១ ៨៩៦,៨៧ហ.ត.
- ប្រជាពលរដ្ឋបានស្ម័គ្រចិត្តរុះរើសំណង់ចំនួន២០៩សំណង់ ស្ថិតក្នុងភូមិសាស្ត្រទក្សិណខាងត្បូង និងភូមិត្រពាំងសេះ សង្កាត់គោកចក និងភូមិស្រះស្រង់ខាងត្បូង សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប
- គ្រួសារប្រជាពលរដ្ឋរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរដែលគ្រប់លក្ខខណ្ឌ និងបានស្ម័គ្រចិត្តចាប់ឆ្នោតទទួលយកដីឡូត៍ទំហំ២០ម.x៣០ម. នៅតំបន់អភិវឌ្ឍន៍រុនតាឯកសរុបចំនួន៣ ៩៧០គ្រួសារ
- បានដាំដើមឈើសរុបចំនួន១២ ៣៧៩ដើម នៅលើទីតាំងដែលបានរុះរើសំណង់រួចរាល់។

**១.៣.៤- ការផ្តល់វិញ្ញាបនបត្រប្រកបអាជីវកម្មក្នុងវិស័យសំណង់**

| ឆ្នាំ | ក្រុមហ៊ុន | ចំនួនក្រុមហ៊ុន | ប្រភេទ៣ | ប្រភេទ២ | ប្រភេទ១ | សរុបរួម |
|---|---|---|---|---|---|---|
| ២០១៨ | ក្រុមហ៊ុនសាងសង់ | ៣២១ | ២១២ | ៤៧ | ៦២ | ៣៣៤ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ១៣ | ០៩ | ០៣ | ១ | |
| ២០១៩ | ក្រុមហ៊ុនសាងសង់ | ៥២៤ | ៣៤៩ | ៦៩ | ១០៦ | ៥៥១ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ២៧ | ២០ | ១ | ៦ | |
| ២០២០ | ក្រុមហ៊ុនសាងសង់ | ៤៤០ | ៣៣៧ | ៣៨ | ៦៥ | ៤៧២ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ៣២ | ២៤ | - | ៨ | |
| ២០២១ | ក្រុមហ៊ុនសាងសង់ | ៣២៨ | ២២៦ | ៤៤ | ៥៨ | ៣៤៥ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ១៧ | ១៥ | ១ | ១ | |
| (៩ខែ)២០២២ | ក្រុមហ៊ុនសាងសង់ | ២៥៧ | ១៦៤ | ៣៧ | ៥៦ | ២៧៨ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ២១ | ១៨ | ១ | ២ | |
| **សរុប** | | **១៩៨០** | **១៣៧៤** | **២៤១** | **៣៦៣** | |

គិតពីចាប់ផ្តើមអនុវត្តដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានផ្តល់វិញ្ញាបនបត្រប្រកបអាជីវកម្មក្នុងវិស័យសំណង់ដល់ក្រុមហ៊ុនប្រកបអាជីវកម្មសិក្សាគម្រោងប្លង់និងសាងសង់បានចំនួន៣២៨៥ក្រុមហ៊ុន ប៉ុន្តែនៅមានសុពលភាពចំនួន១ ២៥០ក្រុមហ៊ុន។

គិតពីចាប់ផ្តើមអនុវត្តឆ្នាំ២០០៩ ដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានផ្តល់វិញ្ញាបនបត្រប្រកបវិជ្ជាជីវៈសិក្សាគម្រោងប្លង់ដល់អ្នកវិជ្ជាជីវៈចំនួន៥៨០រូប ក្នុងនោះមានស្ថាបត្យករចំនួន២៨២រូប(ស្ថាបត្យករសញ្ជាតិបរទេស៥រូប) និងវិស្វករចំនួន២៩៨រូប (វិស្វករសញ្ជាតិបរទេស៦រូប) ប៉ុន្តែនៅមានសុពលភាពចំនួន៤២២រូប។

**១.៣.៥- ការផ្តល់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់**

| ឆ្នាំ | ប្រភេទអាជ្ញាបណ្ណ | កម្រិត៣ (អ្នកវិជ្ជាជីវៈ) | កម្រិត២ | កម្រិត១ | សរុបរួម |
|---|---|---|---|---|---|
| ២០២១ | ត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅ | - | - | ១ | ១ |
| | ត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្ម | - | - | - | - |
| | ត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់ | - | - | - | - |
| | ត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក | - | - | - | - |
| (៩ខែ) ២០២២ | ត្រួតពិនិត្យនិងបញ្ជាក់សំណង់ទូទៅ | - | - | ២ | ២ |
| | ត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្ម | - | - | - | - |
| | ត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកគ្រឿងផ្គុំសំណង់ | - | - | - | - |
| | ត្រួតពិនិត្យនិងបញ្ជាក់សំណង់ផ្នែកមេកានិក អគ្គិសនី និងទឹក | - | - | - | - |
| សរុបរួម | | | | | ៣ |

គិតពីចាប់ផ្តើមអនុវត្តខែធ្នូ ឆ្នាំ២០២១ ដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២ បានផ្តល់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ចំនួន៣ក្រុមហ៊ុន ក្នុងនោះក្រុមហ៊ុនបរទេសចំនួន១ក្រុមហ៊ុន(មានសញ្ជាតិជប៉ុន)។

**១.៣.៦- ការផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ បិទការដ្ឋានសំណង់ និងជួសជុលក្រោមសមត្ថកិច្ចក្រសួង**

| ឆ្នាំ | លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ | លិខិតបិទការដ្ឋានសំណង់ | លិខិតអនុញ្ញាតជួសជុល |
|---|---|---|---|
| ២០១៨ | ១៤៨ | ៨៣ | ១២ |
| ២០១៩ | ២៦៨ | ១០១ | ២៨ |
| ២០២០ | ១៣៩ | ៨២ | ១៩ |
| ២០២១ | ១៧៩ | ១៤៤ | ៩ |
### សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តស្ទឹងត្រែង សម្រេចបាន៖

**ខេត្តស្ទឹងត្រែង** ជាខេត្តមួយក្នុងចំណោមរាជធានី ខេត្តទាំង២៥ និងស្ថិតនៅភាគឦសាននៃព្រះរាជាណាចក្រកម្ពុជា មានព្រំប្រទល់ខាងកើតជាប់នឹងខេត្តរតនគិរី ខាងលិចជាប់ខេត្តព្រះវិហារនិងខេត្តកំពង់ធំ ខាងជើងជាប់ខេត្តចំនួនពីរបស់ប្រទេសឡាវ គឺខេត្តចំប៉ាសាក់និងខេត្តអត្តពឺ ខាងត្បូងជាប់និងខេត្តក្រចេះនិងខេត្តមណ្ឌលគិរី មានចម្ងាយ៤៥៥គ.ម.ពីរាជធានីភ្នំពេញ។ ខេត្តស្ទឹងត្រែងចែកចេញជា ៥ស្រុក ១ក្រុង មាន៣០ឃុំ និង៤សង្កាត់ និងមានភូមិចំនួន១២៨ មានផ្ទៃដីសរុប១២.០១៦គីឡូម៉ែត្រក្រឡា មានប្រជាជនរស់នៅសរុបចំនួន១៦៦ ០២០ នាក់ ស្រី៨៣ ១៦១នាក់ និងមានដង់ស៊ីតេប្រជាជន១៤នាក់ក្នុងមួយគ.ម.។

### ១- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុងនិងទីប្រជុំជន

| ល.រ. | បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ផ្លូវកៅស៊ូ | គ.ម. | ៦ ៥៩៥ | ៣ | ៥,៥ | ១០,១២៨ | ៦,៥ | ៣១,៧២៣ |
| ២ | ផ្លូវបេតុង | គ.ម. | ០,១៩ | ២,០៩៥ | ០,២៨២ | ១,១៤៤ | ២,៥៣៧ | ៦,២៤៨ |
| ៣ | ផ្លូវក្រាលក្រួស | គ.ម. | ១១,៤៥ | ២៩,៣៨៣ | ៣,៦៩៨ | ៦៤,៤៨ | ១០,២៤០ | ១១៩,២៥១ |
| ៤ | សាងសង់ លូមូល បណ្តោយផ្លូវ | ម. | ១ ៨០៨ | ៨៨២ | ១ ៨២១ | ១ ៨៣៩ | ២ ៨៧១ | ៩ ២២១ |
| ៥ | ស្ពានបេតុង | កន្លែង | ១ | ២ | ០ | ១ | ០ | ៤ |
| ៦ | សាងសង់លូប្រអប់មុខមួយ | ម. | ០ | ០ | ៩ | ០ | ៣ | ១២ |
| ៧ | ជួសជុលរ៉ឺហ្គា | កន្លែង | ២២ | ៣៤ | ៣៦ | ៥៣ | ៣៧ | ១៨២ |
| ៨ | សាងសង់លូប្រអប់មុខពីរ | ម. | ០ | ១២ | ០ | ៦ | ២៤ | ៤២ |
| ៩ | សាងសង់លូកាត់ផ្លូវ | ម. | ២៤២ | ២៩៣ | ៣៥ | ៨៧ | ១០៨ | ៧៦៥ |
| ១០ | ស្ពានដែកបាឡេ | ម. | ០ | ២៨ | ៣១២ | ៣៦ | ៣៩ | ៤១៥ |
| ១១ | អណ្តូងស្នប់ | កន្លែង | ០ | ៥ | ៤ | ០ | ០ | ៩ |

### ២- ការពង្រឹងសោភ័ណភាព សេវាទីក្រុងទីប្រជុំជន

| ល.រ. | បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ការគ្រប់គ្រង ការប្រមូលសំរាម | កន្លែង | ៨ | ២ | ០ | ០ | ០ | ១០ |
| ២ | ទីលានចាក់សំរាម | កន្លែង | ១ | ០ | ០ | ០ | ០ | ១ |
| ៣ | ទីផ្លាចំណត | កន្លែង | ១ | ០ | ០ | ០ | ០ | ១ |
| ៤ | សួនច្បារសាធារណៈ | កន្លែង | ៣ | ០ | ០ | ០ | ០ | ៣ |
| ៥ | កសាង និងការពារច្រាំងទន្លេ និងទំនប់ | ម. | ៣១ | ៩៧ | ០ | ០ | ០ | ១២៨ |
| ៦ | ការរៀបចំសណ្តាប់ធ្នាប់ | កន្លែង | ៣ | ០ | ០ | ០ | ០ | ៣ |
| ៧ | ភ្លើងបំភ្លឺនៅក្នុងក្រុង និងទីប្រជុំជន | បង្គោល | ០ | ៦១ | ០ | ០ | ០ | ៦១ |
| ៨ | ផ្សារទំនើបនិងផ្សារលក់កសិផលផ្សេងៗ | ផ្សារ | ២ | ២ | ០ | ០ | ០ | ៤ |
| ៩ | សេវាដឹកជញ្ជូនសាធារណៈ | កន្លែង | ៨ | ២ | ០ | ១ | ០ | ១១ |

## ៣- ការងារទេសចរណ៍

| ល.រ | បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ១ | រមណីយដ្ឋាន | ១១ | ០ | ០ | ១ | ០ | ១២ |
| ២ | សណ្ឋាគារ | ៧ | ០ | ០ | ០ | ០ | ៧ |
| | ចំនួនបន្ទប់ | ២១៤ | ៤៤ | ០ | ០ | ០ | ២៥៨ |
| ៣ | ផ្ទះសំណាក់ | ៣៩ | ២ | ០ | ០ | ០ | ៤១ |
| | ចំនួនបន្ទប់ | ៥១៧ | ៩៩ | ០ | ០ | ០ | ៦១៦ |
| ៤ | ភោជនីយដ្ឋាន | ៣៨ | ១៧ | ០ | ០ | ០ | ៥៥ |
| | ចំនួនកៅអី | ២ ២៧៦ | ៤៧៥ | ០ | ០ | ០ | ២ ៧៥១ |
| ៥ | ខារ៉ាអូខេ | ១០ | ១ | ២ | ០ | ០ | ១៣ |
| | ចំនួនបន្ទប់ | ៧៤ | ០ | ៨ | ០ | ០ | ៨២ |
| ៦ | ក្លឹបកម្សាន្ត | ២ | ០ | ០ | ០ | ០ | ២ |
| | ចំនួនកៅអី | ១៧៣ | ០ | ០ | ០ | ០ | ១៧៣ |
| ៧ | ម៉ាស្សា | ៦ | ៦ | ០ | ០ | ០ | ១២ |
| | ចំនួនបន្ទប់ | ២២ | ២៦ | ០ | ០ | ០ | ៤៨ |
| ៨ | ហាងកាហ្វេ | ៣ | ៤ | ០ | ០ | ២ | ៩ |
| | ចំនួនកៅអី | ៣០ | ១៥ | ០ | ០ | ៤០ | ៧៥ |
| ៩ | បន្ទប់ជួល | ៥ | ២ | ៩ | ០ | ៦ | ២២ |
| | ចំនួនបន្ទប់ | ៣៦ | ២៦ | ៥០ | ០ | ២៥ | ១៣៧ |
| ១០ | បៀរហ្គាដិន | ០ | ០ | ៥ | ០ | ០ | ៥ |
| | ចំនួនកៅអី | ០ | ០ | ២០៧ | ០ | ០ | ២០៧ |
| ១១ | មគ្គុទ្ទេសក៍ | ០ | ២ | ០ | ៣ | ០ | ៥ |
| ១២ | ទីភ្នាក់ងារទេសចរណ៍ | ១ | ០ | ០ | ០ | ០ | ១ |

## ៤- ការសាងសង់អគារចាប់ពី៥ជាន់ឡើង( សណ្ឋាគារ ខុនដូរ ផ្ទះសំណាក់...)

| ល.រ. | បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ១ | សណ្ឋាគារ | ២ | ០ | ០ | ០ | ០ | ២ |
| ២ | សំណង់អគារផ្សេងៗ | ០ | ០ | ០ | ០ | ១ | ១ |

## ៥- ការងារថាមពលអគ្គិសនី

| **ទិន្នផលប្រចាំឆ្នាំ** | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | **គិតជា** |
|---|---|---|---|---|---|---|
| ថាមពលផលិតនិងផ្គត់ផ្គង់ពីបណ្តាញជាតិ | ៨៥ ៤២៥ ២៣២ | ១៥៤ ៨៥២ ៤២០ | ៥១២១៤ ៨៤៨ | ៥២ ២៤៧ ៩៦២ | ៥៣ ៤២៨ ២៨៥ | KWh |
| អានុភាពអតិបរមា | ២០,៣៣៨ | ៤០,៩៥១ | ៨,៧៩៥ | ១០,៥៥ | ៨,៧៤ | MW |

| | | | | | | |
|---|---|---|---|---|---|---|
| ខ្សែបណ្ដាញតង់ស្យុងមធ្យម | ៦៦៧,៨៧ | ៧៧០ | ៨២៥ | ៨៦៦,៣៩ | ៩១៥,០៤ | Km |
| ខ្សែបណ្ដាញតង់ស្យុងទាប | ១៨១,០៤ | ១៩៧,០៤ | ២៥០,៦៩ | ៥២៧,៨៨ | ៥៤២,៦៦ | Km |
| ចំនួនត្រង់ស្វូ | ១៤៨ | ១៦៣ | ១៨០ | ២៣៥ | ២៩៧ | គ្រឿង |
| **អតិថិជនសរុប** | **៩ ៧៤៥** | **១០ ៧៦៥** | **១២ ៥៦៤** | **១៤ ៣៦០** | **១៥ ៤៣៦** | អតិថិជន |

រមណីយដ្ឋានទេសចរណ៍ក្នុងខេត្តស្ទឹងត្រែង មានចំនួន១២កន្លែង ក្នុងនោះរួមមានរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រចំនួន៣កន្លែង រមណីយដ្ឋានធម្មជាតិចំនួន៦កន្លែងនិងកែច្នៃចំនួន៣កន្លែង។

**៦- ការងារទឹកស្អាត**

| ល.រ | បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| **ក- ទឹកស្អាតរដ្ឋ** | | | | | | | | |
| ១ | បរិមាណផលិតទឹកស្អាត | ម.៣ | ៩២០ ៣៧០ | ៩២៧ ២៤៤ | ១០៣៦ ៨៩៩ | ១៣០៤១៣១ | ១៧១៣៤៤៩ | ៥៩០២០៩៣ |
| ២ | ប្រវែងបណ្ដាញទឹកស្អាត | ម. | ៣១ ៥៩៩ | ៣១៥៩៩ | ៤០ ៩២៧ | ៤០ ៩២៧ | ៣៩០ ១៦៥ | ៥៣៥២១៧ |
| ៣ | ភាគរយគ្រួសារប្រើទឹកស្អាត | % | ៣៧ | ៣៨ | ៣៧ | ៤០ | ៣៦ | ១៨៨ |
| **ខ- ទឹកស្អាតឯកជន** | | | | | | | | |
| ១ | បរិមាណផលិតទឹកស្អាត | ម.៣ | ២៤ ៩៦០ | ២៧ ៦៦០ | ៣០ ៩៥២ | ២៨ ៨៤៦ | ១៨ ៩៥០ | ១៣១ ៣៦៨ |
| ២ | ប្រវែងបណ្ដាញទឹកស្អាត | ម. | ១ ៩០០ | ១ ៩៥៥ | ២ ០០០ | ២ ៣០០ | ២ ៣០០ | ១០ ៤៥៥ |
| ៣ | ភាគរយគ្រួសារប្រើទឹកស្អាត | % | ៤០ | ៤២ | ៤៥ | ៤៥ | ៣៩ | ២១១ |

## ២.២០- ខេត្តក្រចេះ

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តក្រចេះ សម្រេចបានដូចខាងក្រោម៖**

ខេត្តក្រចេះ ស្ថិតនៅភាគប៉ែកឦសាននៃប្រទេសកម្ពុជា មានស្ថានភាពដីជាពីរប្រភេទ គឺតំបន់ខ្ពង់រាបនិងតំបន់វាលទំនាប មានចម្ងាយ ៣៤០គ.ម ពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ៧ ឆ្លងកាត់ស្រុកស្នួល ចម្ងាយ២៥០គ.ម ពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ៧៣ ឆ្លងកាត់តាមស្រុកតំបែរ និងស្រុកឆ្លូង និងចម្ងាយ ២២០គ.ម.តាមផ្លូវទឹកទន្លេមេគង្គ។ ទន្លេមេគង្គហូរកាត់ក្រុង១ និងស្រុក៤ ក្នុងចំណោមក្រុង និងស្រុកទាំង៦របស់ខេត្ត ដែលមានប្រវែង ១៤០គ.ម មានព្រែកធំៗចំនួន៥ស្ថិតនៅខាងកើតទន្លេមេគង្គ។ ខេត្តក្រចេះមានផ្ទៃដីធម្មជាតិសរុប១១០.៩៤ គម២ ចែកជាក្រុង១ ស្រុក៥ មាន៥សង្កាត់ ៤៣ឃុំ និង២៩៥ភូមិ ។ ចំនួនប្រជាពលរដ្ឋសរុប៤៣៨ ៦៤១នាក់(ស្ត្រី

៣៧២ ៨២៥នាក់) ស្មើនឹង១០០ ៦៧៧គ្រួសារ ដង់ស៊ីតេប្រជាជន៣៧នាក់ក្នុងមួយគម² ដែលប្រមាណ ៨១% ជាកសិករ។ ខេត្តមានជនជាតិដើមភាគតិចចំនួន៧រស់នៅ ក្នុងនោះជនជាតិព្នង កួយ ស្ទៀង មិល ក្រោល ថ្មូន និងជនជាតិខោញស្ថិតនៅក្នុងស្រុកសំបូរ ស្រុកចិត្របុរីនិងស្រុកស្នួល និងចែកជាពីរតំបន់សំខាន់ៗប៉ែកខាងជើងនិងប៉ែកខាងកើតជាតំបន់ខ្ពង់រាប មានព្រៃឈើ មានស្មៅច្រើនប្រភេទ មានប្រភេទដីក្រហម អំណោយផលដល់ការចិញ្ចឹមសត្វគោ ក្របី និងការដាំដំណាំកសិឧស្សាហកម្ម ដូចជាកៅស៊ូ ម្រេច ស្វាយចន្ទី...។ល។ ប៉ែកខាងត្បូងនិងខាងលិចជាតំបន់ទំនាប និងតំបន់ដីសើមតាមដងទន្លេមេគង្គ សំបូរទៅដោយបឹង ព្រែក អូរ ដីល្បាប់មានជីជាតិ អំណោយផលដល់ការចិញ្ចឹមត្រីនិងដាំដំណាំស្បៀង ដូចជាស្រូវ ពោត សណ្តែក ល្ង...។ល។ ពិសេសទៅទៀតតំបន់ដីសើមសម្បូរទៅដោយជម្រកមច្ឆជាតិចម្រុះពង កូន និងបន្តពូជ មានផ្សោតទន្លេមេគង្គដែលជាសត្វកម្របាននឹងកំពុងទាក់ទាញភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិមកទស្សនាកម្សាន្តមានការកើនឡើងជារៀងរាល់ឆ្នាំ។

ខេត្តក្រចេះ មានព្រំប្រទល់ជាប់ខេត្តប៊ិញភឿកនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលមានព្រំដែនជាប់លាតសន្ធឹងប្រវែង១០៣,៧ គ.ម និងមានច្រកព្រំដែនពីរ គឺច្រកទ្វារតំបន់ព្រំដែន១ (ច្រកទ្វារតំបន់ព្រំដែនជ័យឃ្លាំង) និងច្រកទ្វារព្រំដែនអន្តរជាតិ១(ច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងស្រែ)។

### ១- ការងារសាធារណការនិងដឹកជញ្ជូន

គិតត្រឹមឆ្នាំ២០២២នេះ មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តក្រចេះ គ្រប់គ្រងផ្លូវជាតិ និងផ្លូវខេត្ត ចំនួន ៧៤ខ្សែ ប្រវែងសរុប១ ១៩៦គ.ម ក្នុងនោះមានស្ពានចំនួន១១៤កន្លែង ស្មើនឹងប្រវែង៤,៣៣៩គ.ម និងលូគ្រប់ប្រភេទសរុបប្រវែង២០,៦០៣គ.ម។ ដោយឡែក ក្នុងរយៈពេល៥ឆ្នាំ(ឆ្នាំ២០១៨ ដល់ឆ្នាំ២០២២) នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦នៃរដ្ឋសភា មន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តក្រចេះសម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

| ល.រ | ផ្លូវជាតិ ផ្លូវខេត្ត និងទីប្រជុំជន | ប្រភេទកម្រាល | ទំហំការងារ (ម.) | | ទីតាំងភូមិសាស្ត្រ | កាលបរិច្ឆេទ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | ប្រវែង | ទទឹង | | | |
| ក- ការងារស្តាបនានិងលើកកម្រិតផ្លូវថ្នល់ | | | | | | | |
| ១ | ផ្លូវខេត្តលេខ២៧៩ | គ្រួសក្រហម | ៣ ៤៥០ | ៩,៧ | ឃុំតាម៉ៅ ស្រុកព្រែកប្រសព្វ | ២០១៨ | ថ្នាក់ខេត្ត |
| ២ | ផ្លូវក្នុងវិមាន២ធ្នូ | បេតុង | ២៣៨ | ៧,៥ | ឃុំ២ធ្នូ ស្រុកស្នួល | ២០១៨ | |
| ៣ | ផ្លូវខេត្តលេខ៣៧៧ | គ្រួសក្រហម | ២ ៣៧០ | ១០,៧ | ស្រុកចិត្របុរី និងស្រុកសំបូរ | ២០១៩ | |
| ៤ | ផ្លូវទទឹងលេខ៨-១៥ | បេតុង | ២០៨ | ៨ | សង្កាត់ក្រចេះ ក្រុងក្រចេះ | ២០១៩ | ថ្នាក់ខេត្ត |
| ៥ | ផ្លូវក្នុងទីរួមស្រុកស្នួល | កៅស៊ូ២ជាន់ | ២១០ | ៦ | ឃុំស្នួល ស្រុកស្នួល | ២០១៩ | ថ្នាក់ខេត្ត |
| ៦ | ផ្លូវជាតិលេខ៧៣ | កៅស៊ូ២ជាន់ | ២ ៨០០ | ១០ | ឃុំបុសលាវ ស្រុកចិត្របុរី | ២០២០ | |
| ៧ | ផ្លូវជាតិលេខ៧៦ | កៅស៊ូ២ជាន់ | ៣ ០០០ | ១០ | ឃុំគ្រញូងសែនជ័យ ស្រុកស្នួល | ២០២០ | |
| ៨ | ផ្លូវខេត្តលេខ២៧៩ | កៅស៊ូ២ជាន់ | ៣ ៨០០ | ៧ | ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ | ២០២០ | |
| ៩ | ផ្លូវខេត្តលេខ៣៧១ | កៅស៊ូ២ជាន់ | ៣ ៥០០ | ៧ | ឃុំហាន់ជ័យ ស្រុកឆ្លូង | ២០២០ | |
| ១០ | ផ្លូវសងខាងសាលាខេត្ត | បេតុង | ៣១៧ | ៦ | សង្កាត់ក្រចេះ ក្រុងក្រចេះ | ២០២០ | ថ្នាក់ខេត្ត |
| ១៣ | ផ្លូវជាតិលេខ៧៣ | កៅស៊ូ២ជាន់ | ១ ៨៥០ | ១០ | ឃុំបុសលាវ ស្រុកចិត្របុរី | ២០២១ | |
| ១៤ | ផ្លូវខេត្តលេខ៣៧១ | កៅស៊ូ២ជាន់ | ១ ៧០០ | ៧ | ឃុំពង្រ ស្រុកឆ្លូង | ២០២១ | |
| ១៥ | ផ្លូវខេត្តលេខ២៧៩ | កៅស៊ូ២ជាន់ | ៣ ១៥០ | ៧ | ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ | ២០២១ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៦ | ផ្លូវខេត្តលេខ២៧៩ | កៅស៊ូ២ជាន់ | ២ ៨០០ | ៧ | ឃុំព្រែកប្រសព្វ ស្រុកព្រែកប្រសព្វ | ២០២២ | |
| ១៧ | ផ្លូវខេត្តលេខ៣៧១ | កៅស៊ូ២ជាន់ | ២ ៦០០ | ៧ | ឃុំពង្រ ស្រុកឆ្លូង | ២០២២ | |
| **ខ- ការងារស្ថាបនាសំណង់សិល្បការ្យ (ស្ពាន+លូគ្រប់ប្រភេទ)** | | | | | | | |
| ១ | ស្ពានកូនអក ផ្លូវខេត្តលេខ៣៧៥ | បាឡេ | ៩ | ៤ | ឃុំកញ្ជរ ស្រុកឆ្លូង | ២០១៨ | |
| ២ | ស្ពានកំពង់រាំង ផ្លូវជាតិលេខ៧៣ | បេតុង | ១៥២ | ១២ | ព្រំប្រទល់ត្បូងឃ្មុំ-ក្រចេះ | ២០១៩ | វិស្វកម្ម |
| ៣ | ស្ពានតាលា ផ្លូវខេត្តលេខ៣៧៧ | បេតុង | ២៤ | ៨,២ | ឃុំសណ្ដាន់ ស្រុកសំបូរ | ២០១៩ | |
| ៤ | លូជ្រុង+មូល ផ្លូវជាតិលេខ៧៣ | បេតុង | ១ ២២៤ | | សង្កាត់រកាកណ្ដាល ក្រុងក្រចេះ | ២០១៩ | |
| ៥ | ដាឡ២កន្លែង និងលូទទឹងផ្លូវ១១កន្លែង ផ្លូវខេត្តលេខ៣៧៥-៨ | បេតុង | ៨០ | | ឃុំបុសលាវ ស្រុកចិត្របុរី | ២០១៩ | |
| ៦ | លូមូល ផ្លូវជាតិលេខ៧៦ | បេតុង | ២ ២០០ | | ឃុំគ្រញូងសែនជ័យ ស្រុកស្នួល | ២០២០ | |
| ៧ | លូមូល ផ្លូវខេត្តលេខ៣៧១ | បេតុង | ២ ០០០ | | ឃុំហាន់ជ័យ ស្រុកឆ្លូង | ២០២០ | |
| ៨ | លូជ្រុង ផ្លូវក្នុងក្រុងក្រចេះ | បេតុង | ៣៧០ | | សង្កាត់ក្រចេះ ក្រុងក្រចេះ | ២០២០ | |
| ៩ | ស្ពានព្រែកគ្រៀង ផ្លូវខេត្តលេខ២៧៩ | បេតុង | ៦០ | ១០ | ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ | ២០២០ | វិស្វកម្ម |
| ១០ | លូមូល ផ្លូវខេត្តលេខ៣៧១ | បេតុង | ១ ៧០០ | | ឃុំពង្រ ស្រុកឆ្លូង | ២០២១ | |
| ១១ | លូជ្រុង+មូល ផ្លូវជាតិលេខ៧៣ | បេតុង | ៣ ២៨៦ | | សង្កាត់រកាកណ្ដាល | ២០២១ | |
| ១២ | ស្ពានសណ្ដាយរង ផ្លូវខេត្តលេខ២៧៩ | បេតុង | ៣០ | ១០ | ឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ | ២០២១ | វិស្វកម្ម |
| **គ- ការងារជួសជុលផ្លូវថ្នល់** | | | | | | | |
| ១ | ផ្លូវជាតិលេខ៧៣ | កៅស៊ូ២ជាន់ | ២២០០ | ៧ | ឃុំហាន់ជ័យ ស្រុកឆ្លូង | ២០១៨ | |
| ២ | ផ្លូវជាតិលេខ៧៤ | កៅស៊ូ២ជាន់ | ២២០០ | ៧-១៥ | ឃុំ២ធ្នូ ស្រុកស្នួល | ២០១៩ | |
| ៣ | ផ្លូវជាតិលេខ៧៦ | កៅស៊ូ២ជាន់ | ៩៩៧០ | ១០ | ឃុំគ្រញូងសែនជ័យ ស្រុកស្នួល | ២០២០ | |
| ៤ | ផ្លូវខេត្តលេខ៣៧៧ | កៅស៊ូ២ជាន់ | ៥០០ | ១០ | សង្កាត់ក្រគរ ក្រុងក្រចេះ | ២០២០ | |
| ៥ | ផ្លូវជាតិលេខ៧៦ | កៅស៊ូ២ជាន់ | ២៦០០ | ១០ | ឃុំគ្រញូងសែនជ័យ ស្រុកស្នួល | ២០២១ | |
| ៦ | ផ្លូវជាតិលេខ៧៣ | កៅស៊ូ២ជាន់ | ២៧៧០ | ១០ | ឃុំកញ្ជរ ស្រុកឆ្លូង | ២០២១ | |
| ៧ | ផ្លូវជាតិលេខ៧៣ | កៅស៊ូ២ជាន់ | ៥៤០០ | ១០ | ឃុំកញ្ជរ និងព្រែកសាម៉ាន់ | ២០២២ | |
| ៨ | ផ្លូវជាតិលេខ៧៦ | កៅស៊ូ២ជាន់ | ៣០០០ | ១០ | ឃុំ២ធ្នូ ស្រុកស្នួល | ២០២១ | |

**ជាសរុបរួមៈ (ក+ខ+គ) សមិទ្ធផលការងារវិស័យសាធារណការរយៈពេល៥ឆ្នាំ (ឆ្នាំ២០១៧-២០២១) សម្រេចបានរួមមានៈ**

- ស្ថាបនា និងលើកកម្រិតផ្លូវដោយក្រាលកៅស៊ូ២ជាន់(DBST) ប្រវែង២៥,៤១០គ.ម ផ្លូវបេតុងប្រវែង៧៦៣ម ផ្លូវក្រួសក្រហមប្រវែង៥,៨២០គ.ម

- ស្ថាបនាសំណង់សិល្បការ្យ រួមមានស្ពានបេតុង ចំនួន៤កន្លែង សរុបប្រវែង២៦៦ម, ស្ពានបាឡេចំនួន១កន្លែង ប្រវែង៩ម. និង ជាឡូ៧កន្លែង+លូជ្រុង+មូល សរុបប្រវែង១០,៨៦០គ.ម
- ជួសជុលផ្លូវដោយក្រាលកៅស៊ូ២ជាន់(DBST) ប្រវែង២៨,៦៤០គ.ម ។

**២- គម្រោងអន្តរជាតិ**

១- ផ្លូវជាតិលេខ៧(ខ្លាស្ទុះ-អូរប្រឡង់)លើកកម្រិតគុណភាពផ្លូវពីប្រភេទDBST ទៅជាប្រភេទបេតុងកៅស៊ូ (AC) រួចបំពាក់គ្រឿងសង្ហារឹមគ្រប់គ្រាន់ ប្រវែង៩៣,៥៦៥គ.ម. ជាជំនួយឥតសំណងរបស់ប្រទេសចិន។

២- ផ្លូវជាតិលេខ៧(ស្នួល-ក្រចេះ) លើកកម្រិតគុណភាពផ្លូវពីប្រភេទDBST ទៅជាប្រភេទបេតុងកៅស៊ូ (AC) ប្រវែង៦០,៥៥គ.ម ក្រោមថវិកាកម្ចីធនាគារពិភពលោក(World Bank)។

៣- ស្ពានបេតុងចំនួន៥កន្លែង លើកំណាត់ផ្លូវជាតិលេខ៧៣ ក្នុងភូមិសាស្ត្រខេត្តក្រចេះ ដែលជាជំនួយឥតសំណងរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) រួមមាន៖

| | |
|---|---|
| - ស្ពានសណ្ដាន់ប្រវែង៣៥ម. | សរុបផ្លូវសងខាងក្បាលស្ពានប្រវែង៤៥០ម. |
| - ស្ពានព្រែកឬស្សីប្រវែង ៦២ម. | សរុបផ្លូវសងខាងក្បាលស្ពានប្រវែង៥០៥ម. |
| - ស្ពានព្រែកអន្លង់ឃ្លេប្រវែង ៤៨ម. | សរុបផ្លូវសងខាងក្បាលស្ពានប្រវែង៤៨០ម. |
| - ស្ពានព្រែកឆ្លូងប្រវែង ១៤០ម. | សរុបផ្លូវសងខាងក្បាលស្ពានប្រវែង៥៥៤ម. |
| - ស្ពាន៣មទេរប្រវែង ១៧៥ម. | សរុបផ្លូវសងខាងក្បាលស្ពានប្រវែង៧០០ម. |
| **សរុប៖ ប្រវែង៤៦០ម** | **សរុបផ្លូវសងខាងក្បាលស្ពានប្រវែង២ ៦៨៩ម.។** |

៤- ស្ពានបេតុងអណ្ដែងដូន លើកំណាត់ផ្លូវខេត្តលេខ៣៧៧ ក្នុងក្រុងក្រចេះ មានប្រវែងសរុប៣៦ម. ទទឹង ៨,២ម. ជាអំណោយរបស់ខេត្តប៊ិញយឿង សាធារណរដ្ឋសង្គមនិយមវៀតណាម។

**៣- សូចនាករ គម្រោងផែនការអភិវឌ្ឍន៍**

**ក**- គម្រោងស្ថាបនាផ្លូវជាតិលេខ៦០B ស្ពានឆ្លងទន្លេមេគង្គ និងហេដ្ឋារចនាសម្ព័ន្ធ ក្នុងទីរួមខេត្តក្រចេះ គម្រោងសាងសង់ស្ពានមេគង្គខេត្តក្រចេះ និងផ្លូវតភ្ជាប់ខេត្តក្រចេះ មានទំហំការងារជាសំខាន់ គឺសាងសង់ស្ពានមិត្តភាពកម្ពុជា ចិន ខេត្តក្រចេះ មានប្រវែងសរុប១ ៧៦១ម. ទទឹង១៣,៥០ម. និងផ្លូវភ្ជាប់ក្បាលស្ពានទាំងសងខាងនិងផ្លូវខ្នែងមានប្រវែងសរុប៣១,៦៩៨គ.ម. ដោយក្រាលបេតុងកៅស៊ូ(AC) កម្រាស់៧ស.ម. ក្នុងនោះមានទទឹង ១៩ម. លើតួផ្លូវ៣០ម. ប្រវែង៥,០២៥គ.ម. មានទទឹង១៣ម. លើតួផ្លូវ១ ៩៥០ម. ប្រវែង០,៤២៤គ.ម. ទទឹង១០ម. លើតួផ្លូវ១១ម. ប្រវែង១៥,៤៩គ.ម. ទទឹង៩ម. លើតួផ្លូវ១៣ម. ប្រវែង០,៥៩៧គ.ម. និងមានទទឹងចាប់ពី៩,៥០ម. ទៅ១០ម. លើតួផ្លូវ១២ម. ប្រវែង១០,១៦២គ.ម. និងមានស្ពានប្រវែងមធ្យមចំនួន៤កន្លែង ប្រវែងសរុប៣៨៤ម. (ផ្លូវតភ្ជាប់៣កន្លែង និងផ្លូវខ្នែង១កន្លែង) និងលូគ្រប់ប្រភេទចំនួន៣២កន្លែង។

ខ- គម្រោងស្ថាបនាប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ប្រព័ន្ធលូ និងគម្រោងសាងសង់ទីលានចាក់សំរាម នៅក្នុងខេត្តក្រចេះ ដែលជាគម្រោងអភិវឌ្ឍន៍ក្រុងរបៀង៤ ក្រោមកម្ចីឥណទានសម្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ បច្ចុប្បន្ន គម្រោងសាងសង់ទីលានចាក់សំរាម អនុវត្តសម្រេចបាន២០%។

**គ**- គម្រោងកែលម្អការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ក្រោមហិរញ្ញប្បទានរបស់ធនាគារពិភពលោក (World Bank) ដើម្បីលើកកម្រិត ជួសជុល និងថែទាំកំណាត់ផ្លូវជាតិលេខ៧(ស្វាយជ្រះ-ក្រចេះ) កំណាត់ផ្លូវខេត្តលេខ៣៧៧(ក្រចេះ-សំបូរ) និងកំណាត់ផ្លូវខេត្តលេខ៣៧៧អា(សណ្ដាន់-ស្រែត្រែង)។

**ឃ**- គម្រោងផែនការស្ថាបនា ជួសជុល និងថែទាំប្រចាំផ្លូវថ្នល់ តាមបណ្ដាក្រុងស្រុកទាំង៦ ក្នុងខេត្តក្រចេះ ក្រោមថវិកាគុណប្រយោជន៍ក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋបាលខេត្តក្រចេះ។

**៤- ការងារអភិវឌ្ឍន៍ជនបទ**

| តារាងសង្ខេបរបាយការណ៍ ៥ឆ្នាំ (ឆ្នាំ២០១៨-២០២២) | | | | | |
|---|---|---|---|---|---|
| សមិទ្ធផលប្រចាំឆ្នាំ | | | | | |
| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
| **ក- ការងារផ្លូវជនបទ** | | | | | |
| ការជួសជុលថែទាំផ្លូវលំជនបទជាលក្ខណៈប្រចាំ | ៦៦,១០គ.ម. | ១០៧គ.ម. | ២០គ.ម. | ១០៥គ.ម. | ១០១,៣គ.ម. |
| ការជួសជុលថែទាំផ្លូវលំជនបទជាលក្ខណៈខួប | ៤១,៥០គ.ម. | ១០,៦គ.ម. | ៤៨,៩០គ.ម. | ២៣,៧គ.ម. | ៩,២៥គ.ម. |
| ការងារជួសជុលបន្ទាន់ | ៥,៤០គ.ម. | ៦,០០គ.ម. | ៣គ.ម. | ៤,៧គ.ម. | ៨,៨០គ.ម. |
| ការងារជួសជុល | ៩,៦០គ.ម. | ៦,២០គ.ម. | ៨,២៣គ.ម. | ១០,៥០គ.ម. | ២,៥គ.ម. |
| ការស្រង់ទិន្នន័យនិងធ្វើបច្ចុប្បន្នភាពផ្លូវជនបទ | ២៥៤,៤ គ.ម | ៣៥,៦គ.ម | ៥ខ្សែ | ៥ខ្សែ | 0 |
| សាងសង់ស្ពានឈើ | ២កន្លែង(៨០ម.) | ៣កន្លែង(៥៤ម.) | 00 | 00 | ២កន្លែង(៣០ម.) |
| សាងសង់លូប្រអប់ | 00 | 00 | 00 | ១កន្លែង | ១កន្លែង |
| សាងសង់លូមូល | ២៩កន្លង | ១០កន្លែង | ១៣កន្លែង | ៩កន្លែង | ១កន្លែង |
| ការរាប់ចំនួនចរាចរណ៍យានយន្ត | ១២១,៧០គ.ម. | ៣៦,៧០ | ៦៦គ.ម. | ១៣០គ.ម. | ១០០គ.ម. |
| ការថែទាំផ្លូវទប់ទល់នឹងបម្រែបម្រួលអាកាសធាតុ (ដាំកូនឈើតាមផ្លូវជនបទ) | ៩,៦០គ.ម. | ១០,២០គ.ម. | ១ ០០០ដើម | ១ ០០០ដើម | ១ ០០០ដើម |
| សាងសង់ទីទួលសុវត្ថិភាព | 0 | ១កន្លែង | ១កន្លែង | ១កន្លែង | ១កន្លែង |
| **ខ- ការផ្គត់ផ្គង់ទឹកជនបទ** | | | | | |
| ការងារជួសជុលអណ្តូងគ្រប់ប្រភេទ | ៧១អណ្តូង | ២៥៧កន្លែង | ១៤កន្លែង | ១៥កន្លែង | 0 |
| សាងសង់អណ្តូងស្នប់និងអណ្តូងលូថ្មី | ៧០អណ្តូង | ២០អណ្តូង | ២១កន្លែង | ២៣កន្លែង | ២៤កន្លែង |
| សាងសង់/ស្តារស្រះសហគមន៍ | ១កន្លែង | ១កន្លែង | ២កន្លែង | ៣កន្លែង | ២កន្លែង |
| ការស្រង់ទិន្នន័យនិងបញ្ជីសារពើភណ្ឌអណ្តូង | ៤ស្រុក | ៣ស្រុក | 0 | 0 | 0 |
| សាងសង់ប្រព័ន្ធចែកចាយទឹកខ្នាតតូច | ១កន្លែង | 0 | 0 | ១កន្លែង | ១កន្លែង |
| ការងារសាងសង់អាងត្រងទឹកភ្លៀងចំណុះ៤០០០លីត្រ | 00 | 00 | ១កន្លែង | 0 | 0 |
| **គ- ការងារថែទាំសុខភាពជនបទ** | | | | | |
| បង្គន់អនាម័យជនបទដែលបានសាងសង់ | ២ ០៨៥បង្គន់ | ២ ៨៨០បង្គន់ | ១ ៧៤០បង្គន់ | ៦០០បង្គន់ | ៨៤៤បង្គន់ |
| កម្មវិធីផ្សព្វផ្សាយអំពីអនាម័យតាមសហគមន៍ | ១ ០២០នាក់ | ២ ៤២៦នាក់ | ២ ៤៥០នាក់ | ២ ១០១នាក់ | ២១២២នាក់ |
| សាងសង់បង្គន់អនាម័យ/បដិភាគសម្ភារៈអនាម័យ | ៥៥៥បង្គន់ | ២០០បង្គន់ | ២០០បង្គន់ | ១៣០បង្គន់ | ៥០បង្គន់ |

**៥- វិស័យថាមពល**

គិតត្រឹមឆ្នាំ២០២២នេះ អាជ្ញាធរអគ្គិសនីកម្ពុជា បានចេញអាជ្ញាបណ្ណឱ្យអ្នកចែកចាយអគ្គិសនីចំនួន**៩** អាជ្ញាបណ្ណរួមមានអគ្គិសនីក្រចេះ«EDC» ១អាជ្ញាបណ្ណ និងអគ្គិសនីឯកជនមាន៨អាជ្ញាបណ្ណ ដែលមានដែនអាជ្ញាបណ្ណគ្របដណ្តប់លើភូមិចំនួន២៥០ភូមិ ត្រូវជា៨៤,៧៥% នៃភូមិសរុបចំនួន២៩៥ភូមិ នៅទូទាំងខេត្ត។ ជាលទ្ធផលពង្រីកបណ្តាញចែកចាយជូនប្រជាពលរដ្ឋប្រើប្រាស់បានទាំង៦ក្រុង/ស្រុក រួមមាន៖

- **អគ្គិសនីក្រចេះនិងអគ្គិសនីសាខាស្នួល** ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គិសនីកម្ពុជា ដែលមានដែនអាជ្ញាបណ្ណផ្គត់ផ្គង់នៅក្រុងក្រចេះនិងផ្នែកខ្លះនៃស្រុកស្នួល ស្រុកចិត្របុរី ស្រុកសំបូរ
- **ក្រុមហ៊ុនសេវេនហ៊ីលអេនើជី** មានដែនអាជ្ញាបណ្ណផ្គត់ផ្គង់នៅផ្នែកខ្លះនៃស្រុកឆ្លូងនិងស្រុកចិត្របុរី
- **សេវាករហ៊ាងពៅ** មានដែនអាជ្ញាបណ្ណផ្គត់ផ្គង់នៅផ្នែកខ្លះនៃស្រុកព្រែកប្រសព្វ
- **សហគ្រាសកិន ហម អេឡិចទ្រិកស៊ីធី** មានដែនអាជ្ញាបណ្ណផ្គត់ផ្គង់នៅផ្នែកខ្លះនៃស្រុកព្រែកប្រសព្វ
- **សេវាករពេជ្រ ឧត្តម** មានដែនអាជ្ញាបណ្ណផ្គត់ផ្គង់នៅផ្នែកខ្លះនៃស្រុកសំបូរ
- **សេវាករជា សុខខេង** មានដែនអាជ្ញាបណ្ណផ្គត់ផ្គង់នៅផ្នែកខ្លះនៃស្រុកសំបូ
- **ក្រុមហ៊ុនយានសុភរិទ្ធត្រឌឹង** មានដែនអាជ្ញាបណ្ណផ្គត់ផ្គង់នៅផ្នែកខ្លះនៃស្រុកស្នួលនិងស្រុកចិត្របុរី
- **សេវាករកាង គីមអាង** មានដែនអាជ្ញាបណ្ណផ្គត់ផ្គង់នៅផ្នែកខ្លះនៃស្រុកស្នួល
- **សេវាករសុខ ហេងស៊ាង** មានដែនអាជ្ញាបណ្ណផ្គត់ផ្គង់នៅផ្នែកខ្លះនៃស្រុកព្រែកប្រសព្វនិងស្រុកសំបូរ។

**៦- វិស័យប្រេងឥន្ធនៈ**

មន្ទីរខិតខំជំរុញការអនុវត្តសារាចរលេខ០១៤០រថ.អប្រក.សរច ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងរ៉ែ និងថាមពល ស្តីពីសុវត្ថិភាពសម្រាប់ការរៀបចំស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ និងប្រកាសលេខ០១៤១ រថ.អប្រក.ប្រក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងរ៉ែ និងថាមពល ស្តីពីនីតិវិធីនៃការគ្រប់គ្រងបច្ចេកទេសសុវត្ថិភាពស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ។

បច្ចុប្បន្នក្នុង**៩ខែ ដើមឆ្នាំ២០២២**នេះ មានស្ថានីយរួម(ប្រេង និងឧស្ម័នឥន្ធនៈ) និងស្ថានីយប្រេងឥន្ធនៈសរុបចំនួន**៩២**ស្ថានីយ ក្នុងនោះមាន៖

-ស្ថានីយរួម(ប្រេងនិងឧស្ម័នឥន្ធនៈ) ចំនួន**10**ស្ថានីយ

- ក្រុងក្រចេះ មាន ២ស្ថានីយ
- ស្រុកស្នួល មាន ៦ស្ថានីយ
- ស្រុកចិត្របុរី មាន ១ស្ថានីយ
- ស្រុកឆ្លូង មាន ១ស្ថានីយ។

-ស្ថានីយប្រេងឥន្ធនៈចំនួន**៨២**ស្ថានីយ

- ក្រុងក្រចេះ មាន ១៦ស្ថានីយ
- ស្រុកស្នួល មាន ២៩ស្ថានីយ
- ស្រុកសំបូរ មាន ១៥ស្ថានីយ
- ស្រុកឆ្លូង មាន ៨ស្ថានីយ

- ស្រុកចិត្របុរី មាន ៦ស្ថានីយ
- ស្រុកព្រែកប្រសព្វ មាន ៨ស្ថានីយ។

-ដោយឡែកអាជីវកម្មឧស្ម័នឥន្ធនៈ(ហ្គាស) ខ្នាតតូចមានចំនួន **៣៥**កន្លែង
- ក្រុងក្រចេះ មាន ១០
- ស្រុកស្នួល មាន ៨
- ស្រុកឆ្លូង មាន ៥
- ស្រុកចិត្របុរី មាន ៥
- ស្រុកសំបូរ មាន ៤
- ស្រុកព្រែកប្រសព្វ មាន ៣។

**៧- វិស័យទេសចរណ៍**

សរុបឆ្នាំ២០១៨ មានចំនួន១៤៩កន្លែង ឆ្នាំ២០១៩ មានចំនួន១៥២កន្លែង ឆ្នាំ២០២០ មានចំនួន១៥១កន្លែង ឆ្នាំ២០២១ មានចំនួន១៤១កន្លែង ឆ្នាំ២០២២មានចំនួន២២២កន្លែង។

| ល.រ | ប្រភេទអាជីវកម្ម | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ |
|---|---|---|---|---|---|---|
| ១ | សណ្ឋាគារ | ១៥កន្លែង ស្មើ ៦២១បន្ទប់ | ១៦កន្លែង ស្មើ ៦៥២បន្ទប់ | ១៦កន្លែង ស្មើ ៦៥២បន្ទប់ | ១៥កន្លែង ស្មើ ៥៩៣បន្ទប់ | ១៦កន្លែង ស្មើ ៦៥២បន្ទប់ |
| ២ | ផ្ទះសំណាក់ | ៤៨កន្លែង ស្មើ ៤៥០បន្ទប់ | ៤៨កន្លែង ស្មើ ៤៥០បន្ទប់ | ៤៧កន្លែង ស្មើ ៤៣៥បន្ទប់ | ៤១កន្លែង ស្មើ ៣៦៥បន្ទប់ | ៥១កន្លែង ស្មើ ៤៤៤បន្ទប់ |
| ៣ | ភោជនីយដ្ឋាន | ៥៨កន្លែង | ៥៨កន្លែង | ៦០ កន្លែង | ៦០ កន្លែង | ១១៨កន្លែង |
| ៤ | ខារ៉ាអូខេ | ១៨កន្លែង | ២១កន្លែង | ១៨ កន្លែង | ១៥ កន្លែង | ២១កន្លែង |
| ៥ | ម៉ាស្សា | ៩កន្លែង | ៩កន្លែង | ១០ កន្លែង | ១០ កន្លែង | ១៥កន្លែង |
| ៦ | ក្លឹបកម្សាន្ត | ១កន្លែង | 0 | 0 | 0 | 0 |
| ៧ | បៀហ្គាឌិន | ១កន្លែង | ១កន្លែង | ១កន្លែង | ១កន្លែង | ១កន្លែង |
| **សរុបរួម** | | **១៤៩កន្លែង** | **១៥២កន្លែង** | **១៥១កន្លែង** | **១៤១កន្លែង** | **២២២កន្លែង** |

**៨- ចំនួនភ្ញៀវទេសចរជាតិ និងអន្តរជាតិ៖**

- ភ្ញៀវទេសចរអន្តរជាតិ

| ភ្ញៀវទេសចរអន្តរជាតិ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | សរុបរួម |
|---|---|---|---|---|---|---|
| សរុប | ២៥ ៩៩០ | ២៦ ៨៣៨ | ៨ ៤៣៣ | ៦៦៣ | ៣ ៤៦៥ | ៦៥ ៤២៩ |

-ភ្ញៀវទេសចរជាតិ

| ភ្ញៀវទេសចរជាតិ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ | ឆ្នាំ២០២០ | ឆ្នាំ២០២១ | ឆ្នាំ២០២២ | សរុបរួម |
|---|---|---|---|---|---|---|
| សរុប | ៣២៣ ១៩៦ | ៣៤៦ ៨១៨ | ១៦៦ ៧៥០ | ៥៧ ៦៥៥ | ១៨៨ ៥៧២ | ១ ០៨២ ៩៩១ |

**៩- ស្ថិតិរមណីយដ្ឋានទេសចរណ៍និងសហគមន៍ទេសចរណ៍ក្នុងខេត្ត**

រមណីយដ្ឋានទេសចរណ៍ក្នុងខេត្តក្រចេះសរុបចំនួន២០កន្លែង ក្នុងនោះរួមមានរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ៥កន្លែង រមណីយដ្ឋានធម្មជាតិ១១ រមណីយដ្ឋានកែច្នៃ ៣កន្លែង រមណីយដ្ឋានវប្បធម៌ធម្មជាតិ១កន្លែង។

| បរិយាយ | តារាងស្ថិតិរមណីយដ្ឋានទេសចរណ៍និងសហគមន៍ទេសចរណ៍ | | | | |
|---|---|---|---|---|---|
| **ឆ្នាំ** | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
| រមណីយដ្ឋាន | ១៣កន្លែង | ១៥កន្លែង | ១៥កន្លែង | ១៥កន្លែង | ១៥កន្លែង |
| សហគមន៍ | ០៣កន្លែង | ០៣កន្លែង | ០៣កន្លែង | ០៤កន្លែង | ០៥កន្លែង |
| **សរុប** | **១៦កន្លែង** | **១៨កន្លែង** | **១៨កន្លែង** | **១៩កន្លែង** | **២០កន្លែង** |

**១០- ការងារទឹកស្អាត**

បានចុះត្រួតពិនិត្យការងារទឹកស្អាតចំនួន៣៨មូលដ្ឋាន យកសំណាកទឹកទៅវិភាគគុណភាព៩៤មូលដ្ឋាន ទទួលបានការវិនិយោគវិស័យទឹកស្អាតឯកជនចំនួន១០មូលដ្ឋាន ស្មើ១៤ ឃុំ សង្កាត់ និង១១០ភូមិ ប្រជាពលរដ្ឋទទួលបានទឹកស្អាតប្រើប្រាស់៩ ២៨០គ្រួសារ ស្មើនឹង៤១ ៧៦០នាក់។

## **២.២១- ខេត្តព្រះវិហារ**

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តព្រះវិហារ សម្រេចបានដូចខាងក្រោមៈ**

ខេត្តព្រះវិហារ ស្ថិតនៅភាគឧត្តរនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចម្ងាយផ្លូវប្រវែង៣០០គ.ម. ពីរាជធានីភ្នំពេញ មកកាន់ខេត្តព្រះវិហារ កាត់តាមផ្លូវជាតិលេខ៦A និងផ្លូវជាតិលេខ៦២ មានព្រំប្រទល់ខាងកើតទល់នឹងខេត្តស្ទឹងត្រែង ខាងលិចទល់នឹងខេត្តសៀមរាបនិងខេត្តឧត្តរមានជ័យ ខាងត្បូងទល់នឹងខេត្តកំពង់ធំ និងខាងជើងទល់នឹងប្រទេសថៃប្រវែង១២៩គ.ម. និងប្រទេសឡាវប្រវែង១៤០គ.ម.(៩៣គ.ម. ជាប់នឹងស្រុកឆែប និង៤៧គ.ម.ជាប់នឹងស្រុកជាំក្សាន្ត) ព្រមទាំងមានស្ទឹងសែន១ខ្សែ ដែលមានប្រភពមកពីស្រុកជាំក្សាន្តហូរកាត់ភូមិសាស្ត្រខេត្តព្រះវិហារ មានប្រវែង២១៣គ.ម. និងមានទន្លេមេគង្គហូរកាត់ឃុំកំពង់ស្រឡៅមួយនិងឃុំកំពង់ស្រឡៅពីរ ស្រុកឆែប ខេត្តព្រះវិហារ មានប្រវែង២៤គ.ម.(ជាប់ព្រំដែនប្រទេសឡាវ)។

ខេត្តមានផ្ទៃដីសរុប១៣.៨២១,៧៦គ.ម.² ប្រជាពលរដ្ឋសរុបទូទាំងខេត្តចំនួន៦៤ ១០០គ្រួសារ ស្មើនឹងចំនួនមនុស្ស២៥៨ ០៦៤នាក់(ស្រី១២៩ ៨៦៦នាក់) ដង់ស៊ីតេប្រជាពលរដ្ឋប្រមាណ១៨នាក់ក្នុង១គ.ម² ចែកជា៧ស្រុក ១ក្រុង ៤៩ឃុំ ២សង្កាត់ និង ២៣២ភូមិ។

**១- ការរៀបចំផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងទីប្រជុំជនសម្រាប់គាំទ្រការអភិវឌ្ឍផ្លូវថ្នល់ ផ្លូវដែក និងផ្លូវទឹក ក៏ដូចជាប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីនិងទឹកស្អាត និងជាពិសេសការរៀបចំប្រព័ន្ធលូនិងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់។**

**១.១- ការរៀបចំនិងអនុវត្តគម្រោងខេត្ត**

- រៀបចំក្រាលការ៉ូឡាខាងមុខ និងខាងក្រោយអគារបណ្ណាល័យនិងធ្វើសួនច្បាររង្វង់មូលក្នុងបរិវេណសាលាខេត្តព្រះវិហារ១គម្រោង
- សាងសង់អគារច្រកចេញចូលតែមួយស្រុកជាំក្សាន្ត ស្រុករវៀង២គម្រោង
- សាងសង់អគារសាលាឃុំចំនួន៧គម្រោង សរុប១៧កន្លែង ក្នុងនោះស្រុកឆែប៧កន្លែង ស្រុករវៀង៤កន្លែង ស្រុកជ័យសែន១កន្លែង ស្រុកគូលែន៣កន្លែង ស្រុកជាំក្សាន្ត២កន្លែង
- ជួសជុលសួនច្បាផ្លូវក្លោះទំហំ៧០ម.² និងក្រាលការ៉ូឡា ទីរួមខេត្តប្រវែង៨ ៩២១,៨ម.² លើ៤គម្រោង

- ជួសជុលផ្លូវក្រាលក្រួសក្រហម ផ្លូវក្រាលកៅស៊ូDBST និងផ្លូវចាក់បេតុង ចំនួន១០ខ្សែ ប្រវែង៨៩ ០៩៥ម. ដាក់លូភ្លោះ៣៤កន្លែង និងលូទោល១ ០២២កន្លែង លើ៣៦គម្រោង

- ស្ថាបនាផ្លូវបេតុង ភូមិថ្មី និងទីរួមខេត្តព្រះវិហារប្រវែង៨៩១ម. លើ៩គម្រោង

- ជួសជុលអគារច្រកចេញចូល ឃ្លាំងដាក់សម្ភារៈ អគារក្រុមប្រឹក្សាខេត្ត និងអគារទីចាត់ការផែនការ និងវិនិយោគខេត្ត២ខ្នង លើ២គម្រោង

- ជួសជុលផ្លូវក្រាលកៅស៊ូAC ទីរួមខេត្ត ប្រវែង៥ ៣៥០ម. លើ៦គម្រោង

- កែលម្អផ្លូវកោះកេររៀបសួនច្បារជាំបង្គោលភ្លើង ក្រុងព្រះវិហារ១ ៥៦៤ម. លើ១គម្រោង។

**១.២- ការរៀបចំគម្រោងក្រុង ស្រុក**

- ជួសជុលផ្លូវក្រាលក្រួសក្រហម សរុបប្រវែងផ្លូវ១៩ ៥៨៥ម. ដាក់លូកាត់ផ្លូវ២៤កន្លែង លើ៣៧ គម្រោង

- សាងសង់របងសាលាក្រុង ស្រុក សរុបប្រវែង១ ៦៤៩ម. ដាក់លូរំដោះទឹកប្រវែង៣០០ម. ក្លោងទ្វារ ១កន្លែង និងរ៉ឺហ្គា៨កន្លែង លើ២៨គម្រោង

- សាងសង់ផ្លូវបេតុងប្រវែង២ ៤៨៧ម. និងចាក់សាបប្រវែង៣៩៩ម$^{២}$ លើ១០គម្រោង

- សាងសង់សួនច្បារ(១៨,៤ម. x ១៧ម.) និងទំហំ(១៥០ម. x ២០ម.)ផ្លូវបេតុង ប្រវែង២៩,៥ម. និងដាក់លូចំនួន១កន្លែង លើ៨គម្រោង

- ជួសជុលរៀបចំខឿន និងក្រាលការ៉ូឡា ទំហំ(៤៧ម. X ៣ម.) និងទំហំ១២០ម.$^{២}$ លើ២គម្រោង។

**១.៣- ការរៀបចំគម្រោងឃុំ សង្កាត់**

- សាងសង់និងជួសជុលផ្លូវក្រាលក្រួសក្រហម ប្រវែងផ្លូវ៣៧៥ ៨៨៤ម. ដាក់លូកាត់ផ្លូវចំនួន ៨២៥កន្លែង ស្ពានឈើក្បាលបេតុង៦កន្លែង សំណង់បង្ហៀរ១២កន្លែង និងលូប្រអប់១កន្លែង និងជីស្រះទឹកលើ ១ ៤៣៤គម្រោង

- ជួសជុលទំនប់ទឹក ប្រវែង៥ ៨១០ម. ចំនួន១០គម្រោង លើ១០គម្រោង

- សាងសង់ផ្លូវជីស ប្រវែង២០ ៤៤៨ម. និងដាក់លូកាត់ផ្លូវ២៣កន្លែង លើ៦គម្រោង

- សាងសង់ផ្លូវបេតុង ប្រវែង១ ១៧៦ម. លើ៦គម្រោង។

**១.៤- ការងារអភិវឌ្ឍន៍ជនបទ**

**១.៤.១- ការងារផ្លូវជនបទ**

-ជួសជុលថែទាំផ្លូវជាលក្ខណៈខួប១២ខ្សែ ប្រវែងសរុប១៤០,៦គ.ម. លូមូល៥កន្លែង លើ៥គម្រោង

-ជួសជុលថែទាំផ្លូវជាលក្ខណៈប្រចាំ២០ខ្សែ ប្រវែងសរុប៣៦៤,៧គ.ម. លើ២០គម្រោង

-ជួសជុលបន្ទាន់(ផ្លូវក្រួសក្រហម៥ខ្សែ ប្រវែង១០,២១គ.ម. និងលូមូលមុខ១ម. ចំនួន១កន្លែង ស្ពានឈើ១២កន្លែង ប្រវែង១៨៥,៨ម. និងស្ពានដែកបាឡេ៣កន្លែង ប្រវែង៤៥ម. លើ២០គម្រោង

-ស្ថាបនាផ្លូវក្រាលក្រួសក្រហម១១ខ្សែ ប្រវែង១១៤,០១៥គ.ម. និងលូមូល២២៨កន្លែង លើ ១១១គម្រោង

-ស្ពានបេតុងស្ថាបនាថ្មី២៣កន្លែង ប្រវែង៨៣៥ម. លើ២៣គម្រោង

-ស្ថាបនាផ្លូវកៅស៊ូពីរជាន់DBST ចំនួន៤ខ្សែ ប្រវែង៦២,៨គ.ម. លើ៤គម្រោង

-ស្ពាបនាផ្លូវបេតុង១ខ្សែ ប្រវែង១៨៥ម. លើ១គម្រោង។

**១.៤.២- ការងារផ្គត់ផ្គង់ទឹកជនបទ**

-ជីក ជួលជុលអណ្តូងស្នប់ អណ្តូងលូ និងអណ្តូងចម្រុះសាងសង់ថ្មីបាន១៩១អណ្តូង លើ២គម្រោង

-ស្តារស្រះសហគមន៍ទំហំ៤០ម. X ៣០ម. X ៣ម. = ៥កន្លែង និងស្រះទំហំ៧០ម. X ៥០ម. X ៦ម. = ៣កន្លែង លើ៨គម្រោង

-ផ្តល់ពាងត្រងទឹកភ្លៀង១ ៥៣៩ពាង និងកសាងអាងត្រងទឹកភ្លៀងបាន១៦៥អាង លើ១គម្រោង

-តបណ្តាញប្រព័ន្ធចែកចាយទឹកស្អាតតាមទុយោនៅជនបទបាន៤កន្លែង លើ៤គម្រោង

-កសាងស្ថានីយផលិតទឹកពិសាចំណុះ២០លីត្រ បាន៩កន្លែង លើ៩គម្រោង

-ផ្តល់ធុងចម្រោះទឹកស្អាតបាន២ ៧០៤ធុង

-ប្រជាពលរដ្ឋជនបទទទួលបានសេវាទឹកស្អាតបាន៣៥ ៩៣៩គ្រួសារ ស្មើនឹង៥៨%។

**១.៥- ការងារសាធារណការ និងដឹកជញ្ជូន**

- ការងារសាងសង់ ជួសជុល និងថែទាំ ផ្លូវ ស្ពាន លូ ឆ្នាំ២០១៨ លើគម្រោងចំនួន២ រួមមានទី១- ការងារថែទាំប្រចាំលើកំណាត់ផ្លូវជាតិ និងផ្លូវខេត្តក្រាលកៅស៊ូ DBST ចំនួន១០ខ្សែ មានប្រវែងសរុប៤៧៩,៥១គ.ម. និងថែទាំប្រចាំលើកំណាត់ផ្លូវជាតិ និងផ្លូវខេត្តក្រាលដីល្បាយថ្ម១០ខ្សែ មានប្រវែងសរុប២៨៦,០១គ.ម. និងទី២- ការងារជួសជុលផ្លូវក្រាលកៅស៊ូDBST ប្រវែង៣ ៣០០ម. ទទឹង៦ម. និងលូមូលកាត់ទទឹងផ្លូវមុខកាត់០,៨ម ចំនួន២ កន្លែង លើកំណាត់ផ្លូវជាតិលេខ៩៥PK៣៣ + ៧០០ ដល់PK៣៧ + ៧០០ ស្ថិតក្នុងស្រុកជ័យសែន ខេត្តព្រះវិហារ

- ការងារសាងសង់ ជួសជុល និងថែទាំ ផ្លូវ ស្ពាន លូ ឆ្នាំ២០១៩ លើគម្រោងចំនួន៣ រួមមាន ទី១- ការងារថែទាំប្រចាំលើកំណាត់ផ្លូវជាតិនិងផ្លូវខេត្តក្រាលកៅស៊ូDBST ចំនួន១១ខ្សែ មានប្រវែងសរុប៤៨៥,៩១គ.ម. និងថែទាំប្រចាំ លើកំណាត់ផ្លូវជាតិ និងផ្លូវខេត្តក្រាលដីល្បាយថ្ម ចំនួន៩ខ្សែ មានប្រវែង២៧៨,៦៤គ.ម. ទី២- ការងារកាត់ជួសជុលផ្លូវក្រាលកៅស៊ូDBST ប្រវែង២ ២០០ម. ទទឹង៧ម. ចាប់ពីPK១៧៣ + ០០០ ដល់PK ១៧៤ + ០០០ និងPK១៧៩ +០០០ ដល់PK១៨០ + ២០០ លើកំណាត់ផ្លូវជាតិលេខ៦២ ស្ថិតក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និងទី៣- ការងារស្ថាបនាស្ពានបេតុងសសៃដែក២កន្លែង លើកំណាត់ផ្លូវជាតិលេខ៩៥ស្ពានទី១ (ស្ពានអូឆែប) ប្រវែង៤៥ម. ទទឹង១២,៥០ម ត្រង់ចំណុចPK០០+២២៥ និងស្ពានទី២(ស្ពានអូតាំងយូ) ប្រវែង ១៨ម. ទទឹង១០,៩០ម. ត្រង់ចំណុចPK០១ + ២៧០ ស្ថិតក្នុងស្រុកឆែប ខេត្តព្រះវិហារ

- ការងារសាងសង់ ជួសជុល និងថែទាំផ្លូវ ស្ពាន លូ ឆ្នាំ២០២០ លើគម្រោងចំនួន៤ រួមមាន ទី១- ការងារថែទាំប្រចាំលើកំណាត់ផ្លូវជាតិ និងផ្លូវខេត្តក្រាលកៅស៊ូ DBST ចំនួន១៤ខ្សែ មានប្រវែងសរុប៤៩៨,២៤ គ.ម. និងថែទាំប្រចាំ លើកំណាត់ផ្លូវជាតិនិងផ្លូវខេត្តក្រាលដីល្បាយថ្ម៩ខ្សែ មានប្រវែងសរុប២៦៧,០៤គ.ម. ទី២- ការងារកាត់ជួសជុលផ្លូវក្រាលកៅស៊ូDBST ប្រវែង៥ ៦០០ម. ទទឹង៧ម. ចាប់ពីPK១៥៥ + ១០០ ដល់PK ១៥៥ + ៨០០, PK២៣០ + ៤០០ ដល់ PK២៣៣ + ៥០០ និងPK២៣៤ + ២០០ ដល់PK២៣៥ + ០៥០ រួមទាំង ផ្លូវជុំវិញរង្វង់មូលស្រអែម ប្រវែង៩៥០ម. លើកំណាត់ផ្លូវជាតិលេខ៦២ ស្ថិតក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ទី៣- ការងារស្រោចកៅស៊ូឡើងវិញ(Re-seal) ប្រវែងសរុប១៦ ០០០ម. ទទឹង៧ម. លើកំណាត់ផ្លូវជាតិលេខ៦២ PK ១៦៧ + ៥០០ ដល់PK១៨៥ + ៧០០ និងផ្លូវជាតិលេខ ៦៤ PK៩៤ + ០០០ ដល់PK៩៩ + ០០០ ស្ថិតក្នុង ស្រុកគូលែន និងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និងទី៤- ការងារស្ថាបនា និងជួសជុលប្រព័ន្ធលូបង្ហូរទឹក(លូអ៊ុយ)

ប្រវែង៣ ២១៦ម. លើកំណាត់ផ្លូវជាតិលេខ៦៤ ចាប់ពីPK៩៩ + ៥៤២ ដល់PK១០១ + ១៥០ ស្ថិតក្នុងស្រុកគូលែន ខេត្តព្រះវិហារ

- ការងារសាងសង់ ជួសជុល និងថែទាំផ្លូវ ស្ពាន លូ ឆ្នាំ២០២១ លើគម្រោងចំនួន៦ រួមមានទី១-ការងារថែទាំប្រចាំលើកំណាត់ផ្លូវជាតិ និងផ្លូវខេត្តក្រាលកៅស៊ូDBST ចំនួន១៤ខ្សែ មានប្រវែងសរុប៤៩៨,២៤គ.ម. និងថែទាំប្រចាំ លើកំណាត់ផ្លូវជាតិ និងផ្លូវខេត្តក្រាលដីល្បាយថ្ម៩ខ្សែ មានប្រវែងសរុប២៦៧,០៤គ.ម. ទី២-ការងារជួសជុលពង្រីកផ្លូវជាតិលេខ៦៤ ដោយក្រាលកៅស៊ូDBST ប្រវែង២ ២០០ម. ទទឹងម្ខាងៗ ៤,៥ម. ចាប់ពី PK៩៩ + ២៥០ ដល់PK១០១ + ៤៥០ ស្ថិតក្នុងស្រុកគូលែន ខេត្តព្រះវិហារ ទី៣-ការងារស្រោចកៅស៊ូឡើងវិញ (Re-seal) ប្រវែង៨ ៥០០ម. ទទឹង៧ម. លើកំណាត់ផ្លូវជាតិលេខ៦២ PK២០៧ + ៨០០ ដល់PK២១១ + ៨០០ និងផ្លូវជាតិលេខ៦៤ PK១០៧ + ៦៥០ ដល់PK១១២ +១៥០ ស្ថិតក្នុងស្រុកគូលែន និងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ទី៤- ការងារស្ដាបនាផ្លូវក្រាលកៅស៊ូ DBST ប្រវែង៣ ៥០០ម. ទទឹង៧ម. PK៣០ + ២០០ ដល់PK៣៣ + ៧០០ លើកំណាត់ផ្លូវជាតិលេខ៩៥ ស្ថិតក្នុងស្រុកជ័យសែន ខេត្តព្រះវិហារ ទី៥- ការងារកាត់ជួសជុលផ្លូវក្រាលកៅស៊ូ DBST ប្រវែង៤ ៥០០ម. ទទឹង៧ម. PK១៤១ + ៤០០ ដល់PK១៤៣ + ០០០ PK១៥២ + ៥០០ ដល់PK ១៥៣ + ៩០០ និងPK១៥៦ + ៥០០ ដល់PK១៥៨ + ០០០ លើកំណាត់ផ្លូវជាតិលេខ៦២ ស្ថិតក្នុងស្រុកគូលែន ខេត្តព្រះវិហារ និងទី៦- ការងារសាងសង់ស្ថានីយជញ្ជីងថ្លឹងរថយន្តលើកំណាត់ផ្លូវជាតិលេខ៦២ ត្រង់ចំណុច PK៥២ + ០០០ ស្ថិតក្នុងស្រុករវៀង ខេត្តព្រះវិហារ

- ការងារសាងសង់ ជួសជុល និងថែទាំផ្លូវ ស្ពាន លូ ឆ្នាំ២០២២ លើគម្រោងចំនួន៤ រួមមានទី១-ការងារថែទាំប្រចាំលើកំណាត់ផ្លូវជាតិ និងផ្លូវខេត្តក្រាលកៅស៊ូ DBST ចំនួន១៥ខ្សែ មានប្រវែងសរុប៥៣២,៣៧គ.ម. និងថែទាំប្រចាំ លើកំណាត់ផ្លូវជាតិ និងផ្លូវខេត្តក្រាលដីល្បាយថ្ម១០ខ្សែ មានប្រវែងសរុប២៧០,៥៩គ.ម. (កំពុងអនុវត្ត) ទី២- ការងារស្រោចកៅស៊ូឡើងវិញ(Re-seal) ប្រវែង៧ ៨៥០ម. ទទឹង៧ម. លើកំណាត់ផ្លូវជាតិលេខ៦២ PK១២៧ + ៨០០ ដល់ PK១៣២ + ០០០ និងផ្លូវជាតិលេខ៦៤ PK៧៧ + ៩៨០ ដល់PK៨១ + ៦៣០ ស្ថិតក្នុងក្រុងព្រះវិហារ និងស្រុកគូលែន ខេត្តព្រះវិហារ(អនុវត្តគម្រោងរួច១០០%) ទី៣- ការងារកាត់ជួសជុលផ្លូវក្រាលកៅស៊ូ DBST ប្រវែង៣ ៥០០ម. ទទឹង៧ម. PK១៧៥ + ៥០០ ដល់PK១៧៩ + ០០០ លើកំណាត់ផ្លូវជាតិលេខ៦២ ស្ថិតក្នុងស្រុកគូលែន ខេត្តព្រះវិហារ(កំពុងអនុវត្ត) និងទី៤- គម្រោងស្ថាបនាកំណាត់ផ្លូវជាតិលេខ៩៥ ដោយក្រាលកៅស៊ូ DBST ប្រវែង២ ៤០០ម. ទទឹង(DBST) ៧ម. ចិញ្ចើម(SBST) ០,៥ម. សង្ខាង ចាប់ពី គ.ម.០៤ + ៣០០ ដល់គ.ម.០៦ + ៧០០ ស្ថិតក្នុងស្រុកឆែប ខេត្តព្រះវិហារ(កំពុងអនុវត្ត)។

**១.៦- ការងាររ៉ែនិងថាមពល**

ខេត្តព្រះវិហារ មានអាជ្ញាបណ្ណអគ្គិសនី សរុប១៥អាជ្ញាបណ្ណ ដែលទទួលបានការអនុញ្ញាតពីក្រសួងរ៉ែ និងថាមពល ហើយបានរៀបចំតបណ្ដាញជាតិទៅដល់គ្រប់ក្រុង ស្រុកទាំង៨ និង៥១ឃុំ សង្កាត់ លើ១៥គម្រោង។

**២-** ការបន្តពង្រឹងសោភ័ណ្ឌភាព សេវាទីក្រុង ទីប្រជុំជន តាមរយៈការគ្រប់គ្រង ការប្រមូលសំរាម ទីលានចាក់សំរាម ការរៀបចំផ្លូវថ្មើរជើង ស្ពានអាកាស ទីធ្លាចំណត ការរៀបចំសួនច្បារសាធារណៈ ការកសាង ការការពារប្រាំងទន្លេនិងទំនប់ ការរៀបចំសណ្ដាប់ធ្នាប់ និងភ្លើងបំភ្លឺនៅក្នុងទីក្រុង ភ្លើងសញ្ញាចរាចរណ៍ ផ្សារធំៗ និងការប្រើប្រាស់សេវាដឹកជញ្ជូនសាធារណៈក្នុងទីក្រុង

**ការរៀបចំនិងអនុវត្តគម្រោងខេត្ត**

- ស្តាបនាបង្គោលភ្លើងបំភ្លឺសាធារណៈ ទីរួមខេត្ត៣១៩ដើម លើ៥គម្រោង
- ជួសជុលបង្គោលភ្លើងសូឡា ទីរួមខេត្ត១០០ដើម លើ២គម្រោង
- ជួសជុលបណ្តាញខ្សែភ្លើង ទីរួមខេត្ត៥១ដើម លើ១គម្រោង។

**៣- ការសាងសង់អគារចាប់ពី៥ជាន់ឡើង សណ្ឋាគារ ខុនដូ ផ្ទះសំណាក់**

ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី (ការចេញលិខិតអនុញ្ញាតលើវិស័យសំណង់ធំៗ ឬអគារដែលមានកម្ពស់ចាប់ពី ៥ជាន់)

- អគារការិយាល័យសាខាធនាគារព្រីន ធនាគារវឌ្ឍនៈ និងផ្ទះសំណាក់ ពិសិដ្ឋ ពេជ្រ លើ៣គម្រោង
- ផ្ទះសំណាក់ លី គឹមសេង ផ្ទះសំណាក់ សោ ហួរ អគារការិយាល័យ ប៉ាវ សុវៀត ផ្សារអាជីវកម្ម សោ ហួរ ឃ្លាំងលក់ម៉ូតូ ដោក រៀង ឃ្លាំងលក់សម្ភារៈ វុន វណ្ណារ៉ុម ផ្ទះស្នាក់នៅរួម ឡោ អាន អាគារស្នាក់នៅរួម ចាន់ ឈុនហៀង និងផ្ទះល្វែងលំនៅដ្ឋាន ផង់ វល័ក្ខ លើ៩គម្រោង
- អគារការិយាល័យ ធនាគារអេប៊ីអេ ស៊ឹមនិងស្បា៉ ឈឿន សំណាង ផ្ទះល្វែង ស គង្គារ ផ្ទះល្វែង វ៉ា ឡាំងហ៊ី ប្រាសាទបំពេញបារមី សំណង់សាធារណៈមិនមែនថវិការរដ្ឋ សុខ កុសល វត្តព្រះពុទ្ធមានជ័យ(ហៅវត្តប៉ាលហាល)សំណង់រដ្ឋ លើ៦គម្រោង
- អគារការិយាល័យធនាគារប្រៃសណីយ៍ ផ្ទះសំណាក់ ជិន វិច្ឆិកា ឃ្លាំង៣ណិជ្ជកម្ម ប៉េងលី វ៉ាន់នី សាលាឆាន់សំណង់រដ្ឋ ភូង ភូនជណ្តើរវត្តជុំវាហីង្សី សំណង់រដ្ឋ សុខ សុទ្ធី ហាងលក់ទំនិញពាណិជ្ជកម្ម គី វ៉ាន់នីន អគារការិយាល័យពាណិជ្ជកម្ម គង់ នាង អាហារដ្ឋាន ទេសចរណ៍ ខុក ម៉ាលីន ក្លឹបហាត់ប្រាណពាណិជ្ជកម្ម សូ វឌ្ឍនា ហាងលក់ទំនិញពាណិជ្ជកម្ម តាន់ សុផារី និងផ្ទះដួលពាណិជ្ជកម្ម ផេង គន្ធា លើ១១គម្រោង
- អគារការិយាល័យ អិល អូ ឌី ហាងលក់សំលៀកបំពាក់ពាណិជ្ជកម្ម វ៉ាត ចាន់ណារី ផ្ទះដួលពាណិជ្ជកម្ម លី ស៊ីវលីន ឃ្លាំងពាណិជ្ជកម្ម ផៃ ស្រីពេជ្រ ផ្ទះល្វែង(សម្រាប់លក់)៣គម្រោង ស៊ឹម នីន និងរោងចក្រផលិតទឹកសុទ្ធ ស វ៉ាន់ហ៊ាង លើ៨គម្រោង។

## ២.២២- ខេត្តត្បូងឃ្មុំ

**សមិទ្ធផលនិងស្នាដៃការងារសំខាន់របស់រដ្ឋបាលខេត្តត្បូងឃ្មុំ សម្រេចបានដូចខាងក្រោម៖**

ខេត្តត្បូងឃ្មុំ ជាខេត្តមួយក្នុងចំណោមរាជធានីខេត្តទាំង២៥ មានទីតាំងស្ថិតនៅត្រើយខាងកើតទន្លេមេគង្គ ភាគអាគ្នេយ៍ នៃរាជធានីភ្នំពេញ។ ខេត្តត្បូងឃ្មុំមានព្រំប្រទល់ខាងលិចជាប់ទន្លេមេគង្គប្រវែង៧៩គ.ម. ខាងត្បូងជាប់ខេត្តព្រៃវែង ខាងជើងនិងខាងកើតជាប់ខេត្តក្រចេះ និងមួយផ្នែកទៀតនៅភាគខាងកើតជាប់ព្រំដែន ជាមួយប្រទេសវៀតណាម ប្រវែង១៤២,៧គ.ម.។

ខេត្តត្បូងឃ្មុំ ជាខេត្តមួយដែលមានមានផ្ទៃដីសរុប៥ ២៥០,៥១គ.ម$^{២}$ ចែកចេញជា៦ស្រុក ១ក្រុង ឃុំ៦២ សង្កាត់២ ភូមិ៨៧៣ និងមានប្រជាពលរដ្ឋសរុប៨៧៤ ៩៥៣នាក់ ស្រី៤៣៧ ៣៨៨នាក់ ស្មើនឹង១៩៩ ១១៣គ្រួសារ។

## ១- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុងនិងទីប្រជុំជន

| ល.រ. | បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ផ្លូវកៅស៊ូ | គ.ម. | ១៨០,៧៨ | ៣៦,០៧៧ | ១៨១,៩៨ | ២១,៤២ | ១៤១,៦៣៤ | ៥៦១,៨៩១ |
| ២ | ផ្លូវបេតុង | គ.ម. | ២១,៩០ | ២,៥០ | ៥៣,៧៣ | ០ | ៦៦,២៨ | ១៤៤,៤១ |
| ៣ | ផ្លូវក្រាលក្រួស | គ.ម. | ៧ | ៤៥,៨០ | ៣៩,៧៦ | ៣,៥៥ | ៥២,៨៥ | ១៤៨,៩៦ |
| ៤ | សាងសង់លូមូល បណ្ដោយផ្លូវ | ម. | ១ ៤០១ | ១៥៤ | ៨ | ៥ ១១៨ | ០ | ៦ ៦៨១ |
| ៥ | ជួសជុលបន្ទាន់លូមូល តាមបណ្ដោយផ្លូវ | ម. | ០ | ១ ០០០ | ០ | ០ | ០ | ១ ០០០ |
| ៦ | ជួសជុលរ៉ឺហ្គា | កន្លែង | ៧៤ | ០ | ០ | ០ | ៦៨ | ១៤២ |
| ៧ | ស្ដារប្រព័ន្ធលូ ក្នុងទីប្រជុំជន | ម. | ២ ៦១១ | ៦៨៩ | ៦៦០ | ០ | ០ | ៣ ៩៦០ |
| ៨ | ស្ដារប្រឡាយទឹកស្អុយ នៅទីប្រជុំជនផ្សារ | ម. | ១ ៦២០ | ២ ២០០ | ៤ ៨០០ | ៥ ០០០ | ៥ ២៧២ | ១៨ ៨៩២ |

## ២- ការពង្រឹងសោភ័ណភាព សេវាទីក្រុងទីប្រជុំជន

| ល.រ. | បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ការគ្រប់គ្រងការប្រមូលសំរាម | កន្លែង | ១ ១៣៤ | ១០ | ២ ៧៤៩ | ១ ៧១៧ | ៣ ៩២៨ | ៩ ៥៣៨ |
| ២ | ទីលានចាក់សំរាម | កន្លែង | ១ | ២ | ១ | ១ | ០ | ៥ |
| ៣ | ការរៀបចំផ្លូវថ្មើរជើង | គ.ម. | ០ | ០ | ០ | ២២,៩១ | ០ | ២២,៩១ |
| ៤ | ទីធ្លាចំណត | កន្លែង | ១ | ០ | ០ | ០ | ០ | ១ |
| ៥ | សួនច្បារសាធារណៈ | កន្លែង | ០ | ១ | ១ | ០ | ០ | ២ |
| ៦ | កសាង និងការពារ ច្រាំងទន្លេ និងទំនប់ | ម. | ១៥០ | ១៥០ | ១ ០០០ | ២ ២៥០ | ៤៥០ | ៤ ០០០ |
| ៧ | ការរៀបចំសណ្ដាប់ធ្នាប់ | កន្លែង | ៣ | ៣ | ០ | ៣ | ៣ | ១២ |
| ៨ | ភ្លើងបំភ្លឺនៅក្នុងក្រុងនិង ទីប្រជុំជន | បង្គោល | ២០១ | ១១៨ | ៥៤ | ១.៦៧៥ | ២៥៣ | ២.៣០១ |
| ៩ | ផ្សារទំនើប និងផ្សារ លក់កសិផលផ្សេងៗ | ផ្សារ | ១ | ០ | ០ | ០ | ០ | ១ |

## ៣- ការងារទេសចរណ៍

| ល.រ | បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ១ | រមណីយដ្ឋាន | ៥ | ៥ | ៩ | ១១ | ១៤ | ៤៤ |
| ២ | សណ្ឋាគារ | ៥ | ៦ | ៦ | ៦ | ៦ | ២៩ |
| | ចំនួនបន្ទប់ | ២១១ | ២៤១ | ២១១ | ២០៣ | ២០៦ | ១ ០៧២ |
| ៣ | ផ្ទះសំណាក់ | ៥១ | ៥៤ | ៥៤ | ៥៨ | ៥៧ | ២៧៤ |
| | ចំនួនបន្ទប់ | ៧៩៦ | ៧៩២ | ៦៩៤ | ៧១៤ | ៦៦១ | ៣ ៦៥៧ |
| ៤ | ភោជនីយដ្ឋាន | ៦ | ៨ | ៩ | ១១ | ១៤ | ៤៨ |
| | ចំនួនកៅអី | ៣៤៤ | ៤០៤ | ៥៣៦ | ៥០២ | ៧២០ | ២ ៥០៦ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | ខារ៉ាអូខេ | ២៥ | ២២ | ២៣ | ២៣ | ២៥ | ១១៨ |
| | ចំនួនបន្ទប់ | ១៤២ | ១២៣ | ១២៤ | ១០៨ | ១១២ | ៦០៩ |
| ៦ | ម៉ាស្សា | ៧ | ៨ | ១៥ | ១៥ | ១៥ | ៦០ |
| | ចំនួនគ្រែ | ២៤ | ៤៣ | ៦៧ | ៦៧ | ៦៧ | ២៦៨ |
| ៧ | ហាងកាហ្វេ | ១ | ៣ | ២ | ៨ | ៨ | ២២ |
| | ចំនួនកៅអី | ២៤ | ៥២ | ២៨ | ១៨០ | ២១៨ | ៥០២ |
| ៨ | បន្ទប់ជួល | ០ | ០ | ០ | ៨ | ៨ | ១៦ |
| | ចំនួនបន្ទប់ | ០ | ០ | ០ | ៥៨ | ៥៨ | ១១៦ |

## ៤- ការងារថាមពលអគ្គិសនី

| ទិន្នផល ប្រចាំឆ្នាំ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | គិតជា |
|---|---|---|---|---|---|---|
| ថាមពលផលិត និងផ្គត់ផ្គង់ពីបណ្តាញជាតិ | ៦៧ ៥១៤ ៨៧៧ | ១៤០ ៥៨៣ ៧៥២ | ១៥៧ ៤៣៩ ២៩៩ | ២១៥ ០៤២ ០៩៣ | ១៧៣ ៩៣៣ ៨៣៨ | KWh |
| អានុភាពអតិបរមា | ៩ | ២៧ | ២៣ | ២៨ | ៣១ | MW |
| ខ្សែបណ្តាញតង់ស្យុងមធ្យម | ៩៤០ | ១ ០៧៥ | ១ ១១១ | ១ ២១៦ | ១ ២៤៣ | Km |
| ខ្សែបណ្តាញតង់ស្យុងទាប | ៧៧៣ | ៨៤៤ | ៩៦៣ | ១ ០៩៩ | ១ ១៩៧ | Km |
| ចំនួនត្រង់ស្វូ | ៤៩៣ | ៥៦៤ | ៦១៥ | ៧០១ | ៧៤៥ | គ្រឿង |
| **អតិថិជនសរុប** | **៦២ ០៣៣** | **៦៦ ៣៩៧** | **៧០ ៨៤១** | **៧៤ ៦០៥** | **៧៨ ២៥៦** | **អតិថិជន** |

## ៥- ការងារប្រឡងប្រណាំងនិងការទទួលពានរង្វាន់

| ល.រ | បរិយាយ | ឆ្នាំ | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | |
| ១ | ជ័យលាភីផ្កាវិដ្ឋលពាទង លើកទី២ | ១ | ០ | ០ | ០ | ០ | ទទួលនៅ រាជធានី ភ្នំពេញ |
| ២ | ជ័យលាភីស្លាមញញឹម៣ និងស្លាមញញឹម២ | ១ | ០ | ០ | ០ | ០ | ទទួលនៅ រាជធានីភ្នំពេញ |

រមណីយដ្ឋានទេសចរណ៍ក្នុងខេត្តត្បូងឃ្មុំ មានចំនួន១៤កន្លែង ក្នុងនោះរួមមានរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រចំនួន៤កន្លែង រមណីយដ្ឋានធម្មជាតិចំនួន២កន្លែង និងរមណីយដ្ឋានកែច្នៃចំនួន៨កន្លែង។

### ក- រមណីយដ្ឋានប្រវត្តិសាស្ត្រ រួមមាន៖

១- ហ្លួងព្រះស្តេចកន( ស្ថិតនៅភូមិនគរក្នុង ឃុំដូនតី ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ)។

២- ព្រះធាតុបាស្រី( ស្ថិតនៅភូមិព្រះធាតុ ឃុំព្រះធាតុ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ)។

៣- សារមន្ទីរបុរាណវិទ្យាមេមត់ (ស្ថិតនៅភូមិមេមត់ផ្សារ ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ)។

៤- អិច១៦(x ១៦) (ស្ថិតនៅភូមិចង្កូទី១ ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ)។

**ខ- រមណីយដ្ឋានធម្មជាតិ រួមមាន៖**

១- ទឹកធ្លាក់ហោង(ស្ថិតនៅភូមិលោ ឃុំកំពាន់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ)។

២- ភូមិអភិវឌ្ឍន៍អន្លង់ជ្រៃ (ស្ថិតនៅភូមិអន្លង់ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ)។

**គ- រមណីយដ្ឋានកែច្នៃ**

១- តាសែងដូងក្រអូប(ស្ថិតនៅភូមិឯកភាព ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ)។

២- សួនកម្សាន្តធម្មជាតិទឹកហូរអូរក្លុង (ស្ថិតនៅភូមិស្រែសៀម ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ)។

៣- ឫស្សីឈូករ័ត្ន(ស្ថិតនៅភូមិជីរោទិ៍ក្រោមទី២ ឃុំជីរោទិ៍ទី១ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ)។

៤- សួនបឹងក្រចាប់(ស្ថិតនៅភូមិបឹងត្រស់ ឃុំជីរោទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ)។

៥- សួនកម្សាន្ត អូរតាឃ្លោក(ស្ថិតនៅភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ)។

៦- ចំការកៅស៊ូ(ស្ថិតនៅស្រុកមេមត់,ស្រុកពញាក្រែក,ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ)

៧-ចម្ការទុរេនតាកាំង(ស្ថិតនៅភូមិក្រូច ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ)។

៨- អូរតាទ្រី(ស្ថិតនៅភូមិកំពាន់ ឃុំកំពាន់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ)។

**៦- ការងារទឹកស្អាត**

| ល.រ | បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ក.ទឹកស្អាតរដ្ឋ | | | | | | | | |
| ១ | បរិមាណផលិតទឹកស្អាត | ម.៣ | ០ | ០ | ១៦៧ ៨៥០ | ២១៤ ៩២៧ | ២៩២ ៧២៤ | ៥២៤ ៤៣៦ |
| ២ | ប្រវែងបណ្តាញទឹកស្អាត | គ.ម. | ០ | ០ | ៥៣ | ៨១ | ១០៧ | ២៤១ |
| ៣ | ភាគរយគ្រួសារដែលមានទឹកស្អាតប្រើ | % | ០ | ០ | ៤ | ១២ | ១២ | ២៨ |
| ខ.ទឹកស្អាតឯកជន | | | | | | | | |
| ១ | បរិមាណផលិតទឹកស្អាត | ម.៣ | ៨៣៤ ៧១៧ | ១ ០៩៤ ២៤៤ | ១ ២៩០ ២៣៨ | ១ ៧៨១ ៩៤៨ | ២ ០២២ ៣៣០ | ៧ ០២៣ ៤៧៧ |
| ២ | ប្រវែងបណ្តាញទឹកស្អាត | គ.ម | ១៩៦ | ២៧២ | ៣៥៩ | ៤៥៧ | ៧០៩ | ១ ៩៩៣ |
| ៣ | ភាគរយគ្រួសារដែលមានទឹកស្អាតប្រើ | % | ២៦ | ២៩ | ១៧ | ២៦ | ២៦ | ១២៤ |

## ២.២៣- ខេត្តកំពង់ចាម

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តកំពង់ចាម សម្រេចបានដូចខាងក្រោម៖**

ទីតាំងភូមិសាស្ត្រខេត្តកំពង់ចាម ស្ថិតនៅភាគខាងកើតនៃប្រទេសកម្ពុជា ដែលមានព្រំប្រទល់ខាងកើតទល់នឹងខេត្តត្បូងឃ្មុំ ខាងលិចទល់នឹងខេត្តកំពង់ឆ្នាំង ខាងត្បូងទល់នឹងខេត្តកណ្តាលនិងខេត្តព្រៃវែង ខាងជើង

ទល់នឹងខេត្តក្រចេះនិងខេត្តកំពង់ធំ។ ខេត្តកំពង់ចាម មានចម្ងាយ១២៤គ.ម.ពីរាជធានីភ្នំពេញ ដោយឆ្លងកាត់តាមផ្លូវជាតិលេខ៦ និងផ្លូវជាតិលេខ៧ ដែលមានផ្ទៃដីសរុបចំនួម៤ ៥៤៨,០៩គ.ម.$^{2}$ មានក្រុង១ និងស្រុក៩ គឺក្រុងកំពង់ចាម ស្រុកកំពង់សៀម ស្រុកស្ទឹងត្រង់ ស្រុកចម្ការលើ ស្រុកព្រៃឈរស្រុកជើងព្រៃ ស្រុកបាធាយ ស្រុកកងមាស ស្រុកកោះសូទិន និងស្រុកស្រីសន្ធរ ហើយមានសង្កាត់៤ ឃុំ១០៥ និង៩២៣ភូមិ និងមានប្រជាពលរដ្ឋសរុបចំនួន២៨៤ ៣៨៩គ្រួសារ ស្មើនឹង១ ១១៥ ៥៨៥នាក់(ស្រី៥៧៥ ៣៥៨នាក់) ដែលមានដង់ស៊ីតេ២៤៥នាក់ក្នុមួយគ.ម.$^{2}$។ ប្រជាពលរដ្ឋភាគច្រើនប្រកបរបរកសិកម្ម ដែលមានប្រជាពលរដ្ឋចំនួន៦៧,៩% ប្រកបមុខរបរកសិកម្មជាចម្បងចំនួន០,៧% ប្រកបមុខរបរសេវាកម្មជាចម្បងចំនួន៣១,៤%។ បច្ចុប្បន្នសម្រាប់មនុស្សម្នាក់ (GDP) ក្នុងឆ្នាំ២០២១ មានចំនួន៦ ៤៦៩ ៩៦៤លានរៀល កើនឡើងដល់១,៣% បើធៀបនឹងឆ្នាំ២០២០ មានចំនួន ៦ ៣៨៣ ៨០៨លានរៀល។ បើគិតជាដុល្លារ សម្រាប់មនុស្សម្នាក់ឆ្នាំ២០២១ មានចំនួន១ ៥៩២ដុល្លារអាម៉េរិក បើធៀបនឹងឆ្នាំ២០២០ មានចំនួន១ ៥៨៥ដុល្លារអាម៉េរិក កើនឡើងចំនួន១,៣%។

### ១- ការងារសាធារណៈការ និងដឹកជញ្ជូន

**បណ្តាញផ្លូវ**

| ប្រភេទ | ឯកតា | AC | DBST | MCD | បេតុង | ល្បាយក្រួសក្រហម | ដីធម្មជាតិ |
|---|---|---|---|---|---|---|---|
| ផ្លូវជាតិ ១ខ្ទង់ | គ.ម | ៩៧,៦០០ | | | | | |
| ផ្លូវជាតិ ២ខ្ទង់ | គ.ម | ១៨,៩៧០ | ១១៩,៨០០ | | ១៩,៥៦០ | | ២៤,៥៣៥ |
| ផ្លូវខេត្ត | គ.ម | ២,៦០០ | ២៥៦,៤៩៥ | | ១០,៥៨០ | ២០១,៨០៤ | ៤៧,៣០០ |

**ស្ពាននិងលូ**

| ប្រភេទ | ឯកតា | ប្រវែង |
|---|---|---|
| ស្ពានបេតុង | ម. | ៦ ៣៦៤,៥០ |
| ស្ពានបាឡេ | ម. | ៩៣២,៦០ |
| ស្ពានដាឡូ | ម. | ៤៥៥,២០ |
| លូបណ្តាញផ្លូវ និងកាត់ផ្លូវ | ម. | ៣៧ ២៦១,៧០ |

### ២- លទ្ធផលការងារដែលអនុវត្ត

**ការងារថែទាំប្រចាំ**

| ប្រភេទ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ(AC/DBST) | គ.ម | ៣៤៧,៧៤ | ៣៧០,០១ | ៣៨០,៧២ | ៤០៦,១០ | ៣៧២,០១ |
| ផ្លូវក្រួសក្រហម | | ៧១,៨២ | | | ៩,៥០ | ៩,៥០ |
| ស្ពានបេតុង | គ.ម | ៤ ៤៥០,៨ | ៤ ៤៥០,៨ | ៤ ៤៥០,៨ | ៤ ៥២៥,៨ | ៤ ៥២៥,៨ |
| ស្ពានបាឡេ | ម. | ៤៦៥ | ៤៦៥ | ៤៦៥ | ៣៩០ | ៣៩០ |
| លូគ្រប់ប្រភេទ | ម. | ៤ ០៨០,២ | ៤ ០៨០,២ | ៤ ០៨០,២ | ៤ ០៨០,២ | ៤ ០៨០,២ |
| ប្រឡាយ | ម. | ១៥ ៥៨០ | ១៥ ៥៨០ | ១៥ ៥៨០ | ១៦ ០៨០ | ១៦ ០៨០ |

## ការងារថែទាំខួប

| ប្រភេទ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (គិតត្រឹមខែសីហា) |
|---|---|---|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ (AC/DBST) | គ.ម | ១០,៣០ | ៤,២០ | ៦,០០ | ១០,៤០០ | ២,០០០ |
| ផ្លូវបេតុង | គ.ម | | | ១,៧៣០ | | |
| ស្ពានដាឡូ | ម. | | | | | ៦,២០ |
| លូគ្រប់ប្រភេទ | ម. | ១០៤,០០ | | | ១ ៧៦០,០០ | ៤,៦០០ |

## ការងារសាងសង់ថ្មីឬលើកម្រិត

| ប្រភេទ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (គិតត្រឹមខែសីហា) |
|---|---|---|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ(AC/DBST) | គ.ម | ៣,៨០០ | ៥,៦០០ | ២,៦៨០ | ១,៧០០ | |
| ផ្លូវបេតុង | គ.ម | ១,៦៦០ | | | ០,១៤០ | ១,៣៥០ |
| ស្ពានបេតុង | ម. | | | ៦០,០០ | ៤០,០០ | |
| លូគ្រប់ប្រភេទ | ម. | ៣០,០០ | ៣៦,០០ | | | |

## ការងារជួសជុលបន្ទាន់

| ប្រភេទ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (ត្រឹមខែសីហា) |
|---|---|---|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ(AC/DBST) | គ.ម | ១,៦៥៤ | | | | |
| ផ្លូវបេតុង | គ.ម | ០,២០០ | | | | |
| ផ្លូវក្រាលកំទេចថ្មបំបែក | គ.ម | ៥,៦០០ | | | | |
| ផ្លូវក្រួសក្រហម | គ.ម | ៨,៨០០ | | | ១១,៥៥០ | ២,២០០ |
| ស្ពានបាឡេ | ម. | ១២ | | ៤២០,០០ | | |
| លូគ្រប់ប្រភេទ | ម. | | ១ ០៨៩ | | | |

## ការងារជួសជុលក្រោយទឹកជំនន់

| ប្រភេទ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ (ត្រឹមខែសីហា) |
|---|---|---|---|---|---|---|
| ផ្លូវក្រាលកៅស៊ូ(AC/DBST) | គ.ម | ០,៣០០ | | ៣,៦៨០ | | |
| ស្ពានបាឡេ | ម. | | ៧៥,០០ | | | |

### ៣- ការងារអភិវឌ្ឍន៍ជនបទ

ដើម្បីចូលរួមក្នុងការអភិវឌ្ឍលើវិស័យហេដ្ឋារចនាសម្ព័ន្ធក្នុងជនបទ រដ្ឋបាលខេត្ត បានសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម បានអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងដំណាក់កាលទី៤ ប្រកបដោយចីរភាព ដែលសម្រេចលទ្ធផល ដូចខាងក្រោម៖

| ល.រ | បរិយាយ | ឯកតា | ឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | |
| ១ | ការសាងសង់ផ្លូវក្រាលកៅស៊ូ២ជាន់(DBST) | គ.ម. | ០០ | ១៧,៦ | ១៨,៣ | ១៨,៥ | ១២២,៩ | ១៨៧,៣ |
| ២ | ការសាងសង់ផ្លូវបេតុង | គ.ម. | ៤៥,៣ | ០,៧៥ | ៣,៧ | ៣,៤៥ | ៣០,២៤៨ | ៨៣,៤៤៨ |
| ៣ | ការសាងសង់ផ្លូវក្រាលក្រួសក្រហម | គ.ម. | ០០ | ១២ | ០០ | ០០ | ០០ | ១២ |
| ៤ | ការថែទាំផ្លូវជាលក្ខណៈខួប | គ.ម. | ៥៦,៧ | ៤០,១៣ | ៣៤,០៥ | ៣៥,៤ | ២៩,៦ | ១៩៥,៨៨ |
| ៥ | ការថែទាំផ្លូវជាលក្ខណៈប្រចាំ | គ.ម. | ៦៤,៩ | ១១៣,៩៣ | ១០៣,៦ | ៩៩,៣ | ១១៨,៨ | ៥០០,៥៣ |
| ៦ | ការសាងសង់ស្ពានបេតុង | កន្លែង | ០០ | ២ | ១ | ៣ | ០០ | ៦ |
| ៧ | ការសាងសង់លូកាត់ផ្លូវ | កន្លែង | ០០ | ២៨ | ១៩ | ១១ | ០០ | ៥៨ |
| ៨ | ការសាងសង់លូ | កន្លែង | ០០ | ០០ | ០០ | ០០ | ១៦ | ១៦ |

**គម្រោង និងសកម្មភាពផ្គត់ផ្គង់ទឹកជនបទ ឆ្នាំ២០១៨-២០២២**

| ល.រ | បរិយាយ | ឯកតា | ឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | |
| 1 | សាងសង់អណ្តូងស្នប់អាហ្វ្រីដេវ | អណ្តូង | ០០ | ១១៩ | ១១៩ | ១៦ | ១៥ | ២៦៩ |
| 2 | ជួសជុលអណ្តូងស្នប់អាហ្វ្រីដេវ | អណ្តូង | ៥០ | ៥០ | ៥០ | ០០ | ០០ | ១៥០ |
| 3 | សាងសង់អាងត្រង់ទឹកភ្លៀង ៣៥ម៣ | អាង | ០២ | ០០ | ០០ | ០០ | ០០ | ០២ |
| 4 | ការងារស្តារស្រះសហគមន៍ | ស្រះ | ០១ | ០១ | ០១ | ០០ | ០០ | ០៥ |
| 5 | ការងារស្តារប្រឡាយ | ម. | ០០ | ០០ | ៣ ០០០ | ៣ ៩៧០ | ៣ ៥០០ | ១០ ៤៧០ |

**គម្រោងនិងសកម្មភាពសាងសង់បង្គន់អនាម័យជនបទ ឆ្នាំ២០១៨-២០២២**

| ល.រ | ប្រភពថវិកា | ឯកតា | ឆ្នាំ | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | | | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | |
| 1 | គម្រោងរាជរដ្ឋាភិបាល | បង្គន់ | ១៥០ | ២១៥ | ២២៥ | ១៣៣ | ៥០ | ៧៧៥ |
| 2 | សហការជាមួយអង្គការលោកខាងលិចជួបលោកខាងកើត(EMW) | បង្គន់ | ៧៩១ | ៩៨១ | ៤៩៧ | ០០ | ០០ | ២ ២៦៩ |
| 3 | អង្គការស្អាតកម្ពុជា( Clear Cambodia) | បង្គន់ | ១៤ | ១១ | ០០ | ០០ | ០០ | ២៥ |
| 4 | អង្គការវ៉ាត់ជ័រសិត(Watershed) | បង្គន់ | ២ ៨៣៧ | ២ ១៩៨ | ០០ | ០០ | ០០ | ៥ ០៣៥ |
| 5 | World Hope International | បង្គន់ | ៤៤ | ៣៦ | ៩៥ | ០០ | ០០ | ១៧៥ |
| សរុប | | បង្គន់ | ៣ ៨៣៦ | ៣ ៤៤១ | ៨១៧ | ១៣៣ | ៥០ | ៨ ២៧៧ |

## ៤- ការងារទេសចរណ៍

### ស្ថិតិភ្ញៀវទេសចរណ៍ ដែលមកទស្សនាខេត្តកំពង់ចាម

| បរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| សរុបទេសចរជាតិ-អន្តរជាតិ | ៥២០ ១១១ | ៦៨២ ៩៨៤ | ៣៩២ ២៣០ | ២៤៣ ១៨៥ | ៧១៩ ៣៨៥ |
| ទេសចរជាតិមានចំនួន | ៥០៤ ៤៨២ | ៦៦០ ០១០ | ៣៨៤ ០២៩ | ២៤២ ៦០៦ | ៧១៨ ១៩៣ |
| ទេសចរអន្តរជាតិ | ១៥ ៦២៩ | ២២ ៩៧៤ | ៨ ២០១ | ៥៧៨ | ១ ១៩២ |

## ការងារគ្រប់គ្រងមូលដ្ឋានសេវាកម្មឧស្សាហកម្មទេសចរណ៍

| សណ្ឋាគារនិងផ្ទះសំណាក់... | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|
| **១-សណ្ឋាគារនិងសេវាផ្ទះស្នាក់ទេសចរណ៍** | | | | | |
| សណ្ឋាគារឬម៉ូតែល | ១៦ | ១៨ | ១៧ | ១៧ | ១៧ |
| ផ្ទះភ្ញៀវ(ផ្ទះសំណាក់) | ១២៣ | ១០៤ | ១១៦ | ១០៨ | ១០៨ |
| ផ្ទះស្នាក់ | | | | | |
| ផ្ទះមានបន្ទប់ជួលស្នាក់នៅ | ៣៩៥ | ៤១៦ | ២១៦ | ២១៦ | ២១៦ |
| **២-ភោជនីយដ្ឋានអាហារដ្ឋានទេសចរណ៍ សេវាម្ហូបអាហារ និងភេសជ្ជៈ** | | | | | |
| ភោជនីយដ្ឋាន | ១១ | ១០ | ២៥ | ៣២ | ៣៣ |
| អាហារដ្ឋាន | ៧៨ | ៨៦ | ១១២ | ១១១ | ១១២ |
| តូបលក់អាហារ | ១ | ១២ | ១៧ | ១៧ | ១៧ |
| ហាងគុយទាវ កាហ្វេ | ១០ | ១៣ | ៣៤ | ៣៤ | ៣៤ |
| **៣-មណ្ឌលកម្សាន្តមនុស្សពេញវ័យ** | | | | | |
| ខារ៉ាអូខេ | ៨៧ | ៦២ | ៦២ | ៦១ | ៦១ |
| ឌីស្កូតែក | ១ | ៤ | ៣ | ៣ | ៤ |
| បៀហ្គាឌិន | ២ | | ២ | ៣ | ២ |
| **៤-សេវាម៉ាស្សា ស្ប៉ាសុខភាព** | | | | | |
| ម៉ាស្សា | ១៩ | ២៣ | ២៥ | ២៤ | ២៤ |
| ស្ប៉ា | ១ | ២ | ២ | ២ | ២ |
| **៥-កីឡាទេសចរណ៍** | | | | | |
| ស្នូកឃ័រ | ៣ | ៤ | ៦ | ៦ | ៦ |
| **៦-រមណីយដ្ឋានទេសចរណ៍** | | | | | |
| រមណីយដ្ឋានប្រវត្តិសាស្ត្រ | | | ៤ | ៤ | ៤ |
| រមណីយដ្ឋានថ្នាក់កែច្នៃ | | ៣ | ៣ | ៣ | ៣ |
| រមណីយដ្ឋានថ្នាក់ធម្មជាតិ | | ១ | ៤ | ៤ | ៤ |
| **៧-ផ្សាររាត្រី** | | | | | |
| ក្រុងកំពង់ចាម | ១ | ១ | ១ | ១ | ១ |
| សរុប | **៧៤៨** | **៧៥៩** | **៦៤៩** | **៦៤៦** | **៦៤៨** |

## ស្ថិតិរមណីយដ្ឋានខេត្ត

ខេត្តកំពង់ចាម មានរមណីយដ្ឋានចំនួន១១កន្លែង/ទីតាំង(ទេសចរណ៍ប្រវត្តិសាស្ត្រវប្បធម៌៤កន្លែង ទេសចរណ៍ធម្មជាតិ វប្បធម៌៣កន្លែង និងរមណីយដ្ឋានកែច្នៃ៣កន្លែង ទេសចរណ៍ប្រវត្តិសាស្ត្រ ធម្មជាតិ វប្បធម៌ ១កន្លែង)។

| ល.រ | ឈ្មោះរមណីយដ្ឋាន | ទីតាំង | | | ចម្ងាយផ្លូវពីទីរួមខេត្ត | ប្រភេទរមណីដ្ឋាន | ការគ្រប់គ្រង |
|---|---|---|---|---|---|---|---|
| | | ភូមិ | ឃុំ-សង្កាត់ | ក្រុង/ស្រុក | | | |
| ១ | ភ្នំប្រុសភ្នំស្រី | ត្រពាំងចារ | ក្រឡា | កំពង់សៀម | ៧គ.ម | ប្រវត្តិសាស្ត្រ | រដ្ឋ |
| ២ | ប្រសាទនគរបាជ័យ | ជង្ហុក | អំពិលលើ | កំពង់សៀម | ២គ.ម | ប្រវត្តិសាស្ត្រ | រដ្ឋ |
| ៣ | ភ្នំហាន់ជ័យ | ហាន់ជ័យ | ហាន់ជ័យ | កំពង់សៀម | ២០គ.ម | ប្រវត្តិសាស្ត្រ | រដ្ឋ |
| ៤ | ភ្នំជើងព្រៃ | គោករវៀង | គោករវៀង | ជើងព្រៃ | ៥៥គ.ម | ប្រវត្តិសាស្ត្រ | រដ្ឋ |
| ៥ | ទឹកឆា | ថ្មដា | បឹងណាយ | ព្រៃឈរ | ៤៣គ.ម | ធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រ | រដ្ឋ |
| ៦ | ឆ្នេរខ្សាច់កោះប៉ែន | កោះប៉ែន ក | កោះមិត្ត | កំពង់សៀម | ១គ.ម | ធម្មជាតិ | វិនិយោគ |
| ៧ | បឹងធំ | ក្តីបឹង | វិហារធំ | កំពង់សៀម | ១៤គ.ម | ធម្មជាតិ | វិនិយោគ |
| ៨ | តំនប់តាកុជ | ភូមិកេះ(កើត) ភូមិអូរកណ្តុរ (លិច) | មៀនព្រែក ក្របៅ | ព្រៃឈរ កងមាស | ៣២ គ.ម | ធម្មជាតិ | រដ្ឋ |
| ៩ | នាគខ្មៅ | បែកអន្លូង | អារក្សត្នោត | ស្ទឹងត្រង់ | ៥៩គ.ម | កែច្នៃ | ឯកជន |
| ១០ | កសិទេសចរណ៍ថ្មដាទឹកឆា | ភូមិថ្មដា | បឹងណាយ | ព្រៃឈរ | ៤១គ.ម | កែច្នៃ (កសិទេសចរណ៍) | ឯកជន |
| ១១ | ហាន់ជ័យបែមប៉ូរីស៊ត | ភូមិព្រែកព្រះអណ្តូង | ព្រែកបាក់ | ស្ទឹងត្រង់ | ២០គ.ម | កែច្នៃ | ឯកជន |

## ៥- ការងារផ្គត់ផ្គង់ទឹកស្អាតទូទាំងខេត្ត

ខេត្តកំពង់ចាម មានទឹកស្អាតផ្នែកសាធារណៈចំនួន១មូលដ្ឋាន និងទឹកស្អាតផ្នែកឯកជនចំនួន៦០មូលដ្ឋាន សរុបចំនួន៦១មូលដ្ឋាន មានវិសាលភាពគ្របដណ្តប់នៅទូទាំងខេត្តបានចំនួន១០៧ ឃុំ/សង្កាត់ ស្មើនឹង៩៨,១៦% ដោយមានចំនួន៨៧៦ភូមិ ស្មើនឹង៩៥,៦៣% ក្នុងចំណោម៩១៦ភូមិ។ ក្នុងរយៈពេល៥ឆ្នាំ កន្លងមកនេះ ការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋនៅទូទាំងខេត្តកើនបានចំនួន២៥៥ភូមិ ស្មើនឹងប្រវែងបណ្តាញ១ ១៦៧គ.ម. ដោយមានប្រជាពលរដ្ឋសរុបបានប្រើប្រាស់ទឹកស្អាតកើនបាន៣២ ៣៧៤តំណ(គ្រួសារ) ក្នុងនោះ(១) ទឹកស្អាតផ្នែកឯកជនបានពង្រីកដាក់បណ្តាញថ្មីកើនបានចំនួន២៣៤ភូមិ ស្មើនឹងប្រវែងបណ្តាញ៩៩១គ.ម. ដោយមានប្រជាពលរដ្ឋទទួលបានទឹកស្អាតប្រើប្រាស់កើនបានចំនួន២៥ ៧៦៣តំណ(គ្រួសារ) និង(២) អង្គភាព រដ្ឋាករទឹកសាធារណៈបានពង្រីកបណ្តាញបន្ថែមកើនបាន២១ភូមិ ស្មើនឹងប្រវែងបណ្តាញ១៧៦គ.ម. ដោយមានប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រើប្រាស់កើនបាន៦ ៧១១តំណ(គ្រួសារ)។ បូកយោងការដាក់បណ្តាញបំពង់ផ្គត់ផ្គង់ទឹកស្អាតចែកជូនដល់ប្រជាពលរដ្ឋបូកយោងបានចំនួន៦៨៣ភូមិ ស្មើនឹង៧៤,៥៦% ដោយមានប្រជាពលរដ្ឋចំនួន៨៦ ៩៩៣គ្រួសារទទួលបានទឹកស្អាតប្រើប្រាស់ ស្មើនឹងចំនួន៣១,៧២% ក្នុងចំណោមប្រជាពលរដ្ឋសរុបចំនួន២៧៤,២៥៤គ្រួសារ។

| ការផ្គត់ផ្គង់ទឹកស្អាត | ភូមិ | ភូមិដែលមានការស្នើសុំ | | | | ភូមិមិនទាន់មានការស្នើសុំ | | គ្រួសារសរុប | ចំនួនគ្រួសារទទួលបានទឹកស្អាតប្រើប្រាស់ | |
|---|---|---|---|---|---|---|---|---|---|---|
| | | ភូមិមានបណ្តាញទឹកស្អាតទៅដល់ | | ភូមិមិនទាន់មានបណ្តាញទឹក ស្អាតទៅដល់ | | | | | | |
| | | ចំនួន | % | ចំនួន | % | ចំនួន | % | | ចំនួន | % |
| ទឹកស្អាតផ្នែកឯកជន | ៨៤៦ | ៦១៥ | ៧២,៦៩ | ១៩១ | ២១,០៦ | ៤០ | ៤,៧៣ | ២៥៣ ០៥៤ | ៧១ ១៦៧ | ២៨,១២ |
| ទឹកស្អាតផ្នែកសាធារណៈ | ៧០ | ៦៨ | ៩៥,៧១ | ២ | ៤,២៩ | | | ២១ ២០០ | ១៥ ៨២៦ | ៧៤,៦៥ |
| សរុប | **៩១៦** | **៦៨៣** | **៧៤,៥៦** | **១៩៣** | **២០,០៧** | **៤០** | **៤,៣៧** | **២៧៤ ២៥៤** | **៨៦ ៩៩៣** | **៣១,៧២** |

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ សេវាករទឹកស្អាតផ្នែកឯកជនបានតបណ្តាញទឹកស្អាតផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋចំនួន២៤៣ភូមិ ស្មើនឹងប្រវែងបណ្តាញ៩៩១គ.ម. ដោយមានប្រជាពលរដ្ឋទទួលបានទឹកស្អាតពីបំពង់ចំនួន២៥ ៧៦៣គ្រួសារ បូកយោងសេវាករបានដាក់បណ្តាញបានចំនួន៦១៥ភូមិ ស្មើនឹងប្រវែងបណ្តាញសរុប២ ៥២៤ គ.ម. និងមានប្រជាពលរដ្ឋសរុបចំនួន៧១ ១៦៧ គ្រួសារ ទទួលបានទឹកស្អាតប្រើប្រាស់ពីបំពង់ស្មើនឹង២៨,១២% ក្នុងចំណោមប្រជាពលរដ្ឋសរុបក្នុងតំបន់សេវាកម្មរបស់ខ្លួនចំនួន២៥៣ ០៥៤គ្រួសារ។

**សូមជូនក្រាហ្វិចបង្ហាញលម្អិតដូចខាងក្រោម**



ក្នុងរយៈពេល៥ឆ្នាំនេះ បានតបណ្ដាញទឹកស្អាតផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋបានចំនួន២១ភូមិ ស្មើនឹងប្រវែងបណ្ដាញ១៧៦គ.ម. ដោយមានប្រជាពលរដ្ឋទទួលបានទឹកស្អាតពីបំពង់ចំនួន៦,៧១១គ្រួសារ បូកយោងអង្គភាពបានដាក់បណ្ដាញបានចំនួន៦៨ភូមិ ស្មើនឹងប្រវែងបណ្ដាញសរុប៣៨៥គ.ម. និងមានប្រជាពលរដ្ឋសរុបចំនួន១៥,៨២៦គ្រួសារ ទទួលបានទឹកស្អាតប្រើប្រាស់ពីបំពង់ ស្មើនឹង៧៤,៦៤% ក្នុងចំណោមប្រជាពលរដ្ឋសរុបក្នុងតំបន់សេវាកម្មរបស់ខ្លួនចំនួន ២១,២០០ គ្រួសារ។

**សូមជូនក្រាហ្វិចបង្ហាញលម្អិតដូចខាងក្រោម**




## ៦- ការងារថាមពល

| បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ |
|---|---|---|---|---|---|---|
| **ស្ថិតិថាមពលអគ្គិសនី** | ក្រុមហ៊ុន/សេវាករ | ៣៦ | ៣៧ | ៣៧ | ៣៨ | ៣៨ |
| ភូមិភ្ជាប់បណ្ដាញអគ្គិសនី | ភូមិ | ៨៧០ | ៨៨៥ | ៩១៣ | ៩១៤ | ៩២១ |
| ប្រជាពលរដ្ឋប្រើប្រាស់ | គ្រួសារ | ១៥៨ ៨៩១ | ១៧២ ២០៣ | ១៨៦ ៨០២ | ២០១ ៣៣៧ | ២០៦ ១៣៧ |
| បរិមាណថាមពលសរុប | kwh | ២៨១ ៩៧០ ៨១២ | ៧៣៣ ៤៨៧ ៩៩១ | ៣៨៤ ០៣៧ ៨៩៨ | មិនមាន | មិនមាន |
| **ស្ថិតិស្ថានីយប្រេងឥន្ធនៈ** | ស្ថានីយ | ២០៨ | ២២៥ | ២៥០ | ២៧៩ | ៣០៤ |

| | | | | | | |
|---|---|---|---|---|---|---|
| ស្ថានីយឧស្ម័នឥន្ធនៈ | ស្ថានីយ | ៣ | ៣ | ៣ | ៤ | ៤ |
| ស្ថានីយរួមប្រេងនិងឧស្ម័នឥន្ធនៈ | ស្ថានីយ | ៦ | ៧ | ១៤ | ២២ | ២៤ |
| កន្លែងស្តុកប្រេងនិងឧស្ម័ន | ស្ថានីយ | ១ | ១ | ០ | ០ | ០ |

## ២.២៤- ខេត្តព្រៃវែង

**សមិទ្ធផលនិងស្នាដៃការងារសំខាន់ៗរបស់រដ្ឋបាលខេត្តព្រៃវែង សម្រេចបានដូចខាងក្រោម៖**

ខេត្តព្រៃវែង គឺជាខេត្តមួយក្នុងចំណោមរាជធានី ខេត្ត២៥ ដែលមានព្រំប្រទល់ខាងលិចទល់នឹងខេត្តកណ្តាល ខាងកើតទល់នឹងខេត្តស្វាយរៀងនិងខេត្តតៃនិញនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ខាងជើងទល់នឹងខេត្តកំពង់ចាមនិងខេត្តត្បូងឃ្មុំ និងខាងត្បូងទល់នឹងខេត្តឡុងអាននិងខេត្តដុងថាប់នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ ខេត្តព្រៃវែងស្ថិតនៅប៉ែកអាគ្នេយ៍នៃប្រទេសកម្ពុជា មានចម្ងាយ៩៥គ.ម. ពីរាជធានីភ្នំពេញ មានផ្លូវជាតិឆ្លងកាត់ចំនួន៣ខ្សែ គឺផ្លូវជាតិលេខ១ លេខ១១ និងលេខ៨។ ជាតំបន់វាលរាបនិងវាលទំនាប ស្របតាមដងទន្លេមេគង្គ និងមានទន្លេតូចចំនួន៣ខ្សែ។ ខេត្ត មានសក្តានុពលចម្បងលើវិស័យកសិកម្មដែលមានប្រជាពលរដ្ឋភាគច្រើនជាកសិករ។

| ល.រ | បរិយាយ | សរុប | ឯកតា |
|---|---|---|---|
| ១ | ផ្ទៃដីសរុប | ៤ ៨៨៣ | គ.ម.$^{២}$ |
| ២ | ចំនួនក្រុង ស្រុក | ១៣ | ក្រុង ស្រុក |
| ៣ | ចំនួនឃុំ សង្កាត់ | ១១៦ | ឃុំ សង្កាត់ |
| ៤ | ចំនួនភូមិ | ១ ១៤៩ | ភូមិ |
| ៥ | ចំនួនគ្រួសារ | ២៩៣ ៥១៧ | គ្រួសារ |
| ៦ | ចំនួនប្រជាពលរដ្ឋសរុប | ១ ២៦៣ ៩៩៣ | នាក់ |
| ៧ | ចំនួនស្ត្រីសរុប | ៦៥៣ ៥៥៤ | នាក់ |

**ការគ្រប់គ្រងប្រជាពលរដ្ឋ**

១៤- ពិធីបើកការដ្ឋានសាងសង់ស្ពានឆ្លងកាត់ទន្លេមេគង្គ ពីស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ទៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ និងផ្លូវតភ្ជាប់មានប្រវែង១ ១៣១ម. ទទឹង១៣,៥៦ម. ចំណាយថវិកា៥៧លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨។

១៥- ពិធីបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៨។

១៦- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដល់និស្សិត៤ ១៥៨នាក់(ស្រី២ ១២៥នាក់)នៃសាកលវិទ្យាល័យវេស្ទើន នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨។

១៧- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៥ ១៩៧នាក់ នៅតំបន់វត្តទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨។

១៨- ពិធីបិទសន្និសីទជាតិស្ដីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ«**មេរៀនបទពិសោធ បញ្ហាប្រឈម និងចក្ខុវិស័យទៅអនាគត**» នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨។

១៩- ពិធីគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **ឃុន ឈី** ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅគេហដ្ឋានសង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៨។

២០- ពិធីចូលជួបសម្ដែងការគួរសមនិងពិភាក្សាជាមួយសមាគមខ្មែរ ចិន នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨។

២១- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៧ ៨២៨នាក់ នៅឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨។

២២- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងទេសចរណ៍ ពិធីអបអរសាទរទិវាទីក្រុងស្អាតក្រោមប្រធានបទ«**ទីក្រុងស្អាតដើម្បីទាំងអស់គ្នា**» និងពិធីចែកជ័យលាភីទីក្រុងស្អាតលើកទី២ សម្រាប់ឆ្នាំ២០១៨-២០២១ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨។

២៣- ពិធីកាត់ឫសសីមាព្រះវិហារវត្តជ័យមង្គល(ហៅវត្តជ្រៃ) និងសម្ពោធសមិទ្ធផលនានា នៅឃុំព្រែករំដេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី១ ខែមីនា ឆ្នាំ២០១៨។

២៤- ពិធីសំណេះសំណាលជាមួយគ្រូពេទ្យស្ម័គ្រចិត្តយុវជន**សម្ដេចតេជោ** ៣ ៦០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០១៨។

២៥- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ២១ ១៩១នាក់ នៅតំបន់សេដ្ឋកិច្ចពិសេស ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៨។

២៦- ពិធីសម្ពោធឧបដ្ឋានសាលានិងសមិទ្ធផលនានា នៅវត្តឈូកវ៉ា សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៨។

២៧- ទិវាវប្បធម៌ជាតិ ៣មីនា លើកទី២០ ក្រោមប្រធានបទ«**យុវជន ដើម្បីវប្បធម៌ជាតិ**» និងពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេសលើកទី៤ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៨។

២៨- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៣ ៩៧១នាក់ នៅក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៨។

២៩- ពិធីអបអរសាទរទិវានារីអន្តរជាតិ ៨មីនា ខួបលើកទី១០៧ ក្រោមប្រធានបទ«**ស្ត្រីរួមគ្នារក្សាសន្តិភាពដើម្បីអភិវឌ្ឍន៍ជាតិ**» នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៨។

៣០- ពិធីបើកជាផ្លូវការបុណ្យទន្លេលើកទី៤ ក្រោមប្រធានបទ«**ទន្លេនៃសន្តិភាព មិត្តភាព និងនិរន្តរភាពទេសចរណ៍**» នៅក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីរសៀលថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨។

៣១- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ១ ដំណាក់កាលទី៤ ចំណាយថវិកា ២៣លានដុល្លារអាម៉េរិក ដែលជាជំនួយឥតសំណងរបស់ប្រទេសជប៉ុន នៅសង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨។

៣២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ពានកោះប៉ែន(ស្ពានកំពង់ត្រុំ ឆ្លងកាត់ទន្លេមេគង្គ) ប្រវែង ៧៧៩ម. ទទឹង៩,២០ម. ចំណាយថវិកាជាតិ១៣,៥៥លានដុល្លារអាម៉េរិក សាងសង់ដោយកងវិស្វកម្មនៃកងយោធពលខេមរភូមិន្ទ នៅឃុំកោះមិត្ត ស្រុកកំពង់សៀម ខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨។

៣៣- ពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១៨ ក្រោមប្រធានបទ«**វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ឧស្សាហូបនីយកម្មកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រទេសកម្ពុជា**» នៅសណ្ឋាគារសូហ៊ីលតែលភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨។

៣៤- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៥ ៧៦៣នាក់ នៅផ្លូវវែងស្រេង ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨។

៣៥- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៦-២០១៧ និងលើកទិសដៅឆ្នាំសិក្សា២០១៧-២០១៨ របស់ក្រសួងអប់រំ យុវជន និងកីឡា នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨។

៣៦- ពិធីប្រគល់សញ្ញាបត្រជូនអធិការអប់រំជំនាន់ទី២ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៤ គ្រូបង្រៀនកម្រិតឧត្តម(បរិញ្ញាបត្រ+១) ជំនាន់ទី២២ និងគ្រូបង្រៀនកម្រិតមូលដ្ឋានតាមប្រព័ន្ធពន្លឿនឆ្ពោះទៅកម្រិតបរិញ្ញាបត្រជំនាន់ទី១ សរុប១ ៦៣០នាក់(ស្រី៥៥០នាក់) នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨។

៣៧- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៧ និងលើកទិសដៅការងារ ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ នៅក្រសួងមហាផ្ទៃ កាលពីរសៀលថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨។

៣៨- ពិធីបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ១១ និងផ្លូវវាងប្រវែង៩៦,៤៨គ.ម. ពីអ្នកលឿង (ចំណុចប្រសព្វផ្លូវជាតិលេខ១) ខេត្តព្រៃវែង ដល់ថ្នល់ទទឹង(ចំណុចប្រសព្វផ្លូវជាតិលេខ៧) ខេត្តត្បូងឃ្មុំ ចំណាយថវិកា៩៤,១៥លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឃុំព្រែកណ្ដៀង ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨។

៣៩- ពិធីបើកការដ្ឋានសាងសង់កំណាត់ផ្លូវជាតិលេខ៥ ពីបាត់ដំបង ទៅសិរីសោភ័ណ ប្រវែង ៨៤,៧៤គ.ម. ចំណាយថវិកា១៨៥លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានពីរដ្ឋាភិបាលជប៉ុន នៅស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨។

៤០- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត២ ១២៥នាក់(ស្រី៧៥៩នាក់)នៃសាកលវិទ្យាល័យអាស៊ីអឺរ៉ុប នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨។

៤១- ពិធីបិទសន្និបាតសុខាភិបាលលើកទី៣៩ នៅសណ្ឋាគារសូហ៊ីលតែលភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨។

៤២- ពិធីសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ៣ ៤០១នាក់ ក្នុងរាជធានីភ្នំពេញ នៅមជ្ឈ-មណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០១៨។

៤៣- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត២ ៨៦០នាក់(ស្រី២ ៣២៣នាក់)នៃវិទ្យាស្ថានវ៉ាន់ដា នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៨។

៤៤- ពិធីបើកកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គ លើកទី៣ នៅខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៨។

៤៥- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដល់និស្សិត ៣ ១៨៧នាក់(ស្រី១ ៥៧៨នាក់)នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨។

៤៦- ពិធីពិសាបាយសាមគ្គីជាមួយសមាគមខ្មែរ ចិន ចំនួន៥ ៥០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៨។

៤៧- ពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវមូលនិធិគន្ធបុប្ផា នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨។

៤៨- ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត លើកទី៦ ក្រោមប្រធានបទ«**សាទរមរតកដូនតា**» នៅបរិវេណប្រាសាទអង្គរធំ ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៨។

៤៩- ពិធីបើកកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៧ និងការវាយតម្លៃសមិទ្ធផល៥ឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ នៅសណ្ឋាគារសូហ៊ីលតែលភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៨។

៥០- ពិធីសំណេះសំណាលជាមួយតំណាងសហជីព តាមរោងចក្រ សហគ្រាស គ្រឹះស្ថានសិក្សា តំណាងសមាគមបុគ្គលិកសិក្សា នៅរាជធានីភ្នំពេញ និងមកពីតាមខេត្ត ប្រមាណជាង៤ ០០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៨។

៥១- ពិធីសម្ពោធដាក់ឱ្យដំណើរការសណ្ឋាគារ**ផ្កាយ៥ រ៉ូយ៉ាល់ សេន កោះរ៉ុង** នៅសង្កាត់កោះរ៉ុង ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨។

៥២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ សាកលវិទ្យាល័យក្រចេះ នៅសង្កាត់អូរឫស្សី ក្រុងក្រចេះ ខេត្តក្រចេះ កាលពីព្រឹកថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨។

៥៣- ពិធីប្រគល់វិញ្ញាបនបត្រដល់សិស្សថ្នាក់វិជ្ជាជីវៈ និងពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត១ ៩៦៣នាក់(ស្រី៨៧៣នាក់) នៃសាកលវិទ្យាល័យធនធានមនុស្ស នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨។

៥៤- ពិធីអបអរសាទរទិវាពលកម្មអន្តរជាតិ ១ឧសភា ឆ្នាំ២០១៨ លើកទី១៣២ ជាមួយនិយោជិត កម្មករ កម្មការិនី ៥ ៥១៥នាក់ នៅតំបន់សេដ្ឋកិច្ចពិសេស ក្នុងសង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៨។

៥៥- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៧-២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៨-២០១៩ នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីរសៀលថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៨។

៥៦- ពិធីសំណេះសំណាលនិងពិសាបាយសាមគ្គីជាមួយថ្នាក់ដឹកនាំគ្រិស្តបរិស័ទ៣ ៥០០នាក់ ក្រោមប្រធានបទ«**ដើម្បីសុខដុមនីយកម្ម វិស័យគ្រិស្តសាសនានៅកម្ពុជា**» នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៨។

៥៧- ពិធីសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ៣ ៩០០នាក់ មកពីខណ្ឌទួលគោក ព្រែកព្នៅ ពោធិ៍សែនជ័យ និងខណ្ឌសែនសុខ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៨។

៥៨- ពិធីបើកការដ្ឋានគម្រោងពង្រីកនិងលើកកម្រិតកំណាត់ផ្លូវជាតិលេខ៣ ប្រវែង១៣៤,៨២គ.ម. ចាប់ពីភ្នំពេញ(ចោមចៅ) ដល់ក្រុងកំពត ខេត្តកំពត ចំណាយថវិកា២១៩,៩១១លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅសង្កាត់ក្លើងធេះរទេះ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៨។

៥៩- ពិធីប្រារព្ធទិវាកាកបាទក្រហមពិភពលោក អង្គ្លួចន្ទក្រហម ៨ឧសភា ឆ្នាំ២០១៨ លើកទី១៥៥ ក្រោមប្រធានបទ«**កាកបាទក្រហមកម្ពុជាមានគ្រប់ទីកន្លែងសម្រាប់គ្រប់ៗគ្នា ដោយមិនទុកនរណាម្នាក់ចោល**» នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា កាលពីព្រឹកថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៨។

៦០- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី២៨ ៤៨៤នាក់ នៅសង្កាត់ប្រកម្ទេស ក្រុងបាវិត ខេត្តស្វាយរៀង កាលពីព្រឹកថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៨។

៦១- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៩ ៤៨៩នាក់ នៅតំបន់សេដ្ឋកិច្ចពិសេស ក្រុងបាវិត ខេត្តស្វាយរៀង កាលពីព្រឹកថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨។

៦២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារមិត្តភាព កម្ពុជា កូរ៉េ នៃមន្ទីរពេទ្យកុមារជាតិ ចំណាយថវិកា៧,២៨លានដុល្លារអាម៉េរិក ដែលជាអំណោយរបស់រដ្ឋាភិបាលនិងប្រជាជនកូរ៉េ នៅមន្ទីរពេទ្យកុមារជាតិ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៨។

៦៣- ពិធីបិទសន្និបាតជាតិវិស័យសកម្មភាពមីននិងការប្រកាសដាក់ឱ្យដំណើរការផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ឆ្នាំ២០១៨-២០២៥ នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីរសៀលថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨។

៦៤- ពិធីដាំកូនឈើនៅក្នុងឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា **តេជោសែន ឫស្សីត្រឹប** នៅឃុំឆែប១ និងឃុំឆែប២ ស្រុកឆែប ខេត្តព្រះវិហារ កាលពីព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៨។

៦៥- ពិធីបើកការដ្ឋានសាងសង់កំណាត់ផ្លូវជាតិលេខ៥ ប្រវែង១៣៥,២៤គ.ម. ចាប់ពីព្រែកក្ដាម ស្រុកពញាឮ ខេត្តកណ្ដាល ដល់ថ្លាម្អម ស្រុកក្រគរ ខេត្តពោធិ៍សាត់ ចំណាយថវិកា២៦១លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលជប៉ុននិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង កាលពីព្រឹកថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៨។

៦៦- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត៣ ៣៥៩នាក់ (ស្រី១ ៥៩៤នាក់)នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨។

៦៧- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៩ ៩៥៩នាក់ នៅភូមិបុរីកម្មករ សង្កាត់ច្បារមន ក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨។

៦៨- ពិធីថ្វាយគោរមងារនិងពិធីស្រោចស្រពព្រះសុគន្ធវារី ប្រគេនព្រះពុទ្ធវង្ស **ជា សំអាង** ព្រះមេគណខេត្តកណ្ដាល ជាសម្ដេចព្រះឧត្តមមុនី ព្រះមុនីកោសល **ឃឹម សន** ព្រះមេគណរាជធានីភ្នំពេញ ជាសម្ដេចព្រះពុទ្ធជ័យមុនី និងព្រះសាក្យវង្ស **រ័ត្ន សារឿន** ព្រះអនុគណខណ្ឌសែនសុខ ជាសម្ដេចព្រះសាក្យមុនី ដែលបានប្រារព្ធធ្វើនៅវត្តបទុមវតី រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨។

៦៩- ពិធីបើកការប្រកួតកីឡាជាតិលើកទី២ នៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨។

៧០- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារវឌ្ឍនៈ កាពីតាល់ និងរ៉ូសវូដ មានកម្ពស់៣៩ ជាន់ នៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨។

៧១- ពិធីស្រាយបួសខែ រ៉ាម៉ាឌន នៃសាសនាអ៊ិស្លាមកម្ពុជា លើកទី៥ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨។

៧២- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៦ ៤៧៤នាក់ នៅឃុំសិត្បូ ស្រុកស្អាង និងស្រុកកោះធំ ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨។

៧៣- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការរោងចក្រផលិតស៊ីម៉ងត៍បាត់ដំបង ខនស៍ស៊ីមេន លីមីធីត នៅឃុំស្ពោ ស្រុករតនមណ្ឌល ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨។

៧៤- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារទីស្នាក់ការគណបក្សប្រជាជនកម្ពុជា ស្រុកត្បូងឃ្មុំ នៅឃុំដីពាំទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៨។

៧៥- ពិធីប្រារព្ធខួបលើកទី១១ ទិវាអតីតយុទ្ធជនកម្ពុជា ២១មិថុនា ឆ្នាំ២០១៨ ចំនួន២ ៥០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨។

៧៦- ពិធីបិទការប្រកួតកីឡាជាតិលើកទី២ នៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៨។

៧៧- ពិធីបិទវគ្គប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រជូនសិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការ កម្មសិក្សាការី ឆ្នាំ២០១៧ សរុប៥៦៧នាក់ និងពិធីបើកវគ្គបណ្តុះបណ្តាលឆ្នាំ២០១៨ របស់សាលាភូមិន្ទរដ្ឋបាល នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៨។

៧៨- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី២១ ៩៧០នាក់ នៅឃុំខ្នុរដំបង ស្រុកជើងព្រៃ ខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៨។

៧៩- ពិធីស្រាយបួស ខែរ៉ាម៉ាឌន នៃសាសនាអ៊ិស្លាមកម្ពុជា៤ ៧៥០នាក់ នៅវិហារអាល់សាកាល់ (បឹងកក់) សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៨។

៨០- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការកំណាត់ផ្លូវជាតិលេខ៦ ប្រវែង២៤៨,៥៣គ.ម. ចាប់ពីថ្នល់កែង ខេត្តកំពង់ចាម ដល់អង្គ្រង ខេត្តសៀមរាប ចំណាយថវិកា២៥៥,០២លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីព្រឹកថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨។

៨១- ពិធីប្រកាសគោរមងារវិទ្យាសាស្ត្រ គោរមងារកិត្តិយសនិងការតែងតាំងសមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជាជូនឥស្សរជន៨នាក់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨។

៨២- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៧ ៧៦៧នាក់ នៅសង្កាត់រកាក្រៅ ក្រុងដូនកែវ ខេត្តតាកែវ កាលពីព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨។

៨៣- ពិធីសម្ពោធសមិទ្ធផលនានា ក្នុងទីបញ្ជាការដ្ឋានអង្គរក្ស នៅទីបញ្ជាការដ្ឋានអង្គរក្សទួលក្រសាំង ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨។

៨៤- ពិធីបិទសន្និសីទជាតិលើកទី២ ស្តីពី«**កិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក លើអ្នកជំនាញទេសចរណ៍អាស៊ាន**» ចំនួន១ ០០០នាក់ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨។

៨៥- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត៣ ២៣៣នាក់ (ស្រី១ ៥០៨នាក់) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨។

៨៦- ពិធីសម្ពោធដាក់ឱ្យដំណើរការសួនសត្វភ្នំពេញសាហ្វារី នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៨។

៨៧- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការចំណតកំពង់ផែពហុបំណង នៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ចំណាយថវិកា៧៤លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលជប៉ុននិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨។

៨៨- ពិធីកាត់ឫសសីមាព្រះវិហារ សម្ពោធសមិទ្ធផលនានាក្នុងវត្តព្រះឥន្ទសាមគ្គីធម៌ និងពិធីស្រោចស្រពព្រះសុគន្ធវារី ប្រគេនសម្តេចព្រះសង្ឃនាយករង២ព្រះអង្គនៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រារព្ធធ្វើនៅវត្តព្រះឥន្ទសាមគ្គីធម៌ ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨។

៨៩- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី២៤ ៣៧៥នាក់ នៅឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨។

៩០- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ២១ ៤៦៥នាក់ នៅឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីព្រឹកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។

៩១- ពិធីបើកការដ្ឋានសាងសង់ស្ពានអាកាសនិងផ្លូវក្រោមដីរង្វង់មូលចោមចៅ ចំណាយថវិកាជាតិ២២លានដុល្លារអាម៉េរិក នៅសង្កាត់ចោមចៅទី៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨។

៩២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ពានអាកាសមិត្តភាពកម្ពុជា ចិន សែនសុខ ប្រវែង ៩៤២ម. ទទឹង១៦,៥០ម. ចំណាយថវិកា១៧លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅសង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨។

៩៣- ពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី៦០ នៃការបង្កើតទំនាក់ទំនងការទូតកម្ពុជា ចិន នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨។

៩៤- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី២៧ ៤២៧នាក់ នៅឃុំធក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៨។

៩៥- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី២៧ ៥២៩នាក់ នៅឃុំធក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១៨។

៩៦- ពិធីអបអរសាទរខួប១០ឆ្នាំ នៃប្រាសាទព្រះវិហារ និងខួប១ឆ្នាំ នៃតំបន់ប្រាសាទសម្បូរព្រៃគុក ដែលបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ប្រារព្ធធ្វើនៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៨។

៩៧- ពិធីចុះទស្សនកិច្ចចង្វាក់ផលិតកម្មរោងចក្រ ថប សាមីត ហ្គាមេន អ៊ីន ដែលមានកម្មករ កម្មការិនីបម្រើការងារ៣ ៨៧២នាក់ នៅសង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៨។

៩៨- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការចំណតនាវាដឹកជញ្ជូនអ្នកដំណើរ ពីខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទៅដល់ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ២០១៨។

៩៩- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៤ ៩៧៧នាក់ នៅតំបន់លូប្រាំ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែសីហា ឆ្នាំ២០១៨។

១០០- ពិធីសំណេះសំណាលជាមួយអត្តពលិក កីឡាករ កីឡាការិនី គ្រូបង្វឹក និងប្រតិភូកីឡា៧១នាក់ មុននឹងទៅចូលរួមការប្រកួតកីឡាអាស៊ីលើកទី១៨ នៅប្រទេសឥណ្ឌូណេស៊ី ប្រារព្ធធ្វើនៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៨។

១០១- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៨ ៤៦៧នាក់ នៅតំបន់ផ្លូវជាតិលេខ៤ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៨។

១០២- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៥ ៣៦៨នាក់ នៅតំបន់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨។

១០៣- ពិធីពិគ្រោះនិងផ្តល់យោបល់លើកដំបូងជាមួយប្រធាន និងតំណាងគណបក្សនយោបាយចំនួន១៦ គណបក្សនយោបាយ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨។

១០៤- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៧ ៥០៣នាក់ នៅឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨។

១០៥- ពិធីពិភាក្សាការងារជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា២៨នាក់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨។

១០៦- ពិធីសំណេះសំណាលនិងសម្តែងការគួរសមរបស់គណៈប្រតិភូសហព័ន្ធពាណិជ្ជករចិនទាជីវសកលលោកនិងសមាគមសម្ព័ន្ធខ្មែរ-ចិន នៅកម្ពុជា៧២នាក់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨។

១០៧- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៤ ៧៩៩នាក់ នៅតំបន់ផ្លូវវែងស្រេង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨។

១០៨- ពិធីស្វាគមន៍អបអរកីឡាករ សាលី អ៊ូមើត ដែលទទួលបានមេដាយមាស១គ្រឿង សំរឹទ្ធ១គ្រឿង និងកីឡាការិនី ខាន់ ចេសា ទទួលបានមេដាយមាស១គ្រឿង ពីការប្រកួតកីឡាអាស៊ីលើកទី១៨ នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី ប្រារព្ធធ្វើនៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១៨។

១០៩- ពិធីបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកដំបូង នីតិកាលទី៦នៃរដ្ឋសភា នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨។

១១០- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី២៧ ៤៤៤នាក់ នៅឃុំពពេល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨។

១១១- ពិធីគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **នៃ ម៉េណា** អនុប្រធានទី១ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅភូមិគ្រឹះបុរី ប៉េង ហួត សង្កាត់និរោធន៍ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែតុលា ឆ្នាំ២០១៨។

១១២- ពិធីអបអរសាទរទិវាគ្រូបង្រៀន ៥តុលា ឆ្នាំ២០១៨ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៨។

១១៣- ពិធីចូលជួបសម្តែងការគួរសមនិងផ្តល់អនុសាសន៍ដល់ប្រតិភូនាវាយុវជនអាស៊ីអាគ្នេយ៍ កម្ពុជា២៩នាក់ មុននឹងទៅចូលរួមកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍និងជប៉ុនលើកទី៤៥ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨។

១១៤- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី៦ ៧៨៥នាក់ នៅឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨។

១១៥- ពិធីបើកសន្និសីទអន្តរជាតិថ្នាក់តំបន់ស្តីពីការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយនិងអន់គុណភាព នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

១១៦- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី២៣ ០០០នាក់ នៅឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ កាលពីព្រឹកថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៨។

១១៧- ពិធីសំណេះសំណាលនិងផ្តល់ប្រាក់រង្វាន់ លើកទឹកចិត្តដល់សិស្សប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ ឆ្នាំ២០១៨ ទទួលបាននិទ្ទេសA មាន៤០៨នាក់(ស្រី១៩៤នាក់) នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

១១៨- ពិធីចុះសួរសុខទុក្ខនិងសំណេះសំណាលជាមួយកុមារពិការភ្នែក គ ថ្លង់ នៅអង្គការគ្រួសារថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

១១៩- ពិធីបិទមហាសន្និបាតតំណាងទូទាំងប្រទេសលើកទី៤ របស់សហភាពសហព័ន្ធយុវជនកម្ពុជា នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨។

១២០- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៧ ៩១២នាក់ នៅឃុំសៀមរាប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

១២១- ពិធីអបអរសាទរខួបលើកទី២៥ឆ្នាំ នៃការបង្កើតគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍន៍តំបន់រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ(ICC) នៅសណ្ឋាគារសុខាអង្គរ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨។

១២២- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៧ ៦២១នាក់ នៅឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨។

១២៣- ពិធីបើកបុណ្យសមុទ្រឆ្នាំ២០១៨ លើកទី៧ ក្រោមប្រធានបទ«**ឆ្នេរស្អាត ពលរដ្ឋរមណីយ**» នៅខេត្តកោះកុង កាលពីល្ងាចថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៨។

១២៤- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការវារីអគ្គិសនីសេសានក្រោម២ មានអានុភាព៤០០ មេហ្កាវ៉ាត់ នៅឃុំស្រែគ និងឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង កាលពីព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨។

១២៥- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី ១៥ ៦០៦នាក់ នៅឃុំផ្សារដែក ស្រុកពញាឮ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨។

១២៦- ពិធីសម្ពោធវិមានអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ និងខួបលើកទី២០ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយឈ្នះ ឈ្នះ នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៨។

១២៧- ពិធីប្រគល់ពានរង្វាន់ដល់ជ័យលាភីកីឡាវាយកូនគោល នៅសណ្ឋាគារហ្គាឌិនស៊ីធី សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨។

១២៨- ពិធីអបអរសាទរបុណ្យចូលឆ្នាំសកលឆ្នាំ២០១៩ នៅវិមានអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

**ក្រៅពីនេះ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រីដែលជាតំណាងរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា៖**

***ក- សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងសាធារណការនិងដឹកជញ្ជូននៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨។

២- ពិធីបូកសរុបលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោក ឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក នៅក្រសួងមហាផ្ទៃ កាលពីរសៀលថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨។

៣- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារគ្រឿងញៀនឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅក្រសួងមហាផ្ទៃ កាលពីរសៀលថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨។

៤- ពិធីបញ្ចុះបឋមសិលាសាងសង់អគារថ្មីនៃមន្ទីរពេទ្យបង្អែក ខេត្តបាត់ដំបង ចំណាយថវិកា១៥លានដុល្លារអាម៉េរិក ដែលជាជំនួយឥតសំណងរបស់ប្រទេសជប៉ុន នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨។

៥- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវលេខ១៥៧៧ ប្រវែងសរុប៥១,៨០គ.ម. ចាប់ពីភូមិភ្ជាវ ឃុំគ្រែង ស្រុករតនមណ្ឌល ដល់ភូមិធករកា ឃុំសំឡូត ស្រុកសំឡូត(ច្រកទ្វារព្រំដែន៤០០) ខេត្តបាត់ដំបង ចំណាយថវិកា៣៨,២១១លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិននិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានប្រារព្ធនៅឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី២ ខែមេសា ឆ្នាំ២០១៨។

៦- ពិធីកាត់ឫសសីមាព្រះវិហារវត្តសិរីវឌ្ឍ(ហៅវត្តព្រែកផ្តៅ) នៅឃុំព្រែកអន្ទះ ស្រុកពោធិ៍រៀង ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៨។

៧- ពិធីកាត់ឫសសីមាព្រះវិហារវត្តសិរីសារពេជ្ជ ហៅវត្តតាគោក នៅឃុំល្វា ស្រុកព្រះស្តេច ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៨។

៨- ពិធីកាត់ឫសសីមាព្រះវិហារវត្តកណ្តាលមានជ័យ ឃុំព្រៃរំដេង ស្រុកមេសាង ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨។

៩- ពិធីឆ្លងមហាកុដិនិងសមិទ្ធផលនានា ក្នុងវត្តពារាណសី សិរីមង្គល នៅឃុំពួន ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៨។

**ខ- សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីជូនដំណើរកងវិស្វកម្មលេខ៩៦៣ ចំនួន១៨៤នាក់ ចូលរួមបេសកកម្មរក្សាសន្តិភាពក្រោមឆត្របស់អង្គការសហប្រជាជាតិនៅសាធារណរដ្ឋលីបង់ និងទទួលដំណើរនិវត្តន៍កងវិស្វកម្មលេខ៣៦៩ ចំនួន១៨៤នាក់ និងកងវិស្វកម្មលេខ៤៥៩ ចំនួន២១៦នាក់ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅសាធារណរដ្ឋលីបង់និងអាហ្វ្រិកខាងត្បូង នៅមូលដ្ឋានកងទ័ពអាកាសពោធិ៍ចិនតុង រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨។

២- ពិធីកាត់ឫសសីមាព្រះវិហារវត្តបឹងខ្នារ ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង កាលពីព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៨។

៣- ពិធីប្រារព្ធខួប៤១ឆ្នាំ«**ទិវាចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត**» នៅសាលាបឋមសិក្សា **ហ៊ុន សែន កោះថ្ម** ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៨។

៤- ពិធីរំលឹកខួបអនុស្សាវរីយ៍លើកទី៣០ ថ្ងៃបង្កើតយោធភូមិភាគទី៥«**២៨-៦-១៩៨៨/ ២៨-៦-២០១៨**» នៅសង្កាត់ព្រែកព្រះស្តេច ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨។

៥- ពិធីប្រារព្ធទិវាមច្ឆជាតិ ១កក្កដា ឆ្នាំ២០១៨ លើកទី១៦ នៅកសិណអង្គរវត្ត សង្កាត់គោកចក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៨។

៦- ពិធីទទួលដំណើរនិវត្តន៍កងកម្លាំងវិស្វកម្មព្រលានយន្តហោះលេខ១៨៩ កងកម្ទេចគ្រាប់មិនទាន់ផ្ទុះលេខ១២៣ និងកងរាជអាវុធហត្ថលេខ៦១៩ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅសាធារណរដ្ឋម៉ាលីនិងសាធារណរដ្ឋស៊ូដង់ខាងត្បូង ប្រារព្ធធ្វើនៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីរសៀលថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨។

៧- ពិធីទទួលដំណើរនិវត្តន៍កងវិស្វកម្មលេខ៩៥៤ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល នៅអាកាសយានដ្ឋានទ័ពអាកាសពោធិ៍ចិនតុង រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៨។

៨- ពិធីហោះហើរបង្ហាញឧទ្ធម្ភាគចក្រ នៅអាកាសយានដ្ឋានទ័ពអាកាសពោធិ៍ចិនតុង រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨។

**គ- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីជួបសំណេះសំណាលនិងផ្តល់រង្វាន់ជ័យលាភីជូនអត្តពលិកជនពិការដែលទទួលបានមេដាយប្រាក់២១គ្រឿង មេដាយសំរឹទ្ធិ៥គ្រឿង និងគ្រូបង្វឹក គ្រូជំនួយ ត្រឡប់មកពីការប្រកួតអាស៊ាន ប៉ារ៉ាហ្គេម លើកទី៩ នៅប្រទេសម៉ាឡេស៊ី នៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០១៨។

២- ពិធីប្រកាសចូលកាន់តំណែងអនុប្រធានទី១ និងអគ្គលេខាធិការរងនៃអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន នៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីរសៀលថ្ងៃទី៩ ខែមករា ឆ្នាំ២០១៨។

៣- ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារអាកាសចរណ៍ស៊ីវិលឆ្នាំ២០១៣-២០១៧ និងលើកទិសដៅការងារ ឆ្នាំ២០១៨-២០២៣ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨។

៤- ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម នៅក្រសួងឧស្សាហកម្មនិងសិប្បកម្ម កាលពីព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨។

៥- ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៦-២០១៧ និងលើកទិសដៅឆ្នាំសិក្សា២០១៧-២០១៨ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា កាលពីព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៨។

៦- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ សារមន្ទីរធម្មជាតិសកល **សម្តេចតេជោ ហ៊ុន សែន ព្រះវិហារ** នៅឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ កាលពីព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨។

៧- ពិធីបើកនិងបិទកិច្ចប្រជុំស្តីពីការគ្រប់គ្រងប្រព័ន្ធចរាចរណ៍នាំផ្លូវអាកាសអាស៊ីខាងត្បូងឥណ្ឌា លើកទី៨ និងកិច្ចប្រជុំស្តីពីក្រុមការងារសម្របសម្រួលប្រព័ន្ធត្រួតពិនិត្យចរាចរនាំផ្លូវអាកាសក្នុងតំបន់អាស៊ីអាគ្នេយ៍ លើកទី២៥ នៅសណ្ឋាគារសុខាល័យអង្គរ រីសត ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី២៦ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨។

៨- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ៥ឆ្នាំ និងលើកទិសដៅការងាររបស់វិស័យមុខងារសាធារណៈ នៅសណ្ឋាគារសុខា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨។

៩- ពិធីទិវាជនមានពិការភាពកម្ពុជាលើកទី២០ និងជនមានពិការភាពអន្តរជាតិលើកទី៣៦ ឆ្នាំ២០១៨ ក្រោមប្រធានបទ«**លើកកម្ពស់សិទ្ធិជនមានពិការភាពជានាដល់ការធ្វើបរិយាបន្ននិងសមភាព**» នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៨។

១០- ពិធីបិទអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៧ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៨។

**ឃ- លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីសំពះគ្រូនិងការតាំងពិព័រណ៍មិនអចិន្ត្រៃយ៍ ស្តីពីគ្រឿងអលង្ការនិងការតុបតែងលម្អខ្មែរសម័យបុរាណ នៅសារមន្ទីរជាតិ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៤ ខែមករា ឆ្នាំ២០១៨។

២- ពិធីសម្ពោធឆ្លងប្រាសាទ **នាគរាជតេជោមរតក** និងសមិទ្ធផលនានា ក្នុងវត្តប្រាសាទត្រាំនាគនៅសង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៨។

៣- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារវប្បធម៌និងវិចិត្រសិល្បៈ ឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នៅសាលសន្និសីទចតុម្មុខ រាជធានីភ្នំពេញ កាលពីរសៀលថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៨។

៤- ពិធីបិទការប្រឡងសូត្រគម្ពីរអាល់គួរអានុការីមថ្នាក់ជាតិទូទាំងប្រទេសលើកទី២៧ ឆ្នាំ២០១៨ នៅវិហារអ៊ិស្លាម ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត កាលពីរសៀលថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៨។

៥- ពិធីអបអរសាទរខួបលើកទី៦៩ ទិវាកុមារអន្តរជាតិ ១មិថុនា ខួបលើកទី១៧ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ២០១៨ ចំនួន២ ៥០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨។

៦- ពិធីសំណេះសំណាលជាមួយអាចារ្យ អាចារិនី១ ០០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៨។

**ង- ឯកឧត្តម ឃឹម នៃលី ឧបនាយករដ្ឋមន្ត្រី** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីប្រកាសជាផ្លូវការកម្មវិធីលុបបំបាត់ភាពងងឹតភ្នែកដោយសារជំងឺភ្នែកឡើងបាយ ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន នៅមន្ទីរពេទ្យខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨។

២- ពិធីបញ្ចុះបឋមសិលាសាងសង់អគារមន្ទីរពេទ្យមិត្តភាពកម្ពុជា ចិន ព្រះកុសុមៈ ចំណាយថវិកា ៥៥០លានយ៉ន់ ស្មើនឹងប្រមាណ៨០លានដុល្លារអាម៉េរិក ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមា-និតចិន នៅក្នុងបរិវេណមន្ទីរពេទ្យមិត្តភាពកម្ពុជា ចិន ព្រះកុសុមៈ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨។

៣- ទិវាពិភពលោកប្រយុទ្ធប្រឆាំងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៨ ក្រោមប្រធានបទ«**យើងប្តេជ្ញារួមគ្នាបញ្ចប់បញ្ហាអេដស៍នៅឆ្នាំ២០២៥**» នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៨។

## ឆ្នាំ២០១៩

១- ពិធីចូលជួបសម្តែងការគួរសមនៃសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា១០៥នាក់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២ ខែមករា ឆ្នាំ២០១៩។

២- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៨ ២៧៣នាក់ នៅឃុំពពេល ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីព្រឹកថ្ងៃទី៩ ខែមករា ឆ្នាំ២០១៩។

៣- ពិធីសំណេះសំណាលនិងពិសាបាយសាមគ្គីលើកទី៣ ជាមួយអ្នកសារព័ត៌មានប្រមាណ៤ ៥០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩។

៤- ពិធីបើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុងខ្សែទី៣(ផ្លូវជាតិលេខ៤ ផ្លូវជាតិលេខ១)ប្រវែង៥០,៩៧ គ.ម. ចំណាយថវិកាប្រមាណ២៧៣លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមា-និតចិននិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅផ្លូវជាតិលេខ២ សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩។

៥- ពិធីប្រកាសជាផ្លូវការក្រុមប្រឹក្សាវប្បធម៌អាស៊ី នៅទីលានជល់ដំរី ក្រុងសៀមរាប ខេត្តសៀមរាប កាលពីរាត្រីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩។

៦- ពិធីប្រារព្ធខួប២០ឆ្នាំនៃថ្ងៃបង្កើតបញ្ជាការដ្ឋានកងទ័ពជើងគោកនៃកងយោធពលខេមរភូមិន្ទ នៅបញ្ជាការដ្ឋានកងទ័ពជើងគោក សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩។

៧- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១១ ៧៣៨នាក់ នៅឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត កាលពីព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩។

៨- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៩។

៩- កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩។

១០- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១១ ២២៧នាក់ នៅឃុំចក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩។

១១- ពិធីអបអរសាទរទិវាទីក្រុងស្អាតលើកទី៧ ឆ្នាំ២០១៩ ក្រោមប្រធានបទ«**ទីក្រុងស្អាត ទីក្រុងផ្តល់ភាពកក់ក្តៅ**» នៅសណ្ឋាគារសុខាភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩។

១២- ពិធីបើកកិច្ចប្រជុំឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់លើកទី១ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩។

១៣- ពិធីបញ្ចុះបឋមសិលាសាងសង់មន្ទីរពេទ្យមិត្តភាពកម្ពុជា ចិន ត្បូងឃ្មុំ ចំណាយថវិកាប្រមាណ៥០លានដុល្លារអាម៉េរិក ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន នៅក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១ ខែមីនា ឆ្នាំ២០១៩។

១៤- ពិធីបើកកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៧ ស្តីពីកិច្ចព្រមព្រៀង ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយថ្នាក់តំបន់ នៅសណ្ឋាគារសុខា ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០១៩។

១៥- ពិធីបើកការដ្ឋានសាងសង់សំណង់ផ្សេងៗក្នុងគម្រោងការពារទឹកជំនន់និងកែលម្អប្រព័ន្ធប្រឡាយ លូ ក្នុងរាជធានីភ្នំពេញជំហានទី៤ ចំណាយថវិកាប្រមាណ៣០លានដុល្លារអាម៉េរិក ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន នៅខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៩។

១៦- ពិធីអបអរសាទរទិវាអន្តរជាតិនារី៨មីនា ខួបលើកទី១០៨ ក្រោមប្រធានបទ«**លើកកម្ពស់យេនឌ័រ និងការគាំពារសង្គមដើម្បីអភិវឌ្ឍធនធានមនុស្ស**» នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៩។

១៧- ពិធីអបអរសាទរទិវាវប្បធម៌ជាតិ៣មីនា លើកទី២១ ក្រោមប្រធានបទ«**យុវជនដើម្បីវប្បធម៌ជាតិ**» និងពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំទី៥ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៩។

១៨- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារការបរទេសឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ នៅទីស្តីការក្រសួងការបរទេសនិងសហប្រតិ-បត្តិការអន្តរជាតិ កាលពីព្រឹកថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៩។

១៩- ពិធីសំណេះសំណាលនិងពិសាអាហារជាមួយអ្នកប្រកបមុខរបរជាក់ស៊ីក្លូ៣២០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែមីនា ឆ្នាំ២០១៩។

២០- ពិធីសំណេះសំណាលសួរសុខទុក្ខជាមួយគ្រូ យុវនារី និងកុមារីរងគ្រោះនៅ«**មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈនិងស្តារនីតិសម្បទាយុវនារី អាហ្វេស៊ីប (AFESIP) ទំនី**» នៅសង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៩។

២១- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត៣ ០៤៣នាក់ (ស្រី១ ៤១២នាក់)នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩។

២២- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារសុខាភិបាលឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងសុខាភិបាល នៅសណ្ឋាគារសូហ្វីលតែល ភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩។

២៣- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១៣ ៨៦៦នាក់ នៅតំបន់សេដ្ឋកិច្ចពិសេស ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩។

២៤- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩។

២៥- ពិធីបើកជាផ្លូវការបុណ្យទន្លេលើកទី៥ ក្រោមប្រធានបទ«**ទន្លេផ្សារភ្ជាប់សន្តិភាព ប្រជាជន និងទេសចរណ៍**» នៅខេត្តកំពង់ឆ្នាំង កាលពីល្ងាចថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៩។

២៦- ពិធីប្រគល់វិញ្ញាបនបត្រ ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត១ ៧០៩អង្គ/នាក់(ស្រី៦៧៦នាក់)នៃវិទ្យាស្ថានខ្មែរជំនាន់ថ្មី នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩។

២៧- ពិធីសំណេះសំណាលជាមួយនិយោជិត កម្មករ កម្មការិនី១០ ៦៨៩នាក់ នៅឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ កាលពីព្រឹកថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩។

២៨- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត ដល់និស្សិត**១ ៥៧៨នាក់**(ស្រី៦៤០នាក់)នៃសាកលវិទ្យាល័យអាស៊ីអឺរ៉ុប នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩។

២៩- ពិធីបើកការដ្ឋានសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ ក្រុងព្រះសីហនុ មានប្រវែង១៩០,០១គ.ម. តភ្ជាប់ពីភូមិ១ សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដល់ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ចំណាយថវិកាប្រមាណ២ ០០០លានដុល្លារអាម៉េរិក ក្រោមរូបភាពសាងសង់ធ្វើអាជីវកម្មផ្ទេរ (BOT) ដែលជាទុនវិនិយោគរបស់ក្រុមហ៊ុនសាជីវកម្មស្ពាននិងថ្នល់ចិន នៅឃុំវល្លិ៍ស ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។

៣០- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត **១ ២៤៥នាក់**(ស្រី៥៧២នាក់)នៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩។

៣១- ពិធីបើកសន្និសីទចក្ខុវិស័យកម្ពុជាលើកទី១៣ ឆ្នាំ២០១៩ ក្រោមប្រធានបទ«**ការប្រែក្លាយផ្នែកឌីជីថលឆ្ពោះទៅកាន់ឧស្សាហកម្មទី៤.០**» នៅសណ្ឋាគារហ្រ្គេតឌូក រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩។

៣២- ពិធីប្រគល់សញ្ញាបត្រដល់គរុនិស្សិតនិងគរុសិស្ស**១ ៩១៨នាក់**(ស្រី៧១៣នាក់) នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩។

៣៣- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៧-២០១៨ និងលើកទិសដៅការងារឆ្នាំសិក្សា២០១៨-២០១៩ របស់ក្រសួងអប់រំ យុវជន និងកីឡា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩។

៣៤- ពិធីអបអរសាទរខួប១០០ឆ្នាំ(ឆ្នាំ១៩១៩-២០១៩)របស់អង្គការអន្តរជាតិខាងការងារ(ILO) និងខួប៥០ឆ្នាំ(ឆ្នាំ១៩៦៩-២០១៩)នៃសមាជិកភាពរបស់កម្ពុជា នៅអង្គការអន្តរជាតិខាងការងារ ក្រោមប្រធានបទ «**បង្កើនយុត្តិធម៌សង្គម លើកកម្ពស់ការងារសមរម្យ**» នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩។

៣៥- វេទិការាជរដ្ឋាភិបាលនិងផ្នែកឯកជន លើកទី១៨ ឆ្នាំ២០១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩។

៣៦- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត **៣ ២១៣នាក់**(ស្រី២ ៧០៤នាក់)នៃវិទ្យាស្ថានវ៉ាន់ដា នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែមេសា ឆ្នាំ២០១៩។

៣៧- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតខេត្តកំពត ចំណាយថវិកាប្រមាណ**២៧លានដុល្លារអាម៉េរិក** ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន នៅសង្កាត់កំពង់បាយ ក្រុងកំពត ខេត្តកំពត កាលពីព្រឹកថ្ងៃទី២ ខែមេសា ឆ្នាំ២០១៩។

៣៨- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ឡើងវិញស្ពានមិត្តភាពកម្ពុជា ជប៉ុន(ស្ពានជ្រោយចង្វាទី១) ចំណាយថវិកាប្រមាណជាង៣០លានដុល្លារអាម៉េរិក ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន កាលពីព្រឹកថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៩។

៣៩- ពិធីពិសាបាយសាមគ្គីឆ្នាំ២០១៩ ជាមួយកីឡាករ កីឡាការិនី គ្រូបង្វឹក**៤ ០៩៦នាក់** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៩។

៤០- ពិធីសម្ពោធជាផ្លូវការសារមន្ទីរសេដ្ឋកិច្ចនិងរូបិយវត្ថុ«**ព្រះស្រីឦសានវរ្ម័ន**» នៅសង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩។

៤១- ពិធីពិសាបាយសាមគ្គីជាមួយសមាគមសម្ព័ន្ធខ្មែរ ចិន៥ ៥០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩។

៤២- ពិធីចាក់បេតុងតភ្ជាប់ស្ពានមិត្តភាពកម្ពុជា ថៃ(ស្ទឹងបត់-បានណងអៀង) ចំណាយថវិកាជាង**១៩លានដុល្លារអាម៉េរិក** ដែលជាជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលថៃនិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា និងពិធីបើកការដ្ឋានសាងសង់អគារច្រកទ្វារព្រំដែនអន្តរជាតិស្ទឹងបត់ និងផ្លូវតភ្ជាប់ទៅផ្លូវជាតិលេខ៥ ចំណាយថវិកា**២៦,៤២លានដុល្លារអាម៉េរិក** ដែលជាហិរញ្ញប្បទានសម្បទានពីរាជរដ្ឋាភិបាលថៃ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **ប្រាយុទ្ធ ចាន់អូចា** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ កាលពីព្រឹកថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩។

៤៣- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត**២ ២៨៧នាក់** (ស្រី១ ១៩៤នាក់)នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩។

៤៤- ពិធីសំណេះសំណាលនិងពិសាបាយសាមគ្គីជាមួយនិយោជិត កម្មករ កម្មការិនី**៣ ៧០០នាក់** ដើម្បីអបអរសាទរទិវាពលកម្មអន្តរជាតិ ១ឧសភា ឆ្នាំ២០១៩ លើកទី១៣៣ នៅឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៩។

៤៥- កិច្ចពិភាក្សាការងារជាមួយគណៈប្រតិភូនៃក្រុមទីភ្នាក់ងារអង្គការសហប្រជាជាតិនៅកម្ពុជា ២០នាក់ នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៩។

៤៦- ពិធីពិសាអាហារស្រាយបួសខែរ៉ាម៉ាឌននៃសាសនិកអិស្លាមកម្ពុជា៤ ៧៥០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៩។

៤៧- ពិធីប្រារព្ធទិវាកាកបាទក្រហមពិភពលោក អឌ្ឍចន្ទក្រហម៨ឧសភា ឆ្នាំ២០១៩ លើកទី១៥៦ ក្រោមប្រធានបទ«**ខ្ញុំស្រឡាញ់កាកបាទក្រហមកម្ពុជា**» នៅទីស្នាក់ការកណ្ដាលកាកបាទក្រហមកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៩។

៤៨- វេទិកាធុរកិច្ចកម្ពុជា-នេប៉ាល់ នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៩។

៤៩- ពិធីពិសាអាហារស្រាយបួសខែរ៉ាម៉ាឌននៃសាសនិកអិស្លាមកម្ពុជា៧២៥នាក់ នៅវិហារបឹងកក់ សង្កាត់បឹងកក់១ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីរាត្រីថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៩។

៥០- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត៣ ១៦១នាក់ (ស្រី១ ៨៨៥នាក់)នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៩។

៥១- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត ១ ៣៥៦នាក់(ស្រី៨៧១នាក់)នៃសាកលវិទ្យាល័យពុទ្ធិសាស្រ្ត នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៩។

៥២- សន្និសីទកំពូលសារព័ត៌មានអាស៊ីឆ្នាំ២០១៩ លើកទី១៦ នៅសណ្ឋាគារសុខា ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩។

៥៣- ការចុះពិនិត្យការដ្ឋានផ្ទាល់និងជួបសំណេះសំណាលសួរសុខទុក្ខជាមួយជនរងគ្រោះក្នុងឧបទ្ទវហេតុបាក់រលំអគារកម្ពស់៧ជាន់ នៅសង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីរាត្រីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៩។

៥៤- ពិធីផ្ទេរការគ្រប់គ្រងសាលាកុមារពិការភ្នែកនិងកុមារគថ្លង់នៃអង្គការគ្រួសារថ្មីឱ្យស្ថិតក្រោមក្រសួងអប់រំ យុវជន និងកីឡា និងការដាក់ឱ្យដំណើរការវិទ្យាស្ថានជាតិអប់រំពិសេស នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩។

៥៥- ពិធីសំណេះសំណាលជាមួយកម្មករ កម្មការិនី កីឡាករ កីឡាការិនី ក្នុងឱកាសចុះពិនិត្យការដ្ឋានសាងសង់**ពហុកីឡដ្ឋានជាតិមរតកតេជោ** ដែលបាននិងកំពុងសាងសង់ នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩។

៥៦- ពិធីប្រគល់សញ្ញាបត្រវិទ្យាសាស្រ្តនគរបាល ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បរិញ្ញាបត្រដល់និស្សិតនាយនគរបាលបន្តវេននិងសិក្ខាកាមថ្នាក់វិញ្ញាបនបត្រសរុប១ ៤៦៥នាក់(ស្រី១០២នាក់) នៃបណ្ឌិត្យសភានគរបាលកម្ពុជា នៅបណ្ឌិត្យសភានគរបាលកម្ពុជា ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៩។

៥៧- វេទិកាធុរកិច្ចកម្ពុជា ស្រីលង្កា នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញភូគីត្រា រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៩។

៥៨- ពិធីបើកកិច្ចប្រជុំជាមួយឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ប្រចាំឆមាសលើកទី២ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៩។

៥៩- ពិធីបើកសន្និសីទថ្នាក់រដ្ឋមន្ត្រីការងារលើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យការងារក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម(CLMTV) នៅសណ្ឋាគារអេប្សរាផាលេសក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩។

៦០- ពិធីអបអរសាទរខួប៧០ឆ្នាំ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩។

៦១- ពិធីប្រគល់វិញ្ញាបនបត្រនិងសញ្ញាបត្រដល់សិស្សថ្នាក់វិជ្ជាជីវៈគរុកោសល្យ និងនិស្សិតថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់១ ១៨៣នាក់(ស្រី៦៣៥នាក់)នៃសាកលវិទ្យាល័យប៊ែលធីអន្តរជាតិ និងប្រកាសផ្សព្វផ្សាយជាផ្លូវការសៀវភៅ«**ហ៊ុន សែន កម្ពុជា**» នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៌កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែតុលា ឆ្នាំ២០១៩។

៦២- ពិធីសំណេះសំណាលជាមួយបេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ«**និទ្ទេសA**» ៤៤៣នាក់(ស្រី២២៣នាក់) សម័យប្រឡងថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩។

៦៣- ពិធីចូលជួបសម្តែងការគួរសម និងពិភាក្សាការងាររបស់គណៈប្រតិភូសហគ្រិនចិនដែលដឹកនាំដោយលោក **ហ៊ុន ខឺជូ** ប្រធានសហគ្រិនចិន នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩។

៦៤- ពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី៤០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ(១០ តុលា ១៩៧៩-១០ តុលា ២០១៩) នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩។

៦៥- ពិធីចូលជួបសម្តែងការគួរសមរបស់ប្រតិភូយុវជនកម្ពុជា២៩នាក់ នៃកម្មវិធីនាវាយុវជនអាស៊ីអាគ្នេយ៍ និងជប៉ុនលើកទី៤៦ ឆ្នាំ២០១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩។

៦៦- ពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋខ្មែរជាគ្រិស្តបរិស័ទ ដើម្បីសុខដុមនីយកម្មវិស័យគ្រិស្តសាសនានិងពិសាភោជនាហារ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៩។

៦៧- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត៤ ០៣៨នាក់ (ស្រី១ ៣៤៤នាក់)នៃសាកលវិទ្យាល័យបៀលប្រាយ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩។

៦៨- ពិធីបើកសន្និសីទអគ្គព្រះរាជអាជ្ញាអាស៊ាន ចិន លើកទី១២ ក្រោមប្រធានបទ«**តួនាទីព្រះរាជអាជ្ញាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងតំបន់**» នៅសណ្ឋាគារសុខា ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩។

៦៩- ពិធីផ្សព្វផ្សាយនិងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ«**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣**» នៅសណ្ឋាគារសុខាភ្នំពេញ កាលពីព្រឹកថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧០- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការរោងចក្រផលិតស៊ីម៉ងត៍របស់ក្រុមហ៊ុន ថៃ ប៊ុនរ៉ុង ចំណាយថវិកាប្រមាណ១១០លានដុល្លារអាម៉េរិក នៅឃុំល្អាង ស្រុកដងទង់ ខេត្តកំពត កាលពីព្រឹកថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧១- ពិធីបើកការដ្ឋានស្ថាបនាផ្លូវចំនួន៣៤ខ្សែ ប្រវែង៨៤,៥០គ.ម. នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ចំណាយថវិកាជាតិប្រមាណជិត៣០០លានដុល្លារអាម៉េរិក កាលពីព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧២- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញារង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត **១ ៩៥៨នាក់**(ស្រី៤៤៧នាក់)នៃសាកលវិទ្យាល័យធនធានមនុស្ស នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧៣- ពិធីសំណេះសំណាលជាមួយអត្តពលិកនិងប្រតិភូកីឡាកម្ពុជា ដែលត្រូវទៅចូលរួមប្រកួតកីឡាស៊ីហ្គេមលើកទី៣០ នៅប្រទេសហ្វីលីពីន នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧៤- ពិធីបើកកិច្ចប្រជុំកំពូលអាស៊ីប៉ាស៊ីហ្វិកលើកទី២ ក្រោមប្រធានបទ«**ការឆ្លើយតបចំពោះបញ្ហាប្រឈមគន្លឹះនាពេលបច្ចុប្បន្នៈ សន្តិភាព ការបង្រួបបង្រួមជាតិ ការពឹងពាក់គ្នាទៅវិញទៅមក វិបុលភាពទៅវិញទៅមក និងគុណតម្លៃសកល**» នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧៥- ពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះសពសម្តេចរាជបុត្រីព្រះរាម**នរោត្តម បុប្ផាទេវី** ទេពនាដវត្តីឧត្តមទីប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ នៅវត្តបទុមវតីរាជវរារាម សង្កាត់ចតុមុខ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧៦- ពិធីសម្ពោធ«**អគារឥន្ទ្រទេវី**» របស់រាជបណ្ឌិត្យសភាកម្ពុជា និងអបអរសាទរខួប២០ឆ្នាំ នៃការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា នៅរាជបណ្ឌិត្យសភាកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧៧- ពិធីបើកមហាសន្និបាតសហព័ន្ធអតីតយុទ្ធជនអាស៊ានលើកទី១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩។

៧៨- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដល់និស្សិត**៦ ៧៦២នាក់**(ស្រី២ ៧៦១នាក់)នៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩។

៧៩- ពិធីសម្ពោធពិព័រណ៍ផលិតផលខ្មែរនិងទំនិញនាំចេញ នាំចូលកម្ពុជាលើកទី១៤ កម្រិតអន្តរជាតិឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៩។

៨០- ពិធីប្រគល់សញ្ញាបត្រដល់និស្សិត២ ៥៨៨នាក់(ស្រី១ ៥២២នាក់)នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩។

៨១- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាជាន់ខ្ពស់ ដល់និស្សិត២ ៨៣១នាក់(ស្រី១ ៦១៤នាក់)នៃសាកលវិទ្យាល័យវេស្ទើន នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩។

៨២- ពិធីជួបសំណេះសំណាលជាមួយប្រតិភូសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៩។

៨៣- ពិធីបើកបុណ្យសមុទ្រលើកទី៨ ជុំទី២ នៅខេត្តកំពត កាលពីល្ងាចថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៩។

៨៤- ពិធីសម្ពោធផ្សារគំរូព្រំដែន ចំណាយថវិកាប្រមាណ២លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានឥតសំណងរបស់រដ្ឋាភិបាលវៀតណាម នៅឃុំដារ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៩។

៨៥- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត២ ៧៩០នាក់(ស្រី១ ៣៨០នាក់)នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩។

៨៦- ពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩។

៨៨- ពិធីបើកការប្រកួតវាយកូនគោល«**ពានរង្វាន់សម្តេចតេជោ នាយករដ្ឋមន្ត្រីលើកទី៤**» នៅទីលានវាយកូនគោលវ៉ឺឡនហ្គោលវីសេត ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៩។

៨៩- ពិធីបិទការប្រកួតវាយកូនគោល«**ពានរង្វាន់សម្តេចតេជោ នាយករដ្ឋមន្ត្រីលើកទី៤**» នៅទីលានវាយកូនគោលវ៉ឺឡនហ្គោលវីសេត ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីល្ងាចថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៩។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បាន៖

១- ទទួលសញ្ញាបត្របណ្ឌិតកិត្តិយសផ្នែកទំនាក់ទំនងនយោបាយពីសាកលវិទ្យាល័យគ្រើកនៃព្រះរាជាណាចក្រថៃ ប្រារព្ធធ្វើនៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩។

២- ទទួលគោរមងារជាសាស្ត្រាចារ្យកិត្តិយសផ្នែកទំនាក់ទំនងអន្តរជាតិ ពីសាកលវិទ្យាល័យប៉េកាំង នៅទីក្រុងប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៩។

៣- ទទួលពានរង្វាន់ «**ភាពជាអ្នកដឹកនាំនិងអភិបាលកិច្ចល្អ**» ពីសហព័ន្ធសន្តិភាពសកល(UPF) នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩។

**ក្រៅពីនេះ សម្តេច ឯកឧត្តម និងលោកជំទាវ ឧបនាយករដ្ឋមន្ត្រី ដែលជាតំណាងរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ៖**

**ក- សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តអង្គរជ័យ នៅឃុំអង្គររាជ្យ ស្រុកព្រះស្តេច ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩។

២- ពិធីប្រកួតកីឡាវាយកូនគោល«**ពានរង្វាន់សម្តេចក្រឡាហោម ស ខេង**» នៅទីលានហ្គ្រេនភ្នំពេញ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩។

៣- ពិធីជប់លៀងប្រកាសជ័យលាភីការប្រកួតកីឡាវាយកូនគោល«**ពានរង្វាន់សម្តេចក្រឡាហោម ស ខេង**» នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៩។

៤- ពិធីបញ្ចុះខណ្ឌសីមានិងសម្ពោធសមិទ្ធផលនានា ក្នុងវត្តនទីជោត្តនារាម (ហៅវត្តខ្សោកជើង) នៅឃុំពពឺស ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៩។

៥- ពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩។

៦- ពិធីអបអរសាទរទិវាគ្រូបង្រៀន ក្រោមប្រធានបទ«**គុណភាពគ្រូជាមូលដ្ឋានគ្រឹះនៃយុគសម័យឌីជីថល**» នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៩។

៧- ពិធីបើកវេទិកាជាតិអេកូទេសចរណ៍លើកទី១ នៅសណ្ឋាគារហ្គាឌិនស៊ីធី សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

៨- ពិធីបើកសន្និបាតបូកសរុបការអនុវត្តន៍ផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០១៤-២០១៨ និងប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាពឆ្នាំ២០១៩-២០២៣ ព្រមទាំងទិវាជនមានពិការភាពកម្ពុជាលើកទី២១និងអន្តរជាតិលើកទី៣៧ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១៩។

៩- ពិធីប្រារព្ធទិវាជាតិប្រឆាំងការជួញដូរមនុស្ស ១២ធ្នូ ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៩។

**ខ- សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបញ្ចុះបឋមសិលាបើកការដ្ឋានគម្រោងឈូងសមុទ្រតារា នៅតំបន់អភិវឌ្ឍន៍តារាសាគរ ស្រុកគិរីសាគរ ខេត្តកោះកុង កាលពីល្ងាចថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩។

២- ពិធីទទួលដំណើរនិវត្តន៍កងកម្លាំងវិស្វកម្មលេខ៩៦៣ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅសាធារណរដ្ឋលីបង់ ប្រារព្ធធ្វើនៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩។

៣- ពិធីរំឭកខួប៤២ឆ្នាំ **«ទិវាចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ២០-៦-១៩៧៧/ ២០-៦-២០១៩»** នៅសាលាបឋមសិក្សា **ប៊ុន រ៉ានី ហ៊ុន សែន** កោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩។

៤- ពិធីបើកជាផ្លូវការកិច្ចប្រជុំរដ្ឋមន្ត្រីសុខាភិបាលអាស៊ានលើកទី១៤ និងកិច្ចប្រជុំពាក់ព័ន្ធ នៅសណ្ឋាគារសុខាសៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩។

៥- ពិធីអបអរសាទរខួបអនុស្សាវរីយ៍២៥ឆ្នាំ ថ្ងៃបង្កើតកងពលតូចលេខ៧០(១៥ តុលា ១៩៩៤-១៥ តុលា ២០១៩) នៅបញ្ជាការដ្ឋានកងពលតូចលេខ៧០ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩។

៦- ពិធីសម្ពោធអគារបឋមសិក្សា១ខ្នង អគារអនុវិទ្យាល័យ១ខ្នង និងទីចាត់ការ១ខ្នង ក្នុងអនុវិទ្យាល័យស្ពានត្នោត នៅឃុំត្នោត ស្រុកជីក្រែង ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩។

៧- ពិធីទទួលដំណើរនិវត្តន៍កងវិស្វកម្មលេខ៥៩៤ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល ប្រារព្ធនៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៩។

**គ- ឯកឧត្តម ហោ ណាំបូរ ឧបនាយករដ្ឋមន្ត្រី** បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីបើកមហាសន្និបាតលើកទី៣៩ របស់សមាគមអន្តរជាតិនៃអភិបាលក្រុងប្រើប្រាស់ភាសាបារាំង នៅសណ្ឋាគារសុខាភ្នំពេញ កាលពីព្រឹកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩។

**ឃ- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៧-២០១៨ និងលើកទិសដៅការងារឆ្នាំសិក្សា២០១៨-២០១៩ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩។

២- ពិធីសម្ពោធសមិទ្ធផលនានានិងកាត់ឫសសីមាព្រះវិហារវត្តអង្គនិស្សយ៍ នៅសង្កាត់ឪឡោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩។

៣- ពិធីវប្បធម៌និងទេសចរណ៍កម្ពុជា-ចិន នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៩។

៤- ពិធីបិទអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៨ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩។

**ង- លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទការប្រឡងសូត្រគម្ពីរអាល់គួរអានទូទាំងប្រទេសលើកទី២៨ ឆ្នាំ២០១៩ នៅវិហារជំគ.ម.លេខ៩ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៩។

២- ទិវាជាតិអំណានឆ្នាំ២០១៩ ក្រោមប្រធានបទ«**ការអានបណ្តុះវប្បធម៌ការសិក្សាពេញមួយជីវិត**» នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩។

៣- ពិធីបិទមហោស្រពសិល្បៈចម្រៀងខ្មែរជាសកលលើកទី៥ ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៩។

៤- ពិធីចូលជួបសម្តែងការគួរសមរបស់លោក **រ៉ុសែល អឹម ណិលសុន**(Russel M. Nelson) ប្រធានសាសនាចក្រនៃព្រះយេស៊ូគ្រិស្តនៅទីស្តីការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច កាលពីល្ងាចថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

៥- ពិធីសំណេះសំណាលជាមួយតំណាងអាចារ្យ អាចារិនី មកពីទូទាំងប្រទេស នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩។

៦- ពិធីប្រគេននិងប្រគល់សញ្ញាបត្រដល់សមណនិស្សិតនិងនិស្សិត**១ ១០៦អង្គ/នាក់** នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៩។

**ច- ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី** ប្រធានក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទបានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារអភិវឌ្ឍន៍ជនបទឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារសុខាភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩។

២- ប្រារព្ធទិវាមច្ឆជាតិ ១កក្កដា ឆ្នាំ២០១៩ នៅអាងទឹកបឹងស្នោ សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ កាលពីព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១៩។

៣- ពិធីបិទបញ្ចប់គម្រោងការលុបបំបាត់ភាពពិការភ្នែកដោយសារជំងឺភ្នែកឡើងបាយ ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន នៅខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩។

**ឆ- ឯកឧត្តម កែ គឹមយ៉ាន ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីប្រារព្ធខួបលើកទី៧០ ទិវាកុមារអន្តរជាតិ ១មិថុនា និងខួបលើកទី១៨ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៩។

២- ពិធីប្រារព្ធខួបលើកទី១២ ទិវាអតីតយុទ្ធជនកម្ពុជា ២១មិថុនា ឆ្នាំ២០១៩ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៩។

៣- ប្រារព្ធទិវាពិភពលោកប្រយុទ្ធប្រឆាំងជំងឺអេដស៍១ធ្នូ ឆ្នាំ២០១៩ លើកទី២៦ ក្រោមប្រធានបទ **«ទាំងអស់គ្នាចូលរួមជាចរន្តជាតិមួយក្នុងការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍និងជំងឺអេដស៍»** នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៩។

**ជ- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារសាធារណការនិងដឹកជញ្ជូន ឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩។

២- ពិធីអបអរសាទរទិវាពលកម្មអន្តរជាតិ១ឧសភា ឆ្នាំ២០១៩ លើកទី១៣៣ ជាមួយនិយោជិតកម្មករ កម្មការិនីនៃកំពង់ផែស្វយ័តក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៩។

៣- ពិធីបើកកិច្ចប្រជុំលើកទី១៥ រដ្ឋមន្ត្រីបរិស្ថានអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធឆ្នាំ២០១៩ នៅសណ្ឋាគារសូហ្វីតែល អង្គរភូគីត្រា ហ្គោហ្វ និងស្ប៉ារីហ្សត ក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩។

៤- ពិធីសម្ពោធរោងចក្រផលិតផល មីជាតិ នៅសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩។

៥- ពិធីចូលជួបសម្តែងការគួរសមរបស់គណៈប្រតិភូនៃសហព័ន្ធពាណិជ្ជករចិនទាជីវសកល និងថ្នាក់ដឹកនាំសមាគមសម្ព័ន្ធខ្មែរ ចិន នៅកម្ពុជា នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាច ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩។

៦- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងពាណិជ្ជកម្ម នៅទីស្តីការក្រសួងពាណិជ្ជកម្ម កាលពីល្ងាចថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

**ឈ- ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តរតនមុនីតាប៉ាវ(ហៅវត្តពងទឹក) នៅឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១២ ខែមករា ឆ្នាំ២០១៩។

២- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តគិរីគង្គា(ហៅវត្តប្រផាត់) នៅឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៩។

៣- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តបន្ទាយជ័យមង្គល នៅឃុំកំពង់ទ្រាស ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩។

៤- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តសារពេជ្រពណ្ណរាយ នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៩។

៥- ពិធីស្រោចសុគន្ធវារីព្រះចៅអធិការវត្តនិងសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តពាមមង្គល នៅឃុំពាមជីលាំង ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៩។

៦- ពិធីសម្ពោធអគារសិក្សា១ខ្នង មាន៣ជាន់ ១៥បន្ទប់ និងឆ្លងសមិទ្ធផលនានាក្នុងសាលាបឋមសិក្សាភាសាខ្មែរ ចិន សេង ម៉េង នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៩។

៧- ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារ និងសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តចន្ទរង្សី(ហៅវត្តព្រះអង្គ) នៅឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៩។

៨- ពិធីសម្ពោធឆ្លងកុដិថ្មនិងសមិទ្ធផលនានាក្នុងវត្តព្រះពុទ្ធមហាសាស្រ្តារាម នៅឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីល្ងាចថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៩។

៩- ពិធីសម្ពោធឆ្លងឧបដ្ឋានសាលានិងសមិទ្ធផលនានាក្នុងវត្តពោធិ៍សាល (ហៅវត្តអំពិល) នៅឃុំប៉ឺស២ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩។

១០- ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តគិរីវណ្ណារាម នៅឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។

១១- ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តជ័យមុនី នៅឃុំទួលស្នួល ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩។

១២- ពិធីបញ្ចុះខណ្ឌសីមាព្រះវិហារវត្តបទុមរង្សី នៅឃុំថ្មពេជ្រ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៩។

១៣- ពិធីសម្ពោធឆ្លងសមិទ្ធផលនានាក្នុងវត្តពោធិ៍គយា (ហៅវត្តវិហារខ្ពស់) នៅសង្កាត់សួង ក្រុងសួង ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៩។

## ឆ្នាំ២០២០

១- ការចុះដឹកនាំកិច្ចប្រតិបត្តិការរុករកសង្គ្រោះជនរងគ្រោះនិងបានជួបសួរសុខទុក្ខ ជនរងគ្រោះ នៅពេលអគារប្រភេទបេតុងកម្ពស់៦ជាន់ ដែលកំពុងសាងសង់ ត្រូវបានបាក់ស្រុតនៅភូមិកែប សង្កាត់កែប ខេត្តកែប កាលពីព្រឹកថ្ងៃទី៣ ដល់ថ្ងៃទី៥ ខែមករា ឆ្នាំ២០២០។

២- ពិធីសំណេះសំណាលនិងពិសាបាយសាមគ្គីលើកទី៤ ជាមួយអ្នកសារព័ត៌មានប្រមាណជាង ៥ ០០០នាក់ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០។

៣- ពិធីលៀងសាយភោជន៍អបអរសាទរបុណ្យចូលឆ្នាំប្រពៃណីជនជាតិវៀតណាម ឆ្នាំ២០២០ ជាមួយសហគមន៍និងធុរកិច្ចវៀតណាមនៅកម្ពុជា នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី១៧ ខែមករា ឆ្នាំ២០២០។

៤- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារការបរទេសនិងសហប្រតិបត្តិការអន្តរជាតិឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងពិធីប្រកាសជាផ្លូវការនូវការធ្វើម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ីអឺរ៉ុបលើកទី១៣ ឆ្នាំ២០២០ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០។

៥- ពិធីបើកការដ្ឋានគម្រោងធ្វើឱ្យប្រសើរឡើងវិញកំណាត់ផ្លូវជាតិលេខ២ (ពីរង្វង់មូលតាខ្មៅ ដល់អូរចំបក់) និងផ្លូវជាតិលេខ២២ (ពីអូរចំបក់ ដល់អង្គតាសោម) ប្រវែង៧២,១៧គ.ម. ចំណាយថវិកាប្រមាណ ៥៦,១លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានពីសាធារណរដ្ឋកូរ៉េនិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០។

៦- ពិធីទទួលស្វាគមន៍អ្នកទេសចរណ៍របស់នាវាWesterdam នៅកំពង់ផែក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០។

៧- កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៩និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០។

៨- ពិធីប្រគល់សញ្ញាបត្រដល់អធិការកិច្ចអប់រំនិងនិស្សិត គរុសិស្ស១ ៩៧៧នាក់(ស្រី៨១៥នាក់) របស់វិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។

៩- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីល្ងាចថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០។

១០- ពិធីបើកកិច្ចប្រជុំប្រចាំឆមាសលើកទី៣នៃឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

១១- ពិធីបិទវគ្គប្រគល់សញ្ញាបត្រ វិញ្ញាបនបត្រ ដល់សិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការ និងកម្មសិក្សាការី ឆ្នាំ២០១៨ ចំនួន៥៧៥នាក់(ស្រី១០៥នាក់) និងពិធីបើកវគ្គបណ្តុះបណ្តាលសិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី១១ ឆ្នាំ២០២០ របស់សាលាភូមិន្ទរដ្ឋបាល នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០។

១២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៥៨ ប្រវែង១៧៤,១៦គ.ម. ចាប់ពីក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដល់ក្រុងសំរោង ខេត្តឧត្តរមានជ័យ ចំណាយថវិកាប្រមាណ១២២,៩៨លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានពីសាធារណរដ្ឋប្រជាមានិតចិននិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០។

១៣- ពិធីស្រោចស្រពព្រះសុគន្ធវារី ប្រគេនសម្តេចព្រះសង្ឃនាយករងបីព្រះអង្គ មានសម្តេចព្រះពោធិវង្ស **អ៊ំ លឹមហេង** សម្តេចព្រះសង្ឃនាយករងទី១ សម្តេចព្រះវនរ័ត **ណយ ច្រឹក** សម្តេចព្រះសង្ឃនាយករងទី២ និងសម្តេចព្រះឧត្តមវង្សា **មួង រ៉ា** សម្តេចព្រះសង្ឃនាយករងទី៣ នៅវត្តមុនីសុវណ្ណ (ហៅវត្តចំពុះក្អែក) ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០។

១៤- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត ១ ៥៨៩នាក់(ស្រី៦១៦នាក់) នៃសាកលវិទ្យាល័យអាស៊ីអឺរ៉ុប នៅវិទ្យាស្ថានជាតិអប់រំ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០២០។

១៥- ពិធីអបអរសាទរទិវា**«វប្បធម៌ជាតិ៣មីនា»** លើកទី២២ ឆ្នាំ២០២០ និងពិធីបិទមហោស្រពសិល្បៈយុវជនទូទាំងប្រទេសឆ្នាំទី៦ នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០។

១៦- ពិធីបិទសន្និបាតការងារសុខាភិបាលឆ្នាំ២០១៩និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល នៅសណ្ឋាគារសុខាភ្នំពេញ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី៤ ខែមីនា ឆ្នាំ២០២០។

១៧- ពិធីអបអរសាទរទិវាអន្តរជាតិនារី៨មីនា ខួបលើកទី១០៩ ក្រោមប្រធានបទ**«មានសន្តិភាព មានការលើកកម្ពស់សមភាពយេនឌ័រ»** នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែមីនា ឆ្នាំ២០២០។

១៨- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៥៥ ប្រវែង**១៨២,១៦គ.ម.** ចាប់ពីពោធិ៍សាត់ វាលវែង ដល់ថ្មដា(ព្រំដែនកម្ពុជា ថៃ) និងពិធីបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ១០ ប្រវែង១៩៧,៣៦គ.ម. ចាប់ពីសំឡូត-វាលវែង អូរសោម ដល់កោះកុង ចំណាយថវិកាប្រមាណ១៨៨,៣៨លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានពីសាធារណរដ្ឋប្រជាមានិតចិននិងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅសាលាបឋមសិក្សា **ហ៊ុន សែន ប្រមោយ** ឃុំប្រមោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់ កាលពីព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០។

១៩- ពិធីប្រគល់សញ្ញាបត្រថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដល់និស្សិត៣ ៤៥៨នាក់(ស្រី២ ៩៥៤នាក់) នៃវិទ្យាស្ថានវ៉ាន់ដា នៅមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០។

២០- ពិធីបើកជាផ្លូវការបុណ្យទន្លេលើកទី៦ ឆ្នាំ២០២០ ក្រោមប្រធានបទ**«ទន្លេនៃសន្តិភាព ទន្លេនៃវិបុលភាព»** នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីល្ងាចថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២០។

២១- ពិធីចុះហត្ថលេខាលើលិខិតប្តូរសារ ស្តីពីការផ្តល់ជំនួយអភិវឌ្ឍន៍ផ្លូវការជប៉ុនជូនចំពោះរាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានមានទឹកប្រាក់៣៤ ១៣៨លានយ៉េន ស្មើនឹង៣១០

លានដុល្លារអាម៉េរិក សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានឥតសំណង៣គម្រោងនិងឥណទានសម្បទាន២គម្រោង នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០។

២២- ពិធីសំណេះសំណាលជាមួយគ្រូពេទ្យសម្តេចតេជោប្រឆាំងកូវីដ-១៩ ចំនួន៤២២នាក់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០។

២៣- ចុះពិនិត្យដំណើរការស្ថាបនាផ្លូវក្រុង៣៤ខ្សែ ប្រវែង៨៤,៥០គ.ម. សម្រេចបាន៩៤% នៅខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០។

២៤- ពិធីជួបសំណេះសំណាលជាមួយមន្ត្រីរាជការនិងក្រុមការងារបច្ចេកទេសស្ថាបនា ផ្លូវក្រុង៣៤ខ្សែ នៅខេត្តព្រះសីហនុ កាលពីល្ងាចថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០។

២៥- ចុះពិនិត្យការដ្ឋានសាងសង់អគារថ្មីនៃទីស្នាក់ការគណបក្សប្រជាជនកម្ពុជា**«វិមាន ៧មករា»** សម្រេចបាន៩៥% នៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២០។

២៦- ចុះពិនិត្យការដ្ឋានសាងសង់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញថ្មីសម្រេចបាន៣០% នៅឃុំព្រែកស្លែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០។

២៧- ពិធីប្រកាសអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រនិងងាយរងគ្រោះក្នុងកំឡុងពេលប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០។

២៨- ពិធីក្រុងពាលីសូត្រមន្តសម្ពោធអគារថ្មីទីស្នាក់ការគណបក្សប្រជាជនកម្ពុជា**«វិមាន ៧មករា»** នៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២០។

២៩- ការចុះពិនិត្យវឌ្ឍនភាពនៃការងារវារីវប្បកម្ម នៅមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍វារីវប្បកម្មទឹកសាប និងសំណេះសំណាលជាមួយប្រជាកសិករ នៅឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

៣០- ការចុះពិនិត្យវឌ្ឍនភាពនៃការងារបង្កបង្កើនផលស្រូវ និងជួបសំណេះសំណាលជាមួយប្រជាកសិករ នៅឃុំបានកាម ស្រុកព្រៃកប្បាស ខេត្តតាកែវ កាលពីព្រឹកថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០។

៣១- ពិធីសម្ពោធសួនទឹកហ្គាឌិនស៊ីធី នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០។

៣២- ពិធីបើកកិច្ចប្រជុំជាមួយឧត្តមក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ ប្រចាំឆមាសលើកទី៤ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០។

៣៣- ពិធីសម្ពោធមជ្ឈមណ្ឌលកម្សាន្តព្រីនស៍ ម៉ាណ័រ នៅឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី៧ ខែតុលា ឆ្នាំ២០២០។

៣៤- ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **វ៉ាង យី** ទីប្រឹក្សារដ្ឋនិងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតចិន នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០។

៣៥- ការចុះពិនិត្យស្ថានភាពទឹកជំនន់និងសួរសុខទុក្ខប្រជាពលរដ្ឋដែលរងគ្រោះដោយជំនន់ទឹកភ្លៀង នៅខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីយប់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០។

៣៦- ការចុះសំណេះសំណាលសួរសុខទុក្ខនិងចែកអំណោយដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយទឹកជំនន់ នៅឃុំបត់ត្រង់និងឃុំឫស្សីក្រោក ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០។

៣៧- ការចុះសំណេះសំណាលសួរសុខទុក្ខនិងចែកអំណោយដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយទឹកជំនន់ នៅឃុំគំរូ ស្រុកថ្មពួក និងសង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០។

៣៨- ការចុះសំណេះសំណាលសួរសុខទុក្ខនិងចែកអំណោយដល់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយទឹកជំនន់ នៅស្រុកអូរជ្រៅនិងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០។

៣៩- ពិធីបើកការដ្ឋានសាងសង់ស្ពានបេតុងខ្សែកាបឆ្លងកាត់ទន្លេបាសាក់ ពីទីក្រុងរណបកោះពេជ្រទៅកាន់តំបន់អភិវឌ្ឍន៍កោះនរា និងពីតំបន់អភិវឌ្ឍន៍កោះនរា ទៅផ្លូវជាតិលេខ១ និងពិធីប្រកាសឱ្យបើកដំណើរការជាបណ្ដោះអាសន្នផ្លូវក្រោមដី ស្ពានអាកាសរង្វង់មូលចោមចៅ ប្រព្រឹត្តទៅនៅសង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០។

៤០- ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនិងអនុស្សរណៈនៃការយោគយល់គ្នារវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋហុងគ្រី នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២០។

៤១- ពិធីសំណេះសំណាលនិងពិនិត្យលទ្ធផលការងាររបស់សមាជិកក្រុមមេធាវីរាជរដ្ឋាភិបាល និងមេធាវីស្ម័គ្រចិត្តសម្ដេចតេជោ១៥៣នាក់ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០។

៤២- ពិធីបើកការដ្ឋានសាងសង់ផ្លូវ៣៨ខ្សែ ប្រវែង១០៨,៧៤គ.ម. ចំណាយថវិកាប្រមាណ១៤០ លានដុល្លារអាម៉េរិក នៅក្រុងសៀមរាប ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០។

**ទន្ទឹមនេះ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យ៖**

១- ឯកឧត្តម Muhammad Faruk Khan ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកកិច្ចការបរទេសនៃសភាបង់ក្លាដែស ចូលជួបសម្ដែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី៦ ខែមករា ឆ្នាំ២០២០។

២- ឯកឧត្តមសាស្ត្រាចារ្យ Jeffrey D. Sachs ទីប្រឹក្សាពិសេសរបស់ឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិ ចូលជួបសម្ដែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០២០។

៣- ឯកឧត្តម Yamoto Kozo សមាជិកសភាជប៉ុន ចូលជួបសម្ដែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០។

៤- ឯកឧត្តម Imamura Masahiro ប្រតិភូសភាជប៉ុន ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០។

៥- ឯកឧត្តម ឧត្តមសេនីយ៍ទោ Goh Si Hou មេបញ្ជាការកងទ័ពជើងគោកនៃប្រទេសសិង្ហបុរី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី២១ ខែមករា ឆ្នាំ២០២០។

៦- លោកជំទាវ Liurka Rodriquez Barrias ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃប្រទេសគុយបា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

៧- ឯកឧត្តម Pablo Chiho Kang ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃប្រទេសអូស្ត្រាលី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

៨- ឯកឧត្តម Bounnhang Vorachith អគ្គលេខាធិការនៃគណៈកម្មាធិការមជ្ឈិមបក្សប្រជាជនបដិវត្តន៍ឡាវនិងជាប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២០។

៩- ឯកឧត្តម Mikami Masahiro ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០។

១០- ឯកឧត្តម Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាម៉េរិកប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។

១១- លោក Orlando Ashford ប្រធានក្រុមហ៊ុន Holland America Line ដែលជាម្ចាស់នាវា Westerdam ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០។

១២- ឯកឧត្តម នាយឧត្តមសេនីយ៍ Goro Yuasa មេបញ្ជាការកងទ័ពជើងគោក ប្រទេសជប៉ុន ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០។

១៣- ឯកឧត្តម Takahashi Fumiaki ប្រធានសមាគមកម្ពុជា ជប៉ុន ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

១៤- ឯកឧត្តម Dmitry Tsvetkov ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃសហព័ន្ធរុស្ស៊ី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីល្ងាចថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។

១៥- ឯកឧត្តម Ermenegildo Kupa Lopes ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពរបស់សាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើតតែងតាំងថ្មី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០។

១៦- ឯកឧត្តម Panyarak Poolthup ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពរបស់ព្រះរាជាណាចក្រថៃ ចូលជួបសម្តែងការគួរសម ពិភាក្សាការងារ និងប្រគល់ថវិការបស់រដ្ឋាភិបាលថៃចំនួន**២លានបាត** ជូនរាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០។

១៧- ឯកឧត្តម Motegi Toshimitsu រដ្ឋមន្ត្រីការបរទេសជប៉ុន ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២២ ខែសីហា ឆ្នាំ២០២០។

១៨- លោកជំទាវ Manika Jain ឯកអគ្គរដ្ឋទូតសាធារណរដ្ឋឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម ពិភាក្សាការងារ និងជម្រាបលា នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០។

១៩- ឯកឧត្តម Anatoly Borovik ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីតែងតាំងថ្មីប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០។

**ក្រៅពីនេះ សម្តេច ឯកឧត្តម និងលោកជំទាវ ឧបនាយករដ្ឋមន្ត្រី ដែលជាតំណាងរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ៖**

**ក- សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** បានអញ្ជើញចូលរួមក្នុង៖

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៩និងលើកទិសដៅការងារឆ្នាំ២០២០ និងកិច្ចប្រជុំបូកសរុបលទ្ធផលនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៤ នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីល្ងាចថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០។

២- ពិធីបិទសិក្ខាសាលាជាតិស្តីពីការពិគ្រោះយោបល់លើសេចក្តីព្រាងឯកសារទស្សនទានសម្រាប់រៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២(ឆ្នាំ២០២១-២០៣០) នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីល្ងាចថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០។

៣- ពិធីសំណេះសំណាលសួរសុខទុក្ខនិងចែកអំណោយជូនប្រជាពលរដ្ឋដែលរងគ្រោះដោយជំនន់ទឹកភ្លៀង នៅអាកាសយានដ្ឋានបាត់ដំបង ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២០។

**ខ- សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីទទួលដំណើរនិវត្តន៍កងវិស្វកម្មលេខ៦៩៣ ដែលបានបញ្ចប់បេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅសាធារណរដ្ឋលីបង់ ប្រារព្ធធ្វើនៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០។

២- ពិធីរំលឹកខួបលើកទី៤៣ ទិវាចងចាំដំណើរឆ្ពោះទៅការផ្តួលរលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ២០មិថុនា ១៩៧៧ - ២០មិថុនា ២០២០ នៅចំណុចអាងដាច់«**ដើមត្រយឹង**» ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០។

៣- ពិធីប្រកាសទទួលស្គាល់ឯកឧត្តមអនុប្រធាន អគ្គលេខាធិការរង សមាជិកគណៈកម្មាធិការកណ្តាល និងសមាជិកគណៈអចិន្ត្រៃយ៍សមាគមអតីតយុទ្ធជនកម្ពុជា នៅឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២០។

៤- ពិធីប្រគល់ ទទួលផែនទីឋានលេខាព្រំដែនគោកខ្នាត១/២៥ ០០០ រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសង្គមនិយមវៀតណាម នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០។

៥- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការឡើងវិញអាងហែលទឹក នៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០។

៦- ពិធីប្រគល់អំណោយរបស់រាជរដ្ឋាភិបាលកម្ពុជា មានម៉ាស់២,១លានម៉ាស់ និងបរិក្ខារពេទ្យចំនួន **១២មុខ** ជូនដល់រដ្ឋាភិបាលឡាវ នៅអាកាសយានដ្ឋានអន្តរជាតិក្រុងវៀងចន្ទន៍នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ កាលពីព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០។

**គ- លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទការប្រឡងសូត្រគម្ពីរអាល់គួរអានុលការីមទូទាំងប្រទេស លើកទី២៩ នៅវិហារជំ គ.ម.លេខ៩ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១២ ខែមករា ឆ្នាំ២០២០។

២- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារវប្បធម៌និងវិចិត្រសិល្បៈឆ្នាំ២០១៩និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ នៅសាលសន្និសីទចតុម្មុខ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។

៣- ពិធីសម្ពោធអគារហេងមាសគ្រុបនិងស្ទូឌីយ៉ូភ្លោះរបស់ទូរទស្សន៍ហង្សមាស និងរស្មីហង្សមាស HDTV នៅសង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីល្ងាចថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០។

៤- ទិវាជាតិអំណាន«**១១មីនា**» លើកទី៥ ឆ្នាំ២០២០ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០។

**ឃ- ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងឧស្សាហកម្មនិងសិប្បកម្ម នៅទីស្តីការក្រសួងឧស្សាហកម្មនិងសិប្បកម្ម កាលពីព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០។

២- ពិធីប្រទានភ្លើងបូជាសពឯកឧត្តម **ហ៊ឹម ឆែម** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស នៅមុខវត្តបទុមវតី រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២០។

ង- ឯកឧត្តម **ឃឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិង**ជនបទ** បានអញ្ជើញចូលរួមជាអធិបតីក្នុងៈ

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារអភិវឌ្ឍជនបទឆ្នាំ២០១៩និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០។

២- ពិធីបើកសិក្ខាសាលាផ្សព្វផ្សាយយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភលើកទី២ (២០១៩-២០២៣) នៅអគារមិត្តភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២០។

ច- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច**និងហិរញ្ញវត្ថុ** បានអញ្ជើញចូលរួមជាអធិបតីក្នុងៈ

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារសាធារណការនិងដឹកជញ្ជូនឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី៩ ខែមករា ឆ្នាំ២០២០។

២- ពិធីបិទសន្និបាតបូកសរុបការងារទេសចរណ៍ឆ្នាំ២០១៩និងទិសដៅអនុវត្តបន្តឆ្នាំ២០២០ អមជាមួយពិធីអបអរសាទរទិវាជាតិទីក្រុងស្អាតក្រោមប្រធានបទ«**ទីក្រុងស្អាត ទីក្រុងដែលមានវិថីម្ហូបអាហារស្អាត**» នៅសណ្ឋាគារសុខាភ្នំពេញ កាលពីល្ងាចថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០។

៣- កិច្ចប្រជុំកំពូលអាស៊ានលើកទី៣៧ និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា លើកទី១៥ តាមរយៈប្រព័ន្ធបញ្ជូនរូបភាពនិងសំឡេង(Video Conference) នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាលពីថ្ងៃទី១២ ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២០។

ឆ- ឯកឧត្តម **ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង**សំណង់** បានអញ្ជើញចូលរួមជាអធិបតីក្នុងៈ

១- ពិធីសម្ពោធឆ្លងសាលាធម្មសភា សាលាពុទ្ធិកបឋមសិក្សា កុដិធំ ចាក់សាបទីធ្លា និងសមិទ្ធផលនានាក្នុងវត្តពោធិ៍រង្សី ហៅវត្តត្រពាំងឫស្សី នៅឃុំរកាពប្រាំ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២០។

២- ពិធីសម្ពោធឆ្លងសាលាធម្មសភានិងសមិទ្ធផលនានាក្នុងវត្តគិរីទក្ខិណារាម ហៅវត្តក្បាលបឹងសេះ នៅឃុំគរ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០។

៣- ពិធីសម្ពោធឆ្លងកុដិធំ សាលាបុណ្យ និងឧបដ្ឋានសាលាក្នុងវត្តអង្គនារាម ហៅវត្តស្រែសៀម នៅឃុំជីពេទិ៍ទី២ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២០។

៤- ពិធីសម្ពោធឆ្លងរបង កុដិ ប្រព័ន្ធលូទឹក និងសមិទ្ធផលនានានៅវត្តព្រះពន្លៃ ហៅវត្តពន្លៃ នៅឃុំអញ្ជើម ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០២០។

៥- ពិធីកាត់ឫសសីមានិងសម្ពោធសមិទ្ធផលនានា នៅវត្តព្រះពុទ្ធមហាស្រ្តារាម ហៅវត្តគីឡូ៣៧ នៅឃុំរំចេក ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២០។

# ឆ្នាំ២០២១

១- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារទីស្តីការថ្មី ក្រសួងសាធារណការនិងដឹកជញ្ជូន និងវិទ្យាស្ថាន«**តេជោ សែន សាធារណការនិងដឹកជញ្ជូន**» នៅសង្កាត់ច្រាំងចំរេះទី២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ នាថ្ងៃសុក្រ ៩កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងព្រឹកថ្ងៃទី២២ ខែមករា ឆ្នាំ២០២១។

២- ពិធីបើកការដ្ឋានសាងសង់រោងចក្រប្រព្រឹត្តិកម្មទឹកស្អាតបាក់ខែង និងសម្ពោធរោងចក្រប្រព្រឹត្តិកម្មទឹកស្អាតចំការមន ប្រព្រឹត្តទៅនៅខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ នាថ្ងៃចន្ទ ៤រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងព្រឹកថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២១។

៣- ពិធីប្រគល់ ទទួលវ៉ាក់សាំងស៊ីណូហ្វាម(SARS-COV-2 Sinopharm) ចំនួន៦០ម៉ឺនដូសពីរដ្ឋាភិបាលនិងប្រជាជននៃសាធារណរដ្ឋប្រជាមានិតចិន ជូនដល់រាជរដ្ឋាភិបាលនិងប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាថ្ងៃអាទិត្យ ១០រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងល្ងាចថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២១។

៤- ពិធីប្រគល់ ទទួលអំណោយដ៏ថ្លៃថ្លា វ៉ាក់សាំងកូវីដ-១៩(AstraZeneca) ចំនួន៣៣២ ០០០ដូស ពីរដ្ឋាភិបាលនិងប្រជាជននៃប្រទេសជប៉ុន ជូនរាជរដ្ឋាភិបាលនិងប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាថ្ងៃសុក្រ ១៤កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងរាត្រីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១។

៥- ពិធីបើកយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ សម្រាប់កុមារនិងយុវវ័យ ពីអាយុ១២ឆ្នាំដល់ក្រោម១៨ឆ្នាំ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃអាទិត្យ ៨រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ២០២១។

៦- ពិធីប្រគល់ ទទួលវ៉ាក់សាំងកូវីដ-១៩(AstraZeneca) ចំនួន៤១៥ ០០០ដូស ពីចក្រភពអង់គ្លេស ជូនរាជរដ្ឋាភិបាលនិងប្រជាជននៃព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាថ្ងៃព្រហស្បតិ៍ ១២រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី៥ ខែសីហា ឆ្នាំ២០២១។

៧- ពិធីប្រគល់ទទួលវិមានកីឡដ្ឋាននៃពហុកីឡដ្ឋានជាតិមរតកតេជោ ជាជំនួយហិរញ្ញប្បទានឥតសំណងរបស់សាធារណរដ្ឋប្រជាមានិតចិន ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **វ៉ាង យី** ទីប្រឹក្សារដ្ឋនិងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតចិន នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា នាថ្ងៃអាទិត្យ ៦កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២១។

៨- ពិធីចុះហត្ថលេខាលើឯកសាចំនួន៦ រវាងកម្ពុជា-ចិន ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **វ៉ាង យី** ទីប្រឹក្សារដ្ឋនិងជារដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតចិន នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃអាទិត្យ ៦កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២១។

៩- ពិធីបើកយុទ្ធនាការចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ សម្រាប់កុមារចាប់ពីអាយុ៦ឆ្នាំ ដល់ក្រោម១២ឆ្នាំ ចាប់ផ្តើមពីថ្ងៃសុក្រទី១៧ ខែកញ្ញា ឆ្នាំ២០២១ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃសុក្រ១១កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១។

១០- ពិធីប្រកាសបិទយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជុំទី១ សម្រាប់ក្រុមចាប់ពីអាយុ៦ឆ្នាំឡើង ក្នុងក្របខ័ណ្ឌទូទាំងប្រទេស និងប្រកាសបើកយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនកុមារដល់អាយុ៥ឆ្នាំ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃចន្ទ ១១រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១។

១១- ពិធីគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត **ខួន ញឹុល** អនុប្រធានទី១នៃរដ្ឋសភា ដែលបានទទួលមរណភាពកាលពីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅភូមិគ្រឹះសង្កាត់ព្រែកប្រា ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ កាលពីថ្ងៃសៅរ៍ ២កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២១។

១២- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារទីស្តីការថ្មីនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅសង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពីថ្ងៃចន្ទ ៤កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១។

១៣- ពិធីអបអរសាទរការផ្តល់វ៉ាក់សាំងរបស់រដ្ឋាភិបាលនិងប្រជាជននៃសាធារណរដ្ឋប្រជាមានិតចិនចំនួន**២លានដូស** ជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីថ្ងៃពុធ ១៣កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១។

១៤- ពិធីសម្ពោធស្ពានមិត្តភាពកម្ពុជា ចិន ស្ទឹងត្រង់ ក្រូចឆ្មារ ឬស្ពានភ្ជាប់និស្សរ័យ ប្រវែង១ ១៣១ម. ទទឹង១៣,៥ម. ចំណាយថវិកាប្រមាណ៥៦លានដុល្លារអាម៉េរិក និងពិធីប្រកាសបើកការដ្ឋានសាងសង់ផ្លូវជាតិលេខ ៧១C ប្រវែង១១៤,៦២គ.ម. ចំណាយថវិកាប្រមាណ១៣០លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន នៅខេត្តកំពង់ចាម កាលពីថ្ងៃអង្គារ ៤រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១។

១៥- ពិធីជប់លៀងផ្លូវការជាមួយឯកឧត្តមបណ្ឌិត **ផនខាំ វីផាវ៉ាន់** (Phankham Viphavanh) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃចន្ទ ១០រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១។

១៦- ពិធីសម្ពោធហេដ្ឋារចនាសម្ព័ន្ធផ្លូវ**៣៧ខ្សែ** ប្រវែងជាង**៨៤គ.ម.** ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ ២កន្លែង និងសមិទ្ធផលនានា ក្នុងខេត្តព្រះសីហនុ ចំណាយថវិកាជាតិប្រមាណ៣២៤លានដុល្លារអាម៉េរិក នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃព្រហស្បតិ៍ ១៣រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២១។

១៧- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ១១ និងផ្លូវក្នុងក្រុងព្រៃវែង សរុបប្រវែង**៩៦,៤៨គ.ម.** ចាប់ពីអ្នកលឿងចំណុចប្រសព្វផ្លូវជាតិលេខ១ ខេត្តព្រៃវែងដល់ថ្នល់ទទឹង ចំណុចប្រសព្វផ្លូវជាតិលេខ៧ ខេត្តត្បូងឃ្មុំ ចំណាយថវិកាប្រមាណ៩៨,៣៨លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅខេត្តព្រៃវែង កាលពីថ្ងៃចន្ទ ២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២១។

១៨- ពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះសពសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ប្រធានឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ នៅព្រះរាជដំណាក់ សង្កាត់បឹងរាំង ខណ្ឌដូនពេញរាជធានីភ្នំពេញ កាលពីថ្ងៃចន្ទ ២កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២១។

១៩- ការចុះត្រួតពិនិត្យវឌ្ឍនភាពនៃការសាងសង់ព្រលានយន្តហោះអន្តរជាតិថ្មី(អាកាសយានដ្ឋានអន្តរជាតិតេជោក្រុងតាខ្មៅ) និងសំណេះសំណាលជាមួយក្រុមការងារសាងសង់ ចំណាយថវិកាប្រមាណ១ ៥០០លានដុល្លារអាម៉េរិក នៅឃុំព្រែកស្ដែង ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃព្រហស្បតិ៍ ៥កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២១។

២០- ពិធីក្រុងពាលីនិងសំណេះសំណាលជាមួយក្រុមការងារថតខ្សែភាពយន្តរឿងភាគ«**កូនប្រុសក្រោមពន្លឺព្រះចន្ទពេញបូរមី**» នៅភូមិគ្រឹះក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃចន្ទ ៩កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២១។

២១- ពិធីសម្ពោធសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ របស់ក្រុមហ៊ុនជីប ម៉ុង ចំណាយថវិកាប្រមាណ១៨០លានដុល្លារអាម៉េរិក នៅសង្កាត់ជ័យជំនះ ខណ្ឌដូនពេញរាជធានីភ្នំពេញ កាលពីថ្ងៃពុធ ១១កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១។

២២- ពិធីសម្ពោធវិមានកីឡដ្ឋាននៃពហុកីឡដ្ឋានជាតិមរតកតេជោ រាប់ថយក្រោយ**៥០២ថ្ងៃ** ចំណាយថវិកាប្រមាណ១៥០លានដុល្លារអាម៉េរិក ដែលជាហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និងបើកយុទ្ធនាការផ្សព្វផ្សាយស៊ីហ្គេម អាស៊ាន ប៉ារ៉ាស៊ីហ្គេម ២០២៣ នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា កាលពីថ្ងៃសៅរ៍ ១៤កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១។

២៣- ពិធីចុះហត្ថលេខាលើឯកសារចំនួន៧ ជាមួយឯកឧត្តម **ង្វៀន សួនហ្វ៊ុក** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅវិមានសន្តិភាពនៃទីស្ដីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃអង្គារ ២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១។

២៤- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាលគយ អគារសាលាជាតិគយ និងអគារសារមន្ទីរគយនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៅខណ្ឌដូនពេញ កាលពីថ្ងៃព្រហស្បតិ៍ ៤រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១។

២៥- ពិធីប្រកាសបើកការប្រកួតវាយកូនហ្គោល«**ពានរង្វាន់សម្ដេចតេជោ នាយករដ្ឋមន្ត្រីលើកទី៥**» នៅទីលានកូនហ្គោលវឌ្ឍនៈហ្គោលរីសត នៅក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃសៅរ៍ ៦រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២១។

២៦- ពិធីប្រគល់«**ពានរង្វាន់សម្ដេចតេជោ នាយករដ្ឋមន្ត្រី លើកទី៥**» នៅទីលានកូនហ្គោលវឌ្ឍនៈហ្គោលរីសត នៅក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃសៅរ៍ ៦រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២១។

២៧- ពិធីប្រគល់ទទួលវ៉ាក់សាំងកូវីដ-១៩ Pfizer ចំនួន២,៣៥លានដូស ពីរដ្ឋាភិបាលនិងប្រជាជនប្រទេសអូស្ត្រាលី ជូនរាជរដ្ឋាភិបាលនិងប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីថ្ងៃអាទិត្យ ៧រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងរាត្រីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២១។

២៨- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគាររដ្ឋបាលនិងសាលប្រជុំ ក្រសួងការពារជាតិ នៅសង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃពុធ ១០រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២១។

**ទន្ទឹមនេះ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអនុញ្ញាតឱ្យៈ

១- លោកជំទាវ Devi Uttamkhobragade ឯកអគ្គរដ្ឋទូតឥណ្ឌាថ្មីប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃចន្ទ ៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១។

២- លោកជំទាវ Maria Amelita C. Aquino ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃសាធារណរដ្ឋហ្វីលីពីនថ្មីប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃពុធ ៦កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងព្រឹកថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១។

៣- លោកជំទាវ Tep Lay Cheang ឯកអគ្គរដ្ឋទូតថ្មីសិង្ហបុរីប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃអង្គារ ១០កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១។

៤- លោកជំទាវ Wendy Ruth Sherman អនុរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាម៉េរិកចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃអង្គារ ៦រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១។

៥- ឯកឧត្តម Martin Vavra ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃសាធារណរដ្ឋឆែកតែងតាំងថ្មី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃចន្ទ ៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១។

៦- លោកជំទាវ Eva Nguyen Binh ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃសាធារណរដ្ឋបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា ចប់អាណត្តិចូលជួបសម្តែងការគួរសមនិងជម្រាបលា នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃសុក្រ ៩កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២១។

៧- ឯកឧត្តម **វ៉ូ ក្វាង មិញ**(Vu Quang Minh) ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាពនៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងជម្រាបលា នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃសៅរ៍ ៩រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២១។

៨- លោកជំទាវ **ម៉ារីស ផេន**(Marise Payne) រដ្ឋមន្ត្រីការបរទេសនិងជារដ្ឋមន្ត្រីកិច្ចការនារីនៃប្រទេសអូស្ត្រាលី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃចន្ទ ៤កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១។

៩- ឯកឧត្តម **ង្វៀន ហ៊ុយតាំង**(Nguyen Huy Tang) ឯកអគ្គរដ្ឋទូតវៀតណាមថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃពុធ ៥រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១។

១០- ឯកឧត្តម **ហ្សាក់ ប៉ឺឡេ**(Jacques Pellet) ឯកអគ្គរដ្ឋទូតថ្មីនៃសាធារណរដ្ឋបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃពុធ ៥រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១។

១១- លោកជំទាវ **រ៉េតណូ អិល ភី ម៉ារស៊ូឌី**(Retno L.P.Marsudi) រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋឥណ្ឌូណេស៊ី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃពុធ ១២រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១ ខែធ្នូ ឆ្នាំ២០២១។

១២- ឯកឧត្តម **វុនណា ម៉ោងល្វីន**(Wunna Maung Lwin) រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃអង្គារ ៣កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២១។

១៣- ឯកឧត្តម **នីកូឡាយ ប៉ាទ្រូឆេហ្វ**(Nikolai Patrushev) លេខាធិការនៃក្រុមប្រឹក្សាសន្តិសុខនៃសហព័ន្ធរុស្ស៊ី ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃពុធ ១១កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១។

១៤- ឯកឧត្តម **ដន ប្រាម៉ាត់វីណៃ(Don Pramudwinai)** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនៃព្រះរាជាណាចក្រថៃ ចូលជួបសម្តែងការគួរសមនិងពិភាក្សាការងារ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី នាថ្ងៃសុក្រ ១៣កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២១។

**ក្រៅពីនេះ សម្តេច ឯកឧត្តម និងលោកជំទាវ ឧបនាយករដ្ឋមន្ត្រី ដែលជាតំណាងរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ៖**

**ក- សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១-ពិធីប្រគល់វ៉ាក់សាំងស៊ីណូហ្វាម(SARS-COV-2 Sinopharm) ចំនួន៧០ម៉ឺនដូសពីរដ្ឋាភិបាលនិងប្រជាជននៃសាធារណរដ្ឋប្រជាមានិតចិន ជូនដល់រាជរដ្ឋាភិបាលនិងប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នាថ្ងៃពុធ ៣រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងរាត្រីថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១។

២- ពិធីអបអរសាទរខួប២៣ឆ្នាំ នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា និងការអនុវត្តប្រកបដោយជោគជ័យនយោបាយឈ្នះឈ្នះរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅវិមានឈ្នះឈ្នះ សង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីថ្ងៃព្រហស្បតិ៍ ១០រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១។

**ខ- លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃទូទាំងប្រទេសលើកទី២៩ នៅសាលសន្និសីទចតុមុខ កាលពីថ្ងៃអង្គារ ២រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១។

២- ពិធីរំលឹកគុណអង្គរ នៅស្ថានហាលប្រាសាទអង្គរវត្ត ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃអង្គារ ១០កើត ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១។

**គ- ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ** បានចូលរួមជាអធិបតីក្នុងពិធីប្រារព្ធខួបលើកទី៣០នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃសៅរ៍ ២រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២១។

**ឃ- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២០និងលើកទិសដៅការងារឆ្នាំ២០២១ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន នៅទីស្តីការក្រសួងសាធារណការនិងដឹកជញ្ជូន កាលពីថ្ងៃពុធ ៦កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងល្ងាចថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១។

- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងពាណិជ្ជកម្ម តាមកម្មវិធីZoom កាលពីថ្ងៃអង្គារ ៤រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១។

**ង- ឯកឧត្តម ជា សុផារ៉ា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** បានអញ្ជើញចូលរួមជាអធិបតីក្នុង៖

១- ពិធីកាត់ឫសសីមាឆ្លងព្រះវិហារថ្មី និងសម្ពោធសមិទ្ធផលនានា នៅក្នុងវត្តជោតិរង្សី ហៅវត្តបុស្ស ឃុំរូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃសៅរ៍ ៩កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងព្រឹកថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១

២- ពិធីបញ្ចុះបឋមសិលាសាងសង់អគារទី២ នៃមន្ទីរពេទ្យបង្អែកស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃចន្ទ ៣រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១។

# ឆ្នាំ២០២២

១- ពិធីបើកការដ្ឋានគម្រោងលើកកម្រិតគុណភាពផ្លូវជាតិលេខ៤៨ ប្រវែង**១៤៨គ.ម.** ចាប់ផ្តើមពីចំណុចប្រសព្វផ្លូវជាតិលេខ៤ ត្រង់គ.ម.១៤១ + ៧៥០(អូរជ្រៅដល់ក្រុងខេមរភូមិន្ទ ខេត្តកោះកុង) ចំណាយថវិកាប្រមាណ**៦៥,១៤លានដុល្លារអាម៉េរិក** ដែលជាឥណទានសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ រួមនឹងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង កាលពីថ្ងៃចន្ទ ១កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៣ ខែមករា ឆ្នាំ២០២២។

២- ពិធីប្រគល់ប្រាក់រង្វាន់លើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ជូនដល់កីឡាការិនី **អ៊ុក ស្រីមុំ** ជ័យលាភីមេដាយមាសពិភពលោកកីឡាប៉េតង់ នៅប្រទេសអេស្ប៉ាញ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃពុធ ៣កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៥ ខែមករា ឆ្នាំ២០២២។

៣- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការកំណាត់ផ្លូវប្រវែង**៨៤,៧៤គ.ម.**នៃគម្រោងធ្វើឱ្យប្រសើរឡើងវិញផ្លូវជាតិលេខ៥ បាត់ដំបង សិរីសោភ័ណ ចំណាយថវិកាប្រមាណ**១៦៥,៧៨លានដុល្លារអាម៉េរិក** ដែលជាកម្ចីសម្បទានពីរដ្ឋាភិបាលជប៉ុន រួមនឹងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃចន្ទ ៨កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១០ ខែមករា ឆ្នាំ២០២២។

៤- ពិធីចុះហត្ថលេខាស្តីពីការផ្តល់ឥណទានសម្បទានអនុវត្តគម្រោងគាំទ្របន្តឆ្លើយតបទៅនឹងវិបត្តិកូវីដ-១៩ ដំណាក់កាលទី២ ថវិកាប្រមាណជិត**១៨៥លានដុល្លារអាម៉េរិក** ពីរដ្ឋាភិបាលជប៉ុន នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃពុធ ១០កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១២ ខែមករា ឆ្នាំ២០២២។

៥- ពិធីបើកជាផ្លូវការវេទិកាទេសចរណ៍អាស៊ានឆ្នាំ២០២២ ក្រោមប្រធានបទ«**អាស៊ាន សហគមន៍សន្តិភាពនិងអនាគតតែមួយ**» នៅទីលានតេជោ ខេត្តព្រះសីហនុ កាលពីថ្ងៃអង្គារ ១រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២។

៦- ពិធីបើកពិព័រណ៍អន្តរជាតិវេទិកាទេសចរណ៍អាស៊ានលើកទី៤០ ឆ្នាំ២០២២ នៅសណ្ឋាគារសុខា ខេត្តព្រះសីហនុ កាលពីថ្ងៃពុធ ២រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៩ ខែមករា ឆ្នាំ២០២២។

៧- ពិធីប្រគល់ ទទួលវ៉ាក់សាំងប្រភេទអាស្ត្រាសេណេកា(Astrazeneca)ចំនួន**៣០០ ០០០ដូស** ពីរដ្ឋាភិបាលនិងប្រជាជនប៉ូឡូញ ជូនដល់រាជរដ្ឋាភិបាលនិងប្រជាជនកម្ពុជា នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃអាទិត្យ ១៣រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៣០ ខែមករា ឆ្នាំ២០២២។

៨- ពិធីបើកការដ្ឋានសាងសង់ស្ពានអាកាសតាមបណ្តោយផ្លូវជាតិលេខ៥ ត្រង់ចំណុចប្រសព្វស្ពានបេតុងឆ្លងកាត់ទន្លេសាបនិងផ្លូវជាតិលេខ៥ ចំណាយថវិកាជាតិប្រមាណជិត**១០លានដុល្លារអាម៉េរិក** នៅសង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃចន្ទ ១៤រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២។

៩- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការកំណាត់ផ្លូវប្រវែង**៩៣,៥៦គ.ម.** នៃគម្រោងធ្វើឱ្យប្រសើរឡើងវិញផ្លូវជាតិលេខ៧ ពីខ្លាស្ទុះ ទៅរមាត ខេត្តក្រចេះ ចំណាយថវិកាប្រមាណ**៣៣លានដុល្លារអាម៉េរិក** ដែលជា

ជំនួយឥតសំណងពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន នៅឃុំគោលាប់ ស្រុកចិត្របុរី ខេត្តក្រចេះ កាលពីថ្ងៃចន្ទ ៦កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២២។

១០- ពិធីសំណេះសំណាលនិងផ្តល់អនុសាសន៍សំខាន់ៗជាមួយក្រុមការងារផលិតខ្សែភាពយន្តរឿង **«កូនប្រុសក្រោមពន្លឺព្រះចន្ទពេញបូណ៌មី»** នៅភូមិគ្រឹះទួលក្រសាំង ខេត្តកណ្តាល កាលពីថ្ងៃអង្គារ ៧កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២២។

១១- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្ពាន**៧កន្លែង** ស្ថិតនៅក្នុងខេត្តព្រៃវែង និងខេត្តក្រចេះ នៃគម្រោងសាងសង់ស្ពារឡើងវិញជាបន្ទាន់នៅតំបន់ប្រឈមនឹងទឹកជំនន់ ចំណាយថវិកាប្រមាណ**៣៥លានដុល្លារអាម៉េរិក** ដែលជាជំនួយរបស់រដ្ឋាភិបាលជប៉ុន នៅសង្កាត់កោះកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ កាលពីថ្ងៃពុធ ១៥កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២។

១២- កិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២។

១៣- ពិធីបើកការដ្ឋានសាងសង់ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់បឹងត្របែកនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធលូបង្ហូរទឹកកខ្វក់ក្នុងរាជធានីភ្នំពេញ ចំណាយថវិកាប្រមាណជាង**២០លានដុល្លារអាម៉េរិក** ដែលជាហិរញ្ញប្បទានឥតសំណងពីរដ្ឋាភិបាលជប៉ុន នៅសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃអង្គារ ៦រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២។

១៤- ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារមហាផ្ទៃឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ នៅសណ្ឋាគារសុខាភ្នំពេញ កាលពីថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២។

១៥- ពិធីគោរពវិញ្ញាណក្ខន្ធសពឯកឧត្តមនាយឧត្តមសេនីយ៍ **សុខ សារឿន** រដ្ឋលេខាធិការក្រសួងការពារជាតិ នៅបញ្ជាការដ្ឋានអង្គរក្ស ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃព្រហស្បតិ៍ ៨រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២។

១៦- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការកំណាត់ផ្លូវជាតិលេខ៣ ប្រវែង**១៣៤,៨២គ.ម.** ចាប់ពីភ្នំពេញ(ចោមចៅ) ដល់ក្រុងកំពត ខេត្តកំពត ចំណាយថវិកាប្រមាណជាង**២១៥លានដុល្លារអាម៉េរិក** ដែលជាហិរញ្ញប្បទានសម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន រួមនឹងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឃុំសូភី ស្រុកបាទី ខេត្តតាកែវ កាលពីព្រឹកថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០២២។

១៧- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមន្ទីរពេទ្យមិត្តភាពកម្ពុជា ចិន ត្បូងឃ្មុំ អគារសាលាបឋមសិក្សានិងវិទ្យាល័យតេជោសែន ចំណាយថវិកាប្រមាណជិត**៥០លានដុល្លារអាម៉េរិក** ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន រួមនឹងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្រុងត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីថ្ងៃចន្ទ ៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២។

១៨- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការភូមិកុមារSOS ព្រៃវែង ចំណាយថវិកាប្រមាណ**១,៥លានដុល្លារអាម៉េរិក** ដែលជាអំណោយរបស់សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង កាលពីថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២។

១៩- ពិធីប្រគល់ ទទួលវ៉ាក់សាំងកូវីដ-១៩ អាស្ត្រាសេណេកា(Astrazeneca) ចំនួន**៥២៣ ១០០ដូស** ពីរដ្ឋាភិបាលនិងប្រជាជនហុងគ្រីជូនរាជរដ្ឋាភិបាលនិងប្រជាជននៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទប់ស្កាត់បង្ការជំងឺកូវីដ-១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃសុក្រ ១រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២។

២០- ពិធីចុះហត្ថលេខាលើឯកសារចំនួន**២** ជាមួយឯកឧត្តម **គីស៊ីដា ហ្វូមីអូ**(Kishida Furmio) នាយករដ្ឋមន្ត្រីជប៉ុន នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃអាទិត្យ ៣រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២។

២១- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារមន្ទីរពេទ្យមិត្តភាពកម្ពុជា ចិន ព្រះកុសុមៈ (ពេទ្យលោកសង្ឃ) ចំណាយថវិកាជាង**៨០លានដុល្លារអាម៉េរិក** ដែលជាជំនួយឥតសំណងនៃសាធារណរដ្ឋប្រជាមានិតចិន នៅមន្ទីរពេទ្យមិត្តភាពកម្ពុជា ចិន ព្រះកុសុមៈ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃចន្ទ ៤រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២។

២២- ពិធីប្រកាសផ្សព្វផ្សាយដាក់ឱ្យអនុវត្តជាផ្លូវការកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២(២០២១-២០៣០) នៅសណ្ឋាគារសុខាភ្នំពេញ កាលពីថ្ងៃចន្ទ ៤រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២។

២៣- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ២១ ប្រវែង**៦៣,៦០គ.ម.** ពីរង្វង់មូលក្រុងតាខ្មៅ ដល់ជ្រៃធំ ខេត្តកណ្ដាល ចំណាយថវិកាប្រមាណ**៦០,៩២លានដុល្លារអាម៉េរិក** ដែលជាឥណទានសម្បទានពីរដ្ឋាភិបាលកូរ៉េ រួមនឹងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា កាលពីថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២។

២៤- ពិធីបិទសន្និបាតបូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងល្ងាចថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២។

២៥- ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៥១ ប្រវែង**៣៧,៩៥គ.ម.** ចាប់ពីឧដុង្គ (ចំណុចប្រសព្វផ្លូវជាតិលេខ៥) ដល់ថ្នល់ទទឹង(ចំណុចប្រសព្វផ្លូវជាតិលេខ៤) ចំណាយថវិកាប្រមាណ**៤១លានដុល្លារអាម៉េរិក** ដែលជាហិរញ្ញប្បទានសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន រួមនឹងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីថ្ងៃសុក្រ ៨រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២។

